# ព្រះ
# ត្រៃបិដក

## ប្រែរួមនឹង
## ព្រះអដ្ឋកថា

## ភាគ៥៥

បាលីប្រែ ៦៧ - ៦៨

ពុទ្ធសករាជ ២៥៥៣

ច្បាប់ពិនិត្យ លើកទី២

# ព្រះ

# សុត្តន្តបិដក

## និង

## ខុទ្ទកនិកាយ ចូឡនិទ្ទេស

### សេចក្ដីប្រែជាភាសាខ្មែរ

## បឋមភាគ-ទុតិយភាគ

## ៥៥

## បាលីប្រែ ៦៧-៦៨

*បោះពុម្ពលើកទី ១ ពុទ្ធសករាជ ២៥៥៣*

# ក្បាលទី ៥៥

# សុត្តន្តបិដក

# ខុទ្ទកនិកាយ ចូឡនិទ្ទេស

# បឋមភាគ

*សូមនមស្ការ ចំពោះព្រះអរហន្ត សម្មាសម្ពុទ្ធព្រះអង្គនោះ ។*

## ឆាភាយនវគ្គ

## វត្ថុគាថា

[ ១ ] *ពាវរីព្រាហ្មណ៍អ្នកដល់ត្រើយនៃមន្ត ប្រាថ្នាសេចក្តីមិនមានកង្វល់ ចេញចាកបុរីជាទីរីករាយនៃពួកអ្នកដែនកោសល ទៅកាន់ទក្ខិណាបថជនបទ ។*

[ ២ ] *គាត់អាស្រ័យនៅទៀបច្រាំងស្ទឹងគោធាវរី ក្នុងទីព្រំដែនអស្សកៈនិងមុឡកៈ ( ចិញ្ចឹមជីវិត ) ដោយការស្វែងរកមើម និងផលាផល ។*

[ ៣ ] *ស្រុកអាស្រ័យជិតស្ទឹងគោធាវរីនោះ ជាស្រុកសម្បូណ៌ ព្រាហ្មណ៍ក៏បានបរិច្ចាគមហាយញ្ញ ដោយស្បួយដែលកើតអំពីស្រុកនោះ ។*

[ ៤ ] *លុះពាវរីព្រាហ្មណ៍ បរិច្ចាគមហាយញ្ញរួចហើយ ក៏ចូលមកកាន់អាស្រមវិញ កាលគាត់ត្រឡប់ចូលមកហើយ ព្រាហ្មណ៍ដទៃ បានមកដល់ដែរ ។*

[ ៥ ] *ព្រាហ្មណ៍នោះ មានជើងឯទ្បើង សស្ទក់សស្ទើត មានធ្មេញ*

ពណ៌កក់ ក្បាលប្រឡាក់ធូលី ចូលមករកពាវរីព្រាហ្មណ៍នោះ ហើយសូមទ្រព្យចំនួន ៥០០ ។

[ ៦ ] ពាវរីព្រាហ្មណ៍ លុះឃើញព្រាហ្មណ៍យាចកនោះហើយ ក៏អញ្ជើញដោយអាសនៈ ហើយសាកសួរសេចក្ដីសប្បាយស្រួល ទើបពោលនូវពាក្យនេះថា

[ ៧ ] ទេយ្យធម៌ណា ដែលខ្ញុំគប្បីឲ្យ ទេយ្យធម៌ទាំងអស់នោះ ខ្ញុំបរិច្ចាគអស់រលីងហើយ ម្នាលព្រាហ្មណ៍ ចូរអ្នកអនុញ្ញាតដល់ខ្ញុំផងចុះ ខ្ញុំមិនមានទ្រព្យ ៥០០ ទេ ។

[ ៨ ] ( ព្រាហ្មណ៍យាចកពោលថា ) អ្នកដ៏ចម្រើន កាលបើខ្ញុំសូមប្រសិនបើអ្នកដ៏ចម្រើនមិនឲ្យ សូមឲ្យក្បាលអ្នកបែកជា ៧ ភាគ ក្នុងថ្ងៃជាគម្រប់ ៧ ។

[ ៩ ] ព្រាហ្មណ៍អ្នកកុហកនោះ បានក្លែងក្លាយ ពោលពាក្យគួរខ្លាចពាវរីព្រាហ្មណ៍ បានឮពាក្យនៃព្រាហ្មណ៍នោះហើយ ក៏កើតទុក្ខ ។

[ ១០ ] គាត់អត់អាហារ ដោតដោយសរ គឺសោកក្រៀមក្រំ មួយទៀត កាលព្រាហ្មណ៍មានចិត្តយ៉ាងនេះហើយ ចិត្តក៏មិនរីករាយ ក្នុងការលះបង់ ។

[ ១១ ] ទេវតាអ្នកប្រាថ្នាប្រយោជន៍ បានឃើញពាវរីព្រាហ្មណ៍ កំពុងមានសេចក្ដីតក់ស្លុត កើតទុក្ខ ទើបចូលទៅរកពាវរីព្រាហ្មណ៍ ហើយពោលពាក្យនេះថា

[ ១២ ]( ព្រាហ្មណ៍នោះ ) មិនដឹងប្រាកដនូវអំបែងក្បាល ព្រាហ្មណ៍នោះ ជាអ្នកកុហក ប្រាថ្នាទ្រព្យ ញាណសម្រាប់ដឹងនូវក្បាល ឬធម៌ធ្វើក្បាលឲ្យធ្លាក់ចុះរបស់គាត់នោះ មិនមានទេ ។

[ ១៣ ] ( ពាវរីព្រាហ្មណ៍សួរថា ) នរណាអាចដឹងនូវក្បាល ដឹងធម៌ធ្វើក្បាលឲ្យធ្លាក់ចុះ ខ្ញុំសួរហើយ អ្នកចូរប្រាប់ដំណើរនោះដល់ខ្ញុំ ខ្ញុំនឹងស្តាប់ពាក្យរបស់អ្នកនោះ ។

[ ១៤ ] ( ទេវតាតបថា ) ខ្ញុំក៏មិនដឹងដំណើរនោះដែរ ការដឹងក្នុងដំណើរនុ៎ះរបស់ខ្ញុំមិនមានទេ លុះតែព្រះជិនៈ ទើបទ្រង់ជ្រាបនូវក្បាល និងធម៌ធ្វើក្បាលឲ្យធ្លាក់ចុះ ។

[ ១៥ ] ( ពាវរីព្រាហ្មណ៍សួរថា ) លើប្រឹថពីមណ្ឌលនេះ តើនរណាទើបដឹងនូវក្បាល និងធម៌ធ្វើក្បាលឲ្យធ្លាក់ចុះ ម្នាលទេវតា អ្នកចូរប្រាប់បុគ្គលអ្នកដឹងនោះដល់ខ្ញុំ ។

[ ១៦ ]( ទេវតាតបថា ) ព្រះលោកនាយក ជាពូជពង្សរបស់ព្រះបាទឱក្កាកៈ ជាសក្យបុត្ត ជាអ្នកធ្វើនូវពន្លឺ ព្រះអង្គស្តេចចេញចាកកបិលវត្ថុបុរី ( ទ្រង់ព្រះផ្នួស ) ។

[ ១៧ ] ម្នាលព្រាហ្មណ៍ ព្រះលោកនាយកនោះ ជាអ្នកត្រាស់ដឹងដល់នូវត្រើយនៃធម៌ទាំងពួង ទ្រង់ដល់ហើយនូវអភិញ្ញា និងពលសព្វគ្រប់ ប្រកបដោយសមន្តចក្ខុក្នុងធម៌ទាំងពួង ទ្រង់ដល់នូវធម៌ទាំងពួង ជាទីអស់កិលេស ទ្រង់ផុតវិសេសហើយ និមិត្តធម៌ជាទីក្ស័យនៃឧបធិ ។

[ ១៨ ] ព្រះមានព្រះភាគព្រះអង្គនោះ ទ្រង់ជាព្រះពុទ្ធក្នុងលោក មានបញ្ញាចក្ខុ តែងសម្តែងធម៌ អ្នកចូរទៅក្រាបទូលសួរព្រះសម្ពុទ្ធអង្គនោះចុះ ទ្រង់នឹងព្យាករណ៍នូវធម៌នោះដល់អ្នក ។

[ ១៩ ] ពាវរីព្រាហ្មណ៍ ឮពាក្យថា សម្ពុទ្ធដូច្នេះហើយ ក៏មានចិត្តអណ្តែតឡើង មានសោកស្រាល ទាំងបានបីតិដ៏ខ្លាំងក្លា ។

[ ២០ ] ពាវរីព្រាហ្មណ៍នោះ មានចិត្តត្រេកអរ មានចិត្តអណ្តែតឡើង មានចិត្តរីករាយ សួរទេវតានោះថា ព្រះលោកនាថ ទ្រង់គង់នៅក្នុងស្រុកណា និគមណា ឬក្នុងជនបទណា យើងនឹងទៅនមស្ការព្រះសម្ពុទ្ធដ៏ឧត្តមជាងសត្វជើងពីរនោះក្នុងទីណា ។

[ ២១ ] ( ទេវតាតបថា ) ព្រះជិនៈ ទ្រង់សម្រេចសម្រាន្តព្រះឥរិយាបថក្នុងកោសលមន្ទីរ ជិតក្រុងសាវត្ថី ទ្រង់មានបញ្ញាច្រើន មានបញ្ញាដូចផែនដីដ៏ប្រសើរ ព្រះអង្គជាសក្យបុត្ត ទ្រង់មិនមានធុរៈ មិនមានអាសវៈ ជាឧត្តមបុរស ប្រសើរជាងជន ជ្រាបច្បាស់នូវក្បាល និងធម៌ធ្វើក្បាលឲ្យធ្លាក់ចុះ ។

[ ២២ ] លំដាប់នោះ ពាវរីព្រាហ្មណ៍ ហៅពួកព្រាហ្មណ៍ជាសិស្ស អ្នកដល់នូវត្រើយនៃមន្តថា ម្នាលមាណពទាំងឡាយ អ្នកទាំងឡាយ ចូរមក យើងនឹងប្រាប់អ្នកទាំងឡាយ ចូរស្តាប់ពាក្យរបស់យើង ។

[ ២៣ ] ការកើតប្រាកដរឿយៗ ក្នុងលោកនៃព្រះសម្ពុទ្ធអង្គណា ដែលរកកម្របាន ថ្ងៃនេះ ព្រះសម្ពុទ្ធជាម្ចាស់អង្គនោះ ទ្រង់កើតហើយក្នុងលោក គេ

ដឹងឮល្បីល្បាញប្រាកដថា ព្រះអង្គត្រាស់ដឹងឯង អ្នកទាំងឡាយ ចូរប្រញាប់ទៅកាន់ក្រុងសាវត្ថី គាល់ព្រះអង្គ ទ្រង់ឧត្តមជាងសត្វជើងពីរនោះ ។

[ ២៤ ] ( ព្រាហ្មណ៍ជាសិស្សប្រឹងសួរថា ) បពិត្រព្រាហ្មណ៍ ធ្វើម្ដេចយើងទាំងឡាយ ឃើញហើយ ទើបស្គាល់ថាជាព្រះពុទ្ធ សូមលោកប្រាប់ឧបាយជាហេតុឲ្យយើងស្គាល់នូវព្រះសម្ពុទ្ធនោះ ដល់យើងទាំងឡាយ ដែលមិនធ្លាប់ស្គាល់ ។

[ ២៥ ] ( ពាវរីព្រាហ្មណ៍តបថា ) មហាបុរិសលក្ខណៈទាំងឡាយ ៣២ ប្រការ មានមកក្នុងមន្តទាំងឡាយ ( ដែលពួកព្រាហ្មណាចារ្យ ) ព្យាករណ៍គ្រប់គ្រាន់ហើយ តាមលំដាប់ ។

[ ២៦ ] មហាបុរិសលក្ខណៈទាំងនុ៎ះ រមែងមានក្នុងកាយរបស់មហាបុរសណា មហាបុរសនោះ មានគតិទៀងតែពីរ មិនមានគតិទៅជាគម្រប់ ៣ ទេ ។

[ ២៧ ] បើមហាបុរសនោះ នៅគ្រប់គ្រងផ្ទះ គប្បីឈ្នះប្រឹថពីមណ្ឌលនេះ ដោយមិនមានប្រើអាជ្ញា សស្ត្រាវុធ ទាំងគ្រប់គ្រងតាមច្បាប់ ។

[ ២៨ ] ប្រសិនបើមហាបុរសនោះ ( ចេញ ) ចាកផ្ទះហើយ បួសក្នុងភេទនៃបុគ្គលមិនមានផ្ទះ នឹងបានជាព្រះពុទ្ធ មានដំបូល គឺកិលេសបើកហើយ ជាអរហន្ត ឥតមានបុគ្គលដទៃប្រសើរដូច ។

[ ២៩ ] អ្នកទាំងឡាយ ចូរសួរនូវជាតិ គោត្រ លក្ខណៈ មន្ត នឹងសិស្សទាំងឡាយដទៃទៀតផង នូវក្បាល និងធម៌ធ្វើក្បាលឲ្យធ្លាក់ចុះផង

ដោយចិត្តតែម្យ៉ាង ។

[ ៣០ ] ប្រសិនបើព្រះអង្គជាព្រះពុទ្ធ មានកិរិយាឃើញ ឥតមានអ្វីទើសទាល់ កាលបើអ្នកទាំងឡាយសួរប្រស្នាដោយចិត្តហើយ ទ្រង់នឹងវិសជ្ជនាដោយវាចា ។

[ ៣១ ] លុះស្តាប់ពាក្យពាវរីព្រាហ្មណ៍ហើយ ព្រាហ្មណ៍ជាសិស្ស ១៦ នាក់ គឺអជិតៈ ១ តិស្សមេត្តេយ្យៈ ១ បុណ្ណកៈ ១ មេត្តគូ ១ ធោតកៈ ១ ឧបសីវៈ ១ នន្ទៈ ១ ហេមកៈ ១ តោទេយ្យៈ ១ កប្បៈ ១ ជតុកណ្ណិបណ្ឌិត ១ ភទ្រាវុធ ១ ឧទយៈ ១ បោសាលព្រាហ្មណ៍ ១ មោឃរាជមេធាវី ១ បិង្គិយមហាឫសី ១ ។

[ ៣២ ] អ្នកទាំងអស់គ្នា ជាគណាចារ្យមួយៗ ល្បីទូទៅពេញលោកថា ជាអ្នកមានឈាន ត្រេកអរក្នុងឈាន ជាអ្នកប្រាជ្ញ សឹងមានវាសនាអប់រំមកហើយ ក្នុងបុព្វជាតិ ។

[ ៣៣ ] ( ព្រាហ្មណ៍ទាំងនោះ ) ក៏ក្រាបអភិវាទ ធ្វើប្រទក្សិណនូវពាវរីព្រាហ្មណ៍នោះទាំងអស់គ្នា ជាអ្នកមានជដា ទ្រទ្រង់អជិនចម្មាករណៈ មានមុខឆ្ពោះទៅកាន់ឧត្តរទិស ដើរចេញទៅ ។

[ ៣៤ ] ក្នុងកាលនោះ តាបសទាំងនោះ ទៅកាន់ក្រុងឈ្មោះថា មហិស្សតី ជាទីប្រតិស្ឋាននៃដែនមុឡកៈ ១ ក្រុងឧជ្ជេនី ១ ក្រុងគោនទ្ធៈ ១ ព្រៃវេទិសៈ ១ ព្រៃសុវ្ហយៈ ១ ក្រុងកោសម្ពី ១ ក្រុងសាកេត ១ ក្រុងសាវត្ថីដ៏ឧត្តម ១ ក្រុងសេតព្យៈ ១ ក្រុងកបិលវត្ថុ ១ ក្រុងកុសិនារា ១ ក្រុង

បាវា ១ ភោគនគរ ១ ក្រុងវេសាលី ១ ក្រុងក្នុងដែនមគធៈ ១ និងបាសា-ណកចេតិយដ្ឋាន ជាទីត្រេកអររីករាយចិត្ត ១ ។

[ ៣៥ ] ( ពួកព្រាហ្មណ៍ទាំងនោះ ) នាំគ្នាឡើងកាន់ភ្នំ ប្រញាប់ប្រញាល់ ដូចជាបុគ្គលស្រេក បានទឹកត្រជាក់ ដូចជាពាណិជ្ជ បានលាភធំ ឬដូចជាបុគ្គលដែលត្រូវក្តៅ បានម្លប់ ។

[ ៣៦ ] សម័យនោះ ព្រះមានព្រះភាគ មានភិក្ខុសង្ឃចោមរោម កំពុងសម្តែងធម៌ដល់ពួកភិក្ខុ ដូចសីហៈកំពុងបន្លឺក្នុងព្រៃ ។

[ ៣៧ ] អជិតមាណព បានឃើញព្រះសម្ពុទ្ធ ហាក់ដូចព្រះអាទិត្យ កំពុងផ្សាយចេញនូវរស្មី ពុំនោះសោត ដូចព្រះចន្ទ្រពេញវង់ រះឡើងក្នុងថ្ងៃពេញបូណ៌មី ។

[ ៣៨ ] លុះអជិតមាណព ឃើញព្រះកាយរបស់ព្រះសម្ពុទ្ធ ដ៏បរិបូណ៌ ដោយព្យញ្ជនៈ ក៏មានចិត្តរីករាយ ស្ថិតនៅក្នុងទីសមគួរ ហើយសួរបញ្ហា ដោយចិត្តនឹកថា

[ ៣៩ ] សូមព្រះអង្គ ទ្រង់សម្តែងអាងនូវចំណាស់ សម្តែងនូវគោត្ត ព្រមទាំងលក្ខណៈ សម្តែងនូវសេចក្តីសម្រេចក្នុងមន្តទាំងឡាយ តើព្រាហ្មណ៍ ( ជាអាចារ្យរបស់ខ្ញុំព្រះអង្គ ) បង្រៀនសិស្សប៉ុន្មាន ។

[ ៤០ ] ( ព្រះមានព្រះភាគត្រាស់ថា ) ព្រាហ្មណ៍ជាអាចារ្យរបស់អ្នកនោះ ឈ្មោះពាវរីដោយគោត្រ មានអាយុ ១២០ វស្សា កាយរបស់គាត់មានលក្ខណៈ ៣ យ៉ាង ដល់នូវត្រើយនៃវេទទាំង ៣ ។

[ ៤១ ] គាត់បង្រៀនលក្ខណៈ និងឥតិហាសសាស្ត្រ ព្រមទាំងនិឃណ្ឌុសាស្ត្រ និងកេដុភសាស្ត្រ ដល់សិស្ស ៥០០ នាក់ ដល់នូវការសម្រេចក្នុងធម៌របស់ខ្លួន ។

[ ៤២ ] ( អជិតមាណពទូលសួរថា ) បពិត្រព្រះអង្គឧត្តមជាងជនជាអ្នកផ្តាច់បង់នូវតណ្ហា សូមព្រះអង្គជ្រើសរើសលក្ខណៈទាំងឡាយរបស់ពាវរីព្រាហ្មណ៍ហើយប្រកាស កុំឲ្យយើងខ្ញុំសង្ស័យឡើយ ។

[ ៤៣ ] ( ព្រះមានព្រះភាគត្រាស់ថា ) ពាវរីព្រាហ្មណ៍បិទបាំងមុខដោយជិវ្ហាបាន មានឧណ្ណាលោមត្រង់ចន្លោះចិញ្ចើម មានវត្ថគុយ្ហៈនៅក្នុងស្រោម ម្នាលមាណព ចូរអ្នកដឹងយ៉ាងនេះចុះ ។

[ ៤៤ ] ពួកជនទាំងពួង មិនឮនូវការសួរនីមួយសោះ លុះឮបញ្ហាដែលព្រះមានព្រះភាគព្យាករណ៍ហើយ ក៏កើតសេចក្តីរីករាយ ប្រណម្យអញ្ជលីគិតផ្សេងៗ ថា

[ ៤៥ ] នរណាហ្ន៎ ជាទេវតា ឬជាព្រហ្ម ឬជាព្រះឥន្ទ្រឈ្មោះសុជម្បតិកាលបើគេសួរប្រស្នាដោយចិត្ត ម្តេចក៏ទ្រង់ឆ្លើយតបប្រស្នានោះបាន ។

[ ៤៦ ] ( អជិតមាណព ទូលសួរដោយចិត្តតទៅទៀតថា ) បពិត្រព្រះមានព្រះភាគ ពាវរីព្រាហ្មណ៍សួរនូវក្បាល និងធម៌ធ្វើក្បាលឲ្យធ្លាក់ចុះ សូមព្រះអង្គព្យាករប្រស្នានោះ បពិត្រព្រះអង្គជាឥសី សូមព្រះអង្គកម្ចាត់បង់នូវកង្ខារបស់យើងទាំងឡាយ ។

[ ៤៧ ] ( ព្រះមានព្រះភាគត្រាស់ថា ) ចូរអ្នកដឹងថា អវិជ្ជាជាក្បាល

វិជ្ជាដែលប្រកបដោយសទ្ធា សតិ សមាធិ ឆន្ទៈ វិរិយៈ ជាធម៌ធ្វើក្បាលឲ្យធ្លាក់ចុះ ។

[ ៤៨ ] លំដាប់នោះ ( អជិតមាណព ) មានបីតិ មានកម្លាំងក្លាខ្លាំងកើតហើយ ទើបធ្វើអជិនចម្មាករណៈ ឆៀងស្មាម្ខាង ក្រាបទៀបព្រះបាទដោយសិរសាទូលថា

[ ៤៩ ] បពិត្រព្រះអង្គទ្រង់និទ្ទុក្ខមានចក្ខុ ពាវរីព្រាហ្មណ៍ ព្រមទាំងពួកសិស្ស មានចិត្តរីករាយសោមនស្ស ថ្វាយបង្គំព្រះបាទនៃព្រះអង្គដ៏ចម្រើន ។

[ ៥០ ] ( ព្រះមានព្រះភាគត្រាស់តបថា ) ពាវរីព្រាហ្មណ៍ ព្រមទាំងពួកសិស្ស ចូរបានសុខ ម្នាលមាណព ទាំងអ្នកក៏ចូរបានសុខ ចូរមានជន្មាយុយឺនយូរ ។

[ ៥១ ] អ្នកទាំងឡាយ តថាគតបើកឱកាសឲ្យហើយ ប្រាថ្នាក្នុងចិត្ត ( ដើម្បីសួរ ) នូវប្រស្នាណាមួយ ចូរសួរមកចុះ ដើម្បីកម្ចាត់បង់សេចក្តីសង្ស័យគ្រប់ប្រការរបស់ពាវរីព្រាហ្មណ៍ផង របស់អ្នកផង ទាំងអស់គ្នា ។

[ ៥២ ] អជិតមាណព ដែលព្រះសម្ពុទ្ធទ្រង់បើកឱកាសឲ្យហើយ ក៏អង្គុយប្រណម្យអញ្ជលី សួរប្រស្នាជាបឋម ចំពោះព្រះតថាគត ក្នុងបាសាណកចេតិយនោះ ។

វត្ថុគាថា ចប់

# អជិតមាណវកបញ្ហានិទ្ទេស

[ ៥៣ ] ( *អជិតមាណពមានអាយុសួរដូច្នេះថា* ) លោកត្រូវអ្វីបិទបាំង លោកមិនភ្លឺស្វាងព្រោះហេតុអ្វី សូមព្រះអង្គត្រាស់ប្រាប់នូវធម៌អ្វី ថាជាគ្រឿងលាបលោកនោះ អ្វីជាភ័យធំរបស់លោកនោះ ។

[ ៥៤ ] ពាក្យថា លោកត្រូវអ្វីបិទបាំង សេចក្ដីថា និរយលោក តិរច្ឆានលោក បិត្តិវិសយលោក មនុស្សលោក ទេវលោក ខន្ធលោក ធាតុលោក អាយតនលោក លោកនេះ លោកខាងមុខ ព្រហ្មលោក ព្រមទាំងទេវលោក នេះហៅថា **លោក** ។ លោកនេះ ត្រូវអ្វីបិទបាំង បិទទាំងខាងក្រោម បិទទាំងខាងលើ បិទភ្ជិត គ្រប ហេតុនោះ ( លោកសួរថា ) លោកត្រូវអ្វីបិទបាំង ។

[ ៥៥ ] ពាក្យថា ដូច្នេះ នៃពាក្យថា អជិតមានអាយុសួរ ដូច្នេះ គឺជាពាក្យតបទ ជាពាក្យភ្ជាប់បទ ជាពាក្យបំពេញបទ ជាទីប្រជុំនៃអក្ខរៈ ជាសេចក្ដីពីរោះដោយព្យញ្ជនៈ ពាក្យថា ដូច្នេះ នុ៎ះ ជាលំដាប់នៃបទ ។ ពាក្យថា មានអាយុ គឺពាក្យជាទីស្រឡាញ់ ជាពាក្យគោរព ពាក្យថា មានអាយុ នុ៎ះ ជាពាក្យពោលដោយគោរព កោតក្រែង ។ ពាក្យថា អជិត គឺជានាម ជា សង្ខារ ជាឈ្មោះ ជាបញ្ញត្តិ ជាវោហារ ជានាម ជានាមកម្ម ជានាមធេយ្យៈ ជាភាសា ជាព្យញ្ជនៈ ជាពាក្យហៅរបស់ព្រាហ្មណ៍នោះ ហេតុនោះមានពាក្យថា អជិតមាណពមានអាយុសួរ ដូច្នេះ ។

[ ៥៦ ] ពាក្យថា លោកមិនភ្លឺស្វាងព្រោះហេតុអ្វី គឺលោកមិនភ្លឺស្វាង

មិនមានរស្មី មិនមានពន្លឺ មិនរុងរឿង មិនយល់ច្បាស់ មិនប្រាកដ ព្រោះហេតុអ្វី ហេតុនោះ លោកសួរថា លោកមិនភ្លឺស្វាងព្រោះហេតុអ្វី ។

[ ៥៧ ] ពាក្យថា សូមព្រះអង្គត្រាស់ប្រាប់ នូវធម៌អ្វីជាគ្រឿងលាបលោកនោះ គឺអ្វីជាគ្រឿងលាប ជាគ្រឿងជំពាក់ ជាគ្រឿងចង ជាឧបក្កិលេសរបស់លោកនោះ លោកត្រូវអ្វីលាបស្រឡាប ធ្វើឲ្យសៅហ្មង ឲ្យសៅហ្មងព្រម ឲ្យប្រឡាក់ ឲ្យប្រឡាំព្រម ឲ្យជាប់ ឲ្យជំពាក់ ឲ្យជាប់ស្អិត សូមព្រះអង្គត្រាស់ប្រាប់ សម្តែងបញ្ញត្តិ តាំងទុក បើក ចែក រំលែក ធ្វើឲ្យងាយប្រកាស ហេតុនោះ សូមព្រះអង្គត្រាស់ប្រាប់នូវអ្វី ជាគ្រឿងលាបលោកនោះ ។

[ ៥៨ ] ពាក្យថា អ្វីជាភ័យធំរបស់លោកនោះ គឺអ្វីជាភ័យធំ ជាគ្រឿងបៀតបៀន ជាគ្រឿងគាប ជាឧបទ្រព ជាឧបសគ្គរបស់លោកនោះ ហេតុនោះ លោកសួរថា អ្វីជាភ័យធំរបស់លោកនោះ ។ ហេតុនោះ ព្រាហ្មណ៍នោះពោលហើយថា

លោកត្រូវអ្វីបិទបាំង លោកមិនភ្លឺស្វាងព្រោះហេតុអ្វី សូមព្រះអង្គត្រាស់ប្រាប់នូវធម៌អ្វី ជាគ្រឿងលាបលោកនោះ អ្វីជាភ័យធំរបស់លោកនោះ ។

[ ៥៩ ] ( ព្រះមានព្រះភាគទ្រង់ត្រាស់ថា ម្នាលអជិតៈ ) លោកត្រូវអវិជ្ជាបិទបាំង លោកមិនភ្លឺស្វាង ព្រោះសេចក្តីប្រាថ្នាផ្សេងៗ ( និងសេចក្តីប្រហែស ) តថាគតពោលនូវសេចក្តីប្រាថ្នា ថាជា

គ្រឿងលាប ទុក្ខជាភ័យធំ របស់លោកនោះ ។

[ ៦០ ] អធិប្បាយពាក្យថា លោកត្រូវអវិជ្ជាបិទបាំង ត្រង់ពាក្យថា អវិជ្ជា បានន័យថា សេចក្តីមិនដឹងក្នុងទុក្ខ សេចក្តីមិនដឹងក្នុងតណ្ហា ជាហេតុឲ្យកើតទុក្ខ សេចក្តីមិនដឹងក្នុងកិរិយារលត់ទុក្ខ សេចក្តីមិនដឹងក្នុងបដិបទា ជាដំណើរទៅកាន់ទីរលត់ទុក្ខ សេចក្តីមិនដឹងក្នុងទីបំផុតខាងដើម សេចក្តីមិនដឹងក្នុងទីបំផុតខាងចុង សេចក្តីមិនដឹងក្នុងទីបំផុតខាងដើម និងទីបំផុតខាងចុង សេចក្តីមិនដឹងក្នុងធម៌ដែលកើតឡើងហើយ អាស្រ័យធម៌នេះជាបច្ច័យ កិរិយាមិនដឹង ការមិនឃើញ ការមិនត្រាស់ដឹង ការមិនត្រាស់ដឹងតាម ការមិនត្រាស់ដឹងព្រម ការមិនចាក់ធ្លុះ ការមិនចុះចិត្ត ការមិនចុះចិត្តស៊ប់ ការមិនមានការរំពៃ ការមិនមានការពិចារណា ការមិនមានការយល់ច្បាស់ ការយល់បានដោយក្រ ភាពជាពាល ភាពមិនមានសម្បជញ្ញៈ សេចក្តីវង្វេងទូទៅ សេចក្តីវង្វេងព្រម ឱឃៈ គឺអវិជ្ជា យោគៈ គឺអវិជ្ជា អនុស័យ គឺអវិជ្ជា ការស្ទាក់ដំណើរ គឺអវិជ្ជា បណ្តាញ គឺអវិជ្ជា មោហៈ អកុសលមូលណា មានសភាពយ៉ាងនេះ នេះហៅថា អវិជ្ជា ។ ពាក្យថា លោក គឺនិរយលោក តិរច្ឆានលោក បិត្តិវិសយលោក មនុស្សលោក ទេវលោក ខន្ធលោក ធាតុលោក អាយតនលោក លោកនេះ លោកខាងមុខ ព្រហ្មលោក ព្រមទាំងទេវលោក នេះហៅថា លោក ។ លោកត្រូវអវិជ្ជានេះបិទបាំង បិទបិទខាងក្រោម បិទខាងលើ បិទក្បិត គ្រប ហេតុនោះ ( ទ្រង់ត្រាស់ថា ) លោក ត្រូវអវិជ្ជាបិទបាំង ។

[ ៦១ ] ពាក្យថា អជិត គឺព្រះមានព្រះភាគទ្រង់ត្រាស់ហៅនូវព្រាហ្មណ៍នោះចំណោះ ។ ពាក្យថា ព្រះមានព្រះភាគនេះ ជាពាក្យពោលដោយគោរព ។ មួយទៀត ព្រះនាមថា ព្រះមានព្រះភាគ ព្រោះទ្រង់បំបាក់បង់រាគៈ ។ ព្រះនាមថា ព្រះមានព្រះភាគ ព្រោះទ្រង់បំបាក់បង់ទោសៈ ព្រះនាមថា ព្រះមានព្រះភាគ ព្រោះទ្រង់បំបាក់បង់មោហៈ ។ ព្រះនាមថា ព្រះមានព្រះភាគ ព្រោះទ្រង់បំបាក់បង់មានះ ព្រះនាមថា ព្រះមានព្រះភាគ ព្រោះទ្រង់បំបាក់បង់ទិដ្ឋិ ។ ព្រះនាមថា ព្រះមានព្រះភាគ ព្រោះទ្រង់បំបាក់បង់បន្ទាគឺកាម ។ ព្រះនាមថា ព្រះមានព្រះភាគ ព្រោះទ្រង់បំបាក់បង់កិលេស ។ ព្រះនាមថា ព្រះមានព្រះភាគ ព្រោះទ្រង់ចែក ចែង រំលែក នូវធម្មរតនៈ ។ ព្រះនាមថា ព្រះមានព្រះភាគ ព្រោះទ្រង់ធ្វើនូវទីបំផុតភព ។ ព្រះនាមថា ព្រះមានព្រះភាគ ព្រោះទ្រង់មានកាយចម្រើន ។ ព្រះនាមថា ព្រះមានព្រះភាគ ព្រោះទ្រង់មានសីលចម្រើន ព្រោះទ្រង់មានចិត្តចម្រើន ព្រោះទ្រង់មានបញ្ញាចម្រើន ។ ព្រះនាមថា ព្រះមានព្រះភាគ ព្រោះព្រះមានបុណ្យ ទ្រង់គប់រកសេនាសនៈដ៏ស្ងាត់ ដែលតាំងនៅក្នុងព្រៃតូចព្រៃធំ មិនមានសូរសព្ទ មិនមានគឹកកង ជាទីប្រាសចាកខ្យល់ ដែលកើតអំពីសរីរៈនៃមនុស្ស គួរជាទីកំបាំងនៃមនុស្ស គួរដល់កិរិយាសម្ងំនៅ ។ មួយទៀត ព្រះនាមថា ព្រះមានព្រះភាគ ព្រោះព្រះមានបុណ្យ ទ្រង់មានភាគនៃចីវរ បិណ្ឌបាត សេនាសនៈ និងគ្រឿងបរិក្ខារ គឺថ្នាំកែរោគ ។ ព្រះនាមថា ព្រះមានព្រះភាគ ព្រោះព្រះមានបុណ្យ ទ្រង់មានភាគនៃអត្ថរស ធម្មរស វិមុត្តិរស អធិសីល អធិចិត្ត និងអធិប្បញ្ញា ។ ព្រះនាម

ថា ព្រះមានព្រះភាគ ព្រោះព្រះមានបុណ្យ មានភាគនៃឈាន ៤ អប្បមញ្ញា ៤ និងអរូបសមាបត្តិ ៤ ព្រះនាមថា ព្រះមានព្រះភាគ ព្រោះព្រះមានបុណ្យ ទ្រង់មានភាគនៃវិមោក្ខ ៨ អភិភាយតន ៨ និងអនុបុព្វវិហារសមាបត្តិ ៩ ។ ព្រះនាមថា ព្រះមានព្រះភាគ ព្រោះព្រះមានបុណ្យ ទ្រង់មានភាគនៃសញ្ញា-ភាវនា ១០ កសិណសមាបត្តិ ១០ អានាបានស្សតិសមាធិ និងអសុភ-សមាបត្តិ ។ ព្រះនាមថា មានព្រះភាគ ព្រោះព្រះមានបុណ្យ ទ្រង់មានភាគនៃសតិប្បដ្ឋាន ៤ សម្មប្បធាន ៤ ឥទ្ធិបាទ ៤ ឥន្ទ្រិយ ៥ ពល ៥ ពោជ្ឈង្គ ៧ និងមគ្គប្រកបដោយអង្គ ៨ ដ៏ប្រសើរ ។ ព្រះនាមថា ព្រះមានព្រះភាគ ព្រោះព្រះមានបុណ្យ ទ្រង់មានភាគនៃតថាគតពល ១០ វេសារជ្ជ ៤ បដិសម្ភិទា ៤ អភិញ្ញា ៦ និងពុទ្ធធម៌ ៦ ។ ពាក្យថា ព្រះមានព្រះភាគ នេះ មិនមែនព្រះមាតាថ្វាយ មិនមែនព្រះបិតាថ្វាយ មិនមែនបងប្អូនប្រុសថ្វាយ មិនមែនបងប្អូនស្រីថ្វាយ មិនមែនមិត្ត និងអមាត្យថ្វាយ មិនមែនញាតិសាលោហិតថ្វាយ មិនមែនសមណៈ និងព្រាហ្មណ៍ថ្វាយ មិនមែនទេវតាទាំងឡាយថ្វាយទេ ពាក្យថា ព្រះមានព្រះភាគនុ៎ះ កើតក្នុងទីបំផុតវិមោក្ខរបស់ព្រះពុទ្ធទាំងឡាយទ្រង់មានភាគ ។ បញ្ញត្តិថា ព្រះមានព្រះភាគ នេះ ( កើតហើយ ) ដោយកិរិយាធ្វើឲ្យជាក់ច្បាស់ ព្រមទាំងការបានចំពោះនូវសព្វញ្ញុ-តញ្ញាណ ទៀបគល់ពោធិព្រឹក្ស ហេតុនោះ ទើបមានពាក្យថា ព្រះមានព្រះភាគត្រាស់ថា ម្នាលអជិតៈ ។

[ ៦២ ] ពាក្យថា លោកមិនភ្លឺស្វាង ព្រោះសេចក្តីប្រាថ្នាផ្សេងៗ ( និង

សេចក្តីប្រហែស ) អធិប្បាយថា សេចក្តីកំណាញ់ ៥ គឺកំណាញ់អាវាស កំណាញ់ត្រកូល កំណាញ់លាភ កំណាញ់វណ្ណៈ កំណាញ់ធម៌ ហៅថា សេចក្តីប្រាថ្នាផ្សេងៗ ។ សេចក្តីកំណាញ់ អាការនៃសេចក្តីកំណាញ់ ភាពនៃសេចក្តីកំណាញ់ សេចក្តីកំណាញ់ផ្សេងៗ សេចក្តីកំណាញ់រឹង ភាពនៃសេចក្តីកំណាញ់ក្តៅ ភាពនៃចិត្តហួងហែងមាំណា មានសភាពយ៉ាងនេះ នេះហៅថា សេចក្តីកំណាញ់ ។ មួយទៀត សេចក្តីកំណាញ់ខន្ធ ហៅថា កំណាញ់ សេចក្តីកំណាញ់ធាតុ ហៅថា កំណាញ់ សេចក្តីកំណាញ់អាយតនៈ ហៅថា កំណាញ់ សេចក្តីកាន់ ( ក្តាប់ទុក ) ហៅថា កំណាញ់ ។ សេចក្តីប្រហែស ខ្ញុំគប្បីពោលដូចតទៅ ការបណ្តែតបណ្តោយចិត្ត ការឲ្យកម្លាំងដល់ការបណ្តែតបណ្តោយចិត្តទៅក្នុងកាយទុច្ចរិតក្តី ក្នុងវចីទុច្ចរិតក្តី ក្នុងមនោទុច្ចរិតក្តី ក្នុងកាមគុណ ៥ ក្តី ឬភាពនៃការធ្វើមិនគោរព ភាពនៃកិរិយាមិនធ្វើព្យាយាមរឿយៗ ភាពនៃចិត្តមិនតាំងនៅមាំ ភាពនៃចិត្តប្រព្រឹត្តរួញរា ភាពនៃសេចក្តីប្រាថ្នាដាក់ចុះ ភាពនៃធុរៈដាក់ចុះ ការមិនសេព ការមិនចម្រើន អំពើមិនសន្សំរឿយៗ ការមិនតាំងចិត្ត ការមិនប្រកបព្យាយាមរឿយៗ សេចក្តីប្រហែសក្នុងការចម្រើននូវកុសលធម៌ទាំងឡាយ សេចក្តីប្រហែស អាការនៃសេចក្តីប្រហែស ភាពនៃសេចក្តីប្រហែសណា មានសភាពយ៉ាងនេះ នេះហៅថា សេចក្តីប្រហែស ។ ពាក្យថា លោកមិនភ្លឺស្វាង ព្រោះសេចក្តីប្រាថ្នាផ្សេងៗ ( និងសេចក្តីប្រហែស ) បានសេចក្តីថា លោកមិនភ្លឺស្វាង មិនមានរស្មី មិនមានពន្លឺ មិនរុងរឿង មិនយល់ច្បាស់ មិនប្រាកដ ព្រោះសេចក្តីកំណាញ់នេះ ព្រោះ

សេចក្តីប្រហែសធ្វេសនេះ ហេតុនោះ ( ទ្រង់ត្រាស់ថា ) លោកមិនភ្លឺស្វាង ព្រោះសេចក្តីប្រាថ្នាផ្សេងៗ ( និងសេចក្តីប្រហែស ) ។

[ ៦៣ ] ពាក្យថា តថាគត ពោលនូវសេចក្តីថា ជាគ្រឿងលាប អធិប្បាយថា តណ្ហា លោកហៅថា សេចក្តីប្រាថ្នា បានដល់ តម្រេក តម្រេកខ្លាំង សេចក្តីត្រេកអរ សេចក្តីត្រេកអរខ្លាំង សេចក្តីត្រេកត្រអាល សេចក្តីត្រេកត្រអាលខ្លាំង គឺតម្រេក ចិត្តត្រេកខ្លាំង សេចក្តីប្រាថ្នា សេចក្តីជ្រប់ចុះ កិរិយាលុងចុះ ចំណង់ ចំណង់ខ្លាំង ការជាប់ភក់ ញាប់ញ័រ ការលាក់ពុត ធម្មជាតញ៉ាំងសត្វឲ្យកើត គ្រឿងញ៉ាំងទុក្ខឲ្យកើត គ្រឿងចាក់ស្រេះ បណ្តាញ គ្រឿងហូរទៅ ធម្មជាតដូចពិស ខ្សែតណ្ហា គ្រឿងផ្សព្វផ្សាយ គ្រឿងញ៉ាំងអាយុឲ្យវិនាស សម្លាញ់ ប្រណិធាន គ្រឿងនាំសត្វទៅកាន់ភព ព្រៃធំ ព្រៃតូច សន្ថវៈ ស្នេហា អាល័យ សេចក្តីជាប់ចំពាក់ បំណង សេចក្តីប៉ុនប៉ង ភាពនៃសេចក្តីប៉ុនប៉ង បំណងរូប បំណងសំឡេង បំណងក្លិន បំណងរស បំណងផ្សព្វ បំណងលាភ បំណងទ្រព្យ បំណងបុត្រ បំណងជីវិត ការជាប់ចិត្ត ការជាប់ចិត្តខ្លាំង ការជាប់ចិត្តក្រៃលែង អាការជាប់ចិត្ត ភាពនៃការជាប់ចិត្ត សេចក្តីលោភលន់ ការលោភលន់ ភាពនៃសេចក្តីលោភលន់ សេចក្តីប្រាថ្នាអន្ទះអន្ទែង សេចក្តីប្រាថ្នាក្នុងអារម្មណ៍ស្រួល តម្រេកខុសធម៌ លោភខុសទំនង អាល័យ អាការអាល័យ ការប្រាថ្នា សេចក្តីស្រឡាញ់ ការប្រាថ្នាខ្លាំង ចំណង់កាម ចំណង់ភព ចំណង់វិភវភព ចំណង់រូប ចំណង់អរូប ចំណង់និរោធ ចំណង់រូប ចំណង់សំឡេង

ចំណង់ក្លិន ចំណង់រស ចំណង់ផ្សព្វ ចំណង់ធម្មារម្មណ៍ អន្ទង់ គ្រឿងប្រកប គ្រឿងសាំញ៉ាំ គ្រឿងប្រកាន់ គ្រឿងរាំង គ្រឿងហាម គ្រឿងប្រក់ គ្រឿងចង គ្រឿងចូលទៅឲ្យសៅហ្មង គ្រឿងដេកត្រាំ គ្រឿងស្ទាក់ជំណើរ វល្លិ សេចក្តីប្រាថ្នាផ្សេងៗ ឫសនៃទុក្ខ ហេតុនៃទុក្ខ កំណើតទុក្ខ អន្ទាក់មារ សន្ទូចមារ វិស័យមារ គោចរមារ ចំណងមារ ស្ទឹង គឺតណ្ហា បណ្តាញ គឺតណ្ហា ទន្លីង គឺតណ្ហា សមុទ្រ គឺតណ្ហា សេចក្តីសម្លឹង លោភ អកុសលមូលណា នេះហៅថា សេចក្តីប្រាថ្នា ។ គ្រឿងលាប គ្រឿងជាប់ គ្រឿងចង គ្រឿងចូលទៅឲ្យសៅហ្មងរបស់លោក លោកលាប លាបស្រឡាប សៅហ្មង សៅហ្មងព្រម ប្រឡាក់ ប្រឡាំព្រម ជាប់ជំពាក់ ជាប់ស្អិតហើយ ដោយសេចក្តីប្រាថ្នានេះ ។ តថាគតពោល ប្រាប់ សម្តែង បញ្ញត្ត តាំងទុក បើក បែក រំលែក ធ្វើឲ្យងាយ ប្រកាស ហេតុនោះ ( ទ្រង់ត្រាស់ថា ) តថាគតពោលនូវសេចក្តីប្រាថ្នា ថាជាគ្រឿងលាប ។

[ ៦៤ ] អធិប្បាយពាក្យថា ទុក្ខជាភ័យធំរបស់លោកនោះ ត្រង់ពាក្យថា ទុក្ខ គឺទុក្ខព្រោះកំណើត ទុក្ខព្រោះសេចក្តីចាស់ ទុក្ខព្រោះជំងឺ ទុក្ខព្រោះសេចក្តីស្លាប់ ទុក្ខព្រោះសេចក្តីសោក សេចក្តីខ្សឹកខ្សួល សេចក្តីលំបាកកាយ សេចក្តីតូចចិត្ត សេចក្តីក្រៀមក្រំ ទុក្ខក្នុងកំណើតនរក ទុក្ខក្នុងកំណើតតិរច្ឆាន ទុក្ខក្នុងកំណើតបិត្តិវិស័យ ទុក្ខក្នុងកំណើតមនុស្ស ទុក្ខមានការចុះកាន់គភ៌ជាមូល ទុក្ខមានការស្ថិតនៅក្នុងគភ៌ជាមូល ទុក្ខមានកិរិយាចេញចាកគភ៌ជាមូល ទុក្ខជាបំណងរបស់សត្វដែលកើតហើយ ទុក្ខទាក់ទងដោយបុគ្គលដទៃនៃសត្វ

ដែលកើតហើយ ទុក្ខកើតព្រោះព្យាយាមរបស់ខ្លួន ទុក្ខកើតព្រោះព្យាយាមរបស់បុគ្គលដទៃ ទុក្ខ គឺទុក្ខវេទនា ( ប្រព្រឹត្តទៅក្នុងកាយ និងចិត្ត ) ទុក្ខព្រោះសង្ខារ ទុក្ខព្រោះការផ្លាស់ប្តូរ រោគភ្នែក រោគត្រចៀក រោគច្រមុះ រោគអណ្តាត រោគកាយ រោគក្បាល រោគស្លឹកត្រចៀក រោគមាត់ រោគធ្មេញ ក្អក ហឺត ឬសដូងច្រមុះ ក្តៅក្រហាយ ស្គាំងស្គម រោគផ្ទៃ វិលមុខ ធ្លាក់ឈាម ចុកសៀត ចុះរាក ឃ្លង់ ពក ស្រែង រីងរៃ ឆ្កួតជ្រូក ដំណួចពិស រមាស់ កម រោគក្នុងទីខ្វារដោយក្រចក កមរលាយ ប្រមាត់ក្រហម ទឹកនោមផ្អែម ឬសដូងដុះ រលកកែវ ឬសដូចបាត អាពាធកើតអំពីប្រមាត់ អាពាធកើតអំពីស្លេស្ម អាពាធកើតអំពីខ្យល់ អាពាធកើតអំពីការប្រជុំ ( ខ្យល់ប្រមាត់ស្លេស្ម ) អាពាធកើតអំពីការផ្លាស់ប្តូររដូវ អាពាធកើតអំពីការរក្សាឥរិយាបថមិនស្មើ អាពាធកើតអំពីព្យាយាម ( មានការសម្លាប់ និងចងជាដើម ) អាពាធកើតអំពីផលកម្ម ត្រជាក់ ក្តៅ សេចក្តីឃ្លាន សេចក្តីស្រេក ឧច្ចារៈ បស្សាវៈ ទុក្ខកើតអំពីសម្ផស្សនៃរបោម មូស ខ្យល់ កម្តៅថ្ងៃ និងពស់ ការស្លាប់មាតាជាទុក្ខ ការស្លាប់បិតាជាទុក្ខ ការស្លាប់បងប្អូនប្រុសជាទុក្ខ ការស្លាប់បងប្អូនស្រីជាទុក្ខ ការស្លាប់កូនប្រុសជាទុក្ខ ការស្លាប់កូនស្រីជាទុក្ខ ការព្រាត់ប្រាសញាតិជាទុក្ខ ការវិនាសភោគៈជាទុក្ខ វិនាសគឺរោគជាទុក្ខ វិនាសសីលជាទុក្ខ វិនាសទិដ្ឋិជាទុក្ខ ការកើតឡើងនៃធម៌ទាំងឡាយណា រមែងប្រាកដក្នុងខាងដើម ការលត់ទៅ( នៃធម៌ទាំងឡាយនោះ ) រមែងប្រាកដដោយការវិនាស វិបាកអាស្រ័យកម្ម កម្មអាស្រ័យវិបាក រូប

អាស្រ័យនាម នាមអាស្រ័យរូប ត្រូវជាតិទៅតាមហើយ ត្រូវជរាផ្តេកផ្តិតហើយ ត្រូវព្យាធិគ្របសង្កត់ហើយ ត្រូវមរណៈកម្ចាត់ហើយ តាំងនៅស៊ប់ក្នុងសេចក្តីទុក្ខ ឥតមានទីពឹង ឥតមានទីជ្រក ឥតមានទីរឭក ឥតមានទីសង្ឃឹម នេះហៅថា ទុក្ខ ។ ទុក្ខជាភ័យធំ ជាគ្រឿងបៀតបៀន ជាគ្រឿងគាប ជាគ្រឿងឧបទ្រព ជាឧបសគ្គ របស់លោកនោះ ហេតុនោះ ( ទ្រង់ត្រាស់ថា ) ទុក្ខជាភ័យធំរបស់លោកនោះ ។ ហេតុនោះ ព្រះមានព្រះភាគត្រាស់ហើយថា

( ព្រះមានព្រះភាគត្រាស់ថា ) ម្នាលអជិតៈ លោកត្រូវអវិជ្ជាបិទបាំង លោកមិនភ្លឺស្វាង ព្រោះសេចក្តីប្រាថ្នាផ្សេងៗ ( និងសេចក្តីប្រហែស ) តថាគតពោលនូវសេចក្តីប្រាថ្នា ថាជាគ្រឿងលាប ទុក្ខជាភ័យធំ របស់លោកនោះ ។

[ ៦៥ ] ( អជិតមាណពមានអាយុ ក្រាបបង្គំទូលសួរដូច្នេះថា ) ខ្សែទាំងឡាយ រមែងហូរទៅក្នុងទីទាំងពួង អ្វីជាគ្រឿងរាំងនូវខ្សែទាំងឡាយ សូមព្រះអង្គទ្រង់សម្តែងធម៌ជាគ្រឿងបិទខ្សែទាំងឡាយ បុគ្គលបិទខ្សែទាំងឡាយដោយអ្វី ។

[ ៦៦ ] អធិប្បាយពាក្យថា ខ្សែទាំងឡាយ រមែងហូរទៅក្នុងទីទាំងពួង ត្រង់ពាក្យថា ខ្សែទាំងឡាយ បានដល់ ខ្សែ គឺតណ្ហា ខ្សែ គឺទិដ្ឋិ ខ្សែ គឺកិលេស ខ្សែ គឺទុច្ចរិត ខ្សែ គឺអវិជ្ជា ។ ពាក្យថា ក្នុងទីទាំងពួង គឺក្នុងអាយតនៈទាំងពួង។ ពាក្យថា ហូរទៅ សេចក្តីថា ហូរទៅ ហូរសំយុង ហូរមិនដាច់ ប្រព្រឹត្តទៅ គឺហូរទៅ ហូរសំយុង ហូរមិនដាច់ ប្រព្រឹត្តទៅអំពីភ្នែក

ទៅកាន់រូប ហូរអំពីត្រចៀកទៅកាន់សំឡេង ហូរអំពីច្រមុះទៅកាន់ក្លិន ហូរអំពីអណ្តាតទៅកាន់រស ហូរអំពីកាយទៅកាន់ផ្សព្វ ហូរទៅ ហូរសំយុង ហូរមិនដាច់ ប្រព្រឹត្តទៅអំពីចិត្តទៅកាន់ធម្មារម្មណ៍ រូបតណ្ហា ហូរទៅ ហូរសំយុង ហូរមិនដាច់ ប្រព្រឹត្តទៅអំពីភ្នែក សទ្ទតណ្ហា ហូរទៅ ហូរសំយុង ហូរមិនដាច់ ប្រព្រឹត្តទៅអំពីត្រចៀក គន្ធតណ្ហា ហូរទៅអំពីច្រមុះ រសតណ្ហា ហូរទៅអំពីអណ្តាត ផោដ្ឋព្វតណ្ហា ហូរទៅអំពីកាយ ធម្មតណ្ហា ហូរទៅ ហូរសំយុង ហូរមិនដាច់ ប្រព្រឹត្តទៅអំពីចិត្ត ហេតុនោះ លោកសួរថា ខ្សែទាំងឡាយ រមែងហូរទៅ ក្នុងទីទាំងពួង ។

[ ៦៧ ] ពាក្យថា ដូច្នេះ នៃបទថា អជិតៈមានអាយុ ( ទូលសួរ ) ដូច្នេះ គឺជាការតបទ ជាការជាប់ដោយបទ ជាការបំពេញបទ ជាការប្រជុំនៃអក្ខរៈ ជាសេចក្តីពីរោះ ដោយព្យញ្ជនៈ ពាក្យថា ដូច្នេះ នេះជាលំដាប់នៃបទ។ ពាក្យថា មានអាយុ គឺពាក្យជាទីស្រឡាញ់ ជាពាក្យគោរព ពាក្យថា មានអាយុនេះ ជាពាក្យពោលដោយគោរពកោតក្រែង ។ ពាក្យថា អជិតៈ គឺជានាម ជាសង្ខារ ជាឈ្មោះ ជាបញ្ញត្តិ ជាវោហារ ជានាម ជានាមកម្ម ជានាមធេយ្យៈ ជាភាសា ជាព្យញ្ជនៈ ជាពាក្យហៅរបស់ព្រាហ្មណ៍នោះ ហេតុនោះ មានពាក្យថា អជិតៈមានអាយុ ( ទូលសួរ ) ដូច្នេះ ។

[ ៦៨ ] ពាក្យថា អ្វីជាគ្រឿងរាំងនូវខ្សែទាំងឡាយ គឺអ្វីជាគ្រឿងឃាត់ខាំង ជាគ្រឿងរាំង ជាគ្រឿងបិទ ជាគ្រឿងរក្សា ជាគ្រឿងគ្រប់គ្រងនូវខ្សែទាំងឡាយ ហេតុនោះ លោកសួរថា អ្វីជាគ្រឿងរាំងនូវខ្សែ

ទាំងឡាយ ។

[ ៦៩ ] ពាក្យថា សូមព្រះអង្គទ្រង់សម្តែងធម៌ជាគ្រឿងបិទខ្សែទាំងឡាយ គឺសូមព្រះអង្គពោល ប្រាប់ សម្តែង បញ្ញត្ត តាំងទុក បើក ចែក ធ្វើឲ្យងាយ ប្រកាស នូវធម៌ជាគ្រឿងឃាត់ខាំង គ្រឿងរាំង គ្រឿងបិទ គ្រឿងរក្សា គ្រឿងគ្រប់គ្រងខ្សែទាំងឡាយ ហេតុនោះ លោកសួរថា សូមព្រះអង្គទ្រង់សម្តែងធម៌ជាគ្រឿងបិទខ្សែទាំងឡាយ ។

[ ៧០ ] ពាក្យថា បុគ្គលបិទខ្សែទាំងឡាយដោយអ្វី គឺខ្សែទាំងឡាយបុគ្គលបិទដាច់សូន្យ មិនហូរទៅ មិនហូរសំយុង មិនហូររឿយៗ មិនប្រព្រឹត្តទៅដោយអ្វី ហេតុនោះ លោកសួរថា បុគ្គលបិទខ្សែទាំងឡាយដោយអ្វី ។ ហេតុនោះ ព្រាហ្មណ៍នោះពោលថា

ខ្សែទាំងឡាយ រមែងហូរទៅ ក្នុងទីទាំងពួង អ្វីជាគ្រឿងរាំងនូវ
ខ្សែទាំងឡាយ សូមព្រះអង្គទ្រង់សម្តែងធម៌ ជាគ្រឿងបិទខ្សែ
ទាំងឡាយ បុគ្គលបិទខ្សែទាំងឡាយដោយអ្វី ។

[ ៧១ ] ( ព្រះមានព្រះភាគត្រាស់ថា ម្នាលអជិតៈ ) ខ្សែទាំងឡាយ
ណាក្នុងលោក សតិ ជាគ្រឿងបិទខ្សែទាំងនោះ តថាគតពោលនូវ
ការបិទខ្សែទាំងឡាយ ខ្សែទាំងនុ៎ះ បុគ្គលបិទបានដោយបញ្ញា ។

[ ៧២ ] ពាក្យថា ខ្សែទាំងឡាយណាក្នុងលោក សេចក្តីថា ខ្សែទាំងឡាយណា ដែលតថាគតពោល ប្រាប់ សម្តែង បញ្ញត្ត តាំងទុក ញែក ចែក ធ្វើឲ្យងាយ ប្រកាសហើយថា ខ្សែ គឺតណ្ហា ខ្សែ គឺទិដ្ឋិ ខ្សែ គឺកិលេស ខ្សែ

គឺទុច្ចរិត ខ្សែ គឺអវិជ្ជា ។ ពាក្យថា ក្នុងលោក គឺក្នុងអបាយលោក មនុស្សលោក ទេវលោក ខន្ធលោក ធាតុលោក អាយតនលោក ហេតុនោះ ( ទ្រង់ត្រាស់ថា ) ខ្សែទាំងឡាយណាក្នុងលោក ។ ពាក្យថា អជិតៈ គឺព្រះមានព្រះភាគទ្រង់ត្រាស់ហៅព្រាហ្មណ៍នោះចំឈ្មោះ ។

[ ៧៣ ] ពាក្យថា សតិជាគ្រឿងបិទទាំងនោះ ត្រង់ពាក្យថា សតិ បានដល់ សេចក្តីរឭក សេចក្តីរឭករឿយៗ សេចក្តីរឭកចំពោះ សេចក្តីរឭក អាការនៃសេចក្តីរឭក សេចក្តីចាំ សេចក្តីជ្រួតជ្រាប សេចក្តីមិនវង្វេង សេចក្តីរឭក ឥន្ទ្រិយ គឺសតិ អង្គនៃធម៌ជាគ្រឿងត្រាស់ដឹង គឺសតិ ផ្លូវជាទីទៅនៃបុគ្គលតែម្នាក់ នេះហៅថា សតិ ។ ពាក្យថា ជាគ្រឿងបិទ គឺជាគ្រឿងរាំង ជាគ្រឿងបិទ ជាគ្រឿងឃាត់ខាំង ជាគ្រឿងរក្សា ជាគ្រឿងគ្រប់គ្រង ហេតុនោះ ទ្រង់ត្រាស់ថា សតិ ជាគ្រឿងបិទខ្សែទាំងនោះ ។

[ ៧៤ ] ពាក្យថា តថាគតពោល នូវការបិទខ្សែទាំងឡាយ គឺតថាគតពោល ប្រាប់ សម្តែង បញ្ញត្ត តាំងទុក ញែក បែក ធ្វើឲ្យងាយ ប្រកាសនូវការរារាំង ឃាត់ខាំង បិទរក្សា គ្រប់គ្រងនូវខ្សែទាំងឡាយ ហេតុនោះ ទ្រង់ត្រាស់ថា តថាគតពោលនូវការបិទខ្សែទាំងឡាយ ។

[ ៧៥ ] អធិប្បាយពាក្យថា ខ្សែទាំងនុ៎ះ បុគ្គលមិនបានដោយបញ្ញា ត្រង់ពាក្យថា បញ្ញា បានដល់ប្រាជ្ញា ការដឹងច្បាស់ ។បេ។ សេចក្តីមិនវង្វេង ការពិចារណាធម៌ សេចក្តីយល់ត្រូវ ។ ពាក្យថា ខ្សែទាំងនុ៎ះ បុគ្គលបិទបានដោយបញ្ញា គឺខ្សែទាំងនោះ បុគ្គលបិទ ដាច់ស្សូន្យ មិនហូរទៅ មិនហូរសំយុង

មិនហូររឿយៗ មិនប្រព្រឹត្តទៅដោយបញ្ញា ។ ខ្សែទាំងនុ៎ះ បុគ្គលបិទ ដាច់ សូន្យ មិនហូរទៅ មិនហូរសំយុង មិនហូររឿយៗ មិនប្រព្រឹត្តទៅដោយ បញ្ញារបស់បុគ្គលអ្នកដឹង អ្នកឃើញថា សង្ខារទាំងពួងមិនទៀង ។ ខ្សែទាំង នុ៎ះ បុគ្គលបិទ ដាច់សូន្យ មិនហូរទៅ មិនហូរសំយុង មិនហូររឿយៗ មិន ប្រព្រឹត្តទៅដោយបញ្ញារបស់បុគ្គលអ្នកដឹង អ្នកឃើញថា សង្ខារទាំងពួងជា ទុក្ខ ។ ខ្សែទាំងនុ៎ះ បុគ្គលបិទ ដាច់សូន្យ មិនហូរទៅ មិនហូរសំយុង មិនហូរ រឿយៗ មិនប្រព្រឹត្តទៅដោយបញ្ញារបស់បុគ្គលអ្នកដឹង អ្នកឃើញថា ធម៌ ទាំងពួងជាអនត្តា ។ ខ្សែទាំងនុ៎ះ បុគ្គលបិទ ដាច់សូន្យ មិនហូរទៅ មិនហូរ សំយុង មិនហូររឿយៗ មិនប្រព្រឹត្តទៅដោយបញ្ញារបស់បុគ្គលអ្នកដឹង អ្នក ឃើញថា សង្ខារទាំងឡាយ ( កើតមាន ) ព្រោះអវិជ្ជាជាបច្ច័យ ។ ខ្សែទាំង នុ៎ះ បុគ្គលបិទ ដាច់សូន្យ មិនហូរទៅ មិនហូរសំយុង មិនហូររឿយៗ មិន ប្រព្រឹត្តទៅដោយបញ្ញារបស់បុគ្គលអ្នកដឹង អ្នកឃើញថា វិញ្ញាណ ( កើត មាន ) ព្រោះសង្ខារជាបច្ច័យ ថានាម និងរូប ( កើតមាន ) ព្រោះវិញ្ញាណ ជាបច្ច័យ ថាអាយតនៈ ៦ ( កើតមាន ) ព្រោះនាម និងរូបជាបច្ច័យ ថា ផស្សៈ ( កើតមាន ) ព្រោះអាយតនៈ ៦ ជាបច្ច័យ ថាវេទនា ( កើតមាន ) ព្រោះផស្សៈជាបច្ច័យ ថាតណ្ហា ( កើតមាន ) ព្រោះវេទនាជាបច្ច័យ ថា ឧបាទាន ( កើតមាន ) ព្រោះតណ្ហាជាបច្ច័យ ថាភព ( កើតមាន ) ព្រោះ ឧបាទានជាបច្ច័យ ថាជាតិ ( កើតមាន ) ព្រោះភពជាបច្ច័យ ថាជរា និង មរណៈ ( កើតមាន ) ព្រោះជាតិជាបច្ច័យ ។ ខ្សែទាំងនុ៎ះ បុគ្គលបិទ ដាច់

សូន្យ មិនហូរទៅ មិនហូរសំយុង មិនហូររឿយៗ មិនប្រព្រឹត្តទៅដោយ បញ្ញារបស់បុគ្គលអ្នកដឹង អ្នកឃើញថា សេចក្ដីរលត់សង្ខារ ព្រោះការរលត់អវិជ្ជា ថាសេចក្ដីរលត់វិញ្ញាណ ព្រោះការរលត់សង្ខារ ថាសេចក្ដីរលត់នាមនិងរូប ព្រោះការរលត់វិញ្ញាណ ថាសេចក្ដីរលត់អាយតនៈ ៦ ព្រោះការរលត់នាម និងរូប ថាសេចក្ដីរលត់ផស្សៈ ព្រោះការរលត់អាយតនៈ ៦ ថាសេចក្ដីរលត់វេទនា ព្រោះការរលត់ផស្សៈ ថាសេចក្ដីរលត់តណ្ហា ព្រោះការរលត់វេទនា ថាសេចក្ដីរលត់ឧបាទាន ព្រោះការរលត់តណ្ហា ថាសេចក្ដីរលត់ភព ព្រោះការរលត់ឧបាទាន ថាសេចក្ដីរលត់ជាតិ ព្រោះការរលត់ភព ថាសេចក្ដីរលត់ជរា និងមរណៈ ព្រោះការរលត់ជាតិ ។ ខ្សែទាំងនុ៎ះ បុគ្គលបិទ ដាច់សូន្យ មិនហូរទៅ មិនហូរសំយុង មិនហូររឿយៗ មិនប្រព្រឹត្តទៅដោយបញ្ញារបស់បុគ្គលអ្នកដឹង អ្នកឃើញថា នេះទុក្ខ ថានេះជាហេតុឲ្យកើតទុក្ខ ថានេះជាសេចក្ដីរលត់ទុក្ខ ថានេះបដិបទាដំណើរទៅកាន់ទីរលត់ទុក្ខ ។ ខ្សែទាំងនុ៎ះ បុគ្គលបិទ ដាច់សូន្យ មិនហូរទៅ មិនហូរសំយុង មិនហូររឿយៗ មិនប្រព្រឹត្តទៅដោយបញ្ញារបស់បុគ្គលអ្នកដឹង អ្នកឃើញថា នេះពួកអាសវៈ ថានេះហេតុឲ្យកើតអាសវៈ ថានេះសេចក្ដីរលត់អាសវៈ ថានេះបដិបទាដំណើរទៅកាន់ទីរលត់អាសវៈ ខ្សែទាំងនុ៎ះ បុគ្គលបិទ ដាច់សូន្យ មិនហូរទៅ មិនហូរសំយុង មិនហូររឿយៗ មិនប្រព្រឹត្តទៅដោយបញ្ញារបស់បុគ្គលអ្នកដឹង អ្នកឃើញថា ធម៌ទាំងនេះ គប្បីត្រាស់ដឹង ថាធម៌ទាំងនេះ គប្បីកំណត់ដឹង ថាធម៌ទាំងនេះ គប្បីលះ ថាធម៌ទាំងឡាយនេះ គប្បីចម្រើន ថាធម៌ទាំងឡាយ

នេះ គប្បីធ្វើឲ្យជាក់ច្បាស់ ។ ខ្សែទាំងនុ៎ះ បុគ្គលបិទ ដាច់សូន្យ មិនហូរទៅ មិនហូរសំយុង មិនហូររៀយៗ មិនប្រព្រឹត្តទៅដោយបញ្ញារបស់បុគ្គលអ្នកដឹង អ្នកឃើញសេចក្តីកើតឡើង វិនាសទៅ អានិសង្ស ទោស និងកិរិយារលាស់ចេញនូវផស្សាយតនៈទាំង ៦ ខ្សែទាំងនុ៎ះ បុគ្គលបិទ ដាច់សូន្យ មិនហូរទៅ មិនហូរសំយុង មិនហូររៀយៗ មិនប្រព្រឹត្តទៅដោយបញ្ញារបស់បុគ្គលអ្នកដឹង អ្នកឃើញសេចក្តីកើតឡើង វិនាសទៅ អានិសង្ស ទោស និងកិរិយារលាស់ចេញនូវផស្សាយតនៈទាំង ៦ ។ ខ្សែទាំងនុ៎ះ បុគ្គលបិទ ដាច់សូន្យ មិនហូរទៅ មិនហូរសំយុង មិនហូររៀយៗ មិនប្រព្រឹត្តទៅដោយបញ្ញារបស់បុគ្គលអ្នកដឹង អ្នកឃើញសេចក្តីកើតឡើង វិនាសទៅ អានិសង្ស ទោស និងកិរិយារលាស់ចេញនូវឧបាទានក្ខន្ធ ៥ អ្នកដឹង អ្នកឃើញ នូវការកើតឡើង វិនាសទៅ អានិសង្ស ទោស និងកិរិយារលាស់ចេញនូវមហាភូតទាំង ៤ អ្នកដឹង អ្នកឃើញថា ធម៌ណាមួយមានសភាពកើតឡើងហើយ ធម៌ទាំងអស់នោះ មានកិរិយារលត់ទៅវិញជាធម្មតា ( ហេតុនោះ ទ្រង់ត្រាស់ថា ) ខ្សែទាំងនុ៎ះ បុគ្គលបិទបានដោយបញ្ញា ។ ហេតុនោះ ព្រះមានព្រះភាគត្រាស់ថា

ម្នាលអជិតៈ ខ្សែទាំងឡាយណា ក្នុងលោក សតិ ជាគ្រឿងបិទ
ខ្សែទាំងនោះ តថាគតពោល នូវការបិទខ្សែទាំងឡាយ ខ្សែទាំង
នោះ បុគ្គលបិទបានដោយបញ្ញា ។

[ ៧៦ ] ( អជិតៈមានអាយុក្រាបបង្គំទូលថា ) បពិត្រព្រះអង្គនិរទុក្ខ បញ្ញា ១ សតិ ១ នាម និងរូប ១ ខ្ញុំព្រះអង្គសួរហើយ

សូមទ្រង់សម្ដែងប្រាប់នូវសេចក្ដីនុ៎ះ ដល់ខ្ញុំព្រះអង្គ តើធម៌នុ៎ះ រលត់ទៅក្នុងទីណា ។

[ ៧៧ ] ពាក្យថា បញ្ញា ១ សតិ ១ត្រង់ពាក្យថា បញ្ញា បានខាង ប្រាជ្ញា ការដឹងច្បាស់ ការពិចារណា ការពិចារណាឃើញ ការកំណត់ ការ កំណត់ដឹង ការកំណត់ដឹងសព្វ ភាពនៃការឈ្លាសវៃ ភាពនៃការវាងវៃ ភាព នៃបញ្ញាដ៏ពេញលេញ សេចក្ដីយល់ច្បាស់ ការគិត ការរំពឹង ប្រាជ្ញាក្រាស់ ប្រាជ្ញាសម្រាប់ទម្លាយបង់នូវកិលេស ប្រាជ្ញាសម្រាប់ដឹកនាំ ប្រាជ្ញាសម្រាប់ ឃើញច្បាស់ សេចក្ដីដឹងច្បាស់ សភាពនៃការទម្លុះបញ្ញា ឥន្ទ្រិយ គឺបញ្ញា កម្លាំង គឺបញ្ញា សស្ត្រា គឺបញ្ញា ប្រាសាទ គឺបញ្ញា ពន្លឺ គឺបញ្ញា រស្មី គឺបញ្ញា ការរុងរឿង គឺបញ្ញា កែវ គឺបញ្ញា សេចក្ដីមិនវង្វេង ការពិចារណា ធម៌ សេចក្ដីយល់ត្រូវ ។ ពាក្យថា សតិ បានដល់ សេចក្ដីរឭក សេចក្ដី រឭករឿយៗ ។បេ។ សេចក្ដីរឭកត្រូវ ហេតុនោះ ( មានពាក្យថា ) អជិត- មាណពដ៏មានអាយុពោលថា បញ្ញា ១ សតិ ១ ។

[ ៧៨ ] ពាក្យថា បពិត្រព្រះអង្គនិរទុក្ខ នាម និងរូប ១ ត្រង់ពាក្យថា នាម បានដល់ អរូបក្ខន្ធ ៤ ។ ពាក្យថា រូប គឺមហាភូតរូប ៤ និងរូប ដែលអាស្រ័យមហាភូតរូបទាំង ៤ ។ ពាក្យថា បពិត្រព្រះអង្គនិរទុក្ខ គឺពាក្យ ជាទីស្រឡាញ់ ជាពាក្យគោរព ពាក្យថា បពិត្រព្រះអង្គជានិរទុក្ខ ជាពាក្យ ពោលដោយគោរព កោតក្រែង ហេតុនោះ ( លោកសួរថា ) បពិត្រ ព្រះអង្គនិរទុក្ខ នាម និងរូប ១ ។

[ ៧៩ ] ពាក្យថា ខ្ញុំព្រះអង្គសួរហើយ សូមទ្រង់សម្តែងប្រាប់នូវសេចក្តីនុ៎ះ ដល់ខ្ញុំព្រះអង្គ ត្រង់ពាក្យថា នូវសេចក្តីនុ៎ះដល់ខ្ញុំព្រះអង្គ គឺខ្ញុំព្រះអង្គសួរសេចក្តីណា សូមសេចក្តីណា អារាធនាសេចក្តីណា ជ្រះថ្លាសេចក្តីណា ។ ពាក្យថា ខ្ញុំព្រះអង្គសួរហើយ គឺខ្ញុំព្រះអង្គសួរ សូមអារាធនា ជ្រះថ្លាហើយ ។ ពាក្យថា សូមទ្រង់សម្តែងប្រាប់ គឺសូមទ្រង់ពោល ប្រាប់ សម្តែង បញ្ញត្ត តាំងទុក ញែក ចែក ធ្វើឲ្យងាយ ប្រកាស ហេតុនោះ ( លោកសួរថា ) ខ្ញុំព្រះអង្គសួរហើយ សូមទ្រង់សម្តែងប្រាប់នូវសេចក្តីនុ៎ះ ដល់ខ្ញុំព្រះអង្គ ។

[ ៨០ ] ពាក្យថា តើធម៌នុ៎ះ រលត់ទៅក្នុងទីណា គឺធម៌នុ៎ះ រលត់ទៅ រម្ងាប់ទៅ ដល់នូវសេចក្តីវិនាស ស្ងប់រម្ងាប់ទៅក្នុងទីណា ហេតុនោះ( លោកសួរថា ) ធម៌នុ៎ះរលត់ទៅក្នុងទីណា ។ ហេតុនោះ ព្រាហ្មណ៍នោះពោលថា

បពិត្រព្រះអង្គជានិរទុក្ខ បញ្ញា ១ សតិ ១ នាម និងរូប ១
ខ្ញុំព្រះអង្គសួរហើយ សូមទ្រង់សម្តែងប្រាប់នូវសេចក្តីនុ៎ះ ដល់ខ្ញុំ
ព្រះអង្គ តើធម៌នុ៎ះ រលត់ទៅក្នុងទីណា ។

[ ៨១ ] ( ព្រះមានព្រះភាគត្រាស់ថា ) ម្នាលអជិតៈ អ្នកបាន
សួរហើយនូវប្រស្នាណា តថាគតនឹងពោលនូវប្រស្នានោះដល់អ្នក
នាម និងរូប រលត់មិនមានសេសសល់ក្នុងទីណា នាម និងរូបនុ៎ះ
រលត់ ក្នុងទីនុ៎ះ ព្រោះកិរិយារលត់វិញ្ញាណ ។

[ ៨២ ] ពាក្យថា អ្នកបានសួរហើយ នូវប្រស្នាណា ត្រង់ពាក្យថា នូវប្រស្នាណា គឺនូវបញ្ញា សតិ និងនាមរូប ។ ពាក្យថា បានសួរហើយ គឺ

សួរ សូមអាពធនា ជ្រះថ្លាហើយ ហេតុនោះ ( ទ្រង់ត្រាស់ថា ) អ្នកបាន សួរហើយនូវប្រស្នាណា ។

[ ៨៣ ] ពាក្យថា អជិតៈ នៃបទថា ម្នាលអជិតៈ តថាគតនឹងពោល ប្រស្នានោះដល់អ្នក គឺព្រះមានព្រះភាគត្រាស់ហៅព្រាហ្មណ៍នោះចំឈ្មោះ ។ ពាក្យថា នូវប្រស្នានោះ គឺនូវបញ្ញាផង សតិផង នាម និងរូបផង ។ ពាក្យ ថា នឹងពោល គឺនឹងពោល ប្រាប់ សម្តែង បញ្ញត្ត តាំងទុក ញែក ចែក ធ្វើឲ្យរាយ ប្រកាសនូវប្រស្នានោះ ហេតុនោះ ( ទ្រង់ត្រាស់ថា ) ម្នាល អជិតៈ តថាគតនឹងពោលនូវប្រស្នានោះដល់អ្នក ។

[ ៨៤ ] ពាក្យថា នាម និងរូប រលត់មិនមានសេសសល់ ក្នុងទីណា ត្រង់ពាក្យថា នាម បានដល់ អរូបក្ខន្ធ ៤ ។ ពាក្យថា រូប គឺមហាភូតរូប ៤ និងរូបអាស្រ័យមហាភូតរូប ៤ ។ ពាក្យថា មិនមានសេសសល់ គឺគ្រប់ ទាំងអស់ សព្វទាំងអស់ មិនមានសេសសល់ រកសេសសល់គ្មាន ពាក្យថា មិនមានសេសសល់ នេះជាពាក្យរួមយក ។ ពាក្យថា រលត់ គឺរលត់ រម្ងាប់ ដល់នូវការវិនាស ស្ងប់រម្ងាប់ ហេតុនោះ ( ទ្រង់ត្រាស់ថា ) នាម និងរូប រលត់មិនមានសេសសល់ ក្នុងទីណា ។

[ ៨៥ ] ពាក្យថា នាម និងរូបនុ៎ះ រលត់ក្នុងទីនោះ ព្រោះកិរិយារលត់ វិញ្ញាណ អធិប្បាយថា ធម៌ទាំងឡាយណា គឺនាម និងរូប គប្បីកើតក្នុងសង្សារ មានទីបំផុតខាងដើម ដែលគេមិនអាចដឹងបាន វៀរលែងតែកំណើត ៧ ចេញ ធម៌ទាំងនុ៎ះ រលត់ រម្ងាប់ ដល់នូវការវិនាស ស្ងប់ រម្ងាប់ ក្នុងសោតាបត្តិមគ្គ

នោះ ព្រោះកិរិយារលត់អភិសង្ខារវិញ្ញាណ ដោយសោតាបត្តិមគ្គញ្ញាណ ។ ធម៌ទាំងឡាយណា គឺនាម និងរូប គប្បីកើតក្នុងកំណើត ៥ វៀរលែងតែកំណើត ២ ធម៌ទាំងនុ៎ះ រលត់ រម្ងាប់ ដល់នូវការវិនាស ស្ងប់រម្ងាប់ក្នុងសកទាគាមិមគ្គនោះ ព្រោះកិរិយារលត់អភិសង្ខារវិញ្ញាណ ដោយសកទាគាមិមគ្គញ្ញាណ ។ ធម៌ទាំងឡាយណា គឺនាម និងរូប គប្បីកើតក្នុងកាមធាតុក្តី រូបធាតុក្តី អរូបធាតុក្តី វៀរលែងតែកំណើត ១ ធម៌ទាំងនុ៎ះ រលត់ រម្ងាប់ ដល់នូវការវិនាស ស្ងប់ រម្ងាប់ ក្នុងអនាគាមិមគ្គនុ៎ះ ព្រោះកិរិយារលត់អភិសង្ខារវិញ្ញាណ ដោយអនាគាមិមគ្គញ្ញាណ ។ ធម៌ទាំងឡាយណា គឺនាម និងរូប គប្បីកើត ធម៌ទាំងនុ៎ះ រលត់ រម្ងាប់ ដល់នូវការវិនាស ស្ងប់ រម្ងាប់ ក្នុងអរហត្តមគ្គនុ៎ះ ព្រោះកិរិយារលត់អភិសង្ខារវិញ្ញាណ ដោយអរហត្តមគ្គញ្ញាណ ។ ព្រះអរហន្ត កាលបរិនិព្វានដោយអនុបាទិសេសនិព្វានធាតុ បញ្ញាផង សតិផង នាម និងរូបផង ធម៌ទាំងនុ៎ះ តែងរលត់ រម្ងាប់ ដល់នូវការវិនាស ស្ងប់ រម្ងាប់ ក្នុងអរហត្តមគ្គនុ៎ះ ព្រោះកិរិយារលត់វិញ្ញាណមុនហេតុនោះ ( ទ្រង់ ត្រាស់ថា ) នាម និងរូបនុ៎ះ រលត់ក្នុងទីនុ៎ះ ព្រោះកិរិយារលត់វិញ្ញាណ ។ ហេតុនោះ ព្រះមានព្រះភាគត្រាស់ថា

ម្នាលអជិតៈ អ្នកបានសួរហើយ នូវប្រស្នាណា តថាគតនឹងពោលនូវប្រស្នានុ៎ះដល់អ្នក នាម និងរូប រលត់មិនមានសេសសល់ក្នុងទីណា នាម និងរូបនោះ រលត់ក្នុងទីនុ៎ះ ព្រោះកិរិយារលត់វិញ្ញាណ ។

[ ៨៦ ] ( អជិតៈសួរថា ) បុគ្គលទាំងឡាយណា មានធម៌ពិចារណាឃើញហើយ និងបុគ្គលទាំងឡាយណា ជាសេក្ខៈ មានប្រមាណច្រើន ក្នុងទីនេះ បពិត្រព្រះអង្គនិរទុក្ខ ព្រះអង្គជាបុគ្គលមានបញ្ញាចាស់ក្លា ខ្ញុំព្រះអង្គសួរហើយ សូមទ្រង់ត្រាស់ប្រាប់នូវសេចក្តីប្រព្រឹត្តរបស់បុគ្គលទាំងឡាយនោះ ដល់ខ្ញុំព្រះអង្គ ។

[ ៨៧ ] ពាក្យថា បុគ្គលទាំងឡាយណា មានធម៌ពិចារណាឃើញហើយ អធិប្បាយថា អរហន្តខីណាស្រពទាំងឡាយ លោកហៅថា អ្នកមានធម៌ពិចារណាឃើញហើយ ។ ព្រោះហេតុអ្វី អរហន្តខីណាស្រពទាំងឡាយលោកហៅថា អ្នកមានធម៌ពិចារណាឃើញហើយ ។ អរហន្តខីណាស្រពទាំងនោះ មានធម៌ពិចារណាឃើញហើយ មានធម៌ដឹងហើយ មានធម៌ថ្លឹងហើយ មានធម៌ពិនិត្យហើយ មានធម៌ប្រាកដហើយ មានធម៌ចម្រើនច្បាស់ហើយ គឺមានធម៌ពិចារណាឃើញហើយ មានធម៌ដឹងហើយ មានធម៌ថ្លឹងហើយមានធម៌ពិនិត្យហើយ មានធម៌ប្រាកដហើយ មានធម៌ចម្រើនច្បាស់ហើយថាសង្ខារទាំងពួង មិនទៀង មានធម៌ពិចារណាឃើញហើយ ។បេ។ ថាសង្ខារទាំងពួងជាទុក្ខ មានធម៌ពិចារណាឃើញហើយ ។បេ។ ថាធម៌ទាំងពួងជាអនត្តា មានធម៌ពិចារណាឃើញហើយ ។បេ។ ថាសង្ខារទាំងឡាយកើតមានព្រោះអវិជ្ជាជាបច្ច័យ មានធម៌ពិចារណាឃើញហើយ មានធម៌ដឹងហើយ មានធម៌ថ្លឹងហើយ មានធម៌ពិនិត្យហើយ មានធម៌ប្រាកដហើយ មានធម៌ចម្រើនច្បាស់ហើយថា ធម្មជាតណាមួយ មានកិរិយាកើតឡើងជាធម្មតា ធម្មជាត

ទាំងអស់ទុំះ មានកិរិយារលត់ទៅវិញជាធម្មតា ។ មួយទៀតថា ព្រះអរហន្ត ទាំងនោះ មានខន្ធពិចារណាឃើញហើយ មានធាតុពិចារណាឃើញហើយ មានអាយតនៈពិចារណាឃើញហើយ មានគតិពិចារណាឃើញហើយ មានឧបបត្តិពិចារណាឃើញហើយ មានបដិសន្ធិពិចារណាឃើញហើយ មានភពពិចារណាឃើញហើយ មានសង្សារពិចារណាឃើញហើយ មានវដ្តៈពិចារណាឃើញហើយ ។ មួយទៀតថា ព្រះអរហន្តខីណាស្រពទាំងឡាយនោះ តាំងនៅក្នុងទីបំផុតខន្ធ តាំងនៅក្នុងទីបំផុតធាតុ តាំងនៅក្នុងទីបំផុតអាយតនៈ តាំងនៅក្នុងទីបំផុតគតិ តាំងនៅក្នុងទីបំផុតឧបបត្តិ តាំងនៅក្នុងទីបំផុតបដិសន្ធិ តាំងនៅក្នុងទីបំផុតភព តាំងនៅក្នុងទីបំផុតសង្សារ តាំងនៅក្នុងទីបំផុតវដ្តៈ តាំងនៅក្នុងភពជាទីបំផុត តាំងនៅក្នុងសរីរៈជាទីបំផុត មានកិរិយាទ្រទ្រង់នូវរាងកាយជាទីបំផុត ។

នេះរាងកាយ ជាទីបំផុត នេះរាងកាយ ខាងក្រោយរបស់ព្រះ
អរហន្តទាំងនោះ ការអន្ទោលទៅកាន់ជាតិ និងមរណៈ និងការ
កើតក្នុងភពថ្មីរបស់ព្រះអរហន្តទាំងនោះ មិនមានទេ ។

ហេតុនោះ ព្រះអរហន្តខីណាស្រពទាំងឡាយ លោកហៅថា អ្នកមានធម៌ពិចារណាឃើញហើយ ហេតុនោះ លោកសួរថា បុគ្គលទាំងឡាយណា មានធម៌ពិចារណាឃើញហើយ ។

[ ៨៨ ] អធិប្បាយពាក្យថា បុគ្គលទាំងឡាយណា ជាសេក្ខៈ មានប្រមាណច្រើនក្នុងទីនេះ បុច្ឆាត្រង់ពាក្យថា សេក្ខបុគ្គលទាំងឡាយ ដែល

លោកហៅថា សេក្ខៈ ព្រោះហេតុអ្វី ។ ឈ្មោះថា សេក្ខៈ ព្រោះនៅសិក្សា ។ នៅសិក្សាអ្វី ។ នៅសិក្សាអធិសីលខ្លះ សិក្សាអធិចិត្តខ្លះ សិក្សាអធិប្បញ្ញាខ្លះ ។

អធិសីលសិក្ខា តើដូចម្តេច ។ ភិក្ខុក្នុងធម្មវិន័យនេះ ជាអ្នកមានសីល សង្រួមក្នុងបាតិមោក្ខសំវរសីល បរិបូណ៌ដោយអាចារៈ និងគោចារៈ ឃើញភ័យក្នុងទោសបន្តិចបន្តួច សមាទានសិក្សាក្នុងសិក្ខាបទទាំងឡាយ សីលក្ខន្ធតូចក្តី សីលក្ខន្ធធំក្តី សីលជាទីពឹង ជាគ្រឿងរាំង ជាការសង្រួម ជាការបិទ ជាប្រធាន ជាប្រមុខនៃការបាននូវកុសលធម៌ទាំងឡាយ នេះជាអធិ-សីលសិក្ខា ។

អធិចិត្តសិក្ខា តើដូចម្តេច ។ ភិក្ខុក្នុងធម្មវិន័យនេះ ស្ងាត់ចាកកាមទាំងឡាយ ស្ងាត់ចាកអកុសលធម៌ទាំងឡាយ ចូលបឋមជ្ឈាន ប្រកបដោយវិតក្ក វិចារៈ និងបីតិ សុខដែលកើតអំពីវិវេក ទុតិយជ្ឈាន តតិយជ្ឈាន ចតុត្ថជ្ឈាន នេះជាអធិចិត្តសិក្ខា ។

អធិប្បញ្ញាសិក្ខា តើដូចម្តេច ។ ភិក្ខុក្នុងធម្មវិន័យនេះ ជាអ្នកមានប្រាជ្ញា ប្រកបដោយប្រាជ្ញាទៅក្នុងសេចក្តីចម្រើន និងសេចក្តីវិនាស ជាប្រាជ្ញាដ៏ប្រសើរ ចាក់ធ្លុះ ដល់នូវសេចក្តីអស់ទុក្ខដោយប្រពៃ ភិក្ខុនោះ ដឹងច្បាស់តាមពិតថា នេះទុក្ខ ដឹងច្បាស់តាមពិតថា នេះហេតុឲ្យកើតទុក្ខ នេះសេចក្តីរលត់ទុក្ខ នេះបដិបទាដំណើរទៅកាន់ទីរលត់ទុក្ខ ដឹងច្បាស់តាមពិតថា នេះអាសវៈ នេះហេតុឲ្យកើតអាសវៈ នេះសេចក្តីរលត់អាសវៈ នេះបដិបទា

ដំណើរទៅកាន់ទីរលត់អាសវៈ នេះជាអធិប្បញ្ញាសិក្ខា ។

សេក្ខបុគ្គលទាំងឡាយ ពិចារណា សិក្សាសិក្ខាទាំង ៣ នេះ ដឹងសិក្សា តាំងចិត្តសិក្សា ចុះចិត្តស៊ប់ដោយសទ្ធាសិក្សា ផ្គងព្យាយាមសិក្សា តាំងសតិសិក្សា តាំងចិត្តដោយប្រពៃសិក្សា ដឹងច្បាស់ដោយបញ្ញាសិក្សា ដឹងប្រាកដនូវធម៌ដែលគួរដឹងប្រាកដសិក្សា កំណត់ដឹងធម៌ដែលគួរកំណត់ដឹងសិក្សា លះបង់ធម៌ដែលគួរលះបង់សិក្សា ចម្រើនធម៌ដែលគួរចម្រើនសិក្សា ធ្វើឲ្យជាក់ច្បាស់នូវធម៌ដែលគួរធ្វើឲ្យជាក់ច្បាស់សិក្សា ប្រព្រឹត្តដោយគោរព ប្រព្រឹត្តដោយប្រពៃ សមាទាន ប្រព្រឹត្ត ហេតុនោះ ទើបលោកហៅថា សេក្ខៈ ។ ពាក្យថា មានប្រមាណច្រើន សេក្ខបុគ្គលទាំងឡាយនុ៎ះ មានប្រមាណច្រើន គឺសោតាបន្នបុគ្គល ១ បុគ្គលប្រតិបត្តិ ( ដើម្បីសោតៈ ១ ) សកទាគាមិបុគ្គល ១ បុគ្គលប្រតិបត្តិ ( ដើម្បីសកទាគាមី ១ ) អនាគាមិបុគ្គល ១ បុគ្គលប្រតិបត្តិ ( ដើម្បីអនាគាមី ១ ) អរហន្ត ១ បុគ្គលប្រតិបត្តិ ( ដើម្បីអរហត្ត ១ ) ។ ពាក្យថា ក្នុងទីនេះ គឺក្នុងទិដ្ឋិនេះ ក្នុងការគួរនេះ ក្នុងសេចក្ដីគាប់ចិត្តនេះ ក្នុងសេចក្ដីប្រកាន់នេះ ក្នុងវិន័យនេះ ក្នុងធម៌នេះ ក្នុងធម្មវិន័យនេះ ក្នុងសាសនានេះ ក្នុងព្រហ្មចរិយៈនេះ ក្នុងសត្ថុសាសនានេះ ក្នុងអត្តភាពនេះ ក្នុងមនុស្សលោកនេះ ហេតុនោះ ( លោកសួរថា ) បុគ្គលទាំងឡាយណា ជាសេក្ខៈ មានប្រមាណច្រើន ក្នុងទីនេះ ។

[ ៨៩ ] ពាក្យថា បពិត្រព្រះអង្គនិទ្ទុក្ខ ព្រះអង្គជាបុគ្គលមានបញ្ញាចាស់ក្លា ខ្ញុំព្រះអង្គសួរហើយ សូមព្រះអង្គត្រាស់ សម្ដែងសេចក្ដីប្រព្រឹត្ត

របស់បុគ្គលទាំងឡាយនោះ ដល់ខ្ញុំព្រះអង្គ សេចក្ដីថា ព្រះអង្គជាបុគ្គលមានបញ្ញាចាស់ក្លា ជាបណ្ឌិតមានបញ្ញា មានបញ្ញាជាគ្រឿងត្រាស់ដឹង មានញាណ មានបញ្ញាជាគ្រឿងជ្រាបច្បាស់ មានបញ្ញាជាគ្រឿងទម្លាយកិលេស ( សូមទ្រង់ត្រាស់ប្រាប់ ) នូវសេចក្ដីប្រព្រឹត្ត ចរិយា ការប្រព្រឹត្ត មារយាទ គោចរ ឥរិយាបថ បដិបទានៃអរហន្ត និងសេក្ខបុគ្គលទាំងនោះដល់ខ្ញុំព្រះអង្គ ។ សួរហើយ គឺសួរ ដណ្ដឹង សូម អារាធនា ជ្រះថ្លាហើយ ។ ពាក្យថា សូមទ្រង់ត្រាស់ប្រាប់ គឺសូមទ្រង់ពោល ត្រាស់ បញ្ចេញ សម្ដែង បញ្ញត្ត តាំងទុក វែកញែក ចែក ធ្វើឲ្យងាយ ប្រកាស ។ ពាក្យថា បពិត្រព្រះអង្គនិរទុក្ខ នេះជាពាក្យជាទីស្រឡាញ់ ជាពាក្យគោរព ពាក្យថា បពិត្រព្រះអង្គនិរទុក្ខ នេះជាពាក្យពោលដោយគោរព កោតក្រែង ហេតុនោះ ( លោកសួរថា ) បពិត្រព្រះអង្គនិរទុក្ខ ព្រះអង្គជាបុគ្គលមានបញ្ញាចាស់ក្លា ខ្ញុំព្រះអង្គសួរហើយ សូមទ្រង់ត្រាស់ ប្រាប់ សេចក្ដីប្រព្រឹត្តនៃបុគ្គលទាំងឡាយនោះ ដល់ខ្ញុំព្រះអង្គ ។ ហេតុនោះ ព្រាហ្មណ៍នោះពោលថា

បុគ្គលទាំងឡាយណា មានធម៌ពិចារណាឃើញហើយ និងបុគ្គល
ទាំងឡាយណា ជាសេក្ខៈ មានប្រមាណច្រើន ក្នុងទីនេះ បពិត្រ
ព្រះអង្គនិរទុក្ខ ព្រះអង្គជាបុគ្គលមានបញ្ញាចាស់ក្លា ខ្ញុំព្រះអង្គសួរ
ហើយ សូមទ្រង់ត្រាស់ប្រាប់សេចក្ដីប្រព្រឹត្ត នៃបុគ្គលទាំងឡាយ
នោះ ដល់ខ្ញុំព្រះអង្គ ។

[ ៩០ ] ( ព្រះមានព្រះភាគត្រាស់ថា ) បុគ្គលមិនគប្បីប្រាថ្នា

ក្នុងកាមទាំងឡាយ មិនគប្បីធ្វើចិត្តឲ្យល្អក់ ជាបុគ្គលឈ្លាសវៃ
ក្នុងធម៌ទាំងពួង គប្បីប្រព្រឹត្តមានសតិ ជាភិក្ខុ ។

[ ៩១ ] អធិប្បាយពាក្យថា បុគ្គល មិនគប្បីប្រាថ្នាក្នុងកាមទាំងឡាយ ត្រង់ពាក្យថា កាម បើតាមឧទ្ទាន កាមមាន ២ គឺវត្ថុកាម ១ កិលេសកាម ១ ។

វត្ថុកាម តើដូចម្តេច ។ រូបជាទីគាប់ចិត្ត សំឡេងជាទីគាប់ចិត្ត ក្លិនជាទីគាប់ចិត្ត រសជាទីគាប់ ផ្សព្វជាទីគាប់ចិត្ត កម្រាល គ្រឿងស្លៀកពាក់ ខ្ញុំស្រី ខ្ញុំប្រុស ពពែ ចៀម មាន់ ជ្រូក ដំរី គោ សេះឈ្មោល-ញី ស្រែ ចម្ការ ប្រាក់ មាស ស្រុក និគម រាជធានី ដែន ជនបទ សេនានិករ ឃ្លាំង វត្ថុជាទីតាំងនៃសេចក្តីត្រេកអរណាមួយ ឈ្មោះថា វត្ថុកាម ។ មួយទៀត កាមជាអតីត កាមជាអនាគត កាមជាបច្ចុប្បន្ន កាមខាងក្នុង កាមខាងក្រៅ កាមទាំងខាងក្នុងទាំងខាងក្រៅ កាមថោកទាប កាមយ៉ាងកណ្តាល កាមខ្ពង់ខ្ពស់ កាមប្រព្រឹត្តទៅក្នុងអបាយ កាមជារបស់មនុស្ស កាមជាទិព្វ កាមដែលតាំងឡើងឯង កាមដែលនិម្មិត កាមដែលបុគ្គលដទៃនិម្មិត កាមដែលហួងហែង កាមដែលមិនហួងហែង កាមដែលរាប់អាន កាមដែលមិនរាប់អាន ធម៌ជាកាមាវចរទាំងអស់ក្តី ធម៌ជារូបាវចរទាំងអស់ក្តី ធម៌ជាអរូបាវចរទាំងអស់ក្តី ជាវត្ថុនៃតណ្ហា ជាអារម្មណ៍នៃតណ្ហា ឈ្មោះថា កាម ដោយសេចក្តីថា គប្បីប្រាថ្នា ដោយសេចក្តីថា គប្បីត្រេកអរ ដោយសេចក្តីថា គប្បីស្រវឹងទាំងនេះ លោកហៅថា វត្ថុកាម ។

កិលេសកាម តើដូចម្តេច ។ ចំណង់ ឈ្មោះថា កាម តម្រេក ឈ្មោះថា កាម ចំណង់ និងតម្រេក ឈ្មោះថា កាម តម្រិះ ឈ្មោះថា កាម តម្រេក ឈ្មោះថា កាម តម្រិះ និងតម្រេក ឈ្មោះថា កាម បានដល់ ចំណង់ គឺកាម ក្នុងកាមទាំងឡាយ តម្រេក គឺកាម សេចក្តីរីករាយ គឺកាម តណ្ហា គឺកាម សេចក្តីស្នេហា គឺកាម សេចក្តីស្រេកឃ្លាន គឺកាម សេចក្តីអន្ទះអន្ទែង គឺកាម សេចក្តីប្រាថ្នា គឺកាម សេចក្តីជ្រប់ គឺកាម កិរិយាលង់ចុះ គឺកាម អន្ទង់ គឺកាម គ្រឿងប្រកប គឺកាម សេចក្តីប្រកាន់ គឺកាម នីវរណៈ គឺកាមច្ឆន្ទៈ ។

ម្នាលកាម តថាគតឃើញទីតាំងរបស់អ្នកហើយ ម្នាលកាម អ្នក
កើតអំពីសេចក្តីត្រិះរិះ តថាគតនឹងលែងត្រិះរិះរកអ្នក ម្នាលកាម
អ្នកនឹងមិនមានដោយប្រការយ៉ាងនេះ ។

ពួកនេះ លោកហៅថា កិលេសកាម ។ តណ្ហា លោកហៅថា សេចក្តីប្រាថ្នា បានខាងតម្រេក តម្រេកខ្លាំង ។បេ។ អភិជ្ឈា លោភៈ អកុសលមូល ។ ពាក្យថា បុគ្គលមិនគប្បីប្រាថ្នាក្នុងកាមទាំងឡាយ បានសេចក្តីថា បុគ្គលមិនគប្បីប្រាថ្នា មិនគប្បីជាប់នៅក្នុងកិលេសកាម និងវត្ថុកាមទាំងឡាយ គឺជាអ្នកមិនប្រាថ្នា មិនលង់ចុះ មិនជ្រប់ មិនងប់ ប្រាសចាកប្រាថ្នា ចោលប្រាថ្នា ខ្ជាក់ប្រាថ្នា លែងប្រាថ្នា លះប្រាថ្នា លះចោលប្រាថ្នា ប្រាសចាករាគៈ ចោលរាគៈ ខ្ជាក់រាគៈ លែងរាគៈ លះរាគៈ រលាស់ចោលរាគៈ ចេញចាកតណ្ហា មានសភាពរលត់ មានត្រជាក់កើតហើយ មានកិរិយាបានចំពោះនូវសុខ គប្បី

នៅដោយខ្លួនដ៏ប្រសើរ ហេតុនោះ ទ្រង់ត្រាស់ថា បុគ្គលមិនគប្បីប្រាថ្នាក្នុងកាមទាំងឡាយ ។

[ ៩២ ] អធិប្បាយពាក្យថា មិនគប្បីធ្វើចិត្តឲ្យល្អក់ ត្រង់ពាក្យថា ចិត្ត បានដល់ ធម្មជាតសម្រាប់ត្រិះរិះ សម្រាប់ដឹង សម្រាប់ប្រាថ្នា ហទយៈ កវត្ត ចិត្ត មនាយតនៈ មនិន្ទ្រិយ វិញ្ញាណ វិញ្ញាណក្ខន្ធ មនោវិញ្ញាណធាតុ ។ ចិត្ត ជាធម្មជាតល្អក់ រឹងកវរ ញាប់ញ័រ ចង្អៀតចង្អល់ ឃ្លេងឃ្លោង ភ្ញាក់ផ្អើល មិនស្ងប់ ដោយកាយទុច្ចរិត វចីទុច្ចរិត មនោទុច្ចរិត រាគៈ ទោសៈ មោហៈ ក្រោធ ការចងក្រោធទុក ការលុបលាងគុណ ការវាយឫកស្មើ សេចក្តីឈ្នានីស សេចក្តីកំណាញ់ ការលាក់ពុត ការអួតអាង ការចចេស ការប្រណាំងវាសនា មានះ ការមើលងាយ សេចក្តីស្រវឹង និងសេចក្តីប្រហែសចិត្តនោះ ជាធម្មជាតល្អក់ រឹកវរ ញាប់ញ័រ ចង្អៀតចង្អល់ ឃ្លេងឃ្លោង ភ្ញាក់ផ្អើល មិនស្ងប់ ដោយកិលេសទាំងពួង ទុច្ចរិតទាំងពួង សេចក្តីក្រវល់ក្រវាយទាំងពួង សេចក្តីអន្ទះអន្ទែងទាំងពួង សេចក្តីក្តៅក្រហាយទាំងពួង អកុសលាភិសង្ខារទាំងពួង ។ ពាក្យថា មិនគប្បីធ្វើចិត្តឲ្យល្អក់ បានន័យថា មិនគប្បីមានចិត្តល្អក់ មិនរឹកវរ មិនញាប់ញ័រ មិនចង្អៀតចង្អល់ មិនឃ្លេងឃ្លោង មិនភ្ញាក់ផ្អើល ស្ងប់ គប្បីលះបង់ លះបង់ ផ្តាច់ បន្ទោបង់ ធ្វើឲ្យវិនាស ធ្វើមិនឲ្យមានបែបកាត នូវកិលេសទាំងឡាយ ជាគ្រឿងធ្វើឲ្យល្អក់ មួយទៀត ជាបុគ្គលថ្លាយ វៀរ វៀរស្រឡះ ចេញផុត ស្ងប់ រួចស្រឡះ ប្រកបប្រាសចាក កិលេសទាំងឡាយ ជាគ្រឿងធ្វើឲ្យល្អក់

គប្បីទៅដោយចិត្ត ប្រាសចាកសេចក្ដីសល់រៀល ( ហេតុនោះ ទ្រង់ត្រាស់ថា ) មិនគប្បីធ្វើចិត្តឲ្យល្អក់ ។

[ ៩៣ ] ពាក្យថា ឈ្លាសវៃក្នុងធម៌ទាំងពួង អធិប្បាយថា ឈ្លាសវៃក្នុងធម៌ទាំងពួងថា សង្ខារទាំងពួងមិនទៀង ឈ្លាសវៃក្នុងធម៌ទាំងពួងថា សង្ខារទាំងពួងជាទុក្ខ ឈ្លាសវៃក្នុងធម៌ទាំងពួងថា ធម៌ទាំងពួងជាអនត្តា ឈ្លាសវៃក្នុងធម៌ទាំងពួងថា សង្ខារទាំងឡាយ ( មាន ) ព្រោះអវិជ្ជាជាបច្ច័យ ។បេ។ ឈ្លាសវៃក្នុងធម៌ទាំងពួងថា ធម្មជាតណាមួយ មានសភាពកើតឡើង ធម្មជាតទាំងអស់នោះ មានសភាពរលត់ទៅជាធម្មតា បុគ្គលឈ្លាសវៃក្នុងធម៌ទាំងពួងយ៉ាងនេះឯង ។ មួយទៀត ឈ្លាសវៃក្នុងធម៌ទាំងពួង ថាមិនទៀង ថាជាទុក្ខ ជារោគ ជាបូស ជាសរ ជាអន្តរាយ ជាជំងឺ ជារបស់ដទៃ ជារបស់វិនាស ជាចង្រៃ ជាឧបទ្រព ជារបស់មិនគួរប្រាថ្នា ជាភ័យ ជាឧបសគ្គ ជារបស់ញាប់ញ័រ ជារបស់ពុករលួយ ជារបស់មិនស្ថិតស្ថេរ ជារបស់ពឹងមិនបាន ជារបស់ពួនមិនបាន ជារបស់មិនមែនជាទីរឭក ជារបស់សង្ឃឹមមិនបាន ជារបស់ឥតអំពើ ជារបស់ទទេ ជារបស់សូន្យ ជារបស់មិនមែនខ្លួន ជាទោស ជារបស់តែងប្រែប្រួល ជារបស់ឥតខ្លឹម ជាទីតាំងនៃទុក្ខ ជាអ្នកសម្លាប់ ជារបស់ប្រាសចាកសេចក្ដីចម្រើន ជារបស់ប្រកបដោយអាសវៈ ជារបស់ដែលបច្ច័យតាក់តែង ជានុយរបស់មារ ជារបស់មានជាតិជាធម្មតា មានជរាជាធម្មតា មានព្យាធិជាធម្មតា មានមរណៈជាធម្មតា មានសោក ខ្សឹកខ្សួល ទុក្ខ ទោមនស្ស សេចក្ដីតានតឹងជាធម្មតា មានគ្រឿងសៅហ្មងជាធម្មតា មាន

ការកើត មានការវិនាស មានសភាពមិនគួរជ្រះថ្លាជា ទោស មានការរើចេញមិនបាន បុគ្គលឈ្លាសវៃក្នុងធម៌ទាំងពួងយ៉ាងនេះឯង ។ មួយទៀត ឈ្លាសវៃក្នុងខន្ធ ឈ្លាសវៃក្នុងធាតុ ឈ្លាសវៃក្នុងអាយតនៈ ឈ្លាសវៃក្នុងបដិច្ចសមុប្បាទ ឈ្លាសវៃក្នុងសតិប្បដ្ឋាន ឈ្លាសវៃក្នុងសម្មប្បធាន ឈ្លាសវៃក្នុងឥទ្ធិបាទ ឈ្លាសវៃក្នុងឥន្ទ្រិយ ឈ្លាសវៃក្នុងពល ឈ្លាសវៃក្នុងពោជ្ឈង្គ ឈ្លាសវៃក្នុងមគ្គ ឈ្លាសវៃក្នុងផល ឈ្លាវៃក្នុងនិព្វាន បុគ្គលជាអ្នកឈ្លាសវៃក្នុងធម៌ទាំងពួងយ៉ាងនេះឯង ។ មួយទៀត អាយតនៈ ១២ គឺភ្នែក និងរូប ត្រចៀក និងសំឡេង ច្រមុះ និងក្លិន អណ្តាត និងរស កាយ និងផ្សព្វ ចិត្ត និងធម៌ ហៅថា ធម៌ទាំងពួង ។ តម្រេកក្នុងអាយតនៈ ជាខាងក្នុងខាងក្រៅទាំងឡាយ ជាកិលេសដែលបុគ្គលនោះលះបង់ មានឫសផ្តាច់ចោលហើយ ធ្វើមិនឲ្យមានទីតាំង ដូចជាដើមត្នោត មិនឲ្យមានបែបភាពមិនឲ្យមានសភាពកើតឡើងតទៅ ដោយហេតុណា បុគ្គលនោះ ឈ្មោះថា ឈ្លាសវៃក្នុងធម៌ទាំងពួង ដោយហេតុប៉ុណ្ណោះ ហេតុនោះ ( ទ្រង់ត្រាស់ថា ) ឈ្លាសវៃក្នុងធម៌ទាំងពួង ។

[ ៩៤ ] អធិប្បាយពាក្យថា គប្បីប្រព្រឹត្តមានសតិ ជាភិក្ខុ ត្រង់ពាក្យថា មានសតិ គឺឈ្មោះថា មានសតិ ដោយហេតុ ៤ គឺចម្រើនកាយានុបស្សនាសតិប្បដ្ឋាន ក្នុងកាយ ឈ្មោះថា មានសតិ ចម្រើនវេទនានុបស្សនាសតិប្បដ្ឋាន ក្នុងវេទនាទាំងឡាយ ឈ្មោះថា មានសតិ ចម្រើនចិត្តានុបស្សនាសតិប្បដ្ឋាន ក្នុងចិត្ត ឈ្មោះថា មានសតិចម្រើនធម្មានុបស្សនា-

សតិប្បដ្ឋាន ក្នុងធម៌ទាំងឡាយ ឈ្មោះថា មានសតិ ។ មានសតិដោយហេតុ ៤ ដទៃទៀត គឺឈ្មោះថាមានសតិ ព្រោះវៀរចាកការមិនមានសតិ មានសតិ ព្រោះបានធ្វើធម៌ដែលគប្បីធ្វើដោយសតិ មានសតិ ព្រោះកម្ចាត់បោលធម៌ដែលជាសត្រូវដល់សតិ មានសតិ ព្រោះមិនភ្លេចធម៌ ជានិមិត្តរបស់សតិ ។ មានសតិដោយហេតុ ៤ ដទៃទៀត គឺឈ្មោះថាមានសតិ ព្រោះជាអ្នកបរិបូណ៌ដោយសតិ មានសតិ ព្រោះថ្នឹកដោយសតិ មានសតិ ព្រោះស្ទាត់ជំនាញដោយសតិ មានសតិ ព្រោះមិនឃ្លាតបោលសតិ ។ មានសតិដោយហេតុ ៤ ដទៃទៀត គឺឈ្មោះថាមានសតិ ព្រោះជាអ្នកមានសតិ មានសតិ ព្រោះជាអ្នកស្ងប់ មានសតិ ព្រោះជាអ្នករម្ងាប់ មានសតិ ព្រោះបរិបូណ៌ដោយសប្បុរិសធម៌ ។ ឈ្មោះថា មានសតិ ព្រោះការរឭករឿយៗ នូវព្រះពុទ្ធ មានសតិ ព្រោះការរឭករឿយៗ នូវព្រះធម៌ មានសតិ ព្រោះការរឭករឿយៗ នូវព្រះសង្ឃ មានសតិ ព្រោះការរឭករឿយៗ នូវសីល មានសតិ ព្រោះការរឭករឿយៗ នូវចាគៈ មានសតិ ព្រោះការរឭករឿយៗ នូវធម៌ដែលធ្វើឲ្យជាទេវតា មានសតិ ព្រោះការរឭករឿយៗ នូវខ្យល់ដង្ហើមចេញ-ចូល មានសតិ ព្រោះការរឭករឿយៗ នូវសេចក្ដីស្ងប់ មានសតិ ព្រោះការរឭកប្រព្រឹត្តទៅក្នុងកាយ មានសតិ ព្រោះការរឭករឿយៗ នូវព្រះនិព្វាន ។ ការរឭក ។បេ។ ការរឭកត្រូវ ការរឭកជាអង្គនៃធម៌ជាគ្រឿងត្រាស់ដឹង ជាផ្លូវជាទីទៅនៃបុគ្គលម្នាក់ឯងណា នេះលោកហៅថា សតិ ។ ភិក្ខុប្រកបប្រកបព្រម ចូលទៅ ចូលទៅជិតព្រម ចូលទៅដល់ ចូលទៅដល់ព្រម ប្រកបព្រមហើយដោយសតិនោះ ភិក្ខុនោះ លោក

ហៅថា មានសតិ ។ ពាក្យថា ភិក្ខុ គឺថា ភិក្ខុ ព្រោះជាអ្នកទម្លាយធម៌ ៧ គឺទម្លាយសក្កាយទិដ្ឋិ ទម្លាយវិចិកិច្ឆា ទម្លាយសីលព្វតបរាមាស ទម្លាយរាគៈ ទម្លាយទោសៈ ទម្លាយមោហៈ ទម្លាយមានៈ ទម្លាយអកុសលធម៌លាមកទាំងឡាយ ប្រកបដោយគ្រឿងសៅហ្មងព្រម ដែលឲ្យបដិសន្ធិក្នុងភពថ្មី ប្រកបដោយសេចក្តីក្រវល់ក្រវាយ មានទុក្ខជាផល ជាបច្ច័យនៃជាតិ ជរា មរណៈក្នុងអនាគត ។

ព្រះមានព្រះភាគត្រាស់ថា ម្នាលសភិយៈ បុគ្គលដល់នូវបរិនិព្វាន
ដោយមគ្គដែលខ្លួនចម្រើនហើយ មានសេចក្តីសង្ស័យឆ្លងហើយ
លះបង់នូវសេចក្តីវិនាស និងសេចក្តីចម្រើន មានមគ្គអប់រំហើយ
មានភពថ្មីអស់ហើយ បុគ្គលនោះ ហៅថា ភិក្ខុ ។

ពាក្យថា គប្បីប្រព្រឹត្តមានសតិជាភិក្ខុ បានន័យថា គប្បីប្រព្រឹត្តមានស្មារតីជាភិក្ខុ គឺគប្បីមានសតិដើរទៅ មានសតិឈរ មានសតិអង្គុយ មានសតិសម្រេចនូវសេយ្យាសន៍ មានសតិឈានទៅ មានសតិឈានថយ មានសតិប្រឡេកមើល មានសតិក្រឡេកមើលផ្សេងៗ មានសតិបត់ចូល ( នូវអវយវៈ ) មានសតិលា ( នូវអវយវៈ ) មានសតិទ្រទ្រង់សង្ឃាដី បាត្រនិងចីវរ មានសតិត្រាច់ទៅ គប្បីមានសតិសម្រាន្តនៅ ប្រព្រឹត្តទៅ រក្សាយាត្រា ឲ្យយាត្រាទៅ ហេតុនោះ ទ្រង់ត្រាស់ថា គប្បីប្រព្រឹត្តមានសតិជាភិក្ខុ ។ ហេតុនោះ ព្រះមានព្រះភាគត្រាស់ថា

បុគ្គលមិនគប្បីប្រាថ្នាក្នុងកាមទាំងឡាយ មិនគប្បីធ្វើចិត្តឲ្យល្អក់ ជា

បុគ្គលឈ្លាសវៃក្នុងធម៌ទាំងពួង គប្បីប្រព្រឹត្តមានសតិជាភិក្ខុ ។

[ ៩៥ ] ព្រាហ្មណ៍ទាំងឡាយ មានអធ្យាស្រ័យតែមួយ មានបយោគៈតែមួយ មានសេចក្តីប៉ុនប៉ងតែមួយ មានធម៌ជាគ្រឿងអប់រំតែមួយ អប់រំហើយ ( ក្នុងពុទ្ធសាសនាជាអតីត ) ជាមួយគ្នា មួយអន្លើដោយព្រាហ្មណ៍ ( ឈ្មោះអជិតៈ ) នោះ ធម្មចក្ខុ គឺសោតាបត្តិមគ្គ មានធូលីទៅប្រាសហើយ មានមន្ទិលទៅប្រាសហើយ កើតឡើងដល់ពាន់នៃសត្វដ៏ច្រើនទាំងនោះថា ធម្មជាតណាមួយមានកិរិយាកើតឡើងជាធម្មតា ធម្មជាតទាំងអស់នោះ មានកិរិយារលត់ទៅវិញជាធម្មតា ឯ ( អជិតៈ ) ព្រាហ្មណ៍នោះ មានចិត្តផុតស្រឡះហើយចាកអាសវៈទាំងឡាយ ព្រោះមិនប្រកាន់មាំ ដំណាលគ្នាដោយការចប់គាថា ។ ( លំដាប់នោះ ) ស្បែកខ្លា ជដា សំពត់សម្បកឈើ ឈើច្រត់ កុណ្ឌីទឹក និងសក់ពុកមាត់ពុកចង្កា ក៏បាត់ទៅជាមួយនឹងពេលដែលដល់នូវភាពនៃខ្លួនជាព្រះអរហន្ត ។ ( អជិតព្រាហ្មណ៍ ) ជាឯហិភិក្ខុ ស្លៀកដណ្តប់នូវកណ្ឌៈ គឺសំពត់កាសាយៈ ទ្រទ្រង់នូវសង្ឃាដី បាត្រ និងចីវរ អង្គុយប្រណម្យអញ្ជលី មនស្ការព្រះមានព្រះភាគ ដោយប្រតិបត្តិសមគួរដល់ប្រយោជន៍ ( ហើយប្រកាសថា ) បពិត្រព្រះអង្គដ៏ចម្រើន ព្រះមានព្រះភាគជាសាស្តារបស់ខ្ញុំព្រះអង្គ ខ្ញុំព្រះអង្គជាសាវ័ក ។

**អជិតមាណវកបញ្ហានិទ្ទេស ចប់**

# អដ្ឋកថា
# សទ្ធម្មប្បជ្ជោតិកា
# ខុទ្ទកនិកាយ ចូឡនិទ្ទេស

## បារាយនវគ្គ

### អជិតមាណវកប្បញ្ហានិទ្ទេស

**នមោ តស្ស ភគវតោ អរហតោ សម្មាសម្ពុទ្ធស្ស**

*គប្បីជ្រាបវិនិច្ឆ័យក្នុងអជិតសុត្តនិទ្ទេសទី ១ នៃបារាយនវគ្គដូចតទៅ*

*[ ៥៣ ] អជិតមាណព បានទូលសួរបញ្ហាថា*

*លោកត្រូវអ្វីបិទបាំង លោកមិនភ្លឺស្វាងព្រោះហេតុអ្វី សូមព្រះអង្គត្រាស់ប្រាប់នូវធម៌អ្វី ថាជាគ្រឿងលាប លោកនោះ អ្វីជាភ័យធំរបស់លោកនោះ ។*

*ខ្ញុំនឹងវៀរបទដែលពោលហើយក្នុងបញ្ហាទី ១ ដែលអជិតមាណពទូលសួរក្នុងបញ្ហាដែលក្រៃលែងឡើង និងក្នុងនិទ្ទេសទាំងឡាយ និងបទដែលងាយនឹងពោលចំពោះការផ្សេងគ្នាប៉ុណ្ណោះ ។*

*ក្នុងបទទាំងនោះ បទថា* **និវុតោ** *បានដល់ បិទបាំង ។ បទថា* **កិស្សាភិលេបនំ ព្រូសិ** *បានដល់ អ្វីជាគ្រឿងលាបលោក សូមទ្រង់ត្រាស់ប្រាប់ ។*

[ ៥៤ ] បទថា **អាវុតោ** បានដល់ លាក់បាំង ។ បទថា **និវុតោ** បានដល់ បិទបាំង ។ បទថា **ឱផុដោ** បានដល់ បិទខាងក្រោម ។ បទថា **បិហិតោ** បានដល់ បិទខាងលើ ។ បទថា **បដិច្ឆន្នោ** បានដល់ បិទក្បិត ។ បទថា **បដិកុជ្ជិតោ** បានដល់ គ្រប គឺគ្របឲ្យមានមុខផ្កាប់ចុះក្រោម ។

[ ៥៦ ] បទថា **នប្បកាសតិ** បានដល់ មិនបង្ហាញខ្លួន ។ បទថា **នប្បភាសតិ** បានដល់ មិនធ្វើនូវពន្លឺដោយញាណ ។ បទថា **ន តបតិ** បានដល់ មិនធ្វើនូវពន្លឺដោយញាណ ។ បទថា **ន វិរោចតិ** បានដល់ មិនធ្វើនូវការរុងរឿងដោយញាណ ។ បទថា **ន សញ្ញាយតិ** បានដល់ បុគ្គលណាម្នាក់ដឹងមិនបាន ។ បទថា **ន បញ្ញាយតិ** បានដល់ មិនជាក់ច្បាស់ ។

[ ៥៧ ] បទថា **កេន លិត្តោ** បានដល់ អ្វីជាគ្រឿងលាប ។ បទថា **បលិត្តោ ឧបលិត្តោ** លោកបន្ថែមពាក្យឧបសគ្គ ។ គប្បីឃើញអត្ថយ៉ាងនេះថា ឈ្មោះថា **អាចិក្ខាហិ** ដោយអំណាចនិទ្ទេស គឺលើកមាតិកាឡើងសម្តែង ។ ឈ្មោះថា **ទេសេហិ** ដោយអំណាចបដិនិទ្ទេស គឺការសម្តែងសរុប ។ ឈ្មោះថា **បញ្ញបេហិ** ក៏ដោយប្រការនោះៗ ។ កាលឲ្យដឹងអត្ថ ឈ្មោះថា **បដ្ឋបេហិ** ។ កាលសម្តែងហេតុនៃអត្ថនោះ ឈ្មោះថា **វិវរាហិ** ។ កាលសម្តែងភាពជាព្យញ្ជនៈ ឈ្មោះថា **វិភជាហិ** ។ កាលនាំចេញបាននូវការគ្រប និងការជ្រាលជ្រៅហើយ ឲ្យកើតទីតាំងនៃញាណតាមផ្លូវត្រចៀក ឈ្មោះថា **ឧត្តានីករោហិ** ។ កាលកម្ចាត់ងងឹត គឺការមិនដឹងតាមផ្លូវត្រចៀកដោយអាការទាំងនេះ ឈ្មោះថា **បកាសេហិ** ។

[ ៥៩ ] *បទថា* **វេវិច្ឆា បមាទា នប្បកាសតិ** *សេចក្តីថា លោកមិនប្រាកដ ព្រោះសេចក្តីកំណាញ់ជាហេតុ និងព្រោះការប្រមាទជាហេតុ ។ ពិតហើយ សេចក្តីកំណាញ់ រមែងមិនឲ្យប្រាកដបានដោយគុណទាំងឡាយមានទានជាដើម សេចក្តីប្រមាទ រមែងមិនឲ្យបុគ្គលនោះប្រាកដបានដោយគុណទាំងឡាយ មានសីលជាដើម ។ បទថា* **ជប្បាភិលេបនំ** *សេចក្តីថា តណ្ហាជាគ្រឿងប្រឡាក់លោកនោះ ដូចអន្ទាក់ជាក់ស្វា ជាគ្រឿងប្រឡាក់ស្វា ដូច្នោះ ។ បទថា* **ទុក្ខំ** *បានដល់ ទុក្ខ មានជាតិជាដើម ។*

[ ៦៤ ] *បទថា* **យេសំ ធម្មានំ** *បានដល់ ធម៌ មានរូបជាដើមឯណា ។ បទថា* **អាទិតោ សមុទាគមនំ បញ្ញាយតិ** *សេចក្តីថា ការកើតឡើងរមែងប្រាកដតាំងអំពីខណៈដំបូង គឺឧប្បាទក្ខណៈ ។ បទថា* **អត្ថង្គមតោ និរោធោ** *សេចក្តីថា កាលបែកធ្លាយ ការរលត់ រមែងប្រាកដ ។ បទថា* **កម្មសន្និស្សិតោ វិបាកោ** *បានដល់ កុសលវិបាក និងអកុសលវិបាក លោកហៅថា វិបាកអាស្រ័យកម្ម ព្រោះប្រព្រឹត្តទៅដោយមិនលះកម្ម ។ បទថា* **វិបាកសន្និស្សិតំ កម្មំ** *សេចក្តីថា កុសលកម្ម និងអកុសលកម្ម លោកហៅថា កម្មអាស្រ័យវិបាក ព្រោះធ្វើឱកាសដល់វិបាកតាំងនៅ ។ បទថា* **នាម–សន្និស្សិតំ រូបំ** *សេចក្តីថា រូបក្នុងបញ្ចវោការភព លោកហៅថា រូបអាស្រ័យនាម ព្រោះប្រព្រឹត្តទៅដោយមិនលះនាម ។ បទថា* **រូបសន្និស្សិតំ នាមំ** *សេចក្តីថា នាមក្នុងបញ្ចវោការភព លោកហៅថា នាមអាស្រ័យរូប ព្រោះប្រព្រឹត្តទៅមិនលះរូប ។*

[ ៦៥ ] បទថា **សវន្តិ សព្វធិ សោតា** សេចក្តីថា ក្រសែទាំងឡាយមានតណ្ហាជាដើម រមែងហូរទៅក្នុងអាយតនៈ មានរូបជាដើមទាំងពួង ។ បទថា **កឹ និវារណំ** បានដល់ អ្វីជាគ្រឿងរាំង អ្វីជាគ្រឿងការពារក្រសែទាំងនោះ ។ បទថា **សំវរំ ព្រូហិ** សេចក្តីថា សូមទ្រង់ត្រាស់ប្រាប់ធម៌ ជាគ្រឿងរាំង ពោល គឺធម៌ជាគ្រឿងហាមក្រសែទាំងឡាយនោះ ។ អជិតមាណពទូលសួរដល់ការលះធម៌ ជាគ្រឿងរាំងក្រសែដ៏សេសដោយបទនេះ ។ បទថា **កេន សោតា បិធិយ្យរេ** សេចក្តីថា ក្រសែទាំងនោះ ដែលធម៌ណាមួយរាំង គឺកាត់ផ្តាច់ ។ អជិតមាណពទូលសួរដល់ការលះក្រសែដែលមិនមានចំណែកសេសសល់ ដោយបទនេះ ។

[ ៦៦ ] បទថា **សវន្តិ** បានដល់ រមែងកើតឡើង ។ បទថា **អាសវន្តិ** បានដល់ ហូរចុះទៅខាងក្រោម ។ បទថា **សន្ទន្តិ** បានដល់ ហូរទៅមិនមានទីបំផុត ។ បទថា **បវត្តន្តិ** បានដល់ ប្រព្រឹត្តទៅរឿយៗ ។

[ ៧១ ] បទថា **សតិ តេសំ និវារណំ** សេចក្តីថា សតិដែលប្រកបដោយវិបស្សនា ស្វែងរកគតិនៃកុសលធម៌ និងអកុសលធម៌ទាំងឡាយ ជាគ្រឿងរាំងក្រសែទាំងនោះ ។ បទថា **សោតានំ សំវរំ ព្រូមិ** អធិប្បាយថា តថាគតពោលសតិនោះឯង ថាជាធម៌គ្រឿងរាំងក្រសែទាំងឡាយ ។ បទថា **បញ្ញាយេតេ បិធិយ្យរេ** សេចក្តីថា ក្រសែទាំងនេះ ដែលមគ្គប្បញ្ញា ដែលសម្រេចដោយការចាក់ធ្លុះភាពជារបស់មិនទៀង ក្នុងរូបជាដើមរាំង ដោយប្រការទាំងពួង ។

[ ៧៥ ] បទថា **បច្ចិជ្ជន្តិ** បានដល់ កាត់ផ្តាច់ ។ បទថា **សមុទយញ្ច** បានដល់ បច្ច័យ ។ បទថា **អដ្ឋង្គមញ្ច** បានដល់ កាលកើតឡើងហើយ ក៏ដល់នូវការមិនមាន ឬកាលមិនទាន់កើតឡើង ក៏មិនកើត ។ បទថា **អស្សាទញ្ច** បានដល់ អានិសង្ស ។ បទថា **អាទីនវញ្ច** បានដល់ ទោស ។ បទថា **និស្សរណញ្ច** បានដល់ ឧបាយជាគ្រឿងចេញទៅ ។

[ ៧៦ ] គប្បីជ្រាបអត្ថនៃគាថាដែលជាបញ្ហាថា **បញ្ញា ចេវ** ដូច្នេះជាដើមតទៅ គប្បីជ្រាបសេចក្តីសង្ខេបយ៉ាងនេះថា បញ្ញា សតិ និងនាមរូបដ៏សេស តាមដែលទ្រង់ត្រាស់ហើយទាំងអស់នោះ រមែងរលត់ទៅក្នុងទីណា ។ សូមទ្រង់ត្រាស់ប្រាប់បញ្ហាដែលខ្ញុំព្រះអង្គទូលសួរចុះ ។

[ ៨០ ] បទថា **តត្ថេតំ និរុជ្ឈតិ** បានដល់ នាមរូបនោះ រមែងមិនមានក្នុងទីណា ។ បទថា **វូបសមតិ** បានដល់ រមែងរលត់ឥតសេសសល់ ។ បទថា **អត្ថំ គច្ឆតិ** សេចក្តីថា រមែងដល់នូវការមិនមាន ។ បទថា **បដិ-បស្សម្ភតិ** បានដល់ រមែងស្ងប់រម្ងាប់ ។

[ ៨១ ] ម្យ៉ាងទៀត គប្បីជ្រាបគាថាវិសជ្ជនាបញ្ហារបស់អជិតមាណពតទៅ ព្រោះបញ្ញា និងសតិ សង្គ្រោះចូលជានាមប៉ុណ្ណោះ ដូច្នោះ នឹងមិនពោលដល់បញ្ញា និងសតិដោយឡែក ។ សេចក្តីសង្ខេបក្នុងបទវិសជ្ជនានេះមានដូច្នេះថា ម្នាលអជិតៈ អ្នកបានសួរបញ្ហាណានឹងតថាគតថា នាមរូបនោះរមែងរលត់ក្នុងទីណា ព្រោះហេតុនោះ តថាគតនឹងប្រាប់បញ្ហានោះដល់អ្នកថា នាម និងរូបណា រលត់មិនមានចំណែកសល់ក្នុងទីណា នាម និងរូបនោះ ក៏

រលត់ក្នុងទីនោះ មួយអន្លើដោយការរលត់នៃវិញ្ញាណនោះៗឯង មិនមុន មិនក្រោយ គឺរមែងរលត់ព្រោះវិញ្ញាណរលត់នេះឯង ព្រោះវិញ្ញាណរលត់ខាងក្រោយយ៉ាងនេះ ទើបនាម និងរូបនោះរលត់ទៅដែរ លោកអធិប្បាយថា នាម និងរូបនោះ មិនហួសទៅឡើយ ។

[ ៨៥ ] បទថា **សោតាបត្តិមគ្គញ្ញាណេន អភិសង្ខារវិញ្ញាណស្ស និរោធេន** សេចក្តីថា ព្រោះចិត្តដែលសម្បយុត្តដោយកុសលចេតនា និងអកុសលចេតនារលត់ ដោយបញ្ញាដែលសម្បយុត្តដោយសោតាបត្តិមគ្គ ដោយអំណាចមិនសមគួរនឹងកើតឡើង ។ ក្នុងពាក្យនោះ ការរលត់មាន ២ យ៉ាង គឺការរលត់អនុបាទិន្នកៈ ១ ការរលត់ឧបាទិន្នកៈ ១ ។

ចិត្ត ៥ គឺចិត្តដែលសម្បយុត្តដោយទិដ្ឋិ ៤ ចិត្តដែលសហគតៈដោយវិចិកិច្ឆា ១ រមែងរលត់ទៅដោយសោតាបត្តិមគ្គ ។ ចិត្តទាំងនោះ ធ្វើឲ្យរូបកើតឡើង ។ រូបនោះជាអនុបាទិន្នករូបក្ខន្ធ ។ ចិត្តទាំងនោះ ជាវិញ្ញាណក្ខន្ធ ។ វេទនា សញ្ញា សង្ខារ ដែលសម្បយុត្តជាមួយវិញ្ញាណក្ខន្ធនោះ ជាអរូបក្ខន្ធ ៣ ក្នុងអនុបាទិន្នករូបក្ខន្ធនោះ បើព្រះសោតាបន្នមិនបានអប់រំសោតាបត្តិមគ្គហើយសោត ចិត្ត ៥ នោះ គប្បីដល់នូវការគ្របដណ្តប់ក្នុងអារម្មណ៍ ៦ តែសោតាបត្តិមគ្គហាមនូវការកើតនៃការគ្របដណ្តប់នៃចិត្តទាំងនោះ ធ្វើនូវការដកឡើងដោយអរិយមគ្គ ឲ្យមានភាវៈដែលមិនគួរកើតឡើង ទើបឈ្មោះថារលត់អនុបាទិន្នកៈ ។

ចិត្ត ៦ ដោយអំណាចនៃកាមរាគៈ និងព្យាបាទដែលគ្រោតគ្រាត គឺ

ចិត្ត ៤ ដែលមិនប្រកបដោយទិដ្ឋិ ចិត្ត ២ ដែលសហគតៈដោយទោមនស្ស រមែងរលត់ដោយសកទាគាមិមគ្គ ។

ចិត្ត ៦ នោះ ដោយអំណាចនៃកាមរាគៈ និងព្យាបាទ ដែលសហគតៈដោយចំណែកដែលល្អិត រមែងរលត់ដោយអនាគាមិមគ្គ ។

អកុសលចិត្ត ៥ គឺចិត្ត ៤ ដែលមិនប្រកបដោយទិដ្ឋិ និងចិត្ត ១ ដែលសហគតៈដោយឧទ្ធច្ចៈ រមែងរលត់ដោយអរហត្តមគ្គ ។

ក្នុងចិត្តទាំងនោះ បើព្រះអរិយៈទាំងនោះ មិនអប់រំមគ្គទាំងនោះហើយ សោត ចិត្តទាំងនោះ គប្បីដល់នូវការគ្របដណ្តប់ក្នុងអារម្មណ៍ ៦ ។ ម្យ៉ាងទៀត មគ្គនៃព្រះអរិយៈទាំងនោះ ហាមនូវការកើតនៃការគ្របដណ្តប់ ធ្វើនូវការដកដោយអរិយមគ្គ ឲ្យមានភាវៈដែលមិនគួរកើតឡើង ទើបឈ្មោះថា រលត់អនុបាទិន្នកៈ ។ គប្បីជ្រាបនូវការរលត់អនុបាទិន្នកៈយ៉ាងនេះ ។

បើព្រះសោតាបន្ន មិនបានជាអ្នកអប់រំដោយសោតាបត្តិមគ្គ ការប្រព្រឹត្តទៅនៃឧបាទិន្នកក្ខន្ធ គប្បីប្រព្រឹត្តទៅបានក្នុងសង្សារវដ្ត ដែលមានខាងដើមខាងចុង ដែលបុគ្គលតាមដឹងមិនបាន វៀរកព ៧ ព្រោះហេតុអ្វី ព្រោះមានហេតុនៃការប្រព្រឹត្តទៅរបស់ឧបាទិន្នកក្ខន្ធនោះ ។ មគ្គនោះ កាលកើតឡើង រមែងដកនូវកិលេស ៥ យ៉ាងនេះបាន គឺសំយោជនៈ ៣ ទិដ្ឋានុស័យ ១ វិចិកិច្ឆានុស័យ ១ ។ ការប្រព្រឹត្តទៅនៃឧបាទិន្នកៈរបស់ព្រះសោតាបន្ន នឹងប្រព្រឹត្តទៅក្នុងសង្សារវដ្តដែលមិនមានខាងដើម និងខាងចុង វៀរកព ៧ បាន អំពីណាក្នុងឥឡូវនេះ ។ សោតាបត្តិមគ្គ កាលធ្វើនូវឧបាទិន្នកៈដែលប្រព្រឹត្ត

ទៅ ឲ្យប្រព្រឹត្តទៅមិនបានយ៉ាងនេះ ទើបឈ្មោះថា រលត់ឧបាទិន្នកៈ ។

បើព្រះសកទាគាមីមិនបានជាបុគ្គលអប់រំសកទាគាមិមគ្គ ការប្រព្រឹត្តទៅនៃឧបាទិន្នកៈ គប្បីប្រព្រឹត្តទៅបានក្នុងភព ៥ វៀរភព ២ ។ សួរថា ព្រោះហេតុអ្វី ព្រោះមានហេតុនៃការប្រព្រឹត្តទៅនៃឧបាទិន្នកក្ខន្ធនោះ ។ មគ្គនោះកាលកើត រមែងដកនូវកិលេសទាំង ៤ នេះបាន គឺកាមរាគសំយោជនៈ បដិឃសំយោជនៈយ៉ាងគ្រោតគ្រាត កាមរាគានុស័យ បដិឃានុស័យយ៉ាងគ្រោតគ្រាត ។ ការប្រព្រឹត្តទៅនៃឧបាទិន្នកៈរបស់ព្រះសកទាគាមី នឹងប្រព្រឹត្តទៅ ៥ ភព វៀរ ២ ភព បានអំពីណា ក្នុងឥឡូវនេះ ។ សកទាគាមិមគ្គកាលធ្វើឧបាទិន្នកៈដែលប្រព្រឹត្តទៅ ឲ្យប្រព្រឹត្តទៅមិនបានយ៉ាងនេះ ឈ្មោះថា រម្ងត់ឧបាទិន្នកៈ ។

បើព្រះអនាគាមីមិនបានជាអ្នកអប់រំអនាគាមិមគ្គ ការប្រព្រឹត្តទៅរបស់ឧបាទិន្នកៈ គប្បីប្រព្រឹត្តទៅក្នុងភពទី ២ វៀរភព ១ ព្រោះហេតុអ្វី ព្រោះមានហេតុនៃការប្រព្រឹត្តទៅនៃឧបាទិន្នកក្ខន្ធនោះ ។ មគ្គនោះ កាលកើតឡើងរមែងដកនូវកិលេសទាំង ៤ យ៉ាងនេះបាន គឺកាមរាគសំយោជនៈ បដិឃ-សំយោជនៈ ដែលសហគតៈដោយចំណែកល្អិត កាមរាគានុស័យ បដិឃា-នុស័យ ដែលសហគតៈដោយចំណែកល្អិត ការប្រព្រឹត្តទៅនៃឧបាទិន្នកៈរបស់ព្រះអនាគាមី នឹងប្រព្រឹត្តទៅក្នុងភពទី ២ វៀរភព ១ បានអំពីណាក្នុងឥឡូវនេះ អនាគាមិមគ្គ កាលធ្វើឧបាទិន្នកៈដែលប្រព្រឹត្តទៅ ឲ្យប្រព្រឹត្តទៅមិនបានយ៉ាងនេះ ឈ្មោះថា រម្ងត់ឧបាទិន្នកៈ ។

*បើព្រះអរហន្តមិនបានអប់រំអរហត្តមគ្គ ការប្រព្រឹត្តទៅនៃឧបាទិន្នកៈ គប្បីប្រព្រឹត្តទៅក្នុងរូបភព និងអរូបភពបាន ព្រោះហេតុអ្វី ព្រោះមានហេតុនៃការប្រព្រឹត្តទៅរបស់ឧបាទិន្នកក្ខន្ធនោះ ។ មគ្គនោះ កាលកើត រមែងដកនូវកិលេសទាំង ៨ នេះបាន គឺរូបរាគៈ អរូបរាគៈ មានះ ឧទ្ធច្ចៈ អវិជ្ជា មានានុស័យ ភវរាគានុស័យ អវិជ្ជានុស័យ ការប្រព្រឹត្តទៅនៃឧបាទិន្នកៈរបស់ព្រះខីណាស្រព នឹងប្រព្រឹត្តទៅក្នុងភពថ្មីបានអំពីណា ក្នុងឥឡូវនេះ ។ អរហត្តមគ្គ កាលធ្វើឧបាទិន្នកៈដែលប្រព្រឹត្តទៅ ឲ្យប្រព្រឹត្តទៅមិនបានយ៉ាងនេះ ឈ្មោះថា រម្ងាត់ឧបាទិន្នកៈ ។*

*ម្យ៉ាងទៀត អាចារ្យទាំងឡាយពោលថា បណ្ដាមគ្គទាំងនេះ សោតាបត្តិមគ្គ រមែងរម្ងាត់អបាយភព សកទាគាមិមគ្គ រមែងរម្ងាត់បានចំណែកមួយនៃកាមសុគតិភព អនាគាមិមគ្គ រមែងរម្ងាត់កាមភពបាន ។ អរហត្តមគ្គ រមែងរម្ងាត់រូបភព អរូបភព ក្នុងភពទាំងពួងបាន ។ គប្បីជ្រាបការរម្ងាត់ឧបាទិន្នកៈ ដោយប្រការដូច្នេះ ។*

*បណ្ដាបទទាំងនោះ ព្រះមានព្រះភាគ ទ្រង់សម្ដែងការរលត់អនុបាទិន្នកៈដោយពាក្យនេះថា* **អភិសង្ខារវិញ្ញាណស្ស និរោធេន** *ទ្រង់សម្ដែងការរលត់ឧបាទិន្នកៈដោយបទនេះថា* **យេ ឧប្បជ្ជេយ្យុំ នាមញ្ច រូបញ្ច ឯត្ថេតេ និរុជ្ឈន្តិ ។**

*ក្នុងបទទាំងនោះ បទថា* **សត្ត ភវេ ឋបេត្វា** *សេចក្ដីថា វៀរ ៧ ភពរបស់សត្វដែលអន្ទោលទៅកាន់កាមភពចាកកាមភព ។ បទថា* **អនមតគ្គេ សំសារេ** *បានដល់ ក្នុងសង្សារវដ្ដដែលពណ៌នាយ៉ាងនេះថា*

លំដាប់ខន្ធ ធាតុ អាយតនៈទាំងឡាយ ដែលប្រព្រឹត្តទៅមិនដាច់ លោកហៅថា សង្សារ ។

បទថា **នាមញ្ច រូបញ្ច** បានដល់ ធម៌ទាំងនេះ គឺនាមដែលបានដល់ ខន្ធ ៤ មានការបង្អោនទៅជាលក្ខណៈ និងរូប ដែលបានដល់ ភូតរូប និង ឧបាទាយរូប មានការបែកធ្លាយទៅជាលក្ខណៈ គប្បីកើតឡើង ។ បទថា **ឯត្ថេតេ និរុជ្ឈន្តិ** សេចក្តីថា ធម៌ដែលបានដល់ នាម និងរូបទាំងនេះ រមែង ដល់នូវការរលត់ទៅក្នុងសោតាបត្តិមគ្គនេះ ដោយអំណាចមិនគួរកើតឡើង ។

គប្បីជ្រាបវិគ្គហៈក្នុងបទថា **សកទាគាមិមគ្គញ្ញាណេន** ដូចតទៅនេះ ឈ្មោះថា **សកទាគាមី** ព្រោះមកកាន់លោកនេះដោយអំណាចបដិសន្ធិម្តង ប៉ុណ្ណោះ ។ មគ្គនៃសកទាគាមីនោះ ឈ្មោះថា **សកទាគាមិមគ្គ** ។ ដោយ ញាណដែលប្រកបដោយមគ្គនោះ ។ បទថា **ទ្វេ ភវេ ឋបេត្វា** សេចក្តីថា វៀរ ២ ភព ដែលជាកាមធាតុ ដោយអំណាចបដិសន្ធិ ។ បទថា **បញ្ចសុ ភវេសុ** បានដល់ កើតក្នុង ៥ ភព ដ៏សេសអំពី ២ ភពនោះ ។ បទថា **ឯត្ថេតេ និរុជ្ឈន្តិ** សេចក្តីថា ធម៌ទាំងនោះ រមែងរលត់ទៅដោយន័យដែល ពោលហើយ ក្នុងសកទាគាមិមគ្គនេះ ។ បទថា **ឯកំ ភវំ ឋបេត្វា** បានដល់ វៀរ ១ ភព ក្នុងរូបធាតុ ឬអរូបធាតុ ដោយអំណាចនៃភាពឧក្រិដ្ឋ ។ បទថា **រូបធាតុយា វា អរូបធាតុយា វា** បានដល់ រូបធាតុ និងអរូបធាតុ ក្នុង ទីភពទី ២ ។ ក្នុងបទថា **នាមញ្ច រូបញ្ច** នេះ ក្នុងរូបភព បានដល់ នាម និងរូប ក្នុងអរូបភព បានដល់ នាមប៉ុណ្ណោះ ។ បទថា **ឯត្ថេតេ និរុជ្ឈន្តិ**

បានដល់ ធម៌ដែលជានាម និងរូបទាំងនេះ រមែងរលត់ទៅ ដោយន័យដូចពោលហើយ ក្នុងអនាគាមិមគ្គនេះ ។ បទថា **អរហតោ** បានដល់ ព្រះខីណាស្រព បានឈ្មោះថា **អរហន្ត** ព្រោះជាអ្នកឆ្ងាយចាកកិលេសទាំងឡាយ ។ បទថា **អនុបាទិសេសាយ និព្វានធាតុយា** បានដល់ និព្វានធាតុមាន ២ យ៉ាង គឺសឧបាទិសេសនិព្វានធាតុ ១ អនុបាទិសេសនិព្វានធាតុ ១ ។ ក្នុងបទនោះ ឈ្មោះថា **ឧបាទិ** ព្រោះប្រកាន់មាំ គឺប្រកាន់មាំថា អញ របស់អញ ។ បទនេះ ជាឈ្មោះនៃខន្ធ ៥ ឧបាទិដ៏សេសឈ្មោះថា **ឧបាទិសេស** ។ ឈ្មោះថា **សឧបាទិសេស** ព្រោះប្រព្រឹត្តទៅដោយបញ្ចក្ខន្ធដែលនៅសេសសល់ ។ ឈ្មោះថា **អនុបាទិសេស** ព្រោះមិនមានបញ្ចក្ខន្ធនៅសេសសល់ ។ និព្វានធាតុនេះ ជាអនុបាទិសេស ។ ដោយនិព្វានធាតុដែលជាអនុបាទិសេសនោះ ។ បទថា **បរិនិព្វាយន្តស្ស** បានដល់ រលត់ គឺប្រព្រឹត្តទៅមិនបាន ដូចភ្លើងអស់កំញមហើយ ដូច្នោះ ។ បទថា **ចរិមវិញ្ញាណស្ស និរោធេន** បានដល់ ព្រោះរម្ងត់ខ្យល់ដង្ហើមចូលចេញក្នុងវិញ្ញាណចុងក្រោយនេះ ។

ចរិមៈមាន ៣ គឺភវចរិមៈ ១ ឈានចរិមៈ ១ ចុតិចរិមៈ ១ ក្នុងបណ្ដាភពទាំងឡាយ ខ្យល់ដង្ហើមចូល-ចេញ ប្រព្រឹត្តទៅក្នុងកាមភព មិនប្រព្រឹត្តទៅក្នុងរូបភព និងអរូបភព ព្រោះហេតុនោះ ទើបចរិមៈនោះ ឈ្មោះថា **ភវចរិម** ។ ក្នុងឈានទាំងឡាយ ខ្យល់ដង្ហើមចូល-ចេញ រមែងប្រព្រឹត្តទៅក្នុងឈាន ៣ ខាងដើម មិនប្រព្រឹត្តទៅក្នុងឈានទី ៤ ព្រោះហេតុនោះ ទើប

ចរិមៈនោះ ឈ្មោះថា **ឈានចរិមៈ** ។ ម្យ៉ាងទៀត ធម៌ពួកណាកើតព្រមនឹងចិត្តទី ១៦ ខាងមុខចុតិចិត្ត ធម៌ទាំងនោះ តែងរលត់ជំណាលគ្នានឹងចុតិចិត្ត ចរិមៈនេះ ឈ្មោះថា **ចុតិចរិម** ។ ចុតិចរិមៈនេះ លោកបំណងយកក្នុងពាក្យថា **ចរិម** ក្នុងទីនេះ ។ ព្រះពុទ្ធ ព្រះបច្ចេកពុទ្ធ ព្រះអរិយ-សាវកទាំងឡាយ ដោយហោចសូម្បីតែស្រមោចអាត់ និងស្រមោចភ្លើង រមែងធ្វើកាលកិរិយាដោយភវង្គចិត្តនោះឯង ដែលជាអព្យាកតៈ ជាទុក្ខសច្ចដូចគ្នាទាំងអស់ ។

ព្រោះហេតុនោះ ពាក្យថា **ចរិមវិញ្ញាណស្ស និរោធេន** ព្រោះរលត់ទើបសំដៅដល់ព្រោះរលត់ចុតិចិត្ត ។

គប្បីកំណត់យកអរូបក្ខន្ធ ៤ ដោយបទទាំងនេះ គឺ **បញ្ញា ច សតិ ច នាមញ្ច** គប្បីកំណត់យកមហាភូតរូប ៤ និងឧបាទាយរូប ២៤ ដោយបទនេះថា **រូបញ្ច** ដូច្នេះ ។ ឥឡូវនេះ ព្រះមានព្រះភាគ កាលទ្រង់សម្តែងដល់ឧបាយរម្ងត់នាមរូបនោះ ទើបត្រាស់ថា **វិញ្ញាណស្ស និរោធេន ឯត្ថេតំ ឧបរុជ្ឈតិ** ។ បណ្តាបទទាំងនោះ បទថា **វិញ្ញាណំ** បានដល់ ចរិមវិញ្ញាណខ្លះ អភិសង្ខារវិញ្ញាណខ្លះ ។ ព្រោះលះ និងរលត់អភិសង្ខារវិញ្ញាណ ទើបនាម និងរូបនេះបែក គឺរលត់ក្នុងទីនេះ រមែងដល់នូវការមិនមានបញ្ញត្តិ ដូចអណ្តាតប្រទីប ដូច្នោះ ។ ព្រោះចរិមវិញ្ញាណមិនជាបច្ច័យឲ្យកើត ទើបនាមនិងរូបរលត់ទៅដោយអំណាចការមិនកើតឡើង ដោយការរលត់ គឺការមិនកើតនៃចរិមវិញ្ញាណ ។

ដោយហេតុមានប្រមាណប៉ុណ្ណេះ ឈ្មោះថា ព្រះមានព្រះភាគ ទ្រង់ប្រកាសទុក្ខសច្ច ដោយបទនេះថា **ឧក្ខមស្ស មហព្ភយំ**(១) ទ្រង់ប្រកាសសមុទយសច្ច ដោយបទនេះថា **យានិ សោតានិ** ទ្រង់ប្រកាសមគ្គសច្ច ដោយបទនេះថា **បញ្ញាយេតេ បិធិយ្យរេ**(២) ទ្រង់ប្រកាសនិរោធសច្ច ដោយបទនេះថា **អសេសំ ឧបរុជ្ឈតិ**(៣) ។ អជិតមាណពស្តាប់បានស្តាប់សច្ចៈ ៤ ប្រការយ៉ាងនេះ ដោយប្រការដូច្នេះហើយ ក៏មិនទាន់សម្រេចអរិយភូមិ កាលទូលសួរដល់បដិបទារបស់ព្រះសេក្ខៈ និងព្រះអសេក្ខៈទៀត ទើបពោលថា **យេ ច សង្ខាតធម្មាសេ** ដូច្នេះ ។

[ ៨៦ ] ក្នុងបទទាំងនោះ បទថា **សង្ខាតធម្មា** បានដល់ ធម៌ដែលពិចារណាហើយ ដោយភាពជារបស់មិនទៀងជាដើម ។ បទនេះ ជាឈ្មោះរបស់ព្រះអរហន្តទាំងឡាយ ។ បទថា **សេក្ខា** បានដល់ អរិយបុគ្គលដ៏សេស ដែលត្រូវសិក្សាសីលជាដើម ។ បទថា **បុថូ** បានដល់ អរិយជន ៧ ប្រភេទ ។ បទថា **តេសំ មេ និបកោ ឥរិយំ បុដ្ឋោ បព្រូហិ** សេចក្តីថា ខ្ញុំព្រះអង្គទូលសួរហើយ សូមទ្រង់ដែលជាបណ្ឌិតមានបញ្ញា ប្រាប់ដល់បដិបទារបស់ព្រះសេក្ខៈ និងអសេក្ខៈទាំងនោះ ដល់ខ្ញុំព្រះអង្គចុះ ។

[ ៨៧ ] បទថា **តេសំ ខន្ធា សង្ខាតា** សេចក្តីថា ខន្ធ ៥ ដែលព្រះខីណាស្រពទាំងនោះ ធ្វើឲ្យអស់ទៅហើយ ដោយធ្វើមិនឲ្យមានបដិសន្ធិ

---

១- បទនេះ មានក្នុងលេខឃ្នាប ៦៤ ។ ២- បទនេះ មានក្នុងលេខឃ្នាប ៧១ ។ ៣- បទនេះ មានក្នុងលេខឃ្នាប ៨១ ។

ឬសល់ត្រឹមតែសង្ខេប ។ សូម្បីក្នុងធាតុទាំងឡាយជាដើម ក៏មានន័យនេះដូចគ្នា ។

[ ៨៩ ] បទថា **ឥរិយំ** បានដល់ ការប្រកប ។ បទថា **ចរិយំ** បានដល់ ការធ្វើ ។ បទថា **វុត្តី** បានដល់ ការចូលដល់ ។ បទថា **អាចារំ** បានដល់ ការប្រព្រឹត្ត ។ បទថា **គោចរំ** បានដល់ បច្ច័យ ។ បទថា **វិហារំ** បានដល់ ការប្រព្រឹត្តទៅនៃឥរិយាបថ ។ បទថា **បដិបទំ** បានដល់ វិបស្សនា ។

[ ៩០ ] ព្រោះព្រះសេក្ខៈត្រូវលះកិលេស មានកាមច្ឆន្ទនីវរណៈជាដើម ព្រោះហេតុនោះ ទើបព្រះមានព្រះភាគទ្រង់សម្តែងសេក្ខបដិបទា ដល់អជិតមាណពនោះ ដោយកន្លះគាថា មានបទថា **កាមេសុ** ដូច្នេះជាដើម ។

គាថានោះ មានសេចក្តីដូច្នេះថា ភិក្ខុមិនគប្បីជាប់ចិត្តក្នុងវត្ថុកាមទាំងឡាយ ដោយកិលេសកាម លះធម៌ដែលធ្វើចិត្តឲ្យល្អក់កករ មានកាយទុច្ចរិតជាដើម គប្បីមានចិត្តមិនល្អក់ ។

ម្យ៉ាងទៀត ព្រោះព្រះអសេក្ខៈ ឈ្មោះថា ជាអ្នកឈ្លាសក្នុងធម៌ទាំងពួង ព្រោះជាអ្នកពិចារណាដោយប្រពៃ ដល់សង្ខារទាំងពួងជាដើម ដោយភាពជារបស់មិនទៀងជាដើម ជាអ្នកមានសតិ ដោយចម្រើនកាយានុបស្សនាសតិប្បដ្ឋានជាដើម ជាអ្នកដល់នូវភាពជាភិក្ខុ ព្រោះទម្លាយសក្កាយទិដ្ឋិជាដើម រមែងវៀរដោយជុំវិញក្នុងឥរិយាបថទាំងពួង ព្រោះដូច្នោះ ទើបព្រះមានព្រះភាគ ទ្រង់សម្តែងបដិបទារបស់ព្រះអសេក្ខៈ ដោយកន្លះគាថាថា

**កុសលោ** ដូច្នេះជាដើម ។

[ ៩១ ] បទថា **នាភិគិជ្ឈេយ្យ** បានដល់ មិនជល់នូវតម្រេក ។ បទថា **ន បលិគិជ្ឈេយ្យ** បានដល់ មិនដល់នូវសេចក្តីលោភៈ ។ បទថា **ន បលិពុជ្ឈេយ្យ** បានដល់ មិនជាប់ស្អិតដោយអំណាចលោភៈ ។

[ ៩២ ] បទថា **អាវិលករេ កិលេសេ បជហេយ្យ** បានដល់ គប្បីលះកិលេស គឺការក្តៅក្រហាយដែលធ្វើចិត្តឲ្យល្អក់ ។

[ ៩៣ ] បទថា **សព្វេ ធម្មា អនត្តា** លោកពោលដល់ការធ្វើនិព្វានទុកខាងក្នុង ។ បទថា **យំ កិញ្ចិ សមុទយធម្មំ** បានដល់ វត្ថុណាមួយ មានបច្ច័យជាសភាវៈ ។

[ ៩៥ ] បទថា **សហ គាថា បរិយោសានា** បានដល់ ដំណាលគ្នានឹងចប់គាថានោះឯង ។ បទថា **យេតេ ព្រាហ្មណេន សទ្ធិំ ឯកច្ឆន្ទា** បានដល់ មានកល្យាណឆន្ទៈ មានអធ្យាស្រ័យរួមគ្នាជាមួយនឹងអជិតមាណព ។ បទថា **ឯកប្បយោគា** បានដល់ មានកាយប្រយោគ វចីបយោគ មនោបយោគរួមគ្នា ។ បទថា **ឯកាធិប្បាយា** សេចក្តីថា ឈ្មោះថា **ឯកាធិប្បាយា** ព្រោះមានបំណង គឺឆន្ទៈតែមួយដូចគ្នា អធិប្បាយថា មានការពេញចិត្តតែមួយដូចគ្នា ។ បទថា **ឯកវាសនវាសិតា** បានដល់ មានការអប់រំរួមគ្នាមកក្នុងសាសនារបស់ព្រះពុទ្ធក្នុងអតីត ។ បទថា **អនេកបាណសហស្សានំ** បានដល់ ពួកសត្វ គឺទេវតា និងមនុស្សច្រើនពាន់ ។ បទថា **វិរជំ វីតមលំ** បានដល់ ប្រាសចាកធូលី មានរាគៈជាដើម និងប្រាសចាក

មន្ទិល មានរាគៈជាដើម ។ សោតាបត្តិមគ្គ លោកបំណងយកក្នុងបទថា **ធម្មចក្ខុំ** នេះ ក្នុងទីដទៃ បំណងយកមគ្គខាងក្រោម ៣ លោកពោលថា **យំ កិញ្ចិ សមុទយធម្មំ សព្វន្តំ និរោធធម្មំ** ដើម្បីសម្ដែងហេតុនៃការកើតឡើងនៃមគ្គនោះ ។ ព្រោះសោតាបត្តិមគ្គនោះ ធ្វើនិរោធសច្ចឲ្យជាអារម្មណ៍ ហើយចាក់ធ្លុះសង្ខតធម៌ទាំងពួងយ៉ាងនេះ ដោយអំណាចនៃកិច្ច រមែងកើតឡើង ។ បទថា **តស្ស ច ព្រាហ្មណស្ស អនុបាទាយ អាសវេហិ ចិត្តំ វិមុច្ចិ** សេចក្ដីថា ចិត្តរបស់អជិតព្រាហ្មណ៍នោះ និងអន្តេវាសិក ១០០០ កំពុងផុតចាកកាមាសវៈជាដើមក្នុងខណៈមគ្គ ផុតហើយក្នុងខណៈផល ព្រោះមិនប្រកាន់មាំដោយតណ្ហាជាដើម ។ បទថា **សហ អរហត្តប្បត្តា** សេចក្ដីថា ស្បែកខ្លា ជដា សំពត់ស្បូវក្លាំង ឈើច្រត់ ល័ក្ខចាន់ជាដើមរបស់អជិតៈមួយអន្លើដោយអន្តេវាសិក ក៏បាត់ទៅហើយ មួយអន្លើដោយការសម្រេចអរហត្តនោះឯង ជនទាំងនោះ ទ្រទ្រង់នូវបាត្រ និងចីវរដែលសម្រេចដោយឫទ្ធិ មានសក់ ២ ធ្នាប់ ជាឯហិភិក្ខុ អង្គុយនមស្ការព្រះមានព្រះភាគ ។ តែក្នុងបាលីប្រាកដចំពោះព្រះអជិតត្ថេរប៉ុណ្ណោះ ។ ក្នុងបទទាំងនោះ បទថា **អត្តប្បដិបត្តិយា** សេចក្ដីថា ព្រោះបានការបដិបត្តិដែលជាសច្ចាភិសេកដោយខ្លួនឯង អធិប្បាយថា ព្រោះបានព្រះនិព្វាន ។ បទដ៏សេស ក្នុងបទទាំងពួងជាក់ច្បាស់ហើយ ។ ព្រះមានព្រះភាគទ្រង់បញ្ចប់ទេសនាដោយធម៌ដែលជាកំពូលគឺអរហត្ត ដោយប្រការដូច្នេះឯង ៗ៚

**អដ្ឋកថា អជិតមាណវសុត្តនិទ្ទេសទី ១ ចប់**

# សុត្តន្តបិដក

## តិស្សមេត្តេយ្យមាណវកបញ្ហានិទ្ទេស

[ ៩៦ ] ( តិស្សមេត្តេយ្យមានអាយុទូលសួរដូច្នេះថា ) បុគ្គលណា ក្នុងលោកនេះ ជាអ្នកត្រេកអរពេញលេញ បុគ្គលណា មិនមានសេចក្តីញាប់ញ័រ បុគ្គលណា ដឹងច្បាស់នូវទីបំផុតទាំងពីរ និងកណ្តាល ដោយប្រាជ្ញា ហើយព្រះអង្គទ្រង់ហៅបុគ្គលណាថា មហាបុរស បុគ្គលណា បានកន្លងនូវតណ្ហា ជាគ្រឿងចាក់ស្រែះ ក្នុងលោកនេះ ។

[ ៩៧ ] ពាក្យថា បុគ្គលណា ក្នុងលោកនេះ ជាអ្នកត្រេកអរពេញលេញ គឺជាអ្នកត្រេកអរពេញហើយ មានចិត្តរីករាយ មានសេចក្តីត្រិះរិះពេញលេញ ហេតុនោះ ( លោកសួរថា ) បុគ្គលណា ក្នុងលោកនេះ ជាអ្នកត្រេកអរពេញលេញ ។ ពាក្យថា ដូច្នេះ ក្នុងបទថា តិស្សមេត្តេយ្យមានអាយុ ( ទូលសួរ ) ដូច្នេះ គឺជាបទតភ្ជាប់ ជាពាក្យភ្ជាប់បទ បំពេញបទ ប្រជុំអក្ខរៈ សម្រួលព្យញ្ជនៈ ពាក្យថា ដូច្នេះនុ៎ះ ជាលំដាប់បទ ។ ពាក្យថា មានអាយុ គឺពាក្យជាទីស្រឡាញ់ ជាពាក្យគោរព ពាក្យថា មានអាយុនុ៎ះ ជាពាក្យពោលដោយគោរព កោតក្រែង ។ ពាក្យថា តិស្សៈ គឺជាឈ្មោះ ជាពាក្យសម្រាប់ហៅ សម្រាប់សម្គាល់ ជាបញ្ញត្តិ ជាវោហារ ជានាម ជានាមកម្ម ជានាមប្បញ្ញត្តិ ជាសម្តី ជាគ្រឿងបញ្ជាក់ ជាគ្រឿងប្រកាសនៃព្រាហ្មណ៍នោះ ។ ពាក្យថា មេត្តេយ្យៈ គឺជាគោត្រ ជាពាក្យសម្រាប់ហៅ ជាពាក្យសម្រាប់សម្គាល់ ជាបញ្ញត្តិ ជាវោហារនៃព្រាហ្មណ៍នោះ ហេតុនោះ

( លោកពោលថា ) តិស្សមេត្តេយ្យមានអាយុ ( ទូលសួរ ) ដូច្នេះ ។

[ ៩៨ ] ពាក្យថា បុគ្គលណា មិនមានសេចក្តីញាប់ញ័រ សេចក្តីថា ការញាប់ញ័រដោយតណ្ហា ញាប់ញ័រដោយទិដ្ឋិ ញាប់ញ័រដោយមានះ ញាប់ញ័រដោយកិលេស ញាប់ញ័រដោយកម្ម សេចក្តីញាប់ញ័រទាំងនេះ របស់បុគ្គលណា គ្មាន មិនមាន មិនមានព្រម មិនបាន គឺបុគ្គលណា លះបង់ ផ្តាច់បង់ ចូលទៅរម្ងាប់ រម្ងាប់ចំពោះ ធ្វើមិនគួរឲ្យកើតឡើងបាន ដុតដោយភ្លើង គឺញាណហើយ ហេតុនោះ ( លោកសួរថា ) បុគ្គលណា មិនមានសេចក្តីញាប់ញ័រ ។

[ ៩៩ ] ពាក្យថា បុគ្គលណា ដឹងច្បាស់នូវទីបំផុតទាំង ២ គឺបុគ្គលណាដឹងច្បាស់ ដឹង ថ្លឹង ពិចារណា សម្តែង ធ្វើឲ្យជាក់ច្បាស់នូវទីបំផុតទាំង ២ ហេតុនោះ ( លោកសួរថា ) បុគ្គលណា ដឹងច្បាស់នូវទីផុតទាំង ២ ។

[ ១០០ ] ពាក្យថា និងកណ្តាល ដោយប្រាជ្ញា ហើយមិនជាប់ គឺមិនជាប់ មិនចូលទៅជិតជាប់ ចេញ រលាស់ចេញ រួចស្រឡះ ប្រាសចេញ នៅដោយចិត្ត ដែលប្រាសចាកទំនប់ គឺកិលេស ហេតុនោះ ( លោកសួរថា ) និងកណ្តាលដោយប្រាជ្ញា ហើយមិនជាប់ ។

[ ១០១ ] ពាក្យថា ព្រះអង្គទ្រង់ហៅបុគ្គលណា ថាមហាបុរស គឺព្រះអង្គទ្រង់ហៅបុគ្គលណា ទ្រង់សម្តែងបុគ្គលណា ទ្រង់សម្គាល់បុគ្គលណា ទ្រង់ត្រាស់បុគ្គលណា ទ្រង់ឃើញបុគ្គលណា ទ្រង់ប្រកាសបុគ្គលណា ថាមហាបុរស បុរសលើស បុរសប្រសើរ បុរសវិសេសផុត បុរសចម្បង បុរស

ឧត្តម បុរសថ្លៃថ្លា ហេតុនោះ ( លោកសួរថា ) ព្រះអង្គទ្រង់ហៅបុគ្គលណា ជាមហាបុរស ។

[ ១០២ ] ពាក្យថា បុគ្គលណាបានកន្លងនូវតណ្ហា ជាគ្រឿងចាក់ស្រែះក្នុងលោកនេះ គឺបុគ្គលណា បានកន្លង កន្លងបង់ ឈានកន្លង កន្លងព្រមប្រព្រឹត្តកន្លងនូវតណ្ហាជាគ្រឿងចាក់ស្រែះ ហេតុនោះ ( លោកសួរថា ) បុគ្គលណា បានកន្លងនូវតណ្ហាជាគ្រឿងចាក់ស្រែះក្នុងលោកនេះ ។ ហេតុនោះព្រាហ្មណ៍នោះ ពោលហើយថា

( តិស្សមេត្តេយ្យមានអាយុទូលសួរ ដូច្នេះថា ) បុគ្គលណា ក្នុងលោកនេះ ជាអ្នកត្រេកអរពេញលេញ បុគ្គលណា មិនមានសេចក្តីញាប់ញ័រ បុគ្គលណា ដឹងច្បាស់នូវទីបំផុតទាំងពីរ និងកណ្តាលដោយប្រាជ្ញា ហើយមិនជាប់ ព្រះអង្គទ្រង់ហៅបុគ្គលណាជាមហាបុរស បុគ្គលណា បានកន្លងនូវតណ្ហាជាគ្រឿងចាក់ស្រែះក្នុងលោកនេះ ។

[ ១០៣ ] ( ព្រះមានព្រះភាគត្រាស់ថា ម្នាលមេត្តេយ្យៈ ) ភិក្ខុណា មានព្រហ្មចរិយៈ សង្រួមក្នុងកាមទាំងឡាយ ប្រាសចាសតណ្ហា មានស្មារតីសព្វកាល ដឹងហើយ រលត់ហើយ ឯសេចក្តីញាប់ញ័ររបស់ភិក្ខុនោះ មិនមានទេ ភិក្ខុនោះ ដឹងច្បាស់ទីបំផុតទាំងពីរ និងកណ្តាល ដោយការដឹងហើយ មិនជាប់ តថាគតហៅភិក្ខុនោះ ជាមហាបុរស ភិក្ខុនោះ បានកន្លងនូវតណ្ហា

ជាគ្រឿងចាក់ស្រែះ ក្នុងលោកនេះ ។

[ ១០៤ ] អធិប្បាយពាក្យថា មានព្រហ្មចរិយៈ ក្នុងកាមទាំងឡាយ ត្រង់ពាក្យថា កាមទាំងឡាយ បើតាមឧទ្ទាន កាមមាន ២ គឺវត្ថុកាម ១ កិលេសកាម ១ ។បេ។ នេះ ហៅថា វត្ថុកាម ។បេ។ នេះ ហៅថា កិលេស-កាម ។ ពាក្យថា មានព្រហ្មចរិយៈ សេចក្តីថា ការវៀរ ការចៀសវាង ការវៀរស្រឡះ ការបណ្តេញបង់នូវពៀរ កិរិយាមិនធ្វើ ការមិនធ្វើ ការមិនត្រូវការមិនប្រព្រឹត្តកន្លងនូវដែន ចាកការដល់ព្រមនៃអសទ្ធម្ម លោកហៅថា ព្រហ្មចរិយៈ ។ មួយទៀត ដោយនិប្បរិយាយមគ្គប្រកបដោយអង្គ ៨ ដ៏ប្រសើរ គឺប្រាជ្ញាយល់ត្រូវ សេចក្តីត្រិះរិះត្រូវ វាចាត្រូវ ការងារត្រូវ ការចិញ្ចឹមជីវិតត្រូវ ព្យាយាមត្រូវ សេចក្តីរឭកត្រូវ ការតាំងចិត្តនឹងត្រូវ លោកហៅថា **ព្រហ្មចរិយ** ។ បុគ្គលណា ប្រកប ប្រកបព្រម ចូលមកជិត ចូលមកជិតព្រម ចូលទៅដល់ ចូលទៅដល់ព្រម ប្រកបព្រមដោយមគ្គប្រកបដោយអង្គ ៨ ដ៏ប្រសើរនេះ បុគ្គលនោះ លោកហៅថា អ្នកមានព្រហ្មចរិយៈ ។ ឧបមាដូចជាបុគ្គលដែលលោកហៅថា អ្នកមានទ្រព្យ ព្រោះទ្រព្យ ហៅថា អ្នកមានភោគៈ ព្រោះភោគៈ ហៅថា អ្នកមានយស ព្រោះយស ហៅថា អ្នកមានសិល្បៈ ព្រោះសិល្បៈ ហៅថា អ្នកមានសីល ព្រោះសីល ហៅថា អ្នកមានព្យាយាម ព្រោះព្យាយាម ហៅថា អ្នកមានប្រាជ្ញា ព្រោះប្រាជ្ញា ហៅថា អ្នកមានវិជ្ជា ព្រោះវិជ្ជា យ៉ាងណាមិញ បុគ្គលណា ប្រកប ប្រកបព្រម ចូលមកជិត ចូលមកជិតព្រម ចូលទៅដល់ ចូល

ទៅដល់ព្រម ប្រកបព្រម ដោយមគ្គប្រកបដោយអង្គ ៨ ដ៏ប្រសើរនេះ បុគ្គលនោះ លោកហៅថា ជាអ្នកមានព្រហ្មចរិយៈយ៉ាងនោះឯង ហេតុនោះ ( ទ្រង់ត្រាស់ថា ) អ្នកមានព្រហ្មចរិយៈក្នុងកាមទាំងឡាយ ។ ពាក្យថា ម្នាលមេត្តេយ្យៈ គឺព្រះមានព្រះភាគទ្រង់ហៅព្រាហ្មណ៍នោះដោយគោត្រ ពាក្យថា ព្រះមានព្រះភាគនេះ គឺជាពាក្យសម្រាប់ហៅដោយគោរព ។បេ។ ការបញ្ញត្តិថា មានព្រះភាគនេះ ( កើត ) ព្រោះការធ្វើឲ្យជាក់ច្បាស់ ហេតុនោះ លោកពោលថា ព្រះមានព្រះភាគត្រាស់ថា ម្នាលមេត្តេយ្យៈ ។

[ ១០៥ ] អធិប្បាយពាក្យថា ប្រាសចាកតណ្ហា មានស្មារតីសព្វកាល ត្រង់ពាក្យថា តណ្ហា បានដល់ រូបតណ្ហា សទ្ទតណ្ហា គន្ធតណ្ហា រសតណ្ហា ផោដ្ឋព្វតណ្ហា ធម្មតណ្ហា ។ តណ្ហានេះ បុគ្គលណា បានលះបង់ ផ្តាច់បង់ រម្ងាប់ រម្ងាប់ចំពោះ ធ្វើមិនគួរឲ្យកើតឡើងបាន ដុតដោយភ្លើង គឺញាណហើយ បុគ្គលនោះ លោកហៅថា អ្នកប្រាសចាកតណ្ហា អ្នកលះបង់តណ្ហា មានតណ្ហាខ្ជាក់ចោល មានតណ្ហាលែងហើយ អ្នកលះតណ្ហា អ្នករលាស់ចោលតណ្ហា អ្នកប្រាសចាករាគៈ អ្នកលះរាគៈ អ្នកខ្ជាក់រាគៈ អ្នកលែងរាគៈ អ្នកលះបង់រាគៈ អ្នករលាស់ចោលរាគៈ មិនមានសេចក្តីស្រេកឃ្លាន មានទុក្ខរលត់ហើយ មានសេចក្តីត្រជាក់កើតហើយ អ្នកសោយសុខ មានខ្លួនដ៏ប្រសើរ ។ ពាក្យថា សព្វកាល គឺក្នុងកាលទាំងពួង ក្នុងកាលទាំងអស់ អស់កាលទាំងស្រុង អស់កាលជានិច្ច អស់កាលដ៏ទៀងរឿយៗ ប្រព្រឹត្តទៅព្រម ប្រឡូកប្រឡំ មិនឃ្លាត គ្មានចន្លោះ ប្រកបដោយសេចក្តីព្រមព្រៀង

ពាល់ត្រូវ កាលមុននៃកត្ត កាលជាខាងក្រោយនៃកត្ត យាមខាងដើម យាមកណ្ដាល យាមខាងក្រោយ រនោច ខ្នើត វដូវក្ដៀង វដូវវងា វដូវក្ដៅ ខន្ធអស់ទៅក្នុងខាងដើម ខន្ធអស់ទៅក្នុងកណ្ដាល ខន្ធអស់ទៅក្នុងខាងក្រោយ ពាក្យថា មានស្មារតី គឺឈ្មោះថា អ្នកមានស្មារតីដោយហេតុ ៤ គឺមានស្មារតីព្រោះបានចម្រើនសតិប្បដ្ឋាន គឺការពិចារណារឿយៗ នូវកាយក្នុងកាយ ១ មានស្មារតីព្រោះបានចម្រើនសតិប្បដ្ឋាន គឺការពិចារណារឿយៗ នូវវេទនាក្នុងវេទនាទាំងឡាយ ១ មានស្មារតីព្រោះបានចម្រើនសតិប្បដ្ឋាន គឺការពិចារណារឿយៗ នូវចិត្តក្នុងចិត្ត ១ មានស្មារតីព្រោះបានចម្រើនសតិប្បដ្ឋាន គឺការពិចារណារឿយៗ នូវធម៌ក្នុងធម៌ ១ ។បេ។ បុគ្គលនោះ លោកហៅថា អ្នកមានស្មារតី ហេតុនោះ ( ទ្រង់ត្រាស់ថា ) ប្រាសចាកតណ្ហា មានស្មារតីសព្វកាល ។

[ ១០៦ ] ពាក្យថា ដឹងហើយ រលត់ហើយ ជាភិក្ខុ អធិប្បាយថា ញាណ ឈ្មោះថា ការដឹង បានដល់ បញ្ញា ការដឹងច្បាស់ ការពិចារណា ។បេ។ ការមិនវង្វេង ការពិចារណាធម៌ សេចក្ដីឃើញត្រូវ ។ ពាក្យថា ដឹងហើយ គឺបានដឹង យល់ ពិចារណា ត្រិះរិះ សម្ដែង ធ្វើឲ្យជាក់ច្បាស់ គឺថា ដឹង យល់ ពិចារណា ត្រិះរិះ សម្ដែង ធ្វើឲ្យជាក់ច្បាស់ថា សង្ខារទាំងពួងមិនទៀង បានដឹង យល់ ពិចារណា ត្រិះរិះ សម្ដែង ធ្វើឲ្យជាក់ច្បាស់ថា សង្ខារទាំងពួងជាទុក្ខ ថាធម៌ទាំងពួងជាអនត្តា ថាសង្ខារ ( កើត ) ព្រោះអវិជ្ជាជាបច្ច័យ ។បេ។ ថាធម្មជាតណាមួយ មានកិរិយាកើតឡើងជាធម្មតា ធម្មជាត

ទាំងអស់នោះ មានកិរិយារលត់ទៅជាធម្មតា ។ មួយទៀត បានដឹង យល់ពិចារណា ត្រិះរិះ សម្តែង ធ្វើឲ្យជាក់ច្បាស់ថា មិនទៀង បានដឹង យល់ពិចារណា ត្រិះរិះ សម្តែង ធ្វើជាក់ច្បាស់ថា ជាទុក្ខ ជារោគ ជាបូស ជាសរ ។បេ។ ថាមិនមែនជាគ្រឿងរលាស់ខ្លួនចេញចាកទុក្ខ ។ ពាក្យថា រលត់ហើយ គឺរលត់ហើយ ព្រោះលោកញុំាងរាគៈឲ្យរលត់ រលត់ហើយ ព្រោះញុំាងទោសៈឲ្យរលត់ រលត់ហើយ ព្រោះញុំាងមោហៈឲ្យរលត់ រលត់ហើយ ព្រោះញុំាងក្រោធ ការចងក្រោធទុក សេចក្តីលុបគុណ ការវាយឫកស្មើ សេចក្តីប្រណែន សេចក្តីកំណាញ់ ការបិទបាំងទោសរបស់ខ្លួន សេចក្តីអួតអាង សេចក្តីរឹងត្អឹង ការប្រណាំងប្រជែង មានះ សេចក្តីមើលងាយ សេចក្តីស្រវឹង សេចក្តីធ្វេស កិលេសទាំងពួង ទុច្ចរិតទាំងពួង សេចក្តីក្រវល់ក្រវាយទាំងពួង សេចក្តីរោលរាលទាំងពួង សេចក្តីក្តៅក្រហាយទាំងពួង អភិសង្ខារជាអកុសលទាំងពួងឲ្យរលត់ ។ ពាក្យថា ភិក្ខុ គឺ ឈ្មោះថា ភិក្ខុ ព្រោះទម្លាយបង់ធម៌ ៧ ។បេ។ មានមគ្គអប់រំ មានភពថ្មីអស់ បុគ្គលនោះ លោកហៅថា ភិក្ខុ ហេតុនោះ ( ទ្រង់ត្រាស់ថា ) ដឹងហើយ រលត់ហើយ ជាភិក្ខុ ។

[ ១០៧ ] អធិប្បាយពាក្យថា សេចក្តីញាប់ញ័ររបស់ភិក្ខុនោះ មិនមាន ត្រង់ពាក្យថា របស់ភិក្ខុនោះ បានដល់ការញាប់ញ័រទាំងឡាយ គឺការញាប់ញ័រដោយតណ្ហា ញាប់ញ័រដោយទិដ្ឋិ ញាប់ញ័រដោយមានះ ញាប់ញ័រដោយកិលេស ញាប់ញ័រដោយកម្ម របស់ព្រះអរហន្តខីណាស្រព ។ សេចក្តី

ញាប់ញ័រទាំងនេះ របស់ព្រះខីណាស្រពនោះ គ្មាន មិនមាន មិនមានព្រម មិនបាន ( គឺលោក ) បានលះបង់ ផ្តាច់បង់ រម្ងាប់ រម្ងាប់ចំពោះ ធ្វើមិនគួរឲ្យកើតឡើងបាន ដុតដោយភ្លើង គឺញាណហើយ ហេតុនោះ ( ទ្រង់ត្រាស់ថា ) សេចក្តីញាប់ញ័ររបស់ភិក្ខុនោះ មិនមាន ។

[ ១០៨ ] អធិប្បាយពាក្យថា ភិក្ខុនោះ ដឹងច្បាស់នូវទីបំផុតទាំងពីរ និងកណ្តាលដោយការដឹង ហើយមិនជាប់ ត្រង់ពាក្យថា ទីបំផុត គឺផស្សៈជាទីបំផុត ១ ការកើតឡើងនៃផស្សៈជាទីបំផុតទី ២ ការរលត់នៃផស្សៈ ទុកជាកណ្តាល អតីតជាទីបំផុត ១ អនាគតជាទីបំផុតទី ២ បច្ចុប្បន្នទុកជាកណ្តាល សុខវេទនាជាទីបំផុត ១ ទុក្ខវេទនាជាទីបំផុតទី ២ អទុក្ខមសុខ-វេទនា ទុកជាកណ្តាល នាមជាទីបំផុត ១ រូបជាទីបំផុតទី ២ វិញ្ញាណទុកជាកណ្តាល អាយតនៈខាងក្នុង ៦ ជាទីបំផុត ១ អាយតនៈខាងក្រៅ ៦ ជាទីបំផុតទី ២ វិញ្ញាណទុកជាកណ្តាល សក្កាយៈជាទីបំផុត ១ ការកើតឡើងនៃសក្កាយៈជាទីបំផុតទី ២ ការរលត់នៃសក្កាយៈ ទុកជាកណ្តាល ។ បញ្ញា លោកហៅថា ការដឹង គឺបញ្ញា ការដឹងច្បាស់ ។បេ។ ការមិនវង្វេង ការពិចារណាធម៌ សេចក្តីឃើញត្រូវ ។ ពាក្យថា ការជាប់ បានដល់ ការជាប់ជំពាក់ពីរ គឺការជាប់ជំពាក់ដោយតណ្ហា ១ ការជាប់ជំពាក់ដោយទិដ្ឋិ ១ ការជាប់ជំពាក់ដោយតណ្ហា តើដូចម្តេច ។ សេចក្តីហួងហែង សេចក្តីប្រកាន់ដែលធ្វើឲ្យជាដែន ធ្វើឲ្យជាទំនប់ ធ្វើឲ្យជាចំណែក ធ្វើឲ្យជាទីបំផុត ដោយចំណែកនៃតណ្ហា ជាកំណត់ថា នេះរបស់អញ នោះរបស់អញ វត្ថុមានប្រមាណ

ប៉ុណ្ណេះ របស់អញ ធម្មជាតមានប្រមាណប៉ុណ្ណេះ របស់អញ រូប សំឡេង ក្លិន រស ផ្សព្វ កម្រាល សំពត់ដណ្តប់ ខ្ញុំស្រី ខ្ញុំប្រុស ពពែ ចៀម មាន់ ជ្រូក ដំរី គោ សេះឈ្មោល-ញី ស្រែ ចម្ការ ប្រាក់ មាស ស្រុក និគម រាជធានី ដែន ជនបទ ឃ្លាំង ជង្រុក របស់អញ មួយវិញទៀត បុគ្គល ប្រកាន់មហាប្រឹថពីទាំងមូលដោយអំណាចនៃតណ្ហា តណ្ហាវិចរិតយ៉ាងពិស្តារ ១០៨ ជាកំណត់ នេះឈ្មោះថា ការជាប់ជំពាក់ដោយតណ្ហា ។ ការជាប់ជំពាក់ដោយទិដ្ឋិ តើដូចម្តេច ។ សក្កាយទិដ្ឋិ មានវត្ថុ ២០ មិច្ឆាទិដ្ឋិ មានវត្ថុ ១០ អន្តគ្គាហិកាទិដ្ឋិ មានវត្ថុ ១០ ទិដ្ឋិ ដំណើរ គឺទិដ្ឋិ ព្រៃស្បាត គឺទិដ្ឋិ ផ្លូវលំបាក គឺទិដ្ឋិ ចម្រូង គឺទិដ្ឋិ សេចក្តីញាប់ញ័រ គឺទិដ្ឋិ សញ្ញោជនៈ គឺទិដ្ឋិ ការប្រកាន់ ការប្រកាន់ចំពោះ ការផ្តេកផ្តិត ការស្ទាបអង្អែលផ្លូវខុស ផ្លូវអាក្រក់ ភាពនៃសេចក្តីខុស លទ្ធិដូចជាកំពង់ សេចក្តីប្រកាន់ដោយការស្វែងខុស សេចក្តីប្រកាន់វិបរិត សេចក្តីប្រកាន់វិបល្លាស សេចក្តីប្រកាន់ខុស សេចក្តីប្រកាន់ថាជារបស់ពិត ក្នុងរបស់ដែលមិនពិត ទិដ្ឋិ ៦២ ទាំងប៉ុន្មានឯណា មានសភាពយ៉ាងនេះ នេះឈ្មោះថា ការជាប់ជំពាក់ដោយទិដ្ឋិ ។ ពាក្យថា ភិក្ខុនោះដឹងច្បាស់ទីបំផុតទាំងពីរ និងកណ្តាល ដោយការដឹង ហើយមិនជាប់ បានន័យថា ភិក្ខុនោះដឹងច្បាស់ យល់ ពិចារណា ត្រិះរិះ សម្តែងធ្វើឲ្យប្រាកដ ទីបំផុតទាំងពីរ និងកណ្តាល ដោយការដឹងហើយ មិនចូលទៅជិតជាប់ គឺជាអ្នកមិនជាប់ជំពាក់ មិនចូលទៅជិតជាប់ ចេញ រលាស់ ចេញផុតស្រឡះ មិនប្រកបព្រម នៅដោយចិត្តដែលធ្វើកិលេសដូចជាទំនប់ ទៅ

ប្រាសហើយ ហេតុនោះ ( ទ្រង់ត្រាស់ថា ) ភិក្ខុនោះដឹងច្បាស់ ទីបំផុតទាំង ពីរ និងកណ្ដាល ដោយការដឹងហើយ ។

[ ១០៩ ] ពាក្យថា តថាគតហៅបុគ្គលនោះ ថាមហាបុរស អធិប្បាយ ថា តថាគតហៅបុគ្គលនោះ ប្រាប់បុគ្គលនោះ សម្គាល់បុគ្គលនោះ ពោល បុគ្គលនោះ ឃើញបុគ្គលនោះ ហៅបុគ្គលនោះថាមហាបុរស បុរសដ៏លើស បុរសដ៏ប្រសើរ បុរសវិសេសបំផុត បុរសជាប្រធាន បុរសឧត្តម បុរស ថ្លៃថ្លា ។ ឧទាហរណ៍ ដូចព្រះសារីបុត្តមានអាយុ ទូលសួរពាក្យនេះ នឹងព្រះ មានបុណ្យថា សូមទ្រង់ព្រះមេត្តាប្រោស បុគ្គលដែលគេហៅថា មហាបុរស សូមទ្រង់ព្រះមេត្តាប្រោស បុគ្គលដែលជាមហាបុរស តើដោយហេតុប៉ុន្មាន ។ ម្នាលសារីបុត្ត តថាគតហៅថា មហាបុរស ព្រោះបុគ្គលនោះ មានចិត្តរួច ស្រឡះហើយ មិនហៅថា មហាបុរស ព្រោះបុគ្គលនោះ មានចិត្តគ្រាន់តែ ជឿទេ ម្នាលសារីបុត្ត បុគ្គលមានចិត្តរួចស្រឡះហើយ ដោយប្រការដូចម្ដេច ម្នាលសារីបុត្ត ភិក្ខុក្នុងសាសនានេះ ពិចារណាឃើញរឿយៗ នូវកាយក្នុង កាយជាខាងក្នុង ជាអ្នកមានព្យាយាមដុតកម្ដៅកិលេស ដឹងច្បាស់ មាន ស្មារតី បន្ទោបង់អភិជ្ឈា និងទោមនស្សក្នុងលោក ភិក្ខុនោះ កាលពិចារណា ឃើញរឿយៗ នូវកាយក្នុងកាយ ចិត្តក៏ប្រាសចាកតម្រេក រួចស្រឡះចាក អាសវៈទាំងឡាយ ព្រោះមិនប្រកាន់មាំ ជាអ្នកពិចារណាឃើញរឿយៗ ( នូវ វេទនា ) ក្នុងវេទនាទាំងឡាយ ពិចារណាឃើញរឿយៗ ( នូវចិត្ត ) ក្នុងចិត្ត ពិចារណាឃើញរឿយៗ នូវធម៌ក្នុងធម៌ទាំងឡាយ ជាអ្នកមានព្យាយាម ដុត

កម្តៅកិលេស ដឹងច្បាស់ មានស្មារតី បន្ទោបង់អភិជ្ឈា និងទោមនស្សក្នុងលោក ភិក្ខុនោះ កាលពិចារណាឃើញរឿយៗ នូវធម៌ក្នុងធម៌ទាំងឡាយ ចិត្តក៏ប្រាសចាកតម្រេក រួចស្រឡះចាកអាសវៈទាំងឡាយ ព្រោះមិនប្រកាន់មាំ ម្នាលសារីបុត្ត ភិក្ខុមានចិត្តរួចស្រឡះហើយយ៉ាងនេះឯង ម្នាលសារីបុត្ត តថាគតហៅថា មហាបុរស ព្រោះភិក្ខុនោះ មានចិត្តផុតស្រឡះហើយ មិនហៅថា មហាបុរស ព្រោះភិក្ខុនោះមានចិត្តគ្រាន់តែជឿទេ ហេតុនោះ ( ទ្រង់ត្រាស់ថា ) តថាគតហៅបុគ្គលនោះ ថាមហាបុរស ។

[ ១១០ ] ពាក្យថា ភិក្ខុនោះបានកន្លងតណ្ហា ជាគ្រឿងចាក់ស្រែះក្នុងលោកនេះ សេចក្តីថា តណ្ហា លោកហៅថា ធម្មជាតជាគ្រឿងចាក់ស្រែះ បានខាងសេចក្តីត្រេកអរ សេចក្តីត្រេកអរខ្លាំង ។បេ។ អភិជ្ឈា លោភៈ អកុសលមូល ។ តណ្ហាជាគ្រឿងចាក់ស្រែះនេះ ដែលបុគ្គលណា លះបង់ ផ្តាច់បង់ រម្ងាប់ រម្ងាប់ចំពោះ ធ្វើមិនគួរឲ្យកើតឡើងបាន ដុតដោយភ្លើង គឺញាណហើយ បុគ្គលនោះបានកន្លងចូលទៅកន្លង ឈានកន្លង ឈានកន្លងព្រម ប្រព្រឹត្តកន្លងនូវតណ្ហាជាគ្រឿងចាក់ស្រែះ ហេតុនោះ ( ទ្រង់ត្រាស់ថា ) ភិក្ខុនោះ បានកន្លងតណ្ហាជាគ្រឿងចាក់ស្រែះ ក្នុងលោកនេះ ។ ហេតុនោះ ព្រះមានព្រះភាគត្រាស់ថា

( ព្រះមានព្រះភាគត្រាស់ថា ម្នាលមេត្តេយ្យ ) ( ភិក្ខុណា )
មានព្រហ្មចរិយៈ ( សង្រួម ) ក្នុងកាមទាំងឡាយ ប្រាសចាក
តណ្ហា មានស្មារតីសព្វកាល ដឹងហើយ រលត់ហើយ សេចក្តី

ញាប់ញ័ររបស់ភិក្ខុនោះ មិនមានទេ ភិក្ខុនោះ ដឹងច្បាស់ទីបំផុតទាំងពីរ និងកណ្ដាល ដោយការដឹង ហើយមិនជាប់ តថាគតហៅភិក្ខុនោះថា មហាបុរស ភិក្ខុនោះ បានកន្លងតណ្ហាជាគ្រឿងចាក់ស្រែះ ក្នុងលោកនេះ ។

[ ១១១ ] ព្រាហ្មណ៍មាណពទាំងឡាយ មានអធ្យាស្រ័យតែមួយ មានប្រយោគតែមួយ មានសេចក្ដីប៉ុនប៉ងតែមួយ មានធម៌ជាគ្រឿងអប់រំតែមួយ បានអប់រំហើយ ( ក្នុងព្រះពុទ្ធសាសនាជាអតីត ) ជាមួយគ្នា មួយអន្លើដោយព្រាហ្មណ៍ ( ឈ្មោះតិស្សមេត្តេយ្យ ) នោះ ធម្មចក្ខុ ( សោតាបត្តិមគ្គ ) មានធូលីទៅប្រាសហើយ មានមន្ទិលទៅប្រាសហើយ កើតឡើងដល់ពាន់នៃសត្វដ៏ច្រើនទាំងនោះថា ធម្មជាតណាមួយ មានកិរិយាកើតឡើងជាធម្មតា ធម្មជាតទាំងអស់នោះ មានកិរិយារលត់ទៅវិញជាធម្មតា ឯ ( តិស្សមេត្តេយ្យព្រាហ្មណ៍នោះ ) មានចិត្តផុតស្រឡះហើយ ចាកអាសវៈទាំងឡាយ ព្រោះមិនប្រកាន់ ដំណាលគ្នានឹងការចប់គាថា ។ ( លំដាប់នោះ ) ស្បែកខ្លា ជដា សំពត់សម្បកឈើ ឈើច្រត់ កុណ្ឌីទឹក និងសក់ ពុកមាត់ ពុកចង្កា ក៏បាត់ទៅ ជាមួយនឹងពេលដែលដល់នូវភាពនៃខ្លួនជាព្រះអរហន្ត ។ ( តិស្សមេត្តេយ្យព្រាហ្មណ៍ បានជាឯហិភិក្ខុ ) ស្លៀកដណ្ដប់នូវកណ្ឌៈ គឺសំពត់កាសាយៈ ទ្រទ្រង់នូវសង្ឃាដី បាត្រ និងចីវរ អង្គុយប្រណម្យអញ្ជលីនមស្ការព្រះមានព្រះភាគ ដោយប្រតិបត្តិសមគួរដល់ប្រយោជន៍ ( ហើយប្រកាសថា ) បពិត្រព្រះអង្គដ៏ចម្រើន ព្រះមានព្រះភាគ ជាសាស្ដារបស់ខ្ញុំព្រះអង្គ ខ្ញុំព្រះអង្គជាសាវ័ក ។

# អដ្ឋកថា

## តិស្សមេត្តេយ្យមាណវកបញ្ហានិទ្ទេស

[ ៩៦ ] គប្បីជ្រាបវិនិច្ឆ័យក្នុងតិស្សមេត្តេយ្យសុត្តនិទ្ទេសទី ២ មានពាក្យផ្ដើមថា **កោធ សន្តុសិតោ** ដូច្នេះ ។

កាលអជិតសូត្រចប់ហើយ មោឃរាជមាណពបំណងនឹងទូលសួរយ៉ាងនេះថា បុគ្គលសម្លឹងឃើញលោកដោយប្រការដូចម្ដេច ទើបមច្ចុរាជមិនឃើញ ព្រះមានព្រះភាគជ្រាបថា ឥន្ទ្រិយរបស់មោឃរាជមាណពនោះ មិនទាន់ចាស់ក្លាគ្រប់គ្រាន់ ទើបត្រាស់ឃាត់ថា ម្នាលមោឃរាជ ចូរអ្នកបង្អង់សិន ចូរអ្នកដទៃសួរ ។ លំដាប់នោះ តិស្សមេត្តេយ្យកាលទូលសួរសេចក្ដីសង្ស័យរបស់ខ្លួន ទើបពោលគាថាជាដើមថា **កោធ** ដូច្នេះ ។

ក្នុងបទទាំងនោះ បទថា **កោធ សន្តុសិតោ** បានដល់ អ្នកណាពេញចិត្តហើយក្នុងលោកនេះ ។ បទថា **ឥញ្ជិតា** បានដល់ ការមិនអន្ទះអន្ទែងដោយតណ្ហា និងទិដ្ឋិ ។ បទថា **ឧភន្តមភិញ្ញាយ** បានដល់ អ្នកណាដឹងនូវចំណែកនៃអន្តធម៌ទាំង ២ ហើយ ។ បទថា **មន្តា ន លិម្បតិ** បានដល់ រមែងមិនជាប់ដោយបញ្ញា ។

[ ៩៧ ] បទថា **បរិបុណ្ណសង្កប្បោ** សេចក្ដីថា មានតម្រិះបរិបូណ៌ គឺមានសេចក្ដីប្រាថ្នាបរិបូណ៌ដោយនេក្ខម្មវិតក្កជាដើម ។

[ ៩៨ ] បទថា **តណ្ហិញ្ជិតំ** បានដល់ ការញាប់ញ័រព្រោះតណ្ហា ។ ក្នុងបទថា **ទិដ្ឋិញ្ជិតំ** ជាដើម ក៏មានន័យនេះដូចគ្នា ។ បទថា **កាមិញ្ជិតំ** សេចក្ដីថា ការញាប់ញ័រ គឺការអន្ទះអន្ទែង ព្រោះកិលេសកាម ។ បាឋៈថា

**កម្មិញ្ជិតំ** ដូច្នេះក៏មាន តែបទនេះមិនល្អ ។

[ ១០១ ] បុរសធំ ឈ្មោះថា **មហាបុរិសោ** បុរសឧត្តម ឈ្មោះថា **អគ្គបុរិសោ** បុរសជាប្រធាន ឈ្មោះថា **សេដ្ឋបុរិសោ** បុរសមិនលាមក ឈ្មោះថា **វិសិដ្ឋបុរិសោ** បុរសដែលចម្រើនបំផុត ឈ្មោះថា **ធាមោក្ខបុរិសោ** បុរសមិនថោកថយ ឈ្មោះថា **ឧត្តមបុរិសោ** ។ បុរសដែលដល់នូវភាពជាកំពូលរបស់បុរស ឈ្មោះថា **បធានបុរិសោ** បុរសដែលមនុស្សទាំងឡាយត្រូវការ ឈ្មោះថា **បវរបុរិសោ** ។

[ ១០២ ] បទថា **សិព្វនិមច្ចគា** សេចក្តីថា កន្ទង់តណ្ហាដែលជាគ្រឿងចាក់ស្រេះ គឺកន្ទង់ផុតតណ្ហា តាំងនៅហើយ ។ បទថា **ឧបច្ចគា** បានដល់ កន្ទង់តណ្ហាជាសមុទ្ទេ ។

[ ១០៣ ] ព្រះមានព្រះភាគ កាលទ្រង់ព្យាករសេចក្តីនោះ ដល់តិស្សមេត្តេយ្យមាណពនោះ ទើបត្រាស់ ២ គាថាថា **កាមេសុ** ដូច្នេះជាដើម ។ ក្នុងបទទាំងនោះ បទថា **កាមេសុ ព្រហ្មចរិយវា** សេចក្តីថា មានព្រហ្មចរិយៈ មានកាមជានិមិត្ត អធិប្បាយថា ឃើញទោសក្នុងកាមទាំងឡាយ ហើយប្រកបដោយមគ្គព្រហ្មចរិយៈ ដោយហេតុត្រឹមប៉ុណ្ណេះ ព្រះមានព្រះភាគទ្រង់សម្តែងភាពជាអ្នកសន្តោស ទ្រង់សម្តែងភាពជាអ្នកមិនញាប់ញ័រ ដោយបទជាដើមថា **វីតតណ្ហោ** ដូច្នេះ ។ ក្នុងបទទាំងនោះ បទថា **សង្ខាយ និព្វុតោ** សេចក្តីថា ពិចារណាធម៌ទាំងឡាយ ដោយភាពជារបស់មិនទៀងជាដើម ហើយរម្ងត់ ដោយការរម្ងត់រាគៈជាដើម ។

[ ១០៤ ] បទថា **អសទ្ធម្មសមាបត្តិយា** សេចក្តីថា ប្រកបដោយធម៌ថោកទាប ។ បទថា **អារតិ** បានដល់ ឆ្ងាយអំពីសេចក្តីត្រេកអរ ។ បទថា **វិរតិ** បានដល់ វៀរចាកអសទ្ធម្មនោះ ។ បទថា **បដិវិរតិ** បានដល់ វៀរផ្តាច់អសទ្ធម្មនោះ ។ បទថា **វេរមណី** បានដល់ ឲ្យពៀរវិនាសទៅ ។ បទថា **អកិរិយា** បានដល់ ផ្តាច់នូវការធ្វើ ។ បទថា **អករណំ** បានដល់ កាត់ផ្តាច់នូវការធ្វើ ។ បទថា **អនជ្ឈាបត្តិ** បានដល់ ការមិនពាល់ត្រូវ ។ បទថា **វេលាអនតិក្កមោ** បានដល់ ការមិនកន្លងព្រំដែន ។ បទដ៏សេសជាក់ច្បាស់ល្អហើយ ព្រោះមានន័យដូចបានពោលក្នុងទីនោះៗ ។

ព្រះមានព្រះភាគ ទ្រង់សម្តែងសូត្រនេះ ដោយធម៌ដ៏កំពូល គឺអរហត្ត ដោយប្រការដូច្នេះ កាលចប់ទេសនា ព្រាហ្មណ៍នេះ មួយអន្លើដោយអន្តេវាសិក ១០០០ តាំងនៅក្នុងអរហត្ត ។ ធម្មចក្ខុកើតឡើងហើយដល់ជនដទៃច្រើនពាន់ បទដ៏សេសដូចគ្នានឹងបទមុននោះឯង ។

## អដ្ឋកថា តិស្សមេត្តេយ្យមាណវសុត្តនិទ្ទេសទី ២ ចប់

# សុត្តន្តបិដក

## បុណ្ណកមាណវកបញ្ហានិទ្ទេស

[ ១១២ ] ( បុណ្ណកៈមានអាយុ ក្រាបទូលសួរថា ) យើងខ្ញុំមក ដោយត្រូវការសួរប្រស្នា ចំពោះព្រះអង្គ ជាបុគ្គលមិនមានការញាប់ញ័រ ទ្រង់ឃើញនូវមូល ចុះពួកមនុស្ស គឺឥសី ក្សត្រ និងព្រាហ្មណ៍ច្រើននាក់ ក្នុងលោកនេះ អាស្រ័យអ្វី ទើបបានសម្រេចយញ្ញៈ ដល់ទេវតាទាំងឡាយ បពិត្រព្រះមានព្រះភាគ ខ្ញុំព្រះអង្គ ទូលសួរព្រះអង្គ សូមព្រះអង្គ ប្រាប់សេចក្ដីនោះដល់ខ្ញុំព្រះអង្គ ។

[ ១១៣ ] ពាក្យថា ជាបុគ្គលមិនមានការញាប់ញ័រ ទ្រង់ឃើញនូវមូល អធិប្បាយថា តណ្ហា លោកហៅថា ការញាប់ញ័រ បានដល់ សេចក្ដីត្រេកអរ សេចក្ដីត្រេកអរខ្លាំង ។បេ។ អភិជ្ឈា លោភៈ អកុសលមូល ។ ការញាប់ញ័រ គឺតណ្ហានោះ ព្រះពុទ្ធមានព្រះភាគ លះបង់ហើយ មានឫសផ្ដាច់ផ្ដិលហើយ ធ្វើមិនឲ្យមានទីកើត ដូចជាទីកើតនៃដើមត្នោត ធ្វើឲ្យដល់នូវការមិនមានបែបភាព មិនឲ្យមានការកើតឡើងតទៅ ជាធម្មតា ហេតុនោះ ព្រះពុទ្ធ ឈ្មោះថា មិនមានការញាប់ញ័រ ព្រះពុទ្ធ ឈ្មោះថា មិនញាប់ញ័រ ព្រោះព្រះអង្គលះនូវការញាប់ញ័រ ។ ទុកជាក្នុងលាភ ព្រះមានព្រះភាគ ក៏មិនញាប់ញ័រ ទុកជាក្នុងអលាភ ក៏មិនញាប់ញ័រ ទុកជាក្នុងយស ក៏មិនញាប់ញ័រ ទុកជាក្នុងអយស ក៏មិនញាប់ញ័រ ទុកជាក្នុងសេចក្ដីសរសើរ ក៏មិនញាប់ញ័រ ទុកជាក្នុងសេចក្ដីតិះដៀល ក៏មិនញាប់ញ័រ ទុកជាក្នុងសុខ ក៏មិនញាប់ញ័រ ទុកជា

ក្នុងទុក្ខក៏មិនញាប់ញ័រ មិនកម្រើក មិនរំភើប មិនរន្ធត់ ហេតុនោះ ( លោកសួរថា ) ជាបុគ្គលមិនមានការញាប់ញ័រ ។ ពាក្យថា ឃើញមូល គឺព្រះមានព្រះភាគ ទ្រង់ឃើញឫសគល់ ឃើញហេតុ ឃើញនិទាន ឃើញសម្ភវៈ ឃើញសមុដ្ឋាន ឃើញអាហារ ឃើញអារម្មណ៍ ឃើញបច្ច័យ ឃើញសមុទ័យ ។ អកុសលមូល ៣ គឺលោភៈ ជាអកុសលមូល ទោសៈ ជាអកុសលមូល មោហៈ ជាអកុសលមូល ។ សមដូចព្រះមានព្រះភាគត្រាស់ព្រះតម្រាស់នេះថា ម្នាលភិក្ខុទាំងឡាយ ធម្មជាត ៣ នេះ ជាហេតុឲ្យកើតកម្មទាំងឡាយ គឺលោភៈ ជាហេតុឲ្យកើតកម្ម ទោសៈ ជាហេតុឲ្យកើតកម្ម មោហៈ ជាហេតុឲ្យកើតកម្ម ម្នាលភិក្ខុទាំងឡាយ មិនមែនដោយកម្មកើតអំពីលោភៈ ដោយកម្មកើតអំពីទោសៈ ដោយកម្មកើតអំពីមោហៈទេ ដែល ( ធ្វើឲ្យ ) ពួកទេវតាប្រាកដ ពួកមនុស្សប្រាកដ ឬក៏ពួកសុគតិណានីមួយសូម្បីដទៃ ( ប្រាកដ ) ម្នាលភិក្ខុទាំងឡាយ តាមពិត ដោយកម្មកើតអំពីលោភៈ ដោយកម្មកើតអំពីទោសៈ ដោយកម្មកើតអំពីមោហៈ នរកទើបប្រាកដ កំណើតតិរច្ឆានប្រាកដ វិស័យនៃប្រេតប្រាកដ ឬក៏ពួកទុគ្គតិឯណានីមួយសូម្បីដទៃ ដើម្បីញុំាងអត្តភាពឲ្យកើតក្នុងនរក ក្នុងកំណើតតិរច្ឆាន ក្នុងវិស័យនៃប្រេត ( ក៏ប្រាកដ ) នេះអកុសលមូល ៣ ព្រះមានព្រះភាគ ទ្រង់ជ្រាប ទ្រង់ឃើញ ដូច្នេះ ។ ព្រះមានព្រះភាគ ព្រះអង្គឃើញឫសគល់ ។បេ។ ឃើញសមុទ័យ យ៉ាងនេះឯង ។ កុសលមូល មាន ៣ គឺអលោភៈ ជាកុសលមូល អទោសៈ ជាកុសលមូល អមោហៈ ជាកុសលមូល ។ ដូចព្រះមានព្រះភាគត្រាស់ព្រះ

តម្រាស់នេះថា កុសលមូលទាំង ៣ នេះ ។បេ។ ម្នាលភិក្ខុទាំងឡាយ មិនមែនដោយកម្មកើតអំពីអលោភៈ ដោយកម្មកើតអំពីអទោសៈ ដោយកម្មកើតអំពីអមោហៈទេ ដែលនរកប្រាកដ កំណើតតិរច្ឆានប្រាកដ វិស័យនៃប្រេតប្រាកដ ឬក៏ពួកទុគ្គតិឯណានីមួយសូម្បីដទៃ ( ប្រាកដ ) ម្នាលភិក្ខុទាំងឡាយ តាមពិត ដោយកម្មកើតអំពីអលោភៈ ដោយកម្មកើតអំពីអទោសៈ ដោយកម្មកើតអំពីអមោហៈ ពួកទេវតាទើបប្រាកដ ពួកមនុស្សប្រាកដ ឬក៏ពួកសុគតិឯណានីមួយសូម្បីដទៃ ដើម្បីញុំាងអត្តភាពឲ្យកើតក្នុងទេវតា និងមនុស្ស ( ក៏ប្រាកដ ) នេះកុសលមូល ៣ ព្រះមានព្រះភាគ ទ្រង់ជ្រាបទ្រង់ឃើញ ដូច្នេះ ។ ព្រះមានព្រះភាគ ទ្រង់ឃើញឫសគល់ ។បេ។ ឃើញសមុទ័យ យ៉ាងនេះឯង ។ មួយទៀត ព្រះមានព្រះភាគ ត្រាស់ព្រះតម្រាស់នេះថា ម្នាលភិក្ខុទាំងឡាយ ធម៌ទាំងឡាយណានីមួយ ជាអកុសល ជាចំណែកអកុសល ប្រព្រឹត្តទៅក្នុងពួកអកុសល ធម៌ទាំងអស់នោះ មានអវិជ្ជាជាឫស ប្រជុំចុះក្នុងអវិជ្ជា ធម៌ទាំងអស់នោះ ដល់នូវការបើកឡើងព្រោះបើកឡើងនៃអវិជ្ជា ព្រះមានព្រះភាគ ទ្រង់ជ្រាប ទ្រង់ឃើញ ដូច្នេះ ។ ព្រះមានព្រះភាគ ទ្រង់ឃើញឫសគល់ ។បេ។ ឃើញសមុទ័យយ៉ាងនេះឯង ។ មួយវិញទៀត ព្រះមានព្រះភាគ ត្រាស់ព្រះតម្រាស់នេះថា ម្នាលភិក្ខុទាំងឡាយ ធម៌ទាំងឡាយណានីមួយ ជាកុសល ជាចំណែកកុសល ប្រព្រឹត្តទៅក្នុងពួកកុសល ធម៌ទាំងអស់នោះ មានសេចក្តីមិនប្រហែសជាឫស ប្រជុំចុះក្នុងសេចក្តីមិនប្រហែស សេចក្តីមិនប្រហែស ប្រាកដជាកំពូលធម៌ទាំងនោះ

ព្រះមានព្រះភាគ ទ្រង់ជ្រាប ទ្រង់ឃើញ ដូច្នេះ ។ ព្រះមានព្រះភាគ ទ្រង់ឃើញឫសគល់ ។បេ។ ឃើញសមុទ័យ យ៉ាងនេះឯង ។ ន័យមួយទៀត ព្រះមានព្រះភាគ ទ្រង់ជ្រាប ទ្រង់ឃើញថា អវិជ្ជាជាមូលនៃសង្ខារ សង្ខារជាមូលនៃវិញ្ញាណ វិញ្ញាណជាមូលនៃនាមរូប នាមរូបជាមូលនៃសឡាយតនៈ សឡាយតនៈជាមូលនៃផស្សៈ ផស្សៈជាមូលនៃវេទនា វេទនាជាមូលនៃតណ្ហា តណ្ហាជាមូលនៃឧបាទាន ឧបាទានជាមូលនៃភព ភពជាមូលនៃជាតិ ជាតិជាមូលនៃជរាមរណៈ ព្រះមានព្រះភាគ ទ្រង់ជ្រាប ទ្រង់ឃើញ ដូច្នេះ ។ ព្រះមានព្រះភាគ ទ្រង់ឃើញឫសគល់ ។បេ។ ឃើញសមុទ័យយ៉ាងនេះឯង ។ ហេតុនោះ ទើបព្រះមានព្រះភាគ ត្រាស់ព្រះតម្រាស់នេះថា ម្នាលភិក្ខុទាំងឡាយ ធម៌ទាំងឡាយណានីមួយ ជាអកុសល ជាចំណែកនៃអកុសល ប្រព្រឹត្តទៅក្នុងពួកនៃអកុសល ធម៌ទាំងអស់នោះ មានអវិជ្ជាជាឫស ប្រជុំចុះក្នុងអវិជ្ជា ធម៌ទាំងអស់នោះ ដល់នូវការរបើកឡើង ព្រោះរបើកឡើងនៃអវិជ្ជា ព្រះមានព្រះភាគ ទ្រង់ជ្រាប ទ្រង់ឃើញ ដូច្នេះ ។ ព្រះមានព្រះភាគ ទ្រង់ឃើញឫសគល់ ឃើញហេតុ ឃើញនិទាន ឃើញសម្ភវៈ ឃើញសមុដ្ឋាន ឃើញអាហារ ឃើញអារម្មណ៍ ឃើញបច្ច័យ ឃើញសមុទ័យ យ៉ាងនេះឯង ហេតុនោះ ( លោកសួរថា ) មិនមានការញាប់ញ័រ ទ្រង់ឃើញនូវមូល ។ ពាក្យថា ដូច្នេះ ក្នុងបទថា ព្រះបុណ្ណកៈមានអាយុ ( ក្រាបទូលសួរ ) ដូច្នេះ គឺជាពាក្យតបទ ។ ពាក្យថា មានអាយុ គឺពាក្យជាទីស្រឡាញ់ ។ ពាក្យថា បុណ្ណកៈ ជាឈ្មោះនៃព្រាហ្មណ៍នោះ ។

[ ១១៤ ] ពាក្យថា យើងខ្ញុំមកដោយត្រូវការសួរប្រស្នា អធិប្បាយថា យើងខ្ញុំ មក មានសេចក្តីត្រូវការដោយប្រស្នា មក មានប្រាថ្នាសួរប្រស្នា មក មានប្រាថ្នានឹងស្តាប់ប្រស្នា ហេតុនោះ ( លោកសួរថា ) យើងខ្ញុំ មក ដោយត្រូវការសួរប្រស្នា យ៉ាងនេះឯង ។ មួយទៀត ការមក ការឈានមកចំពោះ ការចូលទៅរក ការចូលទៅអង្គុយជិត ( នៃយើងខ្ញុំ ) ជាអ្នកមានសេចក្តីត្រូវការដោយប្រស្នា ជាអ្នកប្រាថ្នានឹងសួរប្រស្នា ជាអ្នកប្រាថ្នានឹងស្តាប់ប្រស្នា ហេតុនោះ ( លោកសួរថា ) យើងខ្ញុំមក ដោយត្រូវការសួរប្រស្នា យ៉ាងនេះឯង ។ មួយវិញទៀត ការមកដោយប្រស្នាមានចំពោះព្រះអង្គ ព្រះអង្គមានបញ្ញាច្រើន មានព្យាយាម អាចដើម្បីសម្តែង ដោះស្រាយ ពន្យល់ ពោលប្រស្នា ដែលខ្ញុំព្រះអង្គសួរហើយ ហេតុនោះ ( លោកសួរថា ) យើងខ្ញុំមកដោយត្រូវការសួរប្រស្នា យ៉ាងនេះឯង ។

[ ១១៥ ] ពាក្យថា ចុះពួកមនុស្ស គឺឥសី អាស្រ័យអ្វី ត្រង់ពាក្យថា អាស្រ័យអ្វី គឺអាស្រ័យ ផ្អែកផ្អួល ខ្ជាប់ ចូលទៅជិតដល់ ស្រេចចុះ ជឿនូវអ្វី ។ ពាក្យថា ឥសី គឺជនទាំងឡាយណានីមួយ ជាអាជីវក និគ្រន្ថ ជដិល តាបសដែលបួសជាឥសី ជនទាំងនោះ ឈ្មោះថា ឥសី ។ ពួកមនុស្ស លោកហៅថា មនុស្ស ហេតុនោះ ( លោកសួរថា ) ចុះពួកមនុស្ស គឺឥសី អាស្រ័យអ្វី ។

[ ១១៦ ] អធិប្បាយពាក្យថា ក្សត្រ និងព្រាហ្មណ៍ ទើបបានសម្រេចយញ្ញៈ ដល់ទេវតាទាំងឡាយ ត្រង់ពាក្យថា ក្សត្រ គឺជនទាំងឡាយណា

នីមួយ មានជាតិជាក្សត្រ ។ ពាក្យថា ព្រាហ្មណ៍ គឺជនទាំងឡាយណា នីមួយ ជាភោវាទី ។ ពាក្យថា ដល់ទេវតាទាំងឡាយ គឺពួកអាជីវក ជាទេវតារបស់ពួកសាវកនៃអាជីវក ពួកនិគ្រន្ថ ជាទេវតារបស់ពួកសាវកនៃនិគ្រន្ថ ពួកជដិល ជាទេវតារបស់ពួកសាវកនៃជដិល ពួកបរិព្វាជក ជាទេវតារបស់ពួកសាវកនៃបរិព្វាជក ពួកអវរុទ្ធកៈ ជាទេវតារបស់ពួកសាវកនៃអវរុទ្ធកៈ ពួកដំរី ជាទេវតារបស់អ្នកប្រព្រឹត្តវត្តដំរី ពួកសេះ ជាទេវតារបស់អ្នកប្រព្រឹត្តវត្តសេះ ពួកគោ ជាទេវតារបស់អ្នកប្រព្រឹត្តវត្តគោ ពួកឆ្កែ ជាទេវតារបស់អ្នកប្រព្រឹតវត្តឆ្កែ ពួកក្អែក ជាទេវតារបស់ពួកអ្នកប្រព្រឹត្តវត្តក្អែក វាសុទេព ជាទេវតារបស់អ្នកប្រព្រឹត្តវត្តវាសុទេព ពលទេព ជាទេវតារបស់អ្នកប្រព្រឹត្តវត្តពលទេព បុណ្ណភទ្ទៈ ជាទេវតារបស់អ្នកប្រព្រឹត្តវត្តបុណ្ណភទ្ទៈ មណិភទ្ទៈ ជាទេវតារបស់អ្នកប្រព្រឹត្តវត្តមណិភទ្ទៈ ភ្លើង ជាទេវតារបស់អ្នកប្រព្រឹត្តវត្តភ្លើង ពួកនាគ ជាទេវតារបស់អ្នកប្រព្រឹត្តវត្តនាគ ពួកគ្រុឌ ជាទេវតារបស់អ្នកប្រព្រឹត្តវត្តគ្រុឌ ពួកយក្ស ជាទេវតារបស់អ្នកប្រព្រឹត្តវត្តយក្ស ពួកអសុរ ជាទេវតារបស់អ្នកប្រព្រឹត្តវត្តអសុរ ពួកគន្ធព្វ ជាទេវតារបស់អ្នកប្រព្រឹត្តវត្តគន្ធព្វ មហារាជ ជាទេវតារបស់អ្នកប្រព្រឹត្តវត្តមហារាជ ព្រះចន្ទ្រ ជាទេវតារបស់អ្នកប្រព្រឹត្តវត្តព្រះចន្ទ្រ ព្រះអាទិត្យ ជាទេវតារបស់អ្នកប្រព្រឹត្តវត្តព្រះអាទិត្យ ព្រះឥន្ទ្រ ជាទេវតារបស់អ្នកប្រព្រឹត្តវត្តព្រះឥន្ទ្រ ព្រហ្ម ជាទេវតារបស់អ្នកប្រព្រឹត្តវត្តព្រហ្ម ពួកទេវតា ជាទេវតារបស់អ្នកប្រព្រឹត្តអ្នកវត្តទេវតា ទិស ជាទេវតារបស់អ្នកប្រព្រឹត្តវត្តទិស ជន

ទាំងឡាយណា ជាទក្ខិណេយ្យបុគ្គលរបស់ពួកជនណា ជនទាំងនោះ ជាទេវតារបស់ពួកជននោះ ហេតុនោះ ( លោកសួរថា ) ក្សត្រ និងព្រាហ្មណ៍ ទើបបានសម្រេចយញ្ញៈ ដល់ទេវតាទាំងឡាយ ។

[ ១១៧ ] ពាក្យថា ច្រើននាក់ ក្នុងលោកនេះ ទើបបានសម្រេចយញ្ញៈ សេចក្តីថា ទេយ្យធម៌ គឺចីវរ បិណ្ឌបាត សេនាសនៈ គិលានប្បច្ចយ-ភេសជ្ជបរិក្ខារ បាយ ទឹក សំពត់ យាន ផ្កាកម្រង គ្រឿងក្រអូប គ្រឿងលាប ទីដេក ទីសម្នាក់អាស្រ័យ គ្រឿងប្រទីប លោកហៅថា យញ្ញៈ ។ ពាក្យថា ទើបបានសម្រេចយញ្ញៈ គឺពួកជនណា ស្វែងរក ស្វះស្វែងរក ដើររកនូវយញ្ញៈ គឺចីវរ បិណ្ឌបាត សេនាសនៈ គិលានប្បច្ចយភេសជ្ជបរិក្ខារ បាយ ទឹក សំពត់ យាន ផ្កាកម្រង គ្រឿងក្រអូប គ្រឿងលាប ទីដេក ទីសម្នាក់អាស្រ័យ គ្រឿងប្រទីប ពួកជនទាំងនោះ ឈ្មោះថា សម្រេចយញ្ញៈ ។ សូម្បីពួកជនណា តាក់តែងនូវយញ្ញៈ គឺចីវរ បិណ្ឌបាត សេនាសនៈ គិលា-នប្បច្ចយភេសជ្ជបរិក្ខារ បាយ ទឹក សំពត់ យាន ផ្កាកម្រង គ្រឿងក្រអូប គ្រឿងលាប ទីដេក ទីសម្នាក់អាស្រ័យ គ្រឿងប្រទីប ពួកជនទាំងនោះ ក៏ឈ្មោះថា សម្រេចយញ្ញៈ ។ ពួកជនណា ឲ្យបូជា លះបង់នូវយញ្ញៈ គឺចីវរ បិណ្ឌបាត សេនាសនៈ គិលានប្បច្ចយភេសជ្ជបរិក្ខារ បាយ ទឹក សំពត់ យាន ផ្កាកម្រង គ្រឿងក្រអូប គ្រឿងលាប ទីដេក ទីសម្នាក់អាស្រ័យ គ្រឿងប្រទីប ជនទាំងនោះ ក៏ឈ្មោះថា សម្រេចយញ្ញៈ ។ ពាក្យថា ច្រើន គឺពួកយញ្ញៈទុំះច្រើន ឬពួកអ្នកបូជាយញ្ញៈទុំះច្រើន ឬក៏ពួកជនដែលគួរដល់ទក្ខិណានោះ

ច្រើន ។ ពួកយញ្ញៈនុ៎ះ ច្រើន តើដូចម្ដេច ។ ពួកយញ្ញៈនុ៎ះ មានច្រើន គឺចីវរ បិណ្ឌបាត សេនាសនៈ គិលានប្បច្ចយភេសជ្ជបរិក្ខារ បាយ ទឹក សំពត់ យាន ផ្កាកម្រង គ្រឿងក្រអូប គ្រឿងលាប ទីដេក ទីសម្នាក់អាស្រ័យ គ្រឿងប្រទីប ពួកយញ្ញៈនុ៎ះ មានច្រើនយ៉ាងនេះ ។ ពួកអ្នកបូជាយញ្ញៈនុ៎ះ មានច្រើន តើដូចម្ដេច ។ ពួកអ្នកបូជាយញ្ញៈនុ៎ះ មានច្រើន គឺក្សត្រ ព្រាហ្មណ៍ អ្នកជំនួញ អ្នកគ្រួ គ្រហស្ថ បព្វជិត ទេវតា និងមនុស្ស ពួកអ្នកបូជាយញ្ញៈនុ៎ះ មានច្រើនយ៉ាងនេះ ។ ពួកជនដែលគួរដល់ទក្ខិណានុ៎ះ មានច្រើន តើដូចម្ដេច ។ ពួកជនដែលគួរដល់ទក្ខិណានុ៎ះ មានច្រើន គឺសមណព្រាហ្មណ៍ ស្មូម ជនអ្នកពណិ៌នា ហើយសូម និងសាវក ពួកជនដែលគួរដល់ទក្ខិណានុ៎ះ មានច្រើនយ៉ាងនេះ ។ ពាក្យថា ក្នុងលោកនេះ គឺក្នុងមនុស្សលោក ហេតុនោះ លោកសួរថា ច្រើនគ្នា ក្នុងលោកនេះ សម្រេចយញ្ញៈ ។

[ ១១៨ ] អធិប្បាយពាក្យថា បពិត្រព្រះមានព្រះភាគ ខ្ញុំព្រះអង្គទូលសួរព្រះអង្គ សូមព្រះអង្គប្រាប់សេចក្ដីនោះ ដល់ខ្ញុំព្រះអង្គ ត្រង់ពាក្យថា សួរ បានដល់ ការសួរ ៣ គឺការសួរសម្រាប់បំភ្លឺសេចក្ដីដែលមិនយល់ ១ ការសួរសម្រាប់ប្រៀបផ្ទឹមសេចក្ដីដែលខ្លួនយល់ហើយ ១ ការសួរសម្រាប់កាត់សេចក្ដីសង្ស័យ ១ ។

ការសួរសម្រាប់បំភ្លឺសេចក្ដីដែលមិនយល់ តើដូចម្ដេច ។ លក្ខណៈជាធម្មជាត ដែលបុគ្គលមិនបានដឹង មិនបានឃើញ មិនបានថ្លឹង មិនបានពិចារណា មិនបានយល់ច្បាស់ មិនបានប្រាកដដោយប្រក្រតី បុគ្គលសួរប្រស្នា

ដើម្បីដឹង ឃើញ ថ្លឹង ពិចារណា ដើម្បីប្រយោជន៍ដល់ការយល់ច្បាស់ ដើម្បីប្រយោជន៍ឲ្យប្រាកដនូវលក្ខណៈនោះ នេះការសួរសម្រាប់បំភ្លឺសេចក្ដីដែលមិនយល់ ។

ការសួរសម្រាប់ប្រៀបផ្ទឹមសេចក្ដីដែលខ្លួនយល់ហើយ តើដូចម្ដេច ។ លក្ខណៈជាធម្មជាត ដែលបុគ្គលបានដឹង បានឃើញ បានថ្លឹង បានពិចារណា បានយល់ច្បាស់ ប្រាកដដោយប្រក្រតី បុគ្គលសួរប្រស្នា ដើម្បីប្រយោជន៍ដល់ការប្រៀបផ្ទឹម ជាមួយនឹងបណ្ឌិតទាំងឡាយឯទៀត នេះការសួរសម្រាប់ប្រៀបផ្ទឹមសេចក្ដីដែលខ្លួនយល់ហើយ ។

ការសួរសម្រាប់កាត់សេចក្ដីសង្ស័យ តើដូចម្ដេច ។ បុគ្គលស្ទុះទៅកាន់សេចក្ដីសង្ស័យដោយប្រក្រតី ស្ទុះទៅកាន់សេចក្ដីងឿងឆ្ងល់ មានចិត្តបែកជាពីរថា យ៉ាងនេះទេឬ ឬមិនមែនទេ ហេតុដូចម្ដេចហ្ន៎ ប្រការដូចម្ដេចហ្ន៎ បុគ្គលនោះ សួរប្រស្នាដើម្បីកាត់សេចក្ដីសង្ស័យ នេះការសួរសម្រាប់កាត់សេចក្ដីសង្ស័យ ។ នេះការសួរ ៣ ។

ការសួរ ៣ ដទៃទៀត គឺការសួររបស់មនុស្ស ១ ការសួររបស់អមនុស្ស ១ ការសួររបស់ពុទ្ធនិម្មិត ១ ។

ការសួររបស់មនុស្ស តើដូចម្ដេច ។ មនុស្សទាំងឡាយចូលទៅគាល់ព្រះពុទ្ធមានព្រះភាគសួរប្រស្នា គឺពួកភិក្ខុសួរ ពួកភិក្ខុនីសួរ ពួកឧបាសកសួរ ពួកឧបាសិកាសួរ ពួកព្រះរាជាសួរ ពួកក្សត្រសួរ ពួកព្រាហ្មណ៍សួរ ពួកអ្នកជំនួញសួរ ពួកអ្នកគ្រួសួរ ពួកគ្រហស្ថសួរ ពួកបព្វជិតសួរ នេះការសួររបស់

មនុស្ស ។

ការសួររបស់អមនុស្ស តើដូចម្តេច ។ អមនុស្សទាំងឡាយចូលទៅគាល់ព្រះពុទ្ធមានព្រះភាគ សួរប្រស្នា គឺពួកនាគសួរ ពួកគ្រុឌសួរ ពួកយក្សសួរ ពួកអសុរសួរ ពួកគន្ធព្វសួរ ពួកមហារាជសួរ ពួកព្រះឥន្ទ្រសួរ ពួកព្រហ្មសួរ ពួកទេវតាសួរ នេះការសួររបស់អមនុស្ស ។

ការសួររបស់ពុទ្ធនិម្មិត តើដូចម្តេច ។ ព្រះមានព្រះភាគ និម្មិតរូបណាដ៏សម្រេចដោយព្រះហឫទ័យ មានអវយវៈតូចធំគ្រប់សព្វ មានឥន្ទ្រិយមិនខ្វះខាត ពុទ្ធនិម្មិតនោះចូលទៅគាល់ព្រះពុទ្ធមានព្រះភាគសួរប្រស្នា ព្រះមានព្រះភាគទ្រង់ដោះស្រាយ នេះការសួររបស់ពុទ្ធនិម្មិត ។ នេះការសួរ ៣ ។

ការសួរ ៣ ដទៃទៀត គឺការសួរប្រយោជន៍របស់ខ្លួន ១ ការសួរប្រយោជន៍របស់បុគ្គលដទៃ ១ ការសួរប្រយោជន៍ទាំងពីរ ១ ។

ការសួរ ៣ ដទៃទៀត គឺការសួរប្រយោជន៍ក្នុងបច្ចុប្បន្ន ១ ការសួរប្រយោជន៍ក្នុងបរលោក ១ ការសួរប្រយោជន៍ដ៏ក្រៃលែង គឺព្រះនិព្វាន ១ ។

ការសួរ ៣ ដទៃទៀត គឺការសួរប្រយោជន៍មិនមានទោស ១ ការសួរប្រយោជន៍មិនមានសេចក្តីសៅហ្មង ១ ការសួរប្រយោជន៍ដ៏ផូរផង់ ១ ។

ការសួរ ៣ ដទៃទៀត គឺការសួរហេតុជាអតីត ១ ការសួរហេតុជាអនាគត ១ ការសួរហេតុជាបច្ចុប្បន្ន ១ ។

ការសួរ ៣ ដទៃទៀត គឺការសួរធម៌ខាងក្នុង ១ ការសួរធម៌ខាងក្រៅ ១ ការសួរធម៌ទាំងខាងក្នុងទាំងខាងក្រៅ ១ ។

ការសួរ ៣ ដងទៀត គឺការសួរធម៌ជាកុសល ១ ការសួរធម៌ជាអកុ-សល ១ ការសួរធម៌ជាអព្យាកតៈ ១ ។

ការសួរ ៣ ដងទៀត គឺការសួរខន្ធ ១ ការសួរធាតុ ១ ការសួរអាយតនៈ ១ ។

ការសួរ ៣ ដងទៀត គឺការសួរសតិប្បដ្ឋាន ១ ការសួរសម្មប្បធាន ១ ការសួរឥទ្ធិបាទ ១ ។

ការសួរ ៣ ដងទៀត គឺការសួរឥន្ទ្រិយ ១ ការសួរពល ១ ការសួរពោជ្ឈង្គ ១ ។

ការសួរ ៣ ដងទៀត គឺការសួរមគ្គ ១ ការសួរផល ១ ការសួរនិព្វាន ១ ។

ពាក្យថា ខ្ញុំព្រះអង្គទូលសួរព្រះអង្គ គឺខ្ញុំព្រះអង្គទូលសួរព្រះអង្គ អង្វរព្រះអង្គ អារាធនាព្រះអង្គ ញុំាងព្រះអង្គឲ្យជ្រះថ្លា សូមព្រះអង្គប្រាប់ ( សេចក្តីនោះ ) ដល់ខ្ញុំព្រះអង្គ ហេតុនោះ ( លោកសួរថា ) ខ្ញុំព្រះអង្គទូលសួរព្រះអង្គ ។ ពាក្យថា បពិត្រព្រះមានព្រះភាគ នេះ គឺពាក្យហៅដោយគោរព ។បេ។ ការបញ្ញត្តិថា មានព្រះភាគនេះ កើតហើយ ព្រោះការត្រាស់ដឹង ។

ពាក្យថា សូមព្រះអង្គប្រាប់សេចក្តីនោះ ដល់ខ្ញុំព្រះអង្គ គឺសូមព្រះអង្គពោល ប្រាប់ សម្តែង បញ្ញត្ត ផ្តើម បើក ចែករំលែក ធ្វើឲ្យរាក់ ប្រកាស ហេតុនោះ ( លោកសួរថា ) បពិត្រព្រះមានព្រះភាគ ខ្ញុំព្រះអង្គទូលសួរព្រះអង្គ សូមព្រះអង្គប្រាប់សេចក្តីនោះ ដល់ខ្ញុំព្រះអង្គ ។ ហេតុនោះ ព្រាហ្មណ៍

នោះពោលថា

( ព្រះបុណ្ណកៈមានអាយុ ក្រាបទូលសួរថា ) យើងខ្ញុំមកដោយត្រូវការ សួរប្រស្នាចំពោះព្រះអង្គ ជាបុគ្គលមិនមានការញាប់ញ័រ ឃើញនូវមូល ចុះពួកមនុស្ស គឺឥសី ក្សត្រ និងព្រាហ្មណ៍ជាច្រើននាក់ ក្នុងលោកនេះ អាស្រ័យអ្វី ទើបបានសម្រេចយញ្ញៈ ដល់ទេវតាទាំងឡាយ បពិត្រព្រះមានព្រះភាគ ខ្ញុំព្រះអង្គទូលសួរព្រះអង្គ សូមព្រះអង្គប្រាប់សេចក្តីនោះ ដល់ខ្ញុំព្រះអង្គ ។

[ ១១៩ ] ( ព្រះមានព្រះភាគត្រាស់ថា ម្នាលបុណ្ណកៈ ) ពួកមនុស្សណានីមួយ គឺឥសី ក្សត្រ និងព្រាហ្មណ៍ជាច្រើននាក់ ក្នុងលោកនេះ សម្រេចយញ្ញៈ ដល់ទេវតាទាំងឡាយ ម្នាលបុណ្ណកៈ ពួកសត្វទាំងនោះ ប្រាថ្នាភពនេះ អាស្រ័យជរា ទើបបានសម្រេចយញ្ញៈឡើង ។

[ ១២០ ] ពាក្យថា ពួកមនុស្ស ណានីមួយ គឺឥសី ត្រង់ពាក្យថា ណានីមួយ គឺសព្វគ្រប់ សព្វទាំងអស់ ឥតសេសសល់ គ្មានសេសសល់ ពាក្យថា ណានីមួយ នេះជាពាក្យប្រមូល ។ ពាក្យថា ឥសី គឺជនទាំងឡាយណានីមួយ ជាអាជីវក និគ្រន្ថ ជដិល តាបស បួសជាឥសី ( ជនទាំងនោះ ) ឈ្មោះថា ឥសី ។ ពួកមនុស្ស លោកហៅថា មនុស្ស ហេតុនោះ ( ទ្រង់ត្រាស់ថា ) ពួកមនុស្សណានីមួយ គឺឥសី ។ ពាក្យថា ម្នាលបុណ្ណកៈ គឺព្រះមានព្រះភាគ ទ្រង់ហៅព្រាហ្មណ៍នោះដោយចំណោះ ។ ពាក្យថា ព្រះមាន

ព្រះភាគ នេះជាពាក្យហៅដោយគោរព ។បេ។ ការបញ្ញត្តិថា មានព្រះភាគ នេះ ( កើតហើយ ) ព្រោះការត្រាស់ដឹង ហេតុនោះ ( មានពាក្យថា ) ព្រះមានព្រះភាគត្រាស់ថា ម្នាលបុណ្ណកៈ ។

[ ១២១ ] ពាក្យថា ក្សត្រ និងព្រាហ្មណ៍ ( សម្រេចយញ្ញៈ ) ដល់ទេវតាទាំងឡាយ ត្រង់ពាក្យថា ក្សត្រ គឺជនទាំងឡាយណានីមួយ មានជាតិជាក្សត្រ ។ ពាក្យថា ព្រាហ្មណ៍ គឺជនទាំងឡាយណានីមួយ ជាភោវាទី ។ ពាក្យថា ដល់ទេវតាទាំងឡាយ គឺពួកអាជីវក ជាទេវតា របស់ពួកសាវកនៃអាជីវក ។បេ។ ទិសទាំងឡាយ ជាទេវតា របស់អ្នកប្រព្រឹត្តវត្តទិស ពួកជនណា ជាទក្ខិណេយ្យបុគ្គល របស់ពួកជនណា ជនទាំងនោះ ជាទេវតារបស់ពួកជននោះ ហេតុនោះ ( ទ្រង់ត្រាស់ថា ) ក្សត្រ និងព្រាហ្មណ៍ ( សម្រេចយញ្ញៈ ) ដល់ទេវតាទាំងឡាយ ។

[ ១២២ ] ពាក្យថា ជាច្រើននាក់ ក្នុងលោកនេះ សម្រេចយញ្ញៈ សេចក្តីថា ទេយ្យធម៌ គឺចីវរ បិណ្ឌបាត សេនាសនៈ គិលានប្បច្ចយ-ភេសជ្ជបរិក្ខារ បាយ ទឹក សំពត់ យាន ផ្កាកម្រង គ្រឿងក្រអូប គ្រឿងលាប ទីដេក ទីសម្នាក់អាស្រ័យ គ្រឿងប្រទីប លោកហៅថា យញ្ញៈ ។ ពាក្យថា សម្រេចយញ្ញៈ សេចក្តីថា សូម្បីជនទាំងឡាយណា ប្រាថ្នារក ស្វែងរក ស្វះស្វែងរក នូវយញ្ញៈ គឺចីវរ បិណ្ឌបាត សេនាសនៈ គិលា-នប្បច្ចយភេសជ្ជបរិក្ខារ បាយ ទឹក សំពត់ យាន ផ្កាកម្រង គ្រឿងក្រអូប គ្រឿងលាប ទីដេក ទីសម្នាក់អាស្រ័យ គ្រឿងប្រទីប ជនទាំងនោះ ឈ្មោះថា

សម្រេចយញ្ញៈ ។ ពាក្យថា ជាច្រើននាក់ គឺយញ្ញៈទាំងនុ៎ះច្រើន ឬពួកអ្នកស្វែងរកយញ្ញៈនោះច្រើន ឬក៏ពួកជនដែលគួរដល់ទក្ខិណានុ៎ះ ច្រើន ។ ពួកយញ្ញៈទាំងនុ៎ះ ច្រើន តើដោយប្រការដូចម្តេច ។បេ។ ពួកជនដែលគួរដល់ទក្ខិណាទាំងនោះ ច្រើនយ៉ាងនេះ ។ ពាក្យថា ក្នុងលោកនេះ គឺក្នុងមនុស្ស-លោក ហេតុនោះ ( ទ្រង់ត្រាស់ថា ) ជាច្រើននាក់ ក្នុងលោកនេះ សម្រេចយញ្ញៈ ។

[ ១២៣ ] អធិប្បាយពាក្យថា ម្នាលបុណ្ណកៈ ( ជនទាំងនោះ ) ប្រាថ្នានូវភាពនេះ ត្រង់ពាក្យថា ប្រាថ្នា គឺប្រាថ្នាការបានចំពោះរូប ប្រាថ្នាការបានចំពោះសំឡេង ប្រាថ្នាការបានចំពោះក្លិន ប្រាថ្នាការបានចំពោះរស ប្រាថ្នាការបានចំពោះផ្សព្វ ប្រាថ្នាការបានចំពោះកូន ប្រាថ្នាការបានចំពោះប្រពន្ធ ប្រាថ្នាការបានចំពោះទ្រព្យ ប្រាថ្នាការបានចំពោះយស ប្រាថ្នាការបានចំពោះភាព ជាឥស្សរៈ ប្រាថ្នាការបានចំពោះអត្តភាព ក្នុងត្រកូលនៃខត្តិយមហាសាល ប្រាថ្នាការបានចំពោះអត្តភាព ក្នុងត្រកូលនៃព្រាហ្មណមហាសាល ប្រាថ្នាការបានចំពោះអត្តភាពក្នុងត្រកូលនៃគហបតិមហាសាល ប្រាថ្នាការបានចំពោះអត្តភាពក្នុងពួកទេវតា ជាន់ចាតុម្មហារាជិកៈ ប្រាថ្នាចង់បានត្រេកអរ បំណង ស្រឡាញ់ជាប់ចិត្ត នូវការបានចំពោះអត្តភាព ក្នុងពួកទេវតាជាន់តាវត្តិង្ស ក្នុងពួកទេវតាជាន់យាមៈ ក្នុងពួកទេវតាជាន់តុសិត ក្នុងពួកទេវតាជាន់និម្មានរតី ក្នុងពួកទេវតាជាន់បរនិម្មិតវសវត្តី ក្នុងពួកទេវតាដែលប្រព្រឹត្តទៅក្នុងពួកនៃព្រហ្ម ហេតុនោះ ( ទ្រង់ត្រាស់ថា ) ប្រាថ្នា ។ ពាក្យថា ម្នាលបុណ្ណកៈ ( ជន

ទាំងនោះប្រាថ្នា ) នូវភាពនេះ សេចក្តីថា ប្រាថ្នាការកើតអត្តភាពក្នុងត្រកូលទាំងនេះ គឺប្រាថ្នាការកើតអត្តភាពក្នុងត្រកូលខត្តិយមហាសាលនេះ ប្រាថ្នាការកើតអត្តភាព ក្នុងត្រកូលព្រាហ្មណមហាសាលនេះ ប្រាថ្នាការកើតអត្តភាពក្នុងត្រកូលគហបតិមហាសាលនេះ ប្រាថ្នាការកើតអត្តភាពក្នុងពួកទេវតាជាន់ចាតុម្មហារាជិកៈនេះ ប្រាថ្នាចង់បាន ត្រេកអរ បំណង ស្រឡាញ់ ជាប់ចិត្តនូវការកើតអត្តភាពក្នុងពួកទេវតាជាន់តាវត្តិង្សនេះ ក្នុងពួកទេវតាជាន់យាមៈនេះ ក្នុងពួកទេវតាជាន់តុសិតនេះ ក្នុងពួកទេវតាជាន់និម្មានរតីនេះ ក្នុងពួកទេវតាជាន់បរនិម្មិតវសវត្តីនេះ ក្នុងពួកទេវតាដែលប្រព្រឹត្តទៅក្នុងពួកព្រហ្មនេះ ហេតុនោះ ( ទ្រង់ត្រាស់ថា ) ម្នាលបុណ្ណកៈ ( ពួកជនទាំងនោះ ) ប្រាថ្នាភាពនេះ ។

[ ១២៤ ] អធិប្បាយពាក្យថា អាស្រ័យជរា ទើបបានសម្រេចយញ្ញឡើង ត្រង់ពាក្យថា អាស្រ័យជរា គឺអាស្រ័យជរា អាស្រ័យព្យាធិ អាស្រ័យមរណៈ អាស្រ័យសោក សេចក្តីខ្សឹកខ្សួល ទុក្ខ សេចក្តីតូចចិត្ត និងសេចក្តីចង្អៀតចង្អល់ សត្វទាំងនោះ អាស្រ័យជាតិ ក្នុងកាលណា សត្វទាំងនោះអាស្រ័យជរា ក្នុងកាលនោះ សត្វទាំងនោះ អាស្រ័យជរា ក្នុងកាលណា សត្វទាំងនោះ អាស្រ័យព្យាធិ ក្នុងកាលនោះ សត្វទាំងនោះ អាស្រ័យព្យាធិ ក្នុងកាលណា សត្វទាំងនោះ អាស្រ័យមរណៈ ក្នុងកាលនោះ សត្វទាំងនោះ អាស្រ័យមរណៈ ក្នុងកាលណា សត្វទាំងនោះ អាស្រ័យសោក សេចក្តីខ្សឹកខ្សួល ទុក្ខ សេចក្តីតូចចិត្ត និងសេចក្តីចង្អៀតចង្អល់ ក្នុងកាលនោះ សត្វ

ទាំងនោះ អាស្រ័យសោក សេចក្តីខ្សឹកខ្សួល ទុក្ខ សេចក្តីតូចចិត្ត និងសេចក្តីចង្អៀតចង្អល់ ក្នុងកាលណា សត្វទាំងនោះ អាស្រ័យគតិ ក្នុងកាលនោះ សត្វទាំងនោះ អាស្រ័យគតិក្នុងកាលណា សត្វទាំងនោះ អាស្រ័យឧបបត្តិក្នុងកាលនោះ សត្វទាំងនោះ អាស្រ័យឧបបត្តិក្នុងកាលណា សត្វទាំងនោះ អាស្រ័យបដិសន្ធិក្នុងកាលនោះ សត្វទាំងនោះ អាស្រ័យបដិសន្ធិក្នុងកាលណា សត្វទាំងនោះ អាស្រ័យភពក្នុងកាលនោះ សត្វទាំងនោះ អាស្រ័យភពក្នុងកាលណា សត្វទាំងនោះ អាស្រ័យសង្សារក្នុងកាលនោះ សត្វទាំងនោះ អាស្រ័យសង្សារក្នុងកាលណា សត្វទាំងនោះ អាស្រ័យវដ្តៈ អាស្រ័យនៅជាប់នៅ ចូលទៅជិតដល់ លិចចុះ ចុះស៊ប់ ក្នុងកាលនោះ ហេតុនោះ ( ទ្រង់ត្រាស់ថា ) អាស្រ័យជរា ទើបសម្រេចយញ្ញៈឡើង ។ ហេតុនោះ ព្រះមានព្រះភាគត្រាស់ថា

( ព្រះមានព្រះភាគ ត្រាស់ថា ម្នាលបុណ្ណកៈ ) ពួកមនុស្សណានីមួយ គឺឥសី ក្សត្រ និងព្រាហ្មណ៍ជាច្រើននាក់ ក្នុងលោកនេះ សម្រេចយញ្ញៈ ដល់ទេវតាទាំងឡាយ ម្នាលបុណ្ណកៈ ពួកសត្វទាំងនោះ ប្រាថ្នាភាពនេះ អាស្រ័យជរា ទើបសម្រេចយញ្ញៈឡើង ។

[ ១២៥ ] ( បុណ្ណកៈមានអាយុទូលសួរដូច្នេះថា ) ពួកមនុស្សណានីមួយ គឺឥសី ក្សត្រ និងព្រាហ្មណ៍ជាច្រើននាក់ ក្នុងលោកនេះ សម្រេចយញ្ញដល់ទេវតាទាំងឡាយ បពិត្រព្រះមានព្រះភាគ

ពួកមនុស្សទាំងនោះ មិនធ្វេសក្នុងផ្លូវយញ្ញៈ បពិត្រព្រះអង្គនិរទុក្ខ ( មនុស្សទាំងនោះ ) ឆ្លងជាតិ និងជរាបានដែរឬ បពិត្រព្រះមានព្រះភាគ ខ្ញុំព្រះអង្គទូលសួរព្រះអង្គ សូមព្រះអង្គប្រាប់សេចក្តីនោះ ដល់ខ្ញុំព្រះអង្គ ។

[ ១២៦ ] ពាក្យថា ណាទីមួយ ក្នុងបទថា ពួកមនុស្សណាទីមួយ គឺឥសី ។បេ។ អធិប្បាយពាក្យថា បពិត្រព្រះមានព្រះភាគ ពួកមនុស្សទាំងនោះ មិនធ្វេសក្នុងផ្លូវយញ្ញៈ ឆ្លងជាតិ និងជរាបានដែរឬ ត្រង់ពាក្យថា ដែរឬ គឺការសួរដោយសង្ស័យ ការសួរដោយសេចក្តីងឿងឆ្ងល់ ការសួរដោយចិត្តបែកជាពីរ ការសួរដោយចំណែកច្រើនថា យ៉ាងនេះឬ មិនមែនទេឬ ដូចម្តេចហ្ន៎ ដោយប្រការដូចម្តេចហ្ន៎ ហេតុនោះ ( លោកសួរថា ) ដែរឬ ។ ពាក្យថា មនុស្សទាំងនោះ បានដល់ ពួកមនុស្សអ្នកបូជាយញ្ញៈ ។ ពាក្យថា មានព្រះភាគ នុ៎ះ ជាពាក្យហៅដោយគោរព ។បេ។ ការបញ្ញត្តិថា មានព្រះភាគនេះ ( កើត ) ព្រោះការត្រាស់ដឹង ហេតុនោះ ( លោកសួរថា ) បពិត្រព្រះមានព្រះភាគ មនុស្សទាំងនោះ ដែរឬ ។ ពាក្យថា មិនធ្វេសក្នុងផ្លូវយញ្ញៈ សេចក្តីថា យញ្ញៈហ្នឹងឯង លោកហៅថា ផ្លូវយញ្ញៈ ។ មគ្គប្រសើរ ផ្លូវប្រសើរ ផ្លូវទេវតា មាគ៌ាព្រហ្ម ផ្លូវព្រហ្ម យ៉ាងណា យញ្ញៈហ្នឹងឯង លោកហៅថា ផ្លូវយញ្ញៈ យ៉ាងនោះឯង ។ ពាក្យថា មិនធ្វេស គឺមិនធ្វេស ធ្វើដោយគោរព ធ្វើរឿយៗ មានកិរិយាធ្វើតាំងមាំ មានកិរិយាប្រព្រឹត្តមិនរួញរា មានឆន្ទៈមិនដាក់ចុះ មានធុរៈមិនដាក់ចុះ ប្រព្រឹត្តក្នុងផ្លូវយញ្ញៈនោះ ច្រើនក្នុងផ្លូវយញ្ញៈ

នោះ ធូន់ក្នុងផ្លូវយញ្ញៈនោះ ឱនទៅក្នុងផ្លូវយញ្ញៈនោះ ទោរទៅក្នុងផ្លូវយញ្ញៈនោះ ញោចទៅក្នុងផ្លូវយញ្ញៈនោះ ចុះស៊ប់ក្នុងផ្លូវយញ្ញៈនោះ មានផ្លូវយញ្ញៈនោះ ជាអធិបតី ហេតុនោះ ( លោកសួរថា ) មិនធ្វេសក្នុងផ្លូវយញ្ញៈ ។ សូម្បីពួកជនណា ស្វែង ស្វះស្វែង ស្វែងរក នូវយញ្ញៈ គឺចីវរ បិណ្ឌបាត សេនាសនៈ គិលានប្បច្ចយភេសជ្ជបរិក្ខារ បាយ ទឹក សំពត់ យាន ផ្កាកម្រង គ្រឿងក្រអូប គ្រឿងលាប ទីដេក ទីសម្នាក់អាស្រ័យ គ្រឿងប្រទីប ជាអ្នកធ្វើដោយគោរព ។បេ។ មានផ្លូវយញ្ញៈនោះជាអធិបតី ជនទាំងនោះ ឈ្មោះថា មិនធ្វេសក្នុងផ្លូវយញ្ញៈ ។ សូម្បីពួកជនណា គាក់តែងយញ្ញៈ គឺចីវរ បិណ្ឌបាត សេនាសនៈ គិលានប្បច្ចយភេសជ្ជបរិក្ខារ បាយ ទឹក សំពត់ យាន ផ្កាកម្រង គ្រឿងក្រអូប គ្រឿងលាប ទីដេក ទីសម្នាក់អាស្រ័យ គ្រឿងប្រទីប ជាអ្នកធ្វើដោយគោរព ។បេ។ មានផ្លូវយញ្ញៈនោះ ជាអធិបតី ជនទាំងនោះ ឈ្មោះថា មិនធ្វេសក្នុងផ្លូវយញ្ញៈ សូម្បីពួកជនណា ឲ្យបូជា លះបង់នូវយញ្ញៈ គឺចីវរ បិណ្ឌបាត សេនាសនៈ គិលានប្បច្ចយភេសជ្ជបរិក្ខារ បាយ ទឹក សំពត់ យាន ផ្កាកម្រង គ្រឿងក្រអូប គ្រឿងលាប ទីដេក ទីសម្នាក់អាស្រ័យ គ្រឿងប្រទីប ជាអ្នកធ្វើដោយគោរព ។បេ។ មានផ្លូវយញ្ញៈនោះ ជាអធិបតី ជនទាំងនោះ ឈ្មោះថា មិនធ្វេសក្នុងផ្លូវយញ្ញៈ ហេតុនោះ ( លោកសួរថា ) បពិត្រព្រះមានព្រះភាគ មនុស្សទាំងនោះ មិនធ្វេសក្នុងផ្លូវយញ្ញៈ ( ឆ្លងជាតិ និងជរាបាន ) ដែរឬ ។

[ ១២៧ ] ពាក្យថា បពិត្រព្រះអង្គនិទ្ទុក្ខ មនុស្សទាំងនោះ ឆ្លងជាតិ

និងជរាបាន ( ដែរឬ ) គឺឆ្លង ឆ្លងឡើង ឆ្លងទូទៅ កន្លងព្រម ប្រព្រឹត្តកន្លង នូវជាតិ ជរា និងមរណៈបាន ( ដែរឬ ) ។ ពាក្យថា បពិត្រព្រះអង្គនិរទុក្ខ នេះ គឺពាក្យជាទីស្រឡាញ់ ជាពាក្យគោរព ពាក្យថា បពិត្រព្រះអង្គនិរទុក្ខ នេះ ជាពាក្យហៅ ដោយគោរព កោតក្រែង ហេតុនោះ ( លោកសួរថា ) បពិត្រព្រះអង្គនិរទុក្ខ មនុស្សទាំងនោះ ឆ្លងជាតិ និងជរាបាន ( ដែរឬ ) ។

[ ១២៨ ] អធិប្បាយពាក្យថា បពិត្រព្រះមានព្រះភាគ ខ្ញុំព្រះអង្គទូល សួរព្រះអង្គ សូមព្រះអង្គប្រាប់សេចក្ដីនោះ ដល់ខ្ញុំព្រះអង្គ ត្រង់ពាក្យថា ខ្ញុំព្រះអង្គទូលសួរព្រះអង្គ គឺខ្ញុំព្រះអង្គទូលសួរព្រះអង្គ អង្វរព្រះអង្គ អារាធនាព្រះអង្គ ញុំាងព្រះអង្គឲ្យជ្រះថ្លា សូមព្រះអង្គប្រាប់ ( សេចក្ដីនោះ ) ដល់ខ្ញុំព្រះអង្គ ហេតុនោះ ( លោកសួរថា ) ខ្ញុំព្រះអង្គទូលសួរព្រះអង្គ ។ ពាក្យថា បពិត្រព្រះមានព្រះភាគ នុ៎ះជាពាក្យហៅដោយគោរព ។បេ។ ការបញ្ញត្តិថា មានព្រះភាគនេះ ( កើត ) ព្រោះការត្រាស់ដឹង ។ ពាក្យថា សូមព្រះអង្គប្រាប់សេចក្ដីនោះដល់ខ្ញុំព្រះអង្គ គឺសូមព្រះអង្គប្រាប់ បង្ហាញ សម្ដែង បញ្ញត្ត តាំងផ្ដើម បើក ចែករំលែក ធ្វើឲ្យរាក់ ប្រកាស ហេតុនោះ ( លោកសួរថា ) បពិត្រព្រះមានព្រះភាគ ខ្ញុំព្រះអង្គទូលសួរព្រះអង្គ សូមព្រះអង្គប្រាប់សេចក្ដីនោះ ដល់ខ្ញុំព្រះអង្គ ។ ហេតុនោះ ព្រាហ្មណ៍នោះ ពោលថា

( បុណ្ណកៈមានអាយុ ទូលសួរដូច្នេះថា ) ពួកមនុស្សណាមួយ
គឺឥសី ក្សត្រ និងព្រាហ្មណ៍ជាច្រើននាក់ ក្នុងលោកនេះ សម្រេច
យញ្ញៈដល់ទេវតាទាំងឡាយ បពិត្រព្រះមានព្រះភាគ ពួកមនុស្ស

ទាំងនោះ មិនធ្វេសក្នុងផ្លូវយញ្ញៈ បពិត្រព្រះអង្គនិរទុក្ខ ( មនុស្ស ទាំងនោះ ) ឆ្លងជាតិ និងជរាបានដែរឬ បពិត្រព្រះមានព្រះភាគ ខ្ញុំព្រះអង្គទូលសួរព្រះអង្គ សូមព្រះអង្គប្រាប់សេចក្តីនោះ ដល់ខ្ញុំព្រះអង្គ ។

[ ១២៩ ] ( ព្រះមានព្រះភាគ ត្រាស់ថា ម្នាលបុណ្ណកៈ ) ជនទាំងឡាយណា ប្រាថ្នា សរសើរ ( ជាប់ចិត្ត ) បូជា ជាប់ចិត្តក្នុងកាម ព្រោះអាស្រ័យលាភ តថាគតពោលថា ជនទាំងនោះ ប្រកបក្នុងបូជា ត្រេកអរក្នុងភវរាគៈ ឆ្លងជាតិ និងជរា មិនបានទេ ។

[ ១៣០ ] អធិប្បាយពាក្យថា ប្រាថ្នា សរសើរ ( ជាប់ចិត្ត ) បូជា ត្រង់ពាក្យថា ប្រាថ្នា គឺប្រាថ្នាការបាននូវរូប ប្រាថ្នាការបាននូវសំឡេង ប្រាថ្នាការបាននូវក្លិន ប្រាថ្នាការបាននូវរស ប្រាថ្នាការបាននូវផស្សព្វ ប្រាថ្នាការបាននូវកូន ប្រាថ្នាការបាននូវប្រពន្ធ ប្រាថ្នាការបាននូវទ្រព្យ ប្រាថ្នាការបាននូវយស ប្រាថ្នាការបាននូវភាពជាឥស្សរៈ ប្រាថ្នាការបាននូវអត្តភាព ក្នុងត្រកូលខត្តិយមហាសាល ប្រាថ្នា ត្រេកអរ បំណង ស្រឡាញ់ នូវការបានចំពោះអត្តភាព ក្នុងត្រកូលនៃព្រាហ្មណមហាសាល ក្នុងត្រកូលនៃគហបតិមហាសាល ក្នុងពួកទេវតាជាន់ចាតុម្មហារាជិកៈ ។បេ។ ក្នុងពួកទេវតាប្រព្រឹត្តទៅក្នុងពួកព្រហ្ម ហេតុនោះ ( ទ្រង់ត្រាស់ថា ) ប្រាថ្នា ។

ពាក្យថា សរសើរ គឺសរសើរយញ្ញៈក្តី សរសើរផលក្តី សរសើរ

ទក្ខិណេយ្យបុគ្គលក្តី ។ សរសើរយញ្ញៈ តើដូចម្តេច ។ ជនទាំងឡាយ សរសើរ សម្តែង ពណ៌នា ស្ងើចថា បុគ្គលឲ្យវត្ថុជាទីស្រឡាញ់ ឲ្យវត្ថុជាទីគាប់ចិត្ត ឲ្យវត្ថុដ៏ថ្លៃថ្លា ឲ្យវត្ថុដ៏គួរ ឲ្យវត្ថុដែលពិចារណា រួចហើយ ឲ្យវត្ថុមិនមានទោស ឲ្យរឿយៗ កាលឲ្យ ក៏ញុំាងចិត្តឲ្យជ្រះថ្លា សរសើរយញ្ញៈយ៉ាងនេះ ។ សរសើរផល តើដូចម្តេច ។ ជនទាំងឡាយ សរសើរ សម្តែងពណ៌នា ស្ងើចថា ព្រោះការឲ្យនេះជាហេតុ នឹងបានរូប នឹងបានសំឡេង នឹងបានក្លិន នឹងបានរស នឹងបានផ្សព្វ នឹងបានអត្តភាពក្នុងត្រកូលនៃខត្តិយ-មហាសាល ក្នុងត្រកូលនៃព្រាហ្មណមហាសាល ។បេ។ ក្នុងពួកទេវតាដែលប្រព្រឹត្តទៅក្នុងពួកព្រហ្ម សរសើរផល យ៉ាងនេះ ។ សរសើរទក្ខិណេយ្យ-បុគ្គល តើដូចម្តេច ។ ជនទាំងឡាយ សរសើរ សម្តែង ពណ៌នា ស្ងើចថា ទក្ខិណេយ្យបុគ្គលទាំងឡាយ ជាអ្នកបរិបូណ៌ដោយជាតិ បរិបូណ៌ដោយគោត្រ ជាអ្នកស្វាធ្យាយ ទ្រទ្រង់មន្ត ដល់នូវត្រើយនៃវេទ ៣ ព្រមទាំងគម្ពីរនិឃណ្ឌុ និងគម្ពីរកេតុភអក្ខរប្បភេទ មានគម្ពីរឥតិហាសៈជាគម្រប់ ៥ ជាអ្នកចេះបទ ជាអ្នកចេះវេយ្យាករណ៍ មិនខ្វះខាត ក្នុងគម្ពីរលោកាយតៈ និងមហាបុរិសលក្ខណៈ ជាអ្នកមានរាគៈទៅប្រាសហើយ ឬប្រតិបត្តិដើម្បីបន្ទោបង់រាគៈ ជាអ្នកមានទោសៈទៅប្រាសហើយ ឬប្រតិបត្តិដើម្បីបន្ទោបង់ទោសៈ មានមោហៈទៅប្រាសហើយ ឬប្រតិបត្តិដើម្បីបន្ទោបង់មោហៈ ជាអ្នកបរិបូណ៌ដោយសទ្ធា បរិបូណ៌ដោយសីល បរិបូណ៌ដោយសមាធិ បរិបូណ៌ដោយប្រាជ្ញា បរិបូណ៌ដោយវិមុត្តិ បរិបូណ៌ដោយវិមុត្តិញាណទស្សនៈ សរសើរ

ទក្ខិណេយ្យបុគ្គល យ៉ាងនេះ ហេតុនោះ ( ទ្រង់ត្រាស់ថា ) ប្រាថ្នា សរសើរ ។

ពាក្យថា ជាប់ចិត្ត គឺជាប់ចិត្តត្រង់ការបានរូប ជាប់ចិត្តត្រង់ការបានសំឡេង ជាប់ចិត្តត្រង់ការបានក្លិន ជាប់ចិត្តត្រង់ការបានរស ជាប់ចិត្តត្រង់ការបានផ្សព្វ ជាប់ចិត្តត្រង់ការបានអត្តភាព ក្នុងត្រកូលនៃខត្តិយមហាសាល ។បេ។ ជាប់ចិត្តត្រង់ការបានអត្តភាព ក្នុងពួកទេវតាដែលប្រព្រឹត្តទៅក្នុងពួកព្រហ្ម ហេតុនោះ ( ទ្រង់ត្រាស់ថា ) ប្រាថ្នា សរសើរ ជាប់ចិត្ត ។

ពាក្យថា បូជា គឺបូជា ឲ្យ លះ បរិច្ចាគ នូវចីវរ បិណ្ឌបាត សេនាសនៈ គិលានប្បច្ចយភេសជ្ជបរិក្ខារ បាយ ទឹក សំពត់ យាន ផ្កាកម្រង គ្រឿងក្រអូប គ្រឿងលាប ទីដេក ទីសម្នាក់អាស្រ័យ គ្រឿងប្រទីប ហេតុនោះ ( ទ្រង់ត្រាស់ថា ) ប្រាថ្នា សរសើរ ជាប់ចិត្ត បូជា ។ ពាក្យថា ព្រះមានព្រះភាគ ( ត្រាស់ថា ) ម្នាលបុណ្ណកៈ ត្រង់ពាក្យថា ម្នាលបុណ្ណកៈ គឺព្រះមានព្រះភាគហៅព្រាហ្មណ៍នោះ ដោយចំណោះ ។ ពាក្យថា មានព្រះភាគ នេះជាពាក្យហៅដោយគោរព ។បេ។ ថាព្រះមានព្រះភាគនេះ ហេតុនោះ ( មានពាក្យថា ) ព្រះមានព្រះភាគត្រាស់ថា ម្នាលបុណ្ណកៈ ។

[ ១៣១ ] ពាក្យថា ជាប់ចិត្តក្នុងកាម ព្រោះអាស្រ័យលាភ គឺជាប់ចិត្តក្នុងកាម ព្រោះអាស្រ័យការបានរូប ជាប់ចិត្តក្នុងកាម ព្រោះអាស្រ័យការបានសំឡេង ។បេ។ ជាប់ចិត្ត ជាប់ចិត្តស៊ប់ ជាប់ជំពាក់ក្នុងកាម ព្រោះអាស្រ័យការបានអត្តភាព ក្នុងពួកទេវតាដែលប្រព្រឹត្តទៅក្នុងពួកព្រហ្ម ហេតុនោះ

( ទ្រង់ត្រាស់ថា ) ជាប់ចិត្តក្នុងកាម ព្រោះអាស្រ័យលាភ ។

[ ១៣២ ] អធិប្បាយពាក្យថា តថាគតពោលថា ជនទាំងនោះ ជាអ្នកប្រកបក្នុងបូជា ត្រេកអរក្នុងភវរាគៈ ឆ្លងជាតិ និងជរាមិនបានទេ ត្រង់ពាក្យថា ជនទាំងនោះ គឺពួកជនអ្នកបូជាយញ្ញៈ ។ ពាក្យថា ប្រកបក្នុងបូជា គឺជាអ្នកប្រកប ប្រកបទូទៅ ប្រកបព្រម ក្នុងបូជាទាំងឡាយ ជាអ្នកប្រព្រឹត្តក្នុងបូជានោះ ច្រើនក្នុងបូជានោះ ធ្ងន់ក្នុងបូជានោះ ឱនទៅក្នុងបូជានោះ ទោរទៅក្នុងបូជានោះ ញោចទៅក្នុងបូជានោះ ចុះស៊ប់ក្នុងបូជានោះ មានបូជានោះ ជាអធិបតី ហេតុនោះ ( ទ្រង់ត្រាស់ថា ) ជនទាំងនោះ ជាអ្នកប្រកបក្នុងបូជា ។ ពាក្យថា ត្រេកអរក្នុងភវរាគៈ សេចក្តីថា តណ្ហា ហៅថា ភវរាគៈ បានខាងសេចក្តីប៉ុនប៉ងក្នុងភព សេចក្តីត្រេកអរក្នុងភព សេចក្តីប្រាថ្នាក្នុងភព ការស្នេហាក្នុងភព សេចក្តីស្រេកឃ្លានក្នុងភព សេចក្តីក្តៅក្រហាយក្នុងភព សេចក្តីជ្រប់ក្នុងភព សេចក្តីចូលចិត្តមាំក្នុងភព ក្នុងភពទាំងឡាយ ជនទាំងឡាយ ត្រេកអរ ធ្លាក់ចុះ ជ្រុលជ្រប់ ងល់ងប់ ជាប់ ជំពាក់ ព័ន្ធព័ទ្ធ ក្នុងភពទាំងឡាយ ដោយសេចក្តីរីករាយក្នុងភព ហេតុនោះ ( ទ្រង់ត្រាស់ថា ) ជនទាំងនោះ ជាអ្នកប្រកបក្នុងការបូជា ត្រេកអរក្នុងភវរាគៈ ។ ពាក្យថា តថាគតពោលថា ជនទាំងនោះ ឆ្លងជាតិ និងជរាមិនបានទេ គឺជនទាំងនោះ ជាអ្នកប្រកបក្នុងបូជា ត្រេកអរក្នុងភវរាគៈ ឆ្លងមិនបាន ឆ្លងឡើងមិនបាន ឆ្លងទូទៅមិនបាន កន្លងព្រមមិនបាន ប្រព្រឹត្តកន្លងមិនបាន នូវជាតិជរា និងមរណៈ មិនចេញ មិនរលាស់ចេញ មិនឈានកន្លង មិនឈានកន្លងព្រម

មិនប្រព្រឹត្តកន្លងចាកជាតិជរា និងមរណៈ រមែងវិលវល់នៅតែខាងក្នុងនៃជាតិ ជរា និងមរណៈ វិលវល់ខាងក្នុងផ្លូវសង្សារ ប្រព្រឹត្តទៅតាមជាតិ ត្រូវជរាជាប់តាម ត្រូវព្យាធិគ្របសង្កត់ ត្រូវមរណៈកម្ចាត់ហើយ គ្មានទីពំនាក់ គ្មានទីជ្រកកោន គ្មានទីពឹង គ្មានទីផ្អែក តថាគតពោល ប្រាប់ សម្តែង បញ្ញត្ត តាំងផ្តើម បើក បែក រំលែក ធ្វើឲ្យរាក់ ប្រកាស ដូច្នេះ ហេតុនោះ ( ទ្រង់ត្រាស់ថា ) ជនទាំងនោះ ជាអ្នកប្រកបក្នុងបូជា ត្រេកអរក្នុងកវាគៈ ឆ្លងជាតិ និងជរាមិនបានទេ ។ ហេតុនោះ ព្រះមានព្រះភាគត្រាស់ថា

( ព្រះមានព្រះភាគ ត្រាស់ថា ម្នាលបុណ្ណកៈ ) ជនទាំងឡាយណា ប្រាថ្នា សរសើរ ( ជាប់ចិត្ត ) លះបង់ ប្រាថ្នាចំពោះនូវកាម ព្រោះអាស្រ័យលាភ តថាគតពោលថា ជនទាំងនោះជាអ្នកប្រកបក្នុងការបូជា ត្រេកអរក្នុងកវាគៈ ឆ្លងជាតិ និងជរាមិនបានទេ ។

[ ១៣៣ ] ( បុណ្ណកៈមានអាយុ ក្រាបទូលសួរដូច្នេះថា ) បពិត្រព្រះអង្គនិទ្ទុក្ខ បើជនជាអ្នកប្រកប ក្នុងការបូជាទាំងនោះ ឆ្លងជាតិ និងជរា ដោយយញ្ញៈមិនបានទេ បពិត្រព្រះអង្គនិទ្ទុក្ខ តើអ្នកណាក្នុងទេវលោក និងមនុស្សលោក អាចឆ្លងជាតិ និងជរាបាន ក្នុងកាលឥឡូវនេះ បពិត្រព្រះមានព្រះភាគ ខ្ញុំព្រះអង្គទូលសួរព្រះអង្គ សូមព្រះអង្គសម្តែងសេចក្តីនោះ ដល់ខ្ញុំព្រះអង្គ ។

[ ១៣៤ ] ពាក្យថា បើជន ជាអ្នកប្រកបក្នុងការបូជាទាំងនោះ ឆ្លងមិនបានទេ សេចក្តីថា ជនជាអ្នកបូជាយញ្ញ ប្រកបក្នុងការបូជា ត្រេកអរក្នុងកវាគៈ ទាំងនោះ មិនឆ្លងចុះ មិនឆ្លងឡើង មិនឆ្លងទូទៅ មិនកន្លងព្រម មិនប្រព្រឹត្តកន្លងបាន នូវជាតិ ជរា និងមរណៈ ជនទាំងនោះ មិនចេញ មិនរលាស់ចេញ មិនឈានកន្លង មិនឈានកន្លងព្រម មិនប្រព្រឹត្តកន្លងចាកជាតិ ជរា និងមរណៈ វិលវល់ខាងក្នុង នៃជាតិ ជរា និងមរណៈ វិលវល់ខាងក្នុងផ្លូវនៃសង្សារ ប្រព្រឹត្តទៅតាមជាតិ ត្រូវជរាជាប់តាម ត្រូវព្យាធិគ្របសង្កត់ ត្រូវមរណៈកម្ចាត់ហើយ គ្មានទីពំនាក់ គ្មានទីជ្រកកោន គ្មានទីពឹងគ្មានទីផ្អែក ហេតុនោះ ( លោកសួរថា ) បើជនជាអ្នកប្រកបក្នុងការបូជាទាំងនោះ ឆ្លងមិនបានទេ ។ ពាក្យថា ដូច្នេះ ក្នុងបទថា បុណ្ណកៈមានអាយុក្រាបទូលសួរ ដូច្នេះ គឺជាបទតក្ជាប់ ។បេ។ បុណ្ណកៈមានអាយុ ។

[ ១៣៥ ] ពាក្យថា បពិត្រព្រះអង្គនិទុក្ខ ( បើជនទាំងឡាយឆ្លង ) ជាតិ និងជរាដោយយញ្ញមិនបានទេ សេចក្តីថា ដោយយញ្ញទាំងឡាយដ៏ច្រើន ដោយយញ្ញទាំងឡាយផ្សេងៗ ដោយយញ្ញដ៏ក្រាស់ក្រែល ។ ពាក្យថា បពិត្រព្រះអង្គនិទុក្ខ គឺជាពាក្យជាទីស្រឡាញ់ ជាពាក្យគោរព ពាក្យថា បពិត្រព្រះអង្គនិទុក្ខ នុ៎ះជាពាក្យសម្រាប់ហៅដោយគោរព កោតក្រែង ហេតុនោះ ( លោកសួរថា ) បពិត្រព្រះអង្គនិទុក្ខ ( បើជនទាំងឡាយឆ្លង ) ជាតិ និងជរាដោយយញ្ញ មិនបានទេ ។

[ ១៣៦ ] ពាក្យថា បពិត្រព្រះអង្គនិទុក្ខ តើអ្នកណា ក្នុងទេវលោក និងមនុស្សលោក ឆ្លងជាតិ និងជរាបាន ក្នុងកាលឥឡូវនេះ សេចក្តីថា តើ

អ្នកណា ក្នុងលោក ព្រមទាំងទេវលោក មារលោក ព្រហ្មលោក ក្នុងពពួកសត្វ ព្រមទាំងសមណព្រាហ្មណ៍ ព្រមទាំងមនុស្សជាសម្មតិទេព និងមនុស្សដ៏សេស ឆ្លងចុះ ឆ្លងឡើង ឆ្លងទូទៅ កន្លងព្រម ប្រព្រឹត្តកន្លង នូវជាតិ ជរា និងមរណៈបាន ។ ពាក្យថា បពិត្រព្រះអង្គនិទ្ទុក្ខ គឺពាក្យជាទីស្រឡាញ់ ជាពាក្យគោរព ពាក្យថា បពិត្រព្រះអង្គនិទ្ទុក្ខនុ៎ះ ជាពាក្យសម្រាប់ហៅដោយគោរព កោតក្រែង ហេតុនោះ ( លោកសួរថា ) បពិត្រព្រះអង្គនិទ្ទុក្ខ តើអ្នកណា ក្នុងទេវលោក និងមនុស្សលោក ឆ្លងជាតិ និងជរាបាន ក្នុងកាលឥឡូវនេះ ។

[ ១៣៧ ] ពាក្យថា បពិត្រព្រះមានព្រះភាគ ខ្ញុំព្រះអង្គទូលសួរព្រះអង្គ សូមព្រះអង្គសម្តែងសេចក្តីនោះ ដល់ខ្ញុំព្រះអង្គ ត្រង់ពាក្យថា ខ្ញុំព្រះអង្គ ទូលសួរព្រះអង្គ គឺខ្ញុំព្រះអង្គទូលសួរព្រះអង្គ អង្វរព្រះអង្គ អារាធនាព្រះអង្គ ញុំាងព្រះអង្គឲ្យជ្រះថ្លា សូមព្រះអង្គប្រាប់សេចក្តីនោះ ដល់ខ្ញុំព្រះអង្គ ហេតុនោះ ( លោកសួរថា ) ខ្ញុំព្រះអង្គទូលសួរព្រះអង្គ ។ ពាក្យថា បពិត្រព្រះមានព្រះភាគ នុ៎ះជាពាក្យសម្រាប់ហៅដោយគោរព ។បេ។ ការបញ្ញត្តិថា ព្រះមានព្រះភាគ នេះ ( កើត ) ព្រោះការត្រាស់ដឹង ពាក្យថា សូមព្រះអង្គសម្តែងសេចក្តីនោះ ដល់ខ្ញុំព្រះអង្គ គឺសូមព្រះអង្គពោល ប្រាប់ សម្តែង បញ្ញត្ត តាំងផ្តើម បើកបង្ហាញ ធ្វើឲ្យរាក់ ប្រកាស ហេតុនោះ ( លោកសួរថា ) បពិត្រព្រះមានព្រះភាគ ខ្ញុំព្រះអង្គទូលសួរព្រះអង្គ សូមព្រះអង្គសម្តែងសេចក្តីនោះ ដល់ខ្ញុំព្រះអង្គ ។ ហេតុនោះ ព្រាហ្មណ៍នោះពោលថា

( បុណ្ណកៈមានអាយុ ក្រាបទូលសួរជួច្នេះថា ) បពិត្រព្រះអង្គនិទុក្ខ បើជនជាអ្នកប្រកបក្នុងការបូជាទាំងនោះ ឆ្លងជាតិ និងជរាដោយយញ្ញមិនបានទេ បពិត្រព្រះអង្គនិទុក្ខ តើអ្នកណា ក្នុងទេវលោក និងមនុស្សលោក ឆ្លងជាតិ និងជរាបាន ក្នុងកាលឥឡូវនេះ បពិត្រព្រះមានព្រះភាគ ខ្ញុំព្រះអង្គទូលសួរព្រះអង្គ សូមព្រះអង្គសម្តែងសេចក្តីនោះ ដល់ខ្ញុំព្រះអង្គ ។

[ ១៣៨ ] ( ព្រះមានព្រះភាគត្រាស់ថា ម្នាលបុណ្ណកៈ ) សេចក្តីញាប់ញ័រ ក្នុងទីនីមួយក្នុងលោក នៃបុគ្គលណា មិនមានទេ ព្រោះដឹងនូវត្រើយនាយ និងត្រើយអាយក្នុងលោក តថាគតពោលថា បុគ្គលនោះ ជាអ្នកស្ងប់ អ្នកកម្ចាត់បង់ អ្នកមិនមានទុក្ខ អ្នកមិនមានប្រាថ្នា អាចឆ្លងជាតិ និងជរាបាន ។

[ ១៣៩ ] ពាក្យថា ព្រោះដឹង នូវត្រើយនាយ និងត្រើយអាយក្នុងលោក សេចក្តីថា ញាណ លោកហៅថា ការដឹង បានខាងបញ្ញា ការដឹងច្បាស់ ។បេ។ ការមិនវង្វេង ការពិចារណាធម៌ សេចក្តីឃើញត្រូវ ។ ពាក្យថា ត្រើយនាយ និងត្រើយអាយ គឺមនុស្សលោក ហៅថា ត្រើយអាយ ទេវ-លោក ហៅថា ត្រើយនាយ កាមធាតុ ហៅថា ត្រើយអាយ រូបធាតុ និងអរូបធាតុ ហៅថា ត្រើយនាយ កាមធាតុ និងរូបធាតុ ហៅថា ត្រើយអាយ អរូបធាតុ ហៅថា ត្រើយនាយ ។ ពាក្យថា ព្រោះដឹងនូវត្រើយនាយ និងត្រើយអាយ ក្នុងលោក គឺព្រោះដឹងនូវត្រើយនាយ និងត្រើយអាយថា មិន

ទៀត ព្រោះដឹង យល់ ថ្លឹង ពិចារណា សម្តែង ធ្វើឲ្យប្រាកដ ថាជាទុក្ខ ជា រោគ ជាបូស ជាសរ ។បេ។ ថា រលាស់ចេញមិនបាន ហេតុនោះ ( ទ្រង់ត្រាស់ថា ) ព្រោះដឹងនូវត្រើយនាយ និងត្រើយអាយ ក្នុងលោក ។ ពាក្យថា ម្នាលបុណ្ណកៈ ក្នុងបទថា ព្រះមានព្រះភាគត្រាស់ថា ម្នាលបុណ្ណកៈ គឺព្រះមានព្រះភាគត្រាស់ហៅព្រាហ្មណ៍នោះដោយចំណោះ ។ ពាក្យថា ព្រះមានព្រះភាគនុ៎ះ ជាពាក្យហៅដោយគោរព ។បេ។ ( ការបញ្ញត្តិ ) ថា ព្រះមានព្រះភាគនេះ ហេតុនោះ ( មានពាក្យថា ) ព្រះមានព្រះភាគត្រាស់ថា ម្នាលបុណ្ណកៈ ។

[ ១៤០ ] ពាក្យថា សេចក្តីញាប់ញ័រ ក្នុងទីនីមួយ ក្នុងលោក នៃបុគ្គលណា មិនមានទេ ត្រង់ពាក្យថា នៃបុគ្គលណា គឺនៃព្រះអរហន្តខីណាស្រព ។ ពាក្យថា សេចក្តីញាប់ញ័រ គឺការញាប់ញ័រដោយតណ្ហា ការញាប់ញ័រដោយទិដ្ឋិ ការញាប់ញ័រដោយកិលេស ការញាប់ញ័រដោយមានះ ការញាប់ញ័រដោយកម្ម ។ ការញាប់ញ័រទាំងនេះ នៃបុគ្គលណាមិនមាន មិនមានព្រម ( បុគ្គលនោះ ) មិនបាន បានលះបង់ កាត់ផ្តាច់ ចូលទៅរម្ងាប់ រម្ងាប់ចំពោះ ធ្វើមិនគួរឲ្យកើតឡើងបាន ដុតដោយភ្លើង គឺញាណហើយ ។ ពាក្យថា ក្នុងទីនីមួយ គឺក្នុងទីនីមួយ តិចតួច ដូចម្តេចខ្លះ ខាងក្នុងក្តី ខាងក្រៅក្តី ទាំងខាងក្នុងខាងក្រៅក្តី ។ ពាក្យថា ក្នុងលោក គឺក្នុងអបាយលោក ។បេ។ ក្នុងអាយតនលោក ហេតុនោះ ( ទ្រង់ត្រាស់ថា ) សេចក្តីញាប់ញ័រ ក្នុងទីនីមួយ ក្នុងលោក នៃបុគ្គលណា មិនមានទេ ។

[ ១៤១ ] អធិប្បាយពាក្យថា តថាគតពោលថា បុគ្គលនោះជាអ្នកស្ងប់ អ្នកកម្ចាត់បង់ អ្នកមិនមានទុក្ខ អ្នកមិនមានប្រាថ្នា អាចឆ្លងជាតិ និងជរាបាន ត្រង់ពាក្យថា ជាអ្នកស្ងប់ គឺឈ្មោះថា អ្នកស្ងប់ ព្រោះស្ងប់រាគៈ ឈ្មោះថា អ្នកស្ងប់ ព្រោះស្ងប់ទោសៈ ឈ្មោះថា អ្នកស្ងប់ ព្រោះស្ងប់មោហៈ ឈ្មោះថា អ្នកស្ងប់ អ្នករម្ងាប់ អ្នករម្ងាប់ឈឹង អ្នករលត់ អ្នករម្ងាប់ចំពោះ ព្រោះស្ងប់ រម្ងាប់ រម្ងាប់ឈឹង រលត់ រម្លត់ ទៅប្រាស រម្ងាប់ចំពោះនូវក្រោធ ការចងក្រោធទុក សេចក្តីលុបគុណ ការវាយឫកស្មើ សេចក្តីប្រណែន កំណាញ់ កិច្ចកល សេចក្តីអួតអាង សេចក្តីរឹងត្អឹង ការប្រណាំងប្រជែង មានះ សេចក្តីមើលងាយ សេចក្តីស្រវឹង សេចក្តីប្រហែស កិលេសទាំងពួង ទុច្ចរិតទាំងពួង សេចក្តីក្រវល់ក្រវាយទាំងពួង សេចក្តីក្រហល់ក្រហាយទាំងពួង សេចក្តីក្តៅក្រហាយទាំងពួង អភិសង្ខារជាអកុសលទាំងពួង ហេតុនោះ ( ទ្រង់ត្រាស់ថា ) ជាអ្នកស្ងប់ ។ ពាក្យថា អ្នកកម្ចាត់បង់ គឺអ្នកកម្ចាត់បង់ ផ្ចុំចេញ ធ្វើឲ្យរីងស្ងួត ធ្វើឲ្យវិនាសនូវកាយទុច្ចរិត អ្នកកម្ចាត់បង់ ផ្ចុំចេញ ធ្វើឲ្យរីងស្ងួត ធ្វើឲ្យវិនាសនូវវចីទុច្ចរិត នូវមនោទុច្ចរិត អ្នកកម្ចាត់បង់ ផ្ចុំចេញ ធ្វើឲ្យរីងស្ងួត ធ្វើឲ្យវិនាសនូវរាគៈ អ្នកកម្ចាត់បង់ ផ្ចុំចេញ ធ្វើឲ្យរីងស្ងួត ធ្វើឲ្យវិនាសនូវទោសៈ មោហៈ ក្រោធ ការចងក្រោធទុក សេចក្តីលុបគុណ ការវាយឫកស្មើ សេចក្តីប្រណែន សេចក្តីកំណាញ់ កិច្ចកល សេចក្តីអួតអាង សេចក្តីរឹងត្អឹង ការប្រណាំងប្រជែង មានះ សេចក្តីមើលងាយ សេចក្តីស្រវឹង និងសេចក្តីប្រហែស អ្នកកម្ចាត់បង់ ផ្ចុំចេញ ធ្វើឲ្យរីងស្ងួត ធ្វើឲ្យវិនាសនូវ

កិលេសទាំងពួង ទុច្ចរិតទាំងពួង សេចក្ដីក្រវល់ក្រវាយទាំងពួង សេចក្ដីក្រហល់ក្រហាយទាំងពួង សេចក្ដីក្ដៅក្រហាយទាំងពួង អភិសង្ខារជាអកុសលទាំងពួង មួយទៀត ក្រោធ លោកពោលថា ផ្សែង ។

ម្នាលព្រាហ្មណ៍ សេចក្ដីពិតថា មានះរបស់អ្នក ទុកជាអម្រែកដ៏ធ្ងន់ សេចក្ដីក្រោធ ទុកជាផ្សែង ការពោលពាក្យកុហក ទុកជាផេះ អណ្ដាត ទុកជាវែក ហឫទ័យរបស់អ្នកដែលយកចិត្តទុកដាក់ ទុកជាកន្លែងភ្លើង ខ្លួនដែលទូន្មានល្អហើយ ទុកជាជាតិរបស់បុរស ។

មួយទៀត ការក្រោធ កើតដោយអាការ ១០ គឺក្រោធកើតដោយគិតថា គេបានប្រព្រឹត្តអំពើមិនជាប្រយោជន៍ដល់អញ ១ ក្រោធកើតដោយគិតថា គេកំពុងប្រព្រឹត្តអំពើមិនជាប្រយោជន៍ដល់អញ ១ ក្រោធកើតដោយគិតថា គេនឹងប្រព្រឹត្តអំពើមិនជាប្រយោជន៍ដល់អញ ១ ក្រោធកើតដោយគិតថា គេបានប្រព្រឹត្តអំពើមិនជាប្រយោជន៍ ១ ថា កំពុងប្រព្រឹត្តអំពើមិនជាប្រយោជន៍ ១ ថា នឹងប្រព្រឹត្តអំពើមិនជាប្រយោជន៍ដល់សត្វ និងសង្ខារជាទីស្រឡាញ់ ជាទីពេញចិត្តនៃអញ ១ ក្រោធកើតដោយគិតថា គេបានប្រព្រឹតប្រយោជន៍ ១ ថា កំពុងប្រព្រឹត្តប្រយោជន៍ ១ ថា នឹងប្រព្រឹត្តប្រយោជន៍ដល់សត្វ និងសង្ខារមិនជាទីស្រឡាញ់ មិនជាទីពេញចិត្តនៃអញ ១ ឬសេចក្ដីក្រោធកើតក្នុងទីមិនគួរ ១ ។ សេចក្ដីគំនុំ ការគុំកួន ការថ្នាំងថ្នាក់ ការតានតឹងនៃចិត្ត សេចក្ដីខឹង ការខឹងខ្លាំង ការខឹងក្រៃលែង ទោសៈ ទោសៈខ្លាំង

ទោសៈក្រៃលែង ការព្យាបាទនៃចិត្ត ការប្រទូស្តរ៉ាយក្នុងចិត្ត ការក្រោធ អាការក្រោធ ភាពនៃការក្រោធ ការប្រទូស្ត អាការប្រទូស្ត ភាពនៃការប្រទូស្ត ការព្យាបាទ អាការព្យាបាទ ភាពនៃការព្យាបាទ សេចក្តីខឹង ការខឹងខ្លាំង សេចក្តីកាច ការញ៉ាំងទឹកភ្នែកឲ្យហូរធ្លាក់ សេចក្តីមិនរីករាយនៃចិត្ត ឯណា មានសភាពយ៉ាងនេះ នេះហៅថា ការក្រោធ ។ មួយទៀត បណ្ឌិតគប្បីដឹងថា ក្រោធប្រមាណច្រើន និងតិច ។ ក្នុងកាលខ្លះ ក្រោធគ្រាន់តែធ្វើចិត្តឲ្យល្អក់ តែមិនទាន់ធ្វើមុខឲ្យក្រញូវនៅឡើយក៏មាន ។ ក្នុងកាលខ្លះ ក្រោធគ្រាន់តែធ្វើមុខឲ្យក្រញូវ តែមិនទាន់ញ៉ាំងចង្កាឲ្យកម្រើកនៅឡើយក៏មាន ។ ក្នុងកាលខ្លះ ក្រោធគ្រាន់តែញ៉ាំងចង្កាឲ្យកម្រើក តែមិនទាន់បញ្ចេញវាចាអាក្រក់នៅឡើយក៏មាន ។ ក្នុងកាលខ្លះ ក្រោធគ្រាន់តែបញ្ចេញវាចាអាក្រក់ តែមិនទាន់ក្រឡេកមើលទិសតូច និងទិសធំនៅឡើយក៏មាន ។ ក្នុងកាលខ្លះ ក្រោធគ្រាន់តែក្រឡេកមើលទិសតូច និងទិសធំ តែមិនទាន់ចាប់កាន់ដំបង និងកាំបិតនៅឡើយក៏មាន ។ ក្នុងកាលខ្លះ ក្រោធគ្រាន់តែចាប់កាន់ដំបង និងកាំបិត តែមិនទាន់ងារឡើងនូវដំបង និងកាំបិតនៅឡើយក៏មាន ។ ក្នុងកាលខ្លះ ក្រោធគ្រាន់តែងារឡើងនូវដំបង និងកាំបិត តែមិនទាន់សំពងកាប់ដោយដំបង និងកាំបិតនៅឡើយក៏មាន ។ ក្នុងកាលខ្លះ ក្រោធគ្រាន់តែសំពងកាប់ដោយដំបង និងកាំបិត តែមិនទាន់ធ្វើឲ្យធ្លុះធ្លាយ ដាច់ដាចនៅឡើយក៏មាន ។ ក្នុងកាលខ្លះ ក្រោធគ្រាន់តែធ្វើឲ្យធ្លុះធ្លាយដាច់ដាច តែមិនទាន់បំបាក់បំបែកនៅឡើយក៏មាន ។ ក្នុងកាលខ្លះ ក្រោធគ្រាន់តែបំបាក់បំបែក តែមិនទាន់អូស

ទាញមកនូវអវយវៈតូច និងអវយវៈធំនៅឡើយក៏មាន ។ ក្នុងកាលខ្លះ ក្រោធគ្រាន់តែទាញកន្ទ្រាក់មកនូវអវយវៈតូច និងអវយវៈធំ តែមិនទាន់ញុំាងជីវិតឲ្យវិនាសនៅឡើយក៏មាន ។ ក្នុងកាលខ្លះ ក្រោធគ្រាន់តែញុំាងជីវិតឲ្យវិនាស តែមិនទាន់តាំងនៅក្នុងការលះ និងការបរិច្ចាគ(ជីវិត) ទាំងអស់គ្នានៅឡើយក៏មាន ។ ក្នុងកាលណា បុគ្គលអ្នកក្រោធសម្លាប់បុគ្គលដទៃ ហើយសម្លាប់ខ្លួន ក្នុងកាលនោះ ក្រោធក៏ដល់នូវសភាពដ៏ចម្រើនក្រៃលែង ដល់នូវសភាពដ៏ទូលំទូលាយដ៏ក្រៃលែង ដោយហេតុមានប្រមាណប៉ុណ្ណោះ ។ ក្រោធនុ៎ះដែលបុគ្គលណាបានលះបង់ កាត់ផ្តាច់ ចូលទៅរម្ងាប់ រម្ងាប់ចំពោះ ធ្វើមិនគួរឲ្យកើតឡើងបាន ដុតដោយភ្លើង គឺញាណហើយ បុគ្គលនោះ ហៅថា អ្នកកម្ចាត់បង់ ។ បុគ្គលនោះ ឈ្មោះថា អ្នកកម្ចាត់បង់ ព្រោះលះក្រោធហើយ ឈ្មោះថា អ្នកកម្ចាត់បង់ ព្រោះកំណត់ដឹងនូវវត្ថុក្រោធហើយ ឈ្មោះថា អ្នកកម្ចាត់បង់ ព្រោះកាត់ផ្តាច់នូវហេតុនៃក្រោធ ហេតុនោះ ( ទ្រង់ត្រាស់ថា ) អ្នកកម្ចាត់បង់ ។ ពាក្យថា អ្នកមិនមានទុក្ខ សេចក្តីថា រាគៈជាទុក្ខ ទោសៈជាទុក្ខ មោហៈ ជាទុក្ខ ក្រោធ ជាទុក្ខ ការចងក្រោធទុក ជាទុក្ខ ។បេ។ អភិសង្ខារជាអកុសលទាំងពួង ជាទុក្ខ ។ ទុក្ខទាំងនុ៎ះ បុគ្គលណា លះបង់ កាត់ផ្តាច់ចូលទៅរម្ងាប់ រម្ងាប់ចំពោះ ធ្វើមិនគួរឲ្យកើតឡើងបាន ដុតដោយភ្លើង គឺញាណហើយ បុគ្គលនោះ លោកហៅថា អ្នកមិនមានទុក្ខ ។ ពាក្យថា អ្នកមិនមានសេចក្តីប្រាថ្នា សេចក្តីថា តណ្ហា ហៅថា សេចក្តីប្រាថ្នា បានដល់ សេចក្តីរីករាយ សេចក្តីរីករាយខ្លាំង ។បេ។ អភិជ្ឈា លោភៈ អកុ-

សលមូល ។ តណ្ហា គឺការប្រាថ្នានុំៈ បុគ្គលណា លះបង់ កាត់ផ្តាច់ ចូល ទៅរម្ងាប់ រម្ងាប់ចំពោះ ធ្វើមិនគួរឲ្យកើតឡើងបាន ដុតដោយភ្លើង គឺញាណ ហើយ បុគ្គលនោះ លោកហៅថា អ្នកមិនមានសេចក្តីប្រាថ្នា ។ ពាក្យថា ជាតិ បានដល់ ការកើត ការកើតព្រម កិរិយាឈានចុះ ការកើត ការកើតចំពោះ ការកើតប្រាកដនៃខន្ធទាំងឡាយ ការបានចំពោះនូវអាយតនៈទាំងឡាយ នៃ សត្វទាំងឡាយនោះៗ ក្នុងពួកនៃសត្វនោះៗ ។ ពាក្យថា ជរា គឺការចាស់ ភាពនៃសេចក្តីគ្រាំគ្រា ភាពនៃធ្មេញបាក់ ភាពនៃសក់ស្កូវ ភាពនៃស្បែក ជ្រួញជ្រីវ សេចក្តីសាបសូន្យនៃអាយុ សេចក្តីចាស់ជុំវិញនៃឥន្ទ្រិយ នៃសត្វ ទាំងឡាយនោះៗ ក្នុងពួកនៃសត្វនោះៗ ។ ពាក្យថា តថាគតពោលថា បុគ្គល នោះ ជាអ្នកស្ងប់ អ្នកកម្ចាត់បង់ អ្នកមិនមានទុក្ខ អ្នកមិនមានសេចក្តីប្រាថ្នា អាចឆ្លងជាតិ និងជរាបាន បានសេចក្តីថា តថាគតពោល ប្រាប់ សម្តែង បញ្ញត្ត តាំងផ្តើម បើក ចែក ធ្វើឲ្យរាក់ ប្រកាសថា បុគ្គលណា ជាអ្នក ស្ងប់ផង អ្នកកម្ចាត់បង់ផង អ្នកមិនមានទុក្ខផង អ្នកមិនមានសេចក្តីប្រាថ្នាផង បុគ្គលនោះ បានឆ្លង ឆ្លងឡើង ឆ្លងរំលង ផ្លោះកន្លង លោតរំលង នូវជាតិ ជរា និងមរណៈបាន ហេតុនោះ ( ទ្រង់ត្រាស់ថា ) តថាគតពោលថា បុគ្គល នោះ ជាអ្នកស្ងប់ អ្នកកម្ចាត់បង់ អ្នកមិនមានទុក្ខ អ្នកមិនមានសេចក្តីប្រាថ្នា អាចឆ្លងជាតិ និងជរាបាន ។ ហេតុនោះ ព្រះមានព្រះភាគត្រាស់ថា

( ព្រះមានព្រះភាគ ទ្រង់ត្រាស់ថា ម្នាលបុណ្ណកៈ ) សេចក្តី
ញាប់ញ័រ ក្នុងទីនីមួយ ក្នុងលោក នៃបុគ្គលណា មិនមានទេ

ព្រោះដឹងនូវត្រើយនាយ និងត្រើយអាយ ក្នុងលោក តថាគត ពោលថា បុគ្គលនោះ ជាអ្នកស្ងប់ អ្នកកម្ចាត់បង់ អ្នកមិនមាន ទុក្ខ អ្នកមិនមានសេចក្តីប្រាថ្នា អាចឆ្លងជាតិ និងជរាបាន ។

ក្នុងពេលដែលចប់ព្រះគាថា ។បេ។ បុណ្ណកៈមានអាយុ អង្គុយប្រណម្យអញ្ជលី នមស្ការព្រះមានព្រះភាគ ពោលថា បពិត្រព្រះអង្គដ៏ចម្រើន ព្រះមានព្រះភាគ ជាសាស្តានៃខ្ញុំព្រះអង្គ ខ្ញុំព្រះអង្គជាសាវ័ក ។

បុណ្ណកមាណវកបញ្ហានិទ្ទេសទី ៣ ចប់

# អដ្ឋកថា

## បុណ្ណកមាណវកប្បបញ្ហានិទ្ទេស

គប្បីជ្រាបវិនិច្ឆ័យក្នុងបុណ្ណកសុត្តនិទ្ទេសទី ៣ ដូចតទៅ

[ ១១២ ] បទថា **អនេជំ** នេះ បុណ្ណកមាណពក្រាបទូលហើយ ព្រោះព្រះមានព្រះភាគ ទ្រង់ហាមមោឃរាជ ត្រាស់ហើយ ដោយន័យមុន នោះឯង ។

ក្នុងបទទាំងនោះ បទថា **មូលទស្សាវី** បានដល់ ជាអ្នកឃើញឫសគល់ របស់អកុសល ។ បទថា **ឥសយោ** បានដល់ ជដិលទាំងឡាយ មានឈ្មោះ ថា **ឥសី**។ បទថា **យញ្ញំ** បានដល់ ទេយ្យធម៌ ។ បទថា **អកប្បីសុ** បាន ដល់ ស្វែងរក ។ បទទាំងអស់ មានពាក្យថា **ហេតុទស្សាវី** ជាដើម ជា វេវចនៈនៃការណៈនោះឯង ព្រោះការណៈ រមែងទៅ រមែងប្រព្រឹត្តទៅដើម្បី ផលរបស់ខ្លួន ដូច្នោះ ទើបហៅថា ហេតុ ។ ព្រោះការណៈ រមែងប្រគល់ ឲ្យនូវផលនោះ ដូចតាំងចិត្តថា អញ្ជើញពួកអ្នកទទួលផលនោះចុះ ដូច្នោះ ទើបហៅថា និទាន ។ ៥ បទ មានបទថា **សម្ភវទស្សាវី** ជាដើម មានន័យ ដូចសម្តែងហើយខាងដើមនោះឯង ។ ព្រោះការណៈនោះ អាស្រ័យផលនោះ រមែងប្រព្រឹត្តទៅ ទើបផលនោះកើត គឺកើតឡើងអំពីហេតុនោះ ដូច្នោះទើប ហៅថា បច្ច័យ និងសមុទ័យ ។

វេមានិកប្រេតដែលមានសក្តិតូច មានឧត្តរមាតាយក្ខិនីជាដើម ដែល ផុតចាកអបាយ ៤ និងមនុស្សកំព្រាដែលអត់អាហារ និងរកគ្រឿងស្លៀក ដណ្តប់បានលំបាក ត្រូវទុក្ខបៀតបៀន គប្បីជ្រាបថា ឬក៏ពួកសុគតិណាទីមួយ

សូម្បីដទៃ ( ប្រាកដ ) ស្តេចយម នាគ គ្រុឌ ប្រេត ដែលមានឫទ្ធិច្រើន គប្បីជ្រាបថា ឬក៏ពួកទុគ្គតិឯណានីមួយ សូម្បីដទៃ ( ប្រាកដ ) ។ បទថា **អត្តភាវាភិនិព្វត្តិយា** បានដល់ ដើម្បីបានអត្តភាពដោយអំណាចបដិសន្ធិក្នុង ៣ ឋានៈ ។ បទថា **ជានាតិ** បានដល់ ទ្រង់ដឹងដោយសព្វញ្ញុតញ្ញាណ ។ បទថា **បស្សតិ** បានដល់ ទ្រង់ឃើញដោយសមន្តចក្ខុ ។ បទថា **អកុសលា** បានដល់ ដែលកើតអំពីការមិនឈ្លាស ។ ឈ្មោះថា **អកុសលាភាគិយា** ព្រោះសេពធម៌ដែលជាអកុសល ។ ឈ្មោះថា **អកុសលបក្ខិកា** ព្រោះមានក្នុងចំណែកអកុសល ។ ធម៌ទាំងអស់នោះ ឈ្មោះថា **អវិជ្ជាមូលកា** ព្រោះអវិជ្ជាជាមូល គឺហេតុនៃធម៌ទាំងនោះ ។ ឈ្មោះថា **អវិជ្ជាសមោសរណា** ព្រោះរួមចុះ គឺប្រជុំចុះទៅដោយត្រង់ក្នុងអវិជ្ជា ។ បទថា **អវិជ្ជាសមុគ្ឃាតា** បានដល់ ព្រោះអវិជ្ជាត្រូវអរហត្តមគ្គទម្លាយហើយ ។ បទថា **សព្វេ តេ សមុគ្ឃាតំ គច្ឆន្តិ** បានដល់ អកុសលធម៌ដូចពោលហើយ ទាំងអស់នោះ ត្រូវកម្ចាត់ទៅ ។

ក្នុងបទថា **អប្បមាទមូលកា** មានវិគ្គហៈថា ឈ្មោះថា **អប្បមាទមូលកា** ព្រោះមានការមិនប្រមាទ គឺការមិននៅប្រាសចាកសតិជាមូល ។ ឈ្មោះថា **អប្បមាទសមោសរណា** ព្រោះរួមចុះ គឺប្រព្រឹត្តទៅក្នុងការមិនប្រមាទដោយប្រពៃ ។ បទថា **អប្បមាទោ តេសំ ធម្មានំ អគ្គមក្ខាយតិ** សេចក្តីថា ការមិនប្រមាទឯង ប្រព្រឹត្តទៅក្នុងកាមាវចរ ក៏ឈ្មោះថា ជាកំពូល ព្រោះជាទីតាំងនៃធម៌ដែលប្រព្រឹត្តទៅក្នុងភូមិ ៤ ។

[ ១១៤ ] បទថា **អលមត្តោ** បានដល់ ជាអ្នកអាច ។ បទថា **មយា បុច្ឆិតំ** បានដល់ បញ្ហាដែលខ្ញុំព្រះអង្គទូលសួរហើយ ។ បទថា **វិហាស្សេតំ ភារំ**[១] បានដល់ សូមទ្រង់ដោះភារៈដែលនាំមកហើយនោះចុះ ។

[ ១១៥ ] បទថា **យេកេចិ ឥសិបព្វជ្ជំ បព្វជិតា** នេះ បាឋៈថា **ឥសិបព្វជ្ជា បព្វជិតា** ដូច្នេះក៏មាន ។

[ ១១៦ ] បទថា **អាជីវកសាវកានំ អាជីវកា ទេវតា** សេចក្ដីថា ជនពួកណាស្ដាប់កាន់យកនូវពាក្យរបស់អាជីវក ជនទាំងនោះ ឈ្មោះថា ជាសាវករបស់អាជីវក ។ របស់សាវកអាជីវកទាំងនោះ ។ ពួកអាជីវកនោះរមែងទទួលទេយ្យធម៌របស់សាវកទាំងនោះ ទើបអាជីវកទាំងនោះជាទេវតា ។ ក្នុងបទទាំងពួងក៏យ៉ាងនេះដូចគ្នា ។ បទថា **យេ យេសំ ទក្ខិណេយ្យា** សេចក្ដីថា អាជីវកជាដើម ទិសជាទីបំផុតពួកណា ជាអ្នកសមគួរដល់ទេយ្យធម៌របស់ក្សត្រជាដើមពួកណា ។ បទថា **តេ តេសំ ទេវតា** បានដល់ អាជីវកជាដើមទាំងនោះ ក៏ជាទេវតារបស់ក្សត្រទាំងនោះជាដើម ។

[ ១១៧ ] បទថា **យេបិ យញ្ញំ ឯសន្តិ** បានដល់ ប្រាថ្នាទេយ្យធម៌ ។ បទថា **គវេសន្តិ** បានដល់ ពិនិត្យមើល ។ បទថា **បរិយេសន្តិ** បានដល់ ឲ្យកើតឡើង ។ បទថា **យញ្ញា វា ឯតេ ពហូ** បានដល់ យញ្ញទាំងនោះឯងក៏មានច្រើន ។ បទថា **យញ្ញយាជកា វា ឯតេ ពហូ** បានដល់ អ្នកបូជាទេយ្យធម៌ទាំងនោះក៏ច្រើន ។ បទថា **ទក្ខិណេយ្យា វា ឯតេ ពហូ** បាន

---

១- បិដកខ្មែរ ជា សន្ទស្សេតុំ កណិតុំ ។

ដល់ ទក្ខិណេយ្យបុគ្គលទាំងនោះដែលសមគួរដល់ទេយ្យធម៌ក៏ច្រើនដូចគ្នា ។ ដើម្បីទ្រង់សម្តែងដល់យញ្ញទាំងនោះដោយពិស្តារ ទើបព្រះមានព្រះភាគទ្រង់សម្តែងដោយពិស្តារដោយន័យជាដើមថា **កច្ចិ យញ្ញោ វា ឃតេ បុច្ឆ** ដូច្នេះ ។

[ ១១៩ ] បទថា **អាសឹសមានា** បានដល់ ប្រាថ្នារូបជាដើម ។ បទថា **ឥត្ថត្តំ** បានដល់ ប្រាថ្នានូវភាពយ៉ាងនេះ អធិប្បាយថា ប្រាថ្នាភាពជាមនុស្សជាដើម ។ បទថា **ជរំ សិតា** បានដល់ អាស្រ័យជរា ។ ក្នុងបទនេះ ព្រះមានព្រះភាគត្រាស់ដល់ទុក្ខក្នុងវដ្តៈទាំងអស់ ដោយលើកជរាជាធំ ។ ដោយបទនោះ ព្រះមានព្រះភាគទ្រង់សម្តែងថា ឥសីជាដើម អាស្រ័យទុក្ខក្នុងវដ្តៈ កាលមិនផុតចាកទុក្ខនោះ ទើបស្វែងរក ។

[ ១២៣ ] បទថា **រូបប្បដិលាភំ អាសឹសមានា** បានដល់ ប្រាថ្នាបាននូវសម្បត្តិដែលជាប្រកពកើតនៃវណ្ណៈ ។ ក្នុងសំឡេងជាដើម ក៏មានន័យនេះដូចគ្នា ។ បទថា **ខត្តិយមហាសាលកុលេ អត្តភាវប្បដិលាភំ** សេចក្តីថា ប្រាថ្នាបាននូវអត្តភាព គឺបដិសន្ធិក្នុងត្រកូលខត្តិយមហាសាល ដែលដល់ព្រមដោយសម្បត្តិ ។ ក្នុងបទថា **ព្រាហ្មណមហាសាលកុលេ** ជាដើម ក៏មានន័យនេះដូចគ្នា ។ ក្នុងបទថា **ព្រហ្មកាយិកេសុ ទេវេសុ** នេះ ព្រះអង្គត្រាស់សំដៅដល់ចំណែកខាងដើម ។ បទថា **ឯត្ថ** បានដល់ ក្នុងត្រកូលក្សត្រជាដើម ។

[ ១២៤ ] បទថា **ជរំ និស្សិតា** បានដល់ អាស្រ័យនូវការចាស់ ។ ក្នុង

បទថា **ព្យាធិនិស្សិតា** ជាដើម ក៏មានន័យនេះដូចគ្នា ។ ដោយបទទាំងនេះ ឈ្មោះថា ទ្រង់សម្តែងគ្របដណ្តប់ដល់ទុក្ខក្នុងវដ្តៈទាំងអស់ ។

[ ១២៥ ] យញ្ញនោះឯង គឺផូវយញ្ញ ក្នុងបទនេះថា បពិត្រព្រះមានព្រះភាគ ពួកមនុស្សទាំងនោះ មិនធ្វេសក្នុងផ្លូវយញ្ញ បពិត្រព្រះអង្គនិរទុក្ខ ( មនុស្សទាំងនោះ ) ឆ្លងជាតិ និងជរាបានដែរឬ ។ សេចក្តីនេះ មានអធិប្បាយថា អ្នកបូជាយញ្ញទាំងនោះ មិនប្រមាទហើយក្នុងយញ្ញ ប្រាថ្នាយញ្ញ បានឆ្លងផុតទុក្ខក្នុងវដ្តៈខ្លះឬ ។

[ ១២៦ ] បទថា **យេបិ យញ្ញំ ឥទ្ធិ យជន្តិ** បានដល់ បូជាយញ្ញដោយការឲ្យទេយ្យធម៌ ។ បទថា **បរិច្ចជន្តិ** បានដល់ លះបង់ ។

[ ១២៩ ] បទថា **អាសីសន្តិ** បានដល់ ប្រាថ្នាបានរូបជាដើម ។ បទថា **ថោមយន្តិ** បានដល់ សរសើរយញ្ញដោយន័យជាដើមថា ទានដែលឲ្យហើយ រមែងមានផល ។ បទថា **អភិជប្បន្តិ** បានដល់ ពោលវាចាដើម្បីបានរូបជាដើម ។ បទថា **ជុហន្តិ** បានដល់ រមែងឲ្យ ។ បទថា **កាមាភិ-ជប្បន្តិ បដិច្ច លាភំ** បានដល់ អាស្រ័យការបានរូបជាដើម រមែងខ្សឹកខ្សួលដល់កាមទាំងឡាយនោះឯងរឿយៗ គឺពោលថា ធ្វើម្តេចហ្ន៎ កាមទាំងឡាយគប្បីមានដល់អញខ្លះ ។ មានពាក្យអធិប្បាយថា បន្ថែមតណ្ហាក្នុងកាមនោះ ។ បទថា **យាជយោគា** បានដល់ រមែងបង្អោនទៅក្នុងការបូជា ។ បទថា **ភវរាគរត្តា** បានដល់ ត្រេកអរហើយដោយភវរាគៈនោះឯង ដោយសេចក្តីសង្ខេបជាដើមទាំងនេះយ៉ាងនេះ ជាអ្នកត្រេកអរហើយក្នុងភវរាគៈ ធ្វើនូវការ

សន្សឹមជាដើមនេះ ។ បទថា **ឆាតកីសុ** បានដល់ មិនផុតទុក្ខក្នុងវដ្តៈ មានជាតិជាដើម ។

[ ១៣០ ] បទថា **យញ្ញំ វា ថោមេន្តិ** បានដល់ ជនទាំងឡាយ រមែងសរសើរការឲ្យ ។ បទថា **ដលំ វា** បានដល់ ការបានរូបជាដើម ។ បទថា **ទក្ខិណេយ្យំ វា** បានដល់ ក្នុងទក្ខិណេយ្យបុគ្គលដែលសម្បូរដោយជាតិជាដើម ។ បទថា **សុចឹ ទិន្នំ** បានដល់ ធ្វើឲ្យស្អាតហើយឲ្យ ។ បទថា **មនាបំ** បានដល់ របស់ញ៉ាំងចិត្តឲ្យចម្រើន ។ បទថា **បណីតំ** បានដល់ របស់មានរសឆ្ងាញ់ ។ បទថា **កាលេន** បានដល់ ក្នុងកាលដែលដល់ព្រមហើយនោះៗ ។ បទថា **កប្បិយំ** បានដល់ វៀរនូវវត្ថុដែលជាអកប្បិយហើយឲ្យ ។ បទថា **អនវជ្ជំ** បានដល់ មិនមានទោស ។ បទថា **អភិណ្ហំ** បានដល់ រឿយៗ ។ បទថា **ទទំ ចិត្តំ បសាទិតំ** បានដល់ កាលឲ្យ ចិត្តខណៈបរិច្ចាគក៏ផូរផង់ ។ បទថា **ថោមេន្តិ កិត្តេន្តិ** បានដល់ រមែងធ្វើគុណឲ្យប្រាកដ ។ បទថា **វណ្ណេន្តិ** បានដល់ រមែងពោលសរសើរ ។ បទថា **បសំសន្តិ** បានដល់ រមែងឲ្យដល់នូវការជ្រះថ្លា ។ បទថា **ឥតោ និទានំ** បានដល់ ព្រោះឲ្យហើយអំពីមនុស្សលោកនេះជាហេតុ ។ បទថា **អជ្ឈាយកា** បានដល់ រាយមន្ត ។ បទថា **មន្តធរា** បានដល់ ទ្រទ្រង់នូវមន្ត ។ បទថា **តិណ្ណំ វេទានំ** បានដល់ ត្រៃវេទ មានឥរុវេទ យជុវេទ សាមវេទជាដើម ។ ឈ្មោះថា **ចារគូ** ព្រោះជាអ្នកដល់នូវត្រើយ ដោយការធ្វើឲ្យប៉ះបបូរមាត់ ។ ត្រៃវេទ មួយអន្លើដោយគម្ពីរនិឃណ្ឌុសាស្ត្រ និងកេដុភសាស្ត្រ ឈ្មោះថា

**សនិឃណ្ឌុកេដុភានំ** ។ បទថា **និឃណ្ឌុ** បានដល់ ជាគម្ពីរប្រាប់ឈ្មោះ របស់ដើមឈើជាដើម ។ បទថា **កេដុភំ** បានដល់ ការកំណត់កិរិយាមារយាទ គឺជាគម្ពីរដើម្បីជាឧបការៈរបស់កវីទាំងឡាយ ។ ត្រៃវេទ ប្រព្រឹត្តទៅជាមួយ ប្រភេទនៃអក្ខរៈ ឈ្មោះថា **សាក្ខរប្បភេទានំ** ការសិក្សា និងភាសា ឈ្មោះ ថា **អក្ខរប្បភេទានំ** ។ បទថា **ឥតិហាសបញ្ចមានំ** បានដល់ ឈ្មោះថា គម្ពីរឥតិហាសៈជាគម្រប់ ៥ ព្រោះមានគម្ពីរឥតិហាសៈ គឺគម្ពីរប្រវត្តិសាស្ត្រ និងបុរាណបវេណី ពោល គឺរឿងរ៉ាវចាស់ៗ ប្រកបដោយវាចាពោលយ៉ាង នេះថា **ឥតិហ អាស ឥតិហ អាស** ជាគម្រប់ ៥ ព្រោះមានអាថព្វវេទ គឺមន្តអថ័នជាគម្រប់ ៤ ។ នៃវេទទាំងឡាយ មានគម្ពីរឥតិហាសៈជាគម្រប់ ៥ នោះ ។ ឈ្មោះថា **បទកា វេយ្យាករណា** ព្រោះចេះនូវពាក្យ និង វេយ្យាករណ៍ដ៏សេសអំពីពាក្យនោះ ។ តម្រានិយាយឲ្យមនុស្សជឿហៅថា លោកាយតៈ ។ តម្រាប្រមាណ ១២០០០ បទសម្តែងដល់លក្ខណៈរបស់ ព្រះពុទ្ធជាដើម ដែលជាមហាបុរស ឈ្មោះថា មហាបុរិសលក្ខណៈ ឈ្មោះ ថា ជាពុទ្ធមន្ត ប្រមាណ ១៦០០០ គាថា ។ ធម្មតាព្រះពុទ្ធទាំងឡាយ ប្រកប ដោយលក្ខណៈនេះ ដោយអំណាចនៃពុទ្ធមន្តណា ដោយពុទ្ធមន្តនេះ រមែង ដឹងនូវការផ្សេងគ្នាថា ព្រះបច្ចេកពុទ្ធ អគ្គសាវក អសីតិមហាសាវក ព្រះ ពុទ្ធមាតា ព្រះពុទ្ធបិតា អគ្គឧបដ្ឋាក អគ្គឧបដ្ឋាយិកា ព្រះរាជា ស្តេចចក្រ-ពត្តិ ។ បទថា **អនវយា** បានដល់ មិនខ្វះខាត គឺធ្វើឲ្យបរិបូណ៌ អធិប្បាយ ថា មិនខ្វះខាត ក្នុងគម្ពីរលោកាយតៈ និងគម្ពីរមហាបុរិសលក្ខណៈ ។ បុគ្គល

ណា មិនអាចទ្រទ្រង់សាស្រ្តទាំងនោះបាន ដោយអត្ថ និងដោយគន្ថៈ បុគ្គលនោះ ឈ្មោះថា ខ្ទះខាត ។ បទថា **វីតរាគា** បានដល់ លះរាគៈបានហើយ ។ ដោយបទនេះ លោកពោលដល់បុគ្គលដែលតាំងនៅក្នុងអរហត្តផល លោកពោលដល់ការតាំងនៅក្នុងអរហត្តមគ្គ ដោយបទនេះថា **រាគវិនយាយ វា បដិបន្នា** ។ បទថា **វីតទោសា** បានដល់ លោកដែលតាំងនៅក្នុងអនាគាមិផល ។ លោកពោលដល់បុគ្គលដែលតាំងនៅក្នុងអនាគាមិមគ្គ ដោយបទនេះថា **ទោសវិនយាយ វា បដិបន្នា** ។ បទថា **វីតមោហា** បានដល់ ជាអ្នកតាំងនៅក្នុងអរហត្តផល ។ បទថា **មោហវិនយាយ វា បដិបន្នា** បានដល់ បុគ្គលដែលតាំងនៅក្នុងអរហត្តមគ្គ ។ បទថា **សីលសមាធិបញ្ញាវិមុត្តិសម្បន្នា** សេចក្ដីថា ជាអ្នកដល់ព្រមដោយសីលជាដើមដែលលាយឡំដោយលោកិយ និងលោកុត្តរ ៤ គឺសីល សមាធិ បញ្ញា និងវិមុត្តិ ។ គប្បីជ្រាបថា លោកពោលដល់បុគ្គលដែលដល់ព្រមដោយបច្ចវេក្ខណញ្ញាណ ដោយបទនេះថា **វិមុត្តិញ្ញាណទស្សន សម្បន្នា** ។ ញាណនោះ ជាលោកិយតែម្យ៉ាង ។

[ ១៣១ ] បទថា **អភិជប្បន្តិ** បានដល់ រមែងប្រាថ្នា ។ បទថា **ជប្បន្តិ** បានដល់ រមែងសង្ឃឹម ។ បទថា **បជប្បន្តិ** បានដល់ សង្ឃឹមក្រៃលែង ។

[ ១៣២ ] បទថា **យាជយោគេសុ យុត្តា** បានដល់ ដែលប្រកបដោយការបូជាយ៉ាងក្រៃលែងក្នុងទេយ្យធម៌ ដែលគេបូជាឲ្យ ។

[ ១៣៣ ] បទថា **អថ កោ ចរហិ** សេចក្ដីថា បើដូច្នោះ ឥឡូវនេះ

អ្នកណាហ្នឹ៎បានឆ្លងផុតហើយ ។

[ ១៣៨ ] បទថា **សង្ខាយ** បានដល់ ពិចារណាហើយដោយញាណ ។ បទថា **បរោបរានិ** បានដល់ ត្រើយអាយនិងត្រើយនាយ ។ អធិប្បាយថា ត្រើយអាយនិងត្រើយនាយ មានអត្តភាពរបស់អ្នកដទៃ និង អត្តភាពរបស់ខ្លួនជាដើម ។ បទថា **វិធូមោ** បានដល់ ប្រាសចាកផ្សែង មានកាយទុច្ចរិតជាដើម ។ បទថា **អនីឃោ** បានដល់ ប្រាសចាកទុក្ខ មានរាគៈជាដើម ។ បទថា **អតារិ សោ** បានដល់ បុគ្គលនោះ គឺបុគ្គលបែបនោះ បានដល់ ព្រះអរហន្ត បានឆ្លងជាតិជរាបានហើយ ។

[ ១៣៩ ] បទថា **សករូប** បានដល់ រូបទាំងឡាយរបស់ខ្លួន ។ បទថា **បររូប** បានដល់ រូបទាំងឡាយរបស់អ្នកដទៃ ។

[ ១៤១ ] បទថា **កាយទុច្ចរិតំ វិធូមិតំ** បានដល់ ធ្វើកាយទុច្ចរិត ៣ យ៉ាងមិនឲ្យមានផ្សែង ។ បទថា **វិធមិតំ** បានដល់ ធ្វើឲ្យវិនាសទៅ ។

បទថា **មានោ ហិ តេ ព្រាហ្មណ ខារិភារោ** បានដល់ មានះដែល បុគ្គលលើកឡើង ព្រោះអាស្រ័យវត្ថុជាទីតាំងនៃមានះ មានជាតិ គោត្រ និង ត្រកូលជាដើម ឲ្យកើតនូវសេចក្តីប្រណែនក្នុងវត្ថុជាទីតាំងនៃមានះនោះៗ រមែង លិចចុះក្នុងអបាយ ៤ ដូចរែកនូវអម្រែកលើកទៅ សូម្បីតាំងនៅខាងលើ ក៏ គង់សង្កត់ទម្ងន់ចុះលើផែនដី ក្នុងទីដែលជាន់ហើយ ដូច្នោះ ដោយហេតុនោះ ទើបព្រះមានព្រះភាគត្រាស់ថា ម្នាលព្រាហ្មណ៍ សេចក្តីពិតថា មានះរបស់ អ្នក ទុកជាអម្រែកដ៏ធ្ងន់ ដូច្នេះ ។ បទថា **កោធោ ធូមោ** បានដល់ សេចក្តី

ក្រោធ ប្រៀបដូចផ្សែង ព្រោះអត្ថថា ជាមន្ទិលនៃភ្លើង គឺញាណរបស់អ្នក ភ្លើង គឺញាណសៅហ្មងដោយសេចក្តីក្រោធ ប្រៀបដូចផ្សែងនោះ រមែងមិនរុងរឿង ។ បទថា **ភស្មនិ មោសវជ្ជំ** បានដល់ ការពោលកុហក ឈ្មោះថា ដូចផេះ ព្រោះអត្ថថា មិនរុងរឿង ព្រះមានព្រះភាគទ្រង់សម្តែងថា ប្រៀបដូចភ្លើង ត្រូវផេះបិទបាំង រមែងមិនរុងរឿង យ៉ាងណា ញាណរបស់អ្នកត្រូវបិទបាំង ដោយការនិយាយកុហក ក៏ដូច្នោះ ។ បទថា **ជិវ្ហា សុជា** សេចក្តីថា ព្រះមានព្រះភាគត្រាស់ថា អណ្តាតល្មមនឹងឲ្យកើតការបូជាធម៌នៃតថាគត ជាវែក ដូចវែកដើម្បីឲ្យកើតការបូជាយញ្ញ ដែលធ្វើដោយមាស ប្រាក់ មោហៈ ឈើ និងដីស្អិតណាមួយរបស់អ្នក ដូច្នោះ ។ បទថា **ហទយំ ជោតិដ្ឋានំ** សេចក្តីថា ហឫទ័យរបស់សត្វទាំងឡាយជាទីបូជាយញ្ញ ព្រោះអត្ថថា ជាទីឲ្យកើតការបូជារបស់តថាគត ដូចទីបូជាយញ្ញត្រង់ឆ្នេរស្ទឹងរបស់អ្នក ដូច្នោះ ។ បទថា **អត្តា** បានដល់ ចិត្ត ។ បទថា **ជាតិ** បានដល់ កំណើត ដោយអំណាចនៃការកើត ។ បទនេះ ជាសភាវៈចំពោះខ្លួនក្នុងទីនេះ ។ ឈ្មោះថា **សញ្ជាតិ** រមែងមានដោយអំណាចនៃការកើតរួមគ្នា ។ ពាក្យនេះ លោកបន្ថែមបទឧបសគ្គ ។ ឈ្មោះថា **ឱក្កន្តិ** រមែងមានដោយអំណាចនៃការឈមចុះ ។ម្យ៉ាងទៀត ឈ្មោះថា **ជាតិ** ដោយអត្ថថា កើត ។ ការកើតនោះ ប្រកបដោយអាយតនៈមិនទាន់គ្រប់គ្រាន់ ។ ឈ្មោះថា **សញ្ជាតិ** ដោយអត្ថថា កើតព្រម ។ ការកើតព្រមនោះ ប្រកបដោយអាយតនៈគ្រប់គ្រាន់ ។ ឈ្មោះថា **ឱក្កន្តិ** ព្រោះអត្ថថា ឈានចុះ ។ ឈានចុះនោះ រមែងគួរដោយ

អណ្ឌជកំណើត និងជលាពុជកំណើត ។ ព្រោះសត្វទាំងនោះ ឈានចុះកាន់ស៊ុត និងស្បូន ក៏បដិសន្ធិដូចឈានចូលទៅ ។ ឈ្មោះថា **អភិនិព្វត្តិ** ព្រោះអត្ថថា កើតចំពោះ ។ កើតចំពោះនោះ រមែងគួរដោយសំសេទជកំណើត និងឱបបាតិកកំណើត ។ ពិតហើយ សត្វទាំងនោះ កើតប្រាកដជាខ្ជួនតែម្តង ។ នេះត្រឹមតែជាសម្មតិកថា ។ ឥឡូវនេះ នឹងពោលដល់បរមត្ថកថា ។ ពិតហើយ ដោយបរមត្ថ ខន្ធទាំងនោះប្រាកដ មិនមែនសត្វប្រាកដឡើយ ក្នុងបទទាំងនោះ បទថា **ខន្ធានំ** សេចក្តីថា គប្បីជ្រាបការកាន់យកខន្ធ ១ ក្នុងឯកវោការភព ខន្ធ ៤ ក្នុងចតុវោការភព ខន្ធ ៥ ក្នុងបញ្ចវោការភព ។ បទថា **ចាតុភាវោ** បានដល់ ការកើតឡើង ។ ក្នុងបទថា **អាយតនានំ** នេះ គប្បីជ្រាបការសង្គ្រោះអាយតនៈដែលកើតឡើងក្នុងខន្ធនោះៗ ។ បទថា **បដិលាភោ** បានដល់ ការប្រាកដក្នុងបដិសន្ធិនោះឯង ។ ពិតហើយ អាយតនៈទាំងនោះ កាលប្រាកដ ឈ្មោះថា បានហើយ ។ម្យ៉ាងទៀត **ជាតិ** នេះ មានការកើតដំបូងក្នុងភពនោះៗ ជាលក្ខណៈ មានការប្រគល់ឲ្យជាកិច្ច មានការផុសឡើងក្នុងភពនេះអំពីភពក្នុងអតីតជាអាការប្រាកដ ឬមានភាពជាអ្នកពេញទៅដោយទុក្ខ ដោយអំណាចនៃផលជាអាការប្រាកដ ។ បទថា **ជរា** បានដល់ ជាសភាវៈចំពោះខ្ជួន ។ បទថា **ជីរណតា** ជាពាក្យសម្តែងដល់អាការ ។ ៣ បទ មានបទថា **ខណ្ឌិច្ចំ** ជាដើម ជាពាក្យសម្តែងដល់កិច្ចក្នុងកាលកន្លងវ័យទៅ ។ ២ បទខាងក្រោយ សម្តែងដល់ប្រក្រតី ។ ការចាស់នេះលោកសម្តែងដោយភាពជាសភាវៈ ដោយពាក្យនេះថា ជរា ។ នេះជាសភាវៈ

ចំពោះខ្ជួនរបស់ការចាស់ ដោយពាក្យនោះ ។ សម្តែងដោយអាការដោយពាក្យនេះថា **ជីរណតា** ។ នេះជាការសម្តែងអាការរបស់ការចាស់នោះ ដោយពាក្យនោះ ។ សម្តែងដោយកិច្ច ការធ្វើធ្មេញ និងក្រចកឲ្យបាក់ ក្នុងកាលកន្លងវ័យទៅ ដោយពាក្យនេះថា **ខណ្ឌិច្ចំ** ។ សម្តែងដោយកិច្ច គឺការធ្វើឲ្យសក់ និងរោមស្កូវ ដោយពាក្យនេះថា **បាលិច្ចំ** សម្តែងដោយកិច្ច គឺការធ្វើឲ្យសាច់ និងស្បែកជ្រីវជ្រួញ ដោយពាក្យនេះថា **វលិត្តចតា** ។ ៣ បទមានបទថា **ខណ្ឌិច្ចំ** នេះជាដើម ជាពាក្យសម្តែងដល់កិច្ចក្នុងកាលកន្លងវ័យទៅនៃការចាស់នោះ ។ ដោយពាក្យទាំងនោះ លោកសម្តែងការចាស់ដែលប្រាកដច្បាស់ដោយការឃើញការប្រែប្រួលទាំងនេះ ដូចផ្លូវទៅរបស់ទឹក ខ្យល់ ភ្លើង រមែងប្រាកដបាន ព្រោះស្មៅ ដើមឈើជាដើម បាក់រលំ ឬព្រោះត្រូវភ្លើងឆេះ តែផ្លូវទៅមិនប្រាកដ ទឹកជាដើមមិនប្រាកដ យ៉ាងណា ផ្លូវទៅរបស់ជរា រមែងប្រាកដដោយភាពជាអ្នកមានធ្មេញបាក់ជាដើម សូម្បីបើកភ្នែកមើល ក៏កំណត់ដឹងបាន ភាពជាអ្នកមានធ្មេញបាក់ជាដើម មិនប្រាកដជរាក៏មិនប្រាកដ យ៉ាងនោះ ព្រោះជរាមិនគប្បីដឹងដោយភ្នែក ។ ក្នុងបទទាំងនោះ បទថា **អាយុនោ សំហានិ ឥន្ទ្រិយានំ បរិបាកោ** នេះ លោកសម្តែងការចាស់តាមប្រក្រតី ពោល គឺការវិនាសនៃអាយុ និងការចាស់នៃឥន្ទ្រិយ មានចក្ខុន្ទ្រិយជាដើម ព្រោះប្រាកដច្បាស់ ក្នុងកាលកន្លងវ័យទៅ ។ ដោយហេតុនោះ គប្បីជ្រាបថា បទ ២ ខាងក្រោយនេះ សម្តែងដល់ប្រក្រតីនៃការចាស់នោះ ។ ក្នុងបទនោះ ព្រោះកាលដល់ជរាហើយ អាយុ រមែង

វិនាស ដូច្នោះ ជរា លោកពោលដោយភាពជិតនឹងផលថា **អាយុនោ សំហានិ** ព្រោះកាលនៅក្មេង ឥន្ទ្រិយ មានចក្ខុន្ទ្រិយជាដើមផូរផង់ អាចទទួលវិស័យរបស់ខ្លួន សូម្បីល្អិតបានដោយងាយ កាលដល់ជរាហើយ ឥន្ទ្រិយក៏ចាស់ ល្អក់កករ សៅហ្មង មិនអាចទទួលវិស័យរបស់ខ្លួន សូម្បីគ្រោតគ្រាតបាន ដូច្នោះ ទើបពោលដោយជិតផលថា **ឥន្ទ្រិយានំ បរិបាកោ** ។

ជរាដែលលោកសម្តែងទាំងអស់យ៉ាងនេះ មាន ២ យ៉ាង គឺជរាមិនកំបាំង ១ ជរាកំបាំង ១ ។ ក្នុងជរាទាំង ២ នោះ ជរាក្នុងរូបធម៌ ឈ្មោះថា ជរាប្រាកដ ព្រោះសម្តែងនូវភាពធ្មេញបាក់ជាដើម ។ តែជរាក្នុងអរូបធម៌ ឈ្មោះថា ជរាមិនប្រាកដ ព្រោះមិនសម្តែងការប្រែប្រួលបែបនោះ ។ ក្នុងជរា ២ នោះ ភាពជាអ្នកមានធ្មេញបាក់ជាដើម ដែលប្រាកដក៏ត្រឹមតែជាវណ្ណរូបប៉ុណ្ណោះ ព្រោះធ្មេញជាដើមនោះ ជាវត្ថុដែលបុគ្គលដឹងបានងាយ បុគ្គលកាលឃើញវណ្ណរូបនោះដោយភ្នែក គិតដោយចិត្ត ទើបដឹងជរាថា ខន្ធទាំងឡាយ ត្រូវជរាកម្ចាត់ហើយ ដូចសម្លឹងមើលស្នែងគោជាដើម ដែលគេចងក្នុងទីមានទឹក ក៏ដឹងថា ទឹកមាននៅខាងក្រោម ។

ជរាមាន ២ យ៉ាងទៀត គឺអវីចិជរា ១ សវីចិជរា ១ ។ ក្នុងជរា ២ យ៉ាងនោះ ជរារបស់កែវមណី មាស ប្រាក់ កែវប្រពាល ព្រះចន្ទ ព្រះអាទិត្យជាដើម ឈ្មោះថា **អវីចិជរា** ព្រោះដឹងការផ្សេងគ្នានៃពណ៌ ក្នុងចន្លោះៗ បានលំបាក ដូចការផ្សេងគ្នារបស់សត្វមានជីវិត ក្នុងបណ្តាព្រះបាទ

មន្ធាតុរាជ និងសក្កទេវរាជជាដើម[១] និងដូចការផ្សេងគ្នានៃវត្ថុមិនមានជីវិត ក្នុងបណ្តាផ្កា ផ្លែឈើ និងស្លឹកឈើខ្ចីជាដើម អធិប្បាយថា ជរាជាប់ត ។ តែជរាក្នុងវត្ថុដែលពោលហើយដទៃអំពីកែវមណីជាដើម ឈ្មោះថា **សវីចិជរា** ព្រោះដឹងការផ្សេងគ្នានៃពណ៌ក្នុងចន្លោះៗ បានងាយ ។

ក្នុងការចាស់ ២ យ៉ាងនោះ សវីចិជរាគប្បីសម្តែងយ៉ាងនេះ ដោយអំណាចឧបាទិន្នកៈ និងអនុបាទិន្នកៈ ។ ពិតហើយ ធ្មេញព្រៃរបស់កុមារដុះមុន តែមិនមាំទាំ កាលធ្មេញព្រៃ ( ធ្មេញទឹកដោះ ) នោះបាក់ ក៏ដុះឡើងវិញ ធ្មេញទាំងនោះ ដំបូងក៏ស លុះដល់កាលជរា ក៏ខ្មៅ ឯសក់ ដំបូង ក៏ក្រហមខ្លះ ខ្មៅខ្លះ សខ្លះ ។ ឯស្បែកមានពណ៌ក្រហម កាលបុគ្គលចម្រើនធំធាត់ បុគ្គលសក៏ប្រាកដជាពណ៌ស បុគ្គលខ្មៅ ក៏ប្រាកដជាពណ៌ខ្មៅ ។ កាលត្រូវខ្យល់ជរាប៉ះខ្ទប់ក៏ជ្រីវជ្រួញ សូម្បីសម្ទូងក្នុងសាបព្រោះក៏ពណ៌សខាងក្រោយ ក៏ពណ៌ខៀវចាស់ ។ កាលត្រូវជរាប៉ះខ្ទប់ ក៏មានពណ៌ស ។ គួរសម្តែងដោយពន្លកស្វាយដូចគ្នា ។

ម្យ៉ាងទៀត ជរានោះ មានការចាស់របស់ខន្ធជាលក្ខណៈ មានការនាំចូលទៅកាន់មរណៈជាកិច្ច មានការអស់នូវភាពជាកំលោះជាក្រមុំ ជាអាការប្រាកដ បទដ៏សេសក្នុងទីទាំងពួង ប្រាកដច្បាស់ល្អហើយ ។

---

១- ក្នុងកាលព្រះបាទមន្ធាតុគង់ជាមួយព្រះឥន្ទ ពួកទេវតាសម្លឹងមើលភ្នែក ទើបដឹងថា នេះព្រះឥន្ទ នេះព្រះបាទមន្ធាតុ ព្រោះព្រះឥន្ទមិនប៉ព្រិចភ្នែក ។

ព្រះមានព្រះភាគ ទ្រង់សម្តែងសូត្រនេះដោយធម៌កំពូល គឺព្រះអរហត្ត ដោយប្រការដូច្នេះ ។

កាលចប់ទេសនា ព្រាហ្មណ៍ មួយអន្ទើដោយអន្តេវាសិក ១០០០ ក៏តាំងនៅក្នុងអរហត្ត ធម្មចក្ខុកើតឡើងហើយ ដល់ជនដទៃច្រើនពាន់ ។ បទដ៏សេស ដូចគ្នានឹងបទដែលបានពោលហើយនោះឯង ។៚

## អដ្ឋកថា បុណ្ណកមាណវសុត្តនិទ្ទេសទី ៣ ចប់

# សុត្តន្តបិដក

## មេត្តគូមាណវកប្បញ្ហានិទ្ទេស

[ ១៤២ ] *( មេត្តគូមាណពមានអាយុទូលសួរដូច្នេះថា ) បពិត្រព្រះមានព្រះភាគ ខ្ញុំព្រះអង្គសូមទូលសួរព្រះអង្គ សូមព្រះអង្គត្រាស់ប្រាប់នូវសេចក្តីនោះ ដល់ខ្ញុំព្រះអង្គឲ្យទាន ខ្ញុំព្រះអង្គសម្គាល់ឃើញថា ព្រះអង្គជាអ្នកដល់នូវវេទ ជាអ្នកមានខ្លួនបានអប់រំហើយ សេចក្តីទុក្ខទាំងឡាយណាមួយ ជាច្រើនប្រការក្នុងលោក សេចក្តីទុក្ខទាំងនេះ កើតមកអំពីទីណាហ្ន៎ ។*

[ ១៤៣ ] *អធិប្បាយពាក្យថា បពិត្រព្រះមានព្រះភាគ ខ្ញុំព្រះអង្គសូមទូលសួរព្រះអង្គ សូមព្រះអង្គត្រាស់ប្រាប់នូវសេចក្តីនោះ ដល់ខ្ញុំព្រះអង្គ ត្រង់ពាក្យថា សួរ បានដល់សំណួរ ៣ គឺអទិដ្ឋជោតនាបុច្ឆា ( សំណួរជាគ្រឿងបំភ្លឺហេតុ ដែលមិនទាន់បានឃើញ ) ១ ទិដ្ឋសំសន្ទនាបុច្ឆា ( សំណួរជាគ្រឿងប្រៀបផ្ទឹមហេតុ ដែលធ្លាប់ឃើញហើយ ) ១ វិមតិច្ឆេទនាបុច្ឆា ( សំណួរជាគ្រឿងកាត់សេចក្តីងឿងឆ្ងល់ ) ១ ។*

*អទិដ្ឋជោតនាបុច្ឆា តើដូចម្តេច ។ លក្ខណៈដែលបុគ្គលមិនទាន់ដឹង មិនទាន់ឃើញ មិនទាន់ថ្លឹង មិនទាន់ពិចារណា មិនទាន់យល់ច្បាស់ មិនទាន់ប្រាកដ ដោយប្រក្រតី បុគ្គលសួរប្រស្នាដើម្បីការដឹង ការឃើញ ការថ្លឹង ការពិចារណា ដើម្បីប្រយោជន៍ដល់ការយល់ច្បាស់ ដើម្បីប្រយោជន៍ឲ្យប្រាកដនូវលក្ខណៈនោះ នេះ* **អទិដ្ឋជោតនាបុច្ឆា** ។

*ទិដ្ឋសំសន្ទនាបុច្ឆា តើដូចម្តេច ។ លក្ខណៈដែលបុគ្គលបានដឹង ឃើញ*

ថ្លឹង ពិចារណា យល់ច្បាស់ ប្រាកដ ដោយប្រក្រតីហើយ បុគ្គលសួរនូវប្រស្នា ដើម្បីប្រយោជន៍ប្រៀបផ្ទឹម ជាមួយនឹងពួកអ្នកប្រាជ្ញដទៃ នេះ **ទិដ្ឋសំសន្ទនាបុច្ឆា** ។

វិមតិច្ឆេទនាបុច្ឆា តើដូចម្តេច ។ បុគ្គលស្ទុះទៅកាន់សេចក្តីសង្ស័យ ស្ទុះទៅកាន់សេចក្តីងឿងឆ្ងល់ មានគំនិតបែកជាពីរ ដោយប្រក្រតីថា យ៉ាងនេះទេឬ ឬមិនមែនទេ ដូចម្តេចហ្ន៎ ប្រការដូចម្តេចហ្ន៎ បុគ្គលនោះ សួរប្រស្នា ដើម្បីកាត់សេចក្តីងឿងឆ្ងល់ នេះ **វិមតិច្ឆេទនាបុច្ឆា** ។ នេះ បុច្ឆា ៣ ។ បុច្ឆា ( សំណួរ ) ៣ ដទៃទៀត គឺមនុស្សបុច្ឆា អមនុស្សបុច្ឆា និម្មិតបុច្ឆា ។

មនុស្សបុច្ឆា តើដូចម្តេច ។ ពួកមនុស្សចូលទៅគាល់ព្រះមានព្រះភាគ ហើយសួរប្រស្នា គឺពួកភិក្ខុសួរ ពួកភិក្ខុនីសួរ ពួកឧបាសកសួរ ពួកឧបាសិកាសួរ ពួកព្រះរាជាសួរ ពួកក្សត្រសួរ ពួកព្រាហ្មណ៍សួរ ពួកវេស្សៈសួរ ពួកសុទ្ទៈសួរ ពួកគ្រហស្ថសួរ ពួកបព្វជិតសួរ នេះ **មនុស្សបុច្ឆា** ។

អមនុស្សបុច្ឆា តើដូចម្តេច ។ ពួកអមនុស្ស ចូលទៅគាល់ព្រះពុទ្ធមានព្រះភាគ ហើយសួរប្រស្នា គឺពួកនាគសួរ ពួកគ្រុឌសួរ ពួកយក្សសួរ ពួកអសុរសួរ ពួកគន្ធព្វសួរ ពួកមហារាជសួរ ពួកព្រះឥន្ទ្រសួរ ពួកព្រហ្មសួរ ពួកទេវតាសួរ នេះ **អមនុស្សបុច្ឆា** ។

និម្មិតបុច្ឆា តើដូចម្តេច ។ ព្រះមានព្រះភាគ ទ្រង់និម្មិតរូបណា មានអវយវៈសព្វគ្រប់ មានឥន្ទ្រិយមិនខ្វះខាត ដែលសម្រេចអំពីចិត្ត ។ រូបនិម្មិតនោះ ចូលទៅគាល់ព្រះពុទ្ធមានព្រះភាគ ហើយសួរប្រស្នា ព្រះមានព្រះភាគ

ក៏ទ្រង់ដោះស្រាយ នេះ **ឆិន្នមតិបុច្ឆា** ។ នេះ បុច្ឆា ៣ ។

បុច្ឆា ៣ ដទៃទៀត គឺបុច្ឆាចំពោះប្រយោជន៍នៃខ្លួន ១ បុច្ឆាចំពោះប្រយោជន៍បុគ្គលដទៃ ១ បុច្ឆាចំពោះប្រយោជន៍ទាំងពីរ ១ ។

បុច្ឆា ៣ ដទៃទៀត គឺបុច្ឆាចំពោះប្រយោជន៍បច្ចុប្បន្ន ១ បុច្ឆាចំពោះប្រយោជន៍បរលោក ១ បុច្ឆាចំពោះប្រយោជន៍ដ៏ក្រៃលែង ១ ។

បុច្ឆា ៣ ដទៃទៀត គឺបុច្ឆាចំពោះប្រយោជន៍មិនមានទោស ១ បុច្ឆាចំពោះប្រយោជន៍មិនមានកិលេស ១ បុច្ឆាចំពោះប្រយោជន៍ដ៏ផូរផង់ ១ ។

បុច្ឆា ៣ ដទៃទៀត គឺអតីតបុច្ឆា ១ អនាគតបុច្ឆា ១ បច្ចុប្បន្នបុច្ឆា ១ ។

បុច្ឆា ៣ ដទៃទៀត គឺបុច្ឆាធម៌ក្នុង ១ បុច្ឆាធម៌ក្រៅ ១ បុច្ឆាធម៌ទាំងក្នុងទាំងក្រៅ ១ ។

បុច្ឆា ៣ ដទៃទៀត គឺកុសលបុច្ឆា ១ អកុសលបុច្ឆា ១ អព្យាកតបុច្ឆា ១ ។

បុច្ឆា ៣ ដទៃទៀត គឺខន្ធបុច្ឆា ១ ធាតុបុច្ឆា ១ អាយតនបុច្ឆា ១ ។

បុច្ឆា ៣ ដទៃទៀត គឺសតិប្បដ្ឋានបុច្ឆា ១ សម្មប្បធានបុច្ឆា ១ ឥទ្ធិបាទបុច្ឆា ១ ។

បុច្ឆា ៣ ដទៃទៀត គឺឥន្ទ្រិយបុច្ឆា ១ ពលបុច្ឆា ១ ពោជ្ឈង្គបុច្ឆា ១ ។

បុច្ឆា ៣ ដទៃទៀត គឺមគ្គបុច្ឆា ១ ផលបុច្ឆា ១ និព្វានបុច្ឆា ១ ។

ពាក្យថា ខ្ញុំព្រះអង្គសូមទូលសួរព្រះអង្គ គឺខ្ញុំព្រះអង្គសូមទូលសួរព្រះអង្គ សូមអង្វរព្រះអង្គ អារាធនាព្រះអង្គ ជ្រះថ្លាចំពោះព្រះអង្គ សូមព្រះអង្គ

ត្រាស់ប្រាប់ដល់ខ្ញុំព្រះអង្គ ហេតុនោះ ( លោកពោលថា ) ខ្ញុំព្រះអង្គទូលសួរព្រះអង្គ ។ ពាក្យថា ព្រះមានព្រះភាគទុំះ ជាពាក្យពោលដោយគោរព ។បេ។ ការបញ្ញត្តិថា ព្រះមានព្រះភាគ នេះ ( កើត ) ព្រោះការត្រាស់ដឹង ។ ពាក្យថា សូមព្រះអង្គត្រាស់ប្រាប់សេចក្តីនោះ ដល់ខ្ញុំព្រះអង្គ គឺសូមព្រះអង្គពោលប្រាប់ សម្តែង បញ្ញត្ត តាំងទុក បើក ចែក ធ្វើឲ្យរាក់ ប្រកាស ហេតុនោះ ( លោកពោលថា ) បពិត្រព្រះមានព្រះភាគ ខ្ញុំព្រះអង្គសូមទូលសួរព្រះអង្គ សូមព្រះអង្គត្រាស់ប្រាប់សេចក្តីនោះ ដល់ខ្ញុំព្រះអង្គ ។ ពាក្យថា ដូច្នេះ របស់បទថា មេត្តគូមានអាយុ ( ទូលសួរ ) ដូច្នេះ គឺជាបទតភ្ជាប់ ។បេ។ មេត្តគូមានអាយុ ( ទូលសួរ ) ដូច្នេះ ។

[ ១៤៤ ] ពាក្យថា ខ្ញុំព្រះអង្គសម្គាល់ឃើញថា ព្រះអង្គជាអ្នកដល់នូវវេទ ជាអ្នកមានខ្លួនបានអប់រំហើយ អធិប្បាយថា ខ្ញុំព្រះអង្គសម្គាល់ព្រះអង្គថា ជាអ្នកដល់នូវវេទ សម្គាល់ព្រះអង្គថា ជាអ្នកមានខ្លួនអប់រំហើយ ខ្ញុំព្រះអង្គសម្គាល់យ៉ាងនេះ ដឹងយ៉ាងនេះ យល់យ៉ាងនេះ ដឹងច្បាស់យ៉ាងនេះ ដឹងចំពោះយ៉ាងនេះ ចាក់ធ្លុះយ៉ាងនេះថា ព្រះអង្គដល់នូវវេទ មានខ្លួនបានអប់រំហើយ ។

ព្រះមានព្រះភាគ ឈ្មោះថា ទ្រង់ដល់នូវវេទ តើដូចម្តេច ។ ញាណ ប្រាជ្ញា បញ្ញិន្ទ្រិយ បញ្ញាពល ធម្មវិចយសម្ពោជ្ឈង្គ វីមំសា វិបស្សនា សម្មាទិដ្ឋិ ក្នុងមគ្គ ៤ លោកហៅថា វេទ ។ ព្រះមានព្រះភាគ ទៅកាន់ទីបំផុត ដល់នូវទីបំផុត នៃជាតិ ជរា និងមរណៈ ដោយវេទទាំងឡាយនោះ ទៅកាន់

ទីខាងចុង ដល់ទីខាងចុង ទៅកាន់ទីបំផុតជុំវិញ ដល់ទីបំផុតជុំវិញ ទៅកាន់ទីចប់ ដល់ទីចប់ ទៅកាន់ទីពំនាក់ ដល់ទីពំនាក់ ទៅកាន់ទីជ្រកកោន ដល់ទីជ្រកកោន ទៅកាន់ទីពឹង ដល់ទីពឹង ទៅកាន់ទីមិនមានភ័យ ដល់ទីមិនមានភ័យ ទៅកាន់ទីមិនច្យុត ដល់ទីមិនច្យុត ទៅកាន់អមតៈ ដល់អមតៈ ទៅកាន់ព្រះនិព្វាន ដល់ព្រះនិព្វាន ។ មួយទៀត ព្រះអង្គ ឈ្មោះថា ទ្រង់ដល់នូវវេទ ព្រោះទ្រង់ដល់នូវទីបំផុតនៃវេទទាំងឡាយ ។ មួយទៀត ព្រះអង្គ ឈ្មោះថា ទ្រង់ដល់នូវវេទ ព្រោះទ្រង់ដល់ទីបំផុតដោយវេទទាំងឡាយ មួយវិញទៀត ព្រះអង្គ ឈ្មោះថា ទ្រង់ដល់នូវវេទ ព្រោះដឹងច្បាស់នូវធម៌ទាំង ៧ ។ គឺព្រះអង្គទ្រង់ដឹងច្បាស់សក្កាយទិដ្ឋិ ដឹងច្បាស់វិចិកិច្ឆា ដឹងច្បាស់សីលព្វតបរាមាស ដឹងច្បាស់រាគៈ ទោសៈ មោហៈ មានះ ។ ធម៌ជាអកុសលដ៏លាមក ជាគ្រឿងសៅហ្មង នាំឲ្យកើតក្នុងភពថ្មីទៀត ប្រកបដោយសេចក្តីក្រវល់ក្រវាយ មានផលជាទីទុក្ខ មានជាតិ ជរា មរណៈប្រព្រឹត្តទៅខាងមុខ ជាធម៌ គឺព្រះអង្គទ្រង់ជ្រាបច្បាស់ហើយ ។

( ព្រះមានព្រះភាគ ទ្រង់ត្រាស់ថា ម្នាលសភិយៈ ) បុគ្គលណា
ពិនិត្យច្បាស់នូវទេវទាំងអស់ ដែលជារបស់សមណព្រាហ្មណ៍
ទាំងឡាយ ជាអ្នកមានតម្រេកទៅប្រាស ក្នុងវេទនាទាំងពួង
កន្លងផុតនូវវេទទាំងពួង បុគ្គលនោះឈ្មោះថា អ្នកដល់នូវវេទ ។

ព្រះមានព្រះភាគ ឈ្មោះថា មានខ្លួនបានអប់រំហើយ តើដូចម្តេច ។ ព្រះមានព្រះភាគ មានព្រះកាយអប់រំហើយ មានសីលអប់រំហើយ មានព្រះ

ហឫទ័យអប់រំហើយ មានប្រាជ្ញាអប់រំហើយ មានសតិប្បដ្ឋានអប់រំហើយ មាន សម្មប្បធានអប់រំហើយ មានឥទ្ធិបាទអប់រំហើយ មានឥន្ទ្រិយអប់រំហើយ មាន ពលអប់រំហើយ មានពោជ្ឈង្គអប់រំហើយ មានមគ្គអប់រំហើយ មានកិលេស លះបង់ហើយ មានអកុប្បធម៌ត្រាស់ដឹងហើយ មាននិរោធធ្វើឲ្យជាក់ច្បាស់ ហើយ ។ ទុក្ខក៏ព្រះមានព្រះភាគនោះ កំណត់ដឹងហើយ សមុទយៈ ទ្រង់ លះបង់ហើយ មគ្គព្រះអង្គចម្រើនហើយ និរោធព្រះអង្គធ្វើឲ្យជាក់ច្បាស់ហើយ គុណជាតដែលគប្បីជ្រាបច្បាស់ ព្រះអង្គជ្រាបច្បាស់ហើយ ធម្មជាតដែលគួរ កំណត់ដឹង ព្រះអង្គកំណត់ដឹងហើយ កិលេសជាត ដែលត្រូវលះ ព្រះអង្គ លះបង់ហើយ គុណជាតដែលត្រូវចម្រើន ព្រះអង្គចម្រើនហើយ គុណជាត ដែលត្រូវធ្វើឲ្យជាក់ច្បាស់ ព្រះអង្គធ្វើឲ្យជាក់ច្បាស់ហើយ ។ ព្រះមានព្រះភាគ មិនមែនជាបុគ្គលតូចតាចទេ ជាបុគ្គលធំ ជាបុគ្គលជ្រៅ មានប្រមាណមិនបាន ដែលអ្នកផងស្ទង់មើលបានដោយក្រ មានរតនៈច្រើន ប្រៀបដូចសាគរ ជា បុគ្គលប្រកបដោយឆឡង្គុបេក្ខា ។ ព្រះអង្គទតឃើញរូបដោយចក្ខុហើយ មិន ត្រេកអរ មិនអាក់អន់ ទ្រង់គង់ព្រងើយកន្តើយ មានស្មារតីជ្រាបច្បាស់ ព្រះ អង្គឮសំឡេងដោយសោតៈ ធុំក្លិនដោយឃានៈ លិទ្ធរសដោយជិវ្ហា ពាល់ ត្រូវផ្សព្វដោយកាយ ជ្រាបធម្មារម្មណ៍ដោយព្រះហឫទ័យហើយ មិនត្រេកអរ មិនអាក់អន់ ទ្រង់គង់ព្រងើយកន្តើយមានស្មារតីជ្រាបច្បាស់ ។ ព្រះអង្គទត ឃើញរូបដោយចក្ខុហើយ មិនជាប់ មិនស្រឡាញ់ ចំពោះរូបជាទីពេញចិត្ត មិនញុំាងរាគៈឲ្យកើតឡើង ។ ព្រះអង្គមានព្រះកាយខ្ជាប់ខ្ជួន មានព្រះហឫទ័យ

ខ្ជាប់ខ្ជួន ជាព្រះហឫទ័យស្ថិតនៅដោយល្អខាងក្នុងសន្តាន រួចស្រឡះដោយប្រពៃ ។ ព្រះអង្គទតឃើញរូបនុ៎ះ ដោយចក្ខុហើយ ក៏មិនស្អប់ចំពោះរូបមិនជាទីពេញចិត្ត ព្រះអង្គមានព្រះហឫទ័យមិនអាក់អន់ មានព្រះហឫទ័យមិនរួញរា មានព្រះហឫទ័យមិនគុំកួន ។ ព្រះអង្គមានព្រះកាយខ្ជាប់ខ្ជួន មានព្រះហឫទ័យខ្ជាប់ខ្ជួន ជាព្រះហឫទ័យស្ថិតនៅដោយល្អ ខាងក្នុងសន្តាន ជាព្រះហឫទ័យរួចស្រឡះដោយប្រពៃ ។ ព្រះអង្គឮសំឡេងដោយសោតៈ ធុំក្លិនដោយឃានៈ លិទ្ធរសដោយជិវ្ហា ពាល់ត្រូវផ្សព្វដោយកាយ ជ្រាបច្បាស់ធម្មារម្មណ៍ដោយព្រះហឫទ័យហើយ មិនជាប់ មិនស្រឡាញ់ ចំពោះអារម្មណ៍ជាទីពេញចិត្ត មិនញុំាងរាគៈឲ្យកើតឡើង ។ ព្រះអង្គមានព្រះកាយខ្ជាប់ខ្ជួន មានព្រះហឫទ័យខ្ជាប់ខ្ជួន ជាព្រះហឫទ័យស្ថិតនៅដោយល្អ ខាងក្នុងសន្តាន រួចស្រឡះដោយប្រពៃ ។ ព្រះអង្គជ្រាបច្បាស់នូវធម្មារម្មណ៍នុ៎ះ ដោយព្រះហឫទ័យហើយ មិនស្អប់ចំពោះអារម្មណ៍មិនជាទីពេញចិត្ត មានព្រះហឫទ័យមិនថ្នាំងថ្នាក់ មានព្រះហឫទ័យមិនរួញរា មានព្រះហឫទ័យមិនគុំកួន ។ ព្រះអង្គមានព្រះកាយខ្ជាប់ខ្ជួន មានព្រះហឫទ័យខ្ជាប់ខ្ជួន ជាព្រះហឫទ័យ ស្ថិតនៅដោយល្អ ខាងក្នុងសន្តាន រួចស្រឡះដោយប្រពៃ ។ ព្រះអង្គទតឃើញរូបដោយចក្ខុហើយ មានព្រះកាយខ្ជាប់ខ្ជួនក្នុងរូបទាំងឡាយ ជាទីពេញចិត្តនិងមិនជាទីពេញចិត្ត ព្រះអង្គមានព្រះកាយខ្ជាប់ខ្ជួន មានព្រះហឫទ័យខ្ជាប់ខ្ជួន ជាព្រះហឫទ័យស្ថិតនៅដោយល្អ ខាងក្នុងសន្តាន រួចស្រឡះដោយប្រពៃ ។ ព្រះអង្គឮសំឡេងដោយសោតៈ ធុំក្លិនដោយឃានៈ លិទ្ធរសដោយជិវ្ហា ពាល់

ត្រូវផ្សព្វដោយព្រះកាយ ជ្រាបធម្មារម្មណ៍ដោយព្រះហឫទ័យហើយ មានព្រះកាយខ្ជាប់ខ្ជួន ក្នុងធម្មារម្មណ៍ទាំងឡាយជាទីពេញចិត្ត និងមិនជាទីពេញចិត្ត មានព្រះហឫទ័យខ្ជាប់ខ្ជួន ជាព្រះហឫទ័យស្ថិតនៅដោយល្អ ខាងក្នុងសន្តាន រួចស្រឡះដោយប្រពៃ ។ ព្រះអង្គទតឃើញរូបដោយចក្ខុហើយ មិនត្រេកអរក្នុងអារម្មណ៍ដែលគួរត្រេកអរ មិនប្រទូស្តក្នុងអារម្មណ៍ដែលគួរប្រទូស្ត មិនវង្វេងក្នុងអារម្មណ៍ដែលគួរវង្វេង មិនកម្រើកក្នុងអារម្មណ៍ដែលគួរកម្រើក មិនស្រើវើងក្នុងអារម្មណ៍ដែលគួរស្រើវើង មិនសៅហ្មងក្នុងអារម្មណ៍ដែលគួរសៅហ្មង ។ ព្រះអង្គឮសំឡេងដោយសោតៈ ធុំក្លិនដោយឃានៈ លិទ្ធរសដោយជិវ្ហា ពាល់ត្រូវផ្សព្វដោយកាយ ជ្រាបច្បាស់ធម្មារម្មណ៍ដោយព្រះហឫទ័យហើយ មិនត្រេកអរក្នុងអារម្មណ៍ដែលគួរត្រេកអរ មិនប្រទូស្តក្នុងអារម្មណ៍ដែលគួរប្រទូស្ត មិនវង្វេងក្នុងអារម្មណ៍ដែលគួរវង្វេង មិនកម្រើកក្នុងអារម្មណ៍ដែលគួរកម្រើក មិនស្រើវើងក្នុងអារម្មណ៍ដែលគួរស្រើវើង មិនសៅហ្មងក្នុងអារម្មណ៍ដែលគួរសៅហ្មង ។ ព្រះអង្គគ្រាន់តែទតឃើញចំពោះរូបដែលឃើញ គ្រាន់តែឮចំពោះសំឡេងដែលឮ គ្រាន់តែប៉ះពាល់ចំពោះអារម្មណ៍ដែលប៉ះពាល់ គ្រាន់តែជ្រាបចំពោះធម្មារម្មណ៍ដែលជ្រាប មិនប្រឡាក់ក្នុងរូបដែលឃើញ មិនប្រឡាក់ក្នុងសំឡេងដែលឮ មិនប្រឡាក់ក្នុងអារម្មណ៍ដែលប៉ះពាល់ មិនប្រឡាក់ក្នុងធម្មារម្មណ៍ដែលជ្រាបហើយ ព្រះអង្គមិនស្រើបស្រាល មិនអាស្រ័យ មិនជាប់ជំពាក់ក្នុងរូបដែលឃើញ ទ្រង់រួចស្រឡះ ប្រាសចេញ មានព្រះហឫទ័យប្រាសចាកសេចក្តីសល់វល់ ព្រះអង្គមិនស្រើបស្រាល មិន

អាស្រ័យ មិនជាប់ជំពាក់ក្នុងសំឡេងដែលឮ ក្នុងអារម្មណ៍ដែលប៉ះពាល់ ក្នុងធម្មារម្មណ៍ដែលជ្រាបច្បាស់ ព្រះអង្គរួចស្រឡះ ប្រាសចេញ មានព្រះហឫទ័យប្រាសចាកសេចក្តីសល់វល់ ។ ចក្ខុរបស់ព្រះមានព្រះភាគ មានគ្រប់គ្រាន់ ព្រះមានព្រះភាគ ទតឃើញរូបដោយចក្ខុ តែឆន្ទរាគៈនៃព្រះមានព្រះភាគមិនមានទេ ( ព្រោះ ) ព្រះមានព្រះភាគ មានព្រះហឫទ័យរួចស្រឡះដោយប្រពៃ ។ សោតៈរបស់ព្រះមានព្រះភាគ មានគ្រប់គ្រាន់ ព្រះមានព្រះភាគ ទ្រង់ឮសំឡេងដោយសោតៈ តែឆន្ទរាគៈនៃព្រះមានព្រះភាគមិនមានទេ ( ព្រោះ ) ព្រះមានព្រះភាគ មានព្រះហឫទ័យរួចស្រឡះហើយដោយប្រពៃ ។ ឃានៈរបស់ព្រះមានព្រះភាគ មានគ្រប់គ្រាន់ ព្រះមានព្រះភាគទ្រង់ធុំក្លិនដោយឃានៈ តែឆន្ទរាគៈនៃព្រះមានព្រះភាគ មិនមានទេ ( ព្រោះ ) ព្រះមានព្រះភាគ មានព្រះហឫទ័យរួចស្រឡះដោយប្រពៃ ។ ជិវ្ហារបស់ព្រះមានព្រះភាគ មានគ្រប់គ្រាន់ ព្រះមានព្រះភាគ ទ្រង់លិទ្ធរសដោយជិវ្ហា តែឆន្ទរាគៈនៃព្រះមានព្រះភាគ មិនមានទេ ( ព្រោះ ) ព្រះមានព្រះភាគ មានព្រះហឫទ័យរួចស្រឡះដោយប្រពៃ ។ កាយរបស់ព្រះមានព្រះភាគ មានគ្រប់គ្រាន់ ព្រះមានព្រះភាគ ទ្រង់ប៉ះពាល់ផ្សព្វដោយកាយ តែឆន្ទរាគៈនៃព្រះមានព្រះភាគ មិនមានទេ ( ព្រោះ ) ព្រះមានព្រះភាគ មានព្រះហឫទ័យរួចស្រឡះដោយប្រពៃ ។ ព្រះហឫទ័យរបស់ព្រះមានព្រះភាគ មានគ្រប់គ្រាន់ព្រះមានព្រះភាគ ទ្រង់ជ្រាបច្បាស់ធម្មារម្មណ៍ដោយព្រះហឫទ័យ តែឆន្ទរាគៈនៃព្រះមានព្រះភាគ មិនមានទេ ( ព្រោះ ) ព្រះមានព្រះភាគ មានព្រះហឫទ័យ

រូបស្រឡះដោយប្រពៃ ។ ក្អែកមានរូប ជាទីត្រេកអរ ត្រេកអរហើយក្នុងរូប រីករាយព្រមចំពោះរូប ព្រះមានព្រះភាគ ទ្រង់បានទូន្មាន គ្រប់គ្រង រក្សា សង្រួមហើយ ទាំងទ្រង់សម្តែងធម៌ ដើម្បីការសង្រួមក្អែកនោះ ។ ត្រចៀកមានសំឡេងជាទីត្រេកអរ ត្រេកអរហើយក្នុងសំឡេង ប្រមុះមានក្លិនជាទីត្រេកអរ ត្រេកអរហើយក្នុងក្លិន អណ្តាតមានរសជាទីត្រេកអរ ត្រេកអរហើយក្នុងរស រីករាយព្រមចំពោះរស ព្រះមានព្រះភាគ ទ្រង់បានទូន្មាន គ្រប់គ្រង រក្សា សង្រួមហើយ ទាំងទ្រង់សម្តែងធម៌ដើម្បីការសង្រួមអណ្តាតនោះ ។ កាយមានផ្សព្វជាទីត្រេកអរ ចិត្តមានធម្មារម្មណ៍ជាទីត្រេកអរ ត្រេកអរហើយក្នុងធម្មារម្មណ៍ រីករាយព្រមចំពោះធម្មារម្មណ៍ ព្រះមានព្រះភាគ ទ្រង់បានទូន្មាន គ្រប់គ្រង រក្សា សង្រួមហើយ ទាំងទ្រង់សម្តែងធម៌ដើម្បីការសង្រួមកាយនោះ ។ ពួកជនរមែងនាំនូវពាហនៈ ដែលហាត់ហើយទៅកាន់ទីប្រជុំ ព្រះរាជារមែងឡើងគង់ពាហនៈដែលហាត់ហើយបណ្តាមនុស្សទាំងឡាយ មនុស្សណា អត់ធន់នឹងពាក្យពោលទ្រគោះ មនុស្សនោះ ឈ្មោះថាជាអ្នកហាត់ហើយ ជាបុគ្គលប្រសើរបំផុត ។ សេះអស្សតរក្តី សេះសន្ធពអាជានេយ្យក្តី ដំរីដ៏ប្រសើរជាកុញ្ជរជាតិក្តី ដែលគេបង្ហាត់ហើយ ឈ្មោះថា ជាសត្វប្រសើរ តែបុគ្គលអ្នកមានខ្លួនទូន្មានហើយ ប្រសើរជាងសត្វទាំងនោះ ។ បុគ្គលមិនគប្បីទៅកាន់ទិសដែលមិនដែលទៅ គឺព្រះនិព្វាន ដោយយានទាំងនោះបានទេ លុះតែបុគ្គលអ្នកមានខ្លួនទូន្មានហើយ ទើបទៅ ( កាន់ទិស គឺព្រះនិព្វាន ) ដោយខ្លួនដែលទូន្មានហើយ ទូន្មានល្អហើយ ។ ព្រះអរហន្តទាំងឡាយ រួចចាកកពថ្មី

ដល់ហើយនូវទន្តភូមិ គឺ អរហត្តផល រមែងមិនកម្រើកក្នុងតណ្ហា និងទិដ្ឋិផ្សេងៗ ព្រះអរហន្តទាំងនោះ ឈ្មោះថា ជាអ្នកមានជ័យជម្នះក្នុងលោក ។

ឥន្ទ្រិយទាំងឡាយ ដែលព្រះវីណាស្រពណាចម្រើនហើយ ព្រះវីណាស្រពនោះ ឈ្មោះថា មានធម៌ចម្រើនហើយ មានខ្លួនទូន្មានល្អហើយ ដឹងច្បាស់នូវអារម្មណ៍ទាំងខាងក្នុងខាងក្រៅ ក្នុងលោកទាំងពួងផង នូវលោកនេះផង នូវលោកខាងមុខផង រមែងរង់ចាំនូវកាលកិរិយាតែប៉ុណ្ណោះ ។

ព្រះមានព្រះភាគ ទ្រង់មានខ្លួនបានអប់រំហើយយ៉ាងនេះ ហេតុនោះ ខ្ញុំព្រះអង្គសម្គាល់ឃើញថា ព្រះអង្គជាអ្នកដល់នូវវេទ ជាអ្នកមានខ្លួនបានអប់រំហើយ ។

[ ១៤៥ ] អធិប្បាយពាក្យថា សេចក្តីទុក្ខទាំងនេះ កើតអំពីទីណាហ្ន៎ ត្រង់ពាក្យថា អំពីទីណាហ្ន៎ គឺជាសំណួរចំពោះសេចក្តីសង្ស័យ សំណួរចំពោះសេចក្តីងឿងឆ្ងល់ សំណួរចំពោះហេតុដែលបែកជាចម្លាមពីរ សំណួរចំពោះហេតុច្រើនយ៉ាង ថាយ៉ាងនេះឬហ្ន៎ មិនមែនទេឬហ្ន៎ ដូចម្តេចហ្ន៎ ដោយប្រការដូចម្តេចហ្ន៎ ហេតុនោះ ( លោកសួរថា ) អំពីណាហ្ន៎ ។ ពាក្យថា ទុក្ខ បានដល់ ជាតិទុក្ខ ជរាទុក្ខ ព្យាធិទុក្ខ មរណទុក្ខ សោកបរិទេវទុក្ខ ទោមនស្សុ-បាយាសទុក្ខ ទុក្ខក្នុងនរក ទុក្ខក្នុងកំណើតតិរច្ឆាន ទុក្ខក្នុងបិត្តិវិស័យ ទុក្ខជារបស់មនុស្ស ទុក្ខមានការចុះកាន់គភ៌ជាមូល ទុក្ខមានការតាំងនៅក្នុងគភ៌ជាមូល ទុក្ខមានការចេញចាកគភ៌ជាមូល ទុក្ខដែលជាប់ជំពាក់របស់សត្វកើតហើយ ទុក្ខ

ទាក់ទងអំពីអ្នកដទៃ របស់សត្វដែលកើតហើយ ទុក្ខកើតអំពីការព្យាយាម របស់ខ្លួន ទុក្ខកើតអំពីការព្យាយាមរបស់បុគ្គលដទៃ ទុក្ខទុក្ខ សង្ខារទុក្ខ បរិ-ណាមទុក្ខ រោគភ្នែក រោគត្រចៀក រោគច្រមុះរោគអណ្តាត រោគកាយ រោគក្បាល រោគត្រចៀក រោគមាត់ រោគធ្មេញ ក្អក ហឺត រោគច្រមុះ រោគក្តៅក្រហាយ រោគស្គាំងស្គម រោគផ្ទៃ រោគខ្យល់ចាប់ វិលមុខ រោគធ្លាក់ឈាម រោគចុកសៀត រោគចុះរាក ឃ្លង់ បូស ស្រែង រីងរៃ ឆ្កួតជ្រូក ដំនួចពិស រមាស់ កម រោគកើតក្នុងទីដែលខ្វារដោយក្រចក ឃ្លង់ដែក ប្រមាត់ក្រហម ប្រមេះទឹកបាយ ឫសដូងដុះ រលកកែវ ឫសដូងបាត អពាធកើតអំពីប្រមាត់ អាពាធកើតអំពីស្លេស្ម៍ អាពាធកើតអំពីខ្យល់ អពាធកើតអំពីសន្និបាត ( គឺការកម្រើកប្រមាត់ស្លេស្ម៍ និងខ្យល់ប្រជុំគ្នា ) អពាធកើតអំពីការប្រែប្រួលរដូវ អពាធកើតអំពីការផ្លាស់ប្តូរឥរិយាបថមិនស្មើ អាពាធកើតអំពីការព្យាយាមរបស់អ្នកឯទៀត អាពាធកើតអំពីផលកម្ម ត្រជាក់ ក្តៅ សម្រេកគម្លាន ឧច្ចារៈ បស្សាវៈ ទុក្ខព្រោះសម្ផស្សនៃរបោម មូស ខ្យល់ កម្តៅថ្ងៃនិងពស់ ទុក្ខ គឺមរណមាតា ទុក្ខ គឺមរណបិតា ទុក្ខ គឺមរណបងប្អូនប្រុស ទុក្ខ គឺមរណៈបងប្អូនស្រី ទុក្ខ គឺមរណបុត្ត ទុក្ខ គឺមរណធីតា ទុក្ខ គឺការវិនាសញាតិ ទុក្ខ គឺការវិនាសភោគៈ ទុក្ខ គឺការវិនាសសីល ទុក្ខ គឺការវិនាសទិដ្ឋិ ។ ការកើតឡើងអំពីខាងដើមនៃធម៌ទាំងឡាយណា ប្រាកដ ការរលត់ដោយការវិនាស ( នៃធម៌ទាំងនោះ ) ក៏ប្រាកដ ។ ផលអាស្រ័យកម្ម កម្មអាស្រ័យផល រូបអាស្រ័យនាម នាមអាស្រ័យរូប ជារបស់ត្រូវជាតិជាប់តាម ត្រូវជរា

រួបរឹត ត្រូវព្យាធិញាំញី ត្រូវមរណៈគ្របសង្កត់ តាំងនៅក្នុងទុក្ខ ឥតមាន ទីពំនាក់ ឥតមានទីជ្រក ឥតមានទីពឹង ឥតមានទីពំនឹង ធម៌ទាំងនេះ លោក ហៅថា ទុក្ខ ។ ទុក្ខទាំងនេះ ផ្សំផ្គុំមកអំពីណា កើតមកអំពីណា កើតព្រម អំពីណា លូតលាស់អំពីណា ដុះដាលអំពីណា កើតប្រាកដអំពីណា មានអ្វី ជានិទាន មានអ្វីជាទីប្រជុំកើត មានអ្វីជាដែនផ្តើមកើត ( មេត្តគូមាណព ) សួរឫសគល់ សួរហេតុ សួរនិទាន សួរកំណើត សួរហេតុជាដែនផ្តើមកើត សួរសមុដ្ឋាន សួរអាហារ សួរអារម្មណ៍ សួរបច្ច័យ សួរ សូម អារាធនា ជ្រះថ្លា ចំពោះ ទីប្រជុំកើតនៃទុក្ខទាំងនេះ ហេតុនោះ ( លោកសួរថា ) សេចក្តីទុក្ខទាំងនេះ កើតអំពីទីណាហ្ន៎ ។

[ ១៤៦ ] ពាក្យថា សេចក្តីទុក្ខទាំងឡាយណាមួយជាច្រើនប្រការក្នុង លោក ត្រង់ពាក្យថា ឯណាមួយ គឺគ្រប់ទាំងអស់ សព្វទាំងអស់ មិនមាន សល់ ឥតសល់ ពាក្យថា ឯណាមួយ នុ៎ះជាពាក្យរួម ។ ពាក្យថា ក្នុងលោក គឺអបាយលោក មនុស្សលោក ទេវលោក ខន្ធលោក ធាតុលោក អាយតនលោក ។ ពាក្យថា ជាច្រើនប្រការ គឺទុក្ខទាំងឡាយផ្សេងៗ ជាច្រើន មាន ប្រការផ្សេងៗ ហេតុនោះ ( លោកសួរថា ) ទុក្ខទាំងឡាយណាមួយ ជាច្រើនប្រការ ក្នុងលោក ។ ហេតុនោះ ព្រាហ្មណ៍នោះសួរថា

( មេត្តគូមានអាយុ ទូលសួរដូច្នេះថា ) បពិត្រព្រះមានព្រះភាគ
ខ្ញុំព្រះអង្គ សូមទូលសួរព្រះអង្គ សូមព្រះអង្គត្រាស់ប្រាប់ នូវ
សេចក្តីនោះ ដល់ខ្ញុំព្រះអង្គ ឲ្យទាន ខ្ញុំព្រះអង្គសម្គាល់ឃើញថា

ព្រះអង្គជាអ្នកដល់នូវវេទ ជាអ្នកមានខ្លួនបានអប់រំហើយ សេចក្តីទុក្ខទាំងឡាយណាមួយ ជាច្រើនប្រការ ក្នុងលោក សេចក្តីទុក្ខទាំងនេះ កើតមកអំពីទីណាហ្ន៎ ។

[ ១៤៧ ] ( ព្រះមានព្រះភាគត្រាស់ថា ម្នាលមេត្តគូ ) អ្នកសួរហេតុ ជាដែនផ្តើមកើតនៃសេចក្តីទុក្ខនឹងតថាគត តថាគតដឹងយ៉ាងណា នឹងប្រាប់ហេតុជាដែនផ្តើមកើតនៃសេចក្តីទុក្ខនោះ ដល់អ្នកយ៉ាងនោះ សេចក្តីទុក្ខទាំងឡាយណាមួយ ជាច្រើនប្រការក្នុងលោក សេចក្តីទុក្ខ ( ទាំងនោះ ) ផ្តើមកើតឡើង ព្រោះឧបធិជានិទាន ។

[ ១៤៨ ] អធិប្បាយពាក្យថា អ្នកសួរហេតុជាដែនផ្តើមកើតនៃសេចក្តីទុក្ខនឹងតថាគត ត្រង់ពាក្យថា នៃសេចក្តីទុក្ខ គឺនៃជាតិទុក្ខ ជរាទុក្ខ ព្យាធិទុក្ខ មរណទុក្ខ សោកបរិទេវទុក្ខ ទោមនស្សុបាយាសទុក្ខ ហេតុនោះ ( ទ្រង់ត្រាស់ថា ) នៃសេចក្តីទុក្ខ ។ ពាក្យថា អ្នកសួរហេតុជាដែនផ្តើមកើត ( នៃសេចក្តីទុក្ខ ) នឹងតថាគត គឺអ្នកសួរឬសគល់នៃទុក្ខនឹងតថាគត សួរហេតុ សួរនិទាន សួរកំណើត សួរការផ្តើមកើត សួរសមុដ្ឋាន សួរអាហារ សួរអារម្មណ៍ សួរបច្ច័យនៃទុក្ខ សួរ សូម អារាធនា ជ្រះថ្លា ចំពោះហេតុជាទីប្រជុំកើត ហេតុនោះ ( ទ្រង់ត្រាស់ថា ) អ្នកសួរហេតុជាដែនផ្តើមកើតនៃសេចក្តីទុក្ខនឹងតថាគត ។ ពាក្យថា មេត្តគូ គឺព្រះមានព្រះភាគទ្រង់ហៅព្រាហ្មណ៍នោះ តាមឈ្មោះ ។ ពាក្យថា ព្រះមានព្រះភាគនុ៎ះ ជាពាក្យពោល

ដោយគោរព ។បេ។ ការបញ្ញត្តិថា ព្រះមានព្រះភាគនេះ ( កើត ) ព្រោះការត្រាស់ដឹង ហេតុនោះ ( មានពាក្យថា ) ព្រះមានព្រះភាគត្រាស់ថា ម្នាលមេត្តគូ ។

[ ១៤៩ ] អធិប្បាយពាក្យថា តថាគតដឹងយ៉ាងណា នឹងប្រាប់ហេតុជាដែនផ្ដើមកើតនោះដល់អ្នកយ៉ាងនោះ ត្រង់ពាក្យថា តថាគតនឹងប្រាប់ហេតុជាដែនផ្ដើមកើតនុ៎ះ គឺតថាគតនឹងប្រាប់ឫសគល់នៃទុក្ខនោះដល់អ្នក នឹងប្រាប់ហេតុ នឹងប្រាប់និទាន នឹងប្រាប់កំណើត នឹងប្រាប់ហេតុជាដែនផ្ដើមកើត នឹងប្រាប់សមុដ្ឋាន នឹងប្រាប់អាហារ នឹងប្រាប់អារម្មណ៍ នឹងប្រាប់បច្ច័យ គឺនឹងប្រាប់ នឹងបង្ហាញ នឹងសម្ដែង នឹងបញ្ញត្ត នឹងតាំងទុក នឹងបើក នឹងចែក នឹងធ្វើឲ្យរាក់ នឹងប្រកាសនូវហេតុជាទីប្រជុំកើត ហេតុនោះ ( ទ្រង់ត្រាស់ថា ) នឹងប្រាប់ហេតុជាដែនផ្ដើមកើតនោះ ដល់អ្នក ។ ពាក្យថា តថាគតដឹងយ៉ាងណា គឺតថាគតដឹង ដឹងទូទៅ ដឹងច្បាស់ ដឹងចំពោះ ចាក់ធ្លុះ ដោយប្រការយ៉ាងណា គឺមិនមែនដោយអាងថាដូច្នេះៗ មិនមែនដោយឮថាដូច្នេះ មិនមែនដោយតៗ គ្នា មិនមែនដោយការផ្ទៀងតាមតម្រា មិនមែនដោយហេតុនៃសេចក្ដីត្រិះរិះ មិនមែនដោយហេតុនៃការយល់ មិនមែនដោយសេចក្ដីត្រិះរិះគិតតាមអាការ មិនមែនតាមសេចក្ដីយល់ឃើញ ការពិនិត្យ និងសេចក្ដីចូលចិត្តទេ តថាគតសម្ដែងធម៌ ដែលតថាគតត្រាស់ដឹងឯង ដោយខ្លួនឯង ជាធម៌ជាក់ច្បាស់ចំពោះខ្លួន ហេតុនោះ ( ទ្រង់ត្រាស់ថា ) តថាគតដឹងយ៉ាងណា ។

[ ១៥០ ] ពាក្យថា សេចក្ដីទុក្ខ ( ទាំងនោះ ) ផ្ដើមកើតឡើងព្រោះ

ឧបធិ ជានិទាន ត្រង់ពាក្យថា ឧបធិ បានដល់ឧបធិ ១០ គឺតណ្ហូបធិ ទិដ្ឋូ-បធិ កិលេសូបធិ កម្មូបធិ ទុច្ចរិតូបធិ អាហារូបធិ បដិឃូបធិ ឧបាទិន្នធាតុ ៤ ជាឧបធិ អាយតនៈខាងក្នុង ៦ ជាឧបធិ វិញ្ញាណកាយ ៦ ជាឧបធិ សូម្បីទុក្ខទាំងអស់ ឈ្មោះថា ឧបធិ ដោយសេចក្តីថាជាទុក្ខ ទាំងនេះ លោកហៅថា ឧបធិ ១០ ។ ពាក្យថា ទុក្ខ បានដល់ ជាតិទុក្ខ ជរាទុក្ខ ព្យាធិទុក្ខ មរណទុក្ខ សោកបរិទេវទុក្ខ ទោមនស្សុបាយាសទុក្ខ ។បេ។ ការត្រូវព្យាធិគ្របសង្កត់ ការត្រូវមរណៈកម្ចាត់បង់ ការតាំងនៅក្នុងទុក្ខ ការឥតពីពំនាក់ ការឥតមានទីជ្រកកោន ការឥតទីពឹង ការឥតទីពំនឹង ទាំងនេះ ហៅថា ទុក្ខ ។ ទុក្ខទាំងនេះ មាន កើតមាន ផ្តើមកើត កើតឡើង លូតលាស់ ដុះដាល ព្រោះឧបធិជានិទាន ព្រោះឧបធិជាហេតុ ព្រោះឧបធិជាបច្ច័យ ព្រោះឧបធិជាការណ៍ ហេតុនោះ ( ទ្រង់ត្រាស់ថា ) សេចក្តីទុក្ខ ( ទាំងនោះ ) ផ្តើមកើតឡើង ព្រោះឧបធិជានិទាន ។

[ ១៥១ ] ពាក្យថា សេចក្តីទុក្ខទាំងឡាយណាមួយ ជាច្រើនប្រការក្នុងលោក ត្រង់ពាក្យថា ណាមួយ គឺគ្រប់ទាំងអស់ សព្វទាំងអស់ មិនមានសល់ ឥតសល់ ពាក្យថា ណាមួយ នុ៎ះជាពាក្យប្រមូល ។ ពាក្យថា ក្នុងលោក គឺក្នុងអាបាយលោក មនុស្សលោក ទេវលោក ខន្ធលោក ធាតុលោក អាយតនលោក ។ ពាក្យថា ជាច្រើនប្រការ គឺទុក្ខទាំងឡាយផ្សេងៗ ជាច្រើនមានប្រការផ្សេងៗ ហេតុនោះ ( ទ្រង់ត្រាស់ថា ) សេចក្តីទុក្ខទាំងឡាយណាមួយ ជាច្រើនប្រការ ក្នុងលោក ។ ហេតុនោះ ព្រះមានព្រះភាគត្រាស់ថា

( ព្រះមានព្រះភាគត្រាស់ថា ម្នាលមេត្តគូ ) អ្នកសួរហេតុជាដែនផ្ដើមកើតនៃសេចក្ដីទុក្ខនឹងតថាគត តថាគតដឹងយ៉ាងណា នឹងប្រាប់ហេតុ ជាដែនផ្ដើមកើតនៃសេចក្ដីទុក្ខនោះដល់អ្នក យ៉ាងនោះ សេចក្ដីទុក្ខទាំងឡាយណាមួយ ជាច្រើនប្រការ ក្នុងលោក សេចក្ដីទុក្ខ ( ទាំងនោះ ) ផ្ដើមកើតឡើង ព្រោះឧបធិជានិទាន ។

[ ១៥២ ] បុគ្គលណា មិនចេះ តែងធ្វើឧបធិឲ្យកើតឡើង បុគ្គលល្ងង់ខ្លៅនោះ រមែងបានទុក្ខរឿយៗ ព្រោះហេតុនោះ បុគ្គលកាលដឹងច្បាស់ ជាអ្នកពិចារណាឃើញនូវជាតិ ជាដែនផ្ដើមកើតនៃទុក្ខមិនគប្បីធ្វើនូវឧបធិឡើយ ។

[ ១៥៣ ] ពាក្យថា បុគ្គលណា មិនចេះ តែងធ្វើឧបធិឲ្យកើតឡើង ត្រង់ពាក្យថា ណា គឺឯណា បែបណា ប្រកបយ៉ាងណា មានបែបផែនយ៉ាងណា មានប្រការយ៉ាងណា ដល់នូវឋានៈយ៉ាងណា ប្រកបដោយធម៌ណា ទោះជាក្សត្រក្ដី ព្រាហ្មណ៍ក្ដី វេស្សៈក្ដី សុទ្ទៈក្ដី គ្រហស្ថក្ដី បព្វជិតក្ដី ទេវតាក្ដី មនុស្សក្ដី ។ ពាក្យថា មិនចេះ គឺបុគ្គលជាអ្នកមិនចេះ តាំងនៅក្នុងអវិជ្ជា ជាអ្នកគ្មានញាណ មិនឈ្វេងយល់ អប្បឥតប្រាជ្ញា ។ ពាក្យថា ធ្វើឧបធិ គឺធ្វើតណ្ហូបធិ ធ្វើទិដ្ឋូបធិ ធ្វើកិលេសូបធិ ធ្វើកម្មូបធិ ធ្វើទុច្ចរិតូបធិ ធ្វើអាហារូបធិ ធ្វើបដិឃូបធិ ធ្វើឧបធិ គឺឧបាទិន្នធាតុ ៤ ធ្វើឧបធិ គឺអាយតនៈខាងក្នុង ៦ ធ្វើឲ្យកើត ឲ្យកើតព្រម បង្កើតនូវឧបធិ គឺពួកវិញ្ញាណ ៦ ហេតុនោះ ( ទ្រង់ត្រាស់ថា ) បុគ្គលណា មិនចេះ តែងធ្វើឧបធិឲ្យកើតឡើង ។

[ ១៥៤ ] ពាក្យថា បុគ្គលល្ងង់ខ្លៅ ( នោះ ) រមែងបានទុក្ខរឿយៗ ត្រង់ពាក្យថា រមែងបានទុក្ខរឿយៗ គឺដល់ ចូលដល់ ចូលទៅដល់ កាន់យក ស្ទាបអង្អែល ជាប់ជំពាក់ចំពោះជាតិទុក្ខ ជរាទុក្ខ ព្យាធិទុក្ខ មរណទុក្ខ សោកបរិទេវទុក្ខ ទោមនស្សុបាយាសទុក្ខរឿយៗ ហេតុនោះ ( ទ្រង់ត្រាស់ថា ) រមែងបានទុក្ខរឿយៗ ។ ពាក្យថា ល្ងង់ខ្លៅ គឺជាអ្នកល្ងង់ វង្វេង មិនចេះ តាំងនៅក្នុងអវិជ្ជា ជាអ្នកគ្មានញាណ មិនឈ្វេងយល់ ឥតប្រាជ្ញា ហេតុនោះ ( ទ្រង់ត្រាស់ថា ) បុគ្គលល្ងង់ខ្លៅ ( នោះ ) រមែងបានទុក្ខរឿយៗ ។

[១៥៥ ]អធិប្បាយពាក្យថា ព្រោះហេតុនោះ បុគ្គលកាលដឹងច្បាស់ មិនគប្បីធ្វើនូវឧបធិឡើយ ត្រង់ពាក្យថា ព្រោះហេតុនោះ គឺព្រោះហេតុដូច្នោះ ព្រោះដំណើរនោះ ព្រោះហេតុនោះ ព្រោះបច្ច័យនោះ ព្រោះនិទាននោះ បុគ្គលកាលឃើញច្បាស់នូវទោសនុ៎ះ ក្នុងឧបធិទាំងឡាយ ហេតុនោះ ( ទ្រង់ត្រាស់ថា ) ព្រោះហេតុនោះ ។ ពាក្យថា កាលដឹងច្បាស់ គឺកាលដឹងច្បាស់ កាលដឹងទូទៅ កាលដឹងវិសេស កាលដឹងចំពោះ កាលចាក់ធ្លុះថា សង្ខារទាំងពួងមិនទៀង កាលដឹងច្បាស់ កាលដឹងទូទៅ កាលដឹងវិសេស កាលដឹងចំពោះ កាលចាក់ធ្លុះថា សង្ខារទាំងពួង ជាទុក្ខ ថាធម៌ទាំងពួង ជាអនត្តា ។បេ។ កាលដឹងច្បាស់ កាលដឹងទូទៅ កាលដឹងវិសេស កាលដឹងចំពោះ កាលចាក់ធ្លុះថា ធម្មជាតណាមួយ មានកិរិយាកើតឡើងជាធម្មតា ធម្មជាតទាំងអស់នោះ មានកិរិយារលត់ទៅវិញជាធម្មតា ។ ពាក្យថា មិនគប្បីធ្វើឧបធិឡើយ គឺមិនគប្បីធ្វើតណ្ហូបធិ មិនគប្បីធ្វើទិដ្ឋូបធិ មិនគប្បីធ្វើកិលេសូបធិ មិនគប្បី

ធ្វើកម្មូបធិ មិនគប្បីធ្វើទុច្ចរិតូបធិ មិនគប្បីធ្វើអាហារូបធិ មិនគប្បីធ្វើបដិឃូបធិ មិនគប្បីធ្វើឧបធិ គឺឧបាទិន្នធាតុ ៤ មិនគប្បីធ្វើ មិនគប្បីឲ្យកើត មិនគប្បីឲ្យកើតព្រម មិនគប្បីបង្កើតនូវឧបធិ គឺអាយតនៈខាងក្នុង ៦ ហេតុនោះ ( ទ្រង់ត្រាស់ថា ) ព្រោះហេតុនោះ បុគ្គលកាលដឹងច្បាស់ មិនគប្បីធ្វើឧបធិឡើយ ។

[ ១៥៦ ] ពាក្យថា នៃទុក្ខ សេចក្តីថា បុគ្គលពិចារណាឃើញហេតុជាដែនផ្តើមកើត ពិចារណាឃើញឫសគល់ ពិចារណាឃើញហេតុ ពិចារណាឃើញនិទាន ពិចារណាឃើញកំណើត ពិចារណាឃើញសមុដ្ឋាន ពិចារណាឃើញអាហារ ពិចារណាឃើញអារម្មណ៍ ពិចារណាឃើញបច្ច័យ ពិចារណាឃើញទីប្រជុំកើតឡើងនៃជាតិទុក្ខ ជរាទុក្ខ ព្យាធិទុក្ខ មរណទុក្ខ សោកបរិទេវទុក្ខ ទោមនស្សុបាយាសទុក្ខ ។ បញ្ញា លោកហៅថា ការពិចារណាឃើញបានដល់ ប្រាជ្ញា ការដឹងច្បាស់ ។បេ។ ការមិនវង្វេង ការពិចារណាធម៌ ការឃើញត្រូវ ។ បុគ្គលជាអ្នកអែបនែប មូលមិត្ត ជិតជិត កៀកកើយ ផ្តេកផ្តួលកើតឡើងជាមួយ ប្រកបដោយការពិចារណាឃើញ គឺបញ្ញានេះ បុគ្គលនោះលោកហៅថា អ្នកពិចារណាឃើញ ព្រោះហេតុនោះ ទើបទ្រង់ត្រាស់ថា ជាអ្នកពិចារណាឃើញនូវជាតិ ជាដែនផ្តើមកើតនៃទុក្ខ ។ ហេតុនោះ ព្រះមានព្រះភាគត្រាស់ថា

បុគ្គលមិនចេះ តែងធ្វើនូវឧបធិឲ្យកើតឡើង បុគ្គលល្ងង់ខ្លៅនោះ
រមែងបានទុក្ខរឿយៗ ព្រោះហេតុនោះ បុគ្គលកាលដឹងច្បាស់ ជា
អ្នកពិចារណាឃើញនូវជាតិ ជាដែនផ្តើមកើតនៃទុក្ខ មិនគប្បីធ្វើ

នូវឧបធិឡើយ ។

[ ១៥៧ ] ( មេត្តគូទូលថា ) យើងខ្ញុំបានទូលសួរសេចក្តីណា ព្រះអង្គបានត្រាស់ប្រាប់សេចក្តីនោះ ដល់យើងខ្ញុំ យើងខ្ញុំសូមសួរសេចក្តីឯទៀត ចំពោះព្រះអង្គ សូមព្រះអង្គសម្តែងសេចក្តីនោះ អ្នកប្រាជ្ញទាំងឡាយ ឆ្លងឱឃៈផង ជាតិជរាផង សោក និងបរិទេវៈផង ដោយប្រការដូចម្តេចហ្ន៎ សូមព្រះអង្គជាមុនិ ដោះស្រាយនូវឧបាយជាគ្រឿងឆ្លងនោះ ដល់យើងខ្ញុំ ព្រោះព្រះអង្គជ្រាបច្បាស់ធម៌នោះហើយ ។

[ ១៥៨ ] ពាក្យថា យើងខ្ញុំបានទូលសួរនូវសេចក្តីណា ព្រះអង្គបានត្រាស់ប្រាប់សេចក្តីនោះដល់យើងខ្ញុំ គឺយើងខ្ញុំបានសួរ បានសូម បានអារាធនា បានជ្រះថ្លាចំពោះសេចក្តីណា ។ ពាក្យថា ព្រះអង្គបានត្រាស់ប្រាប់សេចក្តីនោះ ដល់យើងខ្ញុំ គឺព្រះអង្គបានសម្តែងប្រាប់សេចក្តីនោះ ពន្យល់សេចក្តីនោះ បញ្ញត្តសេចក្តីនោះ ផ្តួចផ្តើមនូវសេចក្តីនោះ បើកសេចក្តីនោះ ចែកសេចក្តីនោះ ធ្វើឲ្យរាក់សេចក្តីនោះ ប្រកាសសេចក្តីនោះ ដល់យើងខ្ញុំ ហេតុនោះ ( លោកសួរថា ) យើងខ្ញុំបានទូលសួរនូវសេចក្តីណា ព្រះអង្គបានត្រាស់ប្រាប់សេចក្តីនោះ ដល់យើងខ្ញុំ ។

[ ១៥៩ ] អធិប្បាយពាក្យថា យើងខ្ញុំសូមសួរសេចក្តីឯទៀតចំពោះព្រះអង្គ សូមព្រះអង្គសម្តែងសេចក្តីនោះ អ្នកប្រាជ្ញទាំងឡាយ ឆ្លងឱឃៈផង ជាតិជរាផង សោក និងបរិទេវៈផង ដោយប្រការដូចម្តេចហ្ន៎ ត្រង់ពាក្យថា

ដោយប្រការដូចម្តេចហ្ន៎ គឺជាសំណួរចំពោះសេចក្តីសង្ស័យ សំណួរចំពោះសេចក្តីងឿងឆ្ងល់ សំណួរចំពោះផ្លូវបែកជាចម្លាមពីរ សំណួរចំពោះហេតុច្រើនយ៉ាងថា យ៉ាងនេះឬហ្ន៎ មិនមែនទេឬហ្ន៎ ដូចម្តេចហ្ន៎ ដោយប្រការដូចម្តេចហ្ន៎ ហេតុនោះ ( លោកសួរថា ) ដោយប្រការដូចម្តេចហ្ន៎ ។ ពាក្យថា អ្នកប្រាជ្ញទាំងឡាយ គឺអ្នកប្រាជ្ញ បណ្ឌិត អ្នកមានប្រាជ្ញា អ្នកមានយោបល់ អ្នកមានញាណ អ្នកមានការឈ្វេងយល់ អ្នកមានប្រាជ្ញាធុះធ្លាយ ។ ពាក្យថា ឱឃៈ បានដល់ ឱឃៈ គឺកាម ឱឃៈ គឺភព ឱឃៈ គឺទិដ្ឋិ ឱឃៈ គឺអវិជ្ជា ។ ពាក្យថា ជាតិ បានដល់ កំណើត ការកើតព្រម ការចុះកាន់គភ៌ ការផ្ដួចផ្ដើមឡើង ការកើតឡើងចំពោះ ការប្រាកដឡើងនៃខន្ធ ការបានចំពោះនូវអាយតនៈនៃពួកសត្វនោះៗ ក្នុងសត្តនិកាយនោះៗ ។ ពាក្យថា ជរា បានដល់ ការចាស់ ការគ្រាំគ្រា ការរង្គោះធ្មេញ ការស្កូវសក់ ការជ្រួញជ្រីវស្បែក ការរួញថយអាយុ ការចាស់ទុំនៃឥន្ទ្រិយរបស់ពួកសត្វនោះៗ ក្នុងសត្តនិកាយនោះៗ ។ ពាក្យថា សោក គឺការសោកស្តាយ អាការជាទីសោកស្តាយ ភាពនៃការសោកស្តាយ ការស្ងួតខាងក្នុង កាស្រពោនខាងក្នុង ការក្តៅខាងក្នុង ការរោលរាលខាងក្នុង អាការជាទីសញ្ជប់សញ្ជឹងនៃចិត្ត ការអាក់អន់ចិត្ត សរ គឺការសោករបស់បុគ្គលដែលត្រូវសេចក្តីវិនាសញាតិប៉ះពាល់ ឬត្រូវសេចក្តីវិនាសនៃភោគៈប៉ះពាល់ ត្រូវសេចក្តីវិនាស គឺរោគប៉ះពាល់ ឬត្រូវសេចក្តីវិនាសសីលប៉ះពាល់ ត្រូវសេចក្តីវិនាស គឺទិដ្ឋិប៉ះពាល់ ឬប្រកបដោយសេចក្តីវិនាសណាមួយ ឬក៏ត្រូវទុក្ខធម៌ណាមួយប៉ះពាល់ ។ ពាក្យថា

សេចក្ដីខ្សឹកខ្សួល គឺការខ្សឹកខ្សួល អាការយំ អាការខ្សឹកខ្សួល ភាពនៃការយំ ភាពនៃការខ្សឹកខ្សួល ការទួញរៀបរាប់ ការពោលរៀបរាប់ ការរៀបរាប់ដដែលៗ ការពោលរំពូក អការនៃការពោលរំពូក ភាពនៃការពោលរំពូក នៃបុគ្គលដែលត្រូវសេចក្ដីវិនាសញាតិប៉ះពាល់ ឬត្រូវសេចក្ដីវិនាសភោគៈប៉ះពាល់ ត្រូវសេចក្ដីវិនាសរោគប៉ះពាល់ ឬត្រូវសេចក្ដីវិនាសសីលប៉ះពាល់ ត្រូវសេចក្ដីវិនាស គឺទិដ្ឋិប៉ះពាល់ ឬប្រកបដោយសេចក្ដីវិនាសណាមួយ ឬក៏ត្រូវទុក្ខធម៌ណាមួយប៉ះពាល់ ។ ពាក្យថា អ្នកប្រាជ្ញទាំងឡាយ ឆ្លងឱឃៈផងជាតិជរាផង សោក និងបរិទេវៈផង ដោយប្រការដូចម្ដេចហ្ន៎ បានសេចក្ដីថា អ្នកប្រាជ្ញទាំងឡាយ ឆ្លងឡើង ឆ្លងកាត់ ឈានកន្លង ប្រព្រឹត្តកន្លង នូវឱឃៈផង នូវជាតិជរាផង នូវសោកបរិទេវៈផង ដោយប្រការដូចម្ដេច ហេតុនោះ ( លោកសួរថា ) អ្នកប្រាជ្ញទាំងឡាយ ឆ្លងឱឃៈផង ជាតិជរាផង សោក និងបរិទេវៈផង ដោយប្រការដូចម្ដេចហ្ន៎ ។

[ ១៦០ ] អធិប្បាយពាក្យថា សូមព្រះអង្គជាមុនិ ដោះស្រាយនូវឧបាយជាគ្រឿងឆ្លងនោះ ត្រង់ពាក្យថា នោះ គឺខ្ញុំព្រះអង្គទូលសួរសេចក្ដីណា សូមសេចក្ដីណា អារាធនាសេចក្ដីណា ជ្រះថ្លាចំពោះសេចក្ដីណា ។ ពាក្យថា មុនិ សេចក្ដីថា ញាណ លោកហៅថា មោនៈ បានខាងប្រាជ្ញា ការដឹងច្បាស់ ។បេ។ ការមិនវង្វេង ការពិចារណាធម៌ ការឃើញត្រូវ ព្រះមានព្រះភាគប្រកបដោយញាណនោះ ទើបទ្រង់ព្រះនាមថា មុនិ ព្រះអង្គដល់នូវមោនៈ ។ មោនេយ្យៈ ៣ គឺកាយមោនេយ្យៈ វចីមោនេយ្យៈ មនោមោនេយ្យៈ ។

កាយមោនេយ្យៈ តើដូចម្តេច ។ ការលះបង់កាយទុច្ចរិត ៣ ឈ្មោះថា កាយមោនេយ្យៈ កាយសុចរិត ៣ ឈ្មោះថា កាយមោនេយ្យៈ ញាណមានកាយជាអារម្មណ៍ ឈ្មោះថា កាយមោនេយ្យៈ ការកំណត់ដឹងនូវកាយ ឈ្មោះថា កាយមោនេយ្យៈ មគ្គប្រកបដោយការកំណត់ដឹង ឈ្មោះថា កាយ-មោនេយ្យៈ ការលះបង់ឆន្ទរាគៈក្នុងកាយ ឈ្មោះថា កាយមោនេយ្យៈ ការរលត់កាយសង្ខារ គឺចតុត្ថជ្ឈានសមាបត្តិ ឈ្មោះថា កាយមោនេយ្យៈ នេះកាយមោនេយ្យៈ ។

វចីមោនេយ្យៈ តើដូចម្តេច ។ ការលះបង់វចីទុច្ចរិត ៤ ឈ្មោះថា វចី-មោនេយ្យៈ វចីសុចរិត ៤ ឈ្មោះថា វចីមោនេយ្យៈ ញាណមានវាចាជាអារម្មណ៍ ឈ្មោះថា វចីមោនេយ្យៈ ការកំណត់ដឹងនូវវាចា ឈ្មោះថា វចី-មោនេយ្យៈ មគ្គប្រកបដោយការកំណត់ដឹង ឈ្មោះថា វចីមោនេយ្យៈ ការលះបង់ឆន្ទរាគៈក្នុងវាចា ឈ្មោះថា វចីមោនេយ្យៈ ការរលត់វចីសង្ខារ និងទុតិយជ្ឈានសមាបត្តិ ឈ្មោះថា វចីមោនេយ្យៈ នេះ វចីមោនេយ្យៈ ។

មនោមោនេយ្យៈ តើដូចម្តេច ។ ការលះបង់មនោទុច្ចរិត ៣ ឈ្មោះថា មនោមោនេយ្យៈ មនោសុចរិត ៣ ឈ្មោះថា មនោមោនេយ្យៈ ញាណមានចិត្តជាអារម្មណ៍ ឈ្មោះថា មនោមោនេយ្យៈ ការកំណត់ដឹងចិត្ត ឈ្មោះថា មនោមោនេយ្យៈ មគ្គប្រកបដោយការកំណត់ដឹង ឈ្មោះថា មនោមោនេយ្យៈ ការលះបង់ឆន្ទរាគៈក្នុងចិត្ត ឈ្មោះថា មនោមោនេយ្យៈ ការរលត់ចិត្តសង្ខារ គឺសញ្ញាវេទយិតនិរោធសមាបត្តិ ឈ្មោះថា មនោមោនេយ្យៈ នេះ មនោ-

មោនេយ្យៈ ។

អ្នកប្រាជ្ញទាំងឡាយ បានពោលនូវបុគ្គលជាកាយមុនិ ជាវាចាមុនិ ជាមនោមុនិ ជាអនាសវមុនិ ដែលបរិបូណ៌ដោយមោនេយ្យៈ ថាជាអ្នកលះបង់នូវកិលេសទាំងពួង អ្នកប្រាជ្ញទាំងឡាយ បានពោលនូវបុគ្គលជាកាយមុនិ ជាវាចាមុនិ ជាមនោមុនិ ជាអនាសវមុនិ ដែលបរិបូណ៌ដោយមោនេយ្យៈ ថាជាអ្នកលាងបាបហើយ ។

មុនិមាន ៦ ពួក ដែលប្រកបដោយមោនេយ្យធម៌ទាំងនេះ គឺអាគារមុនិ ១ អនាគារមុនិ ១ សេក្ខមុនិ ១ អសេក្ខមុនិ ១ បច្ចេកមុនិ ១ មុនិមុនិ ១ ។ អាគារមុនិ តើដូចម្តេច ។ ពួកជនណា ជាអ្នកគ្រប់គ្រងផ្ទះទេ តែមានព្រះនិព្វានឃើញហើយ មានសាសនធម៌ដឹងច្បាស់ហើយ ពួកជននេះ ឈ្មោះថា អាគារមុនិ ។ អនាគារមុនិ តើដូចម្តេច ។ ពួកបុគ្គលណា ជាបព្វជិត មានព្រះនិព្វានឃើញហើយ មានសាសនធម៌ដឹងច្បាស់ហើយ ពួកបុគ្គលនេះ ឈ្មោះថា អនាគារមុនិ ។ សេក្ខបុគ្គលទាំងឡាយ ៧ ពួក ឈ្មោះថា សេក្ខមុនិ ។ ព្រះបច្ចេកពុទ្ធទាំងឡាយ ឈ្មោះថា បច្ចេកមុនិ ។ ព្រះតថាគតទាំងឡាយ ជាអរហន្តសម្មាសម្ពុទ្ធ ឈ្មោះថា មុនិមុនិ ។

បុគ្គលល្ងង់ខ្លៅ ជាអ្នកមិនចេះ មិនឈ្មោះថា មុនិ ដោយការស្ងៀមទេ លុះតែបុគ្គលណា ជាបណ្ឌិត កាន់យកធម៌ដ៏ប្រសើរ វៀរនូវបាបទាំងឡាយ ដូចបុគ្គលអ្នកថ្លឹងនូវរបស់ដោយជញ្ជីង បុគ្គលនោះ ឈ្មោះថា មុនិ បុគ្គលនោះ ទើបឈ្មោះថា មុនិ ដោយ

ហេតុនោះ បុគ្គលណាដឹងនូវប្រយោជន៍ទាំងពីរក្នុងលោក បុគ្គលនោះ លោកហៅថា មុនិ ដោយហេតុនោះ ។

បុគ្គលណា ដឹងនូវធម៌របស់ពួកអសប្បុរសផង របស់ពួកសប្បុរសផង ដឹងនូវអាយតនៈខាងក្នុងផង ខាងក្រៅផង ក្នុងលោកទាំងពួង ជាបុគ្គលដែលទេវតា និងមនុស្សទាំងឡាយបូជាហើយ កន្លងផុតនូវបណ្តាញ គឺកិលេសជាគ្រឿងជាប់ជំពាក់ បុគ្គលនោះ ឈ្មោះថា មុនិ ។

ពាក្យថា សូមព្រះអង្គដោះស្រាយ គឺសូមព្រះអង្គប្រាប់ សម្តែង បញ្ញត្តតាំងទុក បើក ចែក ធ្វើឲ្យរាក់ ប្រកាស ហេតុនោះ ( លោកសួរថា ) សូមព្រះអង្គជាមុនិ ដោះស្រាយនូវឧបាយជាគ្រឿងឆ្លងនោះ ។

[ ១៦១ ] ពាក្យថា ព្រោះព្រះអង្គជ្រាបច្បាស់ធម៌នោះហើយ គឺព្រោះព្រះអង្គជ្រាប ស្គាល់ ថ្លឹង ពិចារណា យល់ ប្រាកដនូវធម៌នោះហើយ ហេតុនោះ ( លោកសួរថា ) ព្រោះអង្គជ្រាបច្បាស់ធម៌នោះហើយ ។ ហេតុនោះ ព្រាហ្មណ៍នោះពោលថា

យើងខ្ញុំបានទូលសួរសេចក្តីណា ព្រះអង្គបានត្រាស់ប្រាប់សេចក្តីនោះ ដល់យើងខ្ញុំ យើងខ្ញុំសូមសួរសេចក្តីឯទៀត ចំពោះព្រះអង្គ សូមព្រះអង្គសម្តែងសេចក្តីនោះ អ្នកប្រាជ្ញទាំងឡាយឆ្លងឱឃៈផង ជាតិជរាផង សោក និងបរិទេវៈផង ដោយប្រការដូចម្តេចហ្ន៎ សូមព្រះអង្គជាមុនិ ដោះស្រាយនូវឧបាយជាគ្រឿងឆ្លងនោះ ដល់យើង

ខ្ញុំ ព្រោះព្រះអង្គជ្រាបធម៌នោះហើយ ។

[ ១៦២ ] ( ព្រះមានព្រះភាគត្រាស់ថា ម្នាលមេត្តគូ ) តថាគត នឹងសម្តែងធម៌ដល់អ្នក ដែលជាធម៌ជាក់ច្បាស់ក្នុងខ្លួន ចំពោះធម៌ដែលឃើញហើយ ជាធម៌ដែលបុគ្គលមានសតិ ដឹង ហើយប្រព្រឹត្ត គប្បីឆ្លងវិសត្តិកាតណ្ហា ក្នុងលោកបាន ។

[ ១៦៣ ] ពាក្យថា តថាគតនឹងសម្តែងធម៌ដល់អ្នក គឺតថាគតនឹងសម្តែង នឹងពន្យល់ នឹងបញ្ញត្ត នឹងតាំងទុក នឹងបើក នឹងចែក នឹងធ្វើឲ្យរាក់ នឹងប្រកាសនូវព្រហ្មចរិយធម៌ ដ៏បរិសុទ្ធបរិបូណ៌ទាំងអស់ ព្រមទាំងអត្ថ និងព្យញ្ជនៈ មានលម្អក្នុងខាងដើម មានលម្អត្រង់កណ្តាល មានលម្អក្នុងទីបំផុតផង នូវសតិប្បដ្ឋាន ៤ ផង នូវសម្មប្បធាន ៤ ផង នូវឥទ្ធិបាទ ៤ ផង នូវឥន្ទ្រិយ ៥ ផង នូវពល ៥ ផង នូវពោជ្ឈង្គ ៧ ផង នូវមគ្គដ៏ប្រសើរប្រកបដោយអង្គ ៨ ផង នូវព្រះនិព្វានផង នូវបដិបទាជាដំណើរទៅកាន់ព្រះនិព្វានផង ហេតុនោះ ទ្រង់ត្រាស់ថា តថាគតនឹងសម្តែងធម៌ដល់អ្នក ។ ពាក្យថា មេត្តគូ គឺព្រះមានព្រះភាគ ទ្រង់ហៅព្រាហ្មណ៍នោះ ដោយចំណោះ ។

[ ១៦៤ ] អធិប្បាយពាក្យថា ដែលជាធម៌ជាក់ច្បាស់ក្នុងខ្លួនចំពោះធម៌ដែលឃើញហើយ ត្រង់ពាក្យថា ចំពោះធម៌ដែលឃើញហើយ គឺចំពោះធម៌ដែលឃើញ ធម៌ដែលដឹង ធម៌ដែលថ្លឹង ធម៌ដែលពិចារណា ធម៌ដែលឈ្វេងយល់ ធម៌ដែលច្បាស់ហើយថា សង្ខារធម៌ទាំងពួងមិនទៀង ។បេ។ ចំពោះធម៌

ដែលឃើញ ធម៌ដែលថ្លឹង ធម៌ដែលពិចារណា ធម៌ដែលឈ្វេងយល់ ធម៌ដែលច្បាស់ហើយថា ធម្មជាតណាមួយ មានកិរិយាកើតឡើងជាធម្មតា ធម្មជាតទាំងអស់នោះ មានកិរិយារលត់ទៅវិញជាធម្មតា ហេតុនោះ តថាគតនឹងសម្តែងធម៌ ដែលឃើញហើយយ៉ាងនេះខ្លះ ។ មួយទៀត តថាគតនឹងសម្តែងទុក្ខ ចំពោះទុក្ខដែលឃើញហើយ នឹងសម្តែងសមុទ័យ ចំពោះសមុទ័យដែលឃើញហើយ នឹងសម្តែងមគ្គ ចំពោះមគ្គដែលឃើញហើយ នឹងសម្តែងនិរោធ ចំពោះនិរោធដែលឃើញហើយ ហេតុនោះ តថាគតនឹងសម្តែងចំពោះធម៌ដែលឃើញហើយយ៉ាងនេះខ្លះ ។ មួយទៀត គុណជាតដែលបុគ្គលគប្បីឃើញជាក់ច្បាស់ដោយខ្លួនឯងក្នុងបច្ចុប្បន្ន ជាគុណឲ្យផលមិនរង់ចាំកាល ជាធម៌ហាក់ដូចជានឹងហៅថា អ្នកចូរមកមើលចុះ ជាធម៌គួរបង្អោនមកទុកក្នុងខ្លួនបាន ជាធម៌ដែលអ្នកប្រាជ្ញទាំងឡាយ គប្បីដឹងជាក់ច្បាស់ចំពោះខ្លួន ហេតុនោះ តថាគតនឹងសម្តែងចំពោះធម៌ ដែលឃើញហើយយ៉ាងនេះខ្លះ ហេតុនោះ ( ទ្រង់ត្រាស់ថា ) ចំពោះធម៌ដែលឃើញហើយ ។ ពាក្យថា ដែលជាធម៌ជាក់ច្បាស់ក្នុងខ្លួន គឺតថាគតសម្តែងធម៌ ដែលត្រាស់ដឹងឯងដោយខ្លួនឯង ជាក់ច្បាស់ចំពោះខ្លួន មិនមែនដោយអាងថា ដូច្នេះៗ មិនមែនដោយឮថា ដូច្នេះៗ មិនមែនដោយទំនៀម មិនមែនដោយការផ្សំតាមតម្រា មិនមែនដោយហេតុនៃសេចក្តីត្រិះរិះ មិនមែនដោយហេតុនៃការយល់ មិនមែនដោយសេចក្តីរិះគិតតាមអាការ មិនមែនតាមសេចក្តីឃើញ ការពិនិត្យ និងសេចក្តីចូលចិត្តទេ ហេតុនោះ ( ទ្រង់ត្រាស់ថា ) ដែលជាធម៌ជាក់ច្បាស់ក្នុង

ខ្លួន ចំពោះធម៌ដែលឃើញហើយ ។

[ ១៦៥ ] ពាក្យថា ជាធម៌ដែលបុគ្គលមានសតិ ដឹងហើយប្រព្រឹត្ត សេចក្តីថា បុគ្គលធ្វើ ថ្លឹង ពិចារណា ឈ្វេងយល់ ធ្វើឲ្យប្រាកដនូវធម៌ណា ឲ្យច្បាស់ថា សង្ខារទាំងពួងមិនទៀង ។បេ។ ធ្វើ ថ្លឹង ពិចារណា ឈ្វេងយល់ ធ្វើឲ្យប្រាកដនូវធម៌ឲ្យច្បាស់ថា ធម្មជាតណាមួយ មានកិរិយាកើតឡើងជាធម្មតា ធម្មជាតទាំងអស់នោះ មានកិរិយារលត់ទៅវិញជាធម្មតា ។ ពាក្យថា មានសតិ គឺបុគ្គលមានសតិដោយហេតុ ៤ គឺបុគ្គលចម្រើននូវកាយានុ-បស្សនាសតិប្បដ្ឋានក្នុងកាយ ឈ្មោះថា មានសតិ ។បេ។ បុគ្គលនោះ លោកហៅថា អ្នកមានសតិ ។ ពាក្យថា ប្រព្រឹត្ត គឺបុគ្គល កាលត្រាច់ វង្គាត់ សម្រេច ប្រព្រឹត្ត រក្សា យាត្រា យាត្រាទៅ ហេតុនោះ ( ទ្រង់ត្រាស់ថា ) ជាធម៌ដែលបុគ្គលមានសតិដឹងហើយ ប្រព្រឹត្ត ។

[ ១៦៦ ] ពាក្យថា គប្បីឆ្លងវិសត្តិកាតណ្ហា ក្នុងលោក បានសេចក្តីថា តណ្ហា លោកហៅថា វិសត្តិកា បានដល់ រាគៈ រាគៈមានកម្លាំង ។បេ។ អភិជ្ឈា លោភៈ អកុសលមូល ។ សំណួរត្រង់ពាក្យថា វិសត្តិកា ដែលឈ្មោះថា វិសត្តិកា តើដោយអត្ថដូចម្តេច ។ ឈ្មោះថា វិសត្តិកា ព្រោះជាធម្មជាតផ្សាយទៅ ។ ឈ្មោះថា វិសត្តិកា ព្រោះទូលាយ ។ ឈ្មោះថា វិសត្តិកា ព្រោះលាទៅ ។ ឈ្មោះថា វិសត្តិកា ព្រោះរួញរា ។ ឈ្មោះថា វិសត្តិកា ព្រោះពោលខុស ។ ឈ្មោះថាវិសត្តិកា ព្រោះមានឫសគល់ជាពិស ។ ឈ្មោះថា វិសត្តិកា ព្រោះមានផ្លែជាពិស ។ ឈ្មោះថា វិសត្តិកា ព្រោះមាន

គ្រឿងបរិភោគជាពិស ។ មួយទៀត ឈ្មោះថា វិសត្តិកា ព្រោះតណ្ហានោះ ជាកិលេសជាតិ ដ៏ទូលាយ ផ្សាយទៅ ត្រដាងទៅ ក្នុងរូប សំឡេង ក្លិន រស ផ្សព្វ ត្រកូល គណៈ អាវាសៈ លាភ យស សេចក្តីសរសើរ សុខ ចីវរ បិណ្ឌបាត សេនាសនៈ គិលានប្បច្ចយភេសជ្ជបរិក្ខារ កាមធាតុ រូបធាតុ អរូបធាតុ កាមភព រូបភព អរូបភព សញ្ញាភព អសញ្ញាភព នេវសញ្ញានាសញ្ញាភព ឯកវោការភព ចតុវោការភព បញ្ចវោការភព អតីត អនាគត បច្ចុប្បន្ន ក្នុងធម៌ទាំងឡាយ ដែលឃើញ ឮ ប៉ះពាល់ ឬគប្បីដឹង ។ ពាក្យថា ក្នុងលោក គឺក្នុងអបាយលោក មនុស្សលោក ទេវលោក ខន្ធលោក ធាតុលោក អាយតនលោក ។ ពាក្យថា គប្បីឆ្លងវិសត្តិកាតណ្ហា ក្នុងលោកបាន បានសេចក្តីថា តណ្ហាណា ឈ្មោះថា វិសត្តិកាក្នុងលោក បុគ្គលមានសតិ គប្បីឆ្លង ឆ្លងឡើង ឆ្លងកាត់ ឈានកន្លង ប្រព្រឹត្តកន្លង នូវតណ្ហាឈ្មោះថាវិសត្តិកានោះ ក្នុងលោក ព្រោះហេតុនោះ ( ទ្រង់ត្រាស់ថា ) គប្បីឆ្លងវិសត្តិកាតណ្ហា ក្នុងលោកបាន ។ ហេតុនោះ ព្រះមានព្រះភាគត្រាស់ថា

> ( ព្រះមានព្រះភាគត្រាស់ថា ម្នាលមេត្តគូ ) តថាគត នឹងសំដែងធម៌ដល់អ្នក ដែលជាធម៌ជាក់ច្បាស់ក្នុងខ្លួន ចំពោះធម៌ដែលឃើញហើយ ជាធម៌ដែលបុគ្គលមានសតិ ដឹងហើយប្រព្រឹត្ត គប្បីឆ្លងវិសត្តិកាតណ្ហា ក្នុងលោកបាន ។
>
> [ ១៦៧ ] ( មេត្តគូទូលថា ) ព្រះមានព្រះភាគ ព្រះអង្គស្វែងរកគុណដ៏ធំ មានសតិ ទ្រង់ជ្រាបនូវធម៌ណា ជាធម៌ដ៏ឧត្តម

ហើយប្រព្រឹត្ត គប្បីឆ្លងវិសត្តិកាតណ្ហា ក្នុងលោកបាន ចំណែកខ្ញុំព្រះអង្គត្រេកអរចំពោះធម៌នោះ ។

[ ១៦៨ ] ពាក្យថា ខ្ញុំព្រះអង្គត្រេកអរចំពោះធម៌នោះ ត្រង់ពាក្យថា ចំពោះធម៌នោះ គឺចំពោះពាក្យ គន្លងពាក្យ ទេសនា អនុសន្ធិរបស់ព្រះអង្គ ។ ពាក្យថា ខ្ញុំព្រះអង្គត្រេកអរ គឺខ្ញុំព្រះអង្គស្រស់ស្រាយ ត្រេកអររីករាយ រីករាយតាម ប្រាថ្នា ចង់បាន សូម ត្រូវការ ស្រឡាញ់ ជាប់ចិត្ត ហេតុនោះ ( លោកពោលថា ) ខ្ញុំព្រះអង្គត្រេកអរចំពោះធម៌នោះ ។

[ ១៦៩ ] អធិប្បាយពាក្យថា ព្រះអង្គស្វែងរកគុណដ៏ធំ ... ជាធម៌ដ៏ឧត្តម សំណួរត្រង់ពាក្យថា ស្វែងរកគុណដ៏ធំ ចុះឈ្មោះថា ស្វែងរកគុណដ៏ធំ តើដោយអត្ថដូចម្តេច ។ ឈ្មោះថា ស្វែងរកគុណដ៏ធំ ព្រោះព្រះមានព្រះភាគទ្រង់រក ស្វែង ស្ទះស្វែង នូវសីលក្ខន្ធដ៏ធំ ឈ្មោះថា ស្វែងរកគុណដ៏ធំ ព្រោះទ្រង់រក ស្វែង ស្ទះស្វែង នូវសមាធិក្ខន្ធដ៏ធំ បញ្ញាខន្ធដ៏ធំ វិមុត្តិក្ខន្ធដ៏ធំ វិមុត្តិញ្ញាណទស្សនក្ខន្ធដ៏ធំ ។ មួយទៀត ឈ្មោះថា ស្វែងរកគុណដ៏ធំ ព្រោះទ្រង់រក ស្វែង ស្ទះស្វែង នូវការទម្លាយ នូវគំនរនៃងងឹតដ៏ធំ ។ ឈ្មោះថា ស្វែងរកគុណដ៏ធំ ព្រោះទ្រង់រក ស្វែង ស្ទះស្វែង នូវការបំបែកនូវវិបល្លាសដ៏ធំ ។ ឈ្មោះថា ស្វែងរកគុណដ៏ធំ ព្រោះទ្រង់រក ស្វែង ស្ទះស្វែង នូវការដកឡើង នូវសរ គឺតណ្ហាដ៏ធំ ។ ឈ្មោះថា ស្វែងរកគុណដ៏ធំ ព្រោះទ្រង់រក ស្វែង ស្ទះស្វែង នូវការទម្លុះទម្លាយ នូវឃ្នាបគឺទិដ្ឋិដ៏ធំ ។ ឈ្មោះថា ស្វែងរកគុណដ៏ធំ ព្រោះទ្រង់រក ស្វែង ស្ទះស្វែង នូវការទម្លាក់

ចុះនូវទង់ គឺមានះដ៏ធំ ។ ឈ្មោះថា ស្វែងរកគុណដ៏ធំ ព្រោះទ្រង់រក ស្វែង ស្វះស្វែង នូវការរម្ងាប់នូវអភិសង្ខារដ៏ធំ ។ ឈ្មោះថា ស្វែងរកគុណដ៏ធំ ព្រោះទ្រង់រក ស្វែង ស្វះស្វែង នូវការរើឡើងនូវឱឃៈដ៏ធំ ។ ឈ្មោះថា ស្វែងរកគុណដ៏ធំ ព្រោះទ្រង់រក ស្វែង ស្វះស្វែង នូវការដាក់ចុះនូវភារៈដ៏ធំ ឈ្មោះថា ស្វែងរកគុណដ៏ធំ ព្រោះទ្រង់រក ស្វែង ស្វះស្វែង នូវការផ្តាច់បង់នូវសង្សារវដ្តដ៏ធំ ។ ឈ្មោះថា ស្វែងរកគុណដ៏ធំ ព្រោះទ្រង់រក ស្វែង ស្វះស្វែង នូវការរម្ងត់នូវកម្តៅដ៏ធំ ។ ឈ្មោះថា ស្វែងរកគុណដ៏ធំ ព្រោះទ្រង់រក ស្វែង ស្វះស្វែង នូវការរម្ងាប់សេចក្តីក្រេវក្រវដ៏ធំ ។ ឈ្មោះថា ស្វែងរកគុណដ៏ធំ ព្រោះទ្រង់រក ស្វែង ស្វះស្វែង នូវការលើកឡើងនូវទង់ គឺធម៌ដ៏ធំ ។ ឈ្មោះថា ស្វែងរកគុណដ៏ធំ ព្រោះទ្រង់រក ស្វែង ស្វះស្វែង នូវសតិប្បដ្ឋានដ៏ធំ សម្មប្បធានដ៏ធំ ឥទ្ធិបាទដ៏ធំ ឥន្ទ្រិយដ៏ធំ ពលដ៏ធំ ពោជ្ឈង្គធំ មគ្គដ៏ប្រសើរប្រកបដោយអង្គ ៨ ដ៏ធំ អមតនិព្វានមានអត្ថដ៏ក្រៃលែងដ៏ធំ ។ មួយទៀត ឈ្មោះថា ស្វែងរកគុណដ៏ធំ ព្រោះពួកសត្វមានសក្តិដ៏ធំ រក ស្វែង ស្វះស្វែង ថា ព្រះពុទ្ធគង់ក្នុងទីណា ព្រះមានព្រះភាគគង់ក្នុងទីណា ព្រះអង្គជាទេវតាប្រសើរជាងទេវតា គង់ក្នុងទីណា ព្រះអង្គជានរៈដ៏ក្លៀវក្លា គង់ក្នុងទីណា ។ ពាក្យថា ជាធម៌ដ៏ឧត្តម សេចក្តីថា អមតនិព្វាន លោកហៅថា ធម៌ដ៏ឧត្តម បានខាងការរម្ងាប់សង្ខារទាំងពួង ការលះបង់ចោលឧបធិទាំងពួង ការអស់តណ្ហា ការប្រាសចាកតម្រេក ការរលត់ និព្វាន ។ ពាក្យថា ឧត្តម គឺធម៌ជាកំពូល ប្រសើរ ប្រសើរវិសេស ជាប្រធាន ខ្ពង់ខ្ពស់ ថ្លៃថ្លា ហេតុនោះ

( លោកពោលថា ) ព្រះអង្គស្វែងរកគុណដ៏ធំ ... ជាធម៌ដ៏ឧត្តម ។

[ ១៧០ ] ពាក្យថា មានសតិជ្រាបច្បាស់នូវធម៌ណា ហើយប្រព្រឹត្ត គឺធ្វើឲ្យច្បាស់ ថ្លឹង ពិចារណា ឈ្វេងយល់ ធ្វើឲ្យប្រាកដថា សង្ខារទាំងពួង មិនទៀង ។បេ។ ធ្វើឲ្យច្បាស់ ថ្លឹង ពិចារណា ឈ្វេងយល់ ធ្វើឲ្យប្រាកដថា ធម្មជាតឯណានីមួយ មានកិរិយាកើតឡើងជាធម្មតា ធម្មជាតទាំងអស់នោះ មានកិរិយារលត់ទៅវិញជាធម្មតា ។ ពាក្យថា មានសតិ សេចក្តីថា មានសតិ ដោយហេតុ ៤ គឺបុគ្គលចម្រើនកាយានុបស្សនាសតិប្បដ្ឋានក្នុងកាយ ឈ្មោះ ថា អ្នកមានសតិ ។បេ។ បុគ្គលនោះ លោកហៅថា អ្នកមានសតិ ។ ពាក្យ ថា ប្រព្រឹត្ត គឺប្រព្រឹត្ត ត្រួតត្រា សម្រេច ទៅ រក្សា យាត្រា យាត្រាទៅ ហេតុនោះ ( លោកពោលថា ) មានសតិ ជ្រាបច្បាស់នូវធម៌ណា ហើយ ប្រព្រឹត្ត ។

[ ១៧១ ] ពាក្យថា គប្បីឆ្លងវិសត្តិកាតណ្ហា ក្នុងលោកបាន សេចក្តីថា តណ្ហា លោកហៅថា វិសត្តិកា បានដល់ រាគៈ រាគៈមានកម្លាំង ។បេ។ អភិជ្ឈា លោភៈ អកុសលមូល ។ សំណួរត្រង់ពាក្យថា វិសត្តិកា ចុះឈ្មោះ វិសត្តិកា តើដោយអត្ថដូចម្តេច ។បេ។ ឈ្មោះថា វិសត្តិកា ព្រោះផ្សាយទៅ ត្រដាងទៅ ។ ពាក្យថា ក្នុងលោក គឺក្នុងអបាយលោក ។បេ។ អាយតន- លោក ។ ពាក្យថា គប្បីឆ្លងវិសត្តិកាតណ្ហា ក្នុងលោក បានសេចក្តីថា តណ្ហាណា ឈ្មោះវិសត្តិកា ក្នុងលោក ព្រះមហេសីមានសតិ គប្បីឆ្លង ឆ្លង ឡើង ឆ្លងកាត់ ឈានកន្លង ប្រព្រឹត្តកន្លង នូវវិសត្តិកាតណ្ហានោះ ក្នុងលោក

ហេតុនោះ ( លោកពោលថា ) គប្បីឆ្លងវិសត្តិកាតណ្ហា ក្នុងលោកបាន ។ ហេតុនោះ ព្រាហ្មណ៍នោះពោលថា

ព្រះមានព្រះភាគ ព្រះអង្គស្វែងរកនូវគុណដ៏ធំ មានសតិ ទ្រង់ជ្រាបច្បាស់នូវធម៌ណា ជាធម៌ដ៏ឧត្តម ហើយប្រព្រឹត្ត គប្បីឆ្លងធម្មវិសត្តិកាតណ្ហា ក្នុងលោកបាន ចំណែកខ្ញុំព្រះអង្គ ត្រេកអរចំពោះធម៌នោះ ។

[ ១៧២ ] ( ព្រះមានព្រះភាគត្រាស់ថា ម្នាលមេត្តគូ ) អ្នកបើដឹងច្បាស់ នូវធម្មជាតណាមួយ ទាំងខាងលើ ខាងក្រោម និងទទឹង គឺកណ្តាលហើយ អ្នកចូរបន្ទោបង់នូវសេចក្តីត្រេកត្រអាលផង សេចក្តីប្រកាន់ផង វិញ្ញាណផង ក្នុងធម៌ទាំងឡាយនុ៎ះចេញ ទើបមិនស្ថិតនៅក្នុងភព ។

[ ១៧៣ ] ពាក្យថា អ្នកបើដឹងច្បាស់នូវធម្មជាតណាមួយ គឺបើអ្នកដឹងច្បាស់ ដឹងទូទៅ ដឹងវិសេស ដឹងចំពោះ យល់ច្បាស់ នូវធម្មជាតណាមួយ ហេតុនោះ ( ទ្រង់ត្រាស់ថា ) អ្នកបើដឹងច្បាស់នូវធម្មជាតណាមួយ ។ ព្រះមានព្រះភាគ ទ្រង់ហៅព្រាហ្មណ៍នោះតាមឈ្មោះថា មេត្តគូ ។ ពាក្យថា ព្រះមានព្រះភាគនុ៎ះ គឺជាពាក្យហៅដោយគោរព ។បេ។ ការបញ្ញត្តិថា ព្រះមានព្រះភាគនេះ ( កើត ) ព្រោះការត្រាស់ដឹង ហេតុនោះ ( មានពាក្យថា ) ព្រះមានព្រះភាគត្រាស់ថា ម្នាលមេត្តគូ ។

[ ១៧៤ ] ពាក្យថា ទាំងខាងលើ ខាងក្រោម និងទទឹង គឺកណ្តាល

អធិប្បាយថា អនាគត លោកហៅថា ខាងលើ អតីត លោកហៅថា ខាងក្រោម បច្ចុប្បន្ន លោកហៅថា ទទឹង គឺកណ្ដាល ។ ទេវលោក លោកហៅថា ខាងលើ ។ និរយលោក លោកហៅថា ខាងក្រោម ។ មនុស្សលោក លោកហៅថា ទទឹង គឺកណ្ដាល ។ ពាក្យថា ខាងលើ បានដល់ កុសលធម៌ ។ ពាក្យថា ខាងក្រោម បានដល់ អកុសលធម៌ ។ ពាក្យថា ទទឹង គឺកណ្ដាល បានដល់ អព្យាកតធម៌ ។ ពាក្យថា ខាងលើ បានដល់ អរូបធាតុ ។ ពាក្យថា ខាងក្រោម បានដល់ កាមធាតុ ។ ពាក្យថា ទទឹង គឺកណ្ដាល បានដល់ រូបធាតុ ។ ពាក្យថា ខាងលើ បានដល់ សុខវេទនា ។ ពាក្យថា ខាងក្រោម បានដល់ ទុក្ខវេទនា ។ ពាក្យថា ទទឹង គឺកណ្ដាល បានដល់ អទុក្ខមសុខវេទនា ។ ពាក្យថា ខាងលើ គឺខាងលើអំពីបាតជើងឡើងទៅ ។ ពាក្យថា ខាងក្រោម គឺខាងក្រោមតាំងពីចុងសក់ចុះមក ។ ពាក្យថា ទទឹង គឺកណ្ដាល បានដល់ ក្នុងទីពាក់កណ្ដាលខ្លួន ហេតុនោះ ( ទ្រង់ត្រាស់ថា ) ខាងលើ ខាងក្រោម និងទទឹង គឺកណ្ដាល ។

[ ១៧៥ ] អធិប្បាយពាក្យថា អ្នកចូរបន្ទោបង់នូវសេចក្ដីត្រេកត្រអាលផង សេចក្ដីប្រកាន់ផង វិញ្ញាណផង ក្នុងធម៌ទាំងឡាយនុ៎ះចេញ ទើបមិនស្ថិតនៅក្នុងភព ត្រង់ពាក្យថា ក្នុងធម៌ទាំងឡាយនុ៎ះ គឺក្នុងធម៌ទាំងឡាយ ដែលតថាគតប្រាប់ សម្ដែង បញ្ញត្ត តាំងទុក បើក ចែក ធ្វើឲ្យរាក់ប្រកាសហើយ ។ តណ្ហា លោកហៅថា សេចក្ដីត្រេកត្រអាល បានដល់

រាគៈ រាគៈមានកម្លាំង ។បេ។ អភិជ្ឈា លោភៈ អកុសលមូល ។ ពាក្យថា សេចក្តីប្រកាន់ បានដល់ សេចក្តីប្រកាន់ ២ គឺការប្រកាន់ គឺតណ្ហា ១ ការប្រកាន់ គឺទិដ្ឋិ ១ ។ ការប្រកាន់ គឺតណ្ហា តើដូចម្តេច ។ ពោល គឺតណ្ហា មានកំណត់ត្រឹមណា ។បេ។ នេះ សេចក្តីប្រកាន់ គឺតណ្ហា ។ សេចក្តីប្រកាន់ គឺទិដ្ឋិ តើដូចម្តេច ។ សក្កាយទិដ្ឋិមានវត្ថុ ២០ ។បេ។ នេះ សេចក្តីប្រកាន់ គឺទិដ្ឋិ ។ ពាក្យថា ចូរបន្ទោបង់វិញ្ញាណ សេចក្តីថា វិញ្ញាណប្រកបដោយបុញ្ញាភិសង្ខារ វិញ្ញាណប្រកបដោយអបុញ្ញាភិសង្ខារ វិញ្ញាណប្រកបដោយអនេញ្ជាភិសង្ខារ ។ អ្នកចូរខ្ជាក់ រលាស់ បន្សាត់ ផាត់ លះ ប្រាន បន្ទោបង់ ធ្វើឲ្យវិនាស ធ្វើមិនឲ្យមានបែបភាព នូវសេចក្តីត្រេកត្រអាលផង នូវសេចក្តីប្រកាន់ផង នូវវិញ្ញាណប្រកបដោយអភិសង្ខារផង ក្នុងធម៌ទាំងឡាយនោះ ហេតុនោះ ( ទ្រង់ត្រាស់ថា ) អ្នកចូរបន្ទោបង់សេចក្តីត្រេកត្រអាលផង សេចក្តីប្រកាន់ផង វិញ្ញាណផង ក្នុងធម៌ទាំងឡាយនោះ ។ ពាក្យថា ភព របស់បទថា មិនស្ថិតនៅក្នុងភព បានដល់ ភព ២ គឺកម្មភព ១ បុនព្ភព គឺបដិសន្ធិ ១ ។ កម្មភព តើដូចម្តេច ។ គឺបុញ្ញាភិសង្ខារ អបុញ្ញាភិសង្ខារ អនេញ្ជាភិសង្ខារ នេះកម្មភព ។ បុនព្ភព គឺបដិសន្ធិ តើដូចម្តេច ។ រូប វេទនា សញ្ញា សង្ខារ វិញ្ញាណ ដែលប្រកបដោយបដិសន្ធិនេះ បុនព្ភព គឺបដិសន្ធិ ។ ពាក្យថា មិនស្ថិតនៅក្នុងភព គឺបុគ្គលកាលលះបង់ បន្ទោបង់ ធ្វើឲ្យវិនាស មិនឲ្យមានបែបភាព នូវសេចក្តីត្រេកត្រអាលផង នូវសេចក្តីប្រកាន់ផង នូវវិញ្ញាណដែលប្រកបដោយអភិសង្ខារផង នូវកម្មភពផង នូវបុនព្ភព គឺបដិសន្ធិផង ទើប

មិនគប្បីស្ថិតនៅក្នុងកម្មភព មិនគប្បីស្ថិតនៅ មិនគប្បីតាំងនៅក្នុងបុនព្ភព គឺ បដិសន្ធិ ហេតុនោះ ( ទ្រង់ត្រាស់ថា ) អ្នកចូរបន្ទោបង់វិញ្ញាណ ទើបមិនស្ថិតនៅក្នុងភព ។ ហេតុនោះ ព្រះមានព្រះភាគត្រាស់ថា

( ព្រះមានព្រះភាគត្រាស់ថា ម្នាលមេត្តគូ ) អ្នក បើដឹងច្បាស់នូវធម្មជាតណាមួយ ទាំងខាងលើ ខាងក្រោម និងទទឹង គឺកណ្ដាល ហើយ អ្នកចូរបន្ទោបង់នូវសេចក្ដីត្រេកត្រអាលផង សេចក្ដីប្រកាន់ផង វិញ្ញាណផង ក្នុងធម៌ទាំងឡាយនុ៎ះចេញ ទើបមិនស្ថិតនៅក្នុងភព ។

[ ១៧៦ ] ភិក្ខុមានការនៅយ៉ាងនេះ មានសតិ អ្នកមិនប្រហែស លះបង់សេចក្ដីប្រកាន់ ហើយប្រព្រឹត្ត ជាអ្នកចេះដឹង គប្បីលះបង់នូវទុក្ខ គឺជាតិ ជរា សោក និងបរិទេវៈ ក្នុងលោកនេះបាន ។

[ ១៧៧ ] អធិប្បាយពាក្យថា មានការនៅយ៉ាងនេះ មានសតិ អ្នកមិនប្រហែស ត្រង់ពាក្យថា មានការនៅយ៉ាងនេះ គឺភិក្ខុកាលលះបង់ បន្ទោបង់ ធ្វើឲ្យវិនាស ធ្វើមិនឲ្យមានបែបភាព នូវសេចក្ដីត្រេកត្រអាលផង នូវសេចក្ដីប្រកាន់ផង នូវវិញ្ញាណដែលប្រកបដោយអភិសង្ខារផង នូវកម្មភពផង នូវបុនព្ភព គឺបដិសន្ធិផង ហេតុនោះ ( ទ្រង់ត្រាស់ ) ថា មានការនៅយ៉ាងនេះ ។ ពាក្យថា មានសតិ គឺបុគ្គលមានសតិដោយហេតុ ៤ គឺបុគ្គលចម្រើនកាយានុបស្សនាសតិបដ្ឋានក្នុងកាយ ។បេ។ បុគ្គលនោះ លោកហៅថា អ្នកមានសតិ ។ ពាក្យថា អ្នកមិនប្រហែស គឺអ្នកធ្វើដោយគោរព អ្នកធ្វើមិនឈប់

អ្នកប្រព្រឹត្តមិនរួញរា មានបំណងមិនដាក់ចុះ មានធុរៈមិនដាច់ចុះ អ្នកមិនប្រហែសក្នុងកុសលធម៌ គឺបានខាងបំណង ការព្យាយាម សេចក្តីខ្មីឃ្មាត ការប្រឹងប្រែង ការមិនថយក្រោយ សតិ និងសម្បជញ្ញៈ ការខ្នះខ្នែង ការតម្កល់ទុក ការអធិដ្ឋាន ការប្រកបរឿយៗ ការមិនធ្វេសប្រហែស ក្នុងកុសលធម៌ទាំងនោះថា អញ្ចាល់ណា អាត្មាអញនឹងបំពេញសីលក្ខន្ធដែលមិនទាន់ពេញ ឬជ្រោមជ្រែងទុកនូវសីលក្ខន្ធ ដែលពេញហើយ ដោយប្រាជ្ញា ក្នុងធម៌នោះ ( ឬ ) បំណង ការព្យាយាម សេចក្តីខ្មីឃ្មាត សេចក្តីប្រឹងប្រែង ការមិនថយក្រោយ សតិ និងសម្បជញ្ញៈ ការខ្នះខ្នែង ការតម្កល់ទុក ការអធិដ្ឋាន ការប្រកបរឿយៗ ការមិនធ្វេសប្រហែសក្នុងកុសលទាំងនោះថា អញ្ចាល់ណា អាត្មាអញនឹងបំពេញសមាធិក្ខន្ធ វិមុត្តិក្ខន្ធ វិមុត្តិញាណទស្សនក្ខន្ធ ដែលមិនទាន់ពេញ និងជ្រោមជ្រែងទុកនូវវិមុត្តិញាណទស្សនក្ខន្ធ ដែលពេញហើយដោយបញ្ញា ក្នុងធម៌ទាំងនោះ ( ឬក៏ ) បំណង ការព្យាយាម សេចក្តីខ្មីឃ្មាត សេចក្តីប្រឹងប្រែង ការមិនថយក្រោយ សតិ និងសម្បជញ្ញៈ ការខ្នះខ្នែង ការតម្កល់ទុក ការអធិដ្ឋាន ការប្រកបរឿយៗ ការមិនធ្វេសប្រហែសក្នុងកុសលទាំងនោះថា អញ្ចាល់ណា អាត្មាអញនឹងកំណត់ដឹងនូវទុក្ខ ដែលមិនបានកំណត់ដឹង ឬនឹងលះនូវកិលេស ដែលមិនទាន់លះ នឹងចម្រើនមគ្គដែលមិនទាន់ចម្រើន នឹងធ្វើឲ្យជាក់ច្បាស់នូវនិរោធ ដែលមិនទាន់ធ្វើឲ្យជាក់ច្បាស់ ហេតុនោះ ( ទ្រង់ត្រាស់ថា ) មានការនៅយ៉ាងនេះ មានសតិ អ្នកមិនប្រហែស ។

[ ១៧៨ ] ពាក្យថា ភិក្ខុ របស់បទថា ភិក្ខុលះបង់នូវសេចក្តីប្រកាន់ហើយប្រព្រឹត្ត បានដល់ ភិក្ខុជាកល្យាណបុថុជ្ជន ឬភិក្ខុជាសេក្ខៈ ។ ពាក្យថា ប្រព្រឹត្ត គឺប្រព្រឹត្ត ត្រួតត្រាមើល សម្រេច ទៅ រក្សា យាត្រា ឲ្យយាត្រាទៅ ។ ពាក្យថា សេចក្តីប្រកាន់ បានដល់ សេចក្តីប្រកាន់ ២ គឺសេចក្តីប្រកាន់ គឺតណ្ហា ១ សេចក្តីប្រកាន់ គឺទិដ្ឋិ ១ ។បេ។ នេះ សេចក្តីប្រកាន់គឺតណ្ហា ។បេ។ នេះ សេចក្តីប្រកាន់ គឺទិដ្ឋិ ភិក្ខុលះបង់សេចក្តីប្រកាន់ គឺតណ្ហា វលាស់ចោល សេចក្តីប្រកាន់ គឺទិដ្ឋិ លះបង់ លះចោល បន្ទោបង់ធ្វើឲ្យវិនាស ធ្វើមិនឲ្យមានបែបភាព នូវសេចក្តីប្រកាន់ ព្រោះហេតុនោះ ( ទ្រង់ត្រាស់ថា ) ភិក្ខុលះបង់សេចក្តីប្រកាន់ ហើយប្រព្រឹត្ត ។

[ ១៧៩ ] អធិប្បាយពាក្យថា ជាអ្នកចេះដឹង គប្បីលះបង់ទុក្ខ គឺជាតិ ជរា សោក និងបរិទេវៈ ក្នុងលោកនេះបាន ត្រង់ពាក្យថា ជាតិ បានដល់ កំណើត ការកើតព្រម ការចុះកាន់គភ៌ ការផ្ចិតផ្តើមឡើង ការកើតឡើងចំពោះ ការប្រាកដឡើងនៃខន្ធ ការបានចំពោះអាយតនៈនៃពួកសត្វនោះៗ ក្នុងសត្តនិកាយនោះៗ ។ ពាក្យថា ជរា បានដល់ ការចាស់ ការគ្រាំគ្រា ការរង្គោះធ្មេញ ការស្កូវសក់ ការជ្រួញជ្រីវស្បែក ការរួញថយនៃអាយុ ការចាស់ទុំនៃឥន្ទ្រិយរបស់ពួកសត្វនោះៗ ក្នុងសត្តនិកាយនោះៗ ។ ពាក្យថា សោក គឺ សោក អាការសោក ភាពនៃសោក ការស្ងួតស្ងប់ក្នុងសន្តាន ការស្រពោនក្នុងសន្តាន ការក្តៅក្នុងសន្តាន ការរោលរាលក្នុងសន្តាន អាការជាទីសញ្ជប់ជញ្ជីងចិត្ត ការអាក់អន់ចិត្ត សរ គឺសោករបស់បុគ្គលដែលត្រូវវិនាសញាតិ

ប៉ះពាល់ក្តី ត្រូវវិនាសភោគៈប៉ះពាល់ក្តី ត្រូវវិនាស គឺរោគប៉ះពាល់ក្តី ត្រូវវិនាសសីលប៉ះពាល់ក្តី ត្រូវវិនាស គឺទិដ្ឋិប៉ះពាល់ក្តី ប្រកបដោយវិនាសណាមួយក្តី ត្រូវទុក្ខធម៌ណាមួយប៉ះពាល់ក្តី ។ ពាក្យថា សេចក្តីខ្សឹកខ្សួល គឺការយំ ការខ្សឹកខ្សួល អាការយំ អាការខ្សឹកខ្សួល ភាពនៃការយំ ភាពនៃការខ្សឹកខ្សួល ការទួញរៀបរាប់ ការពោលរៀបរាប់ ការរៀបរាប់ដដែលៗ ការពោលរម៉ឹក អាការពោលរៀបរាប់ ភាពនៃការពោលរៀបរាប់របស់បុគ្គលដែលត្រូវវិនាសញាតិប៉ះពាល់ក្តី ត្រូវវិនាសភោគៈប៉ះពាល់ក្តី ត្រូវវិនាស គឺរោគប៉ះពាល់ក្តី ត្រូវវិនាសសីលប៉ះពាល់ក្តី ត្រូវវិនាស គឺទិដ្ឋិប៉ះពាល់ក្តី ប្រកបដោយវិនាសណាមួយក្តី ត្រូវទុក្ខធម៌ណាមួយប៉ះពាល់ក្តី ។ ពាក្យថា ក្នុងលោកនេះ គឺក្នុងទិដ្ឋិនេះ ។បេ។ ក្នុងមនុស្សលោកនេះ ។ពាក្យថា ជាអ្នកចេះដឹង បានដល់ អ្នកចេះ អ្នកតាំងនៅក្នុងវិជ្ជា មានញាណ មានការឈ្វេងយល់ មានប្រាជ្ញាផ្ចុះផ្ចាយ ។ ពាក្យថា ទុក្ខ បានដល់ ជាតិទុក្ខ ។បេ។ សោកបរិទេវទុក្ខ ទោមនស្សុបាយាសទុក្ខ ។ ពាក្យថា អ្នកចេះដឹង គប្បីលះបង់ទុក្ខ គឺជាតិ ជរា សោក និងបរិទេវៈ ក្នុងលោកនេះ បានន័យថា បុគ្គលអ្នកចេះ អ្នកតាំងនៅក្នុងវិជ្ជា មានញាណ មានការឈ្វេងយល់ មានប្រាជ្ញាផ្ចុះផ្ចាយ គប្បីលះបង់ បន្ទោបង់ ធ្វើឲ្យវិនាស មិនឲ្យមានបែបភាពនូវជាតិ និងជរាផង សោក និងបរិទេវៈផង ក្នុងលោកនេះ ហេតុនោះ ( ទ្រង់ត្រាស់ថា ) ជាអ្នកចេះដឹង គប្បីលះបង់ទុក្ខ គឺជាតិ ជរា សោក និងបរិទេវៈ ក្នុងលោកនេះ ។ ហេតុនោះ ព្រះមានព្រះភាគត្រាស់ថា

ភិក្ខុមានការនៅយ៉ាងនេះ មានសតិ អ្នកមិនប្រហែស លះបង់សេចក្ដីប្រកាន់ ហើយប្រព្រឹត្ត ជាអ្នកចេះដឹង គប្បីលះបង់នូវទុក្ខ គឺជាតិ ជរា សោក និងបរិទេវៈ ក្នុងលោកនេះបាន ។

[ ១៨០ ] ( មេត្តគូមាណពទូលថា ) ខ្ញុំព្រះអង្គត្រេកអរចំពោះព្រះវាចាទុំរបស់ព្រះមហេសី បពិត្រព្រះគោតម ព្រះនិព្វានជាគុណជាតមិនមានឧបធិ ព្រះអង្គបានសម្ដែងហើយ ដោយប្រពៃ ព្រះមានព្រះភាគ លះទុក្ខបានដោយពិត ព្រោះធម៌ទុំះ ព្រះអង្គជ្រាបច្បាស់ហើយ ។

[ ១៨១ ] ពាក្យថា ខ្ញុំព្រះអង្គត្រេកអរចំពោះព្រះវាចាទុំះ របស់ព្រះមហេសី ត្រង់ពាក្យថា ចំពោះព្រះវាចាទុំះ គឺចំពោះពាក្យ គន្លងនៃពាក្យទេសនា អនុសន្ធិ របស់ព្រះអង្គ ។ ពាក្យថា ត្រេកអរចំពោះ គឺខ្ញុំព្រះអង្គស្រស់ស្រាយ ត្រេកអរ រីករាយ រីករាយតាម ប្រាថ្នា ចង់បាន សូម ត្រូវការ ស្រឡាញ់ ជាប់ចិត្ត ។ ពាក្យថា របស់ព្រះមហេសី គឺព្រះមានព្រះភាគទ្រង់ព្រះនាមមហេសី ព្រោះទ្រង់ស្វែង ស្វែងរក ស្វះស្វែង នូវសីលក្ខន្ធដ៏ធំ ។បេ។ ទ្រង់ព្រះនាមមហេសី ព្រោះព្រះអង្គជានរៈដ៏អង់អាច តាមតែក្នុងទីណា ហេតុនោះ ( លោកពោលថា ) ខ្ញុំព្រះអង្គត្រេកអរចំពោះព្រះវាចាទុំះរបស់ព្រះមហេសី ។

[ ១៨២ ] អធិប្បាយពាក្យថា បពិត្រព្រះគោតម ព្រះនិព្វានជាគុណជាតមិនមានឧបធិ ព្រះអង្គសម្ដែងហើយ ដោយប្រពៃ ត្រង់ពាក្យថា ព្រះអង្គ

សម្តែងហើយ ដោយប្រពៃគឺព្រះអង្គសម្តែងដោយល្អ ប្រាប់ដោយល្អ ពន្យល់ដោយល្អ សម្តែងដោយប្រពៃ បញ្ញត្តទុកដោយល្អ តាំងទុកដោយល្អ បើកដោយល្អ ចែកដោយល្អ ធ្វើឲ្យរាក់ដោយល្អ ប្រកាសទុកហើយដោយល្អ ហេតុនោះ ( លោកពោលថា ) ព្រះអង្គសម្តែងហើយដោយប្រពៃ ។ ពាក្យថា បពិត្រព្រះគោតម ព្រះនិព្វានជាគុណជាតមិនមានឧបធិ សេចក្តីថា ពួកកិលេស ខន្ធនិងអភិសង្ខារ លោកហៅថា ឧបធិ ។ ការលះឧបធិ ការរម្ងាប់ឧបធិ ការរលាស់ចោលឧបធិ ការស្ងប់រម្ងាប់ឧបធិ ឈ្មោះថា អមតនិព្វាន ហេតុនោះ( លោកពោលថា ) បពិត្រព្រះគោតម ព្រះនិព្វានជាគុណជាតមិនមានឧបធិ ព្រះអង្គសម្តែងហើយ ដោយប្រពៃ ។

[ ១៨៣ ] អធិប្បាយពាក្យថា ព្រះមានព្រះភាគ ទ្រង់លះបង់ទុក្ខដោយពិត ត្រង់ពាក្យថា ដោយពិត គឺជាពាក្យដាច់ខាត ជាពាក្យឥតសង្ស័យ ជាពាក្យឥតងឿងឆ្ងល់ ជាពាក្យមិនបែកជាពីរ ជាពាក្យមិនមានចម្លាមពីរ ជាពាក្យស្រោចស្រង់ ជាពាក្យមិនខុស ពាក្យថា ដោយពិត ជាពាក្យតាំងមាំ ។ ពាក្យថា ព្រះមានព្រះភាគនុ៎ះ ជាពាក្យពោលដោយគោរព ។បេ។ ការបញ្ញត្តិថា ព្រះមានព្រះភាគ នេះ ( កើត ) ព្រោះការត្រាស់ដឹង ។ ពាក្យថា ទ្រង់លះទុក្ខ គឺលះបង់ លះចេញ បន្ទោបង់ ធ្វើឲ្យវិនាស មិនឲ្យមានបែបភាពនូវជាតិទុក្ខ ជរាទុក្ខ ព្យាធិទុក្ខ មរណទុក្ខ សោកបរិទេវទុក្ខ ទោមនស្សុបាយាសទុក្ខ ហេតុនោះ ( លោកសួរថា ) ព្រះមានព្រះភាគ ទ្រង់លះទុក្ខបាន ដោយពិត ។

[ ១៨៤ ] ពាក្យថា ព្រះធម៌នុ៎ះ ព្រះអង្គជ្រាបច្បាស់ហើយ គឺព្រោះធម៌នុ៎ះ ព្រះអង្គជ្រាបច្បាស់ ដឹង ថ្លឹង ពិចារណា ឈ្វេងយល់ ប្រាកដ ហេតុនោះ ( លោកសួរថា ) ព្រោះធម៌នុ៎ះ ព្រះអង្គជ្រាបច្បាស់ហើយ ។ ហេតុនោះព្រាហ្មណ៍នោះពោលថា

ខ្ញុំព្រះអង្គ ត្រេកអរចំពោះព្រះវាចានុ៎ះ របស់ព្រះមហេសី បពិត្រព្រះគោតម ព្រះនិព្វានជាគុណជាត មិនមានឧបធិ ព្រះអង្គសម្ដែងហើយ ដោយប្រពៃ ព្រះមានព្រះភាគ លះទុក្ខបាន ដោយពិត ព្រោះធម៌នុ៎ះ ព្រះអង្គជ្រាបច្បាស់ហើយ ។

[ ១៨៥ ] បពិត្រព្រះមុនិ ព្រះអង្គទូន្មានពួកជនណា ដោយត្រឹមត្រូវ ពួកជនទាំងនោះ ក៏លះទុក្ខបានដោយពិត ព្រោះហេតុនោះ ខ្ញុំព្រះអង្គចូលមក នមស្ការចំពោះព្រះអង្គ ជាព្រះពុទ្ធនាគ សូមព្រះមានព្រះភាគ ទូន្មានខ្ញុំព្រះអង្គ ដោយត្រឹមត្រូវចុះ ។

[ ១៨៦ ] ពាក្យថា ពួកជនទាំងនោះ របស់បទថា ពួកជនទាំងនោះក៏លះទុក្ខបានដោយពិត បានដល់ ពួកក្សត្រ ព្រាហ្មណ៍ វេស្សៈ សុទ្ទៈ គ្រហស្ថ បព្វជិត ទេវតា និងមនុស្ស ក៏លះបង់ ( ទុក្ខបាន ) ។ ពាក្យថា ទុក្ខ គឺគប្បីលះបង់ បន្ទោបង់ ធ្វើឲ្យវិនាស ធ្វើមិនឲ្យមានបែបភាពនូវជាតិទុក្ខ ជរាទុក្ខ ព្យាធិទុក្ខ មរណទុក្ខ សោកបរិទេវទុក្ខ ទោមនស្សុបាយាសទុក្ខ ហេតុនោះ ( លោកពោលថា ) ពួកជនទាំងនោះ ក៏លះទុក្ខបានដោយពិត ។

[ ១៨៧ ] ពាក្យថា ណា របស់បទថា បពិត្រព្រះមុនិ ព្រះអង្គទូន្មាន

ពួកជនណា ដោយត្រឹមត្រូវ បានដល់ ពួកជនជាក្សត្រ ព្រាហ្មណ៍ វេស្សៈ សុទ្ទៈ គ្រហស្ថ បព្វជិត ទេវតា និងមនុស្ស ។ ពាក្យថា ព្រះអង្គ គឺព្រាហ្មណ៍ពោលចំពោះព្រះមានព្រះភាគ ។ ពាក្យថា មុនិ សេចក្ដីថា ញាណ លោកហៅថា មោនៈ ។បេ។ ព្រះមុនិនោះ កន្លងនូវបណ្ដាញ គឺកិលេសជាគ្រឿងជាប់ជំពាក់ ។ ពាក្យថា ទូន្មានដោយត្រឹមត្រូវ គឺគប្បីទូន្មាន ទូន្មានដោយគោរព ទូន្មានរឿយៗ ទូន្មានប្រៀនប្រដៅញយៗ ដាស់តឿន ហេតុនោះ ( លោកពោលថា ) បពិត្រព្រះមុនិ ព្រះអង្គទូន្មានពួកជនណា ដោយត្រឹមត្រូវ ។

[ ១៨៨ ] អធិប្បាយពាក្យថា ខ្ញុំព្រះអង្គចូលមក នមស្ការចំពោះព្រះអង្គជាព្រះពុទ្ធនាគ ត្រង់ពាក្យថា ចំពោះព្រះអង្គ គឺព្រាហ្មណ៍ពោលចំពោះព្រះមានព្រះភាគ ។ ពាក្យថា នមស្ការ គឺខ្ញុំព្រះអង្គសូមថ្វាយបង្គំដោយកាយក្ដី ថ្វាយបង្គំដោយចិត្តក្ដី ថ្វាយបង្គំដោយសេចក្ដីប្រតិបត្តិ ដ៏សមគួរដល់អត្ថក្ដី ថ្វាយបង្គំដោយសេចក្ដីប្រតិបត្តិ ដ៏សមគួរដល់ធម៌ក្ដី ធ្វើសក្ការៈ គោរព រាប់អាន បូជា ។ ពាក្យថា ចូលមក គឺខ្ញុំព្រះអង្គសំដៅមក សំដៅមកចំពោះមកត្រង់ ឆ្ពោះមក នមស្ការព្រះអង្គចំពោះព្រះភក្ត្រ ពាក្យថា ព្រះពុទ្ធនាគ គឺព្រះមានព្រះភាគជាបុគ្គលដ៏ប្រសើរ ។ ព្រះនាមថា នាគ ព្រោះព្រះមានព្រះភាគ មិនធ្វើអំពើអាក្រក់ ព្រះនាមថា នាគ ព្រោះទ្រង់មិនលុះ ។ ព្រះនាមថា នាគ ព្រោះទ្រង់មិនមក ។

ព្រះនាមថា នាគ ព្រោះព្រះមានព្រះភាគមិនធ្វើអំពើអាក្រក់ តើដូច

ម្ដេច ។ អកុសលធម៌ទាំងឡាយដ៏លាមក ប្រកបដោយសេចក្ដីសៅហ្មង នាំមកនូវភពថ្មី ប្រកបដោយសេចក្ដីក្រវល់ក្រវាយ មានផលជាទុក្ខ គួរដល់ជាតិជរា មរណៈតទៅ លោកពោលថា អំពើអាក្រក់ ។

ព្រះមានព្រះភាគ មិនធ្វើអំពើអាក្រក់ណាមួយ ក្នុងលោក ទ្រង់ស្រាយចំណង គឺកិលេស ក្នុងការប្រកបទុកនូវសត្វទាំងពួង ព្រះអង្គរួចហើយ មិនជាប់ក្នុងអារម្មណ៍ទាំងពួង ព្រះអង្គជាបុគ្គលនឹងធឹង ទើបហៅថា នាគ ព្រោះព្រះអង្គជាបុគ្គលទៀង ។

ព្រះនាមថា នាគ ព្រោះព្រះមានព្រះភាគ មិនធ្វើអំពើអាក្រក់យ៉ាងនេះឯង ។

ព្រះនាមថា នាគ ព្រោះទ្រង់មិនលុះ តើដូចម្ដេច ។ ព្រះមានព្រះភាគមិនលុះឆន្ទាគតិ មិនលុះទោសាគតិ មិនលុះមោហាគតិ មិនលុះភយាគតិ មិនលុះដោយអំណាចរាគៈ មិនលុះដោយអំណាចទោសៈ មិនលុះដោយអំណាចមោហៈ មិនលុះដោយអំណាចទិដ្ឋិ មិនលុះដោយអំណាចមានះ មិនលុះដោយអំណាចឧទ្ធច្ចៈ មិនលុះដោយអំណាចវិចិកិច្ឆា មិនលុះដោយអំណាចអនុស័យ គឺព្រះអង្គមិនទៅ មិនឃ្លាត មិនរសាត់ មិនដោយតាមធម៌ជាពួកទាំងឡាយ ព្រះនាមថា នាគ ព្រោះព្រះមានព្រះភាគ មិនលុះយ៉ាងនេះឯង ។

ព្រះនាមថា នាគ ព្រោះព្រះមានព្រះភាគ មិនមក តើដូចម្ដេច ។ កិលេសទាំងឡាយណា ដែលព្រះអង្គលះហើយ ដោយសោតាបត្តិមគ្គ ព្រះអង្គមិនមក មិនបែរមក មិនត្រឡប់មក កាន់កិលេសទាំងនោះវិញ កិលេសទាំង

ឡាយណា ដែលព្រះអង្គលះហើយ ដោយសកទាគាមិមគ្គ អនាគាមិមគ្គ ព្រះអង្គមិនមក មិនបែរមក មិនត្រឡប់មក កាន់កិលេសទាំងនោះវិញ កិលេសទាំងឡាយណា ដែលព្រះអង្គលះហើយ ដោយអរហត្តមគ្គ ព្រះអង្គមិនមក មិនបែរមក មិនត្រឡប់មក កាន់កិលេសទាំងនោះវិញទេ ព្រះនាមថា នាគ ព្រោះព្រះមានព្រះភាគមិនមក យ៉ាងនេះឯង ហេតុនោះ ( លោកពោលថា ) ខ្ញុំព្រះអង្គ ចូលមកនមស្ការ ព្រះអង្គជាព្រះពុទ្ធនាគ ។

[ ១៨៩ ] ពាក្យថា សូមព្រះមានព្រះភាគ ទូន្មានខ្ញុំព្រះអង្គ ដោយត្រឹមត្រូវចុះ គឺសូមព្រះមានព្រះភាគ ទូន្មានខ្ញុំព្រះអង្គ ដោយត្រឹមត្រូវ សូមទូន្មានដោយគោរព ទូន្មានរឿយៗ ទូន្មាន ប្រៀនប្រដៅញយៗ ហេតុនោះ ( លោកពោលថា ) សូមព្រះមានព្រះភាគ ទូន្មានខ្ញុំព្រះអង្គ ដោយត្រឹមត្រូវចុះ ។ ហេតុនោះ ព្រាហ្មណ៍ពោលថា

> បពិត្រព្រះមុនិ ព្រះអង្គទូន្មានពួកជនណា ដោយត្រឹមត្រូវ ពួកជនទាំងនោះ ក៏លះទុក្ខបានដោយពិត ព្រោះហេតុនោះ ខ្ញុំព្រះអង្គ ចូលមកនមស្ការចំពោះព្រះអង្គ ជាព្រះពុទ្ធនាគ សូមព្រះមានព្រះភាគ ទូន្មានខ្ញុំព្រះអង្គ ដោយត្រឹមត្រូវចុះ ។
>
> [ ១៩០ ] ( ព្រះមានព្រះភាគត្រាស់តបថា ) បុគ្គល គប្បីដឹងច្បាស់នូវព្រាហ្មណ៍ណា ដែលជាអ្នកដល់នូវវេទ អ្នកមិនមានកង្វល់ មិនជាប់នៅក្នុងកាមភព ព្រាហ្មណ៍នោះ ឈ្មោះថា បានឆ្លងឱឃៈនេះ ដោយពិត ទាំងឆ្លងដល់ត្រើយ ជាអ្នកមិនមានបង្គោល មិន

មានសេចក្ដីងឿងឆ្ងល់ ។

[ ១៩១ ] អធិប្បាយពាក្យថា បុគ្គលគប្បីដឹងច្បាស់ នូវព្រាហ្មណ៍ណា ដែលជាអ្នកដល់នូវវេទ ត្រង់ពាក្យថា ព្រាហ្មណ៍ សេចក្ដីថា ដែលឈ្មោះថា ព្រាហ្មណ៍ ព្រោះបន្សាត់បង់ធម៌ ៧ ។ គឺបន្សាត់បង់សក្កាយទិដ្ឋិ បន្សាត់បង់វិចិកិច្ឆា បន្សាត់បង់សីលព្វតបរាមាស បន្សាត់បង់រាគៈ បន្សាត់បង់ទោសៈ បន្សាត់បង់មោហៈ បន្សាត់បង់មានះ ។ លោកបានលះបង់នូវអកុសលធម៌ទាំងឡាយដ៏លាមក ប្រកបដោយសេចក្ដីសៅហ្មង នាំមកនូវភពថ្មី ប្រកបដោយសេចក្ដីក្រវល់ក្រវាយ មានផលជាទុក្ខ ជាទីតាំងនៃជាតិ ជរា មរណៈតទៅ ។

( ព្រះមានព្រះភាគត្រាស់ថា ម្នាលសភិយៈ ) ព្រះមានព្រះភាគ បន្សាត់បង់នូវបាបទាំងពួង ជាបុគ្គលប្រាសចាកមន្ទិល មានព្រះហឫទ័យតម្កល់នៅដោយល្អ មានខ្លួនខ្ជាប់ខ្ជួន ព្រះមានព្រះភាគនោះ ជាបុគ្គលបរិសុទ្ធ កន្លងនូវសង្សារ មិនអាស្រ័យ ( តណ្ហា និងទិដ្ឋិ ) ជាបុគ្គលនឹងធឹង លោកហៅថា ព្រាហ្មណ៍ ។

ពាក្យថា អ្នកដល់នូវវេទ សេចក្ដីថា ញាណក្នុងមគ្គ ៤ លោកហៅថា វេទ ។បេ។ បុគ្គលនោះដល់នូវវេទ កន្លងនូវវេទទាំងពួង ពាក្យថា គប្បីដឹងច្បាស់ គឺគប្បីដឹងចំពោះ ដឹងទូទៅ ដឹងវិសេស ដឹងច្បាស់ យល់ច្បាស់ ហេតុនោះ ( ទ្រង់ត្រាស់ថា ) គប្បីដឹងច្បាស់នូវព្រាហ្មណ៍ណា ដែលជាអ្នកដល់នូវវេទ ។

[ ១៩២ ] អធិប្បាយពាក្យថា អ្នកមិនមានកង្វល់ មិនជាប់នៅក្នុងកាមភព ត្រង់ពាក្យថា អ្នកមិនមានកង្វល់ សេចក្តីថា កង្វល់ គឺរាគៈ កង្វល់ គឺទោសៈ កង្វល់ គឺមោហៈ កង្វល់ គឺមានះ កង្វល់ គឺទិដ្ឋិ កង្វល់ គឺកិលេស កង្វល់ គឺទុច្ចរិត ។ គ្រឿងកង្វល់ទាំងឡាយនុ៎ះ ព្រះខីណាស្រពណា បានលះបង់ ផ្តាច់ផ្តិល រម្ងាប់ ស្ងប់រម្ងាប់ ធ្វើមិនគួរឲ្យកើតឡើងបាន ដុតដោយភ្លើង គឺញាណហើយ ព្រះខីណាស្រពនោះ លោកហៅថា អ្នកមិនមានកង្វល់ ។ ពាក្យថា កាម បើតាមឧទ្ទាន បានដល់ កាម ២ គឺវត្ថុកាម ១ កិលេសកាម ១ ។បេ។ នេះហៅថា វត្ថុកាម ។បេ។ នេះហៅថា កិលេសកាម ។ ពាក្យថា ភព បានដល់ ភព ២ គឺកម្មភព ១ បុនព្ភព គឺបដិសន្ធិ ១ ។បេ។ នេះកម្មភព ។បេ។ នេះបុនព្ភព គឺបដិសន្ធិ ។ ពាក្យថា អ្នកមិនមានកង្វល់ មិនជាប់នៅក្នុងកាមភព គឺអ្នកមិនមានកង្វល់ មិនជាប់នៅ មិនជ្ពក់នៅ មិនស្អិតនៅ មិនចាក់កណ្តាញ់ នៅក្នុងកាមភព ហេតុនោះ ( ទ្រង់ត្រាស់ថា ) អ្នកមិនមានកង្វល់ មិនជាប់នៅក្នុងកាមភព ។

[ ១៩៣ ] ពាក្យថា ព្រាហ្មណ៍នោះ ឈ្មោះថា បានឆ្លងឱឃៈនេះ ដោយពិត ត្រង់ពាក្យថា ដោយពិត គឺជាពាក្យដាច់ខាត ។បេ។ ពាក្យថា ដោយពិតនុ៎ះ ជាពាក្យប្រាកដ ។ ពាក្យថា ឱឃៈ បានដល់ ឱឃៈ គឺកាម ឱឃៈ គឺភព ឱឃៈ គឺទិដ្ឋិ ឱឃៈ គឺអវិជ្ជា ។ ពាក្យថា បានឆ្លង គឺបានឆ្លងឡើង ឆ្លងកាត់ ឈានកន្លង ប្រព្រឹត្តកន្លង ហេតុនោះ ( ទ្រង់ត្រាស់ថា ) ព្រាហ្មណ៍នោះ ឈ្មោះថា បានឆ្លងឱឃៈនេះ ដោយពិត ។

[ ១៩៤ ] អធិប្បាយពាក្យថា ទាំងធ្វងដល់ត្រើយ ជាអ្នកមិនមានបង្កោល មិនមានសេចក្តីងឿងឆ្ងល់ ត្រង់ពាក្យថា ធ្វង គឺព្រាហ្មណ៍ណា ធ្វងកាមោឃៈ ធ្វងភវោឃៈ ធ្វងទិដ្ឋោឃៈ ធ្វងអវិជ្ជោឃៈ ធ្វងឡើង ធ្វងចេញកន្ធ្វង ប្រព្រឹត្តកន្ធ្វង ព្រាហ្មណ៍នោះ ឈ្មោះថា ជាអ្នកមានព្រហ្មចរិយធម៌អប់រំហើយ មានចរណធម៌ប្រព្រឹត្តហើយ មានកាលវែងកន្ធ្វងហើយ មានទិសគឺនិព្វានដល់ហើយ មានទីបំផុតដល់ហើយ មានព្រហ្មចរិយធម៌រក្សាហើយ ដល់នូវសម្មាទិដ្ឋិដ៏ឧត្តម មានមគ្គចម្រើនហើយ មានកិលេសលះបង់ហើយ មានអកុប្បធម៌ត្រាស់ដឹងហើយ មាននិរោធធម៌ធ្វើឲ្យជាក់ច្បាស់ហើយ ។ ព្រះអរិយបុគ្គលនោះ កំណត់ដឹងទុក្ខហើយ លះបង់សមុទយៈហើយ ចម្រើនមគ្គហើយ ធ្វើឲ្យជាក់ច្បាស់នូវនិរោធហើយ ត្រាស់ដឹងនូវគុណជាតដែលគប្បីត្រាស់ដឹង កំណត់ដឹងទុក្ខដែលគប្បីកំណត់ដឹង លះបង់នូវកិលេសជាតិដែលគប្បីលះ ចម្រើននូវធម្មជាតដែលគប្បីចម្រើន ធ្វើឲ្យជាក់ច្បាស់នូវគុណជាតដែលគប្បីធ្វើឲ្យជាក់ច្បាស់ ។ ព្រះអរិយបុគ្គលនោះ មានសសរគោល ( គឺអវិជ្ជា ) ដកចេញហើយ មានស្នាមភ្លោះ គឺសង្សារលុបចោលហើយ មានសសរ គឺតណ្ហាដកចេញហើយ មានសន្ទះទ្វារ គឺនីវរណៈបើកចេញហើយ មានទង់ គឺមានះដកចេញហើយ មានភារៈដាក់ចេញហើយ ជាអ្នកប្រាសចាក ( វដ្តៈ ) ជាអ្នកមានអង្គ ៥ លះបង់ហើយ ជាអ្នកប្រកបដោយអង្គ ៦ មានការរក្សាតែមួយ គឺសតិ មានធម៌ជាគ្រឿងពឹងផ្អែក ៤ យ៉ាង មានសច្ចធម៌ផ្សេងបន្ទោបង់ហើយ មានការស្វែងរកទាំងអស់លះបង់ហើយ មានការត្រិះរិះ

មិនល្អក់ មានកាយសង្ខារស្ងប់រម្ងាប់ មានចិត្តរួចស្រឡះដោយប្រពៃ មានប្រាជ្ញារួចស្រឡះប្រពៃ ជាបុគ្គលបរិសុទ្ធ មានព្រហ្មចរិយធម៌ប្រព្រឹត្តចប់ហើយ ជាឧត្តមបុរស ជាបរមបុរស ជាអ្នកដល់នូវគុណជាតជាគ្រឿងដល់ដ៏ក្រៃលែង ។ អរិយបុគ្គលនោះ មិនសន្សំ មិនប្រមូល ឈ្មោះថា ខ្ជាប់ខ្ជួន ព្រោះមិនប្រមូល មិនលះបង់ មិនប្រកាន់ ឈ្មោះថា អ្នកខ្ជាប់ខ្ជួន ព្រោះលះបង់ មិនចាក់ស្រែះ មិនក្រអឺតក្រអោង ឈ្មោះថា អ្នកខ្ជាប់ខ្ជួន ព្រោះលែងចាក់ស្រែះ មិនលត់ មិនបង្កាត់ ឈ្មោះថា អ្នកខ្ជាប់ខ្ជួន ព្រោះរលត់ ឈ្មោះថា អ្នកខ្ជាប់ខ្ជួន ព្រោះប្រកបដោយសីលក្ខន្ធជាអសេក្ខៈ ឈ្មោះថា អ្នកខ្ជាប់ខ្ជួន ព្រោះប្រកបដោយសមាធិក្ខន្ធជាអសេក្ខៈ ដោយបញ្ញាខន្ធជាអសេក្ខៈ ដោយវិមុត្តិក្ខន្ធជាអសេក្ខៈ ដោយវិមុត្តិញាណទស្សនក្ខន្ធជាអសេក្ខៈ ឈ្មោះថា អ្នកខ្ជាប់ខ្ជួន ព្រោះសម្រេចនូវកិច្ចទាំងពួង ឈ្មោះថា អ្នកខ្ជាប់ខ្ជួន ព្រោះកន្ទួង ( តណ្ហា ) យ៉ាងនេះ ឈ្មោះថា អ្នកខ្ជាប់ខ្ជួន ព្រោះរម្ងត់ភ្លើង គឺកិលេស ឈ្មោះថា អ្នកខ្ជាប់ខ្ជួន ព្រោះកិរិយាមិនប្រឡប់មកវិញ ឈ្មោះថា អ្នកខ្ជាប់ខ្ជួន ព្រោះកាន់យកនូវជ័យជម្នះ ឈ្មោះថា អ្នកខ្ជាប់ខ្ជួន ព្រោះកិរិយាសេពនូវវិមុត្តិ ឈ្មោះថា អ្នកខ្ជាប់ខ្ជួន ព្រោះការបរិសុទ្ធដោយមេត្តា ឈ្មោះថា អ្នកខ្ជាប់ខ្ជួន ព្រោះការបរិសុទ្ធដោយករុណា មុទិតា ឧបេក្ខា ឈ្មោះថា អ្នកខ្ជាប់ខ្ជួន ព្រោះសេចក្តីបរិសុទ្ធដ៏ក្រៃលែង ឈ្មោះថា អ្នកខ្ជាប់ខ្ជួន ព្រោះភាពនៃលោកមិនគួរដល់ការផ្ងារ ឈ្មោះថា អ្នកខ្ជាប់ខ្ជួន ព្រោះលោករួចស្រឡះ ឈ្មោះថា អ្នកខ្ជាប់ខ្ជួន ព្រោះភាពនៃលោកមានចិត្តស្ងប់ ឈ្មោះថា

អ្នកខ្ជាប់ខ្ជួនក្នុងទីបំផុតខន្ធ ខ្ជាប់ខ្ជួនក្នុងទីបំផុតធាតុ ខ្ជាប់ខ្ជួនក្នុងទីបំផុតអាយតនៈ ខ្ជាប់ខ្ជួនក្នុងទីបំផុតគតិ ខ្ជាប់ខ្ជួនក្នុងទីបំផុតការកើត ខ្ជាប់ខ្ជួនក្នុងទីបំផុតបដិសន្ធិ ខ្ជាប់ខ្ជួនក្នុងទីបំផុតភព ខ្ជាប់ខ្ជួនក្នុងទីបំផុតសំសារ ខ្ជាប់ខ្ជួនក្នុងទីបំផុតវដ្ដៈ ខ្ជាប់ខ្ជួនក្នុងភពទីបំផុត ខ្ជាប់ខ្ជួនក្នុងរាងកាយជាទីបំផុត ឈ្មោះថា ព្រះអរហន្ត ទ្រទ្រង់នូវអត្តភាពជាទីបំផុត ។

ភពនេះនៃព្រះអរហន្តនោះ ចាត់ថា មានក្នុងទីបំផុតរាងកាយនេះ
ចាត់ថា មានជាខាងក្រោយបង្អស់ ភពថ្មី គឺការអន្ទោលទៅដោយ
ជាតិ ជរា និងមរណៈ នៃព្រះអរហន្តនោះ មិនមាន ។

ពាក្យថា ទាំងធ្វេងដល់ត្រើយ សេចក្ដីថា អមតនិព្វាន លោកហៅថា ត្រើយ បានដល់ ការរម្ងាប់នូវសង្ខារទាំងពួង ការលះបង់ចេញនូវឧបធិទាំងពួង ការអស់តណ្ហា ការប្រាសចាកតម្រេក ទីរលត់ និព្វាន ។ ព្រះអរហន្តនោះ ទៅកាន់ត្រើយ ដល់ត្រើយ ទៅកាន់ទីបំផុត ដល់ទីបំផុត ទៅកាន់ទីខាងចុង ដល់ខាងចុង ទៅកាន់ទីបំផុតជុំវិញ ដល់ទីបំផុតជុំវិញ ទៅកាន់ទីចប់ ដល់ទីចប់ ទៅកាន់ទីពំនាក់ ដល់ទីពំនាក់ ទៅកាន់ទីជ្រកកោន ដល់ទីជ្រកកោន ទៅកាន់ទីពឹង ដល់ទីពឹង ទៅកាន់ទីមិនមានភ័យ ដល់ទីមិនមានភ័យ ទៅកាន់ទីមិនច្យុត ដល់ទីមិនច្យុត ទៅកាន់អមតៈ ដល់អមតៈ ទៅកាន់ព្រះនិព្វាន ដល់ព្រះនិព្វាន ព្រះអរហន្តនោះ មានការអប់រំនៅស្រេចហើយ មានចរណធម៌ប្រព្រឹត្តហើយ ។បេ។ ភពថ្មី គឺការអន្ទោលទៅដោយជាតិ ជរា និងមរណៈ របស់ព្រះអរហន្តនោះ មិនមាន ហេតុនោះ ( ទ្រង់ត្រាស់ថា ) ទាំងធ្វេងទៅ

ដល់ត្រើយ ។ ពាក្យថា មិនមានបង្គោល សេចក្តីថា បង្គោល គឺរាគៈ បង្គោល គឺទោសៈ បង្គោល គឺមោហៈ បង្គោល គឺកោធៈ បង្គោល គឺឧបនាហៈ ។បេ។ បង្គោល គឺការតាក់តែងអកុសលទាំងពួង ។ បង្គោលទាំងនោះ ព្រះអរហន្តណា បានលះបង់ ផ្តាច់ផ្តិល រម្ងាប់ ឲ្យស្ងប់រម្ងាប់ ធ្វើមិនគួរឲ្យកើតឡើងបាន ដុតដោយភ្លើង គឺញាណហើយ ព្រះអរហន្តនោះ លោកហៅថា អ្នកមិនមានបង្គោល ។ ពាក្យថា មិនមានសេចក្តីងឿងឆ្ងល់ សេចក្តីថា ការងឿងឆ្ងល់ក្នុងទុក្ខ ការងឿងឆ្ងល់ក្នុងសមុទយៈ ការងឿងឆ្ងល់ក្នុងទុក្ខនិរោធ ការងឿងឆ្ងល់ក្នុងទុក្ខនិរោធគាមិនីបដិបទា ការងឿងឆ្ងល់ក្នុងទីបំផុតខាងដើម ការងឿងឆ្ងល់ក្នុងទីបំផុតខាងចុង ការងឿងឆ្ងល់ក្នុងទីបំផុតខាងដើម និងខាងចុង ការងឿងឆ្ងល់ក្នុងធម៌ទាំងឡាយដែលកើតឡើង ព្រោះអាស្រ័យឥទប្បច្ច័យ គឺបានដល់សេចក្តីងឿងឆ្ងល់ អាការងឿងឆ្ងល់ ភាពនៃសេចក្តីងឿងឆ្ងល់ ការប្រាសចាកគំនិត សេចក្តីសង្ស័យ ហេតុបែកជាពីរ ផ្លូវបែកជាពីរ ការអលឯក ការកាន់យកច្រើនយ៉ាង ការកន្ទះរា ការអង្គឹអង្គែ ការមិនចុះស៊ប់ ភាពនៃចិត្តស្ទន់ស្ទោ ការប្រេះឆានៃចិត្ត មានសភាពយ៉ាងនេះ ។ សេចក្តីងឿងឆ្ងល់ទាំងនុ៎ះ ព្រះអរហន្តណា បានលះបង់ ផ្តាច់ផ្តិល ស្ងប់រម្ងាប់ ឲ្យស្ងប់រម្ងាប់ ធ្វើមិនគួរឲ្យកើតឡើងបាន ដុតដោយភ្លើង គឺញាណហើយ ព្រះអរហន្តនោះ លោកពោលថា អ្នកមិនមានសេចក្តីងឿងឆ្ងល់ ហេតុនេះ ( ទ្រង់ត្រាស់ថា ) ទាំងឆ្លងដល់ត្រើយ ជាអ្នកមិនមានបង្គោល មិនមានសេចក្តីងឿងឆ្ងល់ ។ ហេតុនោះ ព្រះមានព្រះភាគត្រាស់ថា បុគ្គលគប្បីដឹង

ច្បាស់នូវព្រាហ្មណ៍ណា ដែលជាអ្នកដល់នូវវេទ អ្នកមិនមានកង្វល់ មិនជាប់នៅក្នុងកាមភព ព្រាហ្មណ៍នោះ ឈ្មោះថា បានឆ្លងឱឃៈនេះដោយពិត ទាំងឆ្លងដល់ត្រើយ ជាអ្នកមិនមានបង្គោល មិនមានសេចក្តីងឿងឆ្ងល់ ។

[ ១៩៥ ] នរៈណា ជាអ្នកចេះដឹង អ្នកដល់នូវវេទ ក្នុងលោកនេះ បានស្រាយនូវការជាប់ជំពាក់នេះ ក្នុងភពតូច និងភពធំ តថាគតពោលថា នរៈនោះ ជាអ្នកប្រាសចាកតណ្ហា មិនមានសេចក្តីតានតឹង មិនមានសេចក្តីប៉ុនប៉ង ទាំងពោលថា នរៈនោះ បានឆ្លងនូវជាតិ និងជរា ។

[ ១៩៦ ] ពាក្យថា នរៈណា ជាអ្នកចេះដឹង អ្នកដល់នូវវេទក្នុងលោកនេះ សេចក្តីថា នរៈដែលសម្រេចវិជ្ជា មានញាណ មានការឈ្វេងយល់ មានប្រាជ្ញាធ្ងុះធ្លាយ ( ឈ្មោះថា ជាអ្នកចេះដឹង ) ។ ពាក្យថា ណា គឺអ្នកណាបែបណា ។បេ។ ទោះជាមនុស្សក្តី ។ ពាក្យថា អ្នកដល់នូវវេទ សេចក្តីថា ញាណក្នុងមគ្គ ៤ លោកហៅថា វេទ ។បេ។ បុគ្គលនោះ ដល់នូវវេទ ព្រោះកន្លងនូវវេទទាំងពួង ពាក្យថា នរៈ បានដល់ សត្វ នរៈ មាណព បុរស បុគ្គល ជីវៈ ជនជាតិ សត្វជាតុ សត្វទៅដោយឥន្ទ្រិយ សត្វកើតអំពីមនុស្ស ។ ពាក្យថា ក្នុងលោកនេះ គឺក្នុងទិដ្ឋិនេះ ។បេ។ ក្នុងមនុស្សលោកនេះ ហេតុនោះ ( ទ្រង់ត្រាស់ថា ) នរៈណា ជាអ្នកចេះដឹង អ្នកដល់នូវវេទក្នុងលោកនេះ ។

[ ១៩៧ ] ពាក្យថា បានស្រាយនូវការជាប់ជំពាក់នេះ ក្នុងភពតូច និងភពធំ ត្រង់ពាក្យថា ក្នុងភពតូច និងភពធំ គឺក្នុងកម្មភព បុនព្ភព ឈ្មោះថា

ភពតូច និងភពធំ កាមភព ឈ្មោះថា កម្មភព កាមភព ឈ្មោះថា បុនព្ភព រូបភព ឈ្មោះថា កម្មភព រូបភព ឈ្មោះថា បុនព្ភព អរូបភព ឈ្មោះថា កម្មភព អរូបភព ឈ្មោះថា បុនព្ភព គឺក្នុងការកើតរឿយៗ ក្នុងការទៅរឿយៗ ក្នុងការចូលទៅរឿយៗ ក្នុងបដិសន្ធិរឿយៗ ក្នុងការកើតអត្តភាពរឿយៗ ។ ពាក្យថា ការជាប់ជំពាក់ បានដល់ ការជាប់ជំពាក់ ៧ គឺការជាប់ជំពាក់ គឺរាគៈ ការជាប់ជំពាក់ គឺទោសៈ ការជាប់ជំពាក់ គឺមោហៈ ការជាប់ជំពាក់ គឺមានះ ការជាប់ជំពាក់ គឺទិដ្ឋិ ការជាប់ជំពាក់ គឺកិលេស ការជាប់ជំពាក់ គឺទុច្ចរិត ។ ពាក្យថា ស្រាយ គឺលោស់ចោល ឬដោះនូវការជាប់ជំពាក់ទាំងឡាយ ។ មួយទៀត បុគ្គលដោះ ឬស្រាយនូវការជាប់ជំពាក់ គឺចំណងដែលចង ចងទូទៅ ថ្ពក់ ទាក់ ជំពាក់ ពួកជនរុះរើ ធ្វើឲ្យខ្ទេចខ្ទីនូវ យានក្តី វក្តី រថក្តី រទេះក្តី រថទ្រង់គ្រឿងក្តី យ៉ាងណាមិញ បុគ្គលរលោស់ចោល ឬលះចេញនូវការជាប់ជំពាក់ទាំងនោះ ក៏យ៉ាងនោះដែរ មួយវិញទៀត បុគ្គលដោះចេញ ឬស្រាយនូវការជាប់ជំពាក់ គឺចំណងដែលចង ចងទូទៅ ថ្ពក់ ទាក់ ជំពាក់ ហេតុនោះ ( ទ្រង់ត្រាស់ថា ) បានស្រាយនូវការជាប់ជំពាក់នេះ ក្នុងភពតូច និងភពធំ ។

[ ១៩៨ ] អធិប្បាយពាក្យថា តថាគតពោលថា នរៈនោះជាអ្នកប្រាសចាកតណ្ហា មិនមានសេចក្តីតានតឹង មិនមានសេចក្តីប៉ុនប៉ង ទាំងពោលថា នរៈនោះ បានឆ្លងនូវជាតិ និងជរា ត្រង់ពាក្យថា តណ្ហា បានដល់ រូបតណ្ហា សទ្ទតណ្ហា គន្ធតណ្ហា រសតណ្ហា ផោដ្ឋព្វតណ្ហា ធម្មតណ្ហា ។ តណ្ហានុ៎ះ

នរៈណា បានលះបង់ ផ្ដាច់ផ្ដិល រម្ងាប់ ឲ្យស្ងប់រម្ងាប់ ធ្វើមិនគួរឲ្យកើតឡើងបាន ដុតដោយភ្លើង គឺញាណហើយ នរៈនោះ លោកហៅថា អ្នកប្រាសចាកតណ្ហា លះបោលតណ្ហា ខ្ជាក់ចោលតណ្ហា ផុតចាកតណ្ហា បន្សាត់ចោលតណ្ហា រលាស់ចេញចាកតណ្ហា ប្រាសចាករាគៈ លះបោលរាគៈ ខ្ជាក់ចោលរាគៈ ផុតចាករាគៈ បន្សាត់ចោលរាគៈ រលាស់ចេញចាករាគៈ មិនមានសេចក្ដីប្រាថ្នា រលត់ទុក្ខ មានចិត្តត្រជាក់ សោយសុខ មានចិត្តត្រជាក់ហេតុនោះ ( ទ្រង់ត្រាស់ថា ) នរៈនោះ ប្រាសចាកតណ្ហា ។ ពាក្យថា មិនមានសេចក្ដីតានតឹង សេចក្ដីថា រាគៈ ជាសេចក្ដីតានតឹង ទោសៈ ជាការតានតឹង មោហៈ ជាការតានតឹង កោធៈ ជាការតានតឹង ឧបនាហៈ ជាការតានតឹង ។បេ។ ការតាក់តែងនូវអកុសលទាំងពួង ជាការតានតឹង ។ សេចក្ដីតានតឹងទាំងនុ៎ះ នរៈណា បានលះបង់ ផ្ដាច់ផ្ដិល រម្ងាប់ ឲ្យស្ងប់រម្ងាប់ ធ្វើមិនគួរឲ្យកើតឡើងបាន ដុតដោយភ្លើង គឺញាណហើយ នរៈនោះ លោកហៅថា អ្នកមិនមានសេចក្ដីតានតឹង ។ ពាក្យថា មិនមានសេចក្ដីប៉ុនប៉ង សេចក្ដីថា តណ្ហា លោកហៅថា សេចក្ដីប៉ុនប៉ង បានដល់ រាគៈ រាគៈមានកម្លាំង ។បេ។ អភិជ្ឈា លោភៈ អកុសលមូល ។ តណ្ហា គឺសេចក្ដីប៉ុនប៉ងនោះ នរៈណា បានលះបង់ ផ្ដាច់ផ្ដិល រម្ងាប់ ឲ្យស្ងប់ ធ្វើមិនគួរឲ្យកើតឡើងបាន ដុតដោយភ្លើង គឺញាណហើយ នរៈនោះ លោកហៅថា អ្នកមិនមានសេចក្ដីប៉ុនប៉ង ។ ពាក្យថា ជាតិ បានដល់ កំណើត ការកើតព្រម ការចុះកាន់គភ៌ ការផ្ដួចផ្ដើម ការបម្រើនឡើង ការកើតប្រាកដនៃខន្ធ ការបានចំពោះនូវអាយតនៈនៃ

ពួកសត្វនោះៗ ក្នុងសត្តនិកាយនោះៗ ។ ពាក្យថា ជរា បានដល់ ការចាស់ ការគ្រាំគ្រា ការបាក់ធ្មេញ ការស្កូវសក់ ការជ្រួញជ្រីវស្បែក ការរួញថយនៃអាយុ ការចាស់ឥន្ទ្រិយនៃពួកសត្វនោះៗ ក្នុងសត្តនិកាយនោះៗ ។ ពាក្យថា មរណៈ បានដល់ ការចុតិ ការឃ្លាត ការបែកធ្លាយ ការអន្តរធាន មច្ចុមរណៈ កាលកិរិយា ការបែកធ្លាយខន្ធ ការដាក់ចោលនូវសាកសព ការដាច់សូន្យជីវិតិន្ទ្រិយនៃពួកសត្វនោះៗ ក្នុងសត្តនិកាយនោះៗ ។ ពាក្យថា តថាគតពោលថា នរៈនោះ ជាអ្នកប្រាសចាកតណ្ហា មិនមានសេចក្តីតានតឹង មិនមានសេចក្តីប៉ុនប៉ង ទាំងពោលថា នរៈនោះ បានឆ្លងនូវជាតិ និងជរា បានសេចក្តីថា តថាគតពោល ប្រាប់ សម្តែង បញ្ញត្ត តាំងទុក បើក បែក ធ្វើឲ្យរាក់ ប្រកាសថា នរៈណានោះ ប្រាសចាកតណ្ហាផង មិនមានសេចក្តីតានតឹងផង មិនមានសេចក្តីប៉ុនប៉ងផង នរៈនោះ បានឆ្លង ឆ្លងកាត់ ឈានកន្លង ប្រព្រឹត្តកន្លងនូវជាតិ ជរា និងមរណៈ ហេតុនោះ ( ទ្រង់ត្រាស់ថា ) តថាគតពោលថា នរៈនោះ ជាអ្នកប្រាសចាកតណ្ហា មិនមានសេចក្តីតានតឹង មិនមានសេចក្តីប៉ុនប៉ង ទាំងពោលថា នរៈនោះ បានឆ្លងនូវជាតិ និងជរា ។ ហេតុនោះ ព្រះមានព្រះភាគត្រាស់ថា

នរៈណា ជាអ្នកចេះដឹង អ្នកដល់នូវវេទ ក្នុងលោកនេះ បាន
ស្រាយនូវការជាប់ជំពាក់នេះ ក្នុងភពតូច និងភពធំ តថាគត

ពោលថា នរៈនោះ ជាអ្នកប្រាសចាកតណ្ហា មិនមានសេចក្តីតានតឹង មិនមានសេចក្តីប៉ុនប៉ង ទាំងពោលថា នរៈនោះ បានឆ្លងនូវជាតិ និងជរា ។

( មេត្តគូបានប្រកាសខ្លួន ) ដំណាលគ្នានឹងកាលជាទីចប់គាថា ។បេ។ បពិត្រព្រះអង្គដ៏ចម្រើន ព្រះមានព្រះភាគ ជាសាស្តារបស់ខ្ញុំព្រះអង្គខ្ញុំព្រះអង្គជាសាវ័ក ។

## មេត្តគូមាណវកបញ្ហានិទ្ទេស ចប់

# អដ្ឋកថា

## មេត្តគូមាណវកប្បញ្ហានិទ្ទេស

គប្បីជ្រាបវិនិច្ឆ័យក្នុងមេត្តគូសូត្រទី ៤ ដូចតទៅ

[ ១៤២ ] បទថា **មញ្ញាមិ តំ វេទគុំ ភាវិតត្តំ** សេចក្តីថា ខ្ញុំព្រះអង្គរមែងសម្គាល់នូវព្រះអង្គយ៉ាងនេះថា ព្រះមានព្រះភាគអង្គនេះ ជាអ្នកចប់វេទ និងជាអ្នកមានខ្លួនអប់រំហើយ ។

[ ១៤៤ ] បទថា **អបរិត្តោ** បានដល់ មិនមែនតិច ។ បទថា **មហន្តោ** បានដល់ មិនមែនតូច ។ បទថា **គម្ភីរោ** បានដល់ មិនរាក់ ។ បទថា **អប្បមេយ្យោ** បានដល់ មិនអាចរាប់បាន ។ បទថា **ទុប្បរិយោគាឡ្ហោ** បានដល់ លំបាកនឹងឈមចុះបាន គឺលំបាកស្ទង់ដល់បាន ។ បទថា **ពហុរតនោ សាគរូបមោ** សេចក្តីថា មានធម៌ជារតនៈច្រើន ព្រោះជាប្រភពកើតនៃធម្មរតនៈច្រើន ដូចគ្នានឹងសាគរ គឺដូចសមុទ្រដែលបរិបូណ៌ដោយរតនៈច្រើនយ៉ាង ។ បទថា **ឆ មង្គុ ហោតិ** បានដល់ ទ្រង់មានព្រះកក្រ្កមិនខុសប្រក្រតី ។ បទថា **អប្បតិដ្ឋីនចិត្តោ** បានដល់ មិនមានព្រះហឫទ័យប្រព្រឹត្តទៅដោយអំណាចទោសៈ ។ បទថា **អខិលមនសោ** បានដល់ មានព្រះហឫទ័យមិនរួញរា ។ បទថា **អព្យាបន្នចេតសោ** បានដល់ មិនមានព្រះហឫទ័យស្អុយរលួយ ។ បទថា **ទិដ្ឋេ ទិដ្ឋមត្តោ** បានដល់ ត្រឹមតែឃើញរូបារម្មណ៍ដែលជាវិស័យនៃចក្ខុប៉ុណ្ណោះ ។ ពណ៌ដែលឃើញដោយចក្ខុ ត្រឹមតែជាអារម្មណ៍ប៉ុណ្ណោះ មិនមានអ្នកធ្វើ ឬអ្នកឲ្យធ្វើ ។ ក្នុងសំឡេងដែលបានឮជាដើម ក៏ន័យនេះដូចគ្នា ។

ម្យ៉ាងទៀត បទថា **ឆិន្ទ** លោកសម្តែងវណ្ណាយតនៈ ដោយការប្រកប ជាមួយការឃើញ សម្តែងសទ្ទាយតនៈ ដោយប្រកបជាមួយការស្តាប់ សម្តែង ឃានាយតនៈ ជិវ្ហាយតនៈ និងកាយាយតនៈ ដោយប្រកបជាមួយការជ្រាប ។ លោកសម្តែងគន្ធៈ ជាអាយតនៈនៃឃានៈ សម្តែងរស ជាអាយតនៈនៃជិវ្ហា សម្តែងផោដ្ឋព្វៈ គឺបឋវី តេជោ វាយោ ជាអាយតនៈនៃកាយ សម្តែងធម្មា-យតនៈ ដោយការប្រកបជាមួយការដឹងច្បាស់ ។ បទថា **ឆិន្ទ អន្វុបយោ** បានដល់ វៀរចាកការជាប់ដោយរាគៈក្នុងរូបដែលឃើញដោយចក្ខុវិញ្ញាណ ។ បទថា **អឆចាយោ** បានដល់ វៀរចាកសេចក្តីក្រោធ មិនមានបដិឃៈ ។ បទថា **អនិស្សិតោ** បានដល់ មិនជាប់ទៅដោយតណ្ហា ។ បទថា **អប្បដិ-ពទ្ធោ** បានដល់ មិនជាប់ជំពាក់ដោយមានះ ។ បទថា **វិប្បមុត្តោ** បានដល់ ផុតចាកអារម្មណ៍ទាំងពួង ។ បទថា **វិសញ្ញុត្តោ** បានដល់ ទ្រង់ប្រាសចេញ ហើយចាកកិលេសតាំងនៅ ។ បទថា **សំវិជ្ជតិ ភគវតោ ចក្ខុ** សេចក្តីថា ព្រះមានព្រះភាគទ្រង់បានមំសចក្ខុតាមប្រក្រតី ។ បទថា **បស្សតិ** បានដល់ ទ្រង់ឃើញ ទ្រង់ទត ។ បទថា **ចក្ខុនា រូបំ** បានដល់ ទ្រង់ឃើញរូបារម្មណ៍ ដោយចក្ខុវិញ្ញាណ ។ បទថា **ឆន្ទរាគោ** បានដល់ ការពេញចិត្តដោយ អំណាចតណ្ហា ។

បទថា **ទន្តំ នយន្តិ សមិតឹ** សេចក្តីថា ជនទាំងឡាយកាលទៅកាន់ កណ្តាលមហាជនក្នុងឧទ្យាន និងទីលានកីឡាជាដើម រមែងទឹមគោ ឬសេះ អាជានេយ្យដែលទូន្មានហើយត្រង់យាន នាំទៅ ។ បទថា **រាជា** បានដល់

ព្រះរាជាយាងទៅកាន់ទីនោះ ប្រថាប់ក្នុងយានដែលសារថីទូន្មានហើយនោះឯង ។ បទថា **មនុស្សេសុ** បានដល់ បុគ្គលដែលទូន្មានហើយដោយអរិយមគ្គ ៤ អស់ព្យសន៍ ជាបុគ្គលប្រសើរក្នុងពួកមនុស្ស ។ បទថា **យោតិវាក្យំ** សេចក្ដីថា បុគ្គលណាអត់ធន់ មិនរសាប់រសល់ មិនក្ដៅក្រហាយចំពោះពាក្យលុបលើបែបនេះ សូម្បីគេពោលរឿយៗ បុគ្គលបែបនេះ ឈ្មោះថា ជាអ្នកទូន្មានហើយ ជាបុគ្គលប្រសើរបំផុត ។ បទថា **អស្សតរា** បានដល់ សេះដែលកើតអំពីមេសេះ បាលា ។ បទថា **អាជានីយា** បានដល់ សេះដែលអាចដឹងហេតុដែលសារថីបង្ហឹកឲ្យធ្វើបានដោយរហ័ស ។ បទថា **សិន្ធវា** បានដល់ សេះដែលកើតក្នុងដែនសិន្ធវៈ ។ បទថា **មហានាគា** បានដល់ ដំរីធំជាតិកុញ្ជរ ។ បទថា **អត្តទន្តោ** សេចក្ដីថា សេះអស្សតរក្ដី សេះសិន្ធពក្ដី ដំរីកុញ្ជរក្ដី ទាំងនេះ ដែលទូន្មានហើយ ជាសត្វប្រសើរ ដែលមិនទាន់បានទូន្មាន ជាសត្វមិនប្រសើរ បុគ្គលណាទូន្មានខ្លួនហើយ ព្រោះទូន្មានខ្លួនដោយមគ្គ ៤ ជាអ្នកអស់ព្យសន៍ បុគ្គលនេះ ជាបុគ្គលប្រសើរជាងពួកបុគ្គលដែលមិនបានទូន្មានខ្លួននោះ គឺប្រសើរក្រៃលែង ជាងពាហនៈទាំងអស់នោះ ។ បទថា **ន ហិ ឯតេហិ យានេហិ** សេចក្ដីថា បុគ្គលណាម្នាក់គប្បីទៅកាន់ទិស គឺនិព្វាន ដែលមិនធ្លាប់ទៅ ព្រោះមិនធ្លាប់ទៅ សូម្បីត្រឹមតែយល់សប្ដិ ដោយយានដ៏ឧត្ដម មានដំរីជាដើមឡើយ ដោយហោច បុគ្គលមានបញ្ញា អស់នូវព្យសន៍ ទូន្មានហើយ ដោយការទូន្មានឥន្ទ្រិយខាងដើមខាងក្រោយទូន្មានល្អហើយ ដោយអរិយមគ្គភាវនា រមែងទៅកាន់ទិសដែល

មិនជាប់ទៅនោះបាន គឺដល់នូវភូមិដែលខ្លួនទូន្មានហើយ ព្រោះដូច្នោះ ទើបការទូន្មានខ្លួននោះ ប្រសើរជាង ។

បទថា **វិធាសុ ន វិកម្បន្តិ** បានដល់ ព្រះខីណាស្រពទាំងឡាយរមែងមិនញាប់ញ័រក្នុងចំណែកនៃមានះ ៩ យ៉ាង ។ បទថា **វិប្បមុត្តា បុនព្ភវា** បានដល់ ផុតដោយល្អចាកកម្មក្កិលេស ដោយសមុច្ឆេទវិមុត្តិ ។ បទថា **ទន្តភូមឹ អនុប្បត្តា** បានដល់ សម្រេចអរហត្តផល តាំងនៅហើយ ។ បទថា **តេ លោកេ វិជិតាវិនោ** សេចក្តីថា ព្រះខីណាស្រពដូចពោលហើយនោះឈ្មោះថា ជាអ្នកឈ្នះហើយ ក្នុងសត្វលោក ។ បទថា **យស្សិន្ទ្រិយានិ ភាវិតានិ** បានដល់ ព្រះខីណាស្រពចម្រើនឥន្ទ្រិយ ៥ មានសទ្ធិន្ទ្រិយជាដើម ឲ្យសម្រេចដល់អរហត្តផល ។ បទថា **អជ្ឈត្តញ្ច ពហិទ្ធា ច** សេចក្តីថា ធ្វើអាយតនៈខាងក្នុង មានចក្ខាយតនៈជាដើម និងអាយតនៈខាងក្រៅ មានរូបាយតនៈជាដើម ឲ្យអស់ព្យសន៍ ។ បទថា **សព្វលោកេ** សេចក្តីថា ក្នុងលោកដែលជាធាតុ ៣ ទាំងមូល ។ បទថា **និព្វិជ្ឈ ឥមំ បរញ្ច លោកំ** សេចក្តីថា ព្រះខីណាស្រពកន្លងអត្តភាពនេះ និងអត្តភាពក្នុងលោកដទៃ តាំងនៅហើយ ។ បទថា **កាលំ កង្ខតិ ភាវិតោ ស ទន្តោ** សេចក្តីថា ព្រះខីណាស្រពនោះ ទូន្មានហើយ តាមផ្លូវភ្នែកជាដើម មានចិត្តចម្រើនហើយ តែងប្រាថ្នាមរណកាល ។

[ ១៤៥ ] បទថា **យេសំ ធម្មានំ អាទិតោ សមុទាគមនំ បញ្ញាយតិ** សេចក្តីថា ធម៌ មានខន្ធជាដើមឯណា មានការកើតឡើងប្រាកដ ។ បទថា

**អជ្ឈត្តមតោ និរោធោ** សេចក្តីថា ការមិនមាននៃធម៌ទាំងនោះ រមែងប្រាកដ ដោយអំណាចដល់នូវការរម្ងត់ប្រាកដ ។ បទថា **កម្មសន្និស្សិតោ វិបាកោ** សេចក្តីថា វិបាកអាស្រ័យកុសលកម្ម និងអកុសលកម្ម ឈ្មោះថា វិបាក អាស្រ័យកម្ម ព្រោះមិនលះនូវកម្ម ប្រព្រឹត្តទៅ ។ បទថា **នាមសន្និស្សិតំ រូបំ** បានដល់ រូបទាំងអស់ ឈ្មោះថា អាស្រ័យនាម ព្រោះកាន់យកនាម ប្រព្រឹត្តទៅ ។ បទថា **ជាតិយា អនុគតំ** បានដល់ ទាំងអស់ មានកម្មជាដើម អនុលោមតាមជាតិ ។ បទថា **ជរាយ អនុសដំ** បានដល់ ត្រូវជរាបៀតបៀន ។ បទថា **ព្យាធិនា អភិភូតំ** បានដល់ ត្រូវព្យាធិទុក្ខញាំញី ។ បទថា **មរណេន អព្ភាហតំ** បានដល់ ត្រូវមរណៈទម្លាយ គឺប្រហារ ។ បទថា **អតាណំ** បានដល់ មិនមានអ្វីពឹងពួន ព្រោះកូនជាដើម ក៏ជ្រកកោនមិនបាន មិនមានការរក្សា មិនបានទទួលនូវការផុតភ័យ ។ បទថា **អលេណំ** បានដល់ មិនអាចពួនសម្ងំអាស្រ័យនៅ គឺធ្វើកិច្ចពួនសម្ងំមិនបានដល់អ្នកពួនសម្ងំ ។ បទថា **អសរណំ** បានដល់ នាំភ័យចេញទៅក៏មិនបាន និងធ្វើភ័យឲ្យវិនាសទៅក៏មិនបាន សម្រាប់បុគ្គលចូលទៅអាស្រ័យ ។ បទថា **អសរណីភូតំ** សេចក្តីថា មិនមានទីពឹង ព្រោះភាពមិនជារបស់ខ្លួនតាំងអំពីការកើតឡើង អធិប្បាយថា មិនមានអ្វីជាទីពឹង អស់កាលដែលកើតនោះឯង ។

[ ១៤៧ ] សព្ទថា **អ** ក្នុងបទថា **អបុច្ឆសិ** នេះ ជានិបាត ចុះក្នុងអត្ថថា ធ្វើបទឲ្យពេញ អធិប្បាយថា រមែងសួរនោះឯង ។ បទថា **បវក្ខាមិ យថា បជានំ** សេចក្តីថា តថាគតប្រាប់តាមដែលអ្នកប្រាជ្ញប្រាប់ ។ បទថា

**ឧបធិនិទានា បភវន្តិ ទុក្ខា** បានដល់ ទុក្ខផ្សេងៗ មានជាតិទុក្ខជាដើម មានឧបធិ គឺ តណ្ហាជាដើម ជាហេតុកើតឡើង ។

[ ១៥០ ] បទថា **តណ្ហូបធិ** សេចក្តីថា តណ្ហានោះឯង ឈ្មោះថា **តណ្ហូបធិ** ។ សស្សតទិដ្ឋិ និងឧច្ឆេទទិដ្ឋិនោះឯង ឈ្មោះថា **ទិដ្ឋូបធិ** ។ កិលេស មានរាគៈជាដើមនោះឯង ឈ្មោះថា **កិលេសូបធិ** ។ កម្ម មានបុណ្យជាដើមនោះឯង ឈ្មោះថា **កម្មូបធិ** ។ ទុច្ចរិត ៣ យ៉ាងនោះឯង ឈ្មោះថា **ទុច្ចរិតូបធិ** ។ អាហារ មានកវឡីការាហារជាដើមនោះឯង ឈ្មោះថា **អាហារូបធិ** ។ ទោសៈ និងបដិឃៈនោះឯង ឈ្មោះថា **បដិឃូបធិ** ។ ធាតុ ៤ មានបឋវីធាតុជាដើម ដែលកម្មកាន់យក មានកម្មជាសមុដ្ឋាននោះឯង ឈ្មោះថា **ចតស្សោ ឧបាទិន្នធាតូបធិ** ។ អាយតនៈខាងក្នុង ៦ មានចក្ខាយតនៈជាដើមនោះឯង ឈ្មោះថា **ឆ អជ្ឈត្តិកានិ អាយតនានិ ឧបធី** ។ វិញ្ញាណ ៦ មានចក្ខុវិញ្ញាណជាដើមនោះឯង ឈ្មោះថា **ឆ វិញ្ញាណកាយា ឧបធី** ។ បទថា **សព្វម្បិ ទុក្ខំ ទុក្ខមនដ្ឋេន** បានដល់ ទុក្ខទាំងអស់ដែលប្រព្រឹត្តទៅក្នុងភូមិ ៣ ឈ្មោះថា **ឧបធិ** ព្រោះអត្ថថា អត់ធន់បានដោយក្រ ។

[ ១៥២ ] ក្នុងទុក្ខទាំងឡាយដែលកើតឡើង ព្រោះមានឧបធិជាហេតុយ៉ាងនេះ គប្បីជ្រាបគាថាជាដើមថា **យោ វេ អវិទ្វា** ដូចតទៅ ក្នុងបទទាំងនោះ បទថា **បជានំ** បានដល់ បុគ្គលដែលដឹងនូវសង្ខារទាំងឡាយ ដោយភាពជារបស់មិនទៀងជាដើម ។ បទថា **ទុក្ខស្ស ជាតិប្បភវានុបស្សី** សេចក្តី

ថា ពិចារណាថា ឧបធិជាហេតុកើតនៃទុក្ខក្នុងវដ្ដៈ ក្នុងនិទ្ទេសនៃគាថានេះ មិនមានពាក្យដែលគប្បីពោល ។

[ ១៥៧ ] បទថា **សោកបរិទ្ទវញ្ច** បានដល់ សេចក្ដីសោក និង សេចក្ដីកន្ទក់កន្ទេញ ។ បទថា **តថា ហិ តេ វិទិតោ ឯស ធម្មោ** សេចក្ដីថា ពិតហើយ ធម៌នោះ ដែលព្រះអង្គទ្រង់ជ្រាបហើយ ដោយអំណាចនៃការតាំងនៅរបស់ញាណដោយប្រការដែលសត្វទាំងឡាយដឹងបាន ។

[ ១៥៩ ] ក្នុងបទទាំងនោះ បទថា **តរន្តិ** បានដល់ រមែងឆ្លងទិដ្ឋោឃៈ ដោយបឋមមគ្គ ។ បទថា **ឧត្តរន្តិ** បានដល់ ឆ្លងឡើង ដោយការធ្វើនូវកាមោឃៈឲ្យស្រាលស្ដើង ដោយទុតិយមគ្គ ។ បទថា **បតរន្តិ** បានដល់ ឆ្លងនូវកាមោឃៈនោះឯង ដោយពិសេស ដោយតតិយមគ្គ ដោយអំណាចនៃការលះមិនឲ្យសេសសល់ ។ បទថា **សមតិក្កមន្តិ** បានដល់ ឈានកន្លង ដោយប្រពៃ ដោយចតុត្ថមគ្គ ដោយអំណាចនៃការលះ ភវោឃៈ និង អវិជ្ជោឃៈ ។ បទថា **វីតិវត្តន្តិ** បានដល់ សម្រេចផល ហើយតាំងនៅ ។

[ ១៦២ ] បទថា **កិត្តយិស្សាមិ តេ ធម្មំ** សេចក្ដីថា តថាគតនឹងសម្ដែងនិព្វានធម៌ និងធម៌ដែលជាបដិបទា ឲ្យចូលដល់និព្វានដល់អ្នក ។ បទថា **ទិដ្ឋេ ធម្មេ** សេចក្ដីថា ក្នុងធម៌ មានទុក្ខជាដើមដែលតថាគតឃើញហើយ គឺក្នុងអត្តភាពនេះ ។ បទថា **អនីតិហំ** បានដល់ ប្រចក្សដល់ខ្លួន ។ បទថា **យំ វិទិត្វា** បានដល់ ពិចារណាដឹងច្បាស់នូវធម៌ណា ដោយន័យជាដើមថា សង្ខារទាំងឡាយ មិនទៀង ដូច្នេះ ។

[ ១៦៣ ] ក្នុងបទទាំងនោះ បទថា **អាទិកល្យាណំ** សេចក្តីថា តថាគតលះហើយ និងប្រាប់ធម៌ដែលជាសេចក្តីសុខដែលកើតអំពីវិវេក មិនមានធម៌ដទៃក្រៃលែងជាងដល់អ្នក កាលតថាគតប្រាប់ធម៌នោះតិចក្តី ច្រើនក្តី នឹងប្រាប់ប្រការមានធម៌មានលម្អខាងដើមជាដើមដល់អ្នក អធិប្បាយថា តថាគតនឹងប្រកាសធម៌ ធ្វើឲ្យល្អ ឲ្យចម្រើន ឲ្យមិនមានទោសខាងដើម កណ្តាលក្នុងទីបំផុត តថាគតនឹងប្រកាសធម៌ ធ្វើឲ្យចម្រើន ធ្វើឲ្យមិនមានទោសដូចគ្នា ។ ពិតហើយ ព្រះមានព្រះភាគ ទ្រង់សម្តែងគាថាមួយណា គាថានោះ ល្អខាងដើម ដោយបាទដំបូងនៃធម៌ ល្អត្រង់កណ្តាល ដោយបាទទី ២ ទី ៣ ល្អក្នុងទីបំផុត ដោយបាទទី ៤ ព្រោះជាគាថាដែលចម្រើនគ្រប់គ្រាន់ ។ ព្រះសូត្រដែលមានអនុសន្ធិ ១ ល្អខាងដើម ដោយនិទាន ល្អខាងចុង ដោយនិគមគាថា ល្អត្រង់កណ្តាល ដោយបទដ៏សេស ។ ព្រះសូត្រដែលមានអនុសន្ធិផ្សេងៗ គ្នា ល្អខាងដើម ដោយអនុសន្ធិទី ១ ល្អក្នុងទីបំផុត ដោយអនុសន្ធិចុងក្រោយ ល្អត្រង់កណ្តាល ដោយអនុសន្ធិដ៏សេស ។

ម្យ៉ាងទៀត ឈ្មោះថា ល្អខាងដើម ព្រោះមាននិទាន និងមានរឿងរ៉ាវដែលកើតឡើង ឈ្មោះថា ល្អក្នុងកណ្តាល ព្រោះមានអត្ថមិនវិបរិត និងព្រោះប្រកបដោយការលើកហេតុឡើងមកអាង ដោយអនុរូបដល់វេនេយ្យសត្វ ។ ឈ្មោះថា ល្អក្នុងទីបំផុត ព្រោះធ្វើឲ្យអ្នកស្តាប់ទាំងឡាយបានកើតសទ្ធា និងព្រោះនិគមគាថា ។

ពិតហើយ សាសនធម៌ទាំងមូល ល្អខាងដើមដោយសីល ដែលជាប្រយោជន៍នៃខ្លួន ល្អកណ្ដាលដោយសមថៈ វិបស្សនា មគ្គ និងផល ល្អខាងចុងដោយនិព្វាន ឬល្អខាងដើមដោយសីល សមាធិ ល្អត្រង់កណ្ដាលដោយវិបស្សនា និងមគ្គ ល្អខាងចុង ដោយផល និងនិព្វាន ឬឈ្មោះថា ល្អខាងដើម ព្រោះជាការត្រាស់ដឹងល្អរបស់ព្រះពុទ្ធ ឈ្មោះថា ល្អកណ្ដាល ព្រោះព្រះធម៌ជាធម៌ល្អ ឈ្មោះថា ល្អខាងចុង ព្រោះជាការបដិបត្តិល្អរបស់ព្រះសង្ឃ ។ ឈ្មោះថា ល្អខាងដើម ព្រោះអភិសម្ពោធិញ្ញាណ ដែលអ្នកស្ដាប់ធម៌នោះបដិបត្តិដើម្បីភាពយ៉ាងនោះ ហើយគប្បីសម្រេច ឈ្មោះថា ល្អត្រង់កណ្ដាល ព្រោះបច្ចេកពោធិញ្ញាណ ឈ្មោះថា ល្អខាងចុង ព្រោះសាវកពោធិញ្ញាណ ។

ធម៌ដែលបុគ្គលស្ដាប់នោះ រមែងនាំលម្អមកឲ្យដោយការស្ដាប់ ព្រោះសង្កត់នីវរណៈបាន ព្រោះហេតុនោះ ទើបឈ្មោះថា **អាទិកល្យាណំ** ធម៌ដែលអ្នកបដិបត្តិ រមែងនាំសេចក្ដីល្អមកឲ្យ ដោយការបដិបត្តិ ព្រោះនាំសេចក្ដីសុខដែលកើតអំពីសមថៈ និងវិបស្សនាមកឲ្យ ព្រោះហេតុនោះ ទើបឈ្មោះថា **មជ្ឈេកល្យាណំ** ។ កាលផលនៃការបដិបត្តិសម្រេចហើយ រមែងនាំនូវលម្អមកឲ្យដល់អ្នកបដិបត្តិយ៉ាងនោះៗ ដោយផលនៃការបដិបត្តិ ព្រោះនាំមកនូវភាពជាតាទិបុគ្គល ព្រោះហេតុនោះ ទើបឈ្មោះថា **បរិយោសាន-កល្យាណំ** ។

ម្យ៉ាងទៀត ព្រះមានព្រះភាគ កាលទ្រង់សម្ដែងធម៌ណា រមែងប្រកាសសាសនព្រហ្មចរិយៈ និងមគ្គព្រហ្មចរិយៈ ទ្រង់តែងសម្ដែងដោយន័យផ្សេងៗ ។

សាសនព្រហ្មចរិយៈ និងមគ្គព្រហ្មចរិយៈនោះ ឈ្មោះថា **សាត្ថំ** ព្រោះសម្បូរដោយអត្ថតាមសមគួរ ឈ្មោះថា **សព្យញ្ជនំ** ព្រោះបរិបូណ៌ដោយព្យញ្ជនៈ ។ ឈ្មោះថា **សាត្ថំ** ព្រោះប្រកបព្រមដោយបទនៃអត្ថ គឺការចង្អុលបង្ហាញ ការប្រកាស ការបើកផ្ចារ ការចែក ការធ្វើឲ្យងាយ និងការបញ្ញត្តិ ឈ្មោះថា **សព្យញ្ជនំ** ព្រោះបរិបូណ៌ដោយអក្ខរៈ បទ ព្យញ្ជនៈ អាការ ភាសា និងនិទ្ទេស ។ ឈ្មោះថា **សាត្ថំ** ព្រោះជ្រៅដោយអត្ថ ជ្រៅដោយបដិវេធ ឈ្មោះថា **សព្យញ្ជនំ** ព្រោះជ្រៅដោយធម៌ ជ្រៅដោយទេសនា ឈ្មោះថា **សាត្ថំ** ព្រោះជាវិស័យនៃអត្ថប្បដិសម្ភិទា និងបដិភាណប្បដិសម្ភិទា ឈ្មោះថា **សព្យញ្ជនំ** ព្រោះជាវិស័យនៃធម្មប្បដិសម្ភិទា និងនិរុត្តិប្បដិសម្ភិទា ឈ្មោះថា **សាត្ថំ** ព្រោះជាទីជ្រះថ្លាដល់ជនអ្នកពិចារណា ព្រោះបណ្ឌិតគប្បីដឹង ឈ្មោះថា **សព្យញ្ជនំ** ព្រោះជាទីជ្រះថ្លាដល់លោកិយជន ព្រោះគួរជឿ ឈ្មោះថា **សាត្ថំ** ដោយអធិប្បាយបានជ្រាលជ្រៅ ឈ្មោះថា **សព្យញ្ជនំ** ដោយបទដែលងាយ ឈ្មោះថា **កេវលបរិបុណ្ណំ** ព្រោះមិនមានបទដែលគួរនាំចូលទៅបានទៀត ដោយបរិបូណ៌គ្រប់យ៉ាង ។ ឈ្មោះថា **បរិសុទ្ធំ** ព្រោះមិនមានបទដែលគួរកាត់ចេញ ដោយការមិនមានទោស ។

ម្យ៉ាងទៀត ឈ្មោះថា **សាត្ថំ** ព្រោះមានការមុតស្រួច ក្នុងការសម្រេចដោយបដិបទា ឈ្មោះថា **សព្យញ្ជនំ** ព្រោះមុតស្រួចក្នុងការសិក្សា ដោយបរិយត្តិ ឈ្មោះថា **កេវលបរិបុណ្ណំ** ព្រោះប្រកបដោយធម្មក្ខន្ធ ៥ មានសីលក្ខន្ធជាដើម ឈ្មោះថា **បរិសុទ្ធំ** ព្រោះមិនមានឧបក្កិលេស ព្រោះប្រព្រឹត្ត

ទៅដើម្បីប្រយោជន៍ដល់ការឆ្លងទៅ និងព្រោះមិនសម្លឹងចំពោះលោកាមិស ឈ្មោះថា **ព្រហ្មចរិយំ** ព្រោះដែលបុគ្គលប្រសើរដូចព្រហ្ម គប្បីប្រព្រឹត្ត និងព្រោះជាការប្រព្រឹត្តរបស់បុគ្គលប្រសើរជាងនោះ ។ ព្រោះកំណត់ដោយត្រៃសិក្ខា ។ ព្រះមានព្រះភាគ កាលទ្រង់សម្តែងពោធិបក្ខិយធម៌ ៣៧ ប្រការហើយ ដើម្បីសម្តែងដល់លោកុត្តរធម៌ ដែលកើតឡើងហើយ ទើបត្រាស់ថា **និព្វានញ្ច** ដូច្នេះ ។ បទថា **និព្វានគាមិនិញ្ច បដិបទំ** សេចក្តីថា តថាគតនឹងប្រាប់ធម៌ គឺសីល សមាធិ និងវិបស្សនា ដែលជាចំណែកខាងដើម ។

[ ១៦៤ ] បទថា **ទុក្ខេ និដ្ឋេ** សេចក្តីថា តថាគតនឹងប្រកាសទុក្ខសច្ចក្នុងទុក្ខសច្ច ដែលតថាគតឃើញហើយ មួយអន្លើដោយកិច្ច និងលក្ខណៈ ។ ក្នុងបទថា **សមុទយ** ជាដើម ក៏ន័យនេះដូចគ្នា ។

[ ១៦៧ ] បទថា **តញ្ចាហំ អភិនន្ទាមិ** សេចក្តីថា ខ្ញុំព្រះអង្គប្រាថ្នាព្រះតម្រាស់របស់ទ្រង់ដើម្បីដឹងធម៌ មានប្រការដូចទ្រង់ត្រាស់នោះ ។ បទថា **ធម្មមុត្តមំ** បានដល់ ខ្ញុំព្រះអង្គគាប់ចិត្តក្នុងធម៌ដ៏ឧត្តមនោះ ។

[ ១៦៩ ] ក្នុងបទទាំងនោះ បទថា **មហាតោ តមោកាយស្ស បទាលនំ** សេចក្តីថា កាត់នូវគំនរអវិជ្ជាធំ ។ ទ្រង់រកដោយអនិច្ចលក្ខណៈ ស្វែងដោយទុក្ខលក្ខណៈ ស្ទះស្វែងដោយអនត្តលក្ខណៈដោយជុំវិញ ។ បទថា **មហាតោ វិបល្លាសស្ស បភេទនំ** សេចក្តីថា ទម្លាយវិបល្លាសធំ ១២ យ៉ាង ដោយន័យថា ឃើញក្នុងរបស់មិនស្អាត ថាស្អាត ដូច្នេះជាដើម ។ បទថា **មហាតោ តណ្ហាសល្លស្ស អព្វហានំ** សេចក្តីថា ដកនូវបន្លា គឺ

តណ្ហាធំ ព្រោះអត្ថថា ចាក់ដោតខាងក្នុង ។ បទថា **ទិដ្ឋិសង្ឃាដស្ស វិនិវេឋនំ** សេចក្ដីថា ការបន្ត ព្រោះអត្ថថា ជាប់តគ្នាទៅដោយមិនដាច់ខ្សែនៃទិដ្ឋិ ការត្រឡប់ ការបន្តនៃទិដ្ឋិនោះ ។ បទថា **មានទ្ធជស្ស ឃាតនំ** សេចក្ដីថា ធ្វើមានះដែលដូចជាទង់ដែលមានលក្ខណៈលើកតម្កើងខ្លួន ព្រោះអត្ថថា លើកឡើងឲ្យធ្លាក់ទៅ ។ បទថា **អភិសង្ខារស្ស វូបសមំ** សេចក្ដីថា រម្ងាប់អភិសង្ខារមានបុញ្ញាភិសង្ខារជាដើម ។ បទថា **ឱឃស្ស និត្ថរណំ** សេចក្ដីថា ដកឡើងនូវឱឃៈ មានកាមោឃៈជាដើម ដែលឲ្យសត្វលិចចុះក្នុងវដ្ដៈ ។ បទថា **ភារស្ស និក្ខេបនំ** សេចក្ដីថា ដាក់ចុះនូវភារៈ គឺបញ្ចក្ខន្ធ មានរូបជាដើម ។ បទថា **សំសារវដ្ដស្ស ឧបច្ឆេទំ** សេចក្ដីថា កាត់ការប្រព្រឹត្តទៅនៃសង្សារវដ្ដ គឺលំដាប់នៃខន្ធជាដើម ដោយហេតុ ដោយន័យ ។ បទថា **សន្តាបស្ស និព្វាបនំ** សេចក្ដីថា រម្ងត់នូវការក្ដៅក្រហាយ គឺលិលេស ។ បទថា **បរិឡាហស្ស បដិប្បស្សទ្ធិំ** សេចក្ដីថា ស្ងប់រម្ងាប់នូវការក្ដៅក្រហាយ គឺកិលេស ។ បទថា **ធម្មទ្ធជស្ស ឧស្សាបនំ** សេចក្ដីថា លើកឡើងនូវលោកុត្តរធម៌ ៩ ប្រការតម្កល់ ។ បទថា **បរមត្ថំ អមតំ និព្វានំ** សេចក្ដីថា ឈ្មោះថា **បរមត្ថ** ព្រោះអត្ថថា ឧត្តម ឈ្មោះថា **អមត** ព្រោះនិព្វាននោះ មិនមានការស្លាប់ ឈ្មោះថា **អមត** ព្រោះជាថ្នាំហាមពិស គឺកិលេស ឈ្មោះថា **និព្វាន** ព្រោះរលត់ ដោយគ្រប់សង្កត់សង្សារទុក្ខ ឈ្មោះថា **និព្វាន** ព្រោះមិនមានគ្រឿងដោតក្រង គឺតណ្ហាក្នុងនិព្វាននេះ ។

បទថា **មហោសក្ខេហិ សត្តេហិ** សេចក្ដីថា សត្វទាំងឡាយដែលមាន

សក្កិធំ គឺសក្កៈជាដើម ដែលមានអានុភាពធំក្រៃលែង ។ បទថា **បរិ-យេសិតោ** សេចក្តីថា ស្វែងរក ។ បទថា **កហំ ទេវទេវោ** សេចក្តីថា ទេវតាក្រៃលែងជាងទេវតាទាំងឡាយ នៅក្នុងទីណា ។ បទថា **ឧរាសភោ** សេចក្តីថា បុរសដ៏ឧត្តម ។

[ ១៧២ ] ក្នុងឧទ្ទេសថា **ឧទ្ធំ អធោ តិរិយញ្ចាបិ មជ្ឈេ** សេចក្តីថា អនាគតកាល ហៅថា **ឧទ្ធំ** អតីតកាល ហៅថា **អធោ** បច្ចុប្បន្នកាល ហៅថា **តិរិយញ្ចាបិ មជ្ឈេ** ។ បទថា **ឯតេសុ នន្ទិញ្ច និវេសនញ្ច បនុជ្ជ វិញ្ញាណំ** សេចក្តីថា ចូរអ្នកបន្ទោបង់នូវតណ្ហា ការប្រកាន់ដោយទិដ្ឋិ និង អភិសង្ខារវិញ្ញាណ ក្នុងធម៌ជាចំណែកខាងលើជាដើមនេះ បុគ្គលកាលបន្ទោបង់បានហើយ មិនគប្បីតាំងនៅក្នុងភព គឺថា កាលបើយ៉ាងនេះ បុគ្គលមិនគប្បីតាំងនៅក្នុងភពទាំង ២ ។ សព្ទថា **បនុជ្ជ** គប្បីភ្ជាប់អត្ថវិកប្បនេះថា **បនុទេហិ** ( ចូរបន្ទោបង់ ) ដោយប្រការដូច្នេះ ។ ចំណែកបទថា **បនុទិត្វា** ( កាលបន្ទោបង់ហើយ ) ក្នុងអត្ថវិកប្បនេះ គប្បីភ្ជាប់សេចក្តីថា **ភវេ ន តិដ្ឋេ** ( មិនគប្បីតាំងនៅក្នុងភព ) សេចក្តីថា កាលបន្ទោបង់សេចក្តីត្រេកអរ ការប្រកាន់ និងវិញ្ញាណទាំងនេះបានហើយ មិនគប្បីតាំងនៅក្នុងភពទាំង ២ យ៉ាង ។

[ ១៧៤ ] ក្នុងបទទាំងនោះ បទថា **កុសលា ធម្មា** បានដល់ ធម៌ជាកុសល ទ្រង់ត្រាស់ថា ជាចំណែកខាងលើ ព្រោះលះអបាយហើយ ឲ្យបដិសន្ធិក្នុងខាងលើ អកុសលធម៌ ទ្រង់ត្រាស់ថា ជាចំណែកខាងក្រោម ព្រោះឲ្យបដិសន្ធិក្នុងអបាយទាំងឡាយ អព្យាកតធម៌ ទ្រង់ត្រាស់ថា ជាចំណែកកណ្តាល

ព្រោះផុតចាកចំណែកទាំង ២ នោះ ។ ទេវលោក មួយអន្លើដោយឱកាស-លោក ទ្រង់ត្រាស់ថា ជាចំណែកខាងលើ អបាយលោក ទ្រង់ត្រាស់ថា ជាចំណែកខាងក្រោម មនុស្សលោក ទ្រង់ត្រាស់ថា ជាចំណែកកណ្តាល ។ សុខវេទនា ទ្រង់ត្រាស់ថា ជាចំណែកខាងលើ ដោយអំណាចដឹកអាពាធផ្លូវកាយ និងចិត្ត ទុក្ខវេទនា ទ្រង់ត្រាស់ថា ជាចំណែកខាងក្រោម ដោយឲ្យដល់នូវសេចក្តីទុក្ខ អទុក្ខមសុខវេទនា ទ្រង់ត្រាស់ថា ជាចំណែកកណ្តាល ដោយអំណាចនៃការមិនទុក្ខមិនសុខ ។ អរូបធាតុ ទ្រង់ត្រាស់ថា ជាចំណែកខាងលើ ដោយនៅខាងលើធម៌ទាំងពួង កាមធាតុ ទ្រង់ត្រាស់ថា ជាចំណែកខាងក្រោម ដោយនៅជាន់ទាបជាងធម៌ទាំងពួង រូបធាតុ ទ្រង់ត្រាស់ថា ជាចំណែកកណ្តាល ដោយនៅចន្លោះធម៌ទាំង ២ នោះ ។ ព្រះមានព្រះភាគកាលទ្រង់សម្តែងការកំណត់ដោយអំណាចនៃអត្តភាព ទើបត្រាស់ពាក្យថា **ឧទ្ធំ ឧទ្ធំ បាទតលា** ជាដើម ក្នុងបទទាំងនោះ បទថា **ឧទ្ធំ បាទតលា** បានដល់ ចំណែកខាងលើ តាំងអំពីបាតជើងឡើងទៅ ។ បទថា **អធោ កេសមត្ថកា** បានដល់ ចំណែកខាងក្រោម តាំងអំពីចុងសក់ចុះមក ។ បទថា **មជ្ឈេ** បានដល់ ចន្លោះចំណែកទាំង ២ ។

[ ១៧៥ ] បទថា **បុញ្ញាភិសង្ខារសហគតំ វិញ្ញាណំ** សេចក្តីថា កម្មវិញ្ញាណដែលសម្បយុត្តដោយបុញ្ញាភិសង្ខារ ១៣ ប្រភេទ ។ បទថា **អបុញ្ញាភិសង្ខារសហគតំ វិញ្ញាណំ** សេចក្តីថា កម្មវិញ្ញាណដែលសម្បយុត្តដោយអបុញ្ញាភិសង្ខារ ១២ ប្រភេទ ។ បទថា **អនេញ្ជាភិសង្ខារសហា-**

**គតំ វិញ្ញាណំ** សេចក្តីថា កម្មវិញ្ញាណដែលសហគតៈដោយអនេញ្ជាភិសង្ខារ ៤ ប្រភេទ ។ បទថា **ឆុជ្ជ** បានដល់ ចូរបន្សាត់ទៅ ។ បទថា **បឆុជ្ជ** បានដល់ ចូររលាស់ពេញកម្លាំង ។ បទថា **ឆុឌ** បានដល់ ចូរទាញចេញ ។ បទថា **បឆុឌ** បានដល់ ដកមួយរំពេច ។ បទថា **បជហ** បានដល់ ចូរលះ ។ បទថា **វិនោទេហិ** បានដល់ ចូរធ្វើឲ្យឆ្ងាយ ។

បទថា **កម្មភវញ្ច** បានដល់ ចេតនា មានបុញ្ញាភិសង្ខារជាដើម ។ បទថា **បដិសន្ធិកញ្ច បុនព្ភវំ** សេចក្តីថា ភពថ្មី មានរូបភពជាដើមនៃបដិសន្ធិ កាលលះបង់ ឈ្មោះថា លះបង់ដោយបឋមមគ្គ កាលបន្ទោបង់ ឈ្មោះថា បន្ទោបង់ដោយទុតិយមគ្គ កាលធ្វើឲ្យវិនាស ឈ្មោះថា ធ្វើឲ្យវិនាសដោយតតិយមគ្គ កាលមិនឲ្យមានបែបភាព ឈ្មោះថា ឲ្យដល់នូវការមិនមានបែបភាពដោយចតុត្ថមគ្គ ។ បទថា **កម្មភវេ ន តិដ្ឋេយ្យ** សេចក្តីថា មិនគប្បីតាំងនៅក្នុងអភិសង្ខារ មានបុញ្ញាភិសង្ខារជាដើម ។

[ ១៧៦ ] បទថា **ឯវំ វិហារី** ជាដើម សេចក្តីថា បុគ្គលនោះ កាលបន្ទោបង់សេចក្តីត្រេកអរ ការប្រកាន់ និងវិញ្ញាណទាំងនោះហើយ មិនតាំងនៅក្នុងភព ។ ក្នុងបទទាំងនោះ បទថា **ឥធេវ** បានដល់ ក្នុងសាសនានេះ ឬក្នុងអត្តភាពនេះ ។ និទ្ទេសនៃគាថានេះ មានអត្ថងាយយល់ហើយ ។

[ ១៨០ ] ក្នុងឧទ្ទេសថា **សុកិត្តិតំ គោតមនូបធីកំ** ពាក្យថា **អនូបធីកំ** បានដល់ ព្រះនិព្វាន ។ មេត្តគូមាណព កាលទឹងទូលសន្ទនាជាមួយព្រះមានព្រះភាគ សំដៅដល់ និព្វាននោះ ទើបទូលថា **សុកិត្តិតំ**

**គោតមន្ធុបជីកំ** ដូច្នេះជាដើម ។

[ ១៨២ ] គប្បីជ្រាបវិនិច្ឆ័យក្នុងនិទ្ទេសដូចតទៅ ក្នុងបទទាំងនោះ បទថា **កិលេសា ច** សេចក្តីថា កិលេសទាំងឡាយ មានរាគៈជាដើម ព្រោះអត្ថថា ធ្វើឲ្យក្តៅក្រហាយ បញ្ចក្ខន្ធដែលជាវិបាក ព្រោះអត្ថថា ជាគំនរ និង ចេតនា គឺអភិសង្ខារ មានកុសលជាដើម លោកហៅថា គឺពោលថា ឧបធិ ។ ជាធម៌ដែលលះឧបធិក៏ដោយតទង្គប្បហាន ជាទីស្ងប់ឧបធិ ក៏ដោយវិក្ខម្ភ-នប្បហាន ជាទីលះបង់ឧបធិ ក៏ដោយសមុច្ឆេទប្បហាន ជាទីរម្ងាប់ឧបធិ ក៏ដោយផល ។

[ ១៨៥ ] មិនមែនត្រឹមតែព្រះមានព្រះភាគប៉ុណ្ណោះ ដែលទ្រង់លះទុក្ខបាន គប្បីជ្រាបគាថាថា **តេ ចាបិ** ដូច្នេះជាដើម ។ ក្នុងបទទាំងនោះ បទថា **អដ្ឋិតំ** បានដល់ ដោយការគោរព ឬដោយអើពើ ។ បទថា **តគ្ឃំ ឆមស្សាមិ** បានដល់ ព្រោះដូច្នោះ ខ្ញុំព្រះអង្គសូមនមស្ការព្រះអង្គ ។ បទថា **សមេច្ច** បានដល់ ចូលទៅជិតហើយ ។ មេត្តគូមាណពហៅព្រះមានព្រះភាគថា **ឆាគំ** ។

[ ១៨៨ ] គប្បីជ្រាបវិនិច្ឆ័យក្នុងនិទ្ទេសដូចតទៅ បទថា **សមេច្ច** បានដល់ ដឹង ឬជាអ្នកនៅរួមគ្នា ។ បទថា **អភិសមេច្ច** បានដល់ ចាក់ធ្លុះ ។ បទថា **សមាគន្ត្វា** បានដល់ នៅព្រមគ្នា ។ បទថា **អភិសមាគន្ត្វា** បានដល់ ចូលទៅជិតហើយ ។ បទថា **សម្មុខា** បានដល់ ចំពោះមុខ ។ បទថា **អាគុំ ឆ ករោតិ** បានដល់ មិនធ្វើបាប ។

[ ១៩០ ] ឥឡូវនេះ ព្រះមានព្រះភាគ សូម្បីព្រាហ្មណ៍នោះដឹងយ៉ាងនេះថា សេចក្តីពិត ព្រះមានព្រះភាគទ្រង់លះនូវទុក្ខបានពិតប្រាកដ កាលត្រាស់ប្រៀនប្រដៅព្រាហ្មណ៍ ដោយបុគ្គលដែលលះទុក្ខបានហើយ ដោយមិនអាងដល់ព្រះអង្គ ទើបត្រាស់គាថាថា **យំ ព្រាហ្មណំ** ដូច្នេះជាដើម ។ គាថានោះមានសេចក្តីដូច្នេះថា បុគ្គលកាលស្គាល់បុគ្គលណា គប្បីដឹង គឺគប្បីជ្រាបថា បុគ្គលនេះជាព្រាហ្មណ៍ ព្រោះបន្សាត់បាបបានហើយ ជាអ្នកចប់នូវវេទ ព្រោះសម្រេចវេទទាំងឡាយ ជាអ្នកមិនមានកង្វល់ ព្រោះកន្ទង់កិលេសជាគ្រឿងកង្វល់បានហើយ ជាអ្នកមិនជាប់នៅក្នុងកាមភព ព្រោះមិនជាប់នៅក្នុងកាមនិងក្នុងភព បុគ្គលនោះបានឆ្លងឱឃៈនេះដោយពិត ទាំងឆ្លងដល់ត្រើយ ជាអ្នកមិនមានបង្គោល មិនមានសេចក្តីងឿងឆ្ងល់ ។

[ ១៩២-១៩៤ ] គប្បីជ្រាបវិនិច្ឆ័យក្នុងនិទ្ទេសតទៅ ក្នុងបទទាំងនោះ បទថា **រាគកិញ្ចនំ** បានដល់ គ្រឿងកង្វល់ គឺរាគៈ ។ ក្នុងបទថា **ទោស-កិញ្ចនំ** ជាដើម ក៏មានន័យនេះដូចគ្នា ។ ឆ្លងកាមោឃៈបាន ក៏ដោយអនាគាមិមគ្គ ឆ្លងភវោឃៈបាន ក៏ដោយអរហត្តមគ្គ ឆ្លងទិដ្ឋោឃៈបាន ក៏ដោយសោតាបត្តិមគ្គ ឆ្លងអវិជ្ជោឃៈបាន ក៏ដោយអរហត្តមគ្គ ឆ្លងគន្លងនៃសង្សារទាំងអស់បាន ដោយការកាត់កុសលកម្ម និងអកុសលកម្ម ឆ្លងឡើងហើយដោយបឋមមគ្គ ឆ្លងហើយដោយទុតិយមគ្គ ចេញហើយ ដោយតតិយមគ្គ កន្លងហើយ ដោយចតុត្ថមគ្គ ប្រព្រឹត្តកន្លងហើយ ដោយផល ។

[ ១៩៥ ] គប្បីជ្រាបគាថាថា **វិទ្វា ច យោ** ជាដើមដូចតទៅ ក្នុងបទ

ទាំងនោះ បទថា **ឥធ** បានដល់ ក្នុងសាសនានេះ ឬក្នុងអត្តភាពនេះ ។ បទថា **វិសជ្ជ** បានដល់ លះបង់ហើយ ។

[ ១៩៧ ] គប្បីជ្រាបវិនិច្ឆ័យក្នុងនិទ្ទេសតទៅថា បទថា **សជ្ជំ** បានដល់ លែង ។ បទថា **វិសជ្ជំ** បានដល់ លះបង់ ។ បទដ៏សេសក្នុងទីទាំងពួងជាក់ច្បាស់ល្អហើយ ។ ព្រះមានព្រះភាគ ទ្រង់សម្តែងសូត្រនេះដោយធម៌ជាកំពូល គឺអរហត្ត ដោយប្រការដូច្នេះ ។

កាលចប់ទេសនា សត្វដែលត្រាស់ដឹង ដូចគ្នាតាមដែលបានពោលហើយនោះឯង ។៚

## អដ្ឋកថា មេត្តគូមាណវសុត្តនិទ្ទេសទី ៤ ចប់

# សុត្តន្តបិដក

## ធោតកមាណវកបញ្ហានិទ្ទេស

[ ១៩៩ ] ធោតកៈមានអាយុ ( ទូលសួរដូច្នេះថា ) បពិត្រព្រះមានព្រះភាគ ខ្ញុំព្រះអង្គសូមទូលសួរព្រះអង្គ សូមព្រះអង្គសម្តែងសេចក្តីនោះដល់ខ្ញុំព្រះអង្គ បពិត្រព្រះមហេសី ខ្ញុំព្រះអង្គប្រាថ្នា ( ស្តាប់ ) ព្រះពុទ្ធដីការបស់ព្រះអង្គ ( ព្រោះថា ) បុគ្គលស្តាប់ទេសនារបស់ព្រះអង្គហើយ នឹងសិក្សានូវការរម្ងត់ ( កិលេស ) របស់ខ្លួនបាន ។

[ ២០០ ] អធិប្បាយពាក្យថា បពិត្រព្រះមានព្រះភាគ ខ្ញុំព្រះអង្គសូមទូលសួរព្រះអង្គ សូមព្រះអង្គសម្តែងសេចក្តីនោះដល់ខ្ញុំព្រះអង្គ ត្រង់ពាក្យថា សូមសួរ បានដល់ បុច្ឆា ៣ គឺទិដ្ឋជោតនាបុច្ឆា ១ ទិដ្ឋសំសន្ទនាបុច្ឆា ១ វិមតិច្ឆេទនាបុច្ឆា ១ ។បេ។ នេះ បុច្ឆា ៣ ។បេ។ និព្វានបុច្ឆា ។ ពាក្យថា ខ្ញុំព្រះអង្គសូមទូលសួរព្រះអង្គ គឺខ្ញុំព្រះអង្គសូមសួរចំពោះព្រះអង្គ សូមអង្វរព្រះអង្គ សូមអារាធនាព្រះអង្គ សូមជ្រះថ្លានឹងព្រះអង្គ សូមព្រះអង្គសម្តែងដល់ខ្ញុំព្រះអង្គ ហេតុនោះ ( លោកពោលថា ) ខ្ញុំព្រះអង្គ សូមទូលសួរព្រះអង្គ ។ ពាក្យថា ព្រះមានព្រះភាគ នេះ ជាពាក្យពោលដោយគោរព ។បេ។ ការបញ្ញត្តិថា ព្រះមានព្រះភាគ នេះ ( កើត ) ព្រោះការធ្វើឲ្យជាក់ច្បាស់ ។ ពាក្យថា សូមព្រះអង្គសម្តែងសេចក្តីនោះដល់ខ្ញុំព្រះអង្គ គឺសូមព្រះអង្គពោលប្រាប់ សម្តែង បញ្ញត្ត តាំងទុក បើក ចែក ធ្វើឲ្យ ងាយ ប្រកាស ហេតុនោះ ( លោកពោលថា ) បពិត្រព្រះមានព្រះភាគ ខ្ញុំព្រះអង្គសូមទូលសួរព្រះអង្គ សូមព្រះអង្គសម្តែងសេចក្តីនុ៎ះ ដល់ខ្ញុំព្រះអង្គ ។ ពាក្យថា ដូច្នេះ

នៃបទថា ជោតកៈមានអាយុ ពោលដូច្នេះ គឺជាបទតខាប់ ។ ពាក្យថា មានអាយុ គឺជាពាក្យជាទីស្រឡាញ់ ។ ពាក្យថា ជោតកមាណព ជាឈ្មោះ ។បេ។ ជាពាក្យហៅរបស់ព្រាហ្មណ៍នោះ ។ ហេតុនោះ ( មានពាក្យថា ) ជោតកៈមានអាយុ ទូលសួរដូច្នេះ ។

[ ២០១ ] ពាក្យថា បពិត្រព្រះមហេសី ខ្ញុំព្រះអង្គប្រាថ្នា ( ស្តាប់ ) ព្រះពុទ្ធដីការបស់ព្រះអង្គ គឺខ្ញុំព្រះអង្គប្រាថ្នា ប្រាថ្នាចំពោះ ប៉ង ជ្រះថ្លា ផ្គង ស្រឡាញ់ ជាប់ចិត្ត នូវព្រះពុទ្ធដីកា គន្ធងនៃព្រះពុទ្ធដីកា ទេសនា អនុសន្ធិ របស់ព្រះអង្គ ។ សំណួរត្រង់ពាក្យថា មហេសី ចុះឈ្មោះថា មហេសី ដោយអត្ថដូចម្តេច ។ ឈ្មោះថា មហេសី ព្រោះព្រះមានព្រះភាគ ទ្រង់រកស្វែង ស្វះស្វែង នូវកងសីលដ៏ធំ ។បេ។ ឈ្មោះថា មហេសី ព្រោះព្រះអង្គជានរៈប្រសើរ គង់ក្នុងទីណា ហេតុនោះ ( លោកពោលថា ) បពិត្រព្រះមហេសី ខ្ញុំព្រះអង្គប្រាថ្នា ( ស្តាប់ ) ព្រះពុទ្ធដីការបស់ព្រះអង្គ ។

[ ២០២ ] ពាក្យថា បុគ្គលស្តាប់ទេសនារបស់ព្រះអង្គហើយ គឺបុគ្គលស្តាប់ ឮ រៀន ទ្រទ្រង់ កំណត់ទុកហើយ នូវព្រះពុទ្ធដីកា គន្ធងព្រះពុទ្ធដីកា ទេសនា អនុសន្ធិ របស់ព្រះអង្គ ហេតុនោះ ( លោកពោលថា ) បុគ្គលស្តាប់ទេសនារបស់ព្រះអង្គហើយ ។

[ ២០៣ ] អធិប្បាយពាក្យថា សិក្សា នូវការរលត់ ( កិលេស ) របស់ខ្លួនបាន ត្រង់ពាក្យថា សិក្សា បានដល់ សិក្ខា ៣ គឺអធិសីលសិក្ខា ១ អធិចិត្តសិក្ខា ១ អធិប្បញ្ញាសិក្ខា ១ ។បេ។ នេះ អធិប្បញ្ញាសិក្ខា ។

ពាក្យថា នូវការរម្ងត់ ( កិលេស ) របស់ខ្ញុំបាន គឺនឹងសិក្សាអធិសីល ផង នឹងសិក្សាអធិចិត្តផង នឹងសិក្សាអធិប្បញ្ញាផង ដើម្បីការរលត់រាគៈ រលត់ទោសៈ រលត់មោហៈ រលត់កោធៈ រលត់ឧបនាហៈ ។បេ។ ដើម្បីសេចក្តីស្ងប់រម្ងាប់ ចូលទៅជិតស្ងប់ រម្ងត់ លះបង់ លះបង់ផ្តាច់ នូវអភិ-សង្ខារជាអកុសលទាំងពួង គឺនឹងពិចារណាសិក្សានូវសិក្ខាទាំង ៣ នេះ នឹងដឹងសិក្សា នឹងឃើញសិក្សា នឹងពិចារណាសិក្សា នឹងតាំងចិត្តសិក្សា នឹងចុះចិត្តស៊ប់ដោយសទ្ធាសិក្សា នឹងផ្គងព្យាយាមសិក្សា នឹងប្រុងសតិសិក្សា នឹងតម្កល់ចិត្តឲ្យស្រួលសិក្សា នឹងដឹងដោយប្រាជ្ញាសិក្សា នឹងដឹងជាក់ដោយអភិញ្ញាសិក្សា នឹងកំណត់ដឹងដោយបរិញ្ញាសិក្សា នឹងលះបង់នូវធម៌ដែលគួរលះបង់សិក្សា នឹងចម្រើននូវធម៌ដែលគួរចម្រើនសិក្សា នឹងធ្វើឲ្យជាក់ច្បាស់នូវធម៌ដែលគួរធ្វើឲ្យជាក់ច្បាស់សិក្សា នឹងប្រព្រឹត្តសមាទាន នឹងប្រតិបត្តិសមាទាន ហេតុនោះ លោកពោលថា សិក្សា នូវការរលត់ ( កិលេស ) របស់ខ្ញុំបាន ។ ហេតុនោះ ព្រាហ្មណ៍នោះពោលថា

> បពិត្រព្រះមានព្រះភាគ ខ្ញុំព្រះអង្គសូមទូលសួរព្រះអង្គ សូមព្រះអង្គសម្តែងសេចក្តីនោះ ដល់ខ្ញុំព្រះអង្គ បពិត្រព្រះមហេសី ខ្ញុំព្រះអង្គប្រាថ្នា ( ស្តាប់ ) ព្រះពុទ្ធដីការបស់ព្រះអង្គ ( ព្រោះថា ) បុគ្គលស្តាប់ទេសនារបស់ព្រះអង្គហើយ នឹងសិក្សានូវការរម្ងត់ ( កិលេស ) របស់ខ្ញុំបាន ។

[ ២០៤ ] ( ព្រះមានព្រះភាគត្រាស់ថា ) ម្នាលធោតកៈ បើដូច្នោះ

ចូរអ្នកធ្វើសេចក្តីព្យាយាមចុះ បុគ្គលក្នុងលោកនេះ ជាអ្នកមានបញ្ញាចាស់ក្លា មានស្មារតី ស្តាប់ទេសនាអំពីទីនេះហើយ នឹងសិក្សានូវការរម្ងត់ ( កិលេស ) របស់ខ្លួនបាន ។

[ ២០៥ ] ពាក្យថា បើដូច្នោះ ចូរអ្នកធ្វើសេចក្តីព្យាយាមចុះ គឺអ្នកចូរធ្វើសេចក្តីព្យាយាម ចូរធ្វើឧស្សាហ៍ ចូរធ្វើសេចក្តីប្រឹងប្រែង ចូរធ្វើសេចក្តីសង្វាត ចូរធ្វើសេចក្តីឱហាត ចូរធ្វើសេចក្តីខ្នះខ្នែង ចូរធ្វើសេចក្តីខ្មីឃ្មាត ចូរញុំាងសេចក្តីពេញចិត្តឲ្យកើត ឲ្យកើតព្រម ឲ្យតាំងនៅស៊ប់សួន ឲ្យដុះ ឲ្យដុះចំពោះ ហេតុនោះ ( ទ្រង់ត្រាស់ថា ) បើដូច្នោះ អ្នកចូរធ្វើសេចក្តីព្យាយាមចុះ ។ ពាក្យថា ធោតកៈ នៃបទថា ព្រះមានព្រះភាគត្រាស់ថា ម្នាលធោតកៈ គឺព្រះមានព្រះភាគ ហៅព្រាហ្មណ៍នោះដោយចំណោះ ។ ពាក្យថា ព្រះមានព្រះភាគនេះ ជាពាក្យពោលដោយគោរព ។បេ។ ការបញ្ញត្តិថា ព្រះមានព្រះភាគនេះ ( កើត ) ព្រោះការធ្វើឲ្យជាក់ច្បាស់ ហេតុនោះ ( មានពាក្យថា ) ព្រះមានព្រះភាគត្រាស់ថា ម្នាលធោតកៈ ។

[ ២០៦ ] អធិប្បាយពាក្យថា បុគ្គលក្នុងលោកនេះ ជាអ្នកមានបញ្ញាចាស់ក្លា មានស្មារតី ត្រង់ពាក្យថា ក្នុងលោកនេះ គឺក្នុងទិដ្ឋិនេះ ក្នុងសេចក្តីពេញចិត្តនេះ ក្នុងសេចក្តីគាប់ចិត្តនេះ ក្នុងការកាន់យកនេះ ក្នុងធម៌នេះ ក្នុងវិន័យនេះ ក្នុងធម្មវិន័យនេះ ក្នុងពាក្យជាប្រធាននេះ ក្នុងព្រហ្មចារ្យនេះ ក្នុងសាសនាព្រះសាស្តានេះ ក្នុងអត្តភាពនេះ ក្នុងមនុស្សលោកនេះ ។

ពាក្យថា មានបញ្ញាចាស់ក្លា គឺមានបញ្ញាធ្ងន់ ជាបណ្ឌិតមានប្រាជ្ញា

មានការចេះដឹង មានញាណ ជាអ្នកប្រាជ្ញ មានប្រាជ្ញាជាគ្រឿងទម្លាយបង់នូវកិលេស ។ ពាក្យថា មានស្មារតី គឺមានស្មារតី ដោយហេតុ ៤ គឺបុគ្គលកំពុងចម្រើនកាយានុបស្សនាសតិប្បដ្ឋានក្នុងកាយ ឈ្មោះថា អ្នកមានស្មារតី ។បេ។ បុគ្គលនោះ លោកហៅថា អ្នកមានស្មារតី ហេតុនោះ ( ទ្រង់ត្រាស់ថា ) បុគ្គលក្នុងលោកនេះ ជាអ្នកមានបញ្ញាចាស់ក្លា មានស្មារតី ។

[ ២០៧ ] ពាក្យថា ស្តាប់ទេសនាអំពីទីនេះហើយ គឺស្តាប់ ត្រងត្រាប់ រៀន ទ្រទ្រង់ កំណត់ទុក នូវពាក្យ គន្លងពាក្យ ទេសនា អនុសន្ធិ របស់តថាគតអំពីទីនេះ ហេតុនោះ ( ទ្រង់ត្រាស់ថា ) ស្តាប់នូវទេសនាអំពីទីនេះហើយ ។

[ ២០៨ ] អធិប្បាយពាក្យថា នឹងសិក្សានូវការរម្ងត់ ( កិលេស ) របស់ខ្លួន ត្រង់ពាក្យថា នឹងសិក្សា បានដល់ សិក្ខា ៣ គឺអធិសីលសិក្ខា ១ អធិចិត្តសិក្ខា ១ អធិប្បញ្ញាសិក្ខា ១ ។បេ។ នេះ អធិប្បញ្ញាសិក្ខា ។ ពាក្យថា ការរម្ងត់ ( កិលេស ) របស់ខ្លួន គឺនឹងសិក្សាអធិសីលផង នឹងសិក្សាអធិចិត្តផង នឹងសិក្សាអធិប្បញ្ញាផង ដើម្បីការរម្ងត់រាគៈ ការរម្ងត់ទោសៈ ការរម្ងត់មោហៈ ការរម្ងត់កោធៈ ការរម្ងត់ឧបនាហៈ ។បេ។ ដើម្បីការស្ងប់រម្ងាប់ ស្ងប់រម្ងាប់ រម្ងត់ លះបង់ រម្ងាប់ នូវអភិសង្ខារ ជាអកុសលទាំងពួង នឹងពិចារណាសិក្សានូវសិក្ខាទាំង ៣ នេះ នឹងដឹង សិក្សា ។បេ។ នឹងធ្វើឲ្យជាក់ច្បាស់នូវធម៌ ដែលគួរធ្វើឲ្យជាក់ច្បាស់សិក្សា នឹងប្រព្រឹត្តសមាទាន នឹងប្រតិបត្តិសមាទាន ហេតុនោះ ( ទ្រង់ត្រាស់ថា ) នឹងសិក្សានូវការរលត់

( កិលេស ) របស់ខ្លួនបាន ។ ហេតុនោះ ព្រះមានព្រះភាគត្រាស់ថា

ម្នាលធោតកៈ បើដូច្នោះ ចូរអ្នកធ្វើសេចក្ដីព្យាយាមចុះ បុគ្គល ក្នុងលោកនេះ ជាអ្នកមានបញ្ញាចាស់ក្លា មានស្មារតី ស្ដាប់ទេសនាអំពីទីនេះហើយ នឹងសិក្សានូវការរម្ងាត់ ( កិលេស ) របស់ខ្លួនបាន ។

[ ២០៩ ] ( ធោតកៈពោលថា ) ខ្ញុំព្រះអង្គបានឃើញព្រះអង្គ ជាទេវតា ក្នុងមនុស្សលោក ព្រះអង្គមិនមានកង្វល់ ជាព្រាហ្មណ៍កំពុងប្រព្រឹត្ត បពិត្រព្រះអង្គជាសមន្តចក្ខុ ខ្ញុំព្រះអង្គសូមនមស្ការព្រះអង្គ បពិត្រព្រះអង្គជាសក្កៈ សូមព្រះអង្គដោះខ្ញុំព្រះអង្គ ឲ្យផុតចាកសេចក្ដីសង្ស័យទាំងឡាយ ។

[ ២១០ ] អធិប្បាយពាក្យថា ខ្ញុំព្រះអង្គបានឃើញព្រះអង្គ ជាទេវតា ក្នុងមនុស្សលោក ត្រង់ពាក្យថា ទេវតា បានដល់ ពួកទេព ៣ គឺសម្មតិទេព ១ ឧបបត្តិទេព ១ វិសុទ្ធិទេព ១ ។ សម្មតិទេព តើដូចម្ដេច ។ ពួកព្រះរាជា ព្រះរាជកុមា និងព្រះទេវី លោកហៅថា សម្មតិទេព ។ ឧបបត្តិទេព តើដូចម្ដេច ។ ពួកទេពស្ថិតនៅក្នុងចាតុម្មហារាជិកា ពួកទេពស្ថិតនៅក្នុងតាវត្តិង្ស ពួកទេពស្ថិតនៅក្នុងយាមា ពួកទេពស្ថិតនៅក្នុងតុសិត ពួកទេពស្ថិតនៅក្នុងនិម្មានរតី ពួកទេពស្ថិតនៅក្នុងបរនិម្មិតវសវត្តី និងពួកទេពជាពួកនៃព្រហ្ម ជាពួកទេពដែលស្ថិតនៅខាងលើពួកទេពទាំងនុ៎ះ លោកហៅថា ឧបបត្តិទេព ។ វិសុទ្ធិទេព តើដូចម្ដេច ។ ពួកព្រះអរហន្តខីណាស្រព ជាសាវករបស់ព្រះតថាគត និងពួកព្រះខីណាស្រព ដែលជាព្រះបច្ចេកពុទ្ធ លោកហៅថា

វិសុទ្ធិទេព ។ ព្រះមានព្រះភាគ ជាទេពរបស់ពួកសម្មតិទេព ឧបបត្តិទេព និងវិសុទ្ធិទេព ជាទេពដ៏ក្រៃលែងផង ជាទេពធំកន្លងជាងពួកទេពផង ជាសីហៈ ធំជាងសីហៈផង ជានាគធំជាងនាគផង ជាមេគណៈ ធំជាងមេគណៈផង ជាមុនី ធំជាងមុនីផង ជាព្រះរាជា ធំជាងព្រះរាជាផង ។ ពាក្យថា ខ្ញុំព្រះអង្គបានឃើញព្រះអង្គជាទេវតា ក្នុងមនុស្សលោក បានន័យថា ខ្ញុំព្រះអង្គឃើញព្រះអង្គជាទេវតា គឺខ្ញុំព្រះអង្គឃើញព្រះអង្គ ជាទេវតាកន្លងទេវតា ឃើញ ប្រទះឃើញ រមិលឃើញ សម្លឹងមើល ពិចារណាមើល នូវព្រះអង្គជាទេព ធំជាងពួកទេព ហេតុនោះ លោកពោលថា ខ្ញុំព្រះអង្គបានឃើញព្រះអង្គ ជាទេវតា ក្នុងមនុស្សលោក ។

[ ២១១ ] អធិប្បាយពាក្យថា ព្រះអង្គមិនមានកង្វល់ ជាព្រាហ្មណ៍កំពុងប្រព្រឹត្ត ត្រង់ពាក្យថា ព្រះអង្គមិនមានកង្វល់ បានដល់ កង្វល់ គឺរាគៈ កង្វល់ គឺទោសៈ កង្វល់ គឺមោហៈ កង្វល់ គឺមានះ កង្វល់ គឺទិដ្ឋិ កង្វល់ គឺកិលេស កង្វល់ គឺទុច្ចរិត កង្វល់ទាំងនុ៎ះ ព្រះពុទ្ធមានព្រះភាគ ទ្រង់លះបង់ផ្តាច់ផ្តិលឫសគល់ ធ្វើឲ្យនៅតែទីកើតដូចដើមត្នោត ធ្វើមិនឲ្យមានបែបភាពឲ្យជារបស់មានបែបភាពមិនកើតតទៅទៀត ហេតុនោះ ព្រះពុទ្ធ ឈ្មោះថា មិនមានកង្វល់ ។ ពាក្យថា ជាព្រាហ្មណ៍ គឺព្រះមានព្រះភាគ ឈ្មោះថា ព្រាហ្មណ៍ ព្រោះទ្រង់បន្សាត់បោលធម៌ ៧ គឺបន្សាត់សក្កាយទិដ្ឋិ បន្សាត់វិចិកិច្ឆា បន្សាត់សីលព្វតបរាមាស បន្សាត់រាគៈ បន្សាត់ទោសៈ បន្សាត់មោហៈ បន្សាត់មានះ ទាំងអកុសលធម៌ដ៏លាមកទាំងឡាយ ប្រឡូកប្រឡំ

ដោយសេចក្តីសៅហ្មង នាំឲ្យកើតក្នុងភពថ្មី ប្រកបដោយសេចក្តីក្រវល់ក្រវាយ មានទុក្ខជាផល ជាទីតាំងនៃជាតិ ជរា និងមរណៈទៅខាងមុខ ព្រះអង្គបន្សាត់ចោលហើយ ។

*ព្រះមានព្រះភាគ ទ្រង់ត្រាស់ថា ម្នាលសភិយៈ ព្រះមានព្រះភាគ បន្សាត់បង់នូវបាបទាំងពួង ទ្រង់មិនមានមន្ទិល មានព្រះហឫទ័យតម្កល់ដោយប្រពៃ មានព្រះហឫទ័យនឹងនួន ព្រះមានព្រះភាគនោះ ព្រះអង្គបរិបូណ៌ដោយគុណគ្រប់យ៉ាង កន្លងបង់នូវសង្សារ មិនអាស្រ័យ ( តណ្ហា និងទិដ្ឋិ ) ទ្រង់មិនញាប់ញ័រ ( ដោយលោកធម៌ ) ទើបលោកហៅថា ព្រាហ្មណ៍ ។*

ពាក្យថា កំពុងប្រព្រឹត្ត គឺកំពុងត្រាច់ទៅ ត្រាច់ទៅផ្សេងៗ ទៅប្រព្រឹត្តទៅ រក្សា យាត្រា យាត្រាទៅ ហេតុនោះ ( លោកពោលថា ) ព្រះអង្គមិនមានកង្វល់ ជាព្រាហ្មណ៍ កំពុងប្រព្រឹត្ត ។

[ ២១២ ] ពាក្យថា បពិត្រព្រះអង្គជាសមន្តចក្ខុ ខ្ញុំព្រះអង្គសូមនមស្ការព្រះអង្គ ត្រង់ពាក្យថា ព្រះអង្គ គឺលោកហៅព្រះមានព្រះភាគ ។ ពាក្យថា សូមនមស្ការ គឺសូមនមស្ការដោយកាយក្តី សូមនមស្ការដោយវាចាក្តី សូមនមស្ការដោយចិត្តក្តី សូមនមស្ការដោយសេចក្តីប្រតិបត្តិ ដែលមានប្រយោជន៍ជាលំដាប់ៗ ក្តី សូមនមស្ការធ្វើសក្ការៈ ធ្វើគោរពរាប់អាន បូជាដោយធម្មានុធម្មប្បដិបត្តិក្តី ។ ពាក្យថា សមន្តចក្ខុ សេចក្តីថា សព្វញ្ញុតញ្ញាណ លោកហៅថា សមន្តចក្ខុ ។ ព្រះមានព្រះភាគ ដល់ ដល់ព្រម

មកដល់ មកដល់ព្រម ចូលទៅជិត ចូលទៅជិតព្រម ប្រកបហើយដោយសព្វញ្ញុតញ្ញាណនោះ ។

វត្ថុនីមួយក្នុងលោកនេះ ដែលព្រះមានព្រះភាគមិនឃើញ ឬមិនដឹង មិនគប្បីដឹង មិនមានទេ ព្រះតថាគត ទ្រង់ជ្រាបច្បាស់នូវវត្ថុទាំងអស់ ដែលគួរជ្រាប ហេតុនោះ ព្រះតថាគត ឈ្មោះថា សមន្តចក្ខុ ។

ហេតុនោះ ( លោកពោលថា ) បពិត្រព្រះអង្គ ជាសមន្តចក្ខុ ខ្ញុំព្រះអង្គសូមនមស្ការព្រះអង្គ ។

[ ២១៣ ] អធិប្បាយពាក្យថា បពិត្រព្រះអង្គជាសក្កៈ សូមព្រះអង្គដោះខ្ញុំព្រះអង្គ ឲ្យផុតចាកសេចក្តីសង្ស័យទាំងឡាយ ត្រង់ពាក្យថា បពិត្រព្រះអង្គជាសក្កៈ សេចក្តីថា ព្រះមានព្រះភាគ ចេញចាកសក្យត្រកូលហើយទ្រង់បព្វជ្ជា ហេតុនោះ ទើបទ្រង់ព្រះនាមថា សក្កៈក៏មាន ។ មួយទៀត ព្រះមានព្រះភាគ ស្តុកស្តម្ភ មានទ្រព្យច្រើន មានទ្រព្យធន ហេតុនោះ ទើបទ្រង់ព្រះនាមថា សក្កៈក៏មាន ។ ទ្រព្យទាំងនោះ របស់ព្រះអង្គ គឺទ្រព្យសទ្ធា ទ្រព្យសីល ទ្រព្យហិរិ ទ្រព្យឱត្តប្បៈ ទ្រព្យសុតៈ ទ្រព្យចាគៈ ទ្រព្យបញ្ញា ទ្រព្យសតិប្បដ្ឋាន ទ្រព្យសម្មប្បធាន ទ្រព្យឥទ្ធិបាទ ទ្រព្យឥន្ទ្រិយ ទ្រព្យពល ទ្រព្យពោជ្ឈង្គ ទ្រព្យមគ្គ ទ្រព្យផល ទ្រព្យព្រះនិព្វាន ។ ព្រះមានព្រះភាគ ស្តុកស្តម្ភ មានទ្រព្យច្រើន មានទ្រព្យធន ដោយទ្រព្យប្រសើរទាំងឡាយ ច្រើនប្រការនេះ ហេតុនោះ ទើបទ្រង់ព្រះនាមថា សក្កៈក៏មាន ។

មួយទៀត ព្រះមានព្រះភាគ ទ្រង់អង់អាច អាចហ៊ាន ក្លាហាន មោះមុត ក្លៀវក្លា មានព្យាយាម ធ្លាប់ចូលកាន់សង្គ្រាម មិនខ្លាច មិនរន្ធត់ មិនកត់ស្លុត មិនរត់ចោល លះភ័យគួរខ្លាច ទ្រង់មិនព្រឺរោម ហេតុនោះ ទើបទ្រង់ព្រះនាមថា សក្កៈ ក៏មាន ។ សេចក្ដីស្នាក់ស្ទើ លោកហៅថា សេចក្ដីសង្ស័យ គឺ សង្ស័យក្នុងទុក្ខ សង្ស័យក្នុងតណ្ហា ជាហេតុឲ្យកើតទុក្ខ សង្ស័យក្នុងសេចក្ដីរម្ងាត់ទុក្ខ សង្ស័យក្នុងបដិបទា ជាដំណើរទៅដើម្បីរម្ងាត់ទុក្ខ សង្ស័យក្នុងចំណែកខាងដើម សង្ស័យក្នុងចំណែកខាងចុង សង្ស័យទាំងចំណែកខាងដើមនិងខាងចុង សង្ស័យក្នុងធម៌ទាំងឡាយ ដែលកើតឡើង អាស្រ័យព្រោះបច្ច័យនេះ គឺបានខាងការសង្ស័យ អាការនៃការសង្ស័យ ភាពនៃការសង្ស័យ ការងឿងឆ្ងល់ ការស្នាក់ស្ទើ ការយល់ជាពីរយ៉ាង ការបែកគំនិតជាពីរផ្លូវ ការសន្និះសង្ស័យ ការប្រកាន់ច្រើនចំណែក ការរសេមរសាម ការស្លុតស្លាញ ការប្រកាន់ឆ្វេង ភាពនៃចិត្តញាប់ញ័រ គំនូសនៃចិត្ត មានសភាពយ៉ាងនេះ ។ ពាក្យថា បពិត្រព្រះអង្គជាសក្កៈ សូមព្រះអង្គដោះខ្ញុំព្រះអង្គឲ្យផុតចាកសេចក្ដីសង្ស័យទាំងឡាយ បានន័យថា សូមព្រះអង្គដោះខ្ញុំព្រះអង្គ សូមស្រាយខ្ញុំព្រះអង្គ សូមលែងខ្ញុំព្រះអង្គ សូមជ្រោងឡើងនូវខ្ញុំព្រះអង្គ សូមស្រង់ឡើងនូវខ្ញុំព្រះអង្គ សូមញ៉ាំងខ្ញុំព្រះអង្គឲ្យរួចផុតស្រឡះអំពីសរ គឺសេចក្ដីសង្ស័យ ហេតុនោះ ( លោកពោលថា ) បពិត្រព្រះអង្គជាសក្កៈ សូមព្រះអង្គដោះខ្ញុំព្រះអង្គ ឲ្យផុតចាកសេចក្ដីសង្ស័យទាំងឡាយ ។ ហេតុនោះ ព្រាហ្មណ៍នោះពោលថា

ខ្ញុំព្រះអង្គ បានឃើញព្រះអង្គ ជាទេវតាក្នុងមនុស្សលោក ព្រះអង្គ មិនមានកង្វល់ ជាព្រាហ្មណ៍ កំពុងប្រព្រឹត្ត បពិត្រព្រះអង្គជាសមន្តចក្ខុ ខ្ញុំព្រះអង្គសូមនមស្ការព្រះអង្គ បពិត្រព្រះអង្គជាសក្កៈ សូមព្រះអង្គដោះខ្ញុំព្រះអង្គ ឲ្យផុតចាកសេចក្តីសង្ស័យទាំងឡាយ ។

[ ២១៤ ] ( ព្រះមានព្រះភាគត្រាស់ថា ) ម្នាលធោតកៈ តថាគតមិនអាចដើម្បីដោះអ្នកណាមួយ ក្នុងលោកនេះ ដែលមានសេចក្តីសង្ស័យបានទេ ប៉ុន្តែកាលបើអ្នកបានដឹងច្បាស់នូវធម៌ដ៏ប្រសើរយ៉ាងនេះ នឹងឆ្លងឱឃៈនេះបាន ។

[ ២១៥ ] ពាក្យថា តថាគត មិនអាចដើម្បីដោះ អធិប្បាយថា តថាគត មិនអាចដោះអ្នក ស្រាយចេញ ស្រាយលែង ដោះលែង ជ្រោងឡើង ស្រង់ឡើង ឲ្យក្រោកចេញអំពីសរ គឺសេចក្តីសង្ស័យបាន ហេតុនោះ ( ទ្រង់ត្រាស់ថា ) តថាគត មិនអាចដើម្បីដោះយ៉ាងនេះខ្លះ ។ មួយទៀត តថាគត មិនខ្វល់ខ្វាយ មិនខ្វល់ខ្វាយខ្លាំង មិនឧស្សាហ៍ មិនព្យាយាម មិនធ្វើឧស្សាហ៍ មិនធ្វើសេចក្តីប្រឹងប្រែង មិនធ្វើនូវសេចក្តីខ្នះខ្នែង មិនធ្វើសេចក្តីឱហាត មិនធ្វើព្យាយាម មិនញុំាងឆន្ទៈឲ្យកើត មិនឲ្យកើតព្រម មិនឲ្យដុះ មិនឲ្យដុះដាល ( ដើម្បីដោះ ) នូវពួកបុគ្គល មិនមានឆន្ទៈ ខ្ជិលច្រអូស ថយព្យាយាម មិនប្រតិបត្តិតាម ដោយធម្មទេសនាបានទេ ព្រោះហេតុនោះ ( ទ្រង់ត្រាស់ថា ) តថាគត មិនអាចដោះយ៉ាងនេះខ្លះ ។ មួយ

ទៀត បុគ្គលដទៃណាមួយ ញុំាងបុគ្គលដទៃឲ្យរួចបាន មិនមានទេ ត្រូវតែបុគ្គលទាំងនោះ រួចដោយសេចក្ដីព្យាយាម ដ៏តឹងរ៉ឹងរបស់ខ្លួន ដោយកម្លាំងរបស់ខ្លួន ដោយការព្យាយាមរបស់ខ្លួន ដោយសេចក្ដីប្រឹងប្រែងរបស់ខ្លួន ដោយការព្យាយាមដ៏តឹងរ៉ឹងនៃបុរសរបស់ខ្លួន ដោយកម្លាំងបុរសរបស់ខ្លួន ដោយការព្យាយាមបុរសរបស់ខ្លួន ដោយសេចក្ដីប្រឹងប្រែងបុរសរបស់ខ្លួន គឺប្រតិបត្តិនូវសម្មាបដិបទា អនុលោមប្បដិបទា អនុត្តប្បដិបទា ធម្មានុធម្មប្បដិបទាដោយខ្លួនឯង ទើបរួចបាន ហេតុនោះ ទ្រង់ត្រាស់ថា តថាគតមិនអាចដើម្បីដោះយ៉ាងនេះខ្លះ ។ សមដូចព្រះពុទ្ធតម្រាស់នេះ ដែលព្រះមានព្រះភាគទ្រង់ត្រាស់ថា ម្នាលធោតក បុគ្គលនោះ លិចចុះក្នុងភក់ខ្លួនឯង នឹងស្រង់បុគ្គលដទៃ ដែលលិចចុះក្នុងភក់បាន ហេតុនេះ មិនដែលមានទេ ម្នាលចុន្ទ បុគ្គលនោះ មិនបានទូន្មាន មិនបានប្រៀនប្រដៅ មិនបានរម្ងាប់កិលេសដោយខ្លួនឯង នឹងទូន្មានប្រៀនប្រដៅបុគ្គលដទៃ ឬថា ញុំាងកិលេសរបស់បុគ្គលដទៃ ឲ្យរលត់បាន ហេតុនេះ មិនដែលមានទេ ហេតុនោះ ( ទ្រង់ត្រាស់ថា ) តថាគតមិនអាចដោះយ៉ាងនេះខ្លះ ។ មួយទៀត សមដូចព្រះពុទ្ធតម្រាស់នេះ ដែលព្រះមានព្រះភាគទ្រង់ត្រាស់ថា

> បុគ្គលធ្វើបាប ដោយខ្លួនឯង រមែងសៅហ្មង ដោយខ្លួនឯង មិនធ្វើបាប ដោយខ្លួនឯង រមែងស្អាត ដោយខ្លួនឯង សេចក្ដីបរិសុទ្ធនិងសេចក្ដីមិនបរិសុទ្ធមានចំពោះខ្លួន បុគ្គលដទៃ មិនគប្បីញុំាងបុគ្គលដទៃឲ្យស្អាតបានទេ ។

ហេតុនោះ ( ទ្រង់ត្រាស់ថា ) តថាគត មិនអាចដោះយ៉ាងនេះខ្លះ ។ មួយទៀត សមដូចព្រះពុទ្ធតម្រាស់នេះ ដែលព្រះមានព្រះភាគទ្រង់ត្រាស់ថា ម្នាលព្រាហ្មណ៍ ព្រះនិព្វាន ក៏មាននៅស្រាប់ ទាំងផ្លូវទៅកាន់ព្រះនិព្វាន ក៏មាននៅស្រាប់ តថាគតជាអ្នកបបួល ក៏មាននៅស្រាប់ តែថា ពួកសាវ័ករបស់តថាគត ដែលតថាគតទូន្មានយ៉ាងនេះ ប្រៀនប្រដៅយ៉ាងនេះ ពួកខ្លះ បានសម្រេចព្រះនិព្វានជាទីបំផុតដោយពិត ពួកខ្លះ ក៏មិនបានសម្រេច ម្នាលព្រាហ្មណ៍ តថាគតនឹងធ្វើដូចម្ដេចក្នុងបុគ្គលពួកនេះ ម្នាលព្រាហ្មណ៍ ព្រះតថាគត ជាអ្នកប្រាប់ផ្លូវ បើគេសួរផ្លូវហើយ ទើបព្រះតថាគតប្រាប់បាន បុគ្គលកាលប្រតិបត្តិ ដោយខ្លួនឯង គប្បីរួចបាន ហេតុនោះ ( ទ្រង់ត្រាស់ថា ) តថាគតមិនអាចដោះយ៉ាងនេះខ្លះ ។

[ ២១៦ ] ពាក្យថា ម្នាលធោតកៈ ( តថាគតមិនអាចដើម្បីដោះ ) អ្នកណាមួយ ក្នុងលោកនេះ ដែលមានសេចក្ដីសង្ស័យបានទេ គឺបុគ្គលដែលមានសេចក្ដីសង្ស័យ ប្រកបដោយសេចក្ដីងឿងឆ្ងល់ មានសេចក្ដីរឹងរូស មានការយល់ជាពីរផ្លូវ មានសេចក្ដីស្ទាក់ស្ទើរ ។ ពាក្យថា អ្នកណាមួយ គឺក្សត្រក្ដី ព្រាហ្មណ៍ក្ដី វេស្សៈក្ដី សុទ្ទៈក្ដី គ្រហស្ថក្ដី បព្វជិតក្ដី ទេវតាក្ដី មនុស្សក្ដីណាមួយ ។ ពាក្យថា ក្នុងលោក គឺក្នុងអបាយលោក ។បេ។ ក្នុងអាយតនលោក ហេតុនោះ ( ទ្រង់ត្រាស់ថា ) ម្នាលធោតកៈ តថាគតមិនអាចដើម្បីដោះអ្នកណាមួយ ក្នុងលោកនេះ ដែលមានសេចក្ដីសង្ស័យបានទេ ។

[ ២១៧ ] ពាក្យថា ប៉ុន្តែ កាលបើអ្នកបានដឹងច្បាស់នូវធម៌ដ៏ប្រសើរ

សេចក្តីថា អមតនិព្វាន លោកហៅថា ធម៌ដ៏ប្រសើរ បានខាងការរម្ងាប់សង្ខារទាំងពួង ការលះបង់ឧបធិទាំងពួង ការអស់តណ្ហា ការប្រាសចាករាគៈ ការរលត់ និព្វាន ។ ពាក្យថា ប្រសើរ គឺធម៌ដ៏លើស ដ៏ប្រសើរ ប្រសើរវិសេស ជាប្រធាន ឧត្តម ថ្លៃថ្លា ។ ពាក្យថា ដឹងច្បាស់ គឺដឹងប្រាកដ យល់ច្បាស់ ជ្រាបច្បាស់ ចាក់ធ្លុះចំពោះ ហេតុនោះ ( ទ្រង់ត្រាស់ថា ) ប៉ុន្តែកាលបើអ្នកបានដឹងច្បាស់នូវធម៌ដ៏ប្រសើរ ។

[ ២១៨ ] ពាក្យថា យ៉ាងនេះ នឹងឆ្លងនូវឱឃៈនេះបាន គឺអ្នកគប្បីឆ្លង គប្បីឈានកន្លងគប្បីប្រព្រឹត្តកន្លងនូវកាមោឃៈ ភវោឃៈ ទិដ្ឋោឃៈ អវិជ្ជោឃៈ ហេតុនោះ ( ទ្រង់ត្រាស់ថា ) យ៉ាងនេះ នឹងឆ្លងឱឃៈនេះបាន ។ ហេតុនោះព្រះមានព្រះភាគត្រាស់ថា

ម្នាលធោតកៈ តថាគតមិនអាចដើម្បីដោះអ្នកណាមួយ ក្នុងលោកនេះ ដែលមានសេចក្តីសង្ស័យបានទេ ប៉ុន្តែ កាលបើអ្នកបានដឹងច្បាស់នូវធម៌ដ៏ប្រសើរយ៉ាងនេះ នឹងឆ្លងឱឃៈនេះបាន ។

[ ២១៩ ] ( ធោតកៈក្រាបទូលថា ) បពិត្រព្រះអង្គជាព្រហ្ម សូមព្រះអង្គទ្រង់ព្រះករុណា ប្រៀនប្រដៅ នូវវិវេកធម៌ ឲ្យខ្ញុំព្រះអង្គដឹងច្បាស់ ដើម្បីកុំឲ្យខ្ញុំព្រះអង្គទើសទាក់ ដូចអាកាស ជាបុគ្គលស្ងប់ មិនអាស្រ័យនៅ ( ដោយកិលេស ) ប្រព្រឹត្តក្នុងទីនេះឯង ។

[ ២២០ ] ពាក្យថា បពិត្រព្រះអង្គជាព្រហ្ម សូមព្រះអង្គប្រៀនប្រដៅ

នៃបទថា បពិត្រព្រះអង្គជាព្រហ្ម សូមព្រះអង្គទ្រង់ព្រះករុណា ប្រៀនប្រដៅ គឺបពិត្រព្រហ្ម សូមព្រះអង្គប្រៀនប្រដៅ បពិត្រព្រហ្ម សូមព្រះអង្គអនុគ្រោះ បពិត្រព្រហ្ម សូមព្រះអង្គស្រោចស្រង់ ហេតុនោះ ( លោកពោលថា ) បពិត្រព្រះអង្គជាព្រហ្ម សូមព្រះអង្គប្រៀនប្រដៅ ។ ពាក្យថា ទ្រង់ព្រះករុណា គឺទ្រង់ព្រះករុណា ទ្រង់អាណិត ទ្រង់អាសូរ ទ្រង់អនុគ្រោះ ទ្រង់ស្រោចស្រង់ ហេតុនោះ ( លោកពោលថា ) បពិត្រព្រះអង្គជាព្រហ្ម សូមទ្រង់ព្រះករុណា ប្រៀនប្រដៅ ។

[ ២២១ ] ពាក្យថា នូវវិវេកធម៌ ឲ្យខ្ញុំព្រះអង្គដឹងច្បាស់ សេចក្តីថា អមតនិព្វាន លោកហៅថា វិវេកធម៌ បានដល់ ការរម្ងាប់សង្ខារទាំងពួង ការលះបង់ឧបធិទាំងពួង ការអស់តណ្ហា ការប្រាសចាករាគៈ ការរលត់ និព្វាន ។ ពាក្យថា ឲ្យខ្ញុំព្រះអង្គដឹងច្បាស់ គឺឲ្យខ្ញុំព្រះអង្គចេះដឹង ដឹងច្បាស់ យល់ច្បាស់ ចាក់ធ្លុះចំពោះ ហេតុនោះ ( លោកពោលថា ) នូវវិវេកធម៌ ឲ្យខ្ញុំព្រះអង្គដឹងច្បាស់ ។

[ ២២២ ] ពាក្យថា ដើម្បីកុំឲ្យខ្ញុំព្រះអង្គទើសទាក់ ដូចអាកាស គឺឲ្យខ្ញុំព្រះអង្គមិនទើសទាល់ មិនជាប់ជំពាក់ មិនជាប់ស្អិត ដូចអាកាស មិនទើសទាល់ មិនជាប់ជំពាក់ មិនជាប់ស្អិត ដូច្នោះឯង ហេតុនោះ ( លោកពោលថា ) មិនទើសទាក់ ដូចអាកាស ដោយប្រការដូច្នេះខ្លះ ។ ឲ្យខ្ញុំព្រះអង្គ មិនត្រេកអរ មិនប្រទូស្ត មិនវង្វេង មិនលំបាកដូចអាកាស មិនជិតដោយល័ខ ឬដោយល្មៀត ឬដោយវត្ថុពណ៌ខៀវ ឬដោយវត្ថុពណ៌ហង្សបាទ ដូច្នោះឯង

ហេតុនោះ ( លោកពោលថា ) មិនទើសទាក់ ដូចអាកាស ដោយប្រការដូច្នេះខ្លះ ។ ឲ្យខ្ញុំព្រះអង្គ មិនក្រោធ មិនបៀតបៀន មិនវិលវល់នៅ មិនលំបាក ដូចអាកាស មិនកម្រើក មិនបៀតបៀន មិនវិលវល់នៅ មិនលំបាក ដូច្នោះឯង ហេតុនោះ ( លោកពោលថា ) មិនទើសទាក់ ដូចអាកាស ដោយប្រការដូច្នេះខ្លះ ។

[ ២២៣ ] អធិប្បាយពាក្យថា ជាបុគ្គលស្ងប់ មិនអាស្រ័យនៅ ( ដោយកិលេស ) ប្រព្រឹត្តក្នុងទីនេះឯង ត្រង់ពាក្យថា ជាបុគ្គលស្ងប់ ក្នុងទីនេះឯង គឺជាអ្នកនៅក្នុងទីនេះឯង ជាអ្នកកំពុងអង្គុយក្នុងទីនេះឯង ជាអ្នកអង្គុយលើអាសនៈនេះឯង ជាអ្នកអង្គុយក្នុងបរិស័ទនេះឯង ហេតុនោះ ( លោកពោលថា ) ជាបុគ្គលស្ងប់ក្នុងទីនេះឯង ដោយប្រការដូច្នេះខ្លះ ។ មួយទៀត ជាអ្នកមានចិត្តស្ងប់រម្ងាប់ មានចិត្តស្ងប់រម្ងាប់ មានចិត្តរលត់ មានចិត្តស្ងប់ស្ងាត់ ក្នុងទីនេះឯង ហេតុនោះ ( លោកពោលថា ) ជាអ្នកស្ងប់ ក្នុងទីនេះឯង ដោយប្រការដូច្នេះខ្លះ ។ ពាក្យថា មិនអាស្រ័យ សេចក្តីថា ការអាស្រ័យ ២ គឺការអាស្រ័យ គឺតណ្ហា ១ ការអាស្រ័យ គឺទិដ្ឋិ ១ ។បេ។ នេះ ការអាស្រ័យ គឺតណ្ហា ។បេ។ នេះ ការអាស្រ័យ គឺទិដ្ឋិ ។ បុគ្គលលះបង់នូវការអាស្រ័យ គឺតណ្ហា លះលែងនូវការអាស្រ័យ គឺទិដ្ឋិ មិនអាស្រ័យភ្នែក មិនអាស្រ័យត្រចៀក មិនអាស្រ័យច្រមុះ មិនអាស្រ័យអណ្តាត មិនអាស្រ័យកាយ មិនអាស្រ័យចិត្ត រូប សំឡេង ក្លិន រស ផោដ្ឋព្វៈ ត្រកូល ពួក អាវាស លាភ យស សេចក្តីសរសើរ សុខ ចីវរ បិណ្ឌបាត សេនាសនៈ

គិលានប្បច្ចយភេសជ្ជបរិក្ខារ កាមធាតុ រូបធាតុ អរូបធាតុ កាមភព រូបភព អរូបភព សញ្ញាភព អសញ្ញាភព នេវសញ្ញានាសញ្ញាភព ឯកវោការភព ចតុវោការភព បញ្ចវោការភព អតីត អនាគត បច្ចុប្បន្ន មិនអាស្រ័យ មិនផ្តេកផ្តិត មិនចូលទៅជិត មិនជាប់ចុះ មិនលង់ចុះ ឆាកចេញ មិនជាប់ រលាស់ចេញនូវធម៌ដែលឃើញ ឮ ប៉ះពាល់ ឬគប្បីដឹង ជាបុគ្គលមានចិត្តមិនសល់វល់ ហេតុនោះ ( លោកពោលថា ) មិនអាស្រ័យ ។ ពាក្យថា ប្រព្រឹត្ត គឺនៅត្រាច់ទៅផ្សេងៗ ទៅ ប្រព្រឹត្តទៅ រក្សា យាត្រា ឲ្យយាត្រាទៅ ហេតុនោះ ( លោកពោលថា ) ជាអ្នកស្ងប់មិនអាស្រ័យនៅ ( ដោយកិលេស ) ប្រព្រឹត្ត ក្នុងទីនេះឯង ។ ហេតុនោះ ព្រាហ្មណ៍នោះពោលថា

បពិត្រព្រះអង្គជាព្រហ្ម សូមព្រះអង្គទ្រង់ព្រះករុណា ប្រៀនប្រដៅនូវវិវេកធម៌ ឲ្យខ្ញុំព្រះអង្គដឹងច្បាស់ ដើម្បីកុំឲ្យខ្ញុំព្រះអង្គទើសទាក់ ដូចអាកាស ជាបុគ្គលស្ងប់ មិនអាស្រ័យនៅ ( ដោយកិលេស ) ប្រព្រឹត្ត ក្នុងទីនេះឯង ។

[ ២២៤ ] ( ព្រះមានព្រះភាគ ទ្រង់ត្រាស់ថា ) ម្នាលធោតកៈ បុគ្គលមានស្មារតី ដឹងច្បាស់នូវសន្តិបទណា ហើយគប្បីប្រព្រឹត្តឆ្លងនូវវិសត្តិកាតណ្ហា ក្នុងលោកបាន តថាគតនឹងសម្តែង ប្រាប់អ្នកនូវសន្តិបទនោះ ដែលតថាគតជាក់ច្បាស់ក្នុងខ្លួន ចំពោះធម៌ដែលឃើញហើយ ។

[ ២២៥ ] ពាក្យថា តថាគតនឹងសម្តែងប្រាប់អ្នកនូវសន្តិបទនោះ គឺ

តថាគតនឹងត្រាស់ ប្រាប់ សម្តែង បញ្ញត្ត តែងតាំង បើក ចែក ធ្វើឲ្យងាយ ប្រកាសនូវការស្ងប់រាគៈ ការស្ងប់ទោសៈ ការស្ងប់មោហៈ នូវការរម្ងាប់ ការស្ងប់ ការរម្ងត់ ការស្ងប់ស្ងាត់នៃក្រោធៈ ឧបនាហៈ មក្ខៈ បឡាសៈ ឥស្សា មច្ឆរិយៈ មាយា សាឋេយ្យៈ ថម្ភៈ សារម្ភៈ មានះ អតិមានះ មទៈ បមាទៈ ពួកកិលេសទាំងពួង ទុច្ចរិតទាំងពួង ការក្រវល់ក្រវាយទាំងពួង ការក្រហល់ក្រហាយទាំងពួង ការក្តៅក្រហាយទាំងពួង អកុសលាភិសង្ខារទាំងពួង ព្រោះហេតុនោះ ( ទ្រង់ត្រាស់ថា ) តថាគតនឹងសម្តែងប្រាប់អ្នក នូវសន្តិបទនោះ ។ ពាក្យថា ម្នាលធោតកៈ នៃបទថា ព្រះមានព្រះភាគ ទ្រង់ត្រាស់ថា ម្នាលធោតកៈ គឺព្រះមានព្រះភាគ ត្រាស់ហៅព្រាហ្មណ៍នោះដោយចំណោះ ។ ពាក្យថា ព្រះមានព្រះភាគនេះ ជាពាក្យពោលដោយគោរព ។បេ។ ការបញ្ញត្តិថា ព្រះមានព្រះភាគ នេះ ( កើត ) ព្រោះការធ្វើឲ្យជាក់ច្បាស់ ហេតុនោះ ( មានពាក្យថា ) ព្រះមានព្រះភាគ ទ្រង់ត្រាស់ដូច្នេះថា ម្នាលធោតកៈ ។

[ ២២៦ ] អធិប្បាយពាក្យថា ដែលតថាគតជាក់ច្បាស់ក្នុងខ្លួន ចំពោះធម៌ដែលឃើញហើយ ត្រង់ពាក្យថា ចំពោះធម៌ដែលឃើញហើយ គឺចំពោះធម៌ដែលឃើញ ធម៌ដែលដឹង ធម៌ដែលថ្លឹង ធម៌ដែលពិចារណា ធម៌ដែលចម្រើន ធម៌ដែលកើតប្រាកដហើយថា សង្ខារទាំងពួងមិនទៀង ។បេ។ ចំពោះធម៌ដែលឃើញ ធម៌ដែលដឹង ធម៌ដែលថ្លឹង ធម៌ដែលពិចារណា ធម៌ដែលចម្រើន ធម៌ដែលប្រាកដហើយថា ធម្មជាតណាមួយ មានការកើតឡើងជា

ធម្មតា ធម្មជាតទាំងពួងនោះ មានការលត់ទៅវិញជាធម្មតា ហេតុនោះ ( ទ្រង់ត្រាស់ថា ) ចំពោះធម៌ដែលឃើញហើយ ដោយប្រការដូច្នេះខ្លះ ។ មួយទៀត តថាគតនឹងសម្តែងនូវសេចក្តីទុក្ខ ក្នុងទុក្ខដែលឃើញហើយ សម្តែងនូវសមុទ័យ ក្នុងសមុទ័យដែលឃើញហើយ សម្តែងនូវមគ្គ ក្នុងមគ្គដែលឃើញហើយ សម្តែងនិរោធ ក្នុងនិរោធដែលឃើញហើយ ហេតុនោះ ( ទ្រង់ត្រាស់ថា ) ចំពោះធម៌ដែលឃើញហើយ ដោយប្រការដូច្នេះខ្លះ ។ មួយទៀត ( តថាគតនឹងសម្តែងធម៌ ) ដែលឃើញច្បាស់ដោយខ្លួនឯង ដែលឲ្យផលមិនរង់ចាំកាល ដែលគួរនឹងហៅថា អ្នកចូរមកមើលចុះ ដែលគួរបង្អោនចូលមក ដែលពួកវិញ្ញូជនគប្បីដឹងចំពោះខ្លួន ចំពោះធម៌ដែលតថាគតឃើញហើយ ហេតុនោះ ( ទ្រង់ត្រាស់ថា ) ចំពោះធម៌ដែលឃើញហើយ ដោយប្រការដូច្នេះខ្លះ ហេតុនោះ ( ទ្រង់ត្រាស់ថា ) ចំពោះធម៌ដែលឃើញហើយ ។

ពាក្យថា ដែលតថាគតជាក់ច្បាស់ក្នុងខ្លួន គឺតថាគតនឹងសម្តែងធម៌ដែលដឹងច្បាស់ចំពោះខ្លួនឯង ជាក់ច្បាស់ក្នុងខ្លួន មិនមែនដោយជឿស្តាប់បុគ្គលដទៃ មិនមែនជឿដោយអាងថា ឮមកដូច្នេះ មិនមែនដោយឮតៗ គ្នា មិនមែនដោយការផ្ទៀងផ្ទាត់នឹងក្បួន មិនមែនដោយហេតុនៃការត្រិះរិះ មិនមែនដោយហេតុនៃការត្រួតត្រា មិនមែនដោយការជញ្ជឹងនូវអាការ មិនមែនដោយហេតុដែលខ្លួនយល់ ខ្លួនពិនិត្យ ខ្លួនចូលចិត្តហើយ ហេតុនោះ ( ទ្រង់ត្រាស់ថា ) ដែលតថាគតជាក់ច្បាស់ក្នុងខ្លួន ចំពោះធម៌ដែលឃើញហើយ ។

[ ២២៧ ] ពាក្យថា បុគ្គលមានស្មារតី ដឹងច្បាស់នូវសន្តិបទណា

ហើយ គប្បីប្រព្រឹត្ត សេចក្តីថា បុគ្គលធ្វើឲ្យដឹង ថ្លឹង ពិចារណា ចម្រើន ធ្វើឲ្យជាក់ច្បាស់នូវធម៌ណាថា សង្ខារទាំងពួងមិនទៀង ។បេ។ ធ្វើឲ្យដឹង ថ្លឹង ពិចារណា ចម្រើន ធ្វើឲ្យប្រាកដថា ធម្មជាតណាមួយ មានការកើតឡើង ជាធម្មតា ធម្មជាតទាំងអស់នោះ មានការរលត់ទៅវិញជាធម្មតា ។ ពាក្យថា មានស្មារតី គឺមានស្មារតីដោយហេតុ ៤ គឺបុគ្គលចម្រើនកាយានុបស្សនា-សតិប្បដ្ឋានក្នុងកាយ ឈ្មោះថា អ្នកមានស្មារតី ។បេ។ បុគ្គលនោះ លោកហៅថា អ្នកមានស្មារតី ។ ពាក្យថា ប្រព្រឹត្ត គឺប្រតិបត្តិ ប្រព្រឹត្តផ្សេងៗ ទៅ ប្រព្រឹត្តទៅ រក្សា យាត្រា ឲ្យយាត្រាទៅ ហេតុនោះ ( ទ្រង់ត្រាស់ថា ) បុគ្គលមានស្មារតី គួរដឹងច្បាស់នូវសន្តិបទណាហើយ ប្រព្រឹត្ត ។

[ ២២៨ ] ពាក្យថា ឆ្លងវិសត្តិកាតណ្ហា ក្នុងលោកបាន សេចក្តីថា តណ្ហា លោកហៅថា វិសត្តិកា បានខាងតម្រេក តម្រេកខ្លាំង ។បេ។ អភិជ្ឈា លោភៈ អកុសលមូល ។ សំណួរត្រង់ពាក្យថា វិសត្តិកា ចុះតណ្ហាឈ្មោះថា វិសត្តិកា ដោយអត្ថដូចម្តេច ។បេ។ ឈ្មោះថា វិសត្តិកា ព្រោះជាធម្មជាត ផ្សាយទូទៅ ផ្សព្វផ្សាយទៅ ។ ពាក្យថា ក្នុងលោក គឺក្នុងអបាយលោក ។បេ។ ក្នុងអាយតនលោក ។ ពាក្យថា ឆ្លងវិសត្តិកាតណ្ហា ក្នុងលោកបាន មានន័យថា តណ្ហាណា ដែលផ្សាយទៅកាន់អារម្មណ៍ផ្សេងៗ ក្នុងលោក បុគ្គលមានស្មារតី គប្បីឆ្លង ឆ្លងឡើង ឆ្លងរំលង ឆ្លងកាត់ ផ្ទោះរំលង នូវតណ្ហាដែលផ្សាយទៅកាន់អារម្មណ៍ផ្សេងនោះៗ ក្នុងលោកបាន ហេតុនោះ ( ទ្រង់ត្រាស់ថា ) ឆ្លងនូវវិសត្តិកាតណ្ហា ក្នុងលោកបាន ។ ហេតុនោះ ព្រះមានព្រះភាគ

ត្រាស់ថា

ម្នាលធោតកៈ បុគ្គលមានស្មារតី ដឹងច្បាស់នូវសន្តិបទណា ហើយ គប្បីប្រព្រឹត្តឆ្លងវិសត្តិកាតណ្ហា ក្នុងលោកបាន តថាគត នឹងសម្តែងប្រាប់អ្នក នូវសន្តិបទនោះ ដែលតថាគតជាក់ច្បាស់ ក្នុងខ្លួន ចំពោះធម៌ដែលឃើញហើយ ។

[ ២២៩ ] ( ធោតកៈក្រាបទូលថា ) បពិត្រព្រះមហេសី បុគ្គល មានស្មារតី ដឹងនូវសន្តិបទណាហើយ គប្បីប្រព្រឹត្តឆ្លងនូវវិសត្តិ-កាតណ្ហា ក្នុងលោកបាន ខ្ញុំព្រះអង្គនឹងត្រេកអរចំពោះសន្តិបទ ដ៏ឧត្តមនោះ ។

[ ២៣០ ] អធិប្បាយពាក្យថា ខ្ញុំព្រះអង្គនឹងត្រេកអរចំពោះសន្តិបទនោះ ត្រង់ពាក្យថា ចំពោះសន្តិបទនោះ គឺចំពោះព្រះពុទ្ធដីកា គន្លងព្រះពុទ្ធដីកា ទេសនា អនុសន្ធិរបស់ព្រះអង្គ ។ ពាក្យថា នឹងត្រេកអរ គឺខ្ញុំព្រះអង្គនឹង ត្រេកអរ ត្រេកអរចំពោះ រីករាយ រីករាយតាម ជ្រះថ្លា ប្រាថ្នា ស្រឡាញ់ ជាប់ចិត្ត ហេតុនោះ ( លោកពោលថា ) ខ្ញុំព្រះអង្គនឹងត្រេកអរចំពោះសន្តិបទ នោះ ។ ពាក្យថា បពិត្រព្រះមហេសី ... សន្តិបទដ៏ឧត្តម ត្រង់ពាក្យថា ព្រះ មហេសី សេចក្តីថា ព្រះនាមថា មហេសី ព្រោះព្រះមានព្រះភាគ ទ្រង់រក ស្វែង ស្វះស្វែង នូវកងសីលដ៏ធំ ។ ព្រះនាមថា មហេសី ( ព្រោះព្រះ មានព្រះភាគ ស្វែងរក ) នូវកងសមាធិដ៏ធំ ។បេ។ ព្រះពុទ្ធជាទេវតា កន្លង ជាងទេវតា គង់ក្នុងទីណា ព្រះពុទ្ធជានរៈ អង់អាច គង់ក្នុងទីណា ។ ពាក្យ

ថា សន្តិបទដ៏ឧត្តម សេចក្តីថា អមតនិព្វាន លោកហៅថា សន្តិបទ បាន ខាងការរម្ងាប់សង្ខារទាំងពួង ការលះបង់ឧបធិទាំងពួង ការអស់តណ្ហា ការប្រាសចាករាគៈ ការរលត់ និព្វាន ។ ពាក្យថា ដ៏ឧត្តម គឺប្រសើរ ប្រសើរផុត ប្រសើរវិសេស ជាប្រធាន ឧត្តម ថ្លៃថ្លា ហេតុនោះ ( លោកពោលថា ) បពិត្រព្រះមហេសី ... សន្តិបទដ៏ឧត្តម ។

[ ២៣១ ] ពាក្យថា បុគ្គលមានស្មារតី ដឹងនូវសន្តិបទណាហើយ គប្បីប្រព្រឹត្ត គឺបុគ្គលធ្វើឲ្យដឹង ថ្លឹង ពិចារណា ចម្រើន ធ្វើឲ្យប្រាកដ នូវធម៌ណាថា សង្ខារទាំងពួងមិនទៀង ។បេ។ ធ្វើឲ្យដឹង ថ្លឹង ពិចារណា ចម្រើន ធ្វើឲ្យប្រាកដ នូវធម៌ណាថា ធម្មជាតណាមួយ មានការកើតឡើងជាធម្មតា ធម្មជាតទាំងអស់នោះ មានការរលត់ទៅវិញជាធម្មតា ។ ពាក្យថា មានស្មារតី គឺមានស្មារតីដោយហេតុ ៤ គឺ បុគ្គលចម្រើនកាយានុបស្សនាសតិប្បដ្ឋានក្នុងកាយ ឈ្មោះថា អ្នកមានស្មារតី ។បេ។ បុគ្គលនោះ លោកហៅថា អ្នកមានស្មារតី ។ ពាក្យថា ប្រព្រឹត្ត គឺ ប្រព្រឹត្ត ត្រាច់ទៅផ្សេងៗ ទៅ ប្រព្រឹត្តទៅ រក្សា យាត្រា ឲ្យយាត្រាទៅ ហេតុនោះ ( លោកពោលថា ) មានស្មារតី ដឹងនូវសន្តិបទណាហើយ គប្បីប្រព្រឹត្ត ។

[ ២៣២ ] អធិប្បាយពាក្យថា ឆ្លងវិសត្តិកាតណ្ហា ក្នុងលោកបាន សេចក្តីថា តណ្ហា លោកហៅថា វិសត្តិកា បានខាងតម្រេក តម្រេកខ្លាំង ។បេ។ អភិជ្ឈា លោភៈ អកុសលមូល ។ សំណួរត្រង់ពាក្យថា វិសត្តិកា ចុះតណ្ហាឈ្មោះថា វិសត្តិកា ដោយអត្ថដូចម្តេច ។បេ។ តណ្ហាឈ្មោះវិសត្តិកា ព្រោះ

ផ្សាយទៅ ផ្សព្វផ្សាយទៅ ។ ពាក្យថា ក្នុងលោក គឺក្នុងអបាយលោក ។បេ។ ក្នុងអាយតនលោក ។ ពាក្យថា ឆ្លងនូវវិសត្តិកាតណ្ហាក្នុងលោកបាន សេចក្តីថា តណ្ហាឈ្មោះវិសត្តិកាណា ក្នុងលោក បុគ្គលមានស្មារតី គប្បីឆ្លង ឆ្លងឡើង ឆ្លងរំលង ឆ្លងកាត់ ផ្លោះរំលង នូវតណ្ហាឈ្មោះវិសត្តិកានោះ ក្នុងលោកបាន ហេតុនោះ ( លោកពោលថា ) ឆ្លងនូវវិសត្តិកាតណ្ហា ក្នុងលោកបាន ។ ហេតុនោះ ព្រាហ្មណ៍នោះពោលថា

បពិត្រព្រះមហេសី បុគ្គលមានស្មារតី ដឹងនូវសន្តិបទណាហើយ គប្បីប្រព្រឹត្តឆ្លង នូវវិសត្តិកាតណ្ហា ក្នុងលោកបាន ខ្ញុំព្រះអង្គនឹងត្រេកអរចំពោះសន្តិបទ ដ៏ឧត្តមនោះ ។

[ ២៣៣ ] ( ព្រះមានព្រះភាគ ទ្រង់ត្រាស់ថា ) ម្នាលធោតកៈ បើអ្នកដឹងច្បាស់ នូវអារម្មណ៍ណាមួយ ក្នុងចំណែកខាងលើ ក្នុងចំណែកខាងក្រោម និងក្នុងចំណែកទទឹង គឺកណ្តាល លុះអ្នកបានដឹងនូវអារម្មណ៍នុ៎ះថា ជាគ្រឿងជាប់នៅក្នុងលោកយ៉ាងនេះហើយ អ្នកកុំធ្វើនូវចំណង់ ក្នុងភពតូច ភពធំឡើយ ។

[ ២៣៤ ] ពាក្យថា បើអ្នកដឹងច្បាស់នូវអារម្មណ៍ណាមួយ គឺបើអ្នកដឹងច្បាស់ យល់ច្បាស់ យល់ជាក់ ជ្រាបច្បាស់ នូវអារម្មណ៍ណាមួយ ហេតុនោះ ( ទ្រង់ត្រាស់ថា ) បើអ្នកដឹងច្បាស់នូវអារម្មណ៍ណាមួយ ។ ពាក្យថា ម្នាលធោតកៈ នៃបទថា ព្រះមានព្រះភាគត្រាស់ថា ម្នាលធោតកៈ គឺព្រះមានព្រះភាគត្រាស់ហៅព្រាហ្មណ៍នោះ ដោយចំណោះ ។ ពាក្យថា ព្រះមាន

ព្រះភាគនេះ ជាពាក្យពោលដោយគោរព ។បេ។ ការបញ្ញត្តិថា ព្រះមានព្រះភាគនេះ ( កើត ) ព្រោះការធ្វើឲ្យជាក់ច្បាស់ ហេតុនោះ ( មានពាក្យថា ) ព្រះមានព្រះភាគត្រាស់ថា ម្នាលធោតកៈ ។

[ ២៣៥ ] ពាក្យថា ខាងលើ ខាងក្រោម និងទទឹង គឺកណ្ដាល សេចក្ដីថា អនាគត លោកហៅថា ខាងលើ អតីត លោកហៅថា ខាងក្រោម បច្ចុប្បន្ន លោកហៅថា ទទឹង គឺកណ្ដាល ។ មួយទៀត សុខវេទនា លោកហៅថា ខាងលើ ទុក្ខវេទនា លោកហៅថា ខាងក្រោម អទុក្ខមសុខវេទនា លោកហៅថា ទទឹង គឺកណ្ដាល ។ ពួកកុសលធម៌ លោកហៅថា ខាងលើ ពួកអកុសលធម៌ លោកហៅថា ខាងក្រោម ពួកធម៌អព្យាក្រឹត លោកហៅថា ទទឹង គឺកណ្ដាល ។ ទេវលោក លោកហៅថា ខាងលើ អបាយលោកលោកហៅថា ខាងក្រោម មនុស្សលោក លោកហៅថា ទទឹង គឺកណ្ដាល ។ អរូបធាតុ លោកហៅថា ខាងលើ កាមធាតុ លោកហៅថា ខាងក្រោម រូបធាតុ លោកហៅថា ទទឹង គឺកណ្ដាល ។ តាំងអំពីផ្ទៃបាតជើងឡើងមកហៅថា ខាងលើ តាំងអំពីចុងសក់ចុះទៅ ហៅថា ខាងក្រោម ត្រង់ទីពាក់កណ្ដាលខ្លួន ហៅថា ទទឹង គឺកណ្ដាល ហេតុនោះ ( ទ្រង់ត្រាស់ថា ) ខាងលើ ខាងក្រោម ទទឹង គឺកណ្ដាល ។

[ ២៣៦ ] ពាក្យថា លុះអ្នកដឹងនូវអារម្មណ៍នុ៎ះ ថាជាគ្រឿងជាប់នៅក្នុងលោក គឺបុគ្គលដឹង យល់ ថ្លឹង ពិចារណា ចម្រើន ធ្វើឲ្យប្រាកដថា នុ៎ះការជាប់ នុ៎ះការជំពាក់ នុ៎ះចំណង នុ៎ះកង្វល់ ហេតុនោះ ( ទ្រង់ត្រាស់ថា )

លុះអ្នកបានដឹងនូវអារម្មណ៍នុ៎ះ ថាជាគ្រឿងជាប់នៅក្នុងលោក ។

[ ២៣៧ ] ពាក្យថា អ្នកកុំធ្វើនូវចំណង់ ក្នុងភពតូចភពធំឡើយ គឺចំណង់ក្នុងរូប ចំណង់ក្នុងសំឡេង ចំណង់ក្នុងក្លិន ចំណង់ក្នុងរស ចំណង់ក្នុងផ្សព្វ ចំណង់ក្នុងធម្មារម្មណ៍ ។ ពាក្យថា ក្នុងភពតូចភពធំ គឺអ្នកកុំធ្វើ កុំបង្កើត កុំបង្កើតព្រម កុំបង្កើតប្រាកដ កុំបង្កើតឡើងចំពោះ គឺថា លះបង់ បន្ទោបង់ ធ្វើឲ្យវិនាស ធ្វើមិនឲ្យមានបែបភាពតទៅ នូវចំណង់ក្នុងភពតូចភពធំ គឺកម្មភព បុនព្ភព គឺថា ក្នុងកាមភព កម្មភព ក្នុងកាមភព បុនព្ភព ក្នុងរូបភព កម្មភព ក្នុងរូបភព បុនព្ភព ក្នុងអរូបភព កម្មភព ក្នុងអរូបភព បុនព្ភព គឺក្នុងកំណើតរឿយៗ ក្នុងដំណើររឿយៗ ក្នុងការកើតរឿយៗ ក្នុងបដិសន្ធិរឿយៗ ក្នុងការបាននូវអត្តភាពរឿយៗ ហេតុនោះ ( ទ្រង់ត្រាស់ថា ) អ្នកកុំធ្វើនូវចំណង់ ក្នុងភពតូចភពធំឡើយ ។ ហេតុនោះ ព្រះមានព្រះភាគត្រាស់ថា

ម្នាលធោតកៈ បើអ្នកដឹងច្បាស់នូវអារម្មណ៍ណាមួយ ក្នុងចំណែក
ខាងលើ ក្នុងចំណែកខាងក្រោម និងក្នុងចំណែកទទឹង គឺកណ្តាល
លុះអ្នកបានដឹងនូវអារម្មណ៍នុ៎ះ ថាជាគ្រឿងជាប់នៅក្នុងលោក
យ៉ាងនេះហើយ អ្នកកុំធ្វើនូវចំណង់ ក្នុងភពតូច ភពធំឡើយ ។

លុះចប់គាថាហើយ ។បេ។ ( ធោតកៈក៏ប្រកាសខ្លួនថា ) បពិត្រព្រះអង្គដ៏ចម្រើន ព្រះមានព្រះភាគ ជាព្រះសាស្តារបស់ខ្ញុំព្រះអង្គ ខ្ញុំព្រះអង្គជាសាវ័ក ។

# អដ្ឋកថា

## ធោតកមាណវកប្បញ្ហានិទ្ទេស

គប្បីជ្រាបវិនិច្ឆ័យក្នុងធោតកសូត្រទី ៥ ដូចតទៅ

[ ១៩៩ ] បទថា **វាចាភិកង្ខាមិ** កាត់បទជា **វាចំ អភិកង្ខាមិ** ។ បទថា **សិក្ខេ និព្វានមត្តនោ** សេចក្តីថា គប្បីសិក្សាអធិសីលជាដើម ដើម្បីរម្ងត់រាគៈជាដើមរបស់ខ្លួន ។ ក្នុងនិទ្ទេស មិនមានបទដែលមិនធ្លាប់ពោល ។

[ ២០៤ ] បទថា **ឥតោ** បានដល់ អំពីមាត់របស់តថាគត ។

[ ២០៥ ] គប្បីជ្រាបសេចក្តីក្នុងនិទ្ទេសតទៅថា បទថា **អាតប្បំ** សេចក្តីថា សេចក្តីព្យាយាមដុតកិលេស ។ បទថា **ឧស្សាហំ** បានដល់ ការមិនរួញរា ។ បទថា **ឧស្សោឡ្ហី** បានដល់ ធ្វើសេចក្តីព្យាយាមមាំ ។ បទថា **ថាមំ** បានដល់ មិនធូរថយ ។ បទថា **ធិតឹ** បានដល់ ទ្រទ្រង់ ។ បទថា **វីរិយំ ករោហិ** បានដល់ ធ្វើការឈានទៅខាងមុខ ។ បទថា **ឆន្ទំ ជនេហិ** បានដល់ ឲ្យកើតនូវការពេញចិត្ត ។

[ ២០៩ ] កាលព្រះមានព្រះភាគត្រាស់យ៉ាងនេះហើយ ធោតកព្រាហ្មណ៍ពេញចិត្ត សរសើរព្រះមានព្រះភាគ កាលទូលអារាធនាដើម្បីដោះអំពីសេចក្តីសង្ស័យ ទើបទូលថា **បស្សាមហំ** ដូច្នេះជាដើម ។

ក្នុងបទទាំងនោះ បទថា **បស្សាមហំ ទេវមនុស្សលោកេ** សេចក្តីថា ខ្ញុំព្រះអង្គ ឃើញព្រះអង្គដែលជាទេវ្យ ត្រាច់ទៅក្នុងមនុស្សលោក ។ បទថា **តន្តំ នមស្សាមិ** សេចក្តីថា ខ្ញុំព្រះអង្គសូមនមស្ការព្រះអង្គនោះ ។ បទថា

**បមុញ្ច** សេចក្តីថា សូមព្រះអង្គទ្រង់ដោះ ។

[ ២១០ ] គប្បីជ្រាបវិនិច្ឆ័យក្នុងនិទ្ទេសតទៅថា បទថា **បច្ចេកសច្ចុទ្ធា** មានវិគ្គហៈថា ឈ្មោះថា **បច្ចេកសច្ចុទ្ធា** ព្រោះជាអ្នកត្រាស់ដឹងអរិយសច្ច ដោយខ្លួនឯង ដល់នូវការចាក់ធ្លុះនូវអារម្មណ៍នោះៗ ចំពោះខ្លួន ។ បទថា **សីហាសីហោ** សេចក្តីថា ព្រះមានព្រះភាគដូចសីហៈ ក្រៃលែងជាងសីហៈ ព្រោះទ្រង់មិនតក់ស្លុត ។ បទថា **នាគនាគោ** សេចក្តីថា ជានាគក្រៃលែង ជាងនាគ ព្រោះមិនមានកិលេស ឬព្រោះជាធំ ។ បទថា **គណិគណី** សេចក្តីថា ជាម្ចាស់គណៈក្រៃលែងជាងម្ចាស់គណៈទាំងឡាយ ។ បទថា **មុនិមុនី** បានដល់ មានការដឹងក្រៃលែង ជាងអ្នកដឹងទាំងឡាយ ។ បទថា **រាជរាជា** បានដល់ ជាព្រះរាជាដ៏ឧត្តម ។

[ ២១៣ ] បទថា **មុញ្ច មំ** បានដល់ សូមទ្រង់ដោះនូវខ្ញុំព្រះអង្គ ។ បទថា **បមុញ្ច មំ** បានដល់ សូមព្រះអង្គទ្រង់ដោះខ្ញុំព្រះអង្គដោយវិធីផ្សេងៗ ។ បទថា **មោចេហិ មំ** បានដល់ សូមទ្រង់ធ្វើឲ្យរួចរំលង ។ បទថា **បមោចេហិ មំ** បានដល់ សូមទ្រង់ធ្វើខ្ញុំព្រះអង្គឲ្យរួចរំលងក្រៃលែង ។ បទថា **ឧទ្ធរ មំ** បានដល់ សូមទ្រង់លើកខ្ញុំព្រះអង្គចាកភក់ គឺសង្សារ ហើយឲ្យតាំងនៅលើគោក ។ បទថា **សមុទ្ធរ មំ** បានដល់ សូមទ្រង់ទាញខ្ញុំព្រះអង្គដោយប្រពៃ ហើយឲ្យតាំងនៅលើគោក ។ បទថា **វុដ្ឋាបេហិ** បានដល់ សូមនាំខ្ញុំព្រះអង្គ ចេញពីព្រួញ គឺសេចក្តីសង្ស័យ ហើយធ្វើឲ្យនៅផ្សេងគ្នាដោយឡែក ។

[ ២១៤ ] លំដាប់នោះ ព្រះមានព្រះភាគ កាលទ្រង់សម្តែងនូវការ

ដោះចាកសេចក្តីសង្ស័យក្រៃលែង ដោយព្រះអង្គ ដោយមាតិកា គឺការធ្វេសប្រហែសឱយៈ ទើបត្រាស់គាថាថា **ឆាហំ** ដូច្នេះជាដើម ។

ក្នុងបទទាំងនោះ បទថា **ឆាហំ សមិស្សាមិ** បានដល់ តថាគតមិនអាច តថាគតមិនមានសមត្ថភាព អធិប្បាយថា តថាគតនឹងមិនព្យាយាម ។ បទថា **បមោចនាយ** បានដល់ ដើម្បីដោះ ។ បទថា **កថង្កថី** បានដល់ ដែលមានសេចក្តីសង្ស័យ ។ បទថា **តរេសិ** បានដល់ គប្បីឆ្លងបាន ។

[ ២១៥ ] គប្បីជ្រាបវិនិច្ឆ័យក្នុងនិទ្ទេសតទៅថា បទថា **ន ឦហាមិ** បានដល់ តថាគតមិនធ្វើសេចក្តីខ្វល់ខ្វាយ ។ បទថា **ន សមីហាមិ** បានដល់ មិនធ្វើសេចក្តីខ្វល់ខ្វាយក្រៃលែង ។ បទថា **អស្សទ្ធេ បុគ្គលេ** បានដល់ ជាមួយនឹងបុគ្គលដែលប្រាសចាកសទ្ធាក្នុងព្រះរតនត្រ័យ ។ បទថា **អច្ឆន្ទិកេ** បានដល់ ដែលប្រាសចាកការពេញចិត្តដើម្បីមគ្គផល ។ បទថា **កុសីតេ** បានដល់ ជាអ្នកប្រាសចាកសមាធិ ។ បទថា **ហីនវីរិយេ** បានដល់ ជាអ្នកមិនមានសេចក្តីព្យាយាម ។ បទថា **អប្បដិបជ្ជមានេ** បានដល់ ដែលមិនបដិបត្តិតាមបទដែលគួរបដិបត្តិ ។

[ ២១៩ ] កាលព្រះមានព្រះភាគត្រាស់យ៉ាងនេះហើយ ធោតកព្រាហ្មណ៍ពេញចិត្ត កាលនឹងសរសើរព្រះមានព្រះភាគ ទូលអារាធនាសូមនូវពាក្យប្រៀនប្រដៅ ទើបពោលគាថា **អនុសាស ព្រហ្មេ** ដូច្នេះជាដើម ។

ក្នុងបទទាំងនោះ បទថា **ព្រហ្មេ** នេះ ជាពាក្យសម្តែងដល់ព្រះមានព្រះភាគថាជាបុគ្គលប្រសើរ ។ ដោយហេតុនោះ ធោតកព្រាហ្មណ៍ កាលនឹង

ទូលជាមួយព្រះមានព្រះភាគ ទើបទូលថា **អនុសាស ព្រហ្មេ** ។ បទថា **វិវេកធម្មំ** បានដល់ ធម៌ គឺនិព្វានដែលស្ងាត់ចាកសង្ខារទាំងពួង ។ បទថា **អព្យាបជ្ជមានោ** បានដល់ មិនជាប់ជំពាក់ មានប្រការផ្សេងៗ ។ បទថា **ឥធេវ សន្តោ** បានដល់ មានក្នុងទីនេះ ។ បទថា **អសិតោ** បានដល់ មិនអាស្រ័យហើយ ។

[ ២២៤-២៣៣ ] គាថាបន្ទាប់អំពីនេះទៅ មានន័យដូចបានពោលហើយ ក្នុងមេត្តគូសូត្រនោះឯង ការផ្សេងគ្នាមានម្យ៉ាង គឺក្នុងមេត្តគូសូត្រនោះ ប្រើពាក្យថា **ធម្មំ** ក្នុងសូត្រនេះប្រើពាក្យថា **សន្តឹ** ។ ក្នុងគាថាទី ៣ កន្លះគាថាដំបូង មានន័យដូចពោលហើយ ក្នុងមេត្តគូសូត្រនោះឯង ។ ក្នុងកន្លះគាថាក្រោយ បទថា **សង្គោ** បានដល់ ឋានៈជាគ្រឿងជាប់ជំពាក់ អធិប្បាយថា ជាប់ហើយ ។ បទដ៏សេស ក្នុងបទទាំងពួងជាក់ច្បាស់ល្អហើយ ។

ព្រះមានព្រះភាគ ទ្រង់សំដែងព្រះសូត្រនេះ ដោយធម៌ដ៏កំពូល គឺអរហត្ត ដោយប្រការដូច្នេះ ។

ម្យ៉ាងទៀត កាលចប់ទេសនា សត្វសម្រេចធម៌ដូចគ្នាតាមដែលពោលហើយនោះឯង ។ល។

**អដ្ឋកថា ធោតកមាណវសុត្តនិទ្ទេសទី ៥ ចប់**

# សុត្តន្តបិដក

## ឧបសីវមាណវកប្បញ្ហានិទ្ទេស

[ ២៣៨ ] ( ឧបសីវៈមានអាយុ ទូលសួរដូច្នេះថា ) បពិត្រព្រះអង្គជាសក្កៈ ខ្ញុំព្រះអង្គម្នាក់ឯង មិនបានអាស្រ័យ ( បុគ្គល ឬធម៌ ) ទើបមិនអាចឆ្លងអន្លង់ដ៏ធំបាន បពិត្រព្រះអង្គ ជាសមន្តចក្ខុ សូមព្រះអង្គសម្តែងនូវអារម្មណ៍ ដែលនាំឲ្យខ្ញុំព្រះអង្គអាស្រ័យហើយ ឆ្លងនូវអន្លង់នេះបាន ។

[ ២៣៩ ] អធិប្បាយពាក្យថា បពិត្រព្រះអង្គជាសក្កៈ ខ្ញុំព្រះអង្គម្នាក់ឯង ... អន្លង់ធំបាន ត្រង់ពាក្យថា ម្នាក់ឯង គឺបុគ្គលជាគម្រប់ពីរនឹងខ្ញុំ មិនមាន ឬធម៌ជាគម្រប់ពីរនឹងខ្ញុំ មិនមាន ដែលជាបុគ្គល ឬជាធម៌ដែលខ្ញុំព្រះអង្គអាស្រ័យហើយ គប្បីឆ្លង ឆ្លងឡើង ឆ្លងរំលង ឆ្លងកាត់ ផ្លោះរំលងនូវអន្លង់ គឺកាម អន្លង់ គឺភព អន្លង់ គឺទិដ្ឋិ អន្លង់ គឺអវិជ្ជាដ៏ធំបាន ហេតុនោះ ( លោកពោលថា ) ម្នាក់ឯង ។ ពាក្យថា បពិត្រព្រះអង្គជាសក្កៈ គឺព្រះមានព្រះភាគទ្រង់ព្រះនាមថា សក្កៈ ។ ព្រះមានព្រះភាគ ទ្រង់ព្រះនាមសក្កៈ ព្រោះទ្រង់ចេញចាកសក្យត្រកូល ហើយបព្វជ្ជាក៏បាន ។ មួយទៀត ទ្រង់ព្រះនាមសក្កៈ ព្រោះទ្រង់ស្តុកស្តម្ភ មានទ្រព្យច្រើន មានទ្រព្យធនក៏បាន ។ ទ្រព្យទាំងឡាយនេះ របស់ព្រះមានព្រះភាគនោះ គឺទ្រព្យសទ្ធា ទ្រព្យសីល ទ្រព្យហិរិ ទ្រព្យឱត្តប្បៈ ទ្រព្យសុតៈ ទ្រព្យចាគៈ ទ្រព្យបញ្ញា ទ្រព្យសតិប្បដ្ឋាន ។បេ។ ទ្រព្យ គឺនិព្វាន ។ ព្រះនាមថា សក្កៈ ព្រោះទ្រង់ស្តុកស្តម្ភ មានទ្រព្យច្រើន មានទ្រព្យធន ដោយធនរតន៍ទាំងនេះ ច្រើនប្រការក៏បាន ។ ឬថា

ព្រះនាមថា សក្កៈ ព្រោះព្រះមានព្រះភាគ ទ្រង់អង់អាច អាចហ៊ាន ក្លាហាន មោះមុត ក្លៀវក្លា មានព្យាយាម ជ្ញាប់ចូលកាន់សង្គ្រាម មិនខ្លាច មិនរន្ធត់ មិនតក់ស្លុត មិនរត់ចោល លះភ័យគួរខ្លាច មិនព្រឺរោមក៏បាន ហេតុនោះ ( លោកពោលថា ) បពិត្រព្រះអង្គជាសក្កៈ ខ្ញុំព្រះអង្គម្នាក់ឯង ... អន្លង់ធំក៏បាន ។ ពាក្យថា ដូច្នេះ នៃបទថា ឧបសីវៈមានអាយុទូលសួរដូច្នេះ គឺជាពាក្យតខ្ជាប់ ។ ពាក្យថា មានអាយុ គឺពាក្យជាទីស្រឡាញ់ ។ ពាក្យថា ឧបសីវៈ គឺជានាមរបស់ព្រាហ្មណ៍នោះ ។បេ។ ជាពាក្យហៅព្រាហ្មណ៍នោះ ហេតុនោះ ( មានពាក្យថា ) ឧបសីវៈមានអាយុទូលសួរ ដូច្នេះ ។

[ ២៤០ ] ពាក្យថា ខ្ញុំព្រះអង្គមិនបានអាស្រ័យ ( បុគ្គល ឬធម៌ ) ទើបមិនអាចឆ្លង ត្រង់ពាក្យថា មិនបានអាស្រ័យ គឺមិនបានអាស្រ័យបុគ្គល ឬមិនបានអាស្រ័យធម៌ ។ ពាក្យថា មិនអាច គឺមិនអាច មិនហ៊ាន មិនប្រតិពល ។ ពាក្យថា ឆ្លង គឺរំលង ឆ្លងឡើង ឆ្លងរំលង ឆ្លងកាត់ ផ្លោះរំលងនូវអន្លង់ គឺកាម អន្លង់ គឺភព អន្លង់ គឺទិដ្ឋិ អន្លង់ គឺអវិជ្ជាដ៏ធំ ហេតុនោះ( លោកពោលថា ) ខ្ញុំព្រះអង្គមិនបានអាស្រ័យ ( បុគ្គល ឬធម៌ ) ទើបមិនអាចឆ្លង ។

[ ២៤១ ] ពាក្យថា បពិត្រព្រះអង្គ ជាសមន្តចក្ខុ សូមព្រះអង្គសម្តែងអារម្មណ៍ ត្រង់ពាក្យថា សូមព្រះអង្គសម្តែងអារម្មណ៍ គឺសូមព្រះអង្គពោលប្រាប់ បង្ហាញ បញ្ញត្ត តាំងទុក បើក បែក ធ្វើឲ្យងាយ ប្រកាស នូវសភាពគ្រែកអរ ជាទីតោង ជាទីអាស្រ័យ ជាទីពឹងផ្អែក ហេតុនោះ ( លោកពោល

ថា ) សូមព្រះអង្គសម្តែងអារម្មណ៍ ។ ពាក្យថា សមន្តចក្ខុ សេចក្តីថា សព្វញ្ញុតញ្ញាណ លោកហៅថា សមន្តចក្ខុ ។ ព្រះមានព្រះភាគ ដល់ ដល់ព្រម មកដល់ មកដល់ព្រម ចូលទៅជិត ចូលទៅជិតព្រម ប្រកប ហើយ ដោយសព្វញ្ញុតញ្ញាណនោះ ។

អ្វីមួយក្នុងលោក ដែលព្រះតថាគតនោះមិនឃើញ មិនជ្រាប ឬ
មិនគប្បីជ្រាប មិនមានទេ របស់ណាដែលគួរដឹង ព្រះតថាគត
ទ្រង់ជ្រាបរបស់ទាំងអស់នោះ ហេតុនោះ ព្រះតថាគត ទ្រង់
ព្រះនាមថា សមន្តចក្ខុ ។

ហេតុនោះ ( ទើបមានពាក្យថា ) បពិត្រព្រះអង្គ ជាសមន្តចក្ខុ សូមព្រះអង្គសម្តែងអារម្មណ៍ ។

[ ២៤២ ] ពាក្យថា ដែលនាំឲ្យខ្ញុំព្រះអង្គអាស្រ័យ ហើយគប្បីឆ្លង អន្លង់នេះបាន ត្រង់ពាក្យថា ដែលនាំឲ្យអាស្រ័យ គឺអាស្រ័យបុគ្គល ឬ អាស្រ័យធម៌ ។ ពាក្យថា គប្បីឆ្លងអន្លង់នេះបាន គឺគប្បីឆ្លង ឆ្លងរំលង ឆ្លង កាត់ ផ្ទោះរំលងនូវអន្លង់ គឺកាម អន្លង់ គឺភព អន្លង់ គឺទិដ្ឋិ អន្លង់ គឺអវិជ្ជា ដ៏ធំ ហេតុនោះ ( លោកពោលថា ) ដែលនាំឲ្យខ្ញុំព្រះអង្គអាស្រ័យ ហើយ ឆ្លងអន្លង់នេះបាន ។ ហេតុនោះ ព្រាហ្មណ៍នោះពោលថា

បពិត្រព្រះអង្គជាសក្កៈ ខ្ញុំព្រះអង្គម្នាក់ឯង មិនបានអាស្រ័យ
( បុគ្គល ឬធម៌ ) ទើបមិនអាចឆ្លងនូវអន្លង់ដ៏ធំបាន បពិត្រ
ព្រះអង្គជាសមន្តចក្ខុ សូមព្រះអង្គសម្តែងអារម្មណ៍ ដែលនាំឲ្យ

ខ្ញុំព្រះអង្គអាស្រ័យ ហើយឆ្លងអន្លង់នេះ ។

[ ២៤៣ ] ( ព្រះមានព្រះភាគត្រាស់ថា ) ម្នាលឧបសីវៈ អ្នកចូរមានស្មារតី សម្លឹងអាកិញ្ចញ្ញាយតនជ្ឈាន អាស្រ័យ ( អាកិញ្ចញ្ញាយតនសមាបត្តិ ) ដោយបរិកម្មថា មិនមានៗ ហើយឆ្លងអន្លង់ចុះ អ្នកចូរលះបង់កាមទាំងឡាយ ហើយវៀរចាកកថាទាំងឡាយចេញ ហើយសម្លឹងនូវការអស់តណ្ហា ទាំងយប់ ទាំងថ្ងៃ ។

[ ២៤៤ ] ពាក្យថា អ្នកចូរមានស្មារតី សម្លឹងអាកិញ្ចញ្ញាយតនជ្ឈាន អធិប្បាយថា ព្រាហ្មណ៍នោះ បានអាកិញ្ចញ្ញាយតនសមាបត្តិ តាមប្រក្រតី តែមិនដឹងការអាស្រ័យថា អាកិញ្ចញ្ញាយតនសមាបត្តិនេះ ជាទីអាស្រ័យរបស់អាត្មាទេ ។ ព្រះមានព្រះភាគ ទ្រង់ប្រាប់ទីអាស្រ័យផង ទ្រង់ប្រាប់ផ្លូវជាទីស្រោចស្រង់តទៅទៀតផង ដល់ព្រាហ្មណ៍នោះថា អ្នកចូលកាន់នេវសញ្ញានាសញ្ញាយតនសមាបត្តិ ហើយចេញអំពីសមាបត្តិនោះ ហើយពិចារណាធម៌ គឺចិត្ត និងចេតសិកទាំងឡាយ ដែលកើតហើយក្នុងសមាបត្តិនោះ ដោយសភាពថា មិនទៀង ពិចារណាមើល រំពឹងមើល សម្លឹងមើល រមិលមើល ដោយសភាពថាជាទុក្ខ ជារោគ ជាបូស ជាសរ ជាអន្តរាយ ជាជំងឺ ជារបស់អ្នកដទៃ ជារបស់វិនាស ជារបស់ចង្រៃ ជាឧបទ្រព ជារបស់មិនគួរប្រាថ្នា ជាភ័យ ជាឧបសគ្គ ជារបស់ញាប់ញ័រ ជារបស់ពុករលួយ ជារបស់មិនស្ថិតស្ថេរ ជារបស់ឥតទីពឹងផ្អែក ជារបស់ឥតទីពួន ជារបស់ឥតទីរឭក ជារបស់ឥតទីពំនឹង ជារបស់ឥតអំពើ ជារបស់ទទេ ជារបស់សូន្យ មិនមែនជា

របស់ខ្ជួន ជាទោស ជាសភាវៈប្រែប្រួល ជារបស់ឥតខ្លឹម ជារបស់ជាទីតាំង នៃទោស ជារបស់ប្រាសចាកសេចក្ដីចម្រើន ជារបស់ប្រកបដោយអាសវៈ ជាអ្នកសម្លាប់ ជាទីតាក់តែង ជានុយរបស់មារ មានជាតិជាធម្មតា មានជរាជាធម្មតា មានព្យាធិជាធម្មតា មានមរណៈជាធម្មតា មានសោក បរិទេវៈ ទុក្ខ ទោមនស្ស ឧបាយាសជាធម្មតា ជារបស់មានធម៌ជាគ្រឿងប្រជុំកើតជាធម្មតា ជារបស់ដល់នូវការវិនាសជាធម្មតា ជារបស់មិនមានអានិសង្ស ជារបស់មានទោស មិនជាទីរលាស់ចេញជាធម្មតា ។ ពាក្យថា មានស្មារតី សេចក្ដីថា ស្មារតី ការរឭករឿយៗ ការរឭកចំពោះ ។បេ។ ការរឭកប្រពៃណា នេះ ហៅថា ស្មារតី ។ បុគ្គលណាដល់ ដល់ព្រម ចូលទៅដល់ ចូលទៅដល់ព្រម ចូលទៅជិត ចូលទៅជិតព្រម ប្រកបហើយដោយស្មារតីនេះ បុគ្គលនោះ លោកហៅថា អ្នកមានស្មារតី ហេតុនោះ ( ទ្រង់ត្រាស់ថា ) អ្នកចូរមានស្មារតី សម្លឹងអាកិញ្ចញ្ញាយតនជ្ឈាន ។ ពាក្យថា ម្នាលឧបសីវៈ នៃបទថា ព្រះមានព្រះភាគត្រាស់ថា ម្នាលឧបសីវៈ គឺព្រះមានព្រះភាគហៅព្រាហ្មណ៍នោះដោយចំណោះ ។ ពាក្យថា ព្រះមានព្រះភាគនេះ ជាពាក្យពោលដោយគោរព ។បេ។ ការបញ្ញត្តិថា ព្រះមានព្រះភាគ នេះ ( កើត ) ព្រោះការធ្វើឲ្យជាក់ច្បាស់ ហេតុនោះ ( មានពាក្យថា ) ព្រះមានព្រះភាគត្រាស់ថា ម្នាលឧបសីវៈ ។

[ ២៤៥ ] ពាក្យថា អាស្រ័យ ( អាកិញ្ចញ្ញាយតនសមាបត្តិ ) ដោយបរិកម្មថា មិនមានៗ ហើយឆ្លងអន្លង់ចុះ បានដល់ គឺអាកិញ្ចញ្ញាយតនសមា-

បត្តិ ដោយបរិកម្មថា វត្ថុតិចតួច មិនមាន ។ ចុះអាកិញ្ចញ្ញាយតនសមាបត្តិ ដោយបរិកម្មថា វត្ថុតិចតួច មិនមាន តើព្រោះហេតុអ្វី ។ បុគ្គលមានស្មារតី ចូលវិញ្ញាណញ្ចាយតនសមាបត្តិ ចេញអំពីសមាបត្តិនោះហើយ មិនចម្រើន មិនអប់រំ ធ្វើឲ្យវិនាស នូវវិញ្ញាណនោះឯង ទើបឃើញថា វត្ថុតិចតួចមិនមាន ព្រោះហេតុនោះ អាកិញ្ចញ្ញាយតនសមបត្តិ ដោយបរិកម្មថា វត្ថុតិចតួចមិនមាន ។ អ្នកចូរអាស្រ័យ អាស្រ័យសឹប់នូវអាកិញ្ចញ្ញាយតនសមាបត្តិនោះ ហើយធ្វើឲ្យជាអារម្មណ៍ ឲ្យជាទីតោង ហើយឆ្លង ឆ្លងឡើង ឆ្លងរំលង ឆ្លងកាត់ ផ្ទោះរំលង នូវអន្លង់ គឺកាម អន្លង់ គឺភព អន្លង់ គឺទិដ្ឋិ អន្លង់ គឺអវិជ្ជា ហេតុនោះ ( ទ្រង់ត្រាស់ថា ) អាស្រ័យ ( អាកិញ្ចញ្ញាយតនសមាបត្តិ ) ដោយបរិកម្មថា មិនមានៗ ហើយឆ្លងអន្លង់ចុះ ។

[ ២៨៦ ] អធិប្បាយពាក្យថា អ្នកចូរលះបង់កាមទាំងឡាយ ហើយវៀរចាកកថាទាំងឡាយចេញ បើតាមឧទ្ទាន កាមមាន ២ គឺវត្ថុកាម ១ កិលេសកាម ១ ។បេ។ នេះ លោកហៅថា វត្ថុ ។បេ។ នេះ លោកហៅថា កិលេសវត្ថុ ។ ពាក្យថា អ្នកចូរលះបង់កាមទាំងឡាយ គឺចូរកំណត់ដឹងវត្ថុកាម ហើយលះបង់ បោះបង់ បន្ទោបង់ ធ្វើឲ្យវិនាស ធ្វើមិនឲ្យមានបែបភាពតទៅ នូវកិលេសកាមទាំងឡាយ ហេតុនោះ ( ទ្រង់ត្រាស់ថា ) អ្នកចូរលះបង់កាមទាំងឡាយ ។ ពាក្យថា វៀរចាកកថាទាំងឡាយ សេចក្តីថា វិចិកិច្ឆា លោកហៅថា កថង្កថា ។ សេចក្តីងឿងឆ្ងល់ក្នុងទុក្ខ ។បេ។ ភាពនៃចិត្តញាប់ញ័រ ការរសេមរសាមនៃចិត្ត ។ បុគ្គលវៀរ វៀរស្រឡះ លះបង់

ចេញផុត លះលែង រួចស្រឡះ ប្រាសចេញចាកសេចក្តីសង្ស័យ ជាអ្នកមានចិត្តមិនសល់រវល់ បុគ្គលវៀរចាកកថាទាំងឡាយ ដោយប្រការដូច្នេះក៏បាន ។ មួយទៀត បុគ្គលវៀរ វៀរស្រឡះ លះបង់ ចេញផុត លះលែង រួចស្រឡះ ប្រាសចេញចាកតិរច្ឆានកថា ៣២ ជាបុគ្គលមានចិត្តមិនសល់រវល់ បុគ្គលវៀរចាកកថាទាំងឡាយ ដោយប្រការដូច្នេះក៏បាន ហេតុដូច្នោះ ( ទ្រង់ត្រាស់ថា ) អ្នកចូរលះបង់កាមទាំងឡាយ ហើយវៀរចាកកថាទាំងឡាយចេញ ។

[ ២៤៧ ] អធិប្បាយពាក្យថា សម្លឹងនូវការអស់តណ្ហា ទាំងយប់ទាំងថ្ងៃ ត្រង់ពាក្យថា តណ្ហា គឺរូបតណ្ហា សទ្ទតណ្ហា គន្ធតណ្ហា រសតណ្ហា ផោដ្ឋព្វតណ្ហា ធម្មតណ្ហា ។ ពាក្យថា យប់ គឺរាត្រី ពាក្យថា ថ្ងៃ គឺវេលាដែលមានពន្លឺព្រះអាទិត្យប្រាកដ ។ អ្នកចូរមើល មើលចំពោះ ចូរឃើញ ចូររមិលមើល ចូរសម្លឹងមើល ចូរពិចារណា នូវការអស់តណ្ហា ការអស់រាគៈ ការអស់ទោសៈ ការអស់មោហៈ ការអស់គតិ នូវការអស់ឧបបត្តិ ការអស់បដិសន្ធិ ការអស់ភព ការអស់សង្សារ ការអស់វដ្តៈ ទាំងយប់ ទាំងថ្ងៃ ហេតុនោះ ( ទ្រង់ត្រាស់ថា ) សម្លឹងនូវការអស់តណ្ហា ទាំងយប់ ទាំងថ្ងៃ ។ ហេតុនោះ ព្រះមានព្រះភាគត្រាស់ថា

( ព្រះមានព្រះភាគត្រាស់ថា ម្នាលឧបសីវៈ ) អ្នកចូរមានស្មារតី

សម្លឹងអាកិញ្ចញ្ញាយតនជ្ឈាន អាស្រ័យអាកិញ្ចញ្ញាយតនសមាបត្តិ

ដោយបរិកម្មថា មិនមានៗ ហើយឆ្លងអន្លង់ចុះ អ្នកចូរលះបង់

កាមទាំងឡាយ ហើយវៀរចាកកថាទាំងឡាយចេញ ហើយ សម្ងឹងនូវការអស់តណ្ហា ទាំងយប់ ទាំងថ្ងៃ ។

[ ២៤៨ ] ( ឧបសីវមាណពមានអាយុ ទូលសួរដូច្នេះថា ) បុគ្គលណាមិនមានតម្រេក ក្នុងកាមទាំងឡាយទាំងពួង លះបង់ សមាបត្តិដទៃ អាស្រ័យអាកិញ្ចញ្ញាយតនជ្ឈាន ចុះចិត្តស៊ប់ ក្នុង សញ្ញាវិមោក្ខដ៏ប្រសើរ បុគ្គលនោះ ជាអ្នកមិនឃ្លាត គប្បីតាំង នៅក្នុងអាកិញ្ចញ្ញាយតនជ្ឈាន បានដែរឬទេ ។

[ ២៤៩ ] អធិប្បាយពាក្យថា បុគ្គលណា មិនមានតម្រេកក្នុងកាម ទាំងឡាយទាំងពួង ត្រង់ពាក្យថា ទាំងពួង គឺសព្វទាំងអស់ គ្រប់ទាំងអស់ មិនសល់ ឥតសល់ ពាក្យថា ទាំងពួង នេះ ជាពាក្យប្រមូល ។ ពាក្យថា ក្នុងកាមទាំងឡាយ បើតាមឧទ្ទាន កាមមាន ២ គឺវត្ថុកាម ១ កិលេសកាម ១ ។បេ។ នេះ ហៅថា វត្ថុកាម ។បេ។ នេះ ហៅថា កិលេសកាម ។ ពាក្យថា បុគ្គលណា មិនមានតម្រេកក្នុងកាមទាំងឡាយទាំងពួង មានន័យថា បុគ្គលណា មិនមានរាគៈ ខ្ជាក់រាគៈ ខ្ជាក់ចោលរាគៈ ផុតរាគៈ លះបង់រាគៈ លះបង់ផ្តាច់រាគៈ សន្តត់សន្តិនរាគៈ ក្នុងកាមទាំងឡាយទាំងពួង ហេតុនោះ ( លោកសួរថា ) បុគ្គលណា មិនមានតម្រេកក្នុងកាមទាំងឡាយទាំងពួង ។ ពាក្យថា ដូច្នេះ នៃបទថា ឧបសីវៈមានអាយុសួរដូច្នេះ ជាពាក្យតខ្ជាប់ ។ ពាក្យថា មានអាយុ គឺពាក្យជាទីស្រឡាញ់ ។ ពាក្យថា ឧបសីវៈ ជាឈ្មោះ នៃព្រាហ្មណ៍នោះ ។បេ។ ជាពាក្យហៅព្រាហ្មណ៍នុ៎ះ ហេតុនោះ ( មានពាក្យ

ថា ) ឧបសីវៈមានអាយុសួរដូច្នេះ ។

[ ២៥០ ] ពាក្យថា លះបង់សមាបត្តិដទៃ អាស្រ័យអាកិញ្ចញ្ញាយត-នជ្ឈាន គឺលះបង់ វៀរបង់ បោះបង់ កន្លងបង់ កន្លងរំលង ប្រព្រឹត្តកន្លងនូវសមាបត្តិទាំង ៦ ពួកខាងក្រោម ហើយអាស្រ័យ ផ្តេកផ្តិត ចូលមកជិត ចូលមកជិតព្រម មានចិត្តឱនចុះ មានចិត្តឱនចុះស៊ប់ កាន់អាកិញ្ចញ្ញាយតន-សមាបត្តិ ហេតុនោះ ( លោកសួរថា ) លះបង់សមាបត្តិដទៃ អាស្រ័យអាកិញ្ចញ្ញាយតនជ្ឈាន ។

[ ២៥១ ] ពាក្យថា ចុះចិត្តស៊ប់ ក្នុងសញ្ញាវិមោក្ខដ៏ប្រសើរ សេចក្តីថា សញ្ញាសមាបត្តិទាំង ៧ លោកហៅថា សញ្ញាវិមោក្ខ ។ អាកិញ្ចញ្ញាយត-នសមាបត្តិ ជាវិមោក្ខដ៏ប្រសើរផង វិសេសផង ប្រសើរវិសេសផង ជាប្រធានផង ឧត្តមផង ថ្លៃថ្លាផង ជាងសញ្ញាសមាបត្តិទាំងនោះ ។ បុគ្គលចុះចិត្តស៊ប់ក្នុងសញ្ញាវិមោក្ខដ៏ប្រសើរ ជាកំពូល វិសេស ប្រសើរវិសេស ជាប្រធាន ឧត្តម ថ្លៃថ្លា ដោយអធិមុត្តវិមោក្ខ ចុះចិត្តស៊ប់ក្នុងសញ្ញាវិមោក្ខនោះ មានចិត្តឱនចុះក្នុងសញ្ញាវិមោក្ខនោះ មានចិត្តជឿស៊ប់ក្នុងសញ្ញាវិមោក្ខនោះ ត្រាច់ទៅកាន់សញ្ញាវិមោក្ខនោះ ច្រើនដោយសញ្ញាវិមោក្ខនោះ ធ្ងន់ក្នុងសញ្ញា-វិមោក្ខនោះ ឱនទៅកាន់សញ្ញាវិមោក្ខនោះ ទោរទៅកាន់សញ្ញាវិមោក្ខនោះ ឈមទៅកាន់សញ្ញាវិមោក្ខនោះ មានសញ្ញាវិមោក្ខនោះជាអធិបតី ហេតុនោះ ( លោកសួរថា ) ចុះចិត្តស៊ប់ក្នុងសញ្ញាវិមោក្ខដ៏ប្រសើរ ។

[ ២៥២ ] ពាក្យថា បុគ្គលនោះ ជាអ្នកមិនឃ្លាត គប្បីតាំងនៅក្នុង

អាកិញ្ចញ្ញាយតនជ្ឈានបានដែរឬទេ ត្រង់ពាក្យថា គប្បីតាំងនៅបានដែរឬទេ គឺជាពាក្យសួរដោយសង្ស័យ សួរដោយចិត្តបែកជាចម្លាមពីរ សួរដោយការយល់ច្រើនយ៉ាងថា យ៉ាងនេះទេឬៗ មិនមែនទេ ដូចម្ដេចហ្ន៎ ដោយប្រការដូចម្ដេចហ្ន៎ ហេតុនោះ ( លោកសួរថា ) គប្បីតាំងនៅបានដែរឬទេ ។ ពាក្យថា ក្នុងនោះ គឺក្នុងអាកិញ្ចញ្ញាយតនៈ ។ ពាក្យថា ជាអ្នកមិនឃ្លាត គឺជាអ្នកមិនបែកចេញ មិនកម្រើក មិនប្រាស មិនវិនាស មិនសាបសូន្យ ។ ឬថា ជាអ្នកមិនត្រេកអរ មិនប្រទូស្ត មិនវង្វេង មិនលំបាក ហេតុនោះ ( លោកសួរថា ) បុគ្គលនោះជាអ្នកមិនឃ្លាត គប្បីតាំងនៅក្នុងអាកិញ្ចញ្ញាយតនជ្ឈានបានដែរឬទេ ។ ហេតុនោះ ព្រាហ្មណ៍នោះពោលថា

បុគ្គលណា មិនមានតម្រេកក្នុងកាមទាំងឡាយទាំងពួង លះបង់
សមាបត្តិដទៃ អាស្រ័យអាកិញ្ចញ្ញាយតនជ្ឈាន ចុះចិត្តស៊ប់ក្នុង
សញ្ញាវិមោក្ខដ៏ប្រសើរ បុគ្គលនោះ ជាអ្នកមិនឃ្លាត គប្បីតាំង
នៅក្នុងអាកិញ្ចញ្ញាយតនជ្ឈាន បានដែរឬទេ ។

[ ២៥៣ ] ( ព្រះមានព្រះភាគ ទ្រង់ត្រាស់ថា ម្នាលឧបសីវៈ )
បុគ្គលណា មិនមានតម្រេកក្នុងកាមទាំងឡាយទាំងពួង លះបង់
សមាបត្តិដទៃ អាស្រ័យអាកិញ្ចញ្ញាយតនជ្ឈាន ចុះចិត្តស៊ប់ក្នុង
សញ្ញាវិមោក្ខដ៏ប្រសើរ បុគ្គលនោះ ជាអ្នកមិនឃ្លាត គប្បី
តាំងនៅក្នុងអាកិញ្ចញ្ញាយតនជ្ឈាននោះបាន ។

[ ២៥៤ ] អធិប្បាយពាក្យថា បុគ្គលណា មិនមានតម្រេកក្នុងកាមទាំង

ឡាយទាំងពួង ត្រង់ពាក្យថា ទាំងពួង គឺគ្រប់ទាំងអស់ សព្វទាំងអស់ មិនសល់ ឥតសល់ ពាក្យថា ទាំងពួង នេះជាពាក្យរួបរួម ។ ពាក្យថា ក្នុងកាមទាំងឡាយ បើតាមឧទ្ទាន កាមមាន ២ គឺវត្ថុកាម ១ កិលេសកាម ១ ។បេ។ នេះហៅថា វត្ថុកាម ។បេ។ នេះហៅថា កិលេសកាម ។ ពាក្យថា បុគ្គលណា មិនមានតម្រេកក្នុងកាមទាំងឡាយទាំងពួង បានសេចក្ដីថា បុគ្គលណា មិនមានរាគៈ លះរាគៈ ខ្ជាក់រាគៈ លែងរាគៈ បោលរាគៈ លះបង់រាគៈ សង្កត់សង្កិនរាគៈ ក្នុងកាមទាំងឡាយទាំងពួង ហេតុនោះ ( ទ្រង់ត្រាស់ថា ) បុគ្គលណា មិនមានតម្រេកក្នុងកាមទាំងឡាយទាំងពួង ។ ពាក្យថា ម្នាលឧបសីវៈ នៃបទថា ព្រះមានព្រះភាគត្រាស់ថា ម្នាលឧបសីវៈ គឺព្រះមានព្រះភាគ ទ្រង់ហៅព្រាហ្មណ៍នោះដោយចំណោះ ។ ពាក្យថា ព្រះមានព្រះភាគនេះ ជាពាក្យពោលដោយគោរព ។បេ។ ការបញ្ញត្តិថា ព្រះមានព្រះភាគនេះ ( កើត ) ព្រោះការធ្វើឲ្យជាក់ច្បាស់ ហេតុនោះ ( មានពាក្យថា ) ព្រះមានព្រះភាគត្រាស់ថា ម្នាលឧបសីវៈ ។

[ ២៥៥ ] ពាក្យថា លះបង់សមាបត្តិដទៃ អាស្រ័យអាកិញ្ចញ្ញាយតនជ្ឈាន គឺលះបង់ វៀរបង់ បោះបង់ កន្លងបង់ កន្លងរំលង ប្រព្រឹត្តកន្លងនូវសមាបត្តិទាំង ៦ ខាងក្រោម ហើយអាស្រ័យ ផ្ដេកផ្ដិត ចូលមកជិត ចូលមកជិតព្រម ឱនចុះ ចុះស៊ប់ កាន់អាកិញ្ចញ្ញាយតនសមាបត្តិ ហេតុនោះ ( ទ្រង់ត្រាស់ថា ) លះបង់សមាបត្តិដទៃ អាស្រ័យអាកិញ្ចញ្ញាយតនជ្ឈាន ។

[ ២៥៦ ] ពាក្យថា ចុះចិត្តស៊ប់ក្នុងសញ្ញាវិមោក្ខដ៏ប្រសើរ សេចក្ដីថា

សញ្ញាសមាបត្តិទាំង ៧ ហៅថា សញ្ញាវិមោក្ខ អាកិញ្ចញ្ញាយតនសមាបត្តិ ជាវិមោក្ខដ៏ប្រសើរផង វិសេសផង ប្រសើរវិសេសផង ជាប្រធានផង ឧត្តមផង ថ្លៃថ្លាផង ជាងសញ្ញាសមាបត្តិទាំងនោះ ។ បុគ្គលចុះចិត្តស៊ប់ក្នុងសញ្ញា-វិមោក្ខដ៏ប្រសើរ ជាកំពូល វិសេស ប្រសើរ វិសេស ជាប្រធាន ឧត្តម ថ្លៃថ្លា ដោយអធិមុត្តវិមោក្ខ មានចិត្តឱនចុះក្នុងសញ្ញាវិមោក្ខនោះ ចុះចិត្តស៊ប់ក្នុងសញ្ញាវិមោក្ខនោះ ត្រាច់ទៅកាន់សញ្ញាវិមោក្ខនោះ ច្រើនដោយសញ្ញាវិមោក្ខនោះ ជួន់ក្នុងសញ្ញាវិមោក្ខនោះ ឱនទៅកាន់សញ្ញាវិមោក្ខនោះ ទោរទៅកាន់សញ្ញាវិមោក្ខនោះ ឈមទៅកាន់សញ្ញាវិមោក្ខនោះ មានសញ្ញាវិមោក្ខនោះជាអធិបតី ហេតុនោះ ( ទ្រង់ត្រាស់ថា ) ចុះចិត្តស៊ប់ក្នុងសញ្ញាវិមោក្ខដ៏ប្រសើរ ។

[ ២៥៧ ] ពាក្យថា បុគ្គលនោះ ជាអ្នកមិនឃ្លាត គប្បីតាំងនៅក្នុងអាកិញ្ចញ្ញាយតនជ្ឈាននោះបាន ត្រង់ពាក្យថា គប្បីតាំងនៅ គឺគប្បីតាំងនៅអស់ពាន់នៃកប្ប ៦០ ។ ពាក្យថា ក្នុងអាកិញ្ចញ្ញាយតនជ្ឈាននោះ គឺក្នុងអាកិញ្ចញ្ញាយតនៈ ។ ពាក្យថា ជាអ្នកមិនឃ្លាត គឺជាអ្នកមិនបោះបង់ មិនកម្រើក មិនទៅប្រាស មិនវិនាស មិនសាបសូន្យ ។ ឬថា មិនត្រេកអរ មិនប្រទូស្ត មិនវង្វេង មិនលំបាក ហេតុនោះ ( ទ្រង់ត្រាស់ថា ) បុគ្គលនោះ ជាអ្នកមិនឃ្លាត គប្បីតាំងនៅក្នុងអាកិញ្ចញ្ញាយតនជ្ឈាននោះបាន ។ ហេតុនោះ ព្រះមានព្រះភាគត្រាស់ថា

( ព្រះមានព្រះភាគត្រាស់ថា ម្នាលឧបសីវៈ ) បុគ្គលណា
មិនមានតម្រេកក្នុងកាមទាំងឡាយទាំងពួង លះបង់សមាបត្តិដទៃ

អាស្រ័យអាកិញ្ចញ្ញាយតនជ្ឈាន ចុះចិត្តស៊ប់ក្នុងសញ្ញាវិមោក្ខ ដ៏ប្រសើរ បុគ្គលនោះ ជាអ្នកមិនឃ្លាត គប្បីតាំងនៅក្នុង អាកិញ្ចញ្ញាយតនជ្ឈាននោះបាន ។

[ ២៥៨ ] ( ឧបសីវមាណពទូលសួរថា ) បពិត្រព្រះអង្គជា សមន្តចក្ខុ បើបុគ្គលនោះ ជាអ្នកសាបសូន្យ គប្បីតាំងនៅក្នុង អាកិញ្ចញ្ញាយតនជ្ឈាននោះ សូម្បីអស់គំនរនៃឆ្នាំទាំងឡាយ បុគ្គល នោះ គប្បីជាអ្នកត្រជាក់ រួចស្រឡះ ក្នុងអាកិញ្ចញ្ញាយត-នជ្ឈាននោះឯង ចុះវិញ្ញាណរបស់បុគ្គលមានសភាពដូច្នោះ ត្រូវ កើតទៀតឬទេ ។

[ ២៥៩ ] ពាក្យថា បើបុគ្គលនោះ ជាអ្នកមិនសាបសូន្យ គប្បីតាំង នៅក្នុងអាកិញ្ចញ្ញាយតនជ្ឈាននោះ ត្រង់ពាក្យថា បើបុគ្គលនោះ គប្បីតាំង នៅ គឺប្រសិនបើបុគ្គលនោះ គប្បីតាំងនៅ អស់ពាន់នៃកប្ប ៦០ ។ ពាក្យ ថា ក្នុងនោះ គឺក្នុងអាកិញ្ចញ្ញាយតនជ្ឈាន ។ ពាក្យថា ជាអ្នកមិនសាបសូន្យ គឺជាអ្នកមិនឃ្លាត មិនកម្រើក មិនទៅប្រាស មិនវិនាស មិនសាបសូន្យ ឬ ថា ជាអ្នកមិនត្រេកអរ មិនប្រទូស្ត មិនវង្វេង មិនលំបាក ហេតុនោះ ( លោកសួរថា ) បើបុគ្គលនោះ ជាអ្នកមិនសាបសូន្យ គប្បីតាំងនៅក្នុង អាកិញ្ចញ្ញាយតនជ្ឈាននោះ ។

[ ២៦០ ] ពាក្យថា បពិត្រព្រះអង្គជាសមន្តចក្ខុ ... សូម្បីអស់គំនរនៃ ឆ្នាំទាំងឡាយ ត្រង់ពាក្យថា សូម្បីអស់គំនរនៃឆ្នាំទាំងឡាយ គឺសូម្បីអស់ពួក

នៃឆ្នាំទាំងឡាយ នៃឆ្នាំដ៏ច្រើន នៃរយឆ្នាំដ៏ច្រើន នៃពាន់ឆ្នាំដ៏ច្រើន នៃសែនឆ្នាំដ៏ច្រើន នៃរយកប្បដ៏ច្រើន នៃពាន់កប្បដ៏ច្រើន នៃសែនកប្បដ៏ច្រើន ។ ពាក្យថា បពិត្រព្រះអង្គជាសមន្តចក្ខុ សេចក្តីថា សព្វញ្ញុតញ្ញាណ ហៅថា សមន្តចក្ខុ ។បេ។ ព្រះតថាគតព្រះនាមថា សមន្តចក្ខុដោយហេតុនោះ ហេតុនោះ( លោកសួរថា ) បពិត្រព្រះអង្គជាសមន្តចក្ខុ ... សូម្បីអស់គំនរនៃឆ្នាំទាំងឡាយ ។

[ ២៦១ ] ពាក្យថា បុគ្គលនោះ គប្បីជាអ្នកត្រជាក់ រួចស្រឡះ ក្នុងអាកិញ្ចញ្ញាយតនជ្ឈាននោះឯង ចុះវិញ្ញាណរបស់បុគ្គលមានសភាពដូច្នោះត្រូវកើតទៀតឬទេ គឺព្រះឧបសីវៈ សួរនូវការទៀងទាត់ផង ការដាច់សូន្យផង របស់បុគ្គលដែលកើតហើយ ក្នុងអាកិញ្ចញ្ញាយតនៈថា បុគ្គលនោះដល់នូវភាពជាអ្នកត្រជាក់ក្នុងអាកិញ្ចញ្ញៈនោះឯង ជាបុគ្គលទៀង ស្ថិតស្ថេរមិនប្រែប្រួលជាធម្មតា គប្បីតាំងនៅក្នុងអាកិញ្ចញ្ញៈនោះឯង ស្មើដោយសស្សតិវត្ថុ ឬថា វិញ្ញាណរបស់បុគ្គលនោះ គប្បីឃ្លាត ដាច់សូន្យ វិនាសមិនគប្បីកើត គឺបដិសន្ធិវិញ្ញាណ មិនគប្បីកើតក្នុងកាមធាតុក្តី ក្នុងរូបធាតុក្តី ក្នុងអរូបធាតុក្តី មួយទៀត លោកសួរនូវបរិនិព្វានផង បដិសន្ធិផង របស់បុគ្គលដែលកើតហើយ ក្នុងអាកិញ្ចញ្ញាយតនៈថា ( បុគ្គលនោះ ) គប្បីបរិនិព្វានដោយអនុបាទិសេសនិព្វានធាតុ ក្នុងអាកិញ្ចញ្ញាយតនៈនោះឯង ឬថា វិញ្ញាណរបស់បុគ្គលនោះ គប្បីឃ្លាត គឺបដិសន្ធិវិញ្ញាណ គប្បីកើតទៀតក្នុងកាមធាតុក្តី ក្នុងរូបធាតុក្តី ក្នុងអរូបធាតុក្តី ។ ពាក្យថា របស់បុគ្គលមានសភាពដូច្នោះ

គឺរបស់បុគ្គលមានសភាពបែបនោះ ប្រហែលដូច្នោះ ទ្រង់ទ្រាយដូច្នោះ មាន ប្រការដូច្នោះ មានចំណែកប្រៀបដូច្នោះ កើតហើយក្នុងអាកិញ្ចញ្ញាយតនៈ ហេតុនោះ ( លោកសួរថា ) បុគ្គលនោះ គប្បីជាអ្នកត្រជាក់ រួចស្រឡះក្នុង អាកិញ្ចញ្ញាយតនជ្ឈាននោះឯង ចុះវិញ្ញាណរបស់បុគ្គលមានសភាពដូច្នោះ គប្បីកើតទៀតឬទេ ។ ហេតុនោះ ព្រាហ្មណ៍នោះពោលថា

បពិត្រព្រះអង្គជាសមន្តចក្ខុ បើបុគ្គលនោះ ជាអ្នកមិនសាបសូន្យ គប្បីតាំងនៅក្នុងអាកិញ្ចញ្ញាយតនជ្ឈាននោះ សូម្បីអស់គំនរនៃឆ្នាំ ទាំងឡាយ បុគ្គលនោះ គប្បីជាអ្នកត្រជាក់ រួចស្រឡះ ក្នុង អាកិញ្ចញ្ញាយតនជ្ឈាននោះឯង ចុះវិញ្ញាណរបស់បុគ្គលមាន សភាពដូច្នោះ ត្រូវកើតទៀតឬទេ ។

[ ២៦២ ] ( ព្រះមានព្រះភាគទ្រង់ត្រាស់ថា ម្នាលឧបសីវៈ ) អណ្តាតភ្លើង ដែលត្រូវកម្លាំងខ្យល់ផាត់ហើយ រមែងដល់នូវការ រលត់ មិនដល់នូវការរាប់ ( ថា ទៅក្នុងទីណា ) យ៉ាងណា មុនិរួចស្រឡះហើយចាកនាមកាយ រមែងដល់នូវការរលត់ មិន ដល់នូវការរាប់ ( ថា ទៅក្នុងទីណា ) ក៏យ៉ាងនោះដែរ ។

[ ២៦៣ ] ពាក្យថា អណ្តាតភ្លើង ដែលត្រូវកម្លាំងខ្យល់ផាត់ហើយ យ៉ាងណា សេចក្តីថា អណ្តាតនៃភ្លើង លោកហៅថា អណ្តាតភ្លើង ។ ពាក្យ ថា ខ្យល់ គឺខ្យល់ទិសខាងកើត ខ្យល់ទិសខាងលិច ខ្យល់ទិសខាងជើង ខ្យល់ទិសខាងត្បូង ខ្យល់មានធូលី ខ្យល់មិនមានធូលី ខ្យល់ត្រជាក់ ខ្យល់

ក្តៅ ខ្យល់ខ្លាំងក្លា ខ្យល់កំបុតត្បូង ខ្យល់អំពីស្លាបសត្វ ខ្យល់អំពីគ្រុឌ ខ្យល់អំពីស្លឹកត្នោត ខ្យល់កើតអំពីការបក់ ។ ពាក្យថា ដែលត្រូវកម្លាំងខ្យល់ផាត់ហើយ គឺកម្លាំងខ្យល់ផាត់ហើយ ផាត់ឡើងហើយ បន្ទោបង់ហើយ បន្ទោបង់ចោលហើយ ញាំញីហើយ សង្កត់សង្កិនហើយ ហេតុនោះ (ទ្រង់ត្រាស់ថា ) អណ្តាតភ្លើង ដែលត្រូវកម្លាំងខ្យល់ផាត់ហើយ យ៉ាងណា ។ ត្រង់ពាក្យថា ម្នាលឧបសីវៈ នៃបទថា ព្រះមានព្រះភាគត្រាស់ថា ម្នាលឧបសីវៈ គឺព្រះមានព្រះភាគ ត្រាស់ហៅព្រាហ្មណ៍នោះដោយចំណោះ ។ ពាក្យថា ព្រះមានព្រះភាគនេះ ជាពាក្យពោលដោយគោរព ។បេ។ ការបញ្ញត្តិថា ព្រះមានព្រះភាគនេះ ( កើត ) ព្រោះការធ្វើឲ្យជាក់ច្បាស់ ហេតុនោះ ( ទើបមានពាក្យថា ) ព្រះមានព្រះភាគត្រាស់ថា ម្នាលឧបសីវៈ ។

[ ២៦៤ ] ពាក្យថា ដល់នូវការរលត់ មិនដល់នូវការរាប់ ត្រង់ពាក្យថា ដល់នូវការរលត់ គឺដល់នូវការបាត់ ទៅបាត់ ដល់នូវការបាត់ រលត់រម្ងាប់ ស្ងប់រម្ងាប់ ។ ពាក្យថា មិនដល់នូវការរាប់ គឺមិនដល់នូវការពោល មិនដល់នូវការសម្តែងឡើង មិនដល់នូវការគណនា មិនដល់នូវការបញ្ញត្តិថា ( ភ្លើងនោះ ) ទៅកាន់ទិសឯណោះ ហេតុនោះ ( ទ្រង់ត្រាស់ថា ) ដល់នូវការរលត់ មិនដល់នូវការរាប់ ។

[ ២៦៥ ] ពាក្យថា មុនិរួចស្រឡះហើយ ចាកនាមកាយ ក៏យ៉ាងនោះដែរ ត្រង់ពាក្យយ៉ាងនោះ គឺជាពាក្យញុំាងសេចក្តីឧបមាឲ្យសម្រេច ។ ពាក្យថា មុនិ សេចក្តីថា ញាណ លោកហៅថា មោនៈ ។បេ។ មុនិនោះ ប្រព្រឹត្ត

កន្លងនូវបណ្តាញនៃសេចក្តីជាប់ជំពាក់ ។ ពាក្យថា រួចស្រឡះហើយ ចាកនាមកាយ គឺមុនិនោះ រួចស្រឡះហើយ ចាកនាមកាយ ក្នុងកាលមុនដោយប្រក្រតីផង រួចស្រឡះហើយ ចាករូបកាយផង លះបង់ហើយដោយវិក្ខម្ភនប្បហាន ព្រោះប្រព្រឹត្តកន្លងនូវតទង្គប្បហាន អរិយមគ្គទាំង ៤ មុនិនោះអាស្រ័យនូវភពទីបំផុតបានហើយ ឯនាមកាយ និងរូបកាយ លោកកំណត់ដឹងហើយ ព្រោះបាននូវអរិយមគ្គទាំង ៤ លោករួចហើយ រួចស្រឡះហើយ ចាកនាមកាយ និងរូបកាយ ព្រោះកំណត់ដឹងនាមកាយ និងរូបកាយ ដោយអច្ចន្តវិមោក្ខ ហេតុនោះ ( ទ្រង់ត្រាស់ថា ) មុនិរួចស្រឡះហើយ ចាកនាមកាយ ក៏យ៉ាងនេះដែរ ។

[ ២៦៦ ] ពាក្យថា ដល់នូវការរលត់ មិនដល់ការរាប់ ត្រង់ពាក្យថា ដល់នូវការរលត់ គឺមុនិបរិនិព្វាន ដោយអនុបាទិសេសនិព្វានធាតុ បរិនិព្វានហើយ ដោយអនុបាទិសេសនិព្វានធាតុ ។ ពាក្យថា មិនដល់នូវការរាប់ គឺមិនដល់នូវការពោល មិនដល់នូវការសម្តែងឡើង មិនដល់នូវការគណនា មិនដល់នូវការបញ្ញត្តិថា ថាក្សត្រិយ៍ក្តី ថាព្រាហ្មណ៍ក្តី ថាវេស្សៈក្តី ថាសុទ្ទៈក្តី ថាគ្រហស្ថក្តី ថាបព្វជិតក្តី ថាទេវតាក្តី ថាមនុស្សក្តី ថាមានរូបក្តី ថាឥតរូបក្តី ថាមានសញ្ញាក្តី ថាឥតសញ្ញាក្តី ថាមានសញ្ញាក៏មិនមែន មិនមានសញ្ញាក៏មិនមែនក្តី មុនិគប្បីដល់នូវការរាប់ ដោយហេតុណា ហេតុនោះមិនមាន បច្ច័យមិនមាន សមុដ្ឋានមិនមាន ហេតុនោះ ( ទ្រង់ត្រាស់ថា ) ដល់នូវការរលត់ មិនដល់នូវការរាប់ ។ ហេតុនោះ ព្រះមានព្រះភាគត្រាស់ថា

( ព្រះមានព្រះភាគត្រាស់ថា ម្នាលឧបសីវៈ ) អណ្តាតភ្លើង ដែលត្រូវកម្លាំងខ្យល់ផាត់ហើយ រមែងដល់នូវការរលត់ មិនដល់នូវការរាប់ ( ថា ទៅក្នុងទីណា ) យ៉ាងណា មុនិរួចស្រឡះហើយ ចាកនាមកាយ រមែងដល់នូវការរលត់ មិនដល់នូវការរាប់ ( ថា ទៅក្នុងទីណា ) ក៏យ៉ាងនោះដែរ ។

[ ២៦៧ ] ( ឧបសីវមាណពក្រាបទូលថា ) បុគ្គលនោះ ដល់នូវការរលត់ ឬថា បុគ្គលនោះ លែងមាន ពុំនោះសោត បុគ្គលនោះ មិនមានរោគ ប្រៀបដោយសស្សតិវត្ថុ បពិត្រព្រះមុនិ សូមព្រះអង្គសម្តែងប្រាប់ខ្ញុំព្រះអង្គ ឲ្យជាក់ច្បាស់ នូវហេតុនោះ ដ្បិតថា ធម៌នុ៎ះ ព្រះអង្គជ្រាបហើយ ។

[ ២៦៨ ] ពាក្យថា បុគ្គលនោះ ដល់នូវការរលត់ ឬថា បុគ្គលនោះ លែងមាន គឺបុគ្គលនោះ ដល់នូវការបាត់ ឬថា បុគ្គលនោះ មិនមាន គឺថា បុគ្គលនោះរលត់ ដាច់សូន្យ វិនាសហើយ ហេតុនោះ ( លោកសួរថា ) បុគ្គលនោះ ដល់នូវការរលត់ ឬថា បុគ្គលនោះ រមែងមាន ។

[ ២៦៩ ] ពាក្យថា ពុំនោះសោត បុគ្គលនោះ មិនមានរោគ ប្រៀបដោយសស្សតិវត្ថុ គឺ ពុំនោះសោត បុគ្គលនោះ ទៀងទាត់ ស្ថិតស្ថេរ មិនប្រែប្រួលជាធម្មតា គប្បីស្ថិតនៅក្នុងអាកិញ្ចញ្ញាយតនៈនោះឯង ស្មើដោយសស្សតិវត្ថុ ហេតុនោះ ( លោកសួរថា ) ពុំនោះសោត បុគ្គលនោះ មិនមានរោគ ប្រៀបដោយសស្សតិវត្ថុ ។

[ ២៧០ ] ពាក្យថា នោះ នៃបទថា បពិត្រព្រះមុនិ សូមព្រះអង្គសម្ដែងប្រាប់ខ្ញុំព្រះអង្គ ឲ្យជាក់ច្បាស់ នូវហេតុនោះ គឺខ្ញុំព្រះអង្គសួរនូវហេតុណា អង្វរនូវហេតុណា អារាធនានូវហេតុណា ជ្រះថ្លានូវហេតុណា ។ ពាក្យថា មុនិ សេចក្ដីថា ញាណ លោកហៅថា មោនៈ ។បេ។ មុនិនុ៎ះ ប្រព្រឹត្តកន្លងនូវបណ្ដាញ គឺសេចក្ដីជាប់ជំពាក់ ។ ពាក្យថា សូមព្រះអង្គសម្ដែងឲ្យជាក់ច្បាស់ គឺសូមព្រះអង្គប្រាប់ សម្ដែង បញ្ញត្ត តែងតាំង បើក ចែក ធ្វើឲ្យងាយ ប្រកាស ហេតុនោះ ( លោកសួរថា ) បពិត្រព្រះមុនិ សូមព្រះអង្គសម្ដែងប្រាប់ខ្ញុំព្រះអង្គឲ្យជាក់ច្បាស់នូវហេតុនោះ ។

[ ២៧១ ] ពាក្យថា ដ្បិតថា ធម៌នុ៎ះ ព្រះអង្គជ្រាបហើយ គឺព្រោះថា ធម៌នុ៎ះ ព្រះអង្គជ្រាប យល់ ថ្លឹង ពិចារណា ចម្រើន ធ្វើឲ្យប្រាកដហើយ ហេតុនោះ ( លោកសួរថា ) ដ្បិតថា ធម៌នុ៎ះ ព្រះអង្គជ្រាបហើយ ហេតុនោះ ព្រាហ្មណ៍នោះពោលថា

បុគ្គលនោះ ដល់នូវការរលត់ ឬថា បុគ្គលនោះលែងមាន ពុំនោះសោត ( បុគ្គលនោះ ) មិនមានរោគ ប្រៀបដោយសស្សតវត្ថុ បពិត្រព្រះមុនិ សូមព្រះអង្គសម្ដែងប្រាប់ខ្ញុំព្រះអង្គឲ្យជាក់ច្បាស់ នូវហេតុនោះ ដ្បិតថា ធម៌នុ៎ះ ព្រះអង្គជ្រាបហើយ ។

[ ២៧២ ] ( ព្រះមានព្រះភាគ ត្រាស់ថា ម្នាលឧបសីវៈ ) បុគ្គលដែលរលត់ហើយ ប្រមាណពុំមានទេ បុគ្គលទាំងឡាយពោលចំពោះបុគ្គលនោះ ដោយកិលេសណា កិលេសនុ៎ះ របស់

បុគ្គលនោះ មិនមានឡើយ កាលបើធម៌ទាំងពួង បុគ្គលគាស់រំលើងអស់ហើយ សូម្បីគន្លងនៃវាទៈទាំងពួង ក៏បុគ្គលនោះគាស់រម្លើងហើយដែរ ។

[ ២៧៣ ] ពាក្យថា បុគ្គលដែលរលត់ហើយ ប្រមាណពុំមានទេ សេចក្តីថា បុគ្គលដែលរលត់ហើយ គឺដែលបរិនិព្វានហើយ ដោយអនុបាទិសេសនិព្វានធាតុ ប្រមាណ គឺរូបមិនមានប្រមាណ គឺវេទនា មិនមានប្រមាណ គឺសញ្ញាមិនមានប្រមាណ គឺសង្ខារមិនមានប្រមាណ គឺវិញ្ញាណមិនមាន មិនមានសោះ ដែលមិនបាន គឺលោកលះបង់ហើយ លះបង់ផ្តាច់ហើយ រម្ងាប់ហើយ ស្ងប់រម្ងាប់ហើយ ធ្វើមិនគួរឲ្យកើតឡើងបាន ដុតដោយភ្លើង គឺញាណហើយ ហេតុនោះ ( ទ្រង់ត្រាស់ថា ) បុគ្គលដែលរលត់ហើយ ប្រមាណពុំមានទេ ។ ពាក្យថា ម្នាលឧបសីវៈ នៃបទថា ព្រះមានព្រះភាគត្រាស់ថា ម្នាលឧបសីវៈ គឺព្រះមានព្រះភាគត្រាស់ហៅព្រាហ្មណ៍នោះដោយចំណោះ ។ ពាក្យថា ព្រះមានព្រះភាគនេះ ជាពាក្យពោលដោយគោរព ។បេ។ ការបញ្ញត្តិថា ព្រះមានព្រះភាគ នេះ ( កើត ) ព្រោះការធ្វើឲ្យជាក់ច្បាស់ ហេតុនោះ ( មានពាក្យថា ) ព្រះមានព្រះភាគត្រាស់ថា ម្នាលឧបសីវៈ ។

[ ២៧៤ ] ពាក្យថា បុគ្គលទាំងឡាយ ពោលចំពោះបុគ្គលនោះ ដោយកិលេសណា កិលេសនុ៎ះ របស់បុគ្គលនោះ មិនមានឡើយ អធិប្បាយថា បុគ្គលទាំងឡាយ គប្បីពោលដោយរាគៈណា ពោលដោយទោសៈណា ពោល

ដោយមោហៈណា ពោលដោយមានៈណា ពោលដោយទិដ្ឋិណា ពោលដោយឧទ្ធច្ចៈណា ពោលដោយវិចិកិច្ឆាណា ពោលដោយអនុស័យណាថា បុគ្គលនេះ ជាអ្នកត្រេកអរ ឬជាអ្នកប្រទូស្ត ជាអ្នកវង្វេង ឬជា អ្នកជាប់ជំពាក់ ជាអ្នកស្ទាបអង្អែល ឬជាអ្នកដល់នូវការរាយមាយ ជាអ្នកដល់នូវការមិនសម្រេច ឬជាអ្នកដល់នូវកម្លាំង អភិសង្ខារទាំងនោះ បុគ្គលនោះលះបង់ហើយ ព្រោះលះបង់អភិសង្ខារទាំងឡាយហើយ ជនទាំងឡាយ គប្បីពោលដោយហេតុណា តាមគតិថា បុគ្គលនោះ ជាសត្វនរក ឬជាអ្នកយកកំណើតជាតិរច្ឆាន ជាបិត្តិវិស័យ ជាមនុស្ស ទេវតា ជារបស់មានរូប ឥតរូប មានសញ្ញា ឥតសញ្ញា ឬថា ជាសត្វមានសញ្ញាក៏មិនមែន ឥតសញ្ញាក៏មិនមែន បុគ្គលគប្បីពោល និយាយ ហៅ ដោយហេតុណា ហេតុនោះ មិនមានបច្ច័យមិនមាន សមុដ្ឋានមិនមាន ហេតុនោះ ( ទ្រង់ត្រាស់ថា ) បុគ្គលទាំងឡាយ ពោលនូវបុគ្គលនោះ ដោយកិលេសណា កិលេសទុ៎ះ របស់បុគ្គលនោះ មិនមានទេ ។

[ ២៧៥ ] ពាក្យថា កាលបើធម៌ទាំងពួង បុគ្គលនោះគាស់រម្លើងអស់ហើយ គឺកាលបើធម៌ទាំងអស់ ខន្ធទាំងអស់ អាយតនៈទាំងអស់ ធាតុទាំងអស់ គតិទាំងអស់ ឧបបត្តិទាំងអស់ បដិសន្ធិទាំងអស់ ភពទាំងអស់ សំសារទាំងអស់ វដ្តៈទាំងអស់ បុគ្គលនោះ គាស់ គាស់រម្លើង រើ រើឡើង បោចរោច បោចរោចឡើង លះបង់ ក្របែល រម្ងាប់ ឲ្យស្ងប់រម្ងាប់ ធ្វើមិនគួរឲ្យកើតឡើងបាន ដុតដោយភ្លើង គឺញាណហើយ ហេតុនោះ ( ទ្រង់ត្រាស់

ថា ) កាលបើធម៌ទាំងពួង បុគ្គលនោះ គាស់រម្លើងអស់ហើយ ។

[ ២៧៦ ] ពាក្យថា សូម្បីគន្លងនៃវាទៈទាំងពួង បុគ្គលនោះ គាស់រម្លើងអស់ហើយដែរ សេចក្តីថា កិលេស ខន្ធ និងអភិសង្ខារទាំងឡាយ លោកហៅថា គន្លងនៃវាទៈ ។ វាទៈ គន្លងនៃវាទៈ ឈ្មោះ គន្លងនៃឈ្មោះ សម្តី គន្លងនៃសម្តី បញ្ញត្ត និងគន្លងនៃបញ្ញត្តទាំងឡាយ បុគ្គលនោះគាស់រម្លើង គាស់រម្លើងឡើង រើ រើឡើង បោចរោច បោចរោចឡើង លះបង់ ក្រវែល រម្ងាប់ ឲ្យស្ងប់រម្ងាប់ ធ្វើមិនគួរឲ្យកើតឡើងបាន ដុតដោយភ្លើង គឺញាណហើយ ហេតុនោះ ( ទ្រង់ត្រាស់ថា ) សូម្បីគន្លងនៃវាទៈទាំងពួង បុគ្គលនោះគាស់រម្លើងអស់ហើយដែរ ។ ហេតុនោះ ព្រះមានព្រះភាគត្រាស់ថា

( ព្រះមានព្រះភាគត្រាស់ថា ម្នាលឧបសីវៈ ) បុគ្គលដែលរលត់ហើយ ប្រមាណពុំមានទេ បុគ្គលទាំងឡាយ ពោលចំពោះបុគ្គលនោះ ដោយកិលេសណា កិលេសនុ៎ះ របស់បុគ្គលនោះ មិនមានឡើយ កាលបើធម៌ទាំងពួង បុគ្គលនោះ គាស់រម្លើងហើយ សូម្បីគន្លងនៃវាទៈទាំងពួង ក៏បុគ្គលនោះ គាស់រម្លើងហើយដែរ ។

លុះចប់គាថាហើយ ។បេ។ ( ឧបសីវមាណពប្រកាសខ្លួន ) ថា បពិត្រព្រះអង្គដ៏ចម្រើន ព្រះមានព្រះភាគ ជាព្រះសាស្តារបស់ខ្ញុំព្រះអង្គ ខ្ញុំព្រះអង្គជាសាវ័ក ។

ឧបសីវមាណវកបញ្ហានិទ្ទេស ចប់

# អដ្ឋកថា

## ឧបសីវមាណវកប្បញ្ហានិទ្ទេស

គប្បីជ្រាបវិនិច្ឆ័យក្នុងឧបសីវមាណវសុត្តនិទ្ទេសទី ៦ តទៅ

[ ២៣៨ ] បទថា **មហន្តមោឃំ** កាត់បទជា **មហន្តំ ឱឃំ** ។ បទថា **អនិស្សិតោ** បានដល់ មិនជាប់ក្នុងបុគ្គល ឬធម៌ ។ បទថា **នោ វិសហាមិ** បានដល់ ខ្ញុំព្រះអង្គមិនអាច ។ បទថា **អារម្មណំ** បានដល់ និស្ស័យ ។ បទថា **យំ និស្សិតោ** បានដល់ អាស្រ័យធម៌ ឬបុគ្គលណា ។

[ ២៣៩ ] គប្បីជ្រាបវិនិច្ឆ័យក្នុងនិទ្ទេសតទៅ បទថា **កាមោឃំ** សេចក្តីថា គប្បីឆ្លងកាមោឃៈបានដោយអនាគាមិមគ្គ គប្បីឆ្លងភវោឃៈបានដោយអរហត្តមគ្គ គប្បីឆ្លងទិដ្ឋោឃៈបាន ដោយសោតាបត្តិមគ្គ គប្បីឆ្លងអវិជ្ជោឃៈបានដោយអរហត្តមគ្គ ។ បទថា **សក្យកុលា បព្វជិតោ** លោកពោលដោយអំណាចការសម្តែងដល់ត្រកូលខ្ពស់ របស់ព្រះមានព្រះភាគ ។

[ ២៤១ ] បទថា **អាលម្ពណំ** បានដល់ ទីតោង ។ បទថា **និស្សយំ** បានដល់ ទីអាស្រ័យ ។ បទថា **ឧបនិស្សយំ** បានដល់ ទីពឹងពំនាក់ ។

[ ២៤៣ ] ឥឡូវនេះ ព្រោះឧបសីវមាណពនោះ ជាអ្នកបាននូវអាកិញ្ចញ្ញាយតនៈ តែមិនដឹងនិស្ស័យដែលមាននោះ ព្រោះហេតុនោះ ព្រះមានព្រះភាគ កាលទ្រង់សម្តែងដល់ធម៌ដែលអាស្រ័យ និងគន្លងនៃធម៌ជាគ្រឿងនាំចេញឲ្យក្រៃលែងឡើងដល់ព្រាហ្មណ៍នោះ ទើបត្រាស់គាថាថា **អាកិញ្ចញ្ញំ** ដូច្នេះជាដើម ។

ក្នុងបទទាំងនោះ បទថា **បេក្ខមានោ** បានដល់ មានសតិសម្លឹងមើល ទាំងចូល និងចេញចាកអាកិញ្ចញ្ញាយតនសមាបត្តិនោះ ដោយអំណាចការ មិនទៀងជាដើម ។ បទថា **នត្ថីតិ និស្សាយ** សេចក្តីថា ធ្វើនូវសមាបត្តិ ដែលប្រព្រឹត្តទៅហើយនោះថា អ្វីតិចតួចមិនមាន ឲ្យជាអារម្មណ៍ ។ បទថា **តរស្សុ ឱឃំ** សេចក្តីថា ចូរឆ្លងឱឃៈ ៤ យ៉ាង តាមសមគួរនៃវិបស្សនា ដែលប្រព្រឹត្តទៅហើយចាប់តាំងអំពីនោះ ។ បទថា **កថាហិ** បានដល់ ចាក សេចក្តីសង្ស័យ ។ បទថា **តណ្ហក្ខយំ រត្តមហាភិបស្ស** សេចក្តីថា ចូរ ពិចារណាមើលនិព្វានធ្វើឲ្យជាក់ច្បាស់ អស់យប់ និងថ្ងៃចុះ ។ ដោយបទ នេះ ព្រះមានព្រះភាគត្រាស់ប្រាប់សុខវិហារធម៌ក្នុងបច្ចុប្បន្ន ដល់ព្រាហ្មណ៍ នោះ ។

[ ២៤៥ ] គប្បីជ្រាបវិនិច្ឆ័យក្នុងនិទ្ទេសតទៅ បទថា **តញ្ញេវ វិញ្ញាណំ អភាវេតិ** សេចក្តីថា ធ្វើនូវអាកាសានញ្ចាយតនៈនោះ ឲ្យជាទីប្រកាន់ស្អិត ហើយធ្វើវិញ្ញាណដែលជាមហគ្គតៈដែលប្រព្រឹត្តទៅ មិនឲ្យមាន គឺឲ្យដល់នូវ ការមិនមាន ។ បទថា **វិភាវេតិ** សេចក្តីថា ឲ្យដល់នូវការមិនមាន ដោយ ប្រការផ្សេងៗ ។ បទថា **អន្តរធាបេតិ** សេចក្តីថា ឲ្យដល់នូវការមិនឃើញ ។ បទថា **នត្ថិ កិញ្ចីតិ បស្សតិ** សេចក្តីថា រមែងឃើញថា មិនមានដោយ ហោចត្រឹមតែការបែកធ្លាយនៃវិញ្ញាណនោះ ។

[ ២៤៨ ] ឥឡូវនេះ ឧបសីវមាណពស្តាប់ហើយថា **កាមេ បហាយ** កាលពិចារណាឃើញកាមទាំងឡាយ ដែលខ្លួនលះហើយ ដោយអំណាចការ

សង្កត់សង្កិន ទើបពោលគាថាជាដើមថា **សព្វេសុ** ដូច្នេះ ។ ក្នុងបទទាំងនោះ បទថា **ហិត្វា មញ្ញំ** បានដល់ លះសមាបត្តិ ៦ ដទៃខាងក្រោមអំពីនោះ ។ បទថា **សញ្ញាវិមោក្ខេ បរមេ** បានដល់ ក្នុងសញ្ញាវិមោក្ខដ៏ឧត្តម គឺក្នុងអាកិញ្ចញ្ញាយតនសមាបត្តិ ។ បទថា **តិដ្ឋេ នុ សោ តត្ថ អនានុយាយី** ឧបសីវមាណពទូលសួរថា បុគ្គលនោះ ជាអ្នកមិនឃ្លាត គប្បីតាំងនៅក្នុងអាកិញ្ចញ្ញាយតនជ្ឈាន បានដែរឬទេ ។

[ ២៥២ ] គប្បីជ្រាបវិនិច្ឆ័យក្នុងនិទ្ទេសដូចតទៅនេះ បទថា **អវេធ-មានោ** បានដល់ មិនញាប់ញ័រ ។ បទថា **អវិគច្ឆមានោ** បានដល់ មិនដល់នូវការព្រាត់ប្រាស ។ បទថា **អនន្តរធាយមានោ** បានដល់ មិនដល់នូវការអន្តរធានទៅ ។ បទថា **អបរិហាយមានោ** បានដល់ មិនដល់នូវការវិនាសក្នុងចន្លោះ ។

[ ២៥៣-២៥៨ ] លំដាប់នោះ ព្រះមានព្រះភាគ កាលទ្រង់ឲ្យដឹងដល់ឋានៈក្នុងទីបំផុត ៦ ម៉ឺនកប្ប ទើបត្រាស់គាថាទី ៤ ដល់ឧបសីវមាណពនោះ ។ ឧបសីវមាណព កាលស្តាប់ដល់ឋានៈក្នុងសមាបត្តិនោះ របស់បុគ្គលនោះ ឥឡូវនេះ កាលនឹងទូលសួរដល់ភាពជាសស្សតទិដ្ឋិ និងឧច្ឆេទទិដ្ឋិ របស់បុគ្គលនោះ ទើបពោលគាថាជាដើមថា **តិដ្ឋេ ចេ** ដូច្នេះ ។

ក្នុងបទទាំងនោះ បទថា **បូគម្បិ វស្សានំ** សេចក្តីថា រាប់ឆ្នាំមិនតិច គឺរាប់មិនអស់ ។ បាឋៈថា **បូគម្បិ វស្សានិ** ដូច្នេះក៏មាន ។ ក្នុងបទនោះ ផ្លាស់ឆដ្ឋីវិភត្តិ ជាបឋមាវិភត្តិ ។ មួយវិញទៀត បទថា **បូគំ** គប្បីអធិប្បាយ

សេចក្តីថា មានច្រើន ។ អាចារ្យពួកខ្លះពោលថា **បុត្តានិ** ក៏មាន ។ តែបាឋៈដំបូងល្អជាងបាឋៈទាំងអស់ ។ បទថា **តត្ថេវ សោ សីតិ សិយា វិមុត្តោ** សេចក្តីថា បុគ្គលនោះផុតហើយចាកទុក្ខផ្សេងៗ ក្នុងអាកិញ្ចញ្ញាយតនៈនោះ គប្បីដល់នូវភាពជាអ្នកត្រជាក់ អធិប្បាយថា ជាបុគ្គលទៀងដែលដល់នូវព្រះនិព្វាន តាំងនៅ ។ បទថា **ចវេថ វិញ្ញាណំ តថាវិធស្ស** ឧបសីវមាណពសួរដល់ការដាច់សូន្យថា វិញ្ញាណរបស់បុគ្គលមានសភាពបែបនោះ គប្បីរលត់ដោយមិនប្រកាន់មាំឬ ។ ហើយសួរដល់បដិសន្ធិរបស់បុគ្គលនោះថា វិញ្ញាណរបស់បុគ្គលមានសភាពដូច្នោះ ត្រូវកើតទៀតឬទេ ។

[ ២៦១ ] បទថា **តស្ស វិញ្ញាណំ ចវេយ្យ** បានដល់ វិញ្ញាណរបស់បុគ្គលដែលកើតក្នុងអាកិញ្ចញ្ញាយតនៈនោះ គប្បីដល់នូវការឃ្លាតទៅ ។ បទថា **ឧច្ឆិជ្ជេយ្យ** បានដល់ គប្បីដល់នូវការដាច់សូន្យ ។ បទថា **វិនស្សេយ្យ** បានដល់ គប្បីដល់នូវសេចក្តីវិនាស ។ បទថា **ន ភវេយ្យ** បានដល់ ដល់នូវការមិនមាន ។ បទថា **ឧប្បន្នស្ស** បានដល់ របស់បុគ្គលដែលកើតហើយដោយអំណាចនៃបដិសន្ធិ ។

[ ២៦២ ] លំដាប់នោះ ព្រះមានព្រះភាគ កាលទ្រង់សម្តែងដល់ការរលត់ដោយមិនប្រកាន់មាំនៃព្រះអរិយសាវក ដែលមិនអាស្រ័យឧច្ឆេទទិដ្ឋិនិងសស្សតទិដ្ឋិដែលកើតឡើងហើយក្នុងអាកិញ្ចញ្ញាយតនសមាបត្តិនោះ ទើបត្រាស់គាថាថា **អច្ចិ យថា** ដូច្នេះជាដើម ។ ក្នុងបទទាំងនោះ បទថា **អត្ថំ បលេតិ** បានដល់ រមែងដល់នូវការរលត់ ។ បទថា **ន ឧបេតិ សង្ខំ** បាន

ដល់ មិនដល់នូវការពោលថា ទៅហើយកាន់ទិសនោះ ។ បទថា **ឯវំ មុនិ នាមកាយា វិមុត្តោ** សេចក្ដីថា ព្រះសេក្ខមុនីកើតហើយក្នុងអាកិញ្ចញ្ញា-យតនសមាបត្តិនោះ តាមប្រក្រតី ជាអ្នកផុតហើយចាករូបកាយ មកអំពីមុន ញ៉ាំងចតុត្ថមគ្គ ឲ្យកើតក្នុងអាកិញ្ចញ្ញាយតនសមាត្តិនោះហើយ សូម្បីផុតចាក នាមកាយទៀត ព្រោះកំណត់ដឹងនាមកាយ ជាព្រះខីណាស្រពឧភតោភាគ-វិមុត្តិ រមែងដល់នូវការតាំងនៅមិនបាន ពោល គឺរលត់ ព្រោះមិនប្រកាន់មាំ រមែងមិនដល់នូវការរាប់ថា ជាក្សត្រ ឬជាព្រាហ្មណ៍ជាដើម ។

[ ២៦៣ ] គប្បីជ្រាបវិនិច្ឆ័យក្នុងនិទ្ទេសតទៅដូច្នេះ បទថា **ឥត្តា** បានដល់ ផាត់ទៅ ។ បទថា **ឧក្ខិត្តា** បានដល់ ផាត់ឡើងទៅហើយ ។ បទថា **នុន្នា** បានដល់ បន្ទោបង់ហើយ ។ បទថា **បនុន្នា** បានដល់ ធ្វើឲ្យឆ្ងាយ ។ បទថា **ខម្ភិតា** បានដល់ ញ៉ាំញីហើយ ។ បទថា **វិក្ខម្ភិតា** បានដល់ មិនចូលទៅជិតទៀតហើយ ។

[ ២៦៧ ] ឥឡូវនេះ ឧបសីវមាណពកាលស្ដាប់ថា **អត្ថំ បលេតិ** កំណត់ដល់ការរលត់មិនបាន ដោយឧបាយរបស់មុនីនោះ ទើបពោលគាថាថា **អត្ថង្គតោ សោ** ដូច្នេះជាដើម ។

បទនោះ មានសេចក្ដីដូច្នេះ មុនីនោះ ជាបុគ្គលរលត់ទៅហើយ មុនីនោះ មិនមាន ឬមុនីនោះ ជាអ្នកមិនមានរោគ មានការមិនប្រែប្រួលទៅជាធម្មតា ដោយភាពជាបុគ្គលទៀង គឺស្ថិតស្ថេរ បពិត្រព្រះមុនី សូមព្រះអង្គសម្ដែងប្រាប់ខ្ញុំព្រះអង្គឲ្យជាក់ច្បាស់ ព្រោះហេតុអ្វី ដ្បិតថា ធម៌នុ៎ះ ព្រះអង្គ

ជ្រាបហើយ ។

[ ២៦៨ ] គប្បីជ្រាបវិនិច្ឆ័យក្នុងនិទ្ទេសតទៅនេះ បទថា **ឆិន្នោ** បាន ដល់ ដល់នូវការរលត់ ។ បទថា **ឧច្ឆិន្នោ** បានដល់ មានសន្តានដាច់សូន្យ ហើយ ។ បទថា **វិនដ្ឋោ** បានដល់ ដល់នូវការវិនាស ។

[ ២៧២ ] លំដាប់នោះ ព្រះមានព្រះភាគ កាលទ្រង់សម្តែងដល់ ពាក្យដែលមិនគួរពោលយ៉ាងនោះដល់ឧបសីវមាណព ទើបត្រាស់គាថាថា **អត្ថង្គតស្ស** ដូច្នេះជាដើម ។

ក្នុងបទទាំងនោះ បទថា **អត្ថង្គតស្ស** បានដល់ រលត់ ព្រោះមិន ប្រកាន់មាំ ។ បទថា **ន បមាណមត្ថិ** បានដល់ មិនមានប្រមាណក្នុងរូប ជាដើម ។ បទថា **យេន នំ វជ្ជុំ** សេចក្តីថា ជនទាំងឡាយគប្បីពោល បុគ្គលនោះដោយកិលេស មានរាគៈជាដើមណា ។ បទថា **សព្វេសុ ធម្មេសុ** បានដល់ កាលធម៌ មានខន្ធជាដើមទាំងពួង ។

[ ២៧៦ ] គប្បីជ្រាបវិនិច្ឆ័យក្នុងនិទ្ទេសតទៅនេះ បទថា **អធិវចនានិ** ច សេចក្តីថា ពាក្យដែលពោលធ្វើឲ្យក្រៃលែង ត្រឹមតែពោលថា **សិរីវឌ្ឍក ធនវឌ្ឍក** ជាដើម ឈ្មោះថា **អធិវចនា** ។ គន្លងនៃពាក្យសម្តីដែលក្រៃលែង ឈ្មោះថា **អធិវចនបថា** ។ ពាក្យសម្តីដែលពោលចំពោះ ធ្វើឲ្យមានហេតុ ផលយ៉ាងនេះថា ម្នាលភិក្ខុទាំងឡាយ ព្រោះបច្ច័យទាំងឡាយតាក់តែង ដូច្នោះ ទើបឈ្មោះថា **សង្ខារ** ដូច្នេះ ឈ្មោះថា **និរុត្តិ** ។ គន្លងនៃភាសា ទាំងឡាយ ឈ្មោះថា **និរុត្តិបថា** ។ ឈ្មោះថា **បញ្ញត្តិ** ព្រោះបញ្ញត្តឡើង

*ដោយប្រការនោះៗ យ៉ាងនេះថា* **តក្កោ** *គឺត្រិះរិះ* **វិតក្កោ** *គឺការត្រិះរិះ* **សង្កប្បោ** *គឺតម្រិះ ។ គន្លងនៃបញ្ញត្តទាំងឡាយ ឈ្មោះថា* **បញ្ញត្តិបថា ។** *បទដ៏សេសក្នុងទីទាំងពួង ជាក់ច្បាស់ហើយ ។*

*ព្រះមានព្រះភាគ ទ្រង់សម្តែងសូត្រនេះដោយធម៌ដ៏កំពូល គឺអរហត្ត ដោយប្រការដូច្នេះ ។ កាលចប់ទេសនា មានបុគ្គលសម្រេចធម៌ ដូចបាន ពោលហើយនោះឯង ។៚*

**អដ្ឋកថា ឧបសីវមាណវសុត្តនិទ្ទេសទី ៦ ចប់**

# សុត្តន្តបិដក

## ធន្ធមាណវកប្បញ្ហានិទ្ទេស

[ ២៧៧ ] ( ធន្ធៈមានអាយុទូលសួរដូច្នេះថា ) ជនទាំងឡាយ តែងពោលថា ពួកមុនិ រមែងមានក្នុងលោក ដំណើរនោះ តើយ៉ាងណា ជនទាំងឡាយ តែងហៅបុគ្គល ដែលប្រកបដោយញាណ ថាជាមុនិឬ ឬក៏ហៅបុគ្គលដែលប្រកបដោយការចិញ្ចឹមជីវិត ( ថាជាមុនិ ) ។

[ ២៧៨ ] ពាក្យថា ពួកមុនិរមែងមានក្នុងលោក ត្រង់ពាក្យថា រមែងមាន គឺរមែងមាន មានព្រម កើតមាន ។ ពាក្យថា ក្នុងលោក គឺក្នុងអបាយលោក ។បេ។ ក្នុងអាយតនលោក ។ ពាក្យថា ពួកមុនិ គឺពួកអាជីវកនិគ្រន្ថ ជដិល តាបស មានឈ្មោះថា មុនិ ហេតុនោះ ( លោកសួរថា ) ពួកមុនិរមែងមានក្នុងលោក ។ ពាក្យថា ដូច្នេះ របស់បទថា ធន្ធៈមានអាយុទូលសួរដូច្នេះ គឺជាតំណបទ ។ ពាក្យថា មានអាយុ គឺពាក្យជាទីស្រឡាញ់ ពាក្យថា ធន្ធៈ ជាឈ្មោះ ។បេ។ ជាពាក្យសម្រាប់ហៅព្រាហ្មណ៍នោះ ហេតុនោះ ( មានពាក្យថា ) ធន្ធៈមានអាយុទូលសួរដូច្នេះ ។

[ ២៧៩ ] ពាក្យថា ជនទាំងឡាយតែងពោល ដំណើរនោះ តើយ៉ាងណា ត្រង់ពាក្យថា ជនទាំងឡាយ បានដល់ក្សត្រ ព្រាហ្មណ៍ វេស្សៈ សូទ្រៈ គ្រហស្ថ បព្វជិត ទេវតា និងមនុស្ស ។ ពាក្យថា ពោល គឺសម្តែង ពណ៌នា បំភ្លឺ ថ្លែង ។ ពាក្យថា ដំណើរនោះ តើយ៉ាងណា គឺការសួរដោយសង្ស័យ សួរដោយសេចក្តីងឿងឆ្ងល់ សួរដោយការព្រែកចិត្ត សួរដោយ

ចំណែកជាអនេកថា យ៉ាងនេះឬហ្ន៎ មិនមែនទេឬហ្ន៎ ដូចម្ដេចទៅហ្ន៎ ដោយប្រការដូចម្ដេចហ្ន៎ ហេតុនោះ ( លោកសួរថា ) ជនទាំងឡាយតែងពោលដំណើរនោះ តើយ៉ាងណា ។

[ ២៨០ ] ពាក្យថា ជនទាំងឡាយ តែងហៅបុគ្គលដែលប្រកបដោយញាណ ថាជាមុនិឬ សេចក្ដីថា ជនទាំងឡាយ តែងពោល សម្ដែង ពណ៌នា បំភ្លឺ ថ្លែង នូវបុគ្គលដែលប្រកប ប្រកបព្រម ចូលទៅជិត ចូលទៅជិតព្រម ដល់ ដល់ព្រម បរិបូណ៌ដោយអដ្ឋសមាបត្តិញាណក្ដី ដោយបញ្ចអភិញ្ញាញាណក្ដី ថាជាមុនិឬ ហេតុនោះ ( លោកសួរថា ) ជនទាំងឡាយ តែងហៅបុគ្គលអ្នកប្រកបដោយញាណ ថាជាមុនិឬ ។

[ ២៨១ ] ពាក្យថា ឬក៏ហៅបុគ្គល ដែលប្រកបដោយការចិញ្ចឹមជីវិត ថាជាមុនិ សេចក្ដីថា ជនទាំងឡាយ តែងពោល សម្ដែង ពណ៌នា បំភ្លឺ ថ្លែង នូវបុគ្គលដែលប្រកប ប្រកបព្រម ចូលទៅជិត ចូលទៅជិតព្រម ដល់ ដល់ព្រម បរិបូរណ៌ដោយការប្រកបរឿយៗ នូវការចិញ្ចឹមជីវិត ដ៏សៅហ្មង ជាអំពើដែលបុគ្គលគប្បីធ្វើបានដោយកម្រលើសលុប មានប្រការផ្សេងៗ ជាអនេក ថាជាមុនិ ហេតុនោះ ( លោកសួរថា ) ឬក៏ហៅបុគ្គលប្រកបដោយការចិញ្ចឹមជីវិត ថាជាមុនិ ។ ហេតុនោះ ព្រាហ្មណ៍នោះពោលថា

( នន្ទៈមានអាយុ ទូលសួរដូច្នេះថា ) ជនទាំងឡាយ តែង
ពោលថា ពួកមុនិរមែងមានក្នុងលោក ដំណើរនោះ តើយ៉ាងណា
ជនទាំងឡាយ តែងហៅបុគ្គល ដែលប្រកបហើយដោយញាណ

ថាជាមុនិឬ ឬក៏ហៅ បុគ្គលដែលប្រកបដោយការចិញ្ចឹមជីវិតថាជាមុនិ ។

[ ២៨២ ] ( ព្រះមានព្រះភាគត្រាស់ថា ) ម្នាលនន្ទៈ ជនអ្នកឈ្លាសវៃទាំងឡាយ តែងហៅបុគ្គល ថាមុនិ ក្នុងលោកនេះ មិនមែនព្រោះការឃើញ មិនមែនព្រោះការឮ មិនមែនព្រោះញាណទេ ពួកបុគ្គលណា ធ្វើសេនាឲ្យវិនាស ជាអ្នកមិនមានទុក្ខ មិនមានសេចក្តីប្រាថ្នា ប្រព្រឹត្តនៅ តថាគតហៅពួកបុគ្គលនោះ ថាមុនិ ។

[ ២៨៣ ] ពាក្យថា មិនមែន ព្រោះការឃើញ មិនមែនព្រោះការឮ មិនមែនព្រោះញាណទេ ត្រង់ពាក្យថា មិនមែន ព្រោះការឃើញ គឺមិនមែនព្រោះស្អាតដោយការឃើញ ។ ពាក្យថា មិនមែន ព្រោះការឮ គឺមិនមែនព្រោះស្អាតដោយការស្តាប់ ។ ពាក្យថា មិនមែន ព្រោះញាណ គឺមិនមែនព្រោះអដ្ឋសមាបត្តិញ្ញាណផង មិនមែន ព្រោះមិច្ឆាញាណផង ហេតុនោះ ( ទ្រង់ត្រាស់ថា ) មិនមែនព្រោះការឃើញ មិនមែនព្រោះការឮ មិនមែនព្រោះញាណទេ ។

[ ២៨៤ ] អធិប្បាយពាក្យថា ម្នាលនន្ទៈ ជនអ្នកឈ្លាសវៃទាំងឡាយ តែងហៅបុគ្គលហៅមុនិក្នុងលោកនេះ ត្រង់ពាក្យថា អ្នកឈ្លាសវៃទាំងឡាយ បានដល់ ពួកបុគ្គលណា ជាអ្នកឈ្លាសវៃក្នុងខន្ធ អ្នកឈ្លាសវៃក្នុងធាតុ អ្នកឈ្លាសវៃក្នុងអាយតនៈ អ្នកឈ្លាសវៃក្នុងបដិច្ចសមុប្បាទ អ្នកឈ្លាសវៃក្នុង

សតិប្បដ្ឋាន អ្នកឈ្លាសវៃក្នុងសម្មប្បធាន អ្នកឈ្លាសវៃក្នុងឥទ្ធិបាទ អ្នកឈ្លាសវៃក្នុងឥន្ទ្រិយ អ្នកឈ្លាសវៃក្នុងពល អ្នកឈ្លាសវៃក្នុងពោជ្ឈង្គ អ្នកឈ្លាសវៃក្នុងមគ្គ អ្នកឈ្លាសវៃក្នុងផល អ្នកឈ្លាសវៃក្នុងនិព្វាន បុគ្គលអ្នកឈ្លាសវៃទាំងឡាយនោះ មិនពោល មិនសម្តែង មិនពណ៌នា មិនបំភ្លឺ មិនថ្លែង នូវបុគ្គលដែលប្រកប ប្រកបព្រម ចូលទៅជិត ចូលទៅជិតព្រម ដល់ ដល់ព្រម បរិបូណ៌ដោយការស្អាត ព្រោះការឃើញក្តី ដោយការស្អាតព្រោះការឮក្តី ដោយអដ្ឋសមាបត្តិញាណក្តី ដោយមិច្ឆាញាណក្តី ថាជាមុនិទេ ហេតុនោះ ( ទ្រង់ត្រាស់ថា ) ម្នាលនន្ទៈ ជនអ្នកឈ្លាសវៃទាំងឡាយ តែងហៅបុគ្គល ថាមុនិ ក្នុងលោកនេះ ។

[ ២៨៥ ] ពាក្យថា បុគ្គលណា ធ្វើសេនាឲ្យវិនាស ជាអ្នកមិនមានទុក្ខ មិនមានសេចក្តីប្រាថ្នា ប្រព្រឹត្តនៅ តថាគតហៅពួកបុគ្គលនោះ ថាមុនិ អធិប្បាយថា មារសេនា លោកហៅថា សេនា ។ កាយទុច្ចរិត ជាមារសេនា វចីទុច្ចរិត ជាមារសេនា មនោទុច្ចរិត ជាមារសេនា រាគៈ ជាមារសេនា ទោសៈ ជាមារសេនា មោហៈ ជាមារសេនា កោធៈ ឧបនាហៈ មក្ខៈ បឡាសៈ ឥស្សា មច្ឆរិយៈ មាយា សាថេយ្យៈ ថម្ភៈ សារម្ភៈ មានៈ អតិមានៈ មទៈ បមាទៈ កិលេសទាំងពួង ទុច្ចរិតទាំងពួង សេចក្តីក្រវល់ក្រវាយទាំងពួង សេចក្តីក្រហល់ក្រហាយទាំងពួង សេចក្តីអន្ទះអន្ទែងទាំងពួង អកុសលាភិសង្ខារទាំងពួង ជាមារសេនា ។ សមដូចព្រះពុទ្ធដីកានេះ ដែលព្រះមានព្រះភាគត្រាស់ថា

កាមជាសេនាទី ១ របស់អ្នក សេចក្តីមិនត្រេកអរ ហៅថា សេនាទី ២ សេចក្តីស្រេកឃ្លាន ជាសេនាទី ៣ របស់អ្នក តណ្ហា ហៅថា សេនាទី ៤ ថីនមិទ្ធៈ ជាសេនាទី ៥ របស់អ្នក សេចក្តីតក់ស្លុត ហៅថា សេនាទី ៦ វិចិកិច្ឆាជាសេនាទី ៧ របស់អ្នក សេចក្តីលុបគុណ សេចក្តីរឹងត្អឹង ជាសេនាទី ៨ របស់អ្នក លាភ សេចក្តីសរសើរ សក្ការៈ យស ដែលបាន ខុសផង បុគ្គលលើកតម្កើងខ្លួនឯងផង បង្អាប់បង្អោនអ្នកដទៃផង ម្នាលមារ នោះជាសេនារបស់អ្នក ជាកិលេស បំផ្លាញនូវបុគ្គល ចិត្តខ្មៅ ឯបុគ្គលអ្នកមិនក្លៀវក្លា រមែងមិនឈ្នះនូវកិលេសនោះទេ លុះតែបុគ្គលឈ្នះហើយ ទើបបានសុខ ។

កាលណា មារសេនាទាំងពួងផង កិលេសទាំងពួងផង បុគ្គលបាន ឈ្នះហើយ ផ្ចាញ់ហើយ បំបាត់ចោលហើយ លុបលាងចោលហើយ ក្នុង ទីកំបាំងមុខ ដោយអរិយមគ្គទាំង ៤ បុគ្គលទាំងនោះ លោកពោលថា ធ្វើ សេនាឲ្យវិនាស ។ ពាក្យថា មិនមានទុក្ខ សេចក្តីថា រាគៈ ជាទុក្ខ ទោសៈ ជាទុក្ខ មោហៈ ជាទុក្ខ កោធៈ ជាទុក្ខ ឧបនាហៈ ជាទុក្ខ ។បេ។ អកុ-សលាភិសង្ខារទាំងអស់ ជាទុក្ខ ។ ទុក្ខទាំងនោះ បុគ្គលទាំងឡាយណាបាន លះបង់ ផ្តាច់ផ្តិល រម្ងាប់ គ្របសង្កត់ ធ្វើមិនគួរឲ្យកើតឡើងបាន ដុតដោយ ភ្លើង គឺញាណហើយ បុគ្គលទាំងនោះ លោកហៅថា អ្នកមិនមានទុក្ខ ។ ពាក្យ ថា មិនមានសេចក្តីប្រាថ្នា សេចក្តីថា តណ្ហា លោកហៅថា សេចក្តីប្រាថ្នា

បានខាងតម្រេក តម្រេកដ៏មានកម្លាំង ។បេ។ អភិជ្ឈា លោភៈ អកុសល-មូល ។ សេចក្ដីប្រាថ្នា គឺតណ្ហានុ៎ះ បុគ្គលទាំងឡាយណា បានលះបង់ ផ្ដាច់ផ្ដិល រម្ងាប់ គ្របសង្កត់ ធ្វើមិនគួរឲ្យកើតឡើងបាន ដុតដោយភ្លើង គឺញាណហើយ បុគ្គលទាំងនោះ លោកហៅថា អ្នកមិនមានសេចក្ដីប្រាថ្នា ។ ពាក្យថា ពួកបុគ្គលណា ធ្វើសេនាឲ្យវិនាស មិនមានទុក្ខ មិនមានសេចក្ដីប្រាថ្នាប្រព្រឹត្តនៅ តថាគតហៅពួកបុគ្គលទាំងនោះថា មុនិ បានសេចក្ដីថា ព្រះអរហន្តខីណាស្រពទាំងឡាយណា ធ្វើសេនាឲ្យវិនាសផង មិនមានទុក្ខផង មិនមានសេចក្ដីប្រាថ្នាផង ត្រាច់ទៅ ប្រព្រឹត្តទៅ រក្សា យាត្រា ឲ្យយាត្រាទៅ តថាគតពោល ប្រាប់ សម្ដែង បញ្ញត្ត តាំងទុក បើក បែក ធ្វើឲ្យរាក់ ប្រកាសនូវព្រះអរហន្តខីណាស្រពទាំងនោះថា មុនិ ក្នុងលោក ហេតុនោះ ( ទ្រង់ត្រាស់ថា ) ពួកបុគ្គលណា ធ្វើសេនាឲ្យវិនាស មិនមានទុក្ខ មិនមានសេចក្ដីប្រាថ្នា ប្រព្រឹត្តនៅ តថាគតហៅពួកបុគ្គលទាំងនោះថា មុនិ ។ ហេតុនោះ ព្រះមានព្រះភាគត្រាស់ថា

ម្នាលនន្ទៈ ជនអ្នកឈ្លាសវៃទាំងឡាយ តែងហៅបុគ្គលថាមុនិ
ក្នុងលោកនេះ មិនមែនព្រោះការឃើញ មិនមែនព្រោះការឮ មិន
មែនព្រោះញាណទេ ពួកបុគ្គលណា ធ្វើសេនាឲ្យវិនាស ជាអ្នក
មិនមានទុក្ខ មិនមានសេចក្ដីប្រាថ្នា ប្រព្រឹត្តនៅ តថាគតហៅពួក
បុគ្គលទាំងនោះថា មុនិ ។

[ ២៨៦ ] ( នន្ទៈមានអាយុទូលសួរដូច្នេះថា ) សមណព្រាហ្មណ៍

ទាំងឡាយណាមួយនេះ ពោលថា សេចក្ដីបរិសុទ្ធព្រោះអារម្មណ៍ ដែលឃើញខ្លះ ដែលស្ដាប់ឮខ្លះ ពោលថា សេចក្ដីបរិសុទ្ធ ព្រោះសីល និងវត្តខ្លះ ពោលថា សេចក្ដីបរិសុទ្ធ ព្រោះវិធីច្រើនយ៉ាងខ្លះ ( បពិត្រព្រះមានព្រះភាគ ) អ្នកនិរទុក្ខ សមណព្រាហ្មណ៍ទាំងនោះ ជាអ្នកសង្រួម ប្រព្រឹត្តក្នុងវត្តនោះ តើបានឆ្លងផុតជាតិ និងជរាខ្លះដែរឬ បពិត្រព្រះមានព្រះភាគ ខ្ញុំព្រះអង្គសូមសួរព្រះអង្គ សូមព្រះអង្គត្រាស់ប្រាប់សេចក្ដីនោះ ដល់ខ្ញុំព្រះអង្គ ។

[ ២៨៧ ] ពាក្យថា សមណព្រាហ្មណ៍ទាំងឡាយណាមួយនេះ ត្រង់ពាក្យថា ណាមួយ គឺគ្រប់ទាំងអស់ សព្វទាំងអស់ មិនសល់ ឥតសល់ ពាក្យថា ណាមួយ នេះជាពាក្យប្រមូល ។ ពាក្យថា សមណៈទាំងឡាយ គឺបុគ្គលណាមួយ ចូលកាន់បព្វជ្ជា ខាងក្រៅអំពីសាសនានេះ បួសជាបរិព្វាជក ។ ពាក្យថា ព្រាហ្មណ៍ទាំងឡាយ គឺបុគ្គលណាមួយ ជាភោវាទី ហេតុនោះ ( លោកសួរថា ) សមណព្រាហ្មណ៍ទាំងឡាយណាមួយនេះ ។ ពាក្យថា ដូច្នេះ របស់បទថា នន្ទៈមានអាយុទូលសួរដូច្នេះ គឺជាតំណបទ ។ ពាក្យថា មានអាយុ គឺពាក្យជាទីស្រឡាញ់ ។ ពាក្យថា នន្ទៈ ជាឈ្មោះរបស់ព្រាហ្មណ៍នោះ។បេ។ ជាពាក្យសម្រាប់ហៅព្រាហ្មណ៍នោះ ហេតុនោះ ( មានពាក្យថា ) នន្ទៈមានអាយុទូលសួរដូច្នេះ ។

[ ២៨៨ ] ពាក្យថា ពោលថា សេចក្ដីបរិសុទ្ធ ព្រោះអារម្មណ៍ដែលឃើញខ្លះ ដែលស្ដាប់ឮខ្លះ គឺពោល សម្ដែង ពណ៌នា បំភ្លឺ ថ្លែង នូវការ

ស្អាត ស្អាតវិសេស បរិសុទ្ធ ការរួច រួចវិសេស រួចស្រឡះ ព្រោះអារម្មណ៍ដែលឃើញក្តី ពោល សម្តែង ពណ៌នា បំភ្លឺ ថ្លែង នូវការស្អាត ស្អាតវិសេស បរិសុទ្ធ ការរួច រួចវិសេស រួចស្រឡះ ព្រោះអារម្មណ៍ដែលឮក្តី ពោល សម្តែង ពណ៌នា បំភ្លឺ ថ្លែង នូវការស្អាត ស្អាតវិសេស បរិសុទ្ធ ការរួច រួចវិសេស រួចស្រឡះ ព្រោះអារម្មណ៍ដែលឃើញ ឬដែលឮក្តី ហេតុនោះ ( លោកសួរថា ) ពោលថា សេចក្តីបរិសុទ្ធ ព្រោះអារម្មណ៍ដែលឃើញខ្លះ ដែលស្តាប់ឮខ្លះ ។

[ ២៨៩ ] ពាក្យថា ពោលថា សេចក្តីបរិសុទ្ធ ព្រោះសីល និងវត្តខ្លះ គឺពោល សម្តែង ពណ៌នា បំភ្លឺ ថ្លែង នូវការស្អាត ស្អាតវិសេស បរិសុទ្ធ ការរួច រួចវិសេស រួចស្រឡះ ព្រោះសីលក្តី ពោល សម្តែង ពណ៌នា បំភ្លឺ ថ្លែង នូវការស្អាត ស្អាតវិសេស បរិសុទ្ធ ការរួច រួចវិសេស រួចស្រឡះ ព្រោះវត្តក្តី ពោល សម្តែង ពណ៌នា បំភ្លឺ ថ្លែង នូវការស្អាត ស្អាតវិសេស បរិសុទ្ធ ការរួច រួចវិសេស រួចស្រឡះ ព្រោះសីល និងវត្តក្តី ហេតុនោះ ( លោកសួរថា ) ពោលនូវសេចក្តីបរិសុទ្ធ ព្រោះសីល និងវត្តខ្លះ ។

[ ២៩០ ] ពាក្យថា ពោលថា សេចក្តីបរិសុទ្ធ ព្រោះវិធីច្រើនយ៉ាងខ្លះ គឺពោល សម្តែង ពណ៌នា បំភ្លឺ ថ្លែង នូវការស្អាត ស្អាតវិសេស បរិសុទ្ធ ការរួច រួចវិសេស រួចស្រឡះ ព្រោះវត្ត និងមង្គលភ្ញាក់ផ្អើល មានប្រការផ្សេងៗ ជាអនេក ហេតុនោះ ( លោកសួរថា ) ពោលនូវសេចក្តីបរិសុទ្ធ ព្រោះវិធីច្រើនយ៉ាងខ្លះ ។

[ ២៩១ ] អធិប្បាយពាក្យថា ( បពិត្រព្រះមានព្រះភាគ ) សមណព្រាហ្មណ៍ទាំងនោះ ជាអ្នកសង្រួម ប្រព្រឹត្តក្នុងវត្តនោះ ... ដែរឬ ត្រង់ពាក្យថា ដែរឬ គឺជាសំណួរដោយសេចក្តីសង្ស័យ សំណួរដោយសេចក្តីងឿងឆ្ងល់ សំណួរដោយសេចក្តីកន្ទែកចិត្ត សំណួរដោយចំណែកជាអនេកថា យ៉ាងនេះឬហ្ន៎ មិនមែនទេឬហ្ន៎ ដូចម្តេចទៅហ្ន៎ ដោយប្រការដូចម្តេចទៅហ្ន៎ ហេតុនោះ ( លោកសួរថា ) ដែរឬ ។ ពាក្យថា បុគ្គលទាំងនោះ បានដល់ ពួកបុគ្គលអ្នកលុះក្នុងទិដ្ឋិ ។ ពាក្យថា បពិត្រព្រះមានព្រះភាគ នេះជាពាក្យពោលដោយគោរព ។បេ។ ការបញ្ញត្តិថា ព្រះមានព្រះភាគ ( កើត ) ព្រោះការត្រាស់ដឹង ហេតុនោះ ( លោកសួរថា ) បពិត្រព្រះមានព្រះភាគ សមណព្រាហ្មណ៍ទាំងនោះ ... ដែរឬ ។ ពាក្យថា ជាអ្នកសង្រួម ប្រព្រឹត្តក្នុងវត្តនោះ ត្រង់ពាក្យថា ក្នុងវត្តនោះ គឺក្នុងទិដ្ឋិរបស់ខ្លួន ក្នុងសេចក្តីគួររបស់ខ្លួន ក្នុងសេចក្តីគាប់ចិត្តរបស់ខ្លួន ក្នុងលទ្ធិរបស់ខ្លួន ។ ពាក្យថា ជាអ្នកសង្រួម គឺជាអ្នកសង្រួម សង្រួមចំពោះ គ្រប់គ្រង រក្សា រវាំង ។ ពាក្យថា ប្រព្រឹត្ត គឺប្រព្រឹត្ត ប្រព្រឹត្តផ្សេងៗ ទៅ ប្រព្រឹត្តទៅ រក្សា យាត្រា ឲ្យយាត្រាទៅ ហេតុនោះ ( លោកសួរថា ) ( បពិត្រព្រះមានព្រះភាគ ) សមណព្រាហ្មណ៍ទាំងនោះ ជាអ្នកសង្រួម ប្រព្រឹត្តក្នុងវត្តនោះ ... ដែរឬ ។

[ ២៩២ ] ពាក្យថា ( បពិត្រព្រះអង្គ ) អ្នកនិទ្ទុក្ខ សមណព្រាហ្មណ៍ទាំងនោះ តើបានឆ្លងជាតិ និងជរា ( ដែរឬ ) គឺឆ្លង ឆ្លងឡើង ឆ្លងចេញ កន្លងព្រម ប្រព្រឹត្តកន្លង នូវជាតិ ជរា និងមរណៈ ។ ពាក្យថា អ្នកនិទ្ទុក្ខ គឺ

ពាក្យជាទីស្រឡាញ់ ពាក្យថា អ្នកនិទុក្ខ នេះពាក្យពោលដោយគោរព គោរពខ្លាច ហេតុនោះ ( លោកសួរថា ) បពិត្រព្រះអង្គអ្នកនិទុក្ខ សមណព្រាហ្មណ៍ទាំងនោះ តើបានឆ្លងជាតិ និងជរាដែរឬ ។

[ ២៩៣ ] ពាក្យថា ខ្ញុំសូមសួរព្រះអង្គ របស់បទថា បពិត្រព្រះមានព្រះភាគ ខ្ញុំព្រះអង្គសូមព្រះអង្គ សូមព្រះអង្គត្រាស់ប្រាប់សេចក្តីនោះ ដល់ខ្ញុំព្រះអង្គ ត្រង់ពាក្យថា ខ្ញុំព្រះអង្គសូមសួរព្រះអង្គ គឺខ្ញុំព្រះអង្គសូមសួរព្រះអង្គ សូមអង្វរព្រះអង្គ សូមអារាធនាព្រះអង្គ សូមជ្រះថ្លានឹងព្រះអង្គ សូមព្រះអង្គប្រាប់សេចក្តីនោះ ដល់ខ្ញុំព្រះអង្គឲ្យទាន ហេតុនោះ ( លោកសួរថា ) ខ្ញុំព្រះអង្គសូមសួរព្រះអង្គ ។ ពាក្យថា បពិត្រព្រះមានព្រះភាគ នេះជាពាក្យពោលដោយគោរព ។បេ។ ការបញ្ញត្តិថា ព្រះមានព្រះភាគ នេះ ( កើត ) ព្រោះការត្រាស់ដឹង ។ ពាក្យថា សូមព្រះអង្គត្រាស់ប្រាប់សេចក្តីនោះ ដល់ខ្ញុំព្រះអង្គ គឺសូមព្រះអង្គពោល ប្រាប់ សំដែង បញ្ញត្ត តាំងទុក បើក ចែក ធ្វើឲ្យងាយ ប្រកាស ហេតុនោះ ( លោកសួរថា ) បពិត្រព្រះមានព្រះភាគ ខ្ញុំព្រះអង្គសូមសួរព្រះអង្គ សូមព្រះអង្គត្រាស់ប្រាប់សេចក្តីនោះ ដល់ខ្ញុំព្រះអង្គ ។ ហេតុនោះ ព្រាហ្មណ៍នោះពោលថា

( នន្ទមាណពទូលសួរដូច្នេះថា ) សមណព្រាហ្មណ៍ទាំងឡាយណាមួយនេះ ពោលថា សេចក្តីបរិសុទ្ធ ព្រោះអារម្មណ៍ដែលឃើញខ្លះ ដែលស្តាប់ឮខ្លះ ពោលថា សេចក្តីបរិសុទ្ធ ព្រោះសីល និងវត្តខ្លះ ពោលថា សេចក្តីបរិសុទ្ធ ព្រោះវិធីច្រើន

យ៉ាងខ្លះ ( បពិត្រព្រះមានព្រះភាគ ) អ្នកនិទ្ទុក្ខ សមណ-ព្រាហ្មណ៍ទាំងនោះ ជាអ្នកសង្រួម ប្រព្រឹត្តក្នុងវត្តនោះ តើបានឆ្លងជាតិ និងជរាខ្លះដែរឬ បពិត្រព្រះមានព្រះភាគ ខ្ញុំព្រះអង្គសូមសួរព្រះអង្គ សូមព្រះអង្គត្រាស់ប្រាប់សេចក្តីនោះដល់ខ្ញុំព្រះអង្គ ។

[ ២៩៤ ] ( ព្រះមានព្រះភាគ ទ្រង់ត្រាស់ថា ម្នាលនន្ទៈ ) សមណព្រាហ្មណ៍ទាំងឡាយណាមួយនេះ ពោលថា សេចក្តីបរិសុទ្ធ ព្រោះអារម្មណ៍ដែលឃើញខ្លះ ដែលស្តាប់ឮខ្លះ ពោលថា សេចក្តីបរិសុទ្ធព្រោះសីល និងវត្តខ្លះ ពោលថា សេចក្តីបរិសុទ្ធព្រោះវិធីច្រើនយ៉ាងខ្លះ សមណព្រាហ្មណ៍ទាំងនោះ ជាអ្នកសង្រួម ប្រព្រឹត្តក្នុងសភាវៈនោះ ក៏ពិតមែនហើយ ( ប៉ុន្តែ ) តថាគតពោលថា សមណព្រាហ្មណ៍ទាំងនោះ ឆ្លងជាតិ និងជរាមិនបានទេ ។

[ ២៩៥ ] ពាក្យថា ណាមួយ គឺគ្រប់ទាំងអស់ សព្វទាំងអស់ មិនសល់ ឥតសល់ ពាក្យថា ណាមួយ នេះជាពាក្យប្រមូល ។ ពាក្យថា សមណៈ គឺបុគ្គលណាមួយ ចូលកាន់បព្វជ្ជា ខាងក្រៅអំពីសាសនានេះ បួសជាបរិព្វ-ជក ។ ពាក្យថា ព្រាហ្មណ៍ គឺបុគ្គលណាមួយ ជាភោវាទី ហេតុនោះ ( ទ្រង់ត្រាស់ថា ) សមណព្រាហ្មណ៍ណាមួយនេះ ។ ពាក្យថា នន្ទៈ របស់បទថា ព្រះមានព្រះភាគទ្រង់ត្រាស់ថា ម្នាលនន្ទៈ គឺព្រះមានព្រះភាគហៅព្រាហ្មណ៍នោះតាមឈ្មោះ ។ ពាក្យថា ព្រះមានព្រះភាគ នេះជាពាក្យពោលដោយ

គោរព ។បេ។ ការបញ្ញត្តិថា ព្រះមានព្រះភាគនេះ ( កើត ) ព្រោះការត្រាស់ដឹង ហេតុនោះ ( ទ្រង់ត្រាស់ថា ) ព្រះមានព្រះភាគ ទ្រង់ត្រាស់ថា ម្នាលនន្ទះ ។

[ ២៩៦ ] ពាក្យថា ពោលថា សេចក្តីបរិសុទ្ធ ព្រោះអារម្មណ៍ដែលឃើញខ្លះ ដែលស្តាប់ឮខ្លះ គឺពោល សម្តែង ពណ៌នា បំភ្លឺ ថ្លែង នូវការស្អាត ស្អាតវិសេស បរិសុទ្ធ ការរួច រួចវិសេស រួចស្រឡះ ព្រោះអារម្មណ៍ដែលឃើញក្តី ពោល សម្តែង ពណ៌នា បំភ្លឺ ថ្លែង នូវការស្អាត ស្អាតវិសេស បរិសុទ្ធ ការរួច រួចវិសេស រួចស្រឡះ ព្រោះអារម្មណ៍ដែលឮក្តី ពោល សម្តែង ពណ៌នា បំភ្លឺ ថ្លែង នូវការស្អាត ស្អាតវិសេស បរិសុទ្ធ ការរួច រួចវិសេស រួចស្រឡះ ព្រោះអារម្មណ៍ ដែលឃើញ ឬឮក្តី ហេតុនោះ ( ទ្រង់ត្រាស់ថា ) ពោលថា សេចក្តីបរិសុទ្ធ ព្រោះអារម្មណ៍ដែលឃើញខ្លះ ដែលស្តាប់ឮខ្លះ ។

[ ២៩៧ ] ពាក្យថា ពោលថា សេចក្តីបរិសុទ្ធ ព្រោះសីល និងវត្តខ្លះ គឺពោល សម្តែង ពណ៌នា បំភ្លឺ ថ្លែង នូវការស្អាត ស្អាតវិសេស បរិសុទ្ធ ការរួច រួចវិសេស រួចស្រឡះ ព្រោះសីលក្តី ពោល សម្តែង ពណ៌នា បំភ្លឺ ថ្លែង នូវការស្អាត ស្អាតវិសេស បរិសុទ្ធ ការរួច រួចវិសេស រួចស្រឡះ ព្រោះវត្តក្តី ពោល សម្តែង ពណ៌នា បំភ្លឺ ថ្លែង នូវការស្អាត ស្អាតវិសេស បរិសុទ្ធ ការរួច រួចវិសេស រួចស្រឡះ ព្រោះសីល និងវត្តក្តី ហេតុនោះ ( ទ្រង់ត្រាស់ថា ) ពោលថា សេចក្តីបរិសុទ្ធ ព្រោះសីល និងវត្តខ្លះ ។

[ ២៩៨ ] ពាក្យថា ពោលថាសេចក្ដីបរិសុទ្ធ ព្រោះវិធីច្រើនយ៉ាងខ្លះ គឺពោល សម្ដែង ពណ៌នា បំភ្លឺ ថ្លែង នូវការស្អាត ស្អាតវិសេស បរិសុទ្ធ ការរួច រួចវិសេស រួចស្រឡះ ព្រោះវត្ត និងមង្គលភ្ញាក់ផ្អើល មានប្រការផ្សេងៗ ជាអនេក ហេតុនោះ ( ទ្រង់ត្រាស់ថា ) ពោលថា សេចក្ដីបរិសុទ្ធ ព្រោះវិធីច្រើនយ៉ាងខ្លះ ។

[ ២៩៩ ] ពាក្យថា សមណព្រាហ្មណ៍ទាំងនោះ ជាអ្នកសង្រួមប្រព្រឹត្ត ក្នុងសភាវៈនោះ ក៏ពិតមែនហើយ ត្រង់ពាក្យថា ក៏ពិតមែនហើយ គឺជាពាក្យតំណបទ ជាពាក្យទាក់ទងដោយបទ ជាពាក្យបំពេញបទ ជាពាក្យប្រជុំអក្ខរៈ ជាពាក្យសម្រួលព្យញ្ជនៈ ពាក្យថា ក៏ពិតមែនហើយ នេះជាលំដាប់បទ ។ ពាក្យថា សមណព្រាហ្មណ៍ទាំងនោះ បានដល់ បុគ្គលអ្នកលុះក្នុងទិដ្ឋិ ។ ពាក្យថា ក្នុងសភាវៈនោះ គឺក្នុងទិដ្ឋិរបស់ខ្លួន ក្នុងសេចក្ដីគួររបស់ខ្លួន ក្នុងសេចក្ដីគាប់ចិត្តរបស់ខ្លួន ក្នុងលទ្ធិរបស់ខ្លួន ។ ពាក្យថា ជាអ្នកសង្រួម គឺជាអ្នកសង្រួម សង្រួមចំពោះ គ្រប់គ្រង រក្សា រវាំង ។ ពាក្យថា ប្រព្រឹត្ត គឺប្រព្រឹត្ត ប្រព្រឹត្តផ្សេងៗ ទៅ ប្រព្រឹត្តទៅ រក្សា យាត្រា ឲ្យយាត្រាទៅ ហេតុនោះ ( ទ្រង់ត្រាស់ថា ) សមណព្រាហ្មណ៍ទាំងនោះ ជាអ្នកសង្រួមប្រព្រឹត្តក្នុងសភាវៈនោះ ក៏ពិតមែនហើយ ។

[ ៣០០ ] ពាក្យថា ប៉ុន្តែ តថាគតពោលថា សមណព្រាហ្មណ៍ទាំងនោះ ឆ្លងជាតិ និងជរាមិនបានទេ គឺតថាគត ពោល ប្រាប់ សម្ដែង បញ្ញត្ត តាំងទុក បើក ចែក ធ្វើឲ្យរាក់ ប្រកាសថា សមណព្រាហ្មណ៍ទាំង

នោះ ឆ្លងមិនបាន ឆ្លងឡើងមិនបាន ឆ្លងកាត់មិនបាន កន្លងមិនបាន ប្រព្រឹត្ត កន្លងមិនបាន នូវជាតិ ជរា និងមរណៈ គឺថា ជាអ្នកមិនឃ្លាតចេញ មិនរលាស់ចេញ មិនកន្លង មិនប្រព្រឹត្តកន្លងចាកជាតិ ជរា និងមរណៈ តែងនៅវិលវល់ ក្នុងខាងក្នុងនៃជាតិ ជរា និងមរណៈ តែងវិលវល់ក្នុងខាងក្នុងនៃគន្លងសង្សារ ត្រូវជាតិជាប់តាមហើយ ត្រូវជរារឹតរួតហើយ ត្រូវព្យាធិសង្កត់សង្កិនហើយ ត្រូវមរណៈកម្ចាត់ហើយ ឥតមានទីជ្រក ឥតមានទីពួន ឥតមានទីរឭក ឥតមានបុគ្គលជាទីរឭក ហេតុនោះ ( ទ្រង់ត្រាស់ថា ) តថាគតពោលថា សមណព្រាហ្មណ៍ទាំងនោះ ឆ្លងជាតិ និងជរាមិនបាន ។ ហេតុនោះ ព្រះមានព្រះភាគត្រាស់ថា

( ព្រះមានព្រះភាគត្រាស់ថា ម្នាលនន្ទៈ ) សមណព្រាហ្មណ៍ទាំងឡាយណាមួយនេះ ពោលថា សេចក្តីបរិសុទ្ធ ព្រោះអារម្មណ៍ដែលឃើញខ្លះ ដែលស្តាប់ឮខ្លះ ពោលថា សេចក្តីបរិសុទ្ធព្រោះសីល និងវត្តខ្លះ ពោលថា សេចក្តីបរិសុទ្ធព្រោះវិធីច្រើនយ៉ាងខ្លះ សមណព្រាហ្មណ៍ទាំងនោះ ជាអ្នកសង្រួម ប្រព្រឹត្តក្នុងសភាវៈនោះ ក៏ពិតមែនហើយ ( ប៉ុន្តែ ) តថាគតពោលថា សមណព្រាហ្មណ៍ទាំងនោះ ឆ្លងជាតិ និង ជរាមិនបានទេ ។

[ ៣០១ ] ( នន្ទៈមានអាយុពោលដូច្នេះថា ) សមណព្រាហ្មណ៍ទាំងឡាយណាមួយនេះ ពោលថា សេចក្តីបរិសុទ្ធ ព្រោះអារម្មណ៍ដែលឃើញខ្លះ ដែលស្តាប់ឮខ្លះពោលថា សេចក្តីបរិសុទ្ធ

ព្រោះសីល និងវត្តខ្លះ ពោលថា សេចក្តីបរិសុទ្ធ ព្រោះវិធីច្រើន យ៉ាងខ្លះ បពិត្រមុនិ បើព្រះអង្គត្រាស់ថា សមណព្រាហ្មណ៍ទាំង នោះ ឆ្លងឱឃៈមិនបានទេ បពិត្រព្រះអង្គ ទ្រង់និរទុក្ខ កាលបើ ដូច្នេះ តើនរណា ក្នុងទេវលោក និងមនុស្សលោក ទើបឆ្លងជាតិ និងជរាបាន បពិត្រព្រះមានព្រះភាគ ខ្ញុំព្រះអង្គសូមទូលសួរព្រះ អង្គ សូមព្រះអង្គទ្រង់ប្រាប់សេចក្តីនោះ ដល់ខ្ញុំព្រះអង្គ ។

[ ៣០២ ] ពាក្យថា ណាមួយ របស់បទថា សមណព្រាហ្មណ៍ទាំង ឡាយណាមួយនេះ គឺគ្រប់ទាំងអស់ សព្វទាំងអស់ មិនសល់ ឥតសល់ ពាក្យថា ណាមួយ នេះជាពាក្យប្រមូល ។ ពាក្យថា សមណៈ គឺបុគ្គលណា មួយចូលកាន់ផ្នួសខាងក្រៅ អំពីសាសនានេះ បួសជាបរិព្វាជក ។ ពាក្យថា ព្រាហ្មណ៍ គឺបុគ្គលណាមួយជាភោវាទី ហេតុនោះ ( លោកសួរថា ) សមណ- ព្រាហ្មណ៍ទាំងឡាយណាមួយនេះ ។ ពាក្យថា ដូច្នេះ របស់បទថា នន្ទៈមាន អាយុពោលដូច្នេះ គឺជាតំណបទ ។ ពាក្យថា មានអាយុ គឺពាក្យជាទី ស្រឡាញ់ ពាក្យថា នន្ទៈ ជាឈ្មោះនៃព្រាហ្មណ៍នោះ ។បេ។ ជាពាក្យហៅ ព្រាហ្មណ៍នោះ ហេតុនោះ ( មានពាក្យថា ) នន្ទៈមានអាយុពោលដូច្នេះ ។

[ ៣០៣ ] ពាក្យថា ពោលថា សេចក្តីបរិសុទ្ធ ព្រោះអារម្មណ៍ដែល ឃើញខ្លះ ដែលស្តាប់ឮខ្លះ គឺពោល សម្តែង ពណ៌នា បំភ្លឺ ថ្លែងនូវការស្អាត ស្អាតវិសេស បរិសុទ្ធ ការរួច រួចវិសេស រួចស្រឡះ ព្រោះអារម្មណ៍ដែល ឃើញក្តី ពោល សម្តែង ពណ៌នា បំភ្លឺ ថ្លែងនូវការស្អាត ស្អាតវិសេស

បរិសុទ្ធ ការរួច រួចវិសេស រួចស្រឡះ ព្រោះអារម្មណ៍ដែលឃើញ ឬព្ធក្តី ហេតុនោះ ( លោកសួរថា ) ពោលថា សេចក្តីបរិសុទ្ធ ព្រោះអារម្មណ៍ដែលឃើញខ្លះ ដែលស្តាប់ព្ធខ្លះ ។

[ ៣០៤ ] ពាក្យថា ពោលថា សេចក្តីបរិសុទ្ធ ព្រោះសីល និងវត្តខ្លះ គឺពោល សម្តែង ពណ៌នា បំភ្លឺ ថ្លែង នូវការស្អាត ស្អាតវិសេស បរិសុទ្ធ ការរួច រួចវិសេស រួចស្រឡះ ព្រោះសីលក្តី ពោល សម្តែង ពណ៌នា បំភ្លឺ ថ្លែង នូវការស្អាត ស្អាតវិសេស បរិសុទ្ធ ការរួច រួចវិសេស រួចស្រឡះ ព្រោះវត្តក្តី ពោល សម្តែង ពណ៌នា បំភ្លឺ ថ្លែង នូវការស្អាត ស្អាតវិសេស បរិសុទ្ធ ការរួច រួចវិសេស រួចស្រឡះ ព្រោះសីល និងវត្តក្តី ហេតុនោះ ( លោកសួរថា ) ពោលថា សេចក្តីបរិសុទ្ធ ព្រោះសីល និងវត្តខ្លះ ។

[ ៣០៥ ] ពាក្យថា ពោលថា សេចក្តីបរិសុទ្ធ ព្រោះវិធីច្រើនយ៉ាងខ្លះ គឺពោល សម្តែង ពណ៌នា បំភ្លឺ ថ្លែង នូវការស្អាត ស្អាតវិសេស បរិសុទ្ធ ការរួច រួចវិសេស រួចស្រឡះ ព្រោះវត្ត និងមង្គលភ្ញាក់ផ្អើល មានប្រការផ្សេងៗ ជាអនេក ហេតុនោះ ( លោកសួរថា ) ពោលថា សេចក្តីបរិសុទ្ធ ព្រោះវិធីច្រើនយ៉ាងខ្លះ ។

[ ៣០៦ ] ពាក្យថា បពិត្រព្រះមុនិ បើព្រះអង្គត្រាស់ថា សមណ-ព្រាហ្មណ៍ទាំងនោះ ឆ្លងឱឃៈមិនបានទេ ត្រង់ពាក្យថា សមណព្រាហ្មណ៍ទាំងនោះ គឺពួកបុគ្គលអ្នកលុះក្នុងទិដ្ឋិ ។ ពាក្យថា មុនិ សេចក្តីថា ញាណ លោកហៅថា មោនៈ ។បេ។ មុនិនោះ បានកន្លងនូវបណ្តាញ គឺការជាប់ជំពាក់ ។

ពាក្យថា បើព្រះអង្គត្រាស់ថា សមណព្រាហ្មណ៍ទាំងនោះ ឆ្លងឱឃៈមិនបាន ទេ គឺឆ្លងមិនបាន ឆ្លងឡើងមិនបាន ឆ្លងចេញមិនបាន ឆ្លងរំលងមិនបាន កន្លងមិនបាន ប្រព្រឹត្តកន្លងមិនបាន នូវឱឃៈ គឺកាម ឱឃៈ គឺភព ឱឃៈ គឺទិដ្ឋិ ឱឃៈ គឺអវិជ្ជា គឺវិលវល់នៅក្នុងខាងក្នុងនៃជាតិ ជរា និងមរណៈ វិលវល់នៅក្នុងខាងក្នុងគន្លងសង្សារ ត្រូវជាតិជាប់តាមហើយ ត្រូវជរារឹតរួតហើយ ត្រូវព្យាធិសង្កត់សង្កិនហើយ ត្រូវមរណៈកម្ចាត់ហើយ ជាអ្នកឥតមានទីជ្រក ឥតមានទីពួន ឥតមានទីរឭក ឥតមានបុគ្គលជាទីរឭក ។ ពាក្យថា ត្រាស់ គឺពោល ប្រាប់ សំម្ដែង បញ្ញត្ត តាំងទុក្ខ បើក ចែក ធ្វើឲ្យរាក់ ប្រកាស ហេតុនោះ ( លោកសួរថា ) បពិតព្រះមុនិ បើព្រះអង្គត្រាស់ថា សមណព្រាហ្មណ៍ទាំងនោះ ឆ្លងឱឃៈមិនបានទេ ។

[ ៣០៧ ] ពាក្យថា បពិត្រព្រះអង្គទ្រង់និរទុក្ខ កាលបើដូច្នេះ តើនរណា ក្នុងទេវលោក និងមនុស្សលោក ទើបឆ្លងជាតិ និងជរាបាន គឺកាលបើដូច្នេះ តើនរណា ក្នុងលោក ព្រមទាំងទេវលោក មារលោក ព្រហ្មលោក ក្នុងពួកសត្វ ព្រមទាំងសមណៈ និងព្រាហ្មណ៍ ក្នុងពួកមនុស្សជាសម្មតិទេព និងមនុស្សសាមញ្ញ ឆ្លង ឆ្លងឡើង ឆ្លងកាត់ កន្លង ប្រព្រឹត្តកន្លង នូវជាតិ ជរា និងមរណៈបាន ។ ពាក្យថា បពិត្រព្រះអង្គទ្រង់និរទុក្ខ គឺពាក្យជាទីស្រឡាញ់ ពាក្យជាទីគោរព ពាក្យថា បពិត្រព្រះអង្គទ្រង់និរទុក្ខ នេះជាពាក្យពោលដោយគោរព កោតខ្លាច ហេតុនោះ ( លោកសួរថា ) បពិត្រព្រះអង្គ ទ្រង់និរទុក្ខ កាលបើដូច្នេះ តើនរណា ក្នុងទេវលោក និងមនុស្សលោក ឆ្លង

ជាតិ និងជរាបាន ។

[ ៣០៨ ] ពាក្យថា បពិត្រព្រះមានព្រះភាគ ខ្ញុំព្រះអង្គសូមទូលសួរព្រះអង្គ សូមព្រះអង្គទ្រង់ប្រាប់សេចក្តីនោះ ដល់ខ្ញុំព្រះអង្គ ត្រង់ពាក្យថា ខ្ញុំព្រះអង្គសូមទូលសួរព្រះអង្គ គឺខ្ញុំព្រះអង្គសូមសួរព្រះអង្គ សូមអង្វរព្រះអង្គ សូមអារាធនាព្រះអង្គ សូមព្រះអង្គត្រាស់ប្រាប់សេចក្តីនោះ ដល់ខ្ញុំព្រះអង្គ ហេតុនោះ ( លោកសួរថា ) ខ្ញុំព្រះអង្គសូមទូលសួរព្រះអង្គ ។ ពាក្យថា បពិត្រព្រមានព្រះភាគ នេះជាពាក្យពោលដោយគោរព ។បេ។ ការបញ្ញត្តិថា ព្រះមានព្រះភាគ នេះ ( កើត ) ព្រោះការត្រាស់ដឹង ។ ពាក្យថា សូមប្រាប់សេចក្តីនោះ ដល់ខ្ញុំព្រះអង្គ គឺសូមទ្រង់ប្រាប់ បង្ហាញ សម្តែង បញ្ញត្ត តាំងទុក បើក ចែក ធ្វើឲ្យរាក់ ប្រកាស ហេតុនោះ ( លោកសួរថា ) បពិត្រព្រះមានព្រះភាគ ខ្ញុំព្រះអង្គសូមទូលសួរព្រះអង្គ សូមព្រះអង្គទ្រង់ប្រាប់សេចក្តីនោះ ដល់ខ្ញុំព្រះអង្គ ។ ហេតុនោះ ព្រាហ្មណ៍នោះពោលថា

( នន្ទៈមានអាយុពោលដូច្នេះថា ) សមណព្រាហ្មណ៍ទាំងឡាយណាមួយនេះ ពោលថាសេចក្តីបរិសុទ្ធ ព្រោះអារម្មណ៍ដែលឃើញខ្លះ ដែលស្តាប់ឮខ្លះ ពោលថាសេចក្តីបរិសុទ្ធ ព្រោះសីល និងវត្តខ្លះ ពោលថាសេចក្តីបរិសុទ្ធ ព្រោះវិធីច្រើនយ៉ាងខ្លះ បពិត្រព្រះមុនិ បើព្រះអង្គត្រាស់ថា សមណព្រាហ្មណ៍ទាំងនោះ ឆ្លងឱឃៈមិនបានទេ បពិត្រព្រះអង្គទ្រង់និរទុក្ខ កាលបើដូច្នេះ តើនរណា ក្នុងទេវលោក និងមនុស្សលោក ទើបឆ្លងជាតិ និងជរា

បាន បពិត្រព្រះមានព្រះភាគ ខ្ញុំព្រះអង្គ សូមទូលសួរព្រះអង្គ សូមព្រះអង្គទ្រង់ប្រាប់សេចក្តីនោះ ដល់ខ្ញុំព្រះអង្គ ។

[ ៣០៩ ] ( ព្រះមានព្រះភាគត្រាស់ថា ម្នាលនន្ទៈ) តថាគតមិនបានពោលថា ពួកសមណព្រាហ្មណ៍ទាំងអស់ ត្រូវជាតិ និងជរាបិទបាំងទេ តថាគតពោលថា ជនទាំងឡាយណា ក្នុងលោកនេះ លះបង់នូវអារម្មណ៍ទាំងអស់ ដែលឃើញក្តី ដែលឮក្តី ដែលប៉ះពាល់ក្តី នូវសីល និងវត្តក្តី លះបង់នូវវិធីច្រើនប្រការទាំងអស់ក្តី ឬជនទាំងឡាយណា កំណត់ដឹងនូវតណ្ហា ជាអ្នកមិនមានអាសវៈ ជនទាំងនោះឯង ឈ្មោះថា ឆ្លងផុតឱឃៈបាន ។

[ ៣១០ ] ពាក្យថា ( ព្រះមានព្រះភាគពោលថា ម្នាលនន្ទៈ ) តថាគតមិនបានពោលថា ពួកសមណព្រាហ្មណ៍ទាំងអស់ ត្រូវជាតិ និងជរាបិទបាំងទេ សេចក្តីថា ម្នាលនន្ទៈ តថាគតមិនបានពោលថា សមណ-ព្រាហ្មណ៍ទាំងអស់ ត្រូវជាតិជរា ខ្ទប់ រាំង ហ៊ុមក្ជិត បិទ សង្រួម ផ្តាប់ហើយ តថាគតពោល ប្រាប់ សម្តែង បញ្ញត្ត តាំងទុក្ខ បើក បែក ធ្វើឲ្យរាក់ថា ជាតិក្តី ជរា និងមរណៈក្តី ដែលសមណព្រាហ្មណ៍ទាំងឡាយណា លះបង់ហើយ ផ្តាច់ឫសគល់ហើយ ធ្វើមិនឲ្យមានទីកើតដូចជាទីកើតនៃដើមត្នោត ធ្វើមិនឲ្យកើតមានបែបភាព ឲ្យជាធម៌លែងកើតតទៅទៀត សមណ-ព្រាហ្មណ៍ទាំងនោះ គង់មាន ហេតុនោះ ( មានពាក្យថា ) ( ព្រះមានព្រះភាគពោលថា ម្នាលនន្ទៈ ) តថាគតមិនបានពោលថា ពួកសមណព្រាហ្មណ៍

ទាំងអស់ ត្រូវជាតិ និងជរា បិទបាំងទេ ។

[ ៣១១ ] ពាក្យថា ជនទាំងឡាយណាក្នុងលោកនេះ លះបង់នូវអារម្មណ៍ទាំងអស់ ដែលឃើញក្តី ដែលឮក្តី ដែលប៉ះពាល់ក្តី នូវសីល និងវត្តក្តី សេចក្តីថា ជនទាំងឡាយណា លះបង់ ផ្តាច់បង់ បន្ទោបង់ ធ្វើឲ្យវិនាស ដល់នូវការមិនកើតមាន នូវសេចក្តីបរិសុទ្ធ ព្រោះអារម្មណ៍ដែលឃើញទាំងអស់ ជនទាំងឡាយណា លះបង់ ផ្តាច់បង់ បន្ទោបង់ ធ្វើឲ្យវិនាស ធ្វើមិនឲ្យកើតមានបែបភាព នូវសេចក្តីបរិសុទ្ធ ព្រោះអារម្មណ៍ដែលឮទាំងអស់ នូវសេចក្តីបរិសុទ្ធ ព្រោះអារម្មណ៍ដែលឃើញដែលឮទាំងអស់ នូវសេចក្តីបរិសុទ្ធ ព្រោះអារម្មណ៍ដែលប៉ះពាល់ទាំងអស់ នូវសេចក្តីបរិសុទ្ធ ព្រោះសីលទាំងអស់ នូវសេចក្តីបរិសុទ្ធ ព្រោះវត្តទាំងអស់ នូវសេចក្តីបរិសុទ្ធ ព្រោះសីល និងវត្តទាំងអស់ ហេតុនោះ ( ទ្រង់ត្រាស់ថា ) ជនទាំងឡាយណា ក្នុងលោកនេះ លះបង់នូវអារម្មណ៍ទាំងអស់ ដែលឃើញក្តី ដែលឮក្តី ដែលប៉ះពាល់ក្តី នូវសីល និងវត្តក្តី ។

[ ៣១២ ] ពាក្យថា លះបង់នូវវិធីច្រើនប្រការទាំងអស់ក្តី គឺលះបង់ ផ្តាច់បង់ បន្ទោបង់ ធ្វើឲ្យវិនាស ធ្វើមិនឲ្យកើតមានបែបភាពនូវការស្អាត ស្អាតវិសេស បរិសុទ្ធិ ការរួច រួចវិសេស រួចស្រះឡះដោយវត្ត និងមង្គលភ្ញាក់ផ្អើល មានប្រការផ្សេងៗ ជាអនេក ហេតុនោះ ( ទ្រង់ត្រាស់ថា ) លះបង់នូវវិធីច្រើនប្រការទាំងអស់ក្តី ។

[ ៣១៣ ] អធិប្បាយពាក្យថា តថាគតពោលថា ... ឬជនទាំងឡាយ

ណា កំណត់ដឹងនូវតណ្ហា ជាអ្នកមិនមានអាសវៈ ជនទាំងនោះឯង ឈ្មោះថា ឆ្លងផុតឱឃៈបាន ត្រង់ពាក្យថា តណ្ហា បានដល់ រូបតណ្ហា សទ្ទតណ្ហា គន្ធតណ្ហា រសតណ្ហា ផោដ្ឋព្វតណ្ហា ធម្មតណ្ហា ។ ពាក្យថា កំណត់ដឹង គឺ កំណត់ដឹងនូវតណ្ហា ដោយបរិញ្ញា ៣ គឺ ញាតបរិញ្ញា ១ តីរណបរិញ្ញា ១ បហានបរិញ្ញា ១ ។

ញាតបរិញ្ញា តើដូចម្តេច ។ បុគ្គលដឹងច្បាស់នូវតណ្ហា គឺ ដឹងច្បាស់ ឃើញច្បាស់ថា នេះរូបតណ្ហា នេះសទ្ទតណ្ហា នេះគន្ធតណ្ហា នេះរសតណ្ហា នេះផោដ្ឋព្វតណ្ហា នេះធម្មតណ្ហាដូច្នេះ នេះញាតបរិញ្ញា ។ តីរណបរិញ្ញា តើដូចម្តេច ។ បុគ្គលធ្វើការដឹងយ៉ាងនេះហើយ ត្រិះរិះនូវតណ្ហា ថាមិនទៀង ជាទុក្ខ ជារោគ ជាបូស ។បេ។ ត្រិះរិះនូវតណ្ហាថា មិនមែនជាគ្រឿងរលាស់ចេញដូច្នេះ នេះតីរណបរិញ្ញា ។ បហានបរិញ្ញា តើដូចម្តេច ។ បុគ្គលត្រិះរិះយ៉ាងនេះហើយ លះបង់ បន្ទោបង់ ធ្វើឲ្យវិនាស ធ្វើមិនឲ្យកើតមានបែបភាពនូវតណ្ហា ។ សមដូចព្រះពុទ្ធដីកានេះ ដែលព្រះមានព្រះភាគត្រាស់ថា ម្នាលភិក្ខុទាំងឡាយ ឆន្ទរាគៈក្នុងតណ្ហាណា អ្នកទាំងឡាយ ចូរលះបង់ឆន្ទរាគៈនោះចេញ កាលបើធ្វើបានយ៉ាងនេះ តណ្ហានោះ ឈ្មោះថា ជាធម្មជាតដែលអ្នកលះបង់ហើយ ។ ផ្តាច់ឫសចោលហើយ ធ្វើមិនឲ្យមានទីកើតដូចជាទីកើតនៃដើមត្នោត ធ្វើមិនឲ្យកើតមានបែបភាព ឲ្យជាធម៌លែងកើតតទៅទៀតដូច្នេះ នេះបហានបរិញ្ញា ។ បុគ្គលកំណត់ដឹងតណ្ហា ដោយបរិញ្ញាទាំង ៣ នេះ ហេតុនោះ ( ទ្រង់ត្រាស់ថា ) កំណត់ដឹងនូវតណ្ហា ។

ពាក្យថា មិនមានអាសវៈ សេចក្តីថា អាសវៈ ៤ គឺ កាមាសវៈ ភវាសវៈ ទិដ្ឋាសវៈ អវិជ្ជាសវៈ អាសវៈទាំងនេះ បុគ្គលទាំងឡាយណាបាន លះបង់ ផ្តាច់ឫសចោល ធ្វើមិនឲ្យមានទីកើត ដូចជាទីកើតនៃដើមត្នោត ធ្វើ មិនឲ្យកើតមានបែបភាព ឲ្យជាធម៌លែងកើតតទៅទៀត បុគ្គលទាំងនោះ លោកហៅថា អ្នកមិនមានអាសវៈ ។ ពាក្យថា បុគ្គលទាំងឡាយណា គឺ ព្រះអរហន្តទីណាស្រព ។

ពាក្យថា តថាគតពោលថា... ឬជនទាំងឡាយណា កំណត់ដឹងនូវតណ្ហា ជាអ្នកមិនមានអាសវៈ ជនទាំងឡាយនោះឯង ឈ្មោះថា ឆ្លងផុតឱឃៈបាន បានន័យថា តថាគតពោល ប្រាប់ សម្តែង បញ្ញត្ត តាំងទុក បើក បែក ធ្វើ ឲ្យរាក់ ប្រកាសថា ជនទាំងឡាយណា កំណត់ដឹងតណ្ហា ជាអ្នកមិនមាន អាសវៈ ជនទាំងនោះ ឆ្លងឱឃៈ គឺកាម ឆ្លងឱឃៈ គឺ ភព ឆ្លងឱឃៈ គឺទិដ្ឋិ ឆ្លងឱឃៈ គឺអវិជ្ជា ឆ្លង ឆ្លងឡើង ឆ្លងចេញ កន្លង កន្លងព្រម ប្រព្រឹត្តកន្លង នូវគន្លងសង្សារទាំងអស់ ហេតុនោះ ( ទ្រង់ត្រាស់ថា ) តថាគតពោលថា ... ជនទាំងឡាយណា កំណត់ដឹងនូវតណ្ហា ជាអ្នកមិនមានអាសវៈ ជនទាំងនោះ ឯង ឈ្មោះថា ឆ្លងផុតឱឃៈបាន ។ ហេតុនោះ ព្រះមានព្រះភាគត្រាស់ថា

( ព្រះមានព្រះភាគត្រាស់ថា ម្នាលនន្ទៈ ) តថាគតមិនបាន
ពោលថា ពួកសមណព្រាហ្មណ៍ទាំងអស់ ត្រូវជាតិ និងជរាបិទ
បាំងទេ តថាគតពោលថា ជនទាំងឡាយណា ក្នុងលោកនេះ
លះបង់នូវអារម្មណ៍ទាំងអស់ ដែលឃើញក្តី ដែលឮក្តី ដែល

ប៉ះពាល់ក្តី នូវសីល និងវត្តក្តី លះបង់នូវវិធីច្រើនប្រការទាំងអស់ក្តី ឬជនទាំងឡាយណា កំណត់ដឹងនូវតណ្ហា ជាអ្នកមិនមានអាសវៈ ជនទាំងនោះឯង ឈ្មោះថា ឆ្លងផុតឱឃៈបាន ។

[ ៣១៤ ] ខ្ញុំព្រះអង្គរីករាយចំពោះពាក្យទុំះរបស់ព្រះអង្គ ទ្រង់ស្វែងរកគុណដ៏ធំ បពិត្រព្រះគោតម ព្រះនិព្វានមិនមានឧបធិ ព្រះអង្គត្រាស់ទុកល្អហើយថា តថាគតពោលថា ជនទាំងឡាយណាក្នុងលោកនេះ លះបង់នូវអារម្មណ៍ទាំងអស់ ដែលឃើញក្តី ដែលឮក្តី ដែលប៉ះពាល់ក្តី នូវសីល និងវត្តក្តី លះបង់នូវវិធីច្រើនប្រការទាំងអស់ក្តី ឬជនទាំងឡាយណា កំណត់ដឹងនូវតណ្ហា ជាអ្នកមិនមានអាសវៈ ជនទាំងនោះឯង ឈ្មោះថា ឆ្លងផុតឱឃៈបាន ។

[ ៣១៥ ] អធិប្បាយពាក្យថា ខ្ញុំព្រះអង្គរីករាយចំពោះពាក្យទុំះ របស់ព្រះអង្គ ទ្រង់ស្វែងរកគុណដ៏ធំ ត្រង់ពាក្យថា នោះ គឺខ្ញុំព្រះអង្គត្រេកអរត្រេកអរចំពោះ រីករាយ រីករាយតាម ចង់បាន ជ្រះថ្លា ប្រាថ្នា ស្រឡាញ់ជាប់ចិត្តចំពោះពាក្យ ចំពោះកិរិយាពោល ចំពោះទេសនា ចំពោះអនុសន្ធិរបស់ព្រះអង្គ ពាក្យថា ទ្រង់ស្វែករកគុណដ៏ធំ គឺព្រះមានព្រះភាគ ទ្រង់ស្វែងរកគុណដ៏ធំ ។ ឈ្មោះថា ទ្រង់ស្វែងរកគុណដ៏ធំ ព្រោះទ្រង់រក ស្វែង ស្ទះស្វែង នូវសីលក្ខន្ធដ៏ធំ ឈ្មោះថា ទ្រង់ស្វែងរកគុណដ៏ធំ ព្រោះត្រូវគេស្វែងរកថា ។បេ។ ព្រះពុទ្ធជាទេវតា ធំជាងទេវតា ( គង់ ) ក្នុងទីណា ព្រះពុទ្ធ

ជានរៈដ៏អង់អាច ( គង់ ) ក្នុងទីណា ហេតុនោះ ( លោកពោលថា ) ខ្ញុំព្រះអង្គ រីករាយចំពោះពាក្យនោះ របស់ព្រះអង្គ ទ្រង់ស្វែងរកគុណដ៏ធំ ។

[ ៣១៦ ] អធិប្បាយពាក្យថា បពិត្រព្រះគោតម ព្រះនិព្វានមិនមានឧបធិ ព្រះអង្គត្រាស់ទុកល្អហើយ ត្រង់ពាក្យថា ត្រាស់ល្អហើយ គឺព្រះអង្គប្រាប់ល្អ សម្តែងល្អ បញ្ញត្តល្អ តាំងទុកល្អ បើកល្អ ចែកល្អ ធ្វើឲ្យរាក់ល្អ ប្រកាសល្អហើយ ។ ពាក្យថា បពិត្រព្រះគោតម ព្រះនិព្វានមិនមានឧបធិ សេចក្តីថា កិលេសផង ខន្ធផង អភិសង្ខារផង លោកហៅថា ឧបធិ ។ គឺការលះបង់ឧបធិ ការរម្ងាប់ឧបធិ ការរលាស់ចោលឧបធិ ការស្ងប់ឧបធិ អមតនិព្វាន ហេតុនោះ ( លោកពោលថា ) បពិត្រព្រះគោតម ព្រះនិព្វានមិនមានឧបធិ ព្រះអង្គទ្រង់ត្រាស់ល្អហើយ ។

[ ៣១៧ ] ពាក្យថា ជនទាំងឡាយណា ក្នុងលោកនេះ លះបង់នូវអារម្មណ៍ទាំងអស់ ដែលឃើញក្តី ដែលឮក្តី ដែលប៉ះពាល់ក្តី នូវសីល និងវត្តក្តី សេចក្តីថា ជនទាំងឡាយណា លះបង់ ផ្តាច់បង់ បន្ទោបង់ ធ្វើឲ្យវិនាស ធ្វើមិនឲ្យកើតមានបែបភាព នូវសេចក្តីបរិសុទ្ធ ព្រោះអារម្មណ៍ដែលឃើញទាំងអស់ ជនទាំងឡាយណា លះបង់ ផ្តាច់បង់ បន្ទោបង់ ធ្វើឲ្យវិនាស ធ្វើមិនឲ្យកើតមានបែបភាព នូវសេចក្តីបរិសុទ្ធ ព្រោះអារម្មណ៍ដែលឃើញឬឮទាំងអស់ នូវសេចក្តីបរិសុទ្ធ ព្រោះអារម្មណ៍ដែលប៉ះពាល់ទាំងអស់ នូវសេចក្តីបរិសុទ្ធ ព្រោះសីលទាំងអស់ នូវសេចក្តីបរិសុទ្ធ ព្រោះវត្តទាំងអស់ នូវសេចក្តីបរិសុទ្ធ ព្រោះសីល និងវត្តទាំងអស់ ហេតុនោះ ( លោកពោល

ថា ) ជនទាំងឡាយណា ក្នុងលោកនេះ លះបង់នូវអារម្មណ៍ទាំងអស់ ដែលឃើញក្តី ដែលឮក្តី ដែលប៉ះពាល់ក្តី នូវសីល និងវត្តក្តី ។

[ ៣១៨ ] ពាក្យថា លះបង់នូវវិធីច្រើនប្រការទាំងអស់ក្តី គឺលះបង់ផ្តាច់បង់ បន្ទោបង់ ធ្វើឲ្យវិនាស ធ្វើមិនឲ្យកើតមានបែបភាព នូវការស្អាតស្អាតវិសេស បរិសុទ្ធ ការរួច រួចវិសេស រួចស្រឡះ ព្រោះវត្ត និងមង្គលភ្ញាក់ផ្អើល មានប្រការផ្សេងៗ ជាអនេក ហេតុនោះ ( លោកពោលថា ) លះបង់នូវវិធីច្រើនប្រការទាំងអស់ក្តី ។

[ ៣១៩ ] អធិប្បាយពាក្យថា តថាគតពោលថា ... ឬជនទាំងឡាយណាកំណត់ដឹងតណ្ហា ជាអ្នកមិនមានអាសវៈ ជនទាំងឡាយនោះឯង ឈ្មោះថា ឆ្លងផុតឱឃៈបាន ត្រង់ពាក្យថា តណ្ហា បានដល់ រូបតណ្ហា សទ្ទតណ្ហា គន្ធតណ្ហា រសតណ្ហា ផោដ្ឋព្វតណ្ហា ។ ពាក្យថា កំណត់ដឹងនូវតណ្ហា គឺកំណត់ដឹងនូវតណ្ហា ដោយបរិញ្ញា ៣ គឺញាតបរិញ្ញា ១ តីរណបរិញ្ញា ១ បហានបរិញ្ញា ១ ។

ញាតបរិញ្ញា តើដូចម្តេច ។ បុគ្គលដឹងច្បាស់នូវតណ្ហា គឺដឹងច្បាស់ឃើញច្បាស់ថា នេះរូបតណ្ហា នេះសទ្ទតណ្ហា នេះគន្ធតណ្ហា នេះរសតណ្ហា នេះផោដ្ឋព្វតណ្ហា នេះធម្មតណ្ហា ដូច្នេះ នេះ ញាតបរិញ្ញា ។

តីរណបរិញ្ញា តើដូចម្តេច ។ បុគ្គលធ្វើ នូវការដឹងយ៉ាងនេះ ហើយត្រិះរិះនូវតណ្ហា គឺត្រិះរិះថា មិនទៀង ជាទុក្ខ ជារោគ ជាបូស ជាសរ ជាសេចក្តីតានតឹង ជាអាពាធ ជារបស់បុគ្គលដទៃ ជារបស់សាបសូន្យ ជាចង្រៃ

ជាឧបទ្រព ជាភ័យ ជាឧបសគ្គ ជារបស់ប្រែប្រួល ជារបស់ពុករលួយ ជារបស់មិនស្ថិតស្ថេរ ឥតទីពឹង ឥតទីជ្រក ឥតទីរឭក ឥតបុគ្គលជាទីរឭកគ្មាន ទទេ សោះសូន្យ មិនមែនខ្លួន ជាទោស ជារបស់ប្រែប្រួលជាធម្មតា ឥតខ្លឹម ជាទីតាំងនៃសេចក្តីតានតឹង ជាអ្នកសម្លាប់ ប្រកបដោយអាសវៈ ជារបស់មានបច្ច័យតាក់តែង ជាអាមិសនៃមារ មានជាតិជាធម្មតា មានជរាជាធម្មតា មានព្យាធិជាធម្មតា មានសេចក្តី ស្លាប់ជាធម្មតា មានការសោកខ្សឹកខ្សួល ទុក្ខ ទោមនស្ស ចង្អៀតចង្អល់ជាធម្មតា ជាហេតុឲ្យកើត ជារបស់វិនាស ជារបស់ឥតសង្ឃឹម ជាទោស មិនជាទីរលាស់ចេញ នេះតីរណបរិញ្ញា ។

បហានបរិញ្ញា តើដូចម្តេច ។ បុគ្គលត្រិះរិះយ៉ាងនេះហើយ លះបង់បន្ទោបង់ ធ្វើឲ្យវិនាស ធ្វើមិនឲ្យកើតមានបែបភាពនូវតណ្ហា នេះ បហានបរិញ្ញា ។ បុគ្គលកំណត់ដឹងនូវតណ្ហា ដោយបរិញ្ញា ៣ នេះ ហេតុនោះ ( លោកពោលថា ) កំណត់ដឹងនូវតណ្ហា ។

ពាក្យថា ជាអ្នកមិនមានអាសវៈ សេចក្តីថា អាសវៈ ៤ គឺកាមាសវៈ ភវាសវៈ ទិដ្ឋាសវៈ អវិជ្ជាសវៈ ។ អាសវៈទាំងនេះ បុគ្គលទាំងឡាយណាបានលះបង់ ផ្តាច់ឫសចោល ធ្វើឲ្យសល់តែទីនៅ ដូចជាទីនៅនៃដើមត្នោត ធ្វើមិនឲ្យកើតមានបែបភាព ឲ្យជាធម៌លែងកើតតទៅទៀត ជនទាំងនោះលោកហៅថា អ្នកមិនមានអាសវៈ ។ ពាក្យថា ជនទាំងឡាយណា បានដល់ពួកព្រះអរហន្តខីណាស្រព ។

ពាក្យថា តថាគតពោលថា ... ឬជនទាំងឡាយណា កំណត់ដឹងនូវតណ្ហា ជាអ្នកមិនមានអាសវៈ ជនទាំងនោះឯង ឈ្មោះថា ឆ្លងឱឃៈបាន សេចក្តីថា ជនទាំងឡាយណា កំណត់ដឹងតណ្ហា ជាអ្នកមិនមានអាសវៈ តថាគតពោល និយាយថា ជនទាំងនោះ បានឆ្លងឱឃៈ គឺកាម ឆ្លងឱឃៈ គឺភព ឆ្លងឱឃៈ គឺទិដ្ឋិ ឆ្លងឱឃៈ គឺអវិជ្ជា ឆ្លងឡើង ឆ្លងចេញ កន្លង រំលង ប្រព្រឹត្តកន្លងនូវ គន្លងនៃសង្ខារទាំងអស់ ហេតុនោះ ( លោកពោលថា ) តថាគតពោលថា ... ឬជនទាំងឡាយណា កំណត់ដឹងនូវតណ្ហា ជាអ្នកមិនមានអាសវៈ ជនទាំងនោះឯង ឈ្មោះថា ឆ្លងផុតឱឃៈបាន ។ ហេតុនោះ ព្រាហ្មណ៍នោះពោលថា

ខ្ញុំព្រះអង្គរីករាយចំពោះពាក្យនុ៎ះ របស់ព្រះអង្គ ទ្រង់ស្វែងរកគុណ
ដ៏ធំ បពិត្រព្រះគោតម ព្រះនិព្វានមិនមានឧបធិ ព្រះអង្គត្រាស់
ទុកល្អហើយថា តថាគតពោលថា ជនទាំងឡាយណា ក្នុងលោក
នេះ លះបង់នូវអារម្មណ៍ទាំងអស់ ដែលឃើញក្តី ដែលឮក្តី ដែល
ប៉ះពាល់ក្តី នូវសីល និងវត្តក្តី លះបង់នូវវិធីច្រើនប្រការទាំង
អស់ក្តី ឬជនទាំងឡាយណា កំណត់ដឹងនូវតណ្ហា ជាអ្នកមិនមាន
អាសវៈ ជនទាំងនោះឯង ឈ្មោះថា ឆ្លងផុតឱឃៈបាន ។

លុះចប់គាថាហើយ ។បេ។ នន្ទៈពោលថា បពិត្រព្រះអង្គដ៏ចម្រើន ព្រះមានព្រះភាគ ជាសាស្តារបស់ខ្ញុំព្រះអង្គ ខ្ញុំព្រះអង្គជាសាវ័ក ។

## នន្ទមាណវកបញ្ហានិទ្ទេស ចប់

# អដ្ឋកថា

## ឆន្នមាណវកប្បញ្ហានិទ្ទេស

[ ២៧៧ ] គប្បីជ្រាបវិនិច្ឆ័យក្នុងនន្ទសូត្រទី ៧ ដូចតទៅ

គប្បីជ្រាបអត្ថនៃគាថាដូច្នេះ ជនទាំងឡាយ មានក្សត្រជាដើមក្នុងលោក រមែងពោលថា មុនីទាំងឡាយ មានក្នុងលោក សំដៅដល់អាជីវក និងនិគ្រន្ថជាដើម ។ បទថា **ញាណូបបន្នំ** សេចក្ដីថា ជនទាំងឡាយ រមែងពោលបុគ្គលប្រកបដោយញាណថា ជាមុនី ព្រោះជាអ្នកប្រកបដោយញាណ មានសមាបត្តិញ្ញាណជាដើមដូចម្ដេច ឬថា ពោលដល់បុគ្គលដទៃដែរ ឬរមែងពោលដល់បុគ្គលដែលប្រកបដោយការរស់នៅ ពោល គឺមានភាពជាអ្នកសៅហ្មង មានប្រការផ្សេងៗ ថាជាមុនី ។

[ ២៨០ ] គប្បីជ្រាបវិនិច្ឆ័យក្នុងនិទ្ទេសតទៅ បទថា **អដ្ឋសមាបត្តិញ្ញាណេន វា** បានដល់ ដោយញាណដែលសម្បយុត្តដោយសមាបត្តិ ៨ មានបឋមជ្ឈានជាដើម ។ បទថា **បញ្ចាភិញ្ញាណេន វា** បានដល់ ដោយញាណ គឺ ការដឹងខន្ធបញ្ចកៈដែលអាស្រ័យនៅក្នុងជាតិមុនជាដើម ។

[ ២៨២ ] លំដាប់នោះ ព្រះមានព្រះភាគ កាលទ្រង់ហាមទាំង ២ យ៉ាងរបស់នន្ទមាណពនោះ កាលទ្រង់សម្ដែងភាពជាមុនី ទើបត្រាស់គាថាថា **ន ទិដ្ឋិយា** ដូច្នេះជាដើម ។

[ ២៨៦ ] ឥឡូវនេះ នន្ទមាណពដើម្បីលះសេចក្ដីសង្ស័យក្នុងវាទៈនៃបុគ្គលអ្នកពោលថា សេចក្ដីបរិសុទ្ធ រមែងមានដោយវត្ថុដែលឃើញជាដើម

ទើបទូលសួរថា **យេ កេចិមេ** ដូច្នេះជាដើម ។ ក្នុងបទទាំងនោះ បទថា **អនេករូបេន** បានដល់ ដោយមន្តលក្ខណ៍ផ្សេងៗ ... បានដល់ ដោយមន្តលក្ខាក់ផ្អើលជាដើមខ្លះ ។ បទថា **តត្ថ យតា ចរន្តា** បានដល់ គ្រប់គ្រងហើយក្នុងទិដ្ឋិរបស់ខ្លួននោះ ។

[ ២៩៤ ] លំដាប់នោះ ព្រះមានព្រះភាគ កាលទ្រង់សម្តែងការមិនមានសេចក្តីបរិសុទ្ធយ៉ាងនោះដល់មាណពនោះ ទើបត្រាស់គាថាទី ៤ ។

[ ៣០១ ] នន្ទមាណពកាលស្តាប់ថា **ណាតរឹសុ** ( ឆ្លងជាតិ និងជរាមិនបានទេ ) យ៉ាងនេះហើយ ឥឡូវនេះ បំណងនឹងស្តាប់ដល់បុគ្គលដែលឆ្លងបានហើយ ក៏ទូលសួរថា **យេ កេចិមេ** ដូច្នេះជាដើម ។

[ ៣០៩ ] លំដាប់នោះ ព្រះមានព្រះភាគ កាលទ្រង់សម្តែងដល់បុគ្គលដែលឆ្លងជាតិជរាបាន ដោយមាតិកាថា **ឱឃតិណ្ណា** ដល់ទន្ទះនោះ ទើបត្រាស់គាថាទី ៦ ។

ក្នុងបទទាំងនោះ បទថា **ឆិវុតា** បានដល់ រួបរឹតហើយ ខ្ទប់ហើយ ។ បទថា **យេសីធ** កាត់បទជា **យេ សុ ឥធ**។ ពាក្យថា **សុ** ត្រឹមតែជានិបាត ។ បទថា **តណ្ហំ បរិញ្ញាយ** បានដល់ កំណត់ដឹងហើយនូវតណ្ហា ដោយបរិញ្ញា ៣ បទដ៏សេសក្នុងទីទាំងពួង ជាក់ច្បាស់ល្អហើយ ព្រោះមានន័យដូចពោលមកហើយក្នុងបទមុន ។

ព្រះមានព្រះភាគ ទ្រង់បញ្ចប់ទេសនាដោយធម៌ដ៏កំពូល គឺអរហត្តដោយប្រការដូច្នេះ ។

*[ ៣១៤ ] កាលចប់ទេសនា នន្ទមាណពពេញចិត្តក្នុងព្រះតម្រាស់របស់ព្រះមានព្រះភាគក្រៃលែង ទើបពោលគាថាថា* **ឯតាភិនន្ទាមិ** *ដូច្នេះជាដើម ។ ម្យ៉ាងទៀត ក្នុងនិទ្ទេសនេះ ក៏មានបុគ្គលសម្រេចធម៌ដូចគ្នា តាមដែលពោលហើយ ក្នុងនិទ្ទេសមុននោះឯង ៕*

**អដ្ឋកថា នន្ទមាណវសុត្តនិទ្ទេសទី ៧ ចប់**

# សុត្តន្តបិដក

## ហេមកមាណវកបញ្ហានិទ្ទេស

[ ៣២០ ] ( ហេមកៈមានអាយុទូលសួរដូច្នេះថា ) ក្នុងកាលមុន អំពីសាសនាព្រះគោតម ជនទាំងឡាយណា ព្យាករថា ហេតុធ្លាប់មានហើយដូច្នេះ នឹងមានដូច្នេះ ពាក្យទាំងអស់នោះ ជាពាក្យជឿស្តាប់បុគ្គលដទៃ ពាក្យទាំងអស់នោះ ជាពាក្យធ្វើសេចក្តីត្រិះរិះឲ្យចម្រើន ខ្ញុំព្រះអង្គមិនត្រេកអរក្នុងពាក្យនោះឡើយ ។

[ ៣២១ ] អធិប្បាយពាក្យថា ជនទាំងឡាយណា ព្យាករ ត្រង់ពាក្យថា ជនទាំងឡាយណា គឺពាវរីព្រាហ្មណ៍ណាផង ព្រាហ្មណ៍ទាំងឡាយដទៃណា ជាអាចារ្យរបស់ពាវរីព្រាហ្មណ៍នោះផង ព្រាហ្មណ៍ទាំងនោះ ព្យាករប្រាប់ សម្តែង បញ្ញត្ត តាំងទុក បើក ចែក ធ្វើឲ្យរាក់ ប្រកាសហើយ នូវទិដ្ឋិរបស់ខ្លួន សេចក្តីគួររបស់ខ្លួន សេចក្តីគាប់ចិត្តរបស់ខ្លួន លទ្ធិរបស់ខ្លួន អធ្យាស្រ័យរបស់ខ្លួន សេចក្តីប៉ុនប៉ងរបស់ខ្លួន ហេតុនោះ ( លោកពោលថា ) ជនទាំងឡាយណាព្យាករ ។ ពាក្យថា ដូច្នេះ របស់បទថា ហេមកៈមានអាយុទូលសួរដូច្នេះ ជាពាក្យតំណបទ ។បេ។ ពាក្យថា ដូច្នេះ នេះជាលំដាប់លំដោយនៃបទ ។ ពាក្យថា មានអាយុ គឺពាក្យជាទីស្រឡាញ់ ជាពាក្យគោរព ពាក្យថា មានអាយុនេះ ជាពាក្យពោលដោយគោរព កោតខ្លាច ។ ពាក្យថា ហេមកៈ គឺជាឈ្មោះ ។បេ។ ជាពាក្យសម្រាប់ហៅ ហេតុនោះ ( មានពាក្យថា ) ហេមកៈមានអាយុទូលសួរដូច្នេះ ។

[ ៣២២ ] ពាក្យថា ក្នុងកាលមុនអំពីសាសនាព្រះគោតម គឺមុនអំពីសាសនានៃព្រះគោតម ខាងនាយអំពីសាសនារបស់ព្រះគោតម ខាងដើមអំពីសាសនារបស់ព្រះគោតម ដំបូងអង្គស់អំពីសាសនារបស់ព្រះគោតម អំពីសាសនារបស់ព្រះពុទ្ធ អំពីសាសនារបស់ព្រះជិនស្រី អំពីសាសនារបស់ព្រះតថាគត អំពីសាសនារបស់ព្រះអរហន្ត ហេតុនោះ ( លោកពោលថា ) ក្នុងកាលមុនអំពីសាសនាព្រះគោតម ។

[ ៣២៣ ] ពាក្យថា ហេតុធ្លាប់មានហើយដូច្នេះ នឹងមានដូច្នេះ គឺឮថា ហេតុយ៉ាងនេះមានមកហើយ ឮថា ហេតុយ៉ាងនេះនឹងមាន ហេតុនោះ ( លោកពោលថា ) ហេតុធ្លាប់មានហើយដូច្នេះ នឹងមានដូច្នេះ ។

[ ៣២៤ ] ពាក្យថា ពាក្យទាំងអស់នោះ ជាពាក្យជឿស្តាប់បុគ្គលដទៃ គឺពាក្យទាំងអស់នោះ ជាពាក្យជឿស្តាប់បុគ្គលដទៃ សេចក្តីថា ព្រាហ្មណ៍ទាំងឡាយសម្តែងធម៌ ដោយឮថាដូច្នេះៗ ដោយឮតៗ គ្នា ដោយការផ្ទេរផ្ទេរនឹងក្បួន ដោយហេតុនៃការត្រិះរិះ ដោយហេតុនៃការគ្នេរគ្នាន់ ដោយការជញ្ជីងនូវអាការ ដោយហេតុដែលខ្លួនយល់ ខ្លួនពិនិត្យ ខ្លួនចូលចិត្ត មិនមែនត្រាស់ដឹងចំពោះខ្លួនឯង មិនមែនជាក់ច្បាស់ចំពោះខ្លួន ហេតុនោះ ( លោកពោលថា ) ពាក្យទាំងអស់នោះ ជាពាក្យជឿស្តាប់បុគ្គលដទៃ ។

[ ៣២៥ ] ពាក្យថា ពាក្យទាំងអស់នោះ ជាពាក្យធ្វើសេចក្តីត្រិះរិះ ឲ្យចម្រើន គឺពាក្យទាំងអស់នោះ ជាពាក្យធ្វើសេចក្តីត្រិះរិះឲ្យចម្រើន ធ្វើសេចក្តីត្រិះរិះផ្សេងៗ ឲ្យចម្រើន ធ្វើតម្រិះឲ្យចម្រើន ធ្វើសេចក្តីត្រិះរិះក្នុងកាមឲ្យចម្រើន

ធ្វើសេចក្តីត្រិះរិះក្នុងព្យាបាទឲ្យចម្រើន ធ្វើសេចក្តីត្រិះរិះក្នុងការបៀតបៀនឲ្យចម្រើន ធ្វើសេចក្តីត្រិះរិះញាតិឲ្យចម្រើន ធ្វើសេចក្តីត្រិះរិះជនបទឲ្យចម្រើន ធ្វើសេចក្តីត្រិះរិះការមិនស្លាប់ឲ្យចម្រើន ធ្វើសេចក្តីត្រិះរិះ ដែលប្រកបដោយសេចក្តីអាណិតចំពោះបុគ្គលដទៃឲ្យចម្រើន ធ្វើសេចក្តីត្រិះរិះដែលប្រកបដោយលាភ សក្ការៈ និងសេចក្តីសរសើរឲ្យចម្រើន ធ្វើសេចក្តីត្រិះរិះដែលប្រកបដោយសេចក្តីមិនមើលងាយឲ្យចម្រើន ហេតុនោះ ( លោកពោលថា ) ពាក្យទាំងអស់នោះ ជាពាក្យធ្វើសេចក្តីត្រិះរិះឲ្យចម្រើន ។

[ ៣២៦ ] ពាក្យថា ខ្ញុំព្រះអង្គមិនត្រេកអរក្នុងពាក្យនោះឡើយ គឺខ្ញុំព្រះអង្គ មិនបាន មិនលុះ មិនបានចំពោះ ហេតុនោះ ( លោកពោលថា ) ខ្ញុំព្រះអង្គមិនត្រេកអរក្នុងពាក្យនោះឡើយ ។ ហេតុនោះ ព្រាហ្មណ៍នោះពោលថា

( ហេមកៈមានអាយុ ទូលសួរដូច្នេះថា ) ក្នុងកាលមុនអំពីសាសនា
ព្រះគោតម ជនទាំងឡាយណា ព្យាករថា ហេតុធ្លាប់មានហើយ
ដូច្នេះ នឹងមានដូច្នេះ ពាក្យទាំងអស់នោះ ជាពាក្យជឿស្តាប់
បុគ្គលដទៃ ពាក្យទាំងអស់នោះ ជាពាក្យធ្វើសេចក្តីត្រិះរិះឲ្យចម្រើន
ខ្ញុំព្រះអង្គមិនត្រេកអរក្នុងពាក្យនោះឡើយ ។

[ ៣២៧ ] បពិត្រព្រះមុនិ សូមព្រះអង្គ សំដែងធម៌ សម្រាប់
ដកចេញនូវតណ្ហា ជាធម៌ដែលនាំឲ្យបុគ្គលដឹងច្បាស់ មានសតិ
ប្រព្រឹត្តឆ្លងនូវវិសត្តិកាតណ្ហាក្នុងលោក ដល់ខ្ញុំព្រះអង្គ ។

[ ៣២៨ ] ពាក្យថា សូមព្រះអង្គ សំដែងធម៌ ដល់ខ្ញុំព្រះអង្គ ត្រង់

ពាក្យថា ព្រះអង្គ គឺព្រាហ្មណ៍ពោលចំពោះព្រះមានព្រះភាគ ។ ពាក្យថា ធម៌ របស់បទថា សូមសម្តែងធម៌ គឺសូមព្រះអង្គ ពោល ប្រាប់ សម្តែង បញ្ញត្ត តាំងទុក បើក ចែក ធ្វើឲ្យរាក់ ប្រកាសនូវធម៌ មានពីរោះបទខាងដើម មានពីរោះបទកណ្តាល មានពីរោះបទខាងចុង នូវព្រហ្មចរិយៈ ព្រមទាំងអត្ថ ព្រមទាំងព្យញ្ជនៈ ដ៏បរិសុទ្ធ បរិបូណ៌ សព្វគ្រប់ នូវសតិប្បដ្ឋាន ៤ សម្មប្បធាន ៤ ឥទ្ធិបាទ ៤ ឥន្ទ្រិយ ៥ ពល ៥ ពោជ្ឈង្គ ៧ មគ្គប្រកបដោយអង្គ ៨ ដ៏ប្រសើរ ព្រះនិព្វាន និងបដិបទាជាដំណើរទៅកាន់ព្រះនិព្វាន ហេតុនោះ ( លោកពោលថា ) សូមព្រះអង្គសម្តែងធម៌ ដល់ខ្ញុំព្រះអង្គ ។

[ ៣២៩ ] ពាក្យថា បពិត្រព្រះមុនិ ... សម្រាប់ដកចេញនូវតណ្ហា ត្រង់ពាក្យថា តណ្ហា បានដល់រូបតណ្ហា សទ្ទតណ្ហា គន្ធតណ្ហា រសតណ្ហា ផោដ្ឋព្វតណ្ហា ធម្មតណ្ហា ។ ពាក្យថា សម្រាប់ដកចេញនូវតណ្ហា គឺជាគ្រឿងធ្វើតណ្ហាឲ្យវិនាស ជាគ្រឿងលះបង់តណ្ហា ជាគ្រឿងរម្ងាប់តណ្ហា ជាគ្រឿងរលាស់ចោលតណ្ហា ជាគ្រឿងស្ងប់រម្ងាប់តណ្ហា អមតនិព្វាន ។ ពាក្យថា មុនិ សេចក្តីថា ញាណ លោកហៅថា មោនៈ ។បេ។ មុនិនោះ បានឆ្លងនូវបណ្តាញ គឺការជាប់ជំពាក់ ហេតុនោះ ( លោកពោលថា ) បពិត្រព្រះមុនិ ... សម្រាប់ដកចេញនូវតណ្ហា ។

[ ៣៣០ ] ពាក្យថា ដែលនាំឲ្យបុគ្គលដឹងច្បាស់ មានសតិ ប្រព្រឹត្ត គឺធ្វើឲ្យដឹង ថ្លឹង ត្រិះរិះ ធ្វើឲ្យជាក់ច្បាស់ ធ្វើឲ្យប្រាកដ នូវធម៌ណា គឺធ្វើឲ្យ

ដឹង ថ្លឹង ត្រិះរិះ ធ្វើឲ្យជាក់ច្បាស់ ធ្វើឲ្យប្រាកដ ថាសង្ខារទាំងពួងមិនទៀង ជាសង្ខារទាំងពួងជាទុក្ខ ថាធម៌ទាំងពួងជាអនត្តា ។បេ។ ធ្វើឲ្យដឹង ថ្លឹង ត្រិះរិះ ធ្វើឲ្យជាក់ច្បាស់ ធ្វើឲ្យប្រាកដថា របស់ណាមួយ មានការកើតឡើងជាធម្មតា របស់ទាំងអស់នោះ មានការរលត់ទៅវិញជាធម្មតា ។ ពាក្យថា មានសតិ គឺ មានសតិដោយអាការ ៤ គឺបុគ្គលកំពុងចម្រើនកាយេកាយានុបស្សនាសតិ-ប្បដ្ឋាន ឈ្មោះថា អ្នកមានសតិ ។បេ។ បុគ្គលនោះ ហៅថា អ្នកមានសតិ ។ ពាក្យថា ប្រព្រឹត្ត គឺប្រព្រឹត្ត ប្រព្រឹត្តផ្សេងៗ ប្រព្រឹត្តទៅ រក្សា យាត្រា ឲ្យយាត្រាទៅ ហេតុនោះ ( លោកពោលថា ) ដែលនាំឲ្យបុគ្គលដឹងច្បាស់ មានសតិ ប្រព្រឹត្ត ។

[ ៣៣១ ] ពាក្យថា ឆ្លងវិសត្តិកាតណ្ហាក្នុងលោក សេចក្តីថា តណ្ហា លោកហៅថា វិសត្តិកា បានខាងតម្រេក តម្រេកដ៏មានកម្លាំង ។បេ។ អភិជ្ឈា លោភៈ អកុសលមូល ។ សំណួរត្រង់ពាក្យថា វិសត្តិកា ចុះ វិសត្តិកា ដោយអត្ថដូចម្តេច ។បេ។ ឈ្មោះវិសត្តិកា ព្រោះហេតុជាធម្មជាត លាត ផ្សាយទៅ ។ ពាក្យថា ក្នុងលោក គឺក្នុងអបាយលោក មនុស្សលោក ទេវលោក ខន្ធលោក ធាតុលោក អាយតនលោក ។ ពាក្យថា ឆ្លង វិសត្តិកាតណ្ហាក្នុងលោកបាន សេចក្តីថា តណ្ហាណា ឈ្មោះវិសត្តិកាក្នុង លោក បុគ្គលមានសតិ គប្បីឆ្លង ឆ្លងឡើង ឆ្លងកាត់ កន្លង ប្រព្រឹត្តកន្លង នូវធម្មជាតឈ្មោះវិសត្តិកាក្នុងលោក ហេតុនោះ ( លោកពោលថា ) ឆ្លង នូវវិសត្តិកាតណ្ហាក្នុងលោក ។ ហេតុនោះ ព្រាហ្មណ៍នោះពោលថា

បពិត្រព្រះមុនិ សូមព្រះអង្គសម្ដែងធម៌ សម្រាប់ដកចេញនូវតណ្ហា ជាធម៌ដែលនាំឲ្យបុគ្គលដឹងច្បាស់ មានសតិ ប្រព្រឹត្តឆ្លងនូវវិសត្តិកាតណ្ហាក្នុងលោក ដល់ខ្ញុំព្រះអង្គ ។

[ ៣៣២ ] ( ព្រះមានព្រះភាគ ត្រាស់ថា ) ម្នាលហេមកៈ និព្វានបទ ជាធម្មជាតមិនឃ្លៀងឃ្លាត ជាគ្រឿងបន្ទោបង់ឆន្ទរាគៈក្នុងអារម្មណ៍ទាំងឡាយ មានសភាពជាទីស្រឡាញ់ ដែលឃើញ ឮ ប៉ះពាល់ ( ឬដឹងច្បាស់ ) ក្នុងលោកនេះ ។

[ ៣៣៣ ] ពាក្យថា ដែលឃើញ ឮ ប៉ះពាល់ ឬដឹងច្បាស់ក្នុងលោកនេះ ត្រង់ពាក្យថា ដែលឃើញ គឺដែលឃើញដោយភ្នែក ។ ពាក្យថា ឮ គឺឮដោយត្រចៀក ។ ពាក្យថា ប៉ះពាល់ គឺប៉ះពាល់ គឺធុំក្លិនដោយច្រមុះ លិទ្ធភ្លក្សដោយអណ្ដាត ប៉ះពាល់ដោយកាយ ។ពាក្យថា ដឹងច្បាស់ គឺដឹងដោយចិត្ត ហេតុនោះ ( ទ្រង់ត្រាស់ថា ) ដែលឃើញ ឮ ប៉ះពាល់ ឬដឹងច្បាស់ក្នុងលោកនេះ ។

[ ៣៣៤ ] អធិប្បាយពាក្យថា ម្នាលហេមកៈ ... ក្នុងអារម្មណ៍ទាំងឡាយមានសភាពជាទីស្រឡាញ់ សំណួរថា អារម្មណ៍ដូចម្ដេច មានសភាពជាទីស្រឡាញ់ មានសភាពជាទីត្រេកអរ ក្នុងលោក ។ ចក្ខុ មានសភាពជាទីស្រឡាញ់ មានសភាពជាទីត្រេកអរ ក្នុងលោក សោតៈ ឃានៈ ជិវ្ហា កាយ ចិត្ត មានសភាពជាទីស្រឡាញ់ មានសភាពជាទីត្រេកអរ ក្នុងលោក រូប មានសភាពជាទីស្រឡាញ់ មានសភាពជាទីត្រេកអរ ក្នុងលោក សទ្ទៈ គន្ធៈ

រស: ផោដ្ឋព្វ: ធម្មារម្មណ៍ មានសភាពជាទីស្រឡាញ់ មានសភាពជាទីត្រេកអរ ក្នុងលោក ចក្ខុវិញ្ញាណ មានសភាពជាទីស្រឡាញ់ មានសភាពជាទីត្រេកអរ ក្នុងលោក សោតវិញ្ញាណ ឃានវិញ្ញាណ ជិវ្ហាវិញ្ញាណ កាយវិញ្ញាណ មនោវិញ្ញាណ មានសភាពជាទីស្រឡាញ់ មានសភាពជាទីត្រេកអរ ក្នុងលោក ចក្ខុសម្ផស្ស មានសភាពជាទីស្រឡាញ់ មានសភាពជាទីត្រេកអរ ក្នុងលោក សោតសម្ផស្ស ឃានសម្ផស្ស ជិវ្ហាសម្ផស្ស កាយសម្ផស្ស មនោសម្ផស្ស មានសភាពជាទីស្រឡាញ់ មានសភាពជាទីត្រេកអរ ក្នុងលោក វេទនាកើតអំពីចក្ខុសម្ផស្ស មានសភាពជាទីស្រឡាញ់ មានសភាពជាទីត្រេកអរ ក្នុងលោក វេទនាកើតអំពីសោតសម្ផស្ស វេទនាកើតអំពីឃានសម្ផស្ស វេទនាកើតអំពីជិវ្ហាសម្ផស្ស វេទនាកើតអំពីកាយ-សម្ផស្ស វេទនាកើតអំពីមនោសម្ផស្ស មានសភាពជាទីស្រឡាញ់ មានសភាពជាទីត្រេកអរ ក្នុងលោក សេចក្តីសម្គាល់ក្នុងរូប មានសភាពជាទីស្រឡាញ់ មានសភាពជាទីត្រេកអរ ក្នុងលោក សេចក្តីសម្គាល់ក្នុងសំឡេង សេចក្តីសម្គាល់ក្នុងក្លិន សេចក្តីសម្គាល់ក្នុងរស សេចក្តីសម្គាល់ក្នុងផ្សព្វ សេចក្តីសម្គាល់ក្នុងធម្មារម្មណ៍ មានសភាពជាទីស្រឡាញ់ មានសភាពជាទីត្រេកអរ ក្នុងលោក ការគិតរូប មានសភាពជាទីស្រឡាញ់ មានសភាពជាទីត្រេកអរ ក្នុងលោក ការគិតសំឡេង ការគិតក្លិន ការគិតរស ការគិតផ្សព្វ ការគិតធម្មារម្មណ៍ មានសភាពជាទីស្រឡាញ់ មានសភាពជាទីត្រេកអរ ក្នុងលោក សេចក្តីប្រាថ្នារូប មានសភាពជាទីស្រឡាញ់ មានសភាពជាទីត្រេកអរ

ក្នុងលោក សេចក្តីប្រាថ្នាសំឡេង សេចក្តីប្រាថ្នាក្លិន សេចក្តីប្រាថ្នារស សេចក្តីប្រាថ្នាផ្សព្វ សេចក្តីប្រាថ្នាក្នុងធម្មារម្មណ៍ មានសភាពជាទីស្រឡាញ់ មានសភាពជាទីត្រេកអរ ក្នុងលោក សេចក្តីត្រិះរិះរូប មានសភាពជាទីស្រឡាញ់ មានសភាពជាទីត្រេកអរ ក្នុងលោក សេចក្តីត្រិះរិះសំឡេង សេចក្តីត្រិះរិះក្លិន សេចក្តីត្រិះរិះរស សេចក្តីត្រិះរិះផ្សព្វ សេចក្តីត្រិះរិះធម្មារម្មណ៍ មានសភាពជាទីស្រឡាញ់ មានសភាពជាទីត្រេកអរ ក្នុងលោក ការពិចារណារូប មានសភាពជាទីស្រឡាញ់ មានសភាពជាទីត្រេកអរ ក្នុងលោក ការពិចារណាសំឡេង ការពិចារណាក្លិន ការពិចាណារស ការពិចារណាផ្សព្វ ការពិចារណាធម្មារម្មណ៍ មានសភាពជាទីស្រឡាញ់ មានសភាពជាទីត្រេកអរ ក្នុងលោក ហេតុនោះ ( ទ្រង់ត្រាស់ថា ) ក្នុងអារម្មណ៍ មានសភាពជាទីស្រឡាញ់ ។ ពាក្យថា ម្នាលហេមកៈ គឺព្រះមានព្រះភាគ ត្រាស់ហៅព្រាហ្មណ៍នោះតាមឈ្មោះ ។

[ ៣៣៥ ] ពាក្យថា ជាគ្រឿងបន្ទោបង់ឆន្ទរាគ ត្រង់ពាក្យថា ឆន្ទរាគ បានខាងកាមច្ឆន្ទៈ ក្នុងកាមទាំងឡាយ តម្រេកក្នុងកាម សេចក្តីរីករាយក្នុងកាម សេចក្តីប្រាថ្នាក្នុងកាម សេចក្តីស្នេហាក្នុងកាម សេចក្តីក្តៅក្រហាយក្នុងកាម ការជ្រប់ចុះក្នុងកាម ការងល់ងប់ក្នុងកាម អន្ទង់ គឺកាម ធម៌ជាគ្រឿងប្រកប គឺកាម សេចក្តីប្រកាន់ គឺកាម នីវរណៈ គឺកាមច្ឆន្ទៈ ។ ពាក្យថា ជាគ្រឿងបន្ទោបង់ឆន្ទរាគ បានន័យថា គ្រឿងលះបង់ឆន្ទរាគ រម្ងាប់ឆន្ទរាគ រលាស់ចោលឆន្ទរាគ គ្របសង្កត់ឆន្ទរាគ អមតនិព្វាន ហេតុនោះ ( ទ្រង់ត្រាស់ថា )

ជាគ្រឿងបន្ទោបង់ឆន្ទរាគ ។

[ ៣៣៦ ] ពាក្យថា និព្វានបទ ជាធម្មជាត មិនឃ្លៀងឃ្លាត សេចក្តីថា បទ គឺនិព្វាន បទ គឺទីពឹង បទ គឺទីជ្រក បទ គឺធម៌ជាគ្រឿងប្រព្រឹត្តទៅខាងមុខ បទ គឺទីមិនមានភ័យ ។ ពាក្យថា មិនឃ្លៀងឃ្លាត គឺទៀងទាត់ ស្ថិតស្ថេរ ខ្ជាប់ខ្ជួន មិនប្រែប្រួលជាធម្មតា ហេតុនោះ ( ទ្រង់ត្រាស់ថា ) និព្វានបទ ជាធម្មជាត មិនឃ្លៀងឃ្លាត ។ ហេតុនោះ ព្រះមានព្រះភាគត្រាស់ថា

ម្នាលហេមកៈ និព្វានបទ ជាធម្មជាតមិនឃ្លៀងឃ្លាត ជាគ្រឿងបន្ទោបង់ឆន្ទរាគ ក្នុងអារម្មណ៍ មានសភាពគួរស្រឡាញ់ ដែលឃើញ ឮ ប៉ះពាល់ ( ឬដឹងច្បាស់ ) ក្នុងលោកនេះ ។

[ ៣៣៧ ] ជនទាំងឡាយណា ដឹងនិព្វាននោះ ជាអ្នកមានសតិ មានធម៌ឃើញហើយ រលត់កិលេសហើយ ជនទាំងនោះ ជាអ្នកស្ងប់រម្ងាប់ សព្វកាល ឈ្មោះថា ឆ្លងនូវវិសត្តិកាតណ្ហា ក្នុងលោកបាន ។

[ ៣៣៨ ] អធិប្បាយពាក្យថា ជនទាំងឡាយណា ដឹងនិព្វាននុ៎ះ ជាអ្នកមានសតិ ត្រង់ពាក្យថា និព្វាននុ៎ះ គឺអមតនិព្វាន បានខាងការរម្ងាប់សង្ខារទាំងពួង ការលះបង់ចោលឧបធិទាំងពួង ការអស់តណ្ហា ការប្រាសចាកតម្រេក ការរលត់ទុក្ខ និព្វាន ។ ពាក្យថា ដឹង គឺដឹង យល់ ថ្លឹង ត្រិះរិះ ធ្វើឲ្យជាក់ច្បាស់ ធ្វើឲ្យប្រាកដ គឺដឹង យល់ ថ្លឹង ត្រិះរិះ ធ្វើឲ្យជាក់ច្បាស់ ធ្វើឲ្យ

ប្រាកដថា សង្ខារទាំងពួងមិនទៀង ដឹង យល់ ថ្លឹង ត្រិះរិះ ធ្វើឲ្យច្បាស់ ធ្វើឲ្យប្រាកដ ថាសង្ខារទាំងពួងជាទុក្ខ ថាធម៌ទាំងពួងជាអនត្តា ។បេ។ ថារបស់ណាមួយ មានការកើតឡើងជាធម្មតា របស់ទាំងអស់នោះ មានការរលត់ទៅជាធម្មតា ។ ពាក្យថា ជនទាំងឡាយណា បានដល់ ពួកព្រះអរហន្ត-ខីណាស្រព ។ ពាក្យថា ជាអ្នកមានសតិ គឺមានសតិដោយហេតុ ៤ គឺបុគ្គលកំពុងចម្រើនកាយេកាយានុបស្សនាសតិប្បដ្ឋាន ឈ្មោះថា អ្នកមានសតិ ។បេ។ បុគ្គលទាំងនោះ លោកហៅថា អ្នកមានសតិ ហេតុនោះ ( ទ្រង់ត្រាស់ថា ) ជនទាំងឡាយណា ដឹងនិព្វានទុំះ ជាអ្នកមានសតិ ។

[ ៣៣៩ ] ពាក្យថា មានធម៌ឃើញហើយ រម្ងត់កិលេសហើយ គឺមានធម៌ឃើញហើយ មានធម៌ដឹងហើយ មានធម៌ថ្លឹងហើយ មានធម៌ត្រិះរិះហើយ មានធម៌ជាក់ច្បាស់ហើយ មានធម៌ប្រាកដហើយ ថាសង្ខារទាំងពួងមិនទៀង ។បេ។ មានធម៌ឃើញហើយ មានធម៌ដឹងហើយ មានធម៌ថ្លឹងហើយ មានធម៌ត្រិះរិះហើយ មានធម៌ជាក់ច្បាស់ហើយ មានធម៌ប្រាកដហើយថា របស់ណាមួយ មានការកើតឡើងជាធម្មតា របស់ទាំងអស់នោះ មានការរលត់ទៅជាធម្មតា ។ ពាក្យថា រលត់ហើយ គឺឈ្មោះថា រលត់ហើយ ព្រោះរម្ងត់រាគៈរលត់ហើយ ព្រោះរម្ងត់ទោសៈ រលត់ហើយ ព្រោះរម្ងត់មោហៈ កោធៈឧបនាហៈ ។បេ។ រលត់ហើយ ព្រោះរលត់អកុសលាភិសង្ខារទាំងអស់ ហេតុនោះ ( ទ្រង់ត្រាស់ថា ) មានធម៌ឃើញហើយ រលត់កិលេសហើយ ។

[ ៣៤០ ] ពាក្យថា ជនទាំងនោះ ជាអ្នកស្ងប់រម្ងាប់ សព្វកាល ត្រង់

ពាក្យថា ជាអ្នកស្ងប់រម្ងាប់ គឺស្ងប់រម្ងាប់ ព្រោះស្ងប់រាគៈ ស្ងប់រម្ងាប់ ព្រោះស្ងប់ទោសៈ ស្ងប់រម្ងាប់ ព្រោះស្ងប់មោហៈ កោធៈ ឧបនាហៈ ។បេ។ ជាអ្នកស្ងប់ រម្ងាប់ ចូលទៅរម្ងាប់ រម្ងត់ ស្ងប់រម្ងាប់ ព្រោះស្ងប់រម្ងាប់ ផុត រលត់ទៅប្រាស គ្របសង្កត់ នូវអកុសលាភិសង្ខារទាំងអស់ ហេតុនោះ ( ទ្រង់ត្រាស់ថា ) ជាអ្នកស្ងប់រម្ងាប់ ។ ពាក្យថា ជនទាំងនោះ បានដល់ ពួកព្រះអរហន្តខីណាស្រព ។ ពាក្យថា សព្វកាល គឺសព្វកាល គ្រប់កាល អស់កាលទាំងពួង អស់កាលជានិច្ច អស់កាលដ៏ទៀងទាត់ អស់កាលមិនដាច់ អស់កាលរឿយៗ មិនប្រឡូកប្រឡំ ថែមហើយថែមទៀត ជាប់តគ្នា មិនមានចន្លោះដូចរលកទឹកបន្តគ្នា ប៉ះពាល់គ្នា អស់បុរេភត្ត បច្ឆាភត្ត បឋមយាម មជ្ឈិមយាម បច្ឆិមយាម កាឡបក្ខ សុក្ខបក្ខ វស្សានរដូវ ហេមន្តរដូវ គិម្ហរដូវ ចំណែកបឋមវ័យ ចំណែកមជ្ឈិមវ័យ ចំណែកបច្ឆិមវ័យ ហេតុនោះ ( ទ្រង់ត្រាស់ថា ) ជនទាំងឡាយនោះ ជាអ្នកស្ងប់រម្ងាប់សព្វកាល ។

[ ៣៤១ ] ពាក្យថា ឈ្មោះថា ឆ្លងនូវវិសត្តិកាតណ្ហា ក្នុងលោក សេចក្តីថា តណ្ហា លោកហៅថា វិសត្តិកា បានខាងតម្រេក តម្រេកដ៏មានកម្លាំង ។បេ។ អភិជ្ឈា លោភៈ អកុសលមូល ។ សំណួរត្រង់ពាក្យថា វិសត្តិកា ចុះវិសត្តិកា ដោយអត្ថដូចម្តេច ។ បេ ។ ឈ្មោះ វិសត្តិកា ព្រោះហេតុជាធម្មជាតលាតផ្សាយទៅ ។ ពាក្យថា ក្នុងលោក គឺក្នុងអបាយលោក ។បេ។ អាយតនលោក ។ ពាក្យថា ឈ្មោះថា ឆ្លងនូវវិសត្តិកាតណ្ហា ក្នុងលោក គឺតណ្ហាណា ឈ្មោះវិសត្តិកា ក្នុងលោក ជនទាំងឡាយ បានឆ្លង

ធ្លងឡើង ធ្លងចេញ កន្លង រំលង ប្រព្រឹត្តកន្លង នូវតណ្ហាឈ្មោះវិសត្តិកា នោះ ក្នុងលោក ហេតុនោះ ( ទ្រង់ត្រាស់ថា ) ធ្លងនូវវិសត្តិកាតណ្ហា ក្នុង លោក ហេតុនោះ ព្រះមានព្រះភាគ ទ្រង់ត្រាស់ថា

ជនទាំងឡាយណា ដឹងនិព្វានទុំ ជាអ្នកមានសតិ មានធម៌ឃើញ ហើយ រលត់កិលេសហើយ ជនទាំងនោះ ជាអ្នកស្ងប់រម្ងាប់ សព្វកាល ឈ្មោះថា ធ្លងនូវវិសត្តិកាតណ្ហា ក្នុងលោកបាន ។

លុះចប់គាថាហើយ ។បេ។ ( ហេមកៈមាណពប្រកាសខ្លួនថា ) បពិត្រព្រះអង្គដ៏ចម្រើន ព្រះមានព្រះភាគជាសាស្ដារបស់ខ្ញុំព្រះអង្គ ខ្ញុំព្រះអង្គ ជាសាវ័ក ។

## ហេមកមាណវកបញ្ហានិទ្ទេសទី ៨ ចប់

# អដ្ឋកថា

## ហេមកមាណវកប្បញ្ហានិទ្ទេស

[ ៣២០ ] គប្បីជ្រាបវិនិច្ឆ័យក្នុងហេមកសូត្រទី ៨ ដូចតទៅ

បទថា **យេមេ បុព្វេ វិយាកំសុ** សេចក្តីថា ក្នុងកាលមុន ពាវរីព្រាហ្មណ៍ជាដើម ព្យាករលទ្ធិរបស់ខ្លួនដល់ខ្ញុំព្រះអង្គ ។ បទថា **ហុរំ គោតមសាសនា** បានដល់ មុនអំពីសាសនារបស់ព្រះគោតម ។ បទថា **សព្វន្តំ តក្កវឌ្ឍនំ** បានដល់ ពាក្យទាំងអស់នោះ ជាគ្រឿងញុំាងវិតក្ក មានកាមវិតក្កជាដើមឲ្យចម្រើន ។

[ ៣២១ ] បទថា **យេ ចញ្ញេ តស្ស អាចរិយា** សេចក្តីថា អាចារ្យដទៃឲ្យពាវរីព្រាហ្មណ៍នោះ សិក្សាដល់មារយាទ ។ បទថា **តេ សកំ ទិដ្ឋឹ** សេចក្តីថា អាចារ្យទាំងនោះប្រាប់ដល់ទិដ្ឋិរៀងៗ ខ្លួន ។ បទថា **សកំ ខន្តឹ** បានដល់ ការអត់ធន់របស់ខ្លួន ។ បទថា **សកំ រុចឹ** បានដល់ ការពេញចិត្តរបស់ខ្លួន ។

[ ៣២៥ ] បទថា **វិតក្កវឌ្ឍនំ** បានដល់ ញុំាងវិតក្ក មានកាមវិតក្កជាដើមឲ្យកើតឡើង គឺឲ្យប្រព្រឹត្តទៅរឿយៗ ។ បទថា **សង្កប្បវឌ្ឍនំ** បានដល់ ញុំាងតម្រិះ មានការត្រិះរិះដល់កាមជាដើមឲ្យចម្រើន ។ ២ បទនេះលោកពោលរួមវិតក្កទាំងអស់ ។

ឥឡូវនេះ ព្រះមានព្រះភាគ ដើម្បីទ្រង់សម្តែងដល់កាមវិតក្កជាដើមដោយសរុប ទើបទ្រង់សម្តែងវិតក្កទាំង ៩ យ៉ាង ដោយន័យជាដើមថា **កាមវិតក្កវឌ្ឍនំ** ដូច្នេះ ។

[ ៣២៧ ] បទថា **តណ្ហានិគ្ឃាតនំ** បានដល់ ជាគ្រឿងញ៉ាំងតណ្ហាឲ្យវិនាស ។

[ ៣៣២-៣៣៩ ] លំដាប់នោះ ព្រះមានព្រះភាគ កាលទ្រង់ប្រាប់ធម៌នោះ ដល់ហេមកមាណពនោះ ទើបត្រាស់ ២ គាថាថា **៩៥** ដូច្នេះជាដើម ។ ក្នុងបទទាំងនោះ បទថា **ឯតទញ្ញាយ យេ សតា** សេចក្ដីថា ព្រះខីណាស្រពពួកណា ឃើញច្បាស់ដល់បទនិព្វាននោះ ដែលជាទីមិនចុតិហើយ ដោយន័យជាដើមថា **សព្វេ សង្ខារា អនិច្ចា** សង្ខារទាំងឡាយមិនទៀងជាដើម ដឹងហើយដោយលំដាប់ ជាអ្នកមានសតិ ដោយកាយានុបស្សនាសតិប្បដ្ឋានជាដើម ។ បទថា **ទិដ្ឋធម្មាភិនិព្វុតា** សេចក្ដីថា ឈ្មោះថា **ទិដ្ឋធម្មា** ព្រោះជាអ្នកដឹងច្បាស់នូវធម៌ និងឈ្មោះថា **អភិនិព្វុតា** ព្រោះរលត់កិលេស មានរាគៈជាដើម ។ បទដ៏សេសក្នុងបទទាំងពួង ជាក់ច្បាស់ហើយ ។

ព្រះមានព្រះភាគ ទ្រង់សម្ដែងព្រះសូត្រនេះដោយធម៌ដ៏កំពូល គឺអរហត្តដោយប្រការដូច្នេះ ។

ម្យ៉ាងទៀត កាលចប់ទេសនា សត្វដែលសម្រេចធម៌ ដូចគ្នាតាមដែលពោលហើយ ក្នុងកាលនោះឯង ។៚

**អដ្ឋកថា ហេមកមាណវសុត្តនិទ្ទេសទី ៨ ចប់**

# សុត្តន្តបិដក

## តោទេយ្យមាណវកបញ្ហានិទ្ទេស

[ ៣៨២ ] ( តោទេយ្យមានអាយុទូលសួរដូច្នេះថា ) កាមទាំងឡាយ មិនមាននៅក្នុងបុគ្គលណា តណ្ហារបស់បុគ្គលណា មិនមាន មួយទៀត បុគ្គលណា ឆ្លងសេចក្ដីសង្ស័យបានហើយ វិមោក្ខធម៌របស់បុគ្គលនោះ តើដូចម្ដេចទៅ ។

[ ៣៨៣ ] ពាក្យថា កាមទាំងឡាយ មិនមាននៅក្នុងបុគ្គលណា គឺកាមទាំងឡាយ មិនមាននៅ មិននៅព្រម មិននៅទូទៅក្នុងបុគ្គលណា ។ ពាក្យថា ដូច្នេះ របស់បទថា តោទេយ្យមានអាយុ ពោលដូច្នេះ ជាតំណបទ ។បេ។ បទថា ដូច្នេះ នេះ ជាលំដាប់បទ ពាក្យថា មានអាយុ គឺពាក្យជាទីស្រឡាញ់ ជាពាក្យគោរព ពាក្យថា មានអាយុនេះ ជាពាក្យពោលដោយសេចក្ដីគោរពកោតខ្លាច ។ ពាក្យថា តោទេយ្យ ជាឈ្មោះរបស់ព្រាហ្មណ៍នោះ ។បេ។ ជាពាក្យសម្រាប់ហៅព្រាហ្មណ៍នោះ ហេតុនោះ ( មានពាក្យថា ) តោទេយ្យមានអាយុ ទូលសួរដូច្នេះ ។

[ ៣៨៤ ] ពាក្យថា តណ្ហារបស់បុគ្គលណា មិនមាន គឺតណ្ហានៃបុគ្គលណា មិនមាន មិនមានព្រម មិនកើតមាន គឺបុគ្គលណា លះបង់ រម្ងាប់ ឲ្យស្ងប់រម្ងាប់ ធ្វើមិនគួរឲ្យកើតឡើងបាន ដុតដោយភ្លើង គឺញាណហើយ ហេតុនោះ ( លោកពោលថា ) តណ្ហារបស់បុគ្គលណា មិនមាន ។

[ ៣៨៥ ] ពាក្យថា មួយទៀត បុគ្គលណា ឆ្លងសេចក្ដីសង្ស័យបាន គឺ មួយទៀត បុគ្គលណា ឆ្លង ឆ្លងឡើង ឆ្លងចេញ កន្លង រំលង ប្រព្រឹត្តកន្លង

សេចក្តីសង្ស័យបាន ហេតុនោះ ( លោកពោលថា ) មួយទៀត បុគ្គលណា ឆ្លងសេចក្តីសង្ស័យបានហើយ ។

[ ៣៤៦ ] ពាក្យថា វិមោក្ខធម៌ របស់បុគ្គលនោះ តើដូចម្តេច គឺ តោទេយ្យមាណពសួរវិមោក្ខធម៌ថា វិមោក្ខធម៌របស់បុគ្គលនោះ ដូចម្តេចទៅ តាំងនៅដូចម្តេច មានប្រការដូចម្តេច មានចំណែកប្រៀបដូចម្តេចដែលបុគ្គល គប្បីប្រាថ្នា ហេតុនោះ ( លោកពោលថា ) វិមោក្ខធម៌ របស់បុគ្គលនោះ តើដូចម្តេចទៅ ។ ហេតុនោះ ព្រាហ្មណ៍នោះពោលថា

( តោទេយ្យមានអាយុទូលសួរដូច្នេះថា ) កាមទាំងឡាយ មិន
មាននៅក្នុងបុគ្គលណា តណ្ហារបស់បុគ្គលណា មិនមាន មួយ
ទៀត បុគ្គលណា ឆ្លងសេចក្តីសង្ស័យបានហើយ វិមោក្ខធម៌
របស់បុគ្គលនោះ តើដូចម្តេចទៅ ។

[ ៣៤៧ ] ( ព្រះមានព្រះភាគ ទ្រង់ត្រាស់ថា ម្នាលតោទេយ្យ )
កាមទាំងឡាយ មិនមាននៅក្នុងបុគ្គលណា តណ្ហារបស់បុគ្គល
ណា មិនមាន មួយទៀត បុគ្គលណា ឆ្លងសេចក្តីសង្ស័យបាន
ហើយ វិមោក្ខធម៌របស់បុគ្គលនោះ មិនមែនទៅជាដទៃទេ ។

[ ៣៤៨ ] ពាក្យថា កាមទាំងឡាយ មិនមាននៅក្នុងបុគ្គលណា ត្រង់ ពាក្យថា ក្នុងបុគ្គលណា គឺក្នុងព្រះអរហន្តខីណាស្រព ។ ពាក្យថា កាមទាំង ឡាយ តាមឧទ្ទាន កាមមាន ២ គឺវត្ថុកាម ១ កិលេសកាម ១ ។បេ។ នេះ វត្ថុកាម ។បេ។ នេះ កិលេសកាម ។ ពាក្យថា មិនមាននៅ គឺកាមទាំង

ឡាយ មិននៅ មិននៅព្រម មិននៅទូទៅ ក្នុងបុគ្គលណា ហេតុនោះ ( ទ្រង់ត្រាស់ថា ) កាមទាំងឡាយ មិនមាននៅក្នុងបុគ្គលណា ។ ពាក្យថា តោទេយ្យ របស់បទថា ព្រះមានព្រះភាគត្រាស់ថា ម្នាលតោទេយ្យ គឺព្រះមានព្រះភាគត្រាស់ហៅព្រាហ្មណ៍នោះតាមឈ្មោះ ។ ពាក្យថា ព្រះមានព្រះភាគនេះ ជាពាក្យពោលដោយគោរព ។បេ។ ការបញ្ញត្តិថា ព្រះមានព្រះភាគនេះ ( កើត ) ព្រោះការត្រាស់ដឹង ហេតុនោះ ( មានពាក្យថា ) ព្រះមានព្រះភាគត្រាស់ថា ម្នាលតោទេយ្យ ។

[ ៣៤៩ ] ពាក្យថា តណ្ហា របស់បុគ្គលណា មិនមាន ត្រង់ពាក្យថា តណ្ហា បានដល់ រូបតណ្ហា សទ្ទតណ្ហា គន្ធតណ្ហា រសតណ្ហា ផោដ្ឋព្វតណ្ហា ធម្មតណ្ហា ។ ពាក្យថា របស់បុគ្គលណា គឺរបស់ព្រះអរហន្តខីណាស្រព ។ ពាក្យថា តណ្ហា របស់បុគ្គលណាមិនមាន គឺតណ្ហានៃបុគ្គលណាមិនមាន មិនមានព្រម មិនកើតមាន គឺបុគ្គលណា លះបង់ រម្ងាប់ ឲ្យស្ងប់រម្ងាប់ ធ្វើមិនគួរឲ្យកើតឡើងបាន ដុតដោយភ្លើង គឺញាណហើយ ហេតុនោះ ( ទ្រង់ត្រាស់ថា ) តណ្ហារបស់បុគ្គលណា មិនមាន ។

[ ៣៥០ ] ពាក្យថា មួយទៀត បុគ្គលណា ឆ្លងសេចក្តីសង្ស័យបាន សេចក្តីថា វិចិកិច្ឆា លោកហៅថា សេចក្តីសង្ស័យ គឺសេចក្តីងឿងឆ្ងល់ ក្នុងទុក្ខ ។បេ។ ភាពនៃចិត្តញាប់ញ័រ ការស្ទាក់ស្ទើរនៃចិត្ត ។ ពាក្យថា ណា គឺព្រះខីណាស្រពណា ។ ពាក្យថា មួយទៀត បុគ្គលណា ឆ្លងសេចក្តីសង្ស័យបាន បានន័យថា មួយទៀត បុគ្គលណា ឆ្លង ឆ្លងឡើង ឆ្លងចេញ

កន្ទួង រំលង ប្រព្រឹត្តកន្ទួង នូវសេចក្តីសង្ស័យ ហេតុនោះ ( ទ្រង់ត្រាស់ថា ) មួយទៀត បុគ្គលណា ឆ្លងសេចក្តីសង្ស័យបាន ។

[ ៣៥១ ] ពាក្យថា វិមោក្ខធម៌របស់បុគ្គលនោះ មិនមែនទៅជាដទៃទេ គឺវិមោក្ខធម៌ដទៃ របស់បុគ្គលនោះ មិនមាន បុគ្គលគប្បីរួចដោយវិមោក្ខណា កិច្ចដែលបុគ្គលនោះ គប្បីធ្វើដោយវិមោក្ខនោះដូចម្តេចកើត ហេតុនោះ ( ទ្រង់ត្រាស់ថា ) វិមោក្ខធម៌របស់បុគ្គលនោះ មិនមែនទៅជាដទៃទេ ហេតុនោះ ព្រះមានព្រះភាគត្រាស់ថា

( ព្រះមានព្រះភាគត្រាស់ថា ម្នាលតោទេយ្យ ) កាមទាំងឡាយ មិនមាននៅក្នុងបុគ្គលណា តណ្ហារបស់បុគ្គលណា មិនមាន មួយទៀត បុគ្គលណា ឆ្លងសេចក្តីសង្ស័យបាន វិមោក្ខធម៌របស់បុគ្គលនោះ មិនមែនទៅជាដទៃទេ ។

[ ៣៥២ ] ( តោទេយ្យព្រាហ្មណ៍ទូលសួរថា ) បុគ្គលនោះ ជាអ្នកមិនមានសេចក្តីប្រាថ្នាទេ ឬនៅមានសេចក្តីប្រាថ្នា បុគ្គលនោះ មានបញ្ញា ឬមានការកំណត់ដោយបញ្ញា បពិត្រព្រះសក្កៈ ខ្ញុំព្រះអង្គគប្បីស្គាល់នូវមុនិណា បពិត្រព្រះអង្គជាសមន្តចក្ខុ សូមព្រះអង្គត្រាស់ប្រាប់មុនិនោះ ដល់ខ្ញុំព្រះអង្គ ។

[ ៣៥៣ ] ពាក្យថា បុគ្គលនោះ ជាអ្នកមិនមានសេចក្តីប្រាថ្នាទេ ឬនៅមានសេចក្តីប្រាថ្នា គឺបុគ្គលនោះ មិនមានតណ្ហាទេ ឬប្រកបដោយតណ្ហា គឺប៉ងនូវរូប នឹកប៉ង ចង់បាន ត្រេកអរ ប្រាថ្នា ស្រឡាញ់ ជាប់ចិត្ត នូវសំឡេង

ក្លិន រស ផស្សព្វ ត្រកូល ពួក អាវាស លាភ យស សេចក្ដីសរសើរ សុខ ចីវរ បិណ្ឌបាត សេនាសនៈ និងគិលានប្បច្ចយភេសជ្ជបរិក្ខារ កាមធាតុ រូបធាតុ អរូបធាតុ កាមភព រូបភព អរូបភព សញ្ញាភព អសញ្ញាភព នេវសញ្ញានាសញ្ញាភព ឯកវោការភព ចតុវោការភព បញ្ចវោការភព អតីត អនាគត បច្ចុប្បន្ន អារម្មណ៍ដែលឃើញ ឮ ប៉ះពាល់ ឬដឹងច្បាស់ ហេតុនោះ ( លោកសួរថា ) បុគ្គលនោះ ជាអ្នកមិនមានសេចក្ដីប្រាថ្នាទេ ឬនៅមានសេចក្ដីប្រាថ្នា ។

[ ៣៥៤ ] ពាក្យថា បុគ្គលនោះមានបញ្ញា ឬមានការកំណត់ដឹងដោយបញ្ញា ត្រង់ពាក្យថា បុគ្គលនោះមានបញ្ញា គឺបុគ្គលនោះជាបណ្ឌិត មានប្រាជ្ញា មានប្រាជ្ញាជាគ្រឿងត្រាស់ដឹង មានញាណ មានប្រាជ្ញាភ្លឺច្បាស់ មានប្រាជ្ញាជាគ្រឿងទម្លាយកិលេស ។ ពាក្យថា ឬមានការកំណត់ដោយបញ្ញា គឺកំណត់ បង្កើត បង្កើតព្រម បង្កើត បង្កើតចំពោះ នូវតណ្ហាកប្បៈ ឬទិដ្ឋិកប្បៈ ដោយញាណដែលប្រកបដោយសមាបត្តិ ៨ ក្ដី ដោយញាណដែលប្រកបដោយអភិញ្ញា ៥ ក្ដី ដោយមិច្ឆាញាណក្ដី ហេតុនោះ ( លោកសួរថា ) បុគ្គលនោះ មានបញ្ញា ឬមានការកំណត់ដោយបញ្ញា ។

[ ៣៥៥ ] ពាក្យថា បពិត្រព្រះសក្កៈ ខ្ញុំព្រះអង្គគប្បីស្គាល់នូវមុនិណា ត្រង់ពាក្យថា ព្រះសក្កៈ បានដល់ ព្រះមានព្រះភាគជាសក្កៈ ។ម្យ៉ាងទៀត ព្រះនាមថា សក្កៈ ព្រោះហេតុទ្រង់ចេញចាកសាក្យត្រកូលមកបួសក៏បាន ។ ឬថា ព្រះនាមជាសក្កៈ ព្រោះទ្រង់ស្ដុកស្ដម្ភ មានទ្រព្យច្រើន មានទ្រព្យ

ក៏បាន ។ ទ្រព្យទាំងនេះ របស់ព្រះមានព្រះភាគនោះគឺ ទ្រព្យ គឺសទ្ធា ទ្រព្យ គឺសីល ទ្រព្យ គឺហិរិ ទ្រព្យ គឺឱត្តប្បៈ ទ្រព្យ គឺសុតៈ ទ្រព្យ គឺចាគៈ ទ្រព្យ គឺបញ្ញា ទ្រព្យ គឺសតិប្បដ្ឋាន ទ្រព្យ គឺសម្មប្បធាន ទ្រព្យ គឺឥទ្ធិបាទ ទ្រព្យ គឺឥន្ទ្រិយ ទ្រព្យ គឺពល ទ្រព្យ គឺពោជ្ឈង្គ ទ្រព្យ គឺមគ្គ ទ្រព្យ គឺផល ទ្រព្យ គឺនិព្វាន ។ ព្រះនាមថា សក្កៈ ព្រោះហេតុទ្រង់ស្ដុកស្ដម្ភ មានទ្រព្យច្រើន មានទ្រព្យដោយរតនៈ ទ្រព្យទាំងនោះ មានប្រការជាអនេកក៏បាន ។ ឬថា ព្រះនាមថា សក្កៈ ព្រោះហេតុមានព្យាយាមច្រើន មានចិត្តអង់អាចក្លៀវក្លា ប្រកបដោយព្យាយាម មានព្យាយាមមោះមុត មិនខ្លាច មិនព្រឺរោម មិនតក់ស្លុត មិនរត់ មានភ័យគួរខ្លាចលះបង់ហើយ ប្រាសចាកការព្រឺរោមក៏បាន ។ ពាក្យថា បពិត្រព្រះអង្គជាសក្កៈ ខ្ញុំព្រះអង្គគប្បីដឹងនូវមុនិណា គឺ បពិត្រព្រះអង្គជាសក្កៈ ខ្ញុំព្រះអង្គគប្បីដឹង គប្បីដឹងច្បាស់ គប្បីដឹងចំពោះ គប្បីចាក់ធ្លុះនូវមុនិណា ហេតុនោះ ( លោកសួរថា ) បពិត្រព្រះសក្កៈ ខ្ញុំព្រះអង្គ គប្បីស្គាល់នូវមុនិណា ។

[ ៣៥៦ ] ពាក្យថា បពិត្រព្រះអង្គជាសមន្តចក្ខុ សូមព្រះអង្គត្រាស់ប្រាប់នូវមុនិនោះ ដល់ខ្ញុំព្រះអង្គ ត្រង់ពាក្យថា មុនិនោះ គឺខ្ញុំសួរនូវមុនិណា អង្វរមុនិណា អារាធនាមុនិណា ជណ្ដឹងនូវមុនិណា ។ ពាក្យថា សូមត្រាស់ប្រាប់ គឺសូមប្រាប់ សម្ដែង បញ្ញត្ត តាំងទុក បើក ចែក ធ្វើឲ្យងាយ ប្រកាស ។ ពាក្យថា សមន្តចក្ខុ សេចក្ដីថា សព្វញ្ញុតញ្ញាណ លោកហៅថា សមន្តចក្ខុ ។បេ។ ព្រះតថាគត ទ្រង់ព្រះនាមសមន្តចក្ខុ ដោយហេតុនោះ

ហេតុនោះ ( លោកសួរថា ) បពិត្រព្រះអង្គជាសមន្តចក្ខុ សូមព្រះអង្គត្រាស់ប្រាប់នូវមុនិនោះ ដល់ខ្ញុំព្រះអង្គ ។ ហេតុនោះ ព្រាហ្មណ៍នោះទូលសួរថា

បុគ្គលនោះ ជាអ្នកមិនមានសេចក្តីប្រាថ្នាទេ ឬនៅមានសេចក្តីប្រាថ្នា បុគ្គលនោះ មានបញ្ញា ឬមានការកំណត់ដោយបញ្ញា បពិត្រព្រះសក្កៈ ខ្ញុំព្រះអង្គគប្បីស្គាល់នូវមុនិណា បពិត្រព្រះអង្គ ជាសមន្តចក្ខុ សូមព្រះអង្គត្រាស់ប្រាប់នូវមុនិនោះ ដល់ខ្ញុំព្រះអង្គ ។

[ ៣៥៧ ] ( ព្រះមានព្រះភាគត្រាស់ថា ) បុគ្គលនោះ ជាអ្នកមិនមានសេចក្តីប្រាថ្នា ទាំងមិនប្រកបដោយសេចក្តីប្រាថ្នាទេ បុគ្គលនោះ ជាអ្នកមានបញ្ញា ទាំងមិនមានការកំណត់ដោយបញ្ញាទេ ម្នាលតោទេយ្យ អ្នកចូរស្គាល់នូវបុគ្គលនោះ ថាជាមុនិ ជាអ្នកមិនមានកង្វល់ មិនជាប់នៅក្នុងកាម និងភពយ៉ាងនេះចុះ ។

[ ៣៥៨ ] ពាក្យថា បុគ្គលនោះ ជាអ្នកមិនមានសេចក្តីប្រាថ្នា ទាំងមិនប្រកបដោយសេចក្តីប្រាថ្នាទេ គឺបុគ្គលនោះ ជាអ្នកមិនមានតណ្ហា មិនប្រកបដោយតណ្ហា គឺមិនប៉ងចំពោះនូវរូប សទ្ទៈ គន្ធៈ ។បេ។ មិនប៉ង មិនចង់បាន មិនត្រេកអរ មិនប្រាថ្នា មិនស្រឡាញ់ មិនជាប់ចិត្ត នូវអារម្មណ៍ដែលឃើញ ឮ ប៉ះពាល់ ឬដឹងច្បាស់ ហេតុនោះ ( ទ្រង់ត្រាស់ថា ) បុគ្គលនោះ ជាអ្នកមិនមានសេចក្តីប្រាថ្នា ទាំងមិនប្រកបដោយសេចក្តីប្រាថ្នាទេ ។

[ ៣៥៩ ] ពាក្យថា បុគ្គលនោះ ជាអ្នកមានបញ្ញា ទាំងមិនមានការ

កំណាត់ដោយបញ្ញា ត្រង់ពាក្យថា បុគ្គលនោះ ជាអ្នកមានបញ្ញា គឺជាបណ្ឌិត មានប្រាជ្ញា មានប្រាជ្ញាជាគ្រឿងត្រាស់ដឹង មានញាណ មានប្រាជ្ញាភ្លឺច្បាស់ មានប្រាជ្ញាជាគ្រឿងទម្លាយបង់នូវកិលេស ។ ពាក្យថា ទាំងមិនមានការកំណាត់ដោយបញ្ញា គឺមិនកំណាត់ មិនបង្កើត មិនបង្កើតព្រម មិនបង្កើត មិនបង្កើតចំពោះ នូវតណ្ហាកប្បៈ ឬទិដ្ឋិកប្បៈ ដោយញាណប្រកបដោយសមាបត្តិ ៨ ក្តី ដោយញាណ គឺអភិញ្ញា ៥ ក្តី ដោយមិច្ឆាញាណក្តី ហេតុនោះ ( ទ្រង់ត្រាស់ថា ) បុគ្គលនោះជាអ្នកមានបញ្ញា ទាំងមិនមានការកំណាត់ដោយបញ្ញា ។

[ ៣៦០ ] ពាក្យថា មុនិ របស់បទថា ម្នាលតោទេយ្យ អ្នកចូរស្គាល់នូវបុគ្គលនោះ ថាជាមុនិ យ៉ាងនេះចុះ ត្រង់ពាក្យថា មុនិ សេចក្តីថា ញាណលោកហៅថា មោនៈ ។បេ។ មុនិនោះ កន្លងហើយនូវបណ្តាញ គឺកិលេសជាគ្រឿងជាប់ជំពាក់ ។ ពាក្យថា ម្នាលតោទេយ្យ អ្នកចូរស្គាល់នូវបុគ្គលនោះ ថាជាមុនិយ៉ាងនេះចុះ បានសេចក្តីថា ម្នាលតោទេយ្យ អ្នកចូរដឹង ចូរដឹងច្បាស់ ចូរដឹងចំពោះ នូវបុគ្គលនោះ ថាជាមុនិ យ៉ាងនេះចុះ ហេតុនោះ ( ទ្រង់ត្រាស់ថា ) ម្នាលតោទេយ្យ អ្នកចូរស្គាល់នូវបុគ្គលនោះ ថាជាមុនិយ៉ាងនេះចុះ ។

[ ៣៦១ ] អធិប្បាយពាក្យថា ជាអ្នកមិនមានកង្វល់ មិនជាប់នៅក្នុងកាម និងភព ត្រង់ពាក្យថា ជាអ្នកមិនមានកង្វល់ សេចក្តីថា កង្វល់ គឺរាគៈ កង្វល់ គឺទោសៈ កង្វល់ គឺមោហៈ កង្វល់ គឺមានះកង្វល់ គឺទិដ្ឋិ កង្វល់ គឺកិលេស កង្វល់ គឺទុច្ចរិត កង្វល់ទាំងនោះ បុគ្គលណាបានលះបង់ ផ្តាច់បង់

រម្ងាប់ ឲ្យរម្ងាប់ ធ្វើមិនគួរឲ្យកើតឡើងបាន ដុតដោយភ្លើង គឺញាណហើយ បុគ្គលនោះ លោកហៅថា អ្នកមិនមានកន្លល់ ពាក្យថា កាមទាំងឡាយ របស់បទថា ក្នុងកាម និងភព តាមឧទ្ទាន កាមមាន ២ គឺវត្ថុកាម ១ កិលេសកាម ១ ។បេ។ ទាំងនេះ លោកហៅថា វត្ថុកាម ។បេ។ ទាំងនេះ លោកហៅថា កិលេសកាម ។ ពាក្យថា ភព បានដល់ ភព ២ គឺកម្មភព ១ បុនព្ភព គឺបដិសន្ធិ ១ ។បេ។ នេះ បុនព្ភព គឺបដិសន្ធិ ។ ពាក្យថា ជាអ្នកមិនមានកន្លល់ មិនជាប់នៅក្នុងកាម និងភព បានសេចក្តីថា មិនមានកន្លល់ មិនជាប់ មិនជំពាក់ មិនជាប់ជំពាក់ មិនខ្វល់នៅ គឺជាអ្នកចេញទៅ រលាស់ចោល រួចស្រឡះ មិនប្រកបក្នុងកាមផង ក្នុងភពផង នៅដោយចិត្ត ដែលប្រាសចាកដែន គឺកិលេស ហេតុនោះ ( ទ្រង់ត្រាស់ថា ) មិនមានកន្លល់ មិនជាប់នៅ ក្នុងកាម និងភព ។ ហេតុនោះ ព្រះមានព្រះភាគត្រាស់ថា

បុគ្គលនោះ ជាអ្នកមិនមានសេចក្តីប្រាថ្នា ទាំងមិនប្រកបដោយ
សេចក្តីប្រាថ្នាទេ បុគ្គលនោះ ជាអ្នកមានបញ្ញា ទាំងមិនមានការ
កំណត់ដោយបញ្ញាទេ ម្នាលតោទេយ្យ អ្នកចូរស្គាល់នូវបុគ្គល
នោះ ថាជាមុនិ ជាអ្នកមិនមានកន្លល់ មិនជាប់នៅក្នុងកាម និង
ភព យ៉ាងនេះចុះ ។

លុះចប់គាថាហើយ ។បេ។ បពិត្រព្រះអង្គដ៏ចម្រើន ព្រះមានព្រះភាគ ជាសាស្តារបស់ខ្ញុំព្រះអង្គ ខ្ញុំព្រះអង្គជាសាវ័ក ។

តោទេយ្យមាណវកបញ្ហានិទ្ទេស ចប់

# អដ្ឋកថា

## តោទេយ្យមាណវកបញ្ហានិទ្ទេស

[ ៣៤២ ] គប្បីជ្រាបវិនិច្ឆ័យក្នុងតោទេយ្យសូត្រទី ៩ ដូចតទៅ

បទថា **វិមោក្ខោ តស្ស កីទិសោ** សេចក្តីថា តោទេយ្យមាណពទូលសួរថា វិមោក្ខធម៌របស់បុគ្គលនោះ តើដូចម្តេចទៅ ។

[ ៣៤៧ ] ឥឡូវនេះ ព្រះមានព្រះភាគ កាលទ្រង់សម្តែងការមិនមានវិមោក្ខដទៃ ដល់តោទេយ្យមាណពនោះ ទើបត្រាស់គាថាទី ២ ។ ក្នុងបទទាំងនោះ បទថា **វិមោក្ខោ តស្ស នាបរោ** សេចក្តីថា វិមោក្ខដទៃរបស់បុគ្គលនោះ មិនមាន ។

[ ៣៥២ ] កាលព្រះមានព្រះភាគត្រាស់យ៉ាងនេះថា ការអស់តណ្ហានោះឯងជាវិមោក្ខ តោទេយ្យមាណព ក៏មិនបានយល់សេចក្តីនោះ ទើបទូលសួរទៀតថា **និរាសសោ សោ ឧទ អាសសានោ** ដូច្នេះ ។ ក្នុងបទទាំងនោះ បទថា **ឧទ បញ្ញកប្បី** សេចក្តីថា ឬថា កកើតតណ្ហា ឬទិដ្ឋិ ដោយញាណមានសមាបត្តិញាណជាដើម ។

[ ៣៥៧ ] លំដាប់នោះ ព្រះមានព្រះភាគ កាលទ្រង់ប្រាប់សេចក្តីនោះដល់តោទេយ្យមាណពនោះ ទើបពោលគាថាទី ៤ ។ ក្នុងបទទាំងនោះ បទថា **កាមភវេ** បានដល់ ក្នុងកាម និងក្នុងភព ។

[ ៣៥៨ ] បទថា **រូបេ នាសីសតិ** សេចក្តីថា មិនប្រាថ្នាក្នុងរូបារម្មណ៍ ដែលមានសមុដ្ឋាន ៤ ដោយអំណាចនៃធនូរាគៈ ។ ក្នុងសំឡេងជាដើម ក៏មានន័យនេះដូចគ្នា ។

[ ៣៦១ ] គ្រឿងកង្វល់ គឺរាគៈ ព្រោះអត្ថថា សាំញ៉ាំ ព្រោះអត្ថថា ស្រវឹង ឈ្មោះថា **រាគកិញ្ចនំ** ។ ក្នុងបទថា **ទោសកិញ្ចនំ** ជាដើម ក៏មានន័យដូចគ្នា ។ បទដ៏សេសក្នុងទីទាំងពួង ជាក់ច្បាស់ល្អហើយ ។

ព្រះមានព្រះភាគ ទ្រង់សម្តែងសូត្រនេះ ដោយធម៌កំពូល គឺអរហត្ត ម្យ៉ាងទៀត កាលចប់ទេសនា មានបុគ្គលសម្រេចធម៌ ដូចក្នុងសូត្រមុន នោះឯង ៕

**អដ្ឋកថា តោទេយ្យមាណវសុត្តនិទ្ទេសទី ៩ ចប់**

# សុត្តន្តបិដក

## កប្បមាណវកប្បញ្ហានិទ្ទេស

[ ៣៦២ ] ( កប្បមាណពមានអាយុ ទូលសួរដូច្នេះថា ) បពិត្រព្រះអង្គនិរទុក្ខ សូមព្រះអង្គត្រាស់ប្រាប់នូវទីពឹង របស់ពួកសត្វអ្នកស្ថិតនៅក្នុងកណ្តាលនៃស្រះ ដែលត្រូវជរា និងមច្ចុ គ្របសង្កត់ ព្រោះឱឃៈជាភ័យធំកើតឡើងហើយ ចុះសេចក្តីទុក្ខ ( ក្នុងស្រះ ) នេះ មិនគប្បីមានតទៅទៀត ដោយប្រការណា សូមព្រះអង្គប្រាប់នូវទីពឹងដល់ខ្ញុំព្រះអង្គ ដោយប្រការនោះ ។

[ ៣៦៣ ] ពាក្យថា អ្នកស្ថិតនៅក្នុងកណ្តាលនៃស្រះ អធិប្បាយថា សង្សារ លោកហៅថា ស្រះ បានដល់ ដំណើរមក ដំណើរទៅ ដំណើរទៅនិងមក កាលៈ គតិ ភពតូចធំ ការច្យុតិផង ការចាប់កំណើតផង ការកើតផង ការបែកធ្លាយផង ជាតិផង ជរាផង មរណៈផង ។ ទីបំផុតខាងដើមនៃសង្សារ មិនប្រាកដ ទាំងទីបំផុតខាងចុង ក៏មិនប្រាកដ ។ ពួកសត្វដែលស្ថិតនៅ តាំងនៅ ជាប់ស្អិត នៅកុះករ ជ្រុលជ្រប់ ចុះស៊ប់ក្នុងសង្សារ តែត្រង់កណ្តាល ។ ទីបំផុតខាងដើមនៃសង្សារ មិនប្រាកដ តើដូចម្តេច ។ វដ្តៈវិលទៅមកអស់ជាតិទាំងឡាយប៉ុណ្ណេះ នឹងមិនវិលហួសអំពីនោះ ការដឹងយ៉ាងនេះ មិនមានទេ ទីបំផុតខាងដើមនៃសង្សារ មិនប្រាកដ យ៉ាងនេះខ្លះ ។ វដ្តៈវិលទៅហើយ អស់រយនៃជាតិប៉ុណ្ណេះ នឹងមិនវិលហួសអំពីនោះ ការដឹងយ៉ាងនេះ មិនមានទេ ទីបំផុតខាងដើមនៃសង្សារ មិនប្រាកដ យ៉ាងនេះខ្លះ ។ វដ្តៈវិលទៅហើយ អស់ពាន់នៃជាតិប៉ុណ្ណេះ នឹងមិនវិលហួសអំពីនោះ ការ

ដឹងយ៉ាងនេះ មិនមានទេ ទីបំផុតខាងដើមនៃសង្សារ មិនប្រាកដ យ៉ាងនេះខ្លះ ។ វដ្តៈវិលទៅហើយ អស់សែនកោដិនៃជាតិប៉ុណ្ណោះ នឹងមិនវិលហួសអំពីនោះ ការដឹងយ៉ាងនេះ មិនមានទេ ទីបំផុតខាងដើមនៃសង្សារ មិនប្រាកដ យ៉ាងនេះខ្លះ ។ វដ្តៈវិលទៅហើយ អស់រយកោដិនៃជាតិប៉ុណ្ណោះ នឹងមិនវិលហួសអំពីនោះ ការដឹងយ៉ាងនេះ មិនមានទេ ទីបំផុតខាងដើមនៃសង្សារ មិនប្រាកដយ៉ាងនេះខ្លះ ។ វដ្តៈវិលទៅហើយ អស់រយកោដិនៃជាតិប៉ុណ្ណោះ នឹងមិនវិលហួសអំពីនោះការដឹងយ៉ាងនេះមិនមានទេទីបំផុតខាងដើមនៃសង្សារមិនប្រាកដយ៉ាងនេះខ្លះ ។ វដ្តៈវិលទៅហើយ អស់សែនកោដិនៃជាតិប៉ុណ្ណោះ នឹងមិនវិលហួសអំពីនោះ ការដឹងយ៉ាងនេះ មិនមានទេ ទីបំផុតខាងដើមនៃសង្សារ មិនប្រាកដ យ៉ាងនេះខ្លះ ។ វដ្តៈវិលទៅហើយ អស់ឆ្នាំប៉ុណ្ណោះ នឹងមិនវិលហួសអំពីនោះ ការដឹងយ៉ាងនេះ មិនមានទេ ទីបំផុតខាងដើមនៃសង្សារ មិនប្រាកដ យ៉ាងនេះខ្លះ ។ វដ្តៈវិលទៅហើយ អស់រយនៃឆ្នាំប៉ុណ្ណោះ នឹងមិនវិលហួសអំពីនោះ ការដឹងយ៉ាងនេះ មិនមានទេ ទីបំផុតខាងដើមនៃសង្សារ មិនប្រាកដ យ៉ាងនេះខ្លះ ។ វដ្តៈវិលទៅហើយ អស់ពាន់នៃឆ្នាំប៉ុណ្ណោះ នឹងមិនវិលហួសអំពីនោះ ការដឹងយ៉ាងនេះ មិនមានទេ ទីបំផុតខាងដើមនៃសង្សារ មិនប្រាកដ យ៉ាងនេះខ្លះ ។ វដ្តៈវិលទៅហើយ អស់សែននៃឆ្នាំប៉ុណ្ណោះ នឹងមិនវិលហួសអំពីនោះ ការដឹងយ៉ាងនេះ មិនមានទេ ទីបំផុតខាងដើមនៃសង្សារ មិនប្រាកដ យ៉ាងនេះខ្លះ ។ វដ្តៈវិលទៅហើយ អស់កោដិនៃឆ្នាំប៉ុណ្ណោះ នឹងមិនវិលហួសអំពីនោះ ការដឹងយ៉ាងនេះ មិនមានទេ ទីបំផុតខាងដើមនៃសង្សារ

មិនប្រាកដ យ៉ាងនេះខ្ញុំ ។ វដ្តៈវិលទៅហើយ អស់រយកោដិនៃឆ្នាំប៉ុណ្ណោះ នឹងមិនវិលហួសអំពីនោះ ការដឹងយ៉ាងនេះ មិនមានទេ ទីបំផុតខាងដើមនៃសង្សារ មិនប្រាកដ យ៉ាងនេះខ្ញុំ ។ វដ្តៈវិលទៅហើយ អស់ពាន់កោដិនៃឆ្នាំប៉ុណ្ណោះ នឹងមិនវិលហួសអំពីនោះ ការដឹងយ៉ាងនេះ មិនមានទេ ទីបំផុតខាងដើមនៃសង្សារ មិនប្រាកដ យ៉ាងនេះខ្ញុំ ។ វដ្តៈវិលទៅហើយ អស់សែនកោដិនៃឆ្នាំប៉ុណ្ណោះ នឹងមិនវិលហួសអំពីនោះ ការដឹងយ៉ាងនេះ មិនមានទេ ទីបំផុតខាងដើមនៃសង្សារ មិនប្រាកដ យ៉ាងនេះខ្ញុំ ។ វដ្តៈវិលទៅហើយ អស់កប្បប៉ុណ្ណោះនឹងមិនវិលហួសអំពីនោះការដឹងយ៉ាងនេះមិនមានទេ ទីបំផុតខាងដើមនៃសង្សារ មិនប្រាកដ យ៉ាងនេះខ្ញុំ ។ វដ្តៈវិលទៅហើយ អស់រយនៃកប្បប៉ុណ្ណោះ នឹងមិនវិលហួសអំពីនោះ ការដឹងយ៉ាងនេះ មិនមានទេ ទីបំផុតខាងដើមនៃសង្សារ មិនប្រាកដ យ៉ាងនេះខ្ញុំ ។ វដ្តៈវិលទៅហើយ អស់ពាន់នៃកប្បប៉ុណ្ណោះ នឹងមិនវិលហួសអំពីនោះ ការដឹងយ៉ាងនេះ មិនមានទេ ទីបំផុតខាងដើមនៃសង្សារ មិនប្រាកដ យ៉ាងនេះខ្ញុំ ។ វដ្តៈវិលទៅហើយ អស់សែននៃកប្បប៉ុណ្ណោះ នឹងមិនវិលហួសអំពីនោះ ការដឹងយ៉ាងនេះ មិនមានទេ ទីបំផុតខាងដើមនៃសង្សារ មិនប្រាកដ យ៉ាងនេះខ្ញុំ ។ វដ្តៈវិលទៅហើយ អស់កោដិនៃកប្បប៉ុណ្ណោះ នឹងមិនវិលហួសអំពីនោះ ការដឹងយ៉ាងនេះ មិនមានទេ ទីបំផុតខាងដើមនៃសង្សារ មិនប្រាកដ យ៉ាងនេះខ្ញុំ ។ វដ្តៈវិលទៅហើយ អស់រយកោដិនៃកប្បប៉ុណ្ណោះ នឹងមិនវិលហួសអំពីនោះ ការដឹងយ៉ាងនេះ មិនមានទេ ទីបំផុតខាងដើមនៃសង្សារ មិនប្រាកដ យ៉ាងនេះខ្ញុំ ។ វដ្តៈវិលទៅ

ហើយ អស់ពាន់កោដិនៃបក្សប៉ុណ្ណេះ នឹងមិនវិលហួសអំពីនោះ ការដឹងយ៉ាងនេះ មិនមានទេ ទីបំផុតខាងដើមនៃសង្សារ មិនប្រាកដ យ៉ាងនេះខ្លះ ។ វដ្តៈវិលទៅហើយ អស់សែនកោដិនៃកប្បប៉ុណ្ណេះ នឹងមិនវិលហួសអំពីនោះ ការដឹងយ៉ាងនេះ មិនមានទេ ទីបំផុតខាងដើមនៃសង្សារមិនប្រាកដ យ៉ាងនេះខ្លះ ។

សមដូចពាក្យនេះ ដែលព្រះមានព្រះភាគត្រាស់ថា ម្នាលភិក្ខុទាំងឡាយ សង្សារនេះ មានទីបំផុតដឹងមិនបាន ទីបំផុតខាងដើមនៃសង្សារ មិនប្រាកដទេ ម្នាលភិក្ខុទាំងឡាយ ពួកសត្វដែលត្រូវអវិជ្ជាជាគ្រឿងរាំង មានតណ្ហាជាគ្រឿងប្រកបទុក រន្ធាត់ទៅ អន្ទោលទៅ ទទួលទុក្ខយ៉ាងខ្លាំង ជាគ្រឿងវិនាស ញុំាងព្រៃស្មសានឲ្យចម្រើន អស់កាលយូរយារយ៉ាងនេះឯង ម្នាលភិក្ខុទាំងឡាយ ព្រោះហេតុនោះ អ្នកទាំងឡាយ គួរតែនឿយណាយ គួរតែប្រាស គួរតែគេចចេញចាកសង្ខារទាំងពួង ។ ទីបំផុតខាងដើមនៃសង្សារ មិនប្រាកដ យ៉ាងនេះខ្លះ ។

ទីបំផុតខាងចុងនៃសង្សារ មិនប្រាកដ តើដូចម្តេច ។ វដ្តៈនឹងវិលទៅអស់ជាតិប៉ុណ្ណេះ នឹងមិនវិលហួសអំពីនោះ ការដឹងយ៉ាងនេះ មិនមានទេ ទីបំផុតខាងចុងនៃសង្សារ មិនប្រាកដ យ៉ាងនេះខ្លះ ។ វដ្តៈនឹងវិលទៅ អស់រយនៃជាតិប៉ុណ្ណេះ អស់ពាន់នៃជាតិប៉ុណ្ណេះ អស់សែននៃជាតិប៉ុណ្ណេះ ។បេ។ អស់កោដិនៃជាតិប៉ុណ្ណេះ អស់រយកោដិនៃជាតិប៉ុណ្ណេះ អស់ពាន់កោដិនៃជាតិប៉ុណ្ណេះ អស់សែនកោដិនៃជាតិប៉ុណ្ណេះ អស់ឆ្នាំប៉ុណ្ណេះ អស់រយនៃឆ្នាំប៉ុណ្ណេះ អស់ពាន់នៃឆ្នាំប៉ុណ្ណេះ អស់សែននៃឆ្នាំប៉ុណ្ណេះ អស់កោដិនៃឆ្នាំ

ប៉ុណ្ណេះ អស់រយកោដិនៃឆ្នាំប៉ុណ្ណេះ អស់ពាន់កោដិនៃឆ្នាំប៉ុណ្ណេះ អស់សែនកោដិនៃឆ្នាំប៉ុណ្ណេះ អស់កប្បប៉ុណ្ណេះ អស់រយនៃកប្បប៉ុណ្ណេះ អស់ពាន់នៃកប្បប៉ុណ្ណេះ អស់សែននៃកប្បប៉ុណ្ណេះ អស់កោដិនៃកប្បប៉ុណ្ណេះ អស់រយកោដិនៃកប្បប៉ុណ្ណេះ អស់ពាន់កោដិនៃកប្បប៉ុណ្ណេះ អស់សែនកោដិនៃកប្បប៉ុណ្ណេះ នឹងមិនវិលហួសអំពីនោះ ការដឹងយ៉ាងនេះ មិនមានទេ ទីបំផុតខាងចុងនៃសង្សារ មិនប្រាកដ យ៉ាងនេះខ្វះ ។ ទីបំផុតខាងដើមនៃសង្សារ ក៏មិនប្រាកដ ទាំងទីបំផុតខាងចុងនៃសង្សារក៏មិនប្រាកដយ៉ាងនេះឯង ។ ពួកសត្វអ្នកស្ថិតនៅ តាំងនៅ ជាប់ស្អិត ចូលទៅ នៅ កុះករ ជ្រុលជ្រប់ ចុះស៊ប់ហើយ ក្នុងសង្សារតែត្រង់កណ្តាល ហេតុនោះ ( លោកសួរថា ) អ្នកនៅក្នុងកណ្តាលនៃស្រះ ។ ពាក្យថា ដូច្នេះ របស់បទថា កប្បមាណពមានអាយុទូលសួរដូច្នេះ ជាពាក្យតបទ ។បេ។ ពាក្យថា ដូច្នេះ នុ៎ះ ជាលំដាប់បទ ។ ពាក្យថា មានអាយុ គឺពាក្យជាទីស្រឡាញ់ ជាពាក្យគោរព ពាក្យថា មានអាយុ នុ៎ះ ជាពាក្យពោលដោយគោរពកោតក្រែង ។ ពាក្យថា កប្បៈ ជាឈ្មោះរបស់ព្រាហ្មណ៍ ។បេ។ ជាពាក្យហៅព្រាហ្មណ៍នោះ ហេតុនោះ ( មានពាក្យថា ) កប្បមាណពមានអាយុ ទូលសួរដូច្នេះ ។

[ ៣៦៤ ] ពាក្យថា ព្រោះឱឃៈជាភ័យធំកើតឡើងហើយ គឺព្រោះកាមោឃៈ ភវោឃៈ ទិដ្ឋោឃៈ អវិជ្ជោឃៈ កើត កើតព្រម កកើតកើតចំពោះ កើតប្រាកដ ។ ពាក្យថា ភ័យធំ បានដល់ ភ័យអំពីជាតិ ភ័យអំពីជរា ភ័យអំពីព្យាធិ ភ័យអំពីមរណៈ ហេតុនោះ ( លោកសួរថា ) ព្រោះ

ឱឃៈ ជាភ័យធំ កើតឡើងហើយ ។

[ ៣៦៥ ] ពាក្យថា ដែលត្រូវជរា និងមច្ចុ គ្របសង្កត់ គឺត្រូវជរាប៉ះពាល់ គ្របសង្កត់ រួបរឹត ទន្រ្ទាន ត្រូវមច្ចុប៉ះពាល់ គ្របសង្កត់ រួបរឹត ទន្រ្ទាន ត្រូវជាតិជាប់តាម ត្រូវជរាជ្រួតជ្រាបចូល ត្រូវព្យាធិគ្របសង្កត់ ត្រូវមរណៈកម្ចាត់ មិនមានទីការពារ មិនមានទីជ្រក មិនមានទីពឹង មិនមានបុគ្គលជាទីពំនាក់ ហេតុនោះ ( លោកសួរថា ) ដែលត្រូវជរា និងមច្ចុ គ្របសង្កត់ ។

[ ៣៦៦ ] ពាក្យថា បពិត្រព្រះអង្គនិរទុក្ខ សូមព្រះអង្គត្រាស់ប្រាប់នូវទីពឹង គឺសូមព្រះអង្គពោល ប្រាប់ សម្តែង បញ្ញត្ត តាំងទុក បើក បែក ធ្វើឲ្យរាក់ ប្រកាស នូវទីពឹង ទីការពារ ទីជ្រក ទីពំនាក់ ទីពឹង ការប្រព្រឹត្តនៃដំណើរ ។ ពាក្យថា បពិត្រព្រះអង្គនិរទុក្ខ គឺពាក្យជាទីស្រឡាញ់ ជាពាក្យគោរព ពាក្យថា បពិត្រព្រះអង្គនិរទុក្ខ នេះជាពាក្យពោលដោយគោរព កោតក្រែង ហេតុនោះ ( លោកសួរថា ) បពិត្រព្រះអង្គនិរទុក្ខ សូមព្រះអង្គត្រាស់ប្រាប់នូវទីពឹង ។

[ ៣៦៧ ] ពាក្យថា ព្រះអង្គ របស់បទថា សូមព្រះអង្គប្រាប់នូវទីពឹងដល់ខ្ញុំព្រះអង្គ គឺកប្បមាណពពោលចំពោះព្រះមានព្រះភាគ ។ ពាក្យថា សូមត្រាស់ប្រាប់នូវទីពឹង គឺសូមព្រះអង្គពោល ប្រាប់ សម្តែង បញ្ញត្ត តាំងទុក បើក បែក ធ្វើឲ្យរាក់ ប្រកាស នូវទីពឹង នូវទីការពារ នូវទីជ្រក នូវទីពំនាក់ នូវការប្រព្រឹត្តទៅនៃគតិ ហេតុនោះ ( លោកសួរថា ) សូមព្រះអង្គប្រាប់នូវ

ទីពឹង ដល់ខ្ញុំព្រះអង្គ ។

[ ៣៦៨ ] ពាក្យថា ចុះសេចក្តីទុក្ខ ( ក្នុងស្រះ ) នេះ មិនគប្បីមានតទៅទៀត ដោយប្រការណា សេចក្តីថា ទុក្ខនេះ គប្បីរលត់ រម្ងាប់ ដល់នូវការវិនាស ស្ងប់រម្ងាប់ ក្នុងស្រះនេះឯង គឺសេចក្តីទុក្ខដែលកើតអំពីបដិសន្ធិទៀត មិនគប្បីកើតបាន គឺថា មិនគប្បីកើត មិនគប្បីកើតព្រម មិនគប្បីកកើតក្នុងកាមធាតុក្តី រូបធាតុក្តី អរូបធាតុក្តី កាមភពក្តី រូបភពក្តី អរូបភពក្តី សញ្ញាភពក្តី អសញ្ញាភពក្តី នេវសញ្ញានាសញ្ញាភពក្តី ឯកវោការភពក្តី ចតុ-វោការភពក្តី បញ្ចវោការភពក្តី គតិទៀតក្តី ឧបបត្តិទៀតក្តី បដិសន្ធិទៀតក្តី ភពក្តី សង្សារក្តី វដ្តៈក្តី គឺថា សេចក្តីទុក្ខនេះ គប្បីរលត់ រម្ងាប់ដល់នូវការវិនាស ស្ងប់រម្ងាប់ ក្នុងស្រះនេះឯង ដោយប្រការណា ហេតុនោះ ( លោកសួរថា ) ចុះសេចក្តីទុក្ខ ( ក្នុងស្រះ ) នេះ មិនគប្បីមានតទៅទៀត ដោយប្រការណា ។ ហេតុនោះ ព្រាហ្មណ៍នោះពោលថា

( កប្បមាណពមានអាយុ ទូលសួរដូច្នេះថា ) បពិត្រព្រះអង្គនិរទុក្ខ សូមព្រះអង្គត្រាស់ប្រាប់នូវទីពឹង របស់ពួកសត្វអ្នកស្ថិតនៅក្នុងកណ្តាលនៃស្រះ ដែលត្រូវជរា និងមច្ចុ គ្របសង្កត់ព្រោះឱឃៈជាភ័យធំកើតឡើងហើយ ចុះសេចក្តីទុក្ខ ( ក្នុងស្រះ ) នេះ មិនគប្បីមានតទៅទៀត ដោយប្រការណា សូមព្រះអង្គត្រាស់ប្រាប់នូវទីពឹងដល់ខ្ញុំព្រះអង្គ ដោយប្រការនោះ ។

[ ៣៦៩ ] ( ព្រះមានព្រះភាគ ទ្រង់ត្រាស់ថា ម្នាលកប្បៈ ) តថាគត

នឹងប្រាប់អ្នកនូវទីពឹង របស់ពួកសត្វ អ្នកស្ថិតនៅក្នុងកណ្ដាលនៃស្រះ ដែលត្រូវជរា និងមច្ចុ គ្របសង្កត់ ព្រោះឱឃៈជាភ័យធំកើតឡើងហើយ ។

[ ៣៧០ ] ពាក្យថា អ្នកស្ថិតនៅក្នុងកណ្ដាលនៃស្រះ អធិប្បាយថា សង្សារ លោកហៅថា ស្រះ បានដល់ ដំណើរមក ដំណើរទៅ ដំណើរទៅនិងមក មរណកាល គតិ ភពតូច ភពធំ ការច្យុតផង ការចាប់កំណើតផង ការកើតផង ការបែកធ្លាយផង ជាតិផង ជរាផង មរណៈផង ។ ទីបំផុតខាងដើមនៃសង្សារ មិនប្រាកដ ទាំងទីបំផុតខាងចុង ក៏មិនប្រាជក ។បេ។ ពួកសត្វស្ថិតនៅ តាំងនៅ ជាប់ស្អិត នៅកុះករ ជ្រុលជ្រប់ ចុះស៊ប់ហើយក្នុងសង្សារ តែត្រង់កណ្ដាល ។ ទីបំផុតខាងដើមនៃសង្សារ មិនប្រាកដ តើដូចម្ដេច ។បេ។ ទីបំផុតខាងដើមនៃសង្សារ មិនប្រាកដយ៉ាងនេះខ្លះ ។ ទីបំផុតខាងចុងនៃសង្សារ មិនប្រាកដ តើដូចម្ដេច ។បេ។ ទីបំផុតខាងចុងនៃសង្សារ មិនប្រាកដ យ៉ាងនេះខ្លះ ។ ទីបំផុតខាងដើមនៃសង្សារ ក៏មិនប្រាកដ ទាំងទីបំផុតខាងចុង ក៏មិនប្រាកដយ៉ាងនេះ ។ ពួកសត្វស្ថិតនៅ តាំងនៅ ជាប់ស្អិតនៅ កុះករ ជ្រុលជ្រប់ ចុះស៊ប់ហើយក្នុងសង្សារ តែត្រង់កណ្ដាល ហេតុនោះ ( ទ្រង់ត្រាស់ថា ) អ្នកស្ថិតនៅក្នុងកណ្ដាលនៃស្រះ ។ ពាក្យថា ម្នាលកប្បៈ របស់បទថា ព្រះមានព្រះភាគត្រាស់ថា ម្នាលកប្បៈ គឺព្រះមានព្រះភាគត្រាស់ហៅព្រាហ្មណ៍នោះតាមឈ្មោះ ។ ពាក្យថា ព្រះមានព្រះភាគនុ៎ះ ជាពាក្យពោលដោយគោរព ។បេ។ ការបញ្ញត្តិថា ព្រះមានព្រះភាគនេះ ( កើត ) ព្រោះការធ្វើឲ្យជាក់ច្បាស់ ហេតុនោះ ( មានពាក្យថា ) ព្រះមាន

ព្រះភាគទ្រង់ត្រាស់ថា ម្នាលកប្បៈ ។

[ ៣៧១ ] ពាក្យថា ព្រោះឱឃៈជាភ័យធំ កើតឡើងហើយ គឺព្រោះកាមោឃៈ ភវោឃៈ ទិដ្ឋោឃៈ អវិជ្ជោឃៈ កើត កើតព្រម កកើត ដុះដាល កើតប្រាកដ ។ ពាក្យថា ជាភ័យធំ គឺជាភ័យអំពីជាតិ ភ័យអំពីជរា ភ័យអំពីព្យាធិ ភ័យអំពីមរណៈ ហេតុនោះ ( ទ្រង់ត្រាស់ថា ) ព្រោះឱឃៈជាភ័យធំ កើតឡើងហើយ ។

[ ៣៧២ ] ពាក្យថា ដែលត្រូវជរា និងមច្ចុ គ្របសង្កត់ គឺត្រូវជរាប៉ះពាល់ គ្របសង្កត់ ប្រជុំចុះ ទន្ទ្រាន ត្រូវមច្ចុប៉ះពាល់ គ្របសង្កត់ ប្រជុំចុះ ទន្ទ្រាន ត្រូវជាតិជាប់តាម ត្រូវជរាជ្រួតជ្រាបចូល ត្រូវព្យាធិគ្របសង្កត់ ត្រូវមរណៈកម្ចាត់ មិនមានទីការពារ មិនមានទីជ្រក មិនមានទីពឹង មិនមានបុគ្គលជាទីសង្ឃឹម ហេតុនោះ ( ទ្រង់ត្រាស់ថា ) ដែលត្រូវជរា និងមច្ចុគ្របសង្កត់ ។

[ ៣៧៣ ] ពាក្យថា ម្នាលកប្បៈ តថាគតនឹងប្រាប់អ្នកនូវទីពឹង គឺតថាគតនឹងពោល ប្រាប់ សម្តែង បញ្ញត្ត តាំងទុក បើក ចែក ធ្វើឲ្យរាក់នូវទីពឹង ទីការពារ ទីជ្រក ទីពំនាក់ ការប្រព្រឹត្តទៅនៃគតិ ហេតុនោះ ( ទ្រង់ត្រាស់ថា ) តថាគតនឹងប្រាប់នូវទីពឹង ។ ពាក្យថា ម្នាលកប្បៈ របស់បទថា ម្នាលកប្បៈ ... ដល់អ្នក គឺព្រះមានព្រះភាគ ហៅព្រាហ្មណ៍នោះតាមឈ្មោះ ហេតុនោះ ( ទ្រង់ត្រាស់ថា ) ម្នាលកប្បៈ តថាគតនឹងប្រាប់អ្នកនូវទីពឹង ។ ហេតុនោះ ព្រះមានព្រះភាគត្រាស់ថា

( ព្រះមានព្រះភាគត្រាស់ថា ) ម្នាលកប្បៈ តថាគតនឹងប្រាប់អ្នក នូវនូវទីពឹងរបស់ពួកសត្វ អ្នកស្ថិតនៅក្នុងកណ្តាលនៃស្រះ ដែលត្រូវជរា និងមច្ចុគ្របសង្កត់ ព្រោះឱឃៈជាភ័យធំ កើតឡើងហើយ ។

[ ៣៧៤ ] ការមិនកង្វល់ ការមិនប្រកាន់មាំ នោះឯងជាទីពឹង ឯទីពឹងក្រៅពីនេះ ពុំមានទេ តថាគតហៅនូវទីពឹងនោះ ថានិព្វាន ជាទីអស់ជរា និងមច្ចុ ដោយប្រការដូច្នេះ ។

[ ៣៧៥ ] ពាក្យថា ការមិនកង្វល់ ការមិនប្រកាន់មាំ ត្រង់ពាក្យថា ការមិនកង្វល់ សេចក្តីថា កង្វល់ គឺរាគៈ កង្វល់ គឺទោសៈ កង្វល់ គឺមោហៈ កង្វល់ គឺមានះ កង្វល់ គឺទិដ្ឋិ កង្វល់ គឺកិលេស កង្វល់ គឺទុច្ចរិត ការលះបង់កង្វល់ ការរម្ងាប់កង្វល់ ការរលាស់កង្វល់ ការស្ងប់កង្វល់ អមតនិព្វាន ហេតុនោះ ( ទ្រង់ត្រាស់ថា ) ការមិនកង្វល់ ។ ពាក្យថា ការមិនប្រកាន់មាំ សេចក្តីថា តណ្ហា លោកហៅថា ការប្រកាន់មាំ បានដល់ រាគៈ រាគៈមានកម្លាំង ។បេ។ អភិជ្ឈា លោភៈ អកុសលមូល ការលះបង់សេចក្តីប្រកាន់មាំ ការរម្ងាប់ សេចក្តីប្រកាន់ ការរលាស់ចោលសេចក្តីប្រកាន់មាំ ការស្ងប់សេចក្តីប្រកាន់មាំ អមតនិព្វាន ហេតុនោះ ( ទ្រង់ត្រាស់ថា ) ការមិនកង្វល់ ការមិនប្រកាន់មាំ ។

[ ៣៧៦ ] ពាក្យថា នុ៎ះឯងជាទីពឹង ឯទីពឹងក្រៅពីនេះ ពុំមានទេ គឺនុ៎ះជាទីពឹង ជាទីការពារ ជាទីជ្រក ជាទីពំនាក់ ជាដំណើរប្រព្រឹត្តទៅនៃគតិ ។

ពាក្យថា ឯទីពឹងក្រៅពីនេះ ពុំមានទេ គឺទីពឹងដទៃឯទៀត អំពីទីពឹងនោះ មិនមាន មានតែទីពឹងនោះឯង ជាគុណដ៏លើសផង ប្រសើរផុតផង វិសេសផង ជាប្រធានផង ខ្ពង់ខ្ពស់ផង ថ្លៃថ្លាផង ហេតុនោះ ( ទ្រង់ត្រាស់ថា ) ឯទីពឹងក្រៅពីនេះ ពុំមានទេ ។

[ ៣៧៧ ] អធិប្បាយពាក្យថា តថាគត ហៅនូវទីពឹងនោះថា និព្វាន ដោយប្រការដូច្នេះ សេចក្តីថា តណ្ហា លោកហៅថា វាន: បានដល់ រាគ: រាគ:ដ៏មានកម្លាំង ។បេ។ អភិជ្ឈា លោភ: អកុសលមូល ការលះបង់វាន: រម្ងាប់វាន: រលាស់ចោលវាន: ស្ងប់វាន: អមតនិព្វាន ។ ពាក្យថា ដោយប្រការដូច្នេះ ជាពាក្យភ្ជាប់បទ ។បេ។ ពាក្យថា ដោយប្រការដូច្នេះ នុ៎ះជាលំដាប់បទ ។ ពាក្យថា តថាគតហៅ គឺតថាគតពោល ប្រាប់ សម្តែង បញ្ញត្ត តាំងទុក បើក ចែក ធ្វើឲ្យរាក់ ប្រកាស ហេតុនោះ ( ទ្រង់ត្រាស់ថា ) តថាគតហៅនូវទីពឹងនោះ ថានិព្វាន ដោយប្រការដូច្នេះ ។

[ ៣៧៨ ] ពាក្យថា ជាទីអស់ជរា និងមច្ចុ គឺការលះបង់ ការរម្ងាប់ ការរលាស់ ការស្ងប់រម្ងាប់នូវជរា និងមរណ: អមតនិព្វាន ហេតុនោះ ( ទ្រង់ត្រាស់ថា ) ជាទីអស់ជរា និងមច្ចុ ។ ហេតុនោះ ព្រះមានព្រះភាគត្រាស់ថា

ការមិនមានកង្វល់ ការមិនប្រកាន់មាំ នុ៎ះឯងជាទីពឹង ឯទីពឹងក្រៅពីនេះ ពុំមានទេ តថាគតហៅនូវទីពឹងនោះ ថានិព្វាន ជាទីអស់ជរា និងមច្ចុ ដោយប្រការដូច្នេះ ។

[ ៣៧៩ ] ពួកជនណា ជាអ្នកមានសតិ ដឹងនូវទីពឹងនុ៎ះ មានធម៌

ឃើញហើយ ជាអ្នករម្ងត់ហើយ ពួកជននោះ ជាអ្នកមិនលុះអំណាចមារ ពួកជននោះ ជាអ្នកមិនដល់នូវភាពជាអ្នកបម្រើមារ ។

[ ៣៨០ ] ពាក្យថា ពួកជនណា ជាអ្នកមានសតិ ដឹងនូវទីពឹងនុ៎ះ ត្រង់ពាក្យថា ទីពឹងនុ៎ះ គឺអមតនិព្វាន បានដល់ ការរម្ងាប់សង្ខារទាំងពួង ការលះឧបធិទាំងពួង ការអស់តណ្ហា ការប្រាសចាកតម្រេក ការរលត់ និព្វាន ។ ពាក្យថា ដឹង គឺដឹងច្បាស់ ស្គាល់ ថ្លឹង ពិចារណា យល់ច្បាស់ ធ្វើឲ្យប្រាកដថា សង្ខារទាំងឡាយទាំងពួងមិនទៀង ។បេ។ ដឹងច្បាស់ ថ្លឹង ពិចារណា យល់ច្បាស់ ធ្វើឲ្យប្រាកដថា វត្ថុណាមួយ មានកិរិយាកើតឡើងជាធម្មតា វត្ថុទាំងអស់នោះ មានកិរិយារលត់វិញជាធម្មតា ។ ពាក្យថា ពួកជនណា បានដល់ ពួកព្រះអរហន្តខីណាស្រព ពាក្យថា មានសតិ គឺមានសតិដោយហេតុ ៤ គឺកំពុងចម្រើនកាយេកាយានុបស្សនាសតិប្បដ្ឋាន ឈ្មោះថា មានសតិ ។បេ។ ហេតុនោះ ពួកនោះ លោកហៅថា អ្នកមានសតិ ហេតុនោះ ( ទ្រង់ត្រាស់ថា ) ពួកជនណា មានសតិ ដឹងនូវទីពឹងនុ៎ះ ។

[ ៣៨១ ] ពាក្យថា មានធម៌ឃើញហើយ ជាអ្នករម្ងត់ហើយ គឺមានធម៌ឃើញហើយ មានធម៌ដឹងហើយ មានធម៌ថ្លឹងហើយ មានធម៌ពិចារណាហើយ មានធម៌យល់ច្បាស់ហើយ មានធម៌ប្រាកដហើយ ។ ពាក្យថា ជាអ្នករម្ងត់ គឺជាអ្នករម្ងត់ ព្រោះរម្ងត់រាគៈ ជាអ្នករម្ងត់ ព្រោះរម្ងត់ទោសៈ ជាអ្នករម្ងត់ ព្រោះរម្ងត់មោហៈ ជាអ្នករម្ងត់ ព្រោះរម្ងត់កោធៈ ឧបនាហៈ ។បេ។ ជាអ្នករម្ងត់ ព្រោះរម្ងត់អភិសង្ខារជាអកុសលទាំងពួង ហេតុនោះ ( ទ្រង់ត្រាស់

ថា ) មានធម៌ឃើញហើយ ជាអ្នករម្ងាប់ហើយ ។

[ ៣៨២ ] ពាក្យថា ពួកជននោះ ជាអ្នកមិនលុះក្នុងអំណាចមារ ត្រង់ពាក្យថា មារ បានដល់ អ្នកសម្លាប់ អ្នកមានធម៌ខ្មៅ អ្នកជាអធិបតី អ្នកដល់នូវទីបំផុត ( អកុសលកម្ម ) អ្នកមិនលែង អ្នកជាផៅពង្ស នៃបុគ្គលធ្វេសប្រហែស ។ ពាក្យថា ពួកជននោះ ជាអ្នកមិនលុះអំណាចមារ បានសេចក្តីថា ពួកជននោះ ជាអ្នកមិនលុះក្នុងអំណាចមារ ទាំងមារក៏មិនញុំាងអំណាចឲ្យប្រព្រឹត្តទៅ ក្នុងពួកជននោះបាន ពួកជននោះ គ្របសង្កត់ ញាំញីរួបរឹត រារាំង ជិះជាន់ នូវមារផង ពួកមារផង អន្ទាក់មារផង សន្ទូចមារផង នុយមារផង វិស័យមារផង លំនៅមារផង គោចរមារផង ចំណងមារផង ហើយនៅ ទៅ ប្រព្រឹត្តទៅ រក្សា យាត្រា ឲ្យយាត្រាទៅ ហេតុនោះ ( ទ្រង់ត្រាស់ថា ) ពួកជននោះ ជាអ្នកមិនលុះក្នុងអំណាចមារ ។

[ ៣៨៣ ] ពាក្យថា ពួកជននោះ ជាអ្នកមិនដល់នូវភាពជាអ្នកបម្រើមារ គឺពួកជននោះ មិនមែនជាអ្នកប្រើប្រាស់ ជាអ្នកប្រព្រឹត្តក្នុងការប្រើប្រាស់ ជាអ្នកបម្រើបម្រាស់ ជាអ្នកបម្រើរបស់មារទេ ពួកជននោះ ជាអ្នកប្រើប្រាស់ ប្រព្រឹត្តក្នុងការប្រើប្រាស់ ជាអ្នកបម្រើបម្រាស់ ជាអ្នកបម្រើរបស់ព្រះពុទ្ធមានជោគ ហេតុនោះ ( ទ្រង់ត្រាស់ថា ) ពួកជននោះ ជាអ្នកមិនដល់នូវភាពជាអ្នកបម្រើមារ ។ ហេតុនោះ ព្រះមានព្រះភាគត្រាស់ថា

ពួកជនណា ជាអ្នកមានសតិ ដឹងនូវទីពឹងនុ៎ះ មានធម៌ឃើញហើយ ជាអ្នករម្ងាប់ហើយ ពួកជននោះ ជាអ្នកមិនលុះអំណាចមារ ពួកជននោះ ជាអ្នកមិនដល់នូវភាពជាអ្នកបម្រើមារ ។

ដំណាលគ្នានឹងកាលជាទីចប់នៃគាថា ។បេ។ បពិត្រព្រះអង្គដ៏ចម្រើន ព្រះមានព្រះភាគ ជាសាស្តារបស់ខ្ញុំព្រះអង្គ ខ្ញុំព្រះអង្គជាសាវ័ក ។

កប្បមាណវកប្បញ្ហានិទ្ទេស ចប់

# អដ្ឋកថា

## កប្បមាណវកប្បបញ្ញាតិនិទ្ទេស

[ ៣៦២ ] គប្បីជ្រាបវិនិច្ឆ័យក្នុងកប្បសុត្តនិទ្ទេសទី ១០ ដូចតទៅ បទថា **មជ្ឈេ សរស្មឹ** លោកអធិប្បាយថា ក្នុងសង្សារដែលជាកណ្តាល ព្រោះមិនមានការប្រាកដទីបំផុតខាងដើម និងខាងចុង ។ បទថា **តិដ្ឋតំ** បានដល់ ដល់សត្វទាំងឡាយដែលតាំងនៅ ។ បទថា **យថាយិទំ នាបរំ សិយា** បានដល់ ដោយប្រការដែលទុក្ខនេះ មិនគប្បីកើតទៀត ។

[ ៣៦៣ ] បទថា **អាគមនំ** បានដល់ ការមកក្នុងទីនេះអំពីទីបំផុតចំណែកខាងដើម ។ បទថា **គមនំ** បានដល់ ការទៅអំពីលោកនេះ ទៅកាន់បរលោក ។ បទថា **គមនាគមនំ** បានពោលហើយ ដោយអំណាចទាំងពីរយ៉ាងនោះ ។ បទថា **កាលំ** បានដល់ មរណកាល ។ បទថា **គតិ** បានដល់ ការកើត ។ បទថា **ភវាភវោ** បានដល់ ភពអំពីភព ។ បទថា **ចុតិ ច** បានដល់ ការឃ្លាតចាកភព ។ បទថា **ឧបបត្តិ ច** បានដល់ ការកើតរបស់សត្វដែលចុតិហើយ ។ បទថា **និព្វត្តិ ច** បានដល់ ការប្រាកដ ។ បទថា **ភេទោ ច** បានដល់ ការទម្លាយខន្ធ ។ បទថា **ជាតិ ច** បានដល់ ការកើត ។ បទថា **ជរា ច** បានដល់ ការវិនាសនៃខន្ធទាំងឡាយ ។ បទថា **មរណញ្ច** បានដល់ ការលះបង់ជីវិតិន្ទ្រិយ ។ បទថា **បុរិមាបិ កោដិ ន បញ្ញាយតិ** បានដល់ ទីបំផុតខាងដើមក៏មិនមាន គឺមិនប្រាកដ ។ ទីបំផុតខាងចុងក៏ដូចគ្នា ។ បទថា **ឯត្តកា ជាតិយោ** បានដល់ អស់ជាតិជាទីបំផុត ។

បទថា **វដ្តំ វត្តិ** បានដល់ ការប្រព្រឹត្តទៅនៃសង្សារប្រព្រឹត្តទៅហើយ ។ បទថា **តតោ បរំ ន វត្តតិ** បានដល់ ផុតអំពីនោះហើយ មិនប្រព្រឹត្តទៅ ។ បទថា **ហេវំ នត្ថិ** បានដល់ មិនមានគឺមិនប្រាកដយ៉ាងនេះ ។ **ហិ** សព្ទជានិបាត ។

បទថា **អនមតគ្គោយំ** បានដល់ សង្សារនេះ មានទីបំផុតដឹងមិនបាន ។ បទថា **អវិជ្ជានីវរណានំ** បានដល់ សត្វទាំងឡាយដែលអវិជ្ជាពាំង ។ បទថា **តណ្ហាសញ្ញោជនានំ** បានដល់ មានតណ្ហា ពោល គឺកាមរាគៈ ចងទុក ។ បទថា **សន្ធាវតំ** បានដល់ វិលទៅរឿយៗ ក្នុងកាមធាតុ ។ បទថា **សំសរតំ** បានដល់ អន្ទោលទៅក្នុងរូបធាតុ និងអរូបធាតុ ។ បទថា **ទុក្ខំ បច្ចនុភូតំ** បានដល់ សោយ គឺជួបនូវសេចក្តីទុក្ខដែលប្រព្រឹត្តទៅផ្លូវកាយ និងផ្លូវចិត្ត ។ បទថា **តិព្វំ** បានដល់ ច្រើន ។ បទថា **ព្យសនំ** បានដល់ មិនមានសេចក្តីចម្រើន គឺវិនាស ។ បទថា **កដសីវឌ្ឍិតំ** បានដល់ ធ្វើព្រៃស្មសានឲ្យចម្រើន ។ បទថា **អលមេវ** បានដល់ សមគួរពិត ។ បទថា **សព្វសង្ខារេសុ** បានដល់ ក្នុងសង្ខារដែលប្រព្រឹត្តទៅក្នុងភូមិ ៣ ។ បទថា **និព្វិន្ទិតុំ** បានដល់ ដើម្បីនឿយណាយ ។ បទថា **វិរជ្ជិតុំ** បានដល់ ដើម្បីឲ្យកើតនូវការប្រាសចាកតម្រេក ។ បទថា **វិមុច្ចិតុំ** បានដល់ ដើម្បីរួចផុត ។ បទថា **វដ្តំ វត្តិស្សតិ** សេចក្តីថា វដ្តៈប្រព្រឹត្តទៅក្នុងភូមិ ៣ ដែលប្រព្រឹត្តទៅហើយក្នុងសង្សារ នឹងប្រព្រឹត្តទៅក្នុងអនាគត ។ បទថា **តតោ បរំ ន វត្តិស្សតិ** សេចក្តីថា ការប្រព្រឹត្តទៅក្នុងសង្សារក្នុងអនាគត ផុតអំពីនោះ

នឹងមិនប្រព្រឹត្តទៅ ។

[ ៣៦៤ ] បទថា **ជាតិភយេ** បានដល់ ភ័យអាស្រ័យជាតិកើតឡើង ។ ក្នុងជរាជាដើម ក៏មានន័យនេះដូចគ្នា ។

[ ៣៧៤ ] លំដាប់នោះ ព្រះមានព្រះភាគ កាលទ្រង់ព្យាករសេចក្តីនោះ ដល់កប្បមាណព ទើបត្រាស់គាថាទាំងឡាយតទៅ ។ គាថាទី ២ មានសេចក្តីដូចបានពោលហើយ ។ ក្នុងគាថាទី ៣ គប្បីជ្រាបអត្ថដូចតទៅនេះថា បទថា **អកិញ្ចនំ** បានដល់ ដែលផុយគ្មានទីងកិលេសជាគ្រឿងកង្វល់ ។ បទថា **អនាទានំ** បានដល់ ដែលផុយគ្មានទីងតណ្ហាដែលជាគ្រឿងប្រកាន់មាំ អធិប្បាយថា ចូលទៅស្ងប់កិលេសជាគ្រឿងកង្វល់ និងតណ្ហាជាគ្រឿងប្រកាន់មាំ ។ បទថា **អនាបរំ** បានដល់ វៀរចាកធម៌ដទៃដែលដូចគ្នា អធិប្បាយថា ជាធម៌ប្រសើរបំផុត ។

[ ៣៧៩ ] គប្បីជ្រាបសេចក្តីក្នុងគាថាទី ៤ ដូចតទៅនេះ បទថា **ន តេ មារស្ស បទ្ធគូ** សេចក្តីថា មិនត្រាច់បម្រើមារ ។

[ ៣៨២ ] ឈ្មោះថា **មារោ** ព្រោះប្រកបមហាជនទុកក្នុងបាប ហើយឲ្យស្លាប់ ។ ឈ្មោះថា **កណ្ហោ** ព្រោះជាអ្នកប្រកបក្នុងអកុសលធម៌ ។ ឈ្មោះថា **អធិបតិ** ព្រោះធំក្នុងទេវលោកទាំង ៦ ។ បទថា **អន្តគូ** ព្រោះជាបុគ្គលទៅកាន់ទីបំផុតនៃអកុសលកម្ម ។ ឈ្មោះថា **នមុចិ** ព្រោះមិនលែងមហាជន ។ ឈ្មោះថា **បមត្តពន្ធុ** ព្រោះជាញាតិ ជាទីសរសើររបស់បុគ្គល

ប្រមាទ គឺនៅប្រាសចាកសតិ ។ បទដ៏សេសក្នុងទីទាំងពួង ប្រាកដច្បាស់ហើយ ។

ព្រះមានព្រះភាគ ទ្រង់សម្តែងសូត្រនេះ ដោយកំពូលនៃធម៌ គឺអរហត្តដោយប្រការដូច្នេះ ។

កាលចប់ទេសនា មានបុគ្គលសម្រេចធម៌ ដូចគ្នានឹងសូត្រមុននោះឯង ។៚

**អដ្ឋកថា កប្បមាណវសុត្តនិទ្ទេសទី ១០ ចប់**

# សុត្តន្តបិដក

## ជតុកណ្ណីមាណវកបញ្ហានិទ្ទេស

[ ៣៨៤ ] ( ជតុកណ្ណីមានអាយុទូលសួរដូច្នេះថា ) បពិត្រព្រះអង្គជាវីរបុរស ខ្ញុំព្រះអង្គបានឮហើយ ទើបមក ដើម្បីទូលសួរព្រះអង្គទ្រង់មិនមានប្រាថ្នាក្នុងកាម ទ្រង់ឆ្លងឱឃៈ ទ្រង់មិនមានសេចក្តីប្រាថ្នា បពិត្រព្រះអង្គមានព្រះនេត្រកើតព្រមគ្នា សូមព្រះអង្គសម្តែងនូវសន្តិបទ បពិត្រព្រះមានព្រះភាគ សូមព្រះអង្គសម្តែងនូវសន្តិបទនោះ ដែលជាធម៌ពិត ដល់ខ្ញុំព្រះអង្គឲ្យទាន ។

[ ៣៨៥ ] ពាក្យថា បពិត្រព្រះអង្គជាវីរបុរស ខ្ញុំព្រះអង្គបានឮហើយ ... ទ្រង់មានប្រាថ្នាក្នុងកាម អធិប្បាយថា ខ្ញុំព្រះអង្គឮ ស្តាប់ រៀន ចាំទុក កំណត់ទុកថា ព្រះមានព្រះភាគអង្គនោះ ជាព្រះអរហន្ត ព្រោះហេតុដូច្នេះខ្លះ ។បេ។ ព្រះអង្គត្រាស់ដឹងហើយ ព្រះអង្គមានចំណែកធម៌ ហេតុនោះ ( លោកពោលថា ) ខ្ញុំព្រះអង្គបានឮហើយ ។ ពាក្យថា បពិត្រព្រះអង្គជាវីរបុរស គឺព្រះពុទ្ធជាវីរជន ។ ព្រះមានព្រះភាគជាវីរបុរស ព្រោះទ្រង់មានសេចក្តីព្យាយាម ។ ជាវីរបុរស ព្រោះព្រះអង្គជាអ្នកសម្បូរណ៍ដោយគុណ ។ ជាវីរបុរស ព្រោះព្រះអង្គញ៉ាំងសេចក្តីព្យាយាមឲ្យកើត ( ក្នុងសន្តានរបស់អ្នកដទៃ ) ។ ជាវីរបុរស ព្រោះព្រះអង្គមានព្រះហឫទ័យអង់អាច ។ ជាវីរបុរស ព្រោះព្រះអង្គជាបុគ្គលក្លៀវក្លា មោះមុត មិនខ្លាច មិនរន្ធត់ មិនស្ញុំ មិនរត់ បានលះបង់នូវសេចក្តីខ្លាច និងសេចក្តីញ័រចំប្រប់ ប្រាសចាកសេចក្តីព្រឺព្រួចរោម ។

ព្រះខីណាស្រព វៀរហើយចាកបាបទាំងពួង ក្នុងលោកនេះ មាន កិរិយាអប់រំ ដោយសេចក្តីព្យាយាម កន្លងនិរយទុក្ខ លោកមាន ព្យាយាម មានសេចក្តីប្រឹងប្រែង មិនញាប់ញ័រ មានសភាព ដូច្នោះ ទើបលោកហៅថា វីរបុរស ។

ហេតុនោះ ( លោកពោលថា ) បពិត្រព្រះអង្គជាវីរបុរស ខ្ញុំព្រះអង្គ បានឮហើយ ។ ពាក្យថា កាម របស់បទថា ទ្រង់មិនមានប្រាថ្នាក្នុងកាម បើ តាមឧទ្ទាន កាមមាន ២ គឺវត្ថុកាម ១ កិលេសកាម ១ ។បេ។ ទាំងនេះ លោក ហៅថា វត្ថុកាម ។បេ។ ទាំងនេះ លោកហៅថា កិលេសកាម ។ វត្ថុកាម ព្រះពុទ្ធមានជោគ ទ្រង់កំណត់ដឹងហើយ កិលេសកាម ព្រះអង្គ លះបង់ហើយ ព្រោះទ្រង់កំណត់ដឹងវត្ថុកាម ព្រោះលះបង់កិលេសកាម ព្រះ មានព្រះភាគ ទើបមិនត្រូវការនឹងកាមទាំងឡាយ មិនរីករាយរកកាមទាំង ឡាយ មិនប្រាថ្នាកាមទាំងឡាយថា កាមទាំងឡាយប្រសើរបំផុត ហេតុនោះ ព្រះពុទ្ធ ឈ្មោះថា មិនប្រាថ្នាកាម ចេញចាកកាម លះចោលកាម ខ្ជាក់ ចោលកាម លែងកាម លះកាម រលាស់ចោលកាម ប្រាសចាករាគៈ ឃ្លាត ចាករាគៈ លះចោលរាគៈ ខ្ជាក់ចោលរាគៈ លែងរាគៈ លះរាគៈ រលាស់ ចោលរាគៈ មិនមានប្រាថ្នា រលត់ទុក្ខ ត្រជាក់ សោយសុខ មានព្រះ ហឫទ័យប្រសើរ ហេតុនោះ ( លោកពោលថា ) បពិត្រព្រះអង្គជាវីរបុរស ខ្ញុំព្រះអង្គបានឮហើយ ... ទ្រង់មិនមានប្រាថ្នាក្នុងកាម ។ ពាក្យថា ដូច្នេះ របស់បទថា ជតុកណ្ណីមានអាយុទូលសួរ ដូច្នេះ គឺជាពាក្យតបទ ។បេ។ ពាក្យ

ថា ដូច្នេះ នុ៎ះជាលំដាប់បទ ។ ពាក្យថា មានអាយុ គឺពាក្យជាទីស្រឡាញ់ ពាក្យថា មានអាយុ នុ៎ះជាពាក្យ ពោលដោយគោរព កោតក្រែង ។ ពាក្យ ថា ជតុកណ្ណិ គឺជាគោត្រ ។បេ។ ជាពាក្យហៅព្រាហ្មណ៍នោះ ហេតុនោះ ( មានពាក្យថា ) ជតុកណ្ណិមានអាយុទូលសួរ ដូច្នេះ ។

[ ៣៨៦ ] អធិប្បាយពាក្យថា ទើបមក ដើម្បីទូលសួរព្រះអង្គ ទ្រង់ ធ្ងន់ឱយៈ ទ្រង់មិនមានសេចក្ដីប្រាថ្នា ត្រង់ពាក្យថា ទ្រង់ធ្ងន់ឱយៈ គឺទ្រង់ កន្លងឱយៈ ឈានកន្លង រំលងផុត ប្រព្រឹត្តកន្លងឱយៈ ហេតុនោះ ( លោក ពោលថា ) ទ្រង់ធ្ងន់ឱយៈ ។ ពាក្យថា ដើម្បីទូលសួរ គឺដើម្បីសាកសួរ ដើម្បីដណ្ដឹង ដើម្បីសូម ដើម្បីអារាធនា ដើម្បីឲ្យជ្រះថ្លា ។ ពាក្យថា ទើប មក ... ទ្រង់មិនមានសេចក្ដីប្រាថ្នា គឺយើងខ្ញុំមកហើយ ជាអ្នកមកហើយ ចូលមកហើយ សំដៅមកហើយ គឺជាអ្នកមកជួបនឹងព្រះអង្គ ដើម្បីទូលសួរ ព្រះអង្គ ទ្រង់មិនមានប្រាថ្នា ទ្រង់ចេញចាកកាម ទ្រង់បោលកាម ទ្រង់ខ្ជាក់ កាម ទ្រង់លែងកាម ទ្រង់លះកាម ទ្រង់រលាស់កាម ទ្រង់ប្រាសចាករាគៈ ទ្រង់បោលរាគៈ ទ្រង់ខ្ជាក់រាគៈ ទ្រង់លែងរាគៈ ទ្រង់លះរាគៈ ទ្រង់រលាស់ បោលរាគៈ ហេតុនោះ ( លោកទូលសួរថា ) ខ្ញុំព្រះអង្គទើបមកដើម្បីទូល សួរព្រះអង្គ ទ្រង់ធ្ងន់ឱយៈ ទ្រង់មិនមានសេចក្ដីប្រាថ្នា ។

[ ៣៨៧ ] អធិប្បាយពាក្យថា បពិត្រព្រះអង្គមានព្រះនេត្រកើតព្រមគ្នា សូមព្រះអង្គសម្ដែងនូវសន្តិបទ ត្រង់ពាក្យថា សន្តិ សេចក្ដីថា សន្តិក្ដី សន្តិ- បទក្ដី ដោយអាការតែមួយ គឺអមតនិព្វាននោះឯង បានដល់ ការរម្ងាប់សង្ខារ

ទាំងពួង ការលះបង់ឧបធិទាំងពួង ការអស់តណ្ហា ការប្រាសចាកតម្រេក ការរលត់ និព្វាន ។ សមដូចពាក្យនេះ ដែលព្រះមានព្រះភាគត្រាស់ថា ទុំះជាចំណែកដ៏ស្ងប់ ទុំះជាចំណែកដ៏ឧត្តម គឺការរម្ងាប់សង្ខារទាំងពួង ការលះបង់ឧបធិទាំងពួង ការអស់តណ្ហា ការប្រាសចាកតម្រេក ការរលត់ ព្រះនិព្វាន ។ មួយទៀត បើដោយអាការដទៃ ពួកធម៌ណាប្រព្រឹត្តទៅ ដើម្បីកិរិយាបានសេចក្តីស្ងប់ ដើម្បីការពាល់ត្រូវសេចក្តីស្ងប់ ដើម្បីការធ្វើឲ្យជាក់លាក់ គឺសតិប្បដ្ឋាន ៤ សម្មប្បធាន ៤ ឥទ្ធិបាទ ៤ ឥន្ទ្រិយ ៥ ពល ៥ ពោជ្ឈង្គ ៧ អរិយមគ្គប្រកបដោយអង្គ ៨ ពួកធម៌នេះ លោកហៅថា សន្តិបទ ។ សូមព្រះអង្គ ពោល ប្រាប់ សម្តែង បញ្ញត្ត បើក ចែក ធ្វើឲ្យរាក់ ប្រកាសនូវសន្តិបទ ឧបាយជាគ្រឿងការពារ ឧបាយជាគ្រឿងជ្រក ឧបាយជាគ្រឿងពឹង ឧបាយមិនមានភ័យ ឧបាយមិនច្យុត ឧបាយមិនមានស្លាប់ ឧបាយ គឺព្រះនិព្វាន ។ ពាក្យថា បពិត្រព្រះអង្គ ទ្រង់មានព្រះនេត្រកើតព្រមគ្នា គឺសព្វញ្ញុតញ្ញាណ លោកហៅថា ព្រះនេត្រ ។ ព្រះពុទ្ធមានព្រះភាគ មានព្រះនេត្រ គឺភាពនៃព្រះជិនស្រី ( អ្នកឈ្នះកិលេស ) កើតឡើងមិនមុន មិនក្រោយ គឺក្នុងខណៈតែមួយ ទៀបគល់នៃពោធិព្រឹក្ស ហេតុនោះ ព្រះពុទ្ធឈ្មោះថា មានព្រះនេត្រកើតដំណាលគ្នា ហេតុនោះ ( លោកទូលសួរថា ) បពិត្រព្រះអង្គ មានព្រះនេត្រកើតព្រមគ្នា សូមព្រះអង្គសម្តែងនូវសន្តិបទ ។

[ ៣៨៨ ] ពាក្យថា បពិត្រព្រះមានព្រះភាគ សូមព្រះអង្គសម្តែងសន្តិបទនោះ ដែលជាធម៌ពិត ដល់ខ្ញុំព្រះអង្គ សេចក្តីថា អមតនិព្វាន លោក

ហៅថា ធម៌ពិត បានខាងការរម្ងាប់សង្ខារទាំងពួង ការលះបង់ឧបធិទាំងពួង ការអស់តណ្ហា ការប្រាសចាកតម្រេក ការរម្ងត់ និព្វាន ។ ពាក្យថា ព្រះមានព្រះភាគ នុ៎ះជាពាក្យពោលដោយគោរព ។បេ។ ការបញ្ញត្តិថា ព្រះមានព្រះភាគ នេះ ( កើត ) ព្រោះការធ្វើឲ្យជាក់ច្បាស់ ពាក្យថា សូមព្រះអង្គសម្តែងនូវសន្តិបទនោះ ដល់ខ្ញុំព្រះអង្គ គឺសូមព្រះអង្គសម្តែង ប្រាប់ ។បេ។ ប្រកាស ហេតុនោះ ( លោកពោលថា ) បពិត្រព្រះមានព្រះភាគ សូមព្រះអង្គសម្តែងនូវសន្តិបទនោះ ដែលជាធម៌ពិត ដល់ខ្ញុំព្រះអង្គ ។ ហេតុនោះព្រាហ្មណ៍នោះពោលថា

( ជតុកណ្ណីមានអាយុ ទូលសួរដូច្នេះថា ) បពិត្រព្រះអង្គជាវីរបុរស ខ្ញុំព្រះអង្គបានឮហើយ ទើបមក ដើម្បីទូលសួរព្រះអង្គ ទ្រង់មិនមានប្រាថ្នាក្នុងកាម ទ្រង់ធ្លងឱឃៈ ទ្រង់មិនមានសេចក្តីប្រាថ្នា បពិត្រព្រះអង្គមានព្រះនេត្រកើតព្រមគ្នា សូមព្រះអង្គសម្តែងនូវសន្តិបទ បពិត្រព្រះមានព្រះភាគ សូមព្រះអង្គសម្តែងនូវសន្តិបទនោះ ដែលជាធម៌ពិត ដល់ខ្ញុំព្រះអង្គ ឲ្យទាន ។

[ ៣៨៩ ] ព្រោះថា ព្រះមានព្រះភាគ ប្រព្រឹត្តគ្របសង្កត់នូវកាម ដូចព្រះអាទិត្យ មានតេជះ គ្របសង្កត់ នូវប្រឹថពីមណ្ឌល ដោយតេជះ សូមព្រះអង្គមានប្រាជ្ញាស្មើដោយផែនដី ត្រាស់ប្រាប់ធម៌ ដែលល្មមខ្ញុំព្រះអង្គយល់បាន ជាគ្រឿងលះបង់ស្រឡះ នូវជាតិ និងជរា ក្នុងលោកនេះ ដល់ខ្ញុំព្រះអង្គ ជាអ្នកមានប្រាជ្ញា

ស្តួចស្តើង ឲ្យទាន ។

[ ៣៩០ ] អធិប្បាយពាក្យថា ព្រោះថា ព្រះមានព្រះភាគ ប្រព្រឹត្តគ្របសង្កត់នូវកាម ត្រង់ពាក្យថា ព្រះមានព្រះភាគនេះ គឺជាពាក្យពោលដោយសេចក្តីគោរព ។បេ។ ការបញ្ញត្តិថា ព្រះមានព្រះភាគ នេះ ( កើត ) ព្រោះការធ្វើឲ្យជាក់ច្បាស់ ។ ពាក្យថា កាម បើតាមឧទ្ទាន កាមមាន ២ គឺវត្ថុកាម ១ កិលេសកាម ១ ។បេ។ ទាំងនេះលោកហៅថា វត្ថុកាម ។បេ។ ទាំងនេះលោកហៅថា កិលេសកាម ។ ព្រះមានព្រះភាគ កំណត់ដឹងវត្ថុកាមទាំងឡាយ លះបង់ គ្របសង្កត់ បៀតបៀន រួបរឹត ឈ្ងិចឈ្ងី ញាំញី នូវកិលេសកាមទាំងឡាយ ហើយត្រាច់ទៅ ប្រព្រឹត្តទៅ រក្សា យាត្រា ឲ្យយាត្រាទៅ ហេតុនោះ លោកពោលថា ព្រោះថា ព្រះមានព្រះភាគប្រព្រឹត្តគ្របសង្កត់នូវកាម ។

[ ៣៩១ ] ពាក្យថា ដូចព្រះអាទិត្យ មានតេជះ គ្របសង្កត់នូវប្រឹថពីមណ្ឌល ដោយតេជះ សេចក្តីថា សុរិយទេវបុត្រ លោកហៅថា ព្រះអាទិត្យ ។ ផែនដី លោកហៅថា ប្រឹថពី ។ សុរិយទេវបុត្រមានតេជះ ដោយតេជះ ប្រកបដោយតេជះ គ្របសង្កត់ បៀតបៀន រួបរឹត ឈ្ងេចឈ្ងី កម្តៅ នូវប្រឹថពី ញុំាងវត្ថុដែលតាំងនៅក្នុងអាកាសទាំងអស់ឲ្យវិនាស កម្ចាត់បង់ងងឹត ធ្ងុះនូវពន្លឺ ហើយចរទៅក្នុងផ្លូវ ជាទីចរទៅ គឺអាកាសទទេ យ៉ាងណាមិញ ព្រះមានព្រះភាគមានតេជះ គឺញាណ ប្រកបដោយតេជះ គឺញាណ កម្ចាត់បង់នូវកិរិយាកើតឡើងនៃអភិសង្ខារទាំងពួង ។បេ។ នូវងងឹត គឺកិលេស នូវងងឹត គឺអវិជ្ជា សម្តែងនូវពន្លឺ គឺញាណ កំណត់ដឹងវត្ថុកាមទាំងឡាយ លះបង់ គ្រប

សង្កត់ ឃាត់បង់ រួបរឹត ឈ្លេចឈ្លី ញាំញី នូវកិលេសកាមទាំងឡាយ ហើយត្រាច់ទៅ ប្រព្រឹត្តទៅ រក្សា យាត្រា ឲ្យយាត្រាទៅ ហេតុនោះ ( លោកពោលថា ) ដូចព្រះអាទិត្យ មានតេជះ គ្របសង្កត់នូវប្រឹថពីមណ្ឌលដោយតេជះ ។

[ ៣៩២ ] ពាក្យថា ព្រះអង្គមានប្រាជ្ញាស្មើដោយផែនដី ... ដល់ខ្ញុំព្រះអង្គ ជាអ្នកមានប្រាជ្ញាស្តួចស្តើង គឺខ្ញុំព្រះអង្គជាបុគ្គលមានប្រាជ្ញាតិច មានប្រាជ្ញាឱនថយ មានប្រាជ្ញាជ្រោកជ្រាក ចំណែកខាងព្រះអង្គមានប្រាជ្ញាច្រើន មានប្រាជ្ញាក្រាស់ មានប្រាជ្ញារីករាយ មានប្រាជ្ញាលឿន មានប្រាជ្ញាមុត មានប្រាជ្ញាធ្លុះធ្លាយ ប្រឹថពី ហៅថា ផែនដី ព្រះអង្គប្រកបដោយប្រាជ្ញាស្មើដោយផែនដីនោះ ជាបញ្ញាដ៏ទូលាយ ជ្រាលជ្រៅ ហេតុនោះ ( លោកពោលថា ) ព្រះអង្គមានប្រាជ្ញាស្មើដោយផែនដី ... ដល់ខ្ញុំព្រះអង្គ ជាអ្នកមានប្រាជ្ញាស្តួចស្តើង ។

[ ៣៩៣ ] ពាក្យថា សូមព្រះអង្គត្រាស់ប្រាប់ធម៌ ដែលល្មមខ្ញុំព្រះអង្គយល់បាន ត្រង់ពាក្យថា សូមព្រះអង្គត្រាស់ប្រាប់ធម៌ គឺសូមព្រះអង្គប្រាប់សម្តែង បញ្ញត្ត តាំងទុក បើក ចែក ធ្វើឲ្យរាក់ ប្រកាស នូវព្រហ្មចរិយៈមានលម្អក្នុងខាងដើម មានលម្អក្នុងកណ្តាល មានលម្អក្នុងទីបំផុត ប្រកបដោយអត្ថ ប្រកបដោយព្យញ្ជនៈ បរិបូណ៌ទាំងអស់ ដ៏បរិសុទ្ធ នូវសតិប្បដ្ឋាន ៤ ។បេ។ នូវព្រះនិព្វានផង នូវបដិបទាជាដំណើរទៅកាន់ព្រះនិព្វានផង ហេតុនោះ ( លោកពោលថា ) សូមព្រះអង្គត្រាស់ប្រាប់ធម៌ ។ ពាក្យ

ថា ដែលល្មមខ្ញុំព្រះអង្គយល់បាន គឺដែលល្មមខ្ញុំព្រះអង្គ ដឹង យល់ច្បាស់ ចាក់ធ្លុះ ពាល់ត្រូវ ធ្វើឲ្យជាក់ច្បាស់បាន ហេតុនោះ ( លោកពោលថា ) សូមព្រះអង្គត្រាស់ប្រាប់ធម៌ ដែលល្មមខ្ញុំព្រះអង្គយល់បាន ។

[ ៣៩៤ ] ពាក្យថា ជាគ្រឿងលះបង់ស្រឡះ នូវជាតិ និងជរា ក្នុងលោកនេះ គឺជាគ្រឿងលះបង់ រម្ងាប់ រលាស់ចេញ ស្ងប់រម្ងាប់ នូវជាតិ ជរា និងមរណៈ ក្នុងលោកនេះឯង គឺអមតនិព្វាន ហេតុនោះ ( លោកពោលថា ) ជាគ្រឿងលះបង់ស្រឡះនូវជាតិ និងជរា ក្នុងលោកនេះ ។ ហេតុនោះ ព្រាហ្មណ៍នោះពោលថា

ព្រោះថា ព្រះមានព្រះភាគ ប្រព្រឹត្តគ្របសង្កត់នូវកាម ដូចព្រះអាទិត្យ មានតេជះ គ្របសង្កត់ប្រឹថពីមណ្ឌល ដោយតេជះ សូមព្រះអង្គមានប្រាជ្ញាស្មើដោយផែនដី ត្រាស់ប្រាប់ធម៌ ដែលល្មមខ្ញុំព្រះអង្គយល់បាន ជាគ្រឿងលះបង់ស្រឡះនូវជាតិ និងជរា ក្នុងលោកនេះ ដល់ខ្ញុំព្រះព្រះអង្គជាអ្នកមានប្រាជ្ញាស្ដួចស្ដើង ឲ្យទាន ។

[ ៣៩៥ ] ( ព្រះមានព្រះភាគ ត្រាស់ថា ម្នាលជតុកណ្ណិ ) អ្នកចូរឃើញនូវនេក្ខម្មៈ ថាជាសេចក្ដីក្សេម ហើយកម្ចាត់បង់នូវសេចក្ដីប្រាថ្នា ក្នុងកាមទាំងឡាយចេញ ការប្រកាន់ក្ដី ការត្រូវរលាស់ចេញក្ដី កង្វល់ក្ដី កុំមានដល់អ្នកឡើយ ។

[ ៣៩៦ ] អធិប្បាយពាក្យថា កម្ចាត់បង់នូវសេចក្ដីប្រាថ្នា ក្នុងកាមទាំងឡាយចេញ ត្រង់ពាក្យថា ក្នុងកាមទាំងឡាយ គឺតាមឧទ្ទាន កាមមាន ២ គឺ

វត្ថុកាម ១ កិលេសកាម ១ ។បេ។ ទាំងនេះ ហៅថា វត្ថុកាម ។បេ។ ទាំងនេះ ហៅថា កិលេសកាម ។ ពាក្យថា សេចក្តីប្រាថ្នា សេចក្តីថា តណ្ហា លោកហៅថា សេចក្តីប្រាថ្នា បានដល់ រាគៈ រាគៈមានកម្លាំង ។បេ។ អភិជ្ឈា លោភៈ អកុសលមូល ។ ពាក្យថា កម្ចាត់នូវសេចក្តីប្រាថ្នា ក្នុងកាមទាំងឡាយចេញ គឺកម្ចាត់ កម្ចាត់បង់ បន្ទោបង់ ធ្វើឲ្យវិនាស ធ្វើមិនឲ្យកើតមាន ហេតុនោះ ( ទ្រង់ត្រាស់ថា ) កម្ចាត់បង់នូវសេចក្តីប្រាថ្នាក្នុងកាមទាំងឡាយចេញ ។ ពាក្យថា ម្នាលជតុកណ្ណី គឺព្រះមានព្រះភាគ ត្រាស់ហៅព្រាហ្មណ៍នោះតាមគោត្រ ។ ពាក្យថា ព្រះមានព្រះភាគ នុ៎ះជាពាក្យពោលដោយគោរព ។បេ។ ការបញ្ញត្តិថា ព្រះមានព្រះភាគនេះ ( កើត ) ព្រោះការធ្វើឲ្យជាក់ច្បាស់ ហេតុនោះ ( មានពាក្យថា ) ព្រះមានព្រះភាគត្រាស់ថា ម្នាលជតុ-កណ្ណី ។

[ ៣៩៧ ] ពាក្យថា នេក្ខម្មៈ របស់បទថា អ្នកចូរឃើញនូវនេក្ខម្មៈថាជាសេចក្តីក្សេម គឺអ្នកចូរឃើញ យល់ ថ្លឹង ពិចារណា ឈ្វេងយល់ ធ្វើឲ្យប្រាកដ នូវសេចក្តីប្រតិបត្តិដោយប្រពៃ សេចក្តីប្រតិបត្តិដ៏សមគួរ សេចក្តីប្រតិបត្តិជាសឹកសត្រូវ សេចក្តីប្រតិបត្តិសមគួរដល់ប្រយោជន៍ សេចក្តីប្រតិ-បត្តិសមគួរដល់ធម៌ ការធ្វើឲ្យពេញលេញក្នុងសីលទាំងឡាយ ការគ្រប់គ្រងទ្វារ ក្នុងឥន្ទ្រិយទាំងឡាយ ការដឹងប្រមាណក្នុងភោជន ការប្រកបរឿយៗ នូវសេចក្តីភ្ញាក់រឭក សតិ និងសម្បជញ្ញៈ សតិប្បដ្ឋាន ៤ សម្មប្បធាន ៤ ឥទ្ធិ-បាទ ៤ ឥន្ទ្រិយ ៥ ពល ៥ ពោជ្ឈង្គ ៧ អរិយមគ្គប្រកបដោយអង្គ ៨

ព្រះនិព្វាន និងបដិបទាជាដំណើរទៅកាន់ព្រះនិព្វាន ថាជាសេចក្តីក្សេម ថាជាទីការពារ ថាជាទីជ្រក ថាជាទីពឹង ថាជាទីពំនាក់ ថាជាទីមិនមានភ័យ ថាជាទីមិនច្យុត ថាជាទីមិនមានសេចក្តីស្លាប់ ថាជាទីចេញចាកវាន: ហេតុនោះ ( ទ្រង់ត្រាស់ថា ) អ្នកចូរឃើញនូវនេក្ខម្ម: ថាជាសេចក្តីក្សេម ។

[ ៣៩៨ ] ពាក្យថា ការប្រកាន់ របស់បទថា ការប្រកាន់ក្តី ការត្រូវលោស់ចេញក្តី គឺការប្រកាន់ ការស្ទាបអង្អែល ការជាប់ជំពាក់ ការជ្រុលជ្រប់ ការចុះស៊ប់ ដោយអំណាចតណ្ហា ដោយអំណាចទិដ្ឋិ ។ ពាក្យថា ការត្រូវលោស់ចេញ គឺការត្រូវលះលែង ការត្រូវដកចេញ ការត្រូវលះបង់ ការត្រូវធ្វើឲ្យវិនាស ធ្វើមិនឲ្យកើតមាន ហេតុនោះ ( ទ្រង់ត្រាស់ថា ) ការប្រកាន់ក្តី ការត្រូវលោស់ចេញក្តី ។

[ ៣៩៩ ] ពាក្យថា កង្វល់ក្តី កុំមានដល់អ្នកឡើយ សេចក្តីថា កង្វល់គឺរាគ: កង្វល់ គឺទោស: កង្វល់ គឺមោហ: កង្វល់ គឺមានះ កង្វល់ គឺទិដ្ឋិ កង្វល់ គឺកិលេស កង្វល់ គឺទុច្ចរិត កង្វល់នេះ កុំមាន កុំជិតដល់ កុំមានប្រាកដដល់អ្នក គឺថា អ្នកចូរលះបង់ បន្ទោបង់ ធ្វើឲ្យវិនាស មិនឲ្យកើតមាន ហេតុនោះ ( ទ្រង់ត្រាស់ថា ) កង្វល់ក្តី កុំមានដល់អ្នកឡើយ ។ ហេតុនោះ ព្រះមានព្រះភាគត្រាស់ថា

( ព្រះមានព្រះភាគ ត្រាស់ថា ម្នាលជតុកណ្ណី ) អ្នកចូរឃើញនូវនេក្ខម្ម: ថាជាសេចក្តីក្សេម ហើយកម្ចាត់បង់នូវសេចក្តីប្រាថ្នាក្នុងកាមទាំងឡាយចេញ មួយទៀត ការប្រកាន់ក្តី ការត្រូវលោស់

ចេញក្តី កន្លល់ក្តី កុំមានដល់អ្នកឡើយ ។

[ ៤០០ ] កិលេសជាតណា ( ធ្លាប់មានហើយ ) ក្នុងកាលមុន អ្នកចូរញ៉ាំងកិលេសជាតនោះ ឲ្យរីងស្ងួតទៅ កន្លល់ខាងក្រោយ កុំមានដល់អ្នកឡើយ បើអ្នកនឹងមិនកាន់យកខន្ធជាកណ្តាលទេ អ្នកនឹងជាបុគ្គលស្ងប់ ត្រាច់ទៅ ។

[ ៤០១ ] ពាក្យថា កិលេសជាតណា ( ធ្លាប់មានហើយ ) ក្នុងកាលមុន អ្នកចូរញ៉ាំងកិលេសជាតនោះ ឲ្យរីងស្ងួតទៅ គឺពួកកិលេសណា គប្បីកើត ព្រោះប្រារព្ធសង្ខារទាំងឡាយជាអតីត អ្នកចូរញ៉ាំងកិលេសទាំងនោះឲ្យរីង ឲ្យស្ងួត ឲ្យខះ ឲ្យហួតហែង ចូរធ្វើកុំឲ្យមានពូជ ចូរលះបង់ បន្ទោបង់ ធ្វើឲ្យវិនាស ធ្វើមិនឲ្យកើតមាន ហេតុនោះ ( ទ្រង់ត្រាស់ថា ) កិលេសជាតណា ( ធ្លាប់មានហើយ ) ក្នុងកាលមុន អ្នកចូរញ៉ាំងកិលេសជាតនោះ ឲ្យរីងស្ងួតទៅ យ៉ាងនេះក៏មាន ។ មួយទៀត ពួកកម្មាភិសង្ខារណា ជាអតីត មានវិបាកចាស់ក្លាហើយ អ្នកចូរញ៉ាំងកម្មាភិសង្ខារទាំងនោះ ឲ្យរីង ឲ្យស្ងួត ឲ្យខះ ឲ្យហួតហែង ចូរធ្វើកុំឲ្យមានពូជ ចូរលះបង់ បន្ទោបង់ ធ្វើឲ្យវិនាស ធ្វើមិនឲ្យកើតមាន ហេតុនោះ ( ទ្រង់ត្រាស់ថា ) កិលេសជាតណា ( ធ្លាប់មានហើយ ) ក្នុងកាលមុន អ្នកចូរញ៉ាំងកិលេសជាតនោះ ឲ្យរីងស្ងួតទៅ យ៉ាងនេះក៏មាន ។

[ ៤០២ ] ពាក្យថា កន្លល់ខាងក្រោយកុំមានដល់អ្នកឡើយ សេចក្តីថា កន្លល់ជាអនាគត ហៅថា កន្លល់ខាងក្រោយ បានដល់ កន្លល់ គឺភគ:

កង្វល់ គឺទោសៈ កង្វល់ គឺមោហៈ កង្វល់ គឺមានះ កង្វល់ គឺទិដ្ឋិ កង្វល់ គឺកិលេស កង្វល់ គឺទុច្ចរិត ព្រោះប្រារព្ធសង្ខារទាំងឡាយជាអនាគត កង្វល់នេះ កុំមាន កុំឲ្យកើតមានដល់អ្នក អ្នកចូរកុំញុំាងកង្វល់ឲ្យកើត កុំបង្ក កុំឲ្យលូតលាស់ឡើង ចូរលះបង់ បន្ទោបង់ ធ្វើឲ្យវិនាស ធ្វើមិនឲ្យកើតមានហេតុនោះ ( ទ្រង់ត្រាស់ថា ) កង្វល់ខាងក្រោយ កុំមានដល់អ្នកឡើយ ។

[ ៤០៣ ] ពាក្យថា បើអ្នកមិនកាន់យកខន្ធជាកណ្តាលទេ សេចក្តីថា រូប វេទនា សញ្ញា សង្ខារ វិញ្ញាណ ជាបច្ចុប្បន្ន លោកហៅថា ខន្ធជាកណ្តាល អ្នកនឹងមិនកាន់យក មិនចាប់ មិនស្ទាបអង្អែល មិនរីករាយ មិនជ្រុលជ្រប់ចំពោះសង្ខារទាំងឡាយ ជាបច្ចុប្បន្ន ដោយអំណាចតណ្ហា ដោយអំណាចទិដ្ឋិ គឺថា បើអ្នកនឹងលះបង់ បន្ទោបង់ ធ្វើឲ្យវិនាស ធ្វើមិនឲ្យកើតមានទូវសេចក្តីរីករាយ ការជ្រុលជ្រប់ ការប្រកាន់ ការស្ទាបអង្អែល ការជាប់ជំពាក់ ហេតុនោះ ( ទ្រង់ត្រាស់ថា ) បើអ្នកនឹងមិនកាន់យកខន្ធជាកណ្តាលទេ ។

[ ៤០៤ ] ពាក្យថា អ្នកនឹងជាបុគ្គលស្ងប់ត្រាច់ទៅ គឺឈ្មោះថា អ្នកស្ងប់ ព្រោះស្ងប់រាគៈ ឈ្មោះថា អ្នកស្ងប់ ព្រោះស្ងប់ទោសៈ ឈ្មោះថា អ្នកស្ងប់ ព្រោះស្ងប់មោហៈ ឈ្មោះថា អ្នកស្ងប់ ស្ងប់រម្ងាប់ រម្ងាប់សូន្យ រលត់ រសាយ រលាយ ព្រោះស្ងប់រម្ងាប់ រម្ងាប់សូន្យ ផុតរម្ងត់ ទៅប្រាស រសាយ រលាយ នូវក្រោធៈ ឧបនាហៈ ។បេ។ អភិសង្ខារជាអកុសលទាំងពួង ហើយនឹងត្រាច់ទៅ ត្រាច់ទៅផ្សេងៗ ប្រព្រឹត្ត រក្សា យាត្រា យាត្រាទៅ ហេតុនោះ ( ទ្រង់ត្រាស់ថា ) អ្នកនឹងជាបុគ្គលស្ងប់ត្រាច់ទៅ ។ ហេតុ

នោះ ព្រះមានព្រះភាគត្រាស់ថា

កិលេសជាតណា ( ធ្លាប់មានហើយ ) ក្នុងកាលមុន អ្នកចូរញ៉ាំងកិលេសជាតនោះ ឲ្យរីងស្ងួតទៅ កង្វល់ខាងក្រោយ កុំមានដល់អ្នកឡើយ បើអ្នកនឹងមិនកាន់យកខន្ធជាកណ្ដាលទេ អ្នកនឹងជាបុគ្គលស្ងប់ ត្រាច់ទៅ ។

[ ៤០៥ ] ម្នាលព្រាហ្មណ៍ បុគ្គលតែងលុះអំណាចមច្ចុ ដោយអាសវៈទាំងឡាយណា អាសវៈ ( ទាំងនោះ ) របស់បុគ្គលដែលប្រាសចាកតម្រេក ក្នុងនាមរូបដោយប្រការទាំងពួងនោះ មិនមានទេ ។

[ ៤០៦ ] អធិប្បាយពាក្យថា ម្នាលព្រាហ្មណ៍ ... ដែលប្រាសចាកតម្រេកក្នុងនាមរូប ដោយប្រការទាំងពួង ត្រង់ពាក្យថា ដោយប្រការទាំងពួង គឺព្រោះទាំងអស់ សព្វទាំងអស់ មិនមានសល់ ឥតសេសសល់ ។ ពាក្យថា ដោយប្រការទាំងពួងនោះ ជាពាក្យប្រមូល ។ ពាក្យថា នាម បានដល់អរូបក្ខន្ធ ៤ ។ ពាក្យថា រូប បានដល់ មហាភូតរូប ៤ និងឧបាទាយរូបរបស់មហាភូតរូប ៤ ។ តណ្ហា លោកហៅថា តម្រេក បានដល់ រាគៈ រាគៈមានកម្លាំង ។បេ។ អភិជ្ឈា លោភៈ អកុសលមូល ។ ពាក្យថា ម្នាលព្រាហ្មណ៍ ... ដែលប្រាសចាកតម្រេកក្នុងនាមរូប ដោយប្រការទាំងពួង បានសេចក្ដីថា ប្រាសចាកប្រាថ្នា ឃ្លាតចាកប្រាថ្នា ចោលប្រាថ្នា ខ្ជាក់ប្រាថ្នា លែងប្រាថ្នា លះប្រាថ្នា រលាស់ប្រាថ្នា គឺជាអ្នកប្រាសចាករាគៈ ឃ្លាតចាក

រាគៈ បោលរាគៈ ខ្ជាក់រាគៈ លែងរាគៈ លះរាគៈ រលាស់រាគៈ ក្នុងនាមរូប ដោយប្រការទាំងពួង ហេតុនោះ ( ទ្រង់ត្រាស់ថា ) ម្នាលព្រាហ្មណ៍ ... ដែលប្រាសចាកតម្រេក ក្នុងនាមរូប ដោយប្រការទាំងពួង ។

[ ៤០៧ ] អធិប្បាយពាក្យថា អាសវៈទាំងឡាយរបស់បុគ្គលនោះ មិនមានទេ ត្រង់ពាក្យថា អាសវៈ បានដល់ អាសវៈ ៤ គឺកាមាសវៈ ភវាសវៈ ទិដ្ឋាសវៈ អវិជ្ជាវៈ ។ ពាក្យថា របស់បុគ្គលនោះ គឺរបស់ព្រះអរហន្ត-ខីណាស្រព ។ ពាក្យថា មិនមាន គឺអាសវៈទាំងនេះ របស់ព្រះអរហន្តនោះ មិនមាន ឥតមាន លែងមាន គឺលោកមិនបាន លោកលះបង់ ផ្តាច់ផ្តិល រម្ងាប់ ធ្វើឲ្យស្ងប់រម្ងាប់ ធ្វើមិនគួរឲ្យកើតឡើងបាន ដុតដោយភ្លើង គឺញាណហើយ ហេតុនោះ ( ទ្រង់ត្រាស់ថា ) អាសវៈទាំងឡាយ របស់បុគ្គលនោះ មិនមានទេ ។

[ ៤០៨ ] ពាក្យថា បុគ្គលតែងលុះអំណាចមច្ចុ ដោយអាសវៈទាំងឡាយណា សេចក្តីថា បុគ្គលតែងលុះអំណាចមច្ចុក្តី លុះអំណាចមរណៈក្តី លុះអំណាចមារក្តី ដោយអាសវៈទាំងឡាយណា អាសវៈទាំងនោះ របស់ព្រះអរហន្តនោះ មិនមាន ឥតមាន លែងមាន គឺលោកមិនបាន លោកលះបង់ ផ្តាច់ផ្តិល ឲ្យស្ងប់ រម្ងាប់ ធ្វើមិនគួរឲ្យកើតឡើងបាន ដុតដោយភ្លើង គឺញាណហើយ ហេតុនោះ ( ទ្រង់ត្រាស់ថា ) បុគ្គលតែងលុះអំណាចមច្ចុ ដោយអាសវៈទាំងឡាយណា ។ ហេតុនោះ ព្រះមានព្រះភាគត្រាស់ថា

ម្នាលព្រាហ្មណ៍ បុគ្គលតែងលុះអំណាចមច្ចុ ដោយអាសវៈទាំងឡាយណា អាសវៈ ( ទាំងនោះ ) របស់បុគ្គលដែលប្រាសចាកតម្រេកក្នុងនាមរូប ដោយប្រការទាំងពួងនោះ មិនមានទេ ។

ដំណាលគ្នានឹងកាលជាទីចប់នៃគាថា ។បេ។ បពិត្រព្រះអង្គដ៏ចម្រើន ព្រះមានព្រះភាគ ជាសាស្តារបស់ខ្ញុំព្រះអង្គ ខ្ញុំព្រះអង្គជាសាវ័ក ។

## ជតុកណ្ណីមាណវកបញ្ហានិទ្ទេសទី ១១ ចប់

# អដ្ឋកថា

## ជតុកណ្ណីមាណវកប្បញ្ហានិទ្ទេស

[ ៣៨៤ ] គប្បីជ្រាបវិនិច្ឆ័យក្នុងជតុកណ្ណីសូត្រទី ១១ ដូចតទៅ

បទថា **សុត្វានហំ វីរ អកាមកាមឹ** បានដល់ បពិត្រព្រះអង្គដ៏ចម្រើន ទ្រង់ជាអ្នកក្លៀវក្លា ខ្ញុំព្រះអង្គបានស្តាប់ហើយថា ទ្រង់មិនមានសេចក្តីប្រាថ្នាក្នុងកាម ព្រោះមិនត្រូវការកាមទាំងឡាយ ដោយន័យជាដើមថា **ឥតិបិ សោ ភគវា** ដូច្នេះ ។ បទថា **អកាមមាគមំ** បានដល់ ខ្ញុំព្រះអង្គមកគាល់ដើម្បីទូលសួរព្រះមានព្រះភាគ ដែលទ្រង់មិនមានកាម ។ បទថា **សហាជនេត្ត** បានដល់ ចក្ខុ គឺសព្វញ្ញុតញ្ញាណ ដែលកើតព្រមនឹងការ ត្រាស់ដឹង ។ បទថា **យថាតច្ឆំ** សេចក្តីថា តាមសេចក្តីពិត ។ ជតុកណ្ណីមាណពទូលអារាធនាទៀតថា សូមព្រះអង្គសម្តែងសន្តិបទនោះ ដែលជាធម៌ពិត ដល់ខ្ញុំព្រះអង្គឲ្យទាន ដ្បិតថា បុគ្គលកាលសូម គប្បីសូម ១០០០ ដង នឹងពោលទៅថ្វីត្រឹមតែ ២ ដង ។

[ ៣៨៥ ] សេចក្តីនៃបទទាំងឡាយនេះថា **ឥតិបិ សោ ភគវា អរហំ សម្មាសម្ពុទ្ធោ** បានពោលពិស្តារហើយខាងដើម ។ ព្រះមានព្រះភាគ ឈ្មោះថា **វិជ្ជាចរណសម្បន្នោ** ព្រោះជាអ្នកដល់ព្រមហើយដោយវិជ្ជា និងចរណៈ ។ ក្នុងបទនោះ បទថា **វិជ្ជា** បានដល់ វិជ្ជា ៣ ខ្លះ វិជ្ជា ៨ ខ្លះ ។ វិជ្ជា ៣ គប្បីជ្រាបដោយន័យដែលពោលហើយ ក្នុងភយភេរវសូត្រនោះឯង ។ វិជ្ជា ៨ គប្បីជ្រាបដោយន័យដែលពោលហើយក្នុងអម្ពដ្ឋសូត្រ ។ ក្នុងអម្ពដ្ឋសូត្រនោះ

លោកពោលវិជ្ជា ៨ ដោយកំណត់យកអភិញ្ញា ៦ មួយអន្លើដោយវិបស្សនាញាណ និងមនោមយិទ្ធិ ។ គប្បីជ្រាបធម៌ទាំង ១៥ យ៉ាង គឺការសង្រួមក្នុងសីល ១ ភាពជាអ្នកមានការគ្រប់គ្រងហើយក្នុងឥន្ទ្រិយទាំងឡាយ ១ ភាពជាអ្នកស្គាល់ប្រមាណក្នុងការបរិភោគ ១ ការប្រកបសេចក្ដីព្យាយាម ១ សទ្ធម្ម ៧ រូបាវចរជ្ឈាន ៤ ឈ្មោះថា **ចរណៈ**។ ព្រោះអរិយសាវករមែងប្រព្រឹត្តទៅកាន់ទិសដែលជាអមតៈ ដោយធម៌ ១៥ នេះ ដូច្នោះ ទើបពោលថា **ចរណៈ** សមដូចព្រះមានព្រះភាគត្រាស់ថា បពិត្រមហានាម អរិយសាវកក្នុងសាសនានេះ ជាអ្នកមានសីល ដូច្នេះ ។ បទទាំងពួង គប្បីជ្រាបដោយន័យដែលពោលហើយ ក្នុងមជ្ឈិមបណ្ណាសក ។ ព្រះមានព្រះភាគទ្រង់ប្រកបដោយវិជ្ជាទាំងឡាយនេះ និងដល់ចរណៈនេះ ដោយហេតុនេះ ទើបហៅថា **វិជ្ជាចរណសម្បន្នោ** ។ ក្នុងបទនោះ ការដល់ព្រមដោយវិជ្ជា ញុំាងព្រះសព្វញ្ញុតញ្ញាណរបស់ព្រះមានព្រះភាគឲ្យបរិបូណ៌ តាំងនៅ ។ ការដល់ព្រមដោយចរណៈ ញុំាងភាពជាអ្នកមានព្រះមហាករុណាឲ្យបរិបូណ៌ តាំងនៅ ។ ព្រះមានព្រះភាគអង្គនោះ ទ្រង់ជ្រាបដល់ប្រយោជន៍ និងមិនមែនប្រយោជន៍របស់សព្វសត្វ ព្រោះព្រះសព្វញ្ញុតញ្ញាណ ទើបទ្រង់វៀរនូវវត្ថុមិនជាប្រយោជន៍ ប្រកបសត្វទាំងឡាយក្នុងវត្ថុដែលជាប្រយោជន៍ ព្រោះទ្រង់មានព្រះមហាករុណា សមដូចព្រះអង្គព្រះនាមថា **វិជ្ជាចរណសម្បន្នោ** ។ ដោយហេតុនោះ ទើបសាវករបស់ព្រះអង្គ ជាអ្នកបដិបត្តិប្រពៃ មិនមែនបដិបត្តិមិនប្រពៃ ដូចសាវករបស់អ្នកបដិបត្តិខុស ក្នុងវិជ្ជា និងចរណៈ មានការធ្វើខ្លួន

ឲ្យក្តៅជាដើម ។

ព្រះមានព្រះភាគ ព្រះនាមថា **សុគតោ** ព្រោះយាងទៅល្អ យាងទៅកាន់ឋានៈដែលល្អ យាងទៅដោយប្រពៃ និងព្រោះត្រាស់ប្រពៃ ។ ពិតហើយ សូម្បីការទៅ ក៏ហៅថា **គតំ** ។ ការយាងទៅនៃព្រះមានព្រះភាគអង្គនោះ ស្អាតបរិសុទ្ធ មិនមានទោស ។ សួរថា ការទៅនោះ គឺអ្វី ឆ្លើយថា គឺអរិយមគ្គ ។ ដោយហេតុដែលព្រះមានព្រះភាគអង្គនោះ យាងទៅកាន់ទិសដែលក្សេម មិនជាប់ជំពាក់ ដោយការយាងទៅ ព្រោះហេតុនោះ ទើបឈ្មោះថា **សុគតោ** ព្រោះយាងទៅល្អ ។ម្យ៉ាងទៀត ព្រះមានព្រះភាគអង្គនោះ យាងទៅកាន់ឋានៈដែលល្អ គឺអមតនិព្វាន ព្រោះហេតុនោះ ទើបឈ្មោះថា **សុគតោ** ព្រោះយាងទៅកាន់ឋានៈដែលល្អ ម្យ៉ាងទៀត ព្រះអង្គយាងទៅហើយដោយប្រពៃ ទ្រង់មិនត្រឡប់មករកកិលេស ដែលទ្រង់លះបានហើយដោយមគ្គនោះៗ សមដូចលោកពោលថា ព្រះមានព្រះភាគ ព្រះនាមថា **សុគតោ** ព្រោះកិលេសទាំងឡាយណា ដែលលោកលះបង់ហើយដោយសោតាបត្តិមគ្គ លោកមិនមក គឺមិនវិលមក មិនត្រឡប់មកកាន់កិលេសទាំងឡាយនោះទៀតទេ ។បេ។ ដោយអរហត្តមគ្គ លោកមិនមក គឺមិនវិលមក មិនត្រឡប់មកកាន់កិលេសទាំងឡាយនោះទៀតទេ ។ ឬថា ទ្រង់យាងទៅដោយល្អ ទ្រង់បំពេញប្រយោជន៍សុខប៉ុណ្ណោះដល់លោកទាំងពួង ដោយទ្រង់បដិបត្តិប្រពៃបរិសុទ្ធ ព្រោះទ្រង់បំពេញបារមីគ្រប់ ៣០ ចាប់អំពីបាទមូលរបស់ព្រះទីបង្ករសម្ពុទ្ធ ដរាបដល់ពោធិមណ្ឌល មិនចូលដល់អន្តធម៌ទាំងនេះ

គឺសស្សតទិដ្ឋិ ឧច្ឆេទទិដ្ឋិ កាមសុខ និងការធ្វើខ្លួនឲ្យលំបាក យាងទៅហើយ ព្រោះហេតុនោះ ទើបទ្រង់ព្រះនាមថា **សុគតោ** ព្រោះយាងទៅដោយប្រពៃ ។ ម្យ៉ាងទៀត ព្រះមានព្រះភាគអង្គនោះត្រាស់ប្រពៃ ត្រាស់ព្រះវាចាដ៏សមគួរ ក្នុងឋានៈដែលសមគួរ ព្រោះហេតុនោះ ទើបទ្រង់ព្រះនាមថា **សុគតោ** ព្រោះត្រាស់ប្រពៃ ។

ក្នុងរឿងនោះ មានសូត្រ ( អភយរាជកុមារសូត្រ ) សាធកៈដូចតទៅ

តថាគតដឹងនូវវាចាណា ដែលមិនពិត មិនទៀង មិនប្រកបដោយប្រយោជន៍ វាចានោះ មិនជាទីស្រឡាញ់ មិនជាទីគាប់ចិត្ត របស់ជនទាំងឡាយដទៃផង តថាគតក៏មិនពោលវាចានោះ តថាគតដឹងនូវវាចាណា ដែលពិត ទៀង តែមិនប្រកបដោយប្រយោជន៍ វាចានោះ មិនជាទីស្រឡាញ់ មិនជាទីគាប់ចិត្ត របស់ជនទាំងឡាយដទៃផង តថាគតក៏មិនពោលនូវវាចានោះដែរ មួយវិញទៀត តថាគតដឹងនូវវាចាណា ដែលពិត ទៀង ប្រកបដោយប្រយោជន៍ តែជាវាចានោះ មិនជាទីស្រឡាញ់ មិនជាទីគាប់ចិត្ត របស់ជនទាំងឡាយដទៃ តថាគតស្គាល់កាល គួរនឹងពោលវាចានោះ ក្នុងព្យាករនោះដែរ តថាគតដឹងនូវវាចាណា ដែលមិនពិត មិនទៀង មិនប្រកបដោយប្រយោជន៍ វាចានោះ ទោះបីជាទីស្រឡាញ់ ជាទីគាប់ចិត្ត របស់ជនទាំងឡាយដទៃ តថាគតក៏មិនពោលវាចានោះឡើយ តថាគតដឹងនូវវាចាណា ដែលពិត ទៀង តែមិនប្រកប

ដោយប្រយោជន៍ វាចានោះ ទោះបីជាទីស្រឡាញ់ ជាទីគាប់ចិត្ត របស់ជនទាំងឡាយដទៃ តថាគតក៏មិនពោលវាចានោះដែរ មួយវិញទៀត តថាគតដឹងនូវវាចាណា ដែលពិត ទៀង ប្រកបដោយប្រយោជន៍ វាចានោះ ជាទីស្រឡាញ់ ជាទីគាប់ចិត្ត របស់ជនទាំងឡាយដទៃផង តថាគតស្គាល់កាល គួរនឹងពោលនូវវាចានោះ ក្នុងព្យាករនោះ ដូច្នេះ ។

គប្បីជ្រាបថា ព្រះមានព្រះភាគ ព្រះនាមថា **សុគតោ** ព្រោះត្រាស់ប្រពៃ ដោយប្រការដូច្នេះ ។ ព្រះមានព្រះភាគ ព្រះនាមថា **លោកវិទូ** ព្រោះទ្រង់ដឹងច្បាស់នូវលោក ដោយប្រការទាំងពួង ។ ពិតហើយ ព្រះមានព្រះភាគអង្គនោះ ទ្រង់ដឹងច្បាស់ទូទៅ ទ្រង់ចាក់ធ្លុះលោក ដោយប្រការទាំងពួង គឺដោយសភាវៈ ដោយហេតុកើត ដោយការរលត់ ដោយឧបាយនៃការរលត់ សមដូចព្រះមានព្រះភាគត្រាស់ ( ក្នុងសំយុត្តនិកាយ សគាថវគ្គ ) ថា

ម្នាលអាវុសោ សត្វមិនកើត មិនចាស់ មិនស្លាប់ មិនច្យុត មិនចាប់បដិសន្ធិ ក្នុងទីបំផុតនៃលោកណា តថាគតមិនពោលថា ទីបំផុតនៃលោកនោះ បុគ្គលគប្បីដឹង គប្បីឃើញ គប្បីដល់ដោយការទៅដោយជើង ដូច្នេះឡើយ ម្នាលអាវុសោ មួយទៀត តថាគតមិនបានពោលនូវដំណើរ ដែលសត្វមិនបានដល់នូវទីបំផុតនៃសង្ខារលោក ហើយធ្វើនូវទីបំផុតនៃវដ្តទុក្ខទេ ម្នាលអាវុសោ

ម្យ៉ាងទៀត តថាគតសម្ដែងនូវលោក គឺទុក្ខសច្ចផង នូវហេតុជាទីកើតឡើងនៃលោក គឺសមុទយសច្ចផង នូវទីរលត់នៃលោក គឺនិរោធសច្ចផង នូវបដិបទាជាហេតុទៅកាន់ទីរលត់នៃលោក គឺមគ្គសច្ចផង ក្នុងអត្តភាពប្រមាណមួយព្យាម ដែលប្រកបដោយសញ្ញា ប្រកបដោយចិត្តនេះទេតើ ។

ទីបំផុតនៃលោក បុគ្គលមិនគប្បីដល់ ដោយការទៅ ដោយជើងក្នុងកាលណាៗ ឡើយ ឯការមិនបានដល់នូវទីបំផុតនៃលោក ហើយរួចស្រឡះចាកទុក្ខ មិនមានទេ ព្រោះហេតុនោះ បុគ្គលអ្នកមានបញ្ញាល្អ ដឹងច្បាស់នូវលោក ដល់នូវទីបំផុតនៃលោក មានព្រហ្មចរិយធម៌ នៅស្រេចហើយ មានបាបរម្ងាប់បង់ហើយ ដឹងនូវទីបំផុតនៃលោក រមែងមិនប្រាថ្នានូវលោកនេះផង នូវលោកខាងមុខផង ដូច្នេះ ។

ម្យ៉ាងទៀត លោកមាន ៣ យ៉ាង គឺសង្ខារលោក ១ សត្វលោក ១ ឱកាសលោក ១ ក្នុងលោកទាំង ៣ នោះ គប្បីជ្រាបសង្ខារលោក ក្នុងអាគតដ្ឋានថា លោក ១ បានដល់ ពួកសត្វទាំងអស់ដែលតាំងនៅបានដោយអាហារ ។ គប្បីជ្រាបសត្វលោកក្នុងអាគតដ្ឋានថា លោកទៀង ឬថា លោកមិនទៀង ។ គប្បីជ្រាបឱកាសលោក ក្នុងអាគតដ្ឋានថា

ព្រះអង្គត្រាស់ថា ព្រះចន្ទ្រ និងព្រះអាទិត្យទាំងឡាយ ដើរបំភ្លឺទិសទាំងឡាយ ឲ្យភ្លឺបានត្រឹមណា លោក គឺចក្រវាលទាំងមួយពាន់

ក៏កំណត់ត្រឹមនោះ អំណាចរបស់អ្នកប្រព្រឹត្តទៅ បានតែត្រឹមចក្រវាលមួយពាន់ទុំ ។

ព្រះមានព្រះភាគ ទ្រង់ដឹងឱកាសលោកនោះ ដោយប្រការទាំងពួងពិតហើយ លោក ១ បានដល់ ពួកសត្វទាំងអស់ដែលតាំងនៅបានដោយអាហារ លោក ២ បានដល់ នាម ១ រូប ១ លោក ៣ បានដល់ វេទនា ៣ លោក ៤ បានដល់ អាហារ ៤ លោក ៥ បានដល់ ឧបាទានក្ខន្ធ ៥ លោក ៦ បានដល់ អាយតនៈខាងក្នុង ៦ លោក ៧ បានដល់ ទីតាំងនៃវិញ្ញាណ ៧ លោក ៨ បានដល់ លោកធម៌ ៨ លោក ៩ បានដល់ ទីនៅរបស់សត្វ ៩ លោក ១០ បានដល់ អាយតនៈទាំង ១០ លោក ១២ បានដល់ អាយតនៈ ១២ លោក ១៨ បានដល់ ធាតុ ១៨ ។ សូម្បីសង្ខារលោកនេះ ព្រះមានព្រះភាគ ទ្រង់ក៏ជ្រាបដោយប្រការទាំងពួង ។ម្យ៉ាងទៀត ព្រះមានព្រះភាគអង្គនោះ ទ្រង់ដឹងអធ្យាស្រ័យ អនុស័យ ចរិត ឧបនិស្ស័យ គឺទ្រង់ដឹងសត្វទាំងឡាយ មានកិលេសដូចធូលីក្នុងភ្នែកតិច មានកិលេសដូចធូលីក្នុងភ្នែកច្រើន មានឥន្ទ្រិយចាស់ក្លា មានឥន្ទ្រិយទន់ មានអាការល្អ មានអាការអាក្រក់ ឲ្យត្រាស់ដឹងបានងាយ ឲ្យត្រាស់ដឹងបានលំបាក គួរត្រាស់ដឹង មិនគួរត្រាស់ដឹង ដូច្នោះ ទើបទ្រង់ដឹងច្បាស់នូវសត្វលោក ដោយប្រការទាំងពួង ឱកាសលោក ទ្រង់ក៏ដឹងច្បាស់ដូចសត្វលោក ។ ពិតហើយ ឱកាសលោកនោះ ជាចក្រវាលមួយ ដោយបណ្តាយ ដោយទទឹង ១២៤៥០ យោជន៍ ដោយជុំវិញ ។

ចក្រវាលទាំងអស់ មានបរិមណ្ឌល ៣៦១០៣៥០ យោជន៍ ។ ក្នុងចក្រវាលនោះ ផែនដីនេះ ពោលដោយកម្រាស់ ២៤០០០០ យោជន៍ ទឹកទ្រផែនដី ៤៨០០០០ យោជន៍ តាំងនៅលើខ្យល់ ។ ខ្យល់ដែលទ្រទឹកនោះ ផ្សាយឡើងទៅកាន់អាកាស ៩៦០០០០ យោជន៍ នេះជាការតាំងនៅរបស់លោក ។

កាលលោកតាំងនៅយ៉ាងនេះ ភ្នំសិនេរុចាក់ឫសទៅក្នុងមហាសមុទ្រ ៨៤០០០ យោជន៍ កម្ពស់ឡើងទៅលើ ៨៤០០០ យោជន៍ ដូចគ្នា ។

មានភ្នំធំសម្រេចដោយថ្មក្រាស់ ៧ ជាន់ គឺភ្នំយុគន្ធរ ១ ឥសិន្ធរ ១ ករវិក ១ សុទស្សនៈ ១ នេមិន្ធរ ១ វិនតកៈ ១ អស្សកណ្ណ ១ សម្រេចដោយរតនៈផ្សេងៗ ដូចភ្នំទិព្វ មានឫសចាក់ចុះក្នុងមហាសមុទ្រ និងកម្ពស់ឡើងទៅលើ ប្រមាណពាក់កណ្ដាលៗ ចុះមកតាមលំដាប់ ដូចកាំជណ្ដើរដោយជុំវិញភ្នំសិនេរុរាជ ជាលំនៅរបស់ទេវមហារាជ ជាទីនៅរបស់ទេវតា និងយក្ខ ។

ភ្នំហិមពាន្តមានកម្ពស់ ៥០០ យោជន៍ បណ្ដោយ និងទទឹង ៣០០០ យោជន៍ ប្រដាប់ដោយកំពូល ៨៤០០០ កំពូល ។

ទ្វីបនេះ ជនទាំងឡាយហៅថា ជម្ពូទ្វីប ព្រោះអានុភាពរបស់ដើមព្រីង ដែលមានឈ្មោះថា នគៈ វាស់ដោយជុំវិញដើម បាន ១៥ យោជន៍ វិកាយមែកដែលដុះពីដើមចេញទៅ ៥០ យោជន៍

រំកាយមែកដោយជុំវិញ ១០០ យោជន៍ កម្ពស់ ១០០ យោជន៍ដូចគ្នា ។

ឯទំហំដើមព្រីងនេះប៉ុនណា ដើមប្រទៀងរបស់ពួកអសុរ ដើមរកា របស់ពួកគ្រុឌ ដើមកុម្ពក្នុងអមរគោយានទ្វីប ដើមកប្បព្រឹក្សក្នុងឧត្តរកុរុទ្វីប ដើមប្រេសក្នុងបុព្វវិទេហទ្វីប ដើមបារិច្ឆត្តកៈក្នុងស្ថានតាវត្តិង្ស ក៏មានទំហំប៉ុណ្ណោះដូចគ្នា ។

ដោយហេតុនោះ ទើបបុរាណាចារ្យពោលថា ដើមប្រទៀង ដើមរកា ដើមព្រីង ដើមបារិច្ឆត្តកៈ របស់ពួកទេវតា ដើមកុម្ព ដើមកប្បព្រឹក្ស ដើមប្រេស កើតឡើងជាគម្រប់ ៧ ។ ការកើតឡើងនៃភ្នំកណ្តាប់ចក្រវាល ចាក់ឫសទៅក្នុងមហាសមុទ្រ ៨២០០០ យោជន៍ កម្ពស់ឡើងទៅលើ ក៏មានប្រមាណប៉ុណ្ណោះដូចគ្នា តាំងនៅព័ទ្ធជុំវិញលោកធាតុនោះទាំងអស់ តាំងនៅ ។

ក្នុងចក្រវាលនោះ ចន្ទមណ្ឌលមានប្រមាណ ៤៩ យោជន៍ សូរិយមណ្ឌលមានប្រមាណ ៥០ យោជន៍ ។ តាវត្តិង្សភពមានទំហំ ប្រមាណ ១០០០០ យោជន៍ អសុរភព អវីចិមហានរក និងជម្ពូទ្វីបក៏ដូចគ្នា អមរគោយានទ្វីបមានទំហំប្រមាណ ៧០០០ យោជន៍ បុព្វវិទេហទ្វីបក៏ដូចគ្នា ឧត្តរកុរុទ្វីបមានទំហំប្រមាណ ៨០០០ យោជន៍ ។ ក្នុងចក្រវាលនេះ មហាទ្វីបនីមួយៗ មានទ្វីបតូចមួយទ្វីប ៥០០ ជាបរិវារ ។ សម្ភារៈទាំងអស់នោះ ជាចក្រវាលមួយ គឺជាលោកធាតុមួយ លោកន្តរិកនរក តាំងនៅចន្លោះ

លោកធាតុនោះ ។ ដោយប្រការដូច្នេះ ទើបព្រះមានព្រះភាគទ្រង់ដឹង ទ្រង់ដឹងទូទៅ ទ្រង់ចាក់ធ្លុះនូវចក្រវាលដែលមិនមានទីបំផុត លោកធាតុដែលមិនមានទីបំផុត ដោយព្រះពុទ្ធញ្ញាណ ដែលមិនមានទីបំផុត ។ សូម្បីឱកាសលោក ទ្រង់ក៏ដឹងច្បាស់ ដោយប្រការទាំងពួងយ៉ាងនោះ ។ ព្រះមានព្រះភាគ ព្រះនាមថា ជាលោកវិទូ ព្រោះទ្រង់ដឹងច្បាស់នូវលោក ដោយប្រការទាំងពួង ដោយប្រការដូច្នេះ ។

ម្យ៉ាងទៀត ព្រះមានព្រះភាគ ទ្រង់ព្រះនាមថា **អនុត្តរោ** ព្រោះមិនមានបុគ្គលណាមួយប្រសើរជាង ដោយព្រះគុណរបស់ព្រះអង្គ គឺមិនមានបុគ្គលក្រៃលែងជាង ។ ពិតហើយ ព្រះមានព្រះភាគ ទ្រង់គ្របសង្កត់នូវលោក ដោយគុណ គឺសីលខ្វះ ដោយគុណ គឺសមាធិ បញ្ញា វិមុត្តិ វិមុត្តិញ្ញាណទស្សនៈខ្វះ ព្រះមានព្រះភាគ មិនមានបុគ្គលស្មើ ទ្រង់ស្មើជាបុគ្គលដែលមិនមានបុគ្គលស្មើ មិនមានបុគ្គលប្រៀប មិនមានបុគ្គលផ្ទឹម រកបុគ្គលប្រៀបមិនបាន ដោយគុណ គឺសីលខ្វះ ដោយគុណ គឺសមាធិ បញ្ញា វិមុត្តិ វិមុត្តិញ្ញាណទស្សនៈខ្វះ សមដូចទ្រង់ត្រាស់ថា តែថា ក្នុងលោក ព្រមទាំងទេវលោក ។បេ។ ព្រមទាំងសម្មតិទេព និងមនុស្សដ៏សេស អាត្មាអញ មិនបានឃើញសមណៈ ឬព្រាហ្មណ៍ដទៃ ដែលបរិបូណ៌ដោយសីលជាងខ្លួនអញ ។ សូត្រនេះ គប្បីធ្វើឲ្យពិស្តារ ។

គប្បីញ៉ាំងអគ្គប្បសាទសូត្រជាដើម និងញ៉ាំងគាថាទាំងឡាយជាដើមថា តថាគតមិនមានអាចារ្យទេ ដូច្នេះ ឲ្យពិស្តារ ដោយប្រការដូច្នេះ ។

ព្រះមានព្រះភាគ ទ្រង់ព្រះនាមថា **បុរិសទម្មសារថិ** ព្រោះទ្រង់ទូន្មានបុរសដែលគួរទូន្មានបាន អធិប្បាយថា ទូន្មាន គឺដឹកនាំ ។ បទថា **បុរិសទម្ម** ក្នុងបទថា **បុរិសទម្មសារថិ** នោះ បានដល់ បុរសដែលមិនទាន់បានទូន្មានដែលគួរទូន្មានបាន ជាតិរច្ឆានបុរសក្តី មនុស្សបុរសក្តី អមនុស្សបុរសក្តី ។ ពិតហើយ តិរច្ឆានបុរសជាដើម ដូចជាអបលាលនាគរាជ ចូឡោទរនាគរាជ មហោទរនាគរាជ អគ្គិសិខនាគរាជ ធូមសិខនាគរាជ អារវាឡនាគរាជ និងដំរីឈ្មោះថា ធនបាល ព្រះមានព្រះភាគទ្រង់ទូន្មានបាន ទ្រង់ធ្វើឲ្យអស់ព្យសន៍បាន និងឲ្យតាំងនៅក្នុងសរណៈ និងសីលបាន សូម្បីមនុស្សបុរសដូចជាសច្ចកនិគ្គណ្ឋបុត្រ អម្ពដ្ឋមាណព បោក្ខរសាតិព្រាហ្មណ៍ សោណ-ទន្តព្រាហ្មណ៍ គោដទន្តពាហ្មណ៍ជាដើម ទ្រង់ក៏ទូន្មានបាន ធ្វើឲ្យអស់ព្យសន៍បាន និងឲ្យតាំងនៅក្នុងសរណៈ និងសីលបាន ។ សូម្បីអមនុស្សបុរស មានអាឡវកយក្ខ សូចិលោមយក្ខ ខរលោមយក្ខ និងសក្កទេវរាជជាដើម ទ្រង់ក៏ទូន្មានបាន និងដឹកនាំដោយឧបាយជាគ្រឿងដឹកនាំយ៉ាងវិចិត្របាន ក្នុងទីនេះគប្បីឲ្យពិស្តារ ដោយ ( កេសី ) សូត្រនេះថា ម្នាលកេសី តថាគតរមែងណែនាំបុរសដែលគួរទូន្មាន ដោយល្អខ្លះ ដោយអាក្រក់ខ្លះ ដោយល្អ និងអាក្រក់ខ្លះ ដូច្នេះ ។ម្យ៉ាងទៀត ព្រះមានព្រះភាគ កាលត្រាស់ប្រាប់បឋមជ្ឈានជាដើម ដល់អ្នកមានសីលបរិសុទ្ធជាដើម និងមគ្គប្បដិបទា ដែលក្រៃលែងដល់ព្រះសោតាបន្នជាដើម ឈ្មោះថា រមែងទូន្មានបុគ្គលដែលទូន្មានហើយ ។

ម្យ៉ាងទៀត បទថា **អនុត្តរោ បុរិសទម្មសារថិ** ជាពាក្យមានសេចក្ដីដូចគ្នានោះឯង ។ ពិតហើយ ព្រះមានព្រះភាគ ទ្រង់ធ្វើបុរសដែលគួរទូន្មានបានឲ្យស្ទុះទៅ ដោយប្រការដែលជនទាំងនោះ ក្នុងទីមួយបន្ទុយប៉ុណ្ណោះ ក៏ស្ទុះទៅកាន់ទិសទាំង ៨ ដោយមិនទើសទាក់ ព្រោះហេតុនោះ ទើបហៅថា **អនុត្តរោ បុរិសទម្មសារថិ ។** ម្យ៉ាងទៀត ក្នុងសេចក្ដីនេះ មានព្រះសូត្រ ( សឡាយតនវគ្គ ភទ្ទសូត្រ ) ថា ម្នាលភិក្ខុទាំងឡាយ ដំរីគួរទូន្មានដែលទម័កដំរីបានទូន្មានហើយ រមែងស្ទុះទៅកាន់ទិសតែមួយៗ ដូច្នេះជាដើម បណ្ឌិតគប្បីឲ្យសូត្រនេះពិស្ដារ ។

បទថា **បហុ** បានដល់ ជាអ្នកអាច ។ បទថា **វិសហិ** បានដល់ ញ៉ាំងសេចក្ដីព្យាយាមឲ្យកើតក្នុងសន្ដានរបស់អ្នកដទៃ ។ បទថា **អលមត្តោ** បានដល់ ចិត្តមានសមត្ថភាព ។ បទថា **វិរតោ** បានដល់ ទ្រង់វៀរចាកបាបទាំងពួងដោយអរិយមគ្គ ។ បទថា **សព្វបាបកេហិ និរយទុក្ខមតិច្ច** បានដល់ កន្លងនូវទុក្ខក្នុងនរក ព្រោះមិនមានបដិសន្ធិតទៅ ។ បទថា **វីរិយវាសោ** បានដល់ មានធម៌ជាគ្រឿងនៅ គឺសេចក្ដីព្យាយាម ។ បទថា **សោ វីរិយវា** បានដល់ ទ្រង់ជាអ្នកអស់អាសវៈ រមែងសមគួរនូវភាពជាបុគ្គលដែលគេគួរពោលថា មានវីរិយៈ ។ ចំណែកក្នុងបទថា **បធានវា វីរោ តាទិ** ជាពាក្យសរសើរព្រះអង្គ ព្រោះព្រះអង្គឈ្មោះថា **បធានវា** ព្រោះមានការព្យាយាមក្នុងមគ្គ និងឈាន ឈ្មោះថា **វីរោ** ព្រោះអាចកម្ចាត់សត្រូវ គឺកិលេសបាន ឈ្មោះថា **តាទិ** ព្រោះមិនមានវិការ គឺការខុសប្រក្រតី ។ បទថា **បវុច្ចតេ**

**គចន្តា** បានដល់ បុគ្គលបែបនោះ ហៅថា អ្នកមានវីរិយៈ ។

បទថា **តេ កាមកាមិនោ** បានដល់ ប្រាថ្នាវត្ថុកាម មានរូបជាដើម ។ បទថា **រាគរាគិនោ** បានដល់ តម្រេកដោយរាគៈ ។ បទថា **សញ្ញាសញ្ញិនោ**[១] បានដល់ មានសេចក្ដីសម្គាល់ក្នុងរាគសញ្ញា ។ បទថា **ន កាមេ កាមេតិ** បានដល់ មិនប្រាថ្នាវត្ថុកាម មានរូបជាដើម ។ បទថា **អកាមោ** បានដល់ វៀរចាកកាម ។ បទថា **និក្កាមោ** បានដល់ រលាស់ចេញចាកកាមហើយ ។

[ ៣៨៧ ] បទថា **សព្វញ្ញុតញ្ញាណំ** មានវិគ្គហៈថា ឈ្មោះថា សព្វញ្ញូ ព្រោះទ្រង់ដឹងផ្លូវដែលគួរទូន្មានទាំងពួងក្នុងកាលទាំង ៣ ភាពនៃសព្វញ្ញូនោះ ឈ្មោះថា **សព្វញ្ញុតា** ។ ញាណ គឺភាពជាសព្វញ្ញូ ឈ្មោះថា **សព្វញ្ញុតញ្ញាណំ** ។ ភ្នែក គឺសព្វញ្ញុតញ្ញាណ និងភាពជាអ្នកឈ្នះកិលេស ព្រោះញុំាងកិលេសទាំងឡាយ មួយអន្លើដោយវាសនាឲ្យចាញ់ ហើយឈ្នះ កើតឡើងហើយក្នុងខណៈតែមួយ ក្នុងកាលតែមួយ មិនមុន មិនក្រោយ គឺព្រមគ្នា ។ ឈ្មោះថា **ឧប្បន្នោ** ព្រោះកើតឡើងតាំងអំពីចំណែកអតីត ។

[ ៣៨៩ ] បទថា **តេជី តេជសា** សេចក្ដីថា ព្រះមានព្រះភាគ ទ្រង់ប្រកបដោយតេជះ គ្របសង្កត់ដោយតេជះ ។ បទថា **យមហំ វិជញ្ញំ ជាតិជរាយ ឥធ វិប្បហានំ** សេចក្ដីថា ខ្ញុំព្រះអង្គគប្បីដឹងធម៌ជាគ្រឿងលះជាតិ និងជរាក្នុងភពនេះ ។

---

១- បទ ៣ ខាងនេះមិនឃើញមានក្នុងបិដកខ្មែរទេ ។

[ ៣៩១ ] ក្នុងបទថា **ជគតិ** បានដល់ ផែនដី ។ បទថា **សត្តំ អាកាសគតំ** បានដល់ អណ្តែតផ្សាយទៅក្នុងអាកាសទាំងមូល ។ បទថា **តមគតំ** បានដល់ ការងងឹតនោះឯង ឈ្មោះថា **តមគត** គឺការងងឹត ដូចពាក្យថា **គូថគត** និង **មុត្តគត** ដូច្នោះ ។ បទថា **អភិវិហច្ច** សេចក្តីថា ឲ្យវិនាសទៅ ។ បទថា **អន្ធការំ វិធមិត្វា** បានដល់ ទម្លាយងងឹត ដែលហាមនូវការកើតនៃចក្ខុវិញ្ញាណ ។ បទថា **អាលោកំ ទស្សយិត្វា** បានដល់ ពន្លឺរបស់ព្រះអាទិត្យ ។ បទថា **អាកាសេ** បានដល់ ក្នុងអាកាសដែលជាទីវាល ។ បទថា **អន្តលិក្ខេ** បានដល់ ក្នុងអាកាសទទេ ដែលអណ្តែតបាន ។ បទថា **គមនបថេ** បានដល់ ទៅក្នុងផ្លូវដើររបស់ពួកទេវតា ។

បទថា **សត្តំ អភិសង្ខារសមុទយំ** បានដល់ ហេតុកើតនៃកម្មទាំងពួង គឺការកើតឡើង អធិប្បាយថា តណ្ហា ។ បទថា **កិលេសតមំ អវិជ្ជន្ធការំ វិធមិត្វា** សេចក្តីថា ទ្រង់នាំនូវការមិនដឹង ដែលបានដល់ការងងឹត គឺកិលេស ការងងឹត គឺអវិជ្ជា ចេញឲ្យវិនាសទៅ ហើយទ្រង់សម្តែងពន្លឺ គឺព្រះញាណ ពន្លឺ គឺបញ្ញា ។ បទថា **វត្ថុកាមេ បរិជានិត្វា** បានដល់ ទ្រង់ដឹងវត្ថុកាម មានរូបជាដើម ដោយញាតបរិញ្ញា និងតីរណបរិញ្ញា ។ បទថា **កិលេសកាមេ បហាយ** សេចក្តីថា ទ្រង់លះកិលេសកាម ពោលគឺការធ្វើសេចក្តីក្តៅក្រហាយ ដោយបហានបរិញ្ញា ។

[ ៣៩៥ ] លំដាប់នោះ ព្រះមានព្រះភាគ កាលត្រាស់ប្រាប់ធម៌នោះ ដល់ជតុកណ្ណីមាណព ទើបត្រាស់គាថាតទៅថា

ក្នុងបទទាំងនោះ បទថា **ខេមំ ឥធ ខេមតោ** បានដល់ ឃើញនិព្វាន និងបដិបទាដែលធ្វើឲ្យដល់និព្វានថា ជាដែនក្សេម ។ បទថា **ឧគ្គហិតំ** បានដល់ កិលេសជាគ្រឿងកង្វល់ ដែលអ្នកប្រកាន់ដោយអំណាចនៃតណ្ហា ដោយអំណាចនៃទិដ្ឋិ ។ បទថា **និរត្តំ វា** បានដល់ គប្បីរលាស់ចេញ អធិប្បាយថា គប្បីលែង ។ បទថា **មា តេ វិជ្ជិត្ថ** បានដល់ កុំបីមានដល់អ្នកឡើយ ។ បទថា **កិញ្ចនំ** បានដល់ កិលេសជាគ្រឿងកង្វល់ មានរាគៈជាដើម កិលេសជាគ្រឿងកង្វល់នោះ កុំបីមានដល់អ្នកឡើយ ។

[ ៣៩៨ ] បទថា **មុញ្ចិតព្វំ** បានដល់ លែងហើយ មិនគួរប្រកាន់ទៀត ។ បទថា **បជហិតព្វំ** បានដល់ គួរវៀរ ។ បទថា **វិនោទេតព្វំ** បានដល់ គួរបោលទៅ ។ បទថា **ព្យន្តីកាតព្វំ** បានដល់ គួរធ្វើកិលេសជាគ្រឿងកង្វល់នោះឲ្យប្រាសទៅ ។ បទថា **អនភាវំ គមេតព្វំ** បានដល់ គួរឲ្យដល់នូវការមិនមាន សូម្បីត្រឹមបន្តិចបន្តួច ។

[ ៤០០ ] បទថា **បុព្វេ** បានដល់ កិលេសដែលកើតឡើង ប្រារព្ធសង្ខារក្នុងអតីត ។

[ ៤០៥ ] ព្រះមានព្រះភាគ ទ្រង់ហៅជតុកណ្ណីមាណពថា **ព្រាហ្មណ។** បទដ៏សេសក្នុងទីទាំងពួងប្រាកដច្បាស់ល្អហើយ ។

ព្រះមានព្រះភាគ ទ្រង់សម្តែងព្រះសូត្រនេះ ដោយធម៌ដ៏កំពូល គឺព្រះអរហត្ត ។

កាលចប់ទេសនា សត្វសម្រេចធម៌ដូចគ្នានឹងសូត្រមុនៗនោះឯង ។៚

# សុត្តន្តបិដក

## កទ្រាវុធមាណវកបញ្ហានិទ្ទេស

[ ៤០៩ ] ( កទ្រាវុធមានអាយុ ពោលដូច្នេះថា ) ខ្ញុំព្រះអង្គសូមអារាធនាព្រះមានព្រះភាគ ព្រះអង្គលះបង់ទីលំនៅ កាត់បង់តណ្ហា មិនមានការញាប់ញ័រ លះបង់សេចក្ដីត្រេកអរ ឆ្លងអន្លង់ មានព្រះហឫទ័យរួចស្រឡះ លះគ្រឿងកំណត់ មានបញ្ញាល្អ ពួកជនបានស្ដាប់ ( ព្រះតម្រាស់ ) របស់ព្រះអង្គ ជាព្រះពុទ្ធនាគ ហើយ នឹងចៀសចេញអំពីទីនេះ ។

[ ៤១០ ] អធិប្បាយពាក្យថា ព្រះអង្គលះបង់ទីលំនៅ កាត់បង់តណ្ហា មិនមានការញាប់ញ័រ ត្រង់ពាក្យថា ព្រះអង្គលះបង់ទីលំនៅ សេចក្ដីថា ឆន្ទៈណា រាគៈណា នន្ទិណា តណ្ហាណា ការចូលទៅជិតប្រកាន់ជាគ្រឿងតាំងស៊ប់របស់ចិត្ត ជាទីមកដេកត្រាំជាប់ណា ក្នុងរូបធាតុ កិលេសទាំងនោះ ព្រះពុទ្ធមានជោគលះបង់ ផ្ដាច់ឫសគល់ ធ្វើមិនឲ្យមានទីកើត ដូចជាទីកើតនៃដើមត្នោត ធ្វើមិនឲ្យមានបែបភាព មិនឲ្យកើតឡើងជាធម្មតាតទៅ ហេតុនោះ ព្រះពុទ្ធ ឈ្មោះថា លះបង់ទីលំនៅ ។ ឆន្ទៈណា រាគៈណា នន្ទិណា តណ្ហាណា ការចូលទៅជិតប្រកាន់ជាគ្រឿងតាំងស៊ប់របស់ចិត្ត ជាទីមកដេកត្រាំជាប់ណា ក្នុងវេទនាធាតុ សញ្ញាធាតុ សង្ខារធាតុ វិញ្ញាណធាតុ កិលេសទាំងនោះ ព្រះពុទ្ធមានព្រះភាគ លះបង់ ផ្ដាច់ឫសគល់ ធ្វើមិនឲ្យមានទីកើត ដូចជាទីកើតនៃដើមត្នោត ធ្វើមិនឲ្យមានបែបភាព មិនឲ្យកើតឡើងជាធម្មតាតទៅ ហេតុនោះ ព្រះពុទ្ធ ឈ្មោះថា លះបង់ទីលំនៅ ។ ពាក្យថា តណ្ហា

របស់បទថា កាត់បង់តណ្ហា បានដល់ រូបតណ្ហា សទ្ទតណ្ហា គន្ធតណ្ហា រសតណ្ហា ផោដ្ឋព្វតណ្ហា ធម្មតណ្ហា តណ្ហានោះ ព្រះពុទ្ធមានព្រះភាគ កាត់បង់ ផ្តាច់បង់ ផ្តិលផ្តាច់ រម្ងាប់ ឲ្យស្ងប់រម្ងាប់ ធ្វើមិនគួរឲ្យកើតឡើងបាន ដុតដោយភ្លើង គឺញាណហើយ ហេតុនោះ ព្រះពុទ្ធ ឈ្មោះថា កាត់បង់តណ្ហា ។ ពាក្យថា មិនមានការញាប់ញ័រ សេចក្តីថា តណ្ហា ហៅថា ការញាប់ញ័រ បានដល់ រាគៈ រាគៈមានកម្លាំង ។បេ។ អភិជ្ឈា លោភៈ អកុសលមូល ។ ការញាប់ញ័រ គឺតណ្ហានោះ ព្រះពុទ្ធមានជោគ លះបង់ ផ្តាច់ឫសគល់ ធ្វើមិនឲ្យមានទីកើត ដូចជាទីកើតនៃដើមត្នោត ដល់នូវការមិនមានបែបភាព មិនឲ្យកើតឡើងជាធម្មតាតទៅ ហេតុនោះ ព្រះពុទ្ធ ឈ្មោះថា មិនមានការញាប់ញ័រ ។ ព្រះពុទ្ធ ឈ្មោះថា មិនមានការញាប់ញ័រ ព្រោះទ្រង់លះបង់ការញាប់ញ័រហើយ ។ ព្រះមានព្រះភាគ មិនរំភើបក្នុងលាភផង មិនរំភើបក្នុងអលាភផង មិនរំភើបក្នុងយសផង មិនរំភើបក្នុងអយសផង មិនរំភើបក្នុងបសំសាផង មិនរំភើបក្នុងនិន្ទាផង មិនរំភើបក្នុងសុខផង មិនរំភើប មិនកម្រើក មិនញាប់ញ័រ មិនរញ្ជួយ មិនកម្រើកក្នុងទុក្ខផង ហេតុនោះ ព្រះពុទ្ធ ឈ្មោះថា មិនមានការញាប់ញ័រ ហេតុនោះ ( លោកពោលថា ) ព្រះអង្គលះបង់លំនៅ កាត់បង់តណ្ហា មិនមានការញាប់ញ័រ ។ ពាក្យថា ដូច្នេះ របស់បទថា កទ្រាវុធមានអាយុពោល ដូច្នេះ ជាពាក្យតបទ ។បេ។ ពាក្យថា ដូច្នេះ នុ៎ះ ជាលំដាប់បទ ។ ពាក្យថា មានអាយុ គឺពាក្យជាទីស្រឡាញ់ ជាពាក្យគោរព ពាក្យថា មានអាយុ នុ៎ះ ជាពាក្យពោលដោយ

គោរព កោតក្រែង ។ ពាក្យថា ភទ្រាវុធ ជាឈ្មោះ ។បេ។ ជាពាក្យហៅព្រាហ្មណ៍នោះ ហេតុនោះ ( មានពាក្យថា ) ភទ្រាវុធមានអាយុ ពោលដូច្នេះ ។

[ ៤១១ ] ពាក្យថា លះបង់សេចក្តីត្រេកអរ ធ្វូងអន្ទង់ មានព្រះហឫទ័យរួចស្រឡះ អធិប្បាយថា តណ្ហា លោកហៅថា សេចក្តីត្រេកអរ បានដល់ រាគៈ រាគៈមានកម្លាំង ។បេ។ អភិជ្ឈា លោភៈ អកុសលមូល ។ សេចក្តីត្រេកអរ គឺតណ្ហានោះ ព្រះពុទ្ធមានព្រះភាគ លះបង់ ផ្តាច់ឫសគល់ ធ្វើមិនឲ្យមានទីកើត ដូចជាទីកើតនៃដើមត្នោត ធ្វើមិនឲ្យមានបែបភាព មិនឲ្យកើតតទៅជាធម្មតា ហេតុនោះ ព្រះពុទ្ធ ទើបឈ្មោះថា លះបង់សេចក្តីត្រេកអរ ។ ពាក្យថា ធ្វូងអន្ទង់ គឺព្រះមានព្រះភាគ ទ្រង់ធ្វូងកាមោឃៈ ធ្វូងភវោឃៈ ធ្វូងទិដ្ឋោឃៈ ធ្វូងអវិជ្ជោឃៈ ធ្វូង ធ្វូងឡើង ធ្វូងកាត់ កន្ធ្វូងឈានរំលង ផ្ទោះរំលង នូវផ្លូវ គឺសង្ខារទាំងអស់ ព្រះអង្គមានការអប់រំនៅហើយ មានចរណៈប្រព្រឹត្តហើយ ។បេ។ ភពថ្មី គឺជាតិ ជរា មរណៈ និងសង្ខារ នៃព្រះអង្គមិនមានឡើយ ហេតុនោះ ទើបឈ្មោះថា ទ្រង់លះបង់សេចក្តីត្រេកអរ ធ្វូងអន្ទង់ ។ ពាក្យថា មានព្រះហឫទ័យរួចស្រឡះ គឺព្រះហឫទ័យរបស់ព្រះមានព្រះភាគ ផុត រួចស្រឡះ រួចស្រឡះដោយប្រពៃ ចាករាគៈ ព្រះហឫទ័យ ផុត រួចស្រឡះ រួចស្រឡះដោយប្រពៃ ចាកទោសៈ ព្រះហឫទ័យ ផុត រួចស្រឡះ រួចស្រឡះដោយប្រពៃ ចាកមោហៈ ព្រះហឫទ័យ ផុត រួចស្រឡះ រួចស្រឡះដោយប្រពៃ ចាកកោធៈ ឧបនាហៈ ។បេ។

អកុសលាភិសង្ខារទាំងអស់ ហេតុនោះ ( លោកពោលថា ) លះបង់សេចក្តីត្រេកអរ ឆ្លងអន្លង់ មានព្រះហឫទ័យរួចស្រឡះ ។

[ ៤១២ ] ពាក្យថា ខ្ញុំព្រះអង្គសូមអារាធនា ព្រះមានព្រះភាគ ទ្រង់លះបង់គ្រឿងកំណត់ មានបញ្ញាល្អ ត្រង់ពាក្យថា គ្រឿងកំណត់ បានដល់កប្បៈ ( គ្រឿងកំណត់ ) ២ គឺតណ្ហាកប្បៈ ១ ទិដ្ឋិកប្បៈ ១ ។បេ។ នេះតណ្ហាកប្បៈ ។បេ។ នេះ ទិដ្ឋិកប្បៈ ។ ព្រះពុទ្ធមានព្រះភាគ លះបង់ តណ្ហាកប្បៈ វលាស់ចោលទិដ្ឋិកប្បៈ ព្រះពុទ្ធ ឈ្មោះថា លះបង់បក្សៈ ព្រោះលះបង់តណ្ហាកប្បៈ ព្រោះវលាស់ចោលទិដ្ឋិកប្បៈ ។ ពាក្យថា សូមអារាធនា គឺខ្ញុំព្រះអង្គសូមអង្វរ អារាធនា និមន្ត ត្រេកអរ ប្រាថ្នា ស្រឡាញ់ ប៉ុនប៉ង ។ ពាក្យថា មានបញ្ញាល្អ សេចក្តីថា ប្រាជ្ញា ហៅថា បញ្ញា បានដល់ ប្រាជ្ញា ការដឹងច្បាស់ ។បេ។ សេចក្តីមិនវង្វេង ការពិនិត្យធម៌ ឃើញត្រូវ ។ ព្រះមានព្រះភាគ ប្រកប ប្រកបព្រម ចូលទៅប្រកប ចូលទៅប្រកបព្រម ចូលដល់ ចូលដល់ព្រម មកដល់ព្រម ដោយបញ្ញា ជាគ្រឿងកម្ចាត់នេះឯង ហេតុនោះ ព្រះពុទ្ធ ទើបឈ្មោះថា មានបញ្ញាដ៏ល្អ ហេតុនោះ ( លោកពោលថា ) ខ្ញុំព្រះអង្គសូមអារាធនាព្រះអង្គ ទ្រង់លះបង់គ្រឿងកំណត់ មានបញ្ញាល្អ ។

[ ៤១៣ ] ពាក្យថា ពួកជនបានស្តាប់ ( ព្រះតម្រាស់ ) របស់ព្រះអង្គជាព្រះពុទ្ធនាគហើយ នឹងចៀសចេញអំពីទីនេះ ត្រង់ពាក្យថា នាគ គឺ ( ព្រះពុទ្ធ ) ទ្រង់ព្រះនាមថា ព្រះនាគ ។ ព្រះមានព្រះភាគ ទ្រង់ព្រះនាមថា នាគ ព្រោះមិនធ្វើអំពើអាក្រក់ ។ ទ្រង់ព្រះនាមថា នាគ ព្រោះមិនលុះ ( អគតិ ) ។

ទ្រង់ព្រះនាមថា នាគ ព្រោះមិនមក ។បេ។ ព្រះមានព្រះភាគ ព្រះនាមថា នាគ ព្រោះមិនមក យ៉ាងនេះឯង ។ ពាក្យថា ពួកជនស្តាប់ ( ព្រះតម្រាស់ ) របស់ព្រះអង្គជាព្រះពុទ្ធនាគហើយ នឹងចៀសចេញអំពីទីនេះ គឺពួកជនស្តាប់ឮ ក្ជួបកាន់ ចាំទុក កំណត់ទុក នូវព្រះតម្រាស់ គន្លងនៃវាចា ទេសនា អនុសន្ធិ របស់ព្រះអង្គហើយ នឹងចៀសចេញ នឹងគេចចេញ អំពីទីនេះ ទៅកាន់ទិសផ្សេងៗ ហេតុនោះ ( លោកពោលថា ) ពួកជនស្តាប់ ( ព្រះតម្រាស់ ) របស់ព្រះអង្គ ជាព្រះពុទ្ធនាគហើយ នឹងចៀសចេញអំពីទីនេះ ។ ហេតុនោះ ព្រាហ្មណ៍នោះពោលថា

( ភទ្រាវុធមានអាយុ ពោលដូច្នេះថា ) ខ្ញុំព្រះអង្គសូមអារាធនាព្រះមានព្រះភាគ ព្រះអង្គលះលំនៅ កាត់បង់តណ្ហា មិនមានការញាប់ញ័រ លះបង់សេចក្តីត្រេកអរ ឆ្លងអន្លង់ មានព្រះហឫទ័យរួចស្រឡះ លះបង់គ្រឿងកំណត់ មានបញ្ញាល្អ ពួកជនស្តាប់ ( ព្រះតម្រាស់ ) របស់ព្រះអង្គ ជាព្រះពុទ្ធនាគហើយ នឹងចៀសចេញអំពីទីនេះ ។

[ ៤១៤ ] បពិត្រព្រះអង្គជាវីរបុរស ពួកជនផ្សេងៗ ចេញអំពីជនបទទាំងឡាយ មកប្រជុំគ្នា ត្រូវការព្រះតម្រាស់របស់ព្រះអង្គ សូមព្រះអង្គសម្តែងដោះប្រស្នា ដើម្បីជនទាំងនោះ ព្រោះថា ធម៌នុ៎ះ ព្រះអង្គជ្រាបហើយ ដោយពិត ។

[ ៤១៥ ] អធិប្បាយពាក្យថា ពួកជនផ្សេងៗ ចេញអំពីជនបទទាំង

ឡាយ មកប្រជុំគ្នា ត្រង់ពាក្យថា ពួកជនផ្សេងៗ បានដល់ ពួកក្សត្រ ព្រាហ្មណ៍ វេស្ស: សុទ្ទ: គ្រហស្ថ បព្វជិត ទេវតា និងមនុស្ស ។ ពាក្យថា ចេញអំពីជនបទទាំងឡាយ មកប្រជុំគ្នា គឺចេញអំពីជនបទ ឈ្មោះអង្គៈផង មគធៈផង កាសីផង កោសលផង វជ្ជីផង មល្លៈផង ចេតិយផង សាគរៈផង បញ្ចាលៈផង អវន្តិផង យោនៈផង កម្ពោជៈផង ។ ពាក្យថា មកប្រជុំគ្នា គឺមកជុំ មកព្រមគ្នា មកស្រុះគ្នា មកជួបជុំគ្នា ហេតុនោះ ( លោកពោលថា ) ពួកជនផ្សេងៗ ចេញអំពីជនបទទាំងឡាយ មកប្រជុំគ្នា ។

[ ៤១៦ ] ពាក្យថា បពិត្រព្រះអង្គជាវីរបុរស ( ពួកជន ) ត្រូវការព្រះតម្រាស់របស់ព្រះអង្គ ត្រង់ពាក្យថា បពិត្រព្រះអង្គជាវីរបុរស គឺព្រះពុទ្ធជាវីរបុរស ។ ព្រះមានព្រះភាគ ព្រះនាមថា វីរបុរស ព្រោះទ្រង់មានព្យាយាម ។ ព្រះនាមថា វីរបុរស ព្រោះទ្រង់សម្បូណ៌ដោយគុណ ។ ព្រះនាមថា វីរបុរស ព្រោះទ្រង់ជាអ្នកបណ្តុះសេចក្តីព្យាយាម ។ ព្រះនាមថា វីរបុរស ព្រោះទ្រង់អង់អាច ។បេ។ ព្រះនាមថា វីរបុរស ព្រោះទ្រង់ប្រាសចាកការព្រឺរោម ។

> បុគ្គលណា វៀរហើយ ចាកបាបទាំងពួង ក្នុងលោកនេះ ជាអ្នក
> មានព្យាយាមជាលំនៅ កន្លងនិរយទុក្ខ បុគ្គលនោះ ជាអ្នកមាន
> ព្យាយាម មានសេចក្តីប្រឹងប្រែង មានសភាពដូច្នោះ លោកហៅ
> ថា វីរបុរស ជាបុគ្គលមិនកម្រើក ។

ហេតុនោះ ( លោកពោលថា ) បពិត្រព្រះអង្គជាវីរបុរស ... របស់

ព្រះអង្គ ។ ពាក្យថា ត្រូវការព្រះតម្រាស់ គឺព្រះតម្រាស់ គន្លងនៃវាចា ទេសនា អនុសន្ធិ របស់ព្រះអង្គ ។ ពាក្យថា ត្រូវការ គឺប៉ុនប៉ង ត្រូវការ ប្រាថ្នា ត្រេកអរ ចង់បាន ស្រឡាញ់ ជាប់ចិត្ត ហេតុនោះ ( លោកពោល ថា) បពិត្រព្រះអង្គ ជាវីរបុរស ពួកជនត្រូវការព្រះតម្រាស់របស់ព្រះអង្គ ។

[ ៤១៧ ] ពាក្យថា សូមព្រះអង្គសម្តែងដោះប្រាថ្នា ដើម្បីជនទាំងនោះ ត្រង់ពាក្យថា ដើម្បីជនទាំងនោះ គឺដើម្បីជនទាំងនោះ បានដល់ ក្សត្រ ព្រាហ្មណ៍ វេស្សៈ សុទ្ទៈ គ្រហស្ថ បព្វជិត ទេវតា និងមនុស្ស ។ ពាក្យថា ព្រះអង្គ គឺកទ្រាវុធនិយាយចំពោះព្រះមានព្រះភាគ ។ ពាក្យថា សូមព្រះអង្គ សម្តែង គឺសូមព្រះអង្គប្រាប់ សម្តែង បញ្ញត្ត ផ្តើម បើក បែក ធ្វើឲ្យរាក់ ប្រកាស ហេតុនោះ ( លោកពោលថា ) សូមព្រះអង្គសម្តែង ។

[ ៤១៨ ] ពាក្យថា ធម៌នោះ ព្រះអង្គជ្រាបហើយដោយពិត គឺធម៌នុ៎ះ ព្រះអង្គជ្រាប ដឹង ថ្លឹង ពិចារណា ឈ្វេងយល់ ប្រាកដ ដោយពិត ហេតុ នោះ ( លោកពោលថា ) ធម៌នុ៎ះ ព្រះអង្គជ្រាបហើយដោយពិត ។ ហេតុ នោះ ព្រាហ្មណ៍នោះពោលថា

បពិត្រព្រះអង្គជាវីរបុរស ពួកជនផ្សេងៗ ចេញអំពីជនបទទាំង
ឡាយ មកប្រជុំគ្នា ត្រូវការព្រះតម្រាស់របស់ព្រះអង្គ សូមព្រះ
អង្គសម្តែងដោះប្រស្នា ដើម្បីជនទាំងនោះ ព្រោះថា ធម៌នុ៎ះ
ព្រះអង្គជ្រាបហើយ ដោយពិត ។

[ ៤១៩ ] ( ព្រះមានព្រះភាគ ត្រាស់ថា ម្នាលកទ្រាវុធ ) បុគ្គល

គប្បីកម្ចាត់អាទានតណ្ហា ( តណ្ហាជាគ្រឿងប្រកាន់ ) ទាំងអស់ ទាំងខាងលើ ទាំងខាងក្រោម ទាំងទទឹង គឺកណ្តាល ព្រោះថា ពួកសត្វប្រកាន់នូវខន្ធបញ្ចកៈណាៗ ក្នុងលោក មារតែងជាប់តាមនូវសត្វ ដោយអភិសង្ខារ គឺកម្មនោះឯង ។

[ ៤២០ ] ពាក្យថា បុគ្គលត្រូវកម្ចាត់អាទានតណ្ហាទាំងអស់ គឺរូបតណ្ហា ហៅថា អាទានតណ្ហា ។ ព្រោះហេតុអ្វី រូបតណ្ហា ហៅថា អាទានតណ្ហា ។ ពួកសត្វរមែងកាន់ ប្រកាន់ ក្ដួចកាន់ ស្ទាបអង្អែល ជាប់ជំពាក់ចំពោះរូប ដោយតណ្ហានោះ កាន់ ប្រកាន់ ក្ដួចកាន់ ស្ទាបអង្អែល ជាប់ជំពាក់ចំពោះវេទនា សញ្ញា ពួកសង្ខារ វិញ្ញាណ គតិ ឧបបត្តិ បដិសន្ធិ ភព សង្សារវដ្ដៈ ហេតុនោះ រូបតណ្ហា ហៅថា អាទានតណ្ហា ។ ពាក្យថា បុគ្គលត្រូវកម្ចាត់អាទានតណ្ហាទាំងអស់ គឺបុគ្គលត្រូវកម្ចាត់ បណ្តេញ លះបង់ បន្ទោបង់ ធ្វើឲ្យវិនាស ធ្វើមិនឲ្យមានបែបភាពនូវអាទានតណ្ហាទាំងអស់ ហេតុនោះ ( ទ្រង់ត្រាស់ថា ) បុគ្គលត្រូវកម្ចាត់អាទានតណ្ហាទាំងអស់ ។ ពាក្យថា កប្បាវុធ របស់បទថា ព្រះមានព្រះភាគ ត្រាស់ថា ម្នាលកប្បាវុធៈ គឺព្រះមានព្រះភាគត្រាស់ហៅព្រាហ្មណ៍នោះតាមឈ្មោះ ។ ពាក្យថា ព្រះមានព្រះភាគ នុ៎ះ ជាពាក្យពោលដោយគោរព ។បេ។ ការបញ្ញត្តិថា មានព្រះភាគ នេះ ( កើត ) ព្រោះការធ្វើឲ្យជាក់ច្បាស់ ហេតុនោះ ( មានពាក្យថា ) ព្រះមានព្រះភាគត្រាស់ថា ម្នាលកប្បាវុធ ។

[ ៤២១ ] ពាក្យថា ទាំងខាងលើ ទាំងខាងក្រោម ទាំងទទឹង គឺកណ្តាល

សេចក្តីថា អនាគត ហៅថា ខាងលើ អតីត ហៅថា ខាងក្រោម ។ បច្ចុប្បន្ន ហៅថា ទទឹង គឺកណ្តាល ពួកកុសលធម៌ ហៅថា ខាងលើ ។ ពួកអកុ-សលធម៌ ហៅថា ខាងក្រោម ។ ពួកអព្យាកតធម៌ ហៅថា ទទឹង គឺកណ្តាល ។ ទេវលោក ហៅថា ខាងលើ ។ អបាយលោក ហៅថា ខាងក្រោម ។ មនុស្សលោក ហៅថា ទទឹង គឺកណ្តាល ។ សុខវេទនា ហៅថា ខាងលើ ។ ទុក្ខវេទនា ហៅថា ខាងក្រោម ។ អទុក្ខមសុខវេទនា ហៅថា ទទឹង គឺកណ្តាល ។ អរូបធាតុ ហៅថា ខាងលើ ។ កាមធាតុ ហៅថា ខាងក្រោម ។ រូបធាតុ ហៅថា ទទឹង គឺកណ្តាល ។ សរីរៈខាងលើ អំពីបាតជើងឡើងទៅ ហៅថា ខាងលើ ។ សរីរៈខាងក្រោម អំពីចុងសក់ចុះមក ហៅថា ខាងក្រោម ។ សរីរៈត្រង់ពាក់កណ្តាល ហៅថា ទទឹង គឺកណ្តាល ហេតុនោះ ( ទ្រង់ត្រាស់ថា ) ទាំងខាងលើ ទាំងខាងក្រោម ទាំងទទឹង គឺកណ្តាល ។

[ ៤២២ ] ពាក្យថា ព្រោះពួកសត្វប្រកាន់នូវខន្ធបញ្ចកៈណាៗ ក្នុងលោក គឺព្រោះពួកសត្វកាន់ ក្ដួចកាន់ ប្រកាន់ ស្ទាបអង្អែល ជាប់ជំពាក់ចំពោះរូប វេទនា សញ្ញា សង្ខារ វិញ្ញាណណាៗ ។ ពាក្យថា ក្នុងលោក គឺក្នុងអបាយលោក ។បេ។ ក្នុងអាយតនលោក ហេតុនោះ ( ទ្រង់ត្រាស់ថា ) ពួកសត្វប្រកាន់នូវខន្ធបញ្ចកៈណាៗ ក្នុងលោក ។

[ ៤២៣ ] ពាក្យថា មារតែងជាប់តាមនូវសត្វ ដោយអភិសង្ខារ គឺកម្មនោះឯង បានដល់ មារ គឺខន្ធ មារ គឺធាតុ មារ គឺអាយតនៈ មារ គឺគតិ

មារ គឺឧបបត្តិ មារ គឺបដិសន្ធិ មារ គឺភព មារ គឺសង្សារ មារ គឺវដ្តៈ ដែលប្រកបដោយបដិសន្ធិ តែងជាប់តាម ទៅតាម ប្រព្រឹត្តតាម ដោយអំណាចនៃអភិសង្ខារ គឺកម្មនោះឯង ។ ពាក្យថា សត្វ គឺសត្វ នរៈ មាណព បុរស បុគ្គល ជីវៈ សត្វមានជាតិ មានជរា សត្វទៅដោយឥន្ទ្រិយ សត្វកើតអំពីមនុស្ស ហេតុនោះ ( ទ្រង់ត្រាស់ថា ) មារតែងជាប់តាមនូវសត្វដោយអភិសង្ខារ គឺកម្មនោះឯង ។ ហេតុនោះ ព្រះមានព្រះភាគត្រាស់ថា

( ព្រះមានព្រះភាគ ត្រាស់ថា ម្នាលកប្បុជ ) បុគ្គលត្រូវកម្ចាត់អាទានតណ្ហាទាំងអស់ ទាំងខាងលើ ទាំងខាងក្រោម ទាំងទទឹង គឺកណ្តាល ព្រោះថា ពួកសត្វប្រកាន់នូវខន្ធបញ្ចកៈណាៗ ក្នុងលោក មារតែងជាប់តាមសត្វ ដោយអភិសង្ខារ គឺកម្មនោះឯង ។

[ ៤២៤ ] ព្រោះហេតុដូច្នោះ ភិក្ខុដឹងច្បាស់ នឹករឭកឃើញកាលសម្លឹងឃើញ នូវពួកសត្វដែលជាប់ក្នុងអារម្មណ៍ជាគ្រឿងប្រកាន់នូវប្រជាជននេះ ដែលជាប់ជំពាក់ក្នុងហេតុជាទីតាំងនៃមច្ចុ ដូច្នេះ មិនគប្បីប្រកាន់នូវខន្ធបញ្ចកៈនីមួយ ក្នុងលោកទាំងពួង ។

[ ៤២៥ ] ពាក្យថា ព្រោះហេតុដូច្នោះ ... ដឹងច្បាស់ ... មិនគប្បីប្រកាន់ គឺព្រោះហេតុដូច្នោះ ព្រោះដំណើរនោះ ព្រោះហេតុនោះ ព្រោះបច្ច័យនោះ ព្រោះនិទាននោះ ឃើញច្បាស់នូវទោសនុ៎ះ ក្នុងអាទានតណ្ហា ហេតុនោះ ( ទ្រង់ត្រាស់ថា ) ព្រោះហេតុដូច្នោះ ។ ពាក្យថា ដឹងច្បាស់ គឺដឹង ដឹងច្បាស់

យល់ច្បាស់ ដឹងវិសេស យល់ធ្លុះធ្លាយ ត្រាស់ដឹងថា សង្ខារទាំងឡាយ ទាំងពួងមិនទៀង ។បេ។ ដឹង ដឹងច្បាស់ យល់ច្បាស់ ដឹងវិសេស យល់ធ្លុះធ្លាយ ត្រាស់ដឹងថា ធម្មជាតណានីមួយ មានកិរិយាកើតឡើងជាធម្មតា ធម្មជាតទាំងអស់នោះ មានកិរិយារលត់ទៅវិញជាធម្មតា ។ ពាក្យថា មិនគប្បីប្រកាន់ គឺមិនត្រូវក្ដួចកាន់ មិនត្រូវកាន់យក មិនត្រូវស្ទាបអង្អែល មិនត្រូវជាប់ជំពាក់ចំពោះរូប មិនត្រូវប្រកាន់ មិនត្រូវក្ដួចកាន់ មិនត្រូវកាន់យក មិនត្រូវស្ទាបអង្អែល មិនត្រូវជំពាក់ចំពោះវេទនា សញ្ញា ពួកសង្ខារ វិញ្ញាណ គតិ ឧបបត្តិ បដិសន្ធិ ភព សង្សារ វដ្ដៈ ហេតុនោះ ( ទ្រង់ត្រាស់ថា ) ព្រោះហេតុដូច្នោះ ដឹងច្បាស់ មិនគប្បីប្រកាន់ ។

[ ៤២៦ ] ពាក្យថា ភិក្ខុនឹករឭកឃើញនូវខន្ធបញ្ចកៈនីមួយ ក្នុងលោកទាំងពួង ត្រង់ពាក្យថា ភិក្ខុ គឺភិក្ខុជាកល្យាណបុថុជ្ជន ឬភិក្ខុជាសេក្ខៈ ហេតុនោះ ( ទ្រង់ត្រាស់ថា ) ភិក្ខុ ។ ពាក្យថា នឹករឭកឃើញ គឺនឹករឭកដោយហេតុ ៤ គឺកំពុងចម្រើនកាយេកាយានុបស្សនាសតិប្បដ្ឋាន ឈ្មោះថា នឹករឭកឃើញ ។បេ។ ភិក្ខុនោះ លោកហៅថា ជាអ្នករឭកឃើញ ហេតុនោះ ( ទ្រង់ត្រាស់ថា ) ភិក្ខុនឹករឭកឃើញ ។ ពាក្យថា ខន្ធបញ្ចកៈនីមួយ គឺរូប វេទនា សញ្ញា សង្ខារ វិញ្ញាណណានីមួយ ។ ពាក្យថា ក្នុងលោកទាំងពួង គឺក្នុងអបាយលោកទាំងមូល ក្នុងទេវលោកទាំងមូល ក្នុងមនុស្សលោកទាំងមូល ក្នុងខន្ធលោកទាំងមូល ក្នុងអាយតនលោកទាំងមូល ក្នុងធាតុលោកទាំងមូល ហេតុនោះ ( ទ្រង់ត្រាស់ថា ) ភិក្ខុនឹករឭកឃើញខន្ធបញ្ចកៈនីមួយ

ក្នុងលោកទាំងពួង ។

[ ៤២៧ ] ពាក្យថា កាលសម្លឹងឃើញនូវពួកសត្វ ដែលជាប់ក្នុងអារម្មណ៍ជាគ្រឿងប្រកាន់ដូច្នេះ គឺពួកសត្វណា កាន់ ក្តួចកាន់ ប្រកាន់ ស្ទាបអង្អែល ជាប់ជំពាក់ចំពោះរូប កាន់ ក្តួចកាន់ ប្រកាន់ ស្ទាបអង្អែល ជាប់ជំពាក់ចំពោះវេទនា សញ្ញា ពួកសង្ខារ វិញ្ញាណ គតិ ឧបបត្តិ បដិសន្ធិ ភព សង្សារ វដ្ដៈ សត្វទាំងនោះ លោកហៅថា អ្នកជាប់ក្នុងអារម្មណ៍ជាគ្រឿងប្រកាន់ ។ ពាក្យថា ដូច្នេះ គឺជាពាក្យតបទ ។បេ។ ពាក្យថា ដូច្នេះ នុ៎ះ ជាលំដាប់បទ ។ ពាក្យថា កាលសម្លឹងឃើញ គឺកាលឃើញ មើលឃើញ យល់ឃើញ រមិលមើល គន់មើល ពិចារណាមើល ហេតុនោះ ( ទ្រង់ត្រាស់ថា ) កាលសម្លឹងឃើញនូវពួកសត្វ ដែលជាប់ក្នុងអារម្មណ៍ជាគ្រឿងប្រកាន់ ដូច្នេះ ។

[ ៤២៨ ] ពាក្យថា ប្រជាជននេះ ដែលជាប់ជំពាក់ ក្នុងហេតុជាទីតាំងនៃមច្ចុ ត្រង់ពាក្យថា ប្រជាជន គឺជាឈ្មោះនៃសត្វ ។ ពាក្យថា ហេតុជាទីតាំងនៃមច្ចុ គឺពួកកិលេសក្តី ខន្ធក្តី អភិសង្ខារក្តី លោកហៅថា ហេតុជាទីតាំងនៃមច្ចុ ។ ប្រជាជន ជាប់ ជាប់ទូទៅ ជ្ពក់ ទាក់ ជាប់ជំពាក់ ក្នុងហេតុជាទីតាំងនៃមច្ចុ ហេតុជាទីតាំងនៃមារ ហេតុជាទីតាំងនៃមរណៈ ។ វត្ថុដែលជាប់ ជាប់ទូទៅ ជ្ពក់ ទាក់ ជាប់ជំពាក់ ត្រង់ចម្រឹងជញ្ជាំង ឬដៃកែវ យ៉ាងណា ពួកសត្វជាប់ ជាប់ទូទៅ ជ្ពក់ ទាក់ ជាប់ជំពាក់ ក្នុងហេតុ ជាទីតាំងនៃមច្ចុ ក្នុងហេតុ ជាទីតាំងនៃមារ ក្នុងហេតុ ជាទីតាំងនៃមរណៈ ក៏យ៉ាងនោះដែរ

ហេតុនោះ ( ទ្រង់ត្រាស់ថា ) ប្រជាជននេះ ដែលជាប់ក្នុងហេតុ ជាទីតាំងនៃមច្ចុ ។ ហេតុនោះ ព្រះមានព្រះភាគត្រាស់ថា

ព្រោះហេតុដូច្នោះ ភិក្ខុដឹងច្បាស់ នឹករឭកឃើញ កាលសម្លឹងឃើញ នូវពួកសត្វដែលជាប់ក្នុងអារម្មណ៍ជាគ្រឿងប្រកាន់ នូវប្រជាជននេះ ដែលជាប់ជំពាក់ក្នុងហេតុ ជាទីតាំងនៃមច្ចុ ដូច្នេះ មិនគប្បីប្រកាន់នូវខន្ធបញ្ចកៈនីមួយ ក្នុងលោកទាំងពួង ។

ដំណាលគ្នានឹងកាលជាទីចប់នៃគាថា ។បេ។ បពិត្រព្រះអង្គដ៏ចម្រើន ព្រះមានព្រះភាគ ជាសាស្តារបស់ខ្ញុំព្រះអង្គ ខ្ញុំព្រះអង្គជាសាវ័ក ។

## កថាវត្ថុមាណវកបញ្ហានិទ្ទេសទី ១២ ចប់

# អដ្ឋកថា

## ភទ្រាវុធមាណវកប្បញ្ហានិទ្ទេស

[ ៤០៩ ] គប្បីជ្រាបវិនិច្ឆ័យក្នុងភទ្រាវុធសូត្រទី ១២ ដូចតទៅ បទថា **ឱកញ្ជហំ** បានដល់ លះនូវការជាប់ជំពាក់ ។ បទថា **តណ្ហច្ឆិទំ** បានដល់ កាត់នូវពួកតណ្ហាចេញបាន ។ បទថា **អនេជំ** បានដល់ មិនញាប់ញ័រក្នុងលោកធម៌ទាំងឡាយ ។ បទថា **នន្ទិញ្ជហំ** បានដល់ លះនូវការប្រាថ្នារូប មានរូបក្នុងអនាគតជាដើម ។ ពិតហើយ តណ្ហាតែម្យ៉ាងប៉ុណ្ណោះ លោកពោលក្នុងទីនេះ ដោយប្រការផ្សេងៗ ដោយអំណាចនៃការត្រេកអរ ។ បទថា **កប្បញ្ជហំ** បានដល់ លះនូវការត្រិះរិះ ២ យ៉ាង ។ បទថា **អភិយាចេ** បានដល់ ខ្ញុំព្រះអង្គសូមអារាធនាយ៉ាងក្រៃលែង ។ បទថា **ឞុត្វាន នាគស្ស អបនមិស្សន្តិ ឥតោ** អធិប្បាយថា ជនដ៏ច្រើនបានស្តាប់នូវព្រះតម្រាស់របស់ព្រះនាគហើយ នឹងចៀសចេញ ទៅអំពីបាសាណកចេតិយនេះ ។

[ ៤១០ ] បទថា **យេ ឧបាយុបាទានា** បានដល់ ចូលទៅប្រកាន់មាំដោយតណ្ហា និងទិដ្ឋិ ។ បទថា **ចេតសោ អធិដ្ឋានា** បានដល់ តាំងទុកក្នុងចិត្ត ។ បទថា **អភិនិវេសានុសយា** បានដល់ ជាទីតាំងមាំហើយ មកដេកត្រាំនៅក្នុងសន្តាន ។

[ ៤១៤ ] បទថា **ជនបទេហិ សង្គតា** បានដល់ មកអំពីជនបទទាំងឡាយ មានដែនអង្គៈជាដើម ប្រជុំគ្នាក្នុងទីនេះ ។ បទថា **វិយាករោហិ** បានដល់ សូមទ្រង់សម្តែងធម៌ ។

[ ៤១៥ ] បទថា **សង្គតា** បានដល់ ជនទាំងឡាយនោះ មានក្សត្រជាដើម មានភាពតែមួយ ។ បទថា **សមាគតា** បានដល់ មកអំពីជនបទទាំងឡាយ មានប្រការដូចពោលហើយ ។ បទថា **សមោហិតា** បានដល់ ជាក្រុម ។ បទថា **សន្និបតិតា** បានដល់ មិនបែកចាកគ្នា ។

លំដាប់នោះ ព្រះមានព្រះភាគ កាលទ្រង់សម្តែងធម៌ ដោយអនុលោមតាមអធ្យាស្រ័យរបស់កទ្រាវុធមាណពនោះ ទើបត្រាស់គាថាតទៅ

[ ៤១៩ ] ក្នុងបទទាំងនោះ បទថា **អាទានតណ្ហំ** បានដល់ តណ្ហាជាគ្រឿងប្រកាន់ គឺប្រកាន់នូវរូបជាដើម អធិប្បាយថា ប្រកាន់មាំដោយតណ្ហា ។ បទថា **យំ យំ ហិ លោកស្មឹ ឧបាទិយន្តិ** បានដល់ ព្រោះថាសត្វទាំងឡាយប្រកាន់ឧបាទានក្ខន្ធជាដើមនោះ ឧបាទានក្ខន្ធណាមួយ ។ បទថា **តេនេវ មារោ អន្វេតិ ជន្តុំ** បានដល់ មាររមែងទៅតាមសត្វនោះ ក្នុងខណៈបដិសន្ធិដោយអំណាចអភិសង្ខារ គឺកម្មដែលកើតឡើង ព្រោះឧបាទានជាបច្ច័យនោះឯង ។

[ ៤២៤ ] បទថា **តស្មា បជានំ** បានដល់ ព្រោះហេតុនោះ ភិក្ខុដឹងទោសនោះ ឬសង្ខារទាំងឡាយ ដោយអំណាចជារបស់មិនទៀងជាដើម ។ បទថា **អាទានសត្តេ ឥតិ បេក្ខមានោ បជំ ឥមំ មច្ចុធេយ្យេ វិសត្តំ** សេចក្តីថា កាលឃើញពួកសត្វនេះ ដែលជាប់ជំពាក់ក្នុងអន្ទាក់នៃមច្ចុ ក្នុងលោកទាំងពួង ដែលជាប់ក្នុងរូបជាដើម ដែលជាគ្រឿងប្រកាន់ ដោយអត្ថថាគួរប្រកាន់ ឬឃើញនូវបុគ្គលដែលជាប់ជំពាក់ក្នុងរូបាទិក្ខន្ធ ដែលជាគ្រឿង

ប្រកាន់ គឺការប្រកាន់មាំ និងឃើញពួកសត្វដែលមានការប្រកាន់មាំ និងការជាប់ជំពាក់ជាហេតុ ដែលជាប់ក្នុងអន្ទាក់នៃមារថា មិនអាចកន្ទងផុតចាកអន្ទាក់នៃមច្ចុបាន មិនគប្បីប្រកាន់មាំណាមួយ ក្នុងលោកទាំងពួង ។ បទដ៏សេស ក្នុងទីទាំងពួងជាក់ច្បាស់ហើយ ។

ព្រះមានព្រះភាគ ទ្រង់សម្តែងព្រះសូត្រនេះ ដោយធម៌ជាកំពូល គឺអរហត្ត ដោយប្រការដូច្នេះ កាលចប់ទេសនា មានបុគ្គលសម្រេចធម៌ដូចគ្នាតាមដែលបានពោលហើយ ក្នុងសូត្រមុននោះឯង ។

**អដ្ឋកថា ភទ្រាវុធមាណវសុត្តនិទ្ទេសទី ១២ ចប់**

# សុត្តន្តបិដក
# ខុទ្ទកនិកាយ ចូឡនិទ្ទេស
# ទុតិយភាគ

## ឧទយមាណវកបញ្ហានិទ្ទេស

[ ១ ] ( ឧទយៈមានអាយុ ក្រាបទូលដូច្នេះថា ) ខ្ញុំព្រះអង្គជាអ្នកត្រូវការដោយប្រស្នា ទើបមកគាល់ ( ដើម្បីសួរ ) ព្រះអង្គជាអ្នកមានឈាន មានព្រះសន្តានប្រាសចាកធូលី ទ្រង់គង់នៅ ទ្រង់មានកិច្ចធ្វើរួចហើយ មិនមានអាសវៈ ទ្រង់ដល់នូវត្រើយនៃធម៌ទាំងពួង សូមព្រះអង្គសម្តែងអញ្ញាវិមោក្ខ ជាគ្រឿងទម្លាយអវិជ្ជា ។

[ ២ ] អធិប្បាយពាក្យថា ជាអ្នកមានឈាន មានព្រះសន្តានប្រាសចាកធូលី ទ្រង់គង់នៅ ត្រង់ពាក្យថា មានឈាន គឺព្រះមានព្រះភាគមានឈាន ដោយបឋមជ្ឈានផង មានឈាន ដោយទុតិយជ្ឈានផង មានឈាន ដោយតតិយជ្ឈានផង មានឈាន ដោយចតុត្ថជ្ឈានផង មានឈាន ដោយឈានប្រកបដោយវិតក្ក និងវិចារៈផង មានឈាន ដោយឈានមិនមានវិតក្ក មានតែវិចារៈផង មានឈាន ដោយឈានមិនមានវិតក្ក មិនមានវិចារៈផង មានឈាន ដោយឈានប្រកបដោយបីតិផង មានឈាន ដោយឈានមិន

មានបីតិផង មានឈាន ដោយឈានប្រកបដោយសុខផង មានឈាន ដោយឈានប្រកបដោយឧបេក្ខាផង មានឈាន ដោយឈានប្រកបដោយសុញ្ញតវិមោក្ខផង មានឈាន ដោយឈានប្រកបដោយអនិមិត្តវិមោក្ខផង មានឈាន ដោយឈានប្រកបដោយអប្បណិហិតវិមោក្ខផង មានឈាន ដោយឈានជាលោកិយផង មានឈាន ដោយឈានជាលោកុត្តរផង ជាបុគ្គលត្រេកអរក្នុងឈាន ប្រកបរឿយៗ នូវភាពជាបុគ្គលម្នាក់ឯង ដូន់ក្នុងប្រយោជន៍របស់ខ្លួន ហេតុនោះ ( លោកពោលថា ) អ្នកមានឈាន ។ ពាក្យថា ប្រាសចាកធូលី សេចក្តីថា ធូលី គឺរាគៈ ធូលី គឺទោសៈ ធូលី គឺមោហៈ ធូលី គឺក្រោធៈ ធូលី គឺឧបនាហៈ ។បេ។ ធូលី គឺអភិសង្ខារ ជាអកុសលទាំងអស់ ។ ធូលីទាំងនោះ ព្រះពុទ្ធមានព្រះភាគ លះបង់ ផ្តាច់ផ្តិលឫសគល់ ធ្វើឲ្យនៅសល់តែទីនៅ ដូចជាទីនៅនៃដើមត្នោត ឲ្យដល់នូវការមិនមានបែបភាព មានការមិនកើតតទៅជាធម្មតា ហេតុនោះ ព្រះពុទ្ធឈ្មោះថា មិនមានធូលី ប្រាសចាកធូលី មានធូលីទៅប្រាស លះបង់ធូលី ផុតស្រឡះចាកធូលី ។

ធូលី សំដៅយករាគៈ មិនមែនលម្អងទេ ពាក្យថា ធូលីនុ៎ះ ជាឈ្មោះរាគៈ ព្រះជិនស្រីមានបញ្ញាចក្ខុ លះបង់ធូលីនុ៎ះហើយ ហេតុនោះ ទើបលោកហៅថា អ្នកមានធូលីទៅប្រាស ធូលីសំដៅយកទោសៈ មិនមែនលម្អងទេ ពាក្យថា ធូលីនុ៎ះ ជាឈ្មោះទោសៈ ព្រះជិនស្រីមានបញ្ញាចក្ខុ លះបង់ធូលីនុ៎ះហើយ

ហេតុនោះ ទើបលោកហៅថា អ្នកមានធូលីទៅប្រាស ធូលី
សំដៅយកមោហៈ មិនមែនលម្អងទេ ពាក្យថា ធូលីទុំះ ជា
ឈ្មោះមោហៈ ព្រះជិនស្រីមានបញ្ញាចក្ខុ លះបង់ធូលីទុំះហើយ
ហេតុនោះ ទើបលោកហៅថា អ្នកមានធូលីទៅប្រាស ។

ហេតុនោះ ( លោកពោលថា ) ប្រាសចាកធូលី ។ ពាក្យថា ទ្រង់គង់នៅ គឺព្រះមានព្រះភាគ ទ្រង់គង់ក្បែរបាសាណកចេតិយ ហេតុនោះ ទើបឈ្មោះថា ទ្រង់គង់នៅ ។

ពួកសាវកអ្នកមានត្រៃវិជ្ជា លះបង់មច្ចុហើយ ចូលទៅអង្គុយជិត
ព្រះមុនី ទ្រង់ដល់ត្រើយនៃទុក្ខ គង់ខាងក្នុំ ។

ព្រះមានព្រះភាគ ឈ្មោះថា ទ្រង់គង់នៅ យ៉ាងនេះក៏បាន ។ មួយទៀត ព្រះមានព្រះភាគ ឈ្មោះថា ទ្រង់គង់នៅ ព្រោះព្រះអង្គរម្ងាប់សេចក្តីខ្វល់ខ្វាយទាំងពួង ហើយទ្រង់មានព្រហ្មចរិយៈនៅហើយ មានចរណធម៌សន្សំហើយ ។បេ។ ភពថ្មី គឺជាតិ ជរា មរណៈ សង្សារ របស់ព្រះមានព្រះភាគនោះ មិនមាន ហេតុនោះ ព្រះមានព្រះភាគ ឈ្មោះថា ទ្រង់គង់នៅ យ៉ាងនេះក៏បាន ហេតុនោះ ( លោកពោលថា ) អ្នកមានឈាន ប្រាសចាកធូលី ទ្រង់គង់នៅ ។ ពាក្យថា ដូច្នេះ ក្នុងបទថា ឧទយៈមានអាយុពោលដូច្នេះ គឺជាការតបទ ។បេ។ ពាក្យថា ដូច្នេះ នេះ ជាលំដាប់បទ ។ ពាក្យថា មានអាយុ គឺពាក្យជាទីស្រឡាញ់ ជាពាក្យគោរព ពាក្យថា មានអាយុ នេះ ជាពាក្យពោលដោយគោរព កោតក្រែង ។ ពាក្យថា ឧទយៈ ជាឈ្មោះ ។បេ។ ជាពាក្យហៅនូវ

ព្រាហ្មណ៍នោះ ហេតុនោះ ( ទើបមានពាក្យថា ) ឧទយៈមានអាយុ ពោលដូច្នេះ ។

[ ៣ ] ពាក្យថា ទ្រង់មានកិច្ចធ្វើរួចហើយ មិនមានអាសវៈ គឺកិច្ចគួរធ្វើ និងមិនគួរធ្វើ ព្រះពុទ្ធមានជោគ លះបង់ ផ្តាច់ផ្តិលឫសគល់ ធ្វើឲ្យសល់តែទីនៅ ដូចជាទីនៅនៃដើមត្នោត ឲ្យដល់នូវការមិនមានបែបភាព មិនមានការកើតតទៅជាធម្មតា ហេតុនោះ ព្រះពុទ្ធនោះ ឈ្មោះថា មានកិច្ចធ្វើហើយ ។

ភិក្ខុណា មិនមានតណ្ហា សេចក្តីក្តៅក្រហាយនៃភិក្ខុនោះ ដែលជា
អ្នកកាត់ផ្តាច់នូវខ្សែនៃតណ្ហា លះបង់នូវកិច្ចគួរធ្វើ និងមិនគួរធ្វើ
រមែងមិនមាន ។

ហេតុនោះ ( លោកពោលថា ) មានកិច្ចធ្វើរួចហើយ ។ ពាក្យថា អាសវៈ ក្នុងបទថា មិនមានអាសវៈ បានដល់ អាសវៈ ៤ គឺកាមាសវៈ ភវាសវៈ ទិដ្ឋាសវៈ អវិជ្ជាសវៈ ។ អាសវៈទាំងនោះ ព្រះពុទ្ធមានជោគ លះបង់ ផ្តាច់ផ្តិលឫសគល់ ធ្វើឲ្យសល់តែទីនៅ ដូចជាទីនៅនៃដើមត្នោត ឲ្យដល់នូវការមិនមានបែបភាព មិនមានការកើតតទៅជាធម្មតា ហេតុនោះ ព្រះពុទ្ធ ឈ្មោះថា មិនមានអាសវៈ ហេតុនោះ ( លោកពោលថា ) ទ្រង់មានកិច្ចធ្វើរួចហើយ មិនមានអាសវៈ ។

[ ៤ ] ពាក្យថា ទ្រង់ដល់ត្រើយនៃធម៌ទាំងពួង គឺព្រះមានព្រះភាគទ្រង់ដល់ត្រើយ នៃការត្រាស់ដឹងធម៌ទាំងពួង ដល់ត្រើយនៃការកំណត់ដឹង ដល់ត្រើយនៃការលះបង់ ដល់ត្រើយនៃការចម្រើន ដល់ត្រើយនៃការធ្វើឲ្យជាក់ច្បាស់

ដល់ត្រើយនៃសមាបត្តិ ដល់ត្រើយនៃការត្រាស់ដឹងធម៌ទាំងពួង ដល់ត្រើយនៃការកំណត់ដឹងទុក្ខទាំងពួង ដល់ត្រើយនៃការលះកិលេសទាំងពួង ដល់ត្រើយនៃការចម្រើនមគ្គទាំង ៤ ដល់ត្រើយនៃការធ្វើឲ្យជាក់ច្បាស់នូវនិរោធ ដល់ត្រើយនៃការចូលកាន់សមាបត្តិទាំងពួង ។ ព្រះអង្គដល់នូវការស្ទាត់ ដល់ត្រើយក្នុងអរិយសីល ដល់នូវការស្ទាត់ ដល់ត្រើយក្នុងអរិយសមាធិ ដល់នូវការស្ទាត់ ដល់ត្រើយក្នុងអរិយបញ្ញា ដល់នូវការស្ទាត់ ដល់ត្រើយក្នុងអរិយវិមុត្តិ ព្រះអង្គទៅកាន់ត្រើយ ដល់ត្រើយ ទៅកាន់ទីបំផុត ដល់ទីបំផុត ទៅកាន់ទីខាងចុង ដល់ទីខាងចុង ទៅកាន់ទីបំផុតជុំវិញ ដល់ទីបំផុតជុំវិញ ទៅកាន់ទីចុងបំផុត ដល់ទីចុងបំផុត ទៅកាន់ទីជាទីពឹង ដល់ទីជាទីពឹង ទៅកាន់ទីជាទីពួន ដល់ទីជាទីពួន ទៅកាន់ទីជាទីប្រព្រឹត្ត ដល់ទីជាទីប្រព្រឹត្ត ទៅកាន់ទីមិនមានភ័យ ដល់ទីមិនមានភ័យ ទៅកាន់ទីទៀងទាត់ ដល់ទីទៀងទាត់ ទៅកាន់ទីមិនស្លាប់ ដល់ទីមិនស្លាប់ ទៅកាន់ព្រះនិព្វាន ដល់ព្រះនិព្វាន ព្រះមានព្រះភាគនោះ ទើបឈ្មោះថា ជាបុគ្គលមានអរិយវាស នៅរួចហើយ មានចរណធម៌សន្សំហើយ ។បេ។ ភពថ្មី គឺជាតិ ជរា និងមរណៈ សង្សារ របស់ព្រះមានព្រះភាគនោះ មិនមាន ហេតុនោះ ( លោកពោលថា ) ដល់ត្រើយនៃធម៌ទាំងពួង ។

[ ៥ ] ពាក្យថា ខ្ញុំព្រះអង្គជាអ្នកត្រូវការដោយប្រស្នា ទើបមកគាល់ សេចក្តីថា ពួកខ្ញុំព្រះអង្គ ត្រូវការដោយប្រស្នាទើបមក ជាអ្នកសួរប្រស្នាទើបមក ចង់ស្តាប់ប្រស្នាទើបមក ហេតុនោះ ( លោកពោលថា ) ខ្ញុំព្រះអង្គជា

អ្នកត្រូវការដោយប្រស្នា ទើបមកគាល់យ៉ាងនេះក៏បាន ។ មួយទៀត ការមក ការចូលមក ការចូលមកគាល់ របស់ខ្ញុំព្រះអង្គ ជាអ្នកត្រូវការដោយប្រស្នា ជាអ្នកសួរប្រស្នា ចង់ស្តាប់ប្រស្នា ហេតុនោះ ( លោកពោលថា ) ខ្ញុំព្រះអង្គ ជាអ្នកត្រូវការដោយប្រស្នាទើបមក យ៉ាងនេះក៏បាន ។ ឬថា ការមកដោយប្រស្នា មានដល់ព្រះអង្គៗ ជាបុគ្គលអាច ជាបុគ្គលមានព្យាយាម ជាបុគ្គលល្មមដើម្បីសួរ សម្តែង ដោះស្រាយ ពន្យល់ ពោល ជាមួយនឹងខ្ញុំព្រះអង្គ ហេតុនោះ ( លោកពោលថា ) ខ្ញុំព្រះអង្គ ជាអ្នកត្រូវការដោយប្រស្នាទើបមក យ៉ាងនេះក៏បាន ។

[ ៦ ] ពាក្យថា សូមព្រះអង្គសម្តែងអញ្ញាវិមោក្ខ សេចក្តីថា អរហត្តវិមោក្ខ លោកហៅថា អញ្ញាវិមោក្ខ ។ សូមព្រះអង្គសម្តែង ប្រាប់ ពន្យល់ ប្រញ្ញត្ត តាំងផ្តើម បើក ចែក ធ្វើឲ្យងាយ ប្រកាស នូវអរហត្តវិមោក្ខ ហេតុនោះ ( លោកពោលថា ) សូមព្រះអង្គសម្តែងអញ្ញាវិមោក្ខ

[ ៧ ] ពាក្យថា ជាគ្រឿងទម្លាយអវិជ្ជា គឺជាគ្រឿងបំបែក ទម្លាយ លះបង់ រម្ងាប់ លះចោល កម្ចាត់បង់នូវអវិជ្ជា គឺអមតនិព្វាន ហេតុនោះ ( លោកពោលថា ) ជាគ្រឿងទម្លាយអវិជ្ជា ។ ហេតុនោះ ព្រាហ្មណ៍នោះពោលហើយថា

( ឧទយៈមានអាយុ ក្រាបទូលដូច្នេះថា ) ខ្ញុំព្រះអង្គ ជាអ្នកត្រូវ
ការដោយប្រស្នាទើបមកគាល់ ( ដើម្បីសួរ ) ព្រះអង្គជាអ្នកមាន
ឈាន មានព្រះសន្តានប្រាសចាកធូលី ទ្រង់គង់នៅ ទ្រង់មានកិច្ច
ធ្វើរួចហើយ មិនមានអាសវៈ ទ្រង់ដល់នូវត្រើយនៃធម៌ទាំងពួង

សូមព្រះអង្គសម្តែងអញ្ញាវិមោក្ខ ជាគ្រឿងទម្លាយអវិជ្ជា ។

[ ៨ ] ( ព្រះមានព្រះភាគ ត្រាស់ថា ) ម្នាលឧទយៈ តថាគតសម្តែងថា ការលះនូវអកុសលធម៌ទាំងពីរ គឺកាមច្ឆន្ទៈ និងទោមនស្សផង ការបន្ទោបង់ចិត្តរួញរាផង ការហាមឃាត់កុក្កុច្ចៈទាំងឡាយផង ( ជាអញ្ញាវិមោក្ខ ) ។

[ ៩ ] ពាក្យថា ការលះកាមច្ឆន្ទៈ ត្រង់ពាក្យថា ឆន្ទៈ បានដល់សេចក្តីពេញចិត្តចំពោះកាម សេចក្តីត្រេកត្រអាលចំពោះកាម សេចក្តីរីករាយចំពោះកាម សេចក្តីប្រាថ្នាក្នុងកាម សេចក្តីស្នេហាក្នុងកាម សេចក្តីស្រេកឃ្លានក្នុងកាម សេចក្តីអន្ទះអន្ទែងក្នុងកាម សេចក្តីជ្រប់ចុះក្នុងកាម សេចក្តីងប់ក្នុងកាម ឱឃៈ គឺកាម យោគៈ គឺកាម ឧបាទាន គឺកាម នីវរណៈ គឺកាមច្ឆន្ទៈ ក្នុងកាមទាំងឡាយ ។ ពាក្យថា ការលះកាមច្ឆន្ទៈ គឺការលះ ការរម្ងាប់ ការលះបង់ ការកម្ចាត់បង់កាមច្ឆន្ទៈ អមតនិព្វាន ហេតុនោះ ( ទ្រង់ត្រាស់ថា ) ការលះកាមច្ឆន្ទៈ ។ ពាក្យថា ឧទយៈ ក្នុងបទថា ព្រះមានព្រះភាគ ( ត្រាស់ថា ) ម្នាលឧទយៈ គឺព្រះមានព្រះភាគ ត្រាស់ហៅព្រាហ្មណ៍នោះដោយឈ្មោះ ។ ត្រង់ពាក្យថា ព្រះមានព្រះភាគនុ៎ះ ជាពាក្យនិយាយដោយគោរព ។បេ។ បញ្ញត្តថា មានព្រះភាគនេះ ( កើត ) ព្រោះការត្រាស់ដឹង ហេតុនោះ ( ទើបមានពាក្យថា ) ព្រះមានព្រះភាគត្រាស់ថា ម្នាលឧទយៈ ។

[ ១០ ] ពាក្យថា ការលះបង់នូវអកុសលធម៌ទាំងពីរ គឺទោមនស្ស ត្រង់ពាក្យថា ទោមនស្ស បានដល់ ចេតសិកដែលមិនជាទីត្រេកអរ ចេតសិក

ជាទុក្ខ ការទទួលអារម្មណ៍មិនជាទីត្រេកអរ ជាទុក្ខ ដែលកើតអំពីសម្ផស្ស នៃចិត្ត គឺវេទនាមិនជាទីត្រេកអរ ជាទុក្ខ ដែលកើតអំពីសម្ផស្សនៃចិត្ត ។ ពាក្យថា ការលះនូវអកុសលធម៌ទាំងពីរ គឺទោមនស្ស បានសេចក្តីថា ការលះ ការរម្ងាប់ ការលះបង់ ការកម្ចាត់បង់ នូវអកុសលធម៌ទាំងពីរ គឺកាមច្ឆន្ទៈ និងទោមនស្ស ( ដោយចំពោះ ) អមតនិព្វាន ហេតុនោះ ( ទ្រង់ត្រាស់ថា ) ការលះនូវអកុសលធម៌ទាំងពីរ គឺពួកទោមនស្ស ។

[ ១១ ] ពាក្យថា ការបន្ទោបង់ចិត្តរួញរា បានដល់ភាពនៃចិត្តមិនស្រួល មិនគួរដល់ការងារ កិរិយារួញ ការរួញរា ការក្រាញ អាការនៃការក្រាញ ភាពនៃការក្រាញ ការប្រអូស អាការនៃការប្រអូស ភាពនៃការប្រអូស ។ ពាក្យថា ការបន្ទោបង់ចិត្តរួញរា គឺការបន្ទោបង់ ការលះបង់ ការរម្ងាប់ ការលះបោល ការស្ងប់រម្ងាប់ចិត្តរួញរា ( ដោយចំពោះ ) អមតនិព្វាន ហេតុនោះ ( ទ្រង់ត្រាស់ថា ) ការបន្ទោបង់ចិត្តរួញរា ។

[ ១២ ] ពាក្យថា កុក្កុច្ចៈទាំងឡាយ ក្នុងបទថា ការហាមឃាត់កុក្កុច្ចៈទាំងឡាយ បានដល់ ការរពឹសដៃ ហៅថា កុក្កុច្ចៈក៏បាន ការរពឹសជើង ហៅថា កុក្កុច្ចៈក៏បាន ការរពឹសទាំងដៃទាំងជើង ហៅថា កុក្កុច្ចៈក៏បាន សេចក្តីសម្គាល់ថាគួរ ក្នុងរបស់ដែលមិនគួរ សម្គាល់ថាមិនគួរ ក្នុងរបស់ដែលគួរ សេចក្តីសម្គាល់ថាមិនមានទោស ក្នុងរបស់ដែលមានទោស សេចក្តីសម្គាល់ថាមានទោស ក្នុងរបស់ដែលមិនមានទោស សេចក្តីរពឹស អាការនៃការប្រព្រឹត្តរពឹស ភាពនៃការប្រព្រឹត្តរពឹស សេចក្តីក្តៅក្រហាយចិត្ត គំនូសនៃចិត្តណា

មានសភាពយ៉ាងនេះ នេះលោកហៅថា កុក្កុច្ចៈ ។ មួយទៀត សេចក្ដីរពឹស សេចក្ដីក្ដៅក្រហាយចិត្ត គំនូសនៃចិត្ត តែងកើតដោយហេតុពីរ គឺព្រោះភាពនៃការធ្វើ ១ ព្រោះភាពនៃការមិនធ្វើ ១ ។ ចុះសេចក្ដីរពឹស សេចក្ដីក្ដៅក្រហាយចិត្ត គំនូសនៃចិត្ត កើតព្រោះភាពនៃការធ្វើ ១ ព្រោះភាពនៃការមិនធ្វើ ១ តើដូចម្ដេច ។ សេចក្ដីរពឹស សេចក្ដីក្ដៅក្រហាយចិត្ត គំនូសនៃចិត្ត កើតឡើងដោយគំនិតដូច្នេះថា កាយទុច្ចរិតអាត្មាអញបានធ្វើ កាយសុចរិតអាត្មាអញមិនបានធ្វើឡើយ ។ សេចក្ដីរពឹស សេចក្ដីក្ដៅក្រហាយចិត្ត គំនូសនៃចិត្តកើតឡើង ដោយគំនិតដូច្នេះថា វចីទុច្ចរិតអាត្មាអញបានធ្វើ វចីសុចរិតអាត្មាអញមិនបានធ្វើឡើយ ថាមនោទុច្ចរិតអាត្មាអញបានធ្វើ មនោសុចរិតអាត្មាអញមិនបានធ្វើឡើយ ថាបាណាតិបាតអាត្មាអញបានធ្វើ ការវៀរចាកបាណាតិបាត អាត្មាអញមិនបានធ្វើឡើយ ថាអទិន្នាទានអាត្មាអញបានធ្វើ ការវៀរចាកអទិន្នាទាន អាត្មាអញមិនបានធ្វើឡើយ ថាកាមេសុមិច្ឆាចារ អាត្មាអញបានធ្វើ ការវៀរចាកកាមេសុមិច្ឆាចារ អាត្មាអញមិនបានធ្វើឡើយ ថាមុសាវាទអាត្មាអញបានធ្វើ ការវៀរចាកមុសាវាទ អាត្មាអញមិនបានធ្វើឡើយ ថាបិសុណវាចាអាត្មាអញបានធ្វើ ការវៀរចាកបិសុណវាចា អាត្មាអញមិនបានធ្វើឡើយ ថាផរុសវាចាអាត្មាអញបានធ្វើ ការវៀរចាកផរុសវាចាអាត្មាអញមិនបានធ្វើឡើយ ថាសម្ផប្បលាបៈអាត្មាអញបានធ្វើ ការវៀរចាកសម្ផប្បលាបៈ អាត្មាអញមិនបានធ្វើឡើយ ថាអភិជ្ឈាអាត្មាអញបានធ្វើ ការមិនមានអភិជ្ឈា អាត្មាអញមិនបានធ្វើឡើយ ថាព្យាបាទអាត្មាអញបានធ្វើ ការ

មិនព្យាបាទអាត្មាអញមិនបានធ្វើឡើយ ថាមិច្ឆាទិដ្ឋិអាត្មាអញបានធ្វើ សម្មាទិដ្ឋិអាត្មាអញមិនបានធ្វើឡើយ ។ សេចក្តីរពឹស សេចក្តីក្តៅក្រហាយចិត្ត គំនូសនៃចិត្ត កើតឡើងព្រោះភាពនៃការធ្វើ និងភាពនៃការមិនធ្វើយ៉ាងនេះ ។ មួយទៀត សេចក្តីរពឹស ការក្តៅក្រហាយចិត្ត គំនូសនៃចិត្ត កើតឡើងដោយគំនិតដូច្នេះថា អាត្មាអញមិនបានបំពេញក្នុងសីលទាំងឡាយទេ ។ សេចក្តីរពឹស ការក្តៅក្រហាយចិត្ត គំនូសនៃចិត្តកើតឡើង ដោយគំនិតដូច្នេះថា អាត្មាអញមិនបានគ្រប់គ្រងទ្វារ ក្នុងឥន្ទ្រិយទាំងឡាយ ថាអាត្មាអញ មិនដឹងប្រមាណក្នុងភោជនទេ ថាអាត្មាអញ មិនបានប្រកបរឿយៗ នូវសេចក្តីភ្ញាក់រឭកទេ ថាអាត្មាអញ មិនបានប្រកបដោយសតិ និងសម្បជញ្ញៈទេ ថាសតិប្បដ្ឋានទាំង ៤ អាត្មាអញមិនបានចម្រើនទេ ថាសម្មប្បធានទាំង ៤ អាត្មាអញមិនបានចម្រើនទេ ថាឥទ្ធិបាទ ៤ អាត្មាអញមិនបានចម្រើនទេ ថាឥន្ទ្រិយ ៥ អាត្មាអញមិនបានចម្រើនទេ ថាពល ៥ អាត្មាអញមិនបានចម្រើនទេ ថាពោជ្ឈង្គទាំង ៧ អាត្មាអញមិនបានចម្រើនទេ ថាមគ្គប្រកបដោយអង្គ ៨ ដ៏ប្រសើរ អាត្មាអញមិនបានចម្រើនទេ ថាទុក្ខ អាត្មាអញមិនបានកំណត់ដឹងទេ ថាសមុទ័យ អាត្មាអញមិនបានលះបង់ទេ ថាមគ្គអាត្មាអញមិនបានចម្រើនទេ ថានិរោធ អាត្មាអញមិនបានធ្វើឲ្យជាក់ច្បាស់ទេ ។ ពាក្យថា ការហាមឃាត់កុក្កុច្ចៈទាំងឡាយ បានន័យថា ការទប់ ការរារាំង ការលះ ការរម្ងាប់ ការលះចោល ការស្ងប់រម្ងាប់កុក្កុច្ចៈ ( ដោយចំពោះ ) អមតនិព្វាន ហេតុនោះ ( ទ្រង់ត្រាស់ថា ) ការហាមឃាត់កុក្កុច្ចៈទាំងឡាយ ។ ហេតុនោះ ព្រះមានព្រះភាគ

ត្រាស់ថា

( ព្រះមានព្រះភាគត្រាស់ថា ម្នាលឧទយៈ តថាគតសម្តែងថា ) ការលះនូវអកុសលធម៌ទាំង ២ គឺកាមច្ឆន្ទៈ និងទោមនស្សផង ការបន្ទោបង់ចិត្តរួញរាផង ការហាមឃាត់កុក្កុច្ចៈទាំងឡាយផង ( ជាអញ្ញាវិមោក្ខ ) ។

[ ១៣ ] មួយទៀត តថាគតសម្តែងនូវឧបេក្ខា និងសតិដ៏បរិសុទ្ធ នូវការត្រិះរិះធម៌ស្មុះទៅមុន ថាជាអញ្ញាវិមោក្ខ ជាគ្រឿងទម្លាយអវិជ្ជា ។

[ ១៤ ] ពាក្យថា ឧបេក្ខា ក្នុងបទថា ឧបេក្ខា និងសតិដ៏បរិសុទ្ធ បានដល់ ការព្រងើយ អាការព្រងើយ អាការនៃចិត្តសោះអង្គើយ ការស្ងប់ចិត្ត សេចក្តីថាស្អាតនៃចិត្ត ភាពនៃចិត្តជាកណ្តាល ក្នុងចតុត្ថជ្ឈាន ។ ពាក្យថា សតិ បានដល់ ស្មារតី ការរឭករឿយៗ ។បេ។ ការរឭកដោយប្រពៃ ប្រារព្ធឧបេក្ខាក្នុងចតុត្ថជ្ឈាន ហេតុនោះ ( ទ្រង់ត្រាស់ថា ) ឧបេក្ខា និងសតិ ។ ពាក្យថា បរិសុទ្ធ បានដល់ ឧបេក្ខា និងសតិ ក្នុងចតុត្ថជ្ឈាន ជាធម្មជាតដ៏ស្អាត ស្អាតព្រម ផូរផង់ មិនមានទីទួល គឺកិលេស ប្រាសចាកឧបក្កិលេស ជាធម្មជាតទន់ភ្លន់ គួរដល់ការងារ ជាធម្មជាតនឹងធឹង ដល់នូវការមិនកម្រើក ហេតុនោះ ( ទ្រង់ត្រាស់ថា ) ឧបេក្ខា និងសតិដ៏បរិសុទ្ធ ។

[ ១៥ ] ពាក្យថា ការត្រិះរិះធម៌ស្មុះទៅមុន សេចក្តីថា សម្មាសង្កប្ប លោកហៅថា ការត្រិះរិះធម៌ ។ សម្មាសង្កប្បនោះជាខាងដើម ជាខាងមុខ

ជាប្រធាននៃអញ្ញាវិមោក្ខ ហេតុនោះ ( ទ្រង់ត្រាស់ថា ) ការត្រិះរិះធម៌ស្មុះទៅមុន យ៉ាងនេះក៏បាន ។ មួយទៀត សម្មាទិដ្ឋិ លោកហៅថា ការត្រិះរិះធម៌ ។ សម្មាទិដ្ឋិនោះជាខាងដើម ជាខាងមុខ ជាប្រធាននៃអញ្ញាវិមោក្ខ ហេតុនោះ ( ទ្រង់ត្រាស់ថា ) ការត្រិះរិះធម៌ស្មុះទៅមុន យ៉ាងនេះក៏បាន ។ ឬថាវិបស្សនាក្នុងចំណែកខាងដើមនៃមគ្គទាំង ៤ លោកហៅថា ការត្រិះរិះធម៌ ។ វិបស្សនានោះជាខាងដើម ជាខាងមុខ ជាប្រធាននៃអញ្ញាវិមោក្ខ ហេតុនោះ ( ទ្រង់ត្រាស់ថា ) ការត្រិះរិះធម៌ស្មុះទៅមុន យ៉ាងនេះក៏បាន ។

[ ១៦ ] ពាក្យថា តថាគតសម្តែងថា អញ្ញាវិមោក្ខ គឺអរហត្តវិមោក្ខ លោកហៅថាអញ្ញាវិមោក្ខ តថាគតពោលដោយប្រពៃ ប្រាប់ សម្តែង ប្រញ្ញត្តតាំងផ្តើម បើក វែកញែក ធ្វើឲ្យងាយនូវអរហត្តវិមោក្ខ ហេតុនោះ ( ទ្រង់ត្រាស់ថា ) តថាគតសម្តែងថា អញ្ញាវិមោក្ខ ។

[ ១៧ ] ពាក្យថា អវិជ្ជា ក្នុងបទថាជាគ្រឿងទម្លាយអវិជ្ជា បានដល់ការមិនដឹងក្នុងទុក្ខ ។បេ។ គន្លឹះ គឺអវិជ្ជា មោហៈ អកុសលមូល ។ ពាក្យថា ជាគ្រឿងទម្លាយអវិជ្ជា បានន័យថា ការបំបែក ការទម្លាយ ការលះ ការរម្ងាប់ ការលះបោល ការកម្ចាត់បង់នូវអវិជ្ជា គឺអមតនិព្វាន ហេតុនោះ ( ទ្រង់ត្រាស់ថា ) ជាគ្រឿងទម្លាយអវិជ្ជា ។ ហេតុនោះ ព្រះមានព្រះភាគត្រាស់ថា

( មួយទៀត ) តថាគតសម្តែងនូវឧបេក្ខា និងសតិដ៏បរិសុទ្ធ នូវ
ការត្រិះរិះធម៌ស្មុះទៅមុន ថាជាអញ្ញាវិមោក្ខ ជាគ្រឿងទម្លាយអវិជ្ជា ។

[ ១៨ ] ( ឧទយមាណព ទូលសួរថា ) សត្វលោក មានអ្វីជា

គ្រឿងចងទុក អ្វីជាគ្រឿងត្រាច់ទៅ របស់សត្វលោកនោះ ដែល
លោកពោលថា និព្វាន តើព្រោះការលះអ្វីបាន ។

[ ១៩ ] ពាក្យថា សត្វលោកមានអ្វីជាគ្រឿងចងទុក គឺអ្វីជាគ្រឿងប្រកបព្រម ជាគ្រឿងជាប់ ជាចំណង ជាឧបក្កិលេសនៃសត្វលោក គឺថា សត្វលោកប្រកប ប្រកបសព្វ ប្រកបទូទៅ ផ្សំ ជាប់ ទាក់ ជំពាក់ដោយអ្វី ហេតុនោះ ( លោកសួរថា ) សត្វលោកមានអ្វីជាគ្រឿងប្រកបព្រម ។

[ ២០ ] ពាក្យថា អ្វីជាគ្រឿងត្រាច់ទៅ របស់សត្វលោកនោះ គឺអ្វីជាគ្រឿងដើរ ត្រាច់ទៅ ត្រាច់រង្គាត់របស់សត្វលោកនោះ គឺថា សត្វលោកដើរ ត្រាច់ទៅ ត្រាច់រង្គាត់ដោយអ្វី ហេតុនោះ ( លោកសួរថា ) អ្វីជាគ្រឿងត្រាច់ទៅ របស់សត្វលោកនោះ ។

[ ២១ ] ពាក្យថា ដែលលោកពោលថានិព្វាន តើព្រោះការលះអ្វីបាន គឺដែលលោកហៅ ពោល ថ្លែង សម្តែង ពន្យល់ថានិព្វាន តើដោយការលះ ការរម្ងាប់ ការលោះបោល ការស្ងប់រម្ងាប់នូវអ្វី ហេតុនោះ ( លោកសួរថា ) ដែលលោកពោលថានិព្វាន តើព្រោះការលះអ្វីបាន ។ ហេតុនោះ ព្រាហ្មណ៍នោះពោលថា

សត្វលោកមានអ្វីជាគ្រឿងចងទុក អ្វីជាគ្រឿងត្រាច់ទៅរបស់សត្វ
លោកនោះ ដែលលោកពោលថានិព្វាន តើព្រោះការលះអ្វីបាន ។

[ ២២ ] ( ព្រះមានព្រះភាគត្រាស់ថា ) សត្វលោកមានសេចក្តី
រីករាយ ជាគ្រឿងចងទុក សេចក្តីត្រិះរិះទាំងឡាយ ជាគ្រឿងត្រាច់

ទៅរបស់សត្វលោកនោះ ដែលលោកពោលថានិព្វាន ព្រោះការលះតណ្ហាបាន ។

[ ២៣ ] ពាក្យថា សត្វលោកមានសេចក្តីរីករាយ ជាគ្រឿងចងទុក សេចក្តីថា តណ្ហាលោកហៅថាសេចក្តីរីករាយ បានខាងសេចក្តីត្រេកត្រអាល ការត្រេកត្រអាលខ្លាំង ។បេ។ ការសម្លឹងរំពៃ ( ទ្រព្យអ្នកដទៃ ) លោភៈ អកុសលមូល ។ សេចក្តីរីករាយណា ដែលជាគ្រឿងប្រកបព្រម ជាគ្រឿងជាប់ ជាគ្រឿងចង ជាឧបក្កិលេសនៃលោក សត្វលោកប្រកប ប្រកបសព្វ ប្រកបទូទៅ ផ្សំ ជាប់ ទាក់ ជំពាក់ ដោយសេចក្តីរីករាយនេះ ហេតុនោះ ( ទ្រង់ត្រាស់ថា ) សត្វលោកមានសេចក្តីរីករាយ ជាគ្រឿងចងទុក ។

[ ២៤ ] ពាក្យថា សេចក្តីត្រិះរិះទាំងឡាយ ក្នុងបទថា សេចក្តីត្រិះរិះទាំងឡាយជាគ្រឿងត្រាច់ទៅ របស់សត្វលោកនោះ បានដល់ សេចក្តីត្រិះរិះ ៩ គឺសេចក្តីត្រិះរិះក្នុងកាម សេចក្តីត្រិះរិះក្នុងព្យាបាទ សេចក្តីត្រិះរិះក្នុងវិហឹសា សេចក្តីត្រិះរិះក្នុងញាតិ សេចក្តីត្រិះរិះក្នុងជនបទ សេចក្តីត្រិះរិះក្នុងការមិនស្លាប់ សេចក្តីត្រិះរិះប្រកបចំពោះ ដោយភាពនៃសេចក្តីអាណិតដល់ជនដទៃ សេចក្តីត្រិះរិះប្រកបចំពោះ ដោយលាភសក្ការៈ និងសេចក្តីសរសើរ សេចក្តីត្រិះរិះប្រកបដោយការមិនចង់ឲ្យគេមើលងាយទាំងនេះ ហៅថា សេចក្តីត្រិះរិះ ៩ ។ សេចក្តីត្រិះរិះទាំង ៩ នេះ ជាគ្រឿងដើរទៅ ត្រាច់ទៅ ត្រាច់រង្គាត់ទៅ នៃសត្វលោកនោះ គឺថាសត្វលោកនោះដើរទៅ ត្រាច់ទៅ ត្រាច់រង្គាត់ទៅ ដោយសារសេចក្តីត្រិះរិះ ៩ នេះ ហេតុនោះ ( ទ្រង់ត្រាស់ថា ) សេចក្តីត្រិះរិះទាំងឡាយ

ជាគ្រឿងត្រាច់ទៅរបស់សត្វលោកនោះ ។

[ ២៥ ] ពាក្យថា តណ្ហា ក្នុងបទថា ដែលលោកពោលថានិព្វាន ព្រោះការលះបង់តណ្ហា បានដល់រូបតណ្ហា សទ្ទតណ្ហា គន្ធតណ្ហា រសតណ្ហា ផោដ្ឋព្វ-តណ្ហា ធម្មតណ្ហា ។ ពាក្យថា ដែលលោកពោលថានិព្វាន ព្រោះការលះបង់តណ្ហា គឺថាដែលលោកហៅ ពោល ថ្លែង សម្តែង បំភ្លឺ ពន្យល់ថានិព្វាន ព្រោះការលះ ការរម្ងាប់ ការលះបង់ ការស្ងប់រម្ងាប់តណ្ហា ហេតុនោះ ( ទ្រង់ត្រាស់ថា ) ដែលលោកពោលថានិព្វាន ព្រោះការលះតណ្ហា ។ ហេតុនោះព្រះមានព្រះភាគត្រាស់ថា

សត្វលោកមានសេចក្តីរីករាយ ជាគ្រឿងចងទុក សេចក្តីត្រិះរិះទាំងឡាយ ជាគ្រឿងត្រាច់ទៅ របស់សត្វលោកនោះ ដែលលោកហៅថា និព្វាន ព្រោះការលះតណ្ហាបាន ។

[ ២៦ ] បុគ្គលមានស្មារតី ប្រព្រឹត្តទៅដូចម្តេច វិញ្ញាណទើបរលត់ ពួកខ្ញុំព្រះអង្គមកគាល់ ដើម្បីទូលសួរព្រះមានព្រះភាគ នឹងបានស្តាប់ព្រះពុទ្ធដីការបស់ព្រះអង្គ ។

[ ២៧ ] ពាក្យថា បុគ្គលមានស្មារតីប្រព្រឹត្តទៅដូចម្តេច គឺបុគ្គលមានស្មារតីដឹងព្រម ត្រាច់ទៅ ត្រាច់ទៅផ្សេងៗ ដើរទៅ ប្រព្រឹត្តទៅ រក្សា យាត្រា យាត្រាទៅដូចម្តេច ។ ហេតុនោះ ( លោកសួរថា ) បុគ្គលមានស្មារតីប្រព្រឹត្តទៅដូចម្តេច ។

[ ២៨ ] ពាក្យថា វិញ្ញាណទើបរលត់ គឺវិញ្ញាណរលត់ ស្ងប់ អស្តង្គត

ស្ងប់រម្ងាប់ ហេតុនោះ ( លោកសួរថា ) វិញ្ញាណទើបរលត់ ។

[ ២៩ ] ពាក្យថា ពួកខ្ញុំព្រះអង្គមកគាល់ ដើម្បីទូលសួរព្រះមានព្រះភាគ គឺពួកខ្ញុំព្រះអង្គមក មកដល់ មកគាល់ ដល់ព្រម មកជួបជុំ ជាមួយនឹងព្រះអង្គ ដើម្បីទូលសួរ សាកសួរ អង្វរ អារាធនា ជ្រះថ្លា ចំពោះព្រះពុទ្ធមានជោគ ហេតុនោះ ( លោកសួរថា ) ពួកខ្ញុំព្រះអង្គមកគាល់ ដើម្បីទូលសួរព្រះមានព្រះភាគ ។

[ ៣០ ] ពាក្យថា ព្រះអង្គ ក្នុងបទថា នឹងបានស្តាប់ព្រះពុទ្ធដីការបស់ព្រះអង្គ គឺពួកខ្ញុំព្រះអង្គស្តាប់ រៀន ចងចាំទុក កំណត់ទុកនូវព្រះវាចា ការពោល ការសម្តែង អនុសន្ធិរបស់ព្រះអង្គ ហេតុនោះ ( លោកសួរថា ) នឹងបានស្តាប់ព្រះពុទ្ធដីការបស់ព្រះអង្គ ។ ហេតុនោះ ព្រាហ្មណ៍នោះពោលថា

បុគ្គលមានស្មារតី ប្រព្រឹត្តទៅដូចម្តេច វិញ្ញាណទើបរលត់ ពួកខ្ញុំ
ព្រះអង្គមកគាល់ ដើម្បីទូលសួរព្រះមានព្រះភាគ នឹងបានស្តាប់
ព្រះពុទ្ធដីការបស់ព្រះអង្គ ។

[ ៣១ ] ( ព្រះមានព្រះភាគត្រាស់ថា ) កាលបុគ្គលមិនរីករាយ
ចំពោះវេទនាទាំងខាងក្នុង ទាំងខាងក្រៅ មានស្មារតីប្រព្រឹត្តទៅ
យ៉ាងនេះ វិញ្ញាណទើបរលត់ ។

[ ៣២ ] អធិប្បាយពាក្យថា កាលបុគ្គលមិនរីករាយ ចំពោះវេទនាទាំងខាងក្នុង ទាំងខាងក្រៅ គឺបុគ្គលកាលពិចារណា ឃើញវេទនាក្នុងវេទនាទាំងឡាយខាងក្នុង មិនរីករាយ មិនសរសើរ មិនស្ថិតនៅក្នុងសេចក្តីជ្រប់ចិត្តចំពោះ

វេទនា គឺថា លះបង់ បន្ទោបង់ ធ្វើឲ្យវិនាស ឲ្យដល់នូវការមិនមានបែបភាព នូវការរីករាយ ការសរសើរ ការជ្រប់ចិត្ត ការក្ដួចកាន់ ការស្ទាបអង្អែល ការប្រកាន់ ។ បុគ្គលកាលពិចារណាឃើញ វេទនាក្នុងវេទនាទាំងឡាយខាងក្រៅ មិនរីករាយ មិនសរសើរ មិនស្ថិតនៅក្នុងការជ្រប់ចិត្តចំពោះវេទនា គឺលះបង់ បន្ទោបង់ ធ្វើឲ្យវិនាស ឲ្យដល់នូវការមិនមានបែបភាព នូវការរីករាយ ការសរសើរ ការជ្រប់ចិត្ត ការក្ដួចកាន់ ការស្ទាបអង្អែល ការប្រកាន់ ។ បុគ្គលកាលពិចារណាឃើញវេទនាក្នុងវេទនាទាំងឡាយខាងក្នុង ទាំងខាងក្រៅ មិនរីករាយ មិនសរសើរ មិនស្ថិតនៅក្នុងការជ្រប់ចិត្តចំពោះវេទនា គឺលះបង់ បន្ទោបង់ ធ្វើឲ្យវិនាស ឲ្យដល់នូវការមិនមានបែបភាព នូវការរីករាយ សរសើរ ជ្រប់ចិត្ត ក្ដួចកាន់ ស្ទាបអង្អែល ប្រកាន់ ។ បុគ្គលកាលពិចារណាឃើញ នូវការកើតឡើងជាធម្មតា ក្នុងវេទនាទាំងឡាយខាងក្នុង កាលពិចារណាឃើញ នូវការវិនាសទៅជាធម្មតា ក្នុងវេទនាទាំងឡាយខាងក្នុង កាលពិចារណាឃើញ នូវការកើតឡើង និងការវិនាសទៅជាធម្មតា ក្នុងវេទនាទាំងឡាយខាងក្នុង កាលពិចារណាឃើញ នូវការកើតឡើងជាធម្មតា ក្នុងវេទនាទាំងឡាយខាងក្រៅ កាលពិចារណាឃើញ នូវការវិនាសទៅជាធម្មតា ក្នុងវេទនាទាំងឡាយខាងក្រៅ កាលពិចារណាឃើញ នូវការកើតឡើង និងការវិនាសទៅជាធម្មតា ក្នុងវេទនាទាំងឡាយខាងក្រៅ កាលពិចារណាឃើញ នូវការកើតឡើងជាធម្មតា ក្នុងវេទនាទាំងឡាយខាងក្នុង ទាំងខាងក្រៅ កាលពិចារណាឃើញ នូវការវិនាសទៅជាធម្មតា ក្នុងវេទនាទាំងឡាយខាងក្នុង ទាំងខាងក្រៅ កាលពិចារណាឃើញ នូវ

ការកើតឡើង និងការវិនាសទៅជាធម្មតា ក្នុងវេទនាទាំងឡាយខាងក្នុង ទាំងខាងក្រៅ មិនរីករាយ មិនសរសើរ មិនស្ថិតនៅក្នុងសេចក្តីជ្រប់ចិត្តចំពោះវេទនា គឺលះបង់ បន្ទោបង់ ធ្វើឲ្យវិនាស ឲ្យដល់នូវការមិនមានបែបភាព នូវការរីករាយ សរសើរ ជ្រប់ចិត្ត កួចកាន់ ស្ទាបអង្អែល ប្រកាន់ ។ បុគ្គលកាលពិចារណាឃើញវេទនា ក្នុងវេទនាទាំងឡាយ ដោយអាការទាំង ១២ នេះ មិនរីករាយ មិនសរសើរ មិនស្ថិតនៅក្នុងការជ្រប់ចិត្តចំពោះវេទនា ។បេ។ ឲ្យដល់នូវការមិនមានបែបភាព នូវការរីករាយ ការសរសើរ ការជ្រប់ចិត្ត ។ មួយទៀត បុគ្គលកាលឃើញវេទនា ដោយសេចក្តីថា មិនទៀង មិនរីករាយ មិនសរសើរ មិនស្ថិតនៅក្នុងការជ្រប់ចិត្តចំពោះវេទនា គឺលះបង់ បន្ទោបង់ ធ្វើឲ្យវិនាស ឲ្យដល់នូវការមិនមានបែបភាព នូវការរីករាយ ការសរសើរ ការជ្រប់ចិត្ត ការកួចកាន់ ការស្ទាបអង្អែល ការប្រកាន់ ។ បុគ្គលកាលឃើញវេទនាដោយសេចក្តីថាជាទុក្ខ ជារោគ ជាពក ជាសរ ជាសេចក្តីលំបាក ជាអាពាធ ។បេ។ ដោយសេចក្តីថា មិនជាទីរលាស់ទុក្ខ មិនរីករាយ មិនសរសើរ មិនស្ថិតនៅក្នុងសេចក្តីជ្រប់ចិត្តចំពោះវេទនា គឺលះបង់ បន្ទោបង់ ធ្វើឲ្យវិនាស ឲ្យដល់នូវការមិនមានបែបភាព នូវការរីករាយ ការសរសើរ ការជ្រប់ចិត្ត ការកួចកាន់ ការស្ទាបអង្អែល ការប្រកាន់ ។ បុគ្គលកាលពិចារណាឃើញវេទនាក្នុងវេទនាទាំងឡាយ ដោយអាការទាំងសែសិបពីរនេះ មិនរីករាយ មិនសរសើរ មិនស្ថិតនៅក្នុងសេចក្តីជ្រប់ចិត្តចំពោះវេទនា គឺលះបង់ បន្ទោបង់ ធ្វើឲ្យវិនាស ឲ្យដល់នូវការមិនមានបែបភាព នូវការរីករាយ ការសរសើរ ការជ្រប់ចិត្ត ការកួចកាន់

ការស្តាប់អង្រ្គួល ការប្រកាន់ ហេតុនោះ ( ទ្រង់ត្រាស់ថា ) កាលបុគ្គលមិនរីករាយ ចំពោះវេទនាទាំងឡាយ ទាំងខាងក្នុង ទាំងខាងក្រៅ ។

[ ៣៣ ] ពាក្យថា មានស្មារតីប្រព្រឹត្តទៅយ៉ាងនេះ គឺបុគ្គលមានស្មារតីដឹងខ្លួនយ៉ាងនេះ ត្រាច់ទៅ ត្រាច់ទៅផ្សេងៗ ដើរទៅ ប្រព្រឹត្តទៅ រក្សា យាត្រា យាត្រាទៅ ហេតុនោះ ( ទ្រង់ត្រាស់ថា ) មានស្មារតីប្រព្រឹត្តទៅយ៉ាងនេះ ។

[ ៣៤ ] ពាក្យថា វិញ្ញាណទើបរលត់ បានដល់ វិញ្ញាណ ដែលប្រកបដោយបុញ្ញាភិសង្ខារ វិញ្ញាណដែលប្រកបដោយអបុញ្ញាភិសង្ខារ វិញ្ញាណដែលប្រកបដោយអានេញ្ជាភិសង្ខារ រលត់ ស្ងប់ អស្តង្គត រម្ងាប់ ហេតុនោះ ( ទ្រង់ត្រាស់ថា ) វិញ្ញាណទើបរលត់ ។ ហេតុនោះ ព្រះមានព្រះភាគត្រាស់ថា

កាលបុគ្គលមិនរីករាយ ចំពោះវេទនាទាំងខាងក្នុង ទាំងខាងក្រៅ
មានស្មារតីប្រព្រឹត្តទៅយ៉ាងនេះ វិញ្ញាណទើបរលត់ ។

លុះចប់គាថា ។បេ។ បពិត្រព្រះអង្គដ៏ចម្រើន សូមព្រះមានព្រះភាគ ជាសាស្តារបស់ខ្ញុំព្រះអង្គ ខ្ញុំព្រះអង្គសូមជាសាវ័ក ។

**ឧទយមាណវកប្បញ្ហានិទ្ទេសទី ១៣ ចប់**

# អដ្ឋកថា

## ឧទយមាណវកបញ្ហានិទ្ទេស

គប្បីជ្រាបវិនិច្ឆ័យក្នុងឧទយសូត្រទី ១៣ ដូចតទៅ

[ ១ ] បទថា **អញ្ញាវិមោក្ខំ** សេចក្តីថា ឧទយមាណពទូលសួរដល់វិមោក្ខដែលសម្រេចដោយអានុភាពនៃអរហត្ត ។

[ ២ ] បទថា **បឋមេនបិ ឈានេន ឈាយី** ព្រះមានព្រះភាគឈ្មោះថា **ឈាយី** ព្រោះសម្ពឹងដោយបឋមជ្ឈានមានអង្គ ៥ ដែលសម្បយុត្តដោយវិតក្ក វិចារៈ បីតិ សុខ ចិត្តេកគ្គតា ។ បទថា **ទុតិយេន** បានដល់ទុតិយជ្ឈានដែលសម្បយុត្តដោយបីតិ សុខ ចិត្តេកគ្គតា ។ បទថា **តតិយេន** បានដល់ តតិយជ្ឈានដែលសម្បយុត្តដោយសុខ និងចិត្តេកគ្គតា ។ បទថា **ចតុត្ថេន** បានដល់ ចតុត្ថជ្ឈាន ដែលសម្បយុត្តដោយឧបេក្ខា និងចិត្តេកគ្គតា ។ បទថា **សវិតក្កសវិចារេនបិ ឈានេន ឈាយី** បានដល់ ឈ្មោះថា **ឈាយី** ព្រោះសម្ពឹងឈាន ដែលមានវិតក្ក មានវិចារៈ គឺដោយបឋមជ្ឈាន ក្នុងចតុក្កន័យ និងបញ្ចកន័យ ។ បទថា **អវិតក្កវិចារមត្តេន** បានដល់ ដោយទុតិយជ្ឈានក្នុងបញ្ចកន័យ ។ បទថា **អវិតក្កាវិចារេន** បានដល់ ដោយឈានដ៏សេស មានទុតិយជ្ឈាន ( ក្នុងចតុក្កន័យ ) និងតតិយជ្ឈាន ( បញ្ចកន័យ ) ជាដើម ។ បទថា **សប្បីតិកេន** បានដល់ ដោយទុកជ្ឈាន និងតិកជ្ឈានដែលសម្បយុត្តដោយបីតិ ។ បទថា **និប្បីតិកេន** បានដល់ ដោយឈានដ៏សេសអំពីនោះ ដែលវៀរហើយចាកបីតិ ។ បទថា **សាតសហគតេន** បាន

ដល់ ដោយតិកជ្ឈាន និងចតុក្កជ្ឈានដែលសហគតៈដោយសុខ ។ បទថា **ឧបេក្ខាសហគតេន** បានដល់ ដោយចតុក្កជ្ឈាន និងបញ្ចកជ្ឈាន ។ បទថា **សុញ្ញតេន** បានដល់ ដែលសម្បយុត្តដោយសុញ្ញតវិមោក្ខ ។ បទថា **អនិមិត្តេនបិ** ឈ្មោះថា **ឈាយី** ព្រោះសម្លឹងដោយឈានដែលមិនមាននិមិត្ត ដែលខ្លួនបានហើយ ព្រោះបើកនូវនិមិត្តថា ទៀង និមិត្តថា ស្ថិតស្ថេរ និងនិមិត្តថា ខ្លួនចេញហើយ ។ បទថា **អប្បណិហិតេនបិ** បានដល់ ដោយឈានដែលមិនមានទីតាំង ដោយអំណាចផលសមាបត្តិ ព្រោះជម្រះទីតាំងនៃកិលេសឲ្យអស់ទៅដោយអំណាចការមកដល់នៃមគ្គ ។ បទថា **លោកិយេនបិ** បានដល់ ដោយបឋមជ្ឈាន ទុតិយជ្ឈាន តតិយជ្ឈាន និងចតុត្ថជ្ឈាន ដែលជាលោកិយ ។ បទថា **លោកុត្តរេនបិ** បានដល់ ដោយឈានដែលសម្បយុត្តដោយលោកុត្តរនោះឯង ។ បទថា **ឈានរតោ** បានដល់ ទ្រង់ត្រេកអរក្រៃលែងក្នុងឈានទាំងឡាយ ។ បទថា **ឯកត្តមនុយុត្តោ** បានដល់ ទ្រង់ខ្វល់ខ្វាយ ប្រកបដោយភាពជាបុគ្គលឯក គឺភាពជាអ្នកនៅតែឯង ។ បទថា **សទត្ថគរុកោ** បានដល់ **សកត្ថគរុកោ** សេចក្តីថា ជាអ្នកធ្ងន់ក្នុងប្រយោជន៍របស់ខ្លួន ។ ផ្លាស់ **ក** អក្ខរៈ ជា **ទ** អក្ខរៈ ។ ម្យ៉ាងទៀត បទថា **សទត្ថោ** គប្បីជ្រាបថា បានដល់ អរហត្ត ។ ពិតហើយ អរហត្តនោះ លោកពោលថា ប្រយោជន៍ខ្លួន ព្រោះអត្ថថា ចូលទៅពាក់ព័ន្ធនឹងខ្លួន ព្រោះអត្ថថា មិនលះនូវខ្លួន ព្រោះជាប្រយោជន៍យ៉ាងក្រៃលែងរបស់ខ្លួន ជាប្រយោជន៍ចំពោះខ្លួន ។ ជាអ្នកធ្ងន់ក្នុងប្រយោជន៍ខ្លួន ដោយអំណាចការចូលដល់ផលសមាបត្តិ ។

អាចារ្យពួកមួយពោលថា ជាអ្នកធ្ងន់ក្នុងនិព្វាន ។ បទថា **អរជោ** បានដល់ មិនមានកិលេស ។ បទថា **វិរជោ** បានដល់ ប្រាសចាកកិលេស ។ បទថា **និរជោ**[១] បានដល់ នាំកិលេសចេញទៅហើយ ។ បាឋៈថា **វិគតរជោ** ក៏មាន ឯសេចក្តីក៏ដូចគ្នា ។ បទថា **រជាបគតោ** បានដល់ ជាអ្នកឆ្ងាយចាក កិលេស ។ បទថា **រជវិប្បហីនោ** បានដល់ ជាអ្នកលះកិលេសបានហើយ ។ បទថា **រជវិប្បមុត្តោ** បានដល់ ជាអ្នកផុតចាកកិលេសទាំងឡាយ ។ បទថា **ចាសាណកេ ចេតិយេ** បានដល់ ក្នុងទីដែលព្រះមានព្រះភាគទ្រង់សម្តែង បារាយនសូត្រលើផ្ទាំងថ្ម ។ បទថា **សព្វោសុរត្តបដិបស្សទ្ធត្តា** សេចក្តីថា ឈ្មោះថា **អាសីនោ** ទ្រង់គង់នៅ ព្រោះទ្រង់រម្ងាប់សេចក្តីក្រវល់ក្រវាយ គឺ កិលេសទាំងពួងបានហើយ គឺធ្វើឲ្យអស់សូន្យទៅ ។

(១) បិដកខ្មែរមិនមានបទនេះ តែបិដកឆដ្ឋសង្គាយនាមាន បណ្ឌិតគប្បីជ្រាប។

[ ៣ ] បទថា **កិច្ចាកិច្ចំ** បានដល់ គប្បីគិតដោយចិត្តយ៉ាងនេះថា វត្ថុនេះគួរធ្វើ វត្ថុនេះមិនគួរធ្វើ ដូច្នេះ ។ បទថា **ករណីយាករណីយំ** បាន ដល់ កម្មដែលគួរធ្វើ និងកម្មដែលមិនគួរធ្វើយ៉ាងនេះថា កម្មនេះ ប្រព្រឹត្ត ទៅតាមកាយទ្វារគួរធ្វើ កម្មនេះ មិនគួរធ្វើ ។ បទថា **បហីនំ** បានដល់ លះបង់ហើយ ។

[ ៤ ] បទថា **វសិប្បត្តោ** បានដល់ ដល់នូវភាពជាអ្នកស្ទាត់ជំនាញ ។

លំដាប់នោះ ព្រះមានព្រះភាគ ព្រោះឧទយមាណពជាប្រក្រតី បាន ចតុត្ថជ្ឈាន ដូច្នោះ កាលទ្រង់សម្តែងវិមោក្ខ គឺអរហត្ត ដោយប្រការផ្សេងៗ

ដោយអំណាចនៃឈានដែលឧទយមាណពនោះបានហើយ ទើបត្រាស់គាថាទាំងឡាយតទៅ

[ ៨ ] ក្នុងបទទាំងនោះ បទថា **បហានំ កាមច្ឆន្ទានំ** សេចក្តីថា ព្រះមានព្រះភាគត្រាស់តបនឹងឧទយមាណពថា តថាគតហៅធម៌ជាគ្រឿងលះកាមច្ឆន្ទៈរបស់បុគ្គលដែលធ្វើបឋមជ្ឈានឲ្យកើតថា អញ្ញាវិមោក្ខ ។ គប្បីប្រកបពាក្យទាំងពួង ដោយប្រការដូច្នេះ ។

[ ១១ ] បទថា **យា ចិត្តស្ស អកល្លតា** បានដល់ ភាពជាចិត្តដែលអាពាធ ។ ព្រោះមនុស្សឈឺ លោកហៅថា **អកល្លកោ** ក្នុងវិន័យលោកក៏ពោលថា **នាហំ អកល្លិកោ** ខ្ញុំមិនឈឺទេ ។ បទថា **អកម្មញ្ញតា** បានដល់ អាការដែលចិត្តមិនសមគួរដល់ការងារ ពោល គឺភាពដែលចិត្តមានជំងឺ ។ បទថា **ឱលីយនា** បានដល់ អាការរួញរា ។ ពិតហើយ ចិត្តដែលញាប់ញ័រមិនអាចទ្រទ្រង់ការញ័រខ្លួនបាន រមែងតោង ដូចសត្វប្រចៀវ តោងត្រង់ដើមឈើ និងដូចថ្នាំងទឹកអំពៅព្យួរត្រង់សសរ លោកពោលថា **ឱលីយនា** សំដៅដល់អាការរបស់ចិត្តនោះ ។ បទទី ២ គឺបទថា **សល្លីយនា** លោកបន្ថែមឧបសគ្គចូលទៅ ។ បទថា **លីនំ** បានដល់ ភាពជាបុគ្គលឱនមុខ មិនស្រស់ស្រាយ ។ម្យ៉ាងទៀត ២ បទទៀត សម្តែងភាពជាអាការ ។ បទថា **ថីនំ** សេចក្តីថា តាំងនៅជាដុំ មិនបែកខ្ចាត់ខ្ចាយ ដូចដុំសប្បិ ។ បទថា **ថីយនា** សម្តែងដល់អាការ ភាពជាអ្នកសុបសៅ ។ ឈ្មោះថា **ថីយិតត្តំ** អធិប្បាយថា ជាប់ណែន ព្រោះមិនខ្ចាត់ខ្ចាយ ។

[ ១៣ ] បទថា **ឧបេក្ខាសតិសំសុទ្ធំ** សេចក្តីថា បរិសុទ្ធដោយឧបេក្ខា និងសតិក្នុងចតុត្ថជ្ឈាន ។ ព្រះមានព្រះភាគត្រាស់ដល់អរហត្តវិមោក្ខ ដែលញ៉ាំងអដ្ឋឈាន ដែលតាំងនៅហើយក្នុងវិមោក្ខ គឺចតុត្ថជ្ឈាននោះ ឲ្យវិសេសហើយ សម្រេចហើយ ដោយបទនេះថា **ធម្មតក្កបុរេជវំ** ។ ការត្រិះរិះប្រកបដោយធម៌ គឺដោយការត្រិះរិះប្រពៃដែលសម្បយុត្តដោយមគ្គ ជាធម៌ស៊ុះទៅខាងមុខនៃអរហត្តវិមោក្ខ ។ ហេតុនោះ ទើបព្រះមានព្រះភាគត្រាស់ថា **ធម្មតក្កបុរេជវំ** ។ បទថា **អវិជ្ជាយ បភេទនំ** បានដល់ ព្រះមានព្រះភាគត្រាស់ថា តថាគតប្រាប់អញ្ញាវិមោក្ខនោះឯងថា ជាគ្រឿងទម្លាយអវិជ្ជា ដោយហេតុ និងឧបចារៈ ព្រោះកើតដោយអាស្រ័យនិព្វាន ដែលជាគ្រឿងទម្លាយអវិជ្ជាឲ្យអស់ទៅ ។

[ ១៤ ] ឈ្មោះថា **ឧបេក្ខា** ព្រោះឃើញដោយការចូលដល់ ក្នុងបទនេះថា **យា ចតុត្ថេ ឈានេ ឧបេក្ខា** អធិប្បាយថា ឃើញប្រពៃ គឺឃើញដោយមិនធ្លាក់ទៅជាចំណែកដទៃ ។ បទថា **ឧបេក្ខនា** ជាពាក្យសម្តែងដល់អាការ ។ បទថា **អជ្ឈុបេក្ខនា** ជាបទបន្ថែមឧបសគ្គចូលមក ។ បទថា **ចិត្តសមថោ** បានដល់ ភាពដែលចិត្តមានអារម្មណ៍ ១ ។ បទថា **ចិត្តប្បស្សទ្ធតា** បានដល់ ភាពដែលចិត្តវៀរចាកការខ្វះ ការលើស និងភាពទទេ ។ បទថា **មជ្ឈត្តតា** បានដល់ ភាពដែលចិត្តតាំងនៅត្រង់កណ្តាល ។

[ ១៨ ] ឧទយមាណព កាលស្តាប់ដល់និព្វាន ដែលព្រះមានព្រះភាគត្រាស់ហើយ ដោយព្រះតម្រាស់ជាគ្រឿងទម្លាយអវិជ្ជាយ៉ាងនេះហើយ កាល

នឹងទូលសួរថា ព្រះអង្គត្រាស់ថា និព្វាន ព្រោះលះអ្វីបាន ទើបពោលគាថាថា **កឹ សុ សញ្ញោជនោ** ដូច្នេះជាដើម ។ បណ្តាបទទាំងនោះ បទថា **កឹ សុ សញ្ញោជនោ** បានដល់ មានអ្វីជាគ្រឿងប្រកបទាញ ។ បទ **វិចារណំ** បានដល់ ហេតុជាគ្រឿងត្រាច់ទៅ ។ បទថា **កិស្សស្ស វិប្បហានេន** បានដល់ ព្រោះលះនូវធម៌អ្វី ។

[ ២២ ] លំដាប់នោះ ព្រះមានព្រះភាគ កាលទ្រង់ព្យាករសេចក្តីនោះដល់ឧទយមាណព ទើបត្រាស់ព្រះគាថាថា **នន្ទិសញ្ញោជនោ** ដូច្នេះជាដើម ។

ក្នុងបទទាំងនោះ បទថា **វិតក្កស្ស** បានដល់ វិតក្ក មានកាមវិតក្កជាដើម ជាទីត្រាច់ទៅរបស់លោកនោះ ។

[ ២៦ ] ឥឡូវនេះ ឧទយមាណពកាលនឹងទូលសួរផ្លូវនៃនិព្វាននោះ ទើបពោលគាថាថា **កថំ សតស្ស** ដូច្នេះជាដើម ។

ក្នុងបទទាំងនោះ បទថា **វិញ្ញាណំ** បានដល់ វិញ្ញាណដែលជាអភិសង្ខារ ។

[ ៣១ ] លំដាប់នោះ ព្រះមានព្រះភាគ កាលទ្រង់ប្រាប់ផ្លូវដល់ឧទយមាណពនោះ ទើបត្រាស់គាថាថា **អជ្ឈត្តញ្ច** ដូច្នេះជាដើម ។ ក្នុងបទទាំងនោះ បទថា **ឯវំ សតស្ស** បានដល់ មានសតិសម្បជញ្ញៈ ដឹងយ៉ាង

នេះ ។ បទដ៏សេសក្នុងទីទាំងពួង ជាក់ច្បាស់ល្អហើយ ។

ព្រះមានព្រះភាគ ទ្រង់សម្តែងព្រះសូត្រនេះ ដោយធម៌ដ៏កំពូល គឺអរហត្ត ដោយប្រការដូច្នេះ ។ កាលចប់ទេសនា មានបុគ្គលសម្រេចធម៌ដូចគ្នានឹងសូត្រមុននោះឯង ។l៚

**អដ្ឋកថា ឧទយមាណវសុត្តនិទ្ទេសទី ១៣ ចប់**

# សុត្តន្តបិដក

## ធោតកមាណវកប្បញ្ហានិទ្ទេស

[ ៣៥ ] ( ឬធោតកៈមានអាយុ ក្រាបទូលដូច្នេះថា ) ព្រះមាន ព្រះភាគអង្គណា ពោលអាងកាលជាអតីត មិនមានសេចក្តីញាប់ញ័រ ទ្រង់កាត់សេចក្តីសង្ស័យ ទ្រង់ដល់ត្រើយនៃធម៌ទាំងពួងហើយ ពួកខ្ញុំព្រះអង្គ ជាអ្នកត្រូវការដោយប្រស្នា ទើបមកកាល់ ( ដើម្បីទូលសួរព្រះមានព្រះភាគនោះ ) ។

[ ៣៦ ] អធិប្បាយពាក្យថា ព្រះមានព្រះភាគអង្គណា ពោលអាងកាលជាអតីត ត្រង់ពាក្យថា អង្គណា សំដៅដល់ព្រះមានព្រះភាគ ព្រះអង្គត្រាស់ដឹងឯង ឥតមានអាចារ្យ បានត្រាស់ដឹងសច្ចៈទាំងឡាយ ដោយព្រះអង្គឯងក្នុងធម៌ ដែលព្រះអង្គមិនធ្លាប់បានស្តាប់មកក្នុងកាលមុន ទ្រង់សម្រេចសព្វញ្ញុតញ្ញាណ ក្នុងធម៌ទាំងឡាយនោះផង សម្រេចនូវភាពស្ទាត់ ក្នុងពលធម៌ទាំងឡាយផង ។ ពាក្យថា ទ្រង់ពោលអាងកាលជាអតីត បានដល់ ព្រះមានព្រះភាគ ទ្រង់ពោលអាងកាលជាអតីតផង ទ្រង់ពោលអាងកាលជាអនាគតផង ទ្រង់ពោលអាងកាលជាបច្ចុប្បន្នផង របស់ព្រះអង្គ និងពួកសត្វដទៃ ។

ព្រះមានព្រះភាគ ទ្រង់ពោលអាងកាលជាអតីត របស់ព្រះអង្គ តើដូចម្តេច ។ ព្រះមានព្រះភាគ ទ្រង់ពោលអាងអតីតជាតិរបស់ព្រះអង្គ ១ ជាតិខ្លះ ទ្រង់ពោលអាង ២ ជាតិខ្លះ ទ្រង់ពោលអាង ៣ ជាតិខ្លះ ទ្រង់ពោលអាង ៤ ជាតិខ្លះ ទ្រង់ពោលអាង ៥ ជាតិខ្លះ ទ្រង់ពោលអាង ១០ ជាតិខ្លះ ទ្រង់ពោលអាង ២០ ជាតិខ្លះ ទ្រង់ពោលអាង ៣០ ជាតិខ្លះ ទ្រង់ពោលអាង ៤០ ជាតិខ្លះ

ទ្រង់ពោលអាង ៥០ ជាតិខ្លះ ទ្រង់ពោលអាងមួយរយជាតិខ្លះ មួយពាន់ជាតិខ្លះ មួយសែនជាតិខ្លះ សំវដ្តកប្បជាច្រើនខ្លះ វិវដ្តកប្បជាច្រើនខ្លះ សំវដ្តវិវដ្តកប្បជាច្រើនខ្លះថា តថាគតបានកើតក្នុងភពឯណោះ មានទាមយ៉ាងនេះ មានគោត្តយ៉ាងនេះ មានវណ្ណៈយ៉ាងនេះ មានអាហារយ៉ាងនេះ មានសុខ និងទុក្ខយ៉ាងនេះ មានអាយុត្រឹមប៉ុណ្ណេះ លុះតថាគតនោះ ច្យុតចាកអត្តភាពនោះហើយ ក៏បានទៅកើតក្នុងភពឯណោះ ដែលកើតក្នុងភពនោះ ក៏មានទាមយ៉ាងនេះ មានគោត្តយ៉ាងនេះ មានវណ្ណៈយ៉ាងនេះ មានអាហារយ៉ាងនេះ សោយសុខ និងទុក្ខយ៉ាងនេះ មានអាយុត្រឹមប៉ុណ្ណេះ តថាគតនោះ លុះច្យុតចាកអត្តភាពនោះហើយ ក៏បានមកកើតក្នុងភពនេះ ព្រះមានព្រះភាគ ទ្រង់ពោលអាងការនៅអាស្រ័យក្នុងកាលមុន ជាច្រើនប្រការ ព្រមទាំងអាការ ( គឺវណ្ណៈ និងអាហារជាដើម ) ព្រមទាំងឧទ្ទេស ( គឺឈ្មោះ និងគោត្តជាដើម ) ដោយប្រការដូច្នេះ ព្រះមានព្រះភាគ ទ្រង់ពោលអាងកាលជាអតីត របស់ព្រះអង្គយ៉ាងនេះ ។

ព្រះមានព្រះភាគ ទ្រង់ពោលអាងកាលជាអតីត របស់ពួកសត្វដទៃ តើដូចម្តេច ។ ព្រះមានព្រះភាគ ទ្រង់ពោលអាងអតីតជាតិ របស់ពួកសត្វដទៃ ១ ជាតិខ្លះ ទ្រង់ពោលអាង ២ ជាតិខ្លះ ។បេ។ ទ្រង់ពោលអាងសំវដ្តវិវដ្តកប្បដ៏ច្រើនខ្លះ ថា ( សត្វនេះ ) បានកើតក្នុងភពឯណោះ មានទាមយ៉ាងនេះ មានគោត្តយ៉ាងនេះ មានវណ្ណៈយ៉ាងនេះ មានអាហារយ៉ាងនេះ ទទួលសុខទុក្ខយ៉ាងនេះ មានអាយុត្រឹមប៉ុណ្ណេះ សត្វនោះច្យុតចាកអត្តភាពនោះហើយ ក៏បានទៅកើតក្នុងភពឯណោះ ដែលកើតក្នុងភពនោះ មានទាមយ៉ាងនេះ មានគោត្តយ៉ាង

នេះ មានវណ្ណៈយ៉ាងនេះ មានអាហារយ៉ាងនេះ ទទួលសុខទុក្ខយ៉ាងនេះ មានអាយុត្រឹមប៉ុណ្ណេះ សត្វនោះច្យុតចាកអត្តភាពនោះហើយ ក៏បានមកកើតក្នុងភពនេះ ព្រះមានព្រះភាគទ្រង់ពោលអាង ការនៅអាស្រ័យក្នុងកាលមុន ច្រើនប្រការ ព្រមទាំងអាការ ព្រមទាំងឧទ្ទេស ដោយប្រការដូច្នេះ ព្រះមានព្រះភាគទ្រង់ពោលអាងកាលជាអតីត របស់ពួកសត្វដទៃយ៉ាងនេះឯង ។

ព្រះមានព្រះភាគ ទ្រង់សម្តែងជាតកទាំង ៥០០ ឈ្មោះថា ពោលអាងកាលជាអតីតរបស់ព្រះអង្គផង របស់ពួកសត្វដទៃផង ទ្រង់សម្តែងមហាធនិយ-សូត្រ ឈ្មោះថា ពោលអាងកាលជាអតីត របស់ព្រះអង្គផង របស់ពួកសត្វដទៃផង ទ្រង់សម្តែងមហាសុទស្សនសូត្រ ឈ្មោះថា ពោលអាងកាលជាអតីត របស់ព្រះអង្គផង របស់ពួកសត្វដទៃផង ទ្រង់សម្តែងមហាគោវិន្ទសូត្រ ឈ្មោះថា ពោលអាងកាលជាអតីតរបស់ព្រះអង្គផង របស់ពួកសត្វដទៃផង ទ្រង់សម្តែងមឃទេវសូត្រ ឈ្មោះថា ពោលអាងកាលជាអតីត របស់ព្រះអង្គផង របស់ពួកសត្វដទៃផង ។

ដូចព្រះពុទ្ធដីកា ដែលព្រះមានព្រះភាគត្រាស់ដូច្នេះថា ម្នាលចុន្ទ ញាណជាគ្រឿងរឭកតាម នូវស្មារតីនៃព្រះតថាគត ប្រារព្ធកាលជាអតីតរមែងមានព្រះតថាគតនោះ ប្រាថ្នាត្រឹមណា រឭកឃើញបានត្រឹមនោះ ម្នាលចុន្ទ ញាណជាគ្រឿងរឭកតាម នូវស្មារតីនៃព្រះតថាគត ប្រារព្ធនូវកាលជាអនាគត ។បេ។ ម្នាលចុន្ទ ញាណដែលកើតអំពីពោធិនៃព្រះតថាគត ប្រារព្ធកាលជាបច្ចុប្បន្នរមែងកើតឡើងថា ជាតិនេះ មានក្នុងទីបំផុត ការកើតទៀត ក្នុងកាលឥឡូវ

នេះ មិនមាន ។ ឥន្ទ្រិយបរោបរិយត្តញ្ញាណ ជាតថាគតពលរបស់ព្រះតថាគត សត្តានំអាសយានុសយញ្ញាណ ជាតថាគតពលរបស់ព្រះតថាគត យមកប្បាដិហីរិយញ្ញាណ ជាតថាគតពលរបស់ព្រះតថាគត មហាករុណាសមាបត្តិញ្ញាណ ជាតថាគតពលរបស់ព្រះតថាគត សព្វញ្ញុតញ្ញាណ ជាតថាគតពលរបស់ព្រះតថាគត អនាវរណញ្ញាណ ជាតថាគតពលរបស់ព្រះតថាគត សព្វត្ថអសង្គមប្បដិហតមនាវរណញ្ញាណ ជាតថាគតពលរបស់ព្រះតថាគត ។ ព្រះមានព្រះភាគ ទ្រង់ពោលអាងជាតិជាអតីតផង ពោលអាងជាតិជាអនាគតផង ទ្រង់ពោលអាង ប្រាប់ សម្តែង ប្រញ្ញត្ត តាំងផ្តើម បើក វែកញែក ធ្វើឲ្យរាក់ ប្រកាស នូវជាតិជាបច្ចុប្បន្នរបស់ព្រះអង្គផង របស់ពួកសត្វដទៃផង យ៉ាងនេះ ហេតុនោះ ( លោកពោលថា ) ព្រះមានព្រះភាគអង្គណា ពោលអាងកាលជាអតីត ។ ពាក្យថា ដូច្នេះ ក្នុងបទថា បោសាលៈមានអាយុពោលដូច្នេះ ជាការតបទ ។ ពាក្យថា មានអាយុ គឺពាក្យជាទីស្រឡាញ់ ពាក្យថា បោសាលៈ ជាឈ្មោះ ។បេ។ ជាពាក្យហៅព្រាហ្មណ៍នោះ ហេតុនោះ ( ទើបមានពាក្យថា ) បោសាលៈមានអាយុពោល ដូច្នេះ ។

[ ៣៧ ] ពាក្យថា មិនមានសេចក្តីញាប់ញ័រ ទ្រង់កាត់សេចក្តីសង្ស័យ សេចក្តីថា តណ្ហា លោកហៅថា សេចក្តីញាប់ញ័រ បានខាងតម្រេក តម្រេកខ្លាំង ។បេ។ អភិជ្ឈា លោភៈ អកុសលមូល ។ សេចក្តីញាប់ញ័រ គឺតណ្ហានោះ ព្រះពុទ្ធមានជោគទ្រង់លះបង់ ផ្តាច់ផ្តិលឫសគល់ ធ្វើឲ្យសល់តែទីនៅដូចជាទីនៅនៃដើមត្នោត ឲ្យដល់នូវការមិនមានបែបភាព មិនឲ្យមានការកើត

តទៅជាធម្មតា ហេតុនោះ ព្រះពុទ្ធ ឈ្មោះថា មិនមានសេចក្តីញាប់ញ័រ ។ ព្រោះទ្រង់លះសេចក្តី ញាប់ញ័រ ទើបឈ្មោះថា មិនមានសេចក្តីញាប់ញ័រ ។ ព្រះមានព្រះភាគ មិនញាប់ញ័រក្នុងលាភផង មិនញាប់ញ័រក្នុងអលាភផង មិនញាប់ញ័រក្នុងយសផង មិនញាប់ញ័រក្នុងអយសផង មិនញាប់ញ័រក្នុងសេចក្តីសរសើរផង មិនញាប់ញ័រក្នុងនិន្ទាផង មិនញាប់ញ័រក្នុងសុខផង មិនញាប់ញ័រ មិនកម្រើក មិនរន្ធត់ មិនកក្រើក មិនកក្រើកព្រមក្នុងទុក្ខផង ហេតុនោះ ទើបឈ្មោះថា មិនមានសេចក្តីញាប់ញ័រ ។ ពាក្យថា ទ្រង់កាត់សេចក្តីសង្ស័យ សេចក្តីថា វិចិកិច្ឆា លោកហៅថា សេចក្តីសង្ស័យ គឺសេចក្តីសង្ស័យក្នុងទុក្ខ ។បេ។ សេចក្តីញាប់ញ័រនៃចិត្ត សេចក្តីរសេមរសាមនៃចិត្ត ។ សេចក្តីសង្ស័យនោះ ព្រះពុទ្ធមានជោគ ទ្រង់កាត់ផ្តាច់ ផ្តិលផ្តាច់ រម្ងាប់ ស្ងប់រម្ងាប់ ធ្វើមិនគួរឲ្យកើតឡើងបាន ដុតដោយភ្លើង គឺញាណហើយ ហេតុនោះ ព្រះពុទ្ធ ឈ្មោះថា កាត់សេចក្តីសង្ស័យ ហេតុនោះ ( លោកពោលថា ) មិនមានសេចក្តីញាប់ញ័រ ទ្រង់កាត់សេចក្តីសង្ស័យ ។

[ ៣៨ ] ពាក្យថា ទ្រង់ដល់ត្រើយនៃធម៌ទាំងពួង គឺព្រះមានព្រះភាគ ទ្រង់ដល់ត្រើយនៃការត្រាស់ដឹង ដល់ត្រើយនៃការកំណត់ដឹង ដល់ត្រើយនៃការលះបង់ ដល់ត្រើយនៃការចម្រើន ដល់ត្រើយនៃការធ្វើឲ្យជាក់ច្បាស់ ដល់ត្រើយនៃសមាបត្តិនៃធម៌ទាំងពួង គឺថា ទ្រង់ដល់ត្រើយនៃការត្រាស់ដឹងនូវធម៌ទាំងពួង ។បេ។ ភពថ្មី គឺជាតិ ជរា មរណៈ សង្សារ នៃព្រះមានព្រះភាគនោះ មិនមាន ហេតុនោះ ( លោកពោលថា ) ទ្រង់ដល់ត្រើយនៃធម៌

ទាំងពួង ។

[ ៣៩ ] ពាក្យថា ពួកខ្ញុំព្រះអង្គ ជាអ្នកត្រូវការដោយប្រស្នា ទើបមកគាល់ គឺពួកខ្ញុំព្រះអង្គ ត្រូវការដោយប្រស្នាទើបមក ។បេ។ ដើម្បីបំភ្លឺ ដើម្បីសម្តែង ហេតុនោះ ( លោកពោលថា ) ពួកខ្ញុំព្រះអង្គ ជាអ្នកត្រូវការដោយប្រស្នា ទើបមកគាល់យ៉ាងនេះក៏បាន ។ ហេតុនោះ ព្រាហ្មណ៍នោះពោលថា

( បោសាលៈមានអាយុក្រាបទូលដូច្នេះថា ) ព្រះមានព្រះភាគអង្គណា ពោលអាងកាលជាអតីត មិនមានសេចក្តីញាប់ញ័រ ទ្រង់កាត់សេចក្តីសង្ស័យ ទ្រង់ដល់ត្រើយនៃធម៌ទាំងពួង ពួកខ្ញុំព្រះអង្គជាអ្នកត្រូវការដោយប្រស្នា ទើបមកគាល់ ( ដើម្បីទូលសួរព្រះមានព្រះភាគនោះ ) ។

[ ៤០ ] បពិត្រព្រះអង្គជាសក្យពង្ស ខ្ញុំព្រះអង្គសូមទូលសួរអំពីញាណ របស់បុគ្គលអ្នកមានរូបសញ្ញាជាក់ច្បាស់ អ្នកលះបង់រូបារម្មណ៍ទាំងអស់ អ្នកឃើញទាំងខាងក្នុង ទាំងខាងក្រៅថា វត្ថុបន្តិចបន្តួចមិនមាន បុគ្គលមានសភាពដូច្នោះ តើព្រះអង្គជ្រាបដោយប្រការដូចម្តេច ។

[ ៤១ ] ពាក្យថា អ្នកមានរូបសញ្ញាជាក់ច្បាស់ មានសំណួរថា រូបសញ្ញា តើដូចម្តេច ។ សេចក្តីសម្គាល់ អាការនៃសេចក្តីសម្គាល់ ភាពនៃសេចក្តីសម្គាល់ របស់បុគ្គលអ្នកចូលកាន់រូបាវចរសមាបត្តិក្តី អ្នកញុំាងរូបាវចរសមាបត្តិឲ្យកើតក្តី អ្នកមានឈានសុខ ជាគ្រឿងនៅក្នុងបច្ចុប្បន្នក្តី នេះ ឈ្មោះ

ថា រូបសញ្ញា ។ ពាក្យថា អ្នកមានរូបសញ្ញាជាក់ច្បាស់ បានន័យថា បុគ្គល អ្នកបានអរូបសមាបត្តិទាំង ៤ ហើយ រមែងមានរូបសញ្ញា ( ការសម្គាល់ រូប ) ប្រាកដ ធ្វើឲ្យជាក់ច្បាស់ កន្លង រំលង ប្រព្រឹត្តកន្លង ហេតុនោះ ( លោក ពោលថា ) អ្នកមានរូបសញ្ញាជាក់ច្បាស់ ។

[ ៤២ ] ពាក្យថា អ្នកលះរូបារម្មណ៍ទាំងអស់ សេចក្តីថា រូបកាយ ប្រកបដោយបដិសន្ធិទាំងអស់ បុគ្គលនោះលះបង់ហើយ គឺថា រូបកាយ បុគ្គលនោះលះបង់ហើយ ដោយវិក្ខម្ភនប្បហាន ដែលប្រព្រឹត្តកន្លងនូវតទង្គ-ប្បហាន ហេតុនោះ ( លោកពោលថា ) អ្នកលះរូបារម្មណ៍ទាំងអស់ ។

[ ៤៣ ] ពាក្យថា អ្នកឃើញទាំងខាងក្នុង ទាំងខាងក្រៅថា វត្ថុបន្តិច បន្តួចមិនមាន ត្រង់ពាក្យថា វត្ថុបន្តិចបន្តួចមិនមាន បានដល់ អាកិញ្ចញ្ញា-យតនសមាបត្តិ ។ អាកិញ្ចញ្ញាយតនសមាបត្តិ ដោយបរិកម្មថា វត្ថុបន្តិចបន្តួច មិនមាន តើព្រោះហេតុអ្វី ។ បុគ្គលមានស្មារតី ចូលវិញ្ញាណញ្ចាយតន-សមាបត្តិ លុះចេញចាកសមាបត្តិនោះហើយ ក៏ធ្វើវិញ្ញាណនោះឯងឲ្យវិនាស បាត់បង់ សាបសូន្យទៅវិញ ឈ្មោះថា ឃើញថា វត្ថុបន្តិចបន្តួចមិនមាន ។ អាកិញ្ចញ្ញាយតនសមាបត្តិ ដោយបរិកម្មថា វត្ថុបន្តិចបន្តួចមិនមាន ព្រោះ ហេតុនោះឯង ហេតុនោះ ( លោកពោលថា ) អ្នកឃើញទាំងខាងក្នុង ទាំង ខាងក្រៅថា វត្ថុបន្តិចបន្តួចមិនមាន ។

[ ៤៤ ] ពាក្យថា សក្យពង្ស ក្នុងបទថា បពិត្រព្រះអង្គជាសក្យពង្ស ខ្ញុំព្រះអង្គសូមទូលសួរអំពីញាណ គឺព្រះមានព្រះភាគ ឈ្មោះថា សក្យពង្ស ។

ដែលព្រះមានព្រះភាគ ឈ្មោះសក្យៈ ព្រោះទ្រង់ចេញចាកសក្យត្រកូលហើយ បួសក៏បាន ។បេ។ ឈ្មោះសក្យៈ ព្រោះព្រះអង្គលះបង់ភ័យ និងសេចក្ដីតក់ស្លុត ប្រាសចាកការព្រឺរោមក៏បាន ។ ពាក្យថា បពិត្រព្រះអង្គជាសក្យពង្ស ខ្ញុំព្រះអង្គសូមទូលសួរអំពីញាណ បានន័យថា ខ្ញុំព្រះអង្គសូមទូលសួរញាណរបស់បុគ្គលនោះថា ប្រាកដដូចម្ដេច មានទ្រង់ទ្រាយដូចម្ដេច មានប្រការដូចម្ដេច មានចំណែកប្រៀបដូចម្ដេច ដែលបុគ្គលគប្បីប្រាថ្នា ហេតុនោះ ( លោកពោលថា ) បពិត្រព្រះអង្គជាសក្យពង្ស ខ្ញុំព្រះអង្គសូមទូលសួរអំពីញាណ ។

[ ៤៥ ] ពាក្យថា បុគ្គលមានសភាពដូច្នោះ តើព្រះអង្គជ្រាបដោយប្រការដូចម្ដេច សេចក្ដីថា បុគ្គលនោះ តើព្រះអង្គជ្រាប ជ្រាបសព្វ ជ្រាបច្បាស់ យល់ច្បាស់ ពិនិត្យច្បាស់ សម្លឹង ជ្រះថ្លា ដោយប្រការដូចម្ដេច គឺថា ញាណដ៏ក្រៃលែងរបស់បុគ្គលនោះ ព្រះអង្គគប្បីឲ្យកើតឡើងដូចម្ដេច ។ ពាក្យថា មានសភាពដូច្នោះ គឺមានប្រការដូច្នោះ ប្រាកដដូច្នោះ មានទ្រង់ទ្រាយដូច្នោះ មានសភាពដូច្នោះ មានចំណែកប្រៀបដូច្នោះ បានដល់ បុគ្គលអ្នកបានអាកិញ្ចញ្ញាយតនសមាបត្តិ ហេតុនោះ ( លោកពោលថា ) បុគ្គលមានសភាពដូច្នោះ តើព្រះអង្គជ្រាបដោយប្រការដូចម្ដេច ហេតុនោះ ព្រាហ្មណ៍នោះពោលថា

បពិត្រព្រះអង្គជាសក្យពង្ស ខ្ញុំព្រះអង្គ សូមទូលសួរអំពីញាណ
របស់បុគ្គល អ្នកមានរូបសញ្ញាជាក់ច្បាស់ អ្នកលះបង់រូបារម្មណ៍

ទាំងអស់ អ្នកឃើញទាំងខាងក្នុង ទាំងខាងក្រៅថា វត្ថុបន្តិចបន្តួចមិនមាន បុគ្គលមានសភាពដូច្នោះ តើព្រះអង្គជ្រាបដោយប្រការដូចម្តេច ។

[ ៤៦ ] ( ព្រះមានព្រះភាគត្រាស់ថា ម្នាលបោសាលៈ ) ព្រះតថាគតទ្រង់ជ្រាបច្បាស់ នូវវិញ្ញាណដ្ឋិតិទាំងពួង ទើបទ្រង់ជ្រាបនូវបុគ្គលនោះ ដែលកំពុងរស់នៅ មានចិត្តផប់ ( ក្នុងអាកិញ្ចញ្ញាយតនៈ ) មានអាកិញ្ចញ្ញាយតនៈនោះ ប្រព្រឹត្តទៅខាងមុខ ។

[ ៤៧ ] ពាក្យថា វិញ្ញាណដ្ឋិតិទាំងពួង អធិប្បាយថា ព្រះមានព្រះភាគទ្រង់ជ្រាបវិញ្ញាណដ្ឋិតិ ៤ ដោយអំណាចអភិសង្ខារ ទ្រង់ជ្រាបវិញ្ញាណដ្ឋិតិ ៧ ដោយអំណាចបដិសន្ធិ ។ ព្រះមានព្រះភាគ ទ្រង់ជ្រាបវិញ្ញាណដ្ឋិតិ ៤ ដោយអំណាចអភិសង្ខារ តើដូចម្តេច ។ ព្រះពុទ្ធដីកា ដែលព្រះមានព្រះភាគត្រាស់ដូច្នេះថា ម្នាលភិក្ខុទាំងឡាយ វិញ្ញាណអាស្រ័យរូបខ្ទះ ហើយស្ថិតនៅ រមែងស្ថិតនៅ មានរូបជាអារម្មណ៍ មានរូបជាទីតម្កល់ មានសេចក្តីត្រេកអរ ជាគ្រឿងសេព រមែងដល់នូវសេចក្តីចម្រើន សេចក្តីលូតលាស់ សេចក្តីទូលំទូលាយ ម្នាលភិក្ខុទាំងឡាយ ( វិញ្ញាណ ) អាស្រ័យវេទនាខ្ទះ ។បេ។ ម្នាលភិក្ខុទាំងឡាយ ( វិញ្ញាណ ) អាស្រ័យសញ្ញាខ្ទះ ។បេ។ ម្នាលភិក្ខុទាំងឡាយ វិញ្ញាណអាស្រ័យសង្ខារខ្ទះ ហើយស្ថិតនៅ រមែងស្ថិតនៅ មានសង្ខារជាអារម្មណ៍ មានសង្ខារជាទីតម្កល់ មានសេចក្តីត្រេកអរជាគ្រឿងសេព ដល់នូវសេចក្តីចម្រើន សេចក្តីលូតលាស់ សេចក្តីទូលំទូលាយ ។ ព្រះមានព្រះភាគ

ទ្រង់ជ្រាបវិញ្ញាណដ្ឋិតិ ៤ ដោយអំណាចអភិសង្ខារយ៉ាងនេះ ។ ព្រះមានព្រះភាគ ទ្រង់ជ្រាបវិញ្ញាណដ្ឋិតិ ៧ ដោយអំណាចបដិសន្ធិ តើដូចម្តេច ។ ព្រះមានព្រះភាគ ត្រាស់ព្រះពុទ្ធដីកានេះថា ម្នាលភិក្ខុទាំងឡាយ មានពួកសត្វមានកាយផ្សេងគ្នា មានសញ្ញាផ្សេងគ្នា ដូចពួកមនុស្ស និងទេវតាពួកខ្លះ វិនិបាតិកៈពួកខ្លះ នេះវិញ្ញាណដ្ឋិតិទី ១ ម្នាលភិក្ខុទាំងឡាយ មានពួកសត្វមានកាយផ្សេងគ្នា មានសញ្ញាដូចគ្នា ដូចទេវតាប្រព្រឹត្តទៅក្នុងពួកព្រហ្ម កើតដោយបឋមជ្ឈាន នេះវិញ្ញាណដ្ឋិតិទី ២ ម្នាលភិក្ខុទាំងឡាយ មានពួកសត្វមានកាយដូចគ្នា មានសញ្ញាផ្សេងគ្នា ដូចពួកទេវតាជាន់អាភស្សរៈ នេះវិញ្ញាណដ្ឋិតិទី ៣ ម្នាលភិក្ខុទាំងឡាយ មានពួកសត្វ មានកាយដូចគ្នា មានសញ្ញាដូចគ្នា ដូចពួកទេវតាជាន់សុភកិណ្ហកៈ នេះវិញ្ញាណដ្ឋិតិទី ៤ ម្នាលភិក្ខុទាំងឡាយ មានពួកសត្វ ព្រោះប្រព្រឹត្តកន្លងរូបសញ្ញា ដោយប្រការទាំងពួង ដល់នូវការវិនាសនៃបដិឃសញ្ញា មិនធ្វើទុកក្នុងចិត្តនូវនានត្តសញ្ញា ចូលអាកាសានញ្ចាយតនៈ ដោយបរិកម្មថា អាកាសមិនមានទីបំផុត នេះវិញ្ញាណដ្ឋិតិទី ៥ ( ពួកសត្វ ) ប្រព្រឹត្តកន្លងអាកិញ្ចញ្ញាយតនៈ ដោយប្រការទាំងពួង ចូលវិញ្ញាណញ្ចាយតនៈ ដោយបរិកម្មថា វិញ្ញាណមិនមានទីបំផុត នេះវិញ្ញាណដ្ឋិតិទី ៦ ពួកសត្វប្រព្រឹត្តកន្លងវិញ្ញាណញ្ចាយតនៈ ដោយប្រការទាំងពួង ចូលអាកិញ្ចញ្ញាយតនៈ ដោយបរិកម្មថា របស់តិចតួចមិនមាន នេះវិញ្ញាណដ្ឋិតិទី ៧ ។ ព្រះមានព្រះភាគ ទ្រង់ជ្រាបវិញ្ញាណដ្ឋិតិ ៧ ដោយអំណាចបដិសន្ធិយ៉ាងនេះ ហេតុនោះ ( ទ្រង់ត្រាស់ថា ) វិញ្ញាណដ្ឋិតិទាំងពួង ។ ពាក្យ

ថា បោសាលៈ ក្នុងបទថា ព្រះមានព្រះភាគត្រាស់ថា ម្នាលបោសាលៈ គឺ ព្រះមានព្រះភាគ ត្រាស់ហៅព្រាហ្មណ៍នោះតាមឈ្មោះ ។ ពាក្យថា ព្រះមាន ព្រះភាគនុ៎ះ ជាពាក្យនិយាយដោយគោរព ។បេ។ បញ្ញត្តថា ព្រះមានព្រះភាគ នេះ កើតព្រោះការត្រាស់ដឹង ហេតុនោះ ( ទើបមានពាក្យថា ) ព្រះមាន ព្រះភាគទ្រង់ត្រាស់ថា ម្នាលបោសាលៈ ។

[ ៤៨ ] អធិប្បាយពាក្យថា ព្រះតថាគតទ្រង់ជ្រាបច្បាស់ ត្រង់ពាក្យ ថា ជ្រាបច្បាស់ គឺយល់ច្បាស់ ដឹងប្រាកដ ចាក់ធ្លុះ ។ ពាក្យថា ព្រះតថាគត មានន័យដូចតទៅនេះ មែនពិត ព្រះមានព្រះភាគ ទ្រង់ត្រាស់ពាក្យនេះថា ម្នាល ចុន្ទ បើពាក្យអតីតជាពាក្យមិនពិត មិនទៀង មិនប្រកបដោយប្រយោជន៍ ព្រះ តថាគតមិនពោលពាក្យនោះ ម្នាលចុន្ទ បើពាក្យអតីតជាពាក្យពិត ទៀងត្រង់ តែមិនប្រកបដោយប្រយោជន៍ ព្រះតថាគតក៏មិនពោលពាក្យនោះ ម្នាលចុន្ទ បើពាក្យអតីតជាពាក្យពិត ទៀងត្រង់ ប្រកបដោយប្រយោជន៍ ព្រះតថាគតជា អ្នកដឹងកាលគួរ ទើបព្យាករប្រស្នានោះក្នុងពាក្យនោះ ម្នាលចុន្ទ បើពាក្យ អនាគត ។បេ។ ម្នាលចុន្ទ បើពាក្យបច្ចុប្បន្នជាពាក្យមិនពិត មិនទៀងត្រង់ មិនប្រកបដោយប្រយោជន៍ ព្រះតថាគតមិនពោលពាក្យនោះ ម្នាលចុន្ទ បើ ពាក្យបច្ចុប្បន្នជាពាក្យពិត ទៀងត្រង់ តែមិនប្រកបដោយប្រយោជន៍ ព្រះតថាគត ក៏មិនពោលពាក្យនោះ ម្នាលចុន្ទ បើពាក្យបច្ចុប្បន្នជាពាក្យពិត ទៀងត្រង់ ប្រកបដោយប្រយោជន៍ ព្រះតថាគតជាអ្នកដឹងកាលគួរ ទើបព្យាករប្រស្នានោះ ក្នុងពាក្យនោះ ម្នាលចុន្ទ ព្រះតថាគតជាអ្នកពោលតាមកាល ពោលពាក្យពិត

ពោលអត្ថ ពោលធម៌ ពោលវិន័យ ក្នុងធម៌ទាំងឡាយជាអតីត អនាគត បច្ចុប្បន្ន ដោយប្រការដូច្នេះឯង ហេតុនោះ ទើបហៅថាព្រះតថាគត ។ ម្នាល ចុន្ទ ធម្មជាតណាដែលលោក ព្រមទាំងទេវលោក មារលោក ព្រហ្មលោក ទាំងពួកសត្វ ព្រមទាំងសមណៈ និងព្រាហ្មណ៍ មនុស្សជាសម្មតិទេព និង មនុស្សដ៏សេស ឃើញ ឮ ប៉ះពាល់ ដឹងច្បាស់ សម្រេច ស្វែងរក ពិចា-រណា ធម្មជាតទាំងអស់នោះ ព្រះតថាគតត្រាស់ដឹងហើយដោយចិត្ត ហេតុ នោះ ទើបហៅថា ព្រះតថាគត ។ ម្នាលចុន្ទ ព្រះតថាគតត្រាស់ដឹងសម្មា-សម្ពោធិញ្ញាណដ៏ក្រៃលែង ក្នុងរាត្រីណា បរិនិព្វានដោយអនុបាទិសេសនិព្វាន-ធាតុ ក្នុងរាត្រីណា រមែងពោលចរចា សម្តែងនូវពាក្យណា ក្នុងចន្លោះនៃ ការត្រាស់ដឹង និងការបរិនិព្វាននោះ របស់ទាំងអស់នោះនៅដូចដែល មិន ប្រែប្រួលទេ ហេតុនោះ ទើបហៅថាព្រះតថាគត ។ ម្នាលចុន្ទ ព្រះតថាគត ពោលយ៉ាងណា ធ្វើយ៉ាងនោះ ធ្វើយ៉ាងណា ពោលយ៉ាងនោះ ព្រោះហេតុ តែព្រះតថាគតពោលយ៉ាងណា ធ្វើយ៉ាងនោះ ធ្វើយ៉ាងណា ពោលយ៉ាងនោះ ហេតុនោះ ទើបហៅថា ព្រះតថាគត ។ ម្នាលចុន្ទ ព្រះតថាគតគ្របសង្កត់ នូវលោក ព្រមទាំងទេវលោក មារលោក ព្រហ្មលោក នូវពួកសត្វ ព្រម ទាំងសមណៈ និងព្រាហ្មណ៍ មនុស្សជាសម្មតិទេព និងមនុស្សដ៏សេស មិន មានអ្នកណាគ្របសង្កត់បាន តែងឃើញពិត ញុំាងអំណាចឲ្យប្រព្រឹត្តទៅ ហេតុនោះ ទើបហៅថា ព្រះតថាគត ហេតុនោះ ( ទ្រង់ត្រាស់ថា ) ព្រះ តថាគតទ្រង់ជ្រាបច្បាស់ ។

[ ៤៩ ] ពាក្យថា ទើបទ្រង់ជ្រាបនូវបុគ្គលនោះ ដែលកំពុងរស់នៅ អធិប្បាយថា ព្រះមានព្រះភាគទ្រង់ជ្រាបនូវបុគ្គលដែលស្ថិតនៅក្នុងទីនេះឯង ដោយអំណាចកម្មាភិសង្ខារថា បុគ្គលនេះ លុះបែកធ្លាយរាងកាយស្លាប់ទៅ នឹងទៅកើតក្នុងអបាយ ទុគ្គតិ វិនិបាត នរក ។ ព្រះមានព្រះភាគទ្រង់ជ្រាបនូវបុគ្គលដែលស្ថិតនៅក្នុងទីនេះឯង ដោយអំណាចកម្មាភិសង្ខារថា បុគ្គលនេះ លុះបែកធ្លាយរាងកាយស្លាប់ទៅ នឹងទៅកើតក្នុងកំណើតតិរច្ឆាន ។ ព្រះមានព្រះភាគទ្រង់ជ្រាបនូវបុគ្គលដែលស្ថិតនៅក្នុងទីនេះឯង ដោយអំណាចកម្មាភិ-សង្ខារថា បុគ្គលនេះ លុះបែកធ្លាយរាងកាយស្លាប់ទៅ នឹងទៅកើតក្នុងបិត្តិ-វិស័យ ។ ព្រះមានព្រះភាគទ្រង់ជ្រាបនូវបុគ្គលដែលស្ថិតនៅក្នុងទីនេះឯង ដោយអំណាចកម្មាភិសង្ខារថា បុគ្គលនេះ លុះបែកធ្លាយរាងកាយស្លាប់ទៅ នឹងទៅកើតក្នុងពួកមនុស្ស ។ ព្រះមានព្រះភាគទ្រង់ជ្រាបនូវបុគ្គលដែលស្ថិតនៅក្នុងទីនេះឯង ដោយអំណាចកម្មាភិសង្ខារថា បុគ្គលនេះ លុះបែកធ្លាយរាងកាយស្លាប់ទៅ នឹងទៅកើតក្នុងសុគតិសួគ៌ទេវលោក ។ ដូចពាក្យដែលព្រះមានព្រះភាគទ្រង់ត្រាស់ដូច្នេះថា ម្នាលសារីបុត្ត តថាគតកំណត់ដឹងចិត្ត របស់បុគ្គលពួកខ្លះ ក្នុងលោកនេះ ដោយចិត្ត យ៉ាងនេះថា បុគ្គលនេះ ប្រតិបត្តិដូច្នោះ ប្រព្រឹត្តដូច្នោះ ឡើងកាន់ផ្លូវនោះ លុះបែកធ្លាយរាងកាយស្លាប់ទៅ នឹងទៅកើតក្នុងអបាយ ទុគ្គតិ វិនិបាត នរក ។ ម្នាលសារីបុត្ត តថាគតកំណត់ដឹងចិត្តរបស់បុគ្គលពួកខ្លះ ក្នុងលោកនេះ ដោយចិត្ត យ៉ាងនេះថា បុគ្គលនេះប្រតិបត្តិដូច្នោះ ប្រព្រឹត្តដូច្នោះ ឡើងកាន់ផ្លូវនោះ លុះបែកធ្លាយ

រាងកាយស្លាប់ទៅ នឹងទៅកើតក្នុងកំណើតតិរច្ឆាន ។ ម្នាលសារីបុត្ត តថាគត កំណត់ដឹងចិត្តរបស់បុគ្គលពួកខ្លះ ក្នុងលោកនេះ ដោយចិត្ត យ៉ាងនេះថា បុគ្គលនេះប្រតិបត្តិដូច្នោះ ប្រព្រឹត្តដូច្នោះ ឡើងកាន់ផ្លូវនោះ លុះបែកធ្លាយរាងកាយស្លាប់ទៅ នឹងទៅកើតក្នុងបិត្តិវិស័យ ។ ម្នាលសារីបុត្ត តថាគត កំណត់ដឹងចិត្តរបស់បុគ្គលពួកខ្លះ ក្នុងលោកនេះ ដោយចិត្ត យ៉ាងនេះថា បុគ្គលនោះ ប្រតិបត្តិដូច្នោះ ប្រព្រឹត្តដូច្នោះ ឡើងកាន់ផ្លូវនោះ លុះបែកធ្លាយរាងកាយស្លាប់ទៅ នឹងទៅកើតក្នុងពួកមនុស្ស ។ ម្នាលសារីបុត្ត តថាគត កំណត់ដឹងចិត្តរបស់បុគ្គលពួកខ្លះ ក្នុងលោកនេះ ដោយចិត្ត យ៉ាងនេះថា បុគ្គលនេះប្រតិបត្តិដូច្នោះ ប្រព្រឹត្តដូច្នោះ ឡើងកាន់ផ្លូវនោះ លុះបែកធ្លាយរាងកាយស្លាប់ទៅ នឹងទៅកើតក្នុងសុគតិសួគ៌ទេវលោក ។ ម្នាលសារីបុត្ត តថាគតកំណត់ដឹងចិត្តរបស់បុគ្គលពួកខ្លះ ក្នុងលោកនេះ ដោយចិត្ត យ៉ាងនេះថា បុគ្គលនេះប្រតិបត្តិដូច្នោះ ប្រព្រឹត្តដូច្នោះ ឡើងកាន់ផ្លូវនោះ នឹងត្រាស់ដឹងដោយខ្លួនឯង ធ្វើឲ្យជាក់ច្បាស់ សម្រេចនូវចេតោវិមុត្តិ និងបញ្ញាវិមុត្តិ ដែលមិនមានអាសវៈ ព្រោះអស់ទៅនៃអាសវៈទាំងឡាយ ហើយសម្រេចសម្រាន្តនៅក្នុងបច្ចុប្បន្ន ហេតុនោះ ( ទ្រង់ត្រាស់ថា ) ទើបទ្រង់ជ្រាបនូវបុគ្គលនោះ ដែលកំពុងរស់នៅ ។

[ ៥០ ] អធិប្បាយពាក្យថា អ្នកមានចិត្តជប់ ( ក្នុងអាកិញ្ចញ្ញាយតនៈ ) មានអាកិញ្ចញ្ញាយតនៈនោះប្រព្រឹត្តទៅខាងមុខ ត្រង់ពាក្យថា អ្នកមានចិត្តជប់ គឺមានចិត្តជប់ក្នុងអាកិញ្ចញ្ញាយតនៈ ជ្រប់ក្នុងអាកិញ្ចញ្ញាយតនៈនោះ មាន

អាកិញ្ចញ្ញាយតនៈនោះជាអធិបតី ។ មួយទៀត ព្រះមានព្រះភាគទ្រង់ជ្រាបថា បុគ្គលនេះជាប់ក្នុងរូប ជាប់ក្នុងសំឡេង ជាប់ក្នុងក្លិន ជាប់ក្នុងរស ជាប់ក្នុងផោដ្ឋព្វៈ ជាប់ក្នុងត្រកូល ជាប់ក្នុងគណៈ ជាប់ក្នុងអាវាស ជាប់ក្នុងលាភ ជាប់ក្នុងយស ជាប់ក្នុងសេចក្ដីសរសើរ ជាប់ក្នុងសុខ ជាប់ក្នុងចីវរ ជាប់ក្នុងបិណ្ឌបាត ជាប់ក្នុងសេនាសនៈ ជាប់ក្នុងគិលានប្បច្ចយភេសជ្ជបរិក្ខារ ជាប់ក្នុងព្រះសូត្រ ជាប់ក្នុងវិន័យ ជាប់ក្នុងអភិធម្ម ជាប់ក្នុងបំសុកូលិកង្គៈ ជាប់ក្នុងតេចីវរិកង្គៈ ជាប់ក្នុងបិណ្ឌបាតិកង្គៈ ជាប់ក្នុងសបទានចារិកង្គៈ ជាប់ក្នុងឯកាសនិកង្គៈ ជាប់ក្នុងបត្តបិណ្ឌិកង្គៈ ជាប់ក្នុងខលុបច្ឆាភត្តិកង្គៈ ជាប់ក្នុងអារញ្ញិកង្គៈ ជាប់ក្នុងរុក្ខមូលិកង្គៈ ជាប់ក្នុងអព្ភោកាសិកង្គៈ ជាប់ក្នុងសោសានិកង្គៈ ជាប់ក្នុងយថាសន្ថតិកង្គៈ ជាប់ក្នុងនេសជ្ជិកង្គៈ ជាប់ក្នុងបឋមជ្ឈាន ជាប់ក្នុងទុតិយជ្ឈាន ជាប់ក្នុងតតិយជ្ឈាន ជាប់ក្នុងចតុត្ថជ្ឈាន ជាប់ក្នុងអាកាសានញ្ចាយតនសមាបត្តិ ជាប់ក្នុងវិញ្ញាណញ្ចាយតនសមាបត្តិ ជាប់ក្នុងអាកិញ្ចញ្ញាយតនសមាបត្តិ ជាប់ក្នុងនេវសញ្ញានាសញ្ញាយតនសមាបត្តិ ហេតុនោះ ( ទ្រង់ត្រាស់ថា ) អ្នកមានចិត្តជាប់ ។ ពាក្យថា មានអាកិញ្ចញ្ញាយតនៈប្រព្រឹត្តទៅខាងមុខ គឺសម្រេចដោយអាកិញ្ចញ្ញាយតនៈ មានសមាបត្តិនោះប្រព្រឹត្តទៅខាងមុខ មានកម្មប្រព្រឹត្តទៅខាងមុខ មានវិបាកប្រព្រឹត្តទៅខាងមុខ ធ្ងន់ដោយកម្ម ធ្ងន់ដោយបដិសន្ធិ ។ មួយទៀត ព្រះមានព្រះភាគទ្រង់ជ្រាបថា បុគ្គលនេះ មានរូបប្រព្រឹត្តទៅខាងមុខ ។បេ។ មាននេវសញ្ញានាសញ្ញាយតនសមាបត្តិប្រព្រឹត្តទៅខាងមុខ ហេតុនោះ ( ទ្រង់ត្រាស់ថា ) ជាអ្នកមានចិត្តជាប់ក្នុងអាកិញ្ចញ្ញាយតនៈ មាន

អាកិញ្ចញ្ញាយតនៈនោះប្រព្រឹត្តទៅខាងមុខ ហេតុនោះ ព្រះមានព្រះភាគត្រាស់ថា

( ព្រះមានព្រះភាគត្រាស់ថា ម្នាលបោសាលៈ ) ព្រះតថាគតទ្រង់ជ្រាបច្បាស់នូវវិញ្ញាណដ្ឋិតិទាំងពួង ទើបទ្រង់ជ្រាបនូវបុគ្គលនោះ ដែលកំពុងរស់នៅ មានចិត្តផប់ក្នុងអាកិញ្ចញ្ញាយតនៈ មានអាកិញ្ចញ្ញាយតនៈនោះប្រព្រឹត្តទៅខាងមុខ ។

[ ៥១ ] បុគ្គលដឹងនូវការកើតព្រមនៃអាកិញ្ចញ្ញា ដឹងនូវសេចក្តីរីករាយ ជាគ្រឿងប្រកបដូច្នេះ លុះដឹងច្បាស់សេចក្តីនុ៎ះយ៉ាងនេះហើយ ចេញអំពីសមាបត្តិនោះ រមែងឃើញច្បាស់ក្នុងសមាបត្តិនោះ នេះឯង ជាញាណដ៏ពិតប្រាកដរបស់ព្រាហ្មណ៍ ដែលមានព្រហ្មចរិយៈនៅរួចហើយនោះ ។

[ ៥២ ] ពាក្យថា ដឹងនូវការកើតព្រមនៃអាកិញ្ចញ្ញា សេចក្តីថា កម្មាភិសង្ខារ ដែលញុំាងអាកិញ្ចញ្ញាយតនៈឲ្យប្រព្រឹត្តទៅព្រម លោកហៅថា ការកើតព្រមនៃអាកិញ្ចញ្ញា ។ បុគ្គលដឹងនូវកម្មាភិសង្ខារ ដែលញុំាងអាកិញ្ចញ្ញាយតនៈឲ្យប្រព្រឹត្តទៅព្រមថា ការកើតព្រមនៃអាកិញ្ចញ្ញា ដឹងថា ជាគ្រឿងជាប់ ដឹងថា ជាចំណង ដឹង ស្គាល់ ស្ទង់មើល ពិចារណា ចម្រើន ធ្វើឲ្យប្រាកដថា ជាគ្រឿងកង្វល់ ហេតុនោះ ( ទ្រង់ត្រាស់ថា ) ដឹងនូវការកើតព្រមនៃអាកិញ្ចញ្ញា ។

[ ៥៣ ] ពាក្យថា សេចក្តីរីករាយ ជាគ្រឿងប្រកបដូច្នេះ គឺសេចក្តី

ត្រេកត្រអាលក្នុងអរូប ហៅថា សេចក្តីរីករាយជាគ្រឿងប្រកប ។ កម្មនោះ ជាប់ ជាប់ស្អិត ខ្វល់ដោយសេចក្តីត្រេកត្រអាលក្នុងអរូប បុគ្គលដឹងនូវសេចក្តីត្រេកត្រអាលក្នុងអរូបថា សេចក្តីរីករាយជាគ្រឿងប្រកប ដឹងថា ជាគ្រឿងជាប់ ដឹងថា ជាគ្រឿងចង ដឹង ស្គាល់ សួង់មើល ពិចារណា ចម្រើន ធ្វើឲ្យជាក់ច្បាស់ ថាជាកង្វល់ ។ ពាក្យថាដូច្នោះ ជាការតបទ ។បេ។ ពាក្យថាដូច្នេះនេះ ជាលំដាប់បទ ហេតុនោះ ( ទ្រង់ត្រាស់ថា ) សេចក្តីរីករាយជាគ្រឿងប្រកប ដូច្នេះ ។

[ ៥៤ ] ពាក្យថា លុះដឹងច្បាស់សេចក្តីនុ៎ះយ៉ាងនេះហើយ គឺដឹង ស្គាល់ សួង់មើល ពិចារណា ចម្រើន ធ្វើឲ្យប្រាកដនូវសេចក្តីនុ៎ះយ៉ាងនេះ ហេតុនោះ ( ទ្រង់ត្រាស់ថា ) លុះដឹងច្បាស់សេចក្តីនុ៎ះយ៉ាងនេះហើយ ។

[ ៥៥ ] ពាក្យថា ចេញអំពីសមាបត្តិនោះ រមែងឃើញច្បាស់ក្នុងសមាបត្តិនោះ គឺចូលអាកិញ្ចញ្ញាយតនៈ ហើយចេញចាកសមាបត្តិនោះ រមែងឃើញច្បាស់នូវពួកធម៌ គឺចិត្ត និងចេតសិកដែលកើតក្នុងសមាបត្តិនោះថា មិនទៀង ឃើញច្បាស់ថាជាទុក្ខ យល់ច្បាស់ ឃើញ ក្រឡេកមើល សម្លឹងមើល កំណត់មើលថាជារោគ ។បេ។ ថាមិនជាទីរលាស់ទុក្ខ ហេតុនោះ ( ទ្រង់ត្រាស់ថា ) ចេញអំពីសមាបត្តិនោះ រមែងឃើញច្បាស់ក្នុងសមាបត្តិនោះ ។

[ ៥៦ ] ពាក្យថា នេះឯងជាញាណដ៏ពិតប្រាកដរបស់ព្រាហ្មណ៍នោះ សេចក្តីថា ញាណនុ៎ះរបស់ព្រាហ្មណ៍នោះ ជាធម្មជាតពិត ទៀង ប្រាកដ មិនប្រែប្រួល ហេតុនោះ ( ទ្រង់ត្រាស់ថា ) នេះឯងជាញាណដ៏ពិតប្រាកដរបស់

ព្រាហ្មណ៍នោះ ។

[ ៥៧ ] ពាក្យថា របស់ព្រាហ្មណ៍ ក្នុងបទថា របស់ព្រាហ្មណ៍ដែលមានព្រហ្មចរិយៈនៅរួចហើយ គឺឈ្មោះថាព្រាហ្មណ៍ ព្រោះបន្សាត់បង់ធម៌ទាំង ៧ ។បេ។ ជាបុគ្គលមិនអាស្រ័យកិលេស មិនញាប់ញ័រ បុគ្គលនោះលោកហៅថា ព្រាហ្មណ៍ ហេតុនោះ ( ទ្រង់ត្រាស់ថា ) របស់ព្រាហ្មណ៍ ។ ពាក្យថា មានព្រហ្មចរិយៈនៅរួចហើយ បានដល់ពួកសេក្ខៈទាំង ៧ រាប់បញ្ចូលទាំងកល្យាណបុថុជ្ជន រមែងនៅ នៅគ្រប់គ្រង នៅថែទាំ នៅនិត្យ ដើម្បីសម្រេចគុណវិសេសដែលមិនទាន់ដល់ ដើម្បីបានធម៌ដែលមិនទាន់បាន ដើម្បីធ្វើឲ្យជាក់ច្បាស់ នូវធម៌ដែលមិនទាន់ធ្វើឲ្យជាក់ច្បាស់ ។ ព្រះអរហន្ត មានព្រហ្មរិយៈនៅរួចហើយ មានករណីយកិច្ចធ្វើរួចហើយ មានភារៈដាក់ចុះហើយ មានប្រយោជន៍ខ្លួនសម្រេចហើយ មានសញ្ញោជនៈក្នុងភព អស់រលីងហើយ មានចិត្តផុតស្រឡះហើយ ព្រោះដឹងដោយប្រពៃ ព្រះអរហន្តនោះ ឈ្មោះថាមានអរិយវាសនៅរួចហើយ មានចរណៈសន្សំហើយ ។បេ។ ភពថ្មី គឺជាតិជរា មរណៈ សង្សារ របស់ព្រះអរហន្ត នោះមិនមានទេ ហេតុនោះ ( ទ្រង់ត្រាស់ថា ) របស់ព្រាហ្មណ៍ ដែលមានព្រហ្មចរិយៈនៅរួចហើយ ។ ហេតុនោះ ព្រះមានព្រះភាគត្រាស់ថា

បុគ្គលដឹងនូវការកើតព្រមនៃអាកិញ្ចញ្ញា ដឹងនូវសេចក្តីរីករាយ
ជាគ្រឿងប្រកបដូច្នេះ លុះដឹងច្បាស់សេចក្តីនុ៎ះយ៉ាងនេះហើយ
ចេញអំពីសមាបត្តិនោះ រមែងឃើញច្បាស់ក្នុងសមាបត្តិនោះ

នេះឯងជាញាណដ៏ពិតប្រាកដរបស់ព្រាហ្មណ៍ ដែលមានព្រហ្ម-

ចរិយធម៌នៅរួចហើយនោះ ។

លុះចប់គាថា ។បេ។ បពិត្រព្រះអង្គដ៏ចម្រើន សូមព្រះមានព្រះភាគជាសាស្តារបស់ខ្ញុំព្រះអង្គ ខ្ញុំព្រះអង្គសូមជាសាវ័ក ។

## បោសាលមាណវកបញ្ហានិទ្ទេសទី ១៤ ចប់

# អដ្ឋកថា

## ចោសាលមាណវកប្បបញ្ហានិទ្ទេស

គប្បីជ្រាបវិនិច្ឆ័យក្នុងបោសាលសូត្រទី ១៤ ដូចតទៅ

[ ៣៥ ] បទថា **យោ អតីតំ អាទិសតិ** សេចក្តីថា ព្រះមានព្រះភាគអង្គណា ទ្រង់សម្តែងអតីត គឺទ្រង់សម្តែងអតីត មានជាដើមថា ១ ជាតិខ្លះរបស់ព្រះអង្គ និងរបស់សត្វដទៃ ។

[ ៣៦ ] បទថា **ឯកម្បិ ជាតឹ** សេចក្តីថា ១ ខន្ធសន្តានខ្លះ ដែលមានបដិសន្ធិជាដើម មានចុតិជាបរិយោសាន ដែលទាក់ទងក្នុង ១ ភព ។ ក្នុងបទទាំងឡាយថា **ទ្វេបិ ជាតិយោ** ជាដើម ក៏មានន័យដូច្នេះ ។ ម្យ៉ាងទៀត គប្បីជ្រាបសេចក្តីក្នុងបទទាំងឡាយថា **អនេកេបិ សំវដ្ដកប្បេ** ជាដើមដូចតទៅ កប្បកំពុងវិនាស ឈ្មោះថា សំវដ្តកប្ប ព្រោះក្នុងកាលនោះ សត្វទាំងពួងទៅរួមគ្នាក្នុងព្រហ្មលោក ។ កប្បកំពុងចម្រើន ឈ្មោះថា វិវដ្តកប្ប ព្រោះក្នុងកាលនោះ សត្វទាំងឡាយត្រឡប់អំពីព្រហ្មលោក ។ ក្នុងបទនោះ ជាការកាន់យកអាការតាំងនៅនៃសំវដ្តកប្ប ដោយសំវដ្តកប្ប ។ និងជាការកាន់យកអាការតាំងនៅនៃវិវដ្តកប្ប ដោយវិវដ្តកប្ប ។ ព្រោះបដិសន្ធិនោះជាដើមហេតុ ។ កាលបើដូច្នោះ ព្រះមានព្រះភាគត្រាស់ថា **ចត្តារីមានិ ភិក្ខវេ កប្បស្ស អសង្ខេយ្យានិ ។ កតមានិ ចត្តារិ សំវដ្ដោ សំវដ្ដដ្ឋាយី វិវដ្ដោ វិវដ្ដដ្ឋាយី** ម្នាលភិក្ខុទាំងឡាយ អសង្ខេយ្យ ( កាលដែលយូររាប់មិនបាន ) នៃកប្បនេះមាន ៤ ។ អសង្ខេយ្យ ៤ គឺអ្វីខ្លះ ។ កាលកប្បសូន្យទៅ តាំងមានឡើង កាលកប្បតាំងនៅ ក្នុងចន្លោះវិនាសទៅ តាំងមាន

ឡើង កាលកប្បត្រឡប់ចម្រើន តាំងមានឡើងវិញ កាលកប្បតាំងនៅ ក្នុងចន្លោះចម្រើន តាំងមានឡើង[១] ។ ជាការកំណត់យកអសង្ខេយ្យកប្បទាំងនោះ ។ ម្យ៉ាងទៀត ក្នុងបទថា **សំវដ្ដកប្បេ វិវដ្ដកប្បេ** លោកពោលកាន់យកពាក់កណ្ដាលនៃកប្ប ។ ក្នុងបទថា **សំវដ្ដវិវដ្ដកប្បេ** លោកពោលកាន់យកអស់កប្ប ។ បើសួរថា រឭកដល់ដូចម្ដេច ឆ្លើយថា រឭកដល់ដោយន័យថា **អមុត្រាសឹ** ជាដើម ។ បណ្ដាបទទាំងនោះ បទថា **អមុត្រាសឹ** សេចក្ដីថា អាត្មាអញមានហើយក្នុងសំវដ្ដកប្បនោះ ក្នុងភព កំណើត គតិ វិញ្ញាណដ្ឋិតិ សត្តាវាស សត្តនិកាយនោះ ។ បទថា **ឯវំនាមោ** បានដល់ឈ្មោះថា **តិស្សៈ ឬ ផុស្សៈ** ។ បទថា **ឯវំ គោត្តោ** បានដល់ កច្ចានគោត្រ ឬកស្សបគោត្រ ។ បទនេះ លោកពោលដោយអំណាចដែលបុគ្គលនោះ រឭកដល់ឈ្មោះ និងគោត្ររបស់ខ្លួនក្នុងអតីតភព ។ បើក្នុងកាលនោះ បំណងរឭកដល់វណ្ណសម្បត្តិក្ដី ភាពជាអ្នកមានជីវិតគ្រោតគ្រាត និងប្រណីតក្ដី ភាពជាអ្នកច្រើនដោយសុខ និងទុក្ខក្ដី ភាពជាអ្នកមានអាយុតិច និងអាយុច្រើនក្ដី រមែងរឭកដល់សេចក្ដីនោះបាន ។ ដោយហេតុនោះ ទើបព្រះមានព្រះភាគត្រាស់ថា **ឯវំវណ្ណោ ។បេ។ ឯវមាយុបរិយន្តោ** ដូច្នេះ ។

ក្នុងបទទាំងនោះ បទថា **ឯវំវណ្ណោ** សេចក្ដីថា មានពណ៌សម្បុរ-ស ឬពណ៌លឿង ។ បទថា **ឯវមាហារោ** សេចក្ដីថា មានស្រូវសាលី សាច់បាយជាអាហារ ឬមានផ្លែឈើ ដែលជ្រុះឯង ជារបស់បរិភោគ ។ បទថា

---

១- សេចក្ដីពិស្ដារ មានក្នុងបិដក ៤៣ ឃ្នាប ៦ ឯណោះ ។

**ឯវំសុខទុក្ខប្បដិសំវេទី** *សេចក្តីថា សោយសុខ និងទុក្ខដែលប្រព្រឹត្តទៅតាមផ្លូវកាយ ប្រព្រឹត្តទៅតាមផ្លូវចិត្ត ដោយប្រការមិនមែនតិច ឬមានប្រភេទមានអាមិស និងមិនមានអាមិស ។ បទថា* **ឯវមាយុបរិយន្តោ** *សេចក្តីថា មានកំណត់អាយុប្រមាណ ១០០ ឆ្នាំ ឬ ៨៤០០០ កប្ប ។ បទថា* **សោ តតោ ចុតោ អមុត្រ ឧទបាទឹ** *សេចក្តីថា តថាគតកាលចុតិអំពីភព កំណើត គតិ វិញ្ញាណដ្ឋិតិ សត្តាវាស ឬសត្តនិកាយនោះហើយ បានមកកើតក្នុងភព កំណើត គតិ វិញ្ញាណដ្ឋិតិ សត្តាវាស ឬសត្តនិកាយនោះ ។ បទថា* **តត្រាបាសឹ** *សេចក្តីថា ម្យ៉ាងទៀត តថាគតមានហើយក្នុងភព កំណើត គតិ វិញ្ញាណដ្ឋិតិ សត្តាវាស ឬសត្តនិកាយនោះទៀត ។ បទ មានបទជាដើមថា* **ឯវំនាមោ** *មានន័យដូចពោលហើយនោះឯង ។*

*ម្យ៉ាងទៀត ព្រោះបទថា* **អមុត្រាសឹ** *នេះ ជាការរឭកដល់អស់កាលដែលត្រូវការ របស់បុគ្គលដែលរឭកថយទៅដោយលំដាប់ ។ បទថា* **សោ តតោ ចុតោ** *ជាការពិចារណារបស់បុគ្គលដែលរឭកថយ ដូច្នោះ បទថា* **ឥធូបបន្នោ** *បានដល់ តថាគតនោះចុតិចាកអំពីទីដែលកើត ដែលមិនមានទីបំផុតនោះហើយ កើតក្នុងត្រកូលក្សត្រ ឬក្នុងត្រកូលព្រាហ្មណ៍ឈ្មោះនោះក្នុងទីនេះ ។ បទថា* **ឥតិ** *បានដល់ ដោយប្រការដូច្នេះ ។ បទថា* **សាការំ សឧទ្ទេសំ** *សេចក្តីថា ព្រមទាំងឧទ្ទេស ដោយអំណាចឈ្មោះ និងគោត្រ ព្រមទាំងអាការ ដោយអំណាចពណ៌សម្បុរជាដើម ព្រោះថា សត្វរមែងសម្តែងដោយឈ្មោះ និងគោត្រថា តិស្សៈ កស្សបៈ រមែងប្រាកដដោយ*

ពណ៌សម្បុរជាដើមដោយប្រការផ្សេងៗ ថា លឿង ស ព្រោះហេតុនោះ ឈ្មោះ និងគោត្រជាឧទ្ទេស ក្រៅអំពីនោះជាអាការ ។ បទថា **បុព្វេនិវាសំ** បានដល់ ខន្ធដែលនៅអាស្រ័យក្នុងអតីតជាតិជាដើមក្នុងកាលមុន ឈ្មោះថា **បុព្វេ-និវាសំ** ។ បទថា **និវុដ្ឋា** បានដល់ នៅអាស្រ័យ បានសោយផល គឺកើតឡើងក្នុងសន្តានរបស់ខ្លួន ហើយរលត់ទៅ ឬមានការនៅអាស្រ័យជាធម្មតា ។ បទថា **និវុដ្ឋា** សេចក្តីថា ខន្ធដែលនៅអាស្រ័យដោយជាទីត្រាច់ទៅ កំណត់ដឹងបានដោយវិញ្ញាណរបស់ខ្លួនខ្លះ កំណត់ដឹងបានដោយវិញ្ញាណរបស់អ្នកដទៃខ្លះ ក្នុងការរឭកដល់លោកអ្នកកាត់វដ្ដៈហើយជាដើម ព្រះពុទ្ធទាំងឡាយប៉ុណ្ណោះ រមែងរឭកដល់ខន្ធដែលជាទីនៅអាស្រ័យក្នុងអតីតជាតិបាន ព្រះមានព្រះភាគទ្រង់សម្តែង គឺទ្រង់ពោលដល់អតីតជាតិនោះ ។

បទថា **បរេសំ អតីតំ** សេចក្តីថា ព្រះមានព្រះភាគទ្រង់សម្តែងដល់អតីតជាតិនៃបុគ្គលពួកដទៃ ដោយន័យជាដើមថា **ឯកម្បិ ជាតឹ** ដូច្នេះ ។ បទថា **មហាបធានិយសុត្តន្តំ** បានដល់ មហាបទានសូត្រ ដែលសម្តែងប្រវត្តិនៃព្រះមហាបុរសទាំងឡាយ ។ បទថា **មហាសុទស្សនិយសុត្តន្តំ** បានដល់ មហាសុទស្សនសូត្រ ដែលសម្តែងដល់សម្បត្តិរបស់ស្តេចមហាសុទស្សនៈ ។ បទថា **មហាគោវិន្ទិយសុត្តន្តំ** បានដល់ មហាគោវិន្ទសូត្រ ដែលសម្តែងដល់រឿងរ៉ាវរបស់មហាគោវិន្ទព្រាហ្មណ៍ ។ បទថា **មាឃទេវិយសុត្តន្តំ** បានដល់ មឃទេវសូត្រ ដែលសម្តែងប្រវត្តិរបស់មឃទេវរាជ ។

បទថា **សតានុសារិញាណំ ហោតិ** បានដល់ ញាណដែលសម្បយុត្ត

ដោយការរឭកដល់អតីតជាតិ ។ បទថា **យាវតកំ អាកង្ខតិ** សេចក្តីថា តថាគតប្រាថ្នាដឹងអតីតជាតិប៉ុនណា ក៏បញ្ជូនញាណទៅថា តថាគតនឹងដឹងអតីតជាតិប៉ុណ្ណោះ ។ លំដាប់នោះ ញាណរបស់តថាគត រមែងស្ទុះទៅ មិនមានអ្វីប៉ះខ្ទប់ មិនមានអ្វីរាំង ដូចប្រេងម្កាក់ហូរចូលទៅក្នុងកញ្ចប់ស្លឹកឈើស្ងួត ។ ដោយហេតុនោះ តថាគតរមែងរឭកដល់អតីតជាតិបានតាមប្រាថ្នា ។ បទថា **ពោធិជំ** បានដល់ កើតត្រង់មណ្ឌលពោធិព្រឹក្ស ។ បទថា **ញាណំ ឧប្បជ្ជតិ** បានដល់ ញាណក្នុងមគ្គ ៤ រមែងកើតឡើង ។ បទថា **អយមន្តិមា ជាតិ** សេចក្តីថា ញាណដទៃក៏កើតឡើងទៀតថា ជាតិនេះជាជាតិចុងក្រោយ ឥឡូវនេះ ភពថ្មីមិនមានទេ ព្រោះលះដើមហេតុរបស់ជាតិបានដោយញាណនោះ ។ ក្នុងបទថា **ឥន្ទ្រិយបរោបរិយត្តញ្ញាណំ** នេះ គួរនាំបទថា **សត្តានំ** មកប្រកបខាងមុខថា **សត្តានំ ឥន្ទ្រិយបរោបរិយត្តញ្ញាណំ** ។ កាលគួរពោលថា **បរានិ ច អបរានិ ច បរាបរានិ** លោកចុះ រោ អក្ខរៈ ដោយបទសន្ធិ ពោលថា **បរោបរានិ** ។ ការក្រៃលែង និងការធូរថយ ឈ្មោះថា **បរោបរិយ** ។ ការក្រៃលែង និងការធូរថយនោះឯង ឈ្មោះថា **បរោបរិយត្ត** ។ ការក្រៃលែង និងការធូរថយនៃឥន្ទ្រិយទាំងឡាយ ៥ មានសទ្ធិន្ទ្រិយជាដើមរបស់វេនេយ្យសត្វទាំងឡាយ ឈ្មោះថា **ឥន្ទ្រិយបរោបរិយត្ត** ។ ញាណជាគ្រឿងកំណត់ដឹងនូវការក្រៃលែង និងការធូថយនៃឥន្ទ្រិយ ឈ្មោះថា **ឥន្ទ្រិយបរោបរិយត្តិញ្ញាណ** អធិប្បាយថា ញាណជាគ្រឿងកំណត់ដឹងនូវការខ្ពស់ និងការទាបនៃឥន្ទ្រិយទាំងឡាយ ។ បាឋៈថា **ឥន្ទ្រិយវរោវរិយ-**

**ត្តញ្ញាណំ** ដូច្នេះក៏មាន លោកប្រកបពាក្យម្យ៉ាងទៀតថា **វរានិ ច អវរិយានិ ច វរោវរិយានិ**ការក្រៃលែងនិងការធូរថយ ឈ្មោះថា **វរោវរិយានិ** ភាពនៃការក្រៃលែង និងការធូរថយទាំងនោះ ឈ្មោះថា **វរោវរិយត្តំ** ។ បទថា **អវរិយានិ** បានដល់ ឧត្តម ។ ម្យ៉ាងទៀត លោកប្រកបសេចក្តីថា **បរានិ ច ឱបរានិ ច បរោបរានិ** ការក្រៃលែង និងការធូរថយ ឈ្មោះថា **បរោបរានិ** ភាពនៃការក្រៃលែង និងការធូរថយទាំងនោះ ឈ្មោះថា **បរោបរិយំ** លោកអធិប្បាយថា **ឱបរានិ** ( ការធូរថយ ) គឺ **ឱរានិ** ( ការថោកថយ ) ។ អធិប្បាយថា លាមក ដូចក្នុងប្រយោគជាដើមថា **បរោបរា យស្ស សមេច្ចធម្មា**[១] ។ បាឋៈប្រើជាសត្តមីវិភត្តិថា **ឥន្ទ្រិយបរោបរិយត្តេ ញាណំ** ញាណកំណត់ដឹងក្នុងការក្រៃលែង និងការធូរថយនៃឥន្ទ្រិយក៏មាន ។ បទថា **តថាគតស្ស** បានដល់ យាងមក ដូចលោកអ្នកស្វែងរកគុណអំពីកាលមុន មានព្រះវិបស្សីជាដើមយាងមកហើយ ។ ម្យ៉ាងទៀត យាងទៅដូចលោកអ្នកស្វែងរកគុណទាំងនោះយាងទៅហើយ ។ បទថា **តថាគតពលំ** បានដល់ ជាកម្លាំងរបស់ព្រះតថាគតប៉ុណ្ណោះ មិនទូទៅដោយបុគ្គលដទៃ ម្យ៉ាងទៀត អធិប្បាយថា ជាកម្លាំងមកហើយ ដូចកម្លាំងរបស់ព្រះពុទ្ធកាលមុន ដែលមកហើយដោយការដល់ព្រម ដោយការសន្សំបុណ្យ ។ បណ្តាកម្លាំងទាំងនោះ កម្លាំងរបស់ព្រះតថាគត មាន ២ យ៉ាង គឺកាយពលំ ១ ញាណពលំ ១ ។ ក្នុងកម្លាំងទាំងនោះ គប្បីជ្រាបកម្លាំងព្រះវរកាយ តាមទំនងនៃត្រកូលដំរី ។

---

១- សុត្តនិបាត ទំ. ១៥១ ។

បុរាណាចារ្យពោលទុកដូច្នេះថា

ត្រកូលដំរី ១០ គឺត្រកូលដំរីកាឡាវកៈ ១ គង្គេយ្យៈ ១ បណ្ឌរៈ ១ តម្ពៈ ១ បិង្គលៈ ១ គន្ធៈ ១ មង្គលៈ ១ ហេមៈ ១ ឧបោសថៈ ១ ឆទ្ទន្តៈ ១ ។

កម្លាំងរបស់ដំរី ១ ពាន់កោដិ ដោយចំនួនដំរីប្រក្រតី ( កាឡាវកៈ ) កម្លាំងរបស់បុរស ១ ម៉ឺនកោដិ ដោយចំនួនបុរស នេះជាកម្លាំងព្រះវរកាយរបស់ព្រះតថាគត ។ តែកម្លាំងព្រះញាណ មកហើយក្នុងមហាសីហនាទសូត្រ គឺទសពលញ្ញាណ ចតុវេសារជ្ជញ្ញាណ ញាណមិនញាប់ញ័រក្នុងបរិស័ទទាំង ៨ ញាណកំណត់កំណើត ៤ ញាណកំណត់គតិ ៥ ញាណច្រើនពាន់ដទៃយ៉ាងនេះ គឺញាណ ៧៣ ញាណ ៧៧ មកហើយក្នុងសំយុត្តនិកាយ ឈ្មោះថាកម្លាំងព្រះញាណ ។ ក្នុងទីនេះ បំណងយកកម្លាំងព្រះញាណប៉ុណ្ណោះ ព្រោះព្រះញាណ លោកពោលថា ជាពល ព្រោះអត្ថថា មិនញាប់ញ័រ និងព្រោះអត្ថថា ឧបការៈ ។

គប្បីជ្រាបសេចក្តីក្នុងបទនេះថា **សត្តានំ អាសយានុសយញ្ញាណំ** ដូចតទៅ ឈ្មោះថា **សត្តា** ព្រោះជាអ្នកជាប់ជំពាក់ គឺជាប់ក្នុងខន្ធទាំងឡាយមានរូបជាដើម ដោយឆន្ទរាគៈ សមដូចព្រះមានព្រះភាគត្រាស់ ( ក្នុងសំយុត្តនិកាយ ខន្ធវារវគ្គ ) ថា

ម្នាលរាធៈ សេចក្តីពេញចិត្តណា សេចក្តីត្រេកអរណា សេចក្តីរីករាយណា សេចក្តីប្រាថ្នាណា ក្នុងរូប បុគ្គលដែលជាប់នៅក្នុង

សេចក្តីពេញចិត្តជាដើមនោះ ជំពាក់នៅក្នុងសេចក្តីពេញចិត្តជាដើមនោះ លោកហៅថា សត្វ ។ សេចក្តីពេញចិត្តណា សេចក្តីត្រេកអរណា សេចក្តីរីករាយណា សេចក្តីប្រាថ្នាណា ក្នុងវេទនា ។ ក្នុងសញ្ញា ។ ក្នុងសង្ខារទាំងឡាយ ។ ក្នុងវិញ្ញាណ បុគ្គលដែលជាប់នៅក្នុងសេចក្តីពេញចិត្តជាដើមនោះ ជំពាក់នៅក្នុងសេចក្តីពេញចិត្តជាដើមនោះ លោកហៅថា សត្វ ដូច្នេះ ។

តែអ្នកគិតអក្ខរៈ មិនពិចារណាដល់សេចក្តី សម្រេចការយល់ឃើញថា ពាក្យនោះ ត្រឹមតែជាឈ្មោះ ។ បុគ្គលណាពិចារណាដល់សេចក្តី បុគ្គលនោះ រមែងសម្រេចនូវការយល់ឃើញថា ឈ្មោះថា សត្វ ព្រោះប្រកបដោយការជាប់ជំពាក់ ។ ឈ្មោះថា **អាសយ** ព្រោះជាទីមកដេក អាស្រ័យនៃសត្វទាំងឡាយនោះ ។ ពាក្យនេះ ជាឈ្មោះរបស់ចិត្តសន្តាន ដែលអប់រំដោយមិច្ឆាទិដ្ឋិខ្លះ សម្មាទិដ្ឋិខ្លះ កាមជាដើមខ្លះ នេក្ខម្មៈជាដើមខ្លះ ។ ឈ្មោះថា **អនុសយ** ព្រោះកិលេសទាំងឡាយដេកតាម ចូលទៅជាប់តាមសន្តានរបស់សត្វ ។ ពាក្យនេះ ជាឈ្មោះនៃកាមរាគៈជាដើម ដែលមានកម្លាំង ។ **អាសយ** ផង **អនុសយ** ផង ឈ្មោះថា **អាសយានុសយ** គប្បីជ្រាបថា ជាឯកវចនៈដោយកាន់យកកំណើត និងដោយទ្វន្ទសមាស ( សមាសគូ ) ។ ព្រោះចរិត និងអធ្យាស្រ័យ សង្រ្គោះចូលក្នុងអាសយៈ និងអនុសយៈ ដូច្នោះ ទើបលោកសង្រ្គោះញាណក្នុងចរិត និងញាណក្នុងអធ្យាស្រ័យ ចូលក្នុងអាសយានុសយញ្ញាណនោះឯង ហើយពោលថា **អាសយានុសយញ្ញាណំ** ដូច្នេះ ។

គប្បីជ្រាបសេចក្តីក្នុងបទនេះថា **យមកប្បាដិហីរេ ញាណំ** ដូចតទៅ ឈ្មោះថា **យមកំ** ព្រោះគំនរភ្លើង និងធ្នារទឹកជាដើម ប្រព្រឹត្តទៅតែមួយ មិនមុន មិនក្រោយ ។ ឈ្មោះថា **បាដិហីរំ** ព្រោះនាំបដិបក្ខធម៌ មានភាពជាអ្នកមិនជឿជាដើមចេញទៅ **យមកំ** ផង **បាដិហីរំ** ផង ឈ្មោះថា **យមកប្បាដិហីរំ** ។

គប្បីជ្រាបអត្ថក្នុងបទនេះថា **មហាករុណាសមាបត្តិយា ញាណំ** ដូច្នេះ ឈ្មោះថា **ករុណា** ព្រោះកាលទុក្ខរបស់អ្នកដទៃមាន រមែងធ្វើចិត្តរបស់សប្បុរសទាំងឡាយឲ្យញាប់ញ័រ ។ ម្យ៉ាងទៀត ឈ្មោះថា **ករុណា** ព្រោះកម្ចាត់ទុក្ខរបស់អ្នកដទៃឲ្យអស់ទៅ ។ ឬឈ្មោះថា **ករុណា** ព្រោះជួយស្រោចស្រង់បុគ្គលដែលដល់នូវសេចក្តីទុក្ខ ។ សេចក្តីករុណាធំ ដោយការធ្វើនូវការផ្សាយទៅ និងដោយគុណធម៌ ឈ្មោះថា **មហាករុណា** ។ ឈ្មោះថា **សមាបត្តិ** ព្រោះជាទីចូលដល់របស់បុគ្គលអ្នកមានមហាករុណា ឈ្មោះថា **មហាករុណាសមាបត្តិ** ព្រោះមានមហាករុណាសមាបត្តិ ។ ញាណក្នុងមហាករុណាសមាបត្តិនោះ ឬញាណសម្បយុត្តដោយមហាករុណាសមាបត្តិនោះ ។

គប្បីជ្រាបសេចក្តីក្នុងបទនេះថា **សព្វញ្ញុតញ្ញាណំ អានាវរញ្ញាណំ** ដូច្នេះ ឈ្មោះថា **សព្វញ្ញូ** ព្រោះដឹងទូទៅដល់គ្រប់វត្ថុ ដោយប្រភេទនៃផ្លូវដែលគប្បីដឹង ៥ យ៉ាង ។ ភាពនៃសព្វញ្ញូនោះ ឈ្មោះថា **សព្វញ្ញុតា** ។ ញាណ គឺភាពជាព្រះសព្វញ្ញូនោះឯង ឈ្មោះថា **សព្វញ្ញុតញ្ញាណំ** ។ កាល

គួរពោលថា **សព្វញ្ញុតាញាណំ** តែលោកធ្វើឲ្យជារស្សៈថា **សព្វញ្ញុ-តញ្ញាណំ** ។ ពិតហើយ ធម៌ទាំងអស់ មានប្រភេទជាដើមថា សង្ខតធម៌ និងអសង្ខតធម៌ មានផ្លូវដែលគួរទូន្មាន ៥ ប្រការ គឺសង្ខារ ១ វិការ ១ លក្ខណៈ ១ និព្វាន ១ បញ្ញត្តិ ១ ។ ការរារាំងញាណនោះមិនមាន ព្រោះទាក់ទងដោយអាវជ្ជនៈ ព្រោះដូច្នោះ ទើបញ្ញាណនោះហៅថា **អនាវរណញ្ញាណ** ។

គប្បីជ្រាបសេចក្តីក្នុងបទនេះថា **សព្វត្ថ អសង្គមប្បដិហតមនា-វរណញ្ញាណំ** ដូច្នេះ ញាណប្រាសចាកការរារាំង បានដល់ ញាណដែលប្រព្រឹត្តទៅ មិនទើសទាក់ ប្រាសចាកការទើសទាក់ មិនមានគ្រឿងជំទាស់ ប្រាសចាកបដិបក្ខក្នុងអតីត អនាគត និងបច្ចុប្បន្ន ។

បទថា **អនាគតម្បិ អាចិក្ខតិ** សេចក្តីថា ព្រះមានព្រះភាគ រមែងប្រាប់អនាគតរបស់បុគ្គលទាំងឡាយ ដូចជាទេវទត្តដោយន័យជាដើមថា ក្នុងកប្បនេះ មានព្រះពុទ្ធ ៣ អង្គ ត្រាស់ដឹងហើយ បច្ចុប្បន្ននេះ តថាគតជាព្រះសម្មាសម្ពុទ្ធអង្គទី ៤ តទៅនឹងមានព្រះមេត្តេយ្យ ជាអង្គទី ៥ ។

និងថា ម្នាលភិក្ខុទាំងឡាយ កាលបើពួកមនុស្សមានអាយុ ៨ ម៉ឺនឆ្នាំ ព្រះមានព្រះភាគ ទ្រង់ព្រះនាមមេត្តេយ្យ នឹងកើតឡើងក្នុងលោក ទ្រង់ឆ្ងាយចាកកិលេស ទ្រង់ត្រាស់ដឹងញេយ្យធម៌ទាំងពួង ដោយប្រពៃចំពោះព្រះអង្គ ទ្រង់បរិបូណ៌ដោយវិជ្ជា និងចរណៈ ដូច្នេះ ។ និងថា ម្នាលភិក្ខុទាំងឡាយ លំដាប់នោះឯង ព្រះបាទសង្ខៈ ទ្រង់ត្រាស់បង្គាប់ឲ្យលើកប្រាសាទ ដែលព្រះបាទមហាបនាទៈឲ្យកសាង ហើយទ្រង់ប្រជាប់នៅ ( ក្នុងប្រាសាទនោះ )

ទ្រង់លះបង់ ( ប្រាសាទនោះ ) ឲ្យជាទាន ដល់ពួកសមណព្រាហ្មណ៍ កបណៈ ( មនុស្សកំព្រា ) អទ្ធិកៈ ( អ្នកដំណើរ ) វណិព្វក ( អ្នកនិយាយសរសើរហើយសូម ) និងពួកយាចក ( សូម ) រួចទ្រង់ដាក់ព្រះកេសា និងព្រះមស្សុ ទ្រង់ស្លៀកដណ្ដប់កាសាវពស្ត្រ ចេញចាករាជាគារ-ស្ថាន ចូលទៅកាន់ផ្នួស ក្នុងសម្នាក់នៃព្រះមេត្តេយ្យមានព្រះភាគ អរហន្ត-សម្មាសម្ពុទ្ធ ដូច្នេះ ។ និងថា ក្នុងអនាគត ទេវទត្តនឹងបានជាព្រះបច្ចេកពុទ្ធ ឈ្មោះថា អដ្ឋិស្សរៈ ។ និងថា សុមនមាលាការនឹងបានជាព្រះបច្ចេកពុទ្ធព្រះនាមសុមនិស្សរៈ ។ បទថា **បច្ចុប្បន្នម្បិ អាធិសតិ** មានន័យងាយយល់ហើយ ។

[ ៤០ ] បទថា **វិភូតរូបសញ្ញិស្ស** បានដល់ របស់បុគ្គលដែលមានសេចក្ដីសម្គាល់ក្នុងរូបកន្លងទៅហើយ ។ បទថា **សព្វកាយប្បហាយិនោ** បានដល់ លះរូបកាយទាំងអស់ ដោយតទង្គប្បហាន និងវិក្ខម្ភនប្បហាន អធិប្បាយថា លះបដិសន្ធិក្នុងរូបភពបានហើយ ។ បទថា **នត្ថិ កិញ្ចីតិ បស្សតោ** បានដល់ ឃើញថា មិនមានអ្វី ព្រោះឃើញការមិនមាននៃវិញ្ញាណ ។ អធិប្បាយថា ជាអ្នកបាននូវអាកិញ្ចញ្ញាយតនសមាបត្តិ ។ ក្នុងឧទ្ទេសថា **ញាណំ សក្កានុបុច្ឆាមិ** បោសាលមាណពហៅព្រះមានព្រះភាគថា សក្កៈ ។ ខ្ញុំព្រះអង្គសូមទូលសួរដល់ញាណរបស់បុគ្គលនោះ បុគ្គលនោះ គួរប្រាថ្នាញាណដូចម្ដេច ។ បទថា **កថំ នេយ្យោ** បានដល់ បុគ្គលនោះ គប្បីទូន្មានដូចម្ដេច គួរឲ្យកើតញាណក្រៃលែងឡើងដល់បុគ្គលនោះដូចម្ដេច ។

[ ៤១ ] បទថា **រូបសញ្ញា** ក្នុងបទនេះថា **កតមា រូបសញ្ញា** បាន ដល់ រូបាវចរជ្ឈាន និងអារម្មណ៍នៃរូបាវចរជ្ឈាននោះ ដែលពោលដោយ សំដៅដល់សញ្ញាជាធំ ។ ពិតហើយ សូម្បីរូបាវចរជ្ឈាន លោកក៏ហៅថា រូប ដូចក្នុងប្រយោគជាដើមថា **រូបី រូបានិ បស្សតិ** បានទូវរូបជ្ឈាន ឃើញនូវ ពួករូប ដូច្នេះ ។ អារម្មណ៍របស់រូបាវចរជ្ឈាននោះ ក៏ឈ្មោះថា រូប ដូច ក្នុងប្រយោគជាដើមថា **ពហិទ្ធា រូបានិ បស្សតិ បរិត្តានិ សុវណ្ណទុព្វណ្ណានិ** ឃើញនូវពួករូបខាងក្រៅ ជារូបមានប្រមាណតូច មានពណ៌ល្អ មានពណ៌ អាក្រក់ ដូច្នេះ ។ ព្រោះហេតុនោះ ក្នុងទីនេះ បទថា **រូបសញ្ញា** នេះ ទើប ជាឈ្មោះនៃរូបាវចរជ្ឈាន ដោយសំដៅដល់ **សញ្ញា** ជាធំយ៉ាងនេះថា ការ សម្គាល់ក្នុងរូបនេះ ឈ្មោះថា **រូបសញ្ញា** ។ ឈ្មោះថា **រូបសញ្ញា** ព្រោះ រូបមានសញ្ញា ។ លោកពោលថា **រូប** ជាឈ្មោះនៃរូបាវចរជ្ឈាននោះ ។ ម្យ៉ាងទៀត គប្បីជ្រាបថា បទថា **រូបសញ្ញា** នេះ ជាឈ្មោះរបស់អារម្មណ៍ នៃរូបាវចរជ្ឈាននោះ មានប្រភេទជាដើមថា បឋវីកសិណ ដោយប្រការដូច្នេះ ។ តែក្នុងទីនេះ បំណងយករូបសញ្ញាដែលបានដល់រូបជ្ឈាន ១៥ ដោយអំណាច នៃកុសលវិបាក និងកិរិយា ។ បទថា **រូបាវចរសមាបត្តឹ សមាបន្នស្ស វា** បានដល់ របស់បុគ្គលអ្នកចូលសមាបត្តិ ដែលជារូបាវចរកុសលជ្ឈាន ។ បទ ថា **ឧបបន្នស្ស វា** បានដល់ របស់បុគ្គលដែលកើតឡើងហើយក្នុងភពនោះ ដោយអំណាចនៃវិបាកជ្ឈាន ។ បទថា **ទិដ្ឋធម្មសុខវិហារិស្ស វា** បានដល់ របស់បុគ្គលអ្នកញ៉ាំងសុខដែលកើតអំពីឈានសមាបត្តិ ចំណែកខាងកិរិយា

ឲ្យកើតឡើង ក្នុងអត្តភាពនេះហើយនៅ ។

បទថា **អរូបសមាបត្តិយោ** បានដល់ អាកាសានញ្ចាយតនសមាបត្តិជាដើម ។ បទថា **បដិលទ្ធស្ស**[១] បានដល់ ដែលឲ្យអរូបសមាបត្តិកើតឡើងតាំងនៅហើយ ។ បទថា **រូបសញ្ញា វិភូតា ហោន្តិ** បានដល់ ប្រាសចាករូបសញ្ញា ។ បទថា **វិគតា** បានដល់ អស់ទៅហើយ ។ បាឋៈថា **អភាវិតា** ដូច្នេះក៏មាន បទនេះល្អជាង ។

[ ៤២ ] បទថា **តទង្គសមតិក្កមា** បានដល់ ដោយអំណាចការឈានកន្លង ដោយតទង្គប្បហាន ។ បទថា **វិក្ខម្ភនប្បហានេន បហីនោ** បានដល់ លះដោយវិក្ខម្ភនប្បហាន ព្រោះបានអរូបជ្ឈាន ។ បទថា **តស្ស រូបកាយោ** បានដល់ រូបាវចរកាយរបស់បុគ្គលដែលបានអរូបសមាបត្តិនោះ ។

[ ៤៣ ] គប្បីជ្រាបសេចក្តីក្នុងបទថា **អាកិញ្ចញ្ញាយតនំ** ដូចតទៅ ឈ្មោះថា **អាកិញ្ចនំ** ព្រោះមិនមានអ្វីក្នុងឈាននេះ ។ លោកពោលថា មិនមានអ្វីសេសសល់ ដោយហោចសូម្បីត្រឹមតែភង្គក្ខណៈ ។ ការប្រព្រឹត្តទៅនៃការមិនមានអ្វី ឈ្មោះថា **អាកិញ្ចញ្ញំ** ។ ពាក្យនេះ ជាឈ្មោះនៃការប្រាសចាកវិញ្ញាណក្នុងអាកាសានញ្ចាយតនៈ ។ អាកិញ្ចញ្ញៈនោះ ឈ្មោះថា **អាកិញ្ចញ្ញាយតនំ** ព្រោះជាគ្រឿងបន្តនៃសញ្ញានេះ ដោយការអធិដ្ឋាន ។ ពាក្យថា **អាកិញ្ចញ្ញាយតនំ** នេះ ជាឈ្មោះនៃឈានដែលមានអារម្មណ៍ប្រាសចាកវិញ្ញាណ ដែលប្រព្រឹត្តទៅហើយក្នុងអាកាស ។

---

១- បិដកខ្មែរជា លាភិស្ស ។

បទថា **វិញ្ញាណញ្ចាយតនសមាបត្តឹ សតោ សមាបជ្ជិត្វា** បានដល់ មានសតិចូលដល់វិញ្ញាណញ្ចាយតនសមាបត្តិនោះ ។ បទថា **សតោ វុដ្ឋហិត្វា** បានដល់ ជាអ្នកមានសតិចេញអំពីសមាបត្តិនោះ ។ បទថា **សញ្ញោវ វិញ្ញាណំ** បានដល់ វិញ្ញាណដែលជាមហគ្គតៈ ដែលប្រព្រឹត្តទៅហើយក្នុងអាកាស ។ បទថា **អភាវេតិ** បានដល់ ឲ្យវិនាសទៅ ។ បទថា **វិភាវេតិ** បានដល់ ឲ្យវិនាសទៅដោយវិធីផ្សេងៗ ។ បទថា **អន្តរធាបេតិ** បានដល់ ឲ្យដល់នូវការមិនប្រាកដ ។

[ ៤៥ ] បទថា **កថំ សោ ឈេតព្វោ** បានដល់ បុគ្គលនោះ គួរដឹងដោយប្រការណា ។ បទថា **វិឈេតព្វោ** បានដល់ គួរទូន្មានឲ្យពិសេស គឺគួរដឹងដោយវិធីផ្សេងៗ ។ បទថា **អនុឈេតព្វោ** បានដល់ គួរឲ្យចិត្តប្រព្រឹត្តទៅរឿយៗ ។

[ ៤៦ ] លំដាប់នោះ ព្រះមានព្រះភាគ ទ្រង់ប្រកាសភាពដែលញាណរបស់ព្រះអង្គ មិនទើសទាក់ក្នុងបុគ្គលបែបនោះ ទើបត្រាស់គាថា ដើម្បីទ្រង់ព្យាករញាណនោះ ដល់បោសាលមាណព ។ ក្នុងបទទាំងនោះ បទថា **វិញ្ញាណដ្ឋិតិយោ សព្វា អភិជានំ តថាគតោ** សេចក្តីថា តថាគតដឹងក្រៃលែងនូវវិញ្ញាណដ្ឋិតិទាំងពួងយ៉ាងនេះថា វិញ្ញាណដ្ឋិតិ ៤ ដោយអំណាចនៃអភិសង្ខារ វិញ្ញាណដ្ឋិតិ ៧ ដោយអំណាចនៃបដិសន្ធិ ។ បទថា **តិដ្ឋន្តមេនំ ជានាតិ** បានដល់ រមែងស្គាល់បុគ្គលនោះ ដែលតាំងនៅដោយអំណាចនៃអភិសង្ខារ គឺកម្មថា បុគ្គលនេះនឹងមានគតិយ៉ាងនេះ ដូច្នេះ ។ បទថា **វិមុត្តំ**

បានដល់ ដែលបង្អោនទៅហើយ ក្នុងអាកិញ្ចញ្ញាយតនសមាបត្តិជាដើម ។ បទថា **តប្បរាយណំ** បានដល់ សម្រេចដោយសមាបត្តិនោះ ។

[ ៤៧ ] បទថា **វិញ្ញាណដ្ឋិតិយោ** សេចក្តីថា ទីតាំងនៃបដិសន្ធិ-វិញ្ញាណ គឺសវិញ្ញាណកក្ខន្ធនោះឯង ។ ក្នុងបទទាំងនោះ បទថា **សេយ្យថាបិ** ជានិបាត ចុះក្នុងអត្ថសម្តែងឧបមា អធិប្បាយថា ដូចពួកមនុស្ស ។ ពិតហើយ មនុស្សជាច្រើនក្នុងចក្រវាល មិនមានប្រមាណ រមែងមិនមានមនុស្ស ២ នាក់ ដែលដូចគ្នាតែមួយដោយពណ៌សម្បុរ និងទ្រង់ទ្រាយជាដើម ។ មនុស្សពួកខ្លះ ជាកូនភ្លោះមានពណ៌សម្បុរ ឬទ្រង់ទ្រាយដូចគ្នា មនុស្សទាំងនោះ ក៏មិនដូចគ្នា ដោយការសម្លឹងមើល ការក្រឡេកមើលជាដើម ។ ព្រោះហេតុនោះ ទើបលោកពោលថា **នានត្តកាយា** ។ ឯបដិសន្ធិវិញ្ញាណនៃសត្វទាំងនោះ ជាតិហេតុកៈខ្លះ ទុហេតុកៈខ្លះ អហេតុកៈខ្លះ ព្រោះហេតុនោះ ទើបលោកពោលថា **នានត្តសញ្ញិនោ** ។ បទថា **ឯកច្ចេ ច ទេវា** បានដល់ ទេវតាជាន់កាមាវចរ ៦ ជាន់ ។ ពិតហើយ បណ្តាទេវតាទាំងនោះ ទេវតាពួកខ្លះមានកាយខៀវ ពួកខ្លះ មានសម្បុរលឿងជាដើម តែសញ្ញារបស់ទេវតាទាំងនោះ ជាតិហេតុកៈខ្លះ ទុហេតុកៈខ្លះ ជាអហេតុកៈមិនមាន ។ បទថា **ឯកច្ចេ ច វិនិបាតិកា** បានដល់ វេមានិកប្រេតដទៃ ផុតចាកអបាយ ៤ មានយក្ខិនីដែលជាមាតារបស់បុនព្វសុ យក្ខិនីដែលជាមាតារបស់បិយង្ករៈ យក្ខិនីដែលជាមិត្តរបស់បុស្សៈ អ្នកត្រេកអរក្នុងធម៌ជាដើម ។ រាងកាយនៃវេមានិកប្រេតទាំងនោះ ផ្សេងគ្នាដោយពណ៌ មានពណ៌ស ពណ៌ខ្មៅ ពណ៌មាស និងពណ៌

និលជាដើម ដោយលក្ខណៈ មានស្គម ធាត់ ទាប ខ្ពស់ សូម្បីសញ្ញា ក៏ផ្សេងគ្នាដោយអំណាចនៃតិហេតុកៈ ទុហេតុកៈ និងអហេតុកៈ ដូចរបស់មនុស្សទាំងឡាយ ។ តែវេមានិកប្រេតទាំងនោះ មិនមានសក្តិច្រើនដូចពួកទេវតា មានសក្តិតិច ដូចអ្នកក្រីក្រ រករបស់ស៊ី និងគ្រឿងស្លៀកដណ្តប់បានលំបាក ត្រូវទុក្ខបៀតបៀន ។ ពួកខ្លះ បានទទួលទុក្ខខាងរនោច ទទួលសុខខាងខ្នើត ព្រោះដូច្នោះ ទើបលោកហៅថា វិនិបាតិកៈ ព្រោះធ្លាក់ទៅចាកការសន្សំសេចក្តីសុខ ។ តែវេមានិកប្រេតដែលជាតិហេតុកៈ រមែងជាអ្នកសម្រេចធម៌បាន ដូចការសម្រេចធម៌របស់យក្ខិនីដែលជាមាតារបស់បិយង្ករៈជាដើម ។ បទថា **ព្រហ្មកាយិកា** បានដល់ ព្រហ្មបារិសជ្ជ ព្រហ្មបុរោហិត និងមហាព្រហ្ម ។ បទថា **បឋមាភិនិព្វត្តា** បានដល់ ពួកព្រហ្មទាំងអស់នោះកើតដោយបឋមជ្ឈាន ។ តែព្រហ្មបារិសជ្ជ កើតដោយបរិត្តជ្ឈាន ព្រហ្មបុរោហិត កើតដោយមជ្ឈិមជ្ឈាន តែកាយរបស់ព្រហ្មបុរោហិតនោះ មានរស្មីផ្សាយចេញទៅច្រើនជាង ។ មហាព្រហ្មកើតដោយបណីតជ្ឈាន តែកាយរបស់មហាព្រហ្ម មានរស្មីផ្សាយចេញទៅក្រៃលែងជាងព្រហ្មទាំងនោះ ។ ព្រោះហេតុនោះ ទើបព្រហ្មទាំងនោះ លោកពោលថា **នានត្តកាយា ឯកត្តសញ្ញិនោ** ព្រោះមានកាយផ្សេងគ្នា មានសញ្ញាតែមួយ ដោយអំណាចបឋមជ្ឈាន ។ សត្វទាំងឡាយក្នុងអបាយ ៤ ក៏ដូចទេវតាទាំងនោះ ។ ព្រោះក្នុងនរក សត្វនរកពួកខ្លះមានរាងកាយ ១ គាវុត ពួកខ្លះកន្លះយោជន៍ ពួកខ្លះ ៣ គាវុត ឯកាយរបស់ទេវទត្ត មានកម្ពស់ ១០០ យោជន៍ ។ ក្នុងតិរច្ឆាន

ពួកខ្លះក៏តូច ពួកខ្លះក៏ធំ ។ ក្នុងបិត្តិវិស័យពួកខ្លះ ៦០ ហត្ថ ពួកខ្លះ ៨០ ហត្ថ ពួកខ្លះពណ៌សម្បុរល្អ ពួកខ្លះមានពណ៌សម្បុរអន់ ។ កាឡកញ្ជិកាសុរក៏យ៉ាងនោះ ក្នុងសត្វទាំងនេះ ទីឃបិដ្ឋិកប្រេត គឺប្រេតមានខ្នងវែង កម្ពស់ដល់ ៦០ យោជន៍ តែសញ្ញារបស់សត្វនរកទាំងអស់ ជាអកុសលវិបាក ជាអហេតុកៈ ដោយប្រការដូច្នេះ សូម្បីសត្វក្នុងអបាយ ក៏ហៅបានថា **នានត្ត-កាយា ឯកត្តសញ្ញិនោ** ។ បទថា **អាភស្សរា** ឈ្មោះថា អាភស្សរៈ ព្រោះមានរស្មីចេញពីសរីរៈរបស់ទេវតាទាំងនោះ រមែងស្រុះចេញអំពីសរីរៈរបស់ព្រហ្មទាំងនោះ ដូចដាច់ធ្លាក់ចុះមក ដូចអណ្តាតគប់ភ្លើង ដូច្នោះ ។ បណ្តា អាភស្សរទេវតាទាំងនោះ ទេវតាដែលកើតឡើង ព្រោះចម្រើនឈាន ២ គឺបរិត្តទុតិយជ្ឈាន និងបរិត្តតតិយជ្ឈាន ក្នុងបញ្ចកន័យ ឈ្មោះថា បរិត្តាភា ។ ទេវតាដែលកើតឡើង ព្រោះចម្រើនមជ្ឈិមជ្ឈាន ឈ្មោះថា អប្បមាណាភា ។ ទេវតាដែលកើតឡើង ព្រោះចម្រើនបណីតជ្ឈាន ឈ្មោះថា អាភស្សរ ។ តែក្នុងទីនេះ សំដៅយកទេវតាទាំងអស់ ដោយការកំណត់យ៉ាងឧក្រិដ្ឋ ។ ព្រោះថា កាយរបស់ទេវតាទាំងនោះ មានរស្មីផ្សាយចេញដូចគ្នា តែសញ្ញាផ្សេងៗគ្នា មិនមានវិតក្ក មានត្រឹមវិចារៈ និងមិនមានទាំងវិតក្កទាំងវិចារៈ ។ បទថា **សុភកិណ្ហា** បានដល់ ទេវតាដែលពេញទៅដោយការស្អាត អធិប្បាយថា មានរស្មីដូចគ្នាតែមួយ ដោយពណ៌នៃរស្មីចេញអំពីកាយស្អាត ព្រោះរស្មីរបស់ទេវតាទាំងនោះដាច់ហើយ មិនដូចរស្មីទេវតាអាភស្សរទេពទាំងឡាយ ។ ទេវតាបរិត្តសុភា អប្បមាណសុភា

សុភកិណ្ហា កើតដោយអំណាចនៃឈានដែលជាបរិត្តជ្ឈាន មជ្ឈិមជ្ឈាន និង បណីតជ្ឈាន នៃតតិយជ្ឈាន ក្នុងចតុក្កន័យ នៃចតុត្ថជ្ឈាន ក្នុងបញ្ចកន័យ ។ ទេវតាទាំងអស់នោះ គប្បីជ្រាបថាជា **ឯកត្តកាយា ឯកត្តសញ្ញិនោ** ដោយ ចតុត្ថជ្ឈានសញ្ញា សូម្បីពួកទេវតាវេហប្ផលា ក៏រមែងសេពវិញ្ញាណដ្ឋិតិទី ៤ ។ អសញ្ញសត្វ មិនសង្គ្រោះចូលក្នុងទីនេះ ព្រោះមិនមានវិញ្ញាណ តែសង្គ្រោះ ចូលក្នុងសត្តាវាស ។ ទេវតាសុទ្ធាវាសទាំងអស់ តាំងនៅក្នុងចំណែកវិវដ្តៈ មិនប្រព្រឹត្តទៅសព្វកាលទាំងអស់ មិនកើតក្នុងលោក ក្នុងកាលដែលសូន្យ ចាកព្រះពុទ្ធ មួយសែនកប្បខ្លះ មួយអសង្ខេយ្យកប្បខ្លះ កាលព្រះពុទ្ធ ទាំងឡាយកើតឡើងក្នុងរវាង ១៦០០០ កប្ប ទើបទេវតាទាំងនោះកើត ដូច គ្មានឹងព្រះពន្លាសម្រាប់ស្នាក់អាស្រ័យរបស់ព្រះមានព្រះភាគ ដែលញុំាងធម្ម-ចក្រឲ្យប្រព្រឹត្តទៅ ។ ព្រោះហេតុនោះ ទើបទេវតាទាំងនោះ មិនសង្គ្រោះចូល ក្នុងវិញ្ញាណដ្ឋិតិ មិនសង្គ្រោះចូលក្នុងសត្តាវាស ។

ឯព្រះមហាសីវត្ថេរពោលថា សូម្បីទេវសុទ្ធាវាសទាំងឡាយ ក៏សង្គ្រោះ ចូលក្នុងវិញ្ញាណដ្ឋិតិទី ៤ និងសត្តាវាសទី ៤ ដោយព្រះសូត្រ ( មហា-សីហនាទសូត្រ ) នេះថា ម្នាលសារីបុត្ត អាវាសណាដែលតថាគតមិនធ្លាប់ នៅហើយ ដោយកាលវែងនេះ វៀរលែងតែសុទ្ធាវាសទេវលោកទាំងឡាយ ចេញ អាវាសនុ៎ះឯង បុគ្គលមិនងាយរកបានទេ ដូច្នេះ ។ ពាក្យនោះ ត្រឹម ត្រូវ ព្រោះមិនជំទាស់នឹងសូត្រនេះ ។

គប្បីជ្រាបសេចក្តីក្នុងបទនេះថា **សព្វសោ រូបសញ្ញានំ សមតិក្កមា**

ដូចតទៅ បទថា **សព្វសោ** បានដល់ ដោយអាការទាំងពួង អធិប្បាយថា នៃរូបសញ្ញាមិនមានចំណែកសេសសល់ទាំងពួង ។ បទថា **រូបសញ្ញានំ** បានដល់ នៃរូបាវចរជ្ឈាន ដូចដែលពោលហើយ ដោយសំដៅដល់សញ្ញាជាធំ និងអារម្មណ៍នៃរូបាវចរជ្ឈាននោះ ។ ពិតហើយ សូម្បីរូបាវចរជ្ឈាន ក៏ហៅថា **រូប** ដូចក្នុងយោគជាដើមថា **រូបី រូបានិ បស្សតិ** បាននូវរូបជ្ឈាន ឃើញនូវពួករូប ដូច្នេះ ។ សូម្បីអារម្មណ៍នៃរូបាវចរជ្ឈាននោះ លោកក៏ពោលថា **រូប** ដូចក្នុងប្រយោគជាដើមថា **ពហិទ្ធា រូបានិ បស្សតិ បរិត្តានិ សុវណ្ណ-ទុព្វណ្ណានិ** ឃើញនូវពួករូបខាងក្រៅ ជារូបមានប្រមាណតូច មានពណ៌ល្អ មានពណ៌អាក្រក់ ដូច្នេះ ព្រោះហេតុនោះ ទើបក្នុងទីនេះ ពាក្យថា **រូប-សញ្ញានំ** នេះ ជាឈ្មោះរបស់រូបាវចរជ្ឈាន ដោយបំណងដល់សញ្ញាជាធំយ៉ាងនេះថា ការសម្គាល់ក្នុងរូប ឈ្មោះថា រូបសញ្ញា ឬឈ្មោះថា **រូបសញ្ញា** ព្រោះមានរូបជាសញ្ញា ។ លោកពោលថា **រូប** ជាឈ្មោះរបស់ឈាននោះ ។ គប្បីជ្រាបថា បទថា **រូបសញ្ញានំ** នេះ ជាឈ្មោះនៃអារម្មណ៍របស់រូបជ្ឈាននោះ មានបឋវីកសិណជាដើម ។ បទថា **សមតិក្កមា** បានដល់ ព្រោះប្រាសចាកតម្រេក និងព្រោះរម្លត់ លោកអធិប្បាយដូចម្តេច លោកអធិប្បាយថា ព្រះយោគាវចរចូលដល់អាកាសានញ្ចាយតនៈ តាំងនៅ ព្រោះវិរាគៈជាហេតុ ព្រោះនិរោធជាហេតុ ព្រោះប្រាសចាករាគៈ ព្រោះរម្លត់រូបសញ្ញា ដែលបានដល់ឈាន ១៥ ដោយអំណាចនៃកុសលវិបាក និងកិរិយាក្តី រូប-សញ្ញា ដែលបានដល់អារម្មណ៍ ៨ ដោយអំណាចនៃបឋវីកសិណជាដើមទាំង

នេះក្តី រូបសញ្ញាដ៏សេសដោយអាការទាំងពួងក្តី ។ ព្រោះថា ព្រះយោគាវចរ ដែលមិនទាន់ឈានកន្លងរូបសញ្ញា ដោយប្រការទាំងពួង មិនអាចចូលដល់ អាកាសានញ្ចាយតនជ្ឈាននោះ តាំងនៅបាន ក្នុងពាក្យនោះ ព្រោះកាលមិន ទាន់ប្រាសចាកតម្រេកក្នុងអារម្មណ៍ ទើបមិនជាការឈានកន្លងសញ្ញា ម្យ៉ាង ទៀត កាលឈានកន្លងសញ្ញា ក៏ជាការដែលឈានកន្លងអារម្មណ៍ផងដូចគ្នា ដូច្នោះ ទើបលោកមិនពោលការឈានកន្លងអារម្មណ៍ ហើយពោលការ ឈានកន្លងសញ្ញាតែម្យ៉ាង ក្នុងវិភង្គយ៉ាងនេះថា រូបសញ្ញា តើដូចម្តេច ។ ការសម្គាល់ អាការសម្គាល់ ភាពនៃការសម្គាល់ណា របស់បុគ្គលអ្នកចូល កាន់រូបសមាបត្តិក្តី របស់បុគ្គលអ្នកប្រកប ( ដោយរូបសមាបត្តិ ) ក្តី របស់បុគ្គលអ្នកនៅជាសុខក្នុងបច្ចុប្បន្ន ( ដោយរូបាវចរសមាបត្តិ ) ក្តី នេះ ហៅថា រូបសញ្ញា បុគ្គលកន្លង ប្រព្រឹត្តកន្លង ឈានកន្លង នូវរូបសញ្ញា ទាំងនេះ ព្រោះហេតុនោះ ទើបពោលថា ព្រោះកន្លងរូបសញ្ញា ដោយសព្វ គ្រប់ ដូច្នេះ ។ ព្រោះសមាបត្តិទាំងនេះ ដែលព្រះយោគាវចរគប្បីសម្រេច បាន ដោយការឈានកន្លងអារម្មណ៍ មិនគប្បីដល់បានក្នុងអារម្មណ៍មួយ ប៉ុណ្ណោះ ដូចការសម្រេចរូបជ្ឈាន មានបឋមជ្ឈានជាដើម ដូច្នោះ គប្បីជ្រាប ថា លោកពណ៌នាសេចក្តីនេះ ដោយអំណាចការឈានកន្លងអារម្មណ៍ ។

បទថា **បដិឃសញ្ញានំ អត្ថង្គមា** សេចក្តីថា សញ្ញាដែលកើតឡើង ព្រោះការប៉ះខ្ទប់នៃវត្ថុ មានចក្ខុជាដើម និងនៃអារម្មណ៍ មានរូបជាដើម ឈ្មោះ ថា **បដិសញ្ញា** ពាក្យនេះ ជាឈ្មោះរបស់រូបសញ្ញាជាដើម ដូចព្រះមាន

ព្រះភាគត្រាស់ថា បណ្ដាធម៌ទាំងនោះ បដិឃសញ្ញា តើដូចម្ដេច ។ រូបសញ្ញា សទ្ទសញ្ញា គន្ធសញ្ញា រសសញ្ញា ផោដ្ឋព្វសញ្ញា នេះហៅថា បដិឃសញ្ញា ដូច្នេះ ។ ព្រោះរលត់ ព្រោះលះ ព្រោះមិនកើតឡើង នៃបដិឃសញ្ញា ១០ ដោយប្រការទាំងពួងនោះ គឺសញ្ញាខាងកុសលវិបាក ៥ អកុសលវិបាក ៥ លោកពោលថា ធ្វើមិនឲ្យប្រព្រឹត្តទៅបាន ។

បដិឃសញ្ញាទាំងនេះ រមែងមិនមានដល់បុគ្គលដែលចូលដល់បឋមជ្ឈាន ជាដើមដោយពិត ព្រោះក្នុងសម័យនោះ ចិត្តរមែងមិនប្រព្រឹត្តទៅដោយ អំណាចនៃទ្វារ ៥ តែកាលបើដូច្នោះ គប្បីជ្រាបការពោលដល់បដិឃសញ្ញា ទាំងនោះទុកក្នុងទីនេះ ដោយអំណាចនៃការសរសើរឈាននេះ ក៏ដើម្បីឲ្យ កើតឧស្សាហៈក្នុងឈាននេះ ដូចការពោលដល់សុខ និងទុក្ខ ដែលលះបាន ហើយក្នុងឈានដទៃទុកក្នុងចតុត្ថជ្ឈាន និងដូចការពោលដល់សក្កាយទិដ្ឋិ ជាដើម ដែលលះបានហើយក្នុងមគ្គដទៃ ទុកក្នុងមគ្គទី ៣ ដូច្នោះ ។

ម្យ៉ាងទៀត បដិឃសញ្ញាទាំងនោះ រមែងមិនមានដល់បុគ្គលដែលចូល រូបាវចរសមាបត្តិក៏ពិត តែមិនមែនមិនមាន ព្រោះលះហើយក៏មិនមែន ។ ពិត ហើយ រូបាវចរភាវនា រមែងមិនប្រព្រឹត្តទៅ ព្រោះប្រាសចាកការត្រេកអរ ក្នុងរូប ហើយការប្រព្រឹត្តទៅនៃរូបាវចរភាវនានេះ ទាក់ទងដោយរូប តែ ភាវនានេះ រមែងប្រព្រឹត្តទៅ ព្រោះប្រាសចាកការត្រេកអរក្នុងរូប ព្រោះ ដូច្នោះ គួរនឹងពោលថា លះនូវបដិឃសញ្ញាបានក្នុងឈាននេះ ។ មិនត្រឹមតែ គួរពោលតែម្យ៉ាង គួរទ្រទ្រង់ទុកយ៉ាងនេះ ដោយចំណែកមួយពិត ។ ព្រោះ

លះបង់នូវសញ្ញាទាំងនោះមិនទាន់បានមុនអំពីនេះនោះឯង ទើបព្រះមានព្រះភាគត្រាស់ ( ក្នុងអង្គុត្តរនិកាយ ទសកនិបាត ) ថា សំឡេងជាបន្លារបស់បឋមជ្ឈាន ។ ក្នុងទីនេះ លោកពោលថា អរូបសមាបត្តិទាំងឡាយ មិនញាប់ញ័រ និងពោលថា ជាការរួចផុតយ៉ាងស្ងប់ ព្រោះលះបង់សញ្ញាបានហើយ អាឡារតាបសកាឡាមគោត្រ ចូលអរូបសមាបត្តិ មិនបានឃើញ និងមិនបានឮសំឡេងរទេះ ៥០០ បរឆ្លងទៅ ។

បទថា **នានត្តសញ្ញានំ អមនសិការា** សេចក្តីថា សញ្ញាដែលប្រព្រឹត្តទៅហើយ ក្នុងអារម្មណ៍ផ្សេងគ្នា ឬសញ្ញាផ្សេងគ្នា ។ ព្រោះសញ្ញាទាំងនេះ ព្រះមានព្រះភាគត្រាស់ចែកក្នុងវិភង្គយ៉ាងនេះថា បណ្តាធម៌ទាំងនោះនានត្តសញ្ញា តើដូចម្តេច ។ ការសម្គាល់ អាការសម្គាល់ ភាពនៃការសម្គាល់ណា របស់បុគ្គលអ្នកមិនចូលកាន់ ( រូបសមាបត្តិ ) ជាអ្នកព្រមព្រៀងដោយមនោធាតុក្តី ព្រមព្រៀងដោយមនោវិញ្ញាណធាតុក្តី នេះហៅថានានត្តសញ្ញា ដូច្នេះ ។ នានត្តសញ្ញានេះ លោកបំណងយកក្នុងទីនេះ ។ សញ្ញាដែលសង្គ្រោះចូលក្នុងមនោធាតុ និងមនោវិញ្ញាណធាតុរបស់បុគ្គលមិនចូលសមាបត្តិ រមែងប្រព្រឹត្តទៅក្នុងអារម្មណ៍ផ្សេងគ្នា សភាវៈផ្សេងគ្នា មានរូប និងសំឡេងជាដើម ។ម្យ៉ាងទៀត ព្រោះសញ្ញា ៤៤ នេះ គឺសញ្ញាក្នុងកាមាវចរកុសល ៨ សញ្ញាក្នុងអកុសល ១២ សញ្ញាក្នុងកាមាវចរកុសល-វិបាក ១១ សញ្ញាក្នុងអកុសលវិបាក ២ សញ្ញាក្នុងកាមាវចរកិរិយា ១១ មានសេចក្តីផ្សេងគ្នា មានសភាវៈផ្សេងគ្នា មិនដូចគ្នានិងគ្នា ដូច្នោះ ទើប

លោកពោលថា នានត្តសញ្ញា ។ ព្រោះមិនដាក់ចិត្ត ព្រោះមិនគិតដល់ ព្រោះមិននាំមក ព្រោះមិនពិចារណានូវនានត្តសញ្ញាទាំងនោះ ដោយប្រការទាំងពួង ។ មានអធិប្បាយថា ព្រោះមិនគិតដល់ ព្រោះមិនដាក់ចិត្ត ព្រោះមិនពិចារណានានត្តសញ្ញាទាំងនោះ ។ មួយវិញទៀត ព្រោះក្នុងសញ្ញា ៣ នេះ រូបសញ្ញា និងបដិឃសញ្ញាខាងដើម រមែងមិនមានក្នុងភពដែលកើតដោយឈាននេះ នឹងពោលថ្វីដល់ក្នុងកាលដែលចូលឈាននេះក្នុងភពនោះ ដូច្នោះទើបលោកពោលដល់ ការមិនមាននៃសញ្ញាទាំងនោះដោយចំណែក ២ គឺការឈានកន្លង ១ ការរម្ងត់ ១ ។ ក្នុងនានត្តសញ្ញាទាំងឡាយ ព្រោះសញ្ញា ២៧ នេះ គឺសញ្ញាក្នុងកាមាវចរកុសល ៨ សញ្ញាក្នុងកិរិយា ៩ សញ្ញាក្នុងអកុសល ១០ រមែងមានក្នុងភពដែលកើតឡើងហើយដោយឈាននេះ ដូច្នោះគប្បីជ្រាបថា លោកពោលថា ព្រោះមិនធ្វើទុកក្នុងចិត្តនូវនានត្តសញ្ញា ។ ពិតហើយ ក្នុងសេចក្តីនេះ ព្រះយោគាវចរចូលឈាននេះ ឈ្មោះថា ចូលព្រោះមិនមនសិការនានត្តសញ្ញាទាំងនោះ តែកាលមនសិការដល់នានត្តសញ្ញាទាំងនោះ រមែងជាអ្នកមិនចូលសមាបត្តិ ព្រោះហេតុនោះ ក្នុងទីនេះ ពោលដោយសង្ខេប គប្បីជ្រាបថា លោកពោលដល់ការលះរូបាវចរធម៌ កំណត់ដោយពាក្យនេះថា ព្រោះប្រព្រឹត្តកន្លងរូបសញ្ញា លោកពោលដល់ការលះនិងការមិនមនសិការ ចិត្ត និងចេតសិកដែលជាកាមាវចរទាំងអស់ ដោយពាក្យនេះថា ព្រោះដល់នូវការវិនាសនៃបដិឃសញ្ញា មិនធ្វើទុកក្នុងចិត្តនូវនានត្តសញ្ញា ។

ព្រះមានព្រះភាគត្រាស់ដល់គុណ របស់អាកាសានញ្ចាយតនសមាបត្តិ ដោយ ៣ បទ គឺដោយការឈានកន្លងរូបសញ្ញា ១៥ ដោយការរម្ងត់បដិឃសញ្ញា ១០ ដោយមិនមនសិការនានត្តសញ្ញា ៤៤ ដោយប្រការដូច្នេះ ។ បើសួរថា ព្រោះហេតុអ្វីទើបត្រាស់ ឆ្លើយថា ដើម្បីឲ្យអ្នកស្តាប់កើតឧស្សាហ៍ និងដើម្បីលួងលោមចិត្តអ្នកស្តាប់ ។ ព្រោះថា ជនពួកខ្លះ មិនជាអ្នកឈ្លាសគប្បីពោលថា ព្រះសាស្តាត្រាស់ថា អ្នកទាំងឡាយ ចូរធ្វើអាកាសានញ្ចាយតនសមាបត្តិឲ្យកើតចុះ អ្វីហ្ន៎ ជាប្រយោជន៍ ជាអានិសង្ស នៃការធ្វើសមាត្តិនោះឲ្យកើត ព្រះមានព្រះភាគទ្រង់បំណងថា ជនទាំងឡាយនោះ កុំបីពោលយ៉ាងនេះ ទើបត្រាស់ដល់គុណរបស់សមាបត្តិ ដោយអាការទាំងនេះ ពិតហើយ ជនទាំងនោះ កាលស្តាប់ព្រះតម្រាស់នោះហើយ ទើបគិតយ៉ាងនេះថា បានឮថា សមាបត្តិនេះ ស្ងប់យ៉ាងនេះ ប្រណីតយ៉ាងនេះ អាត្មាអញនឹងធ្វើសមាបត្តិនោះឲ្យកើត ។ បន្ទាប់អំពីនោះ ជនទាំងឡាយក៏នឹងធ្វើឧស្សាហៈ ដើម្បីឲ្យសមាបត្តិនោះកើត ។

ម្យ៉ាងទៀត ដើម្បីលួងលោមចិត្ត ទើបទ្រង់ត្រាស់ដល់គុណរបស់សមាបត្តិនោះដល់ជនទាំងនោះ ដូចឈ្មួញវិសកណ្តកៈ ឈ្មួញវិសកណ្តកៈ ជាឈ្មោះរបស់អ្នកលក់ស្ករអំពៅ ។

បានឮថា ឈ្មួញនោះយករទេះផ្ទុកស្ករអំពៅ ស្ករក្រាម ទៅកាន់ជាយដែនហើយឃោសនាថា អ្នកទាំងឡាយ ចូរទិញវិសកណ្ឌកៈ អ្នកទាំងឡាយ ចូរទិញវិសកណ្ឌកៈចុះ ។ អ្នកស្រុកបានស្តាប់ដូច្នេះហើយ គិតគ្នាថា ធម្មតាថ្នាំ

ពិស មានពិសពន្លឹក អ្នកណាបរិភោគចូលទៅ អ្នកនោះនឹងស្លាប់ សូម្បីកណ្តក: ( បន្លា ) មុតហើយ ក៏ឲ្យស្លាប់បាន ឈ្មួញឃោសនាវត្ថុដែលឃោរឃៅ អានិសង្សអ្វីនឹងមានក្នុងវត្ថុនេះ ទើបបិទទ្វារផ្ទះ នាំកូនគេចទៅ ។ ឈ្មួញឃើញដូច្នោះ គិតថា អ្នកស្រុកទាំងនេះ មិនឈ្លាសក្នុងវោហារ ណ្ហើយចុះ អញនឹងឲ្យគេទិញដោយឧបាយ ទើបឃោសនាថា អ្នកទាំងឡាយ ចូរទិញរបស់ផ្អែម អ្នកទាំងឡាយ ចូរទិញរបស់ផ្អែម អ្នកនឹងបានទឹកអំពៅ ស្ករអំពៅ ស្ករក្រាម ក្នុងតម្លៃថោក អ្នកនឹងយកមាសកចាស់ កហាបណៈចាស់ជាដើម មកទិញក៏បាន ។ អ្នកស្រុកបានស្តាប់ដូច្នោះហើយ នាំគ្នាត្រេកអរនាំគ្នាចេញទៅទិញតាមតម្លៃជាច្រើន ។

ក្នុងពាក្យទាំងនោះ មានឧបមាដូច្នេះថា ព្រះតម្រាស់របស់ព្រះមានព្រះភាគថា អ្នកទាំងឡាយ ចូរធ្វើអាកាសានញ្ចាយតនសមាបត្តិឲ្យកើតឡើង ដូចការឃោសនារបស់ឈ្មួញថា អ្នកទាំងឡាយ ចូរទិញវិសកណ្តក:ចុះ ។ ការដែលព្រះមានព្រះភាគត្រាស់ថា អ្នកទាំងឡាយ ចូរធ្វើអាកាសានញ្ចាយតនៈឲ្យកើតចុះ អ្នកស្តាប់គិតថា អ្វីហ្ន៎ ជាអានិសង្សក្នុងអាកាសានញ្ចាយតនៈនេះ ពួកយើងមិនស្គាល់គុណរបស់អាកាសានញ្ចាយតនៈនោះឡើយ ដូចអ្នកស្រុកគិតថា ឈ្មួញឃោសនាវត្ថុដែលគ្រោតគ្រាត អានិសង្សអ្វី នឹងមានក្នុងវត្ថុនេះ ការប្រកាសអានិសង្ស មានការឈានកន្លងរូបសញ្ញាជាដើមរបស់ព្រះមានព្រះភាគ ដូចពាក្យឃោសនារបស់ឈ្មួញនោះ មានជាដើមថា អ្នកទាំងឡាយ ចូរទិញរបស់ផ្អែម អ្នកទាំងឡាយ ចូរទិញរបស់ផ្អែមចុះ ជន

ទាំងឡាយបាននូវការល្អលោមចិត្តដោយអានិសង្សនេះហើយ នឹងធ្វើឧស្សាហ៍ធំ ហើយញុំាងសមាបត្តិនេះឲ្យកើត ដូចអ្នកស្រុកទាំងនោះ កាលស្តាប់ទេសនាយ៉ាងនេះហើយ ក៏នាំគ្នាទិញស្ករអំពៅឲ្យតម្លៃជាច្រើន ។ ព្រះមានព្រះភាគត្រាស់ដើម្បីឲ្យកើតឧស្សាហ៍ និងដើម្បីល្អលោមចិត្ត ដោយប្រការដូច្នេះ ។

គប្បីជ្រាបវិនិច្ឆ័យក្នុងបទនេះថា **អាកាសានញ្ចាយតនូបគា** ជាដើមដូចតទៅ ឈ្មោះថា **អនន្ត** ព្រោះអាកាសមិនមានទីបំផុត ។ អាកាសមិនមានទីបំផុត ឈ្មោះថា **អាកាសានន្ត** ។ អាកាសានន្តនោះឯង ឈ្មោះថា **អាកាសានញ្ច** ។ អាកាសានញ្ចនោះ ឈ្មោះថា ជាប្រកពកើតនៃឈានមួយអន្លើដោយសម្បយុត្តធម៌ ដោយអត្ថថា តាំងមាំដូចទេវស្ថាននៃទេវតាទាំងឡាយ ព្រោះហេតុនោះ ទើបឈ្មោះថា **អាកាសានញ្ចាយតន** ។ ពាក្យនេះ ជាឈ្មោះរបស់កសិណុគ្ឃាដិមាកាស គឺអាកាសដែលបើកកសិណហើយ ។ សត្វទាំងឡាយញុំាងឈានឲ្យកើតក្នុងអាកាសានញ្ចាយតនៈនោះហើយ ចូលដល់អាកាសានញ្ចាយតនកព ដោយអំណាចនៃបដិសន្ធិ ឈ្មោះថា ចូលអាកាសានញ្ចាយតនជ្ឈាន ក្នុងបទបន្តទៅនេះ នឹងពណ៌នាត្រឹមតែបទដែលផ្សេងគ្នាប៉ុណ្ណោះ ។

គប្បីជ្រាបសេចក្តីក្នុងបទ **អាកាសានញ្ចាយតនំ សមតិក្កម្ម** ដូចតទៅ ឈ្មោះថា **អាកាសានញ្ច** ព្រោះជាប្រកពកើតនៃឈាននេះ ដោយអត្ថថា តាំងមាំ ដោយន័យដូចពោលមកហើយខាងដើម ព្រោះហេតុនោះ សូម្បីឈានក៏ឈ្មោះថា អាកាសានញ្ចាយតនៈ សូម្បីអារម្មណ៍ក៏ឈ្មោះថា

អាកាសានញ្ចាយតនៈ ដោយន័យដូចពោលហើយនោះឯង ដោយប្រការដូច្នេះ គប្បីជ្រាបថា ព្រោះឈានកន្លងសភាវៈទាំងពីរនោះ គឺឈាន និងអារម្មណ៍ ដោយមិនធ្វើឲ្យប្រព្រឹត្តទៅ និងដោយមិនដាក់ចិត្ត ព្រោះគួរចូលដល់វិញ្ញាណញ្ចាយតនៈនេះ ហេតុនោះ ទើបលោកធ្វើទាំង ២ យ៉ាងនេះឲ្យជារបស់តែមួយ ហើយពោលពាក្យនេះថា កន្លងអាកាសានញ្ចាយតនជ្ឈាន ។

ម្យ៉ាងទៀត គប្បីជ្រាបសេចក្តីក្នុងបទ **វិញ្ញាណញ្ចាយតនូបគា** នេះតទៅ ឈ្មោះថា **អនន្ត** ព្រោះមានវិញ្ញាណមិនមានទីបំផុត ដោយអំណាចនៃការគួរមនសិការមិនមានទីបំផុត ។ អនន្តនោះឯង ឈ្មោះថា **អានញ្ចំ** ។ វិញ្ញាណមិនមានទីបំផុត លោកមិនពោលថា **វិញ្ញាណញ្ចំ** តែពោលថា **វិញ្ញានញ្ចំ** ។ នេះជា **រុឡ្ហិ** សព្ទ គឺសព្ទរត់មាត់ក្នុងទីនេះ ។ វិញ្ញាណញ្ចនោះឯង ឈ្មោះថា ជាប្រកពកើត ព្រោះអត្ថថា តាំងមាំ ព្រោះហេតុនោះ ទើបឈ្មោះថា វិញ្ញាណញ្ចាយតនៈ សត្វទាំងឡាយ ញុំាងឈានឲ្យកើតក្នុងវិញ្ញាណញ្ចាយតនៈនោះហើយ ចូលដល់វិញ្ញាណញ្ចាយតនកព ព្រោះហេតុនោះ ទើបឈ្មោះថា **វិញ្ញាណញ្ចាយតនូបគា** ។

ក្នុងបទនេះថា **វិញ្ញាណញ្ចាយតនំ សមតិក្កម្ម** ក៏គប្បីជ្រាបសេចក្តីដូចតទៅ **វិញ្ញាណញ្ចំ** ព្រោះជាប្រកពកើតនៃឈាននេះ ដោយអត្ថថាតាំងមាំ ដោយន័យដូចពោលហើយ ក្នុងកាលមុននោះឯង ព្រោះហេតុនោះ សូម្បីឈានក៏ឈ្មោះថា វិញ្ញាណញ្ចាយតនៈ សូម្បីអារម្មណ៍ក៏ឈ្មោះថា វិញ្ញាណញ្ចាយតនៈ ដោយន័យដូចបានពោលហើយនោះឯង ដោយប្រការ

ដូច្នេះ ។ គប្បីជ្រាបថា ព្រោះឈានកន្ទងសភាវៈទាំង ២ នោះ គឺឈាន និងអារម្មណ៍ ដោយមិនធ្វើឲ្យប្រព្រឹត្តទៅ និងដោយមិនដាក់ចិត្ត ព្រោះគួរចូលដល់អាកិញ្ចញាយតនៈនេះ ព្រោះហេតុនោះ ទើបលោកធ្វើទាំង ២ យ៉ាងនេះឲ្យជារបស់តែមួយ ហើយពោលថា **វិញ្ញាណញ្ចាយតនំ សមតិក្កម្ម** ។

ម្យ៉ាងទៀត គប្បីជ្រាបអត្ថក្នុងបទថា **អាកិញ្ចញ្ញាយតនូបគា** នេះដូចតទៅ ឈ្មោះថា **អាកិញ្ចន** ព្រោះមិនមានគ្រឿងកង្វល់ ។ លោកពោលថា មិនមានគ្រឿងកង្វល់សេសសល់ ដោយហោចសូម្បីត្រឹមតែកង្គក្ខណៈ ការមិនមានគ្រឿងកង្វល់ ឈ្មោះថា **អាកិញ្ចញ្ញ** បទនេះ ជាឈ្មោះនៃការប្រាសចាកវិញ្ញាណ ដែលមានអាកាសានញ្ចាយតនជ្ឈានជាអារម្មណ៍ ។ អាកិញ្ចញ្ញៈនោះ ជាប្រកពកើត ព្រោះអត្ថថា តាំងមាំ ព្រោះហេតុនោះ ទើបឈ្មោះថា **អាកិញ្ចញ្ញាយតន** ។ សត្វទាំងឡាយញុំាងឈានឲ្យកើតក្នុងអាកិញ្ចញ្ញាយតនៈនោះហើយ ចូលដល់អាកិញ្ចញ្ញាយតនភព ទើបឈ្មោះថា **អាកិញ្ចញ្ញាយតនូបគា** ។ បទថា **អយំ សត្តមវិញ្ញាណដ្ឋិតិ** បានដល់រមែងដឹងឋានៈទី ៧ របស់បដិសន្ធិវិញ្ញាណនេះ នេវសញ្ញានាសញ្ញាយតនជ្ឈាន និងថា មានវិញ្ញាណក៏មិនមែន មិនមានវិញ្ញាណក៏មិនមែន ព្រោះវិញ្ញាណដែលដូចគ្នានឹងសញ្ញាជាសភាពល្អិត ព្រោះហេតុនោះ ទើបលោកមិនបានពោលក្នុងវិញ្ញាណដ្ឋិតិ ។

[ ៤៨ ] បទថា **អភូតំ** បានដល់ មិនពិត មានពាក្យថា **រូបំ អត្តា** រូបជាខ្លួនជាដើម ។ ឈ្មោះថា **អតច្ឆំ** ព្រោះពាក្យនោះវិបល្លាស ។ ឈ្មោះថា

**អនត្ថសញ្ហិតំ** ព្រោះជាទីអាស្រ័យនៃទិដ្ឋិ ។ មួយវិញទៀត បទថា **អភូតំ** បាន ដល់ មិនមាន មិនកើត ។ ដូចពាក្យថា ទ្រព្យនេះ ចោរកិរិយារបស់អ្នកលួច មក ទ្រព្យនេះ មិនមានក្នុងផ្ទះរបស់អ្នក មិនមានដល់បុគ្គលដែលមិនមែន ជាចោរ ។ បទថា **អតច្ឆំ** បានដល់ មានអាការមិនពិត មានអាការដទៃ មានដោយប្រការដទៃ ។ បទថា **អនត្ថសញ្ហិតំ** បានដល់ មិនអាស្រ័យ ប្រយោជន៍ក្នុងលោកនេះ ឬប្រយោជន៍ក្នុងលោកដទៃ ។ បទថា **ន តំ តថាគតោ ព្យាករោតិ** បានដល់ ព្រះតថាគតមិនត្រាស់ថា ដែលមិននាំ សត្វចេញទៅនោះ ។ បទថា **ភូតំ តច្ឆំ អនត្ថសញ្ហិតំ** បានដល់ ជាតិរច្ឆាន-កថា មានរាជកថាជាដើម ។ បទថា **ភូតំ តច្ឆំ អត្ថសញ្ហិតំ** បានដល់ ជាពាក្យអាស្រ័យអរិយសច្ច ។ បទថា **តត្រ កាលញ្ញូ តថាគតោ ហោតិ** សេចក្តីថា ក្នុងការព្យាករណ៍លើកទី ៣ នោះ ព្រះតថាគតជាអ្នកស្គាល់កាល ដើម្បីព្យាករបញ្ហានោះ អធិប្បាយថា ព្រះតថាគតទ្រង់ដឹងកាលក្នុងការកាន់ យក កាលក្នុងការទទួលរបស់មហាជន ហើយទ្រង់ធ្វើឲ្យសមជាមួយនឹង ហេតុការណ៍ ទើបទ្រង់ព្យាករតាមសមគួរនោះឯង ។

ឈ្មោះថា **កាលវាទី** ព្រោះពោលក្នុងកាលដែលគួរ ដែលត្រឹមត្រូវ ។ ឈ្មោះថា **ភូតវាទី** ព្រោះពោលសភាវៈដែលពិត ។ ឈ្មោះថា **អត្ថវាទី** ព្រោះពោលដល់និព្វានដែលជាបរមត្ថ ។ ឈ្មោះថា **ធម្មវាទី** ព្រោះពោល ដល់មគ្គធម៌ និងផលធម៌ ។ ឈ្មោះថា **វិនយវាទី** ព្រោះពោលដល់វិន័យ មានការសង្រួមជាដើម ។

ក្នុងបទទាំងនោះ បទថា **ទិដ្ឋំ** សេចក្តីថា ឃើញអាយតនៈនោះ ដោយអាការទាំងពួងថា ឈ្មោះថា រូបារម្មណ៍ដែលមកកាន់គន្លងក្នុងចក្ខុទ្វាររបស់សត្វរាប់មិនអស់ ក្នុងលោកធាតុដែលមិនមានប្រមាណ មាន ។ រូបាយតនៈនោះដែលអ្នកប្រាជ្ញឃើញយ៉ាងនោះ ចែកដោយន័យ ៥២ ដោយវារៈ ១៣ ដោយឈ្មោះមិនមែនតិច ដោយន័យជាដើម ( ក្នុងធម្មសង្គណី ) ថា រូបជារូបាយតនៈនោះ តើដូចម្តេច ។ រូបណា គឺពណ៌អាស្រ័យមហាភូតរូបទាំង ៤ ជាវត្ថុដែលអាចឃើញបាន ប្រកបដោយការប៉ះពាល់ ជាពណ៌ខៀវ លឿងជាដើម ។ ជាធម្មជាតមានពិត មិនពិតមិនមាន ដោយអំណាចឥដ្ឋារម្មណ៍និងអនិដ្ឋារម្មណ៍ ឬដោយអំណាចការបានក្នុងរូបដែលបានឃើញ ក្នុងសំឡេងដែលបានឮ ក្នុងក្លិន រស ផោដ្ឋព្វៈដែលបានជ្រាប និងក្នុងធម្មារម្មណ៍ដែលបានដឹងច្បាស់ ។ ក្នុងសំឡេងជាដើមដែលមកកាន់គន្លង ក្នុងសោតទ្វារជាដើម ក៏ន័យនេះឯង ។

ព្រះមានព្រះភាគ ដើម្បីសម្តែងអាយតនៈច្រើនយ៉ាង ទើបត្រាស់ពាក្យថា **ទិដ្ឋំ សុតំ** ជាដើម ។ ក្នុងបទទាំងនោះ បទថា **ទិដ្ឋំ** បានដល់ រូបាយតនៈ ។ បទថា **សុតំ** បានដល់ សទ្ទាយតនៈ ។ បទថា **មុតំ** បានដល់ គន្ធាយតនៈ រសាយតនៈ ផោដ្ឋព្វាយតនៈ ព្រោះដល់ហើយ ទើបដឹងបាន ។ បទថា **វិញ្ញាតំ** បានដល់ ធម្មារម្មណ៍ មានសុខ និងទុក្ខជាដើម ។ បទថា **បត្តំ** បានដល់ បានដល់ហើយដោយស្វែងរកក្តី មិនស្វែងរកក្តី ។ បទថា **បរិយេសិតំ** បានដល់ ស្វែងរកនូវវត្ថុដែលដល់ហើយក្តី មិនដល់

ហើយក្តី ។ បទថា **អនុវិចរិតំ មនសា** បានដល់ ពិចារណាហើយដោយចិត្ត ។

ព្រះមានព្រះភាគទ្រង់សម្តែងអាយតនៈនោះ ដោយបទនេះថា **តថាគតេន អភិសម្ពុទ្ធំ** ។ រូបារម្មណ៍ណា មានជាដើមថា ពណ៌ខៀវ ពណ៌លឿង របស់លោក ព្រមទាំងទេវលោកនេះ ក្នុងលោកធាតុដែលមិនមានប្រមាណ មកកាន់គន្លងក្នុងចក្ខុទ្វារ សត្វនេះ ឃើញនូវរូបារម្មណ៍ឈ្មោះនេះ ក្នុងខណៈនេះ កើតនូវការត្រេកអរខ្លះ ទោមនស្សខ្លះ ព្រងើយៗ ខ្លះ ដោយហេតុនោះ តថាគតដឹងព្រមនូវរូបារម្មណ៍ទាំងអស់នោះ ។ ម្យ៉ាងទៀត សទ្ទារម្មណ៍ណា មានសំឡេងស្គរ សំឡេងសម្ភោររបស់មនុស្សលោក ព្រមទាំងទេវលោកនេះ ក្នុងលោកធាតុដែលមិនមានប្រមាណ រមែងមកកាន់គន្លងក្នុងសោតទ្វារ ។ គន្ធារម្មណ៍ មានជាដើមយ៉ាងនេះថា ក្លិនឫស ក្លិនសម្បក មកកាន់គន្លងក្នុងឃានទ្វារ រសារម្មណ៍ មានរសកើតអំពីឫស រសកើតអំពីដើម មកកាន់គន្លងក្នុងជិវ្ហាទ្វារ ផោដ្ឋព្វារម្មណ៍ មានបឋវីធាតុ តេជោធាតុ វាយោធាតុ មានជាដើមថា រឹង ទន់ មកកាន់គន្លងក្នុងកាយទ្វារ សត្វនេះ ពាល់ត្រូវនូវផោដ្ឋព្វារម្មណ៍ឈ្មោះនេះ ក្នុងខណៈនេះ កើតនូវការត្រេកអរខ្លះ ទោមនស្សខ្លះ ព្រងើយៗ ខ្លះ ដោយហេតុនោះ តថាគតដឹងព្រមនូវអារម្មណ៍ទាំងអស់នោះ ។ ម្យ៉ាងទៀត ធម្មារម្មណ៍ណា មានប្រភេទជាសុខ និងទុក្ខជាដើម របស់លោក ព្រមទាំងទេវលោកនេះ ក្នុងលោកធាតុប្រមាណមិនបាន មកកាន់គន្លងនៃមនោទ្វារ សត្វនេះ ដឹងច្បាស់នូវធម្មារម្មណ៍ឈ្មោះនេះ ក្នុងខណៈនេះ កើតនូវការត្រេកអរខ្លះ ព្រងើយៗ ខ្លះ តថាគតដឹងព្រមនូវធម្មារម្មណ៍

ទាំងអស់នោះ ។

ម្នាលចុន្ទ អាយតនៈណា ដែលសត្វទាំងឡាយនេះឃើញហើយ ឮហើយ ដឹងហើយ ដឹងច្បាស់ហើយ អាយតនៈនោះ ដែលតថាគតមិនឃើញហើយ មិនឮហើយ មិនដឹងហើយ មិនដឹងច្បាស់ហើយ មិនមាន ។ អាយតនៈដែលមហាជននេះស្វែងរកហើយ មិនទាន់ដល់ខ្វះមាន មិនស្វែងរកហើយ មិនទាន់ដល់ខ្វះមាន ស្វែងរកហើយដល់ខ្វះមាន មិនស្វែងរកហើយដល់ខ្វះមាន អាយតនៈទាំងអស់ តថាគត ឈ្មោះថា មិនទាន់ដល់ មិនទាន់ធ្វើឲ្យជាក់ច្បាស់ដោយញាណ មិនមាន ។ ព្រោះដូច្នោះ ទើបបណ្ឌិតហៅតថាគតថា ព្រះតថាគត ។ ព្រោះទ្រង់យាងទៅដូចសត្វលោកទៅ ទើបហៅថា តថាគត ។ តែក្នុងបាលីពោលថា **អភិសម្ពុទ្ធំ** បទនោះ មានន័យតែមួយដូចគ្នានឹង **គត** សព្ទ ។

គប្បីជ្រាបសេចក្តីនៃបទនេះថា **តថាគតោ** ក្នុងភាវៈទាំងអស់ដោយន័យនេះ ។

គប្បីជ្រាបសេចក្តីក្នុងបទនេះថា ម្នាលចុន្ទ ព្រះតថាគតត្រាស់ដឹងសម្មាសម្ពោធិញ្ញាណដ៏ក្រៃលែងក្នុងរាត្រីណា បរិនិព្វានដោយអនុបាទិសេសនិព្វានធាតុក្នុងរាត្រីណា រមែងពោលចរចា សម្តែងនូវពាក្យណា ក្នុងចន្លោះនៃការត្រាស់ដឹង និងការបរិនិព្វាននោះ របស់ទាំងអស់នោះ នៅដូចដែលមិនប្រែប្រួល ហេតុនោះ ទើបហៅថា ព្រះតថាគត ដូចតទៅនេះថា ក្នុងរាត្រីណា ព្រះមានព្រះភាគ គង់លើអបរាជិតបល្ល័ង្កនាពោធិមណ្ឌល ទ្រង់

ញាំញីមារទាំង ៣ បានហើយ ត្រាស់ដឹងនូវអនុត្តរសម្មាសម្ពោធិញ្ញាណ ក្នុងរាត្រីណា ទ្រង់បរិនិព្វានដោយអនុបាទិសេសនិព្វានធាតុក្នុងចន្លោះដើមសាល-ព្រឹក្សទាំងគូ ក្នុងចន្លោះនេះ ក្នុងកាលមានកំណត់ ៤៥ វស្សា ក្នុងបឋម-ពោធិកាលខ្លះ មជ្ឈិមពោធិកាលខ្លះ បច្ឆិមពោធិកាលខ្លះ ព្រះមានព្រះភាគត្រាស់ពាក្យប្រៀនប្រដៅ គឺសុត្តៈ គេយ្យៈ ។បេ។ វេទល្លៈ ទាំងអស់នោះមិនមានពាក្យដែលគួរតិះដៀល មិនខ្វះ មិនលើស បរិបូណ៌ដោយអាការគ្រប់យ៉ាង កម្ចាត់ការស្រវឹងដោយអំណាចរាគៈ ទោសៈ និងមោហៈ ទាំងដោយអត្ថ ទាំងដោយព្យញ្ជនៈ ក្នុងភាសិតនោះ មិនមានការខុសក្លាំងក្លាត់ សូម្បីប៉ុនចុងរោមទ្រាយ ទាំងអស់នោះពិតប្រាកដ មិនពិតមិនមានឡើយ ដូចប្រថាប់ដោយត្រាមួយ ដូចវាល់ដោយនាឡិមួយ និងដូចថ្លឹងដោយជញ្ជីងមួយ ដោយហេតុនោះ ទើបព្រះមានព្រះភាគត្រាស់ថា ម្នាលចុន្ទ ព្រះតថាគតត្រាស់ដឹងនូវសម្មាសម្ពោធិញ្ញាណដ៏ក្រៃលែង ។បេ។ របស់ទាំងអស់នោះ នៅដូចដែល មិនប្រែប្រួល ហេតុនោះ ទើបហៅថា ព្រះតថាគត ។ **គត** សព្ទក្នុងបទថា **តថាគតោ** នេះ មានសេចក្តីថា ពោល ។ ម្យ៉ាងទៀត ពាក្យពោល ឈ្មោះថា **អគទ** អធិប្បាយថា ពាក្យពោល ។ គប្បីជ្រាបការសម្រេចនៃបទ ក្នុងសេចក្តីនេះយ៉ាងនេះថា ឈ្មោះថា **តថាគតោ** ព្រោះមានព្រះតម្រាស់ពិត មិនវិបរិត ដោយផ្លាស់ **ទ** អក្ខរៈ ជា **ត** អក្ខរៈ ។

គប្បីជ្រាបសេចក្តីក្នុងបទនេះ **យថាវាទី ចុន្ទ ។បេ។ វុច្ចតិ** ដូចតទៅ ព្រះវរកាយរបស់ព្រះមានព្រះភាគ អនុលោមទៅតាមវាចា ព្រះវាចាក៏អនុលោម

ទៅតាមកាយ ព្រោះដូច្នោះ ទើបព្រះមានព្រះភាគជា **យថាវាទី តថាការី** និង **យថាការី តថាវាទី** អធិប្បាយថា ព្រះវរកាយប្រព្រឹត្តទៅដូចព្រះវាចារបស់ព្រះអង្គដែលប្រព្រឹត្តទៅហើយយ៉ាងនោះ ។ គប្បីជ្រាបបទសម្រេចក្នុងបទនេះយ៉ាងនេះថា ឈ្មោះថា **តថាគតោ** ព្រោះវាចាទៅហើយ ប្រព្រឹត្តទៅហើយ ដូចព្រះវរកាយ ។

បទថា **អភិភូ អនភិភូតោ** សេចក្តីថា ព្រះតថាគតទ្រង់គ្របសង្កត់សព្វសត្វក្នុងលោកធាតុទាំងឡាយ ដែលមិនមានប្រមាណ អស់ចំណែកទទឹងដោយធ្វើខាងលើដល់ភវគ្គព្រហ្ម ខាងក្រោមដល់អវីចីជាទីបំផុត ដោយសីលខ្វះ សមាធិខ្វះ បញ្ញាខ្វះ វិមុត្តិខ្វះ វិមុត្តិញ្ញាណទស្សនៈខ្វះ ថ្លឹង ឬប្រមាណព្រះអង្គមិនមាន ព្រះតថាគតថ្លឹងមិនបាន ប្រមាណមិនបាន ជាកំពូលជាព្រះរាជាក្រៃលែងជាងព្រះរាជា ជាទេវតាក្រៃលែងជាងទេវតា ជាសក្កៈក្រៃលែងជាងសក្កៈ ជាព្រហ្មក្រៃលែងជាងព្រហ្ម ។ បទថា **អញ្ញទត្ថុ** ជានិបាត ចុះក្នុងអត្ថថា ចំណែកមួយ ។ ឈ្មោះថា **ទសោ** ព្រោះទ្រង់ឃើញ ។ ឈ្មោះថា **វសវត្តី** ព្រោះជាអ្នកធ្វើឲ្យប្រព្រឹត្តទៅក្នុងអំណាច ។

គប្បីជ្រាបពាក្យសម្រេចក្នុងបទនោះដូច្នេះ ឈ្មោះថា **អគទោ** គឺដូចថ្នាំ ។ សេចក្តីនេះដូចម្តេច សេចក្តីថា ព្រះតថាគតមានលីលាក្នុងការសម្តែងធម៌ដែលជាប់ចិត្ត និងទ្រង់មានបុណ្យដែលបានសន្សំហើយ ដោយហេតុនោះទើបទ្រង់មានអានុភាពច្រើន ទ្រង់គ្របសង្កត់លោក ព្រមទាំងទេវលោកនៃបុគ្គលអ្នកពោលតិះដៀលទាំងអស់ ដូចគ្រូពេទ្យកម្ចាត់ពិសពស់ ដោយទិព្វ-

ឱសថ ដូច្នោះ ។ គប្បីជ្រាបថា ឈ្មោះថា **តថាគត** ព្រោះផ្លាស់ **ឧ** អក្ខរៈ ជា **ត** អក្ខរៈ មានសេចក្តីថា ព្រោះមានថ្នាំ គឺលីលានៃការសម្តែងធម៌ និងការសន្សំបុណ្យមិនវិបរិត ដោយការគ្របសង្កត់លោកទាំងអស់ ដោយប្រការដូច្នេះ ។

[ ៤៩ ] បទថា **ឥធដ្ឋញ្ញោ ជាតាតិ កម្មាភិសង្ខារវសេន** សេចក្តីថា ព្រះមានព្រះភាគទ្រង់ស្គាល់បុគ្គលដែលតាំងនៅក្នុងលោកនេះ ដោយអំណាចនៃកម្មាភិសង្ខារ គឺអបុញ្ញាភិសង្ខារ ។ បទថា **កាយស្ស ភេទា បរម្មរណា** បានដល់ ខាងមុខអំពីសេចក្តីស្លាប់ ព្រោះឧបាទិន្នកក្ខន្ធបែកធ្លាយ ។ គប្បីជ្រាបក្នុងបទជាដើមថា **អបាយំ** ដូចតទៅនេះ ឈ្មោះថា **អបាយ** ព្រោះប្រាសចាកសេចក្តីចម្រើន គឺសេចក្តីសុខ បានដល់ ការចម្រើនដុះដាល ។ ឈ្មោះថា **ទុគ្គតិ** ព្រោះប្រព្រឹត្តទៅជាទីអាស្រ័យរបស់ទុក្ខ ។ ឈ្មោះថា **វិនិបាត** ព្រោះអ្នកធ្វើកម្មអាក្រក់ រមែងធ្លាក់ទៅក្នុងទីនេះ ។ ឈ្មោះថា **និរយ** ព្រោះអត្ថថា មិនមានការត្រេកអរ មិនមានការត្រជាក់ចិត្ត ។ នូវអបាយ ទុគ្គតិ វិនិបាត និងនរកនោះ ។ បទថា **ឧបបជ្ជិស្សតិ** បានដល់ នឹងកើតឡើងដោយអំណាចនៃបដិសន្ធិ ។ បទថា **តិរច្ឆានយោនឹ** មានវិគ្គហៈថា ឈ្មោះថា **តិរច្ឆាន** ព្រោះទៅដោយទទឹង ។ កំណើតនៃតិរច្ឆានទាំងនោះ ឈ្មោះថា **តិរច្ឆានយោនិ** ។ ចូលដល់កំណើតតិរច្ឆាននោះ ។ បទថា **បិត្តិវិសយំ** មានវិគ្គហៈថា ឈ្មោះថា **បិត្តិវិសយ** ព្រោះជាលំនៅរបស់បុគ្គលដែលដល់នូវការលះលោកទៅហើយ ។ ចូលដល់បិត្តិវិស័យនោះ ។

ឈ្មោះថា **មនុស្ស** ព្រោះមានចិត្តខ្ពស់ ។ ក្នុងពួកមនុស្សនោះ ។ តអំពីនេះទៅ គប្បីជ្រាបសេចក្ដីដោយអំណាចនៃបុញ្ញាភិសង្ខារ ក្នុងបទនេះថា **កម្មាភិសង្ខារវសេន** ដូច្នេះ ។ បទថា **អាសវានំ ខយា** បានដល់ ព្រោះការវិនាសទៅនៃអាសវៈ ។ បទថា **អនាសវំ ចេតោវិមុត្តឹ** បានដល់ផលវិមុត្តិដែលប្រាសចាកអាសវៈ ។ បទថា **បញ្ញាវិមុត្តឹ** បានដល់ បញ្ញាក្នុងអរហត្តផល ។ គប្បីជ្រាបថា សមាធិ ឈ្មោះថា **ចេតោវិមុត្តិ** ព្រោះខ្ជាក់នូវរាគៈ បញ្ញាក្នុងអរហត្តផល ឈ្មោះថា **បញ្ញាវិមុត្តិ** ព្រោះខ្ជាក់នូវអវិជ្ជា ។ ម្យ៉ាងទៀត អរហត្តផល ដែលតណ្ហាចរិតបុគ្គល សង្កត់កិលេសទាំងឡាយដោយកម្លាំងនៃអប្បនាឈានហើយសម្រេច ឈ្មោះថា **ចេតោវិមុត្តិ** ព្រោះខ្ជាក់នូវរាគៈ ។ អរហត្តផលដែលទិដ្ឋិចរិតបុគ្គល ធ្វើត្រឹមឧបចារជ្ឈានឲ្យកើតឃើញច្បាស់ហើយ ទើបសម្រេច ឈ្មោះថា **បញ្ញាវិមុត្តិ** ព្រោះខ្ជាក់នូវអវិជ្ជា ។ ម្យ៉ាងទៀត អនាគាមិផល ឈ្មោះថា **ចេតោវិមុត្តិ** ព្រោះខ្ជាក់នូវរាគៈ ដែលសំដៅដល់កាមរាគៈ ។ អរហត្តផល ឈ្មោះថា **បញ្ញាវិមុត្តិ** ព្រោះខ្ជាក់នូវអវិជ្ជា ដោយប្រការទាំងពួង ។

[ ៥០ ] គប្បីជ្រាបសេចក្ដីក្នុងបទ **អាកិញ្ចញ្ញាយតនេ ធិមុត្តន្តិ វិមោក្ខេន** ដូចតទៅ ឈ្មោះថា **វិមោក្ខ** ដោយអត្ថដូចម្ដេច គឺដោយអត្ថថា បង្អោនទៅ ។ អត្ថថា បង្អោនទៅ គឺអ្វី គឺការផុតដោយល្អ ចាកធម៌ដែលជាសត្រូវ និងផុតដោយល្អ ដោយអំណាចការត្រេកអរក្រៃលែងក្នុងអារម្មណ៍ ។ លោកពោលថា វិមោក្ខរមែងប្រព្រឹត្តទៅក្នុងអារម្មណ៍ ព្រោះអស់សង្ស័យ

ព្រោះមិនតិះដៀល ដូចទារកលេងអវយវៈតូចធំតាមសប្បាយ ខណៈដេកលើភ្លៅរបស់បិតា ។ ដោយវិមោក្ខ មានសភាពបែបនោះ ។ បទថា **វិមុត្តំ** សេចក្តីថា លែងនូវវិញ្ញាណញ្ចាយតនៈហើយ ទើបផុតវិសេស ដោយអំណាចនៃការមិនសង្ស័យក្នុងអាកិញ្ចញ្ញាយតនៈ ។ បទថា **តត្រាធិមុត្តំ**(១) បានដល់ បង្អោនទៅក្នុងសមាធិនោះ ។ បទថា **តទធិមុត្តំ** បានដល់ បង្អោនទៅក្នុងឈាននោះ ។ បទថា **តទាធិបតេយ្យំ** បានដល់ មានឈាននោះជាប្រធាន ។

(១) បទនេះ បិដកខ្មែរ មិនមាន ។

៥ បទ មានបទថា **រូបាធិមុត្តោ** ជាដើម លោកពោលដោយការធ្ងន់ក្នុងកាមគុណ ។ ៣ បទថា **កុលាធិមុត្តោ** ជាដើម លោកពោលដោយការធ្ងន់ក្នុងត្រកូល មានក្សត្រជាដើម ។ បទ មានបទថា **លាភាធិមុត្តោ** ជាដើម លោកពោលដោយអំណាចនៃលោកធម៌ ។ ៤ បទ មានបទថា **ចីវរាធិមុត្តោ** ជាដើម លោកពោលដោយអំណាចបច្ច័យ ។ បទ មានបទថា **សុត្តន្តាធិមុត្តោ** ជាដើម លោកពោលដោយអំណាចនៃព្រះត្រៃបិដក ។ បទថា **អារញ្ញិកង្គាធិមុត្តោ** ជាដើម លោកពោលដោយអំណាចនៃធុតង្គ ។ បទថា **បឋមជ្ឈានាធិមុត្តោ** ជាដើម លោកពោលដោយអំណាចនៃការបានចំពោះ ។ បទថា **កម្មូបាយនំ** លោកពោលដោយអំណាចនៃអភិសង្ខារ ។ បទថា **វិបាកូបាយនំ** លោកពោលដោយអំណាចនៃការប្រព្រឹត្តទៅ ។ បទថា **កម្មគរុកំ** បានដល់ ធ្ងន់នៅក្នុងចេតនា ។ បទថា **បដិសន្ធិគរុកំ** បានដល់ ធ្ងន់ក្នុងការកើត ។

[ ៥១ ] បទថា **អាកិញ្ចញ្ញាសម្ភវំ ញត្វា** សេចក្តីថា ដឹងកម្មាភិ-សង្ខារថា ជាហេតុឲ្យកើតក្នុងអាកិញ្ចញ្ញាយតនភព ។ ដឹងដូចម្តេច គឺដឹងថា នេះជាបលិពោធ ។ បទថា **នន្ទិសញ្ញោជនំ ឥតិ** សេចក្តីថា ដឹងថា ការត្រេកអរ ពោលគឺ រាគៈក្នុងអរូបទី ៤ ជាគ្រឿងប្រកប ។ បទថា **តតោ តត្ថ វិបស្សតិ** សេចក្តីថា លំដាប់នោះ ចេញចាកអាកិញ្ចញ្ញាយតនសមាបត្តិ ហើយឃើញច្បាស់ក្នុងសមាបត្តិនោះ ដោយភាពជារបស់មិនទៀងជាដើម ។ បទថា **ឯតំ ញាណំ តថំ តស្ស** សេចក្តីថា នុ៎ះជាអរហត្តញ្ញាណដែលមិនវិបរិត ដែលកើតឡើងហើយតាមលំដាប់ដល់បុគ្គលនោះ ដែលឃើញច្បាស់យ៉ាងនេះ ។ បទថា **វុសីមតោ** បានដល់ មានព្រហ្មចរិយៈនៅចប់ហើយ ។ បទដ៏សេសក្នុងទីទាំងពួង ជាក់ច្បាស់ល្អហើយ ។ ព្រះមានព្រះភាគ ទ្រង់សម្តែងសូត្រនេះ ដោយធម៌កំពូល គឺអរហត្ត ដោយប្រការដូច្នេះ ។

កាលចប់ទេសនា មានបុគ្គលសម្រេចធម៌ដូចគ្នា តាមដែលបានពោលមកហើយខាងដើមនោះឯង ។ល។

**អដ្ឋកថា ធោតកមាណវសុត្តនិទ្ទេសទី ១៤ ចប់**

# សុត្តន្តបិដក

## មោឃរាជមាណវកប្បញ្ហានិទ្ទេស

[ ៥៨ ] ( មោឃរាជមានអាយុទូលដូច្នេះថា ) បពិត្រព្រះអង្គជាសក្កៈ ខ្ញុំព្រះអង្គ បានទូលសួរអស់វារៈពីរដងរួចហើយ ព្រះអង្គមានចក្ខុ ទ្រង់មិនទាន់ដោះស្រាយចំពោះខ្ញុំព្រះអង្គនៅឡើយ ខ្ញុំព្រះអង្គបានឮថា ព្រះអង្គជាទេវឫសី ( កាលបើមានគេសាកសួរ ) អស់វារៈបីដង ទ្រង់តែងតែព្យាករពុំខាន ។

[ ៥៩ ] ពាក្យថា បពិត្រព្រះអង្គជាសក្កៈ ខ្ញុំព្រះអង្គបានទូលសួរអស់វារៈពីរដងរួចហើយ អធិប្បាយថា ព្រាហ្មណ៍នោះ បានទូលសួរប្រស្នាចំពោះព្រះពុទ្ធមានព្រះភាគ អស់វារៈពីរដងរួចហើយ តែព្រះមានព្រះភាគ កាលព្រាហ្មណ៍នោះសួរប្រស្នាហើយ ទ្រង់មិនទាន់ព្យាករនៅឡើយ ដោយទ្រង់ព្រះតម្រិះថា ព្រាហ្មណ៍នេះ នឹងមានឥន្ទ្រិយចាស់ក្លា ក្នុងកាលជាលំដាប់ស្មើនៃធម្មចក្ខុ ។ ពាក្យថា បពិត្រព្រះអង្គជាសក្កៈ គឺព្រះមានព្រះភាគឈ្មោះថាសក្កៈ ។ ដែលព្រះមានព្រះភាគឈ្មោះសក្កៈ ព្រោះហេតុទ្រង់ចេញចាកសក្យត្រកូល ហើយបួសក៏បាន ។ ឬថា ឈ្មោះសក្កៈ ព្រោះហេតុទ្រង់ស្ដុកស្ដម្ភ មានទ្រព្យច្រើន មានធនធានក៏បាន ។ នេះទ្រព្យរបស់ព្រះអង្គគឺ ទ្រព្យគឺសទ្ធា ទ្រព្យ គឺសីល ទ្រព្យ គឺហិរិ ទ្រព្យ គឺឱត្តប្បៈ ទ្រព្យ គឺសុតៈ ទ្រព្យ គឺចាគៈ ទ្រព្យគឺបញ្ញា ទ្រព្យគឺសតិប្បដ្ឋាន ទ្រព្យគឺសម្មប្បធាន ទ្រព្យគឺឥទ្ធិបាទ ទ្រព្យ គឺឥន្ទ្រិយ ទ្រព្យ គឺពល ទ្រព្យ គឺពោជ្ឈង្គ ទ្រព្យ គឺមគ្គ ទ្រព្យ គឺផល ទ្រព្យ គឺនិព្វាន ។ ព្រះនាមសក្កៈ ព្រោះហេតុព្រះអង្គស្ដុកស្ដម្ភ

មានទ្រព្យច្រើន មានធនធាន ដោយទ្រព្យដ៏ប្រសើរច្រើនប្រការទាំងនេះក៏បាន ។ ពុំនោះសោត ឈ្មោះសក្កៈ ព្រោះហេតុទ្រង់អង់អាច មោះមុត ក្លាហាន មានព្យាយាមតស៊ូ ក្លៀវក្លា សង្វាត ប្រឹងប្រែង មិនខ្លាច មិនរន្ធត់ មិនតក់ស្លុត មិនរត់ចោល លះភ័យគួរខ្លាច មិនព្រឺរោមក៏បាន ។ ហេតុនោះ ( លោកពោលថា ) បពិត្រព្រះអង្គ ជាសក្កៈ ខ្ញុំព្រះអង្គ ( បានទូលសួរ ) អស់វារៈពីរដងរួចហើយ ។ ពាក្យថា ខ្ញុំព្រះអង្គបានទូលសួរ ( សេចក្ដីថា ) បពិត្រព្រះអង្គជាសក្កៈ ខ្ញុំព្រះអង្គបានទូលសួរ បានអង្វរ បានអារាធនា បានជ្រះថ្លាអស់វារៈពីរដងរួចហើយ ហេតុនោះ ( លោកពោលថា ) បពិត្រព្រះអង្គជាសក្កៈ ខ្ញុំព្រះអង្គបានទូលសួរអស់វារៈពីរដងរួចហើយ ។ ពាក្យថា ដូច្នេះ នៃបទថា មោឃរាជមានអាយុទូល ដូច្នេះ គឺជាការតបទ ។ ពាក្យថា មានអាយុ គឺពាក្យជាទីស្រឡាញ់ ។ ពាក្យថា មោឃរាជ ជាឈ្មោះ ។បេ។ ជាពាក្យសម្រាប់ហៅព្រាហ្មណ៍នោះ ហេតុនោះ ( មានពាក្យថា ) មោឃរាជមានអាយុទូលដូច្នេះ ។

[ ៦០ ] អធិប្បាយពាក្យថា ព្រះអង្គមានចក្ខុ ទ្រង់មិនទាន់ដោះស្រាយចំពោះខ្ញុំព្រះអង្គនៅឡើយ ត្រង់ពាក្យថា មិនទាន់ដោះស្រាយចំពោះខ្ញុំព្រះអង្គ គឺមិនទាន់ប្រាប់ មិនទាន់សម្ដែង មិនទាន់បញ្ញត្ត មិនទាន់តាំងទុក មិនទាន់បើក មិនទាន់ចែក មិនទាន់ធ្វើឲ្យងាយ មិនទាន់ប្រកាសដល់ខ្ញុំព្រះអង្គ ពាក្យថា មានចក្ខុ គឺព្រះមានព្រះភាគទ្រង់មានចក្ខុដោយចក្ខុ ៥ គឺមានចក្ខុ ដោយមំសចក្ខុ ១ មានចក្ខុ ដោយទិព្វចក្ខុ ១ មានចក្ខុ ដោយបញ្ញាចក្ខុ ១ មានចក្ខុ ដោយ

ពុទ្ធចក្ខុ ១ មានចក្ខុ ដោយសមន្តចក្ខុ ១ ។

ព្រះមានព្រះភាគទ្រង់មានចក្ខុ ដោយមំសចក្ខុ តើដូចម្តេច ។ ក្នុងមំសចក្ខុរបស់ព្រះមានព្រះភាគ មាន ៥ សម្បុរ គឺសម្បុរខៀវ ១ សម្បុរលឿង ១ សម្បុរក្រហម ១ សម្បុរខ្មៅ ១ សម្បុរស ១ ។ ទីណាដែលមានរោមព្រះនេត្រប្រតិស្ឋានទៅ ទីនោះឯង មានសម្បុរខៀវ ខៀវស្រស់គួរជ្រះថ្លា គួរក្រឡេកមើល ជាទីដូចផ្កាត្រកៀត ។ ទីខាងនាយអំពីនោះ មានសម្បុរលឿង លឿងស្រស់ មានសម្បុរដូចមាស គួរជ្រះថ្លា គួរក្រឡេកមើល ជាទីដូចផ្កាកណិការ ។ មួយទៀត រណ្តៅព្រះនេត្រទាំងពីរខាងរបស់ព្រះមានព្រះភាគ មានសម្បុរក្រហម ក្រហមប្រាល គួរជ្រះថ្លា គួរក្រឡេកមើល ជាទីដូចសម្បុរមេភ្លៀង ។ ទីត្រង់កណ្តាលមានសម្បុរខ្មៅ ខ្មៅស្រស់មិនសៅហ្មង ស្និទ្ធគួរជ្រះថ្លា គួរក្រឡេកមើល ជាទីដូចសម្បុរផ្លែផ្តាំ ។ ទីខាងនាយពីនោះ មានសម្បុរស សភ្លឺង សស្រស់ សថ្លា គួរជ្រះថ្លា គួរក្រឡេកមើល ជាទីដូចផ្កាយព្រឹក ។ ហេតុនោះ បានជាព្រះមានព្រះភាគតែងទតឃើញមួយយោជន៍ដោយជុំវិញ ទាំងថ្ងៃទាំងយប់ដោយមំសចក្ខុធម្មតាដែលរាប់បញ្ចូលក្នុងអត្តភាព កើតដោយផលនៃសុចរិតកម្មក្នុងកាលមុន ។ សូម្បីក្នុងកាលណា ដែលមានងងឹត ប្រកបដោយអង្គ ៤ គឺព្រះអាទិត្យអស្តង្គត ១ ឧបោសថខាងកាឡបក្ខ ១ ដងព្រៃយ៉ាងក្រាស់ជិត ១ មហាអកាលមេឃ ( ភ្លៀងធំខុសកាល ) ប្រាកដឡើង ១ ក្នុងកាលនោះ ព្រះមានព្រះភាគទតឃើញមួយយោជន៍ដោយជុំវិញ ក្នុងទីងងឹតប្រកបដោយអង្គ

៤ មានសភាពយ៉ាងនេះ ។ ផ្ទះកំពូលក្តី សន្ទឹកទ្វារក្តី កំពែងក្តី ភ្នំក្តី គុម្ព ឈើក្តី វល្លិ៍ក្តី ជាគ្រឿងរាំងនូវការឃើញរូបនោះ មិនមានឡើយ ។ បើ បុគ្គលដាក់គ្រាប់ល្ងមួយគ្រាប់ក្នុងរទេះ ដែលពេញដោយគ្រាប់ល្ង ធ្វើឲ្យជា គ្រឿងសម្គាល់ ព្រះមានព្រះភាគគប្បីរើសយកគ្រាប់ល្ងនោះដដែលវិញបាន ។ មំសចក្ខុជម្មតារបស់ព្រះមានព្រះភាគបរិសុទ្ធយ៉ាងនេះ ។ ព្រះមានព្រះភាគទ្រង់ មានចក្ខុ ដោយមំសចក្ខុយ៉ាងនេះឯង ។

ព្រះមានព្រះភាគទ្រង់មានចក្ខុ ដោយទិព្វចក្ខុ តើដូចម្តេច ។ ព្រះមាន ព្រះភាគទ្រង់មានចក្ខុដូចជាទិព្វដ៏បរិសុទ្ធ កន្លងផុតចក្ខុរបស់មនុស្សធម្មតា ។បេ។ ទ្រង់ជ្រាបច្បាស់នូវសត្វទាំងឡាយ ដែលរង្គាត់ទៅតាមយថាកម្ម ។ បើព្រះ មានព្រះភាគប្រាថ្នា ( ចង់ឃើញ ) គប្បីទតឃើញលោកធាតុ ១ ក៏បាន ឃើញលោកធាតុ ២ ក៏បាន ឃើញលោកធាតុ ៣ ក៏បាន ឃើញលោកធាតុ ៤ ក៏បាន ឃើញលោកធាតុ ៥ ក៏បាន ឃើញលោកធាតុ ១០ ក៏បាន ឃើញ លោកធាតុ ២០ ក៏បាន ឃើញលោកធាតុ ៣០ ក៏បាន ឃើញលោកធាតុ ៤០ ក៏បាន ឃើញលោកធាតុ ៥០ ក៏បាន ឃើញលោកធាតុ ១០០ ក៏បាន ឃើញលោកធាតុតូចចំនួន ១ ពាន់ក៏បាន ឃើញលោកធាតុកណ្តាលចំនួន ២ ពាន់ក៏បាន ឃើញលោកធាតុចំនួន ៣ ពាន់ក៏បាន ឃើញលោកធាតុមានពាន់ ដ៏ច្រើនក៏បាន ។ មិនតែប៉ុណ្ណោះ ព្រះមានព្រះភាគមានប្រាថ្នា ( នឹងឃើញ ) ត្រឹមណា គប្បីឃើញបានត្រឹមនោះ ។ ទិព្វចក្ខុរបស់ព្រះមានព្រះភាគបរិសុទ្ធ យ៉ាងនេះ ។ ព្រះមានព្រះភាគទ្រង់មានចក្ខុ ដោយទិព្វចក្ខុយ៉ាងនេះឯង ។

ព្រះមានព្រះភាគទ្រង់មានចក្ខុ ដោយបញ្ញាចក្ខុ តើដូចម្តេច ។ ព្រះមានព្រះភាគទ្រង់មានប្រាជ្ញាច្រើន មានប្រាជ្ញាក្រាស់ មានប្រាជ្ញារីករាយ មានប្រាជ្ញារហ័ស មានប្រាជ្ញាមោះមុត មានប្រាជ្ញាជាគ្រឿងទម្លាយកិលេស ទ្រង់ឈ្លាសក្នុងប្រភេទនៃប្រាជ្ញា ទ្រង់បែកព្រះញាណ ទ្រង់បានបដិសម្ភិទា ទ្រង់សម្រេចចតុវេសារជ្ជញ្ញាណ ទ្រទ្រង់នូវកម្លាំង ១០ ជាបុរសប្រសើរ ជាបុរសអង់អាច ជាបុរសនាគ ជាបុរសអាជានេយ្យ ជាបុរសនាំទៅនូវធុរៈ ជាអនន្តញ្ញាណ មានតេជៈមិនមានទីបំផុត មានយសមិនមានទីបំផុត ទ្រង់ស្តុកស្តម្ភ មានទ្រព្យច្រើន មានធនធាន ទ្រង់ដឹកនាំ ទ្រង់ទូន្មានប្រៀនប្រដៅ ទ្រង់ពន្យល់ ទ្រង់ដឹកនាំឲ្យគិតគូរ ទ្រង់ឲ្យគយគន់ ទ្រង់ធ្វើឲ្យជ្រះថ្លា ។ ព្រះមានព្រះភាគអង្គនោះ ទ្រង់ញុំាងមគ្គដែលមិនទាន់កើតឲ្យកើតឡើង ទ្រង់ញុំាងមគ្គដែលមិនទាន់កើតមានឲ្យកើតមាន ទ្រង់ប្រាប់ផ្លូវដែលមិនទាន់ប្រាប់ ទ្រង់ស្គាល់ផ្លូវ ទ្រង់ជ្រាបផ្លូវ ទ្រង់ឈ្លាសវៃក្នុងផ្លូវ ។ ចំណែកពួកសាវក ឥឡូវនេះគ្រាន់តែជាអ្នកដើរតាមផ្លូវ ដើរតាមក្រោយ ។ ព្រះមានព្រះភាគអង្គនោះ ទ្រង់ជ្រាបហេតុដែលគួរជ្រាប ទ្រង់ឃើញហេតុដែលគួរឃើញ មានចក្ខុ មានញាណ មានធម៌ មានធម៌ដ៏ប្រសើរ ទ្រង់ជាអ្នកស្តីប្រដៅ ទ្រង់ពោលរម្ញឹកបង្អោនទៅរកប្រយោជន៍ ឲ្យនូវព្រះនិព្វានជាធម្មស្សាមិជាតថាគត ។ មិនមាន ( វត្ថុអ្វីមួយ ) ដែលព្រះមានព្រះភាគអង្គនោះមិនបានដឹង មិនបានឃើញ មិនបានជ្រាប មិនបានធ្វើឲ្យជាក់ច្បាស់ មិនបានប៉ះពាល់ដោយប្រាជ្ញា ។ ធម៌ទាំងអស់ រាប់ទាំងអតីត អនាគត និងបច្ចុប្បន្ន រមែងមកកាន់វង្វង់ក្នុងប្រធាន

នៃព្រះញាណរបស់ព្រះពុទ្ធមានព្រះភាគ ដោយអាការសព្វគ្រប់ ។ ឈ្មោះថា ធម្មជាតដែលគប្បីដឹងណាមួយ ដែលជារបស់គួរដឹង គឺប្រយោជន៍ខ្លួនក្តី ប្រយោជន៍ជនដទៃក្តី ប្រយោជន៍ទាំងពីរក្តី ប្រយោជន៍ជាបច្ចុប្បន្នក្តី ប្រយោជន៍ក្នុងលោកខាងមុខក្តី ប្រយោជន៍រាក់ក្តី ប្រយោជន៍ជ្រៅក្តី ប្រយោជន៍លាក់លៀមក្តី ប្រយោជន៍កំបិតកំបាំងក្តី ប្រយោជន៍ដែលគួរដឹងក្តី ប្រយោជន៍ដែលបានដឹងហើយក្តី ប្រយោជន៍មិនមានទោសក្តី ប្រយោជន៍មិនមានកិលេសក្តី ប្រយោជន៍ផូរផង់ក្តី ប្រយោជន៍ដ៏ល្អិតក្តី ធម្មជាតទាំងអស់នោះ រមែងវិលនៅក្នុងខាងក្នុងពុទ្ធញាណ ។ កាយកម្មទាំងអស់ រមែងប្រព្រឹត្តទៅតាមព្រះញាណរបស់ព្រះពុទ្ធមានព្រះភាគ វចីកម្មទាំងអស់ រមែងប្រព្រឹត្តទៅតាមព្រះញាណ មនោកម្មទាំងអស់ រមែងប្រព្រឹត្តទៅតាមព្រះញាណ ( របស់ព្រះពុទ្ធមានព្រះភាគ ) ។ ញាណរបស់ព្រះពុទ្ធមានព្រះភាគ មិនមានទើសទាល់ក្នុងអតីត ញាណរបស់ព្រះពុទ្ធមានព្រះភាគ មិនមានទើសទាល់ក្នុងអនាគត ញាណរបស់ព្រះពុទ្ធមានព្រះភាគ មិនមានទើសទាល់ក្នុងបច្ចុប្បន្ន ។ ធម្មជាតដែលគប្បីដឹងមានកំណត់ត្រឹមណា ព្រះញាណក៏មានកំណត់ត្រឹមនោះ ព្រះញាណមានកំណត់ត្រឹមណា ធម្មជាតដែលគប្បីដឹងក៏មានកំណត់ត្រឹមនោះ ព្រះញាណមានធម្មជាតដែលគប្បីដឹងជាកំណត់ ធម្មជាតដែលគប្បីដឹងក៏មានព្រះញាណជាកំណត់ ព្រះញាណប្រព្រឹត្តកន្លងនូវធម្មជាតដែលគប្បីដឹងមិនបាន គន្លងនៃធម្មជាតដែលគប្បីដឹង ក៏ប្រព្រឹត្តកន្លងនូវព្រះញាណមិនបាន ធម៌ទាំងនោះ តាំងនៅក្នុងទីបំផុតនៃគ្នានិងគ្នា ។ ដូចបាតស្នុកពីរ ដែលគេគ្របហើយ

យ៉ាងជិតស្និទ្ធ គឺបាតស្មុគខាងក្រោម មិនប្រព្រឹត្តកន្លងបាតស្មុគខាងលើ បាតស្មុគខាងលើ ក៏មិនប្រព្រឹត្តកន្លងបាតស្មុគខាងក្រោម ( បាតស្មុគទាំងនោះ ) តាំងនៅក្នុងទីបំផុតនៃគ្នានិងគ្នា យ៉ាងណាមិញ ធម្មជាតដែលគប្បីដឹងក្តី ព្រះញាណក្តី របស់ព្រះពុទ្ធមានព្រះភាគ ក៏តាំងនៅក្នុងទីបំផុតនៃគ្នានិងគ្នាយ៉ាងនោះដែរ គឺ ធម្មជាតដែលគប្បីដឹងមានកំណត់ត្រឹមណា ព្រះញាណក៏មានកំណត់ត្រឹមនោះ ព្រះញាណមានកំណត់ត្រឹមណា ធម្មជាតដែលគប្បីដឹងក៏មានកំណត់ត្រឹមនោះ ព្រះញាណមានធម្មជាតដែលគប្បីដឹងជាកំណត់ ធម្មជាតដែលគប្បីដឹងក៏មានព្រះញាណជាកំណត់ ព្រះញាណប្រព្រឹត្តកន្លងធម្មជាតដែលគប្បីដឹងមិនបាន គន្លងនៃធម្មជាតដែលគប្បីដឹង ក៏ប្រព្រឹត្តកន្លងព្រះញាណមិនបាន ធម៌ទាំងនោះ តាំងនៅក្នុងទីបំផុតនៃគ្នានិងគ្នា ។ ព្រះញាណរបស់ព្រះមានព្រះភាគ រមែងប្រព្រឹត្តទៅក្នុងធម៌ទាំងពួង ។ ធម៌ទាំងពួង រមែងជាប់ជំពាក់ដោយការពាវរក ជាប់ជំពាក់ដោយការប្រាថ្នា ជាប់ជំពាក់ដោយការនឹក ជាប់ជំពាក់ដោយការតាំងចិត្តរបស់ព្រះពុទ្ធមានព្រះភាគ ។ ព្រះញាណរបស់ពុទ្ធមានព្រះភាគ រមែងប្រព្រឹត្តទៅក្នុងសត្វទាំងពួង ព្រះមានព្រះភាគតែងជ្រាបអាសយធម៌ ជ្រាបអនុសយធម៌ ជ្រាបចរិត ជ្រាបអធិមុត្តិនៃពួកសត្វទាំងពួង តែងជ្រាបពួកសត្វដែលមានធូលីតិចក្នុងភ្នែក មានធូលីច្រើនក្នុងភ្នែក មានឥន្ទ្រិយរឹង មានឥន្ទ្រិយទន់ មានអាការល្អ មានអាការអាក្រក់ ជាសត្វឲ្យត្រាស់ដឹងងាយ ឲ្យត្រាស់ដឹងក្រ ជាសត្វមានភ័ព្វ និងឥតភ័ព្វ ។ លោក ព្រមទាំងទេវលោក មារលោក ព្រហ្មលោក ពួកសត្វ ព្រមទាំង

សមណៈ និងព្រាហ្មណ៍ ទាំងមនុស្សជាសម្មតិទេព និងមនុស្សសាមញ្ញ ក៏រមែងវិលនៅតែខាងក្នុងពុទ្ធញាណ ។ ដូចហ្វូងត្រី និងអណ្ដើកណាមួយ ដោយហោចទៅ ទោះបីត្រីឈ្មោះតិមិ និងត្រីឈ្មោះតិមិង្គលៈ រមែងវិលនៅតែខាងក្នុងមហាសមុទ្រ យ៉ាងណា លោក ព្រមទាំងទេវលោក មារលោក ព្រហ្មលោក ពួកសត្វ ព្រមទាំងសមណៈ និងព្រាហ្មណ៍ ទាំងមនុស្សជាសម្មតិទេព និងមនុស្សសាមញ្ញ ក៏រមែងវិលនៅតែខាងក្នុងពុទ្ធញាណយ៉ាងនោះឯង ។ ដូចពួកបក្សីណាមួយ ដោយហោចទៅ សូម្បីគ្រុឌឈ្មោះវេនតេយ្យៈ តែងវិលនៅតែក្នុងប្រទេសនៃអាកាស យ៉ាងណាមិញ ពួកជនណា ដែលមានប្រាជ្ញាស្មើដោយប្រាជ្ញារបស់ព្រះសារីបុត្ត សូម្បីពួកជនទាំងនោះ ក៏រមែងវិលនៅតែខាងក្នុងប្រទេសនៃពុទ្ធញាណ យ៉ាងនោះឯង ។ ពុទ្ធញាណរមែងផ្សាយគ្របប្រាជ្ញានៃពួកទេវតា និងមនុស្ស ហើយប្រតិស្ឋាននៅ ។ ពួកជនណាមួយ ទោះបីជាខត្តិយបណ្ឌិតក្ដី ព្រាហ្មណបណ្ឌិតក្ដី គហបតិបណ្ឌិតក្ដី សមណបណ្ឌិតក្ដី ដែលមានប្រាជ្ញាល្អិត ស្គាល់ច្បាំមាត់របស់ជនដទៃ ស្រដៀងនឹងខ្មាន់ធ្នូអ្នកបាញ់រោមទ្រាយ ពួកជនទាំងនោះ មានអាការដូចជាទម្លាយបង់នូវទិដ្ឋិ ដោយប្រាជ្ញា ( ខ្លួន ) ហើយប្រព្រឹត្តទៅ ។ ពួកជនទាំងនោះ ប្រឹងតាក់តែងនូវប្រស្នា លុះតាក់តែងហើយ ក៏ចូលទៅសួរព្រះតថាគត ។ ប្រស្នាទាំងនោះ លុះព្រះមានព្រះភាគបានសម្ដែង បានដោះស្រាយហើយ ក៏បែរទៅជាប្រស្នាមានហេតុ គួរសម្ដែងចេញ និងពង្រីកចេញបាន ។ ពួកជនទាំងនោះ ក៏នាំគ្នាចុះចូលព្រះមានព្រះភាគ ។ គ្រានោះ ព្រះ

មានព្រះភាគ ទ្រង់រុងរឿងកន្លងដោយប្រាជ្ញាក្នុងទីប្រជុំនោះ ហេតុនោះ ព្រះមានព្រះភាគទ្រង់មានចក្ខុ ដោយបញ្ញាចក្ខុយ៉ាងនេះ ។

ព្រះមានព្រះភាគ ទ្រង់មានចក្ខុ ដោយពុទ្ធចក្ខុ តើដូចម្ដេច ។ ព្រះមានព្រះភាគទ្រង់ប្រមើលមើលលោកដោយពុទ្ធចក្ខុ បានទតឃើញពួកសត្វដែលមានធូលីតិចក្នុងភ្នែក មានធូលីច្រើនក្នុងភ្នែក មានឥន្ទ្រិយរឹង មានឥន្ទ្រិយទន់ មានអាការល្អ មានអាការអាក្រក់ ឲ្យត្រាស់ដឹងងាយ ឲ្យត្រាស់ដឹងក្រ សត្វជំពូកខ្លះឃើញភ័យក្នុងទោសខាងបរលោក ។ ដូចក្នុងគុម្ពព្រលិតក្តី គុម្ពឈូកក្រហមក្តី គុម្ពឈូកសក្តី ផ្កាព្រលិត ឬផ្កាឈូកក្រហម ឬក៏ផ្កាឈូកសជំពូកខ្លះ កើតក្នុងទឹក ចម្រើនក្នុងទឹក លូតលាស់ក្នុងទឹក ដុះកប់ខាងក្នុងនៅឡើយ ផ្កាព្រលិត ឬផ្កាឈូកក្រហម ឬក៏ផ្កាឈូកសជំពូកខ្លះ កើតក្នុងទឹក ចម្រើនក្នុងទឹក ស្ថិតនៅស្មើនឹងទឹកហើយ ផ្កាព្រលិត ឬផ្កាឈូកក្រហម ឬក៏ផ្កាឈូកសជំពូកខ្លះ កើតក្នុងទឹក ចម្រើនក្នុងទឹក ស្ថិតនៅផុតអំពីទឹក មិនទទឹកដោយទឹកឡើយ យ៉ាងណាមិញ ព្រះមានព្រះភាគទ្រង់ប្រមើលមើលលោក ដោយពុទ្ធចក្ខុ បានឃើញពួកសត្វ ដែលមានធូលីតិចក្នុងភ្នែក មានធូលីច្រើនក្នុងភ្នែក មានឥន្ទ្រិយរឹង មានឥន្ទ្រិយទន់ មានអាការល្អ មានអាការមិនល្អ ឲ្យត្រាស់ដឹងងាយ ឲ្យត្រាស់ដឹងក្រ សត្វជំពូកខ្លះឃើញភ័យ ក្នុងទោសខាងបរលោក ក៏យ៉ាងនោះឯង ។ ព្រះមានព្រះភាគទ្រង់ជ្រាបថា បុគ្គលនេះ ជារាគចរិត នេះជាទោសចរិត នេះជាមោហចរិត នេះជាវិតក្កចរិត នេះជាសទ្ធាចរិត នេះជាញាណចរិត ។ ព្រះមានព្រះភាគ ទ្រង់សម្តែងអសុភកថា ចំពោះបុគ្គលជា

រាគចរិត ។ ព្រះមានព្រះភាគ ទ្រង់ប្រាប់មេត្តាភាវនា ចំពោះបុគ្គលជាទោសចរិត ។ ព្រះមានព្រះភាគ ទ្រង់ញ៉ាំងបុគ្គលជាមោហចរិត ឲ្យតាំងនៅក្នុងធម្មស្សវនៈតាមកាល ក្នុងធម្មសាកច្ឆាតាមកាល និងការនៅរួមជាមួយគ្រូដើម្បីរៀន និងការសាកសួរ ។ ព្រះមានព្រះភាគ ទ្រង់ប្រាប់អានាបានស្សតិចំពោះបុគ្គលជាវិតក្កចរិត ។ ព្រះមានព្រះភាគ ទ្រង់ប្រាប់និមិត្តដែលគួរជ្រះថ្លា គឺការត្រាស់ដឹងប្រពៃនៃព្រះពុទ្ធ សភាពនៃធម៌ជាធម៌ល្អ ការប្រតិបត្តិប្រពៃនៃព្រះសង្ឃ និងសីលរបស់ខ្លួន ចំពោះបុគ្គលជាសទ្ធាចរិត ។ ព្រះមានព្រះភាគ ទ្រង់ប្រាប់វិបស្សនានិមិត្ត គឺអាការមិនទៀង អាការជាទុក្ខ និងអាការជាអនត្តា ចំពោះបុគ្គលជាញាណចរិត ។

បពិត្រសុមេធ ព្រះអង្គប្រកបដោយសមន្តចក្ខុ ទ្រង់មិនមានសោក
សូមព្រះអង្គឡើងកាន់ប្រាសាទ ជាវិការនៃធម៌ ហើយក្រឡេក
មើលពួកជន ដែលដេរដាសដោយសោក ត្រូវជាតិជរាគ្របសង្កត់
ដូចជាបុរសឈរនៅលើកំពូលភ្នំ ជាវិការនៃថ្ម ហើយក្រឡេក
មើលពួកជន ដែលស្ថិតនៅក្នុងទីជុំវិញដូច្នោះចុះ ។

ព្រះមានព្រះភាគ ទ្រង់មានចក្ខុ ដោយពុទ្ធចក្ខុយ៉ាងនេះ ។

ព្រះមានព្រះភាគ ទ្រង់មានចក្ខុ ដោយសមន្តចក្ខុ តើដូចម្តេច ។ សព្វញ្ញុតញ្ញាណ លោកហៅថា សមន្តចក្ខុ ។ ព្រះមានព្រះភាគ ទ្រង់ដល់ដល់ព្រម មកដល់ មកដល់ព្រម ចូលទៅជិត ចូលទៅជិតព្រម ប្រកបហើយដោយសព្វញ្ញុតញ្ញាណ ។

អ្វីមួយក្នុងលោកនេះ ដែលព្រះតថាគតនោះមិនឃើញ ឬមិនជ្រាប ហើយ មិនគប្បីជ្រាប មិនមានទេ របស់ណាដែលគួរដឹង ព្រះតថាគត ជ្រាបច្បាស់នូវរបស់នោះទាំងអស់ ហេតុនោះ ទើបឈ្មោះថា សមន្តចក្ខុ ។

ព្រះមានព្រះភាគ ទ្រង់មានចក្ខុ ដោយសមន្តចក្ខុយ៉ាងនេះ ហេតុនោះ ( លោកពោលថា ) ព្រះអង្គមានចក្ខុ ទ្រង់មិនទាន់ដោះស្រាយ ដល់ខ្ញុំព្រះអង្គនៅឡើយ ។

[ ៦១ ] ពាក្យថា ខ្ញុំព្រះអង្គបានឮថា ព្រះអង្គជាទេវឫសី ( កាលបើមានគេសាកសួរ ) អស់វារៈបីដង ទ្រង់តែងព្យាករពុំខាន អធិប្បាយថា ខ្ញុំព្រះអង្គបានរៀនមកយ៉ាងនេះ ខ្ញុំព្រះអង្គបានចាំទុកមកយ៉ាងនេះ ខ្ញុំព្រះអង្គបានកំណត់ទុកមកយ៉ាងនេះថា ព្រះពុទ្ធដែលគេសួរប្រស្នា ប្រកបដោយធម៌ ត្រឹមវារៈជាគម្រប់ ៣ តែងទ្រង់ព្យាករ មិនទើសទាល់ ។ ពាក្យថា ព្រះអង្គជាទេវឫសី គឺព្រះមានព្រះភាគ ឈ្មោះថា ទេវឫសី ព្រោះហេតុទ្រង់ជាវិសុទ្ធិទេពផង ជាឫសីផង ។ ដូចពួករាជបព្វជិត គេហៅថា រាជឫសី ពួកព្រាហ្មណបព្វជិត គេហៅថា ព្រហ្មឫសី យ៉ាងណាមិញ ព្រះមានព្រះភាគ ឈ្មោះថា ទេវឫសី ព្រោះហេតុទ្រង់ជាវិសុទ្ធិទេពផង ជាឫសីផង ក៏យ៉ាងនោះដែរ ។ មួយទៀត ព្រះមានព្រះភាគ ឈ្មោះថា ឫសី ព្រោះហេតុទ្រង់ជាបព្វជិត ដូច្នេះក៏បាន ។ ព្រះមានព្រះភាគ ឈ្មោះថា ឫសី ព្រោះទ្រង់រក ស្វែងរក ស្វះស្វែង នូវសីលក្ខន្ធដ៏ធំ ដូច្នេះក៏បាន ។ ព្រះមានព្រះភាគ ឈ្មោះថា ឫសី ព្រោះទ្រង់រក

ស្វែងរក ស្ទះស្វែង នូវសមាធិក្ខន្ធដ៏ធំ បញ្ញាខន្ធដ៏ធំ វិមុត្តិក្ខន្ធដ៏ធំ វិមុត្តិញាណទស្សនក្ខន្ធដ៏ធំ ដូច្នេះក៏បាន ។ ព្រះមានព្រះភាគ ឈ្មោះថា ឫសី ព្រោះទ្រង់រក ស្វែងរក ស្ទះស្វែង នូវការទម្លាយបង់ នូវគំនរងងឹតដ៏ធំ ការទម្លាយបង់នូវវិបល្លាសដ៏ធំ ការដកឡើងនូវសរ គឺតណ្ហាដ៏ធំ ការរុះរើចេញនូវឃ្នាប គឺទិដ្ឋិដ៏ធំ ការទម្លាក់ចុះនូវទង់ជ័យ គឺមានះដ៏ធំ ការរម្ងាប់នូវអភិសង្ខារដ៏ធំ ការរើចេញចាកឱឃៈដ៏ធំ ការដាក់ចុះនូវភារៈដ៏ធំ ការផ្តាច់បង់នូវសង្សារវដ្តដ៏ធំ ការរម្ងត់នូវកម្តៅដ៏ធំ ការរម្ងាប់បង់នូវការក្តៅក្រហាយដ៏ធំ និងការលើកឡើងនូវទង់ជ័យ គឺធម៌ដ៏ធំដូច្នេះក៏បាន ។ ព្រះមានព្រះភាគ ទ្រង់ឈ្មោះថា ឫសី ព្រោះទ្រង់ស្វែងរក ស្ទះស្វែង នូវសតិប្បដ្ឋានដ៏ធំ សម្មប្បធានដ៏ធំ ឥទ្ធិបាទដ៏ធំ ឥន្ទ្រិយដ៏ធំ ពលដ៏ធំ ពោជ្ឈង្គដ៏ធំ អរិយមគ្គប្រកបដោយអង្គ ៨ ដ៏ធំ និងព្រះនិព្វានដ៏ធំ ដូច្នេះក៏បាន ។ ឈ្មោះថា ឫសី ព្រោះ ( ព្រះមានព្រះភាគ ) ត្រូវពួកសត្វមានសក្តិធំ គួររក ស្វែងរក ស្ទះស្វែងថា ព្រះពុទ្ធ ( គង់នៅ ) ក្នុងទីណា ព្រះមានព្រះភាគ ( គង់នៅ ) ក្នុងទីណា ព្រះវិសុទ្ធិទេព ( គង់នៅ ) ក្នុងទីណា ព្រះនរាសភៈ ( គង់នៅ ) ក្នុងទីណា ហេតុនោះ ( លោកពោលថា ) ខ្ញុំព្រះអង្គបានឮថា ព្រះអង្គជាទេវឫសី ( កាលបើមានគេសាកសួរ ) អស់វារៈបីដង ទ្រង់តែងព្យាករពុំខាន ។ ហេតុនោះ ព្រាហ្មណ៍នោះពោលថា

( មោឃរាជមានអាយុ ក្រាបទូលដូច្នេះថា ) បពិត្រព្រះអង្គជា
សក្កៈ ខ្ញុំព្រះអង្គបានទូលសួរ ( ព្រះអង្គ ) អស់វារៈពីរដងរួច
ហើយ ព្រះអង្គមានចក្ខុ ទ្រង់មិនទាន់ដោះស្រាយ ដល់ខ្ញុំព្រះអង្គ

នៅឡើយ ខ្ញុំព្រះអង្គបានឮថា ព្រះអង្គជាទេវឫសី ( កាលបើមានគេសាកសួរ ) អស់វារៈបីដង ទ្រង់តែងព្យាករពុំខាន ។

[ ៦២ ] លោកនេះ លោកដទៃ ព្រហ្មលោក ព្រមទាំងទេវលោក រមែងមិនទាន់ដឹងច្បាស់ នូវសេចក្តីយល់ឃើញរបស់ព្រះអង្គ ជាព្រះគោតមដ៏ទ្រង់យសទេ ។

[ ៦៣ ] ពាក្យថា លោកនេះ របស់បទថា លោកនេះ លោកដទៃ បានដល់ មនុស្សលោក ។ ពាក្យថា លោកដទៃ គឺលោកដទៃទាំងអស់ លើកលែងតែមនុស្សលោកចេញ ហេតុនោះ ( លោកពោលថា ) លោកនេះ លោកដទៃ ។

[ ៦៤ ] ពាក្យថា ព្រហ្មលោក ព្រមទាំងទេវលោក បានដល់ ព្រហ្មលោក ព្រមទាំងទេវលោក មារលោក ពួកសត្វ ព្រមទាំងសមណៈនិងព្រាហ្មណ៍ ទាំងមនុស្សជាសម្មតិទេព និងមនុស្សសាមញ្ញ ហេតុនោះ ( លោកពោលថា ) ព្រហ្មលោក ព្រមទាំងទេវលោក ។

[ ៦៥ ] ពាក្យថា មិនទាន់ដឹងច្បាស់ នូវសេចក្តីឃើញរបស់ព្រះអង្គ គឺសត្វលោកមិនទាន់ដឹង នូវសេចក្តីយល់ឃើញ សេចក្តីចូលចិត្ត សេចក្តីគាប់ចិត្ត លទ្ធិ អធ្យាស្រ័យ បំណងរបស់ព្រះអង្គ គឺថា មិនទាន់ដឹង មិនទាន់ឃើញ មិនទាន់យល់ មិនទាន់ជួបប្រទះ មិនទាន់បាន មិនបានចំពោះថា សមណៈនេះ មានសេចក្តីយល់ឃើញយ៉ាងនេះ មានសេចក្តីចូលចិត្តយ៉ាងនេះ មានសេចក្តីគាប់ចិត្តយ៉ាងនេះ មានលទ្ធិយ៉ាងនេះ មានអធ្យាស្រ័យយ៉ាងនេះ មានបំណង

យ៉ាងនេះទេ ហេតុនោះ ( លោកពោលថា ) មិនទាន់ដឹងច្បាស់ នូវសេចក្តីយល់ឃើញរបស់ព្រះអង្គទេ ។

[ ៦៦ ] ពាក្យថា ជាព្រះគោតមដ៏ទ្រង់យស គឺព្រះមានព្រះភាគ ឈ្មោះថា មានយស ព្រោះហេតុទ្រង់ដល់នូវយស ។ ឬថា ព្រះមានព្រះភាគ មានគេធ្វើសក្ការៈ គោរព រាប់អាន បូជា កោតក្រែង ទ្រង់បានចីវរ បិណ្ឌបាត សេនាសនៈ និងគិលានប្បច្ចយភេសជ្ជបរិក្ខារ ហេតុនោះ ( លោកពោលថា ) ជាព្រះគោតមដ៏ទ្រង់យស ហេតុនោះ ព្រាហ្មណ៍នោះពោលថា

លោកនេះ លោកដទៃ ព្រហ្មលោក ព្រមទាំងទេវលោក រមែង
មិនទាន់ដឹងច្បាស់ នូវសេចក្តីយល់ឃើញរបស់ព្រះអង្គ ជាព្រះ
គោតម ដ៏ទ្រង់យសទេ ។

[ ៦៧ ] ខ្ញុំព្រះអង្គ ជាអ្នកត្រូវការដោយប្រស្នា ទើបមកគាល់
( ដើម្បីទូលសួរ ) ចំពោះព្រះអង្គ ទ្រង់ឃើញវិសេសយ៉ាងនេះ
ចុះបុគ្គលសម្លឹងឃើញលោក ដោយប្រការដូចម្តេច មច្ចុរាជទើប
មិនឃើញ ។

[ ៦៨ ] ពាក្យថា ព្រះអង្គទ្រង់ឃើញវិសេសយ៉ាងនេះ គឺទ្រង់ឃើញវិសេស ឃើញច្បាស់ ឃើញប្រសើរផុត ឃើញប្រសើរវិសេស ឃើញជាប្រធាន ឃើញដ៏ឧត្តម ឃើញដ៏ថ្លៃថ្លាយ៉ាងនេះ ហេតុនោះ ( លោកពោលថា ) ព្រះអង្គឃើញវិសេសយ៉ាងនេះ ។

[ ៦៩ ] ពាក្យថា ខ្ញុំព្រះអង្គ ជាអ្នកត្រូវការដោយប្រស្នា ទើបមកគាល់

គឺពួកខ្ញុំព្រះអង្គ មានសេចក្តីត្រូវការដោយប្រស្នា ទើបមកគាល់ ។បេ។ ដើម្បីសទ្ធនា ដើម្បីក្រាបបង្គំទូលសួរ ហេតុនោះ ( លោកពោលថា ) ខ្ញុំព្រះអង្គជាអ្នកត្រូវការដោយប្រស្នា ទើបមកគាល់យ៉ាងនេះក៏មាន ។

[ ៧០ ] ពាក្យថា បុគ្គលសម្លឹងឃើញលោក ដោយប្រការដូចម្តេច គឺសម្លឹងឃើញ ពិចារណាឃើញ រំពឹងឃើញ ត្រិះរិះឃើញ ធ្វើឲ្យជាក់ច្បាស់ ធ្វើឲ្យប្រាកដ ( នូវលោក ) ដោយប្រការដូចម្តេច ហេតុនោះ ( លោកពោលថា ) បុគ្គលសម្លឹងឃើញលោក ដោយប្រការដូចម្តេច ។

[ ៧១ ] ពាក្យថា មច្ចុរាជទើបមិនឃើញ គឺមច្ចុរាជទើបមិនឃើញ មិនយល់ មិនជួបប្រទះ មិនបាន មិនបានចំពោះ ហេតុនោះ ( លោកពោលថា ) មច្ចុរាជទើបមិនឃើញ ។ ហេតុនោះ ព្រាហ្មណ៍នោះពោលថា

ខ្ញុំព្រះអង្គ ជាអ្នកត្រូវការដោយប្រស្នា ទើបមកគាល់ ( ដើម្បីទូលសួរ ) ចំពោះព្រះអង្គ ទ្រង់ឃើញវិសេសយ៉ាងនេះ ចុះបុគ្គលសម្លឹងឃើញលោក ដោយប្រការដូចម្តេច មច្ចុរាជទើបមិនឃើញ ។

[ ៧២ ] ( ព្រះមានព្រះភាគ ទ្រង់ត្រាស់ថា ) ម្នាលមោឃរាជ អ្នកចូរមានស្មារតីគ្រប់កាល សម្លឹងឃើញលោក ដោយសភាពជារបស់សូន្យ ( ព្រោះ ) បុគ្គលដកអត្តានុទិដ្ឋិចេញ ទើបឆ្លងផុតចាកមច្ចុ បុគ្គលសម្លឹងឃើញលោកយ៉ាងនេះ មច្ចុរាជទើបមិនឃើញ ។

[ ៧៣ ] អធិប្បាយពាក្យថា អ្នកចូរសម្លឹងឃើញលោក ដោយសភាព

ជារបស់សូន្យ ត្រង់ពាក្យថា លោក បានដល់ និរយលោក តិរច្ឆានលោក បិត្តិវិសយលោក មនុស្សលោក ទេវលោក ខន្ធលោក ធាតុលោក អាយតនលោក លោកនេះ លោកដទៃ ព្រហ្មលោក ព្រមទាំងទេវលោក ។

ភិក្ខុមួយរូបក្រាបបង្គំទូល ព្រះមានព្រះភាគដូច្នេះថា បពិត្រព្រះអង្គដ៏ចម្រើន ព្រះមានព្រះភាគតែងត្រាស់ថា លោក លោក ដូច្នេះ បពិត្រព្រះអង្គដ៏ចម្រើន សភាវៈដែលហៅថា លោក តើមានកំណត់ដូចម្តេច ។ ព្រះមានព្រះភាគទ្រង់ត្រាស់ថា ម្នាលភិក្ខុ សភាវៈដែលហៅថា លោក ព្រោះហេតុវិនាស ។ អ្វីតែងវិនាស ។ ចក្ខុតែងវិនាស ពួករូបតែងវិនាស ចក្ខុវិញ្ញាណតែងវិនាស ចក្ខុសម្ផស្សតែងវិនាស ធម្មជាតណាមួយ ដែលបុគ្គលទទួលជាសុខ ឬទុក្ខ ឬមិនមែនទុក្ខមិនមែនសុខ រមែងកើតឡើង ព្រោះចក្ខុសម្ផស្សជាបច្ច័យ ធម្មជាតនោះ តែងវិនាសទៅ ត្រចៀកតែងវិនាស ពួកសំឡេងតែងវិនាស ច្រមុះតែងវិនាស ពួកក្លិនតែងវិនាស អណ្តាតតែងវិនាស ពួករសតែងវិនាស កាយតែងវិនាស ពួកផ្សព្វតែងវិនាស ចិត្តតែងវិនាស ពួកធម្មារម្មណ៍តែងវិនាស មនោវិញ្ញាណតែងវិនាស មនោសម្ផស្សតែងវិនាស ធម្មជាតណាមួយ ដែលបុគ្គលទទួលជាសុខ ឬទុក្ខ ឬមិនមែនទុក្ខមិនមែនសុខ កើតឡើង ព្រោះមនោសម្ផស្សជាបច្ច័យ ធម្មជាតនោះ រមែងវិនាស ម្នាលភិក្ខុ ហេតុនោះ សភាវៈដែលហៅថា លោក ព្រោះហេតុវិនាសដូច្នេះឯង ។ ពាក្យថា អ្នកចូរសម្លឹងឃើញលោក ដោយសភាពជារបស់សូន្យ សេចក្តីថា បុគ្គលសម្លឹងឃើញលោក ដោយសភាពជារបស់សូន្យ ដោយហេតុពីរ គឺដោយអំណាច

នៃការកំណត់សង្ខារ ដែលប្រព្រឹត្តទៅថា មិនមានអំណាច ១ ដោយអំណាចនៃការពិចារណាឃើញរឿយៗ នូវសង្ខារថាជារបស់ទទេ ១ ។

បុគ្គលសម្លឹងឃើញលោក ដោយសភាពជារបស់សូន្យ ដោយអំណាចនៃការកំណត់សង្ខារ ដែលប្រព្រឹត្តទៅថាមិនមានអំណាច តើដូចម្តេច ។ បុគ្គលមិនបានអំណាចក្នុងរូប មិនបានអំណាចក្នុងវេទនា មិនបានអំណាចក្នុងសញ្ញា មិនបានអំណាចក្នុងសង្ខារទាំងឡាយ មិនបានអំណាចក្នុងវិញ្ញាណ ។ ដូចព្រះពុទ្ធដីកានេះ ដែលព្រះមានព្រះភាគត្រាស់ថា ម្នាលភិក្ខុទាំងឡាយ រូបមិនមែនជារបស់ខ្លួន ម្នាលភិក្ខុទាំងឡាយ ប្រសិនបើរូបនេះ ជារបស់ខ្លួនពិតមែន រូបនេះ មិនគប្បីប្រព្រឹត្តទៅដើម្បីអាពាធទេ ទាំងបុគ្គលគប្បីបានក្នុងរូបថា សូមឲ្យរូបអាត្មាមានយ៉ាងនេះ កុំឲ្យរូបអាត្មាមានយ៉ាងនេះឡើយ ម្នាលភិក្ខុទាំងឡាយ ព្រោះហេតុតែរូប មិនមែនជារបស់ខ្លួន ហេតុនោះ រូបទើបប្រព្រឹត្តទៅ ដើម្បីអាពាធ ទាំងបុគ្គលមិនបានក្នុងរូបថា សូមឲ្យរូបអាត្មាមានយ៉ាងនេះ កុំឲ្យរូបអាត្មាមានយ៉ាងនេះឡើយ វេទនាមិនមែនជារបស់ខ្លួន ម្នាលភិក្ខុទាំងឡាយ ប្រសិនបើវេទនានេះ ជារបស់ខ្លួនពិតមែន វេទនានេះ មិនគប្បីប្រព្រឹត្តទៅដើម្បីអាពាធទេ ទាំងបុគ្គលគប្បីបានក្នុងវេទនាថា សូមឲ្យវេទនារបស់អាត្មា មានយ៉ាងនេះកុំឲ្យវេទនារបស់អាត្មាមានយ៉ាងនេះឡើយ ម្នាលភិក្ខុទាំងឡាយ ព្រោះហេតុតែវេទនា មិនមែនជារបស់ខ្លួន ហេតុនោះ វេទនា ទើបប្រព្រឹត្តទៅដើម្បីអាពាធ ទាំងបុគ្គលមិនបានក្នុងវេទនាថា សូមឲ្យវេទនារបស់អាត្មាមានយ៉ាងនេះ កុំឲ្យវេទនារបស់អាត្មាមានយ៉ាងនេះឡើយ សញ្ញាមិនមែនជារបស់ខ្លួនទេ

ម្នាលភិក្ខុទាំងឡាយ ប្រសិនបើសញ្ញានេះ ជារបស់ខ្លួនពិតមែន សញ្ញានេះមិនគប្បីប្រព្រឹត្តទៅដើម្បីអាពាធទេ ទាំងបុគ្គលគប្បីបានក្នុងសញ្ញាថា សូមឲ្យសញ្ញារបស់អាត្មាមានយ៉ាងនេះ កុំឲ្យសញ្ញារបស់អាត្មាមានយ៉ាងនេះឡើយ ម្នាលភិក្ខុទាំងឡាយ ព្រោះហេតុតែសញ្ញា មិនមែនជារបស់ខ្លួន ហេតុនោះ សញ្ញាទើបប្រព្រឹត្តទៅដើម្បីអាពាធ ទាំងបុគ្គលមិនបានក្នុងសញ្ញាថា សូមឲ្យសញ្ញារបស់អាត្មាមានយ៉ាងនេះ កុំឲ្យសញ្ញារបស់អាត្មាមានយ៉ាងនេះឡើយ សង្ខារទាំងឡាយមិនមែនជារបស់ខ្លួនទេ ម្នាលភិក្ខុទាំងឡាយ ប្រសិនបើសង្ខារទាំងឡាយនេះ ជារបស់ខ្លួនពិតមែន សង្ខារទាំងឡាយនេះ មិនគប្បីប្រព្រឹត្តទៅដើម្បីអាពាធទេ ទាំងបុគ្គលគប្បីបានក្នុងសង្ខារទាំងឡាយថា សូមឲ្យសង្ខារទាំងឡាយរបស់អាត្មាមានយ៉ាងនេះ កុំឲ្យសង្ខារទាំងឡាយ របស់អាត្មាមានយ៉ាងនេះឡើយ ម្នាលភិក្ខុទាំងឡាយ ព្រោះហេតុតែសង្ខារទាំងឡាយ មិនមែនជារបស់ខ្លួន ហេតុនោះ សង្ខារទាំងឡាយ ទើបប្រព្រឹត្តទៅដើម្បីអាពាធ ទាំងបុគ្គលមិនបានក្នុងសង្ខារទាំងឡាយថា សូមឲ្យសង្ខារទាំងឡាយ របស់អាត្មាមានយ៉ាងនេះ កុំឲ្យសង្ខារទាំងឡាយ របស់អាត្មាមានយ៉ាងនេះឡើយ វិញ្ញាណមិនមែនជារបស់ខ្លួនទេ ម្នាលភិក្ខុទាំងឡាយ ប្រសិនបើវិញ្ញាណនេះ ជារបស់ខ្លួនពិតមែន វិញ្ញាណនេះ មិនគប្បីប្រព្រឹត្តទៅដើម្បីអាពាធទេ ទាំងបុគ្គលគប្បីបានក្នុងវិញ្ញាណថា សូមឲ្យវិញ្ញាណរបស់អាត្មាមានយ៉ាងនេះ កុំឲ្យវិញ្ញាណរបស់អាត្មាមានយ៉ាងនេះឡើយ ម្នាលភិក្ខុទាំងឡាយ ព្រោះហេតុតែវិញ្ញាណ មិនមែនជារបស់ខ្លួន ហេតុនោះ វិញ្ញាណ ទើបប្រព្រឹត្តទៅដើម្បីអាពាធ ទាំងបុគ្គល

មិនបានក្នុងវិញ្ញាណថា សូមឲ្យវិញ្ញាណរបស់អាត្មាមានយ៉ាងនេះ កុំឲ្យវិញ្ញាណរបស់អាត្មាមានយ៉ាងនេះឡើយ ។ មួយទៀត ព្រះពុទ្ធដីកានេះ ព្រះមានព្រះភាគត្រាស់ថា ម្នាលភិក្ខុទាំងឡាយ កាយនេះ មិនមែនជារបស់អ្នកទាំងឡាយទេ ទាំងមិនមែនជារបស់ជនទាំងឡាយដទៃទេ ម្នាលភិក្ខុទាំងឡាយ អ្នកទាំងឡាយគប្បីឃើញថា កាយនេះ កើតអំពីកម្មចាស់ ដែលបច្ច័យប្រជុំតាក់តែង មានចេតនាជាមូល ជាទីតាំងនៃវេទនា ម្នាលភិក្ខុទាំងឡាយ អរិយសាវកអ្នកចេះដឹង តែងធ្វើទុកក្នុងចិត្ត ដោយឧបាយយ៉ាងប្រពៃ ចំពោះធម៌ដែលកើតអាស្រ័យគ្នានិងគ្នា ក្នុងកាយនោះថា កាលបើធម្មជាតនេះមាន ធម្មជាតនេះក៏មាន ធម្មជាតនេះកើតឡើង ព្រោះការកើតឡើងនៃធម្មជាតនេះ កាលបើធម្មជាតនេះមិនមាន ធម្មជាតនេះក៏មិនមាន ធម្មជាតនេះរលត់ ព្រោះការរលត់ធម្មជាតនេះ គឺថា សង្ខារទាំងឡាយ ( កើតមាន ) ព្រោះអវិជ្ជាជាបច្ច័យ វិញ្ញាណ ( កើតមាន ) ព្រោះសង្ខារជាបច្ច័យ នាមរូប ( កើតមាន ) ព្រោះវិញ្ញាណជាបច្ច័យ សឡាយតនៈ ( កើតមាន ) ព្រោះនាមរូបជាបច្ច័យ ផស្សៈ ( កើតមាន ) ព្រោះសឡាយតនៈជាបច្ច័យ វេទនា ( កើតមាន ) ព្រោះផស្សៈជាបច្ច័យ តណ្ហា ( កើតមាន ) ព្រោះវេទនាជាបច្ច័យ ឧបាទាន ( កើតមាន ) ព្រោះតណ្ហាជាបច្ច័យ ភព ( កើតមាន ) ព្រោះឧបាទានជាបច្ច័យ ជាតិ ( កើតមាន ) ព្រោះភពជាបច្ច័យ ការ ចាស់ ស្លាប់ សោក ខ្សឹកខ្សួល លំបាកកាយ លំបាកចិត្ត ចង្អៀតណែនក្នុងចិត្តទាំងឡាយ កើតមានព្រោះជាតិជាបច្ច័យ កិរិយាកើតឡើងនៃកងទុក្ខទាំងអស់នេះ រមែងកើតមានយ៉ាងនេះ

មួយទៀត កិរិយារលត់សង្ខារ ព្រោះកិរិយាវិនាសទៅ រលត់ទៅមិនមានសេសសល់នៃអវិជ្ជា កិរិយារលត់វិញ្ញាណ ព្រោះកិរិយារលត់សង្ខារ កិរិយារលត់នាមរូប ព្រោះកិរិយារលត់វិញ្ញាណ កិរិយារលត់សឡាយតនៈ ព្រោះកិរិយារលត់នាមរូប កិរិយារលត់ផស្សៈ ព្រោះកិរិយារលត់សឡាយតនៈ កិរិយារលត់វេទនា ព្រោះកិរិយារលត់ផស្សៈ កិរិយារលត់តណ្ហា ព្រោះកិរិយារលត់វេទនា កិរិយារលត់ឧបាទាន ព្រោះកិរិយារលត់តណ្ហា កិរិយារលត់ភព ព្រោះកិរិយារលត់ឧបាទាន កិរិយារលត់ជាតិ ព្រោះកិរិយារលត់ភព ការចាស់ស្លាប់ សោក ខ្សឹកខ្សួល លំបាកកាយ លំបាកចិត្ត ចង្អៀតចង្អល់ចិត្តទាំងឡាយតែងរលត់ទៅ ព្រោះកិរិយារលត់ជាតិ កិរិយារលត់កងទុក្ខទាំងអស់នេះ មានយ៉ាងនេះ ។ បុគ្គលសម្លឹងឃើញលោក ដោយសភាពជារបស់សូន្យ ដោយអំណាចនៃការកំណត់សង្ខារ ដែលប្រព្រឹត្តទៅថា មិនមានអំណាច យ៉ាងនេះឯង ។

បុគ្គលសម្លឹងឃើញលោក ដោយសភាពជារបស់សូន្យ ដោយអំណាចនៃការពិចារណាឃើញរឿយៗ នូវសង្ខារថាជារបស់ទទេ តើដូចម្តេច ។ បុគ្គលមិនបានខ្លឹមក្នុងរូប មិនបានខ្លឹមក្នុងវេទនា មិនបានខ្លឹមក្នុងសញ្ញា មិនបានខ្លឹមក្នុងសង្ខារទាំងឡាយ មិនបានខ្លឹមក្នុងវិញ្ញាណទេ ។ រូបជារបស់មិនមានខ្លឹម ឥតខ្លឹម ប្រាសចាកខ្លឹម ដោយខ្លឹម មានខ្លឹម គឺទៀងក្តី ដោយខ្លឹម មានខ្លឹម គឺសុខក្តី ដោយខ្លឹម មានខ្លឹម គឺរបស់ខ្លួនក្តី ដោយភាពជារបស់ទៀងក្តី យឺនយូរក្តី ស្ថិតស្ថេរក្តី មិនប្រែប្រួលជាធម្មតាក្តី ។ វេទនាជារបស់មិនមានខ្លឹម ឥតខ្លឹម

ប្រាសចាកខ្លឹម សញ្ញាជារបស់មិនមានខ្លឹម ឥតខ្លឹម ប្រាសចាកខ្លឹម សង្ខារទាំងឡាយជារបស់មិនមានខ្លឹម ឥតខ្លឹម ប្រាសចាកខ្លឹម វិញ្ញាណជារបស់មិនមានខ្លឹម ឥតខ្លឹម ប្រាសចាកខ្លឹម ដោយខ្លឹម មានខ្លឹម គឺទៀងក្តី ដោយខ្លឹម មានខ្លឹម គឺសុខក្តី ដោយខ្លឹម មានខ្លឹម គឺរបស់ខ្លួនក្តី ដោយភាពជារបស់ទៀងក្តី យឺនយូរក្តី ស្ថិតស្ថេរក្តី មិនប្រែប្រួលជាធម្មតាក្តី ។ ប្រៀបដូចដើមបបុស ជារបស់មិនមានខ្លឹម ឥតខ្លឹម ប្រាសចាកខ្លឹម ឬដូចដើមល្ហុងខ្វេជារបស់មិនមានខ្លឹម ឥតខ្លឹម ប្រាសចាកខ្លឹម យ៉ាងណាមិញ មួយទៀត ដូចដើមល្វាជារបស់មិនមានខ្លឹម ឥតខ្លឹម ប្រាសចាកខ្លឹម យ៉ាងណាមិញ ឬដូចដើមសេតគច្ឆព្រឹក្ស ( រកស ) ជារបស់មិនមានខ្លឹម ឥតខ្លឹម ប្រាសចាកខ្លឹម យ៉ាងណាមិញ មួយទៀត ដូចដើមបាលកទ្ទុកព្រឹក្ស ( រលួសបាយ ) ជារបស់មិនមានខ្លឹម ឥតខ្លឹម ប្រាសចាកខ្លឹម យ៉ាងណាមិញ ឬដូចជាដុំពពុះទឹកជារបស់មិនមានខ្លឹម ឥតខ្លឹម ប្រាសចាកខ្លឹម យ៉ាងណាមិញ មួយទៀត ដូចក្រពេញទឹក ជារបស់មិនមានខ្លឹម ឥតខ្លឹម ប្រាសចាកខ្លឹម យ៉ាងណាមិញ ឬដូចដើមចេក ជារបស់មិនមានខ្លឹម ឥតខ្លឹម ប្រាសចាកខ្លឹម យ៉ាងណាមិញ មួយទៀត ដូចថ្ងៃបណ្តើរកូន ជារបស់មិនមានខ្លឹម ឥតខ្លឹម ប្រាសចាកខ្លឹម យ៉ាងណាមិញ រូបជារបស់មិនមានខ្លឹម ឥតខ្លឹម ប្រាសចាកខ្លឹម ដោយខ្លឹម មានខ្លឹម គឺទៀងក្តី ដោយខ្លឹម មានខ្លឹម គឺសុខក្តី ដោយខ្លឹម មានខ្លឹម គឺរបស់ខ្លួនក្តី ដោយភាពជារបស់ទៀងក្តី យឺនយូរក្តី ស្ថិតស្ថេរក្តី មិនប្រែប្រួលជាធម្មតាក្តី វេទនាជារបស់មិនមានខ្លឹម ឥតខ្លឹម ប្រាសចាកខ្លឹម សញ្ញាជារបស់

មិនមានខ្លឹម ឥតខ្លឹម ប្រាសចាកខ្លឹម សង្ខារទាំងឡាយជារបស់មិនមានខ្លឹម ឥតខ្លឹម ប្រាសចាកខ្លឹម វិញ្ញាណជារបស់មិនមានខ្លឹម ឥតខ្លឹម ប្រាសចាកខ្លឹម ដោយខ្លឹម មានខ្លឹម គឺទៀងក្តី ដោយខ្លឹម មានខ្លឹម គឺសុខក្តី ដោយខ្លឹម មានខ្លឹម គឺរបស់ខ្លួនក្តី ដោយភាពជារបស់ទៀងក្តី យឺនយូរក្តី ស្ថិតស្ថេរក្តី មិនប្រែប្រួលជាធម្មតាក្តី ក៏យ៉ាងនោះដែរ ។ បុគ្គលសម្លឹងឃើញលោក ដោយសភាពជារបស់សូន្យ ដោយអំណាចការពិចារណារឿយៗ នូវសង្ខារថាជារបស់ទទេយ៉ាងនេះ ។ បុគ្គលសម្លឹងឃើញលោក ដោយសភាពជារបស់សូន្យ ដោយហេតុពីរប្រការនេះឯង ។

មួយទៀត បុគ្គលសម្លឹងឃើញលោក ដោយសភាពជារបស់សូន្យ ដោយអាការ ៦ គឺសម្លឹងឃើញរូប ដោយសភាពជារបស់មិនមានអ្វីជាឥស្សរៈ ១ មិនលុះតាមប្រាថ្នា ១ មិនជាទីសប្បាយ ១ មិនលុះអំណាចខ្លួន ១ ប្រព្រឹត្ត ( ជាប់ដោយបច្ច័យ ) ១ ជារបស់ទទេ ១ សម្លឹងឃើញវេទនា សញ្ញា សង្ខារ វិញ្ញាណ ដោយសភាពជារបស់មិនមានអ្វីជាឥស្សរៈ មិនលុះតាមប្រាថ្នា មិនជាទីសប្បាយ មិនលុះអំណាចខ្លួន ប្រព្រឹត្ត ( ជាប់ដោយបច្ច័យ ) ជារបស់ទទេ ។ បុគ្គលសម្លឹងឃើញលោក ដោយសភាពជារបស់សូន្យ ដោយអាការ ៦ យ៉ាងនេះឯង ។ មួយទៀត បុគ្គលសម្លឹងឃើញលោក ដោយសភាពជារបស់សូន្យ ដោយអាការ ១០ គឺសម្លឹងឃើញរូប ដោយសភាពជារបស់គ្មាន ១ របស់ទទេ ១ របស់សូន្យ ១ របស់មិនមែនខ្លួនប្រាណ ១ របស់មិនមានខ្លឹម ១ ជាអ្នកសម្លាប់ ១ របស់មិនចម្រើន ១ របស់បង្កទុក្ខ ១ របស់ប្រកប

ដោយអាសវៈ ១ របស់ដែលបច្ច័យប្រជុំតាក់តែង ១ សម្លឹងឃើញវេទនា សញ្ញា សង្ខារ វិញ្ញាណ ដោយសភាពជារបស់គ្មាន របស់ទទេ របស់សូន្យ របស់មិនមែនខ្លួនប្រាណ របស់មិនមានខ្លឹម ជាអ្នកសម្លាប់ របស់មិនចម្រើន របស់បង្កទុក្ខ របស់ប្រកបដោយអាសវៈ របស់ដែលបច្ច័យប្រជុំតាក់តែង ។ បុគ្គលសម្លឹងឃើញលោក ដោយសភាពជារបស់សូន្យ ដោយអាការ ១០ យ៉ាងនេះឯង ។ មួយទៀត បុគ្គលសម្លឹងឃើញលោក ដោយសភាពជារបស់សូន្យ ដោយអាការ ១២ គឺឃើញថារូបមិនមែនសត្វ ១ មិនមែនជីវៈ ១ មិនមែនបុរស ១ មិនមែននរៈ ១ មិនមែនមាណព ១ មិនមែនស្រី ១ មិនមែនប្រុស ១ មិនមែនខ្លួន ១ មិនមែនរបស់ខ្លួន ១ មិនមែនយើង ១ មិនមែនរបស់យើង ១ មិនមែនជាបុគ្គលណាៗ ១ ឃើញថា វេទនា សញ្ញា សង្ខារ វិញ្ញាណ មិនមែនសត្វ មិនមែនជីវៈ មិនមែនបុរស មិនមែននរៈ មិនមែនមាណព មិនមែនស្រី មិនមែនប្រុស មិនមែនខ្លួន មិនមែនរបស់ខ្លួន មិនមែនយើង មិនមែនរបស់យើង មិនមែនជាបុគ្គលណាៗ ។ បុគ្គលសម្លឹងឃើញលោក ដោយសភាពជារបស់សូន្យ ដោយអាការ ១២ យ៉ាងនេះឯង ។

ដូចព្រះពុទ្ធដីកា ដែលព្រះមានព្រះភាគ ត្រាស់ហើយនេះថា ម្នាលភិក្ខុទាំងឡាយ របស់ណាមិនមែនជារបស់ពួកអ្នក ពួកអ្នកចូរលះបង់របស់នោះ របស់នោះដែលពួកអ្នកលះបង់ហើយ នឹងបានជាប្រយោជន៍ បានសេចក្តីសុខអស់កាលយូរ ម្នាលភិក្ខុទាំងឡាយ របស់អ្វី ដែលមិនមែនជារបស់ពួកអ្នក ម្នាលភិក្ខុទាំងឡាយ រូបមិនមែនជារបស់ពួកអ្នក ពួកអ្នកចូរលះបង់រូបនោះ រូប

នោះ ដែលពួកអ្នកលះបង់ហើយ នឹងបានជាប្រយោជន៍ បានសេចក្តីសុខ អស់កាលយូរ ម្នាលភិក្ខុទាំងឡាយ វេទនាមិនមែនជារបស់ពួកអ្នក ពួកអ្នក ចូរលះបង់វេទនានោះ វេទនានោះ ដែលពួកអ្នកលះបង់ហើយ នឹងបានជា ប្រយោជន៍ បានសេចក្តីសុខអស់កាលយូរ ម្នាលភិក្ខុទាំងឡាយ សញ្ញាមិន មែនជារបស់ពួកអ្នក ពួកអ្នកចូរលះបង់សញ្ញានោះ សញ្ញានោះ ដែលពួកអ្នក លះបង់ហើយ នឹងបានជាប្រយោជន៍ បានសេចក្តីសុខអស់កាលយូរ ម្នាល ភិក្ខុទាំងឡាយ សង្ខារទាំងឡាយ មិនមែនជារបស់ពួកអ្នក ពួកអ្នកចូរលះបង់ សង្ខារទាំងនោះ សង្ខារទាំងនោះ ដែលពួកអ្នកលះបង់ហើយ នឹងបានជា ប្រយោជន៍ បានសេចក្តីសុខអស់កាលយូរ ម្នាលភិក្ខុទាំងឡាយ វិញ្ញាណមិន មែនជារបស់ពួកអ្នក ពួកអ្នកចូរលះបង់វិញ្ញាណនោះ វិញ្ញាណនោះ ដែលពួក អ្នកលះបង់ហើយ នឹងបានជាប្រយោជន៍ បានសេចក្តីសុខអស់កាលយូរ ។ ម្នាល ភិក្ខុទាំងឡាយ ពួកអ្នកសម្គាល់ហេតុនោះជាដូចម្តេច ស្មៅ ឈើ មែកឈើ ស្លឹកឈើណា ក្នុងវត្តជេតពននេះ ជនគប្បីនាំទៅក្តី ដុតក្តី ធ្វើឲ្យគួរតាម បច្ច័យក្តី នូវរបស់នោះ តើពួកអ្នកគិតយ៉ាងនេះថា ជននាំទៅក្តី ដុតក្តី ធ្វើឲ្យ គួរតាមបច្ច័យក្តី នូវពួកយើងដែរឬ ។ បពិត្រព្រះអង្គដ៏ចម្រើន ដំណើរនោះ មិនដូច្នោះទេ ។ ដំណើរនោះ ព្រោះហេតុអ្វី ។ បពិត្រព្រះអង្គដ៏ចម្រើន ( ព្រោះថា ) ខ្ញុំនក្តី របស់សម្រាប់ខ្ញុំនក្តី មិនមែនជារបស់ពួកខ្ញុំព្រះអង្គ ឡើយ ។ ម្នាលភិក្ខុទាំងឡាយ សេចក្តីនេះ ពិតយ៉ាងនេះហើយ របស់ណា មិនមែនជារបស់ពួកអ្នកទេ ពួកអ្នកចូរលះបង់របស់នោះ របស់នោះ ដែល

ពួកអ្នកលះបង់ហើយ នឹងបានជាប្រយោជន៍ បានសេចក្តីសុខ អស់កាលយូរ ម្នាលភិក្ខុទាំងឡាយ របស់អ្វី ដែលមិនមែនជារបស់ពួកអ្នក ម្នាលភិក្ខុទាំងឡាយ រូបមិនមែនជារបស់ពួកអ្នក ពួកអ្នកចូរលះបង់រូបនោះ រូបនោះ ដែលពួកអ្នកលះបង់ហើយ នឹងបានជាប្រយោជន៍ បានសេចក្តីសុខ អស់កាលយូរ ម្នាលភិក្ខុទាំងឡាយ វេទនា សញ្ញា សង្ខារ វិញ្ញាណ មិនមែនជារបស់ពួកអ្នក ពួកអ្នកចូរលះបង់វេទនា សញ្ញា សង្ខារ វិញ្ញាណនោះ វេទនា សញ្ញា សង្ខារ វិញ្ញាណនោះ ដែលពួកអ្នកលះបង់ហើយ នឹងបានជាប្រយោជន៍ បានសេចក្តីសុខ អស់កាលយូរ ។ បុគ្គលសម្លឹងឃើញលោក ដោយសភាពជារបស់សូន្យយ៉ាងនេះឯង ។

ព្រះអានន្ទមានអាយុ បានទូលសួរព្រះមានព្រះភាគយ៉ាងនេះថា បពិត្រព្រះអង្គដ៏ចម្រើន ព្រះមានព្រះភាគត្រាស់ថា លោកសូន្យ បពិត្រព្រះអង្គដ៏ចម្រើន ព្រះអង្គទ្រង់ត្រាស់ថា លោកសូន្យ តើដោយហេតុដូចម្តេច ។ ព្រះមានព្រះភាគត្រាស់ថា ម្នាលអានន្ទ ព្រោះហេតុតែធម្មជាតសូន្យចាកខ្លួន ឬចាកវត្ថុសម្រាប់ខ្លួន ហេតុនោះ ទើបតថាគតពោលថា លោកសូន្យ ម្នាលអានន្ទ ចុះធម្មជាតអ្វីសូន្យចាកខ្លួន ឬចាកវត្ថុសម្រាប់ខ្លួន ។ ភ្នែកសូន្យ រូបទាំងឡាយសូន្យ ចក្ខុវិញ្ញាណសូន្យ ចក្ខុសម្ផស្សសូន្យ សុខប្បធម្មជាតសម្រាប់ទទួលអារម្មណ៍ណាជាសុខ ឬជាទុក្ខ ឬមិនជាទុក្ខមិនជាសុខ កើតឡើងព្រោះចក្ខុសម្ផស្សជាបច្ច័យ ធម្មជាតនោះក៏សូន្យចាកខ្លួន ឬចាកវត្ថុសម្រាប់ខ្លួន ត្រចៀកសូន្យ សំឡេងទាំងឡាយសូន្យ ច្រមុះសូន្យ ក្លិនទាំងឡាយសូន្យ អណ្តាត

សុូន្យ រសទាំងឡាយសូន្យ កាយសូន្យ ផុស្សទាំងឡាយសូន្យ មនះសូន្យ ធម្មារម្មណ៍សូន្យ មនោវិញ្ញាណសូន្យ មនោសម្ផស្សសូន្យ មួយទៀត សូម្បី ធម្មជាតសម្រាប់ទទួលអារម្មណ៍ណាជាសុខ ឬជាទុក្ខ ឬមិនជាទុក្ខមិនជាសុខ កើតឡើងព្រោះមនោសម្ផស្សជាបច្ច័យ ធម្មជាតនោះក៏សូន្យចាកខ្លួន ឬចាកវត្ថុ សម្រាប់ខ្លួន ម្នាលអានន្ទ ព្រោះហេតុតែធម្មជាតសូន្យចាកខ្លួន ឬចាកវត្ថុ សម្រាប់ខ្លួន ទើបតថាគតពោលថា លោកសូន្យ ។ បុគ្គលសម្លឹងឃើញ លោក ដោយសភាពជារបស់សូន្យយ៉ាងនេះឯង ។

ម្នាលគាមិណិ កាលបុគ្គលឃើញតាមពិត នូវការកើតឡើងនៃធម៌ ដ៏បរិសុទ្ធ និងការដាច់តនៃសង្ខារដ៏បរិសុទ្ធ ភ័យនោះ មិនមានទេ កាលណា បុគ្គលឃើញលោកថា ស្មើគ្នានឹងស្មៅ ឬឈើ ដោយ ប្រាជ្ញា បុគ្គលមិនគប្បីប្រាថ្នារបស់ដទៃណាមួយឡើយ វៀរលែង តែព្រះនិព្វាន ដែលមិនមានបដិសន្ធិ ។

បុគ្គលសម្លឹងឃើញលោក ដោយសភាពជារបស់សូន្យយ៉ាងនេះឯង ។

មួយទៀត ព្រះមានព្រះភាគទ្រង់ត្រាស់ដូច្នេះថា ម្នាលភិក្ខុទាំងឡាយ យ៉ាងនេះមែនហើយ ភិក្ខុស្វែងរករូប រហូតដល់ដំណើររបស់រូប ស្វែងរក-វេទនា រហូតដល់ដំណើររបស់វេទនា ស្វែងរកសញ្ញា រហូតដល់ដំណើរ របស់សញ្ញា ស្វែងរកសង្ខារទាំងឡាយ រហូតដល់ដំណើររបស់សង្ខារទាំង ឡាយ ស្វែងរកវិញ្ញាណ រហូតដល់ដំណើររបស់វិញ្ញាណ កាលភិក្ខុនោះស្វែង រករូប រហូតដល់ដំណើររបស់រូប ស្វែងរកវេទនា រហូតដល់ដំណើររបស់

វេទនា ស្វែងរកសញ្ញា រហូតដល់ដំណើររបស់សញ្ញា ស្វែងរកសង្ខារទាំងឡាយ រហូតដល់ដំណើររបស់សង្ខារទាំងឡាយ ស្វែងរកវិញ្ញាណ រហូតដល់ដំណើររបស់វិញ្ញាណ សេចក្តីប្រកាន់ណារបស់ភិក្ខុណាថា អញក្តី របស់អញក្តី អញមានក្តី សូម្បីសេចក្តីប្រកាន់នោះ របស់ភិក្ខុនោះ ក៏មិនមានទេ ។ បុគ្គលសម្លឹងឃើញលោក ដោយសភាពជារបស់សូន្យ យ៉ាងនេះឯង ។

ពាក្យថា អ្នកចូរសម្លឹងឃើញលោក ដោយសភាពជារបស់សូន្យ គឺអ្នកចូរសម្លឹងមើល ចូរពិចារណា ចូរប្រៀបផ្ទឹម ចូររំពឹង ចូរធ្វើឲ្យប្រាកដ ចូរធ្វើឲ្យច្បាស់លាស់នូវលោក ដោយសភាពជារបស់សូន្យ ហេតុនោះ ( ទ្រង់ត្រាស់ថា ) អ្នកចូរសម្លឹងឃើញលោក ដោយសភាពជារបស់សូន្យ ។

[ ៧៤ ] ពាក្យថា មោឃរាជ របស់បទថា ម្នាលមោឃរាជអ្នកចូរមានស្មារតីគ្រប់កាល គឺព្រះមានព្រះភាគត្រាស់ហៅព្រាហ្មណ៍នោះចំឈ្មោះ ។ ពាក្យថា គ្រប់កាល គឺអស់កាលទាំងពួង ។បេ។ ក្នុងគំនរវ័យជាបំផុត ។ ពាក្យថា មានស្មារតី គឺមានស្មារតីដោយហេតុ ៤ គឺកំពុងចម្រើនកាយានុបស្សនាសតិប្បដ្ឋានក្នុងកាយ ឈ្មោះថា មានស្មារតី ។បេ។ បុគ្គលនោះ លោកហៅថា មានស្មារតី ហេតុនោះ ( ទ្រង់ត្រាស់ថា ) ម្នាលមោឃរាជ អ្នកចូរមានស្មារតីគ្រប់កាល ។

[ ៧៥ ] ពាក្យថា បុគ្គលដកអត្តានុទិដ្ឋិចេញ អធិប្បាយថា សក្កាយទិដ្ឋិមានវត្ថុ ២០ លោកហៅថា អត្តានុទិដ្ឋិ ។ បុថុជ្ជនអ្នកមិនចេះដឹង ក្នុងលោកនេះ មិនឃើញពួកព្រះអរិយៈ មិនឈ្លាសវៃចំពោះអរិយធម៌ មិនបាន

ទូន្មានខ្លួនក្នុងអរិយធម៌ មិនឃើញពួកសប្បុរស មិនឈ្លាសវៃចំពោះសប្បុរិសធម៌ មិនបានទូន្មានខ្លួនក្នុងសប្បុរិសធម៌ រមែងពិចារណាឃើញនូវរូបថាខ្លួន នូវខ្លួនថាមានរូបខ្លះ នូវរូបក្នុងខ្លួនខ្លះ នូវខ្លួនក្នុងរូបខ្លះ ពិចារណាឃើញនូវវេទនា សញ្ញា សង្ខារ វិញ្ញាណថាខ្លួន នូវខ្លួនថាមានវិញ្ញាណខ្លះ នូវវិញ្ញាណក្នុងខ្លួនខ្លះ នូវខ្លួនក្នុងវិញ្ញាណខ្លះ សេចក្តីឃើញ សេចក្តីយល់ ការប្រកាន់តាមយល់ ផ្លូវដាច់ស្រយាល គឺទិដ្ឋិ សត្រូវ គឺទិដ្ឋិ ការញាប់ញ័រ គឺទិដ្ឋិ សំយោជនៈ គឺទិដ្ឋិ ការប្រកាន់ ការប្រកាន់មាំ ការប្រកាន់ស្អិត ការបបោសអង្អែលផ្លូវអាក្រក់ ផ្លូវខុស សេចក្តីខុស លទ្ធិដូចជាកំពង់ ការប្រកាន់ឆ្វេង ការប្រកាន់ឃ្វៀងឃ្វាត ការប្រកាន់វិបល្លាស ការប្រកាន់ខុស ការប្រកាន់ថាពិតក្នុងរបស់មិនពិត ទិដ្ឋិ ៦២ ទាំងប៉ុន្មានយ៉ាងនេះឯណា នេះជាអត្តានុទិដ្ឋិ ។ ពាក្យថា បុគ្គលដកអត្តានុទិដ្ឋិចេញ គឺដក ដករំលើង គាស់ គាស់រំលើង លះបង់ បន្ទោបង់ ធ្វើឲ្យវិនាស ឲ្យដល់នូវការមិនមានបែបភាពនៃអត្តានុទិដ្ឋិ ហេតុនោះ ( ទ្រង់ត្រាស់ថា ) បុគ្គលដកអត្តានុទិដ្ឋិចេញ ។

[ ៧៦ ] ពាក្យថា ទើបឆ្លងផុតចាកមច្ចុយ៉ាងនេះ គឺនឹងឆ្លងចាកមច្ចុផង ឆ្លងចាកជរាផង ឆ្លង ឆ្លងឡើង ឆ្លងរំលង ប្រព្រឹត្តកន្លងមរណៈផងយ៉ាងនេះ ហេតុនោះ ( ទ្រង់ត្រាស់ថា ) ទើបឆ្លងផុតចាកមច្ចុយ៉ាងនេះ ។

[ ៧៧ ] ពាក្យថា បុគ្គលសម្លឹងឃើញនូវលោកយ៉ាងនេះ គឺបុគ្គលកំពុងសម្លឹងមើល ពិចារណា ប្រៀបផ្ទឹម ត្រិះរិះធ្វើឲ្យច្បាស់ ធ្វើឲ្យប្រាកដនូវលោក

យ៉ាងនេះ ហេតុនោះ ( ទ្រង់ត្រាស់ថា ) បុគ្គលសម្លឹងឃើញលោកយ៉ាងនេះ ។

[ ៧៨ ] ពាក្យថា មច្ចុរាជទើបមិនឃើញ អធិប្បាយថា មារ ឈ្មោះថា មច្ចុរាជ សេចក្តីស្លាប់ ឈ្មោះថា មច្ចុរាជ ។ ពាក្យថា មិនឃើញ គឺមច្ចុរាជ មិនឃើញ មិនយល់ មិនជួបប្រទះ មិនបាន មិនបានចំពោះ ។ ដូចព្រះពុទ្ធដីកា ដែលព្រះមានព្រះភាគត្រាស់ហើយនេះថា ម្នាលភិក្ខុទាំងឡាយ ដូចម្រឹគដែលនៅក្នុងព្រៃ ត្រាច់ទៅក្នុងព្រៃធំ រមែងដើរឥតរង្កៀស ឈរឥតរង្កៀស អង្គុយឥតរង្កៀស ដេកឥតរង្កៀស ដំណើរនោះ ព្រោះហេតុអ្វី ម្នាលភិក្ខុទាំងឡាយ ព្រោះម្រឹគនុ៎ះ មិននៅក្នុងគន្លងរបស់ព្រាន យ៉ាងណាមិញ ម្នាលភិក្ខុទាំងឡាយ ភិក្ខុស្ងាត់ចាកកាមទាំងឡាយ ស្ងាត់ចាកអកុសលធម៌ទាំងឡាយ ហើយចូលបឋមជ្ឈាន ដែលមានវិតក្កៈ និងវិចារៈ មានបីតិ និងសុខ ដែលកើតអំពីសេចក្តីស្ងប់ស្ងាត់ ម្នាលភិក្ខុទាំងឡាយ ភិក្ខុនេះ តថាគតហៅថា បានធ្វើមារឲ្យខ្វាក់ សម្លាប់មិនឲ្យមានស្នាមជើង ដល់នូវការមិនឃើញដោយភ្នែកនៃមារដែលមានចិត្តបាប ម្នាលភិក្ខុទាំងឡាយ មួយទៀត ភិក្ខុព្រោះរម្ងាប់វិតក្កៈ និងវិចារៈ ចូលទុតិយជ្ឈាន ជាធម្មជាតកើតមានក្នុងសន្តានប្រកបដោយសេចក្តីជ្រះថ្លា មានសភាពជាចិត្តខ្ពស់ឯក មិនមានវិតក្កៈ និងវិចារៈ មានតែបីតិ និងសុខ ដែលកើតអំពីសមាធិ ចូលតតិយជ្ឈាន ចតុត្ថជ្ឈាន ម្នាលភិក្ខុទាំងឡាយ ភិក្ខុនេះ តថាគតហៅថា បានធ្វើនូវមារឲ្យខ្វាក់ សម្លាប់មិនឲ្យមានស្នាមជើង ដល់នូវការមិនឃើញដោយភ្នែក នៃមារដែលមានចិត្តបាប ម្នាលភិក្ខុទាំងឡាយ មួយទៀត ភិក្ខុ ព្រោះកន្លងរូបសញ្ញា ដោយសព្វ

គ្រប់ ធ្វើបដិឃសញ្ញាឲ្យវិនាស មិនធ្វើទុកក្នុងចិត្តនូវនានត្តសញ្ញា ហើយចូលអាកាសានញ្ចាយតនៈ ដោយបរិកម្មថា អាកាសមិនមានទីបំផុត ម្នាលភិក្ខុទាំងឡាយ ភិក្ខុនេះ តថាគតហៅថា បានធ្វើមារឲ្យខ្វាក់ សម្លាប់មិនឲ្យមានស្នាមជើង ដល់នូវការមិនឃើញដោយភ្នែក នៃមារដែលមានចិត្តបាប ម្នាលភិក្ខុទាំងឡាយ មួយទៀត ភិក្ខុកន្លងអាកាសានញ្ចាយតនៈ ដោយសព្វគ្រប់ ហើយចូលវិញ្ញាណញ្ចាយតនៈ ដោយបរិកម្មថា វិញ្ញាណមិនមានទីបំផុត កន្លងវិញ្ញាណញ្ចាយតនៈ ដោយសព្វគ្រប់ ហើយចូលអាកិញ្ចញ្ញាយតនៈ ដោយបរិកម្មថា អ្វីតិចតួចមិនមាន កន្លងអាកិញ្ចញ្ញាយតនៈ ដោយសព្វគ្រប់ ហើយចូលនេវសញ្ញានាសញ្ញាយតនៈ កន្លងនេវសញ្ញានាសញ្ញាយតនៈ ដោយសព្វគ្រប់ ហើយចូលសញ្ញាវេទយិតនិរោធ លុះភិក្ខុនោះ បានឃើញដោយប្រាជ្ញាអាសវៈទាំងឡាយក៏អស់រលីង ម្នាលភិក្ខុទាំងឡាយ ភិក្ខុនេះ តថាគតហៅថា បានធ្វើមារឲ្យខ្វាក់ សម្លាប់មិនឲ្យមានស្នាមជើង ដល់នូវការមិនឃើញដោយភ្នែកនៃមារដែលមានចិត្តបាប ឆ្លងតណ្ហាឈ្មោះវិសត្តិកាក្នុងលោកបាន ភិក្ខុនោះរមែងដើរឥតរង្កៀស ឈរឥតរង្កៀស អង្គុយឥតរង្កៀស ដេកឥតរង្កៀសដំណើរនោះ ព្រោះហេតុអ្វី ម្នាលភិក្ខុទាំងឡាយ ព្រោះថា ភិក្ខុនោះមិននៅក្នុងគន្លងរបស់មារមានចិត្តបាបក៏យ៉ាងនោះដែរ ហេតុនោះ ( ទ្រង់ត្រាស់ថា ) មច្ចុរាជទើបមិនឃើញ ។ ហេតុនោះ ព្រះមានព្រះភាគត្រាស់ថា

ម្នាលមោឃរាជ អ្នកចូរមានស្មារតីគ្រប់កាល សម្លឹងឃើញលោក ដោយសភាពជារបស់សូន្យ ( ព្រោះ ) បុគ្គលដកអត្តានុទិដ្ឋិចេញ ទើបឆ្លងផុតចាកមច្ចុ បុគ្គលសម្លឹងឃើញលោកយ៉ាងនេះ មច្ចុរាជ ទើបមិនឃើញ ។

ព្រមដោយការចប់គាថា ។បេ។ បពិត្រព្រះអង្គដ៏ចម្រើន ព្រះមានព្រះភាគជាសាស្តារបស់ខ្ញុំព្រះអង្គ ខ្ញុំព្រះអង្គសូមជាសាវ័ក ។

**មោឃរាជមាណវកបញ្ហានិទ្ទេសទី ១៥ ចប់**

# អដ្ឋកថា

## មោឃរាជមាណវកប្បញ្ហានិទ្ទេស

គប្បីជ្រាបវិនិច្ឆ័យក្នុងមោឃរាជសូត្រទី ១៥ ដូចតទៅនេះ

[ ៥៨ ] បទថា **ទ្វាហំ** បានដល់ ខ្ញុំព្រះអង្គបានទូលសួរ ២ ដងហើយ ព្រោះថា មោឃរាជមាណពនោះ កាលមុន ទូលសួរព្រះមានព្រះភាគអស់ វារៈ ២ ដង ក្នុងកាលចប់អជិតសូត្រ និងតិស្សមេត្តេយ្យសូត្រ ។ តែព្រះ មានព្រះភាគ ទ្រង់រង់ចាំឲ្យមោឃរាជមាណពមានឥន្ទ្រិយចាស់ក្លាសិន ទើប ទ្រង់មិនព្យាករ ។ ដោយហេតុនោះ ទើបមោឃរាជមាណពទូលសួរថា **ទ្វាហំ សក្ក អបុច្ឆិស្សំ** ដូច្នេះ ។ បទថា **យាវតតិយញ្ច ទេវិសិ ព្យាករោតីតិ មេ សុតំ** សេចក្ដីថា ខ្ញុំព្រះអង្គបានឮមកយ៉ាងនេះថា ព្រះមានព្រះភាគ ជាឥសី វិសុទ្ធិទេព ជាព្រះសម្មាសម្ពុទ្ធ មានអ្នកទូលសួរបញ្ហាដែលប្រពៃដល់ហេតុ ជាលើកទី ៣ ទ្រង់រមែងព្យាករ ។ បានឮថា មោឃរាជមាណព បានស្ដាប់ មកយ៉ាងនេះ ត្រង់ច្រាំងស្ទឹងគោធាវរីនោះឯង ដោយហេតុនោះ ទើបមោឃ-រាជមាណពទូលថា **ព្យាករោតីតិ មេ សុតំ** ដូច្នេះ ពាក្យណាដែលគប្បី ពោលក្នុងនិទ្ទេសនៃគាថានេះ ពាក្យនោះ មានន័យដូចពោលមកហើយ ខាង ដើមនោះឯង ។

[ ៦២ ] បទថា **អយំ លោកោ** បានដល់ មនុស្សលោក ។ បទថា **បរោ លោកោ** បានដល់ លោកដ៏សេស វៀរមនុស្សលោកនេះ ។ បទថា **សទេវកោ** បានដល់ លោកដ៏សេស គឺលោកដែលប្រកបដោយលោកនៃ

ឧបបត្តិទេព និងសម្មតិទេព វៀរលែងតែព្រហ្មលោក ។ បទថា **ព្រហ្ម-លោកោ សទេវកោ** ត្រឹមតែជាការលើកឧទាហរណ៍នៃពាក្យជាដើមថា **សទេវកោ លោកោ** ។ ដោយហេតុនោះ គប្បីជ្រាបលោកទាំងអស់ មានប្រការដូចបានពោលហើយ ។

[ ៦៧ ] ដោយបទថា **ឯវំ អភិក្កន្តទស្សាវី** មោឃរាជមាណពសម្តែងថា ព្រះមានព្រះភាគទ្រង់ឃើញធម៌ដ៏ប្រសើរយ៉ាងនេះ ទ្រង់អាចឃើញអធ្យាស្រ័យ អធិមុត្តិ គតិ ដែលប្រព្រឹត្តទៅខាងមុខរបស់លោក ។ ព្រមដោយទេវលោកបាន ។

[ ៧២ ] បទថា **សុញ្ញតោ លោកំ អវេក្ខស្សុ** សេចក្តីថា ចូរអ្នកមើលលោកដោយភាពជារបស់សូន្យ ដោយអាការ ២ យ៉ាង គឺដោយការកំណត់ការមិនប្រព្រឹត្តទៅក្នុងអំណាច ១ ដោយពិចារណាឃើញសង្ខារទទេ ១ ។ បទថា **អត្តានុទិដ្ឋឹ ឩហច្ច** បានដល់ ដកនូវការឃើញថា ជាតួខ្លួនចេញ ។

[ ៧៣ ] បទថា **លុជ្ជតិ** បានដល់ បែកធ្លាយ ។ ឈ្មោះថា **ចក្ខុ** ព្រោះឃើញ ។ ចក្ខុនោះ ឲ្យសម្រេចភាពជាវត្ថុ និងទ្វារតាមសមគួរដល់ចក្ខុវិញ្ញាណជាដើម តាំងនៅត្រង់កណ្តាលរង្វង់ពណ៌ខ្មៅ ដែលព័ទ្ធដោយរង្វង់ពណ៌ស ដែលជាសសម្ភារចក្ខុ តាំងនៅក្នុងបរិវេណដែលឃើញបាន ដែលជាទីកើតរបស់សរីរសណ្ឋាននៃវត្ថុដែលតាំងនៅត្រង់មុខ ។ ឈ្មោះថា **រូបា** ព្រោះអត្ថថា រមែងបែកធ្លាយ អធិប្បាយថា រូបទាំងឡាយ ដល់នូវភាពវិការ

ដោយពណ៌ រមែងប្រកាសភាវៈដល់ចិត្ត ។ ឈ្មោះថា **ចក្ខុវិញ្ញាណំ** ព្រោះវិញ្ញាណប្រព្រឹត្តទៅហើយអំពីចក្ខុ ឬវិញ្ញាណរបស់ចក្ខុ ឬវិញ្ញាណអាស្រ័យចក្ខុ ។ សម្ផស្សប្រព្រឹត្តទៅហើយដោយចក្ខុ ឈ្មោះថា **ចក្ខុសម្ផស្សោ** ។ បទថា **ចក្ខុសម្ផស្សប្បច្ចយា** បានដល់ ព្រោះផស្សៈដែលសម្បយុត្តដោយចក្ខុវិញ្ញាណជាបច្ច័យ ។ បទថា **វេទយិតំ** បានដល់ ការសោយអារម្មណ៍ អធិប្បាយថា ការដឹងអារម្មណ៍ ។ ឈ្មោះថា **សុខំ** ព្រោះធ្វើឲ្យកើតសេចក្ដីសុខ អធិប្បាយថា សុខវេទនាកើតដល់បុគ្គលណា រមែងធ្វើបុគ្គលនោះ ឲ្យមានសេចក្ដីសុខ ។ ឬឈ្មោះថា **សុខំ** ព្រោះខាំស៊ី និងជីកដោយល្អនូវអាពាធផ្លូវកាយ និងចិត្ត ។ ឈ្មោះថា **ទុក្ខំ** ព្រោះអត់ធន់បានលំបាក អធិប្បាយថា ទុក្ខវេទនាកើតដល់បុគ្គលណា រមែងធ្វើបុគ្គលនោះ ឲ្យមានសេចក្ដីទុក្ខ ។ ឈ្មោះថា **អទុក្ខមសុខំ** ព្រោះមិនទុក្ខមិនសុខ ។ **ម** អក្ខរៈលោកពោលដោយបទសន្ធិ ។ ម្យ៉ាងទៀត ចក្ខុសម្ផស្សនោះ ជាបច្ច័យដល់វេទនាដែលសម្បយុត្តជាមួយខ្លួន ៨ ប្រការ គឺសហជាតប្បច្ច័យ ១ អញ្ញមញ្ញប្បច្ច័យ ១ និស្សយប្បច្ច័យ ១ វិបាកប្បច្ច័យ ១ អាហារប្បច្ច័យ ១ សម្បយុត្តប្បច្ច័យ ១ អត្ថិប្បច្ច័យ ១ អវិគតប្បច្ច័យ ១ ។ ជាបច្ច័យដល់វេទនាដែលសម្បយុត្តជាមួយសម្បដិច្ឆន្នចិត្ត ៥ ប្រការ គឺអនន្តរប្បច្ច័យ ១ សមនន្តរប្បច្ច័យ ១ ឧបនិស្សយប្បច្ច័យ ១ នត្ថិប្បច្ច័យ ១ វិគតប្បច្ច័យ ១ ជាបច្ច័យដល់វេទនាដែលសម្បយុត្តជាមួយសន្តីរណចិត្តជាដើម ដោយបច្ច័យ ១ គឺឧបនិស្សយប្បច្ច័យ ។

ឈ្មោះថា **សោតំ** ព្រោះបានឮ ។ សោតៈនោះ ធ្វើភាពជាវត្ថុ និងទ្វារឲ្យសម្រេចតាមសមគួរ ដល់សោតវិញ្ញាណជាដើម តាំងនៅក្នុងប្រទេសមានសណ្ឋានល្មមស៊ិកម្រាមដៃចូលទៅបាន មានរោមទន់ និងក្រហម នៅខាងក្នុងប្រទេសសសម្ភារសោតៈ ។ ឈ្មោះថា **សទ្ទា** ព្រោះបញ្ចូនសំឡេង អធិប្បាយថា បន្លឺចេញ ។ ឈ្មោះថា **ឃានំ** ព្រោះហិតស្រូប ។ ឃានៈនោះធ្វើនូវភាពជាវត្ថុ និងទ្វារឲ្យសម្រេចតាមសមគួរដល់ឃានវិញ្ញាណជាដើម តាំងនៅក្នុងទីមានសណ្ឋានដូចជើងពពែ ខាងក្នុងរន្ធរបស់សសម្ភារឃានៈ ។ ឈ្មោះថា **គន្ធា** ព្រោះផ្សាយទៅ អធិប្បាយថា ប្រកាសនូវវត្ថុរបស់ខ្លួន ។ ឈ្មោះថា **ជិវ្ហា** ព្រោះហៅនូវជីវិត ឬឈ្មោះថា **ជិវ្ហា** ព្រោះអត្ថថា លិទ្ធ ជិវ្ហានោះ ធ្វើនូវភាពជាវត្ថុ និងទ្វារឲ្យសម្រេចតាមសមគួរដល់ជិវ្ហាវិញ្ញាណជាដើម តាំងនៅក្នុងទីដែលមានសណ្ឋាន ដូចគ្នានឹងចុងត្របកឈូកដែលរីកក្នុងកណ្តាលផ្ទៃខាងលើ វៀរចុង គល់ និងទទឹងរបស់សសម្ភារជិវ្ហា ។ ឈ្មោះថា **រសា** ព្រោះជាទីត្រេកអររបស់សត្វ អធិប្បាយថា គាប់ចិត្ត ។

ឈ្មោះថា **កាយោ** ព្រោះជាប្រកពកើតនៃធម៌ដែលជាអាសវៈគួរខ្ពើម ។ ពាក្យថា ប្រកពកើត បានដល់ ទីកើត ។ ឈ្មោះថា ការប្រព្រឹត្តទៅនៃរូបមានចិត្តគ្រប់គ្រង មាននៅក្នុងកាយនោះដរាបណា កាយប្បសាទ ក៏គង់ជាវត្ថុ និងទ្វារ ឲ្យសម្រេចតាមសមគួរដល់វិញ្ញាណជាដើមតាំងនៅ ដោយច្រើនក្នុងឧបាទិន្នករូបនោះ ។ ឈ្មោះថា **ផោដ្ឋព្វា** ព្រោះពាល់ត្រូវ ។ ឈ្មោះថា **មនោ** ព្រោះដឹង អធិប្បាយថា ដឹងច្បាស់ ។ ឈ្មោះថា **ធម្មា** ព្រោះទ្រទ្រង់ទុកនូវ

លក្ខណៈរបស់ខ្លួន ។ បទថា **មនោ** បានដល់ ភវង្គ មួយអន្ទើដោយអាវជ្ជនៈ ។ បទថា **ធម្មា** បានដល់ ធម្មារម្មណ៍ដ៏សេស វៀរព្រះនិព្វាន ។ បទថា **មនោវិញ្ញាណំ** បានដល់ ជវនមនោវិញ្ញាណ ។ បទថា **មនោ-សម្ផស្សោ** បានដល់ ផស្សៈដែលសម្បយុត្តដោយជវនមនោវិញ្ញាណនោះ ។ មនោសម្ផស្សនោះ ជាបច្ច័យដល់វេទនាដែលសម្បយុត្តដោយអំណាចបច្ច័យ ៧ ដ៏សេស វៀរវិបាកប្បច្ច័យ ជាបច្ច័យដល់វេទនាបន្ទាប់ទៅ ដោយបច្ច័យ ៧ នោះឯង ជាបច្ច័យដល់វេទនាដ៏សេស ដោយឧបនិស្សយប្បច្ច័យតែម្យ៉ាង ។

បទថា **អវសិយបវត្តសល្លក្ខណាវសេន វា** សេចក្តីថា ដោយអំណាចការឃើញ ការមើលសង្ខារ ប្រព្រឹត្តទៅដោយមិនទៅក្នុងអំណាច ។ បទថា **រូបេ វសោ ន លព្ភតិ** បានដល់ មិនបានអំណាច គឺភាពជាធំក្នុងរូប ។ សូម្បីក្នុងវេទនាជាដើម ក៏ន័យនេះដូចគ្នា ។

បទថា **នាយំ ភិក្ខវេ កាយោ តុម្ហាកំ** សេចក្តីថា ពិតហើយ កាលខ្លួនមាន តែងមានវត្ថុដែលទាក់ទងដោយខ្លួន តែខ្លួននោះឯងមិនមាន ។ ព្រោះដូច្នោះ ទើបព្រះមានព្រះភាគត្រាស់ថា មិនមែនជារបស់អ្នកទាំងឡាយទេ ។ បទថា **នាបិ អញ្ញេសំ** បានដល់ ខ្លួនរបស់អ្នកដទៃ ឈ្មោះថា អ្នកដទៃ កាលខ្លួននោះមាន ខ្លួនរបស់អ្នកដទៃក៏គប្បីមាន តែខ្លួននោះក៏មិនមាន ព្រោះដូច្នោះ ទើបព្រះមានព្រះភាគត្រាស់ថា ទាំងមិនមែនជារបស់ជនទាំងឡាយដទៃទេ ។ បទថា **បុរាណមិទំ ភិក្ខវេ កម្មំ** បានដល់ កាយនេះមិនមែនកម្មចាស់ តែកាយនេះកើតអំពីកម្មចាស់ ព្រោះហេតុនោះ ទើបត្រាស់យ៉ាង

នេះ ដោយបច្ចយហារ ។ បទថា **អភិសង្ខតំ** ជាដើម ទ្រង់ត្រាស់ហើយ ព្រោះមានលិង្គស្មើគ្នា គឺជានបុំសកលិង្គដូចគ្នា ។ ពាក្យនេះ ស្មើគ្នានឹងពាក្យមុន គឺពាក្យថា **កម្មំ** ដោយអំណាចនៃកម្មហារនោះឯង ។ គប្បីឃើញអត្ថក្នុងបទនេះ យ៉ាងនេះថា បទថា **អភិសង្ខតំ** បានដល់ បច្ច័យទាំងឡាយតាក់តែង ។ បទថា **អភិសញ្ចេតយិតំ** បានដល់ មានចេតនាជាទីតាំង មានចេតនាជាមូលហេតុ ។ បទថា **វេទនិយំ** បានដល់ ជាទីតាំងនៃវេទនា ។

បទថា **រូបេ សារោ ន លព្ភតិ** បានដល់ មិនបាននូវសារៈក្នុងរូបថាជារបស់ទៀងជាដើម ។ សូម្បីក្នុងវេទនាជាដើមក៏មានន័យដូចគ្នា ។ បទថា **រូបំ អស្សារំ និស្សារំ** បានដល់ រូបដែលមិនមានខ្លឹមសារ និងវៀរចាកខ្លឹមសារ ។ បទថា **សារាបគតំ** បានដល់ ប្រាសចាកសារៈ ។ បទថា **និច្ចសារសារេន វា** បានដល់ ដោយសារៈថាទៀងប្រព្រឹត្តទៅ ព្រោះឈានកន្លងកង្ខក្ខណៈ មិនមានសារៈ ដោយនិច្ចសារៈ ព្រោះមិនមានការទៀងណាមួយឡើយ ។ បទថា **សុខសារសារេន វា** បានដល់ ដោយសារៈមានសុខសារៈ ព្រោះមិនមានសុខសារៈណាមួយ ដែលកន្លងវិមុត្តិសុខទៅបាន ។ បទថា **អត្តសារសារេន វា** បានដល់ ដោយអត្តសារៈ និងវត្ថុដែលទាក់ទងដោយខ្លួនជាសារៈ ។ បទថា **និច្ចេន វា** បានដល់ ដោយភាពទៀង ព្រោះមិនមានការទៀងណាមួយ ប្រព្រឹត្តទៅ ព្រោះឈានកន្លងកង្ខក្ខណៈ ។ បទថា **ធុវេន វា** បានដល់ ដោយការស្ថិតស្ថេរ ព្រោះមិនមានអ្វីមួយជាការស្ថិតស្ថេរ សូម្បីក្នុងពេលមាន ក៏ប្រព្រឹត្តទៅទាក់ទងដោយ

បច្ច័យ ។ បទថា **សស្សតេន វា** បានដល់ ដោយការមាំទាំ ព្រោះមិនមានអ្វីមានសព្វកាលទាំងពួងឡើយ ។ បទថា **អវិបរិណាមធម្មេន វា** បានដល់ ដោយមានការមិនប្រែប្រួលទៅជាធម្មតា ព្រោះមិនមានអ្វីមួយ ដែលមិនប្រែប្រួលទៅជាប្រក្រតី ដោយអំណាចនៃការចាស់ និងការបែកធ្លាយបាន ។

បទថា **ចក្ខុ សុញ្ញំ អត្តេន វា អត្តនិយេន វា**[១] សេចក្តីថា សូន្យចាកខ្លួនដែលកំណត់យ៉ាងនេះថា អ្នកធ្វើ អ្នកសោយ ចូលទៅឯង និងចាកបរិក្ខារដែលជារបស់ខ្លួន ព្រោះការមិនមានខ្លួននោះឯង អធិប្បាយថា ធម្មជាតដែលជាលោកិយ មានចក្ខុជាដើម ហៅថា សូន្យ ព្រោះខ្លួន និងវត្ថុដែលទាក់ទងដោយខ្លួន មិនមានក្នុងធម្មជាតដែលជាលោកិយ មានចក្ខុជាដើមនេះ សូម្បីលោកុត្តរធម៌ក៏សូន្យចាកខ្លួន និងវត្ថុដែលទាក់ទងដោយខ្លួន លោកអធិប្បាយថា ធម៌ដែលផុតទៅចាកការសូន្យរមែងមិនមាន លោកពោលដល់ការមិនមានសារៈក្នុងខ្លួន និងវត្ថុដែលទាក់ទងដោយខ្លួន ក្នុងធម៌នោះ ។ ក្នុងលោក កាលពោលថា ផ្ទះសូន្យ ឆ្នាំងសូន្យ មិនមែនមិនមានផ្ទះ ឬឆ្នាំង ។ លោកពោលដល់ការមិនមានវត្ថុដទៃក្នុងផ្ទះ និងក្នុងឆ្នាំងនោះ ។ ព្រះមានព្រះភាគត្រាស់សេចក្តីនេះថា របស់ណាមួយ ក្នុងផ្ទះ និងក្នុងឆ្នាំងនោះមិនមាន ផ្ទះ និងឆ្នាំងនោះក៏សូន្យចាកវត្ថុនោះ វត្ថុណា នៅមានសេសសល់ក្នុងផ្ទះ និងក្នុងឆ្នាំងនោះ វត្ថុនោះ កាលនៅមាន ក៏ដឹងថា វត្ថុនេះមាន ។ សេចក្តីនេះ ដូចគ្នាក្នុងគម្ពីរញាយៈ និងគម្ពីរសទ្ទៈ ។ ក្នុងសូត្រនេះ លោក

---

១- បិដកខ្មែរមិនមានបទនេះ ។

ពោលដល់លក្ខណៈនៃអនត្តានោះឯង ដោយប្រការដូច្នេះ ។

បទថា **អនិស្សរិយតោ** បានដល់ ដោយមិនប្រព្រឹត្តទៅក្នុងអំណាច ក្នុងភាពជាធំរបស់ខ្លួន ។ បទថា **អកាមការិយតោ** បានដល់ ដោយអំណាច នៃការធ្វើតាមការពេញចិត្តរបស់ខ្លួនមិនបាន ។ បទថា **អផាសុនិយតោ** បាន ដល់ ដោយការមិនមានទីពឹង ដើម្បីការតាំងនៅ ។ បទថា **អវសវត្តនតោ** បានដល់ ដោយមិនប្រព្រឹត្តទៅក្នុងអំណាចរបស់ខ្លួន ។ បទថា **បរតោ** បាន ដល់ ដោយមិនទៀង គឺដោយប្រព្រឹត្តទៅទាក់ទងដោយបច្ច័យ ។ បទថា **វិវិត្តតោ** បានដល់ ដោយមិនមានសារៈ ។ បទថា **សុញ្ញំ** បានដល់ ទាំងមូល ។ ការកើតឡើងព្រមនៃធម៌ដែលប្រព្រឹត្តទៅ ដោយអំណាចនៃការកើតឡើង ដោយបច្ច័យទាំងអស់ វៀរចាកអ្នកធំ ( ព្រះម្ចាស់សួគ៌ ) កាល និងបកតិ ឈ្មោះថា **សុញ្ញំ** ។ម្យ៉ាងទៀត ឈ្មោះថា **សុញ្ញំ** ព្រោះជាគំនរនៃធម៌សុទ្ធៗ វៀរចាកវត្ថុដែលទាក់ទងនឹងខ្លួន ។ បទថា **សុញ្ញំ ធម្មសមុប្បាទំ សុញ្ញំ សង្ខារសន្តតិំ** បានដល់ កាលឃើញនូវការបន្តនៃសង្ខារ ដែលមិនដាច់ខ្សែ ទាំងមូលយ៉ាងនោះ ។លោកពោលអត្ថតែមួយ មានសង្ខារជាដើម ២-៣ ដង ដោយអើពើ ។ កាលឃើញយ៉ាងនេះ រមែងមិនខ្លាចចំពោះមាត់នៃសេចក្តី ស្លាប់ ។ បទថា **គាមណិ** ជាពាក្យហៅ ។ បទថា **តិណកដ្ឋសមំ លោកំ** សេចក្តីថា កាលណាឃើញលោក ដែលបានដល់ខន្ធ មានចិត្តគ្រប់គ្រងនេះ ស្មើដោយស្មៅ និងឈើដោយបញ្ញា ។ កាលបុគ្គលកាន់យកនូវស្មៅ និង ឈើជាដើមក្នុងព្រៃ រមែងមិនមានបុគ្គលណាគិតថា បុគ្គលនេះ កាន់យកខ្លួន

អញ្ញ ឬវត្ថុដែលទាក់ទងដោយខ្លួនអញទៅ ឬកាលស្មៅ និងឈើជាដើម ទាំងនោះបាត់ទៅឯងខ្លះ វិនាសទៅឯងខ្លះ រមែងមិនគិតថា ខ្លួនវិនាសទៅ ឬ វត្ថុដែលទាក់ទងដោយខ្លួនវិនាសទៅ យ៉ាងណា កាលកាយនេះបាត់ទៅ វិនាសទៅ បុគ្គលកាលមិនឃើញថា ខ្លួន ឬវត្ថុដែលទាក់ទងដោយខ្លួន បែកធ្លាយទៅ ហៅថា ឃើញលោកថា ស្មើគ្នានឹងស្មៅ ឬឈើដោយប្រាជ្ញា យ៉ាងនោះដូចគ្នា ។ បទថា **ន អញ្ញំ បត្ថយតេ កិញ្ចិ អញ្ញត្រ អប្បដិសន្ធិយា** បានដល់ បុគ្គលមិនប្រាថ្នាភព ឬអត្តភាពណាមួយដទៃ ក្រៅអំពីនិព្វានដែលមិនមានបដិសន្ធិ ។

បទថា **រូបំ សមន្នេសតិ** បានដល់ ស្វែងរកសារៈនៃរូប ។ បទថា **អហន្តិ វា** បានដល់ រមែងមានដោយអំណាចនៃទិដ្ឋិ ។ បទថា **មមន្តិ វា** បានដល់ រមែងមានដោយអំណាចតណ្ហា ។ បទថា **អស្មីតិ វា** បានដល់ រមែងមានដោយអំណាចមានះ ។ បទថា **តម្បិ តស្ស ន ហោតិ** បានដល់ ការប្រកាន់ ៣ យ៉ាងនោះ រមែងមានដល់បុគ្គលនោះ ។

[ ៧៥ ] បទថា **ឥធ** ត្រឹមតែជានិបាត ចុះក្នុងការអាងដល់ទីនៅ ។ **ឥធ** និបាតនេះ ទីខ្លះ លោកសំដៅដល់លោក ដូចលោកពោលទុកថា **ឥធ តថាគតោ លោកេ ឧប្បជ្ជតិ** ព្រះតថាគតទ្រង់រមែងកើតឡើងក្នុងលោកនេះ ដូច្នេះ ។ ទីខ្លះ លោកសំដៅយកសាសនា ដូចព្រះមានព្រះភាគត្រាស់ថា **ឥធេវ ភិក្ខវេ បឋមោ សមណោ ឥធ ទុតិយោ សមណោ** សមណៈទី ១ មានតែក្នុងសាសនានេះ សមណៈទី ២ ក៏មានតែក្នុងសាសនានេះ ដូច្នេះ ។

ទី២៖ លោកសំដៅយកឱកាស គឺភព ដូចសក្កទេវរាជក្រាបទូលថា

**ឥធេវ តិដ្ឋមានស្ស ទេវភូតស្ស មេ សតោ**

**បុនរាយុ ច មេ លទ្ធោ ឯវំ ជានាហិ មារិស ។**

កាលអាត្មាអញកើតជាទេវតា ស្ថិតនៅក្នុងឱកាសនេះ

អាត្មាអញ បានអាយុថ្មីទៀត ម្នាលគ្នាយើង អ្នកចូរដឹង

យ៉ាងនេះចុះ ដូច្នេះ ។

កន្លែង២៖ សំដៅយកត្រឹមតែបទបូរណៈ គឺត្រឹមតែធ្វើបទឲ្យពេញប៉ុណ្ណោះ ដូចព្រះមានព្រះភាគត្រាស់ថា **ឥធាហំ ភិក្ខវេ ភុត្តាវី អស្សំ បវារិតោ** ម្នាលភិក្ខុទាំងឡាយ តថាគតបរិភោគស្រេចហើយ ហាមភត្តហើយ ដូច្នេះ ។ តែក្នុងទីនេះ គប្បីជ្រាបថា លោកពោលសំដៅដល់លោក ។

ក្នុងបទថា **អស្សុតវា បុថុជ្ជនោ** គប្បីជ្រាបថា បុគ្គលអ្នកមិនស្តាប់ ព្រោះមិនមានអាគម និងអធិគម គឺការសិក្សា និងការសម្រេច បុគ្គលណា មិនមានអាគម បដិសេធទិដ្ឋិ ព្រោះប្រាសចាកការរៀន ការសាកសួរ និង វិនិច្ឆ័យក្នុងខន្ធ ធាតុ អាយតនៈ បច្ចយាការ និងសតិប្បដ្ឋានជាដើម និងមិន មានអធិគម ព្រោះមិនសម្រេចធម៌ដែលគួរសម្រេច ដោយកិច្ចបដិបត្តិ បុគ្គល នោះ គប្បីជ្រាបថា ជាអ្នកមិនបានស្តាប់ ព្រោះមិនមានអាគម និងអធិគម ។

ជននេះ ឈ្មោះថា បុថុជ្ជន ព្រោះហេតុទាំងឡាយ មានការកើត

កិលេសក្រាស់ជាដើម ឬជននេះ ឈ្មោះថា ជាអ្នកក្រាស់ ព្រោះ

ភាពជាអ្នកកើតកិលេសក្រាស់ ឈមចុះខាងក្នុង ។

ពិតហើយ ជននោះឈ្មោះថា បុថុជ្ជន ដោយហេតុទាំងឡាយ មានការញុំាងកិលេសក្រាស់ គឺមានប្រការផ្សេងៗ ឲ្យកើតឡើង ដូចលោកពោល ( ខុទ្ទកនិកាយ មហានិទ្ទេស ) ថា

ឈ្មោះថា បុថុជ្ជន ព្រោះញុំាងកិលេសក្រាស់ឲ្យកើត ។ ឈ្មោះថា បុថុជ្ជន ព្រោះមិនទាន់កម្ចាត់បង់សក្កាយទិដ្ឋិដ៏ក្រាស់ ។ ឈ្មោះថា បុថុជ្ជន ព្រោះជាអ្នកយល់មុខសាស្តាទាំងឡាយដ៏ច្រើន ។ ឈ្មោះថា បុថុជ្ជន ព្រោះជាអ្នកត្រូវគតិទាំងពួងដ៏ច្រើនរួបរឹត ។ ឈ្មោះថា បុថុជ្ជន ព្រោះតាក់តែងដោយអភិសង្ខារផ្សេងៗ ដ៏ច្រើន ។ ឈ្មោះថា បុថុជ្ជន ព្រោះត្រូវជំនន់ផ្សេងៗ ដ៏ច្រើនបន្សាត់ទៅ ។ ឈ្មោះថា បុថុជ្ជន ព្រោះអន្ទះអន្ទែងដោយសេចក្តីអន្ទះអន្ទែង ផ្សេងៗ ដ៏ច្រើន ។ ឈ្មោះថា បុថុជ្ជន ព្រោះត្រូវសេចក្តីក្តៅក្រហាយផ្សេងៗ ដ៏ច្រើនដុតហើយ ។ ឈ្មោះថា បុថុជ្ជន ព្រោះជាអ្នកត្រេកអរ ចង់បាន ជ្វាក់ចុះ ងុលងប់ ជ្រុលជ្រប់ ជាប់នៅ ជំពាក់នៅ សាន់វ៉ាន់នៅក្នុងកាមគុណទាំង ៥ ដ៏ច្រើន ។ ឈ្មោះថាបុថុជ្ជន ព្រោះត្រូវនីវរណៈទាំង ៥ ដ៏ច្រើនខ្ទប់ រាំង ហ៊ុម បិទបាំង គ្របហើយ ។

ព្រោះជាអ្នកឈមចុះក្នុងខាងក្នុងនៃជនទាំងឡាយដែលក្រាស់ គឺដែលកន្លងនូវធម៌ បែរខ្នងឲ្យអរិយធម៌ ប្រព្រឹត្តថោកថយ ។ ម្យ៉ាងទៀត ឈ្មោះថា បុថុជ្ជន ព្រោះជននេះក្រាស់ ដល់នូវការរាប់បែបគ្នា មិនលាយឡំជាមួយ

ព្រះអរិយបុគ្គល ដែលប្រកបដោយគុណ មានសីល និងសុត្តៈជាដើម ។ ដោយ ២ បទនេះ យ៉ាងនេះថា **អស្សុតវា បុថុជ្ជនោ** លោកពោលដល់បុថុជ្ជន ២ ពួកថា

ព្រះពុទ្ធជាផៅពង្សនៃព្រះអាទិត្យ ត្រាស់ដល់បុថុជ្ជន ២ ពួក គឺ អន្ធបុថុជ្ជន ១ ពួក កល្យាណបុថុជ្ជន ១ ពួក ។

គប្បីជ្រាបថា លោកពោលដល់អន្ធបុថុជ្ជន ។

ក្នុងនិទ្ទេសថា **អរិយានំ អទស្សាវី** ជាដើម ព្រះពុទ្ធ ព្រះបច្ចេកពុទ្ធ និងព្រះសាវករបស់ព្រះពុទ្ធ លោកហៅថា អរិយៈ ព្រោះឆ្ងាយចាកកិលេសទាំងឡាយ ព្រោះមិននាំទៅក្នុងផ្លូវវិនាស ព្រោះនាំទៅក្នុងផ្លូវចម្រើន ព្រោះលោក ព្រមទាំងទេវលោក គប្បីចូលទៅរក ម្យ៉ាងទៀត ក្នុងទីនេះ ព្រះសម្ពុទ្ធប៉ុណ្ណោះជាព្រះអរិយៈ ដូចព្រះតម្រាស់ ( ក្នុងសំយុត្តនិកាយ មហាវារវគ្គ ) ថា ព្រះតថាគតជាអរិយបុគ្គលក្នុងលោក ព្រមទាំងទេវលោក មារលោក ព្រហ្មលោក ក្នុងពពួកសត្វ ព្រមទាំងសមណព្រាហ្មណ៍ ទាំងមនុស្សជាសម្មតិទេព និងមនុស្សដ៏សេស ។ ក្នុងបទថា **សប្បុរិសា** នេះ គប្បីជ្រាបថា ព្រះបច្ចេកពុទ្ធ និងសាវករបស់ព្រះតថាគត ជាសប្បុរស ។ ពិតហើយ លោកទាំងនោះ ជាបុរសស្អាតដោយការប្រកបលោកុត្តរគុណ ព្រោះហេតុនោះ ទើបឈ្មោះថា សប្បុរស ។ ម្យ៉ាងទៀត លោកទាំងអស់នោះ ពោលដោយចំណែក ២ ។ ពិតហើយ ព្រះពុទ្ធជាព្រះអរិយៈផង ជាសប្បុរសផង ព្រះបច្ចេកពុទ្ធក្តី សាវករបស់ព្រះពុទ្ធក្តី ជាព្រះអរិយៈផង ក៏

ជាសប្បុរសផង ដូចលោកពោលថា

បុគ្គលណាជាកតញ្ញូកតវេទី ជាអ្នកប្រាជ្ញ ជាកល្យាណមិត្ត និង ជាអ្នកមានភក្តីមាំទាំ ធ្វើកិច្ចដើម្បីអ្នកបានទទួលទុក្ខ ដោយគោរព បណ្ឌិតទាំងឡាយ ពោលបុគ្គលនោះថា ជាសប្បុរស ។

ពិតហើយ សាវករបស់ព្រះពុទ្ធ លោកពោលដោយបទត្រឹមប៉ុណ្ណេះថា ជាកល្យាណមិត្ត និងជាអ្នកមានភក្តីមាំទាំ ។ ព្រះបច្ចេកពុទ្ធទាំងឡាយ លោកពោលដោយភាពជាអ្នកមានកតញ្ញូជាដើម ។ ឥឡូវនេះ គប្បីជ្រាបថា បុគ្គលមានប្រក្រតីមិនឃើញព្រះអរិយៈទាំងនោះ និងមិនបានប្រយោជន៍ក្នុងការឃើញ ឈ្មោះថា មិនបានឃើញព្រះអរិយៈទាំងឡាយ ។ បុគ្គលមិនបានឃើញព្រះអរិយៈមាន ២ យ៉ាង គឺមិនឃើញដោយចក្ខុ ១ មិនឃើញដោយញាណ ១ ក្នុងបុគ្គល ២ យ៉ាងនោះ ក្នុងទីនេះ លោកបំណងយកការមិនបានឃើញដោយញាណ ។ ពិតហើយ បុគ្គលសូម្បីឃើញព្រះអរិយៈទាំងឡាយ ដោយមំសចក្ខុក្តី ដោយទិព្វចក្ខុក្តី មិនឈ្មោះថាឃើញ ព្រោះបុគ្គលឃើញត្រឹមតែពណ៌ដោយចក្ខុ ព្រោះមិនជាអារម្មណ៍របស់ភាពជាអរិយៈ ។ សូម្បីឆ្កែស្រុក ឆ្កែចចកជាដើម ក៏ឃើញព្រះអរិយៈដោយមំសចក្ខុ តែសត្វទាំងនោះឈ្មោះថា មិនឃើញព្រះអរិយៈទេ ។

ក្នុងរឿងនេះ មានរឿងដូចតទៅនេះ

មានរឿងសម្តែងថា ឧបដ្ឋាករបស់ព្រះថេរខីណាសវៈ នៅអាស្រ័យត្រង់ចិត្តលបពិត បួសឯចាស់ ថ្ងៃមួយ ទៅបិណ្ឌបាតជាមួយព្រះថេរៈ ទទួល

បាត្រ និងចីវររបស់ព្រះថេរៈហើយ ដើរតាមក្រោយ សួរព្រះថេរៈថា បពិត្រលោកម្ចាស់ បុគ្គលដូចម្តេច ឈ្មោះថា ជាអរិយៈ ព្រះថេរៈពោលថា បុគ្គលពួកខ្លះក្នុងលោកនេះ ទទួលបាត្រ និងចីវររបស់ព្រះអរិយៈទាំងឡាយហើយ ធ្វើការប្រណិប័តន៍ សូម្បីត្រាច់ទៅជាមួយគ្នា ក៏មិនស្គាល់ព្រះអរិយៈ នែអាវុសោ ព្រះអរិយៈទាំងឡាយ បុគ្គលដឹងបានលំបាកបែបនេះ កាលព្រះថេរៈពោលយ៉ាងនោះ ឧបដ្ឋាកនោះក៏នៅតែមិនយល់នោះឯង ។

ព្រោះដូច្នោះ ការឃើញដោយចក្ខុ ឈ្មោះថា មិនឃើញ ។ ការឃើញដោយញាណប៉ុណ្ណោះ ឈ្មោះថា ឃើញ ដូចព្រះមានព្រះភាគត្រាស់ ( ក្នុងសំយុត្តនិកាយ ខន្ធវារវគ្គ ) ថា កុំឡើយ វក្កលិ ប្រយោជន៍អ្វី ដោយកាយស្អុយ ដែលអ្នកឃើញហើយនេះ ។ ម្នាលវក្កលិ បុគ្គលណាមួយឃើញធម៌ បុគ្គលនោះ ឈ្មោះថា ឃើញតថាគត ។ ព្រោះហេតុនោះ បុគ្គលសូម្បីឃើញព្រះអរិយៈដោយចក្ខុ តែមិនឃើញនូវអនិច្ចលក្ខណៈជាដើម ដោយញាណដែលព្រះអរិយៈទាំងឡាយឃើញហើយ នឹងមិនសម្រេចធម៌ដែលព្រះអរិយៈសម្រេចហើយ គប្បីជ្រាបថា ជាអ្នកមិនបានឃើញនូវព្រះអរិយៈទាំងឡាយ ព្រោះមិនឃើញធម៌ដែលធ្វើឲ្យជាអរិយៈ និងមិនឃើញភាពជាអរិយៈ ។

បទថា **អរិយធម្មស្ស អកោវិទោ** បានដល់ មិនឈ្លាសក្នុងអរិយធម៌មានសតិប្បដ្ឋានជាដើម ។ ចំណែកក្នុងបទថា **អរិយធម្មេ អវិនីតោ** គប្បីជ្រាបសេចក្តីដូចតទៅ

ឈ្មោះថា វិន័យ មាន ២ យ៉ាង ក្នុង ២ យ៉ាងនេះ វិន័យនីមួយៗ

ចែកជា ៥ ព្រោះមិនមានវិន័យនោះ ទើបបុគ្គលនេះ ហៅថា **អវិនីតោ** ។

វិន័យ ២ យ៉ាង គឺសំវរវិន័យ ១ បហានវិន័យ ១ ក្នុងវិន័យ ២ យ៉ាងនេះ វិន័យនីមួយៗ ចែកចេញជា ៥ យ៉ាង ។ សំវរវិន័យក៏មាន ៥ យ៉ាង គឺសីលសំវរៈ ១ សតិសំវរៈ ១ ញាណសំវរៈ ១ ខន្តិសំវរៈ ១ វីរិយសំវរៈ ១ ។ បហានវិន័យមាន ៥ យ៉ាង គឺតទង្គប្បហាន ១ វិក្ខម្ភនប្បហាន ១ សមុច្ឆេទប្បហាន ១ បដិបស្សទ្ធិប្បហាន ១ និស្សរណប្បហាន ១ ។ ក្នុងសំវរៈទាំង ៥ នោះ សំវរៈក្នុងប្រយោគថា **ឥមិនា បាតិមោក្ខសំវរេន ឧបេតោ ហោតិ សមុបេតោ** ជាអ្នកព្រមព្រៀង មូលមិត ដោយការសង្រួមក្នុងបាតិមោក្ខនេះ[1] ជាដើម នេះឈ្មោះថា **សីលសំវរៈ** ។ សំវរៈក្នុងប្រយោគថា រក្សានូវចក្ខុន្ទ្រិយ ដល់នូវសេចក្តីសង្រួមក្នុងចក្ខុន្ទ្រិយជាដើម នេះឈ្មោះថា **សតិសំវរៈ** ។

សំវរៈក្នុងប្រយោគថា

( ព្រះមានព្រះភាគត្រាស់ថា ម្នាលអជិតៈ ) ខ្សែទាំងឡាយណា
ក្នុងលោក សតិជាគ្រឿងបិទខ្សែទាំងនោះ តថាគតពោលនូវការ
បិទខ្សែទាំងឡាយ ខ្សែទាំងនុ៎ះ បុគ្គលបិទបានដោយបញ្ញា ។

នេះឈ្មោះថា **ញាណសំវរៈ** ។ សំវរៈក្នុងប្រយោគថា អត់ធន់ចំពោះត្រជាក់ ក្តៅជាដើម នេះឈ្មោះថា **ខន្តិសំវរៈ** ។ សំវរៈក្នុងប្រយោគថា ធ្វើ

---

១- សេចក្តីពិស្តារសូមមើលក្នុងបិដកលេខ ៨១ ទំព័រ ២៤៩ ។

*ឲ្យវិនាស បំផ្លាញនូវកាមវិតក្កដែលកើតឡើងហើយជាដើម នេះឈ្មោះថា* **វីរិយសំវរៈ** *។ សំវរៈទាំងអស់នេះ ហៅថា* **សំវរៈ** *ព្រោះរាំងកាយទុច្ចរិតជាដើម ដែលគួររាំងតាមកម្លាំងរបស់ខ្លួន ហៅថា* **វិន័យ** *ព្រោះកម្ចាត់កាយទុច្ចរិតជាដើមដែលគួរកម្ចាត់តាមកម្លាំងរបស់ខ្លួន ។ គប្បីជ្រាបថាសំវរវិន័យចែកជា ៥ ដោយប្រការដូច្នេះ ។*

*ម្យ៉ាងទៀត ការលះអង្គនោះៗ ដោយវិបស្សនាញាណនោះៗ ក្នុងវិបស្សនាញាណទាំងឡាយ មាននាមរូបបរិច្ឆេទញ្ញាណជាដើម ដូចការលះងងឹតដោយពន្លឺប្រទីប ដោយភាពជាបដិបក្ខ ដូចការលះសក្កាយទិដ្ឋិ ដោយការកំណត់នាមរូប ការលះនូវការឃើញថា សង្ខារមិនមានហេតុ និងមិនសមជាមួយហេតុដោយការកំណត់បច្ច័យ លះនូវភាពជាអ្នកសង្ស័យ ដោយការឆ្លងផុតសេចក្តីសង្ស័យ ដែលតអំពីការកំណត់បច្ច័យនោះឯង លះការប្រកាន់ថា អញ របស់អញ ដោយការពិចារណាជាកលាបៈ លះនូវការសម្គាល់ក្នុងវត្ថុដែលមិនមែនផ្លូវថា ជាផ្លូវ ដោយការកំណត់ថា ផ្លូវ និងមិនមែនផ្លូវ លះនូវឧច្ឆេទទិដ្ឋិ ដោយការឃើញនូវការកើត លះសស្សតទិដ្ឋិ ដោយឃើញការរលត់ លះនូវការសម្គាល់ក្នុងវត្ថុដែលជាភ័យ ថាមិនជាភ័យ ដោយការឃើញភ័យ លះនូវការសម្គាល់ក្នុងវត្ថុមិនមានទោស ដោយឃើញថា មានទោស លះនូវការសម្គាល់ក្នុងវត្ថុ ដែលត្រេកអរក្រៃលែង ដោយនិព្វិទានុបស្សនា លះនូវភាពជាអ្នកមិនបំណងនឹងផុតដោយមុញ្ចិតុកម្យតាញាណ លះនូវការមិនព្រងើយ ដោយឧបេក្ខាញាណ លះនូវការបដិលោមក្នុងការតាំង*

នៅក្នុងធម៌ និងក្នុងនិព្វាន ដោយអនុលោមញ្ញាណ លះនូវការប្រកាន់សង្ខារ-និមិត្ត ដោយគោត្រភូញាណ ឈ្មោះថា **តទង្គប្បហាន** ។ ការលះធម៌មាននីវរណៈជាដើមនោះៗ ដោយហាមការប្រព្រឹត្តទៅ ដោយសមាធិ មានឧបចារសមាធិ និងអប្បនាសមាធិ ដូចហាមចកលើទឹក ដោយការគ្របដោយឆ្នាំងដូច្នោះ ឈ្មោះថា **វិក្ខម្ភនប្បហាន** ។

ការលះកិលេសសព្វយ៉ាង ដែលជាចំណែកសមុទយៈ ដូចលោកពោលដោយន័យជាដើមថា ដើម្បីលះទិដ្ឋិ ក្នុងសន្តានរបស់ខ្លួន របស់បុគ្គលដែលមានមគ្គនោះៗ ព្រោះអប់រំអរិយមគ្គ ៤ ហើយ ដោយមិនឲ្យប្រព្រឹត្តទៅបានទៀត ឈ្មោះថា **សមុច្ឆេទប្បហាន** ។

ភាពដែលកិលេសទាំងឡាយ ស្ងប់រម្ងាប់ហើយក្នុងខណៈនៃផល ឈ្មោះថា **បដិបស្សទ្ធិប្បហាន** ។

និព្វានដែលលះសង្ខតធម៌ទាំងពួងហើយ ព្រោះរលាស់ចេញនូវសង្ខត-ធម៌ទាំងពួង ឈ្មោះថា **និស្សរណប្បហាន** ។ ការលះទាំងអស់នេះ ឈ្មោះថា **បហាន** ព្រោះអត្ថថា លះចេញទៅ ។ ឈ្មោះថា **វិន័យ** ព្រោះអត្ថថា កម្ចាត់ ។ ព្រោះហេតុនោះ ទើបហៅថា **បហានវិន័យ** ។ម្យ៉ាងទៀត បហាននោះ ហៅថា បហានវិន័យ ព្រោះមានការលះនោះៗ និងព្រោះមានការកើតនៃវិន័យនោះៗ ។ គប្បីជ្រាបថា បហានវិន័យនេះ ក៏ចែកជា ៥ ដោយប្រការដូច្នេះ ។

វិន័យនេះ ដោយសង្ខេបមាន ២ យ៉ាង និងដោយការចែកមាន ១០ យ៉ាង

*រមែងមិនមានដល់បុថុជ្ជនដែលមិនបានស្តាប់នោះ ព្រោះបុគ្គលនោះ ទម្លាយនូវការសង្រួម និងព្រោះលះវត្ថុដែលគួរលះមិនទាន់បាន ព្រោះហេតុនោះ ទើបបុគ្គលនេះ ហៅថា ជាអ្នកមិនបានទទួលនូវការណែនាំ ព្រោះមិនមានវិន័យនោះ ។ ក្នុងបទនេះថា មិនឃើញពួកសប្បុរស មិនឈ្លាសវៃចំពោះសប្បុរិសធម៌ មិនបានទូន្មានខ្លួនក្នុងសប្បុរិសធម៌ ក៏ន័យនេះដូចគ្នា ពាក្យនេះដោយអត្ថក៏មិនផ្សេងគ្នា ។ ដូចលោកពោលថា បុគ្គលណាជាព្រះអរិយៈ បុគ្គលនោះឯង ជាសប្បុរស បុគ្គលណាជាសប្បុរស បុគ្គលនោះឯង ជាព្រះអរិយៈ ធម៌ណារបស់ព្រះអរិយៈ ធម៌នោះរបស់សប្បុរស ធម៌ណារបស់សប្បុរស ធម៌នោះរបស់ព្រះអរិយៈ អរិយវិន័យ គឺសប្បុរិសវិន័យ សប្បុរិសវិន័យ គឺអរិយវិន័យ ។ បទថា* **អរិយេ** *ក្តី* **សប្បុរិសេ** *ក្តី* **អរិយធម្មេ** *ក្តី* **សប្បុរិសធម្មេ** *ក្តី* **អរិយវិនយេ** *ក្តី* **សប្បុរិសវិនយេ** *ក្តី ជាពាក្យតែមួយ ដូចគ្នាតែមួយ មានអត្ថតែមួយ ស្មើគ្នា ប៉ុនគ្នា សមគ្នានោះឯង ។*

*បទថា* **រូបំ អត្តតោ សមនុបស្សតិ** *សេចក្តីថា បុគ្គលពួកខ្លះក្នុងលោកនេះ តាមឃើញនូវរូបដោយភាពជាខ្លួន គឺតាមឃើញទាំង ២ យ៉ាង គឺទាំងរូប និងខ្លួនថា រូប គឺអញ អញ គឺរូប ដូចបុគ្គលតាមឃើញទាំង ២ យ៉ាង គឺអណ្តាតភ្លើង និងពណ៌របស់ចង្កៀងដែលកំពុងឆេះថា អណ្តាតភ្លើង គឺពណ៌ ពណ៌ គឺអណ្តាតភ្លើង យ៉ាងណា បុគ្គលពួកខ្លះក្នុងលោកនេះ ក៏ដូច្នោះ តាមឃើញនូវរូប ដោយការឃើញខុសថា ជាខ្លួនយ៉ាងនេះថា រមែងពិចារណាឃើញនូវរូបថាខ្លួន ។បេ។ នូវខ្លួនថាមានរូប ។*

បទថា **រូបវន្តំ វា អត្តានំ** សេចក្តីថា កាន់យកនូវវត្ថុ មិនមានរូបថាជាខ្លួន ហើយតាមឃើញវត្ថុមិនមានរូប ដែលឃើញថា មានរូបហើយនោះថាជាខ្លួន ដូចឃើញដើមឈើថា មានស្រមោល ។ បទថា **អត្តនិ វា រូបំ** សេចក្តីថា កាន់យកវត្ថុមិនមានរូបនោះឯងថាជាខ្លួន ហើយតាមឃើញរូបក្នុងខ្លួន ដូចតាមហិតក្លិនក្នុងផ្កា ។ បទថា **រូបស្មឹ វា អត្តានំ** សេចក្តីថា កាន់យកវត្ថុមិនមានរូបនោះឯងថាជាខ្លួន ហើយតាមឃើញខ្លួននោះក្នុងរូប ដូចតាមឃើញកែវមណីក្នុងហិប ។ ក្នុងវេទនាជាដើម ក៏មានន័យនេះដូចគ្នា ។ ក្នុងបទទាំងនោះ បទថា **រូបំ អត្តតោ សមនុបស្សតិ** លោកពោលដល់រូបសុទ្ធៗ ថាជាខ្លួន ។ លោកពោលដល់អរូបថាជាខ្លួន ក្នុងឋានៈ ៧ នេះ គឺតាមឃើញខ្លួនថាមានរូបខ្លះ តាមឃើញរូបក្នុងខ្លួនខ្លះ តាមឃើញខ្លួនក្នុងរូបខ្លះ តាមឃើញវេទនា តាមឃើញសញ្ញា តាមឃើញសង្ខារ តាមឃើញវិញ្ញាណ ដោយភាពជាខ្លួន ។ លោកពោលលាយឡំគ្នាដល់រូប និងអរូប ថាជាខ្លួន ក្នុងឋានៈ ១២ យ៉ាង នីមួយៗ បីៗ ក្នុងខន្ធ ៤ យ៉ាងនេះ គឺតាមឃើញខ្លួនថាមានវេទនាខ្លះ តាមឃើញវេទនាក្នុងខ្លួនខ្លះ តាមឃើញខ្លួនក្នុងវេទនាខ្លះ ។ ក្នុងបទទាំងនោះ លោកពោលដល់ឧច្ឆេទទិដ្ឋិ ក្នុងឋានៈ ៥ គឺតាមឃើញរូប វេទនា សញ្ញា សង្ខារ វិញ្ញាណ ដោយភាពជាខ្លួន ។ លោកពោលដល់សស្សតទិដ្ឋិក្នុងចំណែកដ៏សេស ។ ក្នុងសេចក្តីនេះ មានភវទិដ្ឋិ ១៥ មានវិភវទិដ្ឋិ ៥ ដោយប្រការដូច្នេះ ។ ទិដ្ឋិទាំងនោះ គប្បីជ្រាបថា ហាមនូវមគ្គ មិនហាមស្ថានសួគ៌ គប្បីសម្លាប់បានដោយបឋមមគ្គ ។

[ ៧៨ ] បទថា **អារញ្ញិកោ** បានដល់ ទីអាស្រ័យនៅក្នុងព្រៃ ។ បទថា **បវនេ** បានដល់ ក្នុងព្រៃជ្រៅ ។ បទថា **ចរមានោ** បានដល់ ដើរទៅមកក្នុងទីនោះៗ ។ បទថា **វិស្សត្ថោ គច្ឆតិ** បានដល់ ដើរទៅក៏មិនវង្វៀសមិនតក់ស្លុត ។ បទថា **អនាថាជគតោ លុទ្ទស្ស** សេចក្តីថា ម្រឹគនោះទៅតាមផ្លូវខាងក្រោយរបស់នាយព្រាន ។ បទថា **អន្តមកាសិ មារំ** សេចក្តីថា ធ្វើកិលេសមារ ឬទេវបុត្តមារឲ្យមានទីបំផុត ។ បទថា **អបទំ វធិត្វា** សេចក្តីថា ធ្វើកិលេសមិនឲ្យមានផ្លូវ គឺធ្វើឲ្យវិនាសទៅ ។ បទថា **មារចក្ខុអទស្សនំ គតោ** បានដល់ ទៅកាន់វិស័យដែលមារមិនឃើញ ។ បទថា **អនាថាជគតោ** បានដល់ ទៅផុតមុខមារ ។ បទដ៏សេសក្នុងបទទាំងពួង ជាក់ច្បាស់ល្អហើយ ។

ព្រះមានព្រះភាគ ទ្រង់សម្តែងព្រះសូត្រនេះ ដោយធម៌ដ៏កំពូល គឺអរហត្ត ដោយប្រការដូច្នេះ ។ កាលចប់ទេសនា មានបុគ្គលសម្រេចធម៌ដូចគ្នាតាមដែលពោលហើយនោះឯង ។ល។

**អដ្ឋកថា មោឃរាជមាណវសុត្តនិទ្ទេសទី ១៥ ចប់**

# សុត្តន្តបិដក

## បិង្គិយមាណវកប្បញ្ហានិទ្ទេស

[ ៧៩ ] ( បិង្គិយៈមានអាយុក្រាបទូលដូច្នេះថា ) ខ្ញុំព្រះអង្គជាមនុស្សគ្រាំគ្រា មានកម្លាំងខ្សោយ ប្រាសចាកសម្បុរ ទាំងភ្នែកក៏មិនស្អាត ការស្តាប់ក៏មិនស្រួល សូមកុំឲ្យខ្ញុំព្រះអង្គ ជាបុគ្គលវង្វេងវិនាសក្នុងចន្លោះឡើយ ខ្ញុំព្រះអង្គគប្បីដឹងធម៌ណា ដែលជាគ្រឿងលះបង់ជាតិ និងជរាក្នុងទីនេះ សូមព្រះអង្គត្រាស់ប្រាប់ធម៌នោះឲ្យទាន ។

[ ៨០ ] ពាក្យថា ខ្ញុំព្រះអង្គជាមនុស្សគ្រាំគ្រា មានកម្លាំងខ្សោយប្រាសចាកសម្បុរ គឺជាមនុស្សគ្រាំគ្រា ចម្រើនហើយ មានអាយុច្រើន រស់នៅបានយូរឆ្នាំមកហើយ មានវ័យដល់ហើយតាមលំដាប់ មានអាយុ ១២០ ឆ្នាំអំពីកំណើត ។ ពាក្យថា មានកម្លាំងខ្សោយ គឺមានកម្លាំងថយ មានកម្លាំងកាយតិច មានកម្លាំងចិត្តតិច ។ ពាក្យថា ប្រាសចាកសម្បុរ គឺប្រាសចាកសម្បុរ បាត់សម្បុរ ពន្លឺសម្បុរដ៏ល្អណាមានក្នុងកាលមុន ពន្លឺសម្បុរដ៏ល្អនោះបាត់ទៅ ទោសក៏កើតប្រាកដ ហេតុនោះ ( លោកពោលថា ) ខ្ញុំព្រះអង្គជាមនុស្សគ្រាំគ្រា មានកម្លាំងខ្សោយប្រាសចាកសម្បុរ ។ ពាក្យថា បិង្គិយៈមានអាយុក្រាបទូលដូច្នេះ ត្រង់ពាក្យថា ដូច្នេះ គឺជាការតបទ ។ ពាក្យថា មានអាយុ គឺពាក្យជាទីស្រឡាញ់ ។ ពាក្យថា បិង្គិយៈ ជាឈ្មោះ ។បេ។ ជាពាក្យសម្រាប់ហៅព្រាហ្មណ៍នោះ ហេតុនោះ ( ទើបមានពាក្យថា ) បិង្គិយៈមានអាយុក្រាបទូល ដូច្នេះ ។

[ ៨១ ] ពាក្យថា ភ្នែកមិនស្អាត ការស្តាប់មិនស្រួល គឺភ្នែកទាំងពីរមិនស្អាត មិនហ្មត់ចត់ មិនបរិសុទ្ធ មិនផូរផង់ គឺខ្ញុំព្រះអង្គមិនឃើញរូបដោយភ្នែក ដោយប្រការដូច្នោះ ហេតុនោះ ( លោកពោលថា ) ភ្នែកមិនស្អាត ។ ពាក្យថា ការស្តាប់មិនស្រួល គឺត្រចៀកមិនស្អាត មិនហ្មត់ចត់ មិនបរិសុទ្ធ មិនផូរផង់ គឺខ្ញុំព្រះអង្គមិនឮសំឡេងដោយត្រចៀក ដោយប្រការដូច្នោះ ហេតុនោះ ( លោកពោលថា ) ភ្នែកមិនស្អាត ការស្តាប់មិនស្រួល ។

[ ៨២ ] ពាក្យថា សូមកុំឲ្យខ្ញុំព្រះអង្គជាបុគ្គលវង្វេង ខូចក្នុងចន្លោះឡើយ គឺសូមកុំឲ្យខ្ញុំព្រះអង្គលាញ ខូច វិនាសឡើយ ។ ពាក្យថា ជាបុគ្គលវង្វេង គឺជាបុគ្គលមិនយល់ ដល់នូវសេចក្តីល្ងង់ខ្លៅ មិនដឹង មិនវាងវៃ ឥតប្រាជ្ញា ។ ពាក្យថា ក្នុងចន្លោះ គឺខ្ញុំព្រះអង្គមិនដឹង មិនធ្វើឲ្យជាក់ច្បាស់ មិនធ្វើឲ្យប្រាកដ មិនបានចំពោះ មិនពាល់ត្រូវ មិនធ្វើឲ្យជាក់ច្បាស់នូវធម៌ ទិដ្ឋិ បដិបទា មគ្គរបស់ព្រះអង្គ ហើយធ្វើមរណកាលក្នុងចន្លោះ ហេតុនោះ ( លោកពោលថា ) សូមកុំឲ្យខ្ញុំព្រះអង្គ ជាបុគ្គលវង្វេងខូចក្នុងចន្លោះឡើយ ។

[ ៨៣ ] អធិប្បាយពាក្យថា ខ្ញុំព្រះអង្គគប្បីដឹងធម៌ណា សូមព្រះអង្គត្រាស់ប្រាប់ធម៌នោះ ត្រង់ពាក្យថា សូមព្រះអង្គត្រាស់ប្រាប់ធម៌នោះ គឺសូមព្រះអង្គប្រាប់ សម្តែង បញ្ញត្ត តាំង ផ្តើម បើក វែកញែក ធ្វើឲ្យរាក់ ប្រកាសនូវព្រហ្មចរិយៈ មានពីរោះបទដើម ពីរោះបទកណ្តាល ពីរោះបទចុង ព្រមទាំងអត្ថ ព្រមទាំងព្យញ្ជនៈដ៏ពេញបរិបូណ៌ បរិសុទ្ធទាំងអស់ សតិប្បដ្ឋាន ៤ សម្មប្បធាន ៤ ឥទ្ធិបាទ ៤ ឥន្ទ្រិយ ៥ ពល ៥ ពោជ្ឈង្គ ៧ មគ្គប្រកប

ដោយអដ្ឋ ៨ ដ៏ប្រសើរ និព្វាន និងនិព្វានគាមិនីបដិបទា ហេតុនោះ ( លោកពោលថា ) សូមព្រះអង្គត្រាស់ប្រាប់ធម៌នោះ ។ ពាក្យថា ខ្ញុំព្រះអង្គគប្បីដឹងធម៌ណា គឺខ្ញុំព្រះអង្គគប្បីដឹង យល់ច្បាស់ ដឹងច្បាស់លាស់ ចាក់ធ្លុះចំពោះបានលុះ ពាល់ត្រូវ ធ្វើឲ្យជាក់ច្បាស់នូវធម៌ណា ហេតុនោះ ( លោកពោលថា ) ខ្ញុំព្រះអង្គគប្បីដឹងធម៌ណា សូមព្រះអង្គត្រាស់ប្រាប់ធម៌នោះ ។

[ ៨៤ ] ពាក្យថា ជាគ្រឿងលះបង់ជាតិ និងជរាក្នុងទីនេះ គឺការលះបង់ រម្ងាប់បង់ រលាស់ចោល រម្ងាប់នូវជាតិ ជរា និងមរណៈក្នុងទីនេះឯង គឺអមតនិព្វាន ហេតុនោះ ( លោកពោលថា ) ជាគ្រឿងលះបង់ជាតិ និងជរាក្នុងទីនេះ ។ ហេតុនោះ ព្រាហ្មណ៍នោះពោលថា

( បិង្គិយៈមានអាយុក្រាបទូលដូច្នេះថា ) ខ្ញុំព្រះអង្គជាមនុស្សគ្រាំគ្រា មានកម្លាំងខ្សោយ ប្រាសចាកសម្បុរ ទាំងភ្នែកក៏មិនស្អាត ការស្តាប់ក៏មិនស្រួល សូមកុំឲ្យខ្ញុំព្រះអង្គ ជាបុគ្គលវង្វេងខូចក្នុងចន្លោះឡើយ ខ្ញុំព្រះអង្គគប្បីដឹងធម៌ណាដែលជាគ្រឿងលះបង់ជាតិ និងជរាក្នុងទីនេះ សូមព្រះអង្គត្រាស់ប្រាប់ធម៌នោះឲ្យទាន ។

[ ៨៥ ] ( ព្រះមានព្រះភាគត្រាស់ថា ម្នាលបិង្គិយៈ ) ពួកជនដែលប្រហែស ឃើញសត្វទាំងឡាយកំពុងលំបាកព្រោះរូប ក៏លំបាកព្រោះរូប ម្នាលបិង្គិយៈ ហេតុនោះ អ្នកចូរជាបុគ្គលមិនប្រហែស លះបង់រូបទៅ ដើម្បីការមិនកើតទៀត ។

[ ៨៦ ] អធិប្បាយពាក្យថា ឃើញសត្វទាំងឡាយកំពុងលំបាកព្រោះ

រូប ត្រង់ពាក្យថា រូប បានដល់ មហាភូតរូប ៤ ផង រូបដែលអាស្រ័យនឹងមហាភូតរូប ៤ ផង ។ សត្វទាំងឡាយលំបាក ឈឺចាប់ ក្តៅក្រហាយ ចង្អៀតចង្អល់ ព្រោះហេតុនៃរូប ព្រោះរូបជាបច្ច័យ ព្រោះដំណើរនៃរូប កាលបើរូបមាន សត្វទាំងឡាយ ត្រូវគេធ្វើនូវកម្មករណ៍ផ្សេងៗ គឺវាយដោយរំពាត់ខ្លះ វាយដោយផ្តៅខ្លះ វាយដោយកំណាត់ឈើខ្លះ កាត់ដៃខ្លះ កាត់ជើងខ្លះ កាត់ដៃ និងជើងខ្លះ កាត់ត្រចៀកខ្លះ កាត់ច្រមុះខ្លះ កាត់ត្រចៀក និងច្រមុះខ្លះ ធ្វើពិលង្គថាលិកកម្មខ្លះ ធ្វើសង្ខមុណ្ឌកកម្មខ្លះ ធ្វើរាហុមុខកម្មខ្លះ ធ្វើជោតិមាលិកកម្មខ្លះ ធ្វើហត្ថប្បជោតិកកម្មខ្លះ ធ្វើឯរកវត្តិកកម្មខ្លះ ធ្វើចិរកវាសិកកម្មខ្លះ ធ្វើឯណេយ្យកកម្មខ្លះ ធ្វើពលិសមំសិកកម្មខ្លះ ធ្វើកហាបណិកកម្មខ្លះ ធ្វើខារាបតច្ឆិកកម្មខ្លះ ធ្វើបលិឃបរិវត្តិកកម្មខ្លះ ធ្វើបលាលបីឋកកម្មខ្លះ ស្រោចដោយប្រេងដែលក្តៅខ្លះ ឲ្យឆ្កែខាំខ្លះ ឲ្យដេកផ្ងារលើឈើអណ្តោតទាំងរស់ខ្លះ កាត់ក្បាលដោយដាវខ្លះ ។ សត្វទាំងឡាយលំបាក ឈឺចាប់ ក្តៅក្រហាយ ចង្អៀតចង្អល់ព្រោះរូបជាហេតុ ព្រោះរូបជាបច្ច័យ ព្រោះរូបជាដំណើរ ដោយប្រការយ៉ាងនេះ ។ ឃើញ ជួប ពិចារណា ត្រិះរិះ សំដែង ធ្វើឲ្យប្រាកដនូវសត្វទាំងឡាយកំពុងលំបាក ក្តៅក្រហាយយ៉ាងនេះ ហេតុនោះ ( ទ្រង់ត្រាស់ថា ) ឃើញសត្វទាំងឡាយកំពុងលំបាកព្រោះរូប ។ ពាក្យថា ម្នាលបិង្គិយៈ ក្នុងបទថា ព្រះមានព្រះភាគត្រាស់ថា ម្នាលបិង្គិយៈ គឺព្រះមានព្រះភាគត្រាស់ហៅព្រាហ្មណ៍នោះចំឈ្មោះ ។ ពាក្យថា ព្រះមានព្រះភាគ នុ៎ះជាពាក្យពោលដោយគោរព ។បេ។ បញ្ញត្តថា ព្រះមានព្រះភាគនេះ ហេតុនោះ ( មាន

ពាក្យថា ) ព្រះមានព្រះភាគត្រាស់ថា ម្នាលបិង្គិយៈ ។

[ ៨៧ ] អធិប្បាយពាក្យថា ពួកជនដែលប្រហែស ក៏លំបាកព្រោះរូប ត្រង់ពាក្យថាលំបាក គឺលំបាក កម្រើក បៀតបៀន ខ្ទាំងខ្ទប់ ខ្ទាច ដល់នូវទោមនស្ស ដោយរោគក្នុងភ្នែក លំបាក កម្រើក បៀតបៀន ខ្ទាំងខ្ទប់ ខ្ទាច ដល់នូវទោមនស្ស ដោយរោគក្នុងត្រចៀក ។បេ។ លំបាក កម្រើក បៀតបៀន ខ្ទាំងខ្ទប់ ខ្ទាច ដល់នូវទោមនស្ស ដោយសម្ផស្សនៃរបោម មូស ខ្យល់ កម្តៅថ្ងៃ សត្វលូន ហេតុនោះ ( ទ្រង់ត្រាស់ថា ) ក៏លំបាកព្រោះរូប ។ មួយទៀត សត្វទាំងឡាយ កាលបើភ្នែកសាបសូន្យ បាត់បង់ រលប់រលាយ វិនាស ទៅប្រាស អន្តរធាន ក៏លំបាក ។បេ។ ដល់នូវទោមនស្ស សត្វទាំងឡាយ កាលត្រចៀក ច្រមុះ អណ្តាត កាយ រូប សំឡេង ក្លិន រស ផ្សព្វ ត្រកូល ពួក អាវាស លាភ យស សេចក្តីសរសើរ សុខ ចីវរ បិណ្ឌបាត សេនាសនៈ គិលានប្បច្ចយភេសជ្ជបរិក្ខារសាបសូន្យ បាត់បង់ រលប់រលាយ វិនាស ទៅប្រាស អន្តរធាន លំបាក កម្រើក ត្រូវសេចក្តីវិនាសបៀតបៀន ខ្ទាំងខ្ទប់ ខ្ទាច ដល់នូវទោមនស្ស ហេតុនោះ ( ទ្រង់ត្រាស់ថា ) ក៏លំបាកព្រោះរូបយ៉ាងនេះក៏បាន ។ ពាក្យថា ពួកជន បានដល់ ពួកក្សត្រ ព្រាហ្មណ៍ អ្នកជំនួញ អ្នកគ្រួ គ្រហស្ថ បព្វជិត ទេវតា មនុស្ស ។ ពាក្យថា ប្រហែស គឺការប្រហែស ខ្ញុំត្រូវពោលដូចតទៅនេះ ការបណ្តោយចិត្ត ការផ្តល់កម្លាំងដល់ការបណ្តោយចិត្តទៅក្នុងកាយទុច្ចរិត ក្នុងវចីទុច្ចរិត ក្នុងមនោទុច្ចរិត ឬក្នុងកាមគុណទាំង ៥ ក្តី ភាពនៃកិរិយាមិនធ្វើរឿយៗ ភាពនៃកិរិយាមិនតាំងនៅ

ភាពនៃកិរិយាប្រព្រឹត្តធូរថយ ការដាក់ចុះនូវឆន្ទៈ ការដាក់ចុះនូវធុរៈ ការមិនសេព ការមិនចម្រើន ការមិនធ្វើឲ្យច្រើន ការមិនអធិដ្ឋាន ការមិនប្រកបរឿយៗ ក្នុងការចម្រើនធម៌ជាកុសលក្តី ឈ្មោះថាការប្រហែស សេចក្តីធ្វេសប្រហែស ការបណ្តែតបណ្តោយ ភាពនៃសេចក្តីភ្លេចភ្លាំង ដែលមានសភាពយ៉ាងនេះឯណា នេះលោកហៅថា ការប្រហែស ។ ពួកជនប្រកបដោយសេចក្តីប្រហែសនេះ ឈ្មោះថា អ្នកប្រហែស ហេតុនោះ ( ទ្រង់ត្រាស់ថា ) ពួកជនប្រហែស ក៏លំបាកព្រោះរូប ។

[ ៨៨ ] ពាក្យថា ម្នាលបិង្គិយៈ ព្រោះហេតុនោះ អ្នកចូរជាបុគ្គលមិនប្រហែស ត្រង់ពាក្យថា ព្រោះហេតុនោះ គឺព្រោះហេតុដូច្នោះ ព្រោះការណ៍នោះ ព្រោះហេតុនោះ ព្រោះបច្ច័យនោះ ព្រោះនិទាននោះ បុគ្គលកាលឃើញច្បាស់នូវទោសក្នុងរូបយ៉ាងនេះ ហេតុនោះ ( ទ្រង់ត្រាស់ថា ) ម្នាលបិង្គិយៈ ហេតុនោះ អ្នក ( ចូរជាបុគ្គលមិនប្រហែស ) ។ ពាក្យថា ចូរជាបុគ្គលមិនប្រហែស គឺធ្វើដោយគោរព ធ្វើឲ្យរឿយៗ ។បេ។ មិនប្រហែសក្នុងកុសលធម៌ទាំងឡាយ ហេតុនោះ ( ទ្រង់ត្រាស់ថា ) ម្នាលបិង្គិយៈ ហេតុនោះ អ្នកចូរជាបុគ្គលមិនប្រហែស ។

[ ៨៩ ] អធិប្បាយពាក្យថា ចូរលះបង់រូបដើម្បីការមិនកើតទៀត ត្រង់ពាក្យថា រូប បានដល់ មហាភូតរូប ៤ និងរូបអាស្រ័យមហាភូតរូប ៤ ។ ពាក្យថា ចូរលះបង់រូប គឺចូរលះបង់រូប ចូរចោលរូប ចូរបន្ទោបង់រូប ចូរធ្វើឲ្យវិនាសរូប ចូរឲ្យរូបវិនាស ហេតុនោះ ( ទ្រង់ត្រាស់ថា ) ចូរលះបង់រូប ។

ពាក្យថា ដើម្បីការមិនឲ្យកើតទៀត អធិប្បាយថា រូបរបស់អ្នកគប្បីរលត់ក្នុងភពនេះ យ៉ាងណា បដិសន្ធិភពមិនគប្បីកើតទៀត ក្នុងកាមធាតុក្តី ក្នុងរូបធាតុក្តី ក្នុងអរូបធាតុក្តី ក្នុងកាមភពក្តី ក្នុងរូបភពក្តី ក្នុងអរូបភពក្តី ក្នុងសញ្ញាភពក្តី ក្នុងអសញ្ញាភពក្តី ក្នុងនេវសញ្ញានាសញ្ញាភពក្តី ក្នុងឯកវោ-ការភពក្តី ក្នុងចតុវោការភពក្តី ក្នុងបញ្ចវោការភពក្តី គឺមិនគប្បីកើត មិនគប្បីបង្កើត មិនគប្បីកកើត មិនគប្បីកើតចំពោះទៀតក្នុងគតិក្តី ក្នុងឧបបត្តិក្តី ក្នុងបដិសន្ធិក្តី ក្នុងសង្សារក្តី ក្នុងវដ្ដៈក្តី គឺថា គប្បីរលត់ ស្ងប់រម្ងាប់ ដល់នូវការតាំងនៅមិនបាន រម្ងាប់ចំពោះ ក្នុងភពនេះឯង ក៏យ៉ាងនោះដែរ ហេតុនោះ ( ទ្រង់ត្រាស់ថា ) ចូរលះបង់រូប ដើម្បីការមិនកើតទៀត ។ ហេតុនោះ ព្រះមានព្រះភាគត្រាស់ថា

( ព្រះមានព្រះភាគត្រាស់ថា ម្នាលបិង្គិយៈ ) ពួកជនដែលប្រហែស ឃើញសត្វទាំងឡាយកំពុងលំបាកព្រោះរូប ក៏លំបាកព្រោះរូប ម្នាលបិង្គិយៈ ហេតុនោះ អ្នកចូរជាបុគ្គលមិនប្រហែស លះបង់រូបទៅ ដើម្បីការមិនកើតទៀត ។

[ ៩០ ] ទិសទាំង ១០ នេះ គឺទិសធំ ៤ ទិសតូច ៤ ទិសខាងលើ ១ ទិសខាងក្រោម ១ របស់អ្វីបន្តិចបន្តួច ឈ្មោះថាព្រះអង្គមិនធ្លាប់ឃើញ មិនធ្លាប់ឮ មិនធ្លាប់ប៉ះពាល់មិនមានទេ មួយទៀត របស់អ្វីបន្តិចបន្តួចក្នុងលោក ឈ្មោះថាព្រះអង្គមិនធ្លាប់ជ្រាប មិនមានទេ ខ្ញុំព្រះអង្គគប្បីដឹងធម៌ណា ដែលជាគ្រឿងលះបង់ជាតិ និង

ជក ក្នុងទីនេះ សូមព្រះអង្គត្រាស់ប្រាប់ធម៌នោះឲ្យខ្ញុំទាន ។

[ ៩១ ] ពាក្យថា ទិសទាំង ១០ នេះ គឺទិសធំ ៤ ទិសតូច ៤ ទិសខាងលើ ១ ទិសខាងក្រោម ១ សេចក្តីថា ក្នុងទិសទាំង ១០ របស់អ្វីបន្តិចបន្តួច ដែលជាប្រយោជន៍ខ្លួនក្តី ប្រយោជន៍អ្នកដទៃក្តី ប្រយោជន៍ទាំងពីរក្តី ប្រយោជន៍ប្រព្រឹត្តទៅក្នុងបច្ចុប្បន្នក្តី ប្រយោជន៍ប្រព្រឹត្តទៅក្នុងលោកខាងមុខក្តី ។បេ។ ប្រយោជន៍ដ៏ឧត្តមក្តី ឈ្មោះថា ព្រះអង្គមិនធ្លាប់ឃើញ មិនធ្លាប់ឮ មិនធ្លាប់ប៉ះពាល់ មិនធ្លាប់ជ្រាប មិនមាន គ្មាន ឥតអង្គីមាន គឺថាមិនទាន់បានទេ ហេតុនោះ ( លោកពោលថា ) របស់អ្វីបន្តិចបន្តួច ឈ្មោះថា ព្រះអង្គមិនធ្លាប់ឃើញ មិនធ្លាប់ឮ មិនធ្លាប់ប៉ះពាល់ មិនមានទេ មួយទៀត របស់អ្វីបន្តិចបន្តួចក្នុងលោក ឈ្មោះថា ព្រះអង្គមិនធ្លាប់ជ្រាប មិនមានទេ ។

[ ៩២ ] ពាក្យថា សូមព្រះអង្គត្រាស់ប្រាប់ធម៌ ក្នុងបទថា ខ្ញុំព្រះអង្គគប្បីដឹងធម៌ណា សូមព្រះអង្គត្រាស់ប្រាប់ធម៌នោះ គឺសូមព្រះអង្គប្រាប់ សម្តែង បញ្ញត្ត តាំងផ្តើម បើក វែកញែក ធ្វើឲ្យរាក់ ប្រកាសនូវធម៌ឲ្យមានពីរោះបទដើម ។បេ។ និងនិព្វានគាមិនីបដិបទា ហេតុនោះ ( លោកពោលថា ) សូមព្រះអង្គត្រាស់ប្រាប់ធម៌នោះ ។ ពាក្យថា ខ្ញុំព្រះអង្គគប្បីដឹងធម៌ណា គឺខ្ញុំព្រះអង្គគប្បីដឹង ដឹងច្បាស់ ដឹងជាក់ ចាក់ធ្លុះ ត្រាស់ដឹង ពាល់ត្រូវ ធ្វើឲ្យជាក់ច្បាស់ ហេតុនោះ ( លោកពោលថា ) ខ្ញុំព្រះអង្គគប្បីដឹងធម៌ណា សូមព្រះអង្គត្រាស់ប្រាប់ធម៌នោះ ។

[ ៩៣ ] ពាក្យថា ជាគ្រឿងលះបង់ជាតិ និងជរាក្នុងទីនេះ គឺការលះបង់ ការរម្ងាប់បង់ ការរលាស់ចោល ការរម្ងាប់នូវជាតិ ជរា និងមរណៈ គឺអមតនិព្វាន ក្នុងទីនេះឯង ហេតុនោះ ( លោកពោលថា ) ជាគ្រឿងលះបង់ជាតិ និងជរា ក្នុងទីនេះ ។ ហេតុនោះ ព្រាហ្មណ៍នោះពោលថា

ទិសទាំង ១០ នេះ គឺទិសធំ ៤ ទិសតូច ៤ ទិសខាង លើ ១ ទិសខាងក្រោម ១ របស់អ្វីបន្តិចបន្តួច ឈ្មោះថា ព្រះអង្គមិនធ្លាប់ឃើញ មិនធ្លាប់ឮ មិនធ្លាប់ប៉ះពាល់ មិនមានទេ មួយទៀត របស់អ្វីបន្តិចបន្តួចក្នុងលោក ឈ្មោះថា ព្រះអង្គមិនធ្លាប់ជ្រាប មិនមានទេ ខ្ញុំព្រះអង្គគប្បីដឹងធម៌ណា ដែលជាគ្រឿងលះបង់ជាតិ និងជរា ក្នុងទីនេះ សូមព្រះអង្គត្រាស់ប្រាប់ធម៌នោះឲ្យទាន ។

[ ៩៤ ] ( ព្រះមានព្រះភាគត្រាស់ថា ម្នាលបិង្គិយៈ ) អ្នកកាលបើសម្លឹងមើលនូវពួកមនុស្ស ដែលត្រូវតណ្ហាគ្របសង្កត់ ត្រូវសេចក្តីក្តៅក្រហាយកើតមាន ត្រូវជរាបៀតបៀន ម្នាលបិង្គិយៈ អ្នកនឹងទៅជាបុគ្គលមិនប្រហែស ព្រោះការឃើញនោះ ហេតុនេះ អ្នកចូរលះបង់តណ្ហា ដើម្បីការមិនកើតទៀត ។

[ ៩៥ ] ពាក្យថា អ្នកកាលបើសម្លឹងមើលនូវពួកមនុស្ស ដែលត្រូវតណ្ហាគ្របសង្កត់ ត្រង់ពាក្យថា តណ្ហា បានដល់ រូបតណ្ហា សទ្ទតណ្ហា គន្ធតណ្ហា រសតណ្ហា ផោដ្ឋព្វតណ្ហា ធម្មតណ្ហា ។ ពាក្យថា ដែលត្រូវតណ្ហាគ្របសង្កត់ គឺតណ្ហាគ្របសង្កត់ ទៅតាមតណ្ហា ទាសទៅតាមតណ្ហា ជ្រមុជ

ចុះក្នុងតណ្ហា ត្រូវតណ្ហាគ្របសង្កត់ មានចិត្ត គឺតណ្ហារួបរឹត ។ ពាក្យថា ពួកមនុស្ស គឺជាឈ្មោះនៃសត្វ ។ ពាក្យថា កាលបើសម្លឹងមើល គឺកាលបើសម្លឹងមើល ក្រឡេកមើល រមិលមើល ពិនិត្យមើល ពិចារណាមើល ( ហេតុនោះ ) ទ្រង់ត្រាស់ថា អ្នកកាលបើសម្លឹងមើលពួកមនុស្ស ដែលត្រូវតណ្ហាគ្របសង្កត់ ។ ពាក្យថា ម្នាលបិង្គិយៈ គឺព្រះមានព្រះភាគត្រាស់ហៅព្រាហ្មណ៍ចំឈ្មោះ ។

[ ៩៦ ] ពាក្យថា ត្រូវសេចក្តីក្តៅក្រហាយកើតមាន ត្រូវជរាបៀតបៀនត្រង់ពាក្យថា ត្រូវសេចក្តីក្តៅក្រហាយកើតមាន គឺកើតសេចក្តីក្តៅក្រហាយព្រោះជាតិ កើតសេចក្តីក្តៅក្រហាយព្រោះជរា កើតសេចក្តីក្តៅក្រហាយព្រោះព្យាធិ កើតសេចក្តីក្តៅក្រហាយព្រោះមរណៈ កើតសេចក្តីក្តៅក្រហាយព្រោះសោក ខ្សឹកខ្សួល ទុក្ខ ទោមនស្ស និងសេចក្តីចង្អៀតចង្អល់ចិត្តទាំងឡាយ កើតសេចក្តីក្តៅក្រហាយ ព្រោះទុក្ខប្រព្រឹត្តទៅក្នុងនរក ។បេ។ កើតសេចក្តីក្តៅក្រហាយ កើតមានចង្រៃ កើតមានឧបទ្រព កើតមានឧបសគ្គអំពីទុក្ខ ព្រោះវិនាសទិដ្ឋិ ហេតុនោះ ( ទ្រង់ត្រាស់ថា ) ត្រូវសេចក្តីក្តៅក្រហាយកើតមាន ។ ពាក្យថា ត្រូវជរាបៀតបៀន គឺត្រូវជរាប៉ះពាល់ បៀតបៀន រួបរឹត ប្រព្រឹត្តទៅតាមជាតិ ទាសទៅដោយជរា ត្រូវព្យាធិគ្របសង្កត់ ត្រូវមរណៈកម្ចាត់ មិនមានទីពំនាក់ មិនមានទីជ្រក មិនមានទីពឹង មិនមានទីរំពឹង ហេតុនោះ ( ទ្រង់ត្រាស់ថា ) ត្រូវសេចក្តីក្តៅក្រហាយកើតមាន ត្រូវជរាបៀតបៀន ។

[ ៩៧ ] ពាក្យថា ម្នាលបិង្គិយៈ អ្នកនឹងទៅជាបុគ្គលមិនប្រហែស

ព្រោះការឃើញនោះ ត្រង់ពាក្យថា ព្រោះការឃើញនោះ គឺព្រោះហេតុនោះ ព្រោះដំណើរនោះ ព្រោះហេតុដូច្នោះ ព្រោះបច្ច័យនោះ ព្រោះនិទាននោះ បុគ្គលកាលបើឃើញទោសនៃតណ្ហាយ៉ាងនេះ ហេតុនោះ ( ទ្រង់ត្រាស់ថា ) ម្នាលបិង្គិយៈ អ្នក ... ព្រោះការឃើញនោះ ។ ពាក្យថា នឹងជាបុគ្គលមិនប្រហែស គឺនឹងជាបុគ្គលធ្វើដោយគោរព ធ្វើរឿយៗ ។បេ។ មិនប្រហែសក្នុងកុសលធម៌ ហេតុនោះ ( ទ្រង់ត្រាស់ថា ) ម្នាលបិង្គិយៈ អ្នកនឹងជាបុគ្គលមិនប្រហែស ព្រោះការឃើញនោះ ។

[ ៩៨ ] ពាក្យថា ចូរលះបង់តណ្ហា ដើម្បីការមិនកើតទៀត ត្រង់ពាក្យថា តណ្ហា បានដល់ រូបតណ្ហា សទ្ទតណ្ហា គន្ធតណ្ហា រសតណ្ហា ផោដ្ឋព្វ-តណ្ហា ធម្មតណ្ហា ។ ពាក្យថា ចូរលះបង់តណ្ហា គឺចូរលះបង់តណ្ហា បន្សាត់បង់តណ្ហា បន្ទោបង់តណ្ហា ធ្វើឲ្យវិនាសតណ្ហា ញុំាំងតណ្ហាឲ្យដល់នូវការមិនកើតមាន ហេតុនោះ ( ទ្រង់ត្រាស់ថា ) ចូរលះបង់តណ្ហា ។ ពាក្យថា ដើម្បីការមិនកើតទៀត គឺរូបរបស់អ្នក គប្បីរលត់ក្នុងទីនេះឯង យ៉ាងណា បដិសន្ធិភព មិនគប្បីកើតទៀត ក្នុងកាមធាតុក្តី រូបធាតុក្តី អរូបធាតុក្តី កាមភពក្តី រូបភពក្តី អរូបភពក្តី សញ្ញាភពក្តី អសញ្ញាភពក្តី នេវសញ្ញា-នាសញ្ញាភពក្តី ឯកវោការភពក្តី ចតុវោការភពក្តី បញ្ចវោការភពក្តី គឺមិនកើត មិនបង្កើត មិនកកើត មិនកើតចំពោះក្នុងគតិ ឧបបត្តិ បដិសន្ធិ សង្សារ និងវដ្តៈទៀត គឺថា គប្បីរលត់ គប្បីចូលទៅរម្ងាប់ គប្បីដល់នូវការតាំងនៅមិនបាន គប្បីរម្ងាប់ចំពោះក្នុងភពនេះឯង ក៏យ៉ាងនោះឯង ហេតុនោះ ( ទ្រង់

ត្រាស់ថា ) ចូរលះបង់តណ្ហា ដើម្បីការមិនកើតទៀត ។ ហេតុនោះ ព្រះមានព្រះភាគត្រាស់ថា

( ព្រះមានព្រះភាគត្រាស់ថា ម្នាលបិង្គិយៈ ) អ្នកកាលបើសម្លឹងមើលពួកមនុស្ស ដែលត្រូវតណ្ហាគ្របសង្កត់ ត្រូវសេចក្តីក្តៅក្រហាយកើតមាន ត្រូវជរាបៀតបៀន ម្នាលបិង្គិយៈ អ្នកនឹងទៅជាបុគ្គលមិនប្រហែស ព្រោះការឃើញនោះ ហេតុនោះ អ្នកចូរលះបង់តណ្ហា ដើម្បីការមិនកើតទៀត ។

[ ៩៩ ] ក្នុងពេលដំណាលគ្នា នឹងចប់ព្រះគាថា ពួកសត្វទាំងឡាយណា មានឆន្ទៈតែមួយ មានប្រយោគតែមួយ មានបំណងតែមួយ នៅដោយការនៅតែមួយ ជាមួយនឹងព្រាហ្មណ៍នោះ ធម្មចក្ខុ គឺសោតាបត្តិមគ្គ ប្រាសចាកធូលី ប្រាសចាកមន្ទិល កើតឡើងដល់ពាន់នៃសត្វទាំងឡាយដ៏ច្រើននោះថា ធម្មជាតណានីមួយ មានកិរិយាកើតឡើងជាធម្មតា ធម្មជាតទាំងអស់នោះ មានកិរិយារលត់ទៅវិញជាធម្មតា មួយទៀត ធម្មចក្ខុប្រាសចាកធូលី ប្រាសចាកមន្ទិល កើតឡើងដល់ព្រាហ្មណ៍នោះថា ធម្មជាតណាមួយ មានកិរិយាកើតឡើងជាធម្មតា ធម្មជាតទាំងអស់នោះ មានកិរិយារលត់ទៅវិញជាធម្មតា ។ ស្បែកខ្លា ផ្នួងសក់ សំពត់សម្បកឈើ ឈើច្រត់ កុណ្ឌី សក់ និងពុកមាត់

បាត់ទៅក្នុងពេលដំណាលគ្នានឹងការបានចក្ខុ ។ ព្រាហ្មណ៍នោះ ជាភិក្ខុមានភណ្ឌៈ និងសម្លៀកបំពាក់សំពត់កាសាយៈ ទ្រទ្រង់សង្ឃាដី បាត្រ និងចីវរ អង្គុយប្រណម្យអញ្ជលី នមស្ការព្រះមានព្រះភាគ ដោយការសម្រេចប្រយោជន៍ដ៏សមគួរ បានពោលថា បពិត្រព្រះអង្គដ៏ចម្រើន ព្រះមានព្រះភាគជាគ្រូនៃខ្ញុំព្រះអង្គ ខ្ញុំព្រះអង្គសូមជាសាវ័ក ។

## បិង្គិយមាណវកបញ្ហានិទ្ទេសទី ១៦ ចប់

# អដ្ឋកថា

## បិង្គិយមាណវកប្បញ្ហានិទ្ទេស

*គប្បីជ្រាបវិនិច្ឆ័យក្នុងបិង្គិយសុត្តនិទ្ទេសទី ១៦ ដូចតទៅ*

*[ ៧៩ ] បទថា* **ជិណ្ណោហមស្មិ អពលោ វីតវណ្ណោ** *សេចក្តីថា បាន ឮថា ព្រាហ្មណ៍នោះ ត្រូវជរាគ្របសង្កត់ មានអាយុ ១២០ ឆ្នាំអំពីកំណើត មានកម្លាំងតិច គិតថា នឹងជាក់ជើងក្នុងទីនេះ បែរជាជាក់ជើងក្នុងទីដទៃ ពណ៌សម្បុរដែលធ្លាប់ស្រស់ស្អាតក៏អស់ទៅហើយ ។ ដោយហេតុនោះ ទើបបិង្គិយៈ ទូលថា ខ្ញុំព្រះអង្គជាមនុស្សគ្រាំគ្រា មានកម្លាំងខ្សោយ ប្រាសចាកសម្បុរ ។ បទថា* **មាហំ បនស្សំ មោមុហោ អន្តរាយ** *សេចក្តីថា ខ្ញុំព្រះអង្គមិនទាន់ធ្វើឲ្យជាក់ច្បាស់នូវធម៌របស់ព្រះអង្គ កុំជាមនុស្សវង្វេង វិនាសទៅក្នុងចន្លោះឡើយ ។ បទថា* **ជាតិជរាយ ឥធ វិប្បហានំ** *សេចក្តីថា សូមទ្រង់ត្រាស់ប្រាប់ធម៌ គឺនិព្វានដែលខ្ញុំព្រះអង្គគប្បីដឹងច្បាស់ ដែលជាហេតុលះជាតិ និងជរាក្នុងបាសាណកចេតិយ ទៀបបាទមូលរបស់ព្រះអង្គ ក្នុងទីនេះ ដល់ខ្ញុំព្រះអង្គចុះ ។*

*[ ៨០ ] បទថា* **អពលោ** *បានដល់ វៀរចាកកម្លាំង ។ បទថា* **ទុព្វលោ** *បានដល់ មានកម្លាំងខ្សោយ ។ បទថា* **អប្បពលោ** *បានដល់ មានកម្លាំងបន្តិចបន្តួច ។ បទថា* **អប្បថាមោ** *បានដល់ មានកម្លាំងចិត្តតិច ។ បទថា* **វីតវណ្ណោ** *បានដល់ មានពណ៌សម្បុរប្រែប្រួលទៅ ។ បទថា* **វិគតវណ្ណោ** *បានដល់ មានពណ៌សម្បុរប្រាសទៅ ។ បទថា* **វិគច្ឆិតវណ្ណោ**[១]

---

*១- បទនេះ បិដកខ្មែរមិនឃើញមាន ។*

បានដល់ មានពណ៌សម្បុរវិនាសទៅ ។ បទថា **យា សា បុរិមា សុភា វណ្ណធាតុ** សេចក្តីថា ពណ៌សម្បុរល្អផូរផង់ ក្នុងបឋមវ័យនោះ ឥឡូវនេះ បាត់ទៅហើយ ។ បទថា **អាធីនវោ ចាតុក្ខតោ** បានដល់ មានទោសប្រាកដ ។ អាចារ្យមួយពួកតាំងបទថា **យា សា បុរិមា សុភា វណ្ណធាតុ** ហើយ អធិប្បាយថា **យា សុភា អស្ស** ។

[ ៨១ ] បទថា **អសុទ្ធា** បានដល់ មិនផូរផង់ ដោយមានមន្ទិលជិតជាមជាដើម ។ បទថា **អវិសុទ្ធា** បានដល់ មិនបរិសុទ្ធ ព្រោះកន្ទុយថ្ងៃនជាដើម ។ បទថា **អបរិសុទ្ធា** បានដល់ មិនបរិសុទ្ធ ព្រោះប្រកបដោយពពកភ្នែក និងមន្ទិលជាដើមដោយជុំវិញ ។ បទថា **អវោទាតា** បានដល់ មិនផូរផង់ ដូចគ្នានឹងខ្ទប់ទុក ។ បទថា **នោ តថា ចក្ខុនា រូបេ បស្សាមិ** បានដល់ ឥឡូវនេះ ខ្ញុំព្រះអង្គសម្លឹងមើលរូបារម្មណ៍ដោយចក្ខុ មិនច្បាស់ដូចមុន ។ ក្នុងបទថា **សោតា អសុទ្ធំ** ជាដើម ក៏មានន័យដូចគ្នា ។

[ ៨២ ] បទថា **មាហាម្បនស្សំ** បានដល់ ខ្ញុំព្រះអង្គកុំវិនាសឡើយ ។

[ ៨៥ ] ឥឡូវនេះ បិង្គិយព្រាហ្មណ៍ទូលពាក្យជាដើមថា ខ្ញុំព្រះអង្គជាមនុស្សគ្រាំគ្រា ព្រោះនៅមានការជាប់ជំពាក់ក្នុងកាយ ព្រោះហេតុនោះ ព្រះមានព្រះភាគ ដើម្បីឲ្យបិង្គិយៈដែលជាមនុស្សចាស់ លះនូវការជាប់ជំពាក់ក្នុងកាយ ទើបត្រាស់ពាក្យជាដើមថា **ទិស្វាន រូបេសុ វិហញ្ញមានេ** ដូច្នេះ ។

ក្នុងបទទាំងនោះ បទថា **រូបេសុ** បានដល់ ព្រោះរូបជាហេតុជាបច្ច័យ ។ បទថា **វិហញ្ញមានេ** សេចក្តីថា លំបាកដោយកម្មករណ៍ជាដើម ។ បទថា

រុប្បន្តិ រុប្បេសុ បានដល់ ជនទាំងឡាយ រមែងក្តៅក្រហាយ គឺលំបាកព្រោះរូបជាហេតុ ដោយរោគ មានរោគភ្នែកជាដើម ។

[ ៨៦ ] បទថា **ហញ្ញន្តិ** បានដល់ រមែងត្រូវប៉ះទង្គិច ។ បទថា **វិហញ្ញន្តិ** បានដល់ រមែងត្រូវបៀតបៀន ។ បទថា **ឧបហញ្ញន្តិ** បានដល់ ត្រូវកាត់ដៃ និងជើងជាដើម ។ បទថា **ឧបឃាតិយន្តិ** បានដល់ ដល់នូវការស្លាប់ ។

[ ៨៧ ] បទថា **កុប្បន្តិ** បានដល់ កម្រើក ។ បទថា **បីឡិយន្តិ** បានដល់ ដល់នូវការចង្អៀតចង្អល់ ។ បទថា **ឃដ្ដិយន្តិ** បានដល់ ដល់នូវការខាំងខ្ទប់ ។ បទថា **ព្យត្ថិតា** បានដល់ តក់ស្លុត ។ បទថា **ទោមនស្សិតា** បានដល់ ដល់នូវការលំបាកចិត្ត ។ បទថា **បហាយមានេ** បានដល់ វិនាស ។

[ ៩០ ] បិង្គិយព្រាហ្មណ៍ស្តាប់បដិបទា ដែលព្រះមានព្រះភាគត្រាស់ដរាបដល់អរហត្ត ក៏មិនសម្រេចគុណវិសេស ព្រោះភាពដែលខ្លួនជរា និងមានកម្លាំងតិច កាលនឹងសរសើរព្រះមានព្រះភាគដោយគាថានេះថា **ទិសា ចតស្សោ** ទើបអារាធនាឲ្យព្រះមានព្រះភាគសម្តែងទៀត ។

[ ៩៤ ] លំដាប់នោះ ព្រះមានព្រះភាគ កាលទ្រង់សម្តែងបដិបទារហូតដល់អរហត្ត ដល់បិង្គិយៈនោះ ទើបត្រាស់គាថាថា **តណ្ហាធិបន្នេ** ដូច្នេះជាដើម ។

[ ៩៥ ] បទថា **តណ្ហាធិបន្នេ** បានដល់ ត្រូវតណ្ហាញាំញី ។ បទថា

**តណ្ហានុគេ**[១] បានដល់ មកតាមតណ្ហា ។ បទថា **តណ្ហានុគតេ** បានដល់ ជាប់តាមតណ្ហា ។ បទថា **តណ្ហានុសដេ** បានដល់ ស្ទុះទៅជាមួយតណ្ហា ។ បទថា **តណ្ហាយាបន្នេ** បានដល់ លិចចុះទៅក្នុងតណ្ហា ។ បទថា **បដិបន្នេ**[២] បានដល់ ត្រូវតណ្ហាលិចលង់ ។ បទថា **អភិភូតេ** បានដល់ ត្រូវតណ្ហាបៀតបៀន ។ បទថា **បរិយាទិន្នចិត្តេ** បានដល់ មានកុសលចិត្តដែលតណ្ហាប្រកាន់ ។

[ ៩៦ ] បទថា **សន្តាបជាតេ** បានដល់ កើតនូវការក្តៅក្រហាយនៃចិត្ត ។ បទថា **ព្យាធិជាតេ** បានដល់ កើតនូវរោគ ។ បទថា **ឧបទ្ទវជាតេ** បានដល់ កើតនូវទោស ។ បទថា **ឧបសគ្គជាតេ** បានដល់ កើតទុក្ខ ។

[ ៩៩ ] គប្បីជ្រាបវិនិច្ឆ័យក្នុងបទថា **វិរជំ វីតមលំ** នេះ ដូចតទៅ បទថា **វិរជំ** បានដល់ ប្រាសចាកធូលី មានរាគៈជាដើម ។ បទថា **វីតមលំ** បានដល់ ប្រាសចាកមន្ទិល មានរាគៈជាដើម ។ ពិតហើយ រាគៈជាដើម ឈ្មោះថា **វិរជំ** ព្រោះអត្ថថា គ្របសង្កត់ ឈ្មោះថា **មលំ** ព្រោះអត្ថថា ប្រទូស្ត ។ បទថា **ធម្មចក្ខុំ** សេចក្តីថា ក្នុងទីខ្លះ សំដៅដល់មគ្គញ្ញាណទី ១ ទីខ្លះ សំដៅដល់មគ្គញ្ញាណ ៣ ជាដើម ទីខ្លះ សំដៅដល់មគ្គញ្ញាណទី ៤ តែក្នុងទីនេះ មគ្គញ្ញាណទី ៤ កើតដល់ជដិល ១០០០ នាក់ មគ្គញ្ញាណទី ៣ ប៉ុណ្ណោះ កើតដល់បិង្គិយៈ ។ បទថា **យង្កិញ្ចិ សមុទយធម្មំ សព្វន្តំ និរោធធម្មំ** សេចក្តីថា ភ្នែកឃើញធម៌ កើតឡើងហើយ ដល់បិង្គិយៈដែល

---

១-២ បិដកខ្មែរមិនប្រទះបទនេះ ។

ប្រព្រឹត្តទៅយ៉ាងនេះ ដោយអំណាចនៃវិបស្សនា ។ បទដ៏សេសក្នុងទីទាំងពួង ជាក់ច្បាស់ល្អហើយ ។

ព្រះមានព្រះភាគ ទ្រង់សម្តែងសូត្រនេះ ដោយធម៌ជាកំពូល គឺអរហត្ត ដោយប្រការដូច្នេះ ។ កាលចប់ទេសនា ព្រះបិង្គិយៈបានតាំងនៅក្នុងអនាគាមិផល ។

បានឮថា ព្រះបិង្គិយៈនោះគិតក្នុងចន្លោះៗ ថា ពាវរីព្រាហ្មណ៍ដែលជាឪពុកធំរបស់អញ មិនបានស្តាប់ទេសនាដែលមានបដិភាណវិចិត្រយ៉ាងនេះ ។ ដោយហេតុនោះ ទើបព្រះបិង្គិយៈមិនអាចសម្រេចអរហត្តបាន ព្រោះការរាយមាយដោយការជាប់ជំពាក់ តែជដិលដែលជាអន្តេវាសិក ១០០០ របស់ព្រះបិង្គិយៈ បានសម្រេចអរហត្ត ភិក្ខុទាំងអស់បានជាឯហិភិក្ខុ ជាអ្នកទ្រទ្រង់នូវបាត្រ និងចីវរ ដែលសម្រេចដោយឫទ្ធិ ដោយប្រការដូច្នេះ ។

## អដ្ឋកថា បិង្គិយមាណវសុត្តនិទ្ទេសទី ១៦ ចប់

# សុត្តន្តបិដក

## សោឡសមាណវកប្បញ្ហានិគមនិទ្ទេស

[ ១០០ ] ព្រះមានព្រះភាគ កាលគង់នៅនាបាសាណកចេតិយ ក្នុងមគធជនបទ ទ្រង់បានសម្តែងធម៌នេះ កាលព្រាហ្មណ៍ទាំង ១៦ ជាអ្នកបម្រើ ( នៃពាវរីព្រាហ្មណ៍ ) អារាធនាសួរហើយៗ ព្រះអង្គ ក៏បានទ្រង់ដោះស្រាយប្រស្នា ។

[ ១០១ ] ពាក្យថា ព្រះមានព្រះភាគ ទ្រង់បានសម្តែងធម៌នេះ គឺបាន សម្តែងបារាយនៈនេះ ។ ពាក្យថា ព្រះមានព្រះភាគនុ៎ះ ជាពាក្យពោលដោយ គោរព ។បេ។ បញ្ញត្តថា ព្រះមានព្រះភាគនេះ ( កើត ) ព្រោះការត្រាស់ដឹង ហេតុនោះ ( លោកពោលថា ) ព្រះមានព្រះភាគ ទ្រង់បានសម្តែងធម៌នេះ ។

[ ១០២ ] ពាក្យថា កាលគង់នៅក្នុងមគធជនបទ គឺក្នុងជនបទមាន ឈ្មោះថា មគធៈ ។ ពាក្យថា កាលគង់នៅ គឺកាលស្ថិតនៅ ប្រព្រឹត្ត រក្សា យាត្រា ឲ្យយាត្រាទៅ ។ ពាក្យថា បាសាណកចេតិយ សេចក្តីថា ពុទ្ធាសនៈ លោកហៅថា បាសាណចេតិយ ហេតុនោះ ( លោកពោលថា ) កាលគង់ នៅនាបាសាណកចេតិយ ក្នុងមគធជនបទ ។

[ ១០៣ ] ពាក្យថា កាលត្រូវព្រាហ្មណ៍ជាអ្នកបម្រើទាំង ១៦ សេចក្តី ថា បិង្គិយព្រាហ្មណ៍ ជាអ្នកបម្រើ ប្រសើរ ថ្លៃថ្លា នៃពាវរីព្រាហ្មណ៍ ព្រាហ្មណ៍ទាំង ១៦ នាក់នោះ រាប់ទាំងបិង្គិយព្រាហ្មណ៍ផង ហេតុនោះ ( លោកពោលថា ) កាលព្រាហ្មណ៍ទាំង ១៦ ជាអ្នកបម្រើយ៉ាងនេះក៏បាន ។ ឬថា ព្រាហ្មណ៍ទាំង ១៦ នោះ ជាអ្នកបម្រើ ប្រសើរ ថ្លៃថ្លា នៃព្រះពុទ្ធមាន

ព្រះភាគ ហេតុនោះ ( លោកពោលថា ) កាលព្រាហ្មណ៍ទាំង ១៦ ជាអ្នកបម្រើយ៉ាងនេះក៏បាន ។

[ ១០៤ ] ពាក្យថា អារាធនាសួរហើយៗ ព្រះអង្គក៏បានទ្រង់ដោះស្រាយប្រស្នា គឺអារាធនាហើយ និមន្តហើយ ។ ពាក្យថាសួរហើយៗ គឺសួរហើយ សួរបញ្ជាក់ហើយ អង្វរហើយ អារាធនាហើយ ឲ្យជ្រះថ្លាហើយ ។ ពាក្យថា ទ្រង់ដោះស្រាយប្រស្នា គឺទ្រង់ដោះស្រាយ ប្រាប់ សម្ដែង បញ្ញត្ត តាំងផ្ដើម បើក វែកញែក ធ្វើឲ្យរាក់ ប្រកាសនូវប្រស្នា ហេតុនោះ ( លោកពោលថា ) អារាធនាសួរហើយៗ ព្រះអង្គក៏បានទ្រង់ដោះស្រាយប្រស្នា ។

[ ១០៥ ] ប្រសិនបើបុគ្គល បានដឹងអត្ថ បានដឹងធម៌នៃប្រស្នាមួយៗ ហើយប្រតិបត្តិនូវធម៌ ដ៏សមគួរដល់ធម៌ បុគ្គលនោះ នឹងទៅកាន់ត្រើយនៃជរា និងមរណៈពុំខាន ( ព្រោះថា ) ធម៌ទាំងនេះជាធម៌គួរនាំសត្វទៅកាន់ត្រើយ គឺព្រះនិព្វាន ហេតុនោះ ពាក្យថា បារាយនៈ ជាឈ្មោះនៃធម្មបរិយាយនេះ ។

[ ១០៦ ] ពាក្យថា ប្រសិនបើនៃប្រស្នាមួយៗ គឺប្រសិនបើនៃប្រស្នាអជិតមាណពមួយៗ ប្រសិនបើនៃប្រស្នាតិស្សមេត្តេយ្យមាណពមួយៗ ប្រសិនបើនៃប្រស្នាបុណ្ណកមាណពមួយៗ ប្រសិនបើនៃប្រស្នាមេត្តគូមាណពមួយៗ ប្រសិនបើនៃប្រស្នាធោតកមាណពមួយៗ ប្រសិនបើនៃប្រស្នាឧបសីវមាណពមួយៗ ប្រសិនបើនៃប្រស្នានន្ទមាណពមួយៗ ប្រសិនបើនៃប្រស្នាហេមកមាណពមួយៗ ប្រសិនបើនៃប្រស្នាតោទេយ្យមាណពមួយៗ ប្រសិនបើនៃប្រស្នា

កប្បមាណពមួយៗ ប្រសិនបើនៃប្រស្នាជតុកណ្ណីមាណពមួយៗ ប្រសិនបើនៃប្រស្នាភទ្រាវុធមាណពមួយៗ ប្រសិនបើនៃប្រស្នាឧទយមាណពមួយៗ ប្រសិនបើនៃប្រស្នាបោសាលមាណពមួយៗ ប្រសិនបើនៃប្រស្នាមោឃរាជមាណពមួយៗ ប្រសិនបើនៃប្រស្នាបិង្គិយមាណពមួយៗ ហេតុនោះ ( លោកពោលថា ) ប្រសិនបើនៃប្រស្នាមួយៗ ។

[ ១០៧ ] ពាក្យថា បានដឹងអត្ថ បានដឹងធម៌ គឺបានដឹង យល់ ពិចារណា ត្រិះរិះ សម្តែង ធ្វើឲ្យប្រាកដនូវសេចក្តីថា ធម៌ គឺប្រស្នានោះឯង អត្ថ គឺការដោះស្រាយនោះឯង ហេតុនោះ ( លោកពោលថា ) បានដឹងអត្ថ ។ ពាក្យថា បានដឹងធម៌ គឺបានដឹង យល់ ពិចារណា ត្រិះរិះ សម្តែង ធ្វើឲ្យប្រាកដនូវធម៌ ហេតុនោះ ( លោកពោលថា ) បានដឹងធម៌ ។

[ ១០៨ ] ពាក្យថា ប្រតិបត្តិធម៌ដ៏សមគួរដល់ធម៌ គឺប្រតិបត្តិសម្មាបដិបទា អនុលោមប្បដិបទា អបច្ចនីកប្បដិបទា អន្វត្ថប្បដិបទា ធម្មានុធម្មប្បដិបទា ហេតុនោះ ( លោកពោលថា ) ប្រតិបត្តិធម៌ដ៏សមគួរដល់ធម៌ ។

[ ១០៩ ] ពាក្យថា ទៅកាន់ត្រើយនៃជរា និងមរណៈពុំខាន សេចក្តីថា អមតនិព្វាន លោកហៅថា ត្រើយនៃជរា និងមរណៈ បានដល់ សេចក្តីរម្ងាប់សង្ខារទាំងពួង ការលះបង់ចោលឧបធិទាំងពួង ការអស់តណ្ហា ការប្រាសចាកតម្រេក ការរលត់ និព្វាន ។ ពាក្យថា នឹងទៅកាន់ត្រើយនៃជរា និងមរណៈពុំខាន បានសេចក្តីថា នឹងទៅកាន់ត្រើយ នឹងបានត្រើយ នឹងប៉ះពាល់ត្រើយ នឹងធ្វើឲ្យជាក់ច្បាស់នូវត្រើយ ហេតុនោះ ( លោកពោលថា ) នឹងទៅកាន់

ត្រើយនៃជរា និងមរណៈពុំខាន ។

[ ១១០ ] ពាក្យថា ធម៌ទាំងនេះ ជាធម៌គួរនាំសត្វទៅកាន់ត្រើយ សេចក្តីថា ធម៌ទាំងនេះ ជាធម៌គួរនាំសត្វទៅកាន់ត្រើយ គឺញុំាងសត្វឲ្យដល់ត្រើយ ឲ្យដល់ព្រមនូវត្រើយ ឲ្យដល់ស៊ប់នូវត្រើយ គឺថា ប្រព្រឹត្តទៅដើម្បីឆ្លងជរា និងមរណៈ ហេតុនោះ ( លោកពោលថា ) ធម៌ទាំងនេះ ជាធម៌គួរនាំសត្វទៅកាន់ត្រើយ ។

[ ១១១ ] ពាក្យថា ហេតុនោះ ... នៃធម្មបរិយាយនេះ ត្រង់ពាក្យថា ហេតុនោះ គឺព្រោះហេតុនោះ ព្រោះដំណើរនោះ ព្រោះហេតុដូច្នោះ ព្រោះបច្ច័យនោះ ព្រោះនិទាននោះ ហេតុនោះ ( លោកពោលថា ) ហេតុនោះ ។ ពាក្យថា នៃធម្មបរិយាយនេះ គឺនៃបារាយនៈនេះ ហេតុនោះ ( លោកពោលថា ) ហេតុនោះ ... នៃធម្មបរិយាយនេះ ។

[ ១១២ ] ពាក្យថា បារាយនៈជាឈ្មោះ សេចក្តីថា អមតនិព្វានលោកហៅថា បារៈ បានខាងការរម្ងាប់សង្ខារទាំងពួង ការរលាស់ចោលឧបធិទាំងពួង ការអស់តណ្ហា ការប្រាសចាកតម្រេក ការរលត់ និព្វាន ។ មគ្គ គឺ សម្មាទិដ្ឋិ ។បេ។ សម្មាសមាធិ លោកហៅថា អាយនៈ ។ ពាក្យថា ឈ្មោះ គឺជានាម ការរាប់ សេចក្តីសម្គាល់ បញ្ញត្តិ ។បេ។ ជាពាក្យសម្រាប់ហៅ ហេតុនោះ ( លោកពោលថា ) ពាក្យថា បារាយនៈ ជាឈ្មោះ ។

[ ១១៣ ] អជិតៈ ១ តិស្សមេត្តេយ្យៈ ១ បុណ្ណកៈ ១ មេត្តគូ ១
ធោតកៈ ១ ឧបសីវៈ ១ នន្ទៈ ១ ហេមកៈ ១ ជនទាំងពីរនាក់

គឺតោទេយ្យៈ ១ កប្បៈ ១ និងជតុកណ្ណីបណ្ឌិត ១ កទ្រាវុធ ១ ឧទយៈ ១ បោសាលព្រាហ្មណ៍ ១ មោឃរាជជាអ្នកប្រាជ្ញ ១ បិង្គិយៈ ជាអ្នកស្វែងរកគុណធំ ១ ព្រាហ្មណ៍ទាំង ១៦ នាក់នុ៎ះ ចូលមកគាល់ព្រះពុទ្ធជាឥសី ទ្រង់មានចរណៈបរិបូណ៌ បានចូលមកគាល់សួរប្រស្នាដ៏ល្អិត ចំពោះព្រះពុទ្ធប្រសើរ ។

[ ១១៤ ] អធិប្បាយពាក្យថា ព្រាហ្មណ៍ទាំង ១៦ នាក់នុ៎ះ ចូលមកគាល់ព្រះពុទ្ធ ត្រង់ពាក្យថា នុ៎ះ គឺពួកព្រាហ្មណ៍នុ៎ះ ។ ពាក្យថា ព្រះពុទ្ធ បានដល់ព្រះមានព្រះភាគ ទ្រង់ត្រាស់ដឹងឯង មិនមានបុគ្គលជាអាចារ្យ បានត្រាស់ដឹងដោយព្រះអង្គឯង នូវសច្ចៈទាំងឡាយ ក្នុងធម៌ទាំងឡាយដែលព្រះអង្គ មិនធ្លាប់ឮហើយក្នុងកាលមុន ទាំងបានដល់សព្វញ្ញុតញ្ញាណ ក្នុងសច្ចៈទាំងនោះ និងភាវៈស្ទាត់ក្នុងពលទាំងឡាយ ។ សំណួរត្រង់ពាក្យថា ព្រះពុទ្ធ ចុះឈ្មោះថាព្រះពុទ្ធ ដោយអត្ថដូចម្តេច ។ ឈ្មោះថា ព្រះពុទ្ធ ព្រោះហេតុទ្រង់ត្រាស់ដឹងសច្ចៈទាំងឡាយ ។ ឈ្មោះថា ព្រះពុទ្ធ ព្រោះហេតុទ្រង់ញ៉ាំងពពួកសត្វឲ្យត្រាស់ដឹង ។ ឈ្មោះថា ព្រះពុទ្ធ ព្រោះព្រះអង្គដឹងធម៌ទាំងពួង ។ ឈ្មោះថា ព្រះពុទ្ធ ព្រោះព្រះអង្គឃើញធម៌ទាំងពួង ។ ឈ្មោះថា ព្រះពុទ្ធ ព្រោះព្រះអង្គដឹងច្បាស់ ។ ឈ្មោះថា ព្រះពុទ្ធ ព្រោះព្រះអង្គរីកហើយ ។ ឈ្មោះថា ព្រះពុទ្ធ ព្រោះគេពោលថា ព្រះអង្គមានអាសវៈអស់ហើយ ។ ឈ្មោះថា ព្រះពុទ្ធ ព្រោះគេពោលថា ព្រះអង្គមានឧបក្កិលេសចេញហើយ ។ ឈ្មោះថា ព្រះពុទ្ធ ព្រោះហេតុទ្រង់ប្រាសចាករាគៈ ដោយចំណែកមួយ ។ ឈ្មោះថា ព្រះពុទ្ធ

ព្រោះហេតុទ្រង់ប្រាសចាកទោសៈ ដោយចំណែកមួយ ។ ឈ្មោះថា ព្រះពុទ្ធ ព្រោះហេតុទ្រង់ប្រាសចាកមោហៈ ដោយចំណែកមួយ ។ ឈ្មោះថា ព្រះពុទ្ធ ព្រោះហេតុទ្រង់មានកិលេសចេញហើយ ដោយចំណែកមួយ ។ ឈ្មោះថា ព្រះពុទ្ធ ព្រោះហេតុទ្រង់ទៅហើយកាន់ផ្លូវ ជាទីទៅនៃបុគ្គលម្នាក់ឯង ។ ឈ្មោះថា ព្រះពុទ្ធ ព្រោះហេតុទ្រង់ជាបុគ្គលឯក ត្រាស់ដឹងចំពោះសម្មាសម្ពោធិញ្ញាណ មិនមានគុណជាតដទៃក្រៃលែងជាង ។ ឈ្មោះថា ព្រះពុទ្ធ ព្រោះទ្រង់កម្ចាត់បង់សេចក្តីល្ងង់ ព្រោះការបាននូវប្រាជ្ញា ។ ព្រះនាមព្រះពុទ្ធនុ៎ះ មិនមែនព្រះមាតាថ្វាយ មិនមែនព្រះបិតាថ្វាយ មិនមែនបងប្អូនប្រុសថ្វាយ មិនមែនបងប្អូនស្រីថ្វាយ មិនមែនពួកមិត្ត និងអាមាត្យថ្វាយ មិនមែនពួកញាតិ និងសាលោហិតថ្វាយ មិនមែនពួកសមណព្រាហ្មណ៍ថ្វាយ មិនមែនពួកទេវតាថ្វាយទេ ព្រះនាមថា ព្រះពុទ្ធនុ៎ះ របស់ព្រះពុទ្ធទាំងឡាយមានព្រះភាគ ជាព្រះនាមកើតក្នុងទីបំផុតនៃវិមោក្ខ បញ្ញត្តថា ព្រះពុទ្ធនេះ កើតព្រោះការត្រាស់ដឹង ព្រមដោយការបានចំពោះនូវសព្វញ្ញុតញ្ញាណ ទៀបគល់ពោធិព្រឹក្ស ហេតុនោះ ( លោកពោលថា ) ព្រះពុទ្ធ ។ ពាក្យថា នុ៎ះ ចូលមកគាល់ព្រះពុទ្ធ គឺព្រាហ្មណ៍ទាំងនុ៎ះ ចូលមករក ចូលមកជិត មកអង្គុយជិត សាកសួរ ដណ្តឹងសួរ នូវព្រះពុទ្ធ ហេតុនោះ ( លោកពោលថា ) ព្រាហ្មណ៍ទាំង ១៦ នាក់នុ៎ះ ចូលមកគាល់ព្រះពុទ្ធ ។

[ ១១៥ ] ពាក្យថា ជាឥសី មានចរណៈបរិបូណ៌ អធិប្បាយថា ការសម្រេចដោយសីលាចារៈ លោកហៅថាចរណៈ ។ ការសង្រួមសីល ឈ្មោះថា

ចរណៈ ការសង្រួមឥន្ទ្រិយ ឈ្មោះថា ចរណៈ ភាពជាអ្នកដឹងប្រមាណក្នុងភោជន ឈ្មោះថា ចរណៈ ការប្រកបរឿយៗ នូវសេចក្តីភ្ញាក់រឭក ឈ្មោះថា ចរណៈ ព្រះសទ្ធម្មទាំង ៧ ឈ្មោះថា ចរណៈ ឈានទាំង ៤ ឈ្មោះថា ចរណៈ ។ ពាក្យថា មានចរណៈបរិបូណ៌ គឺមានចរណៈគ្រប់គ្រាន់ មានចរណៈដ៏ប្រសើរ មានចរណៈជាប្រធាន មានចរណៈដ៏ឧត្តម មានចរណៈដ៏ថ្លៃថ្លា ហេតុនោះ ( លោកពោលថា ) មានចរណៈបរិបូណ៌ ។ ពាក្យថា ជាឥសី គឺជាអ្នកស្វែង ។ ព្រះមានព្រះភាគ ឈ្មោះថា ឥសី ព្រោះហេតុទ្រង់ស្វែងស្វែងរក ស្វះស្វែងនូវសីលក្ខន្ធដ៏ធំ ។បេ។ ឬថា ឈ្មោះថា ឥសី ព្រោះហេតុព្រះមានព្រះភាគ ត្រូវសត្វទាំងឡាយមានសក្កៈធំរក ស្វែង ស្វះស្វែងថា ព្រះពុទ្ធ គង់ក្នុងទីណា ព្រះមានព្រះភាគ គង់ក្នុងទីណា ព្រះពុទ្ធជាទេវតាដ៏ធំជាងទេវតា គង់ក្នុងទីណា ព្រះពុទ្ធជានរៈ អង់អាច គង់ក្នុងទីណា ហេតុនោះ ( លោកពោលថា ) ជាឥសី មានចរណៈបរិបូណ៌ ។

[ ១១៦ ] ពាក្យថា សួរប្រស្នាដ៏ល្អិត ត្រង់ពាក្យថា សួរ គឺសួរ អង្វរ អារាធនា ជ្រះថ្លា ។ ពាក្យថា ប្រស្នាដ៏ល្អិត គឺប្រស្នាដ៏ជ្រាលជ្រៅ ដែលបុគ្គលឃើញបានដោយកម្រ ត្រាស់ដឹងបានដោយកម្រ ដ៏ល្អិត ឧត្តម មិនជាទីស្ទង់ដោយសេចក្តីត្រិះ ជាប្រស្នាដ៏ម៉ត់ចត់ មានតែបណ្ឌិតទើបដឹងបាន ហេតុនោះ ( លោកពោលថា ) សួរប្រស្នាដ៏ល្អិត ។

[ ១១៧ ] ពាក្យថា ព្រះពុទ្ធ ក្នុងបទថា ចូលមកគាល់ព្រះពុទ្ធប្រសើរ គឺព្រះមានព្រះភាគ ។បេ។ បញ្ញត្តថា ព្រះពុទ្ធនេះ ( កើត ) ព្រោះការត្រាស់

ដឹង ។ ពាក្យថា ប្រសើរ គឺលើស ប្រសើរ ប្រសើរវិសេស ជាប្រធាន ឧត្តម ថ្លៃថ្លា ហេតុនោះ ( លោកពោលថា ) ព្រះពុទ្ធប្រសើរ ។ ពាក្យថា ចូលមកគាល់ គឺចូលមករក ចូលមកជិត ចូលមកអន្ទយជិត សាកសួរ ដណ្តឹងសួរ ហេតុនោះ ( លោកពោលថា ) ចូលមកគាល់ព្រះពុទ្ធប្រសើរ ។ ហេតុនោះ លោកពោលពាក្យនេះថា

ព្រាហ្មណ៍ទាំង ១៦ នាក់នុ៎ះ ចូលមកគាល់ព្រះពុទ្ធជាឥសី ទ្រង់មានចរណៈបរិបូណ៌ បានចូលមកគាល់សួរប្រស្នាដ៏ល្អិត ចំពោះព្រះពុទ្ធប្រសើរ ។

[ ១១៨ ] ព្រះពុទ្ធ ដែលព្រាហ្មណ៍ទាំងនោះសួរប្រស្នាហើយ ក៏ទ្រង់ព្យាករហើយ តាមសេចក្តីពិត ព្រះមុនិ បានទ្រង់ញុំាងពួកព្រាហ្មណ៍ឲ្យត្រេកអរ ដោយការព្យាករណ៍ប្រស្នាទាំងឡាយ ។

[ ១១៩ ] ពាក្យថា ព្រះពុទ្ធ ដែលព្រាហ្មណ៍ទាំងនោះ ( សួរប្រស្នាហើយ ) ក៏ទ្រង់ព្យាករហើយ ត្រង់ពាក្យថា ដែលព្រាហ្មណ៍ទាំងនោះ គឺដែលពួកព្រាហ្មណ៍ទាំង ១៦ ជាអ្នកគួរទៅកាន់ត្រើយ ។ ពាក្យថា ព្រះពុទ្ធ បានដល់ព្រះមានព្រះភាគ ។បេ។ បញ្ញត្តថា ព្រះពុទ្ធនេះ ( កើត ) ព្រោះការត្រាស់ដឹង ។ ពាក្យថា ទ្រង់ព្យាករហើយ គឺព្រះពុទ្ធទ្រង់ព្យាករ ប្រាប់ សម្តែង តែងតាំង តាំងផ្តើម បើក វែកញែក ធ្វើឲ្យរាក់ ប្រកាសហើយ ចំពោះជនទាំងនោះ ហេតុនោះ ( លោកពោលថា ) ព្រះពុទ្ធដែលព្រាហ្មណ៍ទាំងនោះ ( សួរប្រស្នាហើយ ) ទ្រង់ព្យាករហើយ ។

[ ១២០ ] ពាក្យថា សួរប្រស្នាហើយ ... តាមសេចក្ដីពិត ត្រង់ពាក្យថា សួរប្រស្នាហើយ គឺអង្វរ អារាធនា ឲ្យជ្រះថ្លាហើយនូវប្រស្នា ។ ពាក្យថា តាមសេចក្ដីពិត គឺគួរប្រាប់យ៉ាងណា ទ្រង់ប្រាប់យ៉ាងនោះ គួរសម្ដែងយ៉ាងណា ទ្រង់សម្ដែងយ៉ាងនោះ គួរតែងតាំងយ៉ាងណា ទ្រង់តែងតាំងយ៉ាងនោះ គួរតាំងផ្ដើមយ៉ាងណា ទ្រង់តាំងផ្ដើមយ៉ាងនោះ គួរបើកយ៉ាងណា ទ្រង់បើកយ៉ាងនោះ គួរវែកញែកយ៉ាងណា ទ្រង់វែកញែកយ៉ាងនោះ គួរធ្វើឲ្យរាក់យ៉ាងណា ទ្រង់ធ្វើឲ្យរាក់យ៉ាងនោះ គួរប្រកាសយ៉ាងណា ទ្រង់ប្រកាសយ៉ាងនោះ ហេតុនោះ ( លោកពោលថា ) សួរប្រស្នាហើយ ... តាមសេចក្ដីពិត ។

[ ១២១ ] ពាក្យថា ដោយការព្យាករណ៍ប្រស្នាទាំងឡាយ គឺដោយការព្យាករណ៍ ការប្រាប់ ការសម្ដែង ការតែងតាំង ការតាំងផ្ដើម ការបើក ការវែកញែក ការធ្វើឲ្យរាក់ ការប្រកាស នូវប្រស្នាទាំងឡាយ ហេតុនោះ ( លោកពោលថា ) ដោយការព្យាករណ៍ប្រស្នាទាំងឡាយ ។

[ ១២២ ] ពាក្យថា ឲ្យត្រេកអរ ក្នុងបទថា ព្រះមុនិបានទ្រង់ញ៉ាំងពួកព្រាហ្មណ៍ឲ្យត្រេកអរ គឺឲ្យត្រេកអរ ឲ្យត្រេកអរវិសេស ឲ្យជ្រះថ្លា ឲ្យស្រស់ស្រាយ បានធ្វើពួកព្រាហ្មណ៍ទាំងនោះ ឲ្យមានចិត្តរីករាយ ។ ពាក្យថា ញ៉ាំងពួកព្រាហ្មណ៍ គឺពន្យល់ពួកព្រាហ្មណ៍ទាំង ១៦ ដែលជាអ្នកគួរដល់ត្រើយ ។ ពាក្យថា ព្រះមុនិ សេចក្ដីថា ញាណ លោកហៅថាមោនៈ បានដល់បញ្ញា ការដឹងច្បាស់ ។បេ។ បុគ្គលណា កន្លងបង់នូវបណ្ដាញ ជាគ្រឿងជាប់ជំពាក់ បុគ្គលនោះ ឈ្មោះថា មុនិ ហេតុនោះ ( លោកពោលថា ) ព្រះមុនិបាន

ទ្រង់ញុំាងពួកព្រាហ្មណ៍ឲ្យត្រេកអរ ។ ហេតុនោះ លោកពោលពាក្យនេះថា

ព្រះពុទ្ធ ដែលព្រាហ្មណ៍ទាំងនោះសួរប្រស្នាហើយ ក៏ទ្រង់ព្យាករ
ហើយតាមសេចក្តីពិត ព្រះមុនិ បានញុំាងពួកព្រាហ្មណ៍ឲ្យត្រេកអរ
ដោយការព្យាករណ៍ប្រស្នាទាំងឡាយ ។

[ ១២៣ ] ជនទាំងនោះ ដែលព្រះពុទ្ធទ្រង់ជាផៅពង្ស នៃព្រះ
អាទិត្យ មានចក្ខុបានឲ្យត្រេកអរ ក៏បានប្រព្រឹត្តព្រហ្មចរិយៈ ក្នុង
សម្នាក់ព្រះសាស្តា មានបញ្ញាប្រសើរ ។

[ ១២៤ ] ពាក្យថា ជនទាំងនោះ ដែលព្រះពុទ្ធមានចក្ខុ បានឲ្យត្រេកអរហើយ ត្រង់ពាក្យថា ជនទាំងនោះ គឺពួកព្រាហ្មណ៍ទាំង ១៦ ដែលគួរទៅកាន់ត្រើយ ។ ពាក្យថា បានឲ្យត្រេកអរ គឺបានឲ្យត្រេកអរ ឲ្យត្រេកអរវិសេស ឲ្យជ្រះថ្លា ឲ្យស្រស់ស្រាយ ធ្វើឲ្យមានចិត្តរីករាយ ហេតុនោះ ( លោកពោលថា ) ជនទាំងនោះ ... បានឲ្យត្រេកអរហើយ ។ ពាក្យថា មានចក្ខុ គឺព្រះមានព្រះភាគមានចក្ខុ ដោយចក្ខុ ៥ គឺមានចក្ខុ ដោយមំសចក្ខុ ១ មានចក្ខុ ដោយទិព្វចក្ខុ ១ មានចក្ខុ ដោយបញ្ញាចក្ខុ ១ មានចក្ខុ ដោយពុទ្ធចក្ខុ ១ មានចក្ខុ ដោយសមន្តចក្ខុ ១ ព្រះមានព្រះភាគមានចក្ខុ ដោយមំសចក្ខុ តើដូចម្តេច ។បេ។ ព្រះមានព្រះភាគមានចក្ខុ ដោយសមន្តចក្ខុយ៉ាងនេះ ហេតុនោះ ( លោកពោលថា ) ជនទាំងនោះ ដែលព្រះពុទ្ធមានចក្ខុ បានឲ្យត្រេកអរហើយ ។

[ ១២៥ ] ពាក្យថា ព្រះពុទ្ធទ្រង់ជាផៅពង្សនៃព្រះអាទិត្យ ត្រង់ពាក្យថា

ព្រះពុទ្ធ បានដល់ ព្រះមានព្រះភាគ ។បេ។ បញ្ញត្តថាព្រះពុទ្ធនេះ ( កើត ) ព្រោះការត្រាស់ដឹង ។ ពាក្យថា ទ្រង់ជាផៅពង្សនៃព្រះអាទិត្យ សេចក្តីថា សុរិយៈ លោកហៅថា ព្រះអាទិត្យ ។ សុរិយៈនោះ ជាគោតមដោយគោត្ត ព្រះមានព្រះភាគ ក៏ជាគោតមដោយគោត្ត ព្រះមានព្រះភាគ ជាញាតិដោយគោត្ត ជាផៅពង្សដោយគោត្តនៃសុរិយៈ ហេតុនោះ ព្រះពុទ្ធ ឈ្មោះថា ជាផៅពង្សនៃព្រះអាទិត្យ ហេតុនោះ ( លោកពោលថា ) ដែលព្រះពុទ្ធទ្រង់ជាផៅពង្សនៃព្រះអាទិត្យ ។

[ ១២៦ ] ពាក្យថា បានប្រព្រឹត្តព្រហ្មចរិយៈ សេចក្តីថា ការចៀស ការវាង ការវាងស្រឡះ ចេតនាជាហេតុវៀរ ការវៀរ ការមិនធ្វើ ការមិនសាង ការមិនសម្កុត ការមិនប្រព្រឹត្តកន្លងកម្រិត ការផ្តាច់ស្ពាន ក្នុងការប្រកបដោយអសទ្ធម្ម លោកហៅថា ព្រហ្មចរិយៈ ។ មួយទៀត បើពោលដោយអំណាចនិប្បរិយាយ មគ្គប្រកបដោយអង្គ ៨ ដ៏ប្រសើរ គឺប្រាជ្ញាយល់ឃើញត្រូវ សេចក្តីត្រិះរិះត្រូវ សម្តីត្រូវ ការងារត្រូវ ការចិញ្ចឹមជីវិតត្រូវ ការព្យាយាមត្រូវ សេចក្តីរឭកត្រូវ ការតម្កល់ចិត្តឲ្យនឹងត្រូវ លោកហៅថា ព្រហ្មចរិយៈ ។ ពាក្យថា បានប្រព្រឹត្តព្រហ្មចរិយៈ គឺបានប្រព្រឹត្ត ប្រព្រឹត្តសមាទានព្រហ្មចរិយៈ ហេតុនោះ ( លោកពោលថា ) ក៏បានប្រព្រឹត្តព្រហ្មចរិយៈ ។

[ ១២៧ ] ពាក្យថា ក្នុងសម្នាក់ព្រះសាស្តា មានប្រាជ្ញាប្រសើរ គឺព្រះសាស្តាមានប្រាជ្ញាប្រសើរ មានប្រាជ្ញាដ៏លើស មានប្រាជ្ញាប្រសើរបំផុត មានប្រាជ្ញាជាប្រធាន មានប្រាជ្ញាដ៏ឧត្តម មានប្រាជ្ញាដ៏ថ្លៃថ្លា ។ ពាក្យថា ក្នុងសម្នាក់

គឺក្នុងសម្នាក់ ក្បែរ ជិត មិនឆ្ងាយ កៀក ហេតុនោះ ( លោកពោលថា ) ក្នុងសម្នាក់ព្រះសាស្តា មានប្រាជ្ញាប្រសើរ ។ ហេតុនោះ លោកពោលពាក្យនេះថា

ជនទាំងនោះ ដែលព្រះពុទ្ធទ្រង់ជាផៅពង្សនៃព្រះអាទិត្យ មានចក្ខុ
បានឲ្យត្រេកអរហើយ ក៏បានប្រព្រឹត្តព្រហ្មចរិយៈ ក្នុងសម្នាក់ព្រះ
សាស្តា មានប្រាជ្ញាប្រសើរ ។

[ ១២៨ ] សេចក្តីនៃប្រស្នាមួយៗ ដែលព្រះពុទ្ធសំដែងហើយ
យ៉ាងណា បើបុគ្គលណា ប្រតិបត្តិតាមយ៉ាងនោះ បុគ្គលនោះ
នឹងចេញអំពីទីមិនមែនត្រើយ ទៅកាន់ត្រើយបាន ។

[ ១២៩ ] ពាក្យថា នៃប្រស្នាមួយៗ គឺនៃប្រស្នាអជិតមាណពមួយៗ នៃប្រស្នាតិស្សមេត្តេយ្យមាណពមួយៗ ។បេ។ នៃប្រស្នាបិង្គិយមាណពមួយៗ ហេតុនោះ ( លោកពោលថា ) នៃប្រស្នាមួយៗ ។

[ ១៣០ ] ពាក្យថា ដែលព្រះពុទ្ធសំដែងហើយយ៉ាងណា គឺពាក្យថា ព្រះពុទ្ធ បានដល់ ព្រះមានព្រះភាគ ។បេ។ បញ្ញត្តថា ព្រះពុទ្ធនេះ ( កើត ) ព្រោះការត្រាស់ដឹង ។ ពាក្យថា ដែលព្រះពុទ្ធសំដែងហើយយ៉ាងណា សេចក្តីថា ដែលព្រះពុទ្ធប្រាប់ សំដែង តែងតាំង តាំងផ្តើម បើកវែកញែក ធ្វើឲ្យរាក់ ប្រកាសហើយយ៉ាងណា ហេតុនោះ ( លោកពោលថា ) ដែលព្រះពុទ្ធសំដែងហើយ យ៉ាងណា ។

[ ១៣១ ] ពាក្យថា បើបុគ្គលណា ប្រតិបត្តិតាមយ៉ាងនោះ គឺបើបុគ្គលប្រតិបត្តិសម្មាបដិបទា អនុលោមប្បដិបទា អបច្ចនីកប្បដិបទា អន្វត្ថប្បដិបទា

ធម្មានុធម្មប្បដិបទា ហេតុនោះ ( លោកពោលថា ) បើបុគ្គលណា ប្រតិបត្តិតាមយ៉ាងនោះ ។

[ ១៣២ ] ពាក្យថា បុគ្គលនោះ នឹងចេញអំពីទីមិនមែនត្រើយ ទៅកាន់ត្រើយ សេចក្ដីថា អមតនិព្វានលោកហៅថា ត្រើយ បានដល់ សេចក្ដីរម្ងាប់សង្ខារទាំងពួង ការរលាស់ចោលឧបធិទាំងពួង ការអស់តណ្ហា ការប្រាសចាកតម្រេក សេចក្ដីរលត់ និព្វាន ។ កិលេសទាំងឡាយ ខន្ធទាំងឡាយ និងអភិសង្ខារទាំងឡាយ លោកហៅថា ទីមិនមែនត្រើយ ។ ពាក្យថា បុគ្គលនោះ នឹងចេញអំពីទីមិនមែនត្រើយ ទៅកាន់ត្រើយ គឺបុគ្គលនោះ នឹងចេញអំពីទីមិនមែនត្រើយ ទៅកាន់ត្រើយ បានត្រើយ ពាល់ត្រូវត្រើយ ធ្វើឲ្យជាក់ច្បាស់ត្រើយ ហេតុនោះ ( លោកពោលថា ) បុគ្គលនោះ នឹងចេញអំពីទីមិនមែនត្រើយ ទៅកាន់ត្រើយ ។ ហេតុនោះ លោកពោលពាក្យនេះថា

> សេចក្ដីនៃប្រស្នាមួយៗ ដែលព្រះពុទ្ធសម្ដែងហើយយ៉ាងណា បើបុគ្គលណា ប្រតិបត្តិតាមយ៉ាងនោះ បុគ្គលនោះ នឹងចេញអំពីទីមិនមែនត្រើយ ទៅកាន់ត្រើយបាន ។
>
> [ ១៣៣ ] បុគ្គលកាលចម្រើនមគ្គដ៏ឧត្ដម នឹងចេញអំពីទីមិនមែនត្រើយ ទៅកាន់ត្រើយបាន មគ្គនោះ តែងប្រព្រឹត្តទៅ ដើម្បីទៅកាន់ត្រើយ ហេតុនោះ មគ្គ ( លោកពោលថា ) បារាយនៈដោយប្រការដូច្នេះ ។

[ ១៣៤ ] ពាក្យថា នឹងចេញអំពីទីមិនមែនត្រើយ ទៅកាន់ត្រើយ

សេចក្តីថា កិលេសទាំងឡាយ ខន្ធទាំងឡាយ និងអភិសង្ខារទាំងឡាយ លោកហៅថា ទីមិនមែនត្រើយ ។ អមតនិព្វាន លោកហៅថា ត្រើយ បានដល់សេចក្តីរម្ងាប់សង្ខារទាំងពួង ការរលាស់ចោលឧបធិទាំងពួង ការអស់តណ្ហា សេចក្តីប្រាសចាកតម្រេក សេចក្តីរលត់ និព្វាន ។ ពាក្យថា នឹងចេញអំពីទីមិនមែនត្រើយ ទៅកាន់ត្រើយ បានសេចក្តីថា នឹងចេញអំពីទីមិនមែនត្រើយ ទៅកាន់ត្រើយ បានត្រើយ ពាល់ត្រើយ ធ្វើឲ្យជាក់ច្បាស់នូវត្រើយ ហេតុនោះ ( លោកពោលថា ) នឹងចេញអំពីទីមិនមែនត្រើយ ទៅកាន់ត្រើយ ។

[ ១៣៥ ] ពាក្យថា មគ្គ ក្នុងបទថា កាលចម្រើនមគ្គដ៏ឧត្តម សេចក្តីថា មគ្គប្រកបដោយអង្គ ៨ ដ៏ប្រសើរ គឺប្រាជ្ញាយល់ឃើញត្រូវ ។បេ។ ការតម្កល់ចិត្តឲ្យនឹងត្រូវ លោកហៅថា មគ្គ ។ ពាក្យថា ដ៏ឧត្តម គឺដ៏លើស ដ៏ប្រសើរ ដ៏ប្រសើរវិសេស ជាប្រធាន ឧត្តម ថ្លៃថ្លា ហេតុនោះ ( លោកពោលថា ) មគ្គដ៏ឧត្តម ។ ពាក្យថា កាលចម្រើន គឺកាលចម្រើន កាលសេព កាលធ្វើឲ្យច្រើន ហេតុនោះ ( លោកពោលថា ) កាលចម្រើនមគ្គដ៏ឧត្តម ។

[ ១៣៦ ] ពាក្យថា មគ្គនោះ តែងប្រព្រឹត្តទៅ ដើម្បីទៅកាន់ត្រើយ សេចក្តីថា ឈ្មោះថា មគ្គ បានដល់ តម្រាយ គន្លង ប្រទេសសម្រាប់ទៅដោយជើង ទីសម្រាប់ដើរ ទីសម្រាប់ដើរទៅដើរមក ទូក ស្ពានសម្រាប់ឆ្លងផែ ពោងពាយ ។ ពាក្យថា ដើម្បីទៅកាន់ត្រើយ គឺដើម្បីទៅកាន់ត្រើយ ដើម្បីដល់ព្រមនូវត្រើយ ដើម្បីដល់ចាប់នូវត្រើយ គឺថា ដើម្បីឆ្លងជរា និងមរណៈ ហេតុនោះ ( លោកពោលថា ) មគ្គនោះ តែងប្រព្រឹត្តទៅ ដើម្បី

ទៅកាន់ត្រើយ ។

[ ១៣៧ ] ពាក្យថា ហេតុនោះ ក្នុងបទថា ហេតុនោះ ( លោកពោលថា ) បារាយនៈដោយប្រការដូច្នេះ គឺព្រោះហេតុនោះ ព្រោះដំណើរនោះ ព្រោះដូច្នោះ ព្រោះហេតុនោះ ព្រោះបច្ច័យនោះ ព្រោះនិទាននោះ ។ អមតនិព្វាន លោកហៅថា ត្រើយ បានដល់ សេចក្តីរម្ងាប់សង្ខារទាំងពួង ការរលាស់ចោលឧបធិទាំងពួង ការអស់តណ្ហា សេចក្តីប្រាសចាកតម្រេក សេចក្តីរលត់ និព្វាន ។ មគ្គ លោកហៅថា អាយនៈ ។ ពាក្យថា ដោយប្រការដូច្នេះ គឺជាការតបទ ។បេ។ ពាក្យថា ដូច្នេះ នុ៎ះជាលំដាប់បទ ហេតុនោះ ( លោកពោលថា ) បារាយនៈ ដោយប្រការដូច្នេះ ។ ហេតុនោះ លោកពោលពាក្យនេះថា

បុគ្គលកាលចម្រើនមគ្គដ៏ឧត្តម នឹងចេញអំពីទីមិនមែនត្រើយ ទៅកាន់ត្រើយបាន មគ្គនោះតែងប្រព្រឹត្តទៅ ដើម្បីទៅកាន់ត្រើយ ហេតុនោះ មគ្គ ( លោកពោលថា ) បារាយនៈ ដោយប្រការដូច្នេះ ។

[ ១៣៨ ] ( បិង្គិយៈមានអាយុ ពោលដូច្នោះថា ) ខ្ញុំនឹងច្រៀងតាមបារាយនៈ ព្រះមានព្រះភាគ ព្រះអង្គមានមន្ទិល គឺកិលេសទៅប្រាសហើយ មានប្រាជ្ញាដូចផែនដី មានកាមចេញហើយ មានព្រៃចេញហើយ ជាព្រះពុទ្ធនាគ ( ទ្រង់ឃើញហើយយ៉ាងណា ទ្រង់ពោលយ៉ាងនោះ ) ទ្រង់នឹងពោលមុសា ព្រោះហេតុដូចម្តេចកើត ។

[ ១៣៩ ] ពាក្យថា ខ្ញុំនឹងប្រៀងតាមបារាយនៈ គឺខ្ញុំនឹងប្រៀងតាមចម្រៀង នឹងប្រៀងតាមភាសិត ដែលព្រះមានព្រះភាគសម្តែងហើយ នឹងប្រៀងតាមភាសិត ដែលព្រះមានព្រះភាគពោលហើយ នឹងប្រៀងតាមភាសិត ( របស់ព្រះមានព្រះភាគ ) ហេតុនោះ ( លោកពោលថា ) ខ្ញុំនឹងប្រៀងតាមបារាយនៈ ។ ពាក្យថា ដូច្នេះ ក្នុងបទថា បិង្គិយៈមានអាយុពោលដូច្នេះ គឺជាការតបទ ។បេ។ ពាក្យថា ដូច្នេះ នុ៎ះជាលំដាប់បទ ។ ពាក្យថា មានអាយុ គឺពាក្យជាទីស្រឡាញ់ ជាពាក្យពោលដោយគោរព ពាក្យថា មានអាយុ នុ៎ះជាពាក្យពោលដោយការគោរពកោតក្រែង ។ ពាក្យថា បិង្គិយៈ គឺជាឈ្មោះ ជាពាក្យសម្រាប់រាប់ ជាគ្រឿងសម្គាល់ ជាបញ្ញត្តិ ជាវោហារ ជានាម ជានាមកម្ម ជានាមប្បញ្ញត្តិ ជាសម្តី ជាគ្រឿងបញ្ជាក់ ជាគ្រឿងប្រកាសនៃព្រះថេរៈនោះ ហេតុនោះ ( លោកពោលថា ) បិង្គិយៈមានអាយុពោល ដូច្នេះ ។

[ ១៤០ ] ពាក្យថា ទ្រង់ឃើញយ៉ាងណា ទ្រង់ពោលយ៉ាងនោះ គឺទ្រង់ឃើញយ៉ាងណា ទ្រង់ពោល ប្រាប់ សម្តែង តែងតាំង តាំងផ្តើម បើក វែកញែក ធ្វើឲ្យរាក់ ប្រកាសយ៉ាងនោះថា សង្ខារទាំងពួងមិនទៀង ។បេ។ ធម្មជាតឯណានីមួយ មានកិរិយាកើតឡើងជាធម្មតា ជាធម្មជាតទាំងអស់នោះ មានកិរិយារលត់ទៅវិញជាធម្មតា ទ្រង់ឃើញយ៉ាងណា ទ្រង់ពោល ប្រាប់ សម្តែង តែងតាំង តាំងផ្តើម បើក វែកញែក ធ្វើឲ្យរាក់ ប្រកាសហើយយ៉ាងនោះ ហេតុនោះ ( លោកពោលថា ) ទ្រង់ឃើញយ៉ាងណា ទ្រង់ពោលយ៉ាងនោះ ។

[ ១៤១ ] អធិប្បាយពាក្យថា មានមន្ទិលទៅប្រាសហើយ មានប្រាជ្ញាដូចផែនដី ត្រង់ពាក្យថា មានមន្ទិលទៅប្រាសហើយ សេចក្ដីថា រាគៈ ឈ្មោះថា មន្ទិល ទោសៈ ឈ្មោះថា មន្ទិល មោហៈ ឈ្មោះថា មន្ទិល ក្រោធឈ្មោះថា មន្ទិល ការចងក្រោធទុក ឈ្មោះថា មន្ទិល ។បេ។ អភិសង្ខារជាអកុសលទាំងពួង ឈ្មោះថា មន្ទិល ។ មន្ទិលទាំងនោះ ព្រះពុទ្ធមានព្រះភាគទ្រង់លះបង់ កាត់ផ្ដាច់ឫសចេញហើយ ធ្វើឲ្យនៅសល់តែទីនៅ ដូចជាទីនៅនៃដើមត្នោត ឲ្យដល់នូវការមិនកើតមាន មានកិរិយាមិនកើតតទៅជាធម្មតា ហេតុនោះ ព្រះពុទ្ធ ឈ្មោះថា មិនមានមន្ទិល មានមន្ទិលទៅប្រាសហើយ ដ៏ស្អាតចាកមន្ទិល ប្រាសចាកមន្ទិល លះបង់មន្ទិល រួចស្រឡះចាកមន្ទិល ប្រព្រឹត្តកន្លងនូវមន្ទិលទាំងពួង ។ ប្រឹថពី លោកហៅថា ផែនដី ។ ព្រះមានព្រះភាគប្រកបព្រមហើយ ដោយប្រាជ្ញាដ៏ធំទូលាយ ស្មើដោយប្រឹថពីនេះ ។ ប្រាជ្ញាលោកហៅថា មេធា បានដល់ បញ្ញា ការដឹងច្បាស់ ។បេ។ ការមិនវង្វេងការពិចារណាធម៌ សេចក្ដីឃើញត្រូវ ។ ព្រះមានព្រះភាគ អែប អែបនែបកប ប្រកប ចូលទៅដល់ ចូលទៅដល់ព្រម ប្រកបព្រមដោយមេធា គឺប្រាជ្ញានេះ ហេតុនោះ ព្រះពុទ្ធ ឈ្មោះថា មានប្រាជ្ញាដូចផែនដី ហេតុនោះ ( លោកពោលថា ) មានមន្ទិលទៅប្រាសហើយ មានប្រាជ្ញាដូចផែនដី ។

[ ១៤២ ] អធិប្បាយពាក្យថា មានកាមចេញហើយ មានព្រៃចេញហើយ ជាព្រះពុទ្ធនាគ ត្រង់ពាក្យថា កាម បើពោលតាមឧទ្ទាន កាមមាន ២ គឺវត្ថុកាម ១ កិលេសកាម ១ ។បេ។ ទាំងនេះ លោកហៅថា វត្ថុកាម ។បេ។

ទាំងនេះ លោកហៅថា កិលេសកាម ។ វត្ថុកាម ព្រះពុទ្ធមានព្រះភាគ កំណត់ដឹងហើយ កិលេសកាម ទ្រង់លះបង់ហើយ ។ ព្រោះទ្រង់កំណត់ដឹងវត្ថុកាម ព្រោះទ្រង់លះកិលេសកាម ព្រះមានព្រះភាគ ឈ្មោះថា មិនប្រាថ្នាកាមទាំងឡាយ មិនចង់បានកាមទាំងឡាយ មិនស្រឡាញ់កាមទាំងឡាយ មិនជាប់ព្រះហឫទ័យនឹងកាមទាំងឡាយ ។ ជនទាំងឡាយណា នៅប្រាថ្នាកាមទាំងឡាយ ចង់បានកាមទាំងឡាយ ស្រឡាញ់កាមទាំងឡាយ ជាប់ចិត្តនឹងកាមទាំងឡាយ ជនទាំងឡាយនោះ ឈ្មោះថា មានសេចក្តីប្រាថ្នាកាម មានសេចក្តីរីករាយដោយរាគៈ មានសេចក្តីសម្គាល់ដោយកាមសញ្ញា ។ ព្រះមានព្រះភាគ មិនប្រាថ្នាកាមទាំងឡាយ មិនចង់បានកាមទាំងឡាយ មិនស្រឡាញ់កាមទាំងឡាយ មិនជាប់ព្រះហឫទ័យនឹងកាមទាំងឡាយ ហេតុនោះ ព្រះពុទ្ធឈ្មោះថា មិនមានកាម មានកាមចេញហើយ ចោលកាម ខ្ជាក់កាម លែងកាម លះកាម រលាស់ចោលកាម ប្រាសចាករាគៈ មានរាគៈទៅបាត់ហើយ ចោលរាគៈ ខ្ជាក់រាគៈ លែងរាគៈ លះរាគៈ រលាស់ចោលរាគៈ ប្រាសចាកសេចក្តីប្រាថ្នា មានទុក្ខរលត់ហើយ មានសេចក្តីត្រជាក់កើតហើយ សោយសុខ មានខ្លួនដូចជាព្រហ្ម សម្រេចសម្រាន្តនៅ ហេតុនោះ ( លោកពោលថា ) មានកាមចេញហើយ ។ ពាក្យថា មានព្រៃចេញហើយ សេចក្តីថា រាគៈឈ្មោះថា ព្រៃ ទោសៈ ឈ្មោះថា ព្រៃ មោហៈ ឈ្មោះថា ព្រៃ ក្រោធឈ្មោះថា ព្រៃ ការចងក្រោធទុក ឈ្មោះថា ព្រៃ ។បេ។ អភិសង្ខារជាអកុសលទាំងពួង ឈ្មោះថា ព្រៃ ។ ព្រៃទាំងនោះ ព្រះពុទ្ធមានព្រះភាគលះបង់

ផ្តាច់ផ្តិលឫសគល់ ធ្វើឲ្យមានទីនៅដូចជាទីនៅនៃដើមត្នោត ឲ្យដល់នូវការមិនមានទីកើត មានកិរិយាមិនកើតតទៅជាធម្មតា ហេតុនោះ ព្រះពុទ្ធ ឈ្មោះថា មិនមានព្រៃ មានព្រៃចេញហើយ ប្រាសចាកព្រៃ លះបង់ព្រៃ រួចស្រឡះចាកព្រៃ ប្រព្រឹត្តកន្លងព្រៃទាំងអស់ ហេតុនោះ ( លោកពោលថា ) មានព្រៃចេញហើយ ។ ពាក្យថា ព្រះពុទ្ធនាគ គឺព្រះមានព្រះភាគ ឈ្មោះថា នាគ ព្រោះហេតុទ្រង់មិនធ្វើអំពើអាក្រក់ ។ ឈ្មោះថា នាគ ព្រោះហេតុទ្រង់មិនលុះ ។ ឈ្មោះថា នាគ ព្រោះហេតុទ្រង់មិនមក ។បេ។ ព្រះមានព្រះភាគ ឈ្មោះថា នាគ ព្រោះហេតុទ្រង់មិនមកយ៉ាងនេះ ហេតុនោះ ( លោកពោលថា ) មានកាមចេញហើយ មានព្រៃចេញហើយ ជាព្រះពុទ្ធនាគ ។

[ ១៤៣ ] អធិប្បាយពាក្យថា គប្បីពោលមុសា ព្រោះហេតុដូចម្តេចកើត ត្រង់ពាក្យថា ព្រោះហេតុដូចម្តេចកើត គឺព្រោះហេតុអ្វី ព្រោះការណ៍អ្វី ព្រោះបច្ច័យអ្វី ហេតុនោះ ( លោកពោលថា ) ព្រោះហេតុដូចម្តេចកើត ។ ពាក្យថា គប្បីពោលមុសា គឺគប្បីពោលពាក្យមុសា ពោលមុសាវាទ ពោលពាក្យមិនប្រសើរ ។ បុគ្គលពួកខ្លះក្នុងលោកនេះ ទៅក្នុងទីប្រជុំក្តី ទៅក្នុងបរិស័ទក្តី ទៅក្នុងកណ្តាលពួកញាតិក្តី ទៅក្នុងកណ្តាលរាជត្រកូលក្តី ដែលគេកោះទៅសួរជាសាក្សីថា ម្នាលបុរសដ៏ចម្រើន អ្នកចូរមក អ្នកដឹងហេតុណា ចូរពោលហេតុនោះ កាលមិនដឹង ពោលថា ខ្ញុំដឹងក្តី កាលដឹង ពោលថា ខ្ញុំមិនដឹងក្តី កាលមិនឃើញ ពោលថា ខ្ញុំឃើញក្តី កាលឃើញ ពោលថា ខ្ញុំមិនឃើញក្តី ពោលសម្បជានមុសាវាទព្រោះហេតុនៃខ្លួនក្តី ព្រោះហេតុនៃ

បុគ្គលដទៃក្តី ព្រោះហេតុតែសំណូកណាមួយក្តី នេះលោកហៅថា ពាក្យមុសា ។ មួយទៀត ការពោលមុសាដោយអាការ ៣ គឺមុនដំបូង មុសាវាទរបស់បុគ្គលនោះថា អញនឹងពោលមុសា ១ មុសាវាទរបស់បុគ្គលកំពុងពោលថា អញកំពុងពោលមុសា ១ មុសាវាទរបស់បុគ្គលពោលរួចហើយថា អញពោលមុសាហើយ ១ នេះការពោលមុសាដោយអាការ ៣ ។ មួយទៀត ការពោលមុសាដោយអាការ ៤ យ៉ាង គឺមុនដំបូង មុសាវាទរបស់បុគ្គលនោះថា អញនឹងពោលមុសា ១ ។បេ។ ការពោលមុសាដោយអាការ ៥ ដោយអាការ ៦ ដោយអាការ ៧ ដោយអាការ ៨ គឺមុនដំបូង មុសាវាទរបស់បុគ្គលនោះថា អញនឹងពោលមុសា ១ មុសាវាទរបស់បុគ្គលកំពុងពោលថា អញកំពុងពោលមុសា ១ មុសាវាទរបស់បុគ្គលពោលរួចហើយថា អញពោលមុសាហើយ ១ ពោលបិទបាំងទិដ្ឋិ ១ បិទបាំងខន្តិ ១ បិទបាំងសេចក្តីគាប់ចិត្ត ១ បិទបាំងសញ្ញា ១ បិទបាំងសេចក្តីពិត ១ នេះការពោលមុសាដោយអាការ ៨ ។ ព្រះអង្គគប្បីពោល និយាយ សម្តែង ថ្លែងនូវមុសាព្រោះហេតុម្តេចបាន ហេតុនោះ ( លោកពោលថា ) គប្បីពោលមុសាព្រោះហេតុដូចម្តេចកើត ។ ហេតុនោះ បិង្គិយត្ថេរពោលថា

( បិង្គិយៈមានអាយុ ពោលដូច្នោះថា ) ខ្ញុំនឹងច្រៀងតាមបារាយនៈ
ព្រះមានព្រះភាគ ព្រះអង្គមានមន្ទិល គឺកិលេសទៅប្រាសហើយ
មានប្រាជ្ញាដូចផែនដី មានកាមចេញហើយ មានព្រៃចេញហើយ
ជាព្រះពុទ្ធនាគ ( ទ្រង់ឃើញហើយយ៉ាងណា ទ្រង់ពោលយ៉ាង

នោះ ) ទ្រង់គប្បីពោលមុសា ព្រោះហេតុដូចម្តេចកើត ។

[ ១៤៤ ] បើដូច្នោះ ខ្ញុំនឹងសម្តែងពាក្យដ៏ប្រកបដោយគុណរបស់ព្រះមានព្រះភាគ ព្រះអង្គលះបង់មន្ទិល និងមោហៈហើយ លះបង់មានះ និងមក្ខៈហើយ ។

[ ១៤៥ ] អធិប្បាយពាក្យថា ព្រះអង្គលះបង់មន្ទិល និងមោហៈហើយ ត្រង់ពាក្យថា មន្ទិល បានដល់ រាគៈ ឈ្មោះថា មន្ទិល ទោសៈ ឈ្មោះថា មន្ទិល មោហៈ ឈ្មោះថា មន្ទិល មានះ ឈ្មោះថា មន្ទិល ទិដ្ឋិ ឈ្មោះថា មន្ទិល កិលេស ឈ្មោះថា មន្ទិល ទុច្ចរិតទាំងពួង ឈ្មោះថា មន្ទិល ។ ពាក្យថា មោហៈ គឺការមិនដឹងក្នុងកងទុក្ខ ។បេ។ បង្គោល គឺអវិជ្ជា សេចក្តីវង្វេង ឫសនៃអកុសល នេះលោកហៅថា មោហៈ ។ មន្ទិល និងមោហៈ ព្រះពុទ្ធមានព្រះភាគបានលះបង់ គាស់រម្លើងឫសគល់ ធ្វើឲ្យមានតែទីនៅដូចជាទីនៅនៃដើមត្នោត ឲ្យដល់នូវការមិនកើតមាន មិនឲ្យមានកិរិយាកើតតទៅជាធម្មតា ហេតុនោះ ព្រះពុទ្ធ ឈ្មោះថា មានមន្ទិល និងមោហៈលះបង់ហើយ ហេតុនោះ ( លោកពោលថា ) ព្រះអង្គលះបង់មន្ទិល និងមោហៈហើយ ។

[ ១៤៦ ] អធិប្បាយពាក្យថា លះបង់មានះ និងមក្ខៈហើយ ត្រង់ពាក្យថា មានះ សេចក្តីថា មានះដោយប្រការមួយ បានដល់ ការប៉ោងឡើងនៃចិត្ត ។ មានះដោយប្រការ ២ គឺមានះដោយការលើកតម្កើងខ្លួន ១ មានះដោយការបន្តុះបង្អាប់អ្នកដទៃ ១ ។ មានះដោយប្រការ ៣ គឺមានះថា អញ

ជាបុគ្គលប្រសើរ ១ មានះថា អញជាបុគ្គលស្មើ ១ មានះថា អញជាបុគ្គលថោកទាប ១ ។ មានះដោយប្រការ ៤ គឺបុគ្គលញុំាងមានះឲ្យកើតព្រោះលាភ ១ ញុំាងមានះឲ្យកើតព្រោះយស ១ ញុំាងមានះឲ្យកើតព្រោះសេចក្តីសរសើរ ១ ញុំាងមានះឲ្យកើតព្រោះសុខ ១ ។ មានះដោយប្រការ ៥ គឺបុគ្គលញុំាងមានះឲ្យកើតថា អញបានរូបជាទីគាប់ចិត្ត ១ ញុំាងមានះឲ្យកើតថា អញបានសំឡេង ១ ក្លិន ១ រស ១ ផ្សព្វជាទីគាប់ចិត្ត ១ ។ មានះដោយប្រការ ៦ គឺបុគ្គលញុំាងមានះឲ្យកើតព្រោះការបរិបូណ៌ដោយចក្ខុ ១ ញុំាងមានះឲ្យកើតព្រោះការបរិបូណ៌ដោយសោតៈ ១ ព្រោះការបរិបូណ៌ដោយឃានៈ ១ ព្រោះការបរិបូណ៌ដោយជិវ្ហា ១ ព្រោះការបរិបូណ៌ដោយកាយ ១ ព្រោះការបរិបូណ៌ដោយមនៈ ១ ។ មានះដោយប្រការ ៧ គឺការក្រអឺតក្រអោង ១ ការប្រកាន់គ្រាន់ ១ ការមើលងាយដោយសេចក្តីប្រកាន់ ១ ការប្រកាន់ទាប ១ ការប្រកាន់ថោក ១ ការប្រកាន់ថាអញមាន ១ ការប្រកាន់ខុស ១ ។ មានះដោយប្រការ ៨ គឺបុគ្គលញុំាងការក្រអឺតក្រអោងឲ្យកើតព្រោះលាភ ១ ញុំាងការប្រកាន់ទាបឲ្យកើតព្រោះការមិនមានលាភ ១ ញុំាងការក្រអឺតក្រអោងឲ្យកើតព្រោះយស ១ ញុំាងការប្រកាន់ទាបឲ្យកើតព្រោះការមិនមានយស ១ ញុំាងការក្រអឺតក្រអោងឲ្យកើតព្រោះសេចក្តីសរសើរ ១ ញុំាងការប្រកាន់ទាបឲ្យកើតព្រោះសេចក្តីតិះដៀល ១ ញុំាងការក្រអឺតក្រអោងឲ្យកើតព្រោះសុខ ១ ញុំាងការប្រកាន់ទាបឲ្យកើតព្រោះទុក្ខ ១ ។ មានះដោយប្រការ ៩ គឺបុគ្គលអ្នកខ្ពង់ខ្ពស់មានមានះថា អញខ្ពង់ខ្ពស់ជាងគេ ១ បុគ្គលអ្នកខ្ពង់ខ្ពស់

មានមានះថា អញស្មើ ១ បុគ្គលអ្នកខ្ពង់ខ្ពស់មានមានះថា អញថោកទាប ១ បុគ្គលអ្នកស្មើនឹងគេមានមានះថា អញខ្ពង់ខ្ពស់ ១ បុគ្គលអ្នកស្មើនឹងគេមានមានះថា អញស្មើ ១ បុគ្គលអ្នកស្មើនឹងគេមានមានះថា អញថោទាប ១ បុគ្គលអ្នកថោកទាបមានមានះថា អញខ្ពង់ខ្ពស់ ១ បុគ្គលអ្នកថោកទាបមានមានះថា អញស្មើ ១ បុគ្គលអ្នកថោកទាបមានមានះថា អញថោកទាប ១ ។ មានះដោយប្រការ ១០ គឺបុគ្គលខ្លះក្នុងលោកនេះ ញុំាងមានះឲ្យកើតព្រោះជាតិ ឬគោត្រ ឬការកើតជាកូនអ្នកមានត្រកូល ១ ព្រោះភាពជាអ្នកមានរូបល្អ ១ ព្រោះទ្រព្យ ១ ព្រោះការរៀន ១ ព្រោះការងារ ១ ព្រោះសិល្បៈ ១ ព្រោះទីតាំងនៃវិជ្ជា ១ ព្រោះការចេះដឹង ១ ព្រោះសេចក្តីឆ្លៀវឆ្លាស ១ ព្រោះវត្ថុណា ១ ការមើលងាយ អាការនៃការមើលងាយ ភាពនៃការមើលងាយ ការលើកកម្ពស់ ការប្រកាន់ខ្ពស់ ការផ្គងចិត្ត ភាពនៃចិត្តប្រាថ្នាដូចទង់ មានសភាពយ៉ាងនេះឯណា នេះលោកហៅថា មានះ ។ ពាក្យថា មក្ខៈ បានដល់ សេចក្តីលុបគុណ អាការលុបគុណ ភាពនៃសេចក្តីលុបគុណ អំពើនៃសេចក្តីប្រណៃន នេះលោកហៅ ថាមក្ខៈ ។ មានះ និងមក្ខៈ ព្រះពុទ្ធមានព្រះភាគបានលះបង់ គាស់រម្លើងឫសគល់ ធ្វើឲ្យមានតែទីនៅដូចជាទីនៅនៃដើមត្នោត ឲ្យដល់នូវការមិនមានទីកើត មិនឲ្យមានកិរិយាកើតតទៅជាធម្មតា ហេតុនោះ ព្រះពុទ្ធ ឈ្មោះថា លះបង់មានះ និងមក្ខៈ ហេតុនោះ ( លោកពោលថា ) លះបង់មានះ និងមក្ខៈហើយ ។

[ ១៤៧ ] អធិប្បាយពាក្យថា បើដូច្នោះ ខ្ញុំនឹងសម្តែងពាក្យប្រកប

ដោយគុណ ត្រង់ពាក្យថា បើដូច្នោះខ្ញុំ គឺការតបទ ។បេ។ ពាក្យថា បើដូច្នោះខ្ញុំ នុ៎ះជាលំដាប់បទ ។ ពាក្យថា សម្តែង គឺនឹងពោល បង្ហាញឲ្យដឹងច្បាស់ តាំងផ្តើម បើក វែកញែក ធ្វើឲ្យរាក់ ប្រកាសនូវពាក្យវាចា គន្លងពាក្យ និងសម្តីដែលកប កបព្រម ប្រកប ប្រកបព្រម ចូលដល់ ចូលដល់ព្រម មកដល់ព្រមដោយគុណ ហេតុនោះ ( លោកពោលថា ) បើដូច្នោះ ខ្ញុំនឹងសម្តែងពាក្យប្រកបដោយគុណ ។ ហេតុនោះ បិង្គិយត្ថេរពោលថា

បើដូច្នោះ ខ្ញុំនឹងសម្តែងពាក្យប្រកបដោយគុណ របស់ព្រះមានព្រះភាគ ទ្រង់លះបង់មន្ទិល និងមោហៈហើយ លះបង់មានះនិងមក្ខៈហើយ ។

[ ១៤៨ ] ព្រះពុទ្ធទ្រង់បន្ទោបង់ងងឹត មានសមន្តចក្ខុ ទ្រង់ដល់ទីបំផុតលោក ប្រព្រឹត្តកន្លងហើយនូវភពទាំងពួង មិនមានអាសវៈ ទ្រង់លះបង់ទុក្ខទាំងពួងហើយ មានព្រះនាមដ៏ទៀងទាត់ ខ្ញុំបានចូលទៅគាល់ព្រះមានព្រះភាគប្រសើររួចហើយ ។

[ ១៤៩ ] អធិប្បាយពាក្យថា ព្រះពុទ្ធទ្រង់បន្ទោបង់ងងឹត មានសមន្តចក្ខុ ត្រង់ពាក្យថា បន្ទោបង់ងងឹត គឺព្រះមានព្រះភាគបានបន្ទោបង់ កម្ចាត់បង់ លះបង់ បន្សាត់បង់ ធ្វើឲ្យវិនាស ឲ្យដល់នូវការមិនកើត មាននូវងងឹត គឺរាគៈ ងងឹត គឺទោសៈ ងងឹត គឺមោហៈ ងងឹត គឺមានះ ងងឹត គឺទិដ្ឋិ ងងឹត គឺកិលេស ងងឹត គឺទុច្ចរិត ធម្មជាតធ្វើឲ្យងងឹត ធ្វើមិនឲ្យមានចក្ខុ ធ្វើមិនឲ្យមានញាណ រម្ងត់ប្រាជ្ញា ប្រព្រឹត្តទៅក្នុងពួកនៃសេចក្តីចង្អៀតចង្អល់ មិន

ប្រព្រឹត្តទៅដើម្បីនិព្វាន ហេតុនោះ ( លោកពោលថា ) បន្ទោបង់ងងឹត ។ ពាក្យថា ព្រះពុទ្ធ បានដល់ ព្រះមានព្រះភាគ ។បេ។ បញ្ញត្តថា ព្រះពុទ្ធនេះ ( កើត ) ព្រោះការត្រាស់ដឹង ។ ពាក្យថា សមន្តចក្ខុ សេចក្ដីថា សព្វញ្ញុតញ្ញាណ លោកហៅថា សមន្តចក្ខុ ។បេ។ ព្រះតថាគតព្រះនាមថា សមន្តចក្ខុដោយហេតុនោះ ហេតុនោះ ( លោកពោលថា ) ព្រះពុទ្ធទ្រង់បន្ទោបង់ងងឹត មានសមន្តចក្ខុ ។

[ ១៥០ ] អធិប្បាយពាក្យថា ទ្រង់ដល់ទីបំផុតលោក ប្រព្រឹត្តកន្លងហើយនូវភពទាំងពួង ត្រង់ពាក្យថា លោក គឺលោក ១ បានដល់ ភវលោក ។ លោក ២ បានដល់ សម្បត្តិភវលោក ១ វិបត្តិភវលោក ១ ។ លោក ៣ បានដល់ វេទនា ៣ ។ លោក ៤ បានដល់ អាហារ ៤ ។ លោក ៥ បានដល់ ឧបាទានក្ខន្ធ ៥ ។ លោក ៦ បានដល់ អាយតនៈខាងក្នុង ៦ ។ លោក ៧ បានដល់ វិញ្ញាណដ្ឋិតិ ៧ ។ លោក ៨ បានដល់ លោកធម៌ ៨ ។ លោក ៩ បានដល់ សត្តាវាសៈ ៩ ។ លោក ១០ បានដល់ ឧបក្កិលេស ១០ ។ លោក ១១ បានដល់ កាមភព ១១ ។ លោក ១២ បានដល់ អាយតនៈ ១២ ។ លោក ១៨ បានដល់ ធាតុ ១៨ ។ ពាក្យថា ទ្រង់ដល់ទីបំផុតលោក បានសេចក្ដីថា ព្រះមានព្រះភាគទៅកាន់ទីបំផុត ដល់ទីបំផុត ទៅកាន់ទីខាងចុង ដល់ទីខាងចុងនៃលោក ។បេ។ ទៅនិព្វាន ដល់និព្វាន ព្រះមានព្រះភាគនោះ មានការនៅរួចហើយ មានចរណៈសន្សំហើយ ។បេ។ ភពថ្មី គឺការអន្ទោលទៅកាន់ជាតិ ជរា និងមរណៈរបស់ព្រះអង្គមិនមានឡើយ

ហេតុនោះ ( លោកពោលថា ) ទ្រង់ដល់ទីបំផុតលោក ។ ពាក្យថា ភព ក្នុងបទថា ប្រព្រឹត្តកន្លងហើយនូវភពទាំងពួង បានដល់ ភព ២ គឺកម្មភព ១ បដិសន្ធិកបុនព្ភព ១ ។ កម្មភព តើដូចម្តេច ។ បុញ្ញាភិសង្ខារ អបុញ្ញាភិសង្ខារ អានេញ្ជាភិសង្ខារ នេះ ឈ្មោះថា កម្មភព ។ បដិសន្ធិកបុនព្ភព តើដូចម្តេច ។ រូប វេទនា សញ្ញា សង្ខារ វិញ្ញាណ ដែលប្រកបដោយបដិសន្ធិ នេះ ឈ្មោះថា បដិសន្ធិកបុនព្ភព ។ ព្រះមានព្រះភាគបានកន្លងឈានកន្លង ប្រព្រឹត្តកន្លង នូវកម្មភព និងបដិសន្ធិកបុនព្ភព ហេតុនោះ ( លោកពោលថា ) ទ្រង់ដល់ទីបំផុតលោក ប្រព្រឹត្តកន្លងហើយនូវភពទាំងពួង ។

[ ១៥១ ] អធិប្បាយពាក្យថា មិនមានអាសវៈ ទ្រង់លះបង់ទុក្ខទាំងពួងហើយ ត្រង់ពាក្យថា មិនមានអាសវៈ សេចក្តីថា អាសវៈ ៤ គឺកាមាសវៈ ១ ភវាសវៈ ១ ទិដ្ឋាសវៈ ១ អវិជ្ជាសវៈ ១ ។ អាសវៈទាំងនោះ ព្រះពុទ្ធមានព្រះភាគបានលះបង់ គាស់រំលើងឫសគល់ ធ្វើឲ្យមានតែទីទៅ ដូចជាទីនៅនៃដើមត្នោត ឲ្យដល់នូវការមិនកើតមាន មិនឲ្យមានកិរិយាកើតតទៅជាធម្មតា ហេតុនោះ ព្រះពុទ្ធ ឈ្មោះថា មិនមានអាសវៈ ។ ពាក្យថា ទ្រង់លះបង់ទុក្ខទាំងពួងហើយ សេចក្តីថា ជាតិទុក្ខ ជរាទុក្ខ ព្យាធិទុក្ខ មរណទុក្ខ សោកទុក្ខ បរិទេវទុក្ខ ទោមនស្សុបាយាសទុក្ខ ។បេ។ ទិដ្ឋិព្យសនទុក្ខទាំងពួង ដែលប្រកបដោយបដិសន្ធិ ព្រះពុទ្ធនោះ បានលះបង់ កាត់ផ្តាច់ រម្ងាប់បង់ ធ្វើមិនឲ្យកើតវិញ បានដុតដោយភ្លើង គឺញាណហើយ ហេតុនោះ ព្រះពុទ្ធ

ឈ្មោះថា មានទុក្ខទាំងពួងលះបង់ហើយ ។

[ ១៥២ ] ពាក្យថា មានព្រះនាមដ៏ទៀងទាត់ ក្នុងបទថា មានព្រះនាមដ៏ទៀងទាត់ ខ្ញុំបានចូលទៅគាល់ព្រះមានព្រះភាគប្រសើររួចហើយ សេចក្ដីថា ព្រះពុទ្ធមានព្រះនាមដ៏ទៀងទាត់ដូចគ្នា ។ គឺព្រះវិបស្សី ព្រះនាមថា ភគវា ព្រះសិខី ព្រះនាមថា ភគវា ព្រះវេស្សភូ ព្រះនាមថា ភគវា ព្រះកកុសន្ធៈ ព្រះនាមថា ភគវា ព្រះកោនាគមនៈ ព្រះនាមថា ភគវា ព្រះកស្សបៈ ព្រះនាមថា ភគវា ព្រះពុទ្ធដ៏មានព្រះភាគទាំងឡាយ សឹងមានព្រះនាមដូចគ្នា មានព្រះនាមដ៏ទៀងទាត់ស្មើគ្នា ។ ព្រះសក្យមុនីមានព្រះភាគ មានព្រះនាមដូចគ្នា មានព្រះនាមដ៏ទៀងទាត់ ស្មើនឹងព្រះពុទ្ធមានព្រះភាគទាំងឡាយនោះ ព្រោះហេតុនោះ ព្រះពុទ្ធ ឈ្មោះថា មានព្រះនាមដ៏ទៀងទាត់ ។ ពាក្យថា ខ្ញុំបានចូលទៅគាល់ព្រះមានព្រះភាគប្រសើររួចហើយ គឺព្រះមានព្រះភាគនោះ ខ្ញុំបានចូលទៅ ចូលទៅជិត ចូលទៅអង្គុយជិត សាកសួរ ចោទសួរហើយ ហេតុនោះ ( លោកពោលថា ) ព្រះមានព្រះភាគមានព្រះនាមដ៏ទៀងទាត់ ខ្ញុំបានចូលទៅគាល់ ព្រះមានព្រះភាគប្រសើររួចហើយ ។ ហេតុនោះ បិង្គិយត្ថេរពោលថា

ព្រះពុទ្ធទ្រង់បន្ទោបង់ងងឹត មានសមន្តចក្ខុ ទ្រង់ដល់ទីបំផុតលោក
ប្រព្រឹត្តកន្លងហើយនូវភពទាំងពួង មិនមានអាសវៈ ទ្រង់លះបង់
ទុក្ខទាំងពួងហើយ មានព្រះនាមដ៏ទៀងទាត់ ខ្ញុំបានចូលទៅគាល់
ព្រះមានព្រះភាគប្រសើររួចហើយ ។

[ ១៥៣ ] ( ព្រះបរិន្និយត្ថេរពោលថា ) ទិជសត្វលះបង់ព្រៃតូច ( មានផ្លែតិច ) មកនៅអាស្រ័យនឹងព្រៃធំ មានផ្លែច្រើន ដូចម្តេចមិញ ខ្ញុំលះបង់បុគ្គលទាំងឡាយដែលមានការឃើញតិច ( មកជួបប្រសព្វនឹងព្រះពុទ្ធ ទ្រង់មានប្រាជ្ញាច្រើន ) ដូចហង្សជួបប្រសព្វនូវស្រះដែលមានទឹកច្រើន ដូច្នោះឯង ។

[ ១៥៤ ] ពាក្យថា ទិជសត្វលះបង់ព្រៃតូច មកនៅអាស្រ័យនឹងព្រៃធំដែលមានផ្លែច្រើន ដូចម្តេចមិញ អធិប្បាយថា សត្វស្លាប លោកហៅថា ទិជសត្វ ។ ហេតុអ្វី សត្វស្លាប លោកហៅថា ទិជសត្វ ។ ទិជសត្វតែងកើត ២ លើក គឺកើតអំពីផ្ទៃមេ ១ លើក អំពីស្រោមស៊ុត ១ លើក ហេតុនោះ សត្វស្លាបទើបលោកហៅថា ទិជសត្វ ហេតុនោះ ( លោកពោលថា ) ទិជសត្វ ។ ពាក្យថា លះបង់ព្រៃតូច ដូចម្តេចមិញ គឺទិជសត្វលះបង់ បោះបង់ កន្លង កន្លងបង់នូវព្រៃតូច ព្រៃស្តើង ដែលមានចំណីតិច មានទឹកតិច ហើយបានជួបប្រសព្វ បានចំពោះនូវព្រៃធំដទៃដែលមានផ្លែច្រើន មានចំណីច្រើន មានឈើច្រើន គឺថា គប្បីសម្រេចការនៅក្នុងដងព្រៃនោះ ដូចម្តេចមិញ ហេតុនោះ ( លោកពោលថា ) ទិជសត្វលះបង់ព្រៃតូច មកនៅអាស្រ័យនឹងព្រៃធំដែលមានផ្លែច្រើន ដូចម្តេចមិញ ។

[ ១៥៥ ] អធិប្បាយពាក្យថា ខ្ញុំលះបង់បុគ្គលទាំងឡាយដែលមានការឃើញតិច ( មកជួបប្រសព្វព្រះពុទ្ធ ទ្រង់មានប្រាជ្ញាច្រើន ) ដូចហង្សជួបប្រសព្វនូវស្រះដែលមានទឹកច្រើន ដូច្នោះឯង ត្រង់ពាក្យថា ដូច្នោះឯង គឺជា

ពាក្យញុំាងសេចក្ដីឧបមាឲ្យសម្រេច ។ ពាក្យថា លះបង់បុគ្គលទាំងឡាយដែលមានការឃើញតិច សេចក្ដីថា ពាវរីព្រាហ្មណ៍ណា និងពួកជនដទៃណាជាអាចារ្យរបស់ពាវរីព្រាហ្មណ៍នោះ បើប្រៀបផ្ទឹមនឹងព្រះពុទ្ធមានព្រះភាគ ទៅជាអ្នកមានការឃើញតិច មានការឃើញស្ដួចស្ដើង មានការឃើញថោកថយ មានការឃើញឱនថយ មានការឃើញលាមក មានការឃើញអាក្រក់ ។ ខ្ញុំលះបង់ បោះបង់ កន្លង កន្លងបង់នូវព្រាហ្មណ៍ទាំងនោះ ដែលមានការឃើញតិច មានការឃើញស្ដួចស្ដើង មានការឃើញថោកថយ មានការឃើញឱនថយ មានការឃើញលាមក មានការឃើញអាក្រក់ មកជួប ប្រសព្វ បានចំពោះនូវព្រះពុទ្ធមានព្រះភាគ ទ្រង់ឃើញដ៏លើស ទ្រង់ឃើញដ៏ប្រសើរ ទ្រង់ឃើញវិសេស ទ្រង់ឃើញឧត្ដម ព្រះអង្គជាបុគ្គលប្រសើរ រកបុគ្គលស្មើមិនមាន ព្រះអង្គស្មើដោយព្រះពុទ្ធដែលមិនមានបុគ្គលស្មើ គ្មានចំណែកប្រៀបមិន មានបុគ្គលប្រៀប ទ្រង់ជាទេវតាវិសេសជាងទេវតា ទ្រង់ជានរាសភៈ ជាបុរិសសីហៈ ជាបុរិសនាគ ជាបុរសអាជានេយ្យ ជាបុរិសនិសភៈ ជាអ្នកនាំទៅនូវធុរៈរបស់បុរស ជាទសពល ជាតាទិបុគ្គល ។ ដូចហង្សគប្បីជួបប្រសព្វបានចំពោះនូវស្រះធំ ដែលមនុស្សរកសាងក្ដី អនោតត្តស្រះក្ដី មហាសមុទ្រក្ដីដែលមិនកម្រើក មានទឹករាប់មិនអស់ យ៉ាងណា ខ្ញុំឈ្មោះបិង្គិយព្រាហ្មណ៍បានជួបប្រសព្វ បានចំពោះនូវព្រះពុទ្ធមានព្រះភាគ ព្រះអង្គមិនកម្រើក មានតេជះរាប់មិនបាន មានញាណបែកធ្លាយ មានចក្ខុបើកហើយ ព្រះអង្គឆ្លៀវឆ្លាសក្នុងប្រភេទនៃប្រាជ្ញា ព្រះអង្គបានបដិសម្ភិទា បានចតុវេសារជ្ជញាណ

ទ្រង់មានព្រះហឫទ័យចុះស៊ប់ ក្នុងផលសមាបត្តិដ៏បរិសុទ្ធ ទ្រង់មានអត្តភាពមិនផ្សេងគ្នា ទ្រង់មិនពោលពីរព្រះឱស្ឋ ទ្រង់មិនញាប់ញ័រ ទ្រង់មានការឃ្លាតទៀង ទ្រង់មិនតូច ទ្រង់ធំ ទ្រង់មានប្រាជ្ញាជ្រៅ ទ្រង់មានប្រាជ្ញាប្រមាណមិនបាន ទ្រង់មានប្រាជ្ញាមិនអាចអ្នកណាស្ទង់បាន ទ្រង់មានរតនៈច្រើន ទ្រង់ស្មើដោយសាគរ ទ្រង់ប្រកបដោយឧបេក្ខា ៦ ទ្រង់មានព្រះគុណធំទូលាយថ្លឹងមិនបាន ប្រមាណមិនត្រូវ ព្រះមានព្រះភាគនោះ ទ្រង់ប្រកបដោយតាទិគុណ ទ្រង់ជាអ្នកពោលដ៏ប្រសើរ ជាងជនអ្នកពោលទាំងឡាយ ដូចភ្នំសិនេរុ ប្រសើរជាងភ្នំទាំងឡាយ ឬដូចគ្រុឌ ប្រសើរជាងទិជសត្វទាំងឡាយ ឬក៏ដូចសីហៈប្រសើរជាងពួកម្រឹគ ពុំនោះសោត ដូចសមុទ្រប្រសើរជាងអន្លង់ទឹកទាំងឡាយ ព្រះអង្គជាព្រះជិនស្រីដ៏ប្រសើរក៏យ៉ាងនោះដែរ ហេតុនោះ ( លោកពោលថា ) ខ្ញុំលះបង់បុគ្គលទាំងឡាយ ដែលមានការឃើញតិច ( មកជួបប្រសព្វព្រះពុទ្ធ ទ្រង់មានប្រាជ្ញាច្រើន ) ដូចហង្សដែលជួបប្រសព្វនូវស្រះមានទឹកច្រើន ដូច្នោះឯង ។ ហេតុនោះ ព្រះបិង្គិយត្ថេរពោលថា

ទិជសត្វលះបង់ព្រៃតូច ( មានផ្លែតិច ) មកនៅអាស្រ័យនឹងព្រៃធំ មានផ្លែច្រើន ដូចម្តេចមិញ ខ្ញុំលះបង់បុគ្គលទាំងឡាយដែលមានការឃើញតិច ( មកជួបប្រសព្វនឹងព្រះពុទ្ធ ទ្រង់មានប្រាជ្ញាច្រើន ) ដូចហង្សជួបប្រសព្វនូវស្រះមានទឹកច្រើន ដូច្នោះឯង ។

[ ១៥៦ ] ជនទាំងឡាយណា ក្នុងកាលមុន ( អំពីសាសនានៃ

ព្រះគោតម ) ជនទាំងឡាយនោះបានព្យាករហើយថា ហេតុមាន មកហើយដូច្នេះៗ នឹងមានតទៅដូច្នេះៗ ពាក្យទាំងអស់នោះ ( មិន ទាន់ប្រាកដទេ ) ជាពាក្យជឿស្តាប់បុគ្គលដទៃ ពាក្យទាំងអស់ នោះ ជាពាក្យធ្វើសេចក្តីត្រិះរិះឲ្យចម្រើន ( ខ្ញុំមិនពេញចិត្តនឹង ពាក្យនោះឡើយ ) ។

[ ១៥៧ ] ពាក្យថា ជនទាំងឡាយណា... ជនទាំងឡាយនោះបានព្យាករ ហើយ ត្រង់ពាក្យថា ជនទាំងឡាយណា គឺពាវរីព្រាហ្មណ៍ណា និងពួកជន ដទៃណា ជាអាចារ្យរបស់ពាវរីព្រាហ្មណ៍នោះ ព្រាហ្មណ៍ទាំងនោះបានព្យាករ ប្រាប់ សម្តែង បញ្ញត្ត តាំងទុក បើក វែកញែក ធ្វើឲ្យងាយ ប្រកាសនូវ ទិដ្ឋិរបស់ខ្លួន សេចក្តីគួររបស់ខ្លួន សេចក្តីគាប់ចិត្តរបស់ខ្លួន លទ្ធិរបស់ខ្លួន អធ្យាស្រ័យរបស់ខ្លួន សេចក្តីប៉ុនប៉ងរបស់ខ្លួន ហេតុនោះ ( លោកពោលថា ) ជនទាំងឡាយណា ... ជនទាំងឡាយនោះបានព្យាករហើយ ។

[ ១៥៨ ] ពាក្យថា ក្នុងកាលមុនអំពីសាសនានៃព្រះគោតម គឺក្នុងកាល មុនអំពីសាសនាព្រះគោតម ដទៃអំពីសាសនាព្រះគោតម ក្នុងកាលមុនដំបូង អំពីសាសនាព្រះគោតម ក្នុងកាលមុនបង្អស់អំពីសាសនាព្រះគោតម អំពី សាសនាព្រះពុទ្ធ អំពីសាសនាព្រះជិនស្រី អំពីសាសនាព្រះតថាគត អំពី សាសនាព្រះពុទ្ធជាទេវតា អំពីសាសនាអរហន្ត ហេតុនោះ ( លោកពោល ថា ) ក្នុងកាលមុនអំពីសាសនានៃព្រះគោតម ។

[ ១៥៩ ] ពាក្យថា ហេតុមានមកហើយដូច្នេះៗ នឹងមានតទៅដូច្នេះៗ

គឺឮថា ហេតុយ៉ាងនេះធ្លាប់មានមកហើយ ឮថា ហេតុយ៉ាងនេះនឹងមានតទៅខាងមុខ ហេតុនោះ ( លោកពោលថា ) ហេតុមានហើយដូច្នេះៗ នឹងមានតទៅដូច្នេះៗ ។

[ ១៦០ ] ពាក្យថា ពាក្យទាំងអស់នោះ ជាពាក្យជឿស្តាប់បុគ្គលដទៃ គឺពាក្យទាំងអស់នោះជាពាក្យជឿស្តាប់បុគ្គលដទៃដោយឮដូច្នេះៗ ដោយឮតៗគ្នា ដោយការផ្ទេរផ្ទាំនឹងក្បួន ដោយហេតុនៃការត្រិះរិះ ដោយហេតុនៃការគ្នេរគ្នាន់ ដោយការជញ្ជឹងគិតតាមអាការ ដោយការយល់ ការពិនិត្យ និងការគិតគូរ គឺថា ជនទាំងនោះសម្តែងធម៌ ដែលមិនបានត្រាស់ដឹងចំពោះខ្លួនឯង មិនជាក់ច្បាស់ចំពោះខ្លួនឯង ហេតុនោះ ( លោកពោលថា ) ពាក្យទាំងអស់នោះ ជាពាក្យជឿស្តាប់បុគ្គលដទៃ ។

[ ១៦១ ] ពាក្យថា ពាក្យទាំងអស់នោះ ជាពាក្យធ្វើសេចក្តីត្រិះរិះឲ្យចម្រើន គឺពាក្យទាំងអស់នោះ ជាពាក្យធ្វើសេចក្តីត្រិះរិះឲ្យចម្រើន ធ្វើសេចក្តីត្រិះរិះផ្សេងៗ ឲ្យចម្រើន ធ្វើតម្រិះឲ្យចម្រើន ធ្វើសេចក្តីត្រិះរិះក្នុងកាមឲ្យចម្រើន ធ្វើសេចក្តីត្រិះរិះក្នុងព្យាបាទ និងការបៀតបៀនឲ្យចម្រើន ធ្វើសេចក្តីត្រិះរិះក្នុងញាតិឲ្យចម្រើន ធ្វើសេចក្តីត្រិះរិះក្នុងជនបទឲ្យចម្រើន ធ្វើសេចក្តីត្រិះរិះក្នុងការមិនស្លាប់ឲ្យចម្រើន ធ្វើសេចក្តីត្រិះរិះ ដែលប្រកបដោយសេចក្តីអាណិតចំពោះបុគ្គលដទៃឲ្យចម្រើន ធ្វើសេចក្តីត្រិះរិះ ប្រកបដោយលាភសក្ការៈ និងសេចក្តីសរសើរឲ្យចម្រើន ធ្វើសេចក្តីត្រិះរិះប្រកបដោយការមិនចង់ឲ្យគេមើលងាយឲ្យចម្រើន ហេតុនោះ ( លោកពោលថា ) ពាក្យទាំងអស់នោះ ជាពាក្យ

ធ្វើសេចក្តីត្រិះរិះឲ្យចម្រើន ។ ហេតុនោះ ព្រះបិង្គិយត្ថេរពោលថា

ជនទាំងឡាយណា ក្នុងកាលមុន ( អំពីសាសនានៃព្រះគោតម ) ជនទាំងឡាយនោះ បានព្យាករហើយថា ហេតុមានមកហើយដូច្នេះៗ នឹងមានតទៅដូច្នេះៗ ពាក្យទាំងអស់នោះ ( មិនទាន់ប្រាកដទេ ) ជាពាក្យជឿស្តាប់បុគ្គលដទៃ ពាក្យទាំងអស់នោះ ជាពាក្យធ្វើសេចក្តីត្រិះរិះឲ្យចម្រើន ( ខ្ញុំមិនពេញចិត្តនឹងពាក្យនោះឡើយ ) ។

[ ១៦២ ] ព្រះគោតមនោះ តែមួយព្រះអង្គឯង ទ្រង់បន្ទោបង់ងងឹត គង់នៅជាសុខ ទ្រង់មានរស្មីរុងរឿង ទ្រង់ធ្វើពន្លឺ ( ដល់លោក ) ព្រះគោតមមានប្រាជ្ញា ជាគ្រឿងប្រាកដ ព្រះគោតមមានប្រាជ្ញាដូចផែនដី ។

[ ១៦៣ ] អធិប្បាយពាក្យថា តែមួយព្រះអង្គឯង ទ្រង់បន្ទោបង់ងងឹតគង់នៅជាសុខ ត្រង់ពាក្យថា តែមួយព្រះអង្គឯង គឺព្រះមានព្រះភាគតែមួយព្រះអង្គឯង ដោយចំណែកនៃបព្វជ្ជា តែមួយព្រះអង្គឯង ដោយសេចក្តីថា មិនមានបុគ្គលជាគម្រប់ពីរ តែមួយព្រះអង្គឯង ដោយសេចក្តីថា លះបង់តណ្ហា តែមួយព្រះអង្គឯង ព្រោះហេតុទ្រង់ប្រាសចាករាគៈ ដោយចំណែកមួយ តែមួយព្រះអង្គឯង ព្រោះហេតុទ្រង់ប្រាសចាកទោសៈ ដោយចំណែកមួយ តែមួយព្រះអង្គឯង ព្រោះហេតុទ្រង់ប្រាសចាកមោហៈ ដោយចំណែកមួយ តែមួយព្រះអង្គឯង ព្រោះហេតុទ្រង់មិនមានកិលេស ដោយចំណែកមួយ តែមួយព្រះអង្គឯង ព្រោះហេតុទ្រង់ស្តេចទៅកាន់ផ្លូវ ជាទីទៅនៃបុគ្គលមួយនាក់ តែមួយព្រះ

អង្គឯង ព្រោះហេតុត្រាស់ដឹង នូវសម្មាសម្ពោធិញ្ញាណដ៏ប្រសើរ តែមួយព្រះអង្គ ។

ព្រះមានព្រះភាគ តែមួយព្រះអង្គឯង ដោយចំណែកបព្វជ្ជា តើដូចម្តេច ។ ព្រះមានព្រះភាគ ទ្រង់នៅក្មេង មានព្រះកេសាខ្មៅស្រិល ប្រកបដោយវ័យដ៏ចម្រើន គឺបឋមវ័យ កាលព្រះមាតា និងព្រះបិតា មិនសព្វព្រះហឫទ័យ ( នឹងការចេញបព្វជ្ជា ) មានព្រះភក្ត្រជោកដោយទឹកព្រះនេត្រ ទ្រង់ព្រះកន្សែងពិលាប ទ្រង់ក៏លះបង់ពពួកញាតិ កាត់បលិពោធក្នុងឃរាវាសទាំងអស់ កាត់បលិពោធក្នុងបុត្ត និងព្រះជាយា កាត់បលិពោធក្នុងញាតិ កាត់បលិពោធក្នុងមិត្ត និងអាមាត្យ ទ្រង់ដាក់ព្រះកេសា និងព្រះមស្សុ ទ្រង់ប្រដាប់ព្រះពស្ត្រជ្រលក់ទឹកចត់ ស្តេចចេញចាកព្រះរាជដំណាក់ ចូលទៅកាន់ផ្នួស ដល់ស៊ប់នូវភាពជាអ្នកមិនមានកង្វល់ តែមួយព្រះអង្គឯង ទ្រង់ចរ ត្រាច់ទៅ ប្រព្រឹត្ត រក្សា យាត្រា ឲ្យយាត្រាទៅ ហេតុនោះ ព្រះមានព្រះភាគ តែមួយព្រះអង្គឯង ដោយចំណែកបព្វជ្ជា យ៉ាងនេះ ។

ព្រះមានព្រះភាគ តែមួយព្រះអង្គឯង ដោយសេចក្តីថា មិនមានបុគ្គលជាគម្រប់ពីរ តើដូចម្តេច ។ ព្រះអង្គទ្រង់ផ្នួសយ៉ាងនេះហើយ ទ្រង់សេពចំពោះព្រៃតូច និងព្រៃធំ ជាសេនាសនៈស្ងាត់ មិនមានសំឡេង មិនមានសូរគឹកកង ប្រាសចាកខ្យល់ ដែលកើតអំពីសរីរៈនៃជន ជាសេនាសនៈដ៏ស្ងប់ស្ងាត់ របស់មនុស្ស ដ៏សមគួរដល់ការពួនសម្ងំ ព្រះអង្គទ្រង់ពុទ្ធដំណើរ តែមួយអង្គឯង ទ្រង់ស្ថិតតែមួយអង្គឯង ទ្រង់គង់តែមួយអង្គឯង ទ្រង់សម្រេចការផ្ទំ តែមួយ

អង្គឯង ទ្រង់ចូលទៅបិណ្ឌបាតក្នុងស្រុក តែមួយអង្គឯង ទ្រង់ត្រឡប់មកវិញតែមួយអង្គឯង ទ្រង់គង់ក្នុងទីរហោស្ថាន តែមួយអង្គឯង ទ្រង់អធិដ្ឋានចង្ក្រមតែមួយអង្គឯង ទ្រង់ចរ ត្រាច់ទៅ ប្រព្រឹត្ត រក្សា យាត្រា ឲ្យយាត្រាទៅតែមួយអង្គឯង ហេតុនោះ ព្រះមានព្រះភាគ តែមួយព្រះអង្គឯង ដោយសេចក្តីថា មិនមានបុគ្គលជាគម្រប់ពីរយ៉ាងនេះ ។

ព្រះមានព្រះភាគ តែមួយព្រះអង្គឯង ដោយសេចក្តីថា លះបង់តណ្ហាតើដូចម្តេច ។ ព្រះអង្គតែមួយព្រះអង្គឯង មិនមានបុគ្គលជាគម្រប់ពីរ យ៉ាងនេះហើយ ទ្រង់មិនប្រហែស មានព្យាយាមជាគ្រឿងដុតកម្តៅកិលេស មានព្រះហឫទ័យបញ្ជូនទៅកាន់ព្រះនិព្វាន ទ្រង់តាំងសេចក្តីព្យាយាមធំ ទៀបគល់ពោធិព្រឹក្ស ក្បែរឆ្នេរស្ទឹងនេរញ្ជរា ទ្រង់កម្ចាត់បង់មារ ព្រមទាំងសេនា ដែលជាអ្នកមិនលះបង់អកុសលធម៌ ជាផៅពង្សនៃបុគ្គលប្រហែស ទ្រង់លះបង់បន្ទោបង់ ធ្វើឲ្យវិនាស ឲ្យដល់នូវការមិនកើតមាននូវតណ្ហា មានបណ្តាញដែលហូរទៅ ផ្សាយទៅ ក្នុងអារម្មណ៍ផ្សេងៗ ។

បុរសដែលមានតណ្ហាជាគម្រប់ពីរ រមែងអន្ទោលទៅកាន់ភាពនៃប្រការនេះ និងភាពនៃប្រការដទៃ អស់កាលដ៏វែង មិនកន្លងនូវសង្សារបាន ភិក្ខុអ្នកមានស្មារតី មិនមានសេចក្តីប្រកាន់ ប្រាសចាកតណ្ហា ដឹងទោសនេះហើយ តែងចៀសវាងនូវការកើតនៃទុក្ខព្រោះតណ្ហា ។

ព្រះមានព្រះភាគ តែមួយព្រះអង្គឯង ដោយសេចក្តីថា លះបង់តណ្ហា យ៉ាងនេះ ។

ព្រះមានព្រះភាគ តែមួយព្រះអង្គឯង ព្រោះហេតុទ្រង់ប្រាសចាករាគៈ ដោយចំណែកមួយ តើដូចម្តេច ។ ព្រះមានព្រះភាគ តែមួយព្រះអង្គឯង ព្រោះហេតុទ្រង់ប្រាសចាករាគៈ ដោយចំណែកមួយ ព្រោះទ្រង់លះរាគៈហើយ ។ ព្រះមានព្រះភាគ តែមួយព្រះអង្គឯង ព្រោះហេតុទ្រង់ប្រាសចាកទោសៈ ដោយចំណែកមួយ ព្រោះទ្រង់លះទោសៈហើយ ។ ព្រះមានព្រះភាគ តែមួយព្រះអង្គឯង ព្រោះហេតុទ្រង់ប្រាសចាកមោហៈ ដោយចំណែកមួយ ព្រោះទ្រង់លះមោហៈហើយ ។ ព្រះមានព្រះភាគ តែមួយព្រះអង្គឯង ព្រោះហេតុទ្រង់មិនមានកិលេស ដោយចំណែកមួយ ព្រោះទ្រង់លះកិលេសទាំងឡាយហើយ ។

ព្រះមានព្រះភាគ តែមួយព្រះអង្គឯង ព្រោះហេតុទ្រង់ស្តេចទៅកាន់ផ្លូវជាទីទៅនៃបុគ្គលម្នាក់ឯង តើដូចម្តេច ។ សតិប្បដ្ឋាន ៤ ។បេ។ មគ្គដ៏ប្រសើរមានអង្គ ៨ លោកហៅថា ផ្លូវជាទីទៅនៃបុគ្គលម្នាក់ឯង ។

ព្រះពុទ្ធទ្រង់ឃើញ នូវទីបំផុតនៃជាតិ ជាទីអស់ជាតិ ទ្រង់អនុគ្រោះ
នូវប្រយោជន៍ ទ្រង់ជ្រាបច្បាស់នូវផ្លូវ ជាទីទៅនៃបុគ្គលម្នាក់ឯង
ចំណែកអ្នកប្រាជ្ញទាំងឡាយ ឆ្លងហើយក្នុងអតីត នឹងឆ្លងក្នុង
អនាគត កំពុងឆ្លងក្នុងបច្ចុប្បន្ន នូវឱឃៈតាមផ្លូវនេះ ។

ព្រះមានព្រះភាគ តែមួយព្រះអង្គឯង ព្រោះហេតុទ្រង់ស្តេចទៅកាន់ផ្លូវជាទីទៅនៃបុគ្គលម្នាក់ឯង យ៉ាងនេះ ។

ព្រះមានព្រះភាគ តែមួយព្រះអង្គឯង ព្រោះហេតុទ្រង់ត្រាស់ដឹងសម្មាសម្ពោធិញ្ញាណដ៏ប្រសើរ តែមួយព្រះអង្គ តើដូចម្តេច ។ ញាណ បញ្ញា បញ្ញិន្ទ្រិយ បញ្ញាពល ។បេ។ ធម្មវិចយសម្ពោជ្ឈង្គ វីមំសា វិបស្សនា សម្មាទិដ្ឋិក្នុងមគ្គ ៤ លោកហៅថា ពោធិ ។ ដោយសារពោធិញ្ញាណនោះ ព្រះមានព្រះភាគ ទើបទ្រង់ត្រាស់ដឹងថា សង្ខារទាំងពួងមិនទៀង ។បេ។ ត្រាស់ដឹងថា របស់ណានីមួយ មានការកើតឡើងជាធម្មតា របស់ទាំងអស់នោះ មានការរលត់ទៅវិញជាធម្មតា ។ម្យ៉ាងទៀត ធម្មជាតណា ដែលបណ្ឌិតគប្បីដឹង គប្បីត្រាស់ដឹងតាម គប្បីត្រាស់ដឹងចំពោះ គប្បីត្រាស់ដឹងព្រម គប្បីបាន គប្បីពាល់ត្រូវ គប្បីធ្វើឲ្យជាក់ច្បាស់ ព្រះមានព្រះភាគទ្រង់ត្រាស់ដឹង ត្រាស់ដឹងតាម ត្រាស់ដឹងចំពោះ ត្រាស់ដឹងព្រម បានពាល់ត្រូវ ធ្វើឲ្យជាក់ច្បាស់នូវធម្មជាតទាំងអស់នោះ ដោយសារពោធិញ្ញាណនោះ ។ ព្រះមានព្រះភាគ តែមួយព្រះអង្គឯង ព្រោះហេតុទ្រង់ត្រាស់ដឹង សម្មាសម្ពោធិញ្ញាណដ៏ប្រសើរ តែមួយព្រះអង្គយ៉ាងនេះ ។ ពាក្យថា ទ្រង់បន្ទោបង់ងងឹត គឺព្រះមានព្រះភាគ ទ្រង់បន្ទោបង់ ទម្លាក់ចោល លះបង់ បោះបង់ ធ្វើឲ្យវិនាស ឲ្យដល់នូវការមិនកើតមាននូវងងឹត គឺរាគៈ ងងឹត គឺទោសៈ ងងឹត គឺមោហៈ ងងឹត គឺមានះ ងងឹត គឺទិដ្ឋិ ងងឹត គឺកិលេស ងងឹត គឺទុច្ចរិត គ្រឿងធ្វើឲ្យងងឹត ធ្វើមិនឲ្យមានចក្ខុ ធ្វើមិនឲ្យមានការដឹង នាំឲ្យរលត់បញ្ញា ជាចំណែកនៃសេចក្តីចង្អៀតចង្អល់ មិនប្រព្រឹត្តទៅដើម្បីនិព្វាន ។ ពាក្យថា ទ្រង់គង់នៅជាសុខ គឺព្រះមាន

ព្រះភាគ ទ្រង់គង់ជិតបាសាណកចេតិយ ហេតុនោះ ឈ្មោះថា ទ្រង់គង់នៅជាសុខ ។

ពួកសាវ័កដែលបានវិជ្ជា ៣ លះបង់នូវមច្ចុ តែងចូលទៅអង្គុយ
ជិតព្រះមុនិ ទ្រង់ដល់ត្រើយនៃទុក្ខ ទ្រង់គង់នៅក្បែរខាងភ្នំ ។

ហេតុនោះ ព្រះមានព្រះភាគ ឈ្មោះថា ទ្រង់គង់នៅជាសុខយ៉ាងនេះ ។ម្យ៉ាងទៀត ព្រះមានព្រះភាគ ទ្រង់គង់នៅជាសុខ ព្រោះព្រះអង្គគ្របសង្កត់សេចក្តីខ្វល់ខ្វាយទាំងអស់ ព្រះអង្គមានការនៅ ( ក្នុងអរិយវាស ) នៅរួចហើយ មានចរណៈសន្សំហើយ ។បេ។ ភពថ្មី គឺជាតិ ជរា មរណៈ សង្សារនៃព្រះអង្គ មិនមាន ហេតុនោះ ព្រះមានព្រះភាគ ឈ្មោះថា ទ្រង់គង់នៅជាសុខ យ៉ាងនេះឯង ហេតុនោះ ( លោកពោលថា ) តែមួយព្រះអង្គឯង ទ្រង់បន្ទោបង់ងងឹត គង់នៅជាសុខ ។

[ ១៦៤ ] ពាក្យថា ព្រះគោតមនោះ ទ្រង់មានរស្មីរុងរឿង ទ្រង់ធ្វើពន្លឺ ( ដល់លោក ) ត្រង់ពាក្យថា ទ្រង់មានរស្មីរុងរឿង គឺទ្រង់មានពន្លឺ ជាបណ្ឌិត មានប្រាជ្ញា មានប្រាជ្ញាជាគ្រឿងត្រាស់ដឹង មានញាណ មានប្រាជ្ញាភ្លឺច្បាស់ មានប្រាជ្ញាជាគ្រឿងទម្លាយកិលេស ។ ពាក្យថា ទ្រង់ធ្វើពន្លឺ គឺទ្រង់ធ្វើឲ្យឃើញច្បាស់ ទ្រង់ធ្វើពន្លឺ ទ្រង់ធ្វើប្រទីប ទ្រង់ធ្វើរស្មី ទ្រង់ធ្វើពន្លឺសព្វ ហេតុនោះ ( លោកពោលថា ) ព្រះគោតមនោះ ទ្រង់មានរស្មីរុងរឿង ទ្រង់ធ្វើពន្លឺ ( ដល់លោក ) ។

[ ១៦៥ ] ពាក្យថា ព្រះគោតម មានបញ្ញាជាគ្រឿងប្រាកដ គឺព្រះគោតម

ទ្រង់មានបញ្ញាជាគ្រឿងប្រាកដ មានញាណជាគ្រឿងប្រាកដ មានប្រាជ្ញាជាទង់ជ័យ មានប្រាជ្ញាជាទង់ មានប្រាជ្ញាជាអធិបតី ច្រើនដោយការពិចារណា ច្រើនដោយការពិចារណាសព្វ ច្រើនដោយការប្រមើលមើល មានការប្រមើលមើលជាធម្មតា ជ្រាបច្បាស់ជាប្រក្រតី ប្រព្រឹត្តដោយប្រាជ្ញានោះ ច្រើនដោយប្រាជ្ញានោះ ធ្ងន់ដោយប្រាជ្ញានោះ ទេរទៅរកប្រាជ្ញានោះ ទោរទៅរកប្រាជ្ញានោះ ឈមទៅរកប្រាជ្ញានោះ បង្អោនទៅរកប្រាជ្ញានោះ យកប្រាជ្ញានោះជាអធិបតី ។

រថមានទង់ជាគ្រឿងប្រាកដ ភ្លើងមានផ្សែងជាគ្រឿងប្រាកដ ដែន
មានស្តេចជាគ្រឿងប្រាកដ ស្ត្រីមានភស្តាជាគ្រឿងប្រាកដ ។

ព្រះគោតម ទ្រង់មានប្រាជ្ញាជាគ្រឿងប្រាកដ មានញាណជាគ្រឿងប្រាកដ មានប្រាជ្ញាជាទង់ជ័យ មានប្រាជ្ញាជាទង់ មានប្រាជ្ញាជាអធិបតី ច្រើនដោយការពិចារណា ច្រើនដោយការពិចារណាសព្វ ច្រើនដោយការប្រមើលមើល មានការប្រមើលមើលជាធម្មតា ជ្រាបច្បាស់ជាប្រក្រតី ប្រព្រឹត្តដោយប្រាជ្ញានោះ ច្រើនដោយប្រាជ្ញានោះ ធ្ងន់ដោយប្រាជ្ញានោះ ទេរទៅរកប្រាជ្ញានោះ ទោរទៅរកប្រាជ្ញានោះ ឈមទៅរកប្រាជ្ញានោះ បង្អោនទៅរកប្រាជ្ញានោះ យកប្រាជ្ញានោះជាអធិបតី យ៉ាងនេះឯង ហេតុនោះ ( លោកពោលថា ) ព្រះគោតមមានប្រាជ្ញាជាគ្រឿងប្រាកដ ។

[ ១៦៦ ] ពាក្យថា ព្រះគោតម ទ្រង់មានប្រាជ្ញាដូចផែនដី អធិប្បាយថា ប្រឹថពី លោកហៅថា ផែនដី ។ ព្រះគោតម ទ្រង់ប្រកបដោយប្រាជ្ញាស្មើដោយប្រឹថពីដ៏ធំទូលាយ ។ បញ្ញា លោកហៅថា មេធា បានដល់ ប្រាជ្ញា

ការដឹងច្បាស់ ។បេ។ ការមិនវង្វេង ការពិចារណាធម៌ ការយល់ត្រូវ ។ ព្រះមានព្រះភាគទ្រង់ប្រកប ប្រកបព្រម ចូលទៅជិតដល់ ចូលទៅជិតដល់ព្រម ដល់ស៊ប់ ដល់ស៊ប់ព្រម រួបរួមដោយមេធា គឺប្រាជ្ញានេះ ហេតុនោះ ព្រះពុទ្ធឈ្មោះថា មានប្រាជ្ញាដូចផែនដី ហេតុនោះ ( លោកពោលថា ) ព្រះគោតមទ្រង់មានប្រាជ្ញាដូចផែនដី ។ ហេតុនោះ ព្រះបិង្គិយត្ថេរពោលថា

ព្រះគោតមអង្គនោះ តែមួយព្រះអង្គឯង ទ្រង់បន្ទោបង់ងងឹត គង់នៅជាសុខ ទ្រង់មានរស្មីរុងរឿង ធ្វើពន្លឺ ( ដល់លោក ) ព្រះគោតម មានប្រាជ្ញាជាគ្រឿងប្រាកដ ព្រះគោតម មានប្រាជ្ញាដូចផែនដី ។

[ ១៦៧ ] ព្រះគោតមអង្គណា ទ្រង់សម្តែងធម៌ហើយដល់ខ្ញុំ ជាធម៌ដែលបុគ្គល គប្បីឃើញចំពោះខ្លួន ជាធម៌ឲ្យផលមិនរង់ចាំកាល ជាគ្រឿងអស់តណ្ហា មិនមានចង្រៃ ដែលជាធម៌មិនមានឧបមា ក្នុងទីណាមួយ ។

[ ១៦៨ ] ពាក្យថា ព្រះគោតមអង្គណា ទ្រង់សម្តែងធម៌ដល់ខ្ញុំ ត្រង់ពាក្យថា អង្គណា គឺព្រះមានព្រះភាគអង្គណា ទ្រង់កើតឯង មិនមានអាចារ្យត្រាស់ដឹងសច្ចៈទាំងឡាយ ដោយព្រះអង្គឯង ក្នុងធម៌ទាំងឡាយ ដែលមិនធ្លាប់ឮមកក្នុងកាលមុន ព្រះអង្គទ្រង់ដល់នូវភាពជាសព្វញ្ញូ ក្នុងសច្ចៈទាំងនោះផង ទ្រង់ដល់នូវភាពជាអ្នកស្ទាត់ ក្នុងពលទាំងឡាយផង ។ ពាក្យថា ទ្រង់សម្តែងនូវធម៌ ត្រង់ពាក្យថា នូវធម៌ គឺទ្រង់ប្រាប់ សម្តែង បញ្ញត្ត តាំងទុក បើក

វែកញែក ធ្វើឲ្យរាក់ ប្រកាសនូវព្រហ្មចរិយធម៌ មានពីរោះបទដើម ពីរោះបទកណ្តាល ពីរោះបទចុង ព្រមទាំងអត្ថ ទាំងព្យញ្ជនៈ ដ៏ពេញបរិបូណ៌បរិសុទ្ធទាំងអស់ផង សតិប្បដ្ឋានផង ។បេ។ អដ្ឋង្គិកមគ្គដ៏ប្រសើរផង និព្វានផង បដិបទាជាដំណើរទៅកាន់ព្រះនិព្វានផង ហេតុនោះ ( លោកពោលថា ) ព្រះគោតមអង្គណា ទ្រង់សម្តែងនូវធម៌ដល់ខ្ញុំ ។

[ ១៦៩ ] ពាក្យថា ជាធម៌ដែលបុគ្គលគប្បីឃើញចំពោះខ្លួន ជាធម៌ឲ្យផលមិនរង់ចាំកាល គឺជាធម៌ដែលបុគ្គលគប្បីឃើញចំពោះខ្លួន ជាធម៌ឲ្យផលមិនរង់ចាំកាល ជាធម៌គួរដល់ឯហិបស្សវិធី គួរបង្អោនមកទុកក្នុងខ្លួន ជាធម៌ដែលវិញ្ញូជនទាំងឡាយ គប្បីដឹងចំពោះខ្លួន ហេតុនោះ ( លោកពោលថា ) ជាធម៌ដែលបុគ្គលគប្បីឃើញចំពោះខ្លួន ជាធម៌ឲ្យផលមិនរង់ចាំកាល យ៉ាងនេះ ។ មួយទៀត បុគ្គលណា ចម្រើនអដ្ឋង្គិកមគ្គដ៏ប្រសើរ ក្នុងបច្ចុប្បន្ន បុគ្គលនោះ រមែងជួប បាន បានចំពោះនូវផលក្នុងលំដាប់ លំដាប់ស្មើនៃមគ្គនោះ ហេតុនោះ ( លោកពោលថា ) ជាធម៌ដែលបុគ្គលគប្បីឃើញចំពោះខ្លួន ជាធម៌ឲ្យផលមិនរង់ចាំកាល យ៉ាងនេះក៏បាន ។ មនុស្សទាំងឡាយឲ្យទ្រព្យ ប្រកបដោយកាល មិនបានផលក្នុងលំដាប់ រមែងរង់ចាំកាល យ៉ាងណា ធម៌នេះ មិនមែនយ៉ាងនោះទេ ។ បុគ្គលណា ចម្រើនអដ្ឋង្គិកមគ្គដ៏ប្រសើរ ក្នុងបច្ចុប្បន្ន បុគ្គលនោះ រមែងជួប បាន បានចំពោះនូវផលក្នុងលំដាប់ លំដាប់ស្មើនៃមគ្គនោះ មិនមែនបានក្នុងពេលដទៃ មិនមែនបានក្នុងលោកដទៃទេ ជាធម៌ឲ្យផលមិនរង់ចាំកាល យ៉ាងនេះ ហេតុនោះ ( លោក

ពោលថា ) ជាធម៌ដែលបុគ្គលគប្បីឃើញចំពោះខ្លួន ជាធម៌ឲ្យផល មិនរង់ចាំកាល ។

[ ១៧០ ] ពាក្យថា ជាគ្រឿងអស់តណ្ហា មិនមានចង្រៃ ត្រង់ពាក្យថា តណ្ហា បានដល់ រូបតណ្ហា សទ្ទតណ្ហា គន្ធតណ្ហា រសតណ្ហា ផោដ្ឋព្វតណ្ហា ធម្មតណ្ហា ។ ពាក្យថា ជាគ្រឿងអស់តណ្ហា គឺជាគ្រឿងអស់តណ្ហា អស់រាគៈ អស់ទោសៈ អស់មោហៈ អស់គតិ អស់ឧបបត្តិ អស់បដិសន្ធិ អស់ភព អស់សង្សារ អស់វដ្តៈ ។ ពាក្យថា មិនមានចង្រៃ សេចក្តីថា កិលេស ខន្ធ និងអភិសង្ខារ លោកហៅថា ចង្រៃ ។ ការលះចង្រៃ ការស្ងប់ចង្រៃ ការរលាស់បោលចង្រៃ ការគ្របសង្កត់ចង្រៃ អមតនិព្វាន ហេតុនោះ ( លោកពោលថា ) ជាគ្រឿងអស់តណ្ហា មិនមានចង្រៃ ។

[ ១៧១ ] អធិប្បាយពាក្យថា ដែលជាធម៌មិនមានឧបមា ក្នុងទីណាមួយ ត្រង់ពាក្យថា ធម៌ បានដល់ និព្វាន ។ ពាក្យថា មិនមានឧបមា គឺមិនមានការប្រៀប មិនមានសេចក្តីប្រៀបធៀប មិនមានភាពស្មើគ្នា មិនមានមិនមានព្រម មិនបានទូវចំណែកប្រៀប ។ ពាក្យថា ក្នុងទីណាមួយ គឺក្នុងទីណាមួយ ក្នុងទីណាៗ ក្នុងទីនីមួយ ជាខាងក្នុង ឬខាងក្រៅ ឬទាំងខាងក្នុងទាំងខាងក្រៅ ហេតុនោះ ( លោកពោលថា ) ដែលជាធម៌មិនមានឧបមាក្នុងទីណាមួយ ។ ហេតុនោះ ព្រះបិង្គិយត្ថេរពោលថា

ព្រះគោតមអង្គណា ទ្រង់សម្តែងធម៌ហើយដល់ខ្ញុំ ជាធម៌ដែល
បុគ្គលគប្បីឃើញចំពោះខ្លួន ជាធម៌ឲ្យផលមិនរង់ចាំកាល ជាធម៌

អស់តណ្ហា មិនមានចង្រៃ ដែលជាធម៌មិនមានឧបមា ក្នុងទីណា មួយ ។

[ ១៧២ ] ( ពាវរីព្រាហ្មណ៍សួរថា ) បពិត្រព្រះបិង្គិយៈ ចុះលោកម្ចាស់ ធ្លាប់ឃ្លាតអំពីព្រះគោតម ទ្រង់មានប្រាជ្ញាជាគ្រឿងប្រាកដ អំពីព្រះគោតម មានប្រាជ្ញាដូចផែនដីនោះ សូម្បីមួយរំពេចដែរឬ ។

[ ១៧៣ ] ពាក្យថា ចុះលោកម្ចាស់ ធ្លាប់ឃ្លាតអំពីព្រះគោតមនោះដែរឬ គឺចុះលោកម្ចាស់ធ្លាប់ឃ្លាតឃ្លា ឃ្លាតចេញ ថយចេញ វៀរចេញ អំពីព្រះពុទ្ធនោះដែរឬ ហេតុនោះ ( ព្រាហ្មណ៍ពោលថា ) ចុះលោកម្ចាស់ ធ្លាប់ឃ្លាតអំពីព្រះគោតមនោះដែរឬ ។

[ ១៧៤ ] ពាក្យថា បពិត្រព្រះបិង្គិយៈ ... សូម្បីមួយរំពេច គឺសូម្បីមួយរំពេច មួយខណៈ មួយស្របក់ មួយចំណែក មួយថ្ងៃ ហេតុនោះ ( ព្រាហ្មណ៍ពោលថា ) សូម្បីមួយរំពេច ។ ពាក្យថា បពិត្រព្រះបិង្គិយៈ គឺពាវរីព្រាហ្មណ៍ហៅចៅនោះដោយនាម ។

[ ១៧៥ ] ពាក្យថា អំពីព្រះគោតម ទ្រង់មានប្រាជ្ញាជាគ្រឿងប្រាកដ គឺអំពីព្រះគោតម ទ្រង់មានប្រាជ្ញាជាគ្រឿងប្រាកដ មានញាណជាគ្រឿងប្រាកដ មានប្រាជ្ញាជាទង់ជ័យ មានប្រាជ្ញាជាទង់ យកប្រាជ្ញាជាអធិបតី ច្រើនដោយការពិចារណា ច្រើនដោយការពិចារណាសព្វ ច្រើនដោយការប្រមើលមើល មានការប្រមើលមើលព្រមជាធម្មតា ជ្រាបច្បាស់ជាប្រក្រតី ប្រព្រឹត្តដោយប្រាជ្ញា

នោះ ច្រើនដោយប្រាជ្ញានោះ ធ្ងន់ដោយប្រាជ្ញានោះ ទេរទៅរកប្រាជ្ញានោះ ទោរទៅរកប្រាជ្ញានោះ ឈមទៅរកប្រាជ្ញានោះ ឱនទៅរកប្រាជ្ញានោះ យកប្រាជ្ញានោះជាអធិបតី ហេតុនោះ ( ព្រាហ្មណ៍ពោលថា ) អំពីព្រះគោតម ទ្រង់មានប្រាជ្ញាជាគ្រឿងប្រាកដ ។

[ ១៧៦ ] ពាក្យថា អំពីព្រះគោតម មានប្រាជ្ញាដូចផែនដី សេចក្តីថា ប្រឹថពី លោកហៅថា ផែនដី ។ ព្រះមានព្រះភាគ ទ្រង់ប្រកបដោយប្រាជ្ញាស្មើដោយផែនដីដ៏ធំទូលាយនេះ ។ ប្រាជ្ញា លោកហៅថា មេធា បានដល់ប្រាជ្ញា ការដឹងច្បាស់ ។បេ។ ការមិនវង្វេង ការពិចារណាធម៌ ការយល់ត្រូវ ។ ព្រះមានព្រះភាគប្រកប ប្រកបព្រម ចូលទៅជិតដល់ ចូលទៅជិតដល់ព្រម ដល់ស៊ប់ ដល់ស៊ប់ព្រម រួបរួមដោយមេធា គឺប្រាជ្ញានេះ ហេតុនោះ ព្រះពុទ្ធឈ្មោះថា មានប្រាជ្ញាដូចផែនដី ។ ហេតុនោះ ( ព្រាហ្មណ៍ពោលថា ) អំពីព្រះគោតម មានប្រាជ្ញាដូចផែនដី ។ ហេតុនោះ ពាវរីព្រាហ្មណ៍នោះពោលថា

បពិត្រព្រះបិង្គិយៈ ចុះលោកម្ចាស់ ឃ្លាតអំពីព្រះគោតម ទ្រង់
មានប្រាជ្ញាជាគ្រឿងប្រាកដ អំពីព្រះគោតម មានប្រាជ្ញាដូចផែនដី
នោះ សូម្បីមួយរំពេចដែរឬ ។

[ ១៧៧ ] ព្រះគោតមអង្គណា ទ្រង់សម្តែងធម៌ដល់លោកម្ចាស់
ជាធម៌ដែលបុគ្គល គប្បីឃើញចំពោះខ្លួន ជាធម៌ឲ្យផលមិនរង់ចាំ
កាល ជាគ្រឿងអស់តណ្ហា មិនមានចង្រៃ ដែលជាធម៌មិនមាន
ឧបមា ក្នុងទីណាមួយ ។

[ ១៧៨ ] ត្រង់ពាក្យថា ព្រះគោតមអង្គណា ទ្រង់សម្តែងធម៌ដល់លោកម្ចាស់ ត្រង់ពាក្យថា អង្គណា គឺព្រះមានព្រះភាគអង្គណា ។បេ។ ទ្រង់ដល់នូវភាពជាសព្វញ្ញូ ក្នុងសច្ចៈនោះផង នូវភាពជាអ្នកស្ទាត់ ក្នុងពលទាំងឡាយផង ។ ពាក្យថា ទ្រង់សម្តែងធម៌ ត្រង់ពាក្យថា ធម៌ គឺទ្រង់ប្រាប់ សម្តែង បញ្ញត្ត តាំងទុក បើក វែកញែក ធ្វើឲ្យរាក់ ប្រកាសនូវព្រហ្មចរិយធម៌ មានពីរោះបទដើម ។បេ។ នូវបដិបទា ជាដំណើរទៅកាន់ព្រះនិព្វានផង ហេតុនោះ ( ព្រាហ្មណ៍ពោលថា ) ព្រះគោតមអង្គណា ទ្រង់សម្តែងធម៌ដល់លោកម្ចាស់ ។

[ ១៧៩ ] ពាក្យថា ជាធម៌ដែលបុគ្គល គប្បីឃើញចំពោះខ្លួន ជាធម៌ឲ្យផលមិនរង់ចាំកាល គឺជាធម៌ដែលបុគ្គល គប្បីឃើញចំពោះខ្លួន ជាធម៌ឲ្យផលមិនរង់ចាំកាល ជាធម៌គួរដល់ឯហិបស្សិវិធី គួរបង្អោនមកទុកក្នុងខ្លួន ជាធម៌ដែលវិញ្ញូជនទាំងឡាយ គប្បីដឹងចំពោះខ្លួន ហេតុនោះ ( ព្រាហ្មណ៍ពោលថា ) ជាធម៌ដែលបុគ្គល គប្បីឃើញចំពោះខ្លួន ជាធម៌ឲ្យផលមិនរង់ចាំកាល យ៉ាងនេះ ។ មួយទៀត បុគ្គលណាចម្រើនអដ្ឋង្គិកមគ្គ ដ៏ប្រសើរក្នុងបច្ចុប្បន្ន បុគ្គលនោះ រមែងជួប បាន បានចំពោះនូវផលក្នុងលំដាប់ លំដាប់ស្មើនៃមគ្គនោះ ហេតុនោះ ( ព្រាហ្មណ៍ពោលថា ) ជាធម៌ដែលបុគ្គល គប្បីឃើញចំពោះខ្លួន ជាធម៌ឲ្យផលមិនរង់ចាំកាល យ៉ាងនេះក៏បាន ។ មនុស្សទាំងឡាយឲ្យទ្រព្យ ប្រកបដោយកាល រមែងមិនបានផល ក្នុងលំដាប់ តែងរង់ចាំកាល យ៉ាងណា ធម៌នេះមិនមែនយ៉ាងនោះទេ ។ បុគ្គលណា ចម្រើនអដ្ឋង្គិកមគ្គដ៏ប្រសើរក្នុងបច្ចុប្បន្ន បុគ្គលនោះ រមែងជួប បាន បានចំពោះនូវផលក្នុងលំដាប់

លំដាប់ស្មើនៃមគ្គនោះ មិនមែនបានក្នុងពេលដទៃ មិនមែនបានក្នុងលោកដទៃទេ ជាធម៌ឲ្យផលមិនរង់ចាំកាលយ៉ាងនេះ ហេតុនោះ ( ព្រាហ្មណ៍ពោលថា ) ជាធម៌ដែលបុគ្គល គប្បីឃើញចំពោះខ្លួន ជាធម៌ឲ្យផលមិនរង់ចាំកាល ។

[ ១៨០ ] ពាក្យថា ជាគ្រឿងអស់តណ្ហា មិនមានចង្រៃ ត្រង់ពាក្យថា តណ្ហា បានដល់ រូបតណ្ហា សទ្ទតណ្ហា គន្ធតណ្ហា រសតណ្ហា ផោដ្ឋព្វតណ្ហា ធម្មតណ្ហា ។ ពាក្យថា ជាគ្រឿងអស់តណ្ហា គឺជាគ្រឿងអស់តណ្ហា អស់រាគៈ អស់ទោសៈ អស់មោហៈ អស់គតិ អស់ឧបបត្តិ អស់បដិសន្ធិ អស់ភព អស់សង្សារ អស់វដ្តៈ ។ ពាក្យថា មិនមានចង្រៃ សេចក្ដីថា កិលេស ខន្ធ និងអភិសង្ខារ លោកហៅថា ចង្រៃ ។ ការលះចង្រៃ ការស្ងប់ចង្រៃ ការរលាស់ចោលចង្រៃ ការគ្របសង្កត់ចង្រៃ អមតនិព្វាន ហេតុនោះ ( ព្រាហ្មណ៍ពោលថា ) ជាគ្រឿងអស់តណ្ហា មិនមានចង្រៃ ។

[ ១៨១ ] ពាក្យថា ដែលជាធម៌មិនមានឧបមា ក្នុងទីណាមួយ ត្រង់ពាក្យថា ដែលជាធម៌ បានដល់និព្វាន ។ ពាក្យថា មិនមានឧបមា គឺមិនមានការប្រៀប មិនមានសេចក្ដីប្រៀបធៀប មិនមានភាពស្មើគ្នា មិនមាន មិនមានព្រម មិនបាននូវចំណែកប្រៀប ហេតុនោះ ( ព្រាហ្មណ៍ពោលថា ) មិនមានឧបមា ។ ពាក្យថា ក្នុងទីណាមួយ គឺក្នុងទីណាមួយ ក្នុងទីណាៗ ក្នុងទីនីមួយ ជាខាងក្នុង ឬខាងក្រៅ ឬទាំងខាងក្នុងទាំងខាងក្រៅ ហេតុនោះ ( ព្រាហ្មណ៍ពោលថា ) ដែលជាធម៌មិនមានឧបមា ក្នុងទីណាមួយ ។ ហេតុនោះ ពាវរិ-ព្រាហ្មណ៍នោះពោលថា

ព្រះគោតមអង្គណា ទ្រង់សម្តែងធម៌ដល់លោកម្ចាស់ ជាធម៌ដែលបុគ្គលគប្បីឃើញចំពោះខ្លួន ជាធម៌ឲ្យផលមិនរង់ចាំកាល ជាគ្រឿងអស់តណ្ហា មិនមានចង្រៃ ដែលជាធម៌មិនមានឧបមា ក្នុងទីណាមួយ ។

[ ១៨២ ] ( ព្រះបិង្គិយត្ថេរពោលថា ) បពិត្រព្រាហ្មណ៍ អាត្មាមិនធ្លាប់ឃ្លាត អំពីព្រះគោតម ទ្រង់មានប្រាជ្ញាជាគ្រឿងប្រាកដ អំពីព្រះគោតម មានប្រាជ្ញាដូចផែនដីនោះ សូម្បីមួយរំពេចទេ ។

[ ១៨៣ ] ពាក្យថា អាត្មាមិនធ្លាប់ឃ្លាត អំពីព្រះគោតមនោះ គឺអាត្មាមិនធ្លាប់ឃ្លាតឃ្លា មិនគេចចេញ មិនថយចេញ មិនវៀរចេញ ចាកព្រះពុទ្ធនោះទេ ហេតុនោះ ( លោកពោលថា ) អាត្មាមិនធ្លាប់ឃ្លាត អំពីព្រះគោតមនោះទេ ។

[ ១៨៤ ] ពាក្យថា បពិត្រព្រាហ្មណ៍ ... សូម្បីមួយរំពេច គឺសូម្បីមួយរំពេច មួយខណៈ មួយស្របក់ មួយចំណែក មួយថ្ងៃ ហេតុនោះ ( លោកពោលថា ) សូម្បីមួយរំពេច ។ ពាក្យថា បពិត្រព្រាហ្មណ៍ គឺព្រះបិង្គិយត្ថេរហៅឪពុកធំដោយគោរព ។

[ ១៨៥ ] ពាក្យថា អំពីព្រះគោតម ទ្រង់មានប្រាជ្ញាជាគ្រឿងប្រាកដ គឺអំពីព្រះគោតម ទ្រង់មានប្រាជ្ញាជាគ្រឿងប្រាកដ មានញាណជាគ្រឿងប្រាកដ មានប្រាជ្ញាជាទង់ជ័យ មានប្រាជ្ញាជាទង់ យកប្រាជ្ញាជាអធិបតី ច្រើនដោយការពិចារណា ច្រើនដោយការពិចារណាសព្វ ច្រើនដោយការប្រមើលមើល មានការប្រមើលមើលព្រមជាធម្មតា ជ្រាបច្បាស់ជាប្រក្រតី ប្រព្រឹត្តដោយប្រាជ្ញា

នោះ ច្រើនដោយប្រាជ្ញានោះ ធ្ងន់ដោយប្រាជ្ញានោះ ទេរទៅរកប្រាជ្ញានោះ ទោរទៅរកប្រាជ្ញានោះ ឈមទៅរកប្រាជ្ញានោះ បង្អោនទៅរកប្រាជ្ញានោះ យកប្រាជ្ញានោះជាអធិបតី ហេតុនោះ ( លោកពោលថា ) អំពីព្រះគោតម ទ្រង់មានប្រាជ្ញាជាគ្រឿងប្រាកដ ។

[ ១៨៦ ] ពាក្យថា អំពីព្រះគោតម មានប្រាជ្ញាដូចផែនដី សេចក្តីថា ប្រឹថពី លោកហៅថា ផែនដី ។ ព្រះមានព្រះភាគទ្រង់ប្រកបដោយប្រាជ្ញាស្មើដោយផែនដី ដ៏ធំទូលាយនេះ ។ ប្រាជ្ញា លោកហៅថា មេធា បានដល់ ប្រាជ្ញា ការដឹងច្បាស់ ។បេ។ ការមិនវង្វេង ការពិចារណាធម៌ ការយល់ត្រូវ ។ ព្រះមានព្រះភាគទ្រង់ប្រកប ប្រកបព្រម ចូលទៅជិតដល់ ចូលទៅជិត ដល់ព្រម ដល់ស៊ប់ ដល់ស៊ប់ព្រម រួបរួមដោយមេធា គឺប្រាជ្ញានេះ ហេតុនោះ ព្រះពុទ្ធឈ្មោះថា មានប្រាជ្ញាដូចផែនដី ហេតុនោះ ( លោកពោលថា ) អំពីព្រះគោតម មានប្រាជ្ញាដូចផែនដី ។ ហេតុនោះ ព្រះបិង្គិយត្ថេរពោលថា

បពិត្រព្រាហ្មណ៍ អាត្មាមិនធ្លាប់ឃ្លាតអំពីព្រះគោតម ទ្រង់មានប្រាជ្ញាជាគ្រឿងប្រាកដ អំពីព្រះគោតម មានប្រាជ្ញាដូចផែនដីនោះ សូម្បីមួយរំពេចទេ ។

[ ១៨៧ ] ព្រះគោតមអង្គណា ទ្រង់សម្តែងធម៌ដល់អាត្មា ជាធម៌ដែលបុគ្គលគប្បីឃើញចំពោះខ្លួន ជាធម៌ឲ្យផលមិនរង់ចាំកាល ជាគ្រឿងអស់តណ្ហា មិនមានចង្រៃ ដែលជាធម៌មិនមានឧបមាក្នុងទីណាមួយ ។

[ ១៨៨ ] ពាក្យថា ព្រះគោតមអង្គណា ទ្រង់សម្តែងធម៌ដល់អាត្មា ត្រង់ពាក្យថា អង្គណា គឺព្រះមានព្រះភាគអង្គណា ទ្រង់កើតឯង មិនមានអាចារ្យ ត្រាស់ដឹងសច្ចៈទាំងឡាយដោយព្រះអង្គឯង ក្នុងធម៌ទាំងឡាយដែលមិនធ្លាប់ឮមកក្នុងកាលមុនផង ទ្រង់ដល់នូវភាពជាសព្វញ្ញូក្នុងសច្ចៈទាំងនោះផង ទ្រង់ដល់នូវភាពជាអ្នកស្ទាត់ ក្នុងពលទាំងឡាយផង ។ ពាក្យថា ទ្រង់សម្តែងធម៌ ត្រង់ពាក្យថា ធម៌ គឺទ្រង់ប្រាប់ សម្តែង បញ្ញត្ត តាំងទុក បើកវែកញែក ធ្វើឲ្យរាក់ ប្រកាសនូវព្រហ្មចរិយធម៌ មានពីរោះបទដើម ពីរោះបទកណ្តាល ពីរោះបទចុង ព្រមទាំងអត្ថ ទាំងព្យញ្ជនៈ ដ៏បរិសុទ្ធ បរិបូណ៌ទាំងអស់ នូវសតិប្បដ្ឋាន ៤ សម្មប្បធាន ៤ ឥទ្ធិបាទ ៤ ឥន្ទ្រិយ ៥ ពល ៥ ពោជ្ឈង្គ ៧ អដ្ឋង្គិកមគ្គដ៏ប្រសើរ និព្វាន និងបដិបទាជាដំណើរទៅកាន់ព្រះនិព្វាន ហេតុនោះ ( លោកពោលថា ) ព្រះគោតមអង្គណា ទ្រង់សម្តែងធម៌ដល់អាត្មា ។

[ ១៨៩ ] ពាក្យថា ជាធម៌ដែលបុគ្គលគប្បីឃើញចំពោះខ្លួន ជាធម៌ឲ្យផលមិនរង់ចាំកាល គឺជាធម៌ដែលបុគ្គលគប្បីឃើញច្បាស់ចំពោះខ្លួន ជាធម៌ឲ្យផលមិនរង់ចាំកាល ជាធម៌គួរដល់ឯហិបស្សិកវិធី គួរបង្អោនមកទុកក្នុងខ្លួន ជាធម៌ដែលវិញ្ញូជនគប្បីដឹងចំពោះខ្លួន ហេតុនោះ ( លោកពោលថា ) ជាធម៌ដែលបុគ្គលគប្បីឃើញចំពោះខ្លួន ជាធម៌ឲ្យផលមិនរង់ចាំកាល យ៉ាងនេះ ។ មួយទៀត បុគ្គលណា ចម្រើនអដ្ឋង្គិកមគ្គដ៏ប្រសើរក្នុងបច្ចុប្បន្ន បុគ្គលនោះរមែងជួប បាន បានចំពោះនូវផលក្នុងលំដាប់ លំដាប់ស្មើនៃមគ្គនោះ ហេតុ

នោះ ( លោកពោលថា ) ជាធម៌ដែលបុគ្គលគប្បីឃើញចំពោះខ្លួន ជាធម៌ឲ្យផល មិនរង់ចាំកាលយ៉ាងនេះក៏បាន ។ មនុស្សទាំងឡាយឲ្យទ្រព្យ ប្រកបដោយកាល មិនបានផលក្នុងលំដាប់ រមែងរង់ចាំកាលយ៉ាងណា ធម៌នេះមិនមែនយ៉ាងនោះទេ បុគ្គលណា ចម្រើនអដ្ឋង្គិកមគ្គដ៏ប្រសើរក្នុង បច្ចុប្បន្ន បុគ្គលនោះ រមែងជួប បាន បានចំពោះនូវផលក្នុងលំដាប់ លំដាប់ស្មើនៃមគ្គនោះ មិនមែនបានក្នុងពេលដទៃ មិនមែនបានក្នុងលោកដទៃទេ ជាធម៌ឲ្យផលមិនរង់ចាំកាលយ៉ាងនេះ ហេតុនោះ ( លោកពោលថា ) ជាធម៌ដែលបុគ្គលគប្បីឃើញចំពោះខ្លួន ជាធម៌ឲ្យផលមិនរង់ចាំកាល ។

[ ១៩០ ] អធិប្បាយពាក្យថា ជាគ្រឿងអស់តណ្ហា មិនមានចង្រៃ ត្រង់ពាក្យថា តណ្ហា បានដល់ រូបតណ្ហា សទ្ទតណ្ហា គន្ធតណ្ហា រសតណ្ហា ផោដ្ឋព្វតណ្ហា ធម្មតណ្ហា ។ ពាក្យថា ជាគ្រឿងអស់តណ្ហា គឺជាគ្រឿងអស់ចំណង់ អស់រាគៈ អស់ទោសៈ អស់មោហៈ អស់គតិ អស់ឧបបត្តិ អស់បដិសន្ធិ អស់ភព អស់សង្សារ អស់វដ្តៈ ។ ពាក្យថា មិនមានចង្រៃ សេចក្តីថា កិលេស ខន្ធ និងអភិសង្ខារ លោកហៅថា ចង្រៃ ការលះចង្រៃ ការស្ងប់ចង្រៃ ការរលាស់ចោលចង្រៃ ការគ្របសង្កត់ចង្រៃ អមតនិព្វាន ហេតុនោះ ( លោកពោលថា ) ជាគ្រឿងអស់តណ្ហា មិនមានចង្រៃ ។

[ ១៩១ ] ពាក្យថា ដែលជាធម៌មិនមានឧបមាក្នុងទីណាមួយ ត្រង់ពាក្យថា ដែលជាធម៌ បានដល់ និព្វាន ។ ពាក្យថា មិនមានឧបមា គឺមិនមានការប្រៀបផ្ទឹម មិនមានសេចក្តីប្រៀបធៀប មិនមានភាពស្មើគ្នា មិនមាន មិន

មានព្រម មិនបាននូវចំណែកប្រៀប ហេតុនោះ ( លោកពោលថា ) មិនមានឧបមា ។ ពាក្យថា ក្នុងទីណាមួយ គឺក្នុងទីណាមួយ ក្នុងទីណាៗ ក្នុងទីនីមួយជាខាងក្នុង ឬខាងក្រៅ ឬទាំងខាងក្នុងទាំងខាងក្រៅ ហេតុនោះ ( លោកពោលថា ) ដែលជាធម៌មិនមានឧបមាក្នុងទីណាមួយ ។ ហេតុនោះ ព្រះបិង្គិយត្ថេរពោលថា

ព្រះគោតមអង្គណា ទ្រង់សម្តែងធម៌ដល់អាត្មា ជាធម៌ដែលបុគ្គលគប្បីឃើញចំពោះខ្លួន ជាធម៌ឲ្យផលមិនរង់ចាំកាល ជាគ្រឿងអស់តណ្ហា មិនមានចង្រៃ ដែលជាធម៌មិនមានឧបមាក្នុងទីណាមួយ ។

[ ១៩២ ] បពិត្រព្រាហ្មណ៍ អាត្មាជាអ្នកមិនប្រហែស តែងឃើញព្រះពុទ្ធនោះដោយចិត្ត ហាក់ដូចឃើញដោយភ្នែក ទាំងយប់ ទាំងថ្ងៃ អាត្មាតែងនមស្ការនៅរហូតយប់ និងថ្ងៃ ទើបអាត្មាសម្គាល់ថា ការមិនឃ្លាតដោយហេតុនោះឯង ។

[ ១៩៣ ] ពាក្យថា អាត្មាតែងឃើញព្រះពុទ្ធនោះដោយចិត្ត ហាក់ដូចឃើញដោយភ្នែក គឺបុរសមានភ្នែក គប្បីរមិលមើល គប្បីឃើញ គប្បីជួប គប្បីគន់មើល គប្បីសម្ងឹងមើល គប្បីពិចារណាមើលនូវរូបទាំងឡាយយ៉ាងណា អាត្មាតែងឃើញ ជួប គន់មើល សម្ងឹងមើល ពិចារណាមើលនូវព្រះពុទ្ធមានព្រះភាគដោយចិត្តក៏យ៉ាងនោះដែរ ហេតុនោះ ( លោកពោលថា ) អាត្មាតែងឃើញព្រះពុទ្ធនោះដោយចិត្ត ហាក់ដូចឃើញដោយភ្នែក ។

[ ១៩៤ ] ពាក្យថា បពិត្រព្រាហ្មណ៍ អាត្មាជាអ្នកមិនប្រហែស ទាំង

យប់ទាំងថ្ងៃ គឺអាត្មាខំចម្រើនដោយចិត្ត ទាំងយប់ទាំងថ្ងៃ ឈ្មោះថា ជាអ្នកមិនប្រហែស ហេតុនោះ ( លោកពោលថា ) បពិត្រព្រាហ្មណ៍ អាត្មាជាអ្នកមិនប្រហែសទាំងយប់ ទាំងថ្ងៃ ។

[ ១៩៥ ] ពាក្យថា អាត្មាតែងនមស្ការនៅរហូតយប់ និងថ្ងៃ ត្រង់ពាក្យថា នមស្ការ គឺនមស្ការដោយកាយក្តី នមស្ការដោយវាចាក្តី នមស្ការដោយចិត្តក្តី នមស្ការដោយការប្រតិបត្តិទៅតាមប្រយោជន៍ក្តី នមស្ការ ធ្វើសក្ការៈធ្វើសេចក្តីគោរពកោតអាន បូជាដោយការប្រតិបត្តិធម៌ដ៏សមគួរដល់ធម៌ក្តី នៅរហូតយប់ និងថ្ងៃ គឺញុំាងយប់ និងថ្ងៃឲ្យប្រព្រឹត្តកន្លងទៅ ហេតុនោះ ( លោកពោលថា ) អាត្មាតែងនមស្ការនៅរហូតយប់ និងថ្ងៃ ។

[ ១៩៦ ] ពាក្យថា ទើបអាត្មាសម្គាល់ថា ការមិនឃ្លាតដោយហេតុនោះឯង គឺអាត្មា កាលអប់រំដោយពុទ្ធានុស្សតិនោះ ទើបសម្គាល់នូវអំពើនោះថា ជាការមិនឃ្លាត សម្គាល់ គឺដឹង ដឹងយ៉ាងនេះ យល់យ៉ាងនេះ ដឹងច្បាស់យ៉ាងនេះ ដឹងចំពោះយ៉ាងនេះនូវព្រះពុទ្ធនោះថា ព្រះអង្គមិនធ្លាប់ឃ្លាត ហេតុនោះ ( លោកពោលថា ) ទើបអាត្មាសម្គាល់ថា ការមិនឃ្លាតដោយហេតុនោះឯង ។ ហេតុនោះ ព្រះបិង្គិយត្ថេរពោលថា

បពិត្រព្រាហ្មណ៍ អាត្មាជាអ្នកមិនប្រហែស តែងឃើញព្រះពុទ្ធនោះ
ដោយចិត្ត ហាក់ដូចឃើញដោយភ្នែក ទាំងយប់ទាំងថ្ងៃ អាត្មាតែង
នមស្ការនៅរហូតយប់ និងថ្ងៃ ទើបអាត្មាសម្គាល់ថា ការមិន
ឃ្លាត ដោយហេតុនោះឯង ។

[ ១៩៧ ] ធម៌ទាំង ៤ នេះ គឺសទ្ធា បីតិ មនោ និងសតិ ( របស់អាត្មា ) តែងមិនឃ្លាតចាកសាសនារបស់ព្រះគោតមឡើយ ព្រះគោតម ទ្រង់មានប្រាជ្ញាដូចផែនដី ស្តេចទៅកាន់ទិសណាៗ អាត្មានោះ ក៏ជាអ្នកឱនទៅរកទិសនោះៗ ។

[ ១៩៨ ] អធិប្បាយពាក្យថា សទ្ធា បីតិ មនោ និងសតិ ត្រង់ពាក្យថា សទ្ធា បានដល់ ជំនឿ ការជឿ ការចុះចិត្ត សេចក្តីជ្រះថ្លាខ្លាំង សទ្ធា សទ្ធិន្ទ្រិយ សទ្ធាពល ប្រារព្ធព្រះមានព្រះភាគ ។ ពាក្យថា បីតិ បានដល់ ការផ្អែត បាមោជ្ជ ការរីករាយ ការរីករាយចំពោះ ការត្រេកអរ ការត្រេកអរស៊ើប ភាពនៃចិត្តរបស់ខ្លួន ភាពនៃចិត្តជ្រះថ្លាក្រៃពេក ប្រារព្ធព្រះមានព្រះភាគ ។ ពាក្យថា មនោ បានដល់ ចិត្ត ធម្មជាតសម្រាប់បង្អោនទៅ សេចក្តីប្រាថ្នាក្នុងចិត្ត ហឫទ័យ បណ្ឌរៈ មនោ មនាយតនៈ មនិន្ទ្រិយ វិញ្ញាណ វិញ្ញាណក្ខន្ធ មនោវិញ្ញាណធាតុដែលកើតអំពីវិញ្ញាណក្ខន្ធនោះ ប្រារព្ធព្រះមានព្រះភាគ ។ ពាក្យថា សតិ បានដល់ ស្មារតី ការរឭករឿយៗ ។បេ។ ការរឭកត្រូវប្រារព្ធព្រះមានព្រះភាគ ហេតុនោះ ( លោកពោលថា ) សទ្ធា បីតិ មនោ និងសតិ ។

[ ៤៩៩ ] ពាក្យថា ធម៌ទាំង ៤ នេះ តែងមិនឃ្លាតចាកសាសនារបស់ព្រះគោតម គឺធម៌ទាំង ៤ នេះ តែងមិនប្រាសចេញ មិនមក មិនលះបង់ មិនវិនាស ចាកសាសនាព្រះគោតម ចាកសាសនាព្រះពុទ្ធ ចាកសាសនាព្រះជិនស្រី ចាកសាសនាព្រះតថាគត ចាកសាសនាព្រះអរហន្ត ហេតុនោះ ( លោក

ពោលថា ) ធម៌ទាំង ៤ នេះ តែងមិនប្រាសចាកសាសនារបស់គោតម ។

[ ២០០ ] ពាក្យថា ទ្រង់មានប្រាជ្ញាដូចផែនដី ស្តេចទៅកាន់ទិសណាៗ ត្រង់ពាក្យថា ទិសណាៗ គឺទ្រង់ទៅ ដល់ ឈាន ឈានកន្លងទៅកាន់ទិសខាងកើតក្តី ទិសខាងលិចក្តី ទិសខាងត្បូងក្តី ទិសខាងជើងក្តី ។ ពាក្យថា មានប្រាជ្ញាដូចផែនដី គឺទ្រង់មានប្រាជ្ញាដូចប្រឹថពី មានប្រាជ្ញាច្រើន មានប្រាជ្ញាមុត មានប្រាជ្ញាក្រាស់ មានប្រាជ្ញារីករាយ មានប្រាជ្ញារហ័ស មានប្រាជ្ញាធ្លុះធ្លាយ ហេតុនោះ ( លោកពោលថា ) ទ្រង់មានប្រាជ្ញាដូចផែនដី ស្តេចទៅកាន់ទិសណាៗ ។

[ ២០១ ] ពាក្យថា អាត្មានោះ ជាអ្នកឱនទៅរកទិសនោះៗ គឺព្រះពុទ្ធទ្រង់គង់នៅក្នុងទិសណា អាត្មានោះ ជាអ្នកឱនទៅរកទិសនោះ ទេរទៅរកទិសនោះ ទោរទៅរកទិសនោះ ឈមទៅរកទិសនោះ បង្អោនទៅរកទិសនោះ យកទិសនោះជាអធិបតី ហេតុនោះ ( លោកពោលថា ) អាត្មានោះ ជាអ្នកឱនទៅរកទិសនោះៗ ។ ហេតុនោះ ព្រះបិង្គិយត្ថេរពោលថា

ធម៌ទាំង ៤ នេះ គឺសទ្ធា បីតិ មនោ និងសតិ ( របស់អាត្មា )
តែងមិនឃ្លាតចាកសាសនារបស់ព្រះគោតមឡើយ ព្រះគោតមទ្រង់
មានប្រាជ្ញាដូចផែនដី ស្តេចទៅកាន់ទិសណាៗ អាត្មានោះក៏ជាអ្នក
ឱនទៅរកទិសនោះៗ ។

[ ២០២ ] អាត្មាជាបុគ្គលគ្រាំគ្រា មានកម្លាំងថយហើយ ហេតុ
នោះ កាយទៅក្នុងទិសនោះមិនបានទេ តែអាត្មាទៅដោយដំណើរ

នៃសេចក្តីត្រិះរិះអស់កាលជានិច្ច បពិត្រព្រាហ្មណ៍ ព្រោះថា ចិត្ត របស់អាត្មាប្រកបតាមទិសនោះ ។

[ ២០៣ ] ពាក្យថា អាត្មាជាបុគ្គលគ្រាំគ្រា មានកម្លាំងថយហើយ ត្រង់ពាក្យថា គ្រាំគ្រា គឺចាស់ ចម្រើន មានអាយុច្រើន រស់នៅបានយូរឆ្នាំមកហើយ មានវ័យដល់ហើយតាមលំដាប់ ហេតុនោះ ( លោកពោលថា ) គ្រាំគ្រា ។ ពាក្យថា មានកម្លាំងថយ គឺមានកម្លាំងខ្សោយ មានកម្លាំងតិច មានកម្លាំងស្តួចស្តើង ហេតុនោះ ( លោកពោលថា ) អាត្មាជាបុគ្គលគ្រាំគ្រា មានកម្លាំងថយហើយ ។

[ ២០៤ ] ពាក្យថា កាយទៅក្នុងទិសនោះមិនបានទេ គឺព្រះពុទ្ធគង់ក្នុងទិសណា កាយទៅមិនបាន ចេញទៅមិនបាន ដើរទៅមិនបាន ឈានទៅមិនបានក្នុងទិសនោះទេ ហេតុនោះ ( លោកពោលថា ) កាយទៅក្នុងទិសនោះមិនបានទេ ។

[ ២០៥ ] ពាក្យថា តែអាត្មាទៅដោយដំណើរនៃសេចក្តីត្រិះរិះអស់កាលជានិច្ច គឺអាត្មាទៅ ដើរទៅ ឈានទៅដោយដំណើរនៃតម្រិះ ដោយដំណើរវិតក្ក ដោយដំណើរញាណ ដោយដំណើរបញ្ញា ដោយដំណើរប្រាជ្ញាជាគ្រឿងត្រាស់ដឹង ហេតុនោះ ( លោកពោលថា ) តែអាត្មាទៅដោយដំណើរនៃសេចក្តីត្រិះរិះអស់កាលជានិច្ច ។

[ ២០៦ ] ពាក្យថា បពិត្រព្រាហ្មណ៍ ព្រោះថា ចិត្តរបស់អាត្មាប្រកបតាមទិសនោះ ត្រង់ពាក្យថា ចិត្ត បានដល់ គំនិត ធម្មជាតសម្រាប់បង្អោនទៅ

សេចក្តីប្រាថ្នាក្នុងចិត្ត ហឫទ័យ បណ្ឌរៈ មនោ មនាយតនៈ មនិន្ទ្រិយ វិញ្ញាណ វិញ្ញាណក្ខន្ធ មនោវិញ្ញាណធាតុដែលកើតអំពីវិញ្ញាណក្ខន្ធនោះ ។ ពាក្យថា បពិត្រព្រាហ្មណ៍ ... ប្រកបហើយតាមទិសនោះ គឺព្រះពុទ្ធគង់ក្នុងទិសណា ចិត្តរបស់អាត្មាក៏ប្រកប ប្រកបព្រមតាមទិសនោះ ហេតុនោះ ( លោកពោលថា ) បពិត្រព្រាហ្មណ៍ ព្រោះថា ចិត្តរបស់អាត្មាប្រកបតាមទិសនោះ ។ ហេតុនោះ ព្រះបិង្គិយត្ថេរពោលថា

អាត្មាជាបុគ្គលគ្រាំគ្រា មានកម្លាំងថយហើយ ហេតុនោះ កាយទៅក្នុងទិសនោះមិនបានទេ តែអាត្មាទៅដោយដំណើរ នៃសេចក្តីត្រិះរិះអស់កាលជានិច្ច បពិត្រព្រាហ្មណ៍ ព្រោះថា ចិត្តរបស់អាត្មាប្រកបតាមទិសនោះ ។

[ ២០៧ ] អាត្មាដេកក្នុងភក់ បម្រះនទៀល ស្ទុះចេញអំពីទីពឹង ទៅរកទីពឹង គ្រានោះ អាត្មាបានឃើញព្រះសម្ពុទ្ធទ្រង់ឆ្លងអន្លង់ហើយ ទ្រង់មិនមានអាសវៈទេ ។

[ ២០៨ ] អធិប្បាយពាក្យថា ដេកក្នុងភក់ បម្រះនទៀល ត្រង់ពាក្យថា ដេកក្នុងភក់ គឺដេក ដេកស៊ប់ ដេកត្រាំក្នុងភក់ គឺកាម ក្នុងល្បាប់ គឺកាម ក្នុងកិលេស គឺកាម ក្នុងសន្ទូច គឺកាម ក្នុងសេចក្តីក្តៅក្រហាយ គឺកាម ក្នុងកង្វល់ គឺកាម ហេតុនោះ ( លោកពោលថា ) ដេកក្នុងភក់ ។ ពាក្យថា បម្រះនទៀល គឺបម្រះនទៀលដោយការបម្រះនទៀល គឺតណ្ហា បម្រះនទៀលដោយការបម្រះនទៀល គឺទិដ្ឋិ បម្រះនទៀលដោយការបម្រះនទៀល គឺកិលេស

បម្រះនទៀលដោយការបម្រះនទៀល គឺប្រយោគ បម្រះនទៀលដោយការបម្រះនទៀល គឺវិបាក បម្រះនទៀលដោយការបម្រះនទៀល គឺទុច្ចរិត ជាអ្នកត្រេកអរ បម្រះនទៀលដោយរាគៈ ជាអ្នកប្រទូស្ត បម្រះនទៀលដោយទោសៈ ជាអ្នកវង្វេង បម្រះនទៀលដោយមោហៈ ជាអ្នកជាប់ជំពាក់ បម្រះនទៀលដោយមានះ ជាអ្នកស្ទាបអង្អែល បម្រះនទៀលដោយទិដ្ឋិ ជាអ្នករវើរវាយ បម្រះនទៀលដោយឧទ្ធច្ចៈ ជាអ្នកដល់នូវការមិនដាច់ស្រេច បម្រះនទៀលដោយវិចិកិច្ឆា ជាអ្នកដល់នូវកម្លាំង បម្រះនទៀលដោយអនុស័យ បម្រះនទៀលដោយលាភ បម្រះនទៀលដោយអលាភ បម្រះនទៀលដោយយស បម្រះនទៀលដោយអយស បម្រះនទៀលដោយនិន្ទា បម្រះនទៀលដោយសេចក្ដីសរសើរ បម្រះនទៀលដោយសុខ បម្រះនទៀលដោយទុក្ខ បម្រះនទៀលដោយជាតិ បម្រះនទៀលដោយជរា បម្រះនទៀលដោយព្យាធិ បម្រះនទៀលដោយមរណៈ បម្រះនទៀលដោយសេចក្ដីសោក ខ្សឹកខ្សួល ទុក្ខទោមនស្ស សេចក្ដីតានតឹង បម្រះនទៀលដោយទុក្ខក្នុងនរក បម្រះនទៀលដោយទុក្ខក្នុងតិរច្ឆានកំណើត បម្រះនទៀលដោយទុក្ខក្នុងប្រេតវិស័យ បម្រះនទៀល អន្ទះសា ញាប់ញ័រ ញ័ររន្ធត់ដោយទុក្ខជារបស់មនុស្ស ដោយទុក្ខមានការចុះកាន់គភ៌ជាមូល ដោយទុក្ខមានការតាំងនៅក្នុងគភ៌ជាមូល ដោយទុក្ខមានការចេញចាកគភ៌ជាមូល ដោយទុក្ខដែលទាក់ទងនឹងសត្វកើតហើយ ដោយទុក្ខដែលបណ្ដាលអំពីរឿងដទៃនៃសត្វកើតហើយ ដោយទុក្ខ ព្រោះសេចក្ដីព្យាយាមរបស់ខ្លួន ដោយទុក្ខ ព្រោះសេចក្ដីព្យាយាមរបស់បុគ្គលដទៃ

ដោយទុក្ខទុក្ខ សង្ខារទុក្ខ វិបរិណាមទុក្ខ ចក្ខុរោគទុក្ខ សោតរោគទុក្ខ ឃានរោគទុក្ខ ជិវ្ហារោគទុក្ខ កាយរោគទុក្ខ សីសរោគទុក្ខ កណ្ណរោគទុក្ខ មុខរោគទុក្ខ ទន្តរោគទុក្ខ ដោយទុក្ខ ព្រោះរោគក្អក ហឺត ឫសដូងច្រមុះ ក្តៅក្រហាយ ស្គាំងស្គម ឈឺពោះ វិលមុខ ធ្លាក់ឈាម ចុកសៀត ចុកផ្ទៃ ឃ្លង់ ពក ស្រែង រីងរៃ ឆ្កួតជ្រូក ដំណួចពិស រមាស់ កម រោគកើតក្នុងទីទ្វារដោយក្រចក ឃ្លង់ដែក ឈាម ប្រមាត់ ប្រមេះ ឫសដូងដុះ បូស ឫសដូងបាត ព្រោះអាពាធកើតអំពីប្រមាត់ អាពាធកើតអំពីស្លេស្ម អាពាធកើតអំពីខ្យល់ អាពាធកើតអំពីធាតុប្រជុំគ្នា អាពាធកើតអំពីការប្រែប្រួលរដូវ អាពាធកើតអំពីការរក្សាឥរិយាបថមិនស្មើ អាពាធ កើតអំពីសេចក្តីព្យាយាមមានវាយចងជាដើម អាពាធកើតអំពីកម្មវិបាក ព្រោះត្រជាក់ ក្តៅ ឃ្លានស្រេក ឧច្ចារៈ បស្សាវៈ សម្ផស្ស របោម មូស ខ្យល់ កម្តៅថ្ងៃ សត្វលូនវារ ដោយទុក្ខ ព្រោះស្លាប់មាតា ដោយទុក្ខ ព្រោះស្លាប់បិតា ដោយទុក្ខ ព្រោះស្លាប់បងប្អូនប្រុស ដោយទុក្ខ ព្រោះស្លាប់បងប្អូនស្រី ដោយទុក្ខ ព្រោះស្លាប់កូនប្រុស ដោយទុក្ខ ព្រោះស្លាប់កូនស្រី ដោយទុក្ខ ព្រោះវិនាសញាតិ ដោយទុក្ខ ព្រោះវិនាសភោគសម្បត្តិ ដោយទុក្ខ ព្រោះវិនាសដោយសាររោគ ដោយទុក្ខ ព្រោះវិនាសសីល ដោយទុក្ខ ព្រោះវិនាសទិដ្ឋិ ហេតុនេះ ( លោកពោលថា ) ដេកក្នុងកក់បម្រះននៀល ។

[ ២០៩ ] ពាក្យថា ស្ទុះចេញអំពីទីពឹង ទៅរកទីពឹង គឺស្ទុះ ស្ទុះចេញអំពីសាស្តាទៅរកសាស្តា អំពីអ្នកប្រាប់ធម៌ទៅរកអ្នកប្រាប់ធម៌ អំពីគណៈ

ទៅរកគណៈ អំពីទិដ្ឋិទៅរកទិដ្ឋិ អំពីបដិបទាទៅរកបដិបទា អំពីមគ្គទៅរកមគ្គ ហេតុនោះ ( លោកពោលថា ) ស្ទុះចេញអំពីទីពឹងទៅរកទីពឹង ។

[ ២១០ ] ពាក្យថា គ្រានោះ អាត្មាបានឃើញព្រះសម្ពុទ្ធ ត្រង់ពាក្យថា គ្រានោះ គឺជាការតបទ ។បេ។ ពាក្យថា គ្រានោះ ជាលំដាប់នៃបទ ។ ពាក្យថា បានឃើញ គឺបានឃើញ បានជួប បានប្រសព្វ បានចាក់ធ្លុះ ។ ពាក្យថា ព្រះសម្ពុទ្ធ បានដល់ ព្រះមានបុណ្យ ។បេ។ បញ្ញត្តថា ព្រះពុទ្ធនេះ កើតអំពីការត្រាស់ដឹង ហេតុនោះ ( លោកពោលថា ) គ្រានោះ អាត្មាបានឃើញព្រះសម្ពុទ្ធ ។

[ ២១១ ] ពាក្យថា ទ្រង់ឆ្លងអន្លង់ហើយ គឺព្រះមានព្រះភាគទ្រង់ឆ្លងអន្លង់ គឺកាម ឆ្លងអន្លង់ គឺភព ឆ្លងអន្លង់ទិដ្ឋិ ឆ្លង ឆ្លងឡើង ឆ្លងចេញ កន្លង កន្លងព្រម ប្រព្រឹត្តកន្លងអន្លង់ គឺអវិជ្ជា គឺថា ព្រះអង្គទ្រង់មានការនៅក្នុងអរិយវាស នៅរួចហើយ មានចរណៈសន្សំហើយ ។បេ។ ភពថ្មី គឺជាតិ ជរា មរណៈ សង្សារ នៃព្រះអង្គមិនមាន ហេតុនោះ ( លោកពោលថា ) ទ្រង់ឆ្លងអន្លង់ហើយ ។ ពាក្យថា មិនមានអាសវៈ សេចក្តីថាអាសវៈ ៤ គឺ កាមាសវៈ ភវាសវៈ ទិដ្ឋាសវៈ អវិជ្ជាសវៈ ។ អាសវៈទាំងនោះ ព្រះពុទ្ធមានជោគទ្រង់លះបង់ហើយ មានឫសគល់ផ្តាច់ផ្តិលហើយ ធ្វើឲ្យសល់តែទីនៅ ដូចជាទីនៅនៃដើមត្នោត ធ្វើឲ្យដល់នូវការមិនកើតមាន ឲ្យជាធម៌លែងកើតតទៅទៀត ហេតុនោះ ព្រះពុទ្ធ ឈ្មោះថា មិនមានអាសវៈ ហេតុនោះ ( លោកពោលថា ) ទ្រង់ឆ្លងអន្លង់ហើយ មិនមានអាសវៈ ។ ហេតុនោះ

ព្រះបិង្គិយត្ថេរពោលថា

អាត្មាដេកក្នុងកក់ បម្រះនទៀល ស្ទុះចេញអំពីទីពឹង ទៅរកទីពឹង គ្រានោះ អាត្មាបានឃើញព្រះសម្ពុទ្ធ ព្រះអង្គទ្រង់ឆ្លងអន្លង់ហើយ ទ្រង់មិនមានអាសវៈទេ ។

[ ២១២ ] ( ព្រះមានព្រះភាគត្រាស់ថា ) វក្កលិ ភទ្រាវុធ និង អាឡវិគោតម សុទ្ធតែជាអ្នកមានសទ្ធាបញ្ចេញហើយ យ៉ាងណា សូម្បីអ្នកក៏ចូរបញ្ចេញនូវសទ្ធា យ៉ាងនោះចុះ ម្នាលបិង្គិយៈ អ្នក នឹងដល់នូវត្រើយនៃលំនៅរបស់មច្ចុ ។

[ ២១៣ ] ពាក្យថា វក្កលិ ភទ្រាវុធ និងអាឡវិគោតម សុទ្ធតែជាអ្នក មានសទ្ធាបញ្ចេញហើយយ៉ាងណា អធិប្បាយថា វក្កលិ មានសទ្ធាបញ្ចេញ ហើយ ជាអ្នកជួន់ក្នុងសទ្ធា មានសទ្ធាជាប្រធាន មានចិត្តចុះស៊ប់ក្នុងសទ្ធា មាន សទ្ធាជាអធិបតី បានសម្រេចព្រះអរហត្តយ៉ាងណា ភទ្រាវុធមានសទ្ធាបញ្ចេញ ហើយ ជាអ្នកជួន់ក្នុងសទ្ធា មានសទ្ធាជាប្រធាន មានចិត្តចុះស៊ប់ក្នុងសទ្ធា មាន សទ្ធាជាអធិបតី បានសម្រេចព្រះអរហត្តយ៉ាងណា អាឡវិគោតមមានសទ្ធា បញ្ចេញហើយ ជាអ្នកជួន់ក្នុងសទ្ធា មានសទ្ធាជាប្រធាន មានចិត្តចុះស៊ប់ក្នុង សទ្ធា មានសទ្ធាជាអធិបតី បានសម្រេចព្រះអរហត្តយ៉ាងណា ហេតុនោះ ( ទ្រង់ត្រាស់ថា ) វក្កលិ ភទ្រាវុធ និងអាឡវិគោតម សុទ្ធតែជាអ្នកមាន សទ្ធា បញ្ចេញហើយយ៉ាងណា ។

[ ២១៤ ] ពាក្យថា សូម្បីអ្នកក៏ចូរបញ្ចេញនូវសទ្ធាយ៉ាងនោះចុះ សេចក្តី

ថា អ្នកចូរលែង ចូរបញ្ចេញ ចូរបញ្ចេញព្រម ចូរចុះស៊ប់កាន់សទ្ធា គឺចូរជឿថា សង្ខារទាំងពួងមិនទៀង ។បេ។ អ្នកចូរលែង ចូរបញ្ចេញ ចូរបញ្ចេញព្រម ចូរចុះស៊ប់កាន់សទ្ធា គឺចូរជឿថា របស់ណាមានការកើតឡើងជាធម្មតារបស់ទាំងអស់នោះ មានការរលត់ទៅវិញជាធម្មតាយ៉ាងនោះដែរ ហេតុនោះ ( ទ្រង់ត្រាស់ថា ) សូម្បីអ្នកក៏ចូរបញ្ចេញនូវសទ្ធាយ៉ាងនោះចុះ ។

[ ២១៥ ] ពាក្យថា ម្នាលបិង្គិយៈ អ្នកនឹងដល់ត្រើយនៃលំនៅរបស់មច្ចុ សេចក្តីថា កិលេស ខន្ធ និងអភិសង្ខារ លោកហៅថា លំនៅរបស់មច្ចុ ។ អមតនិព្វាន លោកហៅថា ត្រើយនៃលំនៅរបស់មច្ចុ បានដល់ ការរម្ងាប់សង្ខារទាំងពួង ការរលាស់ចោលឧបធិទាំងពួង ការអស់តណ្ហា ការប្រាសចាកតម្រេក សេចក្តីរលត់ និព្វាន ។ ពាក្យថា ម្នាលបិង្គិយៈ អ្នកនឹងដល់ត្រើយនៃលំនៅរបស់មច្ចុ បានសេចក្តីថា អ្នកនឹងដល់ នឹងបាន នឹងពាល់ត្រូវ នឹងធ្វើឲ្យជាក់ច្បាស់នូវត្រើយ ហេតុនោះ ( ទ្រង់ត្រាស់ថា ) ម្នាលបិង្គិយៈ អ្នកនឹងដល់ត្រើយនៃលំនៅរបស់មច្ចុ ។ ហេតុនោះ ព្រះមានព្រះភាគត្រាស់ថា

វក្កលិ ភទ្រាវុធ និងអាឡវិគោតម សុទ្ធតែជាអ្នកមានសទ្ធា
បញ្ចេញហើយយ៉ាងណា សូម្បីអ្នកក៏ចូរបញ្ចេញសទ្ធា យ៉ាងនោះ
ចុះ ម្នាលបិង្គិយៈ អ្នកនឹងដល់ត្រើយនៃលំនៅរបស់មច្ចុ ។

[ ២១៦ ] ( ព្រះបិង្គិយត្ថេរទូលថា ) ខ្ញុំព្រះអង្គនេះជ្រះថ្លាក្រៃពេក
ព្រោះបានស្តាប់ព្រះបន្ទូលនៃព្រះអង្គ ជាព្រះមុនិ ព្រះអង្គទ្រង់មាន

គ្រឿងបិទបើកហើយ ព្រះអង្គមិនមានគ្រឿងរឹងរូស ទ្រង់មានបដិភាណ ។

[ ២១៧ ] ពាក្យថា ខ្ញុំព្រះអង្គនេះជ្រះថ្លាក្រែពេក គឺខ្ញុំព្រះអង្គនេះជ្រះថ្លា ជឿ ចុះចិត្តស៊ប់ ជឿមាំក្រែពេកថា សង្ខារទាំងពួងមិនទៀង ។បេ។ ខ្ញុំព្រះអង្គនេះជ្រះថ្លា ជឿ ចុះចិត្តស៊ប់ ជឿមាំក្រែពេកថា របស់ណាមានការកើតឡើងជាធម្មតា របស់នោះមានការរលត់ទៅវិញជាធម្មតា ហេតុនោះ ( លោកពោលថា ) ខ្ញុំព្រះអង្គនេះជ្រះថ្លាក្រែពេក ។

[ ២១៨ ] ពាក្យថា ព្រោះបានស្តាប់ព្រះបន្ទូលនៃព្រះអង្គជាព្រះមុនិ ត្រង់ពាក្យថា មុនិ សេចក្តីថា ញាណ លោកហៅថា មោនៈ បានដល់ បញ្ញា ការដឹងច្បាស់ ។បេ។ មុនិនោះ កន្លងនូវបណ្តាញ គឺកិលេសជាគ្រឿងជំពាក់ ។ ពាក្យថា ព្រោះបានស្តាប់ព្រះបន្ទូលនៃព្រះអង្គជាព្រះមុនិ បានសេចក្តីថា ព្រោះបានស្តាប់ ឮ រៀន ចងចាំទុក កំណត់ទុកនូវព្រះបន្ទូល គន្លងនៃព្រះបន្ទូល ទេសនាអនុសន្ធិនៃព្រះអង្គ ហេតុនោះ ( លោកពោលថា ) ព្រោះបានស្តាប់ព្រះបន្ទូលនៃព្រះអង្គជាព្រះមុនិ ។

[ ២១៩ ] ពាក្យថា ព្រះសម្ពុទ្ធទ្រង់មានគ្រឿងបិទបើកហើយ ត្រង់ពាក្យថាគ្រឿងបិទ បានដល់ គ្រឿងបិទ ៥ គឺ គ្រឿងបិទ គឺតណ្ហា គ្រឿងបិទ គឺទិដ្ឋិ គ្រឿងបិទ គឺកិលេស គ្រឿងបិទ គឺទុច្ចរិត គ្រឿងបិទ គឺអវិជ្ជា ។ គ្រឿងបិទទាំងនោះ ព្រះពុទ្ធមានព្រះភាគទ្រង់បើក គឺកម្ចាត់បង់ ដកឡើង លះបង់ ផ្តាច់ផ្តិល រម្ងាប់ គ្របសង្កត់ ធ្វើមិនគួរឲ្យកើតឡើងបាន ដុតដោយភ្លើង គឺ

ញាណហើយ ហេតុនោះ ព្រះពុទ្ធ ឈ្មោះថា មានគ្រឿងបិទបើកហើយ ។ ពាក្យថា ព្រះពុទ្ធ បានដល់ ព្រះមានព្រះភាគ ។បេ។ បញ្ញត្តថា ព្រះពុទ្ធនេះ កើតព្រោះការត្រាស់ដឹង ហេតុនោះ ( លោកពោលថា ) ព្រះសម្ពុទ្ធទ្រង់មាន គ្រឿងបិទបើកហើយ ។

[ ២២០ ] អធិប្បាយពាក្យថា ព្រះអង្គមិនមានគ្រឿងរឹងរូស ទ្រង់មាន បដិភាណ ត្រង់ពាក្យថា មិនមានគ្រឿងរឹងរូស សេចក្ដីថា រាគៈ ឈ្មោះថា គ្រឿងរឹងរូស ទោសៈ ឈ្មោះថា គ្រឿងរឹងរូស មោហៈ ឈ្មោះថា គ្រឿង រឹងរូស ក្រោធ ឈ្មោះថា គ្រឿងរឹងរូស ការចងគំនុំ ឈ្មោះថា គ្រឿងរឹងរូស ។បេ។ អកុសលាភិសង្ខារទាំងអស់ ឈ្មោះថា គ្រឿងរឹងរូស ។ គ្រឿងរឹងរូសទាំងនោះ ព្រះពុទ្ធមានជោគទ្រង់លះបង់ ផ្ដាច់ផ្ដិលឫសគល់ ធ្វើឲ្យសល់តែទីនៅដូចជា ទីនៅនៃដើមត្នោត ឲ្យដល់នូវការមិនកើតមាន ធ្វើឲ្យជាធម៌លែងកើតតទៅទៀត ហេតុនោះ ព្រះពុទ្ធ ឈ្មោះថា មិនមានគ្រឿងរឹងរូស ។ ពាក្យថា ទ្រង់មាន បដិភាណ បានដល់ បុគ្គលមានបដិភាណ ៣ ពួក គឺបុគ្គលមានបដិភាណ ព្រោះបរិយត្តិ ១ បុគ្គលមានបដិភាណព្រោះបរិបុច្ឆា ១ បុគ្គលមាន បដិភាណព្រោះអធិគម ១ ។

បុគ្គលមានបដិភាណព្រោះបរិយត្តិ តើដូចម្ដេច ។ បុគ្គលខ្លះក្នុងលោក នេះ រៀនពុទ្ធវចនៈ គឺសុត្តៈ គេយ្យៈ វេយ្យាករណៈ គាថា ឧទាន ឥតិវុត្តកៈ ជាតក អព្ភូតធម្មៈ វេទល្លៈ ពុទ្ធវចនៈនោះ រមែងភ្លឺច្បាស់ដល់បុគ្គលនោះ ព្រោះអាស្រ័យបរិយត្តិនេះ ឈ្មោះថា បុគ្គលមានបដិភាណ ព្រោះបរិយត្តិ ។

បុគ្គលមានបដិភាណព្រោះបរិបុច្ឆា តើដូចម្តេច ។ បុគ្គលខ្លះក្នុងលោកនេះ ជាអ្នកសាកសួរក្នុងអត្ថ ក្នុងធម៌គួរដឹង ក្នុងលក្ខណៈ ក្នុងហេតុ ក្នុងឋានៈនិងអដ្ឋានៈ សភាវៈមានអត្ថជាដើមនោះ រមែងភ្លឺច្បាស់ដល់បុគ្គលនោះ ព្រោះអាស្រ័យការសាកសួរ នេះឈ្មោះថា បុគ្គលមានបដិភាណ ព្រោះបរិបុច្ឆា ។

បុគ្គលមានបដិភាណព្រោះអធិគម តើដូចម្តេច ។ បុគ្គលខ្លះក្នុងលោកនេះ ត្រាស់ដឹងសតិប្បដ្ឋាន ៤ សម្មប្បធាន ៤ ឥទ្ធិបាទ ៤ ឥន្ទ្រិយ ៥ ពល ៥ ពោជ្ឈង្គ ៧ អដ្ឋង្គិកមគ្គដ៏ប្រសើរ អរិយមគ្គ ៤ សាមញ្ញផល ៤ បដិសម្ភិទា ៤ អភិញ្ញា ៦ បុគ្គលនោះដឹងអត្ថ ដឹងធម៌ ដឹងនិរុត្តិ កាលបុគ្គលដឹងអត្ថហើយ អត្ថក៏ភ្លឺច្បាស់ កាលបុគ្គលដឹងធម៌ហើយ ធម៌ក៏ភ្លឺច្បាស់ កាលបុគ្គលដឹងនិរុត្តិហើយ និរុត្តិក៏ភ្លឺច្បាស់ ការដឹងក្នុងធម៌ទាំង ៣ នេះ ឈ្មោះថា បដិភាណប្បដិសម្ភិទា ។ ព្រះមានព្រះភាគ ទ្រង់ប្រកបហើយ ប្រកបព្រម ចូលទៅជិតដល់ ចូលទៅជិតដល់ព្រម ចូលទៅជិតសម្រេច ចូលទៅជិតសម្រេចព្រម រួបរួម ដោយបដិសម្ភិទានេះ ហេតុនោះ ព្រះពុទ្ធ ឈ្មោះថា ទ្រង់មានបដិភាណ ។ បុគ្គលណាពុំមានបរិយត្តិ ពុំមានបរិបុច្ឆា ពុំមានអធិគមទេ អ្វីនឹងភ្លឺច្បាស់ដល់បុគ្គលនោះ ហេតុនោះ ( លោកពោលថា ) ព្រះអង្គមិនមានគ្រឿងរឹងរូស ទ្រង់មានបដិភាណ ។ ហេតុនោះ ព្រះបិង្គិយត្ថេរពោលថា

ខ្ញុំព្រះអង្គនេះជ្រះថ្លាក្រៃពេក ព្រោះបានស្តាប់ព្រះបន្ទូល នៃព្រះអង្គ
ជាព្រះមុនិ ព្រះសម្ពុទ្ធទ្រង់មានគ្រឿងបិទ បើកហើយ ព្រះអង្គមិន
មានគ្រឿងរឹងរូស ទ្រង់មានបដិភាណ ។

[ ២២១ ] ព្រះសាស្តា ទ្រង់ជ្រាបច្បាស់ នូវអធិទេវតាទាំងឡាយ ទ្រង់ជ្រាបនូវធម្មជាតទាំងអស់ ដែលថោកទាប និងប្រសើរ ទ្រង់ធ្វើទីបំផុតនៃប្រស្នាទាំងឡាយ ដល់ពួកជនអ្នកសង្ស័យ ដែលប្ញ្ជា ( ថា អស់សង្ស័យ ) ។

[ ២២២ ] អធិប្បាយពាក្យថា ទ្រង់ជ្រាបច្បាស់ នូវអធិទេវតាទាំងឡាយ ត្រង់ពាក្យថា ទេវតាទាំងឡាយ បានដល់ ទេវតា ៣ ពួក គឺពួកសម្មតិទេវតា ១ ឧបបត្តិទេវតា ១ វិសុទ្ធិទេវតា ១ ។

សម្មតិទេវតា តើដូចម្តេច ។ ព្រះរាជា ព្រះរាជកុមារ និងព្រះរាជទេវី ទាំងនេះ ហៅថា សម្មតិទេវតា ។ ឧបបត្តិទេវតា តើដូចម្តេច ។ ពួកទេវតាជាន់ចាតុម្មហារាជិកៈ ពួកទេវតាជាន់តាវត្តិង្ស ។បេ។ ពួកទេវតាជាន់ព្រហ្មកាយិកៈ និងពួកទេវតាជាន់ខាងលើអំពីនោះ ទាំងនេះហៅថា ឧបបត្តិទេវតា ។

វិសុទ្ធិទេវតា តើដូចម្តេច ។ ព្រះអរហន្តខីណាស្រេព ជាសាវករបស់តថាគត និងព្រះបច្ចេកសម្ពុទ្ធ ទាំងនេះហៅថា វិសុទ្ធិទេវតា ។ ព្រះមានព្រះភាគជ្រាបច្បាស់ នូវសម្មតិទេវតាទាំងឡាយថា ជាអធិទេវតា ទ្រង់ជ្រាបច្បាស់នូវពួកឧបបត្តិទេវតា ថាជាអធិទេវតា ទ្រង់ជ្រាបច្បាស់ ទ្រង់យល់ ទ្រង់ថ្លឹង ទ្រង់ត្រិះរិះ ទ្រង់ជាក់ច្បាស់ ទ្រង់ធ្វើឲ្យប្រាកដ នូវពួកវិសុទ្ធិទេវតាថា ជាអធិទេវតា ហេតុនោះ ( លោកពោលថា ) ទ្រង់ជ្រាបច្បាស់នូវអធិទេវតាទាំងឡាយ ។

[ ២២៣ ] ពាក្យថា ទ្រង់ជ្រាបច្បាស់ធម្មជាតទាំងអស់ ដ៏ថោកទាប និងប្រសើរ អធិប្បាយថា ព្រះមានព្រះភាគទ្រង់ជ្រាបច្បាស់ ទ្រង់យល់ ទ្រង់

ប៉ះពាល់ ទ្រង់ចាក់ធ្លុះនូវពួកធម៌ ដែលធ្វើព្រះអង្គ និងបុគ្គលដទៃឲ្យជាអធិទេវតា ។ ពួកធម៌ដែលធ្វើព្រះអង្គឲ្យជាអធិទេវតា តើដូចម្តេច ។ សេចក្តីប្រតិបត្តិដោយប្រពៃ សេចក្តីប្រតិបត្តិបណ្តោយតាម សេចក្តីប្រតិបត្តិមិនទំនាស់ សេចក្តីប្រតិបត្តិធម៌ ដ៏សមគួរដល់ធម៌ ការធ្វើបំពេញក្នុងសីល ការគ្រប់គ្រងទ្វារក្នុងឥន្ទ្រិយ ការដឹងប្រមាណក្នុងភោជន ការប្រកបរឿយៗ នូវសេចក្តីភ្ញាក់រឭក សតិ សម្បជញ្ញៈ សតិប្បដ្ឋាន ៤ ។បេ។ អដ្ឋង្គិកមគ្គដ៏ប្រសើរ ទាំងនេះហៅថា ធម៌ដែលធ្វើព្រះអង្គឲ្យជាអធិទេវតា ។ ធម៌ធ្វើបុគ្គលដទៃឲ្យជាអធិទេវតា តើដូចម្តេច ។ សេចក្តីប្រតិបត្តិដោយប្រពៃ ។បេ។ អដ្ឋង្គិកមគ្គដ៏ប្រសើរ ទាំងនេះហៅថា ធម៌ធ្វើបុគ្គលដទៃឲ្យជាអធិទេវតា ។ ព្រះមានព្រះភាគទ្រង់ជ្រាប ទ្រង់យល់ ទ្រង់ប៉ះពាល់ ទ្រង់ចាក់ធ្លុះនូវធម៌ដែលធ្វើព្រះអង្គ និងបុគ្គលដទៃឲ្យជាអធិទេវតា ហេតុនោះ ( លោកពោលថា ) ទ្រង់ជ្រាបធម្មជាតទាំងអស់ ដ៏ថោកទាប និងប្រសើរ ។

[ ២២៤ ] ពាក្យថា ព្រះសាស្តា ទ្រង់ធ្វើទីបំផុតនៃប្រស្នា អធិប្បាយថា ព្រះមានព្រះភាគ ទ្រង់ធ្វើទីបំផុត ធ្វើទីបំផុតជុំវិញ ធ្វើការកំណត់ ធ្វើផ្លូវជុំវិញនៃបារាយនិកបញ្ហា ទ្រង់ធ្វើទីបំផុត ធ្វើទីបំផុតជុំវិញ ធ្វើការកំណត់ ធ្វើផ្លូវជុំវិញនៃបរិសបញ្ហា ទ្រង់ធ្វើទីបំផុត ធ្វើទីបំផុតជុំវិញ ធ្វើការកំណត់ ធ្វើផ្លូវជុំវិញ នៃបិង្គិយបញ្ហា ទ្រង់ធ្វើទីបំផុត ធ្វើទីបំផុតជុំវិញ ធ្វើការកំណត់ ធ្វើផ្លូវជុំវិញ នៃសក្កបញ្ហា អមនុស្សបញ្ហា ភិក្ខុបញ្ហា ភិក្ខុនីបញ្ហា ឧបាសកបញ្ហា ឧបាសិកាបញ្ហា រាជបញ្ហា ខត្តិយបញ្ហា ព្រាហ្មណបញ្ហា វេស្សបញ្ហា សុទ្ទបញ្ហា

ព្រហ្មប្បញ្ហា ហេតុនោះ ( លោកពោលថា ) ទ្រង់ធ្វើនូវទីបំផុតនៃបញ្ហាទាំងឡាយ ។ ពាក្យថា ព្រះសាស្តា បានន័យថា ព្រះមានព្រះភាគ ទ្រង់ជាអ្នកនាំពួក ។ អ្នកនាំពួក ញ៉ាំងពួកឲ្យឆ្លងផ្លូវលំបាក គឺឲ្យឆ្លងផ្លូវលំបាក គឺចោរ ឲ្យឆ្លងផ្លូវលំបាក គឺសត្វសាហាវ ឲ្យឆ្លងផ្លូវលំបាក គឺទុរ្ភិក្ស ឲ្យឆ្លង ឲ្យឆ្លងឡើង ឲ្យឆ្លងចេញអំពីផ្លូវលំបាក គឺមិនមានទឹក ឲ្យដល់ខេមន្តភូមិ យ៉ាងណា ព្រះមានព្រះភាគ ទ្រង់ជាអ្នកនាំពួក ញ៉ាំងសត្វឲ្យឆ្លងនូវផ្លូវលំបាក គឺឲ្យឆ្លងផ្លូវលំបាក គឺជាតិ ជរា ព្យាធិ មរណៈ សោក បរិទេវៈ ទុក្ខ ទោមនស្ស និងឧបាយាស ឲ្យឆ្លងផ្លូវលំបាក គឺរាគៈ ឲ្យឆ្លងផ្លូវលំបាក គឺទោសៈ មោហៈ មានះ ទិដ្ឋិ កិលេស ទុច្ចរិត ឲ្យឆ្លងព្រៃស្បាត គឺរាគៈ ឲ្យឆ្លងព្រៃស្បាត គឺទោសៈ ឲ្យឆ្លងព្រៃស្បាត គឺមោហៈ ឲ្យឆ្លង ឲ្យឆ្លងឡើង ឲ្យឆ្លងចេញអំពីព្រៃស្បាត គឺទិដ្ឋិ កិលេស និងទុច្ចរិត ឲ្យដល់ខេមន្តភូមិ គឺអមតនិព្វានក៏យ៉ាងនោះដែរ ហេតុនោះ ព្រះមានព្រះភាគ ឈ្មោះថា ជាអ្នកនាំពួកយ៉ាងនេះ ។ មួយទៀត ព្រះមានព្រះភាគ ទ្រង់នាំ ទូន្មាន ទូន្មានរឿយៗ ទ្រង់ឲ្យយល់ ឲ្យចូលចិត្ត ឲ្យឃើញ ឲ្យជ្រះថ្លា ហេតុនោះ ព្រះមានព្រះភាគ ឈ្មោះថា ជាអ្នកនាំពួកយ៉ាងនេះក៏បាន ។ ឬថា ព្រះមានព្រះភាគទ្រង់ញ៉ាំងមគ្គ ដែលមិនទាន់កើតឲ្យកើតបាន ញ៉ាំងមគ្គដែលមិនទាន់កកើត ឲ្យកកើតបាន ទ្រង់ប្រាប់មគ្គ ដែលគេមិនទាន់ប្រាប់ ទ្រង់ជ្រាបមគ្គ ទ្រង់ស្គាល់មគ្គ ទ្រង់ឈ្លាសក្នុងមគ្គ ចំណែកខាងពួកសាវក ក្នុងកាលឥឡូវនេះ ជាអ្នកដើរទៅតាមមគ្គ ជាអ្នកប្រកបក្នុងកាលខាងក្រោយ ហេតុនោះ ព្រះមានព្រះភាគ ឈ្មោះថា ជាអ្នក

នាំពួក យ៉ាងនេះក៏បាន ហេតុនោះ ( លោកពោលថា ) ព្រះសាស្តា ទ្រង់ធ្វើទីបំផុតនៃប្រស្នាទាំងឡាយ ។

[ ២២៥ ] ពាក្យថា ដល់ពួកជនអ្នកសង្ស័យ ដែលប្ញដ្ឋា ( ថាជាអ្នកអស់សង្ស័យ ) អធិប្បាយថា ជនទាំងឡាយ ដែលមានសេចក្តីងឿងឆ្ងល់ មកសម្រេចថា ជាអ្នកមិនមានសេចក្តីងឿងឆ្ងល់ អ្នកដែលមានចិត្តរសេមរសាមមកសម្រេចថា ជាអ្នកមានចិត្តមិនរសេមរសាម អ្នកដែលមានចិត្តបែកជាពីរមកសម្រេចថា ជាអ្នកមានចិត្តមិនបែកជាពីរ អ្នកដែលមានសេចក្តីស្ទាក់ស្ទើរមកសម្រេចថា ជាអ្នកមិនមានសេចក្តីស្ទាក់ស្ទើរ អ្នកដែលមានរាគៈ មកសម្រេចថា ជាអ្នកមិនមានរាគៈ អ្នកដែលមានទោសៈ មកសម្រេចថា ជាអ្នកមិនមានទោសៈ អ្នកដែលមានមោហៈ មកសម្រេចថា ជាអ្នកមិនមានមោហៈ អ្នកដែលមានកិលេស មកសម្រេចថា ជាអ្នកមិនមានកិលេស ហេតុនោះ ( លោកពោលថា ) ដល់ពួកជនអ្នកសង្ស័យ ដែលប្ញដ្ឋា ( ថាជាអ្នកអស់សង្ស័យ ) ។ ហេតុនោះ ព្រះបិង្គិយត្ថេរពោលថា

ព្រះសាស្តាទ្រង់ជ្រាបច្បាស់ នូវអធិទេវតាទាំងឡាយ ទ្រង់ជ្រាបនូវធម្មជាតទាំងអស់ ដែលថោកទាប និងប្រសើរ ទ្រង់ធ្វើទីបំផុតនៃប្រស្នាទាំងឡាយ ដល់ពួកជនអ្នកសង្ស័យ ដែលប្ញដ្ឋា ( ថាជាអ្នកអស់សង្ស័យ ) ។

[ ២២៦ ] ទីណា ដែលកិលេសនាំទៅមិនបាន ដែលមិនកម្រើកមួយទៀត ទីណាដែលមិនមានឧបមា ក្នុងឋានណាមួយ ខ្ញុំនឹងទៅ

កាន់ទីនោះដោយពិត ខ្ញុំមិនមានសេចក្ដីងឿងឆ្ងល់ ក្នុងទីនោះទេ សូមព្រះអង្គចាំទុក នូវខ្ញុំព្រះអង្គថា ជាអ្នកមានចិត្តចុះស៊ប់ហើយ យ៉ាងនេះចុះ ។

[ ២២៧ ] ពាក្យថា ទីណា ដែលកិលេសនាំទៅមិនបាន ដែលមិនកម្រើក អធិប្បាយថា អមតនិព្វាន ហៅថា ទីដែលកិលេសនាំទៅមិនបាន បានដល់ការរម្ងាប់សង្ខារទាំងពួង ការរលាស់ចោលឧបធិទាំងពួង ការអស់តណ្ហា ការប្រាសចាករាគៈ សេចក្ដីរលត់ទុក្ខ និព្វាន ។ ត្រង់ពាក្យថា ដែលកិលេសនាំទៅមិនបាន គឺដែលរាគៈ ទោសៈ មោហៈ កោធៈ ឧបនាហៈ មក្ខៈ បឡាសៈ ឥស្សា មច្ឆរិយៈ មាយា សាឋេយ្យៈ ថម្ភៈ សារម្ភៈ មានះ អតិមានះ មទៈ បមាទៈ កិលេសទាំងពួង ទុច្ចរិតទាំងពួង សេចក្ដីក្ដៅក្រហាយទាំងពួង សេចក្ដីអន្ទះអន្ទែងទាំងពួង អកុសលាភិសង្ខារទាំងពួងនាំទៅមិនបាន គឺថា ជាទីទៀងទៀងទាត់ ពិតប្រាកដ មិនប្រែប្រួលជាធម្មតា ហេតុនោះ ( លោកពោលថា ) ដែលកិលេសនាំទៅមិនបាន ។ ត្រង់ពាក្យថា មិនកម្រើក សេចក្ដីថា អមតនិព្វាន ហៅថា ទីមិនកម្រើក បានដល់ការរម្ងាប់សង្ខារទាំងពួង ការរលាស់ ចោលឧបធិទាំងពួង ការអស់តណ្ហា ការប្រាសចាករាគៈ សេចក្ដីរលត់ និព្វាន ។ ការកើតឡើងនៃធម្មជាតណា ប្រាកដ ការវិនាសនៃធម្មជាតណា មិនមានការពិតនៃធម្មជាតនោះ ក៏រមែងប្រាកដ គឺថា ព្រះនិព្វាន ទៀង ជាធម្មជាតទៀងទាត់ ពិតប្រាកដ មិនប្រែប្រួលជាធម្មតា ហេតុនោះ ( លោកពោលថា ) ទីណា ដែលកិលេសនាំទៅមិនបាន ដែលមិនកម្រើក ។

[ ២២៨ ] អធិប្បាយពាក្យថា ទីណាដែលមិនមានឧបមា ក្នុងឋាន ណាមួយ ត្រង់ពាក្យថា ទីណា បានដល់ និព្វាន ។ ពាក្យថា មិនមានឧបមា គឺមិនមានសេចក្តីប្រៀបផ្ទឹម មិនមានការប្រៀបធៀប មិនមានភាពស្មើគ្នា មិន មាន មិនមានព្រម មិនបានទូវចំណែកប្រៀប ហេតុនោះ ( លោកពោលថា ) មិនមានឧបមា ។ ពាក្យថា ក្នុងឋានណាមួយ គឺក្នុងទីណាមួយ ក្នុងទីដូចម្តេច ក្នុងទីណា ជាខាងក្នុង ឬខាងក្រៅ ឬទាំងខាងក្នុង ទាំងខាងក្រៅ ហេតុនោះ ( លោកពោលថា ) ទីណាដែលមិនមានឧបមា ក្នុងឋានណាមួយ ។

[ ២២៩ ] អធិប្បាយពាក្យថា ខ្ញុំនឹងទៅកាន់ទីនោះដោយពិត ខ្ញុំមិនមាន សេចក្តីងឿងឆ្ងល់ក្នុងទីនោះទេ ត្រង់ពាក្យថា ខ្ញុំនឹងទៅដោយពិត គឺខ្ញុំនឹងដើរ ទៅ នឹងបាន នឹងពាល់ត្រូវ នឹងធ្វើឲ្យជាក់ច្បាស់ដោយពិត ហេតុនោះ ( លោក ពោលថា ) ខ្ញុំនឹងទៅដោយពិត ។ ពាក្យថា ខ្ញុំមិនមានសេចក្តីងឿងឆ្ងល់ ក្នុង ទីនោះទេ គឺសេចក្តីងឿងឆ្ងល់មិនមាន ការស្ទាក់ស្ទើរមិនមាន ការគិតបែកជា ពីរមិនមាន ការសង្ស័យមិនមាន មិនមានព្រម មិនកើតមានក្នុងនិព្វាននោះទេ គឺថា ខ្ញុំលះបង់ ផ្តាច់ផ្តិល រម្ងាប់ គ្របសង្កត់ ធ្វើមិនគួរឲ្យកើតឡើងបាន ដុត ដោយភ្លើង គឺញាណហើយ ហេតុនោះ ( លោកពោលថា ) ខ្ញុំនឹងទៅកាន់ទី នោះដោយពិត ខ្ញុំមិនមានសេចក្តីងឿងឆ្ងល់ ក្នុងទីនោះទេ ។

[ ២៣០ ] ពាក្យថា សូមព្រះអង្គចាំទុកនូវខ្ញុំព្រះអង្គ ថាជាអ្នកមានចិត្ត ចុះស៊ប់ហើយយ៉ាងនេះចុះ ត្រង់ពាក្យថា សូមព្រះអង្គចាំទុក នូវខ្ញុំព្រះអង្គយ៉ាង នេះ គឺសូមព្រះអង្គកំណត់ទុក នូវខ្ញុំព្រះអង្គយ៉ាងនេះ ។ ពាក្យថា មានចិត្តចុះ

ស៊ប់ហើយ គឺមានចិត្តទេរទៅរកព្រះនិព្វាន ទោរទៅរកព្រះនិព្វាន ឈមទៅរក ព្រះនិព្វាន ឱនទៅរកព្រះនិព្វាន ហេតុនោះ ( លោកពោលថា ) សូមព្រះអង្គ ចាំទុកនូវខ្ញុំព្រះអង្គ ថាជាអ្នកមានចិត្តចុះស៊ប់ហើយ យ៉ាងនេះចុះ ។ ហេតុនោះ ព្រះបិង្គិយត្ថេរពោលថា

ទីណា ដែលកិលេសនាំទៅមិនបាន ដែលមិនកម្រើក មួយទៀត
ទីណាដែលមិនមានឧបមា ក្នុងឋានណាមួយ ខ្ញុំនឹងទៅកាន់ទីនោះ
ដោយពិត ខ្ញុំមិនមានសេចក្តីងឿងឆ្ងល់ ក្នុងទីនោះទេ សូមព្រះអង្គ
ចាំទុកនូវខ្ញុំព្រះអង្គ ថាជាអ្នកមានចិត្តចុះស៊ប់ហើយ យ៉ាងនេះចុះ ។

បារាយនវគ្គ ចប់

# អដ្ឋកថា
# បារាយនត្ថុតិគាថានិទ្ទេស

[ ១០០ ] បន្ទាប់ពីនេះទៅ ព្រះសង្គីតិកាចារ្យកាលសរសើរទេសនា ទើបពោលថា **ឥទមវោច ភគវា** ដូច្នេះជាដើម ។ ក្នុងបទទាំងនោះ បទថា **ឥទមវោច** បានដល់ ព្រះមានព្រះភាគបានត្រាស់បារាយនសូត្រនេះហើយ ។ បទថា **បរិចារិកសោឡសន្នំ** បានដល់ ព្រាហ្មណ៍ ១៦ នាក់ មួយអន្លើដោយបិង្គិយៈ ដែលជាបរិវាររបស់ពាវរីព្រាហ្មណ៍ ឬព្រាហ្មណ៍ ១៦ នាក់ ជាបរិវាររបស់ព្រះមានព្រះភាគ ដែលជាពុទ្ធៈ គឺព្រាហ្មណ៍ ១៦ នាក់ ដែលបរិចារិកា ។ ព្រាហ្មណ៍ទាំងនោះឯង ។ ក្នុងទីនោះ បរិស័ទ ១៦ គណៈ អង្គុយខាងមុខ ខាងក្រោយ ខាងឆ្វេង ខាងស្តាំ ៦ យោជន៍ៗ ទាំងសងខាង ជា ១២ យោជន៍ ។ បទថា **អជ្ឈិដ្ឋោ** បានដល់ ទូលអង្វរ ។

[ ១០៥ ] បទថា **អត្ថមញ្ញាយ** បានដល់ ដឹងទូទៅដល់អត្ថ គឺដឹងទូទៅដល់អត្ថនៃបាលី ។ បទថា **ធម្មមញ្ញាយ** បានដល់ ដឹង ដឹងទូទៅដល់ធម៌ គឺបាលី ។

[ ១១៣ ] ព្រះសង្គីតិកាចារ្យកាលលើកឈ្មោះរបស់ធម្មបរិយាយនេះយ៉ាងនេះថា បារាយនៈហើយ កាលប្រារព្ធឈ្មោះរបស់ព្រាហ្មណ៍ទាំងនោះ ទើបពោលថា **អជិតោ ។បេ។ ពុទ្ធសេដ្ឋមុបាគមុំ** ដូច្នេះ ។

ក្នុងបទទាំងនោះ បទថា **សម្បន្នចរណំ** បានដល់ ដល់ព្រមហើយដោយបាតិមោក្ខសីលជាដើម ដែលជាបទដ្ឋាននៃនិព្វាន ។ បទថា **ឥសឹ** បានដល់ ជាអ្នកស្វែងរកគុណធំក្រៃលែង ។

[ ១១៤ ] គប្បីជ្រាបវិនិច្ឆ័យក្នុងនិទ្ទេសដូចតទៅ បទថា **ឧបាគមីសុ** បានដល់ ចូលទៅជិត ។ បទថា **ឧបសង្កមីសុ** បានដល់ ចូលទៅកាន់ទីមិនឆ្ងាយ ។ បទថា **បយិរុបាសីសុ** បានដល់ អង្គុយក្នុងទីជិត ។ បទថា **បរិបុច្ឆីសុ** បានដល់ តាំងពាក្យសួរហើយ ។ បទថា **បរិបញ្ហីសុ** បានដល់ ពិចារណាហើយ ។ អាចារ្យពួកខ្លះពោលថា **ចោទយីសុ** គឺសាកសួរ ។

[ ១១៥ ] បទថា **សីលាចារនិប្ផត្តិ** បានដល់ ការសម្រេចនៃសីលនិងអាចារដ៏ឧត្តម អធិប្បាយថា សីលសម្រេចដោយមគ្គ ។

[ ១១៦ ] បទថា **គម្ភីរេ** ជាពាក្យបដិសេធភាពជាប្រស្នារាក់ ។ បទថា **ទុទ្ទសេ** បានដល់ ឈ្មោះថា **ទុទ្ទសេ** ព្រោះឃើញបានដោយក្រ មិនអាចឃើញបានដោយងាយ ។ បទថា **ទុរនុពោធេ** បានដល់ ឈ្មោះថា **ទុរនុពោធេ** ព្រោះដឹងបានដោយក្រ មិនអាចដឹងបានដោយងាយ ។ បទថា **សន្តេ** បានដល់ រម្ងត់ ។ បទថា **បណីតេ** បានដល់ ប្រសើរ ពាក្យទាំង ២ នេះលោកពោលសំដៅដល់លោកុត្តរធម៌ប៉ុណ្ណោះ ។ បទថា **អតក្កាវចរេ** សេចក្តីថា មិនគប្បីឈមចុះ គឺគប្បីកាន់យកដោយការត្រិះរិះ បានដល់ គប្បីឈមចុះបានដោយញាណប៉ុណ្ណោះ ។ បទថា **និបុណេ** បានដល់ ល្អិត ។ បទថា **បណ្ឌិតវេទនីយេ** បានដល់ ដែលបណ្ឌិតបដិបត្តិប្រពៃ គប្បីដឹងបាន ។

[ ១២២ ] បទថា **តោសេសិ** បានដល់ ឲ្យដល់នូវការត្រេកអរ ។ បទថា **វិតោសេសិ** បានដល់ ឲ្យកើតសោមនស្សច្រើនយ៉ាង ។ បទថា **បសាទេសិ** បានដល់ ធ្វើឲ្យព្រាហ្មណ៍ទាំងនោះមានចិត្តជ្រះថ្លា ។ បទថា **អារាធេសិ** បាន

*ដល់ ឲ្យត្រេកអរ ឲ្យដល់សេចក្តីសម្រេច ។ បទថា* **អត្តមនេ អការសិ** *បានដល់ ធ្វើឲ្យត្រេកអរដោយសោមនស្ស ។*

*[ ១២៣ ] តទៅនេះ បទថា* **ព្រហ្មចរិយមចរីសុ** *បានដល់ បានប្រព្រឹត្តមគ្គព្រហ្មចរិយៈ ។*

*[ ១៣៣ ] បទថា* **តស្មា ធោវយនំ** *មានពាក្យអធិប្បាយថា ជាផ្លូវសម្រេចដល់និព្វានដែលជាត្រើយនាយ ។៙*

**អដ្ឋកថា ធោវយនត្ថុតិគាថានិទ្ទេស ចប់**

# អដ្ឋកថា

## ធោតកមាណវកបញ្ហានិទ្ទេស

[ ១៣៨ ] បទថា **ធោតកមាណវកបញ្ហា** នេះ គប្បីជ្រាបសម្ពន្ធ ដូចតទៅនេះ កាលព្រះមានព្រះភាគ ទ្រង់សម្ដែងបារាយនសូត្រហើយ ជដិល ១៦០០០ នាក់ បានសម្រេចអរហត្ត ទេវតា និងមនុស្ស ១៤ កោដិដ៏សេស បានសម្រេចធម៌ សមដូចបុរាណាចារ្យពោលថា

កាលនោះ ព្រះពុទ្ធទ្រង់ញ៉ាំងទេវតា និងមនុស្ស ១៤ កោដិ ឲ្យ
សម្រេចអមតធម៌ ក្នុងបារាយនសមាគម ត្រង់បាសាណកចេតិយ
គួរជាទីត្រេកអរ ។

កាលចប់ព្រះធម្មទេសនា ពួកមនុស្សមកអំពីទីនោះៗ បានប្រាកដក្នុងគាម និងនិគមជាដើមរៀងៗ ខ្លួននោះឯង ដោយអានុភាពនៃព្រះមានព្រះភាគ ។ សូម្បីព្រះមានព្រះភាគ កាលភិក្ខុច្រើនពាន់ មានភិក្ខុ ១៦០០០ រូប ជាបរិវារជាដើមចោមរោមហើយ ក៏បានយាងទៅកាន់នគរសាវត្ថី ។ ក្នុងទីនោះ ព្រះបិង្គិយៈថ្វាយបង្គំព្រះមានព្រះភាគ ហើយក្រាបទូលថា បពិត្រព្រះអង្គដ៏ចម្រើន ខ្ញុំព្រះអង្គនឹងទៅប្រាប់ពាវរីព្រាហ្មណ៍ ដល់ការកើតឡើងនៃព្រះពុទ្ធ ព្រោះខ្ញុំព្រះអង្គបានប្ដេជ្ញាដល់ពាវរីព្រាហ្មណ៍នោះ ។ លំដាប់នោះ បិង្គិយៈបានទទួលអនុញ្ញាតអំពីព្រះមានព្រះភាគ ហើយបានទៅដល់ឆ្នេរស្ទឹងគោធាវរី ដោយយានពាហនៈហើយ ទើបដើរទៅដោយជើង តម្រង់ទៅកាន់អាស្រម ។ ពាវរីអង្គុយសម្លឹងមើលផ្លូវ ឃើញបិង្គិយៈ ប្រាសចាកអម្រែក និងជដា និមន្តមកដោយភេទជាភិក្ខុ ក៏សន្និដ្ឋានថា ព្រះពុទ្ធទ្រង់កើតហើយក្នុងលោក ទើបសួរ

*ព្រះបិង្គិយៈដែលមកដល់ហើយថា បិង្គិយៈ ព្រះពុទ្ធទ្រង់កើតឡើងហើយក្នុងលោកឬ ។ ព្រះបិង្គិយៈ ឆ្លើយថា ត្រូវហើយ ព្រាហ្មណ៍ ព្រះពុទ្ធទ្រង់កើតឡើងហើយ ទ្រង់គង់សម្តែងធម៌ដល់ពួកអាត្មាត្រង់បាសាណកចេតិយ អាត្មានឹងសម្តែងធម៌នោះដល់លោក ។ លំដាប់នោះ ពាវរីព្រាហ្មណ៍មួយអន្លើដោយបរិស័ទ បូជាព្រះបិង្គិយៈដោយសក្ការៈដ៏ធំ ហើយក្រាលអាសនៈ ។ ព្រះបិង្គិយៈអង្គុយលើអាសនៈនោះហើយ ពោលពាក្យថា* **ឧបាយនមនុគាយិស្សំ** *ដូច្នេះជាដើម ។*

*ក្នុងបទទាំងនោះ បទថា* **អនុគាយិស្សំ** *បានដល់ អាត្មានឹងច្រៀងតាមចម្រៀងដែលព្រះមានព្រះភាគទ្រង់បានសម្តែង ។ បទថា* **យថា អទ្ទក្ខិ** *បានដល់ ទ្រង់ឃើញឯង ដោយការត្រាស់ដឹងសច្ចៈ និងដោយញាណ ដែលមិនទូទៅ ។ បទថា* **និក្កាមោ** *បានដល់ លះកាមបានហើយ ។ បាឋៈថា* **និក្ខមោ** *ដូច្នេះក៏មាន ។ អធិប្បាយថា មានសេចក្តីព្យាយាម ឬចេញចាកធម៌ដែលជាចំណែកអកុសល ។ បទថា* **និព្វនោ** *បានដល់ ប្រាសចាកព្រៃ គឺកិលេស ឬប្រាសចាកតណ្ហានោះឯង ។ បទថា* **កិស្ស ហេតុ មុសា ភណេ** *ព្រះបិង្គិយៈសម្តែងថា ព្រះមានព្រះភាគគប្បីពោលកុហកដោយកិលេសពួកណា ព្រះមានព្រះភាគអង្គនោះ ទ្រង់លះកិលេសទាំងនោះបានហើយ ។ ព្រះបិង្គិយៈញុំាងឧស្សាហៈក្នុងការស្តាប់ឲ្យកើត ដល់ព្រាហ្មណ៍ដោយបទនេះ ។*

[ ១៤១ ] *បទថា* **អមលោ** *បានដល់ ប្រាសចាកមន្ទិល គឺកិលេស ។ បទថា* **វិមលោ** *បានដល់ មានមន្ទិល គឺកិលេសអស់ទៅ ។ បទថា*

**ធិម្មលោ** បានដល់ បរិសុទ្ធចាកមន្ទិល គឺកិលេស ។ បទថា **មលាបគតោ** បានដល់ ជាអ្នកប្រព្រឹត្តឆ្ងាយចាកមន្ទិល គឺកិលេស ។ បទថា **មលវិប្ប-ហីនោ** បានដល់ លះនូវមន្ទិល គឺកិលេស ។ បទថា **មលវិប្បមុត្តោ** បានដល់ ផុតហើយចាកកិលេសទាំងឡាយ ។ បទថា **សព្វមលវីតិវត្តោ** បានដល់ កន្លងនូវមន្ទិល គឺកិលេសទាំងពួង មានរាគសនាជាដើមបានហើយ ។

[ ១៤២ ] បទថា **តេ វតា** បានដល់ កិលេស ដូចបានពោលហើយនោះ ។

[ ១៤៤ ] បទថា **វណ្ណូបសញ្ហិតំ** បានដល់ ប្រកបដោយគុណ ។

[ ១៤៨ ] បទថា **សច្ចវ្ហយោ** បានដល់ ប្រកបដោយព្រះនាមពិតដែលហៅថា **ពុទ្ធោ** ដូច្នេះ ។ ព្រះបិង្គិយៈហៅព្រាហ្មណ៍នោះដោយពាក្យថា **ព្រហ្មេ** ។

[ ១៥០ ] ក្នុងបទទាំងនោះ បទថា **លោកោ** ឈ្មោះថា លោក ព្រោះអត្ថថា បែកធ្លាយទៅ ។ បទថា **ឯកោ លោកោ ភវលោកោ** បានដល់ វិបាកដែលប្រព្រឹត្តទៅក្នុងភូមិ ៣ ។ វិបាកដែលប្រព្រឹត្តទៅក្នុងភូមិ ៣ នោះ ឈ្មោះថា **ភព** ព្រោះអត្ថថា កើតមាន ។ លោក គឺភព ឈ្មោះថា **ភវលោក** ។ ក្នុងបទថា **ភវលោកោ ច សម្ភវលោកោ ច** នេះ លោកនីមួយៗ មានពីរៗ ។ ភវលោកមាន ២ យ៉ាង គឺសម្បត្តិភវលោក និងវិបត្តិភវលោក ។ សម្ភវលោកមាន ២ យ៉ាង គឺសម្បត្តិសម្ភវលោក និងវិបត្តិសម្ភវលោក ។ ក្នុងលោកទាំងនោះ ពាក្យថា **សម្បត្តិភវលោក** បាន

ដល់ សុគតិលោក ។ ពិតហើយ សុគតិនោះ ជាលោកដែលស្អាត ព្រោះមានផលជាទីប្រាថ្នា ព្រោះហេតុនោះ ទើបឈ្មោះថា **សម្បត្តិ** ។ ឈ្មោះថា **ភព** ព្រោះអត្ថថា កើតមាន ។ ភព គឺសម្បត្តិនោះឯង ឈ្មោះថា **សម្បត្តិភព** ។ លោក គឺសម្បត្តិភពនោះឯង ឈ្មោះថា **សម្បត្តិភវលោក** ។ ពាក្យថា **សម្បត្តិសម្ភវលោក** បានដល់ កម្មដែលឲ្យចូលដល់សុគតិ ។ កម្មដែលឲ្យចូលដល់សុគតិនោះ ឈ្មោះថា **សម្ភវ** ព្រោះជាដែនកើតនៃផល ។ ការសម្ភពនៃសម្បត្តិ ឈ្មោះថា **សម្បត្តិសម្ភវ** ។ លោក គឺសម្បត្តិសម្ភវ ឈ្មោះថា **សម្បត្តិសម្ភវលោក** ។

បទថា **វិបត្តិភវលោក** បានដល់ អបាយលោក ។ ពិតហើយ អបាយលោកនោះ ជាលោកដែលគួរខ្ពើម ព្រោះមានផលមិនគួរប្រាថ្នា ព្រោះហេតុនោះ ទើបឈ្មោះថា **វិបត្តិ** ។ ឈ្មោះថា **ភព** ព្រោះអត្ថថា កើតមាន ។ ភព គឺវិបត្តិ ឈ្មោះថា **វិបត្តិភព** ។ លោក គឺវិបត្តិភព ឈ្មោះថា **វិបត្តិភវលោក** ។ បទថា **វិបត្តិសម្ភវលោក** បានដល់ កម្មដែលឲ្យចូលដល់អបាយ ។ ពិតហើយ កម្មដែលឲ្យចូលដល់អបាយនោះ ឈ្មោះថា **សម្ភវ** ព្រោះជាដែនកើតនៃផល ។ ការសម្ភពនៃវិបត្តិ ឈ្មោះថា **វិបត្តិសម្ភវ** ។ លោក គឺវិបត្តិសម្ភវ ឈ្មោះថា **វិបត្តិសម្ភវលោក** ។ បទថា **តិស្សោ វេទនា** បានដល់ សុខវេទនា ១ ទុក្ខវេទនា ១ អទុក្ខមសុខវេទនា ១ ជាលោកិយប៉ុណ្ណោះ ។ បទថា **អាហារា** បានដល់ បច្ច័យ ។ ពិតហើយ បច្ច័យហៅថា អាហារ ព្រោះនាំមកនូវផលរបស់ខ្លួន ។ អាហារមាន ៤ គឺកវឡិង្ការាហារ ១

ផស្សាហារ ១ មនោសញ្ចេតនាហារ ១ វិញ្ញាណាហារ ១ ។

ឈ្មោះថា **កពឡិង្ការាហារ** ព្រោះគួរធ្វើឲ្យជាពំនូតដោយវត្ថុ ឈ្មោះថា **អាហារ** ព្រោះគួរទំពាលេបបាន ។ បទនេះជាឈ្មោះនៃឱជៈ ដែលជាវត្ថុមានបាយ និងនំជាដើម ។ ឱជានោះ ឈ្មោះថា **អាហារ** ព្រោះនាំមកនូវរូបទាំងឡាយដែលមានឱជៈជាគម្រប់ ៨ ។

ផស្សៈ ៦ មានចក្ខុសម្ផស្សជាដើម ឈ្មោះថា **អាហារ** ព្រោះនាំមកនូវវេទនា ៣ ។ ឈ្មោះថា **មនោសញ្ចេតនា** ព្រោះជាសញ្ចេតនារបស់ចិត្ត មិនមែនរបស់សត្វ ដូចឯកគ្គតារបស់ចិត្ត ។ ឬថា សញ្ចេតនាដែលសម្បយុត្តជាមួយចិត្ត ឈ្មោះថា **មនោសញ្ចេតនា** ដូចរថដែលទឹមដោយសេះអាជានេយ្យ គឺ កុសលចេតនា និងអកុសលចេតនាដែលប្រព្រឹត្តទៅក្នុងភូមិ ៣ ។ ចេតនានោះ ឈ្មោះថា **អាហារ** ព្រោះនាំមកនូវភព ៣ ។

ពាក្យថា **វិញ្ញាណ** បានដល់ បដិសន្ធិវិញ្ញាណ ១៩ ប្រភេទ ។ វិញ្ញាណនោះ ឈ្មោះថា **អាហារ** ព្រោះនាំមកនូវនាមរូបក្នុងបដិសន្ធិក្ខណៈ ។

បទថា **ឧបាទានក្ខន្ធា** សេចក្តីថា ខន្ធដែលកើតអំពីឧបាទាន ឈ្មោះថា **ឧបាទានក្ខន្ធ** គប្បីឃើញថា ជាសព្ទដែលលុបពាក្យកណ្តាលចេញ ឬខន្ធទាំងឡាយមានព្រោះឧបាទាន ទើបឈ្មោះថា **ឧបាទានក្ខន្ធ** ដូចភ្លើងដែលកើតអំពីស្មៅ ភ្លើងកើតអំពីអង្កាម ។ មួយវិញទៀត ខន្ធទាំងឡាយដែលជាអារម្មណ៍នៃឧបាទាន ឈ្មោះថា **ឧបាទានក្ខន្ធ** ដូចបុរសរបស់ព្រះរាជា ។ ឬខន្ធទាំងឡាយ មានឧបាទានជាដែនកើត ឈ្មោះថា **ឧបាទានក្ខន្ធ** ។ ដូចផ្កា

របស់ឈើ ផ្លែរបស់ឈើ ។ម្យ៉ាងទៀត ឧបាទានមាន ៤ គឺកាមុបាទាន ១ ទិដ្ឋុបាទាន ១ សីលព្វតុបាទាន ១ អត្តវាទុបាទាន ១ ។ តែដោយអត្ថ ឈ្មោះថា **ឧបាទាន** ព្រោះការប្រកាន់ទោសយ៉ាងមាំ ។ ឧបាទានក្ខន្ធមាន ៥ គឺរូបុបាទានក្ខន្ធ ១ វេទនូបាទានក្ខន្ធ ១ សញ្ញូបាទានក្ខន្ធ ១ សង្ខារូបាទានក្ខន្ធ ១ វិញ្ញាណូបាទានក្ខន្ធ ១ ។

បទថា **ឆ អជ្ឈត្តិកានិ អាយតនានិ** បានដល់ ចក្ខាយតនៈ ១ សោតាយតនៈ ១ ឃានាយតនៈ ១ ជិវ្ហាយតនៈ ១ កាយាយតនៈ ១ មនាយតនៈ ១ ។ វិញ្ញាណដ្ឋិតិ ៧ មានន័យដូចពោលហើយនោះឯង ។ លោកធម៌ ៨ ក៏ដូចគ្នា ។ ម្យ៉ាងទៀត លោកធម៌ ៨ គឺលាភ មិនមានលាភ យស មិនមានយស និន្ទា សរសើរ សុខ ទុក្ខ ឈ្មោះថា **លោកធម៌** ព្រោះកាលលោកនៅប្រព្រឹត្តទៅ ធម៌ទាំងនេះ ក៏វិលទៅតាមលោក ។ ធម្មតាសត្វទាំងឡាយ មិនផុតពីលោកធម៌ទាំងនេះបានឡើយ ។ លោកធម៌ទាំងនេះរមែងមានដល់ព្រះពុទ្ធទាំងឡាយ សមដូចព្រះតម្រាស់ ( ក្នុងអង្គុត្តរនិកាយ អដ្ឋកនិបាត ) ថា

> ម្នាលភិក្ខុទាំងឡាយ លោកធម៌ទាំង ៨ យ៉ាងនេះ តែងជាប់តាមសត្វលោក ទាំងសត្វលោក ក៏វិលទៅតាមនូវលោកធម៌ទាំង ៨ យ៉ាងដែរ ។ លោកធម៌ ៨ យ៉ាង តើដូចម្តេចខ្លះ ។ គឺលាភ ១ អលាភ ១ ។បេ។ សុខ ១ ទុក្ខ ១ ។ ម្នាលភិក្ខុទាំងឡាយ លោកធម៌ទាំង ៨ យ៉ាងនេះឯង តែងជាប់តាមសត្វលោក ទាំង

សត្វលោកក៏វិលទៅតាមនូវលោកធម៌ទាំង ៨ យ៉ាងដែរ ដូច្នេះ ។

ក្នុងបទទាំងនោះ ពាក្យថា **តែងជាប់តាម** បានដល់ រមែងជាប់តាម រមែងមិនលះបង់ អធិប្បាយថា មិនត្រឡប់ចេញចាកលោក ។ ពាក្យថា **លាភ** បានដល់ លាភរបស់បព្វជិត មានចីវរជាដើម លាភរបស់គ្រហស្ថ មានទ្រព្យ និងស្រូវជាដើម ។ កាលមិនបានលាភនោះ ឈ្មោះថា **អលាភ** វត្ថុដែលមិនមែនជាលាភ ក៏ហៅថា **អលាភ** ឯអលាភគប្បីកំណត់ដោយដល់នូវការមិនមានប្រយោជន៍ ។ ពាក្យថា **យស** បានដល់ បរិវារយស ។ កាលមិនបានបរិវារយសនោះ ឈ្មោះថា **អយស** ។ ពាក្យថា **និន្ទា** បានដល់ ពោលទោស ។ ពាក្យថា **សរសើរ** បានដល់ ពោលដល់គុណ ។ ពាក្យថា **សុខ** បានដល់ សុខផ្លូវកាយ និងចិត្តរបស់ពួកកាមាវចរបុគ្គលទាំងឡាយ ។ ពាក្យថា **ទុក្ខ** បានដល់ ទុក្ខផ្លូវកាយ និងចិត្តរបស់បុថុជ្ជន ព្រះសោតាបន្ន និងព្រះសកទាគាមី ។ ព្រះអនាគាមី និងព្រះអរហន្តមានទុក្ខផ្លូវកាយប៉ុណ្ណោះ ។ បទថា **សត្តាវាសា** បានដល់ លំនៅរបស់សត្វទាំងឡាយ អធិប្បាយថា ជាទីនៅ ។ ទីនៅទាំងនោះ ដូចគ្នានឹងខន្ធទាំងឡាយ ដែលប្រកាសហើយ ។ ក្នុងវិញ្ញាណដ្ឋិតិ ៧ និងអសញ្ញសត្តភូមិ ១ និងនេវសញ្ញានាសញ្ញាយតនភូមិ ១ ទើបរួមជាសត្តាវាស ៩ ។ បទថា **ទសាយតនានិ** បានដល់ ចក្ខាយតនៈ ១ រូបាយតនៈ ១ សោតាយតនៈ ១ សទ្ទាយតនៈ ១ ឃានាយតនៈ ១ គន្ធាយតនៈ ១ ជិវ្ហាយតនៈ ១ រសាយតនៈ ១ កាយាយតនៈ ១ ផោដ្ឋព្វាយតនៈ ១ រួមជាអាយតនៈ ១០ ដោយប្រការដូច្នេះ ។ បទថា

**ទ្វាទសា យតនានិ** បានដល់ អាយតនៈ ១០ និងមនាយតនៈ ១ ធម្មា-យតនៈ ១ រួមជាអាយតនៈ ១២ ដោយប្រការដូច្នេះ ។ បទថា **អដ្ឋារស ធាតុយោ** បានដល់ ធាតុ ១៨ ព្រោះធ្វើធាតុនីមួយៗ ឲ្យជា ៣ គឺចក្ខុធាតុ រូបធាតុ ចក្ខុវិញ្ញាណធាតុ រហូតដល់មនោធាតុ ធម្មធាតុ មនោវិញ្ញាណធាតុ ។

[ ១៥២ ] បទថា **សនិសនាមោ** បានដល់ មានព្រះនាមសម្ដែងគុណតែម្យ៉ាងដូចគ្នា ។ បទថា **សនិស្សវ្ហយោ** បានដល់ មានព្រះនាមហៅឈ្មោះដោយគុណតែមួយដូចគ្នា ។ បទថា **សច្ចសនិស្សវ្ហយោ** បានដល់ មានព្រះនាមមិនវិបរិត ដែលសម្ដែងដល់ព្រះគុណតែមួយដោយពិត ។ បទថា **អាសិតោ** បានដល់ ចូលទៅរក ។ បទថា **ឧបាសិតោ** បានដល់ ចូលទៅគប់រក ។ បទថា **បយិរុបាសិតោ** បានដល់ ចូលទៅរកដោយភក្តី ។

[ ១៥៣ ] បទថា **កុព្វនកំ** បានដល់ ព្រៃតូច ។ បទថា **ពហុប្ផលំ កាននមាវសេយ្យ** បានដល់ គប្បីនៅអាស្រ័យព្រៃធំដែលពេញទៅដោយផ្លែឈើច្រើនប្រភេទ ។ បទថា **អប្បទស្សេ** បានដល់ ជាអ្នកមានបញ្ញាតិចរាប់តាំងអំពីពាវរីព្រាហ្មណ៍ ។ បទថា **មហោទធិ** បានដល់ ស្រះធំ មានអនោតត្តស្រះជាដើម ។

[ ១៥៥ ] បទថា **អប្បទស្សា** បានដល់ ជាអ្នកមានបញ្ញាទន់ ។ បទថា **បរិត្តទស្សា** បានដល់ ជាអ្នកមានបញ្ញាទន់ពន់ពេក ។ បទថា **ថោកទស្សា** បានដល់ មានបញ្ញាតិចក្រៃលែងជាងតិច ។ បទថា **ឱមកទស្សា** បានដល់ មានបញ្ញាថោកថយ ។ បទថា **លាមកទស្សា** បានដល់ មានបញ្ញាមិនជា

ប្រធាន ។ បទថា **ជឡុត្តមបញ្ញា** បានដល់ មានបញ្ញាទាបគឺល្ងង់បំផុត ។ បទថា **អប្បមាណទស្សំ**[១] សេចក្តីថា ទ្រង់ឃើញព្រះនិព្វានដែលជាអប្ប-មាណធម៌ ព្រោះឈានកន្លងនូវបមាណធម៌ ។ បទថា **អគ្គទស្សំ** បានដល់ ទ្រង់ឃើញធម៌ដ៏ប្រសើរ ដោយន័យ ( ក្នុងអង្គុត្តរនិកាយ ចតុក្កនិបាត ) ថា **អគ្គតោ វេ បសន្នានំ** បុគ្គលទាំងឡាយ អ្នកជ្រះថ្លាចំពោះវត្ថុដ៏ប្រសើរ ដូច្នេះជាដើម ។ បទថា **ជេដ្ឋទស្សំ** បានដល់ មានបញ្ញាប្រសើរ ដោយន័យជាដើមថា **សម្ពុទ្ធោ ទ្វិបទសេដ្ឋោ** ព្រះពុទ្ធ ទ្រង់ប្រសើរជាងសត្វជើង ២ ។ ៤ បទ មានបទថា **វិសេដ្ឋទស្សំ** បានដល់ លោកបន្ថែមឧបសគ្គ ។ បទថា **អសមំ** បានដល់ ទ្រង់ជាព្រះសព្វញ្ញូ មិនមានបុគ្គលស្មើ គឺមិនមានបុគ្គលផ្ទឹម ។ បទថា **អសមសមំ** បានដល់ ស្មើនឹងព្រះពុទ្ធក្នុងអតីត ដែលមិនមានអ្នកស្មើ ឈ្មោះថា ស្មើជាមួយបុគ្គលមិនមានបុគ្គលស្មើ ។ បទថា **អប្បដិសមំ**[២] បានដល់ មិនមានអ្នកស្មើជាមួយព្រះអង្គ ។ បទថា **អប្បដិភាគំ** បានដល់ វៀរចាកចំណែកប្រៀបជាមួយព្រះអង្គ ។ បទថា **អប្បដិបុគ្គលំ** បានដល់ ប្រាសចាកបុគ្គលប្រៀបជាមួយព្រះអង្គ ។ បទថា **ទេវាតិទេវំ** បានដល់ ជាទេវតាក្រៃលែងជាងវិសុទ្ធិទេពទាំងឡាយ ។ បទថា **ឧសភំ** ព្រោះអត្ថថា ដែលគេសន្មតិទូទៅថា ជាអភិមង្គល ។ ឈ្មោះថា **បុរិសសីហំ** ព្រោះអត្ថថា មិនតក់ស្លុត ។ ឈ្មោះថា **បុរិសនាគំ** ព្រោះអត្ថថា មិនមានទោស ។ ឈ្មោះថា **បុរិសាជញ្ញំ** ព្រោះអត្ថថា ជាបុគ្គលដ៏ឧត្តម ។ ឈ្មោះថា

---

១-២ បិដកខ្មែរមិនប្រទះបទទាំងនេះ ។

**បុរិសនិសភំ** ព្រោះអត្ថថា ជាន់នូវផែនដី គឺបរិស័ទ ៨ ហើយតាំងនៅក្នុងឋានៈជាអ្នកក្លៀវក្លា មិនញាប់ញ័រដោយបច្ចាមិត្រជាសត្រូវណាមួយក្នុងលោកមួយអន្ទើដោយទេវលោក ។ ឈ្មោះថា **បុរិសធោរយ្ហំ** ព្រោះអត្ថថា នាំធុរៈ គឺព្រះធម្មទេសនាទៅ ។

បទថា **មានសកំ វា សរំ** បានដល់ ស្រះដែលមនុស្សសាង ដែលមានឈ្មោះយ៉ាងនោះ ។ បទថា **អនោតត្តំ វា ឧឋាំ** សេចក្ដីថា ព្រះចន្ទនិងព្រះអាទិត្យ កាលគោចរបញ្ចិតទៅខាងត្បូង ឬខាងជើង ធ្វើស្រះនោះ ឲ្យក្ដៅតាមប្រកនៃភ្នំ កាលគោចរទៅត្រង់ រមែងមិនឲ្យពន្លឺ ។ ដោយហេតុនោះឯងទើបស្រះនោះ ឈ្មោះថា អនោតត្ត ។ អនោតត្តស្រះ មានសភាពនេះ ។

បទថា **អក្ខោភ្ភំ អមិតោឧកំ** សេចក្ដីថា មិនអាចឲ្យទឹកដែលរាប់មិនអស់ញាប់ញ័របាន ។ បទថា **ឯវមេវ** ជាបទឧបមា ។ ព្រះសម្ពុទ្ធមានព្រះភាគ ទ្រង់មិនញាប់ញ័រ គឺដែលបុគ្គលណាម្នាក់ មិនអាចឲ្យញាប់ញ័រចាកឋានៈដោយឋានៈជាអ្នកអង់អាច ។ បទថា **អមិតតេជំ** បានដល់ មានតេជៈ គឺព្រះញាណរាប់មិនអស់ ។ បទថា **អភិន្នញ្ញាណំ** បានដល់ មានញាណបែកធ្លាយ ដោយអំណាចនៃទសពលញ្ញាណជាដើម ។ បទថា **វិវដចក្ខុំ** បានដល់ មានសមន្តចក្ខុ ។ បទថា **បញ្ញាបភេទកុសលំ** សេចក្ដីថា ទ្រង់ឈ្លាសក្នុងការដឹង ។ ដែលជាប្រភេទនៃបញ្ញា ដោយន័យជាដើមថា ប្រាជ្ញា ការដឹងច្បាស់ ការពិចារណា ការពិចារណាឃើញ[1] ដូច្នេះ ។ បទថា **អធិគ-**

---

១- សេចក្ដីពិស្ដារសូមមើលក្នុងបិដកលេខ ៦៧ ឃ្នាប ៧៧ ។

**តប្បដិសម្ភិទំ** បានដល់ ទ្រង់បានបដិសម្ភិទា ៤ ហើយ ។ បទថា **ចតុ-វេសារជ្ជប្បត្តំ** សេចក្ដីថា ទ្រង់ដល់នូវភាពជាអ្នកក្លៀវក្លាក្នុងឋានៈ ៤ ដូចព្រះតម្រាស់ ( ក្នុងមជ្ឈិមនិកាយ មូលមណ្ណាសក ) ថា ព្រះអង្គគ្រាន់តែប្ដេជ្ញាខ្លួនថាជាអ្នកត្រាស់ដឹងដោយប្រពៃ តែធម៌ទាំងនេះ ព្រះអង្គឥតបានត្រាស់ដឹងឡើយ ដូច្នេះជាដើម ។ បទថា **សុទ្ធាធិមុត្តំ** សេចក្ដីថា បង្អោនទៅក្នុងចិត្តដែលសម្បយុត្តដោយផលសមាបត្តិដ៏បរិសុទ្ធ គឺចូលទៅក្នុងផលសមាបត្តិនោះ ។ បទថា **សេតប្បច្ចត្តំ** សេចក្ដីថា មានអត្តភាពវិសេសបរិសុទ្ធ ព្រោះលះវាសនាបានហើយ ។ បទថា **អទ្វយភាណឹ** បានដល់ ប្រាសចាកវាចាបែកជា ២ ព្រោះមានវាចាកំណត់បានហើយ ។ បទថា **តាទឹ** បានដល់ ជាអ្នកមិនញាប់ញ័រ ឬមិនញាប់ញ័រ ក្នុងអារម្មណ៍ដែលគួរប្រាថ្នានិងមិនគួរប្រាថ្នា ។ ឈ្មោះថា **តថាបដិញ្ញោ** ព្រោះមានប្ដេជ្ញាយ៉ាងនោះ ។ បទថា **អបរិត្តំ** បានដល់ មិនតិច ។ បទថា **មហាន្តំ** បានដល់ ដល់នូវភាពជាអ្នកធំ កន្លងនូវធាតុទាំង ៣ ។

បទថា **គម្ភីរំ** បានដល់ អ្នកដទៃចូលដល់បានលំបាក ។ បទថា **អប្បមេយ្យំ** សេចក្ដីថា មាននូវគុណធម៌ដែលបុគ្គលណាម្នាក់ រាប់មិនបានព្រោះអត្ថថា ថ្លឹងមិនបាន ។ បទថា **ទុប្បរិយោគាហំ** បានដល់ មានគុណដែលបុគ្គលណាម្នាក់ចូលដល់បានដោយក្រ ឈមចុះបានដោយក្រ ។ បទថា **ពហុរតនំ** បានដល់ មានរតនៈច្រើន ដោយរតនៈ មានសទ្ធាជាដើម ។ បទថា **សាគរសមំ** បានដល់ ដូចគ្នានឹងមហាសមុទ្រ ព្រោះជាប្រកតកើតនៃ

រតនៈ ។

បទថា **ឆឡង្គុបេក្ខាយ សមន្នាគតំ** បានដល់ បរិបូណ៌ដោយឧបេក្ខាមានអង្គ ៦ ដោយន័យដែលពោលហើយ ( ក្នុងអង្គុត្តរនិកាយ ឆក្កនិបាត ) ថា ឃើញរូបដោយភ្នែក ជាអ្នកមិនត្រេកអរ មិនអាក់អន់ ដូច្នេះ ។ បទថា **អតុលំ** បានដល់ ប្រាសចាកការថ្លឹង គឺបុគ្គលណាម្នាក់មិនអាចថ្លឹងបាន ។ បទថា **វិបុលំ** បានដល់ មានធម៌ធំក្រៃលែង ។ បទថា **អប្បមេយ្យំ** បានដល់ មិនអាចប្រមាណបាន ។ បទថា **តំ តាទិសំ** បានដល់ ព្រះមានព្រះភាគទ្រង់ដល់ព្រមដោយគុណ គឺការមិនញាប់ញ័រ ។ បទថា **បវទតំ មគ្គវាទិនំ** សេចក្ដីថា គប្បីសម្គាល់ថា អាត្មាបានជួបបុគ្គលអ្នកប្រាប់ អ្នកពោលដ៏ប្រសើរជាងបណ្ដាអ្នកប្រាប់ អ្នកពោលទាំងឡាយ ។ បទថា **សិនេរុមិវ នគានំ** បានដល់ ដូចភ្នំសិនេរុ ក្នុងចន្លោះភ្នំទាំងឡាយ ។ បទថា **គរុឡមិវ ទិជានំ** បានដល់ ដូចគ្រុឌប្រសើរជាងបក្សីទាំងឡាយ ដូច្នោះ ។ បទថា **សីហមិវ មិគានំ** បានដល់ ដូចសីហៈ ប្រសើរក្នុងវវាងសត្វជើង ៤ ទាំងឡាយ ។ បទថា **ឧទធិមិវ អណ្ណវានំ** បានដល់ អាត្មាបានជួបព្រះពុទ្ធ ដូចជួបសមុទ្រក្នុងចន្លោះអន្លង់ទឹកធំទាំងឡាយ ។ បទថា **ជិនបវរំ** បានដល់ ជាព្រះពុទ្ធដ៏ឧត្ដម ។

[ ១៥៦ ] បទថា **យេមេ បុព្វេ** កាត់បទជា **យេ អិមេ បុព្វេ** ។

[ ១៦២ ] បទថា **តមោនុទាសីនោ** បានដល់ ទ្រង់បន្ទោបង់នូវងងឹតប្រថាប់នៅហើយ ។ បទថា **ភូរិបញ្ញាណោ** បានដល់ មានព្រះញាណ

ជាទន់ ។ បទថា **ភូរិមេធសោ** សេចក្តីថា មានព្រះបញ្ញាបរិបូណ៌ ។

[ ១៦៤ ] គប្បីជ្រាបវិនិច្ឆ័យក្នុងនិទ្ទេសដូចតទៅ បទថា **បភង្ករោ** បានដល់ ទ្រង់ផ្សាយព្រះតេជះ ។ បទថា **អាលោកករោ** បានដល់ ទ្រង់កម្ចាត់នូវងងឹត ។ បទថា **ឱភាសករោ** មានវិគ្គហៈថា ឈ្មោះថា **ឱភាសករោ** ព្រោះធ្វើឲ្យមានរស្មីភ្លឺស្វាង ។ ឈ្មោះថា **ទីបង្ករោ** ព្រោះអត្ថថា ទ្រង់ផ្សាយព្រះរស្មីដូចប្រទីប ។ ឈ្មោះថា **បទីបករោ** ព្រោះអត្ថថា ទ្រង់ផ្សាយពន្លឺដូចគ្នានឹងប្រទីប ។ បទថា **ឧជ្ជោតករោ** បានដល់ ទ្រង់ផ្សាយព្រះរស្មីខន្ធ ។ បទថា **បជ្ជោតករោ** បានដល់ ទ្រង់ផ្សាយពន្លឺទៅគ្រប់ទិសធំ ទិសតូច ។

[ ១៦៥ ] បទថា **ភូរិបញ្ញាណោ** បានដល់ មានព្រះញាណទូលាយ ។ បទថា **ញាណាបញ្ញាណោ** បានដល់ ប្រាកដដោយព្រះញាណ ។ បទថា **បញ្ញាធជោ** មានវិគ្គហៈថា បញ្ញាប្រៀបដូចទង់ជ័យរបស់ព្រះអង្គនោះ មានដោយអត្ថថា លើកឡើង ព្រោះហេតុនោះ ទើបឈ្មោះថា មានបញ្ញាដូចទង់ជ័យ ដូចប្រយោគថា **ធជោ រថស្ស បញ្ញាណំ** រថមានទង់ជាគ្រឿងប្រាកដ ។ បទថា **វិភូតវិហារី** បានដល់ មានវិហារធម៌ប្រាកដ ។

[ ១៦៧ ] បទថា **សន្ទិដ្ឋិកមកាលិកំ** បានដល់ ដែលបុគ្គលប្រព្រឹត្តគប្បីឃើញផលឯង មិនឲ្យសម្រេចផលក្នុងលំដាប់កាល ។ បទថា **អនីតិកំ** បានដល់ ប្រាសចាកចង្រៃ មានកិលេសជាដើម ។

[ ១៦៩ ] បទថា **សន្ទិដ្ឋិកំ** មានវិគ្គហៈថា លោកុត្តរធម៌ ឈ្មោះថា **សន្ទិដ្ឋិកំ** ព្រោះអ្នកសម្រេចលះការដល់ធម៌ដោយសទ្ធារបស់អ្នកដទៃហើយ

គប្បីឃើញដោយខ្លួនឯងដោយបច្ចវេក្ខណញ្ញាណ ។ នូវធម៌ដែលអ្នកប្រព្រឹត្ត គប្បីឃើញឯងនោះ ។ ឈ្មោះថា **អកាល** ព្រោះអត្ថថា មិនមានកាល សំដៅដល់ការឲ្យផលរបស់ខ្លួន ។ ធម៌មិនប្រកបដោយកាលនោះឯង ឈ្មោះថា **អកាលិកំ** អធិប្បាយថា បណ្ដាធម៌ទាំងនោះ អរិយមគ្គធម៌ រមែងឲ្យផលរបស់ខ្លួន ក្នុងលំដាប់នោះឯង ។ នូវធម៌ដែលមិនប្រកបដោយកាលនោះ ។ ឈ្មោះថា **ឯហិបស្សិកំ** ព្រោះអត្ថថា គួរហៅឲ្យមកមើល ប្រព្រឹត្តទៅយ៉ាងនេះថា ចូរមកមើលធម៌នេះចុះ ។ នូវធម៌ដែលគួរហៅឲ្យមកមើលនោះ ។ ឈ្មោះថា **ឱបនយិកំ** ព្រោះអត្ថថា គួរបង្អោនចូលមកក្នុងចិត្តរបស់ខ្លួន ដូចសម្លៀងសំពត់ ឬក្បាលដែលត្រូវភ្លើងឆេះ ។ នូវធម៌ដែលគួរបង្អោនចូលទៅនោះ ។ ឈ្មោះថា **បច្ចត្តំ វេទិតព្វំ វិញ្ញូហិ** ព្រោះអត្ថថា ដែលឧគ្ឃដិតញ្ញូបុគ្គលជាដើម គប្បីជ្រាបក្នុងខ្លួនថា មគ្គអញចម្រើនហើយ ផលអញសម្រេចហើយ និរោធអញធ្វើឲ្យជាក់ច្បាស់ហើយ ។

[ ១៧២ ] លំដាប់នោះ ពាវរីព្រាហ្មណ៍ពោល ២ គាថា នឹងព្រះបិង្គិយៈថា **កិន្នុ តម្ហា** ដូច្នេះជាដើម ។

[ ១៧៤ ] បទថា **មុហុត្តម្បិ** បានដល់ សូម្បីបន្តិចបន្តួច ។ បទថា **ខណម្បិ** បានដល់ សូម្បីមិនច្រើន ។ បទថា **លយម្បិ** បានដល់ សូម្បីតិច ។ បទថា **វស្សម្បិ** បានដល់ សូម្បីកោដ្ឋាស ( ចំណែកមួយ ) ។ បទថា **អទ្ធម្បិ** បានដល់ សូម្បីមួយរយៈថ្ងៃ ។

[ ១៨២-១៩២ ] លំដាប់នោះ ព្រះបិង្គិយៈកាលនឹងសម្ដែងដល់ការ

មិននៅប្រាសចាកសម្នាក់របស់ព្រះមានព្រះភាគ ទើបពោលគាថាថា **នាហំ តម្ហា** ដូច្នេះជាដើម ។

បទថា **នាហំ ។បេ។ យោ មេ ។បេ។ បស្សាមិ នំ មនសា ចក្ខុនា វា** បានដល់ អាត្មាឃើញព្រះពុទ្ធអង្គនោះដោយចិត្ត ដូចឃើញដោយមំសចក្ខុ ។ បទថា **នមស្សមានោ វិវសេមិ រត្តឹ** បានដល់ អាត្មានមស្សការអស់យប់និងថ្ងៃ ។

[ ២០១ ] បទថា **យេន យេនេវ នតោ** លោកសម្តែងថា ព្រះពុទ្ធគង់នៅដោយទិសាភាគណា អាត្មាក៏បង្អោនទៅដោយទិសាភាគនោះៗ គឺឱនទៅរកទិសនោះ ទេរទៅរកទិសនោះ ទោរទៅរកទិសនោះ ឈមទៅរកទិសនោះ ។

[ ២០២ ] បទថា **ទុព្វលថាមកស្ស** បានដល់ មានកម្លាំងតិច ។ម្យ៉ាងទៀត មានកម្លាំងតិច និងមានថាមពលតិច អធិប្បាយថា មានកម្លាំងគឺសេចក្តីព្យាយាមដូរថយ ។ បទថា **តេនេវ កាយោ ន បលេតិ** បានដល់ កាយមិនបានទៅ ព្រោះមានកម្លាំងតិចនោះឯង គឺមិនបានទៅគាល់ព្រះពុទ្ធដល់ទីគង់ ។ បាឋៈថា **ន បរេតិ** ដូច្នេះក៏មាន ឯសេចក្តីក៏តែមួយដូចគ្នា ។ បទថា **តត្ថ** បានដល់ ក្នុងសម្នាក់ព្រះពុទ្ធនោះ ។ បទថា **សង្កប្បយន្តាយ** បានដល់ ទៅដោយការត្រិះរិះ ។ ដោយបទថា **យេន យុត្តោ** លោកសម្តែងថា ព្រះពុទ្ធគង់នៅដោយទិសាភាគណា ចិត្តរបស់អាត្មាប្រកបហើយ ប្រកបព្រមហើយ ខ្វល់ខ្វាយហើយ ដោយទិសាភាគនោះ ។

[ ២០៤ ] បទថា **យេន ពុទ្ធោ** បានដល់ គួរចូលទៅគាល់ព្រះពុទ្ធដោយទិសាភាគណា មិនទៅដោយទិសាភាគនោះ ។ ម្យ៉ាងទៀត បទថា **យេន**

ជាតតិយាវិភត្តិ ចុះក្នុងអត្ថនៃសត្តមីវិភត្តិ ។ ព្រះពុទ្ធគង់ក្នុងទីណា កាយរបស់អាត្មាមិនទៅ គឺមិនទៅដល់ក្នុងទីនោះ ។ បទថា **ន វជតិ** បានដល់ មិនប្រព្រឹត្តទៅខាងមុខ ។ បទថា **ន គច្ឆតិ** បានដល់ មិនប្រព្រឹត្តទៅ ។ បទថា **នាភិក្កមតិ** បានដល់ មិនចូលទៅរក ។

[ ២០៧ ] បទថា **បដ្ឋេ សយានោ** បានដល់ ដេកក្នុងភក់ គឺកាម ។ បទថា **ទីបា ទីបំ ឧបល្លវឹ** បានដល់ ផ្លាស់ចាកសាស្តាមួយទៅរកសាស្តាមួយទៀត ។ បទថា **អថទ្ទសាសឹ សម្ពុទ្ធំ** បានដល់ អាត្មានោះកាន់យកនូវមិច្ឆាទិដ្ឋិយ៉ាងនេះ ត្រាច់ទៅ គ្រានោះ បានឃើញព្រះពុទ្ធ គង់បាសាណកចេតិយ ។

[ ២០៨ ] ក្នុងបទទាំងនោះ បទថា **សេមានោ** បានដល់ ដេក ។ បទថា **សយមានោ**[១] បានដល់ សម្រេចការដេក ។ បទថា **អាវសមានោ** បានដល់ អាស្រ័យនៅ ។ បទថា **បរិវសមានោ** បានដល់ អាស្រ័យនៅជានិច្ច ។

[ ២០៩ ] បទថា **បល្លវឹ**[២] បានដល់ ធ្លងឡើងហើយ ។ បទថា **ឧបល្លវឹ** បានដល់ ដល់ត្រើយ ។ បទថា **សម្បល្លវឹ** លោកបន្ថែមឧបសគ្គចូលទៅ ។

[ ២១០ ] បទថា **អទ្ទសំ** ជាពាក្យលើកឡើងដើម្បីពង្រីកសេចក្តី ។ បទថា **អទ្ទសំ** បានដល់ បានឃើញហើយ ។ បទថា **អទក្ខឹ** បានដល់ បានសម្លឹងមើលហើយ ។ បទថា **អបស្សឹ** បានដល់ បានជួបហើយ ។ បទថា

---
១-២ បិដកខ្មែរមិនប្រទះបទទាំងនេះ ។

**បដិវិជ្ឈិ** បានដល់ ចាក់ធ្លុះហើយ ។

[ ២១២ ] កាលគាថានេះចប់ ព្រះមានព្រះភាគ ទ្រង់ជ្រាបថា បិង្គិយៈ និងពាវរីព្រាហ្មណ៍មានឥន្ទ្រិយចាស់ក្លាហើយ ប្រថាប់ឈរក្នុងក្រុងសាវត្ថីនោះឯង បញ្ចេញព្រះរស្មីពណ៌មាសទៅ ។ ព្រះបិង្គិយៈអង្គុយពណ៌នាពុទ្ធគុណដល់ពាវរីព្រាហ្មណ៍ ឃើញពន្លឺនោះហើយ គិតថា នេះអ្វីហ្ន៎ សម្លឹងមើលបានឃើញព្រះមានព្រះភាគ ដូចប្រថាប់ឈរក្នុងទីចំពោះមុខរបស់ខ្លួន ទើបប្រាប់ពាវរីព្រាហ្មណ៍ថា ព្រះពុទ្ធយាងមកហើយ ព្រាហ្មណ៍ក្រោកចាកទីអង្គុយផ្គងអញ្ជលី ។ ព្រះមានព្រះភាគ ទ្រង់បញ្ចេញព្រះរស្មីទៅបង្ហាញព្រះកាយដល់ព្រាហ្មណ៍ ទ្រង់ជ្រាបធម៌ដែលជាទីសប្បាយរបស់ជនទាំង ២ កាលត្រាស់ហៅបិង្គិយៈប៉ុណ្ណោះ ទើបត្រាស់ព្រះគាថានេះថា **យថា អហុ វក្កលិ** ដូច្នេះជាដើម ។

គាថានោះ មានសេចក្ដីដូចតទៅនេះ ព្រះវក្កលិត្ថេរ បណ្ដាមាណពទាំង ១៦ កទ្រាវុធក្ដី អាឡវិគោតមក្ដី សុទ្ធតែមានសទ្ធាបង្អោនទៅហើយ បានសម្រេចអរហត្តដោយសទ្ធាធុរៈនោះឯង យ៉ាងណា អ្នកក៏ចូរបញ្ចេញនូវសទ្ធាយ៉ាងនោះដូចគ្នា ។ បន្ទាប់អំពីនោះ កាលបញ្ចេញសទ្ធា ផ្ដើមវិបស្សនាដោយន័យជាដើមថា **សព្វេ សង្ខារា អនិច្ចា** ដូច្នេះ នឹងដល់ត្រើយនៃធម៌ជាទីតាំងនៃមច្ចុ គឺនិព្វាន ។ ព្រះមានព្រះភាគ ទ្រង់បញ្ចប់ទេសនាដោយធម៌ដ៏កំពូល គឺអរហត្ត ។

កាលចប់ទេសនា ព្រះបិង្គិយៈតាំងនៅក្នុងអរហត្តផល ពាវរីព្រាហ្មណ៍

តាំងនៅក្នុងអនាគាមិផល ។ ឯបរិស័ទ ៥០០ របស់ពាវរីព្រាហ្មណ៍ បានជាសោតាបន្ន ។

[ ២១៤ ] ក្នុងបទទាំងនោះ បទថា **មុញ្ចស្សុ** បានដល់ ចូរលែង ។ បទថា **បមុញ្ចស្សុ** បានដល់ ចូរលែងចេញ ។ បទថា **អធិមុញ្ចស្សុ** បានដល់ ចូរធ្វើការបង្អោនក្នុងសទ្ធានោះ ។ បទថា **ឱក្កប្បេហិ** បានដល់ ចូរឲ្យកើតនូវការរាប់អានច្រើន ។ បទថា **សព្វេ សង្ខារា អនិច្ចា** ដោយអត្ថថា មានហើយ ត្រឡប់ជាមិនមាន ។ បទថា **សព្វេ សង្ខារា ទុក្ខា** ដោយអត្ថថា អត់ធន់បានលំបាក គឺអត់ធន់មិនបាន ។ បទថា **សព្វេ ធម្មា អនត្តា** ដោយអត្ថថា មិននៅក្នុងអំណាច ។

[ ២១៦ ] ឥឡូវនេះ ព្រះបិង្គិយៈកាលប្រកាសនូវសេចក្តីជ្រះថ្លារបស់ខ្លួន ទើបពោលគាថាថា **ឯស ភិយ្យោ** ដូច្នេះជាដើម ។

ក្នុងបទទាំងនោះ បទថា **បដិភានវា** បានដល់ ប្រកបដោយបដិភាណប្បដិសម្ភិទា ។ បទថា **ភិយ្យោ** បានដល់ ក្រៃលែងឡើង ។

[ ២២១ ] បទថា **អធិទេវេ អភិញ្ញាយ** បានដល់ ទ្រង់ដឹងនូវធម៌ដែលធ្វើឲ្យជាអធិទេព ។ បទថា **បរោវរំ** បានដល់ ថោកទាប និងប្រណីត មានពាក្យអធិប្បាយថា ទ្រង់ដឹងនូវធម្មជាតទាំងអស់ ដែលធ្វើនូវភាពជាអធិទេពឲ្យដល់ព្រះអង្គ និងអ្នកដទៃ ។ បទថា **កង្ខីនំ បដិជានតំ** បានដល់ បុគ្គលមានសេចក្តីសង្ស័យប្តេជ្ញាថា ខ្ញុំអស់សង្ស័យហើយ ។

[ ២២៤ ] គប្បីជ្រាបវិនិច្ឆ័យក្នុងនិទ្ទេសដូចតទៅ បទថា **ធារាយនិ-**

**កប្បញ្ញាណំ** បានដល់ នៃពាក្យសួររបស់ពួកព្រាហ្មណ៍ដែលស្វែងរកធម៌ជាគ្រឿងដល់នូវត្រើយ ។ ឈ្មោះថា **អន្តករោ** ព្រោះទ្រង់ធ្វើចំណែកបំផុត ។ ឈ្មោះថា **បរិយន្តករោ** ព្រោះទ្រង់ធ្វើទីបំផុត ។ ឈ្មោះថា **បរិច្ឆេទករោ** ព្រោះទ្រង់ធ្វើនូវការកំណត់ព្រំដែន ។ ឈ្មោះថា **បរិវដុមករោ** ព្រោះទ្រង់ធ្វើនូវការសរុប ។ បទថា **បិង្គិយប្បញ្ញាណំ** សេចក្តីថា ដើម្បីទ្រង់សម្តែងថា មិនមែនធ្វើចំណែកបំផុតនៃបញ្ហារបស់ពួកព្រាហ្មណ៍ អ្នកស្វែងរកធម៌ជាគ្រឿងដល់នូវត្រើយតែម្យ៉ាងប៉ុណ្ណោះទេ តាមពិត ទ្រង់ធ្វើចំណែកទីបំផុតនៃបញ្ហារបស់បិង្គិយបរិញ្វាជកជាដើមផងដែរ ទើបត្រាស់ពាក្យថា **បិង្គិយប្បញ្ញាណំ** ដូច្នេះជាដើម ។

[ ២២៦ ] បទថា **អសំហិរំ** បានដល់ និញ្វាន ដែលរាគៈជាដើមនាំទៅមិនបាន ។ បទថា **អសង្កុប្បំ** បានដល់ មិនកម្រើក មិនមានការប្រែប្រួលទៅជាធម្មតា ។ លោកពោលដល់និញ្វានដោយបទទាំង ២ ។ បទថា **អទ្ធា គមិស្សាមិ** បានដល់ នឹងដល់និញ្វានធាតុដែលជាអនុបាទិសេសនោះដោយចំណែកមួយប៉ុណ្ណោះ ។ បទថា **ន មេត្ថ កង្ខា** បានដល់ សេចក្តីសង្ស័យក្នុងនិញ្វាននេះ មិនមានដល់ខ្ញុំព្រះអង្គ ។ បទថា **ឯវំ មំ ធារេហិ អធិមុត្តចិត្តំ** សេចក្តីថា ព្រះបិង្គិយៈញុំាងសទ្ធាឲ្យ កើតឡើងហើយក្នុងខ្លួនដោយឱវាទរបស់ព្រះមានព្រះភាគនេះថា សូម្បីអ្នកក៏ចូរបញ្ចេញនូវសទ្ធាយ៉ាងនោះដូចគ្នា ហើយរួចផុតដោយសទ្ធាធុរៈនោះឯង កាលប្រកាសសទ្ធាធិមុត្តិនោះ ទើបទូលព្រះមានព្រះភាគថា **ឯវំ មំ ធារេហិ អធិមុត្តចិត្តំ** ក្នុងបទនេះ

*មានអធិប្បាយដូច្នេះថា សូមព្រះអង្គទ្រង់ចាំនូវខ្ញុំព្រះអង្គថា ជាអ្នកមានចិត្តបង្អោនទៅហើយ ដូចដែលទ្រង់បានត្រាស់នឹងខ្ញុំព្រះអង្គហើយ ដូច្នោះ ។*

*[ ២២៩ ] បទថា* **ន សំហារិយតិ** *បានដល់ បុគ្គលណាម្នាក់មិនអាចនាំយកទៅបាន ។ បទថា* **និយោគវចនំ** *ជាពាក្យដែលត្រឹមត្រូវ ។ បទថា* **អវដ្ឋាបនវចនំ** *ជាពាក្យកាត់សម្រេច ។*

*ក្នុងបារាយនវគ្គនេះ បទណាមិនបានពោលក្នុងចន្លោះៗ គប្បីកាន់យកបទនោះ ដោយន័យដែលពោលហើយខាងដើម ។ បទដ៏សេសក្នុងទីទាំងពួង ជាក់ច្បាស់ហើយ ។*

**អដ្ឋកថា ចារាយនានុគីតិគាថានិទ្ទេស ចប់**

**អដ្ឋកថា បារាយនវគ្គ ចប់**

# សុត្តន្តបិដក

## ខគ្គវិសាណសុត្តនិទ្ទេស

[ ២៣១ ] ( ព្រះបច្ចេកពុទ្ធត្រាស់ថា ) បុគ្គលទម្លាក់ចេញនូវអាជ្ញា ចំពោះពួកសត្វទាំងពួង មិនបៀតបៀននូវសត្វទាំងនោះ សូម្បីសត្វណាមួយ គេមិនចង់បានបុត្រទៅហើយ តើនឹងប្រាថ្នាសម្លាញ់អំពីណាកើត បុគ្គលនោះ តែងប្រព្រឹត្តម្នាក់ឯង ដូចកុយរមាស ។

[ ២៣២ ] អធិប្បាយពាក្យថា បុគ្គលទម្លាក់ចេញនូវអាជ្ញា ចំពោះពួកសត្វទាំងពួង ត្រង់ពាក្យថា ទាំងពួង គឺគ្រប់ទាំងអស់ សព្វទាំងអស់ មិនសល់ឥតសល់ ពាក្យថា ទាំងពួងនុ៎ះ ជាពាក្យពោលរួម ។ ពាក្យថា ពួកសត្វ សេចក្តីថា ពួកសត្វតក់ស្លុត និងពួកសត្វនឹងនួន ហៅថា ពួកសត្វ ។ ពាក្យថា ពួកសត្វតក់ស្លុត បានខាងពួកសត្វមិនទាន់លះបង់តណ្ហា និងពួកសត្វមិនទាន់លះបង់ភ័យដែលគួរខ្លាច ។ ដែលលោកពោលថា ពួកសត្វតក់ស្លុត តើព្រោះហេតុដូចម្តេច ។ សត្វទាំងនោះរមែងតក់ស្លុត ញ័រចំប្រប់ ញាប់ញ័រ ដល់នូវសេចក្តីតក់ស្លុត ព្រោះហេតុនោះ លោកពោលថា ពួកសត្វតក់ស្លុត ។ ពាក្យថា ពួកសត្វនឹងនួន បានខាងពួកសត្វលះបង់តណ្ហាហើយ និងពួកសត្វលះបង់ភ័យដែលគួរខ្លាច ។ ដែលលោកពោលថា ពួកសត្វនឹងនួន តើព្រោះហេតុដូចម្តេច ។ សត្វទាំងនោះមិនតក់ស្លុត មិនញ័រចំប្រប់ មិនញាប់ញ័រ មិនដល់នូវសេចក្តីតក់ស្លុត ព្រោះហេតុនោះ លោកពោលថា ពួកសត្វនឹងនួន ។ ពាក្យថា អាជ្ញា បានដល់ អាជ្ញា ៣ គឺអាជ្ញា គឺកាយ ១ អាជ្ញា គឺវាចា ១ អាជ្ញា

គឺចិត្ត ១ ។ កាយទុច្ចរិត ៣ ឈ្មោះថាអាជ្ញាគឺកាយ វចីទុច្ចរិត ៤ ឈ្មោះថា អាជ្ញាគឺវាចា មនោទុច្ចរិត ៣ ឈ្មោះថា អាជ្ញា គឺចិត្ត ។ ពាក្យថា បុគ្គលទម្លាក់ចេញនូវអាជ្ញាចំពោះពួកសត្វទាំងពួង បានន័យថា បុគ្គលទម្លាក់ចេញ ដាក់ចេញ បោះបង់ វលាស់ចោល រម្ងាប់នូវអាជ្ញា ចំពោះពួកសត្វទាំងពួង ហេតុនោះ ( លោកពោលថា ) បុគ្គលទម្លាក់ចេញនូវអាជ្ញា ចំពោះពួកសត្វទាំងពួង ។

[ ២៣៣ ] ត្រង់ពាក្យថា មិនបៀតបៀននូវសត្វទាំងនោះ សូម្បីសត្វណាមួយ គឺមិនបៀតបៀននូវសត្វ សូម្បីតែមួយ ដោយដៃក្តី ដោយដុំដីក្តី ដោយដំបងក្តី ដោយសស្ត្រាក្តី ដោយពួរក្តី ដោយខ្សែក្តី មិនបៀតបៀននូវពួកសត្វទាំងអស់ ដោយដៃក្តី ដោយដុំដីក្តី ដោយដំបងក្តី ដោយសស្ត្រាក្តី ដោយពួរក្តី ដោយខ្សែក្តី ហេតុនោះ ( លោកពោលថា ) មិនបៀតបៀននូវសត្វទាំងនោះ សូម្បីសត្វណាមួយ ។

[ ២៣៤ ] អធិប្បាយពាក្យថា មិនចង់បានបុត្តទៅហើយ តើនឹងប្រាថ្នាសម្លាញ់អំពីណាកើត ត្រង់ពាក្យថា មិន គឺជាពាក្យបដិសេធ ។ ពាក្យថា បុត្រ បានដល់ បុត្ត ៤ គឺបុត្តកើតអំពីខ្លួន ១ បុត្តកើតអំពីខេត្រ ១ បុត្តដែលគេឲ្យ ១ បុត្ត គឺសិស្ស ១ ។ ពាក្យថា សម្លាញ់ សេចក្តីថា ការទៅសប្បាយ ការមកសប្បាយ ការទៅមកសប្បាយ ការអង្គុយសប្បាយ ការដេកសប្បាយ ការហៅរកសប្បាយ ការនិយាយសប្បាយ ការនិយាយឆ្លើយឆ្លងរកគ្នាសប្បាយ ជាមួយនឹងពួកជនណា ពួកជននោះ លោកហៅថា សម្លាញ់ ។ ពាក្យថា មិនចង់បានបុត្តទៅហើយ តើនឹងប្រាថ្នាសម្លាញ់អំពីណាកើត បាន

សេចក្តីថា មិនប្រាថ្នា មិនត្រេកអរ មិនស្រឡាញ់ មិនជាប់ជំពាក់ សូម្បីនូវបុត្តទៅហើយ តើនឹងប្រាថ្នា នឹងត្រេកអរ នឹងស្រឡាញ់ នឹងជាប់ជំពាក់ចំពោះមិត្តក្តី ចំពោះជនដែលធ្លាប់ឃើញគ្នាក្តី ចំពោះមិត្តធ្លាប់បរិភោគរួមគ្នាក្តី ចំពោះសម្លាញ់ក្តីអំពីណាកើត ហេតុនោះ ( លោកពោលថា ) មិនចង់បានបុត្តទៅហើយ តើនឹងប្រាថ្នាសម្លាញ់អំពីណាកើត ។

[ ២៣៥ ] អធិប្បាយពាក្យថា គប្បីប្រព្រឹត្តម្នាក់ឯង ដូចកុយរមាស ត្រង់ពាក្យថា ម្នាក់ឯង គឺព្រះបច្ចេកសម្ពុទ្ធនោះ ជាបុគ្គលម្នាក់ឯង ព្រោះចំណែកបព្វជ្ជា ជាបុគ្គលម្នាក់ឯង ព្រោះអត្ថថា មិនមានបុគ្គលជាគម្រប់ពីរ ជាបុគ្គលម្នាក់ឯង ព្រោះអត្ថថា លះបង់តណ្ហា ជាបុគ្គលម្នាក់ឯង ព្រោះហេតុប្រាសចាករាគៈដោយដាច់ខាត ជាបុគ្គលម្នាក់ឯង ព្រោះហេតុប្រាសចាកទោសៈដោយដាច់ខាត ជាបុគ្គលម្នាក់ឯង ព្រោះហេតុប្រាសចាកមោហៈដោយដាច់ខាត ជាបុគ្គលម្នាក់ឯង ព្រោះហេតុមិនមានកិលេសដោយដាច់ខាត ជាបុគ្គលម្នាក់ឯង ព្រោះហេតុទៅកាន់ផ្លូវ ជាទីទៅតែម្នាក់ឯង ជាបុគ្គលម្នាក់ឯង ព្រោះហេតុត្រាស់ដឹងនូវបច្ចេកសម្ពោធិដ៏ប្រសើរ តែម្នាក់ឯង ។

ព្រះបច្ចេកសម្ពុទ្ធនោះ ឈ្មោះថា ជាបុគ្គលម្នាក់ឯង ព្រោះចំណែកបព្វជ្ជា តើដូចម្តេច ។ ព្រះបច្ចេកសម្ពុទ្ធនោះ ទ្រង់កាត់បលិពោធក្នុងឃរាវាស កាត់បលិពោធក្នុងបុត្ត និងភរិយា កាត់បលិពោធក្នុងញាតិ កាត់បលិពោធក្នុងការសន្សំ កោរសក់ ពុកមាត់ និងពុកចង្កា ស្លៀកដណ្តប់សំពត់កាសាយៈ ចេញចាកផ្ទះបួសទៅកាន់ផ្នួស ដល់នូវភាពមិនមានកង្វល់ ជាបុគ្គលម្នាក់ឯង ចរទៅ

ត្រាច់ទៅ ប្រព្រឹត្ត រក្សា យាត្រា ឲ្យយាត្រាទៅ ហេតុនោះ ព្រះបច្ចេកសម្ពុទ្ធនោះ ឈ្មោះថា ជាបុគ្គលម្នាក់ឯង ព្រោះចំណែកបព្វជ្ជាយ៉ាងនេះ ។

ព្រះបច្ចេកសម្ពុទ្ធនោះ ជាបុគ្គលម្នាក់ឯង ព្រោះអត្ថថា មិនមានបុគ្គលជាគម្រប់ពីរ តើដូចម្ដេច ។ ព្រះបច្ចេកសម្ពុទ្ធនោះ កាលបួសយ៉ាងនេះហើយ ជាបុគ្គលម្នាក់ឯង គប់រកសេនាសនៈដ៏ស្ងាត់ គឺព្រៃរបោះ និងព្រៃញាតស្បាត ជាទីមិនមានសំឡេង មិនមានសំឡេងគឹកកង ប្រាសចាកខ្យល់ដែលកើតអំពីសរីរៈមនុស្ស ជាទីស្ងាត់កំបាំងរបស់មនុស្ស សមគួរដល់ទីពួនសម្ងំ លោកដើរទៅម្នាក់ឯង ឈរនៅម្នាក់ឯង អង្គុយម្នាក់ឯង សម្រេចសេយ្យាម្នាក់ឯង ចូលទៅកាន់ស្រុក ដើម្បីបិណ្ឌបាតម្នាក់ឯង ត្រឡប់មកវិញម្នាក់ឯង អង្គុយក្នុងទីស្ងាត់ម្នាក់ឯង អធិដ្ឋានចង្រ្កមម្នាក់ឯង ចរ ត្រាច់ទៅ ប្រព្រឹត្ត រក្សា យាត្រា ឲ្យយាត្រាទៅតែម្នាក់ឯង ហេតុនោះ ព្រះបច្ចេកសម្ពុទ្ធនោះ ឈ្មោះថា ជាបុគ្គលម្នាក់ឯង ព្រោះអត្ថថា មិនមានបុគ្គលជាគម្រប់ពីរយ៉ាងនេះ ។

ព្រះបច្ចេកសម្ពុទ្ធនោះ ជាបុគ្គលម្នាក់ឯង ព្រោះអត្ថថា លះបង់តណ្ហា តើដូចម្ដេច ។ ព្រះបច្ចេកសម្ពុទ្ធនោះ ជាបុគ្គលម្នាក់ឯង ឥតមានបុគ្គលជាគម្រប់ពីរ យ៉ាងនេះហើយ ជាអ្នកមិនប្រហែស មានព្យាយាមដុតកម្ដៅកិលេស មានចិត្តស្ទុង ( ទៅកាន់ព្រះនិព្វាន ) ផ្គងព្យាយាមធំ កម្ចាត់បង់មារ ព្រមទាំងសេនានៃមារ ដែលមិនដោះលែង ជាផៅពង្សនៃបុគ្គលប្រហែស គឺថា លះបង់ បន្ទោបង់ ធ្វើឲ្យវិនាស ញ៉ាំងតណ្ហាដូចជាបណ្ដាញ ដែលហូរទៅ ផ្សាយទៅ ឲ្យដល់នូវការមិនកើតមាន ។

បុរសមានតណ្ហាជាគម្រប់ពីរ កាលអន្ទោលទៅ អស់កាលដ៏វែង រមែងមិនកន្លងផុតសង្សារ មានភាពបែបនេះ និងភាពដទៃ ភិក្ខុអ្នកមានសតិ ប្រាសចាកតណ្ហា មិនមានសេចក្តីប្រកាន់ លុះឃើញទោសយ៉ាងនេះហើយ គួរវៀរនូវតណ្ហា ជាដែនកើតទុក្ខចេញ ។

ព្រះបច្ចេកសម្ពុទ្ធនោះ ជាបុគ្គលម្នាក់ឯង ព្រោះអត្ថថា លះបង់តណ្ហាយ៉ាងនេះ ។

ព្រះបច្ចេកសម្ពុទ្ធនោះ ជាបុគ្គលម្នាក់ឯង ព្រោះហេតុប្រាសចាករាគៈដោយដាច់ខាត តើដូចម្តេច ។ ជាបុគ្គលម្នាក់ឯង ព្រោះហេតុប្រាសចាករាគៈដោយដាច់ខាត ព្រោះលោកលះរាគៈហើយ ។ ជាបុគ្គលម្នាក់ឯង ព្រោះហេតុប្រាសចាកទោសៈដោយដាច់ខាត ព្រោះលោកលះទោសៈហើយ ។ ជាបុគ្គលម្នាក់ឯង ព្រោះហេតុប្រាសចាកមោហៈដោយដាច់ខាត ព្រោះលោកលះមោហៈហើយ ។ ជាបុគ្គលម្នាក់ឯង ព្រោះហេតុមិនមានកិលេសដោយដាច់ខាត ព្រោះលោកលះកិលេសទាំងឡាយហើយ ។ ព្រះបច្ចេកសម្ពុទ្ធនោះ ជាបុគ្គលម្នាក់ឯង ព្រោះហេតុប្រាសចាករាគៈដោយដាច់ខាតយ៉ាងនេះ ។

ព្រះបច្ចេកសម្ពុទ្ធនោះ ជាបុគ្គលម្នាក់ឯង ព្រោះហេតុទៅកាន់ផ្លូវ ជាទីទៅម្នាក់ឯង តើដូចម្តេច ។ សតិប្បដ្ឋាន ៤ សម្មប្បធាន ៤ ឥទ្ធិបាទ ៤ ឥន្ទ្រិយ ៥ ពល ៥ ពោជ្ឈង្គ ៧ អរិយមគ្គប្រកបដោយអង្គ ៨ លោកហៅថា ផ្លូវជាទីទៅម្នាក់ឯង ។

បុគ្គលអ្នកឃើញទីបំផុត នៃកិរិយាអស់ជាតិ ជាអ្នកអនុគ្រោះនូវ

ប្រយោជន៍ រមែងដឹងច្បាស់នូវផ្លូវជាទីទៅម្នាក់ឯង ពួកអរិយបុគ្គល បានចូលហើយក្នុងអតីតកាលក្តី នឹងចូលក្នុងអនាគតក្តី កំពុងចូលក្នុង បច្ចុប្បន្ននេះក្តី នូវឱឃៈតាមផ្លូវនេះឯង ។

ព្រះបច្ចេកសម្ពុទ្ធនោះ ជាបុគ្គលម្នាក់ឯង ព្រោះហេតុទៅកាន់ផ្លូវជាទីទៅម្នាក់ឯង យ៉ាងនេះ ។

ព្រះបច្ចេកសម្ពុទ្ធនោះ ជាបុគ្គលម្នាក់ឯង ព្រោះហេតុត្រាស់ដឹងនូវបច្ចេកសម្ពោធិដ៏ប្រសើរ តែម្នាក់ឯង តើដូចម្តេច ។ ញាណ បញ្ញា បញ្ញិន្ទ្រិយ បញ្ញាពល ធម្មវិចយសម្ពោជ្ឈង្គ វីមំសា វិបស្សនា សម្មាទិដ្ឋិក្នុងមគ្គទាំង ៤ លោកហៅថា ពោធិ ។ ព្រះបច្ចេកសម្ពុទ្ធនោះ ត្រាស់ដឹងហើយនូវសច្ចៈទាំងឡាយ ដោយបច្ចេកពុទ្ធញាណ ត្រាស់ដឹងហើយថា សង្ខារទាំងពួងមិនទៀង ត្រាស់ដឹងហើយថា សង្ខារទាំងពួងជាទុក្ខ ត្រាស់ហើយថា ធម៌ទាំងពួងជាអនត្តា ត្រាស់ដឹងហើយថា សង្ខារទាំងឡាយ ( កើតមាន ) ព្រោះអវិជ្ជាជាបច្ច័យ ត្រាស់ដឹងហើយថា វិញ្ញាណ ( កើតមាន ) ព្រោះសង្ខារជាបច្ច័យ ត្រាស់ដឹងហើយថា នាម និងរូប ( កើតមាន ) ព្រោះវិញ្ញាណជាបច្ច័យ ត្រាស់ដឹងហើយថា អាយតនៈ ៦ ( កើតមាន ) ព្រោះនាមរូបជាបច្ច័យ ត្រាស់ដឹងហើយថា ផស្សៈ ( កើតមាន ) ព្រោះអាយតនៈ ៦ ជាបច្ច័យ ត្រាស់ដឹងហើយថា វេទនា ( កើតមាន ) ព្រោះផស្សៈជាបច្ច័យ ត្រាស់ដឹងហើយថា តណ្ហា ( កើតមាន ) ព្រោះវេទនាជាបច្ច័យ ត្រាស់ដឹងហើយថា ឧបាទាន ( កើតមាន ) ព្រោះតណ្ហាជាបច្ច័យ ត្រាស់ដឹងហើយថា ភព ( កើតមាន ) ព្រោះឧបាទានជាបច្ច័យ ត្រាស់

ដឹងហើយថា ជាតិ ( កើតមាន ) ព្រោះភពជាបច្ច័យ ត្រាស់ដឹងហើយថា ជរា និងមរណៈ ( កើតមាន ) ព្រោះជាតិជាបច្ច័យ ត្រាស់ដឹងហើយថា ការរលត់សង្ខារ ព្រោះការរលត់ទៅនៃអវិជ្ជា ត្រាស់ដឹងហើយថា ការរលត់វិញ្ញាណ ព្រោះការរលត់សង្ខារ ត្រាស់ដឹងហើយថា ការរលត់នាមរូប ព្រោះការរលត់វិញ្ញាណ ត្រាស់ដឹងហើយថា ការរលត់អាយតនៈ ៦ ព្រោះការរលត់នាម និងរូប ត្រាស់ដឹងហើយថា ការរលត់ផស្សៈ ព្រោះការរលត់អាយតនៈ ៦ ត្រាស់ដឹងហើយថា ការរលត់វេទនា ព្រោះការរលត់ផស្សៈ ត្រាស់ដឹងហើយថា ការរលត់តណ្ហា ព្រោះការរលត់វេទនា ត្រាស់ដឹងហើយថា ការរលត់ឧបាទាន ព្រោះការរលត់តណ្ហា ត្រាស់ដឹងហើយថា ការរលត់ភព ព្រោះការរលត់ឧបាទាន ត្រាស់ដឹងហើយថា ការរលត់ជាតិ ព្រោះការរលត់ភព ត្រាស់ដឹងហើយថា ការរលត់ជរាមរណៈ ព្រោះការរលត់ជាតិ ត្រាស់ដឹងហើយថា នេះទុក្ខ ត្រាស់ដឹងហើយថា នេះការកើតទុក្ខ ត្រាស់ដឹងហើយថា នេះការរលត់ទុក្ខ ត្រាស់ដឹងហើយថា នេះបដិបទាជាដំណើរទៅកាន់ការរលត់ទុក្ខ ត្រាស់ដឹងហើយថា ទាំងនេះអាសវៈ ត្រាស់ដឹងហើយថា នេះការកើតអាសវៈ ត្រាស់ដឹងហើយថា នេះការរលត់អាសវៈ ត្រាស់ដឹងហើយថា នេះបដិបទាជាដំណើរទៅកាន់ការរលត់អាសវៈ ត្រាស់ដឹងហើយថា ធម៌ទាំងនេះគួរដឹងច្បាស់ ត្រាស់ដឹងហើយថា ធម៌ទាំងនេះគួរលះបង់ ត្រាស់ដឹងហើយថា ធម៌ទាំងនេះគួរចម្រើន ត្រាស់ដឹងហើយនូវការកើតឡើងផង ការវិនាសផង ទោសផង ការរលាស់ចេញនូវផស្សាយតនៈ ៦ ផង ត្រាស់ដឹងហើយនូវការកើតឡើងផង ការវិនាស

ផង ទោសផង ការរលាស់ចេញនូវឧបាទានក្ខន្ធ ៥ ផង ត្រាស់ដឹងហើយនូវការកើតឡើងផង ការវិនាសផង ទោសផង ការរលាស់ចេញនូវមហាភូតរូប ៤ ផង ត្រាស់ដឹងហើយថា ធម្មជាតណាមួយមានការកើតឡើងជាធម្មតា ធម្មជាតទាំងអស់នោះ មានការរលត់ទៅវិញជាធម្មតា គឺថា ត្រាស់ដឹង ត្រាស់ដឹងតាម ត្រាស់ដឹងឯង ប៉ះពាល់ ធ្វើឲ្យជាក់ច្បាស់នូវធម៌ដែលត្រូវត្រាស់ដឹង ដែលត្រូវត្រាស់ដឹងតាម ដែលត្រូវត្រាស់ដឹងឯង ដែលត្រូវប៉ះពាល់ ដែលត្រូវធ្វើឲ្យជាក់ច្បាស់ទាំងអស់ ដោយបច្ចេកពោធិញ្ញាណនោះ ហេតុនោះ ព្រះបច្ចេកសម្ពុទ្ធនោះ ជាបុគ្គលម្នាក់ឯង ព្រោះហេតុត្រាស់ដឹងនូវបច្ចេកសម្ពោធិដ៏ប្រសើរម្នាក់ឯងយ៉ាងនេះ ។

ពាក្យថា គប្បីប្រព្រឹត្ត បានដល់ ការប្រព្រឹត្ត ៨ គឺការប្រព្រឹត្តឥរិយាបថ ១ ការប្រព្រឹត្តអាយតនៈ ១ ការប្រព្រឹត្តសតិ ១ ការប្រព្រឹត្តសមាធិ ១ ការប្រព្រឹត្តញាណ ១ ការប្រព្រឹត្តមគ្គ ១ ការប្រព្រឹត្តបដិបត្តិ ១ ការប្រព្រឹត្តជាប្រយោជន៍លោក ១ ។ ពាក្យថា ការប្រព្រឹត្តឥរិយាបថ បានដល់ការប្រព្រឹត្តក្នុងឥរិយាបថ ៤ ។ ពាក្យថា ការប្រព្រឹត្តអាយតនៈ បានដល់ ការប្រព្រឹត្តក្នុងអាយតនៈ ៦ ទាំងខាងក្នុង ទាំងខាងក្រៅ ។ ពាក្យថា ការប្រព្រឹត្តសតិ បានដល់ ការប្រព្រឹត្តក្នុងសតិប្បដ្ឋាន ៤ ។ ពាក្យថា ការប្រព្រឹត្តសមាធិ បានដល់ការប្រព្រឹត្តក្នុងឈាន ៤ ។ ពាក្យថា ការប្រព្រឹត្តញាណ បានដល់ ការប្រព្រឹត្តក្នុងអរិយសច្ច ៤ ។ ពាក្យថា ការប្រព្រឹត្តមគ្គ បានដល់ ការប្រព្រឹត្តក្នុងមគ្គ ៤ ។ ពាក្យថា ការប្រព្រឹត្តបដិបត្តិ បានដល់ ការប្រព្រឹត្តក្នុងសាមញ្ញផល ៤ ។

ពាក្យថា ការប្រព្រឹត្តជាប្រយោជន៍លោក បានដល់ ការប្រព្រឹត្តមានក្នុងព្រះតថាគតទាំងឡាយជាអរហន្តសម្មាសម្ពុទ្ធ ក្នុងព្រះបច្ចេកសម្ពុទ្ធទាំងឡាយដោយឯកទេស ក្នុងសាវកទាំងឡាយដោយឯកទេស ។ ការប្រព្រឹត្តឥរិយាបថសម្រាប់ពួកបុគ្គលអ្នកបរិបូណ៌ដោយសេចក្តីកសាង ការប្រព្រឹត្តអាយតនៈ សម្រាប់បុគ្គលអ្នកមានទ្វារគ្រប់គ្រងក្នុងឥន្ទ្រិយទាំងឡាយ ការប្រព្រឹត្តសតិ សម្រាប់ពួកបុគ្គលអ្នកមានកិរិយានៅដោយសេចក្តីមិនប្រហែស ការប្រព្រឹត្តសមាធិសម្រាប់ពួកបុគ្គលអ្នកប្រកបរឿយៗ នូវអធិចិត្ត ការប្រព្រឹត្តញាណ សម្រាប់ពួកបុគ្គលអ្នកបរិបូណ៌ដោយបញ្ញា ការប្រព្រឹត្តមគ្គ សម្រាប់ពួកបុគ្គលអ្នកប្រតិបត្តិត្រូវ ការប្រព្រឹត្តបដិបត្តិ សម្រាប់ពួកបុគ្គលអ្នកសម្រេចផល ការប្រព្រឹត្តជាប្រយោជន៍ សម្រាប់ព្រះតថាគតទាំងឡាយជាអរហន្តសម្មាសម្ពុទ្ធ និងសម្រាប់ព្រះបច្ចេកសម្ពុទ្ធទាំងឡាយដោយឯកទេស សម្រាប់សាវកទាំងឡាយដោយឯកទេស ។ នេះការប្រព្រឹត្ត ៨ ។ ការប្រព្រឹត្ត ៨ ដោយឡែកទៀត គឺបុគ្គលជឿប្រព្រឹត្តដោយសទ្ធា ១ ប្រឹងប្រព្រឹត្តដោយវីរិយៈ ១ ប្រុងប្រព្រឹត្តដោយសតិ ១ ធ្វើសេចក្តីមិនរាយមាយ ប្រព្រឹត្តដោយសមាធិ ១ ដឹងច្បាស់ប្រព្រឹត្តដោយបញ្ញា ១ ដឹងវិសេស ប្រព្រឹត្តដោយវិញ្ញាណ ១ បុគ្គលប្រព្រឹត្តដោយការប្រព្រឹត្តអាយតនៈថា ពួកធម៌ជាកុសលរបស់បុគ្គលអ្នកប្រតិបត្តិយ៉ាងនេះ រមែងប្រព្រឹត្តទៅ ១ បុគ្គលប្រព្រឹត្តដោយវិសេសចរិយាថា បុគ្គលប្រតិបត្តិយ៉ាងនេះ រមែងបាននូវគុណវិសេស ១ នេះការប្រព្រឹត្ត ៨ ។ ការប្រព្រឹត្ត ៨ ដោយឡែកទៀត គឺការប្រព្រឹត្តដោយការឃើញរបស់សម្មាទិដ្ឋិ ១ ការប្រព្រឹត្ត

ដោយការលើកចិត្តរបស់សម្មាសង្កប្ប ១ ការប្រព្រឹត្តដោយការរក្សារបស់សម្មាវាចា ១ ការប្រព្រឹត្តដោយការតាំងឡើងរបស់សម្មាកម្មន្តៈ ១ ការប្រព្រឹត្តដោយការផូរផង់របស់សម្មាអាជីវៈ ១ ការប្រព្រឹត្តដោយការផ្គងរបស់សម្មាវាយាមៈ ១ ការប្រព្រឹត្តដោយការប្រុងរបស់សម្មាសតិ ១ ការប្រព្រឹត្តដោយការមិនរាយមាយរបស់សម្មាសមាធិ ១ នេះការប្រព្រឹត្ត ៨ ។

ពាក្យថា ដូចកុយរមាស គឺកុយរមាសមានតែមួយ មិនមានពីរយ៉ាងណា ព្រះបច្ចេកសម្ពុទ្ធនោះ ប្រហែលនឹងកុយរមាសនោះ ប្រាកដស្មើដោយកុយរមាសនោះ មានការប្រៀបដោយកុយរមាសនោះយ៉ាងនោះ ។ វត្ថុមានរសប្រៃក្រៃលែង អ្នកផងតែងនិយាយថាដូចអំបិល វត្ថុមានរសល្វីងក្រៃលែង អ្នកផងតែងនិយាយថាដូចម្រះ វត្ថុមានរសផ្អែមក្រៃលែង អ្នកផងតែងនិយាយថាដូចទឹកឃ្មុំ កម្តៅដ៏ក្រៃលែង អ្នកផងតែងនិយាយថាដូចភ្លើង វត្ថុត្រជាក់ក្រៃលែង អ្នកផងតែងនិយាយថាដូចព្រិល ( ឬទឹកកក ) ធារនៃទឹកច្រើន អ្នកផងតែងនិយាយថាដូចសមុទ្រ សាវកដែលដល់នូវកម្លាំងអភិញ្ញាដ៏ច្រើន អ្នកផងតែងនិយាយថាដូចព្រះសាស្តាយ៉ាងណាមិញ ព្រះបច្ចេកសម្ពុទ្ធនោះ ដូចកុយរមាសនោះ ប្រាកដស្មើដោយកុយរមាសនោះ មានការប្រៀបដោយកុយរមាសនោះ ជាបុគ្គលឯក មិនមានបុគ្គលជាគម្រប់ពីរ របូតចាកចំណងហើយ តែងចរ ត្រាច់ ទៅ ប្រព្រឹត្ត រក្សា យាត្រា ឲ្យយាត្រាទៅក្នុងលោកដោយប្រពៃក៏យ៉ាងនោះដែរ ព្រោះហេតុនោះ លោកពោលថា គប្បីប្រព្រឹត្តម្នាក់ឯង ដូចកុយរមាស ។ ហេតុនោះ ព្រះបច្ចេកសម្ពុទ្ធនោះពោលថា

បុគ្គលទម្លាក់ចេញនូវអាជ្ញាចំពោះពួកសត្វទាំងពួង មិនបៀតបៀននូវសត្វទាំងនោះ សូម្បីសត្វណាមួយ គេមិនចង់បានបុត្រទៅហើយ តើនឹងប្រាថ្នាសម្លាញ់អំពីណាកើត បុគ្គលនោះ គប្បីប្រព្រឹត្តម្នាក់ឯង ដូចកុយរមាស ។

# អដ្ឋកថា

## ខគ្គវិសាណសុត្តនិទ្ទេស

តទៅនេះ ដល់ឱកាសពណ៌នាខគ្គវិសាណសុត្តនិទ្ទេស ហើយក្នុងកិច្ចពណ៌នាខគ្គវិសាណសុត្តនិទ្ទេសនោះ ខាងមុខអំពីពាក្យថា **សព្វេសុ ភូតេសុ និធាយ ទណ្ឌំ** ជាដើមទៅ ខ្ញុំពណ៌នាត្រឹមតែពាក្យដែលលើសប៉ុណ្ណោះ ។

# បឋមវគ្គ

## គាថាទី ១

[ ២៣១ ] ក្នុងបទទាំងនោះ បទថា **សព្វេសុ** បានដល់ មិនមានចំណែកសល់ ។ បទថា **ភូតេសុ** បានដល់ ក្នុងសត្វទាំងឡាយ ។

**ភូត** សព្ទ ក្នុងបទថា **ភូតេសុ** នេះ ប្រព្រឹត្តទៅក្នុងអត្ថថា វត្ថុដែលមាន ដូចក្នុងប្រយោគជាដើមថា **ភូតស្មឹ បាចិត្តិយំ** ភិក្ខុណាមួយ ប្រាប់ឧត្តរិមនុស្សធម្មដល់អនុបសម្បន្ន ត្រូវអាបត្តិបាចិត្តិយៈ ព្រោះឧត្តរិមនុស្សធម្មនោះ ភិក្ខុមានពិតមែន ។

ប្រព្រឹត្តទៅក្នុងអត្ថថា ខន្ធ ៥ ដូចក្នុងប្រយោគជាដើមថា **ភូតមិទំ សារិបុត្ត សមនុបស្សសិ** ម្នាលសារីបុត្រ ចូរអ្នកពិចារណានូវខន្ធនេះ ។ ប្រព្រឹត្តទៅក្នុងអត្ថថា រូប ៤ យ៉ាង មានបឋវីធាតុជាដើម ដូចក្នុងប្រយោគជាដើមថា **ចត្តារោ ខោ ភិក្ខុ មហាភូតា ហេតុ** ម្នាលភិក្ខុ មហាភូតទាំង ៤ ជាហេតុ មហាភូតទាំង ៤ ជាបច្ច័យ ដូច្នេះជាដើម ។ ប្រព្រឹត្តទៅក្នុងអត្ថ

ថា ព្រះវីណាស្រេព ដូចក្នុងប្រយោគជាដើមថា **យោ ច កាលឃសោ ភូតោ** បុគ្គលណាជាអ្នកទំពាស៊ីនូវពេលវេលា ដូច្នេះ ។ ប្រព្រឹត្តទៅក្នុងអត្ថថា សត្វទាំងពួង ដូចក្នុងប្រយោគជាដើមថា **សព្វេវ និក្ខិបិស្សន្តិ ភូតា លោកេ សមុស្សយំ** សត្វទាំងឡាយនេះឯង តែងលះបង់រាងកាយក្នុងលោកដូច្នេះ ។ ប្រព្រឹត្តទៅក្នុងអត្ថថា ដើមឈើ ដូចក្នុងប្រយោគជាដើមថា **ភូតគាមបាតព្យតាយ** ភិក្ខុធ្វើភូតគាម មានឈើ និងស្មៅជាដើមឲ្យវិនាស ត្រូវអាបត្តិបាចិត្តិយៈ ដូច្នេះ ។ ប្រព្រឹត្តទៅក្នុងអត្ថថា ពួកសត្វដែលទាបជាងជាន់ចាតុម្មហារាជិកា ដូចក្នុងប្រយោគជាដើមថា **ភូតេ ភូតតោ សញ្ជានាតិ** បុថុជ្ជនសម្គាល់នូវពួកសត្វថា ជាសត្វពិត ដូច្នេះ ។

តែក្នុងទីនេះ គប្បីជ្រាបថា សត្វទាំងឡាយដែលកើតហើយ លើផែនដីនិងភ្នំជាដើម ឈ្មោះថា សត្វ ( ភូត ) ដោយមិនផ្សេងគ្នា ក្នុងសត្វទាំងនោះ ។

បទថា **និធាយ** បានដល់ ដាក់ហើយ ។ បទថា **ទណ្ឌំ** បានដល់ កាយអាជ្ញា វចីអាជ្ញា និងមនោអាជ្ញា ។ បទនេះ ជាឈ្មោះរបស់កាយទុច្ចរិតជាដើម ។ ពិតហើយ កាយទុច្ចរិត ឈ្មោះថា **ទណ្ឌ** ព្រោះដាក់ទោស ។ មានពាក្យអធិប្បាយថា បៀតបៀនឲ្យដល់សេចក្ដីវិនាស ។ វចីទុច្ចរិត និងមនោទុច្ចរិតក៏ដូចគ្នា ។ ម្យ៉ាងទៀត ការដាក់ទោស ដោយការវាយនោះឯង ឈ្មោះថា **ទណ្ឌ** មានពាក្យអធិប្បាយថា ការដាក់ទោសនោះ ។ បទថា **អវិហេឋយំ** បានដល់ មិនបៀតបៀន ។ បទថា **អញ្ញតរម្បិ** បានដល់

សូម្បីតែសត្វណាមួយ ។ បទថា **តេសំ** បានដល់ សព្វសត្វទាំងនោះ ។ បទថា **ន បុត្តមិច្ឆេយ្យ** សេចក្តីថា មិនគប្បីប្រាថ្នាកូន ណាមួយ ក្នុងកូន ៤ ពួក គឺអត្តជៈ កូនកើតអំពីខ្លួន ១ ខេត្តជៈ កូនកើតក្នុងខេត្ត ១ ទិន្នកៈ កូនដែលគេឲ្យ ១ អន្តេវាសិក កូនសិស្ស ១ ។ បទថា **កុតោ សហាយំ** សេចក្តីថា តែគប្បីប្រាថ្នាសម្លាញ់ ព្រោះហេតុនោះ ការប្រាថ្នាសម្លាញ់នោះ នឹងមានអំពីណា ។ បទថា **ឯកោ** បានដល់ ម្នាក់ឯង ដោយការបួស ។ ឈ្មោះថា **ឯកោ** ព្រោះអត្ថថា មិនមានសម្លាញ់ ព្រោះអត្ថថា លះតណ្ហាបាន ព្រោះប្រាសចាកកិលេសដោយពិតប្រាកដ ព្រោះត្រាស់ដឹងនូវបច្ចេកសម្ពោ-ធិញ្ញាណម្នាក់ឯង ។ ពិតហើយ សូម្បីប្រព្រឹត្តទៅក្នុងកណ្តាលសមណៈរាប់ពាន់ ក៏ឈ្មោះថា ម្នាក់ឯង ព្រោះកាត់នូវការប្រឡូកប្រឡំជាមួយគ្រហស្ថ ដោយប្រការដូច្នេះ ទើបឈ្មោះថា ម្នាក់ឯង ដោយការបួស ។ ឈ្មោះថា **ឯកោ** ព្រោះឈរម្នាក់ឯង ទៅម្នាក់ឯង អង្គុយម្នាក់ឯង ដេកម្នាក់ឯង កម្រើកប្រព្រឹត្តទៅម្នាក់ឯង ដោយប្រការដូច្នេះ ទើបឈ្មោះថា ម្នាក់ឯង ដោយអត្ថថា មិនមានសម្លាញ់ ដូចព្រះតម្រាស់ ( ក្នុងខុទ្ទកនិកាយ ឥតិវុត្តកៈ ) ថា

បុរសមានតណ្ហាជាគម្រប់ពីរ កាលអន្ទោលទៅកាន់សង្សារ អស់កាលដ៏វែង រមែងមិនកន្លងនូវសង្សារវដ្ត ដែលមានសភាពយ៉ាងនេះ និងយ៉ាងដទៃបានឡើយ ភិក្ខុដឹងនូវតណ្ហានេះថា ជាទោស ជាដែនកើតនៃទុក្ខហើយ ជាអ្នកប្រាសចាកតណ្ហា មិនមានសេចក្តីប្រកាន់ ជាអ្នកមានសតិ គប្បីវៀរបង់ចោលចេញ ដូច្នេះ ។

*ដោយប្រការដូច្នេះ ទើបឈ្មោះថា ម្នាក់ឯង ដោយអត្ថថា លះនូវតណ្ហាបាន ។ ឈ្មោះថា ម្នាក់ឯង ព្រោះប្រាសចាកកិលេសដោយពិតប្រាកដយ៉ាងនេះ គឺលះនូវកិលេសទាំងអស់ហើយ កាត់នូវឫសដាច់ហើយ ធ្វើឲ្យដូចត្នោតកំបុតចុង មានការមិនកើតឡើងតទៅជាធម្មតា ។ ឈ្មោះថា ម្នាក់ឯង ព្រោះមិនមានអាចារ្យជាព្រះសយម្ភូ ជាអ្នកត្រាស់ដឹងបច្ចេកសម្ពោធិញ្ញាណដោយខ្លួនឯង ដោយប្រការដូច្នេះ ទើបឈ្មោះថា ម្នាក់ឯង ព្រោះត្រាស់ដឹងបច្ចេកសម្ពោធិញ្ញាណម្នាក់ឯង ។ បទថា* **ចរេ** *បានដល់ ចរិយានេះមាន ៨ យ៉ាង គឺឥរិយាបថចរិយា ការត្រាច់ទៅក្នុងឥរិយាបថ ៤ របស់អ្នកដល់ព្រមដោយការតម្កល់ខ្លួនប្រពៃ ១ អាយតនចរិយា គឺការត្រាច់ទៅក្នុងអាយតនៈខាងក្នុង ៦ របស់អ្នកគ្រប់គ្រងទ្វារក្នុងឥន្ទ្រិយទាំងឡាយ ១ សតិចរិយា ការត្រាច់ទៅក្នុងសតិប្បដ្ឋាន ៤ របស់អ្នកមានប្រក្រតីនៅដោយការមិនប្រមាទ ១ សមាធិចរិយា ការត្រាច់ទៅក្នុងឈាន ៤ របស់អ្នកខ្វល់ខ្វាយក្នុងអធិចិត្ត ១ ញាណចរិយា ការត្រាច់ទៅក្នុងអរិយសច្ច ៤ របស់អ្នកដល់ព្រមដោយបញ្ញា ១ មគ្គចរិយា ការត្រាច់ទៅក្នុងអរិយមគ្គ ៤ របស់អ្នកបដិបត្តិដោយប្រពៃ ១ បត្តិចរិយា ការត្រាច់ទៅក្នុងសាមញ្ញផល ៤ របស់អ្នកសម្រេចផល ១ លោកត្ថចរិយា ការប្រព្រឹត្តជាប្រយោជន៍ដល់លោកក្នុងសព្វសត្វទាំងឡាយរបស់បុគ្គលដែលជាពុទ្ធៈ ៣ ពួក ( សម្មាសម្ពុទ្ធ បច្ចេកពុទ្ធ សាវកពុទ្ធ ) ១ ។ ក្នុងព្រះពុទ្ធ ៣ ពួកនោះ ការប្រព្រឹត្តជាប្រយោជន៍ដល់លោក របស់ព្រះបច្ចេកពុទ្ធ និងព្រះសាវកពុទ្ធ បានចំពោះចំណែកខ្លះ ។ ដូចទ្រង់ត្រាស់ថា*

ពាក្យថា គប្បីប្រព្រឹត្ត បានដល់ ការប្រព្រឹត្ត ៨ គឺការប្រព្រឹត្តឥរិយាបថ ១ ដូច្នេះជាដើម ។ គប្បីជ្រាបសេចក្ដីពិស្ដារក្នុងរឿងនោះ សេចក្ដីថា គប្បីជាអ្នកប្រកបដោយចរិយាទាំងនោះ ។

ម្យ៉ាងទៀត អធិប្បាយថា គប្បីជាអ្នកប្រកបដោយចរិយា ៨ ដទៃទៀត ដែលទ្រង់ត្រាស់យ៉ាងនេះថា

បុគ្គលជឿប្រព្រឹត្តដោយសទ្ធា ១ ប្រឹងប្រព្រឹត្តដោយវិរិយៈ ១ ប្រុងប្រព្រឹត្តដោយសតិ ១ ធ្វើសេចក្ដីមិនរាយមាយ ប្រព្រឹត្តដោយសមាធិ ១ ដឹងច្បាស់ ប្រព្រឹត្តដោយបញ្ញា ១ ដឹងវិសេស ប្រព្រឹត្តដោយវិញ្ញាណ ១ បុគ្គលប្រព្រឹត្ត ដោយការប្រព្រឹត្តអាយតនៈថា ពួកធម៌ជាកុសលរបស់បុគ្គលអ្នកប្រតិបត្តិយ៉ាងនេះ រមែងប្រព្រឹត្តទៅ ១ បុគ្គលប្រព្រឹត្តដោយវិសេសចរិយាថា បុគ្គលប្រតិបត្តិយ៉ាងនេះ រមែងបាននូវគុណវិសេស ១ ដូច្នេះ ។

បទថា **ខគ្គវិសាណកប្បោ** បានដល់ កុយរបស់រមាស ឈ្មោះថា **ខគ្គវិសាណ** ។

**កប្ប** សព្ទនេះ មានន័យច្រើនយ៉ាង គឺជឿ វោហារ កាល បញ្ញត្តិ ឆេទ គឺកាត់ វិកប្ប គឺកំណត់ លេស សមន្តភាវៈ គឺភាវៈជុំវិញ សទិស គឺដូច ។

ពិតហើយ **កប្ប** សព្ទនោះ មកក្នុងអត្ថថា ជឿ ដូចក្នុងប្រយោគជាដើមថា **ឱកប្បនីយមេតំ ភោតោ គោតមស្ស យថា តំ អរហតោ**

**សម្មាសម្ពុទ្ធស្ស** ពាក្យរបស់ព្រះគោតមដ៏ចម្រើន ដែលជាអរហន្តសម្មាសម្ពុទ្ធនេះ ជាពាក្យគួរជឿពិតហើយ ។

មកក្នុងអត្ថថា **វោហារ** ដូចក្នុងប្រយោគជាដើមថា **អនុជានាមិ ភិក្ខវេ បញ្ចហិ សមណកប្បេហិ ផលំ បរិភុញ្ជិតុំ** ម្នាលភិក្ខុទាំងឡាយ តថាគតអនុញ្ញាតឲ្យភិក្ខុឆាន់ផ្លែឈើដោយសមណកប្ប ៥ យ៉ាង ។

មកក្នុងអត្ថថា **កាល** ដូចក្នុងប្រយោគជាដើមថា **យេន សុទំ និច្ចកប្បំ វិហរាមិ** តថាគតនោះឯង តែងនៅអស់កាលជានិច្ច ។

មកក្នុងអត្ថថា **បញ្ញត្តិ** ដូចក្នុងប្រយោគជាដើមថា **ឥច្ចាយស្មា កប្បោ** កប្បមាណពដ៏មានអាយុទូលសួរថា ។

មកក្នុងអត្ថថា **ឆេទ** ដូចក្នុងប្រយោគជាដើមថា **អលង្កតោ កប្បិតកេសមស្សុ** មានខ្លួនប្រដាប់ហើយ មានសក់ និងពុកមាត់ កោរកាត់ហើយ ។

មកក្នុងអត្ថថា **វិកប្ប** ដូចក្នុងប្រយោគជាដើមថា **កប្បតិ ទ្វង្គុលកប្បោ** កំណត់ដោយស្រមោលព្រះអាទិត្យជ្រេទៅ ប្រមាណពីរធ្នាប់ខ្ញុំគួរ ។

មកក្នុងអត្ថថា **លេស** ដូចក្នុងប្រយោគជាដើមថា **អត្ថិ កប្បោ និបជ្ជិតុំ** បើដូច្នោះ អាត្មាអញដេកសិន ។

មកក្នុងអត្ថថា **សមន្តភាវ** ដូចក្នុងប្រយោគជាដើមថា **កេវលកប្បំ វេឡុវនំ ឱភាសេត្វា** ញ៉ាំងវត្តវេឡុវ័នឲ្យភ្លឺស្វាងដោយជុំវិញ ។

មកក្នុងអត្ថថា **សទិស** ដូចក្នុងប្រយោគជាដើមថា **សត្ថុកប្បេន វត ភោ កិរ សាវកេន សទ្ធឹ មន្តយមានា ន ជានិម្ហ** ពុទ្ធោអើយ យើងបាន

ប្រឹក្សាជាមួយនឹងសាវ័ក ដែលទុកស្មើនឹងព្រះសាស្តាផងតើ ។ អធិប្បាយថា មានចំណែកប្រៀប ។

ម្យ៉ាងទៀត ក្នុងបទនេះ គប្បីជ្រាបសេចក្តីថា ដូចគ្នា មានចំណែកប្រៀបជាមួយព្រះសាស្តានោះ ។ លោកពោលថា ប្រៀបដូចកុយរមាស ។ នេះជាពណ៌នាសេចក្តីក្នុងទីនេះត្រឹមប៉ុណ្ណោះសិន តែគប្បីជ្រាបអត្ថដោយអធិប្បាយ និងអនុសន្ធិដូចតទៅ អាជ្ញា មានប្រការដូចពោលហើយនេះ នៅប្រព្រឹត្តទៅក្នុងសត្វទាំងឡាយ មិនទាន់ត្រូវដាក់ចុះ បុគ្គលកាលមិនទាន់ញុំាងអាជ្ញានោះឲ្យប្រព្រឹត្តទៅក្នុងសត្វទាំងឡាយនោះ ឈ្មោះថា ដាក់ចុះនូវអាជ្ញាក្នុងសត្វទាំងពួងហើយដោយមេត្តា ដែលជាបដិបក្ខចំពោះអាជ្ញានោះ និងដោយនាំប្រយោជន៍ចូលទៅឲ្យ ព្រោះជាអ្នកដាក់ចុះនូវអាជ្ញាហើយនោះឯងទើបឈ្មោះថា មិនបៀតបៀនបណ្តាសត្វទាំងនោះ សត្វណាមួយឡើយ ដូចសត្វទាំងឡាយដែលមិនទាន់ដាក់ចុះនូវអាជ្ញា រមែងបៀតបៀនសត្វដោយដំបង ដោយសស្ត្រា ដោយបាតដៃ ឬដោយដុំដី យើងអាស្រ័យមេត្តាកម្មដ្ឋាននេះ ឃើញច្បាស់នូវវេទនា សញ្ញា សង្ខារ និងវិញ្ញាណក្នុងសត្វទាំងនោះ និងឃើញច្បាស់នូវសង្ខតធម៌ដទៃអំពីដទៃក្រៅអំពីនោះ តាមគន្លងនៃមេត្តាកម្មដ្ឋាននោះឯង ហើយសម្រេចបច្ចេកសម្ពោធិញ្ញាណនេះ គប្បីជ្រាបអធិប្បាយ ដូច្នេះ ។

គប្បីជ្រាបអនុសន្ធិដូចតទៅនេះ កាលព្រះបច្ចេកពុទ្ធពោលយ៉ាងនោះហើយ ពួកអមាត្យទាំងនោះក៏ពោលថា បពិត្រលោកម្ចាស់ ឥឡូវនេះ លោក

ម្ចាស់ គិតទៅណា កាលព្រះបច្ចេកពុទ្ធពិចារណាថា ព្រះបច្ចេកសម្ពុទ្ធអំពីមុននៅក្នុងទីណា កាលដឹងហើយ ក៏ពោលថា អាត្មានឹងទៅកាន់ភ្នំគន្ធមាទន៍ ពួកអមាត្យក៏ពោលថា ឱ ឥឡូវនេះ លោកម្ចាស់លះបង់ពួកខ្ញុំទៅ សូមលោកម្ចាស់កុំទៅឡើយ ។ លំដាប់នោះ ព្រះបច្ចេកពុទ្ធពោលពាក្យទាំងអស់ថា **ន បុត្តមិច្ឆេយ្យ** ដូច្នេះជាដើម ។

ក្នុងបទនោះ មានអធិប្បាយដូច្នេះថា ឥឡូវនេះ អាត្មាមិនប្រាថ្នាបុត្រណាមួយ មានបុត្រកើតអំពីខ្លួនជាដើម តើប្រាថ្នាសម្លាញ់ដូចពួកអ្នកអំពីណា ព្រោះដូច្នោះ បណ្តាអ្នកទាំងឡាយ បុគ្គលណាជាបុរសក្តី ជាស្ត្រីក្តី បំណងនឹងទៅជាមួយអាត្មា បុគ្គលនោះ គប្បីត្រាច់ទៅតែម្នាក់ឯង ដូចកុយរមាសដូច្នោះ ។

ម្យ៉ាងទៀត កាលអមាត្យទាំងនោះពោលថា បពិត្រលោកម្ចាស់ លោកម្ចាស់លះបង់ពួកខ្ញុំទៅ លោកម្ចាស់មិនត្រូវការពួកខ្ញុំហើយឬ ។ ព្រះបច្ចេក-សម្ពុទ្ធពោលថា អាត្មាមិនប្រាថ្នាបុត្រ តើនឹងប្រាថ្នាសម្លាញ់មកអំពីណា ឃើញគុណនៃការត្រាច់ទៅម្នាក់ឯង តាមដែលខ្លួនពោលហើយ ក៏ត្រេកអរ កើតនូវបីតិសោមនស្ស ទើបបន្លឺឧទាននេះ ។

[ ២៣២ ] ក្នុងបទទាំងនោះ បទថា **គសា** បានដល់ ធ្វើនូវការស្រែកឃ្លាន ។ បទថា **ភយភេរវោ** បានដល់ មានចិត្តតក់ស្លុតបន្លឺសំឡេងភិតភ័យ ។ បទថា **ជាវរា** បានដល់ ព្រះខីណាស្រព ។ បទថា **និធាយ** បានដល់ លះបង់ ។ បទថា **និធហិត្វា** បានដល់ ដាក់ចុះ ។ បទថា **ឱរោ-**

**បយិត្វា** បានដល់ ដាក់ចុះហើយ ។ បទថា **សមោរោបយិត្វា** បានដល់ ដាក់ចុះខាងក្រោម ។ បទថា **និក្ខិបិត្វា** បានដល់ នាំចេញទៅអំពីទីនោះ ។ បទថា **បដិប្បស្សម្ភិត្វា** បានដល់ ឲ្យស្ងប់ស្ងៀម ។

[ ២៣៤ ] បទថា **អាលបនំ** បានដល់ ការចរចាគ្នាអំពីដំបូង ។ បទថា **សល្លបនំ** បានដល់ ការចរចាគ្នាដោយប្រពៃ ។ បទថា **ឧល្លបនំ**[១] បានដល់ ចរចាសរសើរគ្នានិងគ្នា ។ បទថា **សមុល្លបនំ** បានដល់ សរសើរគ្នានិងគ្នារឿយៗ ។

[ ២៣៥ ] បទថា **ឥរិយាបថចរិយា** សេចក្ដីថា ការប្រព្រឹត្ត គឺការប្រព្រឹត្តទៅនៃឥរិយាបថ ។ សូម្បីក្នុងបទដ៏សេស ក៏ន័យនេះដូចគ្នា ។ តែអាយតនចរិយា គឺការដែលសតិ និងសម្បជញ្ញៈត្រាច់ទៅក្នុងអាយតនៈទាំងឡាយ ។ បទថា **បត្តិ** បានដល់ ផលទាំងឡាយ ។ ឯផលទាំងនោះ លោកហៅថា **បត្តិ** ព្រោះជាហេតុឲ្យសម្រេចប្រយោជន៍ទាំងឡាយ ដែលប្រព្រឹត្តទៅក្នុងទិដ្ឋធម៌ និងសម្បរាយកភពរបស់សត្វលោក ឈ្មោះថា **លោកត្ថ** នេះជាការប្លែកផ្សេងគ្នា ។

ឥឡូវនេះ ព្រះបច្ចេកសម្ពុទ្ធកាលនឹងសម្ដែងភូមិនៃចរិយាទាំងនោះ បានពោលពាក្យថា **ចតូសុ ឥរិយាបថេសុ** ដូច្នេះជាដើម ។

បទថា **សតិប្បដ្ឋានេសុ** សេចក្ដីថា កាលពោលដល់សតិប្បដ្ឋានដែលជាអារម្មណ៍ ក៏ជាការពោលដល់ធម៌ ដែលមិនក្រៅអំពីសតិ តែធ្វើដូច

---

១- បិដកខ្មែរមិនប្រទះបទនេះ ។

ជាដើម ដោយអំណាចវោហារ ។ បទថា **អរិយសច្ចេសុ** លោកពោលដោយការកំណត់សច្ចៈជាផ្នែកៗ ដោយសច្ចញាណដែលជាលោកិយ ដែលជាចំណែកខាងដើម ។ បទថា **អរិយមគ្គេសុ** និងបទថា **សាមញ្ញផលេសុ** លោកពោលដោយអំណាចវោហារប៉ុណ្ណោះ ។ បទថា **បទេសតោ** សេចក្តីថា ក្នុងចំណែកមួយរបស់លោកត្ថចរិយា ។ ពិតហើយ ព្រះពុទ្ធទាំងឡាយទ្រង់រមែងបំពេញលោកត្ថចរិយា ដោយមិនមានចំណែកសល់ ។ ព្រះសារីបុត្រកាលនឹងសម្តែងចរិយាទាំងនោះទៀត ដោយអំណាចនៃការកបុគ្គល ទើបពោលពាក្យថា **បណិធិសម្បន្នានំ** ដូច្នេះជាដើម ។

ក្នុងបទទាំងនោះ គប្បីជ្រាបដូចតទៅនេះ បុគ្គលដល់ព្រមដោយការប្រព្រឹត្តទៅនៃឥរិយាបថ មានឥរិយាបថមិនញាប់ញ័រ ព្រោះឥរិយាបថស្ងប់ បុគ្គលដល់ព្រមដោយឥរិយាបថ ដែលស្ងប់សមគួរដល់ភាពជាភិក្ខុ ឈ្មោះថា **បណិធិសម្បន្នានំ** ។

បទថា **ឥន្ទ្រិយេសុ គុត្តទ្វារានំ** សេចក្តីថា ឈ្មោះថា **គុត្តទ្វារានំ** ព្រោះមានទ្វារគ្រប់គ្រងហើយ ក្នុងឥន្ទ្រិយទាំងឡាយ ៦ មានចក្ខុន្ទ្រិយជាដើម ដោយអំណាចទ្វារ ១ ដែលប្រព្រឹត្តទៅហើយក្នុងវិស័យរៀងៗ ខ្លួន ។ ដល់បុគ្គលគ្រប់គ្រងទ្វារទាំងនោះ ។ម្យ៉ាងទៀត ក្នុងបទថា **ទ្វារានំ** នេះ បានដល់ ចក្ខុទ្វារជាដើម ដោយអំណាចនៃទ្វារដែលកើតឡើងតាមធម្មតា ។ បទថា **អប្បមាទវិហារីនំ** បានដល់ ដល់បុគ្គលដែលនៅដោយសេចក្តីមិនប្រមាទក្នុងគុណទាំងឡាយ មានសីលជាដើម ។ បទថា **អធិចិត្តមនុយុត្តានំ** បាន

ដល់ ដល់បុគ្គលដែលខ្វល់ខ្វាយដោយសមាធិ គឺអធិចិត្តដោយភាពជាបាទនៃវិបស្សនា ។ បទថា **ពុទ្ធិសម្បន្នានំ** បានដល់ ដល់បុគ្គលដែលដល់ព្រមដោយញាណ ដែលប្រព្រឹត្តទៅតាំងអំពីការកំណត់នាមរូប រហូតដល់គោត្រភូ ។ បទថា **សម្មាបដិបន្នានំ** បានដល់ ក្នុងខណៈនៃមគ្គ ៤ ។ បទថា **អធិគត-ផលានំ** បានដល់ ក្នុងខណៈនៃផល ៤ ។

បទថា **តថាគតានំ** បានដល់ ដែលមកហើយយ៉ាងនោះ ។ បទថា **អរហន្តានំ** បានដល់ អ្នកឆ្ងាយចាកកិលេស ។ បទថា **សម្មាសម្ពុទ្ធានំ** បានដល់ ដែលត្រាស់ដឹងធម៌ទាំងពួងដោយប្រពៃនិងដោយខ្លួនឯង ។ សេចក្តីនៃពាក្យទាំងឡាយនេះធ្លាប់អធិប្បាយមកហើយនោះឯង ។

បទថា **បទេសតោ បច្ចេកសម្ពុទ្ធានំ** បានដល់ ចំណែកមួយរបស់ព្រះបច្ចេកពុទ្ធទាំងឡាយ ។ បទថា **បទេសតោ សាវកានំ** បានដល់ ចំណែកមួយរបស់សាវកទាំងឡាយ ។ បទថា **អធិមុច្ចន្តោ** បានដល់ ធ្វើការបង្អោនទៅ ។ បទថា **សទ្ធាយ ចរតិ** បានដល់ ប្រព្រឹត្តទៅដោយអំណាចនៃសទ្ធា ។ បទថា **បគ្គណ្ហន្តោ** បានដល់ ជាអ្នកតាំងមាំដោយសេចក្តីព្យាយាម គឺសម្មប្បធាន ៤ ។ បទថា **ឧបដ្ឋបេន្តោ** បានដល់ ចូលទៅតម្កល់អារម្មណ៍ដោយសតិ ។ បទថា **អវិក្ខេបំ ករោន្តោ** បានដល់ ដែលមិនធ្វើនូវការរាយមាយ ដោយអំណាចនៃសមាធិ ។ បទថា **បជានន្តោ** បានដល់ ដឹងច្បាស់ដោយបញ្ញា ដឹងអរិយសច្ច ៤ ។ បទថា **វិជានន្តោ** បានដល់ ដឹងច្បាស់នូវអារម្មណ៍ដោយវិញ្ញាណ គឺអាវជ្ជនចិត្ត ដែលដល់មុនជវនចិត្តដែល

សម្បយុត្តដោយឥន្ទ្រិយ ។ បទថា **វិញ្ញាណចរិយាយ** បានដល់ ដោយអំណាចនៃវិញ្ញាណចរិយា គឺអាវជ្ជនចិត្ត ។ បទថា **ឯវំ បដិសបន្នស្ស** បានដល់ ដែលបដិបត្តិដោយឥន្ទ្រិយចរិយា មួយអន្លើដោយអាវជ្ជនៈ ។ បទថា **កុសលា ធម្មា អាយាបេន្តិ** បានដល់ កុសលធម៌ទាំងឡាយដែលប្រព្រឹត្តទៅដោយអំណាចនៃសមថៈ និងវិបស្សនា ញុំាងសេចក្ដីវិសេសឲ្យប្រព្រឹត្តទៅ គឺឲ្យប្រព្រឹត្តទូទៅ ។ បទថា **អាយតនចរិយាយ** បានដល់ មានពាក្យអធិប្បាយថា ការមាំទាំរបស់កុសលធម៌ទាំងឡាយ ដោយអាយតនចរិយា គឺដោយការប្រព្រឹត្ត ប្រព្រឹត្តទៅ ។ បទថា **វិសេសមធិគច្ឆតិ** បានដល់ រមែងសម្រេចគុណវិសេស ដោយអំណាចនៃវិក្ខម្ភនប្បហាន តទង្គប្បហាន សមុច្ឆេទប្បហាន និងបដិបស្សទ្ធិប្បហាន ។

គប្បីជ្រាបវិនិច្ឆ័យក្នុងបទថា **ទស្សនចរិយា ច សម្មាទិដ្ឋិយា** ជាដើមដូចតទៅ

ឈ្មោះថា **សម្មាទិដ្ឋិយា** ព្រោះឃើញប្រពៃ ឬជាហេតុឃើញប្រពៃ ឬមានទិដ្ឋិស្អាត គួរសរសើរ ។ ការប្រព្រឹត្តសម្មាទិដ្ឋិនោះ ជាការប្រព្រឹត្តឃើញ ( ទស្សនចរិយា ) ដោយធ្វើព្រះនិព្វានឲ្យប្រចក្ស ។ ឈ្មោះថា **សម្មាសង្កប្ប** ព្រោះត្រិះរិះប្រពៃ ឬជាហេតុត្រិះរិះប្រពៃ ឬតម្រិះត្រូវ គួរសរសើរ ។ ការប្រព្រឹត្តិសម្មាសង្កប្បនោះ ជាការប្រព្រឹត្តិលើកចិត្តឡើងទុកក្នុងអារម្មណ៍ ( អភិនិរោបនចរិយា ) ។ ឈ្មោះថា **សម្មាវាចា** ព្រោះនិយាយត្រូវ ឬជាហេតុនៃការចរចាប្រពៃ ឬចរចាគួរសរសើរ ពាក្យនេះ ជា

ឈ្មោះនៃការវៀរចាកមិច្ឆាវាចា ។ ការប្រព្រឹត្តសម្មាវាចានោះ ជាការប្រព្រឹត្តកំណត់វចីសង្ខារ ៤ យ៉ាង ( បរិគ្គហចរិយា ) ។ ឈ្មោះថា **សម្មាកម្មន្ត** ព្រោះធ្វើប្រពៃ ឬជាហេតុធ្វើប្រពៃ ឬការងារដែលគួរសរសើរ ។ ការងារប្រពៃនោះឯង ឈ្មោះថា **សម្មាកម្មន្ត** ពាក្យនេះ ជាឈ្មោះនៃការរួចចាកមិច្ឆាកម្មន្តៈ ។ ការប្រព្រឹត្តសម្មាកម្មន្តៈនោះ ជាការប្រព្រឹត្តតាំងនៅក្នុងកាយសំវរៈ ៣ យ៉ាង ( សមុដ្ឋានចរិយា ) ។ ឈ្មោះថា **សម្មាអាជីវ** ព្រោះចិញ្ចឹមជីវិតប្រពៃ ឬជាហេតុចិញ្ចឹមជីវិតត្រូវ ឬមានអាជីវៈល្អ គួរសរសើរ ពាក្យនេះ ជាឈ្មោះនៃការវៀរមិច្ឆាអាជីវៈ ។ សម្មាអាជីវៈនោះ ជាការប្រព្រឹត្តផូរផង់ ( វោទានចរិយា ) គឺជាការប្រព្រឹត្តបរិសុទ្ធ ។ ឈ្មោះថា **សម្មាវាយាម** ព្រោះព្យាយាមប្រពៃ ឬជាហេតុព្យាយាមប្រពៃ ឬព្យាយាមល្អ គួរសរសើរ ។ ការប្រព្រឹត្តសម្មាវាយាមនោះ ជាការប្រព្រឹត្តផ្គង ( បគ្គហចរិយា ) ។ ឈ្មោះថា **សម្មាសតិ** ព្រោះរឭកប្រពៃ ឬជាហេតុរឭកត្រូវ ឬរឭកល្អ គួរសរសើរ ។ ការប្រព្រឹត្តសម្មាសតិនោះ ជាការប្រព្រឹត្តប្រាកដ ( ឧបដ្ឋានចរិយា ) ។ ឈ្មោះថា **សម្មាសមាធិ** ព្រោះតាំងចិត្តប្រពៃ ឬជាហេតុតាំងចិត្តប្រពៃ ឬតាំងចិត្តល្អ គួរសរសើរ ។ ការប្រព្រឹត្តសម្មាសមាធិនោះ ជាការប្រព្រឹត្តមិនរាយមាយ ( អវិក្ខេបចរិយា ) ។

បទថា **តក្កប្បា** បានដល់ ដូចកុយរមាសនោះ អធិប្បាយថា មានសភាពយ៉ាងនោះ ។ បទថា **តស្សទិសោ** បានដល់ ដូចគ្នានឹងកុយរមាស ។ បាឋៈថា **តស្សទិកោ** ក៏មាន ។ បទថា **តប្បដិភាគោ** មានវិនិច្ឆ័យថា ព្រះ

*បច្ចេកពុទ្ធប្រៀបដូចកុយរមាសនោះ ឈ្មោះថា* **គប្បដិភាគ** *អធិប្បាយថា មានសភាពដូច្នោះ ។ រសប្រែមិនមានរសផ្អែម ឈ្មោះថា* **អតិលោណា** *ពាក្យថា លោណកប្បោ លោកហៅថា ដូចគ្នានឹង អំបិល ។ បទថា* **អតិ-តិត្តិកំ** *បានដល់ វត្ថុល្វីងខ្លាំង មានស្ដៅជាដើម ។ បទថា* **តិត្តិកប្បោ** *លោកហៅថា ដូចគ្នានឹងរបស់ល្វីង ។ បទថា* **អតិមធុរំ** *បានដល់ រសផ្អែម មានបាយាសលាយដោយទឹកដោះជាដើម ។ បទថា* **ហិមកប្បោ** *បានដល់ ដូចគ្នានឹងព្រិល ។ បទថា* **សត្ថុកប្បោ** *បានដល់ ដូចគ្នានឹងព្រះពុទ្ធជាព្រះសាស្ដា ។ បទថា* **ឯវមេវ** *ជានិបាត ប្រាប់នូវការប្រៀបធៀប ។*

*ខ្ញុំនឹងសម្ដែងវិធីប្រាប់វិបស្សនារបស់ព្រះបច្ចេកពុទ្ធមួយអង្គ ក្នុងព្រះបច្ចេកពុទ្ធទាំងនោះដោយសង្ខេប ហើយអធិប្បាយតទៅថា ក្នុងការចម្រើនវិបស្សនានោះ ព្រះបច្ចេកពោធិសត្វបំណងនឹងធ្វើការកំណត់នាមរូប ទើបចូលឈានណាមួយ ក្នុងឈានសមាបត្តិ ៨ ទាំងដែលជារូបជ្ឈាន និងអរូបជ្ឈាន ចេញអំពីឈានហើយ កំណត់អង្គឈាន មានវិតក្កជាដើម និងធម៌ទាំងឡាយ មានផស្សៈជាដើម ដែលសម្បយុត្តដោយអង្គឈាននោះ ដោយអំណាចនៃលក្ខណៈ កិច្ច បច្ចុប្បដ្ឋាន និងបទដ្ឋាន រមែងកំណត់ថា វត្ថុទាំងអស់នោះ ជា* **នាម** *ដោយអត្ថថា បង្អោនទៅ ដោយការបង្អោនទៅចំពោះអារម្មណ៍ ។ បន្ទាប់អំពីនោះ ក៏ជ្រើសរើសបច្ច័យនៃនាមនោះ រមែងឃើញថា នាម រមែងប្រព្រឹត្តទៅព្រោះអាស្រ័យហទយវត្ថុ ។ កាលឃើញភូតរូបដែលជាបច្ច័យនៃវត្ថុ និងឧបាទាយរូបហើយ រមែងកំណត់ថា ទាំងអស់*

នេះជា **រូប** ព្រោះមានលក្ខណៈបែកធ្លាយទៅ ។ កំណត់នាមរូបទាំង ២ នោះទៀត ដោយសង្ខេបយ៉ាងនេះថា នាម មានលក្ខណៈបង្អោនទៅ រូប មានលក្ខណៈបែកធ្លាយទៅ នេះពោលដោយអំណាចនៃសមថយានិកបុគ្គល ។ ឯវិបស្សនាយានិកបុគ្គល កំណត់ភូតរូប និងឧបាទាយរូបដោយមាតិកា នៃការកំណត់ធាតុ ៤ ហើយ ឃើញថា ធម៌ទាំងអស់នេះ ឈ្មោះថា **រូប** ព្រោះបែកធ្លាយទៅ ។ បន្ទាប់ពីនោះ អរូបធម៌ទាំងឡាយដែលអាស្រ័យចក្ខុវត្ថុជាដើមប្រព្រឹត្តទៅ នៃរូបដែលកំណត់យ៉ាងនេះ រមែងមកកាន់គន្លង ។ បន្ទាប់អំពីនោះ រួមអរូបធម៌ទាំងនោះចូលគ្នាតែមួយ ដោយលក្ខណៈបង្អោនទៅ រមែងឃើញថា នេះជានាម បច្ចេកពោធិសត្វនោះ រមែងកំណត់ដោយចំណែក ២ ថា នេះនាម នេះរូប កាលកំណត់យ៉ាងនោះហើយ រមែងឃើញថា សត្វបុគ្គល ទេវតា ឬព្រហ្មដទៃក្រៅអំពីនាមរូបមិនមាន ។ សមដូចពាក្យ ( របស់ព្រះនាងវជិរាភិក្ខុនីពោលក្នុងសំយុត្តនិកាយ សគាថវគ្គ ) ថា

> ដូចសព្ទដែលបានឈ្មោះថា រថ ដូច្នេះ កើតឡើងបាន ព្រោះ
> បរិបូណ៌ដោយអង្គ យ៉ាងណាមិញ កាលបើខន្ធមានហើយ ការ
> សន្មតិថា សត្វដូច្នេះក៏មាន យ៉ាងនោះឯង ដូច្នេះ ។

លោកកំណត់នាមរូបដោយញាណដែលជាទិដ្ឋិវិសុទ្ធិ ពោល គឺការឃើញតាមសេចក្ដីពិតរបស់នាមរូប ដោយន័យជាដើមយ៉ាងនេះថា កាលឧបាទានក្ខន្ធ ៥ មាន ការសន្មតិថា សត្វ បុគ្គល រមែងមានយ៉ាងនោះ ហើយកំណត់បច្ច័យនៃនាមរូបនោះទៀត កាលកំណត់នាមរូបដោយន័យដែលពោលហើយ

ក៏ជ្រើសរើសថា អ្វីហ្ន៎ ជាហេតុនៃនាមរូបនោះ កាលឃើញទោសក្នុងអហេតុកវាទ និងវិសមហេតុវាទហើយ ទើបស្វែងរកហេតុ និងបច្ច័យរបស់នាមរូបនោះ ដូចពេទ្យកាលឃើញរោគហើយ ទើបពិនិត្យមើលហេតុ និងសមុដ្ឋានរបស់រោគនោះ ឃើញធម៌ ៤ នេះ គឺអវិជ្ជា តណ្ហា ឧបាទាន កម្មថាជាហេតុ ព្រោះជាបច្ច័យឲ្យកើតនាមរូប និងឃើញអាហារថា ជាបច្ច័យព្រោះជាបច្ច័យឧបត្ថម្ភ ។ កំណត់បច្ច័យនៃរូបកាយយ៉ាងនេះថា កាយនេះមានធម៌ ៣ មានអវិជ្ជាជាដើមជាឧបនិស្សយបច្ច័យ ដូចទារក មានមាតាជាឧបនិស្សយបច្ច័យ មានកម្មធ្វើឲ្យកើត ដូចបិតាធ្វើបុត្រឲ្យកើត មានអាហារចិញ្ចឹម ដូចមេដោះចិញ្ចឹមទារក ហើយកំណត់បច្ច័យនៃនាមកាយ ដោយន័យជាដើមថា ព្រោះអាស្រ័យចក្ខុ និងរូប ទើបចក្ខុវិញ្ញាណកើត កាលកំណត់យ៉ាងនេះ រមែងសម្រេចចិត្តបានថា ធម៌ដែលជាអតីត និងអនាគត រមែងប្រព្រឹត្តទៅយ៉ាងនេះប៉ុណ្ណោះ ។

លោកពោលវិចិកិច្ឆាដែលប្រារព្ធអតីត របស់វិបស្សនាយានិកបុគ្គលនោះ ៥ យ៉ាង គឺក្នុងអតីតដែលកន្លងមកថា អញបានកើតហើយឬហ្ន៎ ១ អញមិនបានកើតហើយឬហ្ន៎ ១ អញបានកើតមកហើយឬហ្ន៎ ១ អញបានកើតដូចម្តេចហើយហ្ន៎ ១ អញកើតជាអ្វី ហើយបានកើតជាអ្វីទៀតហ្ន៎ ១ ។

លោកពោលវិចិកិច្ឆា ដែលប្រារព្ធអនាគតរបស់វិបស្សនាយានិកបុគ្គលនោះ ៥ យ៉ាង ក្នុងអនាគតកាលថា អញនឹងកើតឬហ្ន៎ ១ អញនឹងមិនកើតឬហ្ន៎ ១ អញនឹងកើតជាអ្វីហ្ន៎ ១ អញនឹងកើតដូចម្តេចហ្ន៎ ១ អញកើតជាអ្វី

ហើយនឹងកើតជាអ្វីទៀតហ្ន៎ ១ ។

ការសង្ស័យឯណា ដែលប្រារព្ធបច្ចុប្បន្នកើតឡើង សេចក្ដីសង្ស័យនោះ លោកពោល ៦ យ៉ាងថា អញកំពុងកើតឬហ្ន៎ ១ អញមិនកំពុងកើតឬហ្ន៎ ១ អញកើតជាអ្វីហ្ន៎ ១ អញកើតដូចម្ដេចហ្ន៎ ១ សត្វនេះមកអំពីទីណាហ្ន៎ ១ សត្វនេះនឹងទៅទីណាហ្ន៎ ១ ។

លោកលះនូវសេចក្ដីសង្ស័យទាំងអស់នោះបាន ។ ដោយការកំណត់បច្ច័យយ៉ាងនេះ ញាណដែលឆ្លងសេចក្ដីសង្ស័យក្នុងកាល ៣ តាំងនៅ ហៅថា ជាកង្ខាវិតរណវិសុទ្ធិក៏មាន ថាជាធម្មដ្ឋិតិញ្ញាណក៏មាន ថាជាយថាភូតញ្ញាណក៏មាន ថាជាសម្មាទស្សនៈក៏មាន ។

មយ៉ាងទៀត គប្បីជ្រាបវិនិច្ឆ័យក្នុងបទនេះថា ពិតហើយ លោកិយបរិញ្ញាមាន ៣ គឺញាតបរិញ្ញា ១ តីរណបរិញ្ញា ១ បហានបរិញ្ញា ១ ។

ក្នុងបរិញ្ញាទាំងនោះ បញ្ញាប្រព្រឹត្តទៅដោយអំណាចការកំណត់លក្ខណៈចំពោះខ្លួនរបស់ធម៌ទាំងនោះយ៉ាងនេះថា រូប មានលក្ខណៈបែកធ្លាយ វេទនាមានលក្ខណៈដោយអារម្មណ៍ ដូច្នេះ ឈ្មោះថា **ញាតបរិញ្ញា** ។

វិបស្សនាបញ្ញាដែលមានលក្ខណៈជាអារម្មណ៍ ដែលប្រព្រឹត្តទៅហើយដោយលើកធម៌ទាំងនោះឡើងកាន់សាមញ្ញលក្ខណៈ ដោយន័យជាដើមថា រូបមិនទៀង វេទនាមិនទៀង ដូច្នេះ ឈ្មោះថា **តីរណបរិញ្ញា** ។

វិបស្សនាបញ្ញា ដែលមានលក្ខណៈជាអារម្មណ៍ ដែលប្រព្រឹត្តទៅហើយដោយអំណាចការលះនិច្ចសញ្ញាជាដើមក្នុងធម៌ទាំងនោះឯង ឈ្មោះថា **បហា-**

ធបរិញ្ញា ។

ក្នុងបរិញ្ញាទាំងនោះ ភូមិនៃញាតបរិញ្ញា ផ្ដើមតាំងអំពីកំណត់សង្ខារ រហូតដល់កំណត់បច្ច័យ ។ ក្នុងចន្លោះនេះ ការចាក់ធ្លុះលក្ខណៈចំពោះខ្លួន នៃធម៌ទាំងឡាយ រមែងជាធំ ។

ភូមិនៃតីរណបរិញ្ញា ផ្ដើមតាំងពីការពិចារណាគំនរនៃសង្ខារ រហូតដល់ឧទយព្វយានុបស្សនា ។ ក្នុងចន្លោះនេះ ការចាក់ធ្លុះនូវសាមញ្ញលក្ខណៈ រមែងជាធំ ។

ភូមិនៃបហានបរិញ្ញា ផ្ដើមតាំងអំពីភង្គានុបស្សនាឡើងទៅ ។ បន្ទាប់អំពីនោះ ពិចារណាឃើញដោយភាពជារបស់មិនទៀង រមែងលះនិច្ចសញ្ញាបាន ពិចារណាឃើញដោយភាពជាទុក្ខ រមែងលះសុខសញ្ញាបាន ពិចារណាឃើញដោយភាពមិនជាតួខ្លួន រមែងលះអត្តសញ្ញាបាន កាលនឿយណាយ រមែងលះការត្រេកអរ ( នន្ទិ ) បាន កាលប្រាសចាកតម្រេក រមែងលះរាគៈបាន កាលរលត់ រមែងលះសមុទយៈបាន កាលរលាស់ រមែងលះនូវការប្រកាន់ ( អាទាន ) បាន ដោយប្រការដូច្នេះ អនុបស្សនា ៧ ដែលសម្រេចដោយការលះនិច្ចសញ្ញាជាដើម រមែងជាធំ ។ ក្នុងបរិញ្ញា ៣ នេះ ឈ្មោះថា ព្រះយោគាវចរនេះសម្រេចញាតបរិញ្ញាហើយ ព្រោះឲ្យសម្រេចនូវការកំណត់សង្ខារ និងការកំណត់បច្ច័យ ។

ព្រះយោគាវចរ រមែងធ្វើការពិចារណាជាកលាបៈ ដោយន័យជាដើមយ៉ាងនេះថា រូបណានីមួយ ជាអតីត អនាគត បច្ចុប្បន្ន ជាខាងក្នុងក្ដី ខាង

ក្រៅក្តី ។បេ។ ស្ថិតនៅក្នុងទីឆ្ងាយក្តី ក្នុងទីជិតក្តី រូបទាំងអស់នោះ ជារបស់មិនទៀង ព្រោះមានហើយប្រែជាមិនមាន ជាទុក្ខ ព្រោះត្រូវបៀតបៀនដោយការកើត និងការរលត់ ជាអនត្តា ព្រោះមិននៅក្នុងអំណាច ។ វេទនាណាមួយ ... ។ សញ្ញាណាមួយ ... ។ សង្ខារទាំងឡាយណាមួយ ... ។ វិញ្ញាណណាមួយ ជាអតីត អនាគត បច្ចុប្បន្ន ជាខាងក្នុងក្តី ខាងក្រៅក្តី គ្រោតគ្រាតក្តី ល្អិតក្តី ថោកទាបក្តី ឧត្តមក្តី ស្ថិតនៅក្នុងទីឆ្ងាយក្តី ក្នុងទីជិតក្តី វិញ្ញាណទាំងអស់នោះ ជារបស់មិនទៀង ព្រោះមានហើយប្រែជាមិនមាន ជាទុក្ខ ព្រោះត្រូវបៀតបៀនដោយការកើត និងការរលត់ ជាអនត្តា ព្រោះមិននៅក្នុងអំណាច ។ ពោលសំដៅដល់ការពិចារណាជាកលាបៈនេះ ទើបលោកពោលថា លើកឡើងកាន់ត្រៃលក្ខណ៍ ។

ព្រះយោគាវចរ ធ្វើការពិចារណាសង្ខារទាំងឡាយជាកលាបៈ ដោយអំណាចនៃការមិនទៀង ជាទុក្ខ ជាអនត្តា យ៉ាងនេះហើយ រមែងឃើញនូវការកើត និងការរលត់នៃសង្ខារទាំងឡាយទៀត ។ សួរថា ឃើញដូចម្តេច ឆ្លើយថា ឃើញនូវការកើតនៃរូបក្ខន្ធ ដោយការឃើញថា រូបក្ខន្ធជារបស់ទាក់ទងដោយបច្ច័យយ៉ាងនេះ ( ក្នុងបដិសម្ភិទាមគ្គ ) ថា ការកើតឡើងនៃរូប ព្រោះកើតឡើងនៃអវិជ្ជា ការកើតឡើងនៃរូប ព្រោះកើតឡើងនៃតណ្ហា ការកើតឡើងនៃរូប ព្រោះកើតឡើងនៃកម្ម ការកើតឡើងនៃរូប ព្រោះកើតឡើងនៃអាហារ ដូច្នេះហើយ កាលឃើញនិព្វត្តិលក្ខណៈ គឺលក្ខណៈនៃការកើត ក៏រមែងឃើញនូវការកើតនៃរូបក្ខន្ធផងដែរ ។ ឈ្មោះថា រមែងឃើញ

នូវការកើតនៃរូបក្ខន្ធដោយអាការ ៥ យ៉ាង ដោយប្រការដូច្នេះ រមែងឃើញនូវការវិនាសនៃរូបក្ខន្ធ ដោយការឃើញការរលត់នៃបច្ច័យថា ការរលត់ទៅនៃរូប ព្រោះរលត់ទៅនៃអវិជ្ជា ការរលត់ទៅនៃរូប ព្រោះរលត់ទៅនៃតណ្ហា ការរលត់ទៅនៃរូប ព្រោះរលត់ទៅនៃកម្ម ការរលត់ទៅនៃរូប ព្រោះរលត់ទៅនៃអាហារ កាលឃើញវិបរិណាមលក្ខណៈ គឺលក្ខណៈប្រែប្រួល ក៏រមែងឃើញការវិនាសនៃរូបក្ខន្ធផងដែរ ។ ឈ្មោះថា រមែងឃើញនូវការវិនាសនៃរូបក្ខន្ធ ដោយអាការ ៥ យ៉ាង ដោយប្រការដូច្នេះ ។

ម្យ៉ាងទៀត ព្រះយោគាវចររមែងឃើញនូវការកើតនៃវេទនាខន្ធ ដោយការឃើញនូវការទាក់ទងដោយបច្ច័យថា ការកើតឡើងនៃវេទនា ព្រោះកើតឡើងនៃអវិជ្ជា ការកើតឡើងនៃវេទនា ព្រោះកើតឡើងនៃតណ្ហា ការកើតឡើងនៃវេទនា ព្រោះកើតឡើងនៃកម្ម ការកើតឡើងនៃវេទនា ព្រោះកើតឡើងនៃផស្សៈ កាលឃើញនិព្វត្តិលក្ខណៈ គឺលក្ខណៈនៃការកើត ក៏រមែងឃើញការកើតនៃវេទនាខន្ធផងដែរ ។ រមែងឃើញនូវការវិនាសនៃវេទនាខន្ធ ដោយការឃើញនូវការរលត់នៃបច្ច័យថា ការរលត់ទៅនៃវេទនា ព្រោះរលត់ទៅនៃអវិជ្ជា ការរលត់ទៅនៃវេទនា ព្រោះរលត់ទៅនៃតណ្ហា ការរលត់ទៅនៃវេទនា ព្រោះរលត់ទៅនៃកម្ម ការរលត់ទៅនៃវេទនា ព្រោះរលត់ទៅនៃផស្សៈ កាលឃើញបរិណាមលក្ខណៈ គឺលក្ខណៈប្រែប្រួល ក៏រមែងឃើញនូវការវិនាសនៃវេទនាខន្ធផងដែរ ។ ក្នុងសញ្ញាខន្ធជាដើមក៏យ៉ាងនេះ ។ តែក៏មានការផ្សេងគ្នាដូច្នេះថា សម្រាប់វិញ្ញាណក្ខន្ធត្រង់ទីដែលជាផស្សៈ គប្បីប្រកប គឺជំនួស

ដោយពាក្យថា ការកើតឡើងនៃវិញ្ញាណ ព្រោះកើតឡើងនៃនាម និងរូប ការរលត់ទៅនៃវិញ្ញាណ ព្រោះរលត់ទៅនៃនាម និងរូប ដូច្នេះ ។ លោកពោលដល់លក្ខណៈ ៥០ បែងចែកជា ១០ ក្នុងការឃើញការកើត និងការរលត់ក្នុងខន្ធនីមួយៗ ដោយការកើតនៃបច្ច័យនិងដោយនិព្វត្តិលក្ខណៈ គឺលក្ខណៈនៃការកើត និងដោយការរលត់នៃបច្ច័យ និងដោយវិបរិណាមលក្ខណៈ គឺលក្ខណៈ នៃការប្រែប្រួល ដោយអំណាចនៃលក្ខណៈទាំងនោះ ព្រះយោគាវចរធ្វើមនសិការដោយពិស្តារ ទាំងដោយបច្ច័យ ទាំងដោយខណៈថា ការកើតនៃរូប រមែងកើតយ៉ាងនេះ ការរលត់នៃរូប រមែងរលត់យ៉ាងនេះ ។

កាលព្រះយោគាវចរធ្វើយ៉ាងនេះ ញាណរមែងជាញាណបរិសុទ្ធថា បានឮថា ធម៌ទាំងនេះមិនមានហើយ រមែងកើត មានហើយ រមែងរលត់ ដោយប្រការដូច្នេះ ។ សង្ខារទាំងឡាយ រមែងប្រាកដជារបស់ថ្មីជានិច្ចថា បានឮថា ធម៌ទាំងនេះ ដែលមិនទាន់កើត រមែងកើតឡើង ដែលកើតឡើងហើយ រមែងរលត់ទៅ ដោយប្រការដូច្នេះ ។ សង្ខារទាំងឡាយ មិនមែនជារបស់ថ្មីជានិច្ចតែម្យ៉ាងនោះទេ នៅជារបស់តាំងនៅអស់កាលបន្តិចបន្តួច ដូចតំណក់ទឹកសន្សើមក្នុងពេលព្រះអាទិត្យរះ ដូចដុំពពុះទឹក ដូចស្នាមគំនូសក្នុងទឹក ដូចគ្រាប់ស្ពៃលើចុងដែកស្រួច ដូចផ្លេកបន្ទោរ រមែងប្រាកដដូចមិនមានសារៈ រកសារៈមិនបាន ដូចកលមាយា ថ្ងៃបណ្ដើរកូន ការយល់សប្តិ វង្វង់ភ្លើង ( ដែលគេគ្រវី ) នគរគន្ធព្វ ក្រពេញទឹក និងដើមចេកជាដើម ។ ដោយ

ហេតុមានប្រមាណប៉ុណ្ណេះ ឈ្មោះថា ព្រះយោគាវចរ បានសម្រេចវិបស្សនា-ញាណយ៉ាងទន់ ជាញាណដំបូង ឈ្មោះថា ឧទយព្វយានុបស្សនាញាណ ដែលចាក់ធ្លុះលក្ខណៈ ៥០ តាំងទៅដោយអាការយ៉ាងនេះថា ធម៌ដែលមានការអស់ទៅសូន្យទៅជាធម្មតានោះឯង រមែងកើតឡើង ធម៌ដែលកើតឡើងហើយ រមែងដល់នូវការអស់ទៅសូន្យទៅ ។ ព្រោះព្រះយោគាវចរសម្រេចតរុណវិបស្សនាញាណ ទើបរាប់ថា ជាអ្នកប្រារព្ធវិបស្សនាហើយ ។

ពេលនោះសម្រាប់កុលបុត្រដែលផ្ដើមវិបស្សនាហើយ វិបស្សនូកិលេស ១០ យ៉ាង រមែងកើតឡើងបាន គឺឱភាស ១ ញាណ ១ បីតិ ១ បស្សទ្ធិ ១ សុខ ១ អធិមោក្ខ ១ បគ្គហៈ ១ ឧបដ្ឋាន ១ ឧបេក្ខា ១ និកន្តិ ១ ។

ក្នុងវិបស្សនូបក្កិលេសទាំងនេះ ឈ្មោះថា **ឱភាស** គឺលោហិតស្ងប់ ព្រោះញាណមានកម្លាំងក្នុងខណៈនៃវិបស្សនា ។ ព្រោះលោហិតស្ងប់នោះ ពន្លឺនៃចិត្តរមែងកើត ។ ព្រះយោគាវចរអ្នកមិនឈ្លាស កាលឃើញដូច្នោះហើយ ពេញចិត្តនឹងពន្លឺនោះ ដោយគិតថា អញសម្រេចមគ្គហើយ ។ សូម្បីញាណក៏គឺវិបស្សនាញាណនោះឯង វិបស្សនាញាណនោះចាស់ក្លា ផូរផង់ រមែងប្រព្រឹត្តទៅដល់អ្នកពិចារណាសង្ខារទាំងឡាយ ។ ព្រះយោគាវចរឃើញដូច្នោះ រមែងពេញចិត្តថា អញបានសម្រេចមគ្គហើយ ដូចក្នុងកាលមុន ។ បីតិក៏គឺវិបស្សនាបីតិនោះឯង ។ ក្នុងខណៈនោះ បីតិ ៥ យ៉ាង រមែងកើតឡើងដល់ព្រះយោគាវចរនោះ ។ បស្សទ្ធិក្នុងវិបស្សនា ឈ្មោះថា **បស្សទ្ធិ** ក្នុងសម័យនោះ កាយ និងចិត្ត មិនក្រវល់ក្រវាយ មិនធ្ងន់ មិនរឹងត្អឹង មិន

មាននូវការមិនគួរដល់ការផ្សារ មិនមានអាពាធ មិនមានការវៀច ។ សូម្បីសុខក៏ជាសុខក្នុងវិបស្សនាប៉ុណ្ណោះ ។ បានឮថា ក្នុងសម័យនោះ សេចក្ដីសុខដ៏ប្រណីតក្រៃលែង រមែងកើតឡើងគ្របដណ្ដប់ ពេញរាងកាយរបស់ព្រះយោគាវចរនោះ ។

សទ្ធាដែលប្រព្រឹត្តទៅក្នុងខណៈនៃវិបស្សនា ឈ្មោះថា **អធិមោក្ខ ។** ពិតហើយ ក្នុងខណៈនោះ សទ្ធាដែលតាំងមាំ ដែលមានកម្លាំង ដែលធ្វើ ចិត្តនិងចេតសិកឲ្យថ្លាផងយ៉ាងក្រៃលែង រមែងកើតឡើង ។ សេចក្ដីព្យាយាមដែលសម្បយុត្តដោយវិបស្សនា ឈ្មោះថា **បគ្គហៈ** ពិតហើយ ក្នុងខណៈនោះ សេចក្ដីព្យាយាមដែលមិនធូរថយពេក មិនតឹងរ៉ឹងពេក ផ្គងល្អហើយ រមែងកើតឡើង ។ សតិដែលសម្បយុត្តដោយវិបស្សនា ឈ្មោះថា **ឧបដ្ឋាន ។** ពិតហើយ ក្នុងសម័យនោះ សតិដែលតាំងមាំល្អហើយ រមែងកើតឡើង ។ ឧបេក្ខាមាន ២ យ៉ាង ដោយអំណាចនៃវិបស្សនា និងអាវជ្ជនៈ ។ ពិតហើយ ក្នុងខណៈនោះ ញាណ ពោល គឺវិបស្សនូបេក្ខា ដែលមានភាពជាកណ្ដាលក្នុងការប្រកាន់នូវសង្ខារទាំងពួង ជាសភាវៈមានកម្លាំង រមែងកើតឡើង ។ ឧបេក្ខាក្នុងមនោទ្វារាវជ្ជនៈ ក៏រមែងកើតឡើង ។ ឧបេក្ខានោះខ្លាំងក្លា រមែងកើតឡើងដល់បុគ្គលអ្នកពិចារណាដល់ឋានៈនោះៗ ។ ការពេញចិត្តក្នុងវិបស្សនា ឈ្មោះថា **និកន្តិ ។** ពិតហើយ ក្នុងវិបស្សនូបក្កិលេស មានឱភាសជាដើម និកន្តិ មានអាការស្ងប់សុខុម ធ្វើនូវសេចក្ដីអាល័យរមែងកើតឡើង ។ ឱភាសជាដើម ក្នុងវិបស្សនូបក្កិលេសនេះ លោកពោលថា ជាឧបក្កិលេស ព្រោះ

ជាទីតាំងនៃកិលេស មិនមែនព្រោះជាអកុសល ។ តែនិកន្តិជាឧបក្កិលេសផង ជាទីតាំងនៃកិលេសផង ។ ភិក្ខុជាបណ្ឌិត កាលឱភាសជាដើមកើតឡើងហើយ កុំវាយមាយ ឲ្យកំណត់មគ្គ និងមិនមែនមគ្គថា ធម៌ទាំងឡាយ មានឱភាសជាដើម មិនមែនមគ្គ តែវិបស្សនាញាណដែលទៅតាមវិថី ផុតចាកឧបក្កិលេសជាមគ្គ ។ ញាណកំណត់ដឹងថា នេះជាមគ្គ នេះមិនមែនមគ្គរបស់អ្នកបដិបត្តិនោះ លោកហៅថា មគ្គាមគ្គញ្ញាណទស្សនវិសុទ្ធិ ។ តាំងអំពីនេះទៅ ធម៌នេះ គឺវិបស្សនាញាណ ដែលដល់នូវភាពជាកំពូល ដោយអំណាចវិបស្សនាញាណ ៨ យ៉ាងនេះ និងសច្ចានុលោមិកញ្ញាណទី ៩ ឈ្មោះថាបដិបទាញាណទស្សនវិសុទ្ធិ ។ ឈ្មោះថា ញាណ ៨ នេះ គឺឧទយព្វយា-នុបស្សនាញាណ ១ ភង្គានុបស្សនាញាណ ១ ភយតូបដ្ឋានញ្ញាណ ១ អាទីនវានុបស្សនាញាណ ១ និព្វិទានុបស្សនាញាណ ១ មុញ្ចិតុកម្យតា-ញាណ ១ បដិសង្ខានុបស្សនាញាណ ១ សង្ខារុបេក្ខាញាណ ១ ។ ពាក្យថាសច្ចានុលោមិកញ្ញាណទី ៩ នេះ ជាឈ្មោះរបស់អនុលោមញ្ញាណ ព្រោះដូច្នោះ បុគ្គលបំណងនឹងឲ្យវិបស្សនាញាណនោះបរិបូណ៌ គួរធ្វើសេចក្តីព្យា-យាមក្នុងញាណទាំងនោះ តាំងអំពីឧទយព្វយញ្ញាណ ដែលផុតចាកឧបក្កិលេសហើយជាដើមទៅ ព្រោះកាលឃើញការកើត និងការរលត់ អនិច្ចលក្ខណៈរមែងប្រាកដតាមសេចក្តីពិត ។ កាលឃើញការបៀតបៀននៃការកើតឡើង និងការរលត់ទៅ ទុក្ខលក្ខណៈ រមែងប្រាកដតាមសេចក្តីពិត កាលឃើញថា ព្រោះថា សេចក្តីទុក្ខ រមែងកើតឡើង សេចក្តីទុក្ខរមែងស្ថិតនៅផង វិនាសទៅផង

អនត្តលក្ខណៈ រមែងប្រាកដតាមសេចក្តីពិត ។

ម្យ៉ាងទៀត ក្នុងសេចក្តីនេះ គប្បីជ្រាបការចែកនេះ គឺនិច្ចំ អនិច្ចលក្ខណៈ ទុក្ខំ ទុក្ខលក្ខណៈ អនត្តា អនត្តលក្ខណៈ ដូចតទៅនេះ

ក្នុងការចែកទាំងនោះ ពាក្យថា **អនិច្ចំ** គឺខន្ធ ៥ ។ ព្រោះហេតុអ្វី ព្រោះខន្ធ ៥ នោះ មានការកើតឡើង មានការវិនាសទៅ និងមានសភាពដទៃ ឬព្រោះមានហើយ ប្រែជាមិនមាន ។ ជរា ឈ្មោះថា ដទៃ ។ ការកើតឡើងនិងការវិនាសទៅ និងភាពដទៃ ឈ្មោះថា អនិច្ចលក្ខណៈ ។ ឬភាពនៃការវិការនៃអាការពោល គឺការមានហើយ ត្រឡប់ជាមិនមាន ឈ្មោះថា អនិច្ចលក្ខណៈ ។ ខន្ធ ៥ នោះឯងជាទុក្ខ ព្រោះព្រះពុទ្ធតម្រាស់ថា របស់ណាមិនទៀង របស់នោះជាទុក្ខ ព្រោះហេតុអ្វី ព្រោះបៀតបៀនរឿយៗ អាការបៀតបៀនរឿយៗ ឈ្មោះថា ទុក្ខលក្ខណៈ ។ ខន្ធ ៥ នោះឯងជាអនត្តា ព្រោះព្រះពុទ្ធតម្រាស់ថា របស់ណាជាទុក្ខ របស់នោះជាអនត្តា ព្រោះហេតុអ្វី ព្រោះមិនប្រព្រឹត្តទៅក្នុងអំណាច ។ អាការមិនប្រព្រឹត្តទៅក្នុងអំណាច ឈ្មោះថា អនត្តលក្ខណៈ ។ លក្ខណៈ ៣ យ៉ាងនេះ រមែងជាអារម្មណ៍របស់អ្នកឃើញការកើត និងការរលត់នោះឯង បុគ្គលនោះ រមែងឃើញរូបធម៌ និងអរូបធម៌នោះឯងទៀត ដោយន័យជាដើមថា មិនទៀង ។ សង្ខារទាំងឡាយរបស់បុគ្គលនោះ រមែងមកកាន់គន្លងដោយឆាប់រហ័ស ។ បន្ទាប់អំពីនោះ កាលមានការអស់នូវការវិនាស និងការរលត់នៃសង្ខារទាំងនោះ ព្រះយោគាវចរមិនធ្វើនូវការកើតឡើង ការតាំងនៅ ការប្រព្រឹត្តទៅ ឬនិមិត្តឲ្យជាអារម្មណ៍

តាំងនៅ នេះ ឈ្មោះថា ភង្គញ្ញាណ ។ ចាប់តាំងពីភង្គញ្ញាណនេះកើត ព្រះយោគាវចរនេះឃើញនូវការរលត់ប៉ុណ្ណោះថា សង្ខារទាំងឡាយនេះ រមែងបែកធ្លាយទៅ យ៉ាងណា សូម្បីក្នុងអតីត សង្ខារក៏បែកហើយ ក្នុងអនាគតក៏បែក ដូច្នោះ កាលព្រះយោគាវចរនោះសេពភង្គានុបស្សនារឿយៗ ធ្វើឲ្យច្រើន សង្ខារទាំងឡាយដែលផ្សេងគ្នា ក្នុងភព កំណើត គតិ ឋិតិ និងសត្តាវាសទាំងពួង រមែងប្រាកដជាភ័យធំ ដូចរណ្តៅរងើកភ្លើងដែលឆេះសន្ធោសន្ធៅជាដើម នេះ ឈ្មោះថា ភយតូបដ្ឋានញ្ញាណ ។

កាលព្រះយោគាវចរនោះសេពភយតូបដ្ឋានញ្ញាណនោះ ភពទាំងអស់ជាដើម រមែងប្រាកដជាទីពឹងមិនបាន មានទោសដូចខ្ទះដែលត្រូវភ្លើងឆេះដូចសត្រូវឆ្មាជាវហើយ ដូច្នោះ នេះ ឈ្មោះថា អាទីនវានុបស្សនាញាណ ។

កាលព្រះយោគាវចរនោះ ឃើញសង្ខារដោយការមានទោសយ៉ាងនេះការនឿយណាយ ការមិនត្រេកអរ រមែងកើតឡើងក្នុងសង្ខារទាំងពួង ព្រោះសង្ខារទាំងឡាយក្នុងភពជាដើម មានទោស នេះ ឈ្មោះថា និព្វិទានុបស្សនាញាណ ។

កាលនឿយណាយ គឺមិនពេញចិត្តក្នុងសង្ខារទាំងពួង ភាពជាអ្នកប្រាថ្នានិងរួចផុត គឺភាពជាអ្នកប្រាថ្នា ដើម្បីរលាស់ចេញអំពីសង្ខារនោះ រមែងមានឡើង នេះ ឈ្មោះថា មុញ្ចិតុកម្យតាញាណ ។

ការលើកសង្ខារទាំងនោះឡើងកាន់ត្រៃលក្ខណ៍ ហើយពិចារណាដោយបដិសង្ខានុបស្សនាញាណ ដើម្បីផុតចាកសង្ខារនោះ ឈ្មោះថា បដិសង្ខា-

នុបស្សនាញាណ ។

ព្រះយោគាវចរនោះ លើកសង្ខារទាំងឡាយឡើងកាន់ត្រៃលក្ខណ៍យ៉ាង នេះហើយ កំណត់ដឹងនូវសង្ខារទាំងឡាយ មិនប្រកាន់ថាជាខ្លួន ឬថា ជារបស់ទាក់ទងដោយខ្លួន ព្រោះឃើញច្បាស់នូវភាពជាអនត្តលក្ខណៈក្នុងសង្ខារទាំងនោះ ទើបលះនូវការខ្លាច និងការត្រេកអរក្នុងសង្ខារទាំងឡាយ ជាអ្នកព្រងើយ ជាកណ្តាល ក្នុងសង្ខារទាំងឡាយ មិនប្រកាន់ថា អញ ឬរបស់អញ ជាអ្នកព្រងើយក្នុងភពទាំង ៣ នេះ ឈ្មោះថា សង្ខារុបេក្ខាញាណ ។

បើព្រះយោគាវចរឃើញព្រះនិព្វានជាផ្លូវស្ងប់ ដោយភាពជាធម្មជាតស្ងប់ សង្ខារុបេក្ខាញាណនេះ ក៏នឹងលះនូវការប្រព្រឹត្តទៅនៃសង្ខារទាំងពួងហើយស្ទុះទៅ បង្អោនទៅក្នុងនិព្វាន ។ បើព្រះយោគាវចរមិនឃើញនិព្វានដោយភាពជាធម្មជាតស្ងប់ សង្ខារុបេក្ខាញាណក៏នឹងមានសង្ខារជាអារម្មណ៍ប៉ុណ្ណោះ ប្រព្រឹត្តទៅរឿយៗ ដោយអំណាចនៃអនុបស្សនា ៣ យ៉ាង គឺ អនិច្ចានុបស្សនា ទុក្ខានុបស្សនា ឬអនត្តានុបស្សនា ។ម្យ៉ាងទៀត សង្ខារុ-បេក្ខាញាណនោះ កាលតាំងនៅយ៉ាងនេះ រមែងដល់នូវភាពជាវិមោក្ខមុខ ( ផ្លូវនៃវិមោក្ខ ) ៣ តាំងនៅ ។

ពិតហើយ អនុបស្សនា ៣ ហៅថា វិមោក្ខមុខ ៣ ។ ក្នុងវិមោក្ខ ៣ យ៉ាងនេះ ព្រះយោគាវចរកាលមនសិការ ដោយភាពជារបស់មិនទៀង ជាអ្នកច្រើនទៅដោយការបង្អោនចិត្តជឿ រមែងបានអនិមិត្តវិមោក្ខ ។ កាលមនសិការដោយភាពជាទុក្ខ ជាអ្នកច្រើនទៅដោយបស្សទ្ធិ រមែងបានចំពោះនូវអប្ប-

ណិហិតវិមោក្ខ ។

កាលមនសិការដោយភាពជាអនត្តា ជាអ្នកច្រើនទៅដោយការស្រឡាញ់ រមែងបានសុញ្ញតវិមោក្ខ ។

គប្បីជ្រាបសេចក្ដីក្នុងវិមោក្ខនេះដូចតទៅ អរិយមគ្គធ្វើនិព្វានឲ្យជាអារម្មណ៍ ប្រព្រឹត្តទៅហើយ ដោយអាការមិនមាននិមិត្ត ឈ្មោះថា អនិមិត្តវិមោក្ខ ។ ពិតហើយ អរិយមគ្គ ឈ្មោះថា មិនមាននិមិត្ត ព្រោះកើតឡើង ដោយធាតុ ដែលមិនមាននិមិត្ត និងឈ្មោះថា វិមោក្ខ ព្រោះផុតចាកកិលេសទាំងឡាយ ។

ដោយន័យនេះដូចគ្នា អរិយមគ្គនោះ ធ្វើនិព្វានឲ្យជាអារម្មណ៍ ប្រព្រឹត្តទៅហើយ ដោយអាការមិនមានទីតាំង ឈ្មោះថា អប្បណិហិតវិមោក្ខ ។ អរិយមគ្គ ធ្វើនិព្វានឲ្យជាអារម្មណ៍ ប្រព្រឹត្តទៅហើយ ដោយអាការជារបស់សូន្យ ឈ្មោះថា សុញ្ញតវិមោក្ខ ។

វិបស្សនារបស់កុលបុត្រ ដែលសម្រេចសង្ខារុបេក្ខាញាណ រមែងដល់នូវកំពូល ដោយអាការយ៉ាងនេះ ។ ពាក្យថា វុដ្ឋានគាមិនីវិបស្សនា ក៏គឺសង្ខារុបេក្ខាញាណនោះឯង ។ កាលព្រះយោគាវចរសេពសង្ខារុបេក្ខាញាណនោះ ការព្រងើយក្នុងសង្ខារយ៉ាងខ្លាំងក្លា រមែងកើតឡើង ។ សង្ខារុបេក្ខាញាណរបស់ភិក្ខុនោះដឹងថា ឥឡូវនេះ មគ្គនឹងកើតឡើង ពិចារណាសង្ខារទាំងឡាយថា មិនទៀង ឬជាទុក្ខ ឬជាអនត្តា ហើយធ្លាក់ចុះកាន់ភវង្គ ។ មនោទ្វារាវជ្ជនៈរមែងកើតឡើងក្នុងលំដាប់បន្ទាប់អំពីភវង្គ ព្រោះមនសិការ

ដោយអាការមិនទៀងជាដើម តាមន័យដែលពោលមកហើយ ក្នុងសង្ខារុ-បេក្ខាញាណ ។ កាលព្រះយោគាវចរមនសិការយ៉ាងនោះ បឋមជវនចិត្ត ដែលហៅថា បរិកម្ម រមែងកើតឡើង ។ បន្ទាប់អំពីបរិកម្មនោះ ទុតិយជវន-ចិត្ត ដែលហៅថា ឧបចារៈ រមែងកើតឡើងយ៉ាងនេះ ។ បន្ទាប់អំពីឧបចារៈ នោះ តតិយជវនចិត្ត ដែលហៅថា អនុលោម រមែងកើតឡើងយ៉ាងនោះ ។ នេះជាឈ្មោះហៅញែកគ្នារបស់ចិត្តទាំងនោះ តែដោយមិនផ្សេងគ្នា ជវនចិត្ត ៣ នេះ ហៅថា អាសេវនៈខ្លះ បរិកម្មខ្លះ ឧបចារៈខ្លះ អនុលោមខ្លះ ។ ឯ អនុលោមញ្ញាណនេះ ជាញាណចុងក្រោយរបស់វុដ្ឋានគាមិនីវិបស្សនា ដែល មានសង្ខារជាអារម្មណ៍ ។ តែដោយត្រង់គោត្រភូញាណប៉ុណ្ណោះ លោកហៅ ថា ទីបំផុតនៃវិបស្សនា ។ បន្ទាប់អំពីនោះ គោត្រភូញាណ ធ្វើនិរោធ គឺ និព្វានឲ្យជាអារម្មណ៍ ឈានកន្លងបុថុជ្ជនគោត្រ ចុះកាន់អរិយគោត្រ ជាធម្ម-ជាតបង្អោនទៅជាដំបូងក្នុងនិព្វានអារម្មណ៍ មិនប្រព្រឹត្តទៅក្នុងភពទៀត រមែង កើតឡើង ។ តែញាណនេះ មិនចាត់ជាបដិបទាញាណទស្សនវិសុទ្ធិ ហើយ ញាណទស្សនវិសុទ្ធិ ជាអព្វោហារិក ក្នុងរវាងញាណទាំង ២ ប៉ុណ្ណោះ ព្រោះ ញាណនេះ ធ្លាក់ទៅក្នុងក្រសែនៃវិបស្សនា ទើបដល់នូវការរាប់ថា ជាបដិ-បទាញាណទស្សនវិសុទ្ធិ ឬវិបស្សនា ។ កាលគោត្រភូញាណធ្វើនិព្វានឲ្យជា អារម្មណ៍រលត់ទៅហើយ សោតាបត្តិមគ្គ ដែលធ្វើនិព្វានឲ្យជាអារម្មណ៍ ដោយសញ្ញា ដែលគោត្រភូញាណនោះឲ្យហើយ កម្ចាត់នូវសំយោជនៈ ៣ គឺទិដ្ឋិសំយោជនៈ សីលព្វតបរាមាសសំយោជនៈ វិចិកិច្ឆាសំយោជនៈ រមែង

កើតឡើង ។ ក្នុងលំដាប់បន្ទាប់អំពីនោះ ផលចិត្ត ២ ឬ ៣ ខណៈ ដែលជាផលនៃសោតាបត្តិមគ្គនោះ រមែងកើតឡើង ព្រោះផលចិត្តជាវិបាកក្នុងលំដាប់បន្ទាប់អំពីលោកុត្តរកុសល ។ ក្នុងទីបំផុតនៃផលចិត្ត មនោទ្វារាវជ្ជនចិត្តរបស់ព្រះយោគាវចរនោះ រមែងឡើងដើម្បីកាត់កវង្គដែលកើតឡើងហើយធ្វើការពិចារណា ។ ព្រះយោគាវចរនោះ រមែងពិចារណាមគ្គថា អញសម្រេចហើយដោយមគ្គនេះហ្ន៎ បន្ទាប់អំពីនោះ ពិចារណាផលថា អញបានអានិសង្សនេះហើយ បន្ទាប់អំពីនោះ ពិចារណាកិលេសដែលលះបានហើយថា កិលេសទាំងនេះ អញលះបានហើយ បន្ទាប់អំពីនោះ ពិចារណាកិលេសដែលគប្បីសម្លាប់ដោយមគ្គ ៣ ខាងលើថា កិលេសទាំងនេះនៅសេសសល់នៅឡើយ ក្នុងទីបំផុត ពិចារណាអមតនិព្វានថា ធម៌នេះ អាត្មាអញចាក់ធ្លុះហើយ ។ ការពិចារណា ៥ យ៉ាង រមែងមានដល់ព្រះសោតាបន្នានោះ ដោយប្រការដូច្នេះ ។ ក្នុងទីបំផុតនៃសកទាគាមិផល និងអនាគាមិផលក៏ដូចគ្នា ។ តែក្នុងទីបំផុតនៃអរហត្តផល មិនមានការពិចារណាកិលេសដែលសេសសល់ឡើយ ការពិចារណាទាំងអស់ មាន ១៩ យ៉ាង ដោយប្រការដូច្នេះ ។

ព្រះយោគាវចរនោះ កាលពិចារណាយ៉ាងនេះហើយ ក៏អង្គុយលើអាសនៈនោះៗ ឯង ឃើញច្បាស់ដោយន័យដែលពោលហើយ ធ្វើនូវកាមរាគៈ និងព្យាបាទឲ្យស្រាលស្តើង រមែងសម្រេចទុតិយមគ្គ ។ ក្នុងលំដាប់បន្ទាប់អំពីទុតិយមគ្គនោះ ក៏សម្រេចផល ដោយន័យដូចបានពោលហើយនោះ

ឯង ។ បន្ទាប់អំពីនោះ ព្រះយោគាវចរឃើញច្បាស់ដោយន័យដូចពោល ហើយ ទើបធ្វើការលះកាមរាគៈ និងព្យាបាទ មិនឲ្យមានចំណែកសេសសល់ រមែងសម្រេចតតិយមគ្គ និងសម្រេចតតិយផលតាមន័យដូចពោលហើយ ។

បន្ទាប់អំពីនោះ ក្នុងអាសនៈនោះឯង ព្រះយោគាវចរឃើញច្បាស់ដោយន័យដែលពោលហើយ ធ្វើការលះនូវរូបរាគៈ អរូបរាគៈ មានៈ ឧទ្ធច្ចៈ និងអវិជ្ជា មិនឲ្យមានចំណែកសេសសល់ រមែងសម្រេចចតុត្ថមគ្គ និងសម្រេចចតុត្ថផល ដោយន័យដូចពោលហើយ ។ ដោយហេតុត្រឹមប៉ុណ្ណេះ ព្រះយោគាវចរនោះ ក៏ជាព្រះបច្ចេកសម្ពុទ្ធអរហន្តមហាខីណាស្រព ញាណក្នុងមគ្គ ៤ នេះ ឈ្មោះថា ញាណទស្សនវិសុទ្ធិ ដោយប្រការដូច្នេះ ។

ដោយពាក្យមានប្រមាណប៉ុណ្ណេះ ឈ្មោះថា លោកពោលដល់សុទ្ធិ ៧ គឺសីលវិសុទ្ធិ ដោយគាថា ២ បាទនេះថា **សព្វេសុ ភូតេសុ និធាយ ទណ្ឌំ អវិហេឋយំ អញ្ញតរម្បិ តេសំ** ព្រោះពោលដល់សីល មានបាតិមោក្ខសំវរៈជាដើម ចិត្តវិសុទ្ធិដោយបាទគាថានេះថា **ន បុត្តមិច្ឆេយ្យ កុតោ សហាយំ** ព្រោះពោលដល់មេត្តាជាដើម ដោយការវៀរចាកនូវការខ្វាំងខ្វប់ និងការត្រេកអរ ទិដ្ឋិវិសុទ្ធិ កង្ខាវិតរណវិសុទ្ធិ មគ្គាមគ្គញាណទស្សនវិសុទ្ធិ បដិបទាញាណទស្សនវិសុទ្ធិ ញាណទស្សនវិសុទ្ធិ ដោយបាទគាថានេះថា **ឯកោ ចរេ ខគ្គវិសាណកប្បោ** ព្រោះពោលដល់ការកំណត់នាមរូបជាដើម ។ នេះជាគ្រឿងចង្អុលបង្ហាញឲ្យឃើញត្រឹមតែមាតិកា ក្នុងវិសុទ្ធិ ៧ នេះ តែបុគ្គលប្រាថ្នានូវសេចក្ដីពិស្ដារ គប្បីមើលក្នុងវិសុទ្ធិមគ្គ ហើយកាន់យកចុះ ។

ដោយហេតុមានប្រមាណប៉ុណ្ណោះ ព្រះបច្ចេកពុទ្ធអង្គនេះ

បុគ្គលមានកិរិយានៅជាសុខ ក្នុងទិស ៤ ទាំងមិនមានសេចក្តីថ្នាំងថ្នាក់ចិត្ត សន្តោសដោយបច្ច័យ តាមមាន តាមបាន ជាអ្នកអត់ធ្មត់ ចំពោះអន្តរាយទាំងឡាយ ជាអ្នកមិនតក់ស្លុត គប្បីប្រព្រឹត្តម្នាក់ឯង ដូចកុយរមាស ។

ព្រោះហេតុនោះ ទើបព្រះបច្ចេកពុទ្ធ ដល់នូវភាពជាទីស្រឡាញ់របស់ត្រកូលទាំងឡាយជាដើម ធ្វើកំគន្ធមាទន៍ឲ្យស្អាត ។ ក្នុងបទទាំងពួង ក៏មានន័យយ៉ាងនេះ ។៚

**អដ្ឋកថាគាថាទី ១ ចប់**

# សុត្តន្តបិដក

[ ២៣៦ ] សេចក្តីស្នេហា របស់បុគ្គលអ្នកមានការជាប់ជំពាក់ រមែងមាន សេចក្តីទុក្ខនេះ មានឡើង ព្រោះអាស្រ័យសេចក្តីស្នេហា បុគ្គលកាលសម្លឹងឃើញទោស ដែលកើតអំពីសេចក្តីស្នេហា គប្បីប្រព្រឹត្តម្នាក់ឯងដូចកុយរមាស ។

[ ២៣៧ ] អធិប្បាយពាក្យថា សេចក្តីស្នេហារបស់បុគ្គលអ្នកមានការជាប់ជំពាក់រមែងមាន ត្រង់ពាក្យថា ការជាប់ជំពាក់ បានដល់ ការជាប់ជំពាក់ ២ គឺការជាប់ជំពាក់ដោយការឃើញ ១ ការជាប់ជំពាក់ដោយការស្តាប់ ១ ។

ការជាប់ជំពាក់ដោយការឃើញ តើដូចម្តេច ។ បុគ្គលខ្លះក្នុងលោកនេះ ឃើញស្ត្រី ឬកុមារីដែលមានរូបល្អ គួររមិលមើល ជាទីជ្រះថ្លា ប្រកបដោយសម្បុរល្អក្រៃលែង លុះមើលឃើញហើយ ក៏កាន់យកនិមិត្តដោយអនុព្យញ្ជនៈ សក់ល្អ មុខល្អ ភ្នែកល្អ ត្រចៀកល្អ ច្រមុះល្អ បបូរមាត់ល្អ ធ្មេញល្អ មាត់ល្អ កល្អ ដោះល្អ ទ្រូងល្អ ពោះល្អ ចង្កេះល្អ ភ្លៅល្អ ជង្គង់ល្អ ដៃល្អ ម្រាមដៃល្អ ក្រចកល្អ លុះមើលឃើញហើយ រមែងត្រេកអរ សរសើរ ប៉ុនប៉ង ក្រវែលរក ជាប់តាមនូវចំណង គឺរាគៈ នេះការជាប់ជំពាក់ដោយការឃើញ ។

ការជាប់ជំពាក់ដោយការឮ តើដូចម្តេច ។ បុគ្គលខ្លះក្នុងលោកនេះ ឮថា ស្ត្រី ឬកុមារីក្នុងស្រុកក្តី ក្នុងនិគមក្តី ឈ្មោះឯណោះមានរូបល្អគួររមិលមើល ជាទីជ្រះថ្លា ប្រកបដោយសម្បុរល្អក្រៃលែង លុះស្តាប់ឮហើយ រមែងត្រេកអរ សរសើរ ប៉ុនប៉ង ក្រវែលរក ជាប់តាមនូវចំណង គឺរាគៈ នេះការជាប់ជំពាក់ដោយការឮ ។

ពាក្យថា សេចក្ដីស្នេហា បានដល់ សេចក្ដីស្នេហា ២ គឺតណ្ហាស្នេហា ១ ទិដ្ឋិស្នេហា ១ ។

តណ្ហាស្នេហា តើដូចម្ដេច ។ អំពើដែលបុគ្គលធ្វើឲ្យមានដែន ធ្វើឲ្យមានខណ្ឌ ធ្វើឲ្យមានជួរ ធ្វើឲ្យមានទីបំផុត ហួងហែង ប្រកាន់ដោយចំណែកតណ្ហា ទាំងប៉ុន្មានថា នេះរបស់អញ នុ៎ះរបស់អញ វត្ថុប៉ុណ្ណោះរបស់អញ វត្ថុមានប្រមាណប៉ុណ្ណោះរបស់អញ រូប សំឡេង ក្លិន រស ផ្សព្វ កម្រាល ប្រដាប់ស្លៀកពាក់ ខ្ញុំស្រីប្រុស ពពែ ចៀម មាន់ ជ្រូក ដំរី គោ សេះ ឈ្មោល សេះញី ស្រែ ចម្ការ ប្រាក់ មាស ស្រុក និគម រាជធានី ដែន ជនបទ ជម្រក ឃ្លាំងរបស់អញ ប្រកាន់នូវមហាប្រឹថពីសូម្បីទាំងអស់ដោយអំណាចតណ្ហា តណ្ហាវិបរិត ១០៨ ទាំងប៉ុន្មាន នេះតណ្ហាស្នេហា ។

ទិដ្ឋិស្នេហា តើដូចម្ដេច ។ សក្កាយទិដ្ឋិ មានវត្ថុ ២០ មិច្ឆាទិដ្ឋិ មានវត្ថុ ១០ អន្តគ្គាហិកទិដ្ឋិ មានវត្ថុ ១០ ទិដ្ឋិ ដំណើរ គឺទិដ្ឋិ ការសាំញ៉ាំ គឺទិដ្ឋិ ផ្លូវលំបាក គឺទិដ្ឋិ គ្រឿងចាក់ដោត គឺទិដ្ឋិ ការអន្ទះសា គឺទិដ្ឋិ គ្រឿងប្រកបទុក្ខ គឺទិដ្ឋិ សេចក្ដីប្រកាន់ សេចក្ដីប្រកាន់ខ្ជាប់ ការជាប់ជំពាក់ ការស្ទាបអង្អែល ផ្លូវអាក្រក់ ផ្លូវខុស សភាពខុស លទ្ធិដូចជាកំពង់ សេចក្ដីប្រកាន់ក្នុងការស្វែងរកខុស ការប្រកាន់ឃ្លៀងឃ្លាត ការប្រកាន់ឃ្លាង ការប្រកាន់ខុស ការប្រកាន់ថាពិតក្នុងវត្ថុមិនពិត ទិដ្ឋិ ៦២ ទាំងប៉ុន្មាន នេះទិដ្ឋិស្នេហា ។

ពាក្យថា សេចក្ដីស្នេហា របស់បុគ្គលអ្នកមានការជាប់ជំពាក់រមែងមាន បានន័យថា តណ្ហាស្នេហាក្ដី ទិដ្ឋិស្នេហាក្ដី រមែងមានកើត កើតព្រម លូត

លាស់ ចម្រើនឡើង កើតប្រាកដឡើងព្រោះវិបល្លាសជាបច្ច័យផង ព្រោះការជាប់ជំពាក់ដោយការមើលឃើញ និងការឮជាបច្ច័យផង ហេតុនោះ ( លោកពោលថា ) សេចក្តីស្នេហា របស់បុគ្គលអ្នកមានការជាប់ជំពាក់រមែងមាន ។

[ ២៣៨ ] អធិប្បាយពាក្យថា សេចក្តីទុក្ខនេះមានឡើងព្រោះអាស្រ័យសេចក្តីស្នេហា ត្រង់ពាក្យថា សេចក្តីស្នេហា បានដល់ សេចក្តីស្នេហា ២ យ៉ាង គឺតណ្ហាស្នេហា ១ ទិដ្ឋិស្នេហា ១ ។បេ។ នេះតណ្ហាស្នេហា ។បេ។ នេះទិដ្ឋិស្នេហា ។ ពាក្យថា សេចក្តីទុក្ខនេះមានឡើង សេចក្តីថា បុគ្គលពួកខ្លះក្នុងលោកនេះ ប្រព្រឹត្តទុច្ចរិតដោយកាយ ប្រព្រឹត្តទុច្ចរិតដោយវាចា ប្រព្រឹត្តទុច្ចរិតដោយចិត្ត សម្លាប់សត្វខ្លះ កាន់យកទ្រព្យដែលគេមិនបានឲ្យខ្លះ កាត់ទីតខ្លះ ប្លន់ធំខ្លះ ប្លន់តូចខ្លះ ចាំស្កាត់ផ្លូវខ្លះ គប់រកកិរិយាបុគ្គលដទៃខ្លះ ពោលពាក្យកុហកខ្លះ ។ ដូចរាជបុរសចាប់បុគ្គលនុ៎ះថ្វាយព្រះរាជាថា បពិត្រព្រះសម្មតិទេព ចោរនេះប្រព្រឹត្តអាក្រក់ ទ្រង់សព្វព្រះហឫទ័យអាជ្ញាណា សូមទ្រង់ដាក់អាជ្ញានោះដល់ចោរនេះចុះ ។ ព្រះរាជាទ្រង់ជៀលត្មះចោរនោះ ។ ចោរនោះរងទុក្ខទោមនស្ស ព្រោះការជៀលត្មះជាបច្ច័យ ។ ភ័យ ទុក្ខ ទោមនស្សនុ៎ះកើតហើយព្រោះអ្វី ។ កើតហើយដល់ចោរនោះ ព្រោះសេចក្តីស្នេហាជាបច្ច័យខ្លះ ព្រោះសេចក្តីរីករាយជាបច្ច័យខ្លះ ព្រោះតម្រេកជាបច្ច័យខ្លះ ព្រោះសេចក្តីរីករាយ និងតម្រេកជាបច្ច័យខ្លះ ។ បើព្រះរាជាមិនសព្វព្រះហឫទ័យដោយហេតុមានប្រមាណប៉ុណ្ណេះទេ ។ ព្រះរាជា ញុំាងរាជបុរសឲ្យចងចោរនោះដោយចំណងគឺខ្នោះក្តី ដោយចំណង គឺខ្សែក្តី ដោយចំណង គឺច្រវាក់ក្តី

ដោយចំណាំ គឺវល្លិក្តី ដោយចំណាំ គឺរបងក្តី ដោយចំណាំ គឺស្រុកក្តី ដោយចំណាំ គឺនិគមក្តី ដោយចំណាំ គឺនគរក្តី ដោយចំណាំ គឺដែនក្តី ដោយចំណាំ គឺជនបទក្តី ដោយហោចទៅ ព្រះរាជាធ្វើការហាមប្រាមដោយព្រះបន្ទូលថា អ្នកមិនត្រូវបានចេញអំពីទីនេះទេ ។ ចោរនោះរងទុក្ខទោមនស្ស ព្រោះការចងជាបច្ច័យ ។ ភ័យ ទុក្ខ ទោមនស្សនុ៎ះ កើតហើយព្រោះអ្វី ។ កើតហើយដល់ចោរនោះ ព្រោះសេចក្តីស្នេហាជាបច្ច័យខ្លះ ព្រោះសេចក្តីរីករាយជាបច្ច័យខ្លះ ព្រោះតម្រេកជាបច្ច័យខ្លះ ព្រោះសេចក្តីរីករាយ និងតម្រេកជាបច្ច័យខ្លះ ។ បើព្រះរាជាមិនសព្វព្រះហឫទ័យដោយហេតុត្រឹមប៉ុណ្ណោះទេ ។ ព្រះរាជាទ្រង់ឲ្យរឹបយកទ្រព្យនោះ រាប់រយ ឬរាប់ពាន់របស់ចោរនោះ ។ ចោរនោះក៏រងទុក្ខទោមនស្សព្រោះការសាបសូន្យទ្រព្យជាបច្ច័យ ។ ភ័យ ទុក្ខ ទោមនស្សនុ៎ះ កើតហើយព្រោះអ្វី ។ កើតហើយដល់ចោរនោះ ព្រោះសេចក្តីស្នេហាជាបច្ច័យខ្លះ ព្រោះសេចក្តីរីករាយជាបច្ច័យខ្លះ ព្រោះតម្រេកជាបច្ច័យខ្លះ ព្រោះសេចក្តីរីករាយ និងតម្រេកជាបច្ច័យខ្លះ ។ បើព្រះរាជាមិនសព្វព្រះរាជហឫទ័យដោយហេតុប៉ុណ្ណោះទេ ។ ព្រះរាជាក៏ទ្រង់ឲ្យធ្វើកម្មករណ៍ផ្សេងៗ ដល់ចោរនោះ គឺឲ្យវាយដោយរំពាត់ខ្លះ ឲ្យវាយដោយរំពាត់ផ្តៅខ្លះ ឲ្យវាយដោយដំបងខ្លីខ្លះ កាត់ដៃខ្លះ កាត់ជើងខ្លះ កាត់ទាំងដៃទាំងជើងខ្លះ កាត់ស្លឹកត្រចៀកខ្លះ កាត់ច្រមុះខ្លះ កាត់ទាំងស្លឹកត្រចៀកទាំងច្រមុះខ្លះ ធ្វើពិលង្គថាលិកកម្មខ្លះ ធ្វើសង្ខមុណ្ឌកកម្មខ្លះ ធ្វើរាហុមុខកម្មខ្លះ ធ្វើជោតិមាលិកកម្មខ្លះ ធ្វើហត្ថប្បជ្ជោតិកកម្មខ្លះ ធ្វើឯរកវត្តិកកម្មខ្លះ ធ្វើចិរវាសិកកម្មខ្លះ ធ្វើ

ឯណេយ្យកកម្មខ្លះ ធ្វើពលិសមំសិកកម្មខ្លះ ធ្វើកហាបណិកកម្មខ្លះ ធ្វើខារា-បតច្ឆិកកម្មខ្លះ ធ្វើបលិឃបរិវត្តិកកម្មខ្លះ ធ្វើបលាលបីឋកកម្មខ្លះ ស្រោចដោយប្រេងក្តៅខ្លះ ឲ្យឆ្កែខាំខ្លះ ឲ្យដេកផ្ងារលើឈើអណ្តោតទាំងរស់ខ្លះ កាត់ក្បាលដោយដាវខ្លះ ។ ចោរនោះក៏រងទុក្ខទោមនស្ស ព្រោះកម្មករណ៍ជាបច្ច័យ ។ ភ័យ ទុក្ខ ទោមនស្សនុ៎ះ កើតហើយព្រោះអ្វី ។ កើតហើយដល់ចោរនោះ ព្រោះសេចក្តីស្នេហាជាបច្ច័យខ្លះ ព្រោះសេចក្តីរីករាយជាបច្ច័យខ្លះ ព្រោះតម្រេកជាបច្ច័យខ្លះ ព្រោះសេចក្តីរីករាយ និងតម្រេកជាបច្ច័យខ្លះ ។ ព្រះរាជា ជាឥស្សរៈនៃអាជ្ញាទាំង ៤ នេះ ។ ចោរនោះលុះបែកធ្លាយរាងកាយស្លាប់ទៅ រមែងទៅកើតឯអបាយ ទុគ្គតិ វិនិបាត នរក ព្រោះកម្មជារបស់ខ្លួន ។ ពួកនាយនិរយបាល ឲ្យធ្វើកម្មករណ៍ឈ្មោះចំណង ៥ ប្រការនុ៎ះ គឺបោះដែកគោលក្តៅត្រង់ដៃ ១ បោះដែកគោលក្តៅត្រង់ដៃទីពីរ ១ បោះដែកគោលក្តៅត្រង់ជើង ១ បោះដែកគោលក្តៅត្រង់ជើងទីពីរ ១ បោះដែកគោលក្តៅត្រង់កណ្តាលទ្រូង ១ ។ សត្វនោះរងទុក្ខវេទនា ខ្លាចផ្សាដ៏ក្លាខ្លាំងក្នុងទីនោះ បាបកម្មនោះមិនទាន់អស់ដរាបណា សត្វនោះក៏មិនទាន់ធ្វើមរណកាលដរាបនោះ ។ ភ័យ ទុក្ខ ទោមនស្សនុ៎ះ កើតហើយព្រោះអ្វី ។ កើតហើយដល់សត្វនោះ ព្រោះសេចក្តីស្នេហាជាបច្ច័យខ្លះ ព្រោះសេចក្តីរីករាយជាបច្ច័យខ្លះ ព្រោះតម្រេកជាបច្ច័យខ្លះ ព្រោះសេចក្តីរីករាយ និងតម្រេកជាបច្ច័យខ្លះ ។ ពួកនាយនិរយបាលញុំាងសត្វនុ៎ះឲ្យដេកសន្ធឹង ហើយចាំងដោយដឹងទាំងឡាយ ។ ពួកនាយនិរយបាល ចាប់សត្វនុ៎ះឲ្យមានជើងឡើង

លើ មានក្បាលចុះក្រោម ហើយប្រាសដោយកាំបិតទាំងឡាយ ។ ពួកនាយនិរយបាល ទឹមសត្វនុ៎ះក្នុងរថ ហើយបរទៅខ្លះ បរត្រឡប់មកវិញខ្លះ លើផែនដីដែលភ្លើងឆេះសន្ធោសន្ធៅរន្ទាលប្រាលផ្លោ ពួកនាយនិរយបាលឲ្យសត្វនុ៎ះ ឡើងកាន់ភ្នំរងើកភ្លើងដ៏ធំ ដែលភ្លើងឆេះសន្ធោសន្ធៅរន្ទាលប្រាលផ្លោខ្លះ ឲ្យចុះមកវិញខ្លះ ។ ពួកនាយនិរយបាលចាប់សត្វនុ៎ះ ឲ្យមានជើងឡើងលើ មានក្បាលចុះក្រោម ហើយបោះទៅក្នុងខ្ទះដែកដ៏ក្តៅ ដែលភ្លើងឆេះសន្ធោសន្ធៅរន្ទាលប្រាលផ្លោ ។ សត្វនោះពុះផុលឡើងដូចពពុះក្នុងខ្ទះនោះ ។ សត្វនោះកាលពុះផុលឡើងដូចពពុះក្នុងខ្ទះនោះ អណ្តែតឡើងលើម្តង លិចចុះក្រោមម្តង ទៅទទឹងម្តង ។ សត្វនោះរងទុក្ខវេទនាដ៏ក្លាខ្លាំងខ្លោចផ្សាក្នុងខ្ទះនោះ បាបកម្មនោះមិនទាន់អស់ដរាបណា សត្វនោះក៏មិនទាន់ធ្វើមរណកាលដរាបនោះ ។ ភ័យ ទុក្ខ ទោមនស្សនុ៎ះ កើតហើយព្រោះអ្វី ។ កើតហើយដល់សត្វនោះ ព្រោះសេចក្តីស្នេហាជាបច្ច័យខ្លះ ព្រោះសេចក្តីរីករាយជាបច្ច័យខ្លះ ព្រោះតម្រេកជាបច្ច័យខ្លះ ព្រោះសេចក្តីរីករាយ និងតម្រេកជាបច្ច័យខ្លះ ។ ពួកនាយនិរយបាល ក៏បោះសត្វនោះទៅក្នុងនរក ។ មហានរកនោះសោត

> មានជ្រុង ៤ មានទ្វារ ៤ ដែលធម្មតា ចែក រាប់តាមចំណែក
> ព័ទ្ធព័ទ្ធដោយកំពែងដែក គ្របដោយបន្ទះដែក ។ ផ្ទៃមហានរកនោះ
> សុទ្ធដែកប្រាលផ្លោ ប្រកបដោយកម្តៅ ផ្សាយទៅមួយយោជន៍
> ដោយជុំវិញសព្វកាល ។ មហានរកទាំងនោះ មានអណ្តាតភ្លើង

អាក្រក់ក្តៅពន្លឹក ពុំគួរត្រេកអរ មានសភាពគួរព្រឺរោម គួរតក់ស្លុត គួរជាទុក្ខ គួរខ្លាច ។ គំនរអណ្តាតភ្លើងដែលតាំងឡើងអំពីជញ្ជាំងខាងកើត ឆាបឆេះសត្វទាំងឡាយដែលមានបាបកម្ម ហើយផ្ទប់ទៅត្រង់ជញ្ជាំងខាងលិច គំនរអណ្តាតភ្លើងដែលតាំងឡើងអំពីជញ្ជាំងខាងលិច ឆាបឆេះសត្វទាំងឡាយដែលមានបាបកម្ម ហើយផ្ទប់ទៅត្រង់ជញ្ជាំងខាងកើត ។ គំនរអណ្តាតភ្លើងដែលតាំងឡើងអំពីជញ្ជាំងខាងត្បូង ឆាបឆេះសត្វទាំងឡាយ ដែលមានបាបកម្ម ហើយផ្ទប់ទៅត្រង់ជញ្ជាំងខាងជើង ។ គំនរអណ្តាតភ្លើងតាំងឡើងអំពីជញ្ជាំងខាងជើង ឆាបឆេះសត្វទាំងឡាយដែលមានបាបកម្ម ហើយផ្ទប់ទៅត្រង់ជញ្ជាំងខាងត្បូង ។ គំនរអណ្តាតភ្លើងគួរខ្លាចតាំងឡើងអំពីខាងក្រោម ឆាបឆេះសត្វទាំងឡាយដែលមានបាបកម្ម ហើយផ្ទប់ទៅទីងដំបូល ។ គំនរអណ្តាតភ្លើងគួរខ្លាច តាំងឡើងអំពីដំបូល ឆាបឆេះសត្វទាំងឡាយដែលមានបាបកម្ម ហើយផ្ទប់មកទីងផ្ទៃ ។ អំបែងដែកកំពុងក្តៅសព្វ រុងរឿង យ៉ាងណា នរកអវិចី ( ក៏ប្រាកដ ) ដល់សត្វដែលតាំងនៅខាងក្រោម និងខាងលើយ៉ាងនោះដែរ ។ សត្វទាំងឡាយជាអ្នកអាក្រក់ខ្លាំង ធ្វើអំពើអាក្រក់ច្រើន មានអំពើបាបតែមួយយ៉ាង រមែងឆេះ តែមិនស្លាប់ក្នុងនរកនោះទេ ។ កាយសត្វនរកទាំងឡាយដែលអាស្រ័យនៅក្នុងនរកនោះ ប្រាកដស្មើដោយភ្លើង អ្នកចូរមើលនូវភាពនៃបាបកម្មដ៏

មាំមួនចុះ សត្វទាំងនោះមិនទៅជាផេះ ទាំងមិនទៅជាធ្យូង ។ សត្វនរកទាំងឡាយ រមែងស្ទុះទៅតាមទិសខាងកើតខ្លះ ស្ទុះចេញអំពីទិសខាងកើតនោះ មកកាន់ទិសខាងលិចខ្លះ ស្ទុះទៅតាមទិសខាងជើងខ្លះ ស្ទុះចេញអំពីទិសខាងជើងនោះ មកកាន់ខាងត្បូងខ្លះ ។ សត្វនរកទាំងនោះ ស្ទុះទៅកាន់ទិសណាៗ ទ្វារក្នុងទិសនោះៗ ក៏បិទជិតឯង សត្វទាំងនោះ សុទ្ធតែមានសេចក្តីប្រាថ្នាដើម្បីចេញស្វែងរកនូវការចេញ ។ សត្វនរកទាំងនោះ ចេញអំពីនរកនោះមិនបាន ព្រោះកម្មជាបច្ច័យ ព្រោះថា បាបកម្មរបស់សត្វទាំងនោះ មានច្រើនយ៉ាងដែលខ្លួនធ្វើហើយ ជាកម្មមិនទាន់ទុំ ។

ភ័យ ទុក្ខ ទោមនស្សទុំ៎ះកើតហើយព្រោះអ្វី ។ កើតហើយដល់សត្វនោះ ព្រោះសេចក្តីស្នេហាជាបច្ច័យខ្លះ ព្រោះសេចក្តីរីករាយជាបច្ច័យខ្លះ ព្រោះតម្រេកជាបច្ច័យខ្លះ ព្រោះសេចក្តីរីករាយ និងតម្រេកជាបច្ច័យខ្លះ ។ ទុក្ខណាមានក្នុងនរកក្តី ទុក្ខណា មានក្នុងកំណើតតិរច្ឆានក្តី ទុក្ខណា មានក្នុងបិត្តិវិស័យក្តី ទុក្ខណា មានក្នុងពួកមនុស្សក្តី ទុក្ខទាំងនោះ កើតហើយព្រោះអ្វី កើតព្រមហើយព្រោះអ្វី ដុះដាលហើយព្រោះអ្វី ចម្រើនហើយព្រោះអ្វី កើតប្រាកដហើយព្រោះអ្វី ។ ទុក្ខទាំងនោះមាន មានព្រម កើត កើតព្រម ដុះដាល ចម្រើន កើតប្រាកដ ព្រោះសេចក្តីស្នេហាជាបច្ច័យខ្លះ ព្រោះសេចក្តីរីករាយជាបច្ច័យខ្លះ ព្រោះតម្រេកជាបច្ច័យខ្លះ ព្រោះសេចក្តីរីករាយ និងតម្រេកជាបច្ច័យខ្លះ ហេតុនោះ ( លោកពោលថា ) សេចក្តីទុក្ខនេះ មានឡើង ព្រោះ

អាស្រ័យសេចក្តីស្នេហា ។

[ ២៣៩ ] អធិប្បាយពាក្យថា បុគ្គលកាលសម្លឹងឃើញទោស ដែលកើតអំពីសេចក្តីស្នេហា ត្រង់ពាក្យថា សេចក្តីស្នេហា បានដល់ សេចក្តីស្នេហា ២ គឺតណ្ហាស្នេហា ១ ទិដ្ឋិស្នេហា ១ ។បេ។ នេះតណ្ហាស្នេហា ។បេ។ នេះទិដ្ឋិស្នេហា ។ ពាក្យថា បុគ្គលកាលសម្លឹងឃើញទោសដែលកើតអំពីសេចក្តីស្នេហា បានសេចក្តីថា បុគ្គលកាលសម្លឹងឃើញ រមិលមើល ពិនិត្យមើល ពិចារណាមើលនូវទោសក្នុងតណ្ហាស្នេហាផង ក្នុងទិដ្ឋិស្នេហាផង ហេតុនោះ ( លោកពោលថា ) បុគ្គលកាលសម្លឹងឃើញទោសដែលកើតអំពីសេចក្តីស្នេហា ។ គប្បីប្រព្រឹត្តម្នាក់ឯង ដូចកុយរមាស ។ ហេតុនោះ ព្រះបច្ចេកសម្ពុទ្ធនោះពោលថា

សេចក្តីស្នេហា របស់បុគ្គលអ្នកមានការជាប់ជំពាក់ រមែងមាន
សេចក្តីទុក្ខនេះ មានឡើង ព្រោះអាស្រ័យសេចក្តីស្នេហា បុគ្គល
កាលសម្លឹងឃើញទោសដែលកើតអំពីសេចក្តីស្នេហា គប្បីប្រព្រឹត្ត
ម្នាក់ឯងដូច កុយរមាស ។

# អដ្ឋកថា

## គាថាទី ២

គប្បីជ្រាបវិនិច្ឆ័យក្នុងគាថាទី ២ ដូចតទៅ

[ ២៣៦ ] បទថា **សំសគ្គជាតស្ស** បុគ្គលដែលមានការជាប់ជំពាក់ ។ ក្នុងបទថា **សំសគ្គជាតស្ស** នោះ សំសគ្គៈមាន ៥ យ៉ាង គឺទស្សនសំសគ្គៈ ១ សវនសំសគ្គៈ ១ កាយសំសគ្គៈ ១ សមុល្លបនសំសគ្គៈ ១ សម្ភោគសំសគ្គៈ ១ ។

ក្នុងសំសគ្គៈទាំងនោះ តម្រេកដែលកើតឡើងដោយអំណាចនៃចក្ខុវិញ្ញាណវិថី ព្រោះឃើញគ្នានិងគ្នា ឈ្មោះថា **ទស្សនសំសគ្គ** ឧបមាក្នុងទស្សនសំសគ្គៈនោះ មានដូច្នេះថា

កូនស្រីកុដុម្ពិកៈឃើញភិក្ខុកំលោះ នៅក្នុងកល្យាណីវិហារ កំពុងត្រាច់បិណ្ឌបាត ក្នុងស្រុកកាឡទីឃវាបិ ក្នុងសីហឡទ្វីប មានចិត្តប្រតិព័ទ្ធ កាលមិនបានសមប្រាថ្នាដោយឧបាយណាមួយ ក៏ស្លាប់ ។ មានរឿងមួយទៀត ភិក្ខុកំលោះរូបនោះឯង ឃើញកំណាត់សំពត់ដែលស្រីនោះដណ្តប់ គិតថា អញមិនបាននៅរួមជាមួយនាង ដែលដណ្តប់សំពត់នេះ ហើយក៏បែកហទយៈដល់នូវមរណភាព ។

តម្រេកកើតដោយអំណាចនៃសោតវិញ្ញាណវិថី ព្រោះស្តាប់នូវសម្បត្តិមានរូបជាដើម ដែលអ្នកដទៃពោលដល់ ឬស្តាប់សំឡេងសើច និងច្រៀងដោយខ្លួនឯង ឈ្មោះថា **សវនសំសគ្គៈ** ។

ក្នុងសវនសំសគ្គៈនោះ ក៏មានរឿងជាគំរូដូច្នេះថា ភិក្ខុកំលោះ ឈ្មោះតិស្សៈ នៅក្នុងគុហាបញ្ចគ្គឡៈ ហោះទៅតាមអាកាស បានឮសំឡេងកូនក្រមុំជាងមាស អ្នកស្រុកគិរិគាមជាមួយស្រីក្រមុំ ៥ នាក់ ងូតទឹកត្រង់ស្រះឈូក បេះផ្កាឈូកប្រដាប់សីសៈ ហើយច្រៀងដោយសំឡេងខ្លាំង ព្រះតិស្សៈក៏សាបសូន្យចាកឈាន ព្រោះកាមរាគៈ ដល់នូវសេចក្ដីវិនាស ។

តម្រេកកើតព្រោះការស្ទាបអង្អែលអវយវៈគ្នានិងគ្នា ឈ្មោះថា **កាយសំសគ្គៈ** ។ ក្នុងកាយសំសគ្គៈ មានរឿងភិក្ខុកំលោះស្វាធ្យាយធម៌ជាគំរូថា

ក្នុងមហាវិហារ ភិក្ខុកំលោះមួយរូប ពោលធម៌ក្នុងមហាវិហារនោះ គ្រាមហាជនត្រឡប់ទៅអស់ហើយ ព្រះរាជាបានយាងទៅព្រមដោយស្រីស្នំ គ្រានោះ តម្រេកយ៉ាងខ្លាំងក្លាកើតឡើងដល់ព្រះរាជធីតា ព្រោះអាស្រ័យរូប និងសំឡេងភិក្ខុកំលោះនោះ ភិក្ខុកំលោះនោះក៏កើតនូវតម្រេកដូចគ្នា ។ ព្រះរាជាទ្រង់ឃើញដូច្នោះ ទ្រង់កំណត់បាន ទ្រង់បញ្ជាឲ្យបាំងរាំងនន ។ ភិក្ខុកំលោះនិងរាជធីតាស្ទាបអង្អែលគ្នា ហើយឱបគ្នារហូតស្លាប់ទាំងពីរ ពួករាជបុរសយករាំងននចេញ បានឃើញជនទាំង ២ ស្លាប់ហើយ ។

តម្រេកកើតឡើង ព្រោះសន្ទនាប្រាស្រ័យគ្នានិងគ្នា ឈ្មោះថា **សមុល្លបនសំសគ្គៈ** ។ តម្រេកកើតព្រោះបរិភោគរួមគ្នារបស់ភិក្ខុ និងភិក្ខុនី ឈ្មោះថា **សម្ភោគសំសគ្គៈ** ក្នុងសំសគ្គៈទាំង ២ នេះ មានរឿងភិក្ខុនីក្នុងមរិចវដ្ដិវិហារជាគំរូដូចតទៅនេះ

មានរឿងតំណាលថា ក្នុងបុណ្យឆ្លងមរិចវដ្ដិមហាវិហារ ព្រះបាទទុដ្ឋ-

គាមិណិអភយមហារាជ ទ្រង់ត្រៀមមហាទានអង្គាសសង្ឃ ២ ចំណែក ។ ក្នុងទីនោះ ទ្រង់ថ្វាយបបរក្តៅ សង្ឃនវកសាមណេរី គឺសាមណេរីបួសថ្មី ប្រគេនថាសដល់សង្ឃនវកសាមណេរ ដែលមានអាយុ ៧ ឆ្នាំ ដែលមិនទាន់មានសណ្តាប់ធ្នាប់រៀបរយ ហើយបានសន្ទនាគ្នា ។ ជនទាំង ២ បួសរហូតមានអាយុ ៦០ ឆ្នាំ បានទៅកាន់ឆ្នេរស្ទឹងដទៃ បានទទួលបុព្វសញ្ញា ដោយការសន្ទនាគ្នានឹងគ្នា រំពេចនោះឯង ក៏កើតស្នេហា កន្លងនូវសិក្ខាបទ ត្រូវអាបត្តិបារាជិក ។

សេចក្តីស្នេហា រមែងមានដល់បុគ្គល ដែលជាប់ជំពាក់ដោយការជាប់ជំពាក់ណាមួយ ក្នុងការជាប់ជំពាក់ ៥ យ៉ាង យ៉ាងនេះ តម្រេកដ៏ខ្លាំងក្លា រមែងកើតឡើង ព្រោះមានរាគៈក្នុងកាលមុនជាបច្ច័យ បន្ទាប់អំពីនោះ ទុក្ខនេះ រមែងកើតឡើងតាមសេចក្តីស្នេហា ។ សេចក្តីទុក្ខដែលមានសេចក្តីស្នេហាជាប់តាម មានប្រការផ្សេងៗ ជាដើមថា សេចក្តីសោក សេចក្តីខ្សឹកខ្សួលក្នុងបច្ចុប្បន្ន និងសម្បរាយភពជាដើម រមែងប្រាកដ រមែងកើត រមែងមាន រមែងកើតឡើង ។ តែអាចារ្យដទៃពោលថា ការបណ្តោយចិត្ត ទៅក្នុងអារម្មណ៍ ឈ្មោះថា សំសគ្គៈ បន្ទាប់អំពីនោះ សំសគ្គរមែងនាំទុក្ខមកឲ្យ ។

ព្រះបច្ចេកពុទ្ធអង្គនោះ កាលពោលកន្លះគាថានេះ មានសេចក្តីយ៉ាងនេះហើយ ទើបពោលថា អាត្មានោះជីកឫសរបស់ទុក្ខ មានទុក្ខដែលកើតអំពីសេចក្តីសោកជាដើម ដែលទៅតាមសេចក្តីស្នេហា ទើបសម្រេចបច្ចេកសម្ពោធិញ្ញាណ ។ កាលព្រះបច្ចេកសម្ពុទ្ធពោលយ៉ាងនេះហើយ បណ្តា

អមាត្យទាំងឡាយនោះ ក៏នាំគ្នាពោលថា បពិត្រលោកម្ចាស់ដ៏ចម្រើន ឥឡូវនេះ ពួកខ្ញុំគប្បីធ្វើដូចម្តេច ខណៈនោះ ទើបព្រះបច្ចេកពុទ្ធពោលថា ពួកអ្នកក្តី ពួកអ្នកដទៃក្តី បុគ្គលណាបំណងនឹងផុតចាកទុក្ខនេះ បុគ្គលកាលសម្លឹងឃើញទោសដែលកើតអំពីសេចក្តីស្នេហា គប្បីប្រព្រឹត្តម្នាក់ឯង ដូចកុយរមាស ដូច្នោះ ក្នុងបទនេះ គប្បីជ្រាបថា លោកពោលបទនេះថា បុគ្គលកាលសម្លឹងឃើញទោសដែលកើតអំពីសេចក្តីស្នេហា សំដៅដល់បទដែលលោកពោលថា សេចក្តីទុក្ខនេះ មានឡើង ព្រោះអាស្រ័យសេចក្តីស្នេហា ។ ម្យ៉ាងទៀត គប្បីភ្ជាប់សេចក្តីយ៉ាងនេះថា សេចក្តីស្នេហា រមែងមានដល់បុគ្គលដែលប្រកបដោយសំសគ្គៈ ដោយសំសគ្គៈតាមដែលពោលហើយ ទុក្ខនេះ រមែងកើតឡើងតាមសេចក្តីស្នេហា អាត្មាសម្លឹងឃើញទោស ដែលកើតអំពីសេចក្តីស្នេហា តាមសេចក្តីពិតនោះ ទើបសម្រេច ដូច្នេះហើយ គប្បីជ្រាបថា បាទទី ៤ លោកពោលដោយពាក្យឧទានតាមន័យដែលបានពោលហើយ ក្នុងកាលមុននោះឯង ។ បទទាំងពួងបន្ទាប់អំពីនោះ ដូចគ្នាតាមដែលពោលហើយ ក្នុងគាថាមុននោះឯង ។

គប្បីជ្រាបវិនិច្ឆ័យក្នុងនិទ្ទេសដូចតទៅ

[ ២៣៧ ] បទថា **អនុប្បាទេតិ** បានដល់ កាលឃើញអនុព្យញ្ជនៈក្នុងរូប រមែងជាប់ចិត្ត ។ បទថា **អនុពន្ធតិ** បានដល់ ចងភ្ជាប់ដោយសេចក្តីស្នេហាក្នុងរូប ។ បទថា **ភវន្តិ** បានដល់ រមែងកើតមាន ។ បទថា **ជាយន្តិ** បានដល់ រមែងកើតឡើង ។ បទថា **និព្វត្តន្តិ** បានដល់ រមែងប្រព្រឹត្តទៅ ។ បទថា **បាតុភវន្តិ** បានដល់ រមែងប្រាកដច្បាស់ ។

[ ២៣៨ ] ៣ បទថា **សម្ភវន្តិ សញ្ជាយន្តិ អភិនិព្វត្តន្តិ** លោកបន្ថែមឧបសគ្គ ។ បន្ទាប់អំពីនោះ គប្បីជ្រាបដោយន័យដែលពោលហើយក្នុងអដ្ឋកវគ្គនោះឯង ៕

**អដ្ឋកថា គាថាទី ២ ចប់**

# សុត្តន្តបិដក

[ ២៨០ ] បុគ្គលមានចិត្តជាប់ជំពាក់ កាលអនុគ្រោះចំពោះមិត្ត និងអ្នកមានចិត្តល្អ រមែងញ៉ាំងប្រយោជន៍ឲ្យវិនាស បុគ្គលកាលសម្លឹងឃើញភ័យក្នុងការស្និទ្ធស្នាលនុ៎ះ គប្បីប្រព្រឹត្តម្នាក់ឯង ដូចកុយរមាស ។

[ ២៨១ ] អធិប្បាយពាក្យថា បុគ្គលអ្នកមានចិត្តជាប់ជំពាក់ កាលអនុគ្រោះចំពោះមិត្តអ្នកមានចិត្តល្អ រមែងញ៉ាំងប្រយោជន៍ឲ្យវិនាស ត្រង់ពាក្យថា មិត្ត បានដល់ មិត្ត ២ គឺអាគារិកមិត្ត ១ អនាគារិកមិត្ត ១ ។

អាគារិកមិត្ត តើដូចម្តេច ។ បុគ្គលខ្លះក្នុងលោកនេះ ឲ្យវត្ថុដែលគេឲ្យបានដោយក្រ លះបង់វត្ថុដែលគេលះបង់បានដោយក្រ ធ្វើអំពើដែលគេធ្វើបានដោយក្រ អត់ទ្រាំហេតុដែលគេអត់ទ្រាំបានដោយក្រ ប្រាប់ការកំបាំងដល់មិត្តនោះ លាក់ការកំបាំងរបស់មិត្តនោះ មិនលះបង់គ្នាក្នុងកាលមានអន្តរាយ សូម្បីជីវិត ក៏ហ៊ានលះបង់ ដើម្បីប្រយោជន៍ដល់មិត្តនោះ មិនមើលងាយមិត្តក្នុងកាលមិត្តអស់ទ្រព្យ នេះអាគារិកមិត្ត ។

អនាគារិកមិត្ត តើដូចម្តេច ។ ភិក្ខុក្នុងសាសនានេះរមែងជាទីស្រឡាញ់ផង ជាទីពេញចិត្តផង គួរគោរពផង គួរអ្នកផងសើ្ញចផង អត់ធន់ក្នុងពាក្យពោលផង ធ្វើពាក្យឲ្យជ្រាលជ្រៅផង មិនដឹកនាំក្នុងហេតុមិនគួរផង ដឹកនាំក្នុងអធិសីល ដឹកនាំក្នុងការប្រកបរឿយៗ នូវការចម្រើនសតិប្បដ្ឋាន ៤ ដឹកនាំក្នុងការប្រកបរឿយៗ នូវការចម្រើនសម្មប្បធាន ៤ ។បេ។ នូវឥទ្ធិបាទ ៤ នូវឥន្ទ្រិយ ៥ នូវពល ៥ នូវពោជ្ឈង្គ ៧ នូវអរិយមគ្គមានអង្គ ៨ ផង នេះ

អនាគារិកមិត្ត ។

ការដើរទៅជាសុខ ការមកជាសុខ ការទៅមកជាសុខ ការឈរជាសុខ ការអង្គុយជាសុខ ការដេកជាសុខ ការហៅរកជាសុខ ការនិយាយរកគ្នាជាសុខ ការនិយាយឆ្លើយឆ្លងគ្នាជាសុខ ការនិយាយស្រុះស្រួលគ្នាជាសុខ ជាមួយនឹងពួកជនណា ពួកជននោះ លោកហៅថា អ្នកមានចិត្តល្អ ។

ពាក្យថា បុគ្គលកាលអនុគ្រោះចំពោះមិត្ត និងអ្នកមានចិត្តល្អ រមែងញុំាងប្រយោជន៍ឲ្យវិនាស គឺបុគ្គលកាលអនុគ្រោះ ទំនុកបម្រុង ផ្គុងផ្គើម ចំពោះមិត្តផង ចំពោះអ្នកមានចិត្តល្អផង ចំពោះជនដែលធ្លាប់ឃើញគ្នាផង ចំពោះជនដែលរាប់គ្នាស្និទ្ធផង ចំពោះសម្លាញ់ផង រមែងញុំាងប្រយោជន៍ខ្លួន និងប្រយោជន៍អ្នកដទៃឲ្យវិនាស ញុំាងប្រយោជន៍ទាំងពីរឲ្យវិនាស ញុំាងប្រយោជន៍បច្ចុប្បន្នឲ្យវិនាស ញុំាងប្រយោជន៍បរលោកឲ្យវិនាស ញុំាងប្រយោជន៍ដ៏ក្រៃលែងឲ្យវិនាស ឲ្យខ្ចាត់ខ្ចាយ ឲ្យបាត់បង់ ឲ្យអន្តរធាន ហេតុនោះ ( លោកពោលថា ) បុគ្គលកាលអនុគ្រោះចំពោះមិត្ត និងអ្នកមានចិត្តល្អ រមែងញុំាងប្រយោជន៍ឲ្យវិនាស ។

ពាក្យថា អ្នកមានចិត្តជាប់ជំពាក់ គឺជាអ្នកមានចិត្តជាប់ជំពាក់ ដោយហេតុពីរ គឺជាអ្នកមានចិត្តជាប់ជំពាក់ តាំងខ្លួនឲ្យទាប តាំងអ្នកដទៃឲ្យខ្ពស់ ឬជាអ្នកមានចិត្តជាប់ជំពាក់ តាំងខ្លួនឲ្យខ្ពស់ តាំងអ្នកដទៃឲ្យទាប ។

បុគ្គលជាអ្នកមានចិត្តជាប់ជំពាក់ តាំងខ្លួនឲ្យទាប តាំងបុគ្គលដទៃឲ្យខ្ពស់ តើដូចម្តេច ។ បុគ្គលនោះពោលថា លោកមានឧបការៈច្រើនដល់ខ្ញុំ ខ្ញុំបាន

ចីវរ បិណ្ឌបាត សេនាសនៈ និងថ្នាំគ្រឿងរក្សារោគ ជាបរិក្ខាររបស់ជីវិត ព្រោះអាស្រ័យលោក ជនទាំងឡាយដទៃ កាលអាស្រ័យលោក ឃើញលោក ទើបសម្គាល់ដើម្បីឲ្យ ឬដើម្បីធ្វើវត្ថុណាដល់ខ្ញុំក្តី នាម និងគោត្តណា ជារបស់មាតាបិតា ដែលមានពីមុនរបស់ខ្ញុំក្តី សូម្បីវត្ថុនោះ ទាំងនាម និងគោត្តនោះ ក៏បាត់បង់ទៅហើយ ( ហេតុនេះ ) ខ្ញុំសូមទទួលស្គាល់លោកថា ជាជីតុនរបស់បុរសឯណោះ ជាជីតុនរបស់ស្ត្រីឯណោះ បុគ្គលជាអ្នកមានចិត្តជាប់ជំពាក់ តាំងខ្លួនឲ្យទាប តាំងអ្នកដទៃឲ្យខ្ពស់ យ៉ាងនេះឯង ។

បុគ្គលជាអ្នកមានចិត្តជាប់ជំពាក់ តាំងខ្លួនឲ្យខ្ពស់ តាំងអ្នកដទៃឲ្យទាប តើដូចម្តេច ។ បុគ្គលនោះពោលថា ខ្ញុំមានឧបការៈច្រើនដល់លោក លោកអាស្រ័យខ្ញុំ ទើបដល់ព្រះពុទ្ធជាទីពឹង ដល់ព្រះធម៌ជាទីពឹង ដល់ព្រះសង្ឃជាទីពឹង វៀរចាកបាណាតិបាត វៀរចាកអទិន្នាទាន វៀរចាកកាមេសុមិច្ឆាចារ វៀរចាកមុសាវាទ វៀរចាកហេតុជាទីតាំងនៃសេចក្តីប្រមាទក្នុងទឹកស្រវឹង គឺសុរា និងមេរ័យ ខ្ញុំបានប្រាប់ឧទ្ទេសផង បរិបុច្ឆាផង សីលផង ឧបោសថផង អធិដ្ឋាននវកម្មដល់លោក ប៉ុន្តែលោកលះបង់ខ្ញុំ ទៅធ្វើសក្ការៈ គោរព រាប់អាន បូជាចំពោះបុគ្គលដទៃវិញ បុគ្គលជាអ្នកមានចិត្តជាប់ជំពាក់ តាំងខ្លួនឲ្យខ្ពស់ តាំងអ្នកដទៃឲ្យទាប យ៉ាងនេះឯង ហេតុនោះ ( លោកពោលថា ) បុគ្គលអ្នកមានចិត្តជាប់ជំពាក់ កាលអនុគ្រោះចំពោះមិត្ត និងអ្នកមានចិត្តល្អ រមែងញុំាងប្រយោជន៍ឲ្យវិនាស ។

[ ២៤២ ] អធិប្បាយពាក្យថា បុគ្គលកាលសម្លឹងឃើញភ័យ ក្នុងការ

ស្និទ្ធស្នាលនុ៎ះ ត្រង់ពាក្យថា ភ័យ បានដល់ ភ័យអំពីជាតិ ភ័យអំពីជរា ភ័យអំពីព្យាធិ ភ័យអំពីមរណៈ ភ័យអំពីព្រះរាជា ភ័យអំពីចោរ ភ័យអំពីភ្លើង ភ័យអំពីទឹក ភ័យអំពីការតិះដៀលខ្លួនឯង ភ័យអំពីការតិះដៀលរបស់បុគ្គលដទៃ ភ័យអំពីអាជ្ញា ភ័យអំពីទុគ្គតិ ភ័យអំពីរលកទឹក ភ័យអំពីក្រពើ ភ័យអំពីទឹកក្តួច ភ័យអំពីត្រីសាហាវ ភ័យអំពីការរកចិញ្ចឹមជីវិត ភ័យអំពីការមិនសរសើរ ភ័យអំពីសេចក្តីរញ៉េរញ៉ៃកណ្តាលបរិស័ទ ហេតុគួរខ្លាច ការញាប់ញ័រ ការព្រឺរោម ការរន្ធត់ចិត្ត ការតក់ស្លុត ។ ពាក្យថា ការស្និទ្ធស្នាល បានដល់ សេចក្តីស្និទ្ធស្នាល ២ គឺសេចក្តីស្និទ្ធស្នាល គឺតណ្ហា ១ សេចក្តីស្និទ្ធស្នាល គឺទិដ្ឋិ ១ ។បេ។ នេះសេចក្តីស្និទ្ធស្នាល គឺតណ្ហា ។បេ។ នេះសេចក្តីស្និទ្ធស្នាល គឺទិដ្ឋិ ។ ពាក្យថា បុគ្គលកាលសម្លឹងឃើញភ័យ ក្នុងសេចក្តីស្និទ្ធស្នាលនុ៎ះ បានសេចក្តីថា បុគ្គលកាលសម្លឹងឃើញ ក្រឡេកមើល ពិនិត្យមើល ពិចារណាមើល នូវភ័យក្នុងសេចក្តីស្និទ្ធស្នាលនុ៎ះ ហេតុនោះ ( លោកពោលថា ) បុគ្គលកាលសម្លឹងឃើញភ័យ ក្នុងសេចក្តីស្និទ្ធស្នាលនុ៎ះ ។ គប្បីប្រព្រឹត្តម្នាក់ឯង ដូចកុយរមាស ។ ហេតុនោះ ព្រះបច្ចេកសម្ពុទ្ធនោះពោលថា

> បុគ្គលអ្នកមានចិត្តជាប់ជំពាក់ កាលអនុគ្រោះចំពោះមិត្ត និងអ្នកមានចិត្តល្អ រមែងញ៉ាំងប្រយោជន៍ឲ្យវិនាស បុគ្គលកាលសម្លឹងឃើញភ័យ ក្នុងការស្និទ្ធស្នាលនុ៎ះ គប្បីប្រព្រឹត្តម្នាក់ឯង ដូចកុយរមាស ។

# អដ្ឋកថា

## គាថាទី ៣

គប្បីជ្រាបវិនិច្ឆ័យក្នុងគាថាទី ៣ ដូចតទៅនេះ

[ ២៤០ ] ឈ្មោះថា **មិត្តេ** ដោយអំណាចនៃសេចក្តីស្រឡាញ់ ឈ្មោះថា **សុហជ្ជេ** ដោយភាពជាអ្នកមានចិត្តល្អ ។ ពិតហើយ បុគ្គលពួកខ្លះជាមិត្ត ព្រោះប្រាថ្នានឹងឲ្យប្រយោជន៍ដោយចំណែកមួយ តែមិនមែនជាសម្លាញ់ ។ បុគ្គលពួកខ្លះ ជាសម្លាញ់ ព្រោះឲ្យកើតសេចក្តីសុខក្នុងការដើរ ឈរ អង្គុយ និងសន្ទនាជាដើម តែមិនមែនជាមិត្ត បុគ្គលពួកខ្លះ ជាសម្លាញ់ផង ជាមិត្តផង ដោយអំណាចកិច្ចទាំង ២ នោះ ។ ជនទាំងនោះមាន ២ ពួក គឺអាគារិយមិត្ត គឺមិត្តគ្រហស្ថ និងអនាគារិយមិត្ត គឺមិត្តបព្វជិត ។

ក្នុងមិត្ត ២ ពួកនោះ អាគារិយមិត្តមាន ៣ គឺមិត្តមានឧបការៈ ១ មិត្តរួមសុខរួមទុក្ខ ១ មិត្តមានសេចក្តីស្រឡាញ់ ១ ។ មានមិត្តណែនាំប្រយោជន៍បន្ថែមចូលមកទៀត ។ មិត្តទាំងនោះ មិត្តមួយប្រភេទៗ ប្រកបដោយអង្គ ៤ ដូចព្រះមានព្រះភាគត្រាស់ដល់សិង្គាលមាណពថា

ម្នាលគហបតិបុត្ត មិត្តមានឧបការៈ ជាមិត្តមានសន្តានល្អ អ្នកត្រូវដឹងដោយស្ថាន ៤ យ៉ាង គឺរក្សាមិត្តដែលធ្វេសប្រហែស ១ រក្សាសម្បត្តិ របស់មិត្តដែលធ្វេសប្រហែស ១ ជាទីពឹងពំនាក់នៃមិត្តដែលមានសេចក្តីភិតភ័យ ១ កាលបើកិច្ចដែលត្រូវធ្វើកើតឡើងហើយ តែងជួយផ្តល់ភោគៈជាទ្វិគុណ ជាងទ្រព្យដែលមិត្ត

ត្រូវការនោះ ១ ។

ម្នាលគហបតិបុត្ត មិត្តរួមសុខទុក្ខ ជាមិត្តមានសន្តានល្អ អ្នកត្រូវដឹងដោយស្ថាន ៤ យ៉ាង គឺប្រាប់នូវអាថ៌កំបាំងរបស់ខ្លួនដល់មិត្ត ១ ជួយបិទបាំងនូវអាថ៌កំបាំងរបស់មិត្ត ១ មិនបោះបង់គ្នាក្នុងគ្រាមានវិបត្តិ ១ សូម្បីជីវិតក៏ហ៊ានលះបង់ ដើម្បីប្រយោជន៍ដល់មិត្ត ( ស៊ូប្តូរជីវិត ) ១ ។

ម្នាលគហបតិបុត្ត មិត្តប្រាប់ប្រយោជន៍ ជាមិត្តមានសន្តានល្អ អ្នកត្រូវដឹងដោយស្ថាន ៤ យ៉ាង គឺហាមមិត្តឲ្យឃ្លាតចាកអំពើអាក្រក់ ១ ដឹកនាំឲ្យមិត្តតម្កល់នៅតែក្នុងអំពើល្អ ១ ឲ្យបានឮពាក្យដែលមិនធ្លាប់បានឮ ១ ប្រាប់ផ្លូវស្ថានសួគ៌ ១ ។

ម្នាលគហបតិបុត្ត មិត្តមានសេចក្តីឈឺឆ្អាល ជាមិត្តមានសន្តានល្អ អ្នកត្រូវដឹងដោយស្ថាន ៤ យ៉ាង គឺជួយព្រួយចិត្ត ពីព្រោះមិត្តបានសេចក្តីវិនាស ១ ជួយត្រេកអរព្រោះមិត្តបានសេចក្តីចម្រើន ១ ទទឹងទាស់នឹងមនុស្ស ដែលពោលទោសមិត្ត ១ សរសើរតែមនុស្សដែលពណ៌នាគុណមិត្ត ១ ។

ក្នុងមិត្តទាំង ២ នោះ ក្នុងទីនេះ លោកបំណងយកអាគារិយមិត្ត ។ តែដោយអត្ថ ប្រើបានជាមួយមិត្តទាំងអស់ ។ គឺមិត្តសម្លាញ់ទាំងនោះ ។

បទថា **អនុកម្បមានោ** សេចក្តីថា អាណិតបំណងនឹងនាំសេចក្តីសុខចូលទៅឲ្យដល់មិត្តទាំងនោះ បំណងនឹងនាំសេចក្តីទុក្ខចេញទៅ ។ បទថា

**ហាបេតិ អត្ថំ** សេចក្តីថា ញុំាងប្រយោជន៍ ៣ យ៉ាង គឺទិដ្ឋធម្មិកត្ថប្រយោជន៍ ១ សម្បរាយិកត្ថប្រយោជន៍ ១ បរមត្ថប្រយោជន៍ ១ ម្យ៉ាងទៀត ប្រយោជន៍របស់ខ្លួន ១ ប្រយោជន៍អ្នកដទៃ ១ ប្រយោជន៍ទាំងពីរ ១ ឲ្យសូន្យទៅ ឲ្យវិនាសទៅ ដោយហេតុទាំង ២ គឺដោយឲ្យវត្ថុដែលបានហើយវិនាសទៅ ១ ដោយឲ្យវត្ថុដែលមិនទាន់បានមិនឲ្យកើតឡើង ១ ។ បទថា **បដិពទ្ធចិត្តោ** សេចក្តីថា តម្កល់ខ្លួនទុកក្នុងឋានៈទាបយ៉ាងនេះថា អញវៀរបុគ្គលនេះចេញហើយ នឹងរស់នៅមិនបាន បុគ្គលនេះជាបែបផែនរបស់អញ បុគ្គលនេះជាទីពឹងដល់អញ ក៏ឈ្មោះថា **បដិពទ្ធចិត្តោ** ( ជាអ្នកមានចិត្តជាប់ជំពាក់ហើយ ) ។ សូម្បីតាំងខ្លួនទុកក្នុងឋានៈដែលខ្ពស់យ៉ាងនេះថា បុគ្គលទាំងនេះវៀរអាត្មាអញហើយ ក៏រស់នៅមិនបាន អញជាបែបផែនរបស់ពួកគេ អញជាទីពឹងដល់ពួកគេ ក៏ឈ្មោះថា **បដិពទ្ធចិត្តោ** ។ ក្នុងទីនេះ បំណងយកភាពជាអ្នកមានចិត្តជាប់ជំពាក់យ៉ាងនេះ ។

បទថា **ឯតំ ភយំ** សេចក្តីថា ភ័យ គឺការធ្វើប្រយោជន៍ឲ្យវិនាសនោះ ព្រះបច្ចេកពុទ្ធ ពោលសំដៅដល់ការវិនាសចាកសមាបត្តិរបស់ខ្លួន ។ បទថា **សន្ថវេ** បានដល់ ការស្និទ្ធស្នាល មាន ៣ យ៉ាង គឺតណ្ហាសន្ថវៈ ១ ទិដ្ឋិសន្ថវៈ

១ មិត្តសន្ថវ: ១ ។ ក្នុងការស្និទ្ធស្នាល ៣ យ៉ាងនោះ តណ្ហាមានប្រភេទ ១០៨ ជាតណ្ហាសន្ថវ: ។ ទិដ្ឋិមានប្រភេទ ៦២ ជាទិដ្ឋិសន្ថវ: ការជួយស្រោចស្រង់មិត្ត ព្រោះមានចិត្តជាប់ជំពាក់គ្នា ជាមិត្តសន្ថវ: ។ មិត្តសន្ថវ:នោះ បំណងយកក្នុងទីនេះ ។ សមាបត្តិរបស់ព្រះបច្ចេកពុទ្ធនោះវិនាសទៅ ដោយមិត្តសន្ថវ:នោះ ដោយហេតុនោះ ទើបព្រះបច្ចេកពុទ្ធពោលថា អាត្មាឃើញភ័យក្នុងការស្និទ្ធស្នាលនោះ ទើបបានសម្រេច ។ បទដ៏សេស គប្បីជ្រាបថា ដូចគ្នានឹងពាក្យដែលពោលទុកហើយនោះឯង ។ ក្នុងនិទ្ទេស មិនមានអ្វីដែលគួរពោល ។ល។

## អដ្ឋកថាគាថាទី ៣ ចប់

# សុត្តន្តបិដក

[ ២៨៣ ] អាល័យណា ក្នុងពួកបុត្រ និងប្រពន្ធ អាល័យនោះ ចាក់ស្រេះដូចឫស្សី មានមែកសាងញ៉ាង បុគ្គលមិនជាប់ជំពាក់ ដូចទំពាំងឫស្សី គប្បីប្រព្រឹត្តម្នាក់ឯង ដូចកុយរមាស ។

[ ២៨៤ ] ពាក្យថា អាល័យនោះ ចាក់ស្រេះដូចឫស្សី មានមែកសាងញ៉ាង អធិប្បាយថា គុម្ពឫស្សី ហៅថា ឫស្សី ។ បន្ទាក្នុងគុម្ពឫស្សី សាំញុំ ចាក់ស្រេះ ចាក់កណ្តាញ់ ប្រទាក់គ្នា ច្វាក់គ្នា ជាប់គ្នា យ៉ាងណាមិញ តណ្ហា លោកពោលថា វិសត្តិកា ក៏យ៉ាងនោះដែរ គឺបានខាងតម្រេក តម្រេកខ្លាំង សេចក្តីត្រេកអរ សេចក្តីស្រើបស្រាល សេចក្តីរីករាយ សេចក្តីត្រេកត្រអាល តម្រេកខ្លាំងនៃចិត្ត ការចង់បាន ការជ្រប់ចិត្ត ការងប់ចិត្ត ការប្រាថ្នា ការប្រាថ្នាខ្លាំង ការជាប់នៅ កិលេសដូចភក់ ការញាប់ញ័រ កិលេសជាតិជាគ្រឿងបិទបាំងទោស កិលេសជាតិនាំឲ្យកើត ញុំាងទុក្ខឲ្យកើត ជាគ្រឿងដេរភ្ជាប់ដូចជាបណ្តាញ ជាទីហូរទៅ ជាគ្រឿងចាក់ស្រេះដូចជាខ្សែ ផ្សាយទៅ ជាគ្រឿងប្រមូលមក ជាគម្រប់ពីរ ( របស់សត្វ ) ជាគ្រឿងតម្កល់ទុក ជាគ្រឿងនាំទៅកាន់ភព ដូចជាព្រៃតូច ព្រៃធំ សេចក្តីស្និទ្ធស្នាល សេចក្តីស្នេហា ការអាល័យ ការជាប់ចំពោះ ចំណង់ ការប៉ុនប៉ង ភាពនៃសេចក្តីប៉ុនប៉ង ការប៉ុនប៉ងរូប ការប៉ុនប៉ងសំឡេង ការប៉ុនប៉ងក្លិន ការប៉ុនប៉ងរស ការប៉ុនប៉ងផ្សព្វ ការប៉ុនប៉ងលាភ ការប៉ុនប៉ងទ្រព្យ ការប៉ុនប៉ងបុត្ត ការប៉ុនប៉ងជីវិត ការជាប់ចិត្ត ការជាប់ចិត្តទូទៅ ការជាប់ចិត្តខ្លាំង អាការជាទីជាប់ចិត្ត ភាពនៃការជាប់ចិត្ត ការវេះវាម អាការជាទីវេះវាម ភាពនៃចិត្តវេះវាម ការធ្វើឲ្យ

ញាប់ញ័រ ការធ្វើមិនប្រពៃ តម្រេកមិនត្រូវតាមធម៌ តម្រេកមិនចេះល្មម លោភមិនល្មម ការស្រឡាញ់ ការក្តួចកាន់ ការប្រាថ្នា ការពេញចិត្ត ការប្រាថ្នាខ្លាំង ការអន្ទះសាក្នុងកាម ការអន្ទះសាក្នុងភព ការអន្ទះសាក្នុងវិភព ការអន្ទះសាក្នុងរូប ការអន្ទះសាក្នុងអរូប ការអន្ទះសាក្នុងនិរោធ ការអន្ទះសាក្នុងរូប ការអន្ទះសាក្នុងសំឡេង ការអន្ទះសាក្នុងក្លិន ការអន្ទះសាក្នុងរស ការអន្ទះសាក្នុងផ្សព្វ ការអន្ទះសាក្នុងធម្មារម្មណ៍ កិលេសដូចជាជំនន់ ជាគ្រឿងប្រកបទុក ជាគ្រឿងរួបរឹត ជាគ្រឿងថ្ពក់ ជាគ្រឿងរាំង ជាគ្រឿងហាម ជាគ្រឿងប្រក់ ជាគ្រឿងចង គ្រឿងសៅហ្មង ជាគ្រឿងដេកនៅរឿយៗ ជាគ្រឿងស្ទាក់ វល្លិ៍ គឺតណ្ហា សេចក្តីប្រាថ្នាផ្សេងៗ ឫសគល់នៃទុក្ខ ហេតុនៃទុក្ខ ដែនផ្តើមកើតទុក្ខ អន្ទាក់មារ សន្ទូចមារ វិស័យមារ លំនៅមារ ចំណងមារ ស្ទឹង គឺតណ្ហា បណ្តាញ គឺតណ្ហា ដងដោយ គឺតណ្ហា សមុទ្ទ គឺតណ្ហា អភិជ្ឈា លោភៈ អកុសលមូល ។ សំណួរត្រង់ពាក្យថា វិសត្តិកា ចុះកិលេសជាតិ ឈ្មោះថា វិសត្តិកា តើដោយសេចក្តីដូចម្តេច ។ ឈ្មោះថា វិសត្តិកា ព្រោះហេតុផ្សាយទៅ ។ ឈ្មោះថា វិសត្តិកា ព្រោះហេតុធំទូលាយ ។ ឈ្មោះថា វិសត្តិកា ព្រោះហេតុជ្រួតជ្រាប ។ ឈ្មោះថា វិសត្តិកា ព្រោះហេតុអត់ធន់ ។ ឈ្មោះថា វិសត្តិកា ព្រោះហេតុនាំខុស ។ ឈ្មោះថា វិសត្តិកា ព្រោះហេតុពោលខុស ។ ឈ្មោះថា វិសត្តិកា ព្រោះហេតុមានឫសគល់ជាពិស ។ ឈ្មោះថា វិសត្តិកា ព្រោះហេតុមានផ្លែជាពិស ។ ឈ្មោះថា វិសត្តិកា ព្រោះហេតុមានការបរិភោគជាពិស ។ មួយទៀត ឈ្មោះថា វិសត្តិកា

ព្រោះហេតុតណ្ហាដ៏ធំទូលាយ ផ្សាយ លាតទៅក្នុងរូប សំឡេង ក្លិន រស ផ្សព្វ ត្រកូល គណៈ អាវាស លាភ យស សេចក្ដីសរសើរ សេចក្ដីសុខ ចីវរ បិណ្ឌបាត សេនាសនៈ និងថ្នាំគ្រឿងរក្សារោគ ជាបរិក្ខាររបស់ជីវិត ក្នុងកាមធាតុ រូបធាតុ អរូបធាតុ កាមភព រូបភព អរូបភព សញ្ញាភព អសញ្ញាភព នេវសញ្ញានាសញ្ញាភព ឯកវោការភព ចតុវោការភព បញ្ច-វោការភព ឬក្នុងអតីត អនាគត បច្ចុប្បន្ន ក្នុងអារម្មណ៍ទាំងឡាយដែលឃើញ ឮ ប៉ះពាល់ ដឹងច្បាស់ ហេតុនោះ ( លោកពោលថា ) អាល័យនោះ ចាក់ស្រែះដូចឫស្សី មានមែកសាងញ៉ាង ។

[ ២៤៥ ] ពាក្យថា អាល័យណា ក្នុងពួកបុត្ត និងប្រពន្ធ ត្រង់ពាក្យថា បុត្ត បានដល់ បុត្ត ៤ ពួក គឺបុត្តកើតអំពីខ្លួន ១ បុត្តកើតក្នុងខេត្ត ១ បុត្តដែលគេឲ្យ ១ បុត្ត គឺសិស្ស ១ ។ ភរិយា ហៅថា ប្រពន្ធ ។ តណ្ហា ហៅថា អាល័យ បានខាងតម្រេក តម្រេកខ្លាំង ។បេ។ អភិជ្ឈា លោភៈ អកុសលមូល ហេតុនោះ ( លោកពោលថា ) អាល័យណា ក្នុងពួកបុត្ត និងប្រពន្ធ ។

[ ២៤៦ ] ពាក្យថា បុគ្គលមិនជាប់ជំពាក់ ដូចទំពាំងឫស្សី អធិប្បាយថា គុម្ពឫស្សី ហៅថា ឫស្សី ។ ទំពាំងដ៏ខ្ចីក្នុងគុម្ពឫស្សី មិនជាប់ មិនជំពាក់ មិនព័ទ្ធព័ន្ធ មិនចាក់កណ្ដាញ់ គឺចេញ រលាស់ផុតស្រឡះហើយ យ៉ាងណាមិញ ការជំពាក់ ២ គឺការជំពាក់ គឺតណ្ហា ១ ការជំពាក់ គឺទិដ្ឋិ ១ ក៏យ៉ាងនោះដែរ ។បេ។ នេះការជំពាក់ គឺតណ្ហា ។បេ។ នេះការជំពាក់ គឺទិដ្ឋិ ។

ព្រះបច្ចេកសម្ពុទ្ធនោះ លះការជំពាក់ គឺតណ្ហា រលាស់ចោលការជំពាក់ គឺទិដ្ឋិហើយ ព្រោះលះការជំពាក់ គឺតណ្ហា ព្រោះរលាស់ចោលការជំពាក់ គឺទិដ្ឋិ ព្រះបច្ចេកសម្ពុទ្ធនោះ ទើបមិនជាប់ក្នុងរូប មិនជាប់ក្នុងសំឡេង មិនជាប់ក្នុងក្លិន មិនជាប់ក្នុងរស មិនជាប់ក្នុងផ្សព្វ មិនជាប់ មិនប្រកាន់ មិនចង មិនជាប់ស្អិតក្នុងត្រកូល គណៈ អាវាស លាភ យស សេចក្ដីសរសើរ សេចក្ដីសុខ ចីវរ បិណ្ឌបាត សេនាសនៈ និងថ្នាំគ្រឿងរក្សារោគ ជាបរិវាររបស់ជីវិត ក្នុងកាមធាតុ រូបធាតុ អរូបធាតុ កាមភព រូបភព អរូបភព សញ្ញាភព អសញ្ញាភព នេវសញ្ញានាសញ្ញាភព ឯកវោការភព ចតុវោការភព បញ្ច-វោការភព ក្នុងអតីត អនាគត បច្ចុប្បន្ន ក្នុងអារម្មណ៍ទាំងឡាយដែលឃើញ ឮ ប៉ះពាល់ ដឹងច្បាស់ គឺលោកចេញ រលាស់ ផុតស្រឡះ ប្រាសចេញ មានចិត្តប្រាសចាកសេចក្ដីសល់វល់ ហេតុនោះ ( លោកពោលថា ) បុគ្គលមិនជាប់ជំពាក់ ដូចទំពាំងឫស្សី ។ គប្បីប្រព្រឹត្តម្នាក់ឯង ដូចកុយរមាស ហេតុនោះ ព្រះបច្ចេកសម្ពុទ្ធនោះពោលថា

អាល័យណា ក្នុងពួកបុត្ត និងប្រពន្ធ អាល័យនោះ ចាក់ស្រែះ
ដូចឫស្សី មានមែកសាងញ៉ាង បុគ្គលមិនជាប់ជំពាក់ ដូចទំពាំង
ឫស្សី គប្បីប្រព្រឹត្តម្នាក់ឯង ដូចកុយរមាស ។

# អដ្ឋកថា

## គាថាទី ៤

គប្បីជ្រាបវិនិច្ឆ័យក្នុងគាថាទី ៤ ដូចតទៅនេះ

[ ២៤៣ ] បទថា **វំសោ** បានដល់ ដើមឫស្សី ។ បទថា **វិសាលោ** បានដល់ ធំទូលាយ ។ វ អក្ខរៈ ជាអវធារណៈ ។ ម្យ៉ាងទៀត វ អក្ខរៈនេះ ក៏គឺ **ឯវ** នោះឯង ។ ក្នុងពាក្យនេះ **ឯ** អក្ខរៈ បាត់ទៅដោយអំណាចសន្ធិ គប្បីភ្ជាប់ វ អក្ខរៈនោះជាមួយពាក្យក្រោយ ( របស់បទថា **វិសាលោ** ) ។ ខ្ញុំនឹងប្រើ វ អក្ខរៈនោះតាមន័យក្រោយ ។ បទថា **យថា** ជាពាក្យប្រើក្នុងការប្រៀបធៀប ។ បទថា **វិសត្តោ** បានដល់ ជាប់ចំពាក់ រឹតរុំ ចាក់ស្រែះ ។ បទថា **បុត្តេសុ ទារេសុ** ច បានដល់ ក្នុងបុត្រ ធីតា និងភរិយា ។ បទថា **យា អបេក្ខា** បានដល់ តណ្ហាណា សេចក្ដីស្នេហាណា ។ បទថា **វំស–កឡីរោវ អសជ្ជមានោ** សេចក្ដីថា ព្រះបច្ចេកសម្ពុទ្ធមិនជាប់ចំពាក់ ដូចទំពាំងឫស្សី លោកអធិប្បាយដូចម្ដេច លោកអធិប្បាយថា គុម្ពឫស្សីធំជាប់ចំពាក់គ្នា យ៉ាងណា តណ្ហាក្នុងបុត្រ និងភរិយាទាំងឡាយ ក៏ចាក់ស្រែះគ្នាយ៉ាងនោះឯង ព្រោះរួបរឹតវត្ថុទាំងនោះឯង តាំងនៅ អាត្មានោះ ឃើញទោសនៃការជាប់ជំពាក់យ៉ាងនេះថា បុគ្គលដែលមានការជាប់ជំពាក់ ដោយ

ការជាប់ជំពាក់នោះ រមែងជាអ្នកជាប់ស្អិត ដូចគុម្ពឬស្សីធំចាក់ស្រែះគ្នាដូច្នោះ ហើយកាត់នូវការជាប់ជំពាក់នោះចោល ដោយមគ្គញាណ មិនជាប់ក្នុងរូបជាដើម ក្នុងទិដ្ឋិជាដើម ក្នុងលាភជាដើម ក្នុងកាមភពជាដើម ដោយអំណាចនៃតណ្ហា មានះ និងទិដ្ឋិ ដូចទំពាំងមិនជាប់ដូច្នោះ ទើបសម្រេចបច្ចេកសម្ពោធិញ្ញាណ ។ បទដ៏សេស គប្បីជ្រាបដោយន័យដែលមានក្នុងកាលមុននោះឯងក្នុងនិទ្ទេសនៃគាថានេះ មិនមានអ្វីក្រៅអំពីនេះឡើយ ៕៚

## អដ្ឋកថាគាថាទី ៤ ចប់

# សុត្តន្តបិដក

[ ២៤៧ ] ម្រឹគក្នុងព្រៃ ជាសត្វមិនជាប់ចំណង ទៅរកចំណីតាមប្រាថ្នាបាន យ៉ាងណា វិញ្ញូជន កាលសម្លឹងឃើញសេរីភាព គប្បីប្រព្រឹត្តម្នាក់ឯង ដូចកុយរមាស យ៉ាងនោះ ។

[ ២៤៨ ] អធិប្បាយពាក្យថា ម្រឹគក្នុងព្រៃ ជាសត្វមិនជាប់ចំណង ទៅរកចំណីតាមប្រាថ្នាបាន យ៉ាងណា ត្រង់ពាក្យថា ម្រឹគ បានដល់ ម្រឹគ ២ ពួក គឺឯណិម្រឹគ ១ សរភម្រឹគ ១ ។ ម្រឹគព្រៃ កាលនៅក្នុងព្រៃ រមែងដើរទៅតាមតម្រេក ឈប់តាមតម្រេក អង្គុយតាមតម្រេក សម្រេចការដេកតាមតម្រេក យ៉ាងណាមិញ ។

សមដូចពាក្យដែលព្រះមានព្រះភាគ ទ្រង់ត្រាស់ដូច្នេះថា ម្នាលភិក្ខុទាំងឡាយ ម្រឹគព្រៃ កាលត្រាច់ទៅក្នុងព្រៃរបោះ ព្រៃស្បាត រមែងដើរទៅតាមតម្រេក ឈប់តាមតម្រេក អង្គុយតាមតម្រេក សម្រេចការដេកតាមតម្រេកដំណើរនោះ ព្រោះហេតុអ្វី ម្នាលភិក្ខុទាំងឡាយ ព្រោះថា ម្រឹគនោះ នៅក្នុងទីមិនមែនជាគន្លងរបស់ព្រាន យ៉ាងណាមិញ ម្នាលភិក្ខុទាំងឡាយ ភិក្ខុស្ងាត់ចាកកាមទាំងឡាយ ស្ងាត់ចាកធម៌ទាំងឡាយជាអកុសលហើយ ចូលបឋមជ្ឈាន ប្រកបដោយវិតក្ក និងវិចារៈ មានបីតិ និងសុខដែលកើតអំពីវិវេក ក៏យ៉ាងនោះដែរ ម្នាលភិក្ខុទាំងឡាយ ភិក្ខុនេះ តថាគតពោលថា បានធ្វើមារឲ្យងងឹត សម្លាប់មារមិនឲ្យមានដានជើង ដល់នូវការមិនជួបប្រទះដោយភ្នែកមាររបស់មារលាមក ម្នាលភិក្ខុទាំងឡាយ មួយទៀត ភិក្ខុចូលទុតិយជ្ឈាន ជាទីផូរផង់ ប្រព្រឹត្តក្នុងសន្តាន មានសេចក្តីជ្រះថ្លា គឺសទ្ធា មានសភាពជាធម្មជាត

ខ្ពស់ឯក មិនមានវិតក្ក មិនមានវិចារៈ មានតែបីតិ និងសុខ ដែលកើតអំពីសមាធិ គឺបឋមជ្ឈាន ព្រោះរម្ងាប់វិតក្ក និងវិចារៈ ម្នាលភិក្ខុទាំងឡាយ ភិក្ខុនេះ តថាគតពោលថា បានធ្វើមារឲ្យងងឹត សម្ងាប់មារមិនឲ្យមានដានជើង ដល់នូវការមិនជួបប្រទះដោយភ្នែកមារ របស់មារលាមក ម្នាលភិក្ខុទាំងឡាយ មួយទៀត ភិក្ខុជាអ្នកព្រងើយកន្តើយ មានសតិ និងការដឹងច្បាស់ សោយសុខដោយនាមកាយ ព្រោះសោយនៃបីតិ ព្រះអរិយៈទាំងឡាយ តែងសរសើរបុគ្គលដែលបានតតិយជ្ឈាននោះឯង ថាជាបុគ្គលមានចិត្តព្រងើយកន្តើយ មានស្មារតី មានការនៅជាសុខ ភិក្ខុចូលតតិយជ្ឈាននោះ ម្នាលភិក្ខុទាំងឡាយ ភិក្ខុនេះ តថាគតពោលថា បានធ្វើមារឲ្យងងឹត សម្ងាប់មារមិនឲ្យមានដានជើង ដល់នូវការមិនជួបប្រទះដោយភ្នែកមារ របស់មារលាមក ម្នាលភិក្ខុទាំងឡាយ មួយទៀត ភិក្ខុចូលចតុត្ថជ្ឈាន ឥតទុក្ខឥតសុខ មានសតិដ៏បរិសុទ្ធដោយឧបេក្ខា ព្រោះលះបង់សុខផង លះបង់ទុក្ខផង ព្រោះដល់នូវការវិនាសនៃសោមនស្ស និងទោមនស្ស ក្នុងកាលមុនផង ម្នាលភិក្ខុទាំងឡាយ ភិក្ខុនេះ តថាគតពោលថា បានធ្វើមារឲ្យងងឹត សម្ងាប់មារមិនឲ្យមានដានជើង ដល់នូវការមិនជួបប្រទះដោយភ្នែកមារ របស់មារលាមក ម្នាលភិក្ខុទាំងឡាយ មួយទៀត ព្រោះកន្លងរូបសញ្ញា ព្រោះវិនាសនៃបដិឃសញ្ញា ព្រោះមិនធ្វើទុកក្នុងចិត្ត នូវនានត្តសញ្ញា ដោយប្រការទាំងពួង ភិក្ខុចូលអាកាសានញ្ចាយតនៈ ( ដោយបរិកម្ម ) ថា អាកាសមិនមានទីបំផុត ម្នាលភិក្ខុទាំងឡាយ ភិក្ខុនេះ តថាគតពោលថា បានធ្វើមារឲ្យងងឹត សម្ងាប់មារមិនឲ្យមានដានជើង ដល់

នូវការមិនជួបប្រទះដោយភ្នែកមារ របស់មារ ម្នាលភិក្ខុទាំងឡាយ មួយទៀត ព្រោះកន្លងអាកាសានញ្ចាយតនៈ ដោយប្រការទាំងពួង ហើយចូលវិញ្ញា-ណញ្ចាយតនៈ ( ដោយបរិកម្ម ) ថា វិញ្ញាណមិនមានទីបំផុត ព្រោះកន្លងវិញ្ញាណញ្ចាយតនៈ ដោយប្រការទាំងពួង ភិក្ខុចូលអាកិញ្ចញ្ញាយតនៈ ( ដោយបរិកម្ម ) ថា វត្ថុតិចតួចមិនមាន ព្រោះកន្លងអាកិញ្ចញ្ញាយតនៈ ដោយប្រការទាំងពួង ហើយចូលនេវសញ្ញានាសញ្ញាយតនៈ ( ដោយបរិកម្ម ) ថា ធម្មជាតនុ៎ះ ជាគុណដ៏ស្ងប់ ធម្មជាតនុ៎ះ ជាគុណដ៏ឧត្តម ព្រោះកន្លងនេវ-សញ្ញានាសញ្ញាយតនៈ ដោយប្រការទាំងពួង ហើយចូលសញ្ញាវេទយិត-និរោធ ទាំងអាសវៈទាំងឡាយរបស់ភិក្ខុនោះក៏អស់ ព្រោះឃើញដោយបញ្ញា ម្នាលភិក្ខុទាំងឡាយ ភិក្ខុនេះ តថាគតពោលថា បានធ្វើមារឲ្យងងឹត សម្លាប់មារមិនឲ្យមានជានជើង ដល់នូវការមិនជួបប្រទះដោយភ្នែកមារ របស់មារលាមក បានឆ្លងតណ្ហាឈ្មោះវិសត្តិកាក្នុងលោក ភិក្ខុនោះ រមែងដើរទៅឥតរង្កៀស ឈរឥតរង្កៀស អង្គុយឥតរង្កៀស សម្រេចការដេកឥតរង្កៀស ដំណើរនោះ ព្រោះហេតុអ្វី ម្នាលភិក្ខុទាំងឡាយ ( ព្រោះថា ) ភិក្ខុនោះ នៅក្នុងទីមិនមែនជាគន្លងនៃមារដ៏លាមក ហេតុនោះ ( លោកពោលថា ) ម្រឹគក្នុងព្រៃ ជាសត្វមិនជាប់ចំណង ទៅរកចំណីតាមប្រាថ្នាបាន យ៉ាងណា ។

[ ២៤៩ ] អធិប្បាយពាក្យថា វិញ្ញូជន កាលសម្លឹងឃើញសេរីភាព ត្រង់ពាក្យថា វិញ្ញូជន គឺបុគ្គលអ្នកដឹង ជាបណ្ឌិត មានបញ្ញា មានយោបល់ មានញាណ មានបញ្ញាឈ្វេងយល់ មានបញ្ញាផ្ទុះធ្លាយ ។ ពាក្យថា ជន បានដល់

សត្វ មាណព បុរស បុគ្គល សត្វមានជីវៈ សត្វមានជាតិ សត្វមានជរា សត្វទៅដោយឥន្ទ្រិយ សត្វកើតអំពីមនុស្ស ។ ត្រង់ពាក្យថា សេរី បានដល់សេរី ២ គឺធម៌សេរី ១ បុគ្គលសេរី ១ ។

ធម៌សេរី តើដូចម្តេច ។ សតិប្បដ្ឋាន ៤ សម្មប្បធាន ៤ ឥទ្ធិបាទ ៤ ឥន្ទ្រិយ ៥ ពោជ្ឈង្គ ៧ អរិយមគ្គប្រកបដោយអង្គ ៨ ។ នេះ ធម៌សេរី ។

បុគ្គលសេរី តើដូចម្តេច ។ បុគ្គលណា ប្រកបដោយធម៌សេរីនេះ បុគ្គលនោះ លោកហៅថា បុគ្គលសេរី ។

ពាក្យថា វិញ្ញូជន កាលសម្លឹងឃើញសេរីភាព បានសេចក្តីថា វិញ្ញូជន កាលរំពឹងមើល គន់មើល ពិនិត្យមើល ពិចារណាមើលនូវធម៌ គឺសេរីភាព ហេតុនោះ ( លោកពោលថា ) វិញ្ញូជន កាលសម្លឹងឃើញសេរីភាព ។ គប្បីប្រព្រឹត្តម្នាក់ឯង ដូចកុយរមាស ។ ហេតុនោះ ព្រះបច្ចេកសម្ពុទ្ធនោះពោលថា

ម្រឹគក្នុងព្រៃ ជាសត្វមិនជាប់ចំណង ទៅរកចំណីតាមប្រាថ្នាបាន
យ៉ាងណា វិញ្ញូជន កាលសម្លឹងឃើញសេរីភាព គប្បីប្រព្រឹត្ត
ម្នាក់ឯង ដូចកុយរមាស យ៉ាងនោះ ។

# អដ្ឋកថា

## គាថាទី ៥

គប្បីជ្រាបវិនិច្ឆ័យក្នុងគាថាទី ៥ ដូចតទៅនេះ

[ ២៤៧ ] បទថា **មិគោ** នេះ ជាឈ្មោះរបស់សត្វជើង ៤ ដែលនៅក្នុងព្រៃគ្រប់ប្រភេទ ក្នុងទីនេះ លោកបំណងយកសត្វប្រើស ។ បទថា **អរញ្ញម្ហិ** បានដល់ ព្រៃដ៏សេស វៀរស្រុក និងទីក្បែរស្រុក ។ តែក្នុងទីនេះ លោកបំណងយកឧទ្យាន ។ ព្រោះដូច្នោះ ទើបលោកពោលថា **ឧយ្យានម្ហិ** ។ បទថា **យថា** ជាពាក្យប្រើក្នុងការប្រៀបធៀប ។ បទថា **អពទ្ធោ** សេចក្តីថា ដែលគ្រឿងចងណាមួយ ក្នុងបណ្តាខ្សែ និងគ្រឿងចងជាដើម មិនបានចង ។ ដោយបទនេះ លោកសម្តែងដល់ការប្រព្រឹត្តដែលស្និទ្ធស្នាលគ្នា ។ បទថា **យេនិច្ឆកំ គច្ឆតិ គោចរាយ** សេចក្តីថា ទៅដើម្បីរកអាហារតាមទិសដែលត្រូវការទៅ ព្រោះហេតុនោះ ទើបក្នុងបទនោះ លោកសម្តែងថា ទៅកាន់ទិសដែលត្រូវការទៅ ទំពាស៊ីអាហារដែលត្រូវការទំពាស៊ី ។ បទថា **វិញ្ញូ នរោ** បានដល់ បុរសដែលជាបណ្ឌិត ។ បទថា **សេរិតំ** បានដល់ ការប្រព្រឹត្តដោយការពេញចិត្តរបស់ខ្លួន គឺមិនអាស្រ័យអ្នកដទៃ ។ បទថា **បេក្ខមានោ** សេចក្តីថា មើលដោយបញ្ញាចក្ខុ ។ ម្យ៉ាងទៀត បានដល់ សេរីក្នុងធម៌ និងសេរីក្នុងបុគ្គល ។ ពិតហើយ លោកុត្តរធម៌ទាំងឡាយ ឈ្មោះថា សេរី ព្រោះមិនទៅកាន់អំណាចនៃកិលេស ហើយបុគ្គលដែលប្រកបដោយលោកុត្តរធម៌ទាំងនោះ ឈ្មោះថា **សេរី** ។ ការអធិប្បាយដល់ភាវៈនៃលោកុត្តរធម៌ និងបុគ្គលទាំងនោះ ក៏សំដៅដល់ការប្រព្រឹត្តតាមការពេញចិត្តរបស់ខ្លួន ។ លោក

អធិប្បាយដូចម្តេច អធិប្បាយថា ម្រឹគក្នុងព្រៃ ដែលមិនត្រូវចង រមែងទៅរកស៊ីតាមសេចក្តីប្រាថ្នា យ៉ាងណា កាលអាត្មាគិតថា កាលណាហ្ន៎ អញគប្បីកាត់នូវចំណង គឺតណ្ហា ហើយទៅយ៉ាងនោះបាន ដូច្នេះហើយ ត្រូវពួកអ្នកឈរចោមរោមទាំងខាងមុខ ទាំងខាងក្រោយ ជាប់ជំពាក់មិនបានទៅតាមប្រាថ្នា អាត្មាឃើញទោស ក្នុងការមិនបានទៅតាមប្រាថ្នា ឃើញអានិសង្សក្នុងការទៅបានតាមប្រាថ្នានោះហើយ បានដល់នូវភាពបរិបូណ៌ដោយសមថៈនិងវិបស្សនាតាមលំដាប់ បន្ទាប់អំពីនោះ ក៏បានសម្រេចបច្ចេកសម្ពោធិញ្ញាណ ព្រោះហេតុនោះ វិញ្ញូជន កាលសម្លឹងឃើញសេរីភាព គប្បីត្រាច់ទៅម្នាក់ឯង ដូចកុយរមាស យ៉ាងនោះ ៗ។

## អដ្ឋកថា គាថាទី ៥ ចប់

# សុត្តន្តបិដក

[ ២៥០ ] ការប្រឹក្សាក្នុងលំនៅ ក្នុងទី ( បម្រើ ) ក្នុងការដើរ ក្នុងចារិក រមែងមានក្នុងកណ្តាលសម្លាញ់ បុគ្គលកាលសម្លឹងឃើញសេរីភាព ដែលបុគ្គលពាលមិនប្រាថ្នា គប្បីប្រព្រឹត្តម្នាក់ឯង ដូចកុយរមាស ។

[ ២៥១ ] ពាក្យថា ការប្រឹក្សាក្នុងលំនៅ ក្នុងទី ( បម្រើ ) ក្នុងការដើរ ក្នុងចារិក រមែងមានក្នុងកណ្តាលសម្លាញ់ សេចក្តីថា ការដើរទៅជាសុខ ការមកជាសុខ ការទៅមកជាសុខ ការឈរជាសុខ ការអង្គុយជាសុខ ការដេកជាសុខ ការហៅរកជាសុខ ការចរចាជាសុខ ការឆ្លើយឆ្លងរកគ្នាជាសុខ ការនិយាយស្រស់ស្រាយជាសុខ ជាមួយនឹងពួកជនណា ពួកជននោះ លោកហៅថា សម្លាញ់ ។ ពាក្យថា ការប្រឹក្សាក្នុងលំនៅ ក្នុងទី ( បម្រើ ) ក្នុងការដើរ ក្នុងចារិក រមែងមានក្នុងកណ្តាលនៃសម្លាញ់ បានសេចក្តីថា ការប្រឹក្សាអំពីប្រយោជន៍របស់ខ្លួន ការប្រឹក្សាអំពីប្រយោជន៍របស់បុគ្គលដទៃ ការប្រឹក្សាអំពីប្រយោជន៍ទាំងពីរ ការប្រឹក្សាអំពីប្រយោជន៍បច្ចុប្បន្ន ការប្រឹក្សាអំពីប្រយោជន៍បរលោក ការប្រឹក្សាអំពីប្រយោជន៍ដ៏ក្រៃលែង គឺព្រះនិព្វាន ក្នុងលំនៅក្តី ក្នុងទី ( បម្រើ ) ក្តី ក្នុងការដើរក្តី ក្នុងចារិកក្តី ( រមែងមាន ) ក្នុងកណ្តាលសម្លាញ់ ហេតុនោះ ( លោកពោលថា ) ការប្រឹក្សាក្នុងលំនៅ ក្នុងទី ( បម្រើ ) ក្នុងការដើរ ក្នុងចារិក រមែងមានក្នុងកណ្តាលសម្លាញ់ ។

[ ២៥២ ] ពាក្យថា បុគ្គលកាលសម្លឹងឃើញសេរីភាព ដែលបុគ្គលពាលមិនប្រាថ្នា អធិប្បាយថា វត្ថុដែលពួកជនពាល ជាអសប្បុរស ជាពួក

តិត្ថិយ ជាពួកសាវ័កនៃតិត្ថិយ មិនប្រាថ្នា គឺការកោរសក់ ពុកមាត់ និងការស្លៀកដណ្តប់សំពត់កាសាយៈ វត្ថុដែលពួកបណ្ឌិត ជាសប្បុរស ជាពួកសាវ័កព្រះពុទ្ធ និងព្រះបច្ចេកពុទ្ធទាំងឡាយ ប្រាថ្នាហើយ គឺការកោរសក់ ពុកមាត់ និងការស្លៀកដណ្តប់សំពត់កាសាយៈ ។ ពាក្យថា សេរី បានដល់ សេរី ២ គឺ ធម៌សេរី ១ បុគ្គលសេរី ១ ។ ធម៌សេរី តើដូចម្តេច ។ សតិប្បដ្ឋាន ៤ ។បេ។ អរិយមគ្គប្រកបដោយអង្គ ៨ នេះ ធម៌សេរី ។ បុគ្គលសេរី តើដូចម្តេច ។ បុគ្គលណា ប្រកបដោយធម៌សេរីនេះ បុគ្គលនោះ លោកហៅថា បុគ្គលសេរី ។ ពាក្យថា បុគ្គលកាលសម្លឹងឃើញសេរីភាព ដែលបុគ្គលពាលមិនប្រាថ្នា បានសេចក្តីថា បុគ្គលកាលសម្លឹងឃើញ គន់មើល ពិនិត្យមើល ពិចារណាមើល នូវសេរីភាព ហេតុនោះ ( លោកពោលថា ) បុគ្គលកាលសម្លឹងឃើញសេរីភាព ដែលបុគ្គលពាលមិនប្រាថ្នា ។ គប្បីប្រព្រឹត្តម្នាក់ឯង ដូចកុយរមាស ។ ហេតុនោះ ព្រះបច្ចេកសម្ពុទ្ធនោះពោលថា

> ការប្រឹក្សាក្នុងលំនៅ ក្នុងទី ( បម្រើ ) ក្នុងការដើរ ក្នុងចារិក
> រមែងមានក្នុងកណ្តាលសម្លាញ់ បុគ្គលកាលសម្លឹងឃើញសេរីភាព
> ដែលបុគ្គលពាលមិនប្រាថ្នា គប្បីប្រព្រឹត្តម្នាក់ឯង ដូចកុយរមាស ។

# អដ្ឋកថា

## គាថាទី ៦

គប្បីជ្រាបវិនិច្ឆ័យក្នុងគាថាទី ៦ ដូចតទៅនេះ

[ ២៥០ ] និទ្ទេសនេះ ជាបិណ្ឌត្ថ គឺបូកវគ្គក្រោយៗ ចូលជាមួយនឹងវគ្គមុនៗ ឬមានអត្ថថា ប្រមូលសេចក្តី កាលតាំងនៅក្នុងកណ្តាលសម្មាញ់ ចាំបាច់ត្រូវមានការប្រឹក្សាយ៉ាងនោះៗ ដោយន័យជាដើមថា ចូរអ្នកស្តាប់រឿងនេះរបស់ខ្ញុំ ចូរឲ្យវត្ថុនេះដល់ខ្ញុំ ទាំងក្នុងទីលំនៅ គឺទីសម្រាកពេលថ្ងៃ ក្នុងទីឈរ គឺត្រង់ទីប្រឹក្សាជុំ ក្នុងទីដើរ គឺក្នុងការទៅឧទ្យាន ក្នុងទីចារិក គឺក្នុងទីត្រាច់ទៅក្នុងជនបទ ព្រោះហេតុនោះ កាលអាត្មានៀយណាយក្នុងទីនោះៗ ឃើញបព្វជ្ជាដែលអរិយជនសេព មានអានិសង្សច្រើន ជាសេចក្តីសុខដោយចំណែកមួយ កាលបើដូច្នោះ បុរសអាក្រក់ទាំងឡាយ ត្រូវលាភសក្ការៈគ្របសង្កត់ ក៏មិនសម្ងឹង មិនប្រាថ្នា និងឃើញសេរីភាពដោយអំណាចនៃធម៌ និងបុគ្គល ដោយមិនធ្លាក់នៅក្នុងអំណាចរបស់អ្នកដទៃ ទើបប្រារព្ធនូវវិបស្សនា ហើយសម្រេចបច្ចេកសម្ពោធិញ្ញាណតាមលំដាប់ ដោយប្រការដូច្នេះ បទដ៏សេស មានន័យដូចពោលហើយនោះឯង ៕

**អដ្ឋកថា គាថាទី ៦ ចប់**

# សុត្តន្តបិដក

[ ២៥៣ ] ល្បែង តម្រេក រមែងមានក្នុងកណ្តាលសម្វាញ់ ទាំងសេចក្តីស្រឡាញ់ដ៏ធំទូលាយ រមែងមានក្នុងពួកបុគ្គ បុគ្គលកាលធុញទ្រាន់ ចំពោះការព្រាត់ប្រាសចាកអារម្មណ៍ ជាទីស្រឡាញ់ គប្បីប្រព្រឹត្តម្នាក់ឯង ដូចកុយរមាស ។

[ ២៥៤ ] អធិប្បាយពាក្យថា ល្បែង តម្រេក រមែងមានក្នុងកណ្តាលសម្វាញ់ ត្រង់ពាក្យថា ល្បែង បានដល់ ល្បែង ២ គឺល្បែងខាងផ្លូវកាយ ១ ល្បែងខាងផ្លូវវាចា ១ ។ ល្បែងខាងផ្លូវកាយ តើដូចម្តេច ។ ពួកជនរមែងលេងដោយដំរីខ្លះ លេងសេះខ្លះ លេងរថខ្លះ លេងធ្នូខ្លះ លេងចត្រង្គមានក្រឡាប្រាំបីខ្លះ លេងល្បែងមានក្រឡាដប់ខ្លះ លេងចត្រង្គក្នុងអាកាសខ្លះ លេងផ្លូវវាងដែលគួរវាងខ្លះ លេងផ្ទាត់គ្រាប់មានគ្រាប់ក្រួសជាដើមខ្លះ លេងបាស្កាក្នុងលានសម្រាប់លេងខ្លះ លេងហ៊ឹងខ្លះ លេងរលាស់ទឹកល័ខឲ្យទាយរូបខ្លះ លេងអង្គញ់ខ្លះ លេងផ្លុំប៉ីស្លឹកខ្លះ លេងនង្គ័លតូចខ្លះ លេងល្បែងដាំដូងខ្លះ លេងកង្ហារខ្លះ លេងវាល់ខ្សាច់ខ្លះ លេងរទេះតូចខ្លះ លេងធ្នូតូចខ្លះ លេងសរសេរអក្សរពួដ៏អាកាសឲ្យទាយខ្លះ លេងទាយចិត្ត ( ស្តេចចង់ ) ខ្លះ លេងកំប្លែងត្រាប់គេខ្លះ នេះល្បែងខាងផ្លូវកាយ ។

ល្បែងខាងផ្លូវវាចា តើដូចម្តេច ។ ការលេងវាយស្គរដោយមាត់ ការធ្វើសំឡេងស្គរដែលជាប់ដោយមាត់ ការយកមាត់ធ្វើត្រាប់សំឡេងស្គរ ការហួច ការពោលសំឡេងដូចជាសំឡេងស្គរដោយមាត់ ការបង្រៀនរាំ ការច្រៀងបញ្ចើត ការច្រៀង ការធ្វើឲ្យសើច នេះល្បែងខាងផ្លូវវាចា ។

សេចក្តីនៃពាក្យថា តម្រេក គឺពាក្យថា តម្រេកនុ៎ះ ជាឈ្មោះនៃសេចក្តីមិនអផ្សុក ។ ពាក្យថា ក្នុងកណ្តាលសម្លាញ់ គឺការដើរទៅជាសុខ ការមកជាសុខ ការទៅមកជាសុខ ការឈរជាសុខ ការអង្គុយជាសុខ ការដេកជាសុខ ការហៅរកជាសុខ ការចរចាជាសុខ ការឆ្លើយឆ្លងរកគ្នាជាសុខ ការនិយាយស្រស់ស្រាយជាសុខ ជាមួយពួកជនណា ពួកជននោះ លោកហៅថាសម្លាញ់ ។ ពាក្យថា ល្បែង តម្រេក ( រមែងមាន ) ក្នុងកណ្តាលសម្លាញ់ គឺលេងផង តម្រេកផង រមែងមានក្នុងកណ្តាល ហេតុនោះ ( លោកពោលថា ) ល្បែង តម្រេក រមែងមានក្នុងកណ្តាលសម្លាញ់ ។

[ ២៥៥ ] អធិប្បាយពាក្យថា សេចក្តីស្រឡាញ់ដ៏ធំទូលាយ រមែងមានក្នុងពួកបុត្រ ត្រង់ពាក្យថា បុត្រ បានដល់ បុត្រ ៤ ពួក គឺបុត្រកើតអំពីខ្លួន បុត្រកើតក្នុងខេត្ត ១ បុត្រដែលគេឲ្យ ១ បុត្រ គឺសិស្ស ១ ។ ពាក្យថា សេចក្តីស្រឡាញ់ដ៏ធំទូលាយ រមែងមានក្នុងពួកបុត្រ គឺសេចក្តីស្រឡាញ់ដ៏ក្រៃលែង រមែងមានក្នុងពួកបុត្រ ហេតុនោះ ( លោកពោលថា ) ទាំងសេចក្តីស្រឡាញ់ដ៏ធំទូលាយ រមែងមានក្នុងពួកបុត្រ ។

[ ២៥៦ ] ពាក្យថា បុគ្គលកាលធុញទ្រាន់ចំពោះការព្រាត់ប្រាសចាកអារម្មណ៍ជាទីស្រឡាញ់ អធិប្បាយថា អារម្មណ៍ជាទីស្រឡាញ់ មាន ២ គឺ ពួកសត្វជាទីស្រឡាញ់ ១ ពួកសង្ខារជាទីស្រឡាញ់ ១ ។

ពួកសត្វជាទីស្រឡាញ់ តើដូចម្តេច ។ ពួកជនណាក្នុងលោកនេះ ទោះជាមាតាក្តី បិតាក្តី បងប្អូនប្រុសក្តី បងប្អូនស្រីក្តី បុត្រក្តី ធីតាក្តី មិត្តក្តី

អាមាត្យក្តី ញាតិក្តី សាលោហិតក្តី ជាអ្នកប្រាថ្នាសេចក្តីចម្រើន ប្រាថ្នាប្រយោជន៍ ប្រាថ្នាសេចក្តីសុខ ប្រាថ្នាការក្សេមចាកយោគៈរបស់ជននោះ នេះពួកសត្វជាទីស្រឡាញ់ ។

ពួកសង្ខារជាទីស្រឡាញ់ តើដូចម្តេច ។ រូបជាទីពេញចិត្ត សំឡេងជាទីពេញចិត្ត ក្លិនជាទីពេញចិត្ត រសជាទីពេញចិត្ត ផ្សព្វជាទីពេញចិត្ត នេះពួកសង្ខារជាទីស្រឡាញ់ ។

ពាក្យថា បុគ្គលកាលធុញទ្រាន់ចំពោះការព្រាត់ប្រាសចាកអារម្មណ៍ជាទីស្រឡាញ់ បានសេចក្តីថា បុគ្គលកាលធុញទ្រាន់ នឿយណាយ ខ្ពើមរអើមចំពោះការព្រាត់ប្រាសចាកអារម្មណ៍ជាទីស្រឡាញ់ ហេតុនោះ ( លោកពោលថា ) បុគ្គលកាលធុញទ្រាន់ចំពោះការព្រាត់ប្រាសចាកអារម្មណ៍ជាទីស្រឡាញ់ ។ គប្បីប្រព្រឹត្តម្នាក់ឯងដូចកុយរមាស ។ ហេតុនោះ ព្រះបច្ចេកសម្ពុទ្ធនោះពោលថា

ល្បែង តម្រេក រមែងមានក្នុងកណ្តាលសម្លាញ់ ទាំងសេចក្តីស្រឡាញ់ដ៏ធំទូលាយ រមែងមានក្នុងពួកបុត្ត បុគ្គលកាលធុញទ្រាន់ ចំពោះការព្រាត់ប្រាសចាកអារម្មណ៍ ជាទីស្រឡាញ់ គប្បីប្រព្រឹត្តម្នាក់ឯង ដូចកុយរមាស ។

# អដ្ឋកថា

## គាថាទី ៧

គប្បីជ្រាបវិនិច្ឆ័យក្នុងគាថាទី ៧ ដូចតទៅនេះ

[ ២៥៣ ] បទថា **ខិឌ្ឌា** បានដល់ ការលេង ។ ការលេង មាន ២ យ៉ាង គឺលេងផ្លូវកាយ និងផ្លូវវាចា ។ ក្នុងការលេង ២ យ៉ាងនោះ ការលេងយ៉ាងនេះ គឺការលេងដោយដំរី សេះ រថ ធ្នូ ដាវជាដើម ឈ្មោះថា លេងផ្លូវកាយ ។ ការលេងយ៉ាងនេះ គឺច្រៀង ពោលពាក្យស្លោក ( កំណាព្យ ) លេងស្គរមាត់ជាដើម ឈ្មោះថា ការលេងផ្លូវវាចា ។ បទថា **រតី** បានដល់ ការត្រេកអរក្នុងកាមគុណ ៥ ។ បទថា **វិបុលំ** បានដល់ ជ្រួតជ្រាបចូលទៅក្នុងអត្តភាពទាំងមូល រហូតដល់ខួរក្នុងឆ្អឹង ។ បទដ៏សេស ប្រាកដច្បាស់ហើយ ។ សូម្បីយោជនាក្នុងនិទ្ទេសនេះ គប្បីជ្រាបតាមន័យដែលពោលហើយ ក្នុងសំសគ្គគាថានោះឯង ។៙

**អដ្ឋកថា គាថាទី ៧ ចប់**

# សុត្តន្តបិដក

[ ២៥៧ ] បុគ្គលមានកិរិយានៅជាសុខក្នុងទិស ៤ ទាំងមិនមានសេចក្តីថ្នាំងថ្នាក់ចិត្ត សន្តោសដោយបច្ច័យតាមមានតាមបាន ជាអ្នកអត់ធ្មត់ចំពោះអន្តរាយទាំងឡាយ ជាអ្នកមិនតក់ស្លុត គប្បីប្រព្រឹត្តម្នាក់ឯង ដូចកុយរមាស ។

[ ២៥៨ ] អធិប្បាយពាក្យថា បុគ្គលមានកិរិយានៅជាសុខក្នុងទិស ៤ ទាំងមិនមានសេចក្តីថ្នាំងថ្នាក់ចិត្ត ត្រង់ពាក្យថា មានកិរិយានៅជាសុខ សេចក្តីថា ព្រះបច្चេកសម្ពុទ្ធនោះ មានចិត្តប្រកបដោយមេត្តា ផ្សាយទៅកាន់ទិសទី ១ ទិសទី ២ ក៏ដូចគ្នា ទិសទី ៣ ក៏ដូចគ្នា ទិសទី ៤ ក៏ដូចគ្នា មានចិត្តប្រកបដោយមេត្តាដ៏ធំទូលាយ ដល់នូវសេចក្តីប្រសើរ ប្រមាណមិនបាន មិនមានពៀរ មិនមានព្យាបាទ ផ្សាយទៅកាន់លោកដែលមានសត្វទាំងអស់ ក្នុងទិសខាងលើ ទិសខាងក្រោម ទិសទទឹង ព្រោះយកខ្លួនទៅប្រៀបផ្ទឹមក្នុងសត្វទាំងអស់ ក្នុងទិសទាំងអស់ ហើយសម្រេចសម្រាន្តនៅ ដោយប្រការដូច្នេះ មានចិត្តប្រកបដោយករុណា មានចិត្តប្រកបដោយមុទិតា មានចិត្តប្រកបដោយឧបេក្ខា ផ្សាយទៅកាន់ទិសទី ១ ក៏ដូចគ្នា ទិសទី ២ ក៏ដូចគ្នា ទិសទី ៣ ក៏ដូចគ្នា ទិសទី ៤ ក៏ដូចគ្នា មានចិត្តប្រកបដោយឧបេក្ខាដ៏ធំទូលាយ ដល់នូវសេចក្តីប្រសើរ ប្រមាណមិនបាន មិនមានពៀរ មិនមានព្យាបាទ ផ្សាយទៅកាន់លោកដែលមានសត្វទាំងអស់ ក្នុងទិសខាងលើ ទិសខាងក្រោម ទិសទទឹង ព្រោះយកខ្លួនទៅប្រៀបផ្ទឹមក្នុងសត្វទាំងអស់ ក្នុងទិសទាំងអស់ ហើយសម្រេចសម្រាន្តនៅ ដោយប្រការដូច្នេះ ។ ពាក្យថា បុគ្គលមានកិរិយានៅ

ជាសុខក្នុងទិស ៤ ទាំងមិនមានសេចក្តីថ្នាំងថ្នាក់ចិត្ត បានសេចក្តីថា ព្រោះបានចម្រើនមេត្តា ( ទើបយល់ថា ) ពួកសត្វណា ក្នុងទិសខាងកើត ពួកសត្វនោះ មិនគួរខ្ពើម ពួកសត្វណា ក្នុងទិសខាងលិច ពួកសត្វនោះ មិនគួរខ្ពើម ពួកសត្វណា ក្នុងទិសខាងជើង ពួកសត្វនោះ មិនគួរខ្ពើម ពួកសត្វណា ក្នុងទិសអាគ្នេយ៍ ពួកសត្វនោះ មិនគួរខ្ពើម ពួកសត្វណា ក្នុងទិសពាយ័ព្យ ពួកសត្វនោះ មិនគួរខ្ពើម ពួកសត្វណា ក្នុងទិសនិរតី ពួកសត្វនោះ មិនគួរខ្ពើម ពួកសត្វណា ក្នុងទិសឦសាន ពួកសត្វនោះ មិនគួរខ្ពើម ពួកសត្វណា ក្នុងទិសខាងក្រោម ពួកសត្វនោះ មិនគួរខ្ពើម ពួកសត្វណា ក្នុងទិសខាងលើ ពួកសត្វនោះ មិនគួរខ្ពើម ពួកសត្វណា ក្នុងទិសធំទិសតូចទាំងឡាយ ពួកសត្វនោះ មិនគួរខ្ពើម ព្រោះបានចម្រើនករុណា ព្រោះបានចម្រើនមុទិតា ព្រោះបានចម្រើនឧបេក្ខា ( ទើបយល់ថា ) ពួកសត្វណា ក្នុងទិសខាងកើត ពួកសត្វនោះ មិនគួរខ្ពើម ។បេ។ ពួកសត្វណា ក្នុងទិសធំទិសតូចទាំងឡាយ ពួកសត្វនោះ មិនគួរខ្ពើម ហេតុនោះ ( លោកពោលថា ) បុគ្គលមានកិរិយានៅជាសុខក្នុងទិស ៤ ទាំងមិនមានសេចក្តីថ្នាំងថ្នាក់ចិត្ត ។

[ ២៥៩ ] ពាក្យថា សន្តោសដោយបច្ច័យតាមមានតាមបាន អធិប្បាយថា ព្រះបច្ចេកសម្ពុទ្ធនោះ ជាបុគ្គលសន្តោសដោយចីវរតាមមានតាមបានផង ថ្លែងគុណសន្តោសដោយចីវរតាមមានតាមបានផង មិនដល់នូវអនេសនៈដែលមិនសមគួរ ព្រោះហេតុតែចីវរផង មិនបានចីវរក៏មិនតក់ស្លុតផង បានចីវរហើយក៏មិនជក់ចិត្ត មិនឈ្លក់ចិត្ត មិនងប់ចិត្ត ឃើញទោស មានប្រាជ្ញាជាគ្រឿង

រលាស់ ប្រើប្រាស់ផង មួយទៀត មិនលើកតម្កើងខ្លួន មិនបន្អាប់បុគ្គលដទៃ ព្រោះតែសេចក្ដីសន្ដោស ដោយចីវរតាមមានតាមបាននោះ ដ្បិតថា ព្រះបច្ចេកសម្ពុទ្ធណាវាងវៃ មិនខ្ជិល ដឹងខ្លួន មានស្មារតីស៊ប់ស្ងួន ក្នុងការសន្ដោសដោយចីវរតាមមាន តាមបាននោះ ព្រះបច្ចេកសម្ពុទ្ធនេះ លោកពោលថា អ្នកស្ថិតនៅក្នុងអរិយវង្ស មានក្នុងកាលមុន ដែលពួកបណ្ឌិតគួរស្គាល់ថា ប្រសើរ ។ ជាអ្នកសន្ដោសដោយបិណ្ឌបាតតាមមានតាមបានផង ថ្លែងគុណសន្ដោសដោយបិណ្ឌបាតតាមមានតាមបានផង មិនដល់នូវអនេសនៈដែលមិនសមគួរ ព្រោះហេតុតែបិណ្ឌបាតផង មិនបានបិណ្ឌបាតក៏មិនតក់ស្លុតផង បានបិណ្ឌបាតហើយ ក៏មិនជក់ចិត្ត មិនឈ្ងក់ចិត្ត មិនងប់ចិត្ត ឃើញទោស មានប្រាជ្ញាជាគ្រឿងរលាស់ ប្រើប្រាស់ផង មួយទៀត មិនលើកតម្កើងខ្លួន មិនបន្អាប់បុគ្គលដទៃ ព្រោះតែការសន្ដោសដោយបិណ្ឌបាតតាមមានតាមបាននោះ ដ្បិតថា ព្រះបច្ចេកសម្ពុទ្ធណាវាងវៃ មិនខ្ជិល ដឹងខ្លួន មានស្មារតីស៊ប់ស្ងួន ក្នុងការសន្ដោសដោយបិណ្ឌបាតតាមមានតាមបាននោះ ព្រះបច្ចេក-សម្ពុទ្ធនេះ លោកពោលថា អ្នកស្ថិតនៅក្នុងអរិយវង្ស មានក្នុងកាលមុន ដែលពួកបណ្ឌិតគួរស្គាល់ថា ប្រសើរ ។ ជាអ្នកសន្ដោសដោយសេនាសនៈតាមមានតាមបានផង ថ្លែងគុណសន្ដោសដោយសេនាសនៈ តាមមាន តាមបានផង មិនដល់នូវអនេសនៈដែលមិនសមគួរ ព្រោះហេតុតែសេនាសនៈផង មិនបានសេនាសនៈក៏មិនតក់ស្លុតផង បានសេនាសនៈហើយ ក៏មិនជក់ចិត្ត មិនឈ្ងក់ចិត្ត មិនងប់ចិត្ត ឃើញទោស មានប្រាជ្ញាជាគ្រឿងរលាស់ ប្រើប្រាស់

ផង មួយទៀត មិនលើកតម្កើងខ្លួន មិនបន្អាប់បុគ្គលដទៃ ព្រោះតែការសន្តោសដោយសេនាសេនៈតាមមានតាមបាននោះ ដ្បិតថា ព្រះបច្ចេកសម្ពុទ្ធណាឯង៉ៃ មិនខ្ជិល ដឹងខ្លួន មានស្មារតីស៊ប់ស្ងួន ក្នុងការសន្តោសដោយសេនាសនៈតាមមានតាមបាននោះ ព្រះបច្ចេកសម្ពុទ្ធនេះ លោកពោលថា អ្នកស្ថិតនៅក្នុងអរិយវង្ស មានក្នុងកាលមុន ដែលពួកបណ្ឌិតគួរស្គាល់ថា ប្រសើរ ។ ជាបុគ្គលសន្តោសដោយគិលានប្បច្ចយភេសជ្ជបរិក្ខារ តាមមានតាមបានផង ថ្លែងគុណសន្តោសដោយគិលានប្បច្ចយភេសជ្ជបរិក្ខារ តាមមានតាមបានផង មិនដល់នូវអនេសនៈដែលមិនសមគួរ ព្រោះហេតុតែគិលា-នប្បច្ចយភេសជ្ជបរិក្ខារ មិនបានគិលានប្បច្ចយភេសជ្ជបរិក្ខារ ក៏មិនតក់ស្លុតផង បានគិលានប្បច្ចយភេសជ្ជបរិក្ខារហើយ ក៏មិនជក់ចិត្ត មិនឈ្លក់ចិត្ត មិនងប់ចិត្ត ឃើញទោស មានប្រាជ្ញាជាគ្រឿងរលាស់ ប្រើប្រាស់ផង មួយទៀត មិនលើកតម្កើងខ្លួន មិនបន្អាប់បុគ្គលដទៃទេ ព្រោះតែការសន្តោសដោយគិលានប្បច្ចយភេសជ្ជបរិក្ខារតាមមានតាមបាននោះ ដ្បិតថា ព្រះបច្ចេកសម្ពុទ្ធណាឯង៉ៃ មិនខ្ជិល ដឹងខ្លួន មានស្មារតីស៊ប់ស្ងួន ក្នុងការសន្តោសដោយគិលានប្បច្ចយភេសជ្ជបរិក្ខារ តាមមានតាមបាននោះ ព្រះបច្ចេកសម្ពុទ្ធនេះ លោកពោលថា ស្ថិតនៅក្នុងអរិយវង្សក្នុងកាលមុន ដែលពួកបណ្ឌិតស្គាល់ថា ប្រសើរ ។ ហេតុនោះ ( លោកពោលថា ) សន្តោសដោយបច្ច័យតាមមាន តាមបាន ។

[ ២៦០ ] អធិប្បាយថា ជាអ្នកអត់ធ្មត់ចំពោះអន្តរាយទាំងឡាយ ជាអ្នក

មិនតក់ស្លុត ត្រង់ពាក្យថា អន្តរាយ បានដល់ អន្តរាយ ២ គឺអន្តរាយប្រាកដ ១ អន្តរាយកំបាំង ។ អន្តរាយប្រាកដ តើដូចម្តេច ។ ពួកសីហៈ ពួកខ្លាធំ ខ្លាដំបង ពួកខ្លាឃ្មុំ និងខ្លារខិន ពួកឆ្កែព្រៃ ពួកគោ និងក្របី ពួកដំរី ពស់ ខ្ទួយ ក្អែប ឬពួកមាណពជាចោរធ្វើកម្មហើយ ឬមិនទាន់ធ្វើកម្មហើយ ឬ រោគក្នុងភ្នែក រោគត្រចៀក រោគច្រមុះ រោគអណ្តាត រោគកាយ រោគក្បាល រោគស្លឹកត្រចៀក រោគមាត់ រោគធ្មេញ ក្អក ហឺត រោគខាងក្រៅច្រមុះ រោគក្តៅ រោគគ្រាំគ្រា រោគពោះ ខ្យល់ចាប់ ធ្លាក់ឈាម ចុកសៀត រាករូស ឃ្លង់ បូស ស្រែង របេង ឆ្កួតជ្រូក ដំណួចពិស រមាស់ កម រោគក្លាយ អំពីក្រចក ឃ្លង់ដែក ឈាម ប្រមាត់ ទឹកមូត្រផ្អែម ឫសដូងដុះ រលកកែវ ឫសដូងបាត ពួកអាពាធកើតអំពីប្រមាត់ ពួកអាពាធកើតអំពីស្លេស្ម ពួកអាពាធកើតអំពីខ្យល់ ពួកអាពាធកើតអំពីនៃប្រមាត់ស្លេស្ម និងខ្យល់ ពួកអាពាធកើតអំពីការប្រែប្រួលរដូវ ពួកអាពាធកើតអំពីការប្រើឥរិយាបថមិនស្មើ ពួកអាពាធកើតអំពីសេចក្តីព្យាយាម ( មានការសម្លាប់ ចាប់ចងជាដើម ) ពួកអាពាធកើតអំពីវិបាករបស់កម្ម ត្រជាក់ ក្តៅ គម្លាន សម្រេក ឧច្ចារៈ បស្សាវៈ ពួកសម្ផស្សនៃរបោម មូស ខ្យល់ កម្តៅថ្ងៃ និងសត្វលូន ទាំងនេះ លោកហៅថា អន្តរាយប្រាកដ ។

អន្តរាយកំបាំង តើដូចម្តេច ។ កាយទុច្ចរិត វចីទុច្ចរិត មនោទុច្ចរិត កាមច្ឆន្ទនីវរណៈ ព្យាបាទនីវរណៈ ថីនមិទ្ធនីវរណៈ ឧទ្ធច្ចកុក្កុច្ចនីវរណៈ វិចិកិច្ឆានីវរណៈ រាគៈ ទោសៈ មោហៈ កោធៈ ឧបនាហៈ មក្ខៈ បឡាសៈ ឥស្សា

មិច្ឆរិយៈ មាយា សាថេយ្យៈ ថម្ភៈ សារម្ភៈ មានះ អតិមានះ មទៈ បមាទៈ ពួកកិលេសទាំងពួង សេចក្តីក្រវល់ក្រវាយទាំងពួង សេចក្តីក្រហល់ក្រហាយទាំងពួង សេចក្តីក្តៅក្រហាយទាំងពួង អកុសលាភិសង្ខារទាំងពួង ទាំងនេះ លោកហៅថា អន្តរាយកំបាំង ។

សំណួរត្រង់ពាក្យថា ពួកអន្តរាយ ចុះអន្តរាយ តើដោយសេចក្តីដូចម្តេច ។ ឈ្មោះថា អន្តរាយ ព្រោះហេតុបង្រ្កប ។ ឈ្មោះថា អន្តរាយ ព្រោះហេតុប្រព្រឹត្តទៅដើម្បីសេចក្តីសាបសូន្យ ។ ឈ្មោះថា អន្តរាយ ព្រោះហេតុអាស្រ័យក្នុងសរីរៈនោះ ។

ចុះឈ្មោះថា អន្តរាយ ព្រោះហេតុបង្រ្កប តើដូចម្តេច ។ ពួកអន្តរាយនោះ សង្រ្កប បង្រ្កប គ្របសង្កត់ រួបរឹត សង្កត់សង្កិន បៀតបៀនទូវបុគ្គលនោះ ឈ្មោះថា អន្តរាយ ព្រោះហេតុបង្រ្កបយ៉ាងនេះឯង ។

ចុះឈ្មោះថា អន្តរាយ ព្រោះហេតុប្រព្រឹត្តទៅដើម្បីសាបសូន្យ តើដូចម្តេច ។ ពួកអន្តរាយប្រព្រឹត្តទៅព្រម ដើម្បីសេចក្តីអន្តរាយ ដើម្បីសេចក្តីសាបសូន្យពួកធម៌ជាកុសល ។ ពួកធម៌ជាកុសល តើដូចម្តេចខ្លះ ។ សម្មាបដិបទា អនុលោមប្បដិបទា អបច្ចនីកប្បដិបទា អន្វត្ថប្បដិបទា ធម្មានុធម្មប្បដិបទា ការធ្វើឲ្យពេញលេញក្នុងសីលទាំងឡាយ ការគ្រប់គ្រងទ្វារក្នុងឥន្រ្ទិយទាំងឡាយ ការដឹងប្រមាណក្នុងភោជន ការប្រកបរឿយៗ នូវសេចក្តីភ្ញាក់រឭក សតិ និងសម្បជញ្ញៈ ការប្រកបរឿយៗ នូវការចម្រើន សតិប្បដ្ឋាន ៤ ការប្រកបរឿយៗ នូវកិរិយាចម្រើនសម្មប្បធាន ៤ ឥទ្ធិបាទ ៤ ឥន្រ្ទិយ ៥

ពល ៥ ពោជ្ឈង្គ ៧ អរិយមគ្គប្រកបដោយអង្គ ៨ ពួកអន្តរាយនោះ ប្រព្រឹត្តទៅព្រមដើម្បីសេចក្តីអន្តរាយ ដើម្បីសេចក្តីសាបសូន្យ នូវពួកធម៌ជាកុសលទាំងនេះ ឈ្មោះថា អន្តរាយ ព្រោះហេតុប្រព្រឹត្តទៅដើម្បីសេចក្តីសាបសូន្យ យ៉ាងនេះឯង ។

ចុះឈ្មោះថា អន្តរាយ ព្រោះហេតុអាស្រ័យក្នុងសរីរៈនោះ តើដូចម្តេច ។ ពួកធម៌ជាអកុសលដ៏អាក្រក់ទាំងនុ៎ះ អាស្រ័យព្រមនូវអត្តភាព រមែងកើតក្នុងអត្តភាពនោះ ។ ពួកពិលាសយសត្វ ( សត្វនៅក្នុងរន្ធ ) តែងដេកក្នុងរន្ធ ពួកឧទកាសយសត្វ ( សត្វនៅក្នុងទឹក ) តែងដេកក្នុងទឹក ពួកវនាសយសត្វ ( សត្វនៅក្នុងព្រៃ ) តែងដេកក្នុងព្រៃ ពួករុក្ខាសយសត្វ ( សត្វនៅលើឈើ ) តែងដេកលើឈើ យ៉ាងណា ពួកធម៌ជាអកុសលដ៏អាក្រក់ទាំងនុ៎ះ អាស្រ័យព្រមនូវអត្តភាព រមែងកើតក្នុងអត្តភាពនោះ យ៉ាងនោះដែរ ឈ្មោះថា អន្តរាយ ព្រោះហេតុអាស្រ័យក្នុងសរីរៈនោះ យ៉ាងនេះក៏មាន ។

សមដូចព្រះមានព្រះភាគ បានត្រាស់ព្រះតម្រាស់នេះថា ម្នាលភិក្ខុទាំងឡាយ ភិក្ខុអ្នកនៅរួមដោយសិស្ស អ្នកនៅរួមដោយអាចារ្យ តែងនៅជាទុក្ខមិនសប្បាយ ម្នាលភិក្ខុទាំងឡាយ ភិក្ខុអ្នកនៅរួមដោយសិស្ស អ្នកនៅរួមដោយអាចារ្យ តែងនៅជាទុក្ខមិនសប្បាយ តើដូចម្តេច ម្នាលភិក្ខុទាំងឡាយ ពួកធម៌ជាអកុសលដ៏អាក្រក់ណា គឺសេចក្តីត្រិះរិះដែលកើតដោយអំណាច នៃការវង្វាត់ទៅ ( ក្នុងអារម្មណ៍ផ្សេងៗ ) ជាគ្រឿងទំនុកបម្រុងដល់សំយោជនៈរបស់ភិក្ខុក្នុងសាសនានេះ កើតឡើងព្រោះឃើញរូបដោយចក្ខុ ពួកធម៌ជា

អកុសលដ៏អាក្រក់នោះ នៅខាងក្នុងសន្ដានរបស់ភិក្ខុនោះ ជាប់ជិត ប្រកិតតាមភិក្ខុនោះ ព្រោះហេតុនោះ ភិក្ខុនោះ តថាគតហៅថា អ្នកនៅរួមដោយសិស្ស ពួកធម៌ជាអកុសលដ៏អាក្រក់នោះ រមែងប្រើភិក្ខុនោះ ព្រោះហេតុនោះ ភិក្ខុនោះ តថាគតហៅថា អ្នករួមដោយអាចារ្យ ម្នាលភិក្ខុទាំងឡាយ មួយទៀត ពួកធម៌ជាអកុសលដ៏អាក្រក់ណា គឺសេចក្ដីត្រិះរិះដែលកើតដោយអំណាចនៃការវង្កាត់ទៅ ជាគ្រឿងទំនុកបម្រុងដល់សំយោជនៈរបស់ភិក្ខុកើតឡើង ព្រោះឮសំឡេងដោយត្រចៀក ធុំក្លិនដោយច្រមុះ ក្រេបជញ្ជក់រសដោយអណ្ដាត ពាល់ត្រូវផ្សព្វដោយកាយ ដឹងធម្មារម្មណ៍ដោយចិត្ត ពួកធម៌ជាអកុសលដ៏អាក្រក់ នៅខាងក្នុងសន្ដានរបស់ភិក្ខុនោះ ជាប់ជិត ប្រកិតតាមភិក្ខុនោះ ព្រោះហេតុនោះ ភិក្ខុនោះ តថាគតហៅថា អ្នករួមដោយសិស្ស ពួកធម៌ជាអកុសលដ៏អាក្រក់នោះ រមែងប្រើភិក្ខុនោះ ព្រោះហេតុនោះ ភិក្ខុនោះ តថាគតហៅថា អ្នកនៅរួមដោយអាចារ្យ ម្នាលភិក្ខុទាំងឡាយ ភិក្ខុអ្នកនៅរួមដោយសិស្ស អ្នករួមដោយអាចារ្យ តែងនៅជាទុក្ខមិនសប្បាយ យ៉ាងនេះឯង ។ ឈ្មោះថា អន្តរាយ ព្រោះហេតុអាស្រ័យក្នុងសរីរៈ យ៉ាងនេះក៏មាន ។

មួយទៀត ព្រះមានព្រះភាគបានត្រាស់ព្រះតម្រាស់នេះថា ម្នាលភិក្ខុទាំងឡាយ អកុសលធម៌ ៣ នេះ ជាមន្ទិលខាងក្នុង ជាអមិត្តខាងក្នុង ជាសត្រូវខាងក្នុង ជាពេជ្ឈឃាតខាងក្នុង ជាខ្មាំងខាងក្នុង អកុសលធម៌ ៣ តើដូចម្ដេចខ្លះ ម្នាលភិក្ខុទាំងឡាយ លោភៈជាមន្ទិលខាងក្នុង ជាអមិត្តខាងក្នុង ជាសត្រូវខាងក្នុង ជាពេជ្ឈឃាតខាងក្នុង ជាខ្មាំងខាងក្នុង ម្នាលភិក្ខុទាំងឡាយ

ទោសៈ ។បេ។ ម្នាលភិក្ខុទាំងឡាយ មោហៈជាមន្ទិលខាងក្នុង ជាអមិត្តខាងក្នុង ជាសត្រូវខាងក្នុង ជាពេជ្ឈឃាតខាងក្នុង ជាខ្មាំងខាងក្នុង ម្នាលភិក្ខុទាំងឡាយ អកុសលធម៌ ៣ នេះឯង ជាមន្ទិលខាងក្នុង ជាអមិត្តខាងក្នុង ជាសត្រូវខាងក្នុង ជាពេជ្ឈឃាតខាងក្នុង ជាខ្មាំងខាងក្នុង ។

លោភៈឲ្យកើតវិនាស លោភៈឲ្យចិត្តរំជួល ភ័យកើតខាងក្នុង អ្នកផងមិនយល់ភ័យនោះ ជនលោភមិនស្គាល់អត្ថ ជនលោភមិនឃើញធម៌ សេចក្ដីងងឹតឈឹង តែងមានក្នុងកាលដែលលោភៈគ្របសង្កត់នរៈនោះ ទោសៈឲ្យកើតវិនាស ទោសៈឲ្យចិត្តរំជួល ភ័យកើតខាងក្នុង អ្នកផង មិនយល់ភ័យនោះ ជនប្រទូស្តមិនស្គាល់អត្ថ ជនប្រទូស្តមិនឃើញធម៌ សេចក្ដីងងឹតឈឹង តែងមានក្នុងកាលដែលទោសៈគ្របសង្កត់នរៈនោះ មោហៈឲ្យកើតវិនាស មោហៈឲ្យចិត្តរំជួល ភ័យកើតខាងក្នុង អ្នកផង មិនយល់ភ័យនោះ ជនវង្វេង មិនស្គាល់អត្ថ ជនវង្វេង មិនឃើញធម៌ សេចក្ដីងងឹតឈឹង តែងមានក្នុងកាលដែលមោហៈគ្របសង្កត់នរៈនោះ ។

ឈ្មោះថា អន្តរាយ ព្រោះហេតុអាស្រ័យក្នុងសរីរៈនោះ យ៉ាងនេះក៏មាន ។

មួយទៀត ព្រះមានព្រះភាគ បានត្រាស់ព្រះតម្រាស់នេះថា បពិត្រមហារាជ អកុសលធម៌ ៣ ជាធម៌អន្តរាយ កាលកើតខាងក្នុង កើតឡើងដើម្បីមិនជាគុណ ដើម្បីការលំបាក ដើម្បីការនៅមិនស្រួល អកុសលធម៌ ៣

តើដូចម្តេចខ្លះ បពិត្រមហារាជ លោភៈជាធម៌អន្តរាយ កាលកើតខាងក្នុង កើតឡើង ដើម្បីមិនជាគុណ ដើម្បីការលំបាក ដើម្បីការនៅមិនស្រួល បពិត្រមហារាជ ទោសៈ ។បេ។ បពិត្រមហារាជ មោហៈជាធម៌អន្តរាយ កាលកើតខាងក្នុង កើតឡើងដើម្បីមិនជាគុណ ដើម្បីការលំបាក ដើម្បីការនៅមិនស្រួល បពិត្រមហារាជ អកុសលធម៌ ៣ នេះឯង កាលកើតខាងក្នុង កើតឡើង ដើម្បីមិនជាគុណ ដើម្បីការលំបាក ដើម្បីការនៅមិនស្រួល ។

លោភៈ ទោសៈ និងមោហៈកើតពីខ្លួន រមែងសម្លាប់បុរសដែល
មានចិត្តបាប ដូចផ្លែឫស្សីដែលសម្លាប់ដើមរបស់ខ្លួន ។

ឈ្មោះថា អន្តរាយ ព្រោះហេតុអាស្រ័យក្នុងសរីរៈនោះ យ៉ាងនេះក៏មាន ។ មួយទៀត ព្រះមានព្រះភាគបានត្រាស់ព្រះតម្រាស់នេះថា

រាគៈ ទោសៈ មោហៈ មានអត្តភាពនេះជាហេតុ សេចក្តីមិន
ត្រេកអរ សេចក្តីត្រេកអរ និងសេចក្តីព្រឺព្រួចរោម កើតហើយ
អំពីអត្តភាពនេះ សេចក្តីត្រិះរិះក្នុងចិត្តទាំងឡាយ ដាលឡើងអំពី
អត្តភាពនេះហើយ លែងចិត្ត ដូចជាពួកក្មេងលែងក្អែក ។

ឈ្មោះថា អន្តរាយ ព្រោះហេតុអាស្រ័យក្នុងសរីរៈនោះ យ៉ាងនេះក៏មាន ។

ពាក្យថា ជាអ្នកអត់ធ្មន់ចំពោះអន្តរាយទាំងឡាយ គឺជាអ្នកអត់ធ្មត់ មិនជក់ចិត្ត រួបរឹត បៀតបៀននូវអន្តរាយ ហេតុនោះ ( លោកពោលថា ) ជាអ្នកអត់ធ្មត់ចំពោះអន្តរាយទាំងឡាយ ។ ពាក្យថា ជាអ្នកមិនតក់ស្លុត គឺព្រះ

បច្ចេកសម្ពុទ្ធនោះ មិនខ្លាច មិនតក់ស្លុត មិនរន្ធត់ មិនរត់ លះបង់សេចក្តីខ្លាច និងញ័រចំប្រប់ហើយ ប្រាសចាកសេចក្តីព្រឺព្រួចរោម ហេតុនោះ ( លោកពោលថា ) ជាអ្នកអត់ធ្មត់ចំពោះអន្តរាយទាំងឡាយ ជាអ្នកមិនតក់ស្លុត ។ គប្បីប្រព្រឹត្តម្នាក់ឯង ដូចកុយរមាស ។ ហេតុនោះ ព្រះបច្ចេកសម្ពុទ្ធនោះពោលថា

បុគ្គលមានកិរិយានៅជាសុខក្នុងទិស ៤ ទាំងមិនមានសេចក្តីថ្នាំងថ្នាក់ចិត្ត សន្តោសដោយបច្ច័យតាមមានតាមបាន ជាអ្នកអត់ធ្មត់ចំពោះអន្តរាយទាំងឡាយ ជាអ្នកមិនតក់ស្លុត គប្បីប្រព្រឹត្តម្នាក់ឯងដូចកុយរមាស ។

# អដ្ឋកថា

## គាថាទី ៨

គប្បីជ្រាបវិនិច្ឆ័យក្នុងគាថាទី ៨ ដូចតទៅនេះ

[ ២៥៧ ] បទថា **ចាតុទ្ទិសោ** សេចក្តីថា នៅតាមសប្បាយក្នុងទិសទាំង ៤ ។ ផ្សាយនូវព្រហ្មវិហារភាវនា ដោយន័យជាដើមថា **ឯកំ ទិសំ ផរិត្វា វិហរតិ** រមែងផ្សាយទៅកាន់ទិសទី ១ ។ ឈ្មោះថា **ចាតុទ្ទិសោ** ព្រោះនៅបានទាំង ៤ ទិស ។ ឈ្មោះថា **អប្បដិឃោ** ព្រោះមិនបៀតបៀនសត្វ ឬសង្ខារ ដោយភ័យក្នុងទិសណាមួយ ក្នុង ៤ ទិស ៤ ។ បទថា **សន្តុស្សមានោ** បានដល់ ត្រេកអរដោយអំណាចសន្តោស ១២ យ៉ាង ។ បទថា **ឥតរីតរេន** បានដល់ ដោយបច្ច័យខ្ពស់ និងទាប ។ ក្នុងបទថា **បរិស្សយានំ សហិតា អឆម្ភី** នេះ ឈ្មោះថា **បរិស្សយា** ព្រោះគ្របសង្កត់កាយ និងចិត្ត ទម្លាយគុណសម្បត្តិរបស់កាយ និងចិត្តទាំងនោះ ឬញាំញីកាយ និងចិត្តទាំងនោះ ។ ពាក្យនេះ ជាឈ្មោះរបស់អន្តរាយផ្លូវកាយ និងចិត្តខាងក្រៅ មានរាជសីហ៍ និងខ្លាធំជាដើម ខាងក្នុងមានកាមច្ឆន្ទៈជាដើម ។ ឈ្មោះថា **បរិស្សយានំ សហិតា** ព្រោះគ្របសង្កត់អន្តរាយទាំងនោះ ដោយការអត់ធន់ គឺការអត់ធ្មត់ និងដោយធម៌ មានវិរិយៈជាដើម ។ ឈ្មោះថា **អឆម្ភី** ព្រោះមិនមានការខ្លាចដែលធ្វើនូវការរឹងត្អឹង ។ លោកអធិប្បាយដូចម្តេច អធិប្បាយថា សមណៈ ៤ ពួក យ៉ាងណា យោគាវចរក៏ដូច្នោះ ជាអ្នកសន្តោសដោយបច្ច័យតាមមានតាមបានយ៉ាងនោះ តាំងនៅក្នុងសន្តោសដែលជាផ្លូវនៃកិច្ចបដិបត្តិនេះ មានប្រក្រតីនៅតាមសប្បាយក្នុងទិសទាំង ៤

ព្រោះបំពេញធម៌ មានមេត្តាជាដើមក្នុងទិសទាំង ៤ មិនមានការអាក់អន់ ព្រោះមិនមានភ័យដែលធ្វើឲ្យខ្វាំងខ្វប់ក្នុងសត្វ និងសង្ខារទាំងឡាយ យោគាវចរនោះ គ្របសង្កត់អន្តរាយទាំងឡាយ ដូចបានពោលហើយ ព្រោះមានប្រក្រតីនៅតាមសប្បាយ ក្នុងទិសទាំង ៤ មិនមានការតក់ស្លុត ព្រោះមិនមានការខ្វាំងខ្វប់ ព្រោះហេតុនោះ អាត្មាឃើញគុណនៃកិច្ចបដិបត្តិនេះ ទើបបដិបត្តិដោយឧបាយ ហើយសម្រេចបច្ចេកសម្ពោធិញ្ញាណ ។

ម្យ៉ាងទៀត អាត្មាដឹងថា បុគ្គលសន្តោសដោយបច្ច័យតាមមាន តាមបាន ដូចសមណៈទាំងនោះ មានប្រក្រតីនៅតាមសប្បាយក្នុងទិសទាំង ៤ តាមន័យដែលពោលហើយនេះ ទើបប្រាថ្នាភាពជាអ្នកមានប្រក្រតី នៅតាមសប្បាយ ក្នុងទិសទាំង ៤ យ៉ាងនេះ បានបដិបត្តិដោយឧបាយ ទើបសម្រេច ព្រោះដូច្នោះ អ្នកដទៃប្រាថ្នាឋានៈបែបនោះខ្វះ ជាអ្នកគ្របសង្កត់អន្តរាយទាំងឡាយ ព្រោះជាអ្នកមានប្រក្រតីនៅតាមសប្បាយ ក្នុងទិសទាំង ៤ និងជាអ្នកមិនតក់ស្លុត ព្រោះមិនមានការខ្វាំងខ្វប់ គប្បីត្រាច់ទៅម្នាក់ឯង ដូចកុយរមាស ដូច្នោះ ។

គប្បីជ្រាបវិនិច្ឆ័យក្នុងនិទ្ទេសដូចតទៅនេះ

[ ២៥៨ ] បទថា **មេត្តា** គប្បីជ្រាបដោយអត្ថមុន ឈ្មោះថា **មេត្តា** ព្រោះមានការជាប់ជំពាក់ អធិប្បាយថា ព្រោះស្រឡាញ់ ។ ឈ្មោះថា **មេត្តា** ព្រោះមានសេចក្តីស្រឡាញ់ ឬការប្រព្រឹត្តទៅនៃសេចក្តីស្រឡាញ់ ។ បទថា **មេត្តាសហគតេន** បានដល់ ប្រកបទៅដោយមេត្តា ។ បទថា **ចេតសា**

បានដល់ មានចិត្ត ។ បទថា **ឯកំ ទិសំ** បានដល់ ក្នុងទិស ១ ។ លោកពោលបំណងយកសត្វដែលកំណត់ជាទី ១ ដោយការផ្សាយទៅដល់សត្វដែលទាក់ទងក្នុងទិស ១ ។ បទថា **ផរិត្វា** បានដល់ ពាល់ត្រូវ គឺធ្វើឲ្យជាអារម្មណ៍ ។ បទថា **វិហរតិ** បានដល់ ធ្វើការនៅនៃឥរិយាបថ ដែលតាំងនៅក្នុងព្រហ្មវិហារឲ្យប្រព្រឹត្តទៅ ។ បទថា **តថា ទុតិយំ** សេចក្តីថា ផ្សាយទៅកាន់ទិស ១ ក្នុងទិសបូព៌ជាដើម ទិសណាមួយ យ៉ាងណា បន្ទាប់អំពីទិសនោះ ក៏យ៉ាងនោះ អធិប្បាយថា ទិសទី ២ ទី ៣ និងទិសទី ៤ ។ បទថា **ឥតិ ឧទ្ធំ** លោកពោលថា ទិសខាងលើ ដោយន័យនោះដូចគ្នា ។ បទថា **អធោ តិរិយំ** បានដល់ ក្នុងទិសខាងក្រោម សូម្បីទិសទទឹងក៏ដូចគ្នា ។ម្យ៉ាងទៀត ក្នុងបទទាំងនោះ បទថា **អធោ** បានដល់ ខាងក្រោម ។ បទថា **តិរិយំ** បានដល់ ទិសតូច ។ ព្រះបច្ចេកពុទ្ធញុំាងចិត្តសហគតៈដោយមេត្តាឲ្យស្ទុះទៅខ្លះ ឲ្យស្ទុះត្រឡប់ខ្លះ ក្នុងទិសទាំងពួងយ៉ាងនេះ ដូចបុគ្គលបង្ហាត់សេះ ញុំាងសេះឲ្យរត់ទៅខ្លះ ឲ្យរត់ត្រឡប់ខ្លះ ក្នុងទីលានកីឡាសម្រាប់បង្ហាត់សេះ ។ ដោយហេតុមានប្រមាណប៉ុណ្ណោះ លោកកំណត់ទិសនីមួយៗ ហើយសម្តែងដល់ការផ្សាយមេត្តាដោយចំពោះ ។ បទថា **សព្វធិ** ជាដើម លោកពោលដើម្បីសម្តែងការផ្សាយមេត្តាដោយមិនចំពោះ ។ ក្នុងបទទាំងនោះ បទថា **សព្វធិ** បានដល់ ក្នុងទិសទាំងពួង ។ បទថា **សព្វត្តតាយ** បានដល់ដោយមានខ្លួនក្នុងសត្វទាំងពួង មានហីនៈ មជ្ឈិម ឧក្រិដ្ឋ មិត្រ សត្រូវ និងមនុស្សជាកណ្តាល ។ លោកពោលថា ដោយស្មើគ្នានឹងខ្លួន ដោយមិនធ្វើ

ការចែកថា នេះជាសត្វដទៃ ។

ម្យ៉ាងទៀត បទថា **សព្វត្តតាយ** បានដល់ ដោយភាពជាចិត្តទាំងអស់ លោកអធិប្បាយថា មិនបន្សាត់ចិត្តចេញទៅខាងក្រៅសូម្បីតែបន្តិច ។ បទថា **សព្វាវន្តំ** បានដល់ សត្វទាំងពួង គឺប្រកបដោយសត្វទាំងពួង ។ បទថា **លោកំ** បានដល់ គ្រប់សត្វលោក ។ លោកពោលថា ប្រកបដោយមេត្តា ក្នុងទីនេះទៀត ព្រោះសម្តែងដោយបរិយាយយ៉ាងនេះថា **វិបុលេន** ជាដើម ។ ម្យ៉ាងទៀត **តថា** សព្ទក្តី **ឥតិ** សព្ទក្តី លោកមិនបានពោលក្នុងទីនេះទៀត ដូចដែលពោលក្នុងការផ្សាយទៅដោយចំពោះ ព្រោះហេតុនោះ ទើបលោក ពោលទៀតថា មានចិត្តប្រកបដោយមេត្តា ។ ម្យ៉ាងទៀត សូត្រនេះ លោក ពោលដោយសរុប ។ ម្យ៉ាងទៀត ក្នុងបទថា **វិបុលេន** នេះ គប្បីឃើញ នូវភាពជាអ្នកមានចិត្តទូលាយដោយការផ្សាយទៅ ។ ចិត្តនោះ ជាមហគ្គតៈ ដោយអំណាចនៃភូមិ ។ ជាអប្បមាណដោយអំណាចនៃការស្ទាត់ជំនាញ និង ដោយអំណាចនៃសត្វមិនមានប្រមាណជាអារម្មណ៍ ។ ជា **អវេរ** ព្រោះលះ នូវសត្រូវ គឺព្យាបាទបាន ។ ជា **អព្យាបជ្ឈ** ព្រោះលះទោមនស្សបាន ។ មានពាក្យអធិប្បាយថា អស់ទុក្ខ ។ ករុណា មានន័យដូចបានពោលហើយ ខាងដើមនោះឯង ។ ឈ្មោះថា **មុទិតា** ព្រោះជាហេតុឲ្យបុគ្គលប្រកបត្រេកអរ ឬត្រេកអរដោយខ្លួនឯង ឬត្រឹមតែការត្រេកអរប៉ុណ្ណោះ ។ ឈ្មោះថា **ឧបេក្ខា** ព្រោះសម្លឹងដោយការលះព្យាបាទថា សត្វទាំងឡាយ កុំបីមានពៀរនឹងគ្នា ឡើយជាដើម និងដោយការចូលដល់ភាពជាកណ្តាល ។

ម្យ៉ាងទៀត គប្បីជ្រាបសេចក្តីក្នុងបទនេះ ដោយលក្ខណៈជាដើមដូចតទៅ មេត្តា មានការប្រព្រឹត្តទៅនៃអាការអនុគ្រោះជាលក្ខណៈ មានការនាំប្រយោជន៍ចូលទៅជាកិច្ច មានការកម្ចាត់នូវអាឃាតជាអាការប្រាកដ មានការឃើញថា សត្វទាំងឡាយគួរពេញចិត្តជាហេតុជិត ។ មេត្តានេះ មានការស្ងប់ព្យាបាទជាសម្បត្តិ មានការកើតសេចក្តីស្រឡាញ់ជាវិបត្តិ ។

ករុណា មានការប្រព្រឹត្តទៅ នៃអាការជួយឲ្យសត្វផុតទុក្ខជាលក្ខណៈ មានការអត់ធន់មិនបានក្នុងទុក្ខរបស់សត្វដទៃជាកិច្ច មានការមិនបៀតបៀនជាអាការប្រាកដ មានការឃើញសត្វទាំងឡាយ ត្រូវសេចក្តីទុក្ខគ្របសង្កត់ មិនមានទីពឹងជាហេតុជិត ។ ករុណានេះ មានការស្ងប់នូវការបៀតបៀនជាសម្បត្តិ មានការកើតសេចក្តីសោកជាវិបត្តិ ។

មុទិតា មានការត្រេកអរជាលក្ខណៈ មានការមិនច្រណែនជាកិច្ច មានការកម្ចាត់ការមិនត្រេកអរជាអាការប្រាកដ មានការឃើញសម្បត្តិរបស់សត្វទាំងឡាយជាហេតុជិត ។ មុទិតានេះ មានការស្ងប់ការមិនត្រេកអរជាសម្បត្តិ មានការកើតនូវសេចក្តីត្រេកអរជាវិបត្តិ ។

ឧបេក្ខា មានការប្រព្រឹត្តទៅ នៃអាការដាក់ខ្លួនជាកណ្តាលក្នុងសត្វទាំងឡាយជាលក្ខណៈ មានការឃើញការស្មើគ្នាក្នុងសត្វទាំងឡាយជាកិច្ច មានការចូលទៅស្ងប់នូវការអាក់អន់ និងការត្រេកអរជាអាការប្រាកដ មានការឃើញភាពដែលសត្វមានកម្មជារបស់ខ្លួន ដែលប្រព្រឹត្តទៅយ៉ាងនេះថា សត្វទាំងឡាយ មានកម្មជារបស់ខ្លួន សត្វទាំងនោះ នឹងមានសុខ ផុតចាកទុក្ខ ឬ

នឹងមិនវិនាសចាកសម្បត្តិដែលមាន តាមការគាប់ចិត្តនៃបុគ្គលណាម្នាក់ជាហេតុ ជិត ។ ឧបេក្ខានេះ មានការស្ងប់ចាកការអាក់អន់ និងការត្រេកអរជាសម្បត្តិ មានការកើតនូវឧបេក្ខា គឺការមិនដឹងដែលអាស្រ័យផ្ទះជាវិបត្តិ ។

[ ២៥៩ ] ក្នុងបទទាំងនោះ បទថា **សន្តុដ្ឋោ ហោតិ** សេចក្តីថា ជាអ្នកត្រេកអរដោយការត្រេកអរក្នុងបច្ច័យ ។ បទថា **ឥតរីតរេន ចីវរេន** សេចក្តីថា ត្រេកអរដោយចីវរណាមួយ ក្នុងចីវរសាច់គ្រោតគ្រាត សាច់ម៉ដ្ឋ សៅហ្មង ប្រណីត មាំទាំ និងចាស់ជាដើម អធិប្បាយថា ដែលពិតហើយ ជាអ្នកសន្តោសដោយចីវរតាមមានតាមបាន នៃចីវរតាមដែលបានហើយ ។ ពិតហើយ ក្នុងចីវរ មានសន្តោស ៣ យ៉ាង គឺយថាលាភសន្តោស ១ យថាពលសន្តោស ១ យថាសារុប្បសន្តោស ១ ក្នុងបិណ្ឌបាតជាដើម ក៏ន័យដូចគ្នា ។ លោកពោលថា ជាអ្នកសន្តោសដោយចីវរតាមមានតាមបាន គឺជាអ្នកសន្តោសដោយចីវរផ្សេងណាមួយ ក្នុងបណ្តាចីវរ តាមដែលបានហើយ សំដៅដល់សន្តោសទាំង ៣ នេះ ។

ម្យ៉ាងទៀត ក្នុងបទនេះ គប្បីជ្រាបចីវរ ខេត្តរបស់ចីវរ សំពត់បង្សុកូល ការសន្តោសក្នុងចីវរ និងធុតង្គដែលសម្បយុត្តដោយចីវរ ។

ពាក្យថា គប្បីជ្រាបចីវរ សេចក្តីថា គប្បីស្គាល់នូវចីវរ ៦ ប្រភេទ មានសំពត់ធ្វើដោយសម្បកឈើជាដើម និងចីវរអនុលោម ៦ ប្រភេទ មានចីវរធ្វើដោយសំពត់សាច់ល្អជាដើម ។ ចីវរ ១២ ប្រភេទនេះ ជាកប្បិយ-ចីវរ ។ ចីវរ មានចីវរដែលធ្វើដោយស្បូវក្លាំង ធ្មៃ សម្បកឈើ សក់មនុស្ស

រោមសត្វ ស្លឹករឹត ស្បែក ស្លាបមៀម ដើមឈើ វល្លិ រំទឹក ចេក ឫស្សី ជាដើម ជាអកប្បិយចីវរ ។ ពាក្យថា ខេត្តរបស់ចីវរ សេចក្តីថា ខេត្តមាន ៦ ព្រោះកើតឡើងយ៉ាងនេះ គឺកើតអំពីសង្ឃ ១ កើតអំពីគណៈ ១ កើតអំពីញាតិ ១ កើតអំពីមិត្រ ១ កើតអំពីទ្រព្យរបស់ខ្លួន ១ ជាសំពត់បង្សុកូល ១ ។ គប្បីជ្រាបខេត្ត ៨ ដោយអំណាចនៃមាតិកា ៨ ។

ក្នុងពាក្យថា សំពត់បង្សុកូល គប្បីជ្រាបសំពត់បង្សុកូល ២៣ ប្រភេទ គឺសំពត់បានមកអំពីព្រៃខ្មោច ១ សំពត់ដែលគេចោលតាមរានផ្សារ ១ សំពត់ដែលគេចោលតាមផ្លូវ ១ សំពត់ដែលគេចោលតាមគំនរសំរាម ១ សំពត់ដែលគេជូតមន្ទិលគភ៌ ១ សំពត់ដែលធ្លាក់ក្នុងទីងូតទឹក ១ សំពត់ដែលធ្លាក់ត្រង់កំពង់ទឹក ១ សំពត់រុំសាកសព ១ សំពត់ភ្លើងឆេះ ១ សំពត់ដែលគោទំពាស៊ី ១ សំពត់ដែលកណ្តៀរកាត់ ១ សំពត់ដែលកណ្តុរកាត់ ១ សំពត់ដែលរហែកខាងក្នុង ១ សំពត់ដែលមានជាយដាច់ដាច ១ សំពត់ដែលគេធ្វើទង់ ១ សំពត់បូជាស្តូប ១ សំពត់សមណចីវរ ១ សំពត់ដែលសមុទ្របន្សាត់ឡើងមកលើគោក ១ សំពត់ដែលគេចោលក្នុងពិធីរាជាភិសេក ១ សំពត់ដើរផ្លូវ ១ សំពត់ដែលខ្យល់បក់មក ១ សំពត់ដែលសម្រេចដោយឫទ្ធិ ១ សំពត់ដែលទេវតាឲ្យ ១ ។

ក្នុងពាក្យទាំងនោះ ពាក្យថា សំពត់ជូតមន្ទិលគភ៌ បានដល់ សំពត់ជូតមន្ទិលគភ៌ ។ ពាក្យថា សំពត់រុំសព បានដល់ សំពត់ដែលគេរុំសព នាំទៅកាន់ព្រៃខ្មោច ហើយនាំត្រឡប់មក ។ ពាក្យថា សំពត់ដែលគេធ្វើទង់ បាន

ដល់ សំពត់ដែលគេលើកឡើងធ្វើជាទង់ហើយនាំមក ។ ពាក្យថា សំពត់បូជាស្តូប បានដល់ សំពត់ដែលគេបូជាត្រង់ជំបូក ។ ពាក្យថា សំពត់ដែលសមុទ្របន្សាត់ឡើងមកលើគោក បានដល់ សំពត់ដែលត្រូវរលកសមុទ្របន្សាត់ឡើងលើគោក ។ ពាក្យថា សំពត់ដើរផ្លូវ បានដល់ សំពត់ដែលអ្នកដំណើរយកថ្មដំ ព្រោះខ្លាចចោរ ហើយនាំមកដណ្តប់ ។ ពាក្យថា សំពត់ដែលសម្រេចដោយឫទ្ធិ បានដល់ សំពត់របស់ឯហិភិក្ខុ ។ បទដ៏សេសប្រាកដច្បាស់ហើយ ។

ពាក្យថា ការសន្តោសក្នុងចីវរ បានដល់ សន្តោសដោយចីវរ ២០ គឺ វិតក្កសន្តោស គឺសន្តោសក្នុងការត្រិះរិះ ១ គមនសន្តោស គឺសន្តោសក្នុងការទៅ ១ បរិយេសនសន្តោស គឺសន្តោសក្នុងការស្វែងរក ១ បដិលាភ-សន្តោស គឺសន្តោសក្នុងការបាន ១ មត្តបដិគ្គហណសន្តោស គឺសន្តោសក្នុងការទទួលល្មមប្រមាណ ១ លោលុប្បវិវជ្ជនសន្តោស គឺសន្តោសក្នុងការវៀរះឡោះ ១ យថាលាភសន្តោស គឺសន្តោសតាមមានតាមបាន ១ យថា-ពលសន្តោស គឺសន្តោសតាមកម្លាំង ១ យថាសារុប្បសន្តោស គឺសន្តោសតាមសមគួរ ១ ឧទកសន្តោស គឺសន្តោសដោយទឹក ១ ធោវនសន្តោស គឺសន្តោសក្នុងការបោកគក់ ១ ករណសន្តោស គឺសន្តោសក្នុងការធ្វើ ១ បរិ-មាណសន្តោស គឺសន្តោសក្នុងបរិមាណ ១ សុត្តសន្តោស គឺសន្តោសក្នុងសរសៃអំបោះ ១ សិព្វនសន្តោស គឺសន្តោសក្នុងការដេរ ១ រជនសន្តោស គឺសន្តោសក្នុងការជ្រលក់ ១ កប្បសន្តោស គឺសន្តោសក្នុងកប្ប ១ បរិភោគ-

សន្តោស គឺសន្តោសក្នុងការប្រើប្រាស់ ១ សន្និធិបរិវជ្ជនសន្តោស គឺសន្តោសក្នុងការវៀរចាកនូវការសន្សំ ១ វិវជ្ជនសន្តោស គឺសន្តោសក្នុងការលះបង់ ១ ។

ក្នុងសន្តោសទាំងនោះ ភិក្ខុដែលត្រេកអរក្នុងគហបតិចីវរ នៅចាំវស្សាអស់ ៣ ខែហើយ ត្រិះរិះត្រឹមតែមួយខែ រមែងគួរ ព្រោះថា ភិក្ខុនោះ កាលចេញវស្សាហើយ ធ្វើចីវរក្នុងខែដែលធ្វើចីវរ ភិក្ខុដែលកាន់យកសំពត់បង្សុកូលជាវត្ត រមែងធ្វើដោយកន្លះខែប៉ុណ្ណោះ ការត្រិះរិះត្រឹមកន្លះខែ និងមួយខែដោយប្រការដូច្នេះ ឈ្មោះថា **វិតក្កសន្តោស** ។

ភិក្ខុកាលទៅរកចីវរ មិនបានគិតថា អញនឹងបានចីវរក្នុងទីណា ហើយទៅដោយកាន់យកត្រឹមកម្មដ្ឋាន ដែលជាប្រធានប៉ុណ្ណោះ ឈ្មោះថា **គមនសន្តោស** ។ កាលភិក្ខុស្វែងរកចីវរ មិនបានស្វែងរកជាមួយបុគ្គលណាមួយកាន់យក ភិក្ខុអ្នកខ្មាស មានសីលជាទីស្រឡាញ់ហើយ ទើបស្វែងរក ឈ្មោះថា **បរិយេសនសន្តោស** ។

កាលភិក្ខុកំពុងស្វែងរកយ៉ាងនេះ ឃើញចីវរដែលគេនាំមកអំពីចម្ងាយ មិនបានត្រិះរិះយ៉ាងនេះថា ចីវរនេះនឹងជាទីពេញចិត្ត ចីវរនេះនឹងមិនជាទីពេញចិត្ត ដូច្នេះហើយ ត្រេកអរដោយចីវរតាមដែលបាន ក្នុងបណ្តាចីវរដែលមានសាច់គ្រោតគ្រាត និងសាច់ល្អិតជាដើម ឈ្មោះថា **បដិលាភសន្តោស** ។

កាលភិក្ខុកាន់យកចីវរដែលបានយ៉ាងនេះហើយ ត្រេកអរល្មមប្រមាណដល់ខ្លួនថា ចីវរប្រមាណប៉ុណ្ណេះនឹងជាពីរជាន់ ចីវរប្រមាណប៉ុណ្ណេះនឹងធ្វើ

មួយជាន់ ដូច្នេះ ឈ្មោះថា **មត្តុបដិគ្គហណសល្លេខ** ។

កាលភិក្ខុស្វែងរកចីវរ មិនបានគិតថា អាត្មាអញនឹងបានចីវរគាប់ចិត្ត ត្រង់ទ្វារផ្ទះរបស់បុគ្គលនោះ ហើយត្រាច់ទៅតាមលំដាប់ទ្វារផ្ទះ ឈ្មោះថា **លោលុប្បវិវជ្ជនសល្លេខ** ។

កាលភិក្ខុអាចញ៉ាំងខ្លួន ឲ្យប្រព្រឹត្តទៅបានដោយចីវរណាមួយ ក្នុងបណ្តាចីវរសាច់សៅហ្មង និងសាច់ល្អិត ក៏ញ៉ាំងអត្តភាពឲ្យប្រព្រឹត្តទៅដោយចីវរតាមដែលខ្លួនបានប៉ុណ្ណោះ ឈ្មោះថា **យថាលាភសល្លេខ** ។

ភិក្ខុដឹងនូវកម្លាំងរបស់ខ្លួនហើយ រស់នៅបានដោយចីវរដែលអាចញ៉ាំងខ្លួនឲ្យរស់នៅបាន ឈ្មោះថា **យថាពលសល្លេខ** ។

ភិក្ខុឲ្យចីវរដែលពេញចិត្តដល់ភិក្ខុរូបដទៃហើយ ញ៉ាំងខ្លួនឲ្យប្រព្រឹត្តទៅបានដោយចីវរមួយផ្សេង ឈ្មោះថា **យថាសារុប្បសល្លេខ** ។

ភិក្ខុមិនបានពិចារណាថា ទឹកត្រង់ណាគួរពេញចិត្ត ទឹកត្រង់ណាមិនគួរពេញចិត្ត ហើយបោកគក់ចីវរដោយទឹកដែលល្មមបោកគក់បានឯណានីមួយ ឈ្មោះថា **ឧទកសល្លេខ** ។ តែគួរវៀរទឹកដែលស្មោកគ្រោក ដោយដីពណ៌លឿង សម្បកឈើ លម្អិតដី ស្លឹកឈើស្អុយ ។

កាលភិក្ខុបោកចីវរ មិនយកដំបងជាដើមវាយ យកដៃញី ឈ្មោះថា **ធោវនសល្លេខ** ។

គួរបោកចីវរដែលកខ្វក់ ដោយទឹកដែលដាក់ស្លឹកឈើហើយស្ងោរ ។ កាលបោកយ៉ាងនេះហើយ កាលនឹងធ្វើកុំធ្វើសន្តោសឲ្យខូច ដោយគិតថា នេះ

សាច់គ្រោតគ្រាត នេះសាច់ម៉ដ្ឋ ហើយធ្វើដោយទំនងដែលគ្រប់គ្រាន់ ដល់សេចក្តីត្រូវការនោះឯង ឈ្មោះថា **ករុណាសន្ថោស** ។

ការធ្វើត្រឹមតែបិទបាំងមណ្ឌលទាំង ៣ ប៉ុណ្ណោះ ឈ្មោះថា **បរិមាណសន្ថោស** ។

ភិក្ខុមិនត្រាច់ទៅ ដោយគិតថា អញនឹងស្វែងរកអំបោះដែលគាប់ចិត្ត ដើម្បីដេរចីវរ ហើយកាន់យកអំបោះត្រង់ផ្លូវជាដើម ឬត្រង់ទេវស្ថាន ឬដែលគេនាំមកទុកត្រង់ជើង ហើយដេរចីវរ ឈ្មោះថា **សុត្តសន្ថោស** ។

ពេលធ្វើខ្នង់ចីវរ មិនគួរដេរ ៧ ដង ក្នុងទីសំពត់ប្រមាណ ១ ធ្នាប់ ។ កាលភិក្ខុធ្វើយ៉ាងនេះ ការបែកធ្លាយនៃវត្ត ក៏មិនមានដល់ភិក្ខុអ្នកមិនព្រមជាសម្មាញ់ ( ជួយដេរ ) ។ តែគួរចាក់ ៧ ដង ក្នុងទីសំពត់ប្រមាណ ៣ ធ្នាប់ កាលភិក្ខុធ្វើយ៉ាងនេះ ភិក្ខុដែលកំពុងដើរផ្លូវក៏ត្រូវជាសម្មាញ់ ( ជួយដេរ ) ។ ការបែកធ្លាយនៃវត្ត រមែងមានដល់ភិក្ខុដែលមិនព្រមជាសម្មាញ់នេះ ឈ្មោះថា **សិព្វនសន្ថោស** ។

ភិក្ខុដែលជ្រលក់ចីវរ មិនគួរស្វែងរកមក្លឿជាដើម គប្បីជ្រលក់ដោយរបស់ដែលបាន ក្នុងបណ្តាសម្បកឈើដែលមានពណ៌លឿងចាស់ជាដើម កាលមិនបាន គួរកាន់យកគ្រឿងជ្រលក់ ដែលពួកមនុស្សកាន់យកសម្បកឈើក្នុងព្រៃ ហើយចោល ឬកាកសំណល់ដែលពួកភិក្ខុស្ងោរ ហើយចោលជ្រលក់ នេះ ឈ្មោះថា **រជនសន្ថោស** ។

កាលភិក្ខុកាន់យកពណ៌ណាមួយ បណ្តាពណ៌ខៀវ ពណ៌ភក់ ពណ៌ខ្មៅ

ហើយចុចឲ្យប្រាកដដល់បុគ្គលដែលអង្គុយលើខ្នងដំរី ឈ្មោះថា **កប្ប-សន្តោស** ។

ការប្រើប្រាស់ត្រឹមតែបិទបាំងអវយវៈដែលញ៉ាំងហិរិឲ្យកម្រើក ឈ្មោះថា **បរិភោគសន្តោស** ។

កាលបានសំពត់ហើយ តែមិនទាន់បានអំបោះ ម្ជុល ឬអ្នកធ្វើ គួររក្សាទុក កាលបានមិនគួររក្សា ។ ធ្វើហើយ បើបំណងនឹងឲ្យដល់អន្តេវាសិកជាដើម អន្តេវាសិកជាដើមនោះមិននៅ គួររក្សាទុកទម្រាំត្រឡប់មក លុះអន្តេវាសិកជាដើមមកហើយ គួរឲ្យ កាលមិនអាចឲ្យបាន គួរអធិដ្ឋាន ។ កាលមានចីវរផ្ទាំងដទៃ គួរអធិដ្ឋានធ្វើជាកម្រាល ។ ព្រះមហាសិវត្ថេរពោលថា បើមិនអធិដ្ឋាន ជាអាបត្តិសន្និធិ គឺសន្សំ បើអធិដ្ឋានហើយមិនជាអាបត្តិ ។ នេះ ឈ្មោះថា **សន្និធិបរិវជ្ជនសន្តោស** ។

ការលះបង់ មិនគួរឲ្យព្រោះយល់មុខ គួរតាំងនៅក្នុងសារាណីយធម៌ហើយឲ្យ នេះ ឈ្មោះថា **វិសជ្ជនសន្តោស** ។

បំសុកូលិកង្គធុតង្គ និងតិចីវរិកង្គធុតង្គ ឈ្មោះថា ធុតង្គដែលទាក់ទងដោយចីវរ ។

ព្រះបច្ចេកសម្ពុទ្ធបំពេញមហាអរិយវង្ស គឺការសន្តោសដោយចីវរ រមែងរក្សាធុតង្គទាំង ២ នេះ កាលរក្សាយ៉ាងនេះ ឈ្មោះថា ជាអ្នកសន្តោសដោយអំណាចនៃមហាអរិយវង្ស គឺសន្តោសដោយចីវរ ។

បទថា **វណ្ណវាទី** សេចក្តីថា ភិក្ខុមួយរូបជាអ្នកសន្តោស តែមិនពោល

ដល់គុណរបស់សន្តោស មួយរូបមិនសន្តោស តែពោលដល់គុណនៃសន្តោស មួយរូបមិនសន្តោសផង មិនពោលដល់គុណនៃសន្តោសផង មួយរូបជាអ្នកសន្តោសផង ពោលដល់គុណនៃការសន្តោសផង ព្រះបច្ចេកពុទ្ធក៏យ៉ាងនោះ ដើម្បីសម្តែងដល់ព្រះបច្ចេកពុទ្ធនោះ ទើបលោកពោលថា **ឥតរីតរចីវរសន្តុដ្ឋិយា ច វណ្ណវាទី** ដូច្នេះ ។

បទថា **អនេសនំ** បានដល់ ស្វែងរកដែលមិនសមគួរ មានប្រការផ្សេងៗ មានធ្វើជាទូត ជាអ្នកបញ្ជូនសាសន៍ និងជាអ្នកបញ្ជូនដំណឹងជាដើម ។ បទថា **អប្បដិរូបំ** បានដល់ ដែលមិនសមគួរ ។ បទថា **អលទ្ធា ច** បានដល់ មិនបានហើយ ។ ព្រះបច្ចេកសម្ពុទ្ធកាលមិនបានចីវរ ក៏មិនតក់ស្លុតដូចភិក្ខុរូបខ្លះ គិតថា អញនឹងបានចីវរដូចម្តេចហ្ន៎ ទើបរួមជាមួយពួកភិក្ខុដែលមានបុណ្យ ធ្វើនូវការបោកបញ្ឆោត រមែងតក់ស្លុត ។ បទថា **លទ្ធា ច** បានដល់ បានហើយដោយធម៌ ដោយត្រឹមត្រូវ ។ បទថា **អគធិតោ** បានដល់ ប្រាសចាកសេចក្តីលោភ ។ បទថា **អមុច្ឆិតោ** បានដល់ មិនដល់នូវការស្រុបស្រាវដោយចំណង់យ៉ាងក្រៃលែង ។ បទថា **អនជ្ឈាបន្នោ** បានដល់ មិនត្រូវចំណង់គ្របសង្កត់ ។ បទថា **អាទីនវទស្សាវី** សេចក្តីថា ឃើញទោសក្នុងការស្វែងរកដែលមិនសមគួរ និងទោសក្នុងការបរិភោគវត្ថុ ដែលមិនបានអធិដ្ឋាន ។ បទថា **និស្សរណបញ្ញោ** សេចក្តីថា ដឹងនូវការរលាស់ចេញ ដែលត្រាស់ទុកថា ដើម្បីការពារនូវត្រជាក់ ។ បទថា **ឥតរីតរចីវរសន្តុដ្ឋិយា** បានដល់ ព្រោះការសន្តោសដោយចីវរណាមួយ ។ បទថា

**នេវត្តានុក្កំសេតិ** បានដល់ ព្រះបច្ចេកពុទ្ធនោះ មិនលើកខ្លួន ដូចភិក្ខុរបខ្លះក្នុងសាសនានេះ លើកខ្លួនថា អញជាបុគ្គលសមាទានបង្សុកូលចីវរជាវត្ត អញសមាទានបំសុកូលិកង្គធុតង្គ តាំងអំពីពេលឧបសម្បទានោះឯង អ្នកណាស្មើអញបាន ។ បទថា **ន បរំ វម្ភេតិ** សេចក្តីថា មិនសង្កត់សង្កិនភិក្ខុដទៃយ៉ាងនេះថា ភិក្ខុរបដទៃទាំងនេះ មិនជាអ្នកសមាទានបង្សុកូលចីវរជាវត្ត ឬថា ភិក្ខុទាំងនេះ មិនមានសូម្បីត្រឹមតែសំពត់បង្សុកូល ។ បទថា **យោ ហិ តត្ថ ឧក្ខោ** សេចក្តីថា ព្រះបច្ចេកពុទ្ធអង្គណា ជាអ្នកខ្មីឃ្មាតក្នុងចីវរសន្តោសនោះ ឬក្នុងភាពជាអ្នកពោលសរសើរសន្តោសជាដើម ។ បទថា **អនលសោ** សេចក្តីថា ប្រាសចាកការខ្ជិលច្រអូស ដោយធ្វើនូវសេចក្តីព្យាយាមជាប់ត ។ បទថា **សម្បជានោ បដិស្សតោ** បានដល់ ប្រកបដោយការដឹងខ្លួន និងមានសតិ ។ បទថា **អរិយវំសេ ឋិតោ** បានដល់ តាំងមាំនៅក្នុងវង្សរបស់ព្រះអរិយៈ ។

បទថា **ឥតរីតរេន បិណ្ឌបាតេន** បានដល់ ដោយបិណ្ឌបាតណាមួយ ។ ក្នុងបទនេះ គប្បីជ្រាបបិណ្ឌបាត ខេត្តរបស់បិណ្ឌបាត ការសន្តោសក្នុងបិណ្ឌបាត ធុតង្គដែលទាក់ទងនឹងបិណ្ឌបាត ។

ក្នុងបទទាំងនោះ បិណ្ឌបាត ១៦ ប្រភេទ ឈ្មោះថា បិណ្ឌបាត គឺបាយ ១ នំសណ្តែក ១ សជូវ ១ ត្រី ១ សាច់ ១ នំស្រស់ ១ ទធិ ១ សប្បិ ១ នវនីត ១ ប្រេង ១ ទឹកឃ្មុំ ១ ទឹកអំពៅ ១ យាគូ ១ របស់ទំពា ១ របស់ភ្លក្ស ១ របស់លិទ្ធ ១ ។

ក្នុងពាក្យថា ខេត្តរបស់បិណ្ឌបាត ខេត្តរបស់បិណ្ឌបាត មាន ១៥ ប្រភេទ គឺសង្ឃភត្ត ១ ឧទ្ទេសភត្ត ១ និមន្តនភត្ត ១ សលាកភត្ត ១ បក្ខិកភត្ត ១ ឧបោសថិកភត្ត ១ បាដិបទិកភត្ត ១ អាគន្តុកភត្ត ១ គមិកភត្ត ១ គិលានភត្ត ១ គិលានុបដ្ឋាកភត្ត ១ ធុរភត្ត ១ កុដិភត្ត ១ វារិកភត្ត ១ វិហារភត្ត ១ ។

ក្នុងពាក្យថា ការសន្តោសក្នុងបិណ្ឌបាត សេចក្តីថា សន្តោសក្នុងបិណ្ឌបាត មាន ១៥ យ៉ាង គឺវិតក្កសន្តោស ១ គមនសន្តោស ១ បរិយេសនសន្តោស ១ បដិលាភសន្តោស ១ បដិគ្គហនសន្តោស ១ មត្តបដិគហណសន្តោស ១ លោលុប្បវិវជ្ជនសន្តោស ១ យថាលាភសន្តោស ១ យថាពលសន្តោស ១ យថាសារុប្បសន្តោស ១ ឧបការសន្តោស ១ បរិមាណសន្តោស ១ បរិភោគសន្តោស ១ សន្និធិបរិវជ្ជនសន្តោស ១ វិសជ្ជនសន្តោស ១ ។

ក្នុងសន្តោសទាំងនោះ ភិក្ខុត្រេកអរ ( ក្នុងបិណ្ឌបាត ) លុបមុខហើយ ទើបត្រិះរិះ ភិក្ខុដែលបិណ្ឌបាតជាវត្ត ត្រាច់ទៅព្រមជាមួយនឹងគណៈ កាលដល់ពេលបម្រើព្រះថេរៈ ក្នុងវេលាល្ងាច គិតថា ស្អែកនេះ អញនឹងទៅបិណ្ឌបាតក្នុងទីណា មានអ្នកឆ្លើយថា ត្រង់ស្រុកនោះ តាំងអំពីពេលនោះ មិនគប្បីត្រិះរិះ ។ ភិក្ខុដែលត្រាច់ទៅមួយរូប គប្បីឈរត្រិះរិះក្នុងរោងសម្រាប់ត្រិះរិះ កាលត្រិះរិះបន្តអំពីនោះ ជាអ្នកឃ្លាតឆ្ងាយចាកវង្សរបស់ព្រះអរិយៈ នេះ ឈ្មោះថា **វិតក្កសន្តោស** ។

ភិក្ខុចូលទៅបិណ្ឌបាត មិនគប្បីគិតថា អញនឹងបានក្នុងទីណា គួរទៅដោយកាន់យកកម្មដ្ឋានជាគោល នេះ ឈ្មោះថា **គមនសន្តោស** ។

កាលស្វែងរកមិនគួរកាន់យកបុគ្គលដែលខ្ជិលខ្ជាះ គួរកាន់យកភិក្ខុដែលជាអ្នកខ្មាស ជាអ្នកមានសីលជាទីស្រឡាញ់ប៉ុណ្ណោះ ស្វែងរក នេះ ឈ្មោះថា **បរិយេសនសន្តោស** ។

ភិក្ខុឃើញមនុស្សនាំអាហារមកអំពីចម្ងាយ មិនគួរគិតថា អាហារនុ៎ះល្អ អាហារនុ៎ះមិនល្អ នេះ ឈ្មោះថា **បដិលាភសន្តោស** ។

ភិក្ខុមិនគួរគិតថា អញនឹងកាន់យករបស់ដែលគាប់ចិត្តនេះ នឹងមិនកាន់យករបស់ដែលមិនគាប់ចិត្តនេះ ហើយគប្បីកាន់យកយ៉ាងណាមួយ ត្រឹមតែឲ្យជីវិតប្រព្រឹត្តទៅប៉ុណ្ណោះ នេះ ឈ្មោះថា **បដិគ្គហណសន្តោស** ។

ម្យ៉ាងទៀត ក្នុងបដិគ្គហណនេះ ទេយ្យធម៌មានច្រើន បុគ្គលអ្នកឲ្យបំណងនឹងឲ្យតិច គប្បីទទួលយកតែបន្តិច ទេយ្យធម៌មានច្រើន អ្នកឲ្យក៏បំណងនឹងឲ្យច្រើន គួរកាន់យកល្មមប្រមាណប៉ុណ្ណោះ សូម្បីទេយ្យធម៌ មិនមានច្រើន អ្នកឲ្យក៏បំណងឲ្យតិចតួច គប្បីកាន់យកតែបន្តិចបន្តួច ។ បើទេយ្យធម៌តិច អ្នកឲ្យបំណងនឹងឲ្យច្រើន គួរកាន់យកល្មមប្រមាណ ។

ពិតហើយ ក្នុងការទទួល កាលមិនដឹងប្រមាណ រមែងទម្លាយនូវការជ្រះថ្លារបស់មុននោះ រមែងញុំាងសទ្ធាទេយ្យឲ្យធ្លាក់ចុះទៅ មិនធ្វើតាមពាក្យប្រៀនប្រដៅ មិនអាចរក្សាទឹកចិត្តរបស់មាតាបង្កើតបាន ។ កាលស្គាល់នូវប្រមាណដោយប្រការដូច្នេះហើយ ទើបគួរទទួល នេះ ឈ្មោះថា **មត្តបដិគ្គ-**

ហាណាសន្តោស ។

ភិក្ខុមិនគួរទៅកាន់ត្រកូលដែលស្គុកស្គម្ភប៉ុណ្ណោះ គួរទៅតាមលំដាប់ទ្វារផ្ទះ នេះ ឈ្មោះថា **លោលុប្បវិវជ្ជនសន្តោស** ។

យថាលាភសន្តោសជាដើម មានន័យដូចពោលហើយក្នុងចីវរនោះឯង។ ភិក្ខុដឹងឧបការៈយ៉ាងនេះថា អាត្មាអញឆាន់អាហារបិណ្ឌបាតហើយ នឹងរក្សាសមណធម៌ ហើយទើបឆាន់ ឈ្មោះថា **ឧបការសន្តោស** ។ សូម្បីអាហារពេញបាត្រហើយ នៅមានអ្នកនាំមក ក៏មិនគួរទទួល ។

កាលមានអនុបសម្បន្នទៅផង គួរឲ្យអនុបសម្បន្ននោះទទួល កាលមិនមាន គួរឲ្យនាំមកហើយ ទទួលយកត្រឹមល្មមទទួលបាន នេះ ឈ្មោះថា **បរិមាណសន្តោស** ។

ការឆាន់ដោយគិតយ៉ាងនេះថា ការឆាន់ជាគ្រឿងបន្ទោបង់នូវការស្រេកឃ្លាន មិនមែនជាគ្រឿងរលាស់ចេញចាកទុក្ខ ឈ្មោះថា **បរិភោគសន្តោស** ។

មិនគួរសន្សំទុកឆាន់ នេះ ឈ្មោះថា **សន្និធិបរិវជ្ជនសន្តោស** ។

មិនគួរយល់មុខ គួរតាំងនៅក្នុងសារាណិយធម៌ហើយឲ្យ នេះ ឈ្មោះថា **វិសជ្ជនសន្តោស** ។

ធុតង្គដែលទាក់ទងដោយបិណ្ឌបាត មាន ៥ យ៉ាង គឺបិណ្ឌបាតិកង្គ គឺត្រាច់បិណ្ឌបាតជាវត្ត ១ សបទានចារិកង្គ គឺត្រាច់បិណ្ឌបាត ទៅតាមលំដាប់ប្រកជាវត្ត ១ ឯកាសនិកង្គ គឺការអង្គុយឆាន់ក្នុងអាសនៈមួយជាវត្ត ១ បត្តបិណ្ឌិកង្គ គឺឆាន់ចំពោះក្នុងបាត្រជាវត្ត ១ ខលុបច្ឆាភត្តិកង្គ គឺហាមភត្ត

ដែលគេនាំមកប្រគេនខាងក្រោយជាវត្ត ១ ។

ព្រះបច្ចេកពុទ្ធ បំពេញមហាអរិយវង្ស គឺការសន្តោសដោយបិណ្ឌបាត ដោយប្រការដូច្នេះ ឈ្មោះថា រក្សាធុតង្គទាំង ៥ នេះ កាលរក្សាធុតង្គទាំងនេះ ឈ្មោះថា ជាអ្នកសន្តោសដោយអំណាចនៃមហាអរិយវង្ស គឺសន្តោសដោយបិណ្ឌបាត ។ បទថា **វណ្ណវាទី** ជាដើម គប្បីជ្រាបដោយន័យដែលពោលហើយនោះឯង ។

គប្បីជ្រាបក្នុងបទថា **សេនាសនេន** នេះ ដូចតទៅ គប្បីជ្រាបសេនាសនៈ គប្បីជ្រាបខេត្តរបស់សេនាសនៈ គប្បីជ្រាបការសន្តោសក្នុងសេនាសនៈ គប្បីជ្រាបធុតង្គដែលទាក់ទងដោយសេនាសនៈ ។

ក្នុងពាក្យទាំងនោះ ពាក្យថា សេនាសនៈ បានដល់ សេនាសនៈ ១៥ យ៉ាង គឺគ្រែ ១ តាំង ១ ពូក ១ ខ្នើយ ១ វិហារ ១ អឌ្ឍយោគ ១ ប្រាសាទ ១ ប្រាសាទត្រដិល ១ គុហា ១ ទីសម្ងំ ( លេណៈ ) ១ ប៉ម ១ ផ្ទះមានកំពូល ១ គុម្ពឫស្សី ១ គុម្ពឈើ ១ គល់ឈើ ១ ឬទីដែលភិក្ខុទាំងឡាយចូលទៅសម្រាក ។

ពាក្យថា ខេត្តរបស់សេនាសនៈ ខេត្តមាន ៦ យ៉ាង គឺសេនាសនៈអំពីសង្ឃ ១ អំពីគណៈ ១ អំពីញាតិ ១ អំពីមិត្រ ១ អំពីទ្រព្យរបស់ខ្លួន ១ ទីជាទីបង្សុកូល ១ ។

ពាក្យថា ការសន្តោសក្នុងសេនាសនៈ ការសន្តោសក្នុងសេនាសនៈមាន ១៥ យ៉ាង មានសន្តោសដោយការត្រិះរិះជាដើម ។ គប្បីជ្រាបសន្តោស

ទាំងនោះ ដោយន័យដូចពោលហើយក្នុងបិណ្ឌបាតនោះឯង ។

ពាក្យថា ធុតង្គដែលទាក់ទងជាមួយសេនាសនៈ ធុតង្គដែលទាក់ទងជាមួយសេនាសនៈ មាន ៥ យ៉ាង គឺអារញ្ញិកង្គ ១ រុក្ខមូលិកង្គ ១ អព្ភោកាសិកង្គ ១ សោសានិកង្គ ១ យថាសណ្ឋតិកង្គ ១ ។

ព្រះបច្ចេកពុទ្ធបំពេញមហាអរិយវង្ស គឺការសន្តោសក្នុងសេនាសនៈ ដោយប្រការដូច្នេះ ឈ្មោះថា រក្សាធុតង្គ ៥ កាលរក្សាធុតង្គយ៉ាងនេះ ឈ្មោះថា ជាអ្នកសន្តោសដោយអំណាចនៃមហាអរិយវង្ស គឺការសន្តោសក្នុងសេនាសនៈ ។

ព្រះធម្មសេនាបតីសារីបុត្រពោលអរិយវង្ស គឺការសន្តោសក្នុងចីវរជាប្រការទី ១ ដូចលោកអ្នកមានឫទ្ធិ ពង្រីកផែនដីឲ្យទូលាយ ដូចញ៉ាំងផ្ទៃមហាសមុទ្រឲ្យពេញ និងដូចញ៉ាំងអាកាសឲ្យផ្សាយចេញទៅដូច្នោះ ពោលអរិយវង្ស គឺការសន្តោសដោយបិណ្ឌបាតជាប្រការទី ២ ដូចបុគ្គលអ្នកមានឫទ្ធិធ្វើព្រះចន្ទឲ្យរះ និងធ្វើព្រះអាទិត្យឲ្យប្រាកដដូច្នោះ ពោលអរិយវង្ស គឺសេចក្តីសន្តោសក្នុងសេនាសនៈជាប្រការទី ៣ ដូចលើកភ្នំសិនេរុឡើងដូច្នោះ ឥឡូវនេះ ដើម្បីពោលដល់អរិយវង្ស គឺការសន្តោសក្នុងគិលានបច្ច័យ ទើបពោលពាក្យថា **សន្តុដ្ឋោ ហោតិ ឥតរីតរេន គិលានបច្ចយភេសជ្ជ-បរិក្ខារេន** ជាដើម បទនោះ ប្រព្រឹត្តទៅដូចគ្នានឹងបិណ្ឌបាតនោះឯង ។ ក្នុងបទនោះ គប្បីសន្តោសដោយយថាលាភសន្តោស ថាពលសន្តោស និងយថាសារុប្បសន្តោសដូចគ្នា ។ តែអរិយវង្ស គឺមានការនាំជាទីមកត្រេកអរ

មិនបានមកក្នុងនិទ្ទេសនេះ នេសជ្ជិកង្គធុតង្គ គឺការកាន់យកការអង្គុយជាវត្ត ចាត់ចូលក្នុងអរិយវង្ស គឺការមានភាវនាជាទីមកត្រេកអរ សមដូចលោកពោលថា

ក្នុងសេនាសនៈ លោកពោលធុតង្គទុក ៥ ធុតង្គដែលទាក់ទងដោយអាហារ មាន ៥ ទាក់ទងដោយសេចក្តីព្យាយាមមាន ១ ទាក់ទងដោយចីវរមាន ២ ។

គប្បីជ្រាបវិនិច្ឆ័យក្នុងបទនេះថា **ចោរាណោ អគ្គញ្ញោ អរិយវំសេ ឋិតោ** ដូចតទៅនេះ បទថា **ចោរាណោ** បានដល់ មិនមែនកើតឡើងឥឡូវនេះ ។ បទថា **អគ្គញ្ញោ** បានដល់ ដែលសន្មតថា ជាវង្សដ៏ប្រសើរ ។ បទថា **អរិយវំសេ** បានដល់ ក្នុងវង្សរបស់ព្រះអរិយៈទាំងឡាយ ។ ឧបមាដូចវង្សរបស់ក្សត្រ វង្សរបស់ព្រាហ្មណ៍ វង្សរបស់វេស្សៈ វង្សរបស់សូទ្រៈ វង្សរបស់សមណៈ វង្សត្រកូល រាជវង្ស យ៉ាងណា អរិយវង្សទី ៨ នេះក៏យ៉ាងនោះ ឈ្មោះថា ជាបវេណីរបស់ព្រះអរិយៈ ។ វង្សនេះ លោកពោលថា ប្រសើរជាងវង្សទាំងឡាយ ដូចក្លិនក្លាំពាក់ ប្រសើរជាងក្លិនឫសឈើទាំងឡាយជាដើម វង្សរបស់ព្រះអរិយៈទាំងឡាយពួកណាខ្លះ គឺព្រះពុទ្ធ ព្រះបច្ចេកពុទ្ធ និងសាវករបស់ព្រះតថាគត ហៅថា **អរិយ** ។ វង្សរបស់ព្រះអរិយៈទាំងឡាយនេះ ឈ្មោះថា **អរិយវង្ស** ។ ពិតហើយ មុនអំពីនេះ ព្រះពុទ្ធ ៤ អង្គ គឺព្រះតណ្ហង្ករ ព្រះមេធង្ករ ព្រះសរណង្ករ ព្រះទីបង្ករ ទ្រង់កើតក្នុងទីបំផុត ៤ អសង្ខេយ្យ និង ១ សែនកប្ប លោកទាំងនោះ

ក៏ជាអរិយៈ ។ វង្សរបស់ព្រះអរិយៈទាំងនោះ ក៏ឈ្មោះថា **អរិយវង្ស។**

ក្រោយអំពីព្រះពុទ្ធទាំងនោះ ទ្រង់បរិនិព្វានកន្លងទៅអស់មួយអសង្ខេយ្យ ព្រះពុទ្ធព្រះនាមកោណ្ឌញ្ញៈទ្រង់កើតឡើង ។បេ។ ក្នុងកប្បនេះ ព្រះពុទ្ធ ៤ អង្គ គឺព្រះកកុសន្ធៈ ព្រះកោនាគមនៈ ព្រះកស្សបៈ និងព្រះមានព្រះភាគ ព្រះនាមគោតមនៃយើងទ្រង់កើតឡើង ។ វង្សរបស់ព្រះអរិយៈទាំងនោះ ក៏ឈ្មោះថា អរិយវង្ស ។ ម្យ៉ាងទៀត វង្សរបស់ព្រះអរិយៈអស់ គឺព្រះពុទ្ធ ព្រះបច្ចេកពុទ្ធ និងសាវកពុទ្ធ ដែលមានក្នុងអតីត អនាគត ក្នុងបច្ចុប្បន្ន ក៏ឈ្មោះថា អរិយវង្ស ។ ក្នុងអរិយវង្សនោះ ។

បទថា **ឋិតោ** បានដល់ តាំងនៅហើយ ។ បទដ៏សេស គប្បីជ្រាបដោយន័យដែលពោលហើយនោះឯង ៗ៕

**អដ្ឋកថា គាថាទី ៨ ចប់**

# សុត្តន្តបិដក

[ ២៦១ ] ពួកបព្វជិតខ្លះ និងពួកគ្រហស្ថដែលនៅគ្រប់គ្រងផ្ទះខ្លះ គេសង្គ្រោះបានដោយកម្រ បុគ្គលជាអ្នកមិនខ្វល់ខ្វាយក្នុងពួកបុត្រនៃអ្នកដទៃទេ គប្បីប្រព្រឹត្តម្នាក់ឯង ដូចកុយរមាស ។

[ ២៦២ ] ពាក្យថា ពួកបព្វជិតខ្លះគេសង្គ្រោះបានដោយកម្រ អធិប្បាយថា ពួកបព្វជិតខ្លះ ក្នុងលោកនេះ កាលបើគេឲ្យនិស្ស័យក្តី ឲ្យឧទ្ទេសក្តី ឲ្យបរិបុច្ឆាក្តី ឲ្យចីវរក្តី ឲ្យបាត្រក្តី ឲ្យផ្តិលលោហៈក្តី ឲ្យធម្មក្រកក្តី ឲ្យតម្រងទឹកក្តី ឲ្យកូនសោក្តី ឲ្យស្បែកជើងក្តី ឲ្យវត្ថពន្ធចង្កេះក្តី តែងមិនស្តាប់ មិនផ្ទៀងត្រចៀក មិនតាំងចិត្តចង់ដឹង ជាអ្នកមិនព្រមស្តាប់ មិនធ្វើតាមពាក្យប្រព្រឹត្តប្រាស បែរមុខទៅកាន់ទីដទៃ ហេតុនោះ ( លោកពោលថា ) ពួកបព្វជិតខ្លះ គេសង្គ្រោះបានដោយកម្រ ។

[ ២៦៣ ] ពាក្យថា ពួកគ្រហស្ថដែលនៅផ្ទះខ្លះ គឺពួកគ្រហស្ថខ្លះ ក្នុងលោកនេះ កាលបើគេឲ្យដំរីក្តី ឲ្យរថក្តី ស្រែក្តី ចម្ការក្តី ប្រាក់ក្តី មាសក្តី ឲ្យស្រុកក្តី ក្រុងក្តី ខេត្តក្តី តែងមិនស្តាប់ មិនផ្ទៀងត្រចៀក មិនតាំងចិត្តចង់ដឹង ជាអ្នកមិនព្រមស្តាប់ មិនធ្វើតាមពាក្យ ប្រព្រឹត្តប្រាស បែរមុខទៅកាន់ទីដទៃ ហេតុនោះ ( លោកពោលថា ) ពួកគ្រហស្ថដែលគ្រប់គ្រងផ្ទះខ្លះ ។

[ ២៦៤ ] ពាក្យថា បុគ្គលមិនខ្វល់ខ្វាយក្នុងពួកបុត្តនៃអ្នកដទៃ គឺបុគ្គលទាំងអស់ លើកលែងតែខ្ញុំចេញ លោកពោលក្នុងអត្ថនោះ ។ ពាក្យថា បុគ្គលជាអ្នកមិនខ្វល់ខ្វាយក្នុងពួកបុត្តនៃអ្នកដទៃ បានសេចក្តីថា បុគ្គលជាអ្នកមិនខ្វល់ខ្វាយ ជាអ្នកមិនក្រវើន ជាអ្នកមិនអាឡោះអាល័យ ហេតុនោះ ( លោក

ពោលថា ) បុគ្គលជាអ្នកមិនខ្វល់ខ្វាយក្នុងពួកបុត្តនៃអ្នកដទៃ ។ គប្បីប្រព្រឹត្ត ម្នាក់ឯង ដូចកុយរមាស ។ ហេតុនោះ ព្រះបច្ចេកពុទ្ធនោះពោលថា

ពួកបព្វជិតខ្លះ និងពួកគ្រហស្ថដែលនៅគ្រប់គ្រងផ្ទះខ្លះ គេសង្គ្រោះ
បានដោយកម្រ បុគ្គលជាអ្នកមិនខ្វល់ខ្វាយក្នុងពួកបុត្រនៃអ្នកដទៃ
ទេ គប្បីប្រព្រឹត្តម្នាក់ឯង ដូចកុយរមាស ។

# អដ្ឋកថា

## គាថាទី ៩

ក្នុងគាថាទី ៩ គប្បីជ្រាបយោជនាដូចតទៅនេះ

[ ២៦១ ] បព្វជិតពួកខ្លះ ត្រូវការមិនសន្ដោសគ្រប់សង្កត់ ក៏ជាបុគ្គលដែលសង្គ្រោះបានលំបាក គ្រហស្ថទាំងឡាយ អ្នកគ្រប់គ្រងផ្ទះយ៉ាងនោះ ក៏ជាបុគ្គលដែលសង្គ្រោះបានលំបាក អាត្មារង្កៀសនូវភាពដែលបុគ្គលដទៃសង្គ្រោះបានដោយក្រនោះ ទើបប្រារព្ធវិបស្សនា ហើយសម្រេចបច្ចេក-ពោធិញ្ញាណ ។ បទដ៏សេស គប្បីជ្រាបដោយន័យមុននោះឯង ។

[ ២៦២ ] គប្បីជ្រាបវិនិច្ឆ័យក្នុងនិទ្ទេសដូចតទៅនេះ បទថា **អនស្សវា** បានដល់ ជាបុគ្គលមិនស្ដាប់នូវពាក្យ ។ បទថា **អវចនករា** បានដល់ ប្រដៅក្រ ។ បទថា **បដិលោមវុត្តិនោ** បានដល់ មានប្រក្រតីពោលពាក្យគ្រោតគ្រាត អធិប្បាយថា ប្រាថ្នានឹងតតាំងនោះឯង ។ បទថា **អញ្ញេនេវ មុខំ ករោន្តិ** សេចក្ដីថា ឃើញអ្នកឲ្យឱវាទហើយ បែរមុខទៅកាន់ទិសដទៃ ។

[ ២៦៤ ] បទថា **អព្យាវដោ ហុត្វា** បានដល់ គប្បីជាអ្នកមិនដាក់ចិត្ត ។ បទថា **អនបេក្ខោ ហុត្វា** បានដល់ ជាអ្នកមិនមិនអាល័យ ។

**អដ្ឋកថាគាថាទី ៩ ចប់**

# សុត្តន្តបិដក

[ ២៦៥ ] វីរបុរស លះបង់វត្ថុទាំងឡាយជាគ្រឿងប្រាកដរបស់គ្រហស្ថ កាត់ចំណងរបស់គ្រហស្ថទាំងឡាយ ដូចរលួសផ្អុនដែលជម្រុះស្លឹក គប្បីប្រព្រឹត្តម្នាក់ឯង ដូចកុយរមាស ។

[ ២៦៦ ] ពាក្យថា លះបង់វត្ថុទាំងឡាយជាគ្រឿងប្រាកដរបស់គ្រហស្ថ សេចក្តីថា សក់ ពុកមាត់ ពុកចង្កា កម្រងផ្កា គ្រឿងក្រអូប គ្រឿងលាប គ្រឿងអាភរណៈ គ្រឿងប្រដាប់ សំពត់ គ្រឿងដណ្តប់ ឈ្នួតក្បាល គ្រឿងដុសខាត់ ការគក់រឹតនួត ការផ្ងូត ការគក់ប្រឋាប់ កញ្ចក់ ប្រដាប់សម្រាប់បន្តក់កម្រងផ្កា និងគ្រឿងលាបស្រឡាប គ្រឿងលម្អិតសម្រាប់ប្រស់មុខ គ្រឿងសម្រាប់លុបលាងមុខ គ្រឿងចងដៃ គ្រឿងចងជុក ដំបង បំពង់ថ្នាំ ព្រះខ័នឆត្រ ស្បែកជើង ក្បាំងមុខ ស្នៀតសក់ ស៊ែ សំពត់សវែង និងខ្ទី លោកហៅថា វត្ថុជាគ្រឿងប្រាកដរបស់គ្រហស្ថ ។ ពាក្យថា លះបង់វត្ថុទាំងឡាយជាគ្រឿងប្រាកដរបស់គ្រហស្ថ គឺទម្លាក់ចោល ដាក់ចោល ជម្រុះចោល ហេតុនោះ ( លោកពោលថា ) លះបង់វត្ថុទាំងឡាយជាគ្រឿងប្រាកដ ។

[ ២៦៧ ] ពាក្យថា ដូចរលួសផ្អុនដែលជម្រុះស្លឹក សេចក្តីថា ស្លឹកទាំងឡាយរបស់រលួសផ្អុនដែលរបេះ ជាច់ ជ្រុះយ៉ាងណា វត្ថុទាំងឡាយជាគ្រឿងប្រាកដរបស់គ្រហស្ថ នៃព្រះបច្ចេកសម្ពុទ្ធនោះ ក៏ជាច់ជ្រុះយ៉ាងនោះដែរ ហេតុនោះ ( លោកពោលថា ) ដូចរលួសផ្អុនដែលជម្រុះស្លឹក ។

[ ២៦៨ ] ពាក្យថា វីរបុរសកាត់ចំណងរបស់គ្រហស្ថទាំងឡាយ អធិប្បាយថា ឈ្មោះថា វីរបុរស ព្រោះហេតុមានសេចក្តីព្យាយាម ។ ឈ្មោះ

ថាវី របុរស ព្រោះហេតុជាអ្នកអាច ។ ឈ្មោះថា វីរបុរស ព្រោះហេតុញ៉ាំង សេចក្តីព្យាយាមឲ្យកើត ។ ឈ្មោះថា វីរបុរស ព្រោះហេតុមានចិត្តអង់អាច ។ ឈ្មោះថា វីរបុរស ព្រោះហេតុជាអ្នកហ៊ាន ។ ឈ្មោះថា វីរបុរស ព្រោះហេតុជាអ្នកមោះមុត មិនខ្លាច មិនរន្ធត់ មិនស្រឡាំងកាំង មិនរត់ លះបង់សេចក្តីខ្លាច និងសេចក្តីញ័រចំប្រប់ហើយ ប្រាសចាកសេចក្តីព្រឺរោម ។

ព្រះខីណាស្រព វៀរចាកបាបទាំងពួងក្នុងលោកនេះឯង មានការ
ព្យាយាមជាលំនៅ កន្លងទុក្ខក្នុងនរក លោកមានព្យាយាម មាន
សេចក្តីប្រឹងប្រែង ជាអ្នកនឹងធឹង មានសភាពដូច្នោះ ទើបលោក
ហៅថា វីរបុរស ។

ពួកកូន ខ្ញុំស្រី និងខ្ញុំប្រុស ពពែ និងចៀម មាន់ និងជ្រូក ដំរី គោ សេះឈ្មោល សេះញី ស្រែចម្ការ ប្រាក់ មាស ស្រុក និគម រាជធានី ដែន ជនបទ បន្ទាយ ឃ្លាំង និងវត្ថុជាទីត្រេកត្រអាលណាមួយ លោកហៅថា ចំណងរបស់គ្រហស្ថ ។ ពាក្យថា វីរបុរសកាត់ចំណងរបស់គ្រហស្ថទាំងឡាយ បានសេចក្តីថា ព្រះបច្ចេកសម្ពុទ្ធនោះ ជាវីរបុរស កាត់ ក្រំបែល លះ បន្ទោបង់ ធ្វើឲ្យវិនាស នូវចំណងរបស់គ្រហស្ថទាំងឡាយ ធ្វើឲ្យដល់នូវកិរិយាលែងកើត ហេតុនោះ ( លោកពោលថា ) វីរបុរសកាត់ចំណង

របស់គ្រហស្ថទាំងឡាយ ។ គប្បីប្រព្រឹត្តម្នាក់ឯង ដូចកុយរមាស ។ ហេតុនោះ ព្រះបច្ចេកសម្ពុទ្ធនោះពោលថា

វីរបុរស លះបង់វត្ថុទាំងឡាយជាគ្រឿងប្រាកដរបស់គ្រហស្ថ កាត់ចំណងរបស់គ្រហស្ថទាំងឡាយ ដូចរលួសផ្អុង ដែលជម្រុះស្លឹក គប្បីប្រព្រឹត្តម្នាក់ឯង ដូចកុយរមាស ។

# អដ្ឋកថា

## គាថាទី ១០

គប្បីជ្រាបវិនិច្ឆ័យក្នុងគាថាទី ១០ ដូចតទៅ

[ ២៦៥ ] បទថា **ឱរោបយិត្វា** បានដល់ នាំចេញទៅហើយ ។ បទថា **គិហិព្យញ្ជនានិ** សេចក្តីថា គ្រឿងសម្គាល់នៃភាពជាគ្រហស្ថ មានសក់ ពុក មាត់ សំពត់ស គ្រឿងប្រដាប់ ផ្កា គ្រឿងប្រអប់ គ្រឿងលាប ស្រី បុត្រ ទាសី ទាសាជាដើម ព្រោះហេតុនោះ ទើបលោកពោលថា គ្រឿងប្រាកដ របស់គ្រហស្ថ ។ បទថា **សញ្ឆិន្នបត្តោ** បានដល់ មានស្លឹកជ្រុះចុះហើយ ។ បទថា **ឆេត្វាន** បានដល់ កាត់ហើយដោយមគ្គញាណ ។ បទថា **វីរោ** បាន ដល់ ប្រកបហើយដោយសេចក្តីព្យាយាមក្នុងមគ្គ ។ បទថា **គិហិពន្ធនានិ** បានដល់ គ្រឿងចង គឺកាម ព្រោះថា កាមជាគ្រឿងចងរបស់គ្រហស្ថ ។ គប្បីជ្រាបអត្ថនៃបទប្រមាណប៉ុណ្ណោះសិន ។

តទៅនេះ ជាពាក្យអធិប្បាយ ព្រះបច្ចេកពុទ្ធត្រិះរិះយ៉ាងនេះថា ធ្វើម្តេច ហ្ន៎ អាត្មាអញគប្បីដាក់នូវគ្រឿងសម្គាល់នៃគ្រហស្ថ ដូចជាដើមរលួសផ្អុំ ដែលដាច់ស្លឹកហើយដូច្នោះ ហើយទើបផ្តើមវិបស្សនា បានសម្រេច បច្ចេកភូមិ ។ បទដ៏សេសគប្បីជ្រាបដោយន័យមុននោះឯង ។

[ ២៦៧ ] គប្បីជ្រាបវិនិច្ឆ័យក្នុងនិទ្ទេសតទៅថា បទថា **សាកាស-ណញ្ញ**[១] បានដល់ អាសនៈដែលជាសារៈ ។ បទថា **ឆិន្ទានិ** បានដល់ ជ្រុះ ។ បទថា **សញ្ឆិន្ទានិ** បានដល់ ដាច់ស្ទីក ។ បទថា **បតិតានិ** បានដល់ ជ្រុះចាកទង ។ បទថា **បរិបតិតានិ** បានដល់ ធ្លាក់ចុះទៅលើផែនដី ។ល។

## អដ្ឋកថា គាថាទី ១០ ចប់

## បឋមវគ្គ ចប់

១- បិដកខ្មែរមិនប្រែបទនេះ ។

# សុត្តន្តបិដក

[ ២៦៩ ] បើបុគ្គលបានសម្លាញ់ មានប្រាជ្ញាចាស់ទុំ ជាអ្នកប្រព្រឹត្តត្រូវគ្នា មានការនៅប្រពៃ ជាអ្នកប្រាជ្ញ អាចគ្របសង្កត់អន្តរាយទាំងពួងបាន គប្បីមានស្មារតី មានចិត្តត្រេកអរ ប្រព្រឹត្តនៅជាមួយសម្លាញ់នោះចុះ ។

[ ២៧០ ] ពាក្យថា បើបុគ្គលបានសម្លាញ់ មានប្រាជ្ញាចាស់ទុំ គឺបើបុគ្គលគប្បីបាន គប្បីជួប គប្បីប្រទះ គប្បីពើបពះនូវសម្លាញ់មានប្រាជ្ញាចាស់ទុំ ជាបណ្ឌិត ជាបញ្ញវន្ត មានសេចក្តីចេះ មានសេចក្តីដឹង មានសេចក្តីយល់ច្បាស់ មានប្រាជ្ញាជាគ្រឿងទម្លាយកិលេស ហេតុនោះ ( លោកពោលថា ) បើបុគ្គលបានសម្លាញ់មានប្រាជ្ញា ។

[ ២៧១ ] អធិប្បាយពាក្យថា ជាអ្នកប្រព្រឹត្តត្រូវគ្នា មានការនៅប្រពៃ ជាអ្នកប្រាជ្ញ ត្រង់ពាក្យថា ជាអ្នកប្រព្រឹត្តត្រូវគ្នា គឺប្រព្រឹត្តក្នុងមុខការជាមួយគ្នា ។ ពាក្យថា មានការនៅប្រពៃ គឺមានការនៅដ៏ប្រពៃ ដោយបឋមជ្ឈានក៏បាន មានការនៅដ៏ប្រពៃ ដោយទុតិយជ្ឈានក៏បាន ដោយតតិយជ្ឈានក៏បាន ដោយចតុត្ថជ្ឈានក៏បាន មានការនៅដ៏ប្រពៃ ដោយចេតោវិមុត្តិ គឺមេត្តាក៏បាន មានការនៅដ៏ប្រពៃ ដោយចេតោវិមុត្តិ គឺករុណាក៏បាន មុទិតាក៏បាន ឧបេក្ខាក៏បាន មានការនៅដ៏ប្រពៃ ដោយអាកាសានញ្ចាយតនសមាបត្តិក៏បាន មានការនៅដ៏ប្រពៃ ដោយវិញ្ញាណញ្ចាយតនសមាបត្តិក៏បាន ដោយអាកិញ្ចញ្ញាយតន-សមាបត្តិក៏បាន ដោយនេវសញ្ញានាសញ្ញាយតនសមាបត្តិក៏បាន មានការនៅដ៏ប្រពៃ ដោយនិរោធសមាបត្តិក៏បាន មានការនៅដ៏ប្រពៃ ដោយផលសមាបត្តិ

ក៏បាន ។ ពាក្យថា ជាអ្នកប្រាជ្ញ គឺជាអ្នកមានប្រាជ្ញា ជាបណ្ឌិត ជាបញ្ញវន្ត មានសេចក្តីចេះ មានសេចក្តីដឹង មានសេចក្តីយល់ច្បាស់ មានប្រាជ្ញាជាគ្រឿងទម្លាយកិលេស ហេតុនោះ ( លោកពោលថា ) ជាអ្នកប្រព្រឹត្តត្រូវគ្នា មានការនៅប្រពៃ ជាអ្នកប្រាជ្ញ ។

[ ២៧២ ] អធិប្បាយពាក្យថា គ្របសង្កត់អន្តរាយទាំងពួង ត្រង់ពាក្យថា អន្តរាយ បានដល់ អន្តរាយ ២ គឺអន្តរាយប្រាកដ ១ អន្តរាយកំបាំង ១ ។បេ។ ទាំងនេះ ហៅថា អន្តរាយប្រាកដ ។បេ។ ទាំងនេះ ហៅថា អន្តរាយកំបាំង ។ ពាក្យថា គ្របសង្កត់អន្តរាយទាំងពួង បានសេចក្តីថា គ្រប គ្របសង្កត់ បង្រ្កប រួបរឹត នូវពួកអន្តរាយទាំងពួង ហេតុនោះ ( លោកពោលថា ) គ្របសង្កត់អន្តរាយទាំងពួង ។

[ ២៧៣ ] ពាក្យថា គប្បីមានស្មារតី មានចិត្តត្រេកអរប្រព្រឹត្តនៅជាមួយសម្លាញ់នោះចុះ អធិប្បាយថា ព្រះបច្ចេកសម្ពុទ្ធនោះ មានចិត្តត្រេកអរ មានចិត្តសប្បាយ មានចិត្តរីករាយ មានចិត្តស្រស់ស្រាយ មានចិត្តអណ្តែត មានចិត្តពព្រាយ គប្បីត្រាច់ទៅ គប្បីត្រាច់ទៅផ្សេងៗ ទៅ ប្រព្រឹត្ត រក្សា យាត្រា ឲ្យយាត្រាទៅ ជាមួយនឹងសម្លាញ់ជាអ្នកមានប្រាជ្ញាចាស់ទុំ ជាបណ្ឌិត ជាបញ្ញវន្ត មានសេចក្តីចេះ មានសេចក្តីដឹង មានសេចក្តីយល់ច្បាស់ មានប្រាជ្ញាជាគ្រឿងទម្លាយកិលេសនោះ ហេតុនោះ ( លោកពោលថា ) គប្បីមានចិត្តត្រេកអរ ប្រព្រឹត្តនៅជាមួយសម្លាញ់នោះចុះ ។ ពាក្យថា មានស្មារតី គឺព្រះបច្ចេកសម្ពុទ្ធនោះ ជាបុគ្គលមានស្មារតី ប្រកបដោយស្មារតី និងប្រាជ្ញា

ដ៏ក្រៃលែង រឭក រឭកឃើញនូវអំពើដែលលោកធ្វើយូរមកហើយផង នូវពាក្យដែលលោកពោលយូរមកហើយផង ហេតុដូច្នោះ ( លោកពោលថា ) គប្បីមានស្មារតី មានចិត្តត្រេកអរ ប្រព្រឹត្តនៅជាមួយសម្លាញ់នោះចុះ ។ ហេតុនោះ ព្រះបច្ចេកសម្ពុទ្ធនោះពោលថា

បើបុគ្គលបានសម្លាញ់មានប្រាជ្ញាចាស់ទុំ ជាអ្នកប្រព្រឹត្តត្រូវគ្នា មានការនៅប្រពៃ ជាអ្នកប្រាជ្ញ អាចគ្របសង្កត់អន្តរាយទាំងពួងបាន គប្បីមានស្មារតី មានចិត្តត្រេកអរ ប្រព្រឹត្តនៅជាមួយសម្លាញ់នោះចុះ ។

[ ២៧៤ ] បើបុគ្គលរកមិនបានសម្លាញ់មានប្រាជ្ញាចាស់ទុំ ជាអ្នកប្រព្រឹត្តត្រូវគ្នា មានការនៅប្រពៃ ជាអ្នកប្រាជ្ញទេ គប្បីប្រព្រឹត្តម្នាក់ឯង ដូចព្រះរាជាលះបង់ដែនដែលទ្រង់ឈ្នះហើយ ឬដូចកុយរមាស ។

[ ២៧៥ ] ពាក្យថា បើបុគ្គលរកមិនបានសម្លាញ់ មានប្រាជ្ញាចាស់ទុំ គឺបើបុគ្គលរកមិនបាន មិនជួប មិនប្រទះ មិនពើបពះនូវសម្លាញ់ដែលមានប្រាជ្ញាចាស់ទុំ ជាបណ្ឌិត ជាបញ្ញវន្ត មានសេចក្តីចេះ មានសេចក្តីដឹង មានសេចក្តីយល់ច្បាស់ មានប្រាជ្ញាជាគ្រឿងទម្លាយកិលេស ហេតុនោះ ( លោកពោលថា ) បើបុគ្គលរកមិនបានសម្លាញ់មានប្រាជ្ញាចាស់ទុំ ។

[ ២៧៦ ] អធិប្បាយពាក្យថា ជាអ្នកប្រព្រឹត្តត្រូវគ្នា មានការនៅប្រពៃ ជាអ្នកប្រាជ្ញ ត្រង់ពាក្យថា ជាអ្នកប្រព្រឹត្តត្រូវគ្នា គឺជាអ្នកប្រព្រឹត្តក្នុងមុខការ

ជាមួយគ្នា ។ ពាក្យថា មានការនៅប្រពៃ គឺមានការនៅប្រពៃដោយបឋមជ្ឈាន ក៏បាន ។បេ។ មានការនៅប្រពៃដោយនិរោធសមាបត្តិក៏បាន មានការនៅប្រពៃ ដោយផលសមាបត្តិក៏បាន ។ ពាក្យថា ជាអ្នកប្រាជ្ញ គឺជាអ្នកមានប្រាជ្ញា ជា បណ្ឌិត ជាបញ្ញវន្ត មានសេចក្តីចេះ មានសេចក្តីដឹង មានសេចក្តីយល់ច្បាស់ មានប្រាជ្ញាជាគ្រឿងទម្លាយកិលេស ហេតុនោះ ( លោកពោលថា ) ជាអ្នក ប្រព្រឹត្តត្រូវគ្នា មានការនៅប្រពៃ ជាអ្នកប្រាជ្ញ ។

[ ២៧៧ ] ពាក្យថា ដូចព្រះរាជាលះបង់ដែនដែលទ្រង់ឈ្នះហើយ អធិប្បាយថា ព្រះរាជា ជាក្សត្រិយ៍ដែលបានមុទ្ធាភិសេក បានឈ្នះសង្គ្រាម បានកម្ចាត់បច្ចាមិត្ត បានសម្រេចតាមព្រះបំណងហើយ មានឃ្លាំងបរិបូណ៌ ទ្រង់លះបង់ដែនផង ជនបទផង ឃ្លាំងដាក់ប្រាក់ និងមាសច្រើនផង នគរផង ហើយកោរព្រះកេស និងព្រះមស្សុ ទ្រង់កាសាយពស្ត្រ ចេញចាកដំណាក់ ហើយទ្រង់ព្រះផ្នួស ដល់នូវភាពមិនមានកង្វល់ ត្រាច់ ត្រាច់ទៅផ្សេងៗ ទៅ ប្រព្រឹត្ត រក្សា យាត្រា ឲ្យយាត្រាទៅមួយអន្លើង ( យ៉ាងណា ) ឯព្រះបច្ចេក- សម្ពុទ្ធ កាត់កង្វល់ក្នុងឃរាវាសទាំងអស់ កាត់សេចក្តីកង្វល់ក្នុងកូន និងប្រពន្ធ កាត់សេចក្តីកង្វល់ក្នុងញាតិ កាត់សេចក្តីកង្វល់ក្នុងមិត្ត និងអាមាត្យ កោរសក់ ពុកមាត់ ពុកចង្កា ស្លៀកដណ្តប់កាសាយពស្ត្រ ចេញចាកគេហដ្ឋាន ហើយ ដល់នូវភាពមិនមានកង្វល់ ត្រាច់ ត្រាច់ទៅផ្សេងៗ ទៅ ប្រព្រឹត្ត រក្សា យាត្រា

ឲ្យយាត្រាទៅតែម្នាក់ឯង ក៏យ៉ាងនោះ ហេតុនោះ ( លោកពោលថា ) ដូច ព្រះរាជាលះបង់ដែនដែលទ្រង់ឈ្នះហើយ ។ គប្បីប្រព្រឹត្តម្នាក់ឯង ដូចកុយ រមាស ។ ហេតុនោះ ព្រះបច្ចេកសម្ពុទ្ធនោះពោលថា

បើបុគ្គលរកមិនបានសម្លាញ់មានប្រាជ្ញាចាស់ទុំ ជាអ្នកប្រព្រឹត្តត្រូវ
គ្នា មានការនៅប្រពៃ ជាអ្នកប្រាជ្ញទេ គប្បីប្រព្រឹត្តម្នាក់ឯង ដូច
ព្រះរាជាលះបង់ដែនដែលទ្រង់ឈ្នះហើយ ឬដូចកុយរមាស ។

# អដ្ឋកថា

## ទុតិយវគ្គ

### គាថាទី ១ ទី ២

គប្បីជ្រាបវិនិច្ឆ័យក្នុងគាថាទី ១ ទី ២ នៃទុតិយវគ្គដូចតទៅ

[ ២៦៩-២៧៤ ] បទថា **និបកំ** បានដល់ បណ្ឌិតដែលមានបញ្ញាតាមប្រក្រតី ជាអ្នកឈ្លាសក្នុងបរិកម្ម មានកសិណបរិកម្មជាដើម ។ បទថា **សាធុវិហារិ** បានដល់ ប្រកបដោយធម៌ជាគ្រឿងនៅ គឺអប្បនា ឬឧបចារៈ ។ បទថា **ធីរំ** បានដល់ ដល់ព្រមដោយបញ្ញា ។ ក្នុងបទនោះ លោកពោលការដល់ព្រមដោយបញ្ញា ដោយអត្ថថា មានបញ្ញាជាគ្រឿងរក្សាខ្លួន តែក្នុងទីនេះ មានអធិប្បាយថា ជាអ្នកដល់ព្រមដោយបញ្ញា ( ធិតិ ) ។ ភាពជាអ្នកមានសេចក្តីព្យាយាមមិនធូរថយ ឈ្មោះថា **ធិតិ** បទនេះ ជាឈ្មោះនៃសេចក្តីព្យាយាម ដែលប្រព្រឹត្តទៅយ៉ាងនេះថា **កាមំ តចោ ច ន្ហារុ ច**[១] ដូច្នេះជាដើម ។ម្យ៉ាងទៀត ឈ្មោះថា **ធីរំ** ព្រោះជាអ្នកខ្ពើមបាបដូច្នេះក៏មាន ។ បទថា **រាជាវ រដ្ឋំ វិជិតំ បហាយ** សេចក្តីថា ដូចព្រះរាជាដែលជាសត្រូវទ្រង់ដឹងថា ដែនដែលទ្រង់ឈ្នះនឹងនាំសេចក្តីវិនាសមកឲ្យ ក៏ទ្រង់លះបង់នូវដែននោះ ។ បទថា **ឯកោ ចរេ** បានដល់ លះនូវសម្លាញ់ដែលជាបុគ្គលពាលយ៉ាងនេះហើយ គប្បីត្រាច់ទៅតែម្នាក់ឯង ។ ម្យ៉ាងទៀត បទថា **រាជាវ**

---

១- បិដកលេខ ៤០ ឃ្នាប ២៥១ ។

**វដ្ដំ** មានអធិប្បាយថា គប្បីត្រាច់ទៅតែម្នាក់ឯង ដូចព្រះបាទសុតសោម ទ្រង់លះនូវដែនដែលទ្រង់ឈ្នះហើយ ទៅមួយអង្គឯង និងដូចព្រះមហាជនក យាងទៅមួយព្រះអង្គឯង ដូច្នោះ ។ បទដ៏សេស អាចដឹងបានដោយទំនង ដែលពោលហើយ ព្រោះហេតុនោះ ទើបមិនពោលឲ្យពិស្តារ ។ មិនមានអ្វី ដែលគប្បីពោលក្នុងនិទ្ទេស ៕

## អដ្ឋកថា គាថាទី ១-២ ចប់

# សុត្តន្តបិដក

[ ២៧៨ ] តាមពិត យើងសរសើរនូវការបរិបូណ៌ដោយសម្មាញ់ហើយ តែបុគ្គលគួរគប់រកសម្មាញ់ មានគុណប្រសើរជាងខ្លួន និងសម្មាញ់មានគុណស្មើនឹងខ្លួន បើរកមិនបានសម្មាញ់ទាំងនុ៎ះទេ គប្បីជាអ្នកបរិភោគ ភោជនមិនមានទោស ហើយប្រព្រឹត្តម្នាក់ឯងដូចកុយរមាស ។

[ ២៧៩ ] អធិប្បាយពាក្យថា តាមពិត យើងសរសើរនូវការបរិបូណ៌ដោយសម្មាញ់ហើយ ត្រង់ពាក្យថា តាមពិត គឺពាក្យពោលដោយចំណែកមួយ ជាពាក្យពោលដោយឥតមានសង្ស័យ ជាពាក្យពោលដោយឥតងឿងឆ្ងល់ ជាពាក្យមិនបែកជាពីរ ជាពាក្យមិនព្រែកជាពីរ ជាពាក្យប្រកបអស់ជើង ជាពាក្យមិនខុស ពាក្យថា តាមពិតនុ៎ះ ជាពាក្យកំណត់ ។ ពាក្យថា ការបរិបូណ៌ដោយសម្មាញ់ សេចក្តីថា ដែលហៅថា ការបរិបូណ៌ដោយសម្មាញ់ប្រកបដោយអសេក្ខសីលក្ខន្ធ ប្រកបដោយអសេក្ខសមាធិក្ខន្ធ ដោយអសេក្ខប្បញ្ញាខន្ធ ដោយអសេក្ខវិមុត្តិក្ខន្ធ ដោយអសេក្ខវិមុត្តិញាណទស្សនក្ខន្ធ ។ ពាក្យថា តាមពិត យើងសរសើរនូវការបរិបូណ៌ដោយសម្មាញ់ហើយ គឺយើងសរសើរ ស្ញើចកោត ថ្លែងគុណនូវការបរិបូណ៌ដោយសម្មាញ់ ហេតុនោះ ( លោកពោលថា ) តាមពិត យើងសរសើរនូវការបរិបូណ៌ដោយសម្មាញ់ហើយ ។

[ ២៨០ ] ពាក្យថា គួរគប់រកសម្មាញ់មានគុណប្រសើរជាងខ្លួន និងសម្មាញ់មានគុណស្មើនឹងខ្លួន អធិប្បាយថា សម្មាញ់ជាបុគ្គលប្រសើរជាងដោយសីល សមាធិ បញ្ញា វិមុត្តិ វិមុត្តិញាណទស្សនៈ សម្មាញ់ជាបុគ្គល

ស្មើដោយសីល សមាធិ បញ្ញា វិមុត្តិ វិមុត្តិញាណទស្សនៈ បុគ្គលត្រូវសេព គប់ ត្រូវគប់រក ត្រូវចូលទៅអង្គុយជិត ត្រូវសាកសួរ ត្រូវជេញដោលនូវសម្លាញ់មានគុណប្រសើរជាងខ្លួន ឬសម្លាញ់មានគុណស្មើនឹងខ្លួន ហេតុនោះ ( លោកពោលថា ) បុគ្គលគួរគប់រកសម្លាញ់មានគុណប្រសើរជាងខ្លួន និងសម្លាញ់មានគុណស្មើនឹងខ្លួន ។

[ ២៨១ ] ពាក្យថា បើរកមិនបានសម្លាញ់ទាំងនុ៎ះទេ គប្បីជាអ្នកបរិភោគភោជនមិនមានទោស អធិប្បាយថា បុគ្គលបរិភោគភោជនប្រកបដោយទោសក៏មាន បុគ្គលបរិភោគភោជនមិនមានទោសក៏មាន ។

ចុះបុគ្គលបរិភោគភោជនប្រកបដោយទោស តើដូចម្តេច ។ បុគ្គលខ្លះក្នុងលោកនេះ បាន ជួប ប្រទះ ពើបពះ ប្រសព្វដោយអធម៌មិនរាបទាបហើយចិញ្ចឹមជីវិត គឺកិរិយាបំភាន់ កិរិយារួសរាំវ កិរិយាបញ្ចិតបញ្ចៀង កលល្បិច កិរិយាស្វែងលាភដោយលាភ ដោយការឲ្យឈើ ឲ្យឫស្សី ឲ្យស្លឹកឈើ ឲ្យផ្កាឈើ ឲ្យគ្រឿងសម្រាប់ងូត ឲ្យលម្អិត ឲ្យដីស្អិត ឲ្យឈើស្ទន់ ឲ្យទឹកសម្រាប់លុបមុខ ដោយការបន្ទាបខ្លួនចំពោះត្រកូល ដោយសម្តីដូចជាសម្ល សណ្តែកបាយ ដោយការបី-ពបញ្ចិះសេះកូនត្រកូល ដោយការស៊ីសាច់ខ្នងគេ ដោយវត្ថុវិជ្ជា តិរច្ឆានវិជ្ជា អង្គវិជ្ជា នក្ខត្តវិជ្ជា ដោយធ្វើទូតេយ្យកម្ម ហើយទៅដោយការទៅកាន់ទីដែលគេប្រើទៅ ដោយការបម្រើគេដោយស្មង ដោយវេជ្ជកម្ម ទូតកម្ម ដោយដុំបាយតបដុំបាយ ដោយការឲ្យវត្ថុដែលគេឲ្យដល់ខ្លួនវិញ នេះ លោកហៅថា បុគ្គលបរិភោគភោជនប្រកបដោយទោស ។

ចុះបុគ្គលបរិភោគភោជនមិនមានទោស តើដូចម្តេច ។ បុគ្គលខ្លះ ក្នុងលោកនេះ បាន ជួប ប្រទះ ពើបពះ ប្រសព្វដោយធម៌ដ៏រាបទាប ហើយចិញ្ចឹមជីវិត គឺមិនមែនដោយការបំភាន់ មិនមែនដោយការរួសរាក់ មិនមែនដោយការបញ្ចិតបញ្ចៀង មិនមែនដោយកលល្បិច មិនមែនដោយការស្វែងលាភដោយលាភ មិនមែនដោយការឲ្យឈើ មិនមែនដោយការឲ្យឫស្សី មិនមែនដោយការឲ្យស្លឹកឈើ មិនមែនដោយការឲ្យផ្កាឈើ មិនមែនដោយការឲ្យគ្រឿងសម្រាប់ងូត មិនមែនដោយការឲ្យលម្អិត មិនមែនដោយការឲ្យដីស្អិត មិនមែនដោយការឲ្យឈើស្ទន់ មិនមែនដោយការឲ្យទឹកសម្រាប់លុបមុខ មិនមែនដោយការបន្ទន់បន្ទាបខ្លួនចំពោះត្រកូល មិនមែនដោយសម្តី ដូចជាសម្លសណ្តែកបាយ មិនមែនដោយការបី ព បញ្ចុះសេះកូនត្រកូល មិនមែនដោយការស៊ីសាច់ខ្នងគេ មិនមែនដោយវត្ថុវិជ្ជា មិនមែនដោយតិរច្ឆានវិជ្ជា មិនមែនដោយអង្គវិជ្ជា មិនមែនដោយនក្ខត្តវិជ្ជា មិនមែនដោយទូតេយ្យកម្ម ហើយទៅមិនមែនដោយកិរិយាទៅកាន់ទី ដែលគេបញ្ជូនទៅ មិនមែនដោយការបម្រើគេដោយស្មង មិនមែនដោយវេជ្ជកម្ម មិនមែនដោយទូតកម្ម មិនមែនដោយដុំបាយតបដុំបាយ មិនមែនដោយការឲ្យនូវវត្ថុដែលគេឲ្យដល់ខ្លួនវិញ នេះលោកហៅថា បុគ្គលបរិភោគភោជនមិនមានទោស ។

ពាក្យថា បើរកមិនបានសម្ងាញ់ទាំងនុ៎ះទេ គប្បីជាអ្នកបរិភោគភោជនមិនមានទោស គឺមិនបាន មិនជួប មិនប្រទះ មិនពើបពះ មិនប្រសព្វនូវសម្ងាញ់នុ៎ះ ហេតុនោះ ( លោកពោលថា ) បើរកមិនបានសម្ងាញ់ទាំងនុ៎ះទេ គប្បីជា

អ្នកបរិភោគភោជន មិនមានទោស ។ គប្បីប្រព្រឹត្តម្នាក់ឯង ដូចកុយរមាស ។ ហេតុនោះ ព្រះបច្ចេកសម្ពុទ្ធនោះពោលថា

តាមពិត យើងសរសើរនូវការបរិបូណ៌ដោយសម្លាញ់ហើយ តែបុគ្គលគួរគប់រកសម្លាញ់មានគុណប្រសើរជាងខ្លួន និងសម្លាញ់មានគុណស្មើនឹងខ្លួន បើរកមិនបានសម្លាញ់ទាំងនុ៎ះទេ គប្បីជាអ្នកបរិភោគភោជន មិនមានទោស ហើយប្រព្រឹត្តម្នាក់ឯង ដូចកុយរមាស ។

# អដ្ឋកថា

## គាថាទី ៣

[ ២៧៨ ] គាថាទី ៣ មានអត្ថងាយយល់ហើយ ឯសម្លាញ់ដែលដល់ព្រមដោយសីលក្ខន្ធជាដើម ដែលជាអសេក្ខៈ គប្បីជ្រាបថា សម្លាញ់ដែលជាអ្នកដល់ព្រមដោយសីលក្ខន្ធជាដើម ក្នុងបទថា **សហាយសម្បទំ** នេះ ត្រឹមតែប៉ុណ្ណេះ ។ តែក្នុងបទនេះ យោជនាលម្អិតថា អាត្មាសរសើរសម្លាញ់ដែលដល់ព្រមដោយធម៌ ដែលពោលហើយពិតប្រាកដ ។ មានពាក្យអធិប្បាយថា អាត្មាសរសើរដោយចំណែកមួយប៉ុណ្ណោះ ។ សរសើរដូចម្តេច ( សរសើរថា ) បុគ្គលគួរគប់រកសម្លាញ់មានគុណប្រសើរជាងខ្លួន និងសម្លាញ់មានគុណស្មើនឹងខ្លួន ព្រោះហេតុអ្វី ព្រោះកាលគប់រកបុគ្គលប្រសើរជាងខ្លួនដោយសីលជាដើម ធម៌ មានសីលជាដើម ដែលមិនទាន់កើតរមែងកើត ដែលកើតហើយ រមែងដល់នូវសេចក្តីចម្រើន ដុះដាលបរិបូណ៌ ។ កាលគប់រកបុគ្គលស្មើគ្នា ធម៌ទាំងឡាយ ដែលបានដោយការទ្រទ្រង់ស្មើគ្នានិងគ្នា ដោយការបន្ទោបង់នូវការខ្វល់ខ្វាយហើយ រមែងមិនវិនាស ។ កុលបុត្តអ្នករក្សាខ្លួន កាលមិនបានសម្លាញ់ដែលប្រសើរជាង ឬស្មើគ្នា គួរវៀរមិច្ឆាជីវៈ មានការបោកបញ្ឆោតជាដើម ហើយបរិភោគភោជនដែលកើត

ដោយធម៌ដោយត្រឹមត្រូវ និងមិនញុំាងនូវការបង្អៀតបង្អល់ និងការត្រេកអរឲ្យកើតឡើងក្នុងភោជននោះ ជាអ្នកបរិភោគបច្ច័យដែលមិនមានទោស គប្បីត្រាច់ទៅម្នាក់ឯង ដូចកុយរមាស ដូច្នោះ ។ ពិតហើយ សូម្បីអាត្មាកាលត្រាច់ទៅយ៉ាងនេះ ក៏សម្រេចដល់សម្បត្តិនេះ ដោយប្រការដូច្នេះ ។ ក្នុងនិទ្ទេសមានន័យដូចពោលហើយនោះឯង ។l៚

## អដ្ឋកថា គាថាទី ៣ ចប់

# សុត្តន្តបិដក

[ ២៨២ ] បុគ្គលឃើញកងមាសទាំងពីរ ដ៏ភ្លឺផ្លេកៗ ដែលកម្មារបុត្តធ្វើសម្រេចល្អហើយ ទង្គិចគ្នាឰដ៏ដៃ គប្បីប្រព្រឹត្តម្នាក់ឯង ដូចកុយរមាស ។

[ ២៨៣ ] ពាក្យថា ឃើញកងមាសដ៏ភ្លឺផ្លេកៗ គឺឃើញ មើល ស្ទង់ត្រួត បញ្ជាក់ ធ្វើឲ្យច្បាស់ ។ ពាក្យថា មាស គឺជាតរូប ។ ពាក្យថា ភ្លឺផ្លេកៗ គឺស្អាត ផូរផង់ ហេតុនោះ ( លោកពោលថា ) ឃើញកងមាសដ៏ភ្លឺផ្លេកៗ ។

[ ២៨៤ ] ពាក្យថា ដែលកម្មារបុត្តធ្វើសម្រេចល្អហើយ សេចក្តីថា ជាងមាស លោកហៅថា កម្មារបុត្ត ។ ពាក្យថា ដែលកម្មារបុត្តធ្វើសម្រេចល្អហើយ បានសេចក្តីថា ដែលកម្មារបុត្តឲ្យសម្រេចល្អហើយ ធ្វើល្អហើយ មានការសម្រិតសម្រាំងល្អហើយ ហេតុនោះ ( លោកពោលថា ) ដែលកម្មារបុត្តធ្វើសម្រេចល្អហើយ ។

[ ២៨៥ ] ពាក្យថា កងមាសទាំងពីរដែលទង្គិចគ្នាឰដ៏ដៃ អធិប្បាយថា ហត្ថ លោកហៅថា ដៃ ។ កងមាសទាំងពីរឰដ៏ដៃមួយ ទង្គិចគ្នាយ៉ាងណា ពួកសត្វតែងទង្គិចដោយអំណាចតណ្ហា គឺទង្គិចក្នុងកំណើតតិរច្ឆាន ទង្គិចក្នុងបិត្តិវិស័យ ទង្គិចក្នុងមនុស្សលោក ទង្គិចក្នុងទេវលោក គឺថា ទង្គិច ត្រាច់ នៅ ទៅ ប្រព្រឹត្ត រក្សា យាត្រា ឲ្យយាត្រាទៅកាន់គតិដោយគតិ កាន់ឧបបត្តិ

ដោយឧបបត្តិ កាន់បដិសន្ធិដោយបដិសន្ធិ កាន់ភពដោយភព កាន់សង្សារដោយសង្សារ កាន់វដ្តៈដោយវដ្តៈ ហេតុនោះ ( លោកពោលថា ) កងមាសទាំងពីរដែលទង្គិចគ្នាដ៏ដៃ ។ គប្បីប្រព្រឹត្តម្នាក់ឯង ដូចកុយរមាស ។ ហេតុនោះ ព្រះបច្ចេកសម្ពុទ្ធនោះពោលថា

បុគ្គលឃើញកងមាសទាំងពីរដ៏ភ្លឺផ្លេកៗ ដែលកម្មារបុត្តធ្វើសម្រេចល្អហើយ ទង្គិចគ្នាព្ធដ៏ដៃ គប្បីប្រព្រឹត្តម្នាក់ឯង ដូចកុយរមាស ។

# អដ្ឋកថា

## គាថាទី ៤

គប្បីជ្រាបវិនិច្ឆ័យក្នុងគាថាទី ៤ ដូចតទៅនេះ

[ ២៨២ ] បទថា **ទិស្វា** បានដល់ សម្លឹងមើលហើយ ។ បទថា **សុវណ្ណស្ស** បានដល់ មាស ។ គប្បីបន្ថែមបាលីដ៏សេសថា **វលយានិ** ព្រោះនៅមានអត្ថសេសសល់ ។ បទថា **បភស្សរានិ** បានដល់ ចែងចាំង ជាប្រក្រតី ។ មានពាក្យអធិប្បាយថា រុងរឿង ។ ពាក្យដ៏សេស មានអត្ថនៃបទងាយយល់ហើយ ។ តែយោជនាលម្អិតថា អាត្មាឃើញកងដៃត្រង់ដៃទើបគិតថា កាលនៅរួមគ្នាជាគណៈ ការខ្ទាំងខ្ទប់រមែងមាន តែកាលបុគ្គលនៅម្នាក់ឯង ការខ្ទាំងខ្ទប់រមែងមិនមាន ទើបផ្តើមវិបស្សនា ហើយសម្រេចបច្ចេកពោធិញ្ញាណ ។ បទដ៏សេស មានន័យដូចពោលហើយនោះឯង ។ បទថា **ទ្វេ ភុជស្មឹ** បានដល់ កងដៃ ។ អាចារ្យពួកខ្លះពោលថា **និយុរា** ដូច្នេះក៏មាន ។ បទថា **ឃដ្តេន្តិ** បានដល់ ប៉ះទង្គិចគ្នានឹងគ្នា ។ ៚

**អដ្ឋកថា គាថាទី ៤ ចប់**

# សុត្តន្តបិដក

[ ២៨៦ ] ការរួសរាយដោយវាចាក្តី ការជាប់ជំពាក់ក្តី ជាមួយនឹងបុគ្គលជាគម្រប់ពីររបស់អញយ៉ាងនេះ បុគ្គលកាលសម្លឹងឃើញភ័យនុ៎ះ ក្នុងអនាគត គប្បីប្រព្រឹត្តម្នាក់ឯង ដូចកុយរមាស ។

[ ២៨៧ ] អធិប្បាយពាក្យថា ជាមួយនឹងបុគ្គលជាគម្រប់ពីររបស់អញយ៉ាងនេះ គឺបុគ្គលមានតណ្ហាជាគម្រប់ពីរ ។ បុគ្គលមានតណ្ហាជាគម្រប់ពីរក៏មាន មានបុគ្គលគម្រប់ពីរក៏មាន ។ បុគ្គលមានតណ្ហាជាគម្រប់ពីរ តើដូចម្តេច ។ ពាក្យថា តណ្ហា បានដល់ រូបតណ្ហា សទ្ទតណ្ហា គន្ធតណ្ហា រសតណ្ហា ផោដ្ឋព្វតណ្ហា ធម្មតណ្ហា ។ បុគ្គលណា មិនបានលះបង់តណ្ហានេះ បុគ្គលនោះ លោកហៅថា មានតណ្ហាជាគម្រប់ពីរ ។

បុរសមានតណ្ហាជាគម្រប់ពីរ តែងអន្ទោលទៅអស់កាលយូរ មិន
ប្រព្រឹត្តកន្លងនូវសង្សារដែលមានភាពនេះ និងភាពដទៃបានទេ ។

បុគ្គលមានតណ្ហាជាគម្រប់ពីរយ៉ាងនេះឯង ។ បុគ្គលមានបុគ្គលគម្រប់ពីរ តើដូចម្តេច ។ បុគ្គលខ្លះ ក្នុងលោកនេះ រាយមាយ មានចិត្តមិនស្ងប់រម្ងាប់ មិនមែនព្រោះហេតុខ្លួន មិនមែនព្រោះហេតុដំណើរទេ ជាគម្រប់ពីរនឹងបុគ្គលមួយនាក់ក៏មាន ជាគម្រប់បីនឹងបុគ្គលពីរនាក់ក៏មាន ជាគម្រប់បួននឹងបុគ្គលបីនាក់ក៏មាន និយាយសម្ផប្បលាបៈច្រើនក្នុងទីនោះ គឺនិយាយរាជកថា ចោរកថា មហាមត្តកថា សេនាកថា ភយកថា យុទ្ធកថា អន្នកថា បានកថា វត្ថកថា មាលាកថា ញាតិកថា យានកថា គាមកថា និគមកថា នគរកថា ជនបទកថា ឥត្ថីកថា បុរិសកថា សូរកថា វិសិខាកថា កុម្ភដ្ឋានកថា

លោកក្ខាយិកកថា សមុទ្ទក្ខាយិកកថា ឥតិភវាភវកថា ដូច្នេះៗ ខ្លះ បុគ្គលមានបុគ្គលជាគម្រប់ពីរយ៉ាងនេះឯង ហេតុនោះ ( លោកពោលថា ) ជាមួយនឹងបុគ្គលជាគម្រប់របស់អញយ៉ាងនេះ ។

[ ២៨៨ ] ពាក្យថា ការរួសរាយដោយវាចាក្តី ការជាប់ជំពាក់ក្តី អធិប្បាយថា ការរួសរាយដោយវាចា លោកសម្តៅយកតិរច្ឆានកថា ៣២ គឺរាជកថា ចោរកថា ។បេ។ ឥតិភវាភវកថា ដូច្នេះៗ ខ្លះ ។ ពាក្យថា ការជាប់ជំពាក់ បានដល់ ការជាប់ជំពាក់ ២ គឺការជាប់ជំពាក់ គឺតណ្ហា ១ ការជាប់ជំពាក់ គឺទិដ្ឋិ ១ ។បេ។ នេះ ការជាប់ជំពាក់ គឺតណ្ហា ។បេ។ នេះការជាប់ជំពាក់ គឺទិដ្ឋិ ហេតុនោះ ( លោកពោលថា ) ការរួសរាយដោយវាចាក្តី ការជាប់ជំពាក់ក្តី ។

[ ២៨៩ ] អធិប្បាយពាក្យថា បុគ្គលកាលសម្លឹងឃើញភ័យទុំះ ក្នុងអនាគត ត្រង់ពាក្យថា ភ័យ បានដល់ ភ័យអំពីជាតិ ភ័យអំពីជរា ភ័យអំពីព្យាធិ ភ័យអំពីមរណៈ ភ័យអំពីព្រះរាជា ភ័យអំពីចោរ ភ័យអំពីភ្លើង ភ័យអំពីទឹក ភ័យអំពីការតិះដៀលរបស់ខ្លួន ភ័យអំពីការតិះដៀលរបស់បុគ្គលដទៃ ភ័យអំពីអាជ្ញា ភ័យអំពីទុគ្គតិ ភ័យអំពីរលក ភ័យអំពីក្រពើ ភ័យអំពីកន្លែងទឹកវិល ភ័យអំពីត្រីឆ្លាម ភ័យអំពីការចិញ្ចឹមជីវិត ភ័យអំពីជំនៀល ភ័យអំពីការញាញើតបរិស័ទ អារម្មណ៍គួរស្បើម សេចក្តីរន្ធត់ សេចក្តីព្រឺរោមសេចក្តីតក់ស្លុតចិត្ត សេចក្តីស្រឡាំងកាំងចិត្ត ។ ពាក្យថា បុគ្គលកាលសម្លឹងឃើញភ័យទុំះ ក្នុងអនាគត សេចក្តីថា បុគ្គលកាលសម្លឹងឃើញ មើល

រមិលមើល ពិនិត្យ ជញ្ជីងនូវភ័យទុំះ ក្នុងអនាគត ហេតុនោះ ( លោកពោលថា ) បុគ្គលកាលសម្លឹងឃើញភ័យទុំះ ក្នុងអនាគត ។ គប្បីប្រព្រឹត្តម្នាក់ឯង ដូចកុយរមាស ។ ហេតុនោះ ព្រះបច្ចេកសម្ពុទ្ធនោះពោលថា

ការរួសរាយដោយវាចាក្តី ការជាប់ជំពាក់ក្តី ជាមួយនឹងបុគ្គលជាគម្រប់ពីររបស់អញយ៉ាងនេះ បុគ្គលកាលសម្លឹងឃើញភ័យទុំះ ក្នុងអនាគត គប្បីប្រព្រឹត្តម្នាក់ឯងដូចកុយរមាស ។

# អដ្ឋកថា

## គាថាទី ៥

[ ២៨៦ ] គាថាទី ៥ កាលពោលដោយបទ មានអត្ថងាយយល់ហើយ តែក្នុងទីនេះ មានអធិប្បាយដូចតទៅនេះថា កាលកុមារដែលជាសម្លាញ់នោះ ប្រាប់ថា ( ខ្ញុំ ) រង់ា ( ខ្ញុំ ) ក្តៅជាដើម ការចរចារបស់អាត្មាដែល លួងលោមកុមារនោះឲ្យនៅរួមគ្នាក្តី ការជាប់ជំពាក់ដោយអំណាចសេចក្តី ស្រឡាញ់ក្នុងកុមារនោះក្តី កើតហើយ ។ បើអាត្មាមិនលះកុមារ ដែលជា សម្លាញ់នេះតទៅ ការចរចាក្តី ការជាប់ជំពាក់ក្តី ជាមួយកុមារដែលជា សម្លាញ់នោះ ក៏គប្បីមានដល់អាត្មាដូចក្នុងឥឡូវនេះឯង ហេតុទាំងពីរនោះ នឹងធ្វើអន្តរាយដល់ការសម្រេចគុណវិសេស ព្រោះហេតុនោះ អាត្មាសម្លឹង ឃើញភ័យនេះ ក្នុងអនាគត ទើបលះបង់កុមារនោះ បដិបត្តិដោយឧបាយ ទើបសម្រេចបច្ចេកពោធិញ្ញាណ ដោយប្រការដូច្នេះ ។ បទដ៏សេស មាន ន័យដូចពោលហើយនោះឯង ។៚

**អដ្ឋកថា គាថាទី ៥ ចប់**

# សុត្តន្តបិដក

[ ២៩០ ] ពិតណាស់ កាមទាំងឡាយដ៏វិចិត្រ មានរសឆ្ងាញ់ ជាទីត្រេកអរនៃចិត្ត តែងញាំញីចិត្តដោយសភាពនៃរូបផ្សេងៗ បុគ្គលឃើញទោសក្នុងកាមគុណទាំងឡាយហើយ គប្បីប្រព្រឹត្តម្នាក់ឯងដូចកុយរមាស ។

[ ២៩១ ] អធិប្បាយពាក្យថា ពិតណាស់ កាមទាំងឡាយដ៏វិចិត្រ មានរសឆ្ងាញ់ ជាទីត្រេកអរនៃចិត្ត ត្រង់ពាក្យថា កាម តាមឧទ្ទាន កាមមាន ២ គឺវត្ថុកាម ១ កិលេសកាម ១ ។បេ។ ទាំងនេះ ហៅថា វត្ថុកាម ។បេ។ ទាំងនេះ ហៅថា កិលេសកាម ។ ពាក្យថា ដ៏វិចិត្រ គឺរូបមានបែបផ្សេងៗ សំឡេងមានបែបផ្សេងៗ ក្លិនមានបែបផ្សេងៗ រសមានបែបផ្សេងៗ ផោដ្ឋព្វៈមានបែបផ្សេងៗ ។ ពាក្យថា មានរសឆ្ងាញ់ សេចក្តីថា មែនពិត ព្រះមានព្រះភាគបានត្រាស់ព្រះតម្រាស់នេះថា ម្នាលភិក្ខុទាំងឡាយ កាមគុណនេះ មាន ៥ កាមគុណ ៥ គឺអ្វីខ្លះ គឺរូបដែលត្រូវដឹងដោយចក្ខុ ជាទីប្រាថ្នា ជាទីស្រឡាញ់ ជាទីគាប់ចិត្ត មានភាពជាទីស្រឡាញ់ ប្រកបដោយកាមគួរឲ្យត្រេកត្រអាល ១ សំឡេងដែលត្រូវដឹងដោយសោតៈ ១ ក្លិនដែលត្រូវដឹងដោយឃានៈ ១ រសដែលត្រូវដឹងដោយជិវ្ហា ១ ផោដ្ឋព្វៈដែលត្រូវដឹងដោយកាយ ជាទីប្រាថ្នា ជាទីស្រឡាញ់ ជាទីគាប់ចិត្ត មានភាពជាទីស្រឡាញ់ ប្រកបដោយកាមគួរឲ្យត្រេកត្រអាល ១ ម្នាលភិក្ខុទាំងឡាយ នេះឯងកាមគុណ ៥ ម្នាលភិក្ខុទាំងឡាយ សុខសោមនស្សណា កើតឡើងព្រោះអាស្រ័យកាមគុណ ៥ នេះ សុខសោមនស្សនេះ តថាគតហៅថា សុខក្នុងកាម សុខដូចលាមក សុខរបស់

បុថុជ្ជន សុខមិនប្រសើរ តថាគតពោលថា បុគ្គលមិនគួរសេព មិនគួរគប់ មិនគួរចម្រើន មិនគួរធ្វើឲ្យរឿយៗ បុគ្គលគួរខ្លាចសុខនុ៎ះ ហេតុនោះ ( លោកពោលថា ) ពិតណាស់ កាមទាំងឡាយដ៏វិចិត្រ មានរសឆ្ងាញ់ ។ ពាក្យថា ជាទីត្រេកអរនៃចិត្ត ត្រង់ពាក្យថា ចិត្ត បានដល់ ចិត្ត មនៈ មានសៈ ហទយៈ បណ្ឌរៈ មនៈ មនាយតនៈ មនិន្ទ្រិយ វិញ្ញាណ វិញ្ញាណក្ខន្ធ មនោវិញ្ញាណធាតុ ដែលកើតអំពីវិញ្ញាណក្ខន្ធនោះ ។

[ ២៩២ ] ពាក្យថា តែងញាំញីចិត្តដោយសភាពនៃរូបផ្សេងៗ គឺតែងញាំញី ញាំងចិត្តឲ្យតក់ស្លុត ឲ្យសាបសូន្យ ឲ្យសាបរលាបដោយរូបទាំងឡាយមានបែបផ្សេងៗ ។បេ។ ដោយផោដ្ឋព្វៈទាំងឡាយ មានបែបផ្សេងៗ ហេតុនោះ ( លោកពោលថា ) តែងញាំញីចិត្តដោយសភាពនៃរូបផ្សេងៗ ។

[ ២៩៣ ] ពាក្យថា បុគ្គលឃើញទោសក្នុងកាមគុណទាំងឡាយ អធិប្បាយថា មែនពិត ព្រះមានព្រះភាគ បានត្រាស់ព្រះតម្រាស់នេះថា ម្នាលភិក្ខុទាំងឡាយ ទោសរបស់កាមទាំងឡាយ តើដូចម្ដេច ម្នាលភិក្ខុទាំងឡាយ កុលបុត្រក្នុងលោកនេះ ចិញ្ចឹមជីវិតដោយថ្នាក់នៃសិប្បៈណា គឺការរាប់ដោយដៃទទេក្ដី ការរាប់មិនដាច់ក្ដី ការរាប់បូកក្ដី ការក្ដួររាស់ក្ដី ជំនួញក្ដី ការរក្សាគោក្ដី ការកាន់អាវុធបម្រើក្ដី ភាពជារាជបុរសក្ដី សិប្បៈ មានហត្ថិសិប្បៈជាដើមក្ដី ជាអ្នកត្រូវត្រជាក់បៀតបៀន ត្រូវកម្ដៅបៀតបៀន ប៉ះ ទង្គិច ទង្ក្កដោយសម្ផស្សនៃរបោម មូស ខ្យល់ កម្ដៅថ្ងៃ និងសត្វលូន ស្លាប់ដោយគម្លាន និងសម្រេក ម្នាលភិក្ខុទាំងឡាយ នេះទោសរបស់កាមទាំងឡាយ

ដែលគេត្រូវឃើញផ្ទាល់ខ្លួន ជាកងទុក្ខ ( កើតឡើង ) ព្រោះកាមជាហេតុ ព្រោះកាមជាដើមចង ព្រោះកាមជាដើមទង ព្រោះហេតុនៃកាមទាំងឡាយ តែម្យ៉ាង ម្នាលភិក្ខុទាំងឡាយ បើកាលកុលបុត្តនោះខ្នះខ្នែង ប្រឹងប្រែង ព្យាយាមយ៉ាងម្ល៉េះហើយ ភោគៈទាំងនោះ មិនសម្រេចទេ កុលបុត្តនោះ តែងក្រៀមក្រំ លំបាក ខ្សឹកខ្សួល កន្ទក់កន្ទេញ គក់ទ្រូង ដល់នូវសេចក្ដីវង្វេង វង្វាងថា ការប្រឹងប្រែងរបស់អញ ឥតអំពើហើយតើ សេចក្ដីព្យាយាម របស់អញ មិនមានផលហើយតើ ម្នាលភិក្ខុទាំងឡាយ នេះទោសរបស់កាម ទាំងឡាយ ដែលគេត្រូវឃើញផ្ទាល់ខ្លួន ជាកងទុក្ខ ( កើតឡើង ) ព្រោះកាម ជាហេតុ ព្រោះកាមជាដើមចង ព្រោះកាមជាដើមទង ព្រោះហេតុនៃកាមទាំង ឡាយតែម្យ៉ាង ម្នាលភិក្ខុទាំងឡាយ បើកាលកុលបុត្តនោះខ្នះខ្នែង ប្រឹងប្រែង ព្យាយាមយ៉ាងម្ល៉េះហើយ ភោគៈទាំងនោះសម្រេច កុលបុត្តនោះ ក៏គង់វេទនាទុក្ខ និងទោមនស្ស ដែលមានការហួងហែងភោគៈទាំងនោះជាហេតុថា ធ្វើដូចម្ដេច កុំឲ្យព្រះរាជានាំយកទៅបាន កុំឲ្យចោរនាំយកទៅបាន កុំឲ្យភ្លើងឆេះ កុំឲ្យទឹក នាំយកទៅបាន កុំឲ្យពួកជនជាទាយាទ មិនជាទីស្រឡាញ់នាំយកទៅបាន នូវ ភោគៈទាំងឡាយរបស់អញ កាលបើកុលបុត្តនោះហួងហែង គ្រប់គ្រងយ៉ាង ម្ល៉េះហើយ ព្រះរាជាទាំងឡាយ នាំយកទៅក្ដី ចោរទាំងឡាយនាំយកទៅក្ដី ភ្លើងឆេះក្ដី ទឹកនាំទៅក្ដី ពួកជនជាទាយាទមិនជាទីស្រឡាញ់នាំយកទៅក្ដី នូវ ភោគៈទាំងឡាយនោះ កុលបុត្តនោះ តែងក្រៀមក្រំ ។បេ។ ដល់នូវសេចក្ដី វង្វេងវង្វាងថា ទ្រព្យណារបស់អញមានហើយ អញមិនមានទ្រព្យនោះវិញ ម្នាល

ភិក្ខុទាំងឡាយ នេះទោសរបស់កាមទាំងឡាយ ដែលគេត្រូវឃើញផ្ទាល់ខ្លួន ជាកងទុក្ខ ( កើតឡើង ) ព្រោះកាមជាហេតុ ព្រោះកាមជាដើមចង ព្រោះកាមជាដើមទង ព្រោះហេតុនៃកាមទាំងឡាយតែម្យ៉ាង ។ ម្នាលភិក្ខុទាំងឡាយ មួយទៀត ព្រោះកាមជាហេតុ ព្រោះកាមជាដើមចម ព្រោះកាមជាដើមទង ព្រោះហេតុនៃកាមទាំងឡាយតែម្យ៉ាង ពួកព្រះរាជាក៏វិវាទដោយពួកព្រះរាជា ពួកក្សត្រិយ៍ក៏វិវាទដោយពួកក្សត្រិយ៍ ពួកព្រាហ្មណ៍ក៏វិវាទដោយពួកព្រាហ្មណ៍ ពួកគហបតីក៏វិវាទដោយពួកគហបតី មាតាក៏វិវាទដោយបុត្ត បុត្តក៏វិវាទដោយមាតា បិតាក៏វិវាទដោយបុត្ត បុត្តក៏វិវាទដោយបិតា បងប្អូនប្រុសក៏វិវាទដោយបងប្អូនស្រី បងប្អូនស្រីក៏វិវាទដោយបងប្អូនប្រុស សម្លាញ់ក៏វិវាទដោយសម្លាញ់ ពួកជននោះ ដល់នូវជម្លោះ និងការវិវាទក្នុងទីនោះ ប្រហារគ្នាដោយដៃខ្លះ ប្រហារគ្នាដោយដុំដីខ្លះ ប្រហារគ្នាដោយដំបងខ្លះ ប្រហារគ្នាដោយសស្ត្រាខ្លះ ពួកជននោះ ដល់នូវសេចក្ដីស្លាប់ខ្លះ ដល់នូវទុក្ខស្មើរស្លាប់ខ្លះ ព្រោះតែការប្រហារគ្នានោះ ម្នាលភិក្ខុទាំងឡាយ នេះទោសរបស់កាមទាំងឡាយ ដែលគេត្រូវឃើញផ្ទាល់ខ្លួន ជាកងទុក្ខ ( កើតឡើង ) ព្រោះកាមជាហេតុ ព្រោះកាមជាដើមចម ព្រោះកាមជាដើមទង ព្រោះហេតុនៃកាមទាំងឡាយតែម្យ៉ាង ។ ម្នាលភិក្ខុទាំងឡាយ មួយទៀត ព្រោះកាមជាហេតុ ព្រោះកាមជាដើមចម ព្រោះកាមជាដើមទង ព្រោះហេតុនៃកាមទាំងឡាយតែម្យ៉ាង ជនទាំងឡាយក៏កាន់ដាវ និងខែល សៀតធ្នូ និងបំពង់ព្រួញ ហើយរុករានគង្គាន ទៅកាន់សង្គ្រាម ដែលពពាក់ពពូនទាំងសងខាង កាលបើព្រួញទាំងឡាយ

ដែលគេបាញ់ទៅខ្លះ លំពែងទាំងឡាយ ដែលគេពួយទៅខ្លះ ដាវទាំងឡាយ ដែលគេគ្រវីគ្រវាត់ខ្លះ ជនទាំងនោះ បាញ់ដោយព្រួញទាំងឡាយក្នុងសង្គ្រាមនោះខ្លះ ចាក់ដោយលំពែងទាំងឡាយខ្លះ កាត់ក្បាលដោយដាវខ្លះ ជនទាំងនោះ ដល់នូវសេចក្ដីស្លាប់ខ្លះ ដល់នូវទុក្ខស្មើរស្លាប់ខ្លះ ក្នុងសង្គ្រាមនោះ ម្នាលភិក្ខុទាំងឡាយ នេះទោសរបស់កាមទាំងឡាយ ដែលគេត្រូវឃើញផ្ទាល់ខ្លួន ជាកងទុក្ខ (កើតឡើង) ព្រោះកាមជាហេតុ ព្រោះកាមជាដើមចម ព្រោះកាមជាដើមទង ព្រោះហេតុនៃកាមទាំងឡាយតែម្យ៉ាង ។ ម្នាលភិក្ខុទាំងឡាយមួយទៀត ព្រោះកាមជាហេតុ ព្រោះកាមជាដើមចម ព្រោះកាមជាដើមទង ព្រោះហេតុនៃកាមទាំងឡាយតែម្យ៉ាង ជនទាំងឡាយក៏កាន់ដាវ និងខែល សៀតធ្នូ និងបំពង់ព្រួញ រុករានគន្លានទៅកាន់ជើងកំពែង មានប៉មដែលបូកដោយបាយអ កាលបើព្រួញទាំងឡាយ ដែលគេបាញ់ទៅខ្លះ លំពែងទាំងឡាយ ដែលគេពួយទៅខ្លះ ដាវទាំងឡាយ ដែលគេគ្រវីគ្រវាត់ខ្លះ ជនទាំងនោះ បាញ់ដោយព្រួញទាំងឡាយ ក្នុងសង្គ្រាមនោះខ្លះ ចាក់ដោយលំពែងទាំងឡាយខ្លះ ស្រោចចុះដោយអាចម៍គោកំពុងពុះខ្លះ ប្រំដោយអាវុធមានធ្មេញ ៧ ខ្លះ កាត់ក្បាលដោយដាវខ្លះ ជនទាំងនោះ ដល់នូវសេចក្ដីស្លាប់ខ្លះ ដល់នូវទុក្ខស្មើរស្លាប់ខ្លះ ក្នុងសង្គ្រាមនោះ ម្នាលភិក្ខុទាំងឡាយ នេះទោសរបស់កាមទាំងឡាយ ដែលគេត្រូវឃើញផ្ទាល់ខ្លួន ជាកងទុក្ខ ( កើតឡើង ) ព្រោះកាមជាហេតុ ព្រោះកាមជាដើមចម ព្រោះកាមជាដើមទង ព្រោះហេតុនៃកាមតែម្យ៉ាង ។ ម្នាលភិក្ខុទាំងឡាយ មួយទៀត ព្រោះកាមជាហេតុ ព្រោះកាមជាដើមចម ព្រោះកាម

ជាដើមទង ព្រោះហេតុនៃកាមតែម្យ៉ាង ជនទាំងឡាយកាត់ទីតផ្ទះខ្លះ ប្លន់ធំខ្លះ ធ្វើនូវការប្លន់ផ្ទះមួយខ្លះ ឈរស្ទាក់ផ្លូវខ្លះ គប់ប្រពន្ធគេខ្លះ ព្រះរាជាទាំងឡាយ ប្រើគេឲ្យចាប់ជននោះ ហើយឲ្យធ្វើកម្មករណ៍ផ្សេងៗ គឺឲ្យវាយដោយខ្សែតី ទាំងឡាយខ្លះ ឲ្យវាយដោយរំពាត់ផ្តៅទាំងឡាយខ្លះ ឲ្យដំដោយអន្ទង់ទាំងឡាយ ខ្លះ ឲ្យកាត់ដៃខ្លះ ឲ្យកាត់ជើងខ្លះ ។បេ។ ឲ្យកាត់ក្បាលដោយដាវខ្លះ ជនទាំង នោះ ដល់នូវសេចក្តីស្លាប់ខ្លះ ដល់នូវទុក្ខស្មើស្លាប់ខ្លះ ព្រោះតែដំណើរនោះ ម្នាលភិក្ខុទាំងឡាយ នេះទោសរបស់កាមទាំងឡាយ ដែលគេត្រូវឃើញផ្ទាល់ ខ្លួន ជាកងទុក្ខ ( កើតឡើង ) ព្រោះកាមជាហេតុ ព្រោះកាមជាដើមចម ព្រោះ កាមជាដើមទង ព្រោះហេតុនៃកាមទាំងឡាយតែម្យ៉ាង ។ ម្នាលភិក្ខុទាំងឡាយ មួយវិញទៀត ព្រោះកាមជាហេតុ ព្រោះកាមជាដើមចម ព្រោះកាមជាដើមទង ព្រោះហេតុនៃកាមទាំងឡាយតែម្យ៉ាង ជនទាំងឡាយ ប្រព្រឹត្តទុច្ចរិតដោយកាយ ប្រព្រឹត្តទុច្ចរិតដោយវាចា ប្រព្រឹត្តទុច្ចរិតដោយចិត្ត ជនទាំងនោះ ប្រព្រឹត្តទុច្ចរិត ដោយកាយ ប្រព្រឹត្តទុច្ចរិតដោយវាចា ប្រព្រឹត្តទុច្ចរិតដោយចិត្តហើយ លុះ បែកធ្លាយរាងកាយស្លាប់ទៅ រមែងទៅកើតក្នុងទុគ្គតិ វិនិបាត នរក ម្នាលភិក្ខុ ទាំងឡាយ នេះទោសរបស់កាមទាំងឡាយ ដែលត្រូវឃើញក្នុងលោកខាងនាយ ជាកងទុក្ខ ( កើតឡើង ) ព្រោះកាមជាហេតុ ព្រោះកាមជាដើមចម ព្រោះកាម

ជាដើមទង ព្រោះហេតុនៃកាមទាំងឡាយតែម្យ៉ាង ។ ពាក្យថា បុគ្គលឃើញទោសក្នុងកាមគុណទាំងឡាយ បានសេចក្តីថា ឃើញ មើល ថ្លឹង ត្រួត បញ្ជាក់ ធ្វើឲ្យជាក់នូវទោសក្នុងកាមគុណទាំងឡាយ ហេតុនោះ ( លោកពោលថា ) បុគ្គលឃើញទោសក្នុងកាមគុណទាំងឡាយ ។ គប្បីប្រព្រឹត្តម្នាក់ឯង ដូចកុយរមាស ។ ហេតុនោះ ព្រះបច្ចេកសម្ពុទ្ធនោះពោលថា

ពិតណាស់ កាមទាំងឡាយដ៏វិចិត្រ មានរសឆ្ងាញ់ ជាទីត្រេកអរនៃ
ចិត្ត តែងញាំញីចិត្ត ដោយសភាពនៃរូបផ្សេង បុគ្គលឃើញទោស
ក្នុងកាមគុណទាំងឡាយហើយ គប្បីប្រព្រឹត្តម្នាក់ឯង ដូចកុយ
រមាស ។

# អដ្ឋកថា

## គាថាទី ៦

គប្បីជ្រាបវិនិច្ឆ័យក្នុងគាថាទី ៦ ដូចតទៅនេះ

[ ២៩០ ] បទថា **កាមា** បានដល់ កាម មាន ២ យ៉ាង គឺវត្ថុកាម និងកិលេសកាម ។ ក្នុងកាម ២ យ៉ាងនោះ ធម៌ មានរូបជាដើមដែលគួរពេញចិត្ត ឈ្មោះថា វត្ថុកាម ។ កិលេសទាំងឡាយ មានឆន្ទៈជាដើមប្រភេទរាគៈទាំងអស់ ឈ្មោះថា កិលេសកាម តែក្នុងទីនេះ បំណងយកវត្ថុកាម ។ កាមទាំងឡាយ ឈ្មោះថា វិចិត្រ ក៏ដោយអំណាចដែលមានជាអនេកនៃរូបជាដើម ឈ្មោះថា មានរសឆ្ងាញ់ ដោយអំណាចធ្វើនូវការត្រេកអរឲ្យដល់សត្វលោក ឈ្មោះថា ជាទីត្រេកអរនៃចិត្ត ព្រោះធ្វើចិត្តរបស់បុថុជ្ជនល្ងង់ខ្លៅឲ្យត្រេកអរ ។ បទថា **វិរូបរូបេន** បានដល់ ដោយរូបប្លែកៗ មានពាក្យអធិប្បាយថា ដោយសភាពប្លែកៗ ច្រើនយ៉ាង ។ ពិតហើយ កាមទាំងនោះ ឈ្មោះថា វិចិត្រ ក៏ដោយអំណាចនៃអារម្មណ៍ មានរូបជាដើម ឈ្មោះថា ដោយសភាពនៃរូបផ្សេងៗ ដោយរូបដែលមានពណ៌ខៀវជាដើម ក្នុងអារម្មណ៍ទាំងឡាយ មានរូបជាដើម រមែងសម្តែងនូវការត្រេកអរ ដោយប្រការនោះៗ ដោយរូបដែលប្លែកៗ នោះ យ៉ាងនោះ តែងញាំញីចិត្ត គឺមិនឲ្យចិត្តរបស់បុគ្គលត្រេកអរក្នុងការបួស ។ បទដ៏សេស ក្នុងនិទ្ទេសនេះ ប្រាកដច្បាស់ហើយ សូម្បីបទសរុបក៏គប្បីប្រកបដោយ ២ បទ ឬ ៣ បទ ហើយគប្បីជ្រាបដោយន័យដូចពោលហើយក្នុងគាថាខាងដើម ។

[ ២៩១ ] បទថា **កាមគុណា** មានអត្ថវិគ្គហៈថា ឈ្មោះថា **កាម**

ព្រោះអត្ថថា ដែលសត្វគប្បីប្រាថ្នា ឈ្មោះថា **គុណា** ព្រោះអត្ថថា ជាគ្រឿងចង ។

**គុណា** សព្ទ មានអត្ថថា ជាន់ ដូចក្នុងប្រយោគជាដើមថា **អនុជានាមិ ភិក្ខវេ អហតានំ ទុស្សានំ អហតកប្បានំ ទិគុណំ សង្ឃាដឹ** ម្នាលភិក្ខុទាំងឡាយ កាលបើសំពត់នូវថ្មោង ឬសំពត់ដែលគេបោកលាងម្តងហើយ តថាគតអនុញ្ញាត ( ឲ្យអ្នកទាំងឡាយធ្វើ ) សង្ឃាដិពីរជាន់ ដូច្នេះ ។ **គុណា** សព្ទ មានអត្ថថា គំនរ ដូចក្នុងប្រយោគជាដើមថា **អច្ចេន្តិ កាលា តរយន្តិ រត្តិយោ វយោគុណា អនុបុព្វំ ជហន្តិ** កាលទាំងឡាយ តែងកន្លងផុតទៅ រាត្រីទាំងឡាយ តែងឆ្លងហួសទៅ ជំនាន់នៃវ័យទាំងឡាយ តែងលះបង់នូវលំដាប់ ដូច្នេះ ។ **គុណា** សព្ទ មានអត្ថថា អានិសង្ស ដូចក្នុងប្រយោគជាដើមថា **សតគុណា ទក្ខិណា បាដិកង្ខិតព្វា** ទក្ខិណាមានគុណ ១០០ ដែលបុគ្គលត្រូវបាន ( ព្រោះឲ្យទានចំពោះសត្វតិរច្ឆាន ) ដូច្នេះ ។

**គុណា** សព្ទ មានអត្ថថា ជាគ្រឿងចង ដូចក្នុងប្រយោគជាដើមថា **អន្តំ អន្តគុណំ** ពោះវៀនធំ ពោះវៀនតូច និងប្រយោគមួយទៀតថា **កយិរា មាលាគុណេ ពហូ** មាលាការបេះធ្វើសំណុំនៃកម្រងផ្កាអំពីគំនរនៃផ្កា ( ផ្សេងៗគ្នា ) ឲ្យច្រើនបាន ដូច្នេះ ។ ក្នុងនិទ្ទេសនេះ បំណងយកអត្ថថា ជាគ្រឿងចង ដោយហេតុនោះ ទើបខ្ញុំពោលថា ឈ្មោះថា **គុណា** ព្រោះអត្ថថា ជាគ្រឿងចង ។ បទថា **ចក្ខុវិញ្ញេយ្យា** បានដល់ គប្បីឃើញបានដោយចក្ខុ-

វិញ្ញាណ ។ ក្នុងសោតវិញ្ញាណជាដើម ក៏គប្បីជ្រាបដោយឧបាយនេះ ។ បទថា **ឥដ្ឋា** បានដល់ អារម្មណ៍ដែលគួរប្រាថ្នា ដែលស្វែងរកក្តី ដែលមិនស្វែងរកក្តី ។ បទថា **កន្តា** បានដល់ ជាទីត្រូវការ ។ បទថា **មនាបា** បានដល់ គួរចម្រើនចិត្ត ។ បទថា **បិយរូបា** បានដល់ គួរពេញចិត្ត ។ បទថា **កាមូបសំហិតា** បានដល់ ប្រកបដោយកាមដែលកើតឡើងជាអារម្មណ៍ ។ បទថា **រជនីយា** បានដល់ ដឹកនាំឲ្យកើតសេចក្តីស្រឡាញ់ អធិប្បាយថា ជាហេតុឲ្យកើតតម្រេក ។

[ ២៩៣ ] គប្បីជ្រាបសេចក្តីក្នុងពាក្យថា **យទិ មុទ្ទាយ** ជាដើម ដូចតទៅ បទថា **មុទ្ទា** បានដល់ ការរាប់ដោយម្រាមដៃ កំណាត់ចំណាំត្រង់ថ្នាំងម្រាមដៃទាំងឡាយ ។ បទថា **គណនា** បានដល់ ការរាប់ជាប់តគ្នា ។ បទថា **សង្ខានំ** បានដល់ ការរាប់ជាក្រុម ។ ជនទាំងឡាយ សម្លឹងមើលស្រែហើយ ប្រមាណយកថា ក្នុងស្រែនេះ នឹងមានស្រូវប្រមាណប៉ុណ្ណេះ សម្លឹងមើលដើមឈើហើយ ប្រមាណយកថា ដើមឈើនេះ នឹងមានផ្លែប្រមាណប៉ុណ្ណេះ សម្លឹងមើលអាកាសហើយ ប្រមាណយកថា ក្នុងអាកាសនេះ នឹងមានបក្សីប្រមាណប៉ុណ្ណេះ ។ បទថា **កសិ** បានដល់ កម្មរបស់ខេត្តករ ។ បទថា **វណិជ្ជា** បានដល់ ផ្លូវនៃជំនួញ មានការដើរលក់ដូរតាមផ្លូវទឹក និងផ្លូវគោកជាដើម ។ បទថា **គោរក្ខំ** បានដល់ ការចិញ្ចឹមគោរបស់ខ្លួន ឬរបស់អ្នកដទៃ ហើយតម្កល់ជីវិតដោយការលក់បញ្ចគោរស ។ ការកាន់អាវុធ ហើយមើលថែរក្សា លោកហៅថា **ឥស្សត្ថ** ។ បទថា **រាជ-**

**ចោរិសំ** បានដល់ ការធ្វើការងាររបស់ព្រះរាជា ហើយបម្រើព្រះរាជាដោយមិនមានអាវុធ ។ បទថា **សិប្បញ្ញតរំ** បានដល់ សិប្បៈដ៏សេសអំពីសិប្បៈដែលប្រារព្ធហើយ មានសិប្បៈក្នុងការចិញ្ចឹមដំរី និងសេះជាដើម ។

បទថា **សីតស្ស បុរក្ខតោ** បានដល់ អត់ធន់ចំពោះរងា ដូចក្តារប៉ាយអត់ធន់ចំពោះព្រួញ ដូច្នោះ អធិប្បាយថា ត្រូវរងាបៀតបៀន ។ សូម្បីក្នុងការក្តៅក៏មានន័យនេះដូចគ្នា ។

គប្បីជ្រាបអត្ថក្នុងពាក្យថា **ឌំស** ជាដើមដូចតទៅ បទថា **ឌំសា** បានដល់ សត្វល្អិតក្អែកលឿង ។ បទថា **មកសា** បានដល់ សត្វល្អិតគ្រប់ប្រភេទ ។ បទថា **សរីសបា** បានដល់ សត្វលូនវារគ្រប់ប្រភេទ ។ បទថា **រិស្សមានោ** បានដល់ បៀតបៀន គឺទម្លាយ ។ បទថា **មីយមានោ** បានដល់ ឲ្យស្លាប់ ។ បទថា **អយំ ភិក្ខវេ** សេចក្តីថា ម្នាលភិក្ខុទាំងឡាយ ទោសនេះជាការបៀតបៀនដែលមានរងាជាដើមជាបច្ច័យ ព្រោះអាស្រ័យការចិញ្ចឹមជីវិតដោយសិប្បៈ មានការរាប់ម្រាមដៃជាដើម ។ បទថា **កាមានំ អាទីនវោ** បានដល់ អន្តរាយ ឧបសគ្គ ក្នុងកាមទាំងឡាយ ។ បទថា **សន្ទិដ្ឋិកោ** បានដល់ ឃើញច្បាស់ គឺឃើញឯង ។ បទថា **ទុក្ខក្ខន្ធោ** បានដល់ គំនរនៃទុក្ខ ។

គប្បីជ្រាបអត្ថក្នុងបទថា **កាមហេតុ** ជាដើមដូចតទៅនេះ ឈ្មោះថា **កាមហេតុ** ព្រោះកាមជាហេតុ ដោយអត្ថថា ជាបច្ច័យ ។ ឈ្មោះថា **កាម-និទានោ** ព្រោះមានកាមជាដើមចម ដោយអត្ថថា ជាឫសគល់ ។ តែលោក

ពោលក្នុងបាលីថា **កាមនិទានំ** ព្រោះលិង្គវិបល្លាស ។ ឈ្មោះថា **កាមា-**
**ធិករណោ** ព្រោះមានកាមជាការធ្វើ ដោយអត្ថថា ជាហេតុឲ្យធ្វើ ។ លោក
ពោលក្នុងបាលីថា **កាមាធិករណំ** ព្រោះលិង្គវិបល្លាសដូចគ្នា ។ បទថា
**កាមានមេវ ហេតុ** នេះ ជាពាក្យកំណត់ពិតប្រាកដ អធិប្បាយថា កើត
ព្រោះកាមជាបច្ច័យនោះឯង ។

បទថា **ឧដ្ឋហតោ** បានដល់ ខ្មីឃ្មាតដោយសេចក្តីព្យាយាម ក្នុង
ការប្រកបអាជីវៈ ។ បទថា **ឃដតោ** បានដល់ ធ្វើនូវសេចក្តីព្យាយាម
ជាប់តគ្នា តាំងអំពីដើមរហូតដល់ខាងចុង ។ បទថា **វាយមតោ** បានដល់
ធ្វើនូវសេចក្តីព្យាយាម ឲ្យឈានមុខតទៅ ។ បទថា **នាភិនិប្ផជ្ជន្តិ** បានដល់
ភោគសម្បត្តិទាំងនោះមិនចម្រើន មិនលូតលាស់ក្នុងទីនេះ ។ បទថា **សោចតិ**
បានដល់ រមែងសោយសោក ដោយសេចក្តីសោកមានកម្លាំង កើតឡើងក្នុង
ចិត្ត ។ បទថា **កិលមតិ** បានដល់ រមែងលំបាកដោយទុក្ខដែលកើតឡើង
ក្នុងកាយ ។ បទថា **បរិទេវតិ** បានដល់ រមែងខ្សឹកខ្សួលដោយវាចា ។ បទ
ថា **ឧរត្តាឡឹ** បានដល់ គក់ទ្រូង ។ បទថា **កន្ទតិ** បានដល់ យំ ។ បទថា
**សម្មោហំ អាបជ្ជតិ** បានដល់ មានការវង្វេង ដូចសន្លប់ ។ បទថា **មោឃំ**

បានដល់ ទទេ ។ បទថា **អផលោ** បានដល់ មិនមានផល ។ បទថា **អារក្ខាធិករណំ** បានដល់ ព្រោះហេតុនៃការរក្សា ។ បទថា **កិន្តិ មេ** បានដល់ ដោយឧបាយដូចម្ដេចហ្ន៎ ភោគៈរបស់ ។ បទថា **យម្បិ មេ** បានដល់ ទ្រព្យដែលខ្ញុំប្រមូល ដែលកើតព្រោះធ្វើកសិកម្មជាដើម ។ បទថា **តម្បិ នោ នត្ថិ** បានដល់ ឥឡូវនេះ ទ្រព្យរបស់យើងអស់ទៅ ។

ព្រះមានព្រះភាគ កាលទ្រង់សម្ដែងហេតុ ដោយព្រះតម្រាស់ជាដើមថា **បុន ចបរំ ភិក្ខវេ កាមហេតុ** ដូច្នេះហើយ ទើបទ្រង់សម្ដែងដល់ទោសទាំងឡាយតទៅ ។ ក្នុងបទទាំងនោះ បទថា **កាមហេតុ** សេចក្ដីថា ព្រះរាជាទាំងឡាយទាស់ទែងជាមួយព្រះរាជាក្ដី ក៏ព្រោះកាមជាហេតុ ។ បទថា **កាមនិទានំ** ជាការនៃបុំសកលិង្គ អធិប្បាយថា វិវាទគ្នា ព្រោះកាមជាដើមចម ។ បទថា **កាមាធិករណំ** ក៏ជាការនៃបុំសកលិង្គដូចគ្នា អធិប្បាយថា វិវាទព្រោះកាមជាដើមទង ។ បទថា **កាមានមេវ ហេតុ** សេចក្ដីថា វិវាទគ្នាព្រោះហេតុនៃកាមទាំងឡាយ មានស្រុក និគម តំណែងនៃសេនាបតី និងតំណែងនៃបុរោហិតជាដើម ។ បទថា **ឧបក្កមន្តិ** បានដល់ ប្រទូស្ដគ្នា ។ បទថា **អសិចម្មំ** បានដល់ ដាវ និងខែលជាដើម ។ បទថា **ធនុកលាបំ សន្នយ្ហិត្វា** បានដល់ កាន់ធ្នូចងបន្ទោះធ្នូ ។ បទថា **ឧភតោព្យូឡ្ហំ** បានដល់ ប្រឈមមុខគ្នាទាំង ២ ចំណែក ។ បទថា **បក្ខន្ទន្តិ** បានដល់ ចូលទៅ ។ បទថា **ឧសូសុ** បានដល់ ព្រួញ ។ បទថា **វិជ្ជោតលន្តេសុ** បានដល់ គ្រវី

ដាវ ។ បទថា **តេ តត្ថ** បានដល់ ជនទាំងនោះក្នុងសង្គ្រាមនោះ ។

ម្យ៉ាងទៀត គប្បីជ្រាបអត្ថក្នុងបទនេះថា **អទ្ធាវលេបនា ឧបការិយោ** ដូចតទៅ ជនទាំងឡាយយកឥដ្ឋ-កគ្រឹះប៉ម ដោយសណ្ឋានដូចជើងសេះ ហើយយកបាយ-អបូកខាងលើប៉ម ។ គ្រឹះប៉មដែលធ្វើយ៉ាងនេះ លោកហៅថា **ឧបការិយោ** ។ ប៉មទាំងនោះ យកជ័រឈើ និងកក់ បូកលាបខាងលើ ទើបឈ្មោះថា **អទ្ធាវលេបនា** ។ បទថា **បក្ខន្ទន្តិ** សេចក្ដីថា ជនទាំងឡាយ ត្រូវចាក់ដោយលំពែងដែក និងលំពែងឈើ ដែលគេបន្ទប់ក្រោមប៉មទាំងនោះ មិនអាចឡើងទៅបាន ព្រោះកំពែងរអិល ក៏នៅតែរត់ចូលទៅនោះឯង ។ បទថា **ឧសភាកាយា** បានដល់ ដោយគោម័យដែលដុតឲ្យក្ដៅ ។ បទថា **អភិវ-គ្គេន** បានដល់ ដោយអន្ទប់ ដែលមានធ្មេញ ១០០ មនុស្សទាំងឡាយធ្វើអន្ទប់ដែលមានធ្មេញ ៨ នោះ ដោយអាការដូចគ្នានឹងរនាស់ឈរខាងលើទ្វារ កាត់ខ្សែដែលចង គ្រងអន្ទប់នោះ ហើយសង្កត់មនុស្សដែលមកដោយគិតថា អញនឹងទម្លាយ ទ្វារនគរចូលទៅដោយអន្ទប់នោះ ។

បទថា **សន្ធិម្បិ ឆិន្ទន្តិ** បានដល់ ចោរទាំងឡាយ រមែងកាត់នូវទី-តរបស់ផ្ទះខ្លះ ។ បទថា **និល្លោបំ** បានដល់ ប្រទូស្តអ្នកស្រុក ហើយធ្វើការប្លន់ ។ បទថា **ឯកាគារិកំ** បានដល់ ចោរ ៥០ នាក់ខ្លះ ៦០ នាក់ខ្លះ ព័ទ្ធចាប់ ហើយប្លន់យកទ្រព្យទៅ ។ បទថា **បរិបន្ថេបិ តិដ្ឋន្តិ** បានដល់ ប្លន់អ្នកដំណើរខ្លះ ។ បទថា **អឌ្ឍធណ្ឌកេហិ** បានដល់ ដោយព្រនង់ ។ បទដ៏សេស មានន័យដូចពោលហើយនោះឯង ។៙

# សុត្តន្តបិដក

[ ២៩៤ ] បុគ្គលឃើញភ័យនុ៎ះ ក្នុងកាមគុណទាំងឡាយថា នេះជាចង្រៃ ជាបូស ជាឧបទ្រព ជរោគ ជាព្រួញ និងជាភ័យរបស់អញហើយ គប្បីប្រព្រឹត្តម្នាក់ឯង ដូចកុយរមាស ។

[ ២៩៥ ] ពាក្យថា នេះជាចង្រៃ ជាបូស ជាឧបទ្រព ជារោគ ជាព្រួញ និងជាភ័យរបស់អញ អធិប្បាយថា ព្រះមានព្រះភាគ បានត្រាស់ព្រះតម្រាស់នេះថា ម្នាលភិក្ខុទាំងឡាយ ពាក្យថា ភ័យនេះ ជាឈ្មោះនៃកាមទាំងឡាយ ម្នាលភិក្ខុទាំងឡាយ ពាក្យថា ទុក្ខនេះ ជាឈ្មោះនៃកាមទាំងឡាយ ម្នាលភិក្ខុទាំងឡាយ ពាក្យថា រោគនេះ ជាឈ្មោះនៃកាមទាំងឡាយ ម្នាលភិក្ខុទាំងឡាយ ពាក្យថា បូសនេះ ជាឈ្មោះនៃកាមទាំងឡាយ ម្នាលភិក្ខុទាំងឡាយ ពាក្យថា ថ្ពក់នេះ ជាឈ្មោះនៃកាមទាំងឡាយ ម្នាលភិក្ខុទាំងឡាយ ពាក្យថា ភាវៈជាប់នេះ ជាឈ្មោះនៃកាមទាំងឡាយ ម្នាលភិក្ខុទាំងឡាយ ពាក្យថា ភក់នេះ ជាឈ្មោះនៃកាមទាំងឡាយ ម្នាលភិក្ខុទាំងឡាយ ពាក្យថា គភ៌នេះ ជាឈ្មោះនៃកាមទាំងឡាយ ម្នាលភិក្ខុទាំងឡាយ ព្រោះហេតុតែពាក្យថាភ័យនេះ ជាឈ្មោះនៃកាមទាំងឡាយ ម្នាលភិក្ខុទាំងឡាយ បានជាសត្វអ្នកត្រេកត្រអាល ដោយកាមរាគនេះ ជាប់ជំពាក់ដោយឆន្ទរាគ ទើបមិនរួចចាកភ័យ ដែលមានក្នុងបច្ចុប្បន្នផង មិនរួចចាកភ័យដែលមានក្នុងបរលោកផង ព្រោះហេតុនោះ ពាក្យថា ភ័យនេះ ជាឈ្មោះនៃកាមទាំងឡាយ ម្នាលភិក្ខុទាំងឡាយ ព្រោះហេតុតែពាក្យថា ទុក្ខនេះ ថារោគ ថាបូស ថាការថ្ពក់ ថាភាវៈជាប់ ថាភក់ ថាគភ៌នេះ ជាឈ្មោះនៃកាមទាំងឡាយ ម្នាលភិក្ខុទាំងឡាយ បានជាសត្វអ្នក

ត្រេកត្រអាលដោយកាមរាគនេះ ជាប់ជំពាក់ដោយឆន្ទរាគ ទើបមិនរួចចាក គតិ ដែលមានក្នុងបច្ចុប្បន្នផង មិនរួចចាកគតិ ដែលមានក្នុងបរលោកផង ព្រោះហេតុនោះ ពាក្យថា គតិនេះ ជាឈ្មោះនៃកាមទាំងឡាយ ។

បុថុជ្ជន ជាប់ក្នុងកាមទាំងឡាយណា កាមទាំងឡាយនុ៎ះ ព្រះមាន
ព្រះភាគត្រាស់ហៅថា ភ័យផង ទុក្ខផង រោគផង ភាវៈជាប់ផង
ភក់ផង ធម្មជាតទាំងពីរ គឺការជ្លក់ផង គតិផង ជាសត្វត្រូវរាគៈ
មានសភាពធ្លាញ់សម្រុតហើយ តែងទៅកាន់គតិ ។ ម្នាលភិក្ខុទាំង
ឡាយ លុះណាតែភិក្ខុមិនលះបង់ឈាន ទើបភិក្ខុនោះកន្លងផុតផ្លូវ
មានភក់ គឺកាមនេះជាផ្លូវមានបែបដូច្នោះ ហើយសម្លឹងមើលនូវ
ពួកសត្វ ដែលប្រកបដោយជាតិ និងជរា កំពុងញញាក់ញញ័រ ។

ហេតុនោះ ( លោកពោលថា ) នេះជាចង្រៃ ជាបូស ជាឧបទ្រព ជារោគ ជាព្រួញ និងជាភ័យរបស់អញ ។

[ ២៩៦ ] ពាក្យថា បុគ្គលឃើញភ័យនុ៎ះ ក្នុងកាមគុណទាំងឡាយ គឺ ឃើញ មើល ថ្លឹង ត្រួត បញ្ជាក់ ធ្វើឲ្យច្បាស់នូវភ័យនុ៎ះ ក្នុងកាមគុណទាំង ឡាយ ហេតុនោះ ( លោកពោលថា ) បុគ្គលឃើញភ័យនុ៎ះ ក្នុងកាមគុណ ទាំងឡាយ ។ គប្បីប្រព្រឹត្តម្នាក់ឯង ដូចកុយរមាស ។ ហេតុនោះ ព្រះ បច្ចេកសម្ពុទ្ធនោះពោលថា

បុគ្គលឃើញភ័យនុ៎ះ ក្នុងកាមគុណទាំងឡាយថា នេះជាចង្រៃ ជា
បូស ជាឧបទ្រព ជារោគ ជាព្រួញ និងជាភ័យរបស់អញហើយ
គប្បីប្រព្រឹត្តម្នាក់ឯង ដូចកុយរមាស ។

# អដ្ឋកថា

## គាថាទី ៧

គប្បីជ្រាបវិនិច្ឆ័យក្នុងគាថាទី ៧ ដូចតទៅនេះ

[ ២៩៤ ] កាម ឈ្មោះថា **ឦតិ** ព្រោះជាចង្រៃ ។ ពាក្យនេះ ជាឈ្មោះនៃហេតុវិនាសទាំងឡាយ ដែលជាចំណែកនៃអកុសលដែលចរមក ។ ព្រោះដូច្នោះ កាមគុណទាំងនេះ ក៏ឈ្មោះថា **ឦតិ** ព្រោះនាំមកនូវសេចក្តីវិនាសមិនតិច និងព្រោះលិចចុះយ៉ាងធ្ងន់ ។ បូសក៏ជារបស់មិនស្អាត រមែងហូរចេញ រមែងទុំ បែកហូរខ្ទុះចេញ ព្រោះហេតុនោះ កាមគុណទាំងនោះ ឈ្មោះថា ដូចជាបូស ព្រោះជាទីហូរចេញនៃរបស់មិនស្អាត គឺកិលេស និងព្រោះហើម ទុំបែកហូរខ្ទុះចេញដោយការកើត ការចាស់ និងការបែកធ្លាយ ។ ឈ្មោះថា **ឧបទ្ទវោ** ព្រោះជាប់ជំពាក់ អធិប្បាយថា ឧបទ្រវញ៉ាំងសេចក្តីវិនាសឲ្យកើតឡើង គ្របសង្កត់នូវបុគ្គល ដែលជាប់ក្នុងកាមនោះ ។ ពាក្យនេះ ជាឈ្មោះនៃទោសទាំងឡាយ មានអាជ្ញាផែនដីជាដើម ។ ព្រោះដូច្នោះ ទើបកាមគុណទាំងនេះ ឈ្មោះថា ឧបទ្រវ ព្រោះជាហេតុមិនឲ្យបុគ្គលដល់នូវប្រយោជន៍ គឺព្រះនិព្វានដែលខ្លួនមិនទាន់ដឹងហើយ និងព្រោះជាទីតាំងនៃអន្តរាយទាំងពួង ព្រោះហេតុដែលកាមគុណទាំងនេះ ញ៉ាំងនូវការក្តៅក្រហាយ ព្រោះកិលេសឲ្យកើត ឬញ៉ាំងនូវសេចក្តីប្រាថ្នាក្នុងការមិនមានរោគពោល គឺភាពជាប្រក្រតីឲ្យកើតឡើង រមែងទម្លាយនូវការមិនមានរោគ គឺភាពជាប្រក្រតីនោះឯង ដូច្នោះ ទើបកាម ឈ្មោះថា រោគ ព្រោះអត្ថថា ទម្លាយនូវការមិនមានរោគ ។ មួយវិញទៀត ឈ្មោះថា **សល្លំ** ព្រោះអត្ថថា ចាក់ចូលទៅ

ខាងក្នុង ព្រោះអត្ថថា ទម្ងុះខាងក្នុង និងព្រោះអត្ថថា ដកបានដោយក្រ ។ ឈ្មោះថា **ភយំ** ព្រោះនាំភ័យក្នុងបច្ចុប្បន្ន និងភពខាងមុខមកឲ្យ ។ បទថា **មេតំ** កាត់បទជា **មេ ឯតំ** ។ បទដ៏សេស ក្នុងទីនេះប្រាកដច្បាស់ហើយនោះឯង ។ និគមគាថា គប្បីជ្រាបដោយន័យដូចពោលហើយនោះឯង ។

[ ២៩៥ ] បទថា **កាមរាគរត្តាយំ** បានដល់ សត្វនេះតម្រេកហើយដោយកាមរាគៈ ។ បទថា **ឆន្ទរាគវិនិពន្ធោ** បានដល់ ដែលឆន្ទរាគៈ គឺសេចក្តីស្នេហាចងភ្ជាក់ ។ បទថា **ទិដ្ឋធម្មិកាបិ គន្ថា** បានដល់ ចាកគតិ គឺសឡាយតនៈ ដែលប្រព្រឹត្តទៅក្នុងអត្តភាពនេះ ។ បទថា **សម្បរាយិកាបិ ភគ្គា** បានដល់ ចាកគតិ គឺសឡាយតនៈក្នុងលោកខាងមុខ ។ បទថា **ន បរិមុច្ចតិ** បានដល់ មិនអាចផុតទៅបាន ។ បទថា **ឱតិណ្ណោ សាតរូបេន** សេចក្តីថា ឈានចុះ ឈមចុះដោយរាគៈ ដែលមានសភាពឆ្ងាញ់ ។ បទថា **បលិបថំ** បានដល់ ឈានចុះកាន់ផ្លូវ មានភក់ គឺកាម ។ បទថា **ទុគ្គំ** បានដល់ ទៅបានដោយក្រ ។៚

**អដ្ឋកថា គាថាទី ៧ ចប់**

# សុត្តន្តបិដក

[ ២៩៧ ] បុគ្គលគ្របសង្កត់ នូវធម្មជាតទាំងអស់នុ៎ះ គឺត្រជាក់ ក្ដៅ គម្លាន សម្រេក ខ្យល់ និងកម្ដៅថ្ងៃ របោម និងសត្វលូន ហើយ គប្បីប្រព្រឹត្តម្នាក់ឯង ដូចកុយរមាស ។

[ ២៩៨ ] ពាក្យថា ត្រជាក់ ក្ដៅ គម្លាន សម្រេក សេចក្ដីថា ត្រជាក់ដោយហេតុ ២ គឺត្រជាក់ដោយអំណាចកម្រើកធាតុខាងក្នុង ឬត្រជាក់ដោយអំណាចរដូវខាងក្រៅ ។ ពាក្យថា ក្ដៅ បានដល់ ក្ដៅដោយហេតុ ២ គឺ ក្ដៅដោយអំណាចកម្រើកធាតុខាងក្នុង ឬក្ដៅដោយអំណាចរដូវខាងក្រៅ ។ ដែលហៅថា គម្លាន បានដល់ សេចក្ដីឃ្លាន ។ ដែលហៅថា សម្រេក បានដល់ ការស្រេកទឹក ហេតុនោះ ( លោកពោលថា ) ត្រជាក់ ក្ដៅ គម្លាន សម្រេក ។

[ ២៩៩ ] ពាក្យថា ខ្យល់ និងកម្ដៅថ្ងៃ របោម និងសត្វលូន ត្រង់ពាក្យថា ខ្យល់ គឺខ្យល់ខាងកើត ខ្យល់ខាងលិច ខ្យល់ខាងជើង ខ្យល់ខាងត្បូង ខ្យល់មានធូលី ខ្យល់ត្រជាក់ ខ្យល់ក្ដៅ ខ្យល់រំភើយ ខ្យល់យ៉ាងខ្លាំង ខ្យល់កំបុតត្បូង ខ្យល់គ្រុឌ ខ្យល់ស្លឹកត្នោត ខ្យល់ផ្លិត ។ ដែលហៅថា កម្ដៅថ្ងៃ បានដល់ កម្ដៅព្រះអាទិត្យ ។ ដែលហៅថា របោម បានដល់ ពួកមក្ខិកាលឿង ។ ដែលហៅថា សត្វលូន បានដល់ ពួកសត្វពស់ ហេតុនោះ ( លោកពោលថា ) ខ្យល់ និងកម្ដៅថ្ងៃ របោម និងសត្វលូន ។

[ ៣០០ ] ពាក្យថា បុគ្គលគ្របសង្កត់ នូវធម្មជាតទាំងអស់ទុំះ គឺគ្រប សង្កត់ បង្ក្រប សង្កត់សង្កិន ញាំញី ហេតុនោះ ( លោកពោលថា ) បុគ្គល គ្របសង្កត់ នូវធម្មជាតទាំងអស់ទុំះ ។ គប្បីប្រព្រឹត្តម្នាក់ឯង ដូចកុយរមាស ។ ហេតុនោះ ព្រះបច្ចេកសម្ពុទ្ធនោះពោលថា

បុគ្គលគ្របសង្កត់ នូវធម្មជាតទាំងអស់ទុំះ គឺត្រជាក់ កម្តៅ គម្លាន
សម្រេក ខ្យល់ និងកម្តៅថ្ងៃ របោម និងសត្វលូនហើយ គប្បី
ប្រព្រឹត្តម្នាក់ឯង ដូចកុយរមាស ។

# អដ្ឋកថា

## គាថាទី ៨

គប្បីជ្រាបវិនិច្ឆ័យក្នុងគាថាទី ៨ ដូចតទៅនេះ

[ ២៩៧ ] បទថា **សីតំ** បានដល់ រងា មាន ២ យ៉ាង គឺធាតុខាងក្នុងកម្រើកជាបច្ច័យ ១ ធាតុខាងក្រៅកម្រើកជាបច្ច័យ ១ ។ កម្តៅក៏ដូចគ្នា ។ ក្នុងបទទាំងនោះ បទថា **ឌំស** បានដល់ សត្វល្អិតភ្នែកលឿង ។ បទថា **សរីសបេ** បានដល់ សត្វលូនវារពួកណាមួយ ដែលលូនវារទៅ ។ បទដ៏សេស ប្រាកដច្បាស់ទាំងអស់ហើយ ។ សូម្បីនិគមគាថា ក៏គប្បីជ្រាបដោយន័យដែលពោលហើយនោះឯង ។៚

**អដ្ឋកថា គាថាទី ៨ ចប់**

# សុត្តន្តបិដក

[ ៣០១ ] បុគ្គលដូចនាគ មានខន្ធកើតព្រមហើយ មានសម្បុរដូច
ផ្កាឈូក ជាសត្វធំខ្ពស់ គេចចាកហ្វូង ហើយនៅក្នុងព្រៃតាម
សប្បាយ គប្បីប្រព្រឹត្តម្នាក់ឯង ដូចកុយរមាស ។

[ ៣០២ ] ពាក្យថា ដូចនាគគេចចាកហ្វូង អធិប្បាយថា ដំរីដ៏ប្រសើរ លោកហៅថា នាគ ។ ព្រះបច្ចេកសម្ពុទ្ធ ក៏ឈ្មោះនាគដែរ ។ ព្រះបច្ចេក-សម្ពុទ្ធ ឈ្មោះថា នាគ ព្រោះហេតុអ្វី ។ ឈ្មោះថា នាគ ព្រោះហេតុមិនធ្វើអំពីអាក្រក់ ។ ឈ្មោះថា នាគ ព្រោះហេតុមិនលុះ ។ ឈ្មោះថា នាគ ព្រោះហេតុមិនមក ។

ព្រះបច្ចេកសម្ពុទ្ធនោះ ឈ្មោះថា នាគ ព្រោះហេតុមិនធ្វើអំពើអាក្រក់ តើដូចម្តេច ។ ធម៌ទាំងឡាយជាអកុសលដ៏លាមក ប្រកបដោយសេចក្តីសៅហ្មង នាំសត្វឲ្យកើតក្នុងភពថ្មី ប្រកបដោយសេចក្តីក្រវល់ក្រវាយ មានទុក្ខជាវិបាក ជាទីតាំងនៃជាតិ ជរា និងមរណៈតទៅ លោកហៅថា អំពើអាក្រក់ ។

ព្រះបច្ចេកសម្ពុទ្ធ មិនធ្វើអំពើអាក្រក់តិចតួចក្នុងលោក លះបង់
កិលេស ជាគ្រឿងប្រកបទាំងពួង និងចំណងទាំងឡាយ ផុតស្រឡះ
មិនជាប់ជំពាក់ ក្នុងអារម្មណ៍ទាំងពួង មិនរំភើបដោយលោកធម៌
លោកហៅថា នាគ ព្រោះទ្រង់គុណប្រាកដ ដូច្នោះ ។

ព្រះបច្ចេកសម្ពុទ្ធនោះ ឈ្មោះថា នាគ ព្រោះហេតុមិនធ្វើនូវអំពើអាក្រក់យ៉ាងនេះឯង ។

ព្រះបច្ចេកសម្ពុទ្ធនោះ ឈ្មោះថា នាគ ព្រោះហេតុមិនលុះ តើដូចម្ដេច ។ ព្រះបច្ចេកសម្ពុទ្ធនោះ មិនលុះឆន្ទាគតិ មិនលុះទោសាគតិ មិនលុះមោហាគតិ មិនលុះភយាគតិ មិនលុះដោយអំណាចរាគៈ មិនលុះដោយអំណាចទោសៈ មិនលុះដោយអំណាចមោហៈ មិនលុះដោយអំណាចមានះ មិនលុះដោយអំណាចទិដ្ឋិ មិនលុះដោយអំណាចឧទ្ធច្ចៈ មិនលុះដោយអំណាចវិចិកិច្ឆា មិនលុះដោយអំណាចអនុស័យ មិនត្រូវធម៌ជាពួកនាំទៅ ដឹកទៅ បន្សាត់ទៅ កួចទៅ ព្រះបច្ចេកសម្ពុទ្ធនោះ ឈ្មោះថា នាគ ព្រោះហេតុមិនលុះយ៉ាងនេះឯង ។

ព្រះបច្ចេកសម្ពុទ្ធ ឈ្មោះថា នាគ ព្រោះហេតុមិនមក តើដូចម្ដេច ។ កិលេសទាំងឡាយណា ដែលលោកលះបង់ហើយ ដោយសោតាបត្តិមគ្គ លោកមិនមក មិនត្រឡប់មក មិនវិលមក រកកិលេសទាំងនោះទៀត កិលេសទាំងឡាយណា ដែលលោកលះបង់ហើយ ដោយសកទាគាមិមគ្គ អនាគាមិមគ្គ អរហត្តមគ្គ លោកមិនមក មិនត្រឡប់មក មិនវិលមក រកកិលេសទាំងនោះទៀត ព្រះបច្ចេកសម្ពុទ្ធនោះ ឈ្មោះថា នាគ ព្រោះហេតុមិនមកយ៉ាងនេះឯង ។ ពាក្យថា ដូចនាគគេចចាកហ្វូង បានសេចក្ដីថា ដំរីដ៏ប្រសើរនោះ វៀរលែង ចៀសវាង វៀរស្រឡះនូវហ្វូងទាំងឡាយ ចូលទៅនៅកណ្ដាលព្រៃ ក្នុងអរញ្ញប្រទេស ចរ ត្រាច់ទៅ ប្រព្រឹត្ត រក្សា យាត្រា ឲ្យយាត្រាទៅតែម្នាក់ឯងយ៉ាងណា ចំណែកព្រះបច្ចេកសម្ពុទ្ធ ក៏វៀរលែង ចៀសវាង វៀរស្រឡះនូវពួក ប្រព្រឹត្តនៅតែមួយអង្គឯង ដូចកុយរមាស ទ្រង់គប់រកព្រៃតូច និងព្រៃធំជាសេនាសនៈដ៏ស្ងាត់ មិនមានសំឡេង មិនមានសូរគឹកកង ប្រាសចាកខ្យល់

ដែលកើតអំពីសរីរៈនៃជន ជាសេនាសនៈដ៏ស្ងាត់ចាកមនុស្ស សមគួរដល់ការពួនសម្ងំ ព្រះបច្ចេកសម្ពុទ្ធនោះ និមន្តទៅតែមួយអង្គឯង ឈរតែមួយអង្គឯង គង់នៅតែមួយអង្គឯង សម្រេចការសិងតែមួយអង្គឯង ចូលទៅបិណ្ឌបាតក្នុងស្រុកតែមួយអង្គឯង ត្រឡប់មកវិញតែមួយអង្គឯង គង់ក្នុងទីស្ងាត់តែមួយអង្គឯង អធិដ្ឋានចង្រ្កមតែមួយអង្គឯង ចរ ត្រាច់ទៅ ប្រព្រឹត្ត រក្សា យាត្រា ឲ្យយាត្រាទៅ តែមួយអង្គឯង ( ក៏យ៉ាងនោះដែរ ) ហេតុនោះ ( លោកពោលថា ) ដូចនាគគេចចាកហ្វូង ។

[ ៣០៣ ] ពាក្យថា មានខន្ធកើតព្រមហើយ មានសម្បុរដូចផ្កាឈូក ជាសត្វខ្ពង់ខ្ពស់ អធិប្បាយថា ដំរីដ៏ប្រសើរនោះ មានខន្ធកើតព្រមហើយ ជាដំរី ៧ ហត្ថ ឬ ៨ ហត្ថ យ៉ាងណា ឯព្រះបច្ចេកសម្ពុទ្ធ ក៏មានខន្ធកើតព្រមហើយ ដោយអសេក្ខសីលក្ខន្ធ អសេក្ខសមាធិក្ខន្ធ អសេក្ខបញ្ញាខន្ធ អសេក្ខវិមុត្តិក្ខន្ធ អសេក្ខវិមុត្តិញាណទស្សនក្ខន្ធ ក៏យ៉ាងនោះ ។ ដំរីដ៏ប្រសើរនោះ មានផ្កាឈូកយ៉ាងណា ឯព្រះបច្ចេកសម្ពុទ្ធ ឈ្មោះថាមានផ្កាឈូក ដោយផ្កា គឺពោជ្ឈង្គ ៧ គឺដោយផ្កា គឺសតិសម្ពោជ្ឈង្គ ១ ផ្កា គឺធម្មវិចយសម្ពោជ្ឈង្គ ១ ផ្កា គឺវីរិយសម្ពោជ្ឈង្គ ១ ផ្កា គឺបីតិសម្ពោជ្ឈង្គ ១ ផ្កា គឺបស្សទ្ធិសម្ពោជ្ឈង្គ ១ ផ្កា គឺសមាធិសម្ពោជ្ឈង្គ ១ ផ្កា គឺឧបេក្ខសម្ពោជ្ឈង្គ ១ ( យ៉ាងនោះដែរ ) ។ ដំរីដ៏ប្រសើរនោះ ជាសត្វលើសលុបដោយកម្លាំងកាយ កម្លាំងចិត្ត សម្ទុះ និងសេចក្ដីក្លៀវក្លា យ៉ាងណា ឯព្រះបច្ចេកសម្ពុទ្ធ ក៏ជាបុគ្គលលើសលុបដោយសីល សមាធិ បញ្ញា វិមុត្តិ និងវិមុត្តិញាណទស្សនៈ

( យ៉ាងនោះដែរ ) ហេតុនោះ ( លោកពោលថា ) មានខន្ធកើតព្រមហើយ មានសម្បុរដូចផ្កាឈូក ជាសត្វ ខ្ពង់ខ្ពស់ ។

[ ៣០៤ ] ពាក្យថា នៅក្នុងព្រៃតាមសប្បាយ សេចក្តីថា ដំរីដ៏ប្រសើរនោះ នៅក្នុងព្រៃតាមសប្បាយ យ៉ាងណា ឯព្រះបច្ចេកសម្ពុទ្ធ ក៏នៅក្នុងព្រៃតាមសប្បាយ ( យ៉ាងនោះដែរ ) គឺនៅក្នុងព្រៃតាមសប្បាយ ដោយបឋមជ្ឈានខ្លះ នៅក្នុងព្រៃតាមសប្បាយ ដោយទុតិយជ្ឈានខ្លះ តតិយជ្ឈានខ្លះ ចតុត្ថជ្ឈានខ្លះ នៅក្នុងព្រៃតាមសប្បាយ ដោយមេត្តាចេតោវិមុត្តិខ្លះ នៅក្នុងព្រៃតាមសប្បាយ ដោយករុណាចេតោវិមុត្តិខ្លះ មុទិតាចេតោវិមុត្តិខ្លះ ឧបេក្ខាចេតោ-វិមុត្តិខ្លះ នៅក្នុងព្រៃតាមសប្បាយ ដោយអាកាសានញ្ចាយតនសមាបត្តិខ្លះ នៅក្នុងព្រៃតាមសប្បាយ ដោយវិញ្ញាណញ្ចាយតនសមាបត្តិខ្លះ ដោយអាកិញ្ចញ្ញា-យតនសមាបត្តិខ្លះ ដោយនេវសញ្ញានាសញ្ញាយតនសមាបត្តិខ្លះ ដោយផលសមាបត្តិខ្លះ ហេតុនោះ ( លោកពោលថា ) នៅក្នុងព្រៃតាមសប្បាយ ។ គប្បីប្រព្រឹត្តម្នាក់ឯង ដូចកុយរមាស ។ ហេតុនោះ ព្រះបច្ចេកសម្ពុទ្ធនោះពោលថា

> បុគ្គលដែលដូចនាគ មានខន្ធកើតព្រមហើយ មានសម្បុរដូចផ្កា
> ឈូក ជាសត្វខ្ពង់ខ្ពស់ គេចចាកហ្វូង ហើយនៅក្នុងព្រៃតាម
> សប្បាយ គប្បីប្រព្រឹត្តម្នាក់ឯង ដូចកុយរមាស ។

# អដ្ឋកថា

## គាថាទី ៩

[ ៣០១ ] គាថាទី ៩ ប្រាកដហើយ ដោយអត្ថនៃបទនោះឯង ។ ក្នុងគាថានេះ មានយោជនាដូចតទៅ គាថានោះ ប្រាកដដោយសេចក្តីត្រឹមត្រូវ ( យុត្តិ ) មិនប្រាកដដោយការស្តាប់តាមគ្នាមក ។ ដំរីនេះ ឈ្មោះថា **នាគ** ព្រោះមិនមកកាន់ទីដែលមិនបានទូន្មាន ព្រោះទូន្មានក្នុងសីល ដែលពួកមនុស្សពេញចិត្ត ឬព្រោះជាសត្វមានកាយធំ យ៉ាងណា សូម្បីអាត្មាក៏ដូច្នោះ ឈ្មោះថា នាគ ព្រោះមិនមកកាន់ទីដែលមិនបានទូន្មាន ព្រោះមិនធ្វើបាប និងព្រោះមិនត្រឡប់មកកាន់ភាពជាយ៉ាងនេះទៀត ព្រោះទូន្មានហើយក្នុងសីលទាំងឡាយដែលព្រះអរិយៈពេញចិត្ត ឬព្រោះហេតុដែលខ្លួនមានសរីរៈ គឺគុណធំ ។ ដំរីនេះ លះនូវហ្វូងហើយ នៅក្នុងព្រៃតាមពេញចិត្ត ដោយសេចក្តីសុខដែលកើតអំពីការត្រាច់ទៅម្នាក់ឯង គប្បីត្រាច់ទៅម្នាក់ឯង ដូចកុយរមាស ដូច្នោះ យ៉ាងណា សូម្បីអាត្មាក៏យ៉ាងនោះ លះពួកគណៈហើយ នៅក្នុងព្រៃតាមគាប់ចិត្ត ដោយសុខដែលមានតែការត្រេកអរក្រៃលែង ដោយចំណែកមួយ គឺដោយសេចក្តីសុខកើតអំពីឈាន ប្រាថ្នាសេចក្តីសុខ តាមដែលខ្លួនគប្បីរកបាននៅក្នុងព្រៃនោះ គប្បីត្រាច់ទៅម្នាក់ឯង ដូចកុយរមាស ដូច្នោះ ។

ម្យ៉ាងទៀត ដំរីនោះ ឈ្មោះថា មានខន្ធកើតព្រមហើយ ព្រោះមានរាងកាយតាំងនៅបានយ៉ាងល្អ យ៉ាងណា សូម្បីអាត្មាក៏យ៉ាងនោះ ឈ្មោះថា ជាអ្នកមានខន្ធកើតល្អហើយ ព្រោះភាពជាធំដោយសីលក្ខន្ធដែលជាអសេក្ខៈ ។ ម្យ៉ាងទៀត ដំរីនោះ ឈ្មោះថា មានខ្លួនដូចផ្កាឈូក ព្រោះមានរាងកាយដូចគ្នា

នឹងផ្កាឈូក ឬព្រោះកើតក្នុងត្រកូលដ៏វិបទុម យ៉ាងណា អាត្មាក៏យ៉ាងនោះ ឈ្មោះថា ជា **បទុមី** ព្រោះមានធម៌ គឺពោជ្ឈង្គ ដូចគ្នានឹងផ្កាឈូក ឬព្រោះកើតក្នុងផ្កាឈូក គឺអរិយជាតិ ។ម្យ៉ាងទៀត ដំរីនោះ ឈ្មោះថា **ឧឡារោ** ព្រោះមានថាមពល និងកម្លាំងរហ័សជាដើម យ៉ាងណា ឯអាត្មាក៏យ៉ាងនោះ ឈ្មោះថា **ឧឡារោ** ព្រោះមានការប្រព្រឹត្តប្រពៃផ្លូវកាយបរិសុទ្ធជាដើម ឬព្រោះមានសីល សមាធិ និងបញ្ញាមុតស្រួចជាដើម ។ អាត្មាកាលគិតយ៉ាងនេះ ទើបផ្ដើមវិបស្សនា ហើយសម្រេចបច្ចេកសម្ពោធិញ្ញាណ ដោយប្រការដូច្នេះ ៕

## អដ្ឋកថា គាថាទី ៩ ចប់

# សុត្តន្តបិដក

[ ៣០៥ ] បុគ្គល គប្បីបានសាមយិកវិមុត្តិ ( វិមុត្តិប្រព្រឹត្តទៅតាមសម័យ គឺវិមុត្តិជាលោកិយ ) ដោយហេតុណា ហេតុនោះមិនមែនជាទីតាំង នៃបុគ្គលអ្នកត្រេកអរក្នុងពួកទេ បុគ្គលពិចារណាពាក្យនៃព្រះពុទ្ធ ជាព្រះអាទិច្ចពន្ធុហើយ គប្បីប្រព្រឹត្តម្នាក់ឯងដូចកុយរមាស ។

[ ៣០៦ ] ពាក្យថា បុគ្គលគប្បីបានសាមយិកវិមុត្តិ ដោយហេតុណា ហេតុនោះ មិនមែនជាទីតាំង នៃបុគ្គលអ្នកត្រេកអរក្នុងពួកទេ អធិប្បាយថា មែនពិត ព្រះមានព្រះភាគ បានត្រាស់ព្រះពុទ្ធដីកានេះថា ម្នាលអានន្ទ ភិក្ខុមានការនៅប្រឡូកប្រឡំ ដោយពួកជាទីត្រេកអរ ត្រេកអរក្នុងការនៅប្រឡូកប្រឡំដោយពួក ប្រកបរឿយៗ នូវសេចក្តីត្រេកអរ ក្នុងការនៅប្រឡូកប្រឡំដោយពួក មានពួកជាទីត្រេកអរ ត្រេកអរក្នុងពួក រួសរាយក្នុងពួក ប្រកបរឿយៗ នូវសេចក្តីត្រេកអរក្នុងពួក ជាកំណត់ សេចក្តីសុខក្នុងការចេញបួស សេចក្តីសុខក្នុងការស្ងាត់ សេចក្តីសុខក្នុងការស្ងប់ សេចក្តីសុខក្នុងការត្រាស់ដឹងណា ( ភិក្ខុនោះ ) នឹងជាអ្នកបានតាមប្រាថ្នា បានដោយមិនក្រ បានដោយមិនលំបាក នូវសេចក្តីសុខនោះ ហេតុការណ៍បែបនេះ មិនមានទេ ។ ម្នាលអានន្ទ លុះតែភិក្ខុណាចៀសចេញចាកពួក ហើយនៅតែម្នាក់ឯង សេចក្តីសុខនុ៎ះ ទើបមានប្រាកដដល់ភិក្ខុនោះ គឺថា សេចក្តីសុខក្នុងការចេញបួស សេចក្តីសុខក្នុងការស្ងាត់ សេចក្តីសុខក្នុងការស្ងប់ សេចក្តីសុខក្នុងការត្រាស់ដឹងណា ( ភិក្ខុនោះ ) នឹងជាអ្នកបានតាមប្រាថ្នា បានដោយមិនក្រ បានដោយ

មិនលំបាក នូវសេចក្ដីសុខនោះ ហេតុការណ៍បែបនេះ ទើបមាន ។ ម្នាលអានន្ទ ភិក្ខុមានការនៅប្រឡូកប្រឡំដោយពួក ជាទីត្រេកអរ ត្រេកអរក្នុងការនៅប្រឡូកប្រឡំដោយពួក ប្រកបរឿយៗ នូវសេចក្ដីត្រេកអរ ក្នុងការនៅប្រឡូកប្រឡំដោយពួក មានពួកជាទីត្រេកអរ ត្រេកអរក្នុងពួក រួសរាយក្នុងពួក ប្រកបរឿយៗ នូវសេចក្ដីត្រេកអរក្នុងពួក ជាកំណត់ ( ភិក្ខុនោះ ) នឹងបានសាមយិកចេតោវិមុត្តិ ( ចេតោវិមុត្តិជាលោកិយ ) ឬអសាមយិកអកុប្បធម៌ ( មគ្គជាលោកុត្តរ ) ហេតុការណ៍ បែបនេះ មិនមានទេ ។ ម្នាលអានន្ទ លុះតែភិក្ខុណាចៀសចេញចាកពួក ហើយនៅតែម្នាក់ឯង សេចក្ដីសុខនោះ ទើបមានប្រាកដដល់ភិក្ខុនោះ គឺថា ( ភិក្ខុនោះ ) នឹងបានសាមយិកចេតោវិមុត្តិ ឬអសាមយិកអកុប្បធម៌ ហេតុការណ៍បែបនេះ ទើបមាន ហេតុនោះ ( លោកពោលថា ) បុគ្គលគប្បីបានសាមយិកវិមុត្តិ ដោយហេតុណា ហេតុនោះ មិនមែនជាទីតាំងនៃបុគ្គល អ្នកត្រេកអរក្នុងពួកទេ ។

[ ៣០៧ ] ពាក្យថា បុគ្គលពិចារណាពាក្យនៃព្រះពុទ្ធ ជាព្រះអាទិច្ចពន្ធុ សេចក្ដីថា ព្រះអាទិត្យ លោកហៅថា អាទិច្ចៈ ។ ព្រះអាទិត្យនោះ ជាគោតមដោយគោត្ត ចំណែកព្រះបច្ចេកសម្ពុទ្ធ ក៏ជាគោតមដោយគោត្ត ព្រះបច្ចេក-សម្ពុទ្ធ ជាញាតិដោយគោត្ត ជាផៅពង្សដោយគោត្តនៃព្រះអាទិត្យ ព្រោះហេតុនោះ ព្រះបច្ចេកសម្ពុទ្ធ ឈ្មោះថា ព្រះអាទិច្ចពន្ធុ ។ ពាក្យថា បុគ្គលពិចារណាពាក្យនៃព្រះពុទ្ធ ជាព្រះអាទិច្ចពន្ធុ បានសេចក្ដីថា បុគ្គលបានស្ដាប់ ឮ រៀនចាំទុក កំណត់នូវពាក្យ គន្លងពាក្យ ទេសនា អនុសន្ធិនៃព្រះពុទ្ធ ជាព្រះ

អាទិច្ចពន្ធុ ហេតុនោះ ( លោកពោលថា ) បុគ្គលពិចារណាពាក្យនៃព្រះពុទ្ធ ជាព្រះអាទិច្ចពន្ធុ ។ គប្បីប្រព្រឹត្តម្នាក់ឯង ដូចកុយរមាស ។ ហេតុនោះ ព្រះបច្ចេកសម្ពុទ្ធនោះពោលថា

បុគ្គល គប្បីបានសាមយិកវិមុត្តិ ដោយហេតុណា ហេតុនោះ មិនមែនជាទីតាំង នៃបុគ្គលអ្នកត្រេកអរក្នុងពួកទេ បុគ្គលពិចារណាពាក្យនៃព្រះពុទ្ធ ជាព្រះអាទិច្ចពន្ធុហើយ គប្បីប្រព្រឹត្តម្នាក់ឯង ដូចកុយរមាស ។

# អដ្ឋកថា

## គាថាទី ១០

គប្បីជ្រាបវិនិច្ឆ័យក្នុងគាថាទី ១០ ដូចតទៅនេះ

[ ៣០៥ ] បទថា **អដ្ឋាន តំ** គឺ **អដ្ឋានំ តំ** អធិប្បាយថា នុ៎ះមិនមែនហេតុ ។ លោកលុបនិគ្គហិតចេញ ជា **អដ្ឋាន** ដូចក្នុងបទជាដើមថា **អរិយសច្ចាន ទស្សនំ** ដូច្នេះ ។ បទថា **សង្គណិការតស្ស** បានដល់ដែលត្រេកអរដោយពួក ។ បទថា **យំ** នេះ ជាពាក្យសម្ដែងដល់ហេតុ ដូចក្នុងបទថា **យំ ហិរីយតិ ហិរីយិតព្វេន** ត្រង់ដែលបុគ្គលខ្មាស ដោយអំពើដែលគួរខ្មាសជាដើម ។ បទថា **ផុស្សយេ** បានដល់ គប្បីដក់ ។ បទថា **សាមយិកំ វិមុត្តិំ** បានដល់ លោកិយសមាបត្តិ ។ ពិតហើយ លោកិយ-សមាបត្តិនោះ លោកហៅថា សាមយិកវិមុត្តិ ព្រោះផុតហើយចាកសត្រូវក្នុងសម័យដែលចិត្តអែបនែប ឆ្អែតស្កប់ស្កល់នោះឯង ។ នូវវិមុត្តិដែលមានក្នុងសម័យនោះ ។ ព្រះបច្ចេកពុទ្ធពោលថា អាត្មាពិចារណាពាក្យរបស់ព្រះបច្ចេកពុទ្ធព្រះនាមអាទិច្ចពន្ធុដែលពោលថា ការដែលបុគ្គលត្រេកអរដោយការប្រឡូកប្រឡំដោយពួកគណៈហើយ គប្បីសម្រេចវិមុត្តិ មិនមែនជាឋានៈមិនមែនជាហេតុឡើយ ហើយលះសេចក្ដីត្រេកអរ ដោយការប្រឡូកប្រឡំដោយពួក ដោយគណៈ បដិបត្តិដោយឧបាយ ទើបបានសម្រេច ដូច្នេះ ។ បទដ៏សេស មានន័យដូចពោលហើយនោះឯង ។

[ ៣០៦ ] គប្បីជ្រាបវិនិច្ឆ័យក្នុងនិទ្ទេសដូចតទៅ បទថា **នេក្ខម្មសុខំ**

បានដល់ សេចក្ដីសុខក្នុងបព្វជ្ជា ។ បទថា **បវិវេកសុខំ** បានដល់ សេចក្ដីសុខក្នុងកាយវិវេក ចិត្តវិវេក និងឧបធិវិវេក ។ បទថា **ឧបសមសុខំ** បានដល់ សេចក្ដីសុខដែលកើតអំពីផលសមាបត្តិ ដែលស្ងប់ចាកកិលេស ។ បទថា **សម្ពោធិសុខំ** បានដល់ សេចក្ដីសុខក្នុងមគ្គ ។ បទថា **និកាមលាភី** បានដល់ អ្នកមានប្រក្រតីបានតាមបំណង ដោយអំណាចការពេញចិត្តរបស់ខ្លួន ។ បទថា **អកិច្ឆលាភី** បានដល់ អ្នកមានប្រក្រតីបានមិនលំបាក ។ បទថា **អកសិរលាភី** បានដល់ បានយ៉ាងបរិបូណ៌ ។ បទថា **អសាមយិកំ** បានដល់ លោកុត្តរ ។ បទថា **អកុប្បំ** បានដល់ លោកុត្តរមគ្គ ដែលមិនកម្រើក មិនញាប់ញ័រ ។l

**អដ្ឋកថា គាថាទី ១០ ចប់**

**ទុតិយវគ្គ ចប់**

# សុត្តន្តបិដក

[ ៣០៨ ] បុគ្គលប្រព្រឹត្តកន្លង នូវចម្រូង គឺទិដ្ឋិទាំងឡាយ បាន សម្រេចធម៌ដ៏ទៀងទាត់ បានចំពោះនូវមគ្គ មិនមានបុគ្គលដទៃ ណែនាំ ( ព្រោះដឹងថា ) អាត្មាអញមានញាណកើតហើយ គប្បី ប្រព្រឹត្តម្នាក់ឯង ដូចកុយរមាស ។

[ ៣០៩ ] ពាក្យថា បុគ្គលប្រព្រឹត្តកន្លងនូវចម្រូង គឺទិដ្ឋិទាំងឡាយ សេចក្តីថា សក្កាយទិដ្ឋិមានវត្ថុ ២០ ហៅថា ចម្រូង គឺទិដ្ឋិ ។ បុថុជ្ជនក្នុង លោកនេះ ជាអ្នកមិនចេះដឹង មិនឃើញនូវពួកព្រះអរិយៈ មិនឈ្លាសវៃក្នុង អរិយធម៌ មិនបានទូន្មានខ្លួនក្នុងអរិយធម៌ មិនឃើញពួកសប្បុរស មិន ឈ្លាសវៃក្នុងសប្បុរិសធម៌ មិនបានទូន្មានខ្លួនក្នុងសប្បុរិសធម៌ រមែងពិចារណា ឃើញរូបថាខ្លួន នូវខ្លួនថាមានរូបខ្លះ នូវរូបក្នុងខ្លួនខ្លះ នូវខ្លួនក្នុងរូបខ្លះ ពិចារណាឃើញនូវវេទនា សញ្ញា សង្ខារ វិញ្ញាណថាខ្លួន នូវខ្លួនថាមាន វិញ្ញាណខ្លះ នូវវិញ្ញាណក្នុងខ្លួនខ្លះ នូវខ្លួនក្នុងវិញ្ញាណខ្លះ ទិដ្ឋិ ដំណើរ គឺទិដ្ឋិ ព្រៃស្បាត គឺទិដ្ឋិ ផ្លូវដាច់ស្រយាល គឺទិដ្ឋិ ចម្រូង គឺទិដ្ឋិ សេចក្តីញាប់ញ័រ គឺទិដ្ឋិ ចំណង គឺទិដ្ឋិ ការប្រកាន់ ការប្រកាន់ខ្ជាប់ ការប្រកាន់មាំ ការស្ទាប អង្អែលផ្លូវខុស គន្លងខុស សេចក្តីខុស លទ្ធិដូចជាកំពង់ សេចក្តីប្រកាន់ ដោយការស្វែងរកខុស ការប្រកាន់វិបរិត ការប្រកាន់វិបល្លាស ការប្រកាន់ ខុស ការប្រកាន់ថាពិត ក្នុងរបស់ដែលមិនពិត ទិដ្ឋិ ៦២ ទាំងប៉ុន្មាន មាន សភាពយ៉ាងនេះឯណា នេះ ឈ្មោះថា ចម្រូង គឺទិដ្ឋិ ។ ពាក្យថា ប្រព្រឹត្ត កន្លង គឺប្រព្រឹត្តរំលង ឈានកន្លង ឈានរំលង ប្រព្រឹត្តកន្លង នូវចម្រូង គឺ

ទិដ្ឋិទាំងឡាយ ហេតុនោះ ( លោកពោលថា ) បុគ្គលប្រព្រឹត្តកន្លងនូវចម្រូង គឺទិដ្ឋិទាំងឡាយ ។

[ ៣១០ ] ពាក្យថា បានសម្រេចធម៌ដ៏ទៀងទាត់ បានចំពោះនូវមគ្គ សេចក្តីថា មគ្គ ៤ មគ្គដ៏ប្រសើរប្រកបដោយអង្គ ៨ គឺសម្មាទិដ្ឋិ ១ សម្មា-សង្កប្ប ១ សម្មាវាចា ១ សម្មាកម្មន្តៈ ១ សម្មាអាជីវៈ ១ សម្មាវាយាមៈ ១ សម្មាសតិ ១ សម្មាសមាធិ ១ លោកហៅថា ធម៌ដ៏ទៀង ។ បុគ្គលប្រកប សម្រេច បានប៉ះពាល់ ធ្វើឲ្យជាក់ច្បាស់ ដោយអរិយមគ្គទាំង ៤ ហេតុនោះ ( លោកពោលថា ) បានសម្រេចធម៌ដ៏ទៀងទាត់ ។ ពាក្យថា បានចំពោះនូវមគ្គ គឺបានមគ្គ បានចំពោះមគ្គ បានសម្រេចមគ្គ បានប៉ះពាល់មគ្គ ហេតុនោះ ( លោកពោលថា ) បានសម្រេចធម៌ដ៏ទៀងទាត់ បានចំពោះនូវមគ្គ ។

[ ៣១១ ] ពាក្យថា មិនមានបុគ្គលដទៃណែនាំ ( ព្រោះដឹងថា ) អាត្មាអញមានញាណកើតហើយ អធិប្បាយថា ព្រះបច្ចេកសម្ពុទ្ធនោះ មានញាណកើតឡើង កើតឡើងព្រម កើត កើតចំពោះ កើតប្រាកដ គឺមានញាណកើតឡើង កើតឡើងព្រម កើត កើតចំពោះ កើតប្រាកដថា សង្ខារទាំងពួងមិនទៀង ថាសង្ខារទាំងពួងជាទុក្ខ ។បេ។ មានញាណកើតឡើង កើតឡើងព្រម កើត កើតចំពោះ កើតប្រាកដថា របស់ណាមួយ មានការកើតឡើងជាធម្មតា របស់ទាំងអស់នោះ មានការរលត់ទៅវិញជាធម្មតា ហេតុនោះ ( លោកពោលថា ) អាត្មាអញមានញាណកើតហើយ ។ ពាក្យថា មិនមានបុគ្គលដទៃណែនាំ គឺ ព្រះបច្ចេកសម្ពុទ្ធនោះ មិនមានបុគ្គលដទៃណែនាំ មិនមានបុគ្គលដទៃឲ្យជឿ មិន

មានបុគ្គលដទៃជាទីអាង មិនដល់នូវការជាប់ជំពាក់ ដោយបុគ្គលដទៃ រមែងដឹង ឃើញតាមពិត ជាបុគ្គលមិនវង្វេង ជាអ្នកដឹងច្បាស់ មានស្មារតីប្រុងជានិច្ចថា សង្ខារទាំងពួងមិនទៀង ។បេ។ មិនមានបុគ្គលដទៃណែនាំ មិនមានបុគ្គលដទៃឲ្យជឿ មិនមានបុគ្គលដទៃជាទីអាង មិនដល់នូវការជាប់ជំពាក់ ដោយបុគ្គលដទៃ រមែងដឹង ឃើញតាមពិត ជាបុគ្គលមិនវង្វេង ជាអ្នកដឹងច្បាស់ មានស្មារតីប្រុងជានិច្ចថា របស់ណាមួយ មានការកើតឡើងជាធម្មតា របស់ទាំងអស់នោះ មានការរលត់ទៅវិញជាធម្មតា ហេតុនោះ ( លោកពោលថា ) មិនមានបុគ្គលដទៃណែនាំ ( ព្រោះដឹងថា ) អាត្មាអញមានញាណកើតហើយ ។ គប្បីប្រព្រឹត្តម្នាក់ឯង ដូចកុយរមាស ។ ហេតុនោះ ព្រះបច្ចេកសម្ពុទ្ធនោះពោលថា

> បុគ្គល ប្រព្រឹត្តកន្លងនូវចម្រូង គឺទិដ្ឋិទាំងឡាយ បានសម្រេចធម៌ដ៏ទៀងទាត់ បានចំពោះនូវមគ្គ មិនមានបុគ្គលដទៃណែនាំ ( ព្រោះដឹងថា ) អាត្មាអញមានញាណកើតហើយ គប្បីប្រព្រឹត្តម្នាក់ឯង ដូចកុយរមាស ។

# អដ្ឋកថា

## តតិយវគ្គ

### គាថាទី ១

គប្បីជ្រាបវិនិច្ឆ័យក្នុងគាថាទី ១ នៃវគ្គទី ៣ ដូចតទៅ

[ ៣០៨ ] បទថា **ទិដ្ឋីវិសូកានិ** បានដល់ ទិដ្ឋិ ៦២ ។ ទិដ្ឋិទាំងនោះ ឈ្មោះថា ជាចម្រូង ព្រោះអត្ថថា ប្រទូស្ត ចាក់ដោត ជាសត្រូវដល់សម្មាទិដ្ឋិក្នុងមគ្គ ។ ចម្រូងនៃទិដ្ឋិយ៉ាងនេះ ឈ្មោះថា **ទិដ្ឋីវិសូកានិ** ។ ឬថា ចម្រូងគឺទិដ្ឋិ ឈ្មោះថា **ទិដ្ឋីវិសូកានិ** ។ បទថា **ឧបាតិវត្តោ** បានដល់ កន្លងបានហើយដោយមគ្គទស្សនៈ ។ បទថា **បត្តោ និយាមំ** បានដល់ ដល់នូវភាពជាអ្នកទៀង មិនធ្លាក់ចុះជាធម្មតា និងព្រោះមានការត្រាស់ដឹងខាងមុខ ។ ឬសម្រេចបឋមមគ្គ ដែលបានដល់សម្មត្តនិយាម គឺនិយាមប្រពៃ ដោយហេតុប្រមាណប៉ុណ្ណោះ ដែលលោកពោលដល់សេចក្តីសម្រេចនៃកិច្ចក្នុងបឋមមគ្គ និងការបាននូវបឋមមគ្គនោះ ។ ឥឡូវនេះ ព្រះបច្ចេកសម្ពុទ្ធ សម្តែងដល់ការបានមគ្គដ៏សេស ដោយបទនេះថា **បដិលទ្ធមគ្គោ** ។ បទថា **ឧប្បន្ន-ញាណោម្හិ** បានដល់ អាត្មាជាអ្នកមានបច្ចេកពោធិញ្ញាណកើតឡើងហើយ ។ ព្រះបច្ចេកសម្ពុទ្ធសម្តែងដល់ផល ដោយពាក្យនេះ ។ បទថា **អនញ្ញនេយ្យោ** បានដល់ ដែលបុគ្គលដទៃមិនត្រូវទូន្មានថា នេះជាសច្ចៈ នេះជាសច្ចៈ ដូច្នេះ ។ ព្រះបច្ចេកសម្ពុទ្ធសម្តែងភាពជាព្រះសយម្ភូ ដោយបទនេះ ឬសម្តែងនូវភាពជាអ្នកជំនាញដោយខ្លួនឯង ព្រោះមិនមានអ្នកដទៃដឹកនាំ ក្នុងបច្ចេកពោធិញ្ញាណ

*ដែលខ្លួនសម្រេចហើយ ឬកន្លងនូវចម្រូង គឺទិដ្ឋិទាំងឡាយដោយវិបស្សនា ដល់នូវមគ្គនិយាម ដោយមគ្គខាងដើម ជាអ្នកបានមគ្គដោយមគ្គដ៏សេស ជាអ្នកមានញាណដែលកើតហើយ ដោយផលញ្ញាណ ។ ឈ្មោះថា* **អនញ្ញ-ណេយ្យោ** *ព្រោះសម្រេចធម៌ទាំងអស់នោះដោយខ្លួនឯង ។ បទដ៏សេស គប្បីជ្រាបដោយន័យដែលពោលហើយនោះឯង ។*

*[ ៣១១ ] បទថា* **ន បរណេយ្យោ** *បានដល់ អ្នកដទៃមិនត្រូវទូន្មាន ។ បទថា* **បរបត្តិយោ** *បានដល់ ព្រោះជាធម៌ប្រចក្សហើយ មិនត្រូវជឿអ្នកដទៃ ។ បទថា* **ន បរប្បច្ចយោ** *មានវិគ្គហៈថា ឈ្មោះថា* **ន បរប្បច្ចយោ** *ព្រោះអត្ថថា មិនគប្បីមានអ្នកដទៃជាបច្ច័យ មិនប្រព្រឹត្តទៅដោយសទ្ធារបស់អ្នកដទៃ ។ បទថា* **ន បរប្បដិពទ្ធគូ** *បានដល់ មិនទៅដោយញាណដែលទាក់ទងដោយអ្នកដទៃ ៕*

**អដ្ឋកថា គាថាទី ១ ចប់**

# សុត្តន្តបិដក

[ ៣១២ ] បុគ្គលអ្នកមិនលោភ អ្នកមិនកុហក អ្នកមិនមានការស្រេកឃ្លាន អ្នកមិនមានការលុបគុណគេ មានទឹកចត់ និងមោហៈកម្ចាត់ចេញហើយ មិនមានសេចក្តីប្រាថ្នា ក្នុងលោកទាំងមូល គប្បីប្រព្រឹត្តម្នាក់ឯង ដូចកុយរមាស ។

[ ៣១៣ ] ពាក្យថា បុគ្គលអ្នកមិនលោភ អ្នកមិនកុហក អ្នកមិនមានការស្រេកឃ្លាន អធិប្បាយថា តណ្ហា ហៅថា សេចក្តីលោភ បានដល់ តម្រេក តម្រេកខ្លាំង ។បេ។ អភិជ្ឈា លោភៈ អកុសលមូល ។ តណ្ហា គឺសេចក្តីលោភនោះ ព្រះបច្ចេកសម្ពុទ្ធនោះ បានលះបង់ គាស់រម្លើងឫស ធ្វើឲ្យសល់តែទីនៅ ដូចជាទីនៅនៃដើមត្នោត ឲ្យដល់នូវការមិនកើតមាន ឲ្យជាធម៌លែងកើតឡើងតទៅទៀត ហេតុនោះ ព្រះបច្ចេកសម្ពុទ្ធនោះ ឈ្មោះថា អ្នកមិនមានលោភ ។ ពាក្យថា អ្នកមិនកុហក សេចក្តីថា កុហនវត្ថុ មាន ៣ គឺកុហនវត្ថុប៉ែកខាងការសេពបច្ច័យ ១ កុហនវត្ថុ ប៉ែកខាងឥរិយាបថ ១ កុហនវត្ថុប៉ែកខាងការខ្សឹប ១ ។

កុហនវត្ថុប៉ែកខាងសេពបច្ច័យ តើដូចម្តេច ។ ពួកគហបតិក្នុងសាសនានេះ និមន្តភិក្ខុដោយចីវរ បិណ្ឌបាត សេនាសនៈ និងគិលានប្បច្ចយ-ភេសជ្ជបរិក្ខារ ។ ភិក្ខុនោះ ជាអ្នកមានសេចក្តីប្រាថ្នាលាមក ត្រូវសេចក្តីគ្របសង្កត់ មានសេចក្តីត្រូវការដោយចីវរ បិណ្ឌបាត សេនាសនៈ និងគិលា-នប្បច្ចយភេសជ្ជបរិក្ខារ អាស្រ័យសេចក្តីប្រាថ្នាខ្លាំង ក៏ពោលឃាត់ចីវរ ពោលឃាត់បិណ្ឌបាត ពោលឃាត់សេនាសនៈ ពោលឃាត់គិលានប្បច្ចយ-

ភេសជ្ជបរិក្ខារ ។ ភិក្ខុនោះបាននិយាយយ៉ាងនេះថា សមណៈមានប្រយោជន៍អ្វីដោយចីវរដែលមានថ្លៃច្រើន ឯអំពើដ៏សមគួរទុំះ ត្រង់សមណៈរើសកំណាត់សំពត់អំពីព្រៃស្មសាន អំពីគំនរសំរាម ឬអំពីរានផ្សារ ធ្វើជាសង្ឃាដី ហើយទ្រទ្រង់ សមណៈមានប្រយោជន៍អ្វីដោយបិណ្ឌបាតដែលមានថ្លៃច្រើន ឯអំពើដ៏សមគួរទុំះ ត្រង់សមណៈចិញ្ចឹមជីវិតដោយពំនូតអាហារ ដោយការដើរស្វែង សមណៈមានប្រយោជន៍អ្វីសេនាសនៈដែលមានថ្លៃច្រើន ឯអំពើដ៏សមគួរទុំះ ត្រង់សមណៈគួរជាអ្នកនៅជិតគល់ឈើ ឬនៅក្នុងទីវាល សមណៈមានប្រយោជន៍អ្វីដោយគិលានប្បច្ចយភេសជ្ជបរិក្ខារដែលមានថ្លៃច្រើន ឯអំពើដ៏សមគួរទុំះ ត្រង់សមណៈធ្វើថ្នាំដោយទឹកមូត្រគោ ឬដោយចំណិតផ្លែសម៉ ភិក្ខុអាស្រ័យដំណើរនោះ ក៏ទ្រទ្រង់ចីវរសៅហ្មង ប្រើប្រាស់សេនាសនៈសៅហ្មង សេពគិលានប្បច្ចយភេសជ្ជបរិក្ខារសៅហ្មង ។ ពួកគហបតិដឹងនូវភិក្ខុនោះ យ៉ាងនេះថា សមណៈនេះ ជាអ្នកប្រាថ្នាតិច ជាអ្នកសន្តោស ជាអ្នកស្ងប់ស្ងាត់ ជាអ្នកមិនច្រឡូកច្រឡំ ( ដោយពួក ) ប្រារព្ធព្យាយាម ពោលពាក្យជាគ្រឿងកម្ចាត់បង់កិលេស ក៏រឹតតែនិមន្តដោយចីវរ បិណ្ឌបាត សេនាសនៈ និងគិលានប្បច្ចយភេសជ្ជបរិក្ខារ ។

ភិក្ខុនោះ បាននិយាយយ៉ាងនេះថា កុលបុត្រអ្នកមានសទ្ធា បានបុណ្យច្រើនព្រោះធម៌ ៣ ចំពោះមុខ គឺកុលបុត្រអ្នកមានសទ្ធា បានបុណ្យច្រើនព្រោះមានសទ្ធាចំពោះមុខ ១ កុលបុត្រអ្នកមានសទ្ធា បានបុណ្យច្រើន ព្រោះមានទេយ្យធម៌ចំពោះមុខ ១ កុលបុត្រអ្នកមានសទ្ធា បានបុណ្យច្រើន ព្រោះ

ពួកទក្ខិណេយ្យបុគ្គលមានចំពោះមុខ ១ ( ឥឡូវ ) សទ្ធានេះ របស់អ្នកទាំងឡាយក៏មានផង ទេយ្យធម៌ក៏មានផង ទាំងអាត្មាក៏ជាអ្នកទទួលស្រាប់ បើអាត្មាមិនទទួលទេ អ្នកទាំងឡាយនឹងសាបសូន្យចាកបុណ្យយ៉ាងនេះមិនខាន អាត្មាមិនមានសេចក្តីត្រូវការដោយទេយ្យធម៌នេះទេ ប៉ុន្តែអាត្មាទទួលដើម្បីអនុគ្រោះដល់អ្នកទាំងឡាយប៉ុណ្ណោះ ( ភិក្ខុ ) អាស្រ័យដំណើរនោះ ក៏ទទួលចីវរយ៉ាងច្រើនផង ទទួលបិណ្ឌបាតយ៉ាងច្រើនផង ទទួលសេនាសនៈយ៉ាងច្រើនផង ទទួលគិលានប្បច្ចយភេសជ្ជបរិក្ខារយ៉ាងច្រើនផង ។ អាការធ្វើមុខស្រពោន ភាពនៃការធ្វើមុខស្រពោន ការកុហក អាការនៃកុហក ភាពនៃកុហក មានសភាពយ៉ាងនេះឯណា នេះលោកហៅថាកុហនវត្ថុប៉ែកខាងការសេពបច្ច័យ ។

កុហនវត្ថុប៉ែកខាងឥរិយាបថ តើដូចម្តេច ។ ភិក្ខុខ្លះ ក្នុងសាសនានេះ មានសេចក្តីលាមក ត្រូវសេចក្តីប្រាថ្នាគ្របសង្កត់ មានបំណងនូវការសរសើរថា អ្នកផងនឹងសរសើរអញយ៉ាងនេះ ក៏រៀបចំដំណើរ រៀបចំជំហរ រៀបចំបន្ទុយ រៀបចំដំណេក រៀបឫកដើរ រៀបឫកឈរ រៀបឫកអង្គុយ រៀបឫកសម្រេចការដេក ដើរដូចជាមានចិត្តតម្កល់មាំ ឈរដូចជាមានចិត្តតម្កល់មាំ អង្គុយដូចជាមានចិត្តតម្កល់មាំ សម្រេចការដេកដូចជាមានចិត្តតម្កល់មាំ ហាក់ដូចជាចូលឈានក្នុងទីចំពោះមុខ ( នៃអ្នកផង ) ។ ការតាំងក្នុងខាងដើម ការតាំងទុក ការរៀបចំឥរិយាបថ អាការធ្វើមុខស្រពោន ភាពនៃការធ្វើមុខស្រពោន ការកុហក អាការនៃកុហក ភាពនៃកុហក មានសភាពយ៉ាងនេះឯណា នេះ ហៅថា កុហនវត្ថុប៉ែកខាងឥរិយាបថ ។

កុហនវត្ថុប៉ែកខាងការខ្សឹប តើដូចម្ដេច ។ ភិក្ខុខ្លះ ក្នុងសាសនានេះ មានសេចក្ដីប្រាថ្នាលាមក ត្រូវសេចក្ដីប្រាថ្នាគ្របសង្កត់ មានបំណងនូវការសរសើរថា អ្នកផងនឹងសរសើរអញយ៉ាងនេះ ក៏ពោលវាចាផ្លូវទៅរកអរិយធម៌ គឺពោលថា សមណៈណា ទ្រទ្រង់ចីវរ មានសភាពយ៉ាងនេះ សមណៈនោះ មានសក្តិធំ ។ ពោលថា សមណៈណា ទ្រទ្រង់បាត្រ ទ្រទ្រង់ផ្តិលលោហៈ ទ្រទ្រង់ធម្មក្រក ទ្រទ្រង់សំពត់តម្រងទឹក ទ្រទ្រង់កូនសោ ទ្រទ្រង់ស្បែកជើង ទ្រទ្រង់វត្ថពន្ធចង្កេះ ទ្រទ្រង់សំពត់អាយោគពន្ធ មានសភាពយ៉ាងនេះៗ សមណៈនោះ មានសក្តិធំ ។ ពោលថា ឧបជ្ឈាយ៍នៃសមណៈណា មានសភាពយ៉ាងនេះ សមណៈនោះ មានសក្តិធំ ។ ពោលថា សមណៈណា មានអាចារ្យ មានពួកភិក្ខុដែលមានឧបជ្ឈាយ៍ស្មើគ្នា មានពួកភិក្ខុដែលមានអាចារ្យស្មើគ្នា មានមិត្ត មានមិត្តស្គាល់ស្មើរ មានមិត្តស៊ប់សួន មានសម្លាញ់ មានសភាពយ៉ាងនេះៗ សមណៈនោះ មានសក្តិធំ ។ ពោលថា សមណៈណា នៅក្នុងវិហារ មានសភាពយ៉ាងនេះ សមណៈនោះ មានសក្តិធំ ។ ពោលថា សមណៈណា នៅក្នុងអឌ្ឍយោគ ( បន្ទា ) នៅក្នុងប្រាសាទមានកំពូល នៅក្នុងគុហា នៅក្នុងខ្ទម នៅក្នុងផ្ទះកំពូល នៅក្នុងប៉ម នៅក្នុងរោងមូល នៅក្នុងថែវ នៅក្នុងឧបដ្ឋានសាលា នៅក្នុងមណ្ឌប ( បារាំ ) នៅក្បែរគល់ឈើមានសភាពយ៉ាងនេះៗ សមណៈនោះ មានសក្តិធំ ។ មួយវិញទៀត ភិក្ខុជាអ្នកស្រគត់ស្រគំពេក មានមុខស្រពាប់ស្រពោនពេក ជាអ្នកកុហកពេក ជាអ្នកប្រួសរាយពេក ដែលត្រូវគេសរសើរ ដោយអំណាចមាត់ ( របស់

ខូន ) ថា សមណៈនេះ ជាអ្នកបាននូវវិហារសមាបត្តិទាំងនេះ ជាគុណដ៏ស្ងប់ស្ងាត់ មានសភាពយ៉ាងនេះ តែងពោលពាក្យប្រាកដដូច្នោះ ជាពាក្យជ្រាលជ្រៅ លំបាកយល់ ដ៏ល្អិត កំបិទកំបាំង ជាវាចាប្រកបដោយលោកុត្តរធម៌ និងសុញ្ញតនិព្វាន ។ អាការធ្វើមុខស្រពោន ភាពនៃការធ្វើមុខស្រពោន ការកុហក អាការនៃកុហក ភាពនៃកុហក មានសភាពយ៉ាងនេះឯណា នេះហៅថា កុហនវត្ថុប៉ែកខាងការខ្សឹប ។

កុហនវត្ថុទាំង ៣ នេះ ព្រះបច្ចេកសម្ពុទ្ធនោះបានលះបង់ ផ្តាច់ផ្តិលរម្ងាប់ គ្របសង្កត់ ធ្វើមិនគួរឲ្យកើតឡើងបាន ដុតដោយភ្លើង គឺញាណហើយ ហេតុនោះ ព្រះបច្ចេកសម្ពុទ្ធនោះ ឈ្មោះថា អ្នកមិនកុហក ។ ពាក្យថា អ្នកមិនមានការស្រេកឃ្លាន សេចក្តីថា តណ្ហា លោកហៅថា ការស្រេកឃ្លាន បានដល់ តម្រេក តម្រេកខ្លាំង ។បេ។ អភិជ្ឈា លោភៈ អកុសលមូល ។ តណ្ហា គឺការស្រេកឃ្លាននោះ ព្រះបច្ចេកសម្ពុទ្ធនោះបានលះបង់ គាស់ឫសគល់ ធ្វើឲ្យសល់តែទីនៅដូចជាទីនៅនៃដើមត្នោត ឲ្យដល់នូវការមិនកើតមាន ឲ្យជាធម៌លែងកើតតទៅទៀត ហេតុនោះ ព្រះបច្ចេកសម្ពុទ្ធនោះ ឈ្មោះថា អ្នកមិនមានការស្រេកឃ្លាន ហេតុនោះ ( លោកពោលថា ) បុគ្គលអ្នកមិនលោភ អ្នកមិនកុហក អ្នកមិនមានការស្រេកឃ្លាន ។

[ ៣១៤ ] អធិប្បាយពាក្យថា អ្នកមិនមានការលុបគុណគេ មានទឹកចត់ និងមោហៈកម្ចាត់ចេញហើយ ត្រង់ពាក្យថា ការលុបគុណ បានខាងការបំបាត់គុណ អាការនៃការលុបគុណ ភាពនៃការលុបគុណ សេចក្តីប្រណែន

កម្ម គឺសេចក្តីប្រណែន ។ ពាក្យថា ទឹកចត់ សម្តៅយករាគៈ ឈ្មោះថា ទឹកចត់ ទោសៈ ឈ្មោះថា ទឹកចត់ មោហៈ ឈ្មោះថា ទឹកចត់ កោធៈ ឧបនាហៈ មក្ខៈ បឡាសៈ ។បេ។ អកុសលាភិសង្ខារទាំងអស់ ឈ្មោះថា ទឹកចត់ ។ ពាក្យថា មោហៈ បានដល់ ការមិនដឹងក្នុងទុក្ខ ការមិនដឹងក្នុងទុក្ខសមុទ័យ ការមិនដឹងក្នុងទុក្ខនិរោធ ការមិនដឹងក្នុងទុក្ខនិរោធគាមិនីបដិបទា ការមិនដឹងក្នុងចំណែកខន្ធមុន ការមិនដឹងក្នុងចំណែកខន្ធក្រោយ ការមិនដឹងក្នុងចំណែកខន្ធមុន និងចំណែកខន្ធក្រោយ ការមិនដឹងក្នុងធម៌ទាំងឡាយដែលអាស្រ័យគ្នាកើតឡើង ព្រោះធម៌នេះជាបច្ច័យ គឺដែលជាការមិនដឹង ការមិនឃើញ ការមិនយល់ច្បាស់ ការមិនត្រាស់ដឹងតាម ការមិនត្រាស់ដឹងព្រម ការមិនចាក់ធ្លុះ ការមិនកាន់យក ( ដោយសាមញ្ញលក្ខណៈ ) ការមិនចុះកាន់ ( សាមញ្ញលក្ខណៈ ) ការមិនសម្លឹងស្មើ ការមិនពិចារណា អំពើមិនជាក់ច្បាស់ សន្តានចិត្តអាក្រក់ ភាពជាបុគ្គលល្ងង់ ការមិនដឹងខ្លួន ការវង្វេង ការវង្វេងសព្វ អន្ធង់ គឺអវិជ្ជា យោគៈ គឺអវិជ្ជា អនុស័យ គឺអវិជ្ជា កិលេសជាគ្រឿងគ្របសង្កត់ចិត្ត គឺអវិជ្ជា បណ្តាញ គឺអវិជ្ជា សន្ទះទ្វារធំ គឺអវិជ្ជា មោហៈ អកុសលមូលមានសភាពយ៉ាងនេះ ។ ការលុបគុណ ទឹកចត់ និងមោហៈ ព្រះបច្ចេកសម្ពុទ្ធនោះ បានខ្ជាក់ចោល កម្ចាត់ចោល លះបង់ កាត់ផ្តាច់ រម្ងាប់ គ្របសង្កត់ ធ្វើមិនគួរឲ្យកើតឡើងបាន ដុតបំផ្លាញដោយភ្លើង គឺញាណ ព្រោះហេតុនោះ ព្រះបច្ចេកសម្ពុទ្ធនោះ ឈ្មោះថា អ្នកមិនមានការលុបគុណគេ មានទឹកចត់ និងមោហៈកម្ចាត់ចេញហើយ ។

[ ៣១៥ ] ពាក្យថា មិនមានសេចក្តីប្រាថ្នាក្នុងលោកទាំងមូល សេចក្តីថា តណ្ហា លោកហៅថា សេចក្តីប្រាថ្នា បានខាងតម្រេក តម្រេកខ្លាំង ។បេ។ អភិជ្ឈា លោភៈ អកុសលមូល ។ ពាក្យថា ក្នុងលោកទាំងមូល គឺក្នុងអបាយលោកទាំងមូល មនុស្សលោកទាំងមូល ទេវលោកទាំងមូល ខន្ធលោកទាំងមូល ធាតុលោកទាំងមូល អាយតនលោកទាំងមូល ។ ពាក្យថា មិនមានសេចក្តីប្រាថ្នាក្នុងលោកទាំងមូល បានសេចក្តីថា ជាអ្នកមិនមានសេចក្តីប្រាថ្នា មិនមានតណ្ហា មិនមានសេចក្តីស្រេកឃ្លានក្នុងលោកទាំងមូល ហេតុនោះ ( លោកពោលថា ) មិនមានសេចក្តីប្រាថ្នាក្នុងលោកទាំងមូល ។ គប្បីប្រព្រឹត្តម្នាក់ឯង ដូចកុយរមាស ។ ព្រោះហេតុនោះ ព្រះបច្ចេកសម្ពុទ្ធនោះពោលថា

បុគ្គលអ្នកមិនលោភ អ្នកមិនកុហក អ្នកមិនមានការស្រេកឃ្លាន
អ្នកមិនមានការលុបគុណគេ មានទឹកចត់ និងមោហៈកម្ចាត់ចេញ
ហើយ មិនមានសេចក្តីប្រាថ្នាក្នុងលោកទាំងមូល គប្បីប្រព្រឹត្តម្នាក់
ឯង ដូចកុយរមាស ។

# អដ្ឋកថា

## គាថាទី ២

គប្បីជ្រាបវិនិច្ឆ័យក្នុងគាថាទី ២ ដូចតទៅនេះ

[ ៣១២ ] បទថា **និល្លោលុប្បោ** បានដល់ ជាអ្នកមិនលោភ ។ ពិតហើយ បុគ្គលណាត្រូវតណ្ហាក្នុងរសគ្របសង្កត់ បុគ្គលនោះ រមែងលោភខ្លាំង គឺលោភរឿយៗ ។ ដោយហេតុនោះ ទើបហៅថា **លោលុប្បោ** ។ ព្រោះហេតុនោះ ព្រះបច្ចេកសម្ពុទ្ធអង្គនេះ កាលហាមនូវលោភខ្លាំងនោះ ទើបពោលថា **និល្លោលុប្បោ** ។

ក្នុងបទថា **និក្កុហោ** នេះ វត្ថុសម្រាប់បោកបញ្ឆោត ៣ យ៉ាង មិនមានដល់បុគ្គលណា បុគ្គលនោះ លោកហៅថា **និក្កុហោ** ក៏ពិត តែគាថានេះ មានអធិប្បាយដូចតទៅ ឈ្មោះថា **និក្កុហោ** ព្រោះមិនដល់នូវការអស្ចារ្យក្នុងភោជនដែលគួរពេញចិត្តជាដើម ។ ក្នុងបទថា **និប្បិបាសោ** នេះ សេចក្ដីថា ការប្រាថ្នានឹងផឹក ឈ្មោះថា **បិបាសោ** ។ ព្រោះមិនមាន **បិបាសោ** នោះ ទើបឈ្មោះថា **និប្បិបាសោ** ។ អធិប្បាយថា ជាអ្នកផុតចាកការប្រាថ្នាបរិភោគដោយសេចក្ដីលោភ ក្នុងរសឆ្ងាញ់ ។ ក្នុងបទថា **និម្មក្ខោ** នេះ សេចក្ដីថា ឈ្មោះថា **មក្ខោ** ដែលមានលក្ខណៈធ្វើគុណអ្នកដទៃឲ្យវិនាស ឈ្មោះថា **និម្មក្ខោ** ព្រោះមិនមាន **មក្ខោ** នោះ ។ ព្រះបច្ចេកសម្ពុទ្ធពោលសំដៅដល់ការមិនលុបគុណរបស់អ្នកដទៃ កាលខ្លួននៅជាគ្រហស្ថ ។ ក្នុងបទនេះថា **និទ្ធន្តកសាវមោហោ** ធម៌ ៦ យ៉ាង គឺអកុសល ៣ មាន

រាគៈជាដើម និងទុច្ចរិត ៣ មានកាយទុច្ចរិតជាដើម គប្បីជ្រាបថា ជាបាបធម៌ ដូចទឹកចត់ ព្រោះអត្ថថា មិនផូរផង់តាមកំណើត ព្រោះអត្ថថា លះនូវភាវៈនៃខ្លួនហើយ កាន់យកភាវៈដទៃ និងព្រោះអត្ថថា ជាកាកសំណល់ ដូចព្រះមានព្រះភាគត្រាស់ ( អភិធម្មវិភង្គ ) ថា

បណ្ដាធម៌ទាំងនោះ ទឹកចត់ ៣ តើដូចម្ដេច ។ ទឹកចត់ គឺរាគៈ ១ ទឹកចត់ គឺទោសៈ ១ ទឹកចត់ គឺមោហៈ ១ នេះ ទឹកចត់ ៣ ។

បណ្ដាធម៌ទាំងនោះ ទឹកចត់ ៣ ដទៃទៀត តើដូចម្ដេច ។ ទឹកចត់ គឺកាយ ១ ទឹកចត់ គឺវាចា ១ ទឹកចត់ គឺចិត្ត ១ នេះ ទឹកចត់ ៣ ដូច្នេះ ។

ក្នុងទឹកម្ចត់ទាំងនោះ ឈ្មោះថា **និក្កសាវមោហោ** ព្រោះកម្ចាត់កិលេស ដូចទឹកម្ចត់ ៥ វៀរមោហៈ និងកម្ចាត់មោហៈ ដែលជាឫសគល់នៃកិលេស ដូចរសចត់ទាំងអស់នោះ ។ ម្យ៉ាងទៀត ឈ្មោះថា **និក្កសាវ-មោហោ** ព្រោះកម្ចាត់កិលេសដូចទឹកម្ចត់តាមកាយ វាចា និងចិត្តទាំង ៣ មួយអន្លើដោយមោហៈ ។

ក្នុងបទក្រៅអំពីនេះ ជាការបាននូវសេចក្ដីសម្រេចថា កម្ចាត់ទឹកម្ចត់ គឺរាគៈ ដោយការមិនលោភជាដើម កម្ចាត់ទឹកម្ចត់ គឺទោសៈ ដោយការមិន

លុបគុណ ។ បទថា **និរាសសោ** បានដល់ មិនមាននូវការចង់បាន ។ បទថា **សព្វលោកេ** បានដល់ ក្នុងលោកទាំងមូល អធិប្បាយថា ជាអ្នកប្រាសចាក ភវតណ្ហា និងវិភវតណ្ហាក្នុងភព ៣ និងក្នុងអាយតនៈ ១២ ។ បទដ៏សេស គប្បីជ្រាបដោយន័យដូចពោលហើយនោះឯង ។ ម្យ៉ាងទៀត គប្បីពោល ៣ វារៈ ហើយធ្វើនូវការភ្ជាប់ក្នុងបទនេះយ៉ាងនេះថា **ឯកោ ចរេ** ខ្វះ ឬភ្ជាប់ សេចក្តីយ៉ាងនេះថា **ឯកោ ចរិតុំ សក្កុណេយ្យ** គឺគប្បីអាចត្រាច់ទៅ ម្នាក់ឯងខ្វះ ។៚

## អដ្ឋកថា គាថាទី ២ ចប់

# សុត្តន្តបិដក

[ ៣១៦ ] បុគ្គល គួរចៀសវាងនូវសម្មាញ់អាក្រក់ អ្នកឃើញអំពើមិនមានប្រយោជន៍ អ្នកតាំងនៅក្នុងអំពើមិនស្មើ មិនគួរសេពគប់នូវបុគ្គលអ្នកខ្វល់ខ្វាយ អ្នកធ្វេសប្រហែសដោយខ្លួនឯង គប្បីប្រព្រឹត្តម្នាក់ឯង ដូចកុយរមាស ។

[ ៣១៧ ] ពាក្យថា បុគ្គលគួរចៀសវាងនូវសម្មាញ់អាក្រក់ សេចក្ដីថា ដែលហៅថាសម្មាញ់អាក្រក់ បានដល់ សម្មាញ់ដែលប្រកបដោយមិច្ឆាទិដ្ឋិ មានវត្ថុ ១០ យ៉ាងថា ទានដែលគេឲ្យមិនមានផល បូជាធំមិនមានផល បូជាតូច មិនមានផល ផលវិបាកនៃកម្មដែលបុគ្គលធ្វើល្អ ធ្វើអាក្រក់មិនមាន លោកនេះ មិនមាន លោកដទៃ មិនមាន មាតាមិនមានគុណ បិតាមិនមានគុណ ពួកសត្វជាឱបបាតិកៈ មិនមាន ពួកសមណព្រាហ្មណ៍ក្នុងលោក ដែលប្រព្រឹត្តត្រឹមត្រូវ ប្រតិបត្តិត្រឹមត្រូវ បានធ្វើឲ្យជាក់ច្បាស់ដោយប្រាជ្ញាយ៉ាងខ្ពង់ខ្ពស់ចំពោះខ្លួន ហើយប្រកាសនូវលោកនេះ និងលោកខាងមុខ មិនមាន សម្មាញ់បែបនេះ ឈ្មោះថា សម្មាញ់អាក្រក់ ។ ពាក្យថា បុគ្គលគួរចៀសវាងនូវសម្មាញ់អាក្រក់ បានសេចក្ដីថា បុគ្គលគួរចៀសវាង គួរវៀរលែង គួរគេចវាងនូវសម្មាញ់អាក្រក់ ហេតុនោះ ( លោកពោលថា ) បុគ្គលគួរចៀសវាងនូវសម្មាញ់អាក្រក់ ។

[ ៣១៨ ] ពាក្យថា អ្នកឃើញនូវអំពើមិនមានប្រយោជន៍ អ្នកតាំងនៅក្នុងអំពើមិនស្មើ សេចក្ដីថា ដែលហៅថា អ្នកឃើញនូវអំពើមិនមានប្រយោជន៍ បានខាងសម្មាញ់ដែលប្រកបដោយមិច្ឆាទិដ្ឋិ មានវត្ថុ ១០ យ៉ាងថា ទានដែល

គេឲ្យមិនមានផល បូជាធំមិនមានផល ។បេ។ ដែលបានធ្វើឲ្យជាក់ច្បាស់ដោយប្រាជ្ញាយ៉ាងខ្ពង់ខ្ពស់ចំពោះខ្លួន ហើយប្រកាសនូវលោកនេះ និងលោកខាងមុខ មិនមានសម្មាញ់បែបនេះ ឈ្មោះថា សម្មាញ់អ្នកឃើញនូវអំពើមិនមានប្រយោជន៍ ។ ពាក្យថា អ្នកតាំងនៅក្នុងអំពើមិនស្មើ សេចក្តីថា អ្នកតាំងនៅក្នុងកាយកម្មមិនស្មើ តាំងនៅក្នុងវចីកម្មមិនស្មើ តាំងនៅក្នុងមនោកម្មមិនស្មើ គឺថា តាំងនៅក្នុងកម្មមិនស្មើ គឺបាណាតិបាត តាំងនៅក្នុងកម្មមិនស្មើ គឺអទិន្នាទាន តាំងនៅក្នុងកម្មមិនស្មើ គឺកាមេសុមិច្ឆាចារ តាំងនៅក្នុងកម្មមិនស្មើ គឺមុសាវាទ តាំងនៅក្នុងកម្មមិនស្មើ គឺបិសុណាវាចា តាំងនៅក្នុងកម្មមិនស្មើ គឺផរុសវាចា តាំងនៅក្នុងកម្មមិនស្មើ គឺសម្ផប្បលាបៈ តាំងនៅក្នុងកម្មមិនស្មើ គឺអភិជ្ឈា តាំងនៅក្នុងកម្មមិនស្មើ គឺព្យាបាទ តាំងនៅក្នុងកម្មមិនស្មើ គឺមិច្ឆាទិដ្ឋិ តាំងនៅក្នុងកម្មទាំងឡាយមិនស្មើ គឺសង្ខារ តាំងនៅ ជាប់ ជាប់ស្អិត ចូលទៅ ដល់ ស៊ប់ លិចចុះ ចុះចិត្តស៊ប់ក្នុងកម្មមិនស្មើ គឺកាមគុណ ៥ ហេតុនោះ ( លោកពោលថា ) អ្នកឃើញនូវអំពើមិនមានប្រយោជន៍ អ្នកតាំងនៅក្នុងអំពើមិនស្មើ ។

[ ៣១៩ ] អធិប្បាយពាក្យថា មិនគួរសេពគប់នូវបុគ្គលអ្នកខ្វល់ខ្វាយ អ្នកធ្វេសប្រហែសដោយខ្លួនឯង ត្រង់ពាក្យថា បុគ្គលខ្វល់ខ្វាយ សេចក្តីថា បុគ្គលណាដើររក ស្វែងរក ស្វះស្វែងរកនូវកាមទាំងឡាយ ជាអ្នកប្រព្រឹត្តកាមនោះ ច្រើនដោយកាមនោះ ធ្ងន់ក្នុងកាមនោះ ទេរទៅរកកាមនោះ ទោរទៅរកកាមនោះ ឈមទៅរកកាមនោះ ចុះចិត្តស៊ប់ក្នុងកាមនោះ យកកាមនោះជា

អធិបតិ បុគ្គលនោះឯង ឈ្មោះថា អ្នកខ្វល់ខ្វាយក្នុងកាម ។ បុគ្គលណា ស្វះស្វែងរកនូវរូបទាំងឡាយ ដោយអំណាចតណ្ហាក្តី បុគ្គលណា បានរូបទាំងឡាយ ដោយអំណាចតណ្ហាក្តី បុគ្គលណា ប្រើប្រាស់រូបទាំងឡាយ ដោយអំណាចតណ្ហាក្តី ប្រើប្រាស់សំឡេង ក្លិន រស និងផោដ្ឋព្វៈ ដោយអំណាចតណ្ហាក្តី ជាអ្នកប្រព្រឹត្តអារម្មណ៍នោះ ច្រើនដោយអារម្មណ៍នោះ ធ្ងន់ក្នុងអារម្មណ៍នោះ ទេរទៅរកអារម្មណ៍នោះ ទោរទៅរកអារម្មណ៍នោះ ឈមទៅរកអារម្មណ៍នោះ ចុះចិត្តស៊ប់ក្នុងអារម្មណ៍នោះ យកអារម្មណ៍នោះជាអធិបតិ បុគ្គលនោះឯង ក៏ឈ្មោះថា អ្នកខ្វល់ខ្វាយក្នុងកាមដែរ ។ ពាក្យថា អ្នកធ្វេសប្រហែស គឺសេចក្តីធ្វេសប្រហែស ខ្ញុំគប្បីពោលដូចតទៅនេះ ។ ការបណ្តោយចិត្ត ការផ្តល់កម្លាំងដល់ការបណ្តោយចិត្តក្នុងកាយទុច្ចរិតក្តី ក្នុងវចីទុច្ចរិតក្តី ក្នុងមនោទុច្ចរិតក្តី ក្នុងកាមគុណទាំង ៥ ក្តី ពុំនោះសោត ការមិនធ្វើដោយផ្ចិតផ្ចង់ ការមិនធ្វើរឿយៗ ការមិនធ្វើឲ្យស្ថិតស្ថេរ កិរិយាប្រព្រឹត្តរួញរា ការដាក់សេចក្តីប្រាថ្នា ការដាក់ធុរៈ ការមិនសេពគប់ ការមិនចម្រើន ការមិនធ្វើឲ្យច្រើន ការមិនអធិដ្ឋាន ការមិនប្រកបរឿយៗ ក្នុងការចម្រើននូវធម៌ទាំងឡាយជាកុសល សេចក្តីប្រហែស សេចក្តីធ្វេសប្រហែស ភាពនៃសេចក្តីធ្វេសប្រហែស មានសភាពយ៉ាងនេះឯណា នេះ លោកហៅថា សេចក្តីធ្វេសប្រហែស ។ ពាក្យថា មិនគួរសេពគប់នូវបុគ្គលអ្នកខ្វល់ខ្វាយ អ្នកធ្វេសប្រហែសដោយខ្លួនឯង បានសេចក្តីថា មិនគួរសេពគប់ នូវបុគ្គលអ្នកខ្វល់ខ្វាយផង មិនគួរសេព មិនគួរគប់រក មិនគួររាប់រក មិនគួររាប់អាន មិនគួរ

ប្រព្រឹត្តអើពើ មិនគួរប្រព្រឹត្តរួម មិនគួរប្រព្រឹត្ត សមាទាននូវបុគ្គលអ្នកធ្វេសប្រហែសផង ហេតុនោះ ( លោកពោលថា ) មិនគួរសេពគប់នូវបុគ្គលអ្នកខ្ជិលច្រអូស អ្នកធ្វេសប្រហែសដោយខ្លួនឯង ។ គប្បីប្រព្រឹត្តម្នាក់ឯង ដូចកុយរមាស ។ ព្រោះហេតុនោះ ព្រះបច្ចេកសម្ពុទ្ធនោះពោលថា

បុគ្គល គួរចៀសវាងនូវសម្លាញ់អាក្រក់ អ្នកឃើញអំពើមិនមានប្រយោជន៍ អ្នកតាំងនៅក្នុងអំពើមិនស្មើ មិនគួរសេពគប់នូវបុគ្គលអ្នកខ្ជិលច្រអូស អ្នកធ្វេសប្រហែសដោយខ្លួនឯង គប្បីប្រព្រឹត្តម្នាក់ឯង ដូចកុយរមាស ។

# អដ្ឋកថា

## គាថាទី ៣

ក្នុងគាថាទី ៣ មានសេចក្ដីសង្ខេប ដូចតទៅនេះ

[ ៣១៦ ] សម្លាញ់ ឈ្មោះថា អាក្រក់ ព្រោះប្រកបដោយទិដ្ឋិអាក្រក់ ១០ យ៉ាង ។ ឈ្មោះថា **អនត្ថទស្សី** ព្រោះសម្ដែងសេចក្ដីវិនាសដល់អ្នកដទៃ និងឈ្មោះថា **វិសមេ និវិដ្ឋោ** ព្រោះមានកាយទុច្ចរិតជាដើម កុលបុត្រអ្នកស្រឡាញ់ខ្លួន គប្បីវៀរសម្លាញ់អាក្រក់នោះ ដែលណែនាំនូវវត្ថុមិនជាប្រយោជន៍ ដែលតាំងមាំក្នុងធម៌ខុស ។ បទថា **សយំ ន សេវេ** បានដល់ មិនគប្បីសេពគប់បុគ្គលនោះ គឺដោយអំណាចរបស់ខ្លួន ដោយប្រការដូច្នេះ ។

មានពាក្យអធិប្បាយថា ទោះអ្នកដទៃមានអំណាច តើអាចធ្វើអ្វីបាន ។ បទថា **បសុតំ** បានដល់ បុគ្គលដែលបណ្ដែតបណ្ដោយខ្លួន មានអធិប្បាយថា ដែលជាប់នៅក្នុងបាបធម៌នោះៗ ដោយអំណាចនៃទិដ្ឋិ ។ បទថា **បមត្តំ** បានដល់ ជាអ្នកបណ្ដោយចិត្តទៅហើយក្នុងកាមគុណ គឺវៀរចាកកុសលភាវនា បុគ្គលមិនគប្បីសេព គឺមិនគប្បីគប់រក បានដល់ មិនគប្បីចូលទៅជិតបុគ្គលបែបនោះ ដោយពិត គប្បីត្រាច់ទៅតែម្នាក់ឯង ដូចកុយរមាស ដូច្នោះ ។

[ ៣១៩ ] គប្បីជ្រាបវិនិច្ឆ័យក្នុងនិទ្ទេសដូចតទៅ បទថា **សយំ ន សេវេយ្យ** បានដល់ មិនគប្បីចូលទៅរកដោយខ្លួនឯង ។ បទថា **សាមំ ន សេវេយ្យ** បានដល់ មិនគប្បីចូលទៅជិត ដោយហោចសូម្បីត្រឹមតែចិត្ត ។ បទថា **ន សេវេយ្យ** បានដល់ មិនគប្បីសេពគប់ ។ បទថា **ន និសេវេយ្យ** បានដល់ មិនចូលទៅសូម្បីក្នុងទីជិត ។ បទថា **ន សំសេវេយ្យ** បានដល់ គប្បីនៅឲ្យឆ្ងាយ ។ បទថា **ន បដិសេវេយ្យ** បានដល់ ចៀសចេញទៅ ។ល។

## អដ្ឋកថា គាថាទី ៣ ចប់

# សុត្តន្តបិដក

[ ៣២០ ] បុគ្គលគួរគប់រកជនជាពហុស្សូត អ្នកទ្រទ្រង់ធម៌ ជាមិត្តដ៏ខ្ពង់ខ្ពស់ មានបដិភាណ បុគ្គលបានដឹងនូវប្រយោជន៍ទាំងឡាយហើយ គួរកម្ចាត់នូវសេចក្តីសង្ស័យ គប្បីប្រព្រឹត្តម្នាក់ឯងដូចកុយរមាស ។

[ ៣២១ ] អធិប្បាយពាក្យថា បុគ្គលគួរគប់រកជនជាពហុស្សូត អ្នកទ្រទ្រង់ធម៌ ត្រង់ពាក្យថា ជនជាពហុស្សូត គឺជនអ្នកចេះដឹងច្រើន អ្នកចងចាំនូវសូត្រ សន្សំទុកនូវសូត្រ គឺថា ធម៌ទាំងឡាយណា មានលម្អបទដើម លម្អកណ្តាល លម្អបទចុង ព្រមទាំងអត្ថ និងព្យញ្ជនៈ ប្រកាសនូវព្រហ្មចរិយៈដ៏បរិសុទ្ធ បរិបូណ៌ទាំងអស់ ធម៌ទាំងឡាយមានសភាពដូច្នោះ ជននោះបានស្តាប់ច្រើន បានទ្រទ្រង់ បានចាំស្ទាត់រត់មាត់ បានពិនិត្យមើលដោយចិត្ត បានចាក់ធ្លុះប្រពៃដោយសេចក្តីយល់ ។ ពាក្យថា អ្នកទ្រទ្រង់ធម៌ សេចក្តីថា អ្នកទ្រទ្រង់នូវធម៌ គឺសុត្តៈ គេយ្យៈ វេយ្យាករណៈ គាថា ឧទាន ឥតិវុត្តកៈ ជាតក អព្ភូតធម្មៈ វេទល្លៈ ។ ពាក្យថា បុគ្គលគួរគប់រកជនជាពហុស្សូត អ្នកទ្រទ្រង់ធម៌ បានសេចក្តីថា បុគ្គលគួរគប់រក គួរសេព គួររាប់រក គួររាប់អាន គួរសេពចំពោះនូវមិត្តជាពហុស្សូតផង អ្នកទ្រទ្រង់ធម៌ផង ហេតុនោះ ( លោកពោលថា ) បុគ្គលគួរគប់រកជនជាពហុស្សូត អ្នកទ្រទ្រង់ធម៌ ។

[ ៣២២ ] ពាក្យថា ជាមិត្តដ៏ខ្ពង់ខ្ពស់ មានបដិភាណ អធិប្បាយថា ជនជាមិត្តដ៏ខ្ពង់ខ្ពស់ដោយសីល សមាធិ បញ្ញា វិមុត្តិ វិមុត្តិញ្ញាណទស្សនៈ ។ ពាក្យថា មានបដិភាណ គឺជនមានបដិភាណ ៣ ពួក គឺមានបដិភាណក្នុង

បរិយត្តិ ១ មានបដិភាណក្នុងបរិបុច្ឆា ១ មានបដិភាណក្នុងអធិគម ១ ។

ជនអ្នកមានបដិភាណក្នុងបរិយត្តិ តើដូចម្តេច ។ ជនខ្លះ ក្នុងសាសនានេះ បានរៀននូវពុទ្ធវចនៈ គឺសុត្តៈ គេយ្យៈ វេយ្យាករណៈ គាថា ឧទាន ឥតិវុត្តកៈ ជាតក អព្ភុតធម្មៈ វេទល្លៈ ( ពុទ្ធវចនៈនោះ ) រមែងភ្លឺច្បាស់ដល់ជននោះ ព្រោះអាស្រ័យបរិយត្តិ នេះ ឈ្មោះថា អ្នកមានបដិភាណក្នុងបរិយត្តិ ។

ជនអ្នកមានបដិភាណក្នុងបរិបុច្ឆា តើដូចម្តេច ។ ជនខ្លះ ក្នុងសាសនានេះ ជាអ្នកសាកសួរក្នុងអត្ថ ក្នុងធម៌ដែលគួរដឹង ក្នុងលក្ខណៈ ក្នុងហេតុ ក្នុងឋានៈ និងអឋានៈ ( សភាវៈមានអត្ថជាដើម ) រមែងភ្លឺច្បាស់ដល់ជននោះ ព្រោះអាស្រ័យការសាកសួរ នេះ ឈ្មោះថា អ្នកមានបដិភាណក្នុងបរិបុច្ឆា ។

ជនអ្នកមានបដិភាណក្នុងអធិគម តើដូចម្តេច ។ ជនខ្លះ ក្នុសាសនានេះ បានត្រាស់ដឹងនូវសតិប្បដ្ឋាន ៤ សម្មប្បធាន ៤ ឥទ្ធិបាទ ៤ ឥន្ទ្រិយ ៥ ពល ៥ ពោជ្ឈង្គ ៧ មគ្គដ៏ប្រសើរប្រកបដោយអង្គ ៨ អរិយមគ្គ សាមញ្ញផល ៤ បដិសម្ភិទា ៤ អភិញ្ញា ៦ ។ បុគ្គលនោះ បានដឹងអត្ថ ដឹងធម៌ ដឹងនិរុត្តិ ។ កាលបើដឹងអត្ថហើយ អត្ថរមែងច្បាស់ប្រាកដ កាលបើដឹងធម៌ហើយ ធម៌រមែងច្បាស់ប្រាកដ កាលបើដឹងនិរុត្តិហើយ និរុត្តិរមែងច្បាស់ប្រាកដ ។ ការដឹងក្នុងបដិភាណទាំង ៣ នេះ ឈ្មោះថា បដិភាណប្បដិសម្ភិទា ។ ព្រះបច្ចេកសម្ពុទ្ធនោះ ប្រកប ប្រកបព្រម ចូលទៅជិត ចូលទៅជិតព្រម ចូលទៅដល់ ចូលទៅដល់ព្រម ប្រកបព្រមដោយបដិភាណ-

ប្បដិសម្ភិទានេះ ព្រោះហេតុនោះ ព្រះបច្ចេកសម្ពុទ្ធ ឈ្មោះថា មានបដិភាណ ។ បុគ្គលណា មិនមានបរិយត្តិ មិនមានបរិបុច្ឆា មិនមានអធិគម ធម្មជាតអ្វីនឹងច្បាស់ប្រាកដដល់បុគ្គលនោះបាន ហេតុនោះ ( លោកពោលថា ) ជាមិត្តដ៏ខ្ពង់ខ្ពស់ មានបដិភាណ ។

[ ៣២៣ ] ពាក្យថា បុគ្គលបានដឹងច្បាស់នូវប្រយោជន៍ទាំងឡាយហើយ គួរកម្ចាត់នូវសេចក្តីសង្ស័យ សេចក្តីថា បុគ្គលដឹងនូវប្រយោជន៍ខ្លួន ដឹងនូវប្រយោជន៍ជនដទៃ ដឹងនូវប្រយោជន៍ទាំងពីរ ដឹងនូវប្រយោជន៍បច្ចុប្បន្ន ដឹង ដឹងច្បាស់ ស្គាល់ ថ្លឹង ត្រិះរិះ ធ្វើឲ្យច្បាស់ ធ្វើឲ្យប្រាកដនូវប្រយោជន៍ក្នុងលោកខាងមុខហើយ គួរកម្ចាត់ បំបាត់ចេញ លះបង់ បន្ទោបង់ ធ្វើឲ្យវិនាស ឲ្យដល់នូវការមិនកើតមាន នូវសេចក្តីសង្ស័យ ហេតុនោះ ( លោកពោលថា ) បុគ្គលបានដឹងច្បាស់នូវប្រយោជន៍ទាំងឡាយហើយ គួរកម្ចាត់នូវសេចក្តីសង្ស័យ គប្បីប្រព្រឹត្តម្នាក់ឯង ដូចកុយរមាស ។ ហេតុនោះ ព្រះបច្ចេកសម្ពុទ្ធនោះពោលថា

បុគ្គលគួរគប់រកជនជាពហុស្សូត អ្នកទ្រទ្រង់ធម៌ ជាមិត្តដ៏ខ្ពង់ខ្ពស់
មានបដិភាណ បុគ្គលបានដឹងនូវប្រយោជន៍ទាំងឡាយហើយ គួរ
កម្ចាត់នូវសេចក្តីសង្ស័យ គប្បីប្រព្រឹត្តម្នាក់ ឯងដូចកុយរមាស ។

# អដ្ឋកថា

## គាថាទី ៤

ក្នុងគាថាទី ៤ មានសេចក្ដីសង្ខេបដូចតទៅ

[ ៣២០ ] បទថា **ពហុស្សុតំ** សេចក្ដីថា ពហូសូត មាន ២ ពួក គឺពហូសូតក្នុងបរិយត្តិ ជំនាញដោយអត្ថក្នុងព្រះត្រៃបិដក ១ ពហូសូតក្នុងបដិវេធ ព្រោះចាក់ធ្លុះនូវមគ្គ ផល វិជ្ជា និងអភិញ្ញា ១ ។

បុគ្គលមានអាគមដែលមកហើយ ដោយការទ្រទ្រង់ចាំទុកបាន ឈ្មោះថា **ធម្មធរោ** ។ ឯបុគ្គលដែលប្រកបដោយកាយកម្ម វចីកម្ម និងមនោកម្មដ៏ឧឡារ ឈ្មោះថា **ឧឡារោ** ។ លោកដែលមានបដិភាណពាល់ត្រូវ ជាអ្នកមានបញ្ញារហ័ស និងជាអ្នកមានបញ្ញាពាល់ត្រូវរហ័ស ឈ្មោះថា **បដិភានវា** ។

ម្យ៉ាងទៀត គប្បីជ្រាបអ្នកមានបដិភាណ ៣ ពួក គឺបរិយត្តិបដិភាណ ១ បរិបុច្ឆាបដិភាណ ១ អធិគមបដិភាណ ១ ។

បុគ្គលដឹងច្បាស់ក្នុងបរិយត្តិ ឈ្មោះថា **បរិយត្តិបដិភាណា** ។ បុគ្គលដឹងច្បាស់ក្នុងការសាកសួរ កាលគេសួរដល់អត្ថ ញេយ្យធម៌ លក្ខណៈ ឋានៈ អដ្ឋានៈ ឈ្មោះថា **បរិបុច្ឆាបដិភាណា** ។ បុគ្គលចាក់ធ្លុះនូវគុណវិសេសទាំងឡាយ មានមគ្គជាដើម ឈ្មោះថា **បដិវេធបដិភាណា** ។

បុគ្គលគួរសេពគប់មិត្រដែលជាពហូសូត ជាអ្នកទ្រទ្រង់នូវធម៌ មានគុណក្រៃលែង មានបដិភាណបែបនោះ បន្ទាប់អំពីនោះ ដោយអានុភាពរបស់មិត្រនោះ បានដឹងប្រយោជន៍ជាច្រើន ដោយចែកជាប្រយោជន៍ខ្លួន ប្រយោជន៍អ្នកដទៃ និងប្រយោជន៍ទាំង ២ ឬដោយចែកជាប្រយោជន៍បច្ចុប្បន្ន ប្រយោជន៍ខាងមុខ និងបរមត្ថប្រយោជន៍ បន្ទាប់អំពីនោះ កម្ចាត់នូវសេចក្តីសង្ស័យ ធ្វើនូវការសង្ស័យឲ្យអស់ទៅក្នុងឋានៈនៃសេចក្តីសង្ស័យថា អញបានកើតហើយអស់កាលក្នុងអតីតឬហ្ន៎ ជាអ្នកធ្វើកិច្ចគ្រប់យ៉ាងស្រេចហើយយ៉ាងនេះ គប្បីត្រាច់ទៅម្នាក់ឯង ដូចកុយរមាស ដូច្នោះ ។ល។

## អដ្ឋកថា គាថាទី ៤ ចប់

# សុត្តន្តបិដក

[ ៣២៤ ] បុគ្គលមិនអើពើ មិនអាឡោះអាល័យនូវល្បែង នូវសេចក្តីត្រេកអរ និងកាមសុខក្នុងលោក ជាអ្នកវៀរចាកគ្រឿងស្អិតស្អាង អ្នកពោលពាក្យពិត គប្បីប្រព្រឹត្តម្នាក់ឯង ដូចកុយរមាស ។

[ ៣២៥ ] អធិប្បាយពាក្យថា នូវល្បែង នូវសេចក្តីត្រេកអរ និងកាមសុខក្នុងលោក ត្រង់ពាក្យថា ល្បែង បានដល់ ល្បែង ២ យ៉ាង គឺ ល្បែងប្រកបដោយកាយ ១ ល្បែងប្រកបដោយវាចា ១ ។បេ។ នេះល្បែងប្រកបដោយកាយ ។បេ។ នេះល្បែងប្រកបដោយវាចា ។ ពាក្យថា សេចក្តីត្រេកអរ ចំពោះពាក្យថា សេចក្តីត្រេកអរនេះ ជាឈ្មោះនៃសេចក្តីមិនអផ្សុក ។ ពាក្យថា កាមសុខ សេចក្តីថា មែនពិត ព្រះមានព្រះភាគបានត្រាស់ព្រះពុទ្ធដីកានេះថា ម្នាលភិក្ខុទាំងឡាយ កាមគុណនេះ មាន ៥ កាមគុណ ៥ តើដូចម្តេច រូប ដែលគប្បីដឹងដោយភ្នែក ជាទីប្រាថ្នា ជាទីត្រេកអរ ជាទីគាប់ចិត្ត មានសភាពគួរស្រឡាញ់ ប្រកបដោយសេចក្តីប្រាថ្នា ជាទីតាំងនៃសេចក្តីត្រេកអរ សំឡេង ដែលគប្បីដឹងដោយត្រចៀក ក្លិន ដែលគប្បីដឹងដោយប្រមុះ រស ដែលគប្បីដឹងដោយអណ្តាត ផោដ្ឋព្វៈ ដែលគប្បីដឹងដោយកាយ ជាទីប្រាថ្នា ជាទីត្រេកអរ ជាទីគាប់ចិត្ត មានសភាពគួរស្រឡាញ់ ប្រកបដោយសេចក្តីប្រាថ្នា ជាទីតាំងនៃសេចក្តីត្រេកអរ ម្នាលភិក្ខុទាំងឡាយ នេះឯងកាមគុណ ៥ ម្នាលភិក្ខុទាំងឡាយ សេចក្តីសុខសោមនស្សណា កើតឡើងព្រោះអាស្រ័យកាមគុណ ៥ នេះ សេចក្តីសុខសោមនស្សនេះ តថាគតហៅថា កាមសុខ ហេតុនោះ ( លោកពោលថា ) កាមសុខ ។ ពាក្យថា

ក្នុងលោក គឺក្នុងមនុស្សលោក ហេតុនោះ ( លោកពោលថា ) នូវល្បែង នូវសេចក្តីត្រេកអរ និងកាមសុខក្នុងលោក ។

[ ៣២៦ ] ពាក្យថា មិនអើពើ មិនអាឡោះអាល័យ សេចក្តីថា មិនអើពើ មិនអាឡោះអាល័យ គឺថាលះបង់ បន្ទោបង់ ធ្វើឲ្យវិនាស ឲ្យដល់នូវការមិនកើតមាននូវល្បែងផង នូវសេចក្តីត្រេកអរផង នូវកាមសុខផង ក្នុងលោក ហេតុនោះ ( លោកពោលថា ) មិនអើពើ មិនអាឡោះអាល័យ ។

[ ៣២៧ ] អធិប្បាយពាក្យថា ជាអ្នកវៀរចាកគ្រឿងស្អិតស្អាង អ្នកពោលពាក្យពិត ត្រង់ពាក្យថា គ្រឿងស្អិតស្អាង សំដៅយកគ្រឿងស្អិតស្អាង ២ យ៉ាង គឺគ្រឿងស្អិតស្អាងសម្រាប់គ្រហស្ថក៏មាន គ្រឿងស្អិតស្អាងសម្រាប់បព្វជិតក៏មាន ។

គ្រឿងស្អិតស្អាងសម្រាប់គ្រហស្ថ តើដូចម្តេច ។ សក់ ពុកមាត់ ពុកចង្កា ផ្កាកម្រង គ្រឿងក្រអូប គ្រឿងស្រឡាប គ្រឿងអាភរណៈ គ្រឿងប្រដាប់ សំពត់ គ្រឿងសម្អាង ឈ្នួត គ្រឿងអប់ ការប្រេបាច់រឹត ការផ្ងូតទឹក ការគក់ប្របាច់ កញ្ចក់ គ្រឿងបន្តក់ កម្រងផ្កា គ្រឿងលាប លម្អិតសម្រាប់ប្រស់មុខ វត្ថុសម្រាប់លាបមុខ គ្រឿងប្រដាប់ដៃ ប្រដាប់ផ្នួងសក់ ដំបងបំពង់ថ្នាំ ព្រះខ័ន ឆត្រ ស្បែកជើង ក្បាំងមុខ ស៊ែ សំពត់ស វែងខ្វះ ខ្លីខ្វះ នេះគ្រឿងស្អិតស្អាតសម្រាប់គ្រហស្ថ ។

គ្រឿងស្អិតស្អាងសម្រាប់បព្វជិត តើដូចម្តេច ។ គ្រឿងប្រដាប់ចីវរ គ្រឿងប្រដាប់បាត្រ គ្រឿងប្រដាប់សេនាសនៈ ការប្រដាប់ ការស្អិតស្អាង ការលេង

ការលេងសព្វ ការជាប់ចិត្ត សេចក្តីជាប់ចិត្ត ការតាក់តែង សេចក្តីតាក់តែងនូវកាយស្អុយនេះ ឬនូវបរិក្ខារខាងក្រៅ នេះគ្រឿងស្អិតស្អាងសម្រាប់បព្វជិត ។

ពាក្យថា អ្នកពោលពាក្យពិត សេចក្តីថា ព្រះបច្ចេកសម្ពុទ្ធនោះ ជាអ្នកពោលពាក្យពិត តពាក្យពិត មានសម្តីទៀង មានសម្តីគួរជឿ មិនបោកប្រាសសត្វលោក គឺជាអ្នកនៅឆ្ងាយ វៀរស្រឡះ ឃ្លាតចេញ រលាស់ចេញ ផុតស្រឡះ ប្រាសចេញចាកគ្រឿងស្អិតស្អាង នៅដោយចិត្តដែលប្រាសចាកដែនគឺកិលេស ហេតុនោះ ( លោកពោលថា ) ជាអ្នកវៀរចាកគ្រឿងស្អិតស្អាង អ្នកពោលនូវពាក្យពិត ។ គប្បីប្រព្រឹត្តម្នាក់ឯង ដូចកុយរមាស ។ ព្រោះហេតុនោះ ព្រះបច្ចេកសម្ពុទ្ធនោះពោលថា

បុគ្គលមិនអើពើ មិនអាឡោះអាល័យនូវល្បែង នូវសេចក្តីត្រេកអរ
និងកាមសុខក្នុងលោក ជាអ្នកវៀរចាកគ្រឿងស្អិតស្អាង អ្នកពោល
ពាក្យពិត គប្បីប្រព្រឹត្តម្នាក់ឯង ដូចកុយរមាស ។

# អដ្ឋកថា

## គាថាទី ៥

គប្បីជ្រាបវិនិច្ឆ័យក្នុងគាថាទី ៥ ដូចតទៅ

[ ៣២៤ ] ការលេង និងការត្រេកអរ បានពោលហើយខាងដើម ។ បទថា **កាមសុខំ** បានដល់ សុខក្នុងវត្ថុកាម ពិតហើយ វត្ថុកាម លោកពោលថា ជាសេចក្ដីសុខ ដោយភាពជានិស្ស័យជាដើមនៃសេចក្ដីសុខ ។ ដូចព្រះមានព្រះភាគត្រាស់ ( ក្នុងសំយុត្តនិកាយ ខន្ធវារវគ្គ ) ថា រូបនេះជាសុខ មានសុខជាប់តាម ដូច្នេះ ។ ព្រះបច្ចេកសម្ពុទ្ធមិនធ្វើនូវការពេញចិត្ត គឺមិនធ្វើនូវការពេញចិត្តក្នុងការលេង ការត្រេកអរ និងកាមសុខក្នុងឱកាសលោកនេះ មិនពិចារណាយ៉ាងនេះថា មានប្រការដូច្នេះ ឬជាសារៈ ។ បទថា **អនបេក្ខមានោ** បានដល់ មានប្រក្រតីមិនសម្លឹង ដោយមិនធ្វើនូវការពេញចិត្ត មិនប្រាថ្នា មិនចង់បាន ជាអ្នកវៀរចាកគ្រឿងស្អិតស្អាង អ្នកពោលពាក្យពិត គប្បីប្រព្រឹត្តម្នាក់ឯង ។

ក្នុងបទទាំងនោះ គ្រឿងប្រដាប់មាន ២ យ៉ាង គឺគ្រឿងប្រដាប់សម្រាប់អ្នកគ្រប់គ្រងផ្ទះ មានសំពត់សាដក ឈ្នួតក្បាល ផ្កា និងគ្រឿងក្រអូបជាដើម ១ គ្រឿងប្រដាប់សម្រាប់បព្វជិត មានគ្រឿងតាក់តែងឆត្រជាដើម ១ គ្រឿងប្រដាប់នោះឯង ឈ្មោះថា **វិភូសនដ្ឋានំ** ។ ព្រោះហេតុនោះ គប្បីឃើញសេចក្ដីយ៉ាងនេះថា ព្រះបច្ចេកសម្ពុទ្ធវៀរចាកឋានៈនៃការប្រដាប់ ដោយវិរតិ ៣ យ៉ាង ជាអ្នកពោលពិត ព្រោះពោលមិនឃ្លៀងឃ្លាតដូច្នេះ ។ល។

**អដ្ឋកថា គាថាទី ៥ ចប់**

# សុត្តន្តបិដក

[ ៣២៨ ] បុគ្គល លះបង់នូវបុត្រ ប្រពន្ធ បិតា មាតា ទ្រព្យ ស្រូវ ផៅពង្ស និងកាមទាំងឡាយ តាមថ្នាក់ តាមជាន់ហើយ គប្បីប្រព្រឹត្តម្នាក់ឯង ដូចកុយរមាស ។

[ ៣២៩ ] ពាក្យថា បុត្រ ប្រពន្ធ បិតា មាតា ត្រង់ពាក្យថា បុត្រ បានដល់ បុត្រ ៤ ពួក គឺបុត្រកើតអំពីខ្លួន ១ បុត្រកើតក្នុងខេត្ត ១ បុត្រដែលគេឲ្យ ១ បុត្រ គឺកូនសិស្ស ១ ។ ភរិយាទាំងឡាយ ហៅថា ប្រពន្ធ ។ ពាក្យថា បិតា បានដល់ បុរសអ្នកបង្កើតកូន ។ ពាក្យថា មាតា បានដល់ ស្ត្រីអ្នកបង្កើតកូន ហេតុនោះ ( លោកពោលថា ) បុត្រ ប្រពន្ធ បិតា មាតា ។

[ ៣៣០ ] ពាក្យថា ទ្រព្យ ស្រូវ ផៅពង្ស គឺកែវមុក្តា កែវមណី កែវពៃទូរ្យ ស័ង្ខ ថ្ម កែវប្រពាល ប្រាក់ មាស កែវទទឹម កែវមក៌ត ហៅថា ទ្រព្យ ។ បុព្វន្នជាត ( វត្ថុដែលត្រូវបរិភោគមុន ) អបរន្នជាត ( វត្ថុដែលត្រូវបរិភោគក្រោយ ) ហៅថា ស្រូវ ។ ស្រូវខ្សាយស ស្រូវខ្សាយក្រហម ស្រូវជំណើប ស្រងែ ស្គួរ ស្កួយ គែលលក ឈ្មោះថា បុព្វន្នជាត ។ គ្រឿងសម្ល ឈ្មោះថា អបរន្នជាត ។ ពាក្យថា ផៅពង្ស បានដល់ ផៅពង្ស ៤ ពួក គឺបុគ្គលជាប់ដោយញាតិ ឈ្មោះថា ផៅពង្ស ១ បុគ្គលជាប់ដោយគោត្រ ឈ្មោះថា ផៅពង្ស ១ បុគ្គលជាប់ដោយមិត្ត ឈ្មោះថា ផៅពង្ស ១ បុគ្គលជាប់ដោយសិល្បៈ ឈ្មោះថា ផៅពង្ស ១ ហេតុនោះ ( លោកពោលថា ) ទ្រព្យ ស្រូវ ផៅពង្ស ។

[ ៣៣១ ] អធិប្បាយពាក្យថា លះបង់កាមទាំងឡាយ តាមថ្នាក់ តាម

ជាន់ ត្រង់ពាក្យថា កាម តាមឧទ្ទាន កាមមាន ២ វត្ថុកាម ១ កិលេសកាម ១ ។បេ។ ទាំងនេះ ហៅថា វត្ថុកាម ។បេ។ ទាំងនោះ ហៅថា កិលេសកាម ។ ពាក្យថា លះបង់កាមទាំងឡាយ គឺកំណត់ដឹងនូវវត្ថុកាម ហើយលះបង់ ផ្តាច់បង់ បន្ទោបង់ ធ្វើឲ្យវិនាស ឲ្យដល់នូវការមិនកើតមាននូវកិលេសកាម ហេតុនោះ ( លោកពោលថា ) លះបង់កាមទាំងឡាយ ពាក្យថា តាមថ្នាក់ តាមជាន់ គឺកិលេសទាំងឡាយណាដែលព្រះបច្ចេកសម្ពុទ្ធលះបង់ហើយ ដោយសោតាបត្តិមគ្គ លោកមិនមក មិនវិលមក មិនត្រឡប់មកកាន់កិលេសទាំងនោះទេ កិលេសទាំងឡាយណាដែលលោកលះបង់ ដោយសកទាគាមិមគ្គ កិលេសទាំងឡាយណាដែលលោកលះបង់ហើយ ដោយអនាគាមិមគ្គ កិលេសទាំងឡាយណាដែលលោកលះបង់ហើយ ដោយអរហត្តមគ្គ លោកមិនមក មិនវិលមក មិនត្រឡប់មកកាន់កិលេសទាំងនោះទេ ហេតុនោះ ( លោកពោលថា ) លះបង់នូវកាមទាំងឡាយ តាមថ្នាក់ តាមជាន់ ។ គប្បីប្រព្រឹត្តម្នាក់ឯងដូចកុយរមាស ។ ព្រោះហេតុនោះ ព្រះបច្ចេកសម្ពុទ្ធនោះពោលថា

> បុគ្គល លះបង់នូវបុត្រ ប្រពន្ធ បិតា មាតា ទ្រព្យ ស្រូវ ផៅពង្ស
> និងកាមទាំងឡាយ តាមថ្នាក់ តាមជាន់ហើយ គប្បីប្រព្រឹត្តម្នាក់
> ឯង ដូចកុយរមាស ។

# អដ្ឋកថា

## គាថាទី ៦

គប្បីជ្រាបវិនិច្ឆ័យក្នុងគាថាទី ៦ ដូចតទៅ

[ ៣២៨ ] បទថា **ធនានិ** បានដល់ រតនៈ មានកែវមុក្តា កែវមណី កែវពិទូរ្យ ស័ង្ខ សិលា កែវប្រពាល ប្រាក់ និងមាសជាដើម ។

បទថា **ធញ្ញានិ** បានដល់ ធញ្ញជាតិ ៧ ប្រភេទ គឺស្រូវសាលី ស្រូវខ្សាយ ស្រូវជំណើប ស្រងែ ថ្កា ស្កួយ ស្មៅគែលលក និងអបរន្ន-ជាតិដ៏សេស ។ បទថា **ពន្ធវានិ** បានដល់ ផៅពង្ស ៤ ប្រភេទ គឺផៅពង្សដែលជាញាតិ ១ ផៅពង្សដោយគោត្រ ១ ផៅពង្សដោយមិត្រ ១ ផៅពង្សដោយសិប្បៈ ១ ។ បទថា **យថោធិកានិ** បានដល់ តាំងនៅតាមចំណែករៀងៗ ខ្លួន បទដ៏សេស មានន័យដូចពោលហើយនោះឯង ។៚

**អដ្ឋកថា គាថាទី ៦ ចប់**

# សុត្តន្តបិដក

[ ៣៣២ ] កាមគុណនេះជាគ្រឿងជំពាក់ សេចក្តីសុខក្នុងកាមគុណនេះ មានប្រមាណតិច កាមគុណនេះ មានសេចក្តីត្រេកអរតិច សេចក្តីទុក្ខ ក្នុងកាមគុណនេះ មានច្រើនក្រៃលែង កាមគុណនេះជាពក បុគ្គលអ្នកមានប្រាជ្ញា បានដឹងដូច្នេះហើយ គប្បីប្រព្រឹត្តម្នាក់ឯង ដូចកុយរមាស ។

[ ៣៣៣ ] អធិប្បាយពាក្យថា កាមគុណនេះ ជាគ្រឿងជាប់ជំពាក់ សេចក្តីសុខក្នុងកាមនេះ មានប្រមាណតិច ពាក្យថា គ្រឿងជំពាក់ក្តី ថាសន្ទូចក្តី ថានុយក្តី ថាគ្រឿងជួក់ក្តី ថាកង្វល់ក្តី នេះជាឈ្មោះនៃកាមគុណទាំង ៥ ។ ពាក្យថា សេចក្តីសុខក្នុងកាមនេះ មានប្រមាណតិច សេចក្តីថាមែនពិត ព្រះមានព្រះភាគ បានត្រាស់ព្រះពុទ្ធដីកានេះថា ម្នាលភិក្ខុទាំងឡាយ កាមគុណនេះមាន ៥ កាមគុណ ៥ តើដូចម្តេច រូបដែលគប្បីដឹងដោយភ្នែក ជាទីប្រាថ្នា ជាទីត្រេកអរ ជាទីគាប់ចិត្ត មានសភាពគួរស្រឡាញ់ ប្រកបដោយសេចក្តីប្រាថ្នា ជាទីតាំងនៃសេចក្តីត្រេកអរ សំឡេងដែលគប្បីដឹងដោយត្រចៀក ក្លិនដែលគប្បីដឹងដោយច្រមុះ រសដែលគប្បីដឹងដោយអណ្តាត ផ្សព្វដែលគប្បីដឹងដោយកាយ ជាទីប្រាថ្នា ជាទីត្រេកអរ ជាទីគាប់ចិត្ត មានសភាពគួរស្រឡាញ់ ប្រកបដោយសេចក្តីប្រាថ្នា ជាទីតាំងនៃសេចក្តីត្រេកអរ ម្នាលភិក្ខុទាំងឡាយ ទាំងនេះឯងកាមគុណ ៥ ម្នាលភិក្ខុទាំងឡាយ សេចក្តីសុខសោមនស្សណា កើតឡើងព្រោះអាស្រ័យកាមគុណ ៥ នេះ សេចក្តីសុខសោមនស្សនេះ តថាគតហៅថា កាមសុខ សេចក្តីសុខនេះ មានប្រមាណ

តិច សេចក្តីសុខនេះ ថោកទាប សេចក្តីសុខនេះ លាមក សេចក្តីសុខនេះ នាំមកនូវទុក្ខ ហេតុនោះ ( លោកពោលថា ) កាមគុណនេះ ជាគ្រឿងជំពាក់ សេចក្តីសុខក្នុងកាមនេះ មានប្រមាណតិច ។

[ ៣៣៤ ] ពាក្យថា កាមគុណនេះ មានសេចក្តីត្រេកអរតិច សេចក្តីទុក្ខក្នុងកាមគុណនេះ មានច្រើនក្រៃលែង អធិប្បាយថា កាមទាំងឡាយ ព្រះមានព្រះភាគត្រាស់ថា មានសេចក្តីត្រេកអរតិច មានទុក្ខច្រើន មានសេចក្តីចង្អៀតចង្អល់ច្រើន ទោសក្នុងកាមនេះ មានច្រើនក្រៃលែង ។ កាមទាំងឡាយ ព្រះមានព្រះភាគត្រាស់ថា មានឧបមាដោយរាងឆ្អឹង ។ កាមទាំងឡាយ ព្រះមានព្រះភាគត្រាស់ថា មានឧបមាដោយដុំសាច់ ។ កាមទាំងឡាយ ព្រះមានព្រះមានព្រះភាគត្រាស់ថា មានឧបមាដោយគប់ភ្លើង ។ កាមទាំងឡាយ ព្រះមានព្រះភាគត្រាស់ថា មានឧបមាដោយរណ្តៅរងើកភ្លើង ។ កាមទាំងឡាយ ព្រះមានព្រះភាគត្រាស់ថា មានឧបមាដោយការយល់សប្តិ ។ កាមទាំងឡាយ ព្រះមានព្រះភាគត្រាស់ថា មានឧបមាដោយរបស់ខ្ចីគេ ។ កាមទាំងឡាយ ព្រះមានព្រះភាគត្រាស់ថា មានឧបមាដោយផ្លែឈើ ។ កាមទាំងឡាយ ព្រះមានព្រះភាគត្រាស់ថា មានឧបមាដោយកាំបិត និងជ្រញ់ ។ កាមទាំងឡាយ ព្រះមានព្រះភាគត្រាស់ថា មានឧបមាដោយចុងលំពែង ។ កាមទាំងឡាយ ព្រះមានព្រះភាគត្រាស់ថា មានឧបមាដោយក្បាលពស់ កាមទាំងឡាយមានទុក្ខច្រើន មានសេចក្តីចង្អៀតចង្អល់ច្រើន ទោសក្នុងកាមនេះមានច្រើនក្រៃលែង ហេតុនោះ ( លោពោលថា ) កាមមានសេចក្តីត្រេកអរតិច ទុក្ខក្នុងកាមនេះ

មានច្រើនក្រៃលែង ។

[ ៣៣៥ ] អធិប្បាយពាក្យថា កាមគុណនេះជាពក បុគ្គលអ្នកមានប្រាជ្ញាដឹងដូច្នេះហើយ ពាក្យថា ពកក្តី ថាសន្ទូចក្តី ថាន្ទុយក្តី ថាកន្លល់ក្តី នេះជាឈ្មោះនៃកាមគុណ ៥ ។ ពាក្យថា ដូច្នេះ ជាតំណាបទ ជាពាក្យភ្ជាប់បទ ជាពាក្យបំពេញបទ ជាពាក្យប្រជុំអក្ខរៈ ជាពាក្យសម្រួលព្យញ្ជនៈ ពាក្យថា ដូច្នេះ នេះជាលំដាប់បទ ។ ពាក្យថា កាមគុណនេះជាពក បុគ្គលអ្នកមានប្រាជ្ញាដឹងដូច្នេះហើយ បានសេចក្តីថា គឺបុគ្គលអ្នកមានគំនិត ជាបណ្ឌិតមានប្រាជ្ញា មានការត្រាស់ដឹង មានញាណ មានប្រាជ្ញាភ្លឺច្បាស់ មានប្រាជ្ញាជាគ្រឿងទម្លាយនូវកិលេស ដឹងថា ជាពក ដឹងថា ជាសន្ទូច ដឹងថា ជាន្ទុយ ដឹងថា ជាគ្រឿងជាប់ ដឹង យល់ ថ្លឹង ត្រិះរិះ ធ្វើឲ្យជាក់ច្បាស់ ធ្វើឲ្យប្រាកដថាជាកន្លល់ ហេតុនោះ ( លោកពោលថា ) កាមគុណនេះជាពក បុគ្គលអ្នកមានប្រាជ្ញា ដឹងដូច្នេះហើយ ។ គប្បីប្រព្រឹត្តម្នាក់ឯង ដូចកុយរមាស ។ ហេតុនោះ ព្រះបច្ចេកសម្ពុទ្ធនោះពោលថា

> កាមគុណនេះជាគ្រឿងជំពាក់ សេចក្តីសុខក្នុងកាមគុណនេះ មានប្រមាណតិច កាមគុណនេះ មានសេចក្តីត្រេកអរតិច សេចក្តីទុក្ខក្នុងកាមគុណនេះ មានច្រើនក្រៃលែង កាមគុណនេះជាពក បុគ្គលអ្នកមានប្រាជ្ញាដឹងដូច្នេះហើយ គប្បីប្រព្រឹត្តម្នាក់ឯង ដូចកុយរមាស ។

# អដ្ឋកថា

## គាថាទី ៧

គប្បីជ្រាបវិនិច្ឆ័យក្នុងគាថាទី ៧ ដូចតទៅ

[ ៣៣២ ] បទថា **សង្គោ ឯសោ** ព្រះបច្ចេកសម្ពុទ្ធសម្តែងដល់គ្រឿងឧបភោគរបស់ខ្លួន ។ កាមនោះ ឈ្មោះថា **សង្គោ** ព្រោះសត្វទាំងឡាយរមែងជាប់ជំពាក់ក្នុងកាមនោះ ដូចដំរីជាប់ក្នុងភក់ ដូច្នោះ ។ បទថា **បរិត្ត-មេត្ថ សោខ្យំ** សេចក្តីថា ក្នុងបញ្ចកាមគុណនេះ ដែលមានសុខតិច ព្រោះជារបស់ថោកថយ ព្រោះឲ្យកើតនូវការសម្គាល់ខុស ក្នុងការបរិភោគកាមគុណ ៥ ឬព្រោះទាក់ទងក្នុងធម៌ដែលជាកាមាវចរ ។ លោកអធិប្បាយថា ប្រព្រឹត្តទៅអស់កាលបន្តិចបន្តួច ដូចសេចក្តីសុខក្នុងការឃើញនូវការរាំត្រង់ពន្លឺដែលកើតឡើងអំពីផ្លេកបន្ទោរ ដូច្នោះ ។ បទថា **អប្បស្សាទោ ទុក្ខមេត្ថ ភិយ្យោ** សេចក្តីថា ក្នុងបទនេះ ព្រះមានព្រះភាគត្រាស់ ( មជ្ឈិមនិកាយ មូល-បណ្ណាសក ) ថា ម្នាលភិក្ខុទាំងឡាយ សេចក្តីសុខសោមនស្ស កើតឡើងព្រោះអាស្រ័យកាមគុណទាំង ៥ ប្រការនេះ នេះឯងជាតម្រេករបស់កាមទាំងឡាយ ដូច្នេះ ។ ព្រះមានព្រះភាគត្រាស់ដល់ទុក្ខ ដោយន័យជាដើមយ៉ាងនេះថា ម្នាលភិក្ខុទាំងឡាយ ចុះអ្វីជាទោសរបស់កាមទាំងឡាយ ។ ម្នាលភិក្ខុទាំងឡាយ កុលបុត្រក្នុងលោកនេះ ចិញ្ចឹមជីវិតដោយសេចក្តីប្រឹងប្រែង ដោយសិល្បសាស្ត្រណាមួយ ទោះបីដោយការរាប់ម្រាមដៃទទេក្តី ដោយការរាប់លេខនព្វន្តក្តី ដូច្នេះ ។ ព្រោះប្រៀបគ្នានឹងទុក្ខនោះ សេចក្តីសុខក្នុងកាមគុណទើបឈ្មោះថា តិច គឺប៉ុនតំណក់ទឹក ដែលពិត សេចក្តីទុក្ខប៉ុណ្ណោះ ច្រើន

*ក្រៃលែង ប្រៀបបាននឹងទឹកក្នុងមហាសមុទ្រទាំង ៤ ដោយហេតុនោះ ទើបលោកពោលថា* **អប្បស្សាទោ ទុក្ខមេត្ថ ភិយ្យោ** *ដូច្នេះ ។ បទថា* **គណ្ឌោ ឯសោ** *សេចក្តីថា កាម គឺកាមគុណ ៥ ប្រៀបដូចសន្ទូច ដោយអំណាចសម្តែងនូវការត្រេកអរ ហើយទាញមក ។ បទថា* **ឥតិ ញត្វា មតិមា** *សេចក្តីថា បុរសជាអ្នកប្រាជ្ញដឹងយ៉ាងនេះហើយ លះនូវកាមទាំងអស់នោះគប្បីត្រាច់ទៅតែម្នាក់ឯង ដូចកុយរមាស ដូច្នោះ ។៕*

## អដ្ឋកថា គាថាទី ៧ ចប់

# សុត្តន្តបិដក

[ ៣៣៦ ] បុគ្គល ទម្លាយនូវសំយោជនៈទាំងឡាយ ដូចសត្វត្រាច់ទៅក្នុងទឹក ដែលទម្លាយនូវបណ្តាញ គេមិនត្រឡប់មក ( រកសំយោជនៈវិញ ) ដូចភ្លើងឆេះ ( មិនត្រឡប់វិលវិញ ) គប្បីប្រព្រឹត្តម្នាក់ឯង ដូចកុយរមាស ។

[ ៣៣៧ ] ពាក្យថា ទម្លាយនូវសំយោជនៈទាំងឡាយ បានដល់សំយោជនៈទាំង ១០ គឺកាមរាគសំយោជនៈ បដិឃសំយោជនៈ មានសំយោជនៈទិដ្ឋិសំយោជនៈ វិចិកិច្ឆាសំយោជនៈ សីលព្វតបរាមាសសំយោជនៈ ភវរាគសំយោជនៈ ឥស្សាសំយោជនៈ មច្ឆរិយសំយោជនៈ អវិជ្ជាសំយោជនៈ ។ ពាក្យថា ទម្លាយនូវសំយោជនៈទាំងឡាយ គឺទម្លាយ ទម្លាយចោល លះបង់បន្ទោបង់ ធ្វើឲ្យវិនាស ឲ្យដល់នូវការមិនកើតមាន នូវសំយោជនៈទាំង ១០ ហេតុនោះ ( លោកពោលថា ) ទម្លាយនូវសំយោជនៈទាំងឡាយ ។

[ ៣៣៨ ] ពាក្យថា ដូចសត្វត្រាច់ទៅក្នុងទឹក ដែលទម្លាយនូវបណ្តាញ អធិប្បាយថា សំណាញ់ដែលគេត្បាញដោយអំបោះ ហៅថា បណ្តាញ ។ ឧទក ហៅថា ទឹក ។ ត្រី ហៅថា សត្វត្រាច់ទៅក្នុងទឹក ។ ត្រីទម្លាយ ទម្លុះ ហែក ប្រឹងទម្លាយ ប្រឹងទម្លុះ នូវសំណាញ់ ហើយចរ ត្រាច់ ទៅ ប្រព្រឹត្ត រក្សា យាត្រា ឲ្យយាត្រាទៅ ។ បណ្តាញ មាន ២ គឺបណ្តាញ គឺតណ្ហា ១ បណ្តាញ គឺទិដ្ឋិ ១ ។បេ។ នេះ បណ្តាញ គឺតណ្ហា ។បេ។ នេះ បណ្តាញ គឺទិដ្ឋិ ។ ព្រះបច្ចេកសម្ពុទ្ធនោះ លះបង់នូវបណ្តាញ គឺតណ្ហា បានរលាស់ចោលនូវបណ្តាញ គឺទិដ្ឋិ ដូចត្រីទម្លាយសំណាញ់យ៉ាងនោះឯង ។ ព្រោះ

លះបង់នូវបណ្ដាញ គឺតណ្ហា ព្រោះលះបង់ចោលនូវបណ្ដាញ គឺទិដ្ឋិហើយ ទើបព្រះបច្ចេកសម្ពុទ្ធនោះ មិនជាប់ក្នុងរូប មិនជាប់ក្នុងសំឡេង មិនជាប់ក្នុងក្លិន ។បេ។ មិនជាប់ មិនក្ដួចកាន់ មិនជំពាក់ក្នុងធម្មារម្មណ៍ ដែលឃើញ ឮ ប៉ះពាល់ ដឹងច្បាស់ គឺថា លោកឃ្លាត ចេញ រលាស់ចេញ ផុតស្រឡះ មិនប្រកប នៅដោយចិត្តដែលប្រាសចាកដែន គឺកិលេស ហេតុនោះ ( លោកពោលថា ) ដូចសត្វត្រាច់ទៅក្នុងទឹក ដែលទម្លាយនូវបណ្ដាញ ។

[ ៣៣៩ ] ពាក្យថា មិនត្រឡប់មក ( រកសំយោជនៈវិញ ) ដូចភ្លើងឆេះ ( មិនត្រឡប់វិលវិញ ) អធិប្បាយថា ភ្លើងកាលឆេះនូវចំណីភ្លើង គឺស្មៅនិងឧស រាលទៅ មិនវិលត្រឡប់វិញ យ៉ាងណា ព្រះបច្ចេកសម្ពុទ្ធនោះ លះបង់កិលេសទាំងឡាយណា ដោយសោតាបត្តិមគ្គហើយ លោកមិនមក មិនវិលមក មិនត្រឡប់មក រកកិលេសទាំងនោះទេ លោកលះបង់កិលេសទាំងឡាយណា ដោយសកទាគាមិមគ្គ លះបង់កិលេសទាំងឡាយណា ដោយអនាគាមិមគ្គ លះបង់កិលេសទាំងឡាយណា ដោយអរហត្តមគ្គ លោកមិនមក មិនវិលមក មិនត្រឡប់មករកកិលេសទាំងនោះទេ ក៏យ៉ាងនោះដែរ ហេតុនោះ ( លោកពោលថា ) ដូចភ្លើងឆេះ ( មិនត្រឡប់វិលវិញ ) ។ គប្បី

ប្រព្រឹត្តម្នាក់ឯង ដូចកុយរមាស ។ ហេតុនោះ ព្រះបច្ចេកសម្ពុទ្ធនោះពោលថា

បុគ្គល ទម្លាយនូវសំយោជនៈទាំងឡាយ ដូចសត្វត្រាច់ទៅក្នុងទឹក ដែលទម្លាយនូវបណ្តាញ មិនត្រឡប់មក ( រកសំយោជនៈវិញ ) ដូចភ្លើងឆេះ ( មិនត្រឡប់វិលវិញ ) គប្បីប្រព្រឹត្តម្នាក់ឯង ដូចកុយរមាស ។

# អដ្ឋកថា

## គាថាទី ៨

គប្បីជ្រាបវិនិច្ឆ័យក្នុងបាទទី ២ នៃគាថាទី ៨ ដូចតទៅ

[ ៣៣៦ ] វត្ថុដែលធ្វើដោយអំបោះ លោកហៅថា **ជាលំ** គឺសំណាញ់ ។ បទថា **អម្ពុ** ជាឈ្មោះរបស់ទឹក ។ ឈ្មោះថា **អម្ពុចារី** ព្រោះត្រាច់ទៅក្នុងទឹកនោះ ។ បទនេះ ជាឈ្មោះរបស់ត្រី ។ ត្រីរមែងត្រាច់ទៅក្នុងទឹក ទើបឈ្មោះថា **សលិលម្ពុចារី** មានពាក្យអធិប្បាយថា ដូចត្រីទម្លាយសំណាញ់ក្នុងទឹក ដូច្នោះ ។

គប្បីជ្រាបវិនិច្ឆ័យក្នុងបាទទី ៣ ដូច្នេះ ទីដែលត្រូវភ្លើងឆេះ ហៅថា **ទឌ្ឍំ** អធិប្បាយថា ភ្លើងដែលឆេះ មិនបានត្រឡប់មកកាន់ទីដែលឆេះហើយ គឺមិនត្រឡប់មកឆេះទីនោះវិញ យ៉ាងណា ព្រះបច្ចេកសម្ពុទ្ធក៏មិនត្រឡប់មកកាន់ទីនៃកាមគុណ ដែលភ្លើង គឺញាណឆេះហើយ គឺមិនត្រឡប់មកក្នុងកាមគុណនោះទៀត ដូច្នោះ បទដ៏សេស មានន័យដូចបានពោលហើយនោះឯង ។

[ ៣៣៧ ] ពាក្យថា **សញ្ញោជនានិ** មានវិគ្គហៈថា កិលេសពួកណាមានដល់បុគ្គលណា ក៏រមែងចងផ្ទាក់ គឺរមែងរួបរឹតបុគ្គលនោះទុកក្នុងវដ្ដៈ ព្រោះហេតុនោះ ទើបកិលេសទាំងនោះ ឈ្មោះថា **សំយោជន។** ម្យ៉ាងទៀត គួរនាំនូវសំយោជនៈទាំងនេះមកតាមលំដាប់នៃកិលេសខ្វះ តាមលំដាប់នៃមគ្គខ្វះ គឺកាមរាគសំយោជនៈ និងបដិឃសំយោជនៈ លះបានដោយអនាគាមិមគ្គ

មានសំយោជនៈ លះបានដោយអរហត្តមគ្គ ។ ទិដ្ឋិសំយោជនៈ វិចិកិច្ឆា-សំយោជនៈ សីលព្វតបរាមាសសំយោជនៈ លះបានដោយសោតាបត្តិមគ្គ ។ ភវរាគសំយោជនៈ លះបានដោយអរហត្តមគ្គ ឥស្សាសំយោជនៈ និងមច្ឆ-រិយសំយោជនៈ លះបានដោយសោតាបត្តិមគ្គ ។ អវិជ្ជាសំយោជនៈ លះបានដោយអរហត្តមគ្គ ។ ពោលតាមលំដាប់មគ្គ ទិដ្ឋិសំយោជនៈ វិចិកិច្ឆា-សំយោជនៈ សីលព្វតបរាមាសសំយោជនៈ ឥច្ឆាសំយោជនៈ និងមច្ឆរិយ-សំយោជនៈ លះបានដោយសោតាបត្តិមគ្គ ។ កាមរាគសំយោជនៈ និងបដិ-ឃសំយោជនៈ លះបានដោយអនាគាមិមគ្គ មានសំយោជនៈ ភវរាគ-សំយោជនៈ និងអវិជ្ជាសំយោជនៈ លះបានដោយអរហត្តមគ្គ ។

[ ៣៣៨ ] បទថា **ភិន្ទិត្វា** បានដល់ ធ្វើឲ្យដាច់ ។ បទថា **បភិន្ទិត្វា** បានដល់ ធ្វើឲ្យជាប្រហោង ។ បទថា **ទាលយិត្វា** បានដល់ ជ្រែកចេញទៅ ។ បទថា **បទាលយិត្វា** បានដល់ ត្បូលចេញទៅ ។ បទថា **សម្ប-ទាលយិត្វា** បានដល់ បម្រះចេញទៅ ៕

**អដ្ឋកថា គាថាទី ៨ ចប់**

# សុត្តន្តបិដក

[ ៣៨០ ] ភិក្ខុមានចក្ខុដាក់ចុះ ជាអ្នកមិនរពឹសជើង ជាអ្នកគ្រប់គ្រងឥន្ទ្រិយ រក្សាចិត្តទុក មានចិត្តមិនទទឹក មិនរោលរាល ( ដោយកិលេស ) គប្បីប្រព្រឹត្តម្នាក់ឯង ដូចកុយរមាស ។

[ ៣៨១ ] អធិប្បាយពាក្យថា ភិក្ខុមានចក្ខុដាក់ចុះ ជាអ្នកមិនរពឹសជើង សំណួរថា ភិក្ខុមានចក្ខុបោះទៅ តើដូចម្តេច ។ ភិក្ខុខ្លះ ក្នុងសាសនានេះ ជាអ្នករពឹសភ្នែក ប្រកបដោយការរពឹសភ្នែក ដោយគិតថា អាត្មាគប្បីឃើញនូវរបស់ដែលមិនធ្លាប់ឃើញ គប្បីរំលងចោលនូវរបស់ដែលធ្លាប់ឃើញហើយ ជាអ្នកប្រកបរឿយៗ នូវការត្រាច់ទៅឆ្ងាយៗ នូវការត្រាច់ទៅរឿយៗ ដើម្បីឃើញរូប គឺចេញអំពីអារាមទៅអារាម ចេញអំពីឧទ្យានទៅឧទ្យាន ចេញអំពីស្រុកទៅស្រុក ចេញអំពីនិគមទៅនិគម ចេញអំពីនគរទៅនគរ ចេញអំពីដែនទៅដែន ចេញអំពីជនបទទៅជនបទ ភិក្ខុជាអ្នកមានចក្ខុបោះទៅ យ៉ាងនេះឯង ។ មួយទៀត ភិក្ខុចូលទៅកាន់ចន្លោះផ្ទះ ដើរទៅកាន់ថ្នល់ មិនសង្រួមដើរទៅ ក្រឡេកមើលដំរី ក្រឡេកមើលសេះ ក្រឡេកមើលរថ ក្រឡេកមើលពលថ្មើរជើង ក្រឡេកមើលពួកក្មេងប្រុស ក្រឡេកមើលពួកក្មេងស្រី ក្រឡេកមើលពួកស្ត្រី ក្រឡេកមើលពួកបុរស ក្រឡេកមើលរានផ្សារ ក្រឡេកមើលមុខផ្ទះ ក្រឡេកមើលលើ ក្រឡេកមើលក្រោម ក្រឡេកមើលក្នុងទិសតូច និងទិសធំ ដើរទៅ ភិក្ខុជាអ្នកមានចក្ខុបោះទៅ យ៉ាងនេះខ្លះ ។ មួយទៀត ភិក្ខុឃើញនូវរូបដោយភ្នែក ជាអ្នកកាន់យកនូវនិមិត្ត កាន់យកនូវអនុព្យញ្ជនៈ អភិជ្ឈា និងទោមនស្ស ដែលជាអកុសលធម៌ដ៏លាមក គប្បីជាប់

តាមភិក្ខុដែលមិនសង្រួម នូវចក្ខុន្ទ្រិយនុ៎ះ ព្រោះហេតុមិនបានសង្រួមនូវចក្ខុន្ទ្រិយណា មិនប្រតិបត្តិដើម្បីសង្រួមនូវចក្ខុន្ទ្រិយនោះ មិនរក្សានូវចក្ខុន្ទ្រិយ មិនដល់នូវការសង្រួមក្នុងចក្ខុន្ទ្រិយ ភិក្ខុជាអ្នកមានចក្ខុបោះទៅ យ៉ាងនេះខ្លះ ។ មួយវិញទៀត សមណព្រាហ្មណ៍ដ៏ចម្រើនពួកខ្លះ បរិភោគភោជន ដែលគេឲ្យដោយសទ្ធាហើយ សមណព្រាហ្មណ៍ទាំងនោះ តែងប្រកបរឿយៗ នូវការមើលរបស់ដែលជាសត្រូវ មានសភាពយ៉ាងនេះ គឺរបាំ ចម្រៀង ប្រគំមហោស្រព ការនិយាយ ( រឿងស្តេចភារតៈ និងព្រះរាមជាដើម ) គងរគាំង ស្គរមានជ្រុង ៤ រូបគំនូរ ល្បែងដុំដែក ល្បែងកាវ ល្បែងលាងឆ្អឹង ប្រជល់ដំរី ប្រខាំសេះ ប្រជល់ក្របី ប្រជល់គោ ប្រជល់កែះ ប្រជល់មាន់ គុណជំបង ប្រដាល់ ចំបាប់ ទីសម្រាប់ច្បាំង ទីសម្រាប់រៀបពល ទីនៅសេនា ទីត្រួតកងទ័ព ភិក្ខុជាអ្នកប្រកបរឿយៗ នូវការមើលរបស់ដែលជាសត្រូវ មានសភាពយ៉ាងនេះ ដូច្នេះៗ ខ្លះ ភិក្ខុជាអ្នកមានចក្ខុបោះទៅ យ៉ាងនេះខ្លះ ។

ភិក្ខុជាអ្នកមានចក្ខុដាក់ចុះ តើដូចម្តេច ។ ភិក្ខុក្នុងសាសនានេះ មិនមែនជាអ្នករពឹសភ្នែក មិនមែនប្រកបដោយការរពឹសភ្នែក ដោយគិតថា អាត្មាអញគប្បីឃើញរបស់ ដែលមិនឃើញ គប្បីដើររំលង របស់ដែលបានឃើញហើយ ដូច្នេះទេ ជាអ្នកមិនប្រកបនូវការត្រាច់ទៅឆ្ងាយៗ នូវការត្រាច់ទៅរឿយៗ ដើម្បីឃើញរូបទេ គឺមិនចេញអំពីអារាមទៅអារាម មិនចេញអំពីឧទ្យានទៅឧទ្យាន មិនចេញអំពីស្រុកទៅស្រុក មិនចេញអំពីនិគមទៅនិគម មិនចេញអំពីនគរទៅនគរ មិនចេញអំពីដែនទៅដែន មិនចេញអំពីជនបទទៅជនបទ

ភិក្ខុជាអ្នកមានចក្ខុដាក់ចុះ យ៉ាងនេះខ្លះ ។ មួយទៀត ភិក្ខុចូលទៅកាន់ចន្លោះផ្ទះ ដើរទៅតាមថ្នល់ ជាអ្នកសង្រួមដើរទៅ មិនក្រឡេកមើលដំរី មិនក្រឡេកមើលសេះ មិនក្រឡេកមើលរថ មិនក្រឡេកមើលពលថ្មើរជើង មិនក្រឡេកមើលពួកក្មេងប្រុស មិនក្រឡេកមើលពួកក្មេងស្រី មិនក្រឡេកមើលពួកស្រី មិនក្រឡេកមើលពួកប្រុស មិនក្រឡេកមើលរានផ្សារ មិនក្រឡេកមើលមុខផ្ទះ មិនក្រឡេកមើលលើ មិនក្រឡេកមើលក្រោម មិនមៀងមើលក្នុងទិសតូច និងទិសធំ ដើរទៅ ភិក្ខុជាអ្នកមានចក្ខុដាក់ចុះ យ៉ាងនេះខ្លះ ។ មួយទៀត ភិក្ខុឃើញរូបដោយភ្នែក តែជាអ្នកមិនកាន់យកនូវនិមិត្ត មិនកាន់យកនូវអនុព្យញ្ជនៈ អភិជ្ឈា និងទោមនស្ស ដែលជាអកុសលធម៌ដ៏លាមក គប្បីជាប់តាមភិក្ខុអ្នកមិនសង្រួម នូវចក្ខុន្ទ្រិយនុ៎ះ ព្រោះហេតុមិនសង្រួមនូវចក្ខុន្ទ្រិយណា មិនប្រតិបត្តិដើម្បីសង្រួមនូវចក្ខុន្ទ្រិយនុ៎ះ រក្សានូវចក្ខុន្ទ្រិយ ដល់នូវការសង្រួមក្នុងចក្ខុន្ទ្រិយ ភិក្ខុជាអ្នកមានចក្ខុដាក់ចុះ យ៉ាងនេះខ្លះ ។ មួយវិញទៀត សមណព្រាហ្មណ៍ដ៏ចម្រើនពួកខ្លះ បរិភោគភោជន ដែលគេឲ្យដោយសទ្ធាហើយ សមណព្រាហ្មណ៍ទាំងនោះ មិនប្រកបរឿយៗ នូវការមើលនូវល្បែងដែលជាសត្រូវ មានសភាពយ៉ាងនេះ គឺរបាំ ចម្រៀង ប្រគំ ។បេ។ ទីសម្រាប់ត្រួតកងទ័ព ជាអ្នកវៀរចាកការប្រកបរឿយៗ នូវការមើលល្បែង ដែលជាសត្រូវ មានសភាពយ៉ាងនេះ ដូច្នេះៗ ភិក្ខុជាអ្នកមានចក្ខុដាក់ចុះ យ៉ាងនេះខ្លះ ។

អធិប្បាយពាក្យថា ជាអ្នកមិនរពឹសជើង សំណួរថា ភិក្ខុជាអ្នករពឹសជើង តើដូចម្តេច ។ ភិក្ខុខ្លះក្នុងសាសនានេះ ជាអ្នករពឹសជើង ប្រកបដោយ

ការរពឹសជើង ជាអ្នកប្រកបរឿយៗ នូវការត្រាច់ទៅឆ្ងាយៗ នូវការត្រាច់ទៅរឿយៗ គឺចេញអំពីអារាមទៅអារាម ចេញអំពីឧទ្យានទៅឧទ្យាន ចេញអំពីស្រុកទៅស្រុក ចេញអំពីនិគមទៅនិគម ចេញអំពីនគរទៅនគរ ចេញអំពីដែនទៅដែន ចេញអំពីជនបទទៅជនបទ ភិក្ខុជាអ្នករពឹសជើង យ៉ាងនេះខ្លះ ។ ម្យ៉ាងទៀត ភិក្ខុជាអ្នកប្រកបដោយការរពឹសជើង តែខាងក្នុងអារាមរបស់សង្ឃ ជាអ្នកមានចិត្តរាយមាយ មានចិត្តមិនស្ងប់ មិនមែនព្រោះហេតុប្រយោជន៍ មិនមែនព្រោះហេតុដំណើអ្វីទេ ចេញអំពីបរិវេណទៅបរិវេណ ចេញអំពីវិហារទៅវិហារ ចេញអំពីអឌ្ឍយោគទៅអឌ្ឍយោគ ចេញអំពីប្រាសាទទៅប្រាសាទ ចេញអំពីប្រាសាទត្រងិល ទៅប្រាសាទត្រងិល ចេញអំពីគុហាទៅគុហា ចេញអំពីលេណដ្ឋាន ទៅលេណដ្ឋាន ចេញអំពីខ្ទមទៅខ្ទម ចេញអំពីផ្ទះកំពូលទៅផ្ទះកំពូល ចេញអំពីប៉មទៅប៉ម ចេញអំពីរោងមូលទៅរោងមូល ចេញអំពីរោងដោលទៅរោងដោល ចេញអំពីឃ្លាំងរបស់ទៅឃ្លាំងរបស់ ចេញអំពីឧបដ្ឋានសាលា ទៅឧបដ្ឋានសាលា ចេញអំពីមណ្ឌបទៅមណ្ឌប ចេញអំពីគល់ឈើទៅគល់ឈើ បើពុំនោះទេ ពួកភិក្ខុអង្គុយ ឬដើរទៅក្នុងទីណា ( ភិក្ខុនោះ ) ជាគម្រប់ពីរនឹងភិក្ខុមួយរូបខ្លះ ជាគម្រប់បីនឹងភិក្ខុពីររូបខ្លះ ជាគម្រប់បួននឹងភិក្ខុបីរូបខ្លះ ក្នុងទីទាំងនោះ និយាយពាក្យឥតប្រយោជន៍ច្រើន ក្នុងទីនោះ គឺនិយាយរាជកថា ចោរកថា ។បេ។ ឥតិភវាភវកថា ដូច្នេះៗ ភិក្ខុជាអ្នករពឹសជើងយ៉ាងនេះខ្លះ ។ ពាក្យថា ជាអ្នកមិនរពឹសជើង សេចក្ដីថា ព្រះបច្ចេកសម្ពុទ្ធនោះ នៅឆ្ងាយ វៀរ វៀរលែង ចេញ រលាស់ចេញ រួចផុត ប្រាសចេញ

ចាកការពើសដោយជើង មានព្រះហឫទ័យមិនសល់វល់ មានការសម្ងំនៅក្នុងកម្មដ្ឋានជាទីត្រេកអរ ត្រេកអរក្នុងការសម្ងំ ប្រកបរឿយៗ នូវការស្ងប់ចិត្តក្នុងខាងក្នុង មិនឃ្លាតចាកឈាន ប្រកបដោយវិបស្សនា ចម្រើនសុញ្ញាគារដ្ឋាន ជាអ្នកមានឈាន ត្រេកអរក្នុងឈាន ប្រកបរឿយៗ នូវភាពនៃខ្លួន ជាបុគ្គលម្នាក់ឯង ជាអ្នកធ្ងន់ក្នុងប្រយោជន៍របស់ខ្លួន ហេតុនោះ ( លោកពោលថា ) មានចក្ខុដាក់ចុះ ទាំងមិនពើសជើង ។

[ ៣៤២ ] ពាក្យថា អ្នកគ្រប់គ្រងឥន្ទ្រិយ អធិប្បាយថា ព្រះបច្ចេកសម្ពុទ្ធនោះ ឃើញរូបដោយភ្នែក មិនកាន់យកនិមិត្ត មិនកាន់យកអនុព្យញ្ជនៈ ពួកអកុសលធម៌ដ៏លាមក គឺអភិជ្ឈា និងទោមនស្ស គប្បីជាប់តាមបុគ្គលមិនសង្រួមចក្ខុន្ទ្រិយនោះ ព្រោះហេតុមិនសង្រួមនូវចក្ខុន្ទ្រិយណា លោកប្រតិបត្តិដើម្បីសង្រួមចក្ខុន្ទ្រិយនោះ រក្សាចក្ខុន្ទ្រិយ ដល់នូវការសង្រួមក្នុងចក្ខុន្ទ្រិយ ឮសំឡេងដោយត្រចៀក ធុំក្លិនដោយច្រមុះ ទទួលរសដោយអណ្តាត ពាល់ត្រូវផោដ្ឋព្វៈដោយកាយ ដឹងធម្មារម្មណ៍ដោយចិត្ត មិនកាន់យកនិមិត្ត មិនកាន់យកអនុព្យញ្ជនៈ ពួកអកុសលធម៌ដ៏លាមក គឺអភិជ្ឈា និងទោមនស្ស គប្បីជាប់តាមបុគ្គលអ្នកមិនសង្រួមមនិន្ទ្រិយនោះ ព្រោះហេតុមិនសង្រួមមនិន្ទ្រិយណា លោកប្រតិបត្តិដើម្បីសង្រួមមនិន្ទ្រិយនោះ រក្សានូវមនិន្ទ្រិយ ដល់នូវការសង្រួមក្នុងមនិន្ទ្រិយ ហេតុនោះ ( លោកពោលថា ) ជាអ្នកគ្រប់គ្រងឥន្ទ្រិយ ។ ពាក្យថា រក្សាចិត្ត គឺគ្រប់គ្រងចិត្ត ថែទាំចិត្ត ហេតុនោះ ( លោកពោលថា ) ជាអ្នកគ្រប់គ្រងឥន្ទ្រិយ រក្សាចិត្ត ។

[ ៣៤៣ ] អធិប្បាយពាក្យថា មានចិត្តមិនទទឹក មិនរោលរាល ( ដោយកិលេស ) ត្រង់ពាក្យថា មានចិត្តមិនទទឹក សេចក្ដីថា ព្រះមហាមោគ្គល្លានមានអាយុ បានពោលពាក្យនេះថា ម្នាលលោកមានអាយុ ខ្ញុំនឹងសម្ដែងនូវបរិយាយនៃបុគ្គល មានចិត្តទទឹកផង នូវបរិយាយនៃបុគ្គល មានចិត្តមិនទទឹកផង ចំពោះអ្នកទាំងឡាយ ចូរអ្នកទាំងឡាយស្ដាប់នូវបរិយាយនោះ ចូរធ្វើទុកក្នុងចិត្តឲ្យល្អចុះ ខ្ញុំនឹងសម្ដែង ។ ភិក្ខុទាំងនោះ ទទួលស្ដាប់ព្រះមហាមោគ្គល្លានមានអាយុថា អើអាវុសោ ។ ព្រះមហាមោគ្គល្លានមានអាយុ បានពោលពាក្យនេះថា ម្នាលអាវុសោ បុគ្គលមានចិត្តទទឹក តើដូចម្ដេច ម្នាលអាវុសោ ភិក្ខុក្នុងសាសនានេះ ឃើញរូបដោយភ្នែកហើយ ងប់ក្នុងរូប មានសភាពជាទីស្រឡាញ់ ស្អប់ក្នុងរូប មានសភាពមិនជាទីស្រឡាញ់ មិនប្រុងសតិក្នុងកាយ មានចិត្តស្តួចស្តើងផង អកុសលធម៌ដ៏លាមកទាំងនោះ កើតឡើងដល់បុគ្គលនោះហើយ រលត់ទៅវិញមិនសេសសល់ ក្នុងវិមុត្តិណា ក៏មិនដឹងច្បាស់នូវចេតោវិមុត្តិ និងបញ្ញាវិមុត្តិនោះតាមពិតផង ឮសំឡេងដោយត្រចៀក ធុំក្លិនដោយច្រមុះ ទទួលរសដោយអណ្ដាត ពាល់ត្រូវសម្ផស្សដោយកាយ ដឹងធម្មារម្មណ៍ដោយចិត្តហើយ ងប់ក្នុងធម្មារម្មណ៍ មានសភាពជាទីស្រឡាញ់ ស្អប់ធម្មារម្មណ៍ដែលមានសភាពមិនជាទីស្រឡាញ់ មិនប្រុងសតិក្នុងកាយ មានចិត្តស្តួចស្តើងផង អកុសលធម៌ដ៏លាមកទាំងនោះ កើតឡើងដល់បុគ្គលនោះ ហើយរលត់ទៅវិញ មិនសេសសល់ក្នុងវិមុត្តិណា ក៏មិនដឹងច្បាស់ នូវចេតោវិមុត្តិ និងបញ្ញាវិមុត្តិនោះតាមពិតផង ម្នាលអាវុសោ ភិក្ខុ

នេះ គេហៅថា អ្នកមានចិត្តទទឹកក្នុងរូប ដែលគប្បីដឹងដោយភ្នែក អ្នកមានចិត្តទទឹកក្នុងសំឡេង ដែលគប្បីដឹងដោយត្រចៀក ។បេ។ អ្នកមានចិត្តទទឹកក្នុងធម្មារម្មណ៍ ដែលគប្បីដឹងដោយចិត្ត ម្នាលអាវុសោ ភិក្ខុមានកិរិយានៅយ៉ាងនេះ ប្រសិនបើមារចូលទៅជិតភិក្ខុនោះ តាមទ្វារភ្នែក មារគង់បាននូវឱកាស មារគង់បាននូវអារម្មណ៍ ប្រសិនបើ ( មារចូលទៅ ) ជិតភិក្ខុនោះ តាមទ្វារត្រចៀក ។បេ។ ប្រសិនបើមារចូលទៅជិតភិក្ខុនោះ តាមទ្វារចិត្ត មារគង់បាននូវឱកាស មារគង់បាននូវអារម្មណ៍ ម្នាលអាវុសោ ដូចផ្ទះបបុសក្ដី ផ្ទះស្មៅក្ដី ជាអាគារស្ងួត ពុក កន្លងយូរឆ្នាំ ប្រសិនបើបុរសកាន់គប់ស្មៅដែលភ្លើងឆេះ ទៅជិតផ្ទះនោះ ពីទិសខាងកើត ភ្លើងតែងបាននូវឱកាស ភ្លើងតែងបាននូវអារម្មណ៍ ប្រសិនបើ ( ទៅ ) ជិតផ្ទះនោះ ពីទិសខាងលិច ប្រសិនបើ ( ទៅ ) ជិតផ្ទះនោះ ពីទិសខាងជើង ប្រសិនបើ ( ទៅ ) ជិតផ្ទះនោះ ពីទិសខាងត្បូង ប្រសិនបើ ( ទៅ ) ជិតផ្ទះនោះពីខាងក្រោម ប្រសិនបើ ( ទៅ ) ជិតផ្ទះនោះពីខាងលើ ប្រសិនបើបុរសកាន់គប់ស្មៅដែលភ្លើងឆេះ ទៅជិតផ្ទះនោះ ពីទិសខាងណាក៏ដោយ ភ្លើងតែងបាននូវឱកាស ភ្លើងតែងបាននូវអារម្មណ៍ មានឧបមាយ៉ាងណាមិញ ម្នាលអាវុសោ ភិក្ខុមានកិរិយានៅយ៉ាងនេះ ប្រសិនបើមារចូលទៅជិតភិក្ខុនោះ តាមទ្វារភ្នែក មារគង់បាននូវឱកាស មារគង់បាននូវអារម្មណ៍ ប្រសិនបើ ( មារចូលទៅ ) ជិតភិក្ខុនោះ តាមទ្វារត្រចៀក ។បេ។ ប្រសិនបើមារចូលទៅជិតភិក្ខុនោះ តាមទ្វារចិត្ត មារតែងបាននូវឱកាស មារតែងបាននូវអារម្មណ៍ មានឧបមេយ្យដូច្នោះឯង ម្នាល

អាវុសោ រូបគ្របសង្កត់ភិក្ខុ អ្នកមានកិរិយានៅយ៉ាងនេះ ភិក្ខុមិនគ្របសង្កត់រូបបានឡើយ សំឡេងគ្របសង្កត់ភិក្ខុ ភិក្ខុមិនគ្របសង្កត់សំឡេងបានឡើយ ក្លិនគ្របសង្កត់ភិក្ខុ ភិក្ខុមិនគ្របសង្កត់ក្លិនបានឡើយ រសគ្របសង្កត់ភិក្ខុ ភិក្ខុមិនគ្របសង្កត់រសបានឡើយ ផ្សព្វគ្របសង្កត់ភិក្ខុ ភិក្ខុមិនគ្របសង្កត់ផ្សព្វបានឡើយ ម្នាលអាវុសោ ភិក្ខុនេះ គេហៅថា អ្នកត្រូវរូបគ្របសង្កត់ អ្នកត្រូវសំឡេងគ្របសង្កត់ អ្នកត្រូវក្លិនគ្របសង្កត់ អ្នកត្រូវរសគ្របសង្កត់ អ្នកត្រូវផ្សព្វគ្របសង្កត់ អ្នកត្រូវពួកកិលេសទាំងនោះ គ្របសង្កត់ ព្រោះថា ភិក្ខុនោះមិនបានគ្របសង្កត់នូវពួកអកុសលធម៌ដ៏លាមក ដែលប្រកបដោយសេចក្ដីសៅហ្មង នាំទៅកើតក្នុងភពថ្មីទៀត ប្រកបដោយសេចក្ដីក្រវល់ក្រវាយ មានទុក្ខជាផល មានជាតិ ជរា និងមរណៈតទៅខាងមុខទៀតទេ ម្នាលអាវុសោ ភិក្ខុមានចិត្តទទឹក យ៉ាងនេះឯង ។ ម្នាលអាវុសោ ភិក្ខុមានចិត្តមិនទទឹក តើដូចម្ដេច ម្នាលអាវុសោ ភិក្ខុក្នុងសាសនានេះ ឃើញរូបដោយភ្នែក មិនជាប់ក្នុងរូប មានសភាពជាទីស្រឡាញ់ មិនស្អប់រូប មិនជាទីស្រឡាញ់ ប្រុងសតិក្នុងកាយ មានចិត្តប្រមាណមិនបានផង អកុសលធម៌ដ៏លាមកទាំងនោះ កើតឡើងដល់បុគ្គលនោះហើយ រលត់ទៅមិនមានសេសសល់ ក្នុងវិមុត្តិណា ក៏ដឹងច្បាស់នូវចេតោវិមុត្តិ និងបញ្ញាវិមុត្តិនោះតាមពិតផង ឮសំឡេងដោយត្រចៀក ។បេ។ ដឹងធម្មារម្មណ៍ដោយចិត្ត មិនជាប់ក្នុងធម្មារម្មណ៍ មានសភាពជាទីស្រឡាញ់ មិនស្អប់ធម្មារម្មណ៍ មានសភាពមិនជាទីស្រឡាញ់ ប្រុងសតិក្នុងកាយ មានចិត្តប្រមាណមិនបានផង អកុសលធម៌ដ៏លាមកទាំងនោះ កើតឡើងដល់បុគ្គល

នោះហើយ រលត់ទៅមិនមានសេសសល់ ក្នុងវិមុត្តិណា ក៏ដឹងច្បាស់នូវចេតោ-វិមុត្តិ និងបញ្ញាវិមុត្តិនោះតាមពិតផង ម្នាលអាវុសោ ភិក្ខុនេះគេហៅថា អ្នកមានចិត្តមិនទទឹកក្នុងរូប ដែលគប្បីដឹងដោយភ្នែក អ្នកមានចិត្តមិនទទឹកក្នុងសំឡេង ដែលគប្បីដឹងដោយត្រចៀក ។បេ។ អ្នកមានចិត្តមិនទទឹកក្នុងធម្មារម្មណ៍ ដែលគប្បីដឹងដោយចិត្ត ម្នាលអាវុសោ ភិក្ខុមានកិរិយានៅយ៉ាងនេះ ប្រសិនបើមារចូលទៅជិតភិក្ខុនោះ តាមទ្វារភ្នែក មារមិនបាននូវឱកាស មារមិនបាននូវអារម្មណ៍ ប្រសិនបើមារ ( ចូលទៅ ) ជិតភិក្ខុនោះ តាមទ្វារត្រចៀក ។បេ។ ប្រសិនបើមារចូលទៅជិតភិក្ខុនោះ តាមទ្វារចិត្ត មារមិនបាននូវឱកាស មារមិនបាននូវអារម្មណ៍ ម្នាលអាវុសោ ប្រៀបដូចកូដាគារសាលាក្ដី សណ្ឋាគារសាលាក្ដី ដែលបូកដោយដីដ៏ក្រាស់ លាបដោយអាចម៍គោស្រស់ ប្រសិនបើបុរសកាន់គប់ស្មៅដែលភ្លើងឆេះ ទៅជិតសាលានោះ ពីទិសខាងកើត ភ្លើងមិនបាននូវឱកាស ភ្លើងមិនបាននូវអារម្មណ៍ ប្រសិនបើទៅជិតសាលានោះ ពីទិសខាងលិច ប្រសិនបើទៅជិតសាលានោះ ពីទិសខាងជើង ប្រសិនបើទៅជិតសាលានោះ ពីទិសខាងត្បូង ប្រសិនបើទៅជិតសាលានោះពីខាងក្រោម ប្រសិនបើទៅជិតសាលានោះពីខាងលើ ប្រសិនបើបុរសកាន់គប់ស្មៅដែលភ្លើងឆេះ ទៅជិតសាលានោះ ពីទិសខាងណាក៏ដោយ ភ្លើងមិនបាននូវឱកាស ភ្លើងមិនបាននូវអារម្មណ៍ មានឧបមាយ៉ាងណាមិញ ម្នាលអាវុសោ ភិក្ខុមានកិរិយានៅយ៉ាងនេះ ប្រសិនបើមារចូលទៅជិតភិក្ខុនោះ តាមទ្វារភ្នែក មារមិនបាននូវឱកាស មារមិនបាននូវអារម្មណ៍ ប្រសិនបើ ( ចូលទៅ ) ជិតភិក្ខុនោះ តាម

ទ្វារត្រចៀក ។បេ។ ប្រសិនបើមារចូលទៅជិតភិក្ខុនោះ តាមទ្វារចិត្ត មារមិន បានទូវឱកាស មារមិនបានទូវអារម្មណ៍ មានឧបមេយ្យដូច្នោះឯង ម្នាលអាវុសោ រូបមិនគ្របសង្កត់ភិក្ខុ ដែលមានកិរិយានៅយ៉ាងនេះ ភិក្ខុគ្របសង្កត់រូប សំឡេង មិនគ្របសង្កត់ភិក្ខុ ភិក្ខុគ្របសង្កត់សំឡេង ។បេ។ ធម្មារម្មណ៍មិនគ្របសង្កត់ ភិក្ខុ ភិក្ខុគ្របសង្កត់ធម្មារម្មណ៍ ម្នាលអាវុសោ ភិក្ខុនេះគេហៅថា អ្នកគ្របសង្កត់ រូប អ្នកគ្របសង្កត់សំឡេង អ្នកគ្របសង្កត់ក្លិន អ្នកគ្របសង្កត់រស អ្នកគ្រប សង្កត់ផោដ្ឋព្វៈ អ្នកគ្របសង្កត់ធម្មារម្មណ៍ អ្នកមិនត្រូវពួកកិលេសទាំងនោះ គ្របសង្កត់ទេ ព្រោះថា ភិក្ខុនោះគ្របសង្កត់ពួកអកុសលធម៌ដ៏លាមក ដែល ប្រកបដោយសេចក្តីសៅហ្មង នាំឲ្យកើតក្នុងភពថ្មី ប្រកបដោយសេចក្តីក្រវល់ ក្រវាយ មានទុក្ខជាផល ជាទីតាំងនៃជាតិ ជរា និងមរណៈតទៅ ម្នាលអាវុសោ ភិក្ខុមានចិត្តមិនទទឹក យ៉ាងនេះឯង ហេតុនោះ ( លោកពោលថា ) មានចិត្ត មិនទទឹក ។ ពាក្យថា មិនរោលរាល គឺមិនក្តៅក្រហាយដោយភ្លើងរាគៈ មិន ក្តៅក្រហាយដោយភ្លើងទោសៈ មិនក្តៅក្រហាយដោយភ្លើងមោហៈ ហេតុនោះ ( លោកពោលថា ) មានចិត្តមិនទទឹក មិនរោលរាល ( ដោយកិលេស ) ។ គប្បីប្រព្រឹត្តម្នាក់ឯង ដូចកុយរមាស ។ ហេតុនោះ ព្រះបច្ចេកសម្ពុទ្ធនោះ ពោលថា

ភិក្ខុមានចក្ខុដាក់ចុះ ជាអ្នកមិនរពឹសជើង អ្នកគ្រប់គ្រងឥន្ទ្រិយ
រក្សាចិត្ត មានចិត្តមិនទទឹក មិនរោលរាល ( ដោយកិលេស )
គប្បីប្រព្រឹត្តម្នាក់ឯង ដូចកុយរមាស ។

# អដ្ឋកថា

## គាថាទី ៩

គប្បីជ្រាបវិនិច្ឆ័យក្នុងគាថាទី ៩ ដូចតទៅ

[ ៣៨០ ] បទថា **ឱក្ខិត្តចក្ខុ** បានដល់ ជាអ្នកមានចក្ខុដាក់ចុះ មានអធិប្បាយថា ភិក្ខុតម្កល់ឆ្អឹងកទាំង ៧ ឲ្យត្រួតលើគ្នាតាមលំដាប់ ហើយសម្លឹងមើលមួយជួរនឹម ដើម្បីមើលវត្ថុដែលគួរវៀរ និងគួរលះ តែកុំឲ្យឆ្អឹងទ្រូងប៉ះឆ្អឹងចង្កា ។ ព្រោះការដែលភិក្ខុជាអ្នកមានភ្នែកដាក់ចុះយ៉ាងនេះ មិនគួរដល់សមណៈ ។ បទថា **ន ច បាទលោលោ** សេចក្តីថា មិនធ្វើដូចមនុស្សដែលរពឹសជើងប្រាថ្នានឹងចូលទៅកាន់កណ្តាលគណៈយ៉ាងនេះ គឺជាមនុស្សទី ២ របស់មនុស្សម្នាក់ ជាមនុស្សទី ៣ របស់មនុស្ស ២ នាក់ ជាអ្នកវៀរចាកការត្រាច់ទៅយូរ គឺត្រាច់ទៅមិនឈប់ ។ បទថា **គុត្តិន្ទ្រិយោ** បានដល់ មានឥន្ទ្រិយគ្រប់គ្រងហើយក្នុងឥន្ទ្រិយទាំង ៦ ដោយឥន្ទ្រិយដ៏សេស ដែលបានពោលចែកដោយឡែកក្នុងទីនេះ ។ បទថា **រក្ខិតមានសានោ** បានដល់ មានសៈនោះឯង ឈ្មោះថា ចិត្ត ។ ចិត្តនោះដែលបុគ្គលនោះរក្សាហើយ ព្រោះហេតុនោះ ទើបឈ្មោះថា **រក្ខិតមានសានោ** អធិប្បាយថា មានចិត្តដែលរក្សាហើយដោយប្រការដែលកិលេសទាំងឡាយ មិនចោមរោម ។ បទថា **អនវស្សុតោ** បានដល់ ដែលវៀរហើយចាកការលិចស្រោចរបស់កិលេសក្នុងអារម្មណ៍ទាំងឡាយនោះៗ ដោយបដិបត្តិនេះ ។ បទថា **អបរិឌយ្ហមានោ** បានដល់ ភ្លើង គឺកិលេសមិនបានដុត ព្រោះវៀរចាកការលិចស្រោចរបស់កិលេសយ៉ាងនេះ ។ ម្យ៉ាងទៀត បុគ្គលដែលកិលេសខាងក្រៅមិនរួបរឹត ដែល

កិលេសខាងក្នុងមិនដុតពេល ។ បទដ៏សេស មានន័យដូចពោលហើយនោះឯង ។

[ ៣៨១ ] បទថា **ចក្ខុនា រូបំ ទិស្វា** បានដល់ ឃើញរូបដោយចក្ខុវិញ្ញាណ ដែលអាចឃើញរូបបាន ដែលហៅតាមវោហារថា **ចក្ខុ** ដោយអំណាចនៃហេតុ ។ ឯបុរាណាចារ្យទាំងឡាយពោលថា ចក្ខុរមែងមិនឃើញរូប ព្រោះមិនមានចិត្ត ចិត្តក៏រមែងមិនឃើញរូប ព្រោះមិនមានចក្ខុ បុគ្គលឃើញរូបបានដោយចិត្តដែលមានបសាទរូបជាវត្ថុព្រោះទ្វារ និងអារម្មណ៍ប៉ះខ្ទប់គ្នា ។ ពាក្យពោលបែបនេះ ឈ្មោះថា សសម្ភារកថា ដូចក្នុងប្រយោគជាដើមថា បាញ់ដោយធ្នូ ដូច្នោះ ព្រោះហេតុនោះ ទើបក្នុងទីនេះ មានសេចក្តីយ៉ាងនេះថា ឃើញរូបដោយចក្ខុវិញ្ញាណ ដូច្នេះ ។ បទថា **និមិត្តគ្គាហី** សេចក្តីថា កាន់យកនិមិត្តស្ត្រី និងបុរស ឬនិមិត្តដែលជាទីតាំងនៃកិលេស មាននិមិត្តថាស្អាតជាដើម ដោយអំណាចនៃឆន្ទរាគៈ មិនតាំងនៅដោយអំណាចត្រឹមតែការឃើញ ។ បទថា **អនុព្យញ្ជនគ្គាហី** សេចក្តីថា រមែងកាន់យកអាការដោយចែកជាដៃ ជើង ការសើច ការចរចា ការក្រឡេកមើលជាដើម ដែលហៅតាមវោហារថា **អនុព្យញ្ជនៈ** ព្រោះចែក គឺធ្វើកិលេសទាំងឡាយឲ្យប្រាកដ ។ ក្នុងបទថា **យត្វាធិករណមេនំ** ជាដើម មានសេចក្តីដូច្នេះ ធម៌ទាំងឡាយ មានអភិជ្ឈាជាដើមនេះ គប្បីលិចលង់ គឺតាមចងនូវបុគ្គលនោះ ដែលមិនសង្រួមចក្ខុន្ទ្រិយ គឺដែលមានចក្ខុទ្វារមិនបិទហើយ ដោយបង្អួច គឺសតិ ព្រោះហេតុនៃការមិនសង្រួមចក្ខុន្ទ្រិយណា ។

បទថា **តស្ស សំវរាយ ន បដិបជ្ជតិ** សេចក្តីថា មិនបដិបត្តិដើម្បីបិទនូវចក្ខុន្ទ្រិយនោះ ដោយបន្ទះ គឺសតិ ។ បុគ្គលបែបនេះឯង ហៅថា មិនរក្សាចក្ខុន្ទ្រិយនោះ មិនដល់នូវការសង្រួមក្នុងចក្ខុន្ទ្រិយនោះ ។

ក្នុងសេចក្តីនោះ ការសង្រួម ឬការមិនសង្រួម រមែងមិនមានក្នុងចក្ខុន្ទ្រិយ ដ្បិតថា សតិ ឬការមិនមានស្មារតី មិនកើតឡើងព្រោះអាស្រ័យចក្ខុបសាទឡើយ ទោះជាយ៉ាងនោះ កាលណារូបារម្មណ៍មកកាន់គន្លងនៃចក្ខុក្នុងកាលណា កាលនោះ ភវង្គចិត្តកើតឡើង ២ ដង ហើយរលត់ទៅ កិរិយាមនោធាតុកើតឡើង ធ្វើអាវជ្ជនកិច្ចឲ្យសម្រេច ហើយរលត់ទៅ ។ បន្ទាប់អំពីនោះ ទើបចក្ខុវិញ្ញាណកើតឡើងធ្វើទស្សនកិច្ចឲ្យសម្រេច ហើយរលត់ទៅ បន្ទាប់អំពីនោះ វិបាកមនោធាតុកើតឡើង ធ្វើសម្បដិច្ឆន្នកិច្ចឲ្យសម្រេច ហើយរលត់ទៅ ។ បន្ទាប់អំពីនោះ វិបាកមនោវិញ្ញាណធាតុ ដែលជាអហេតុកៈកើតឡើង ធ្វើសន្តីរណកិច្ចឲ្យសម្រេចហើយ ហើយរលត់ទៅ ។ បន្ទាប់អំពីនោះ កិរិយាមនោវិញ្ញាណធាតុ ដែលជាអហេតុកៈកើតឡើង ធ្វើវោដ្ឋព្វនកិច្ចឲ្យសម្រេច ហើយរលត់ទៅ ក្នុងលំដាប់នោះ ជវនចិត្តរមែងស្ទុះទៅ ។ ក្នុងសេចក្តីនោះ ការសង្រួម ឬការមិនសង្រួម រមែងមិនមានក្នុងសម័យនៃភវង្គចិត្ត រមែងមិនមានក្នុងសម័យនៃចិត្តទាំងឡាយ មានអាវជ្ជនចិត្តជាដើម សម័យណាមួយ ។ តែក្នុងខណៈនៃជវនចិត្ត បើការទ្រុស្តសីលក្តី ការមិនមានស្មារតីក្តី ការមិនដឹងក្តី ការមិនអត់ធន់ក្តី ការខ្ជិលច្រអូសក្តី កើតឡើង ការមិនសង្រួមរមែងមិនមាន ។ ការមិនសង្រួមយ៉ាងនេះ ហៅថា ការ

មិនសង្រួមក្នុងចក្ខុន្ទ្រិយ ព្រោះហេតុអ្វី ព្រោះកាលការមិនសង្រួមនោះមានទ្វារក្តី ភវង្គចិត្តក្តី វិថីចិត្តទាំងឡាយ មានអាវជ្ជនចិត្តជាដើមក្តី ឈ្មោះថាមិនគ្រប់គ្រងហើយ ប្រៀបដូចអ្វី ប្រៀបដូចកាលទ្វារ ៤ ក្នុងព្រះនគរមិនបិទទោះបីបិទទ្វារខាងក្នុងផ្ទះ ទ្វារបន្ទប់ជាដើមក្តី ទោះជាយ៉ាងនោះ របស់ទាំងអស់ខាងក្នុងព្រះនគរ ក៏ឈ្មោះថា មិនរក្សា មិនគ្រប់គ្រងដូចគ្នា ព្រោះចោរទាំងឡាយ ចូលទៅតាមទ្វារនគរ រមែងលួចប្លន់យកវត្ថុដែលត្រូវការទៅបានយ៉ាងណា កាលការទ្រុស្តសីលជាដើមកើតឡើងហើយ ក្នុងជវនចិត្ត កាលការមិនសង្រួមនោះមានទ្វារក្តី ភវង្គចិត្តក្តី វិថីចិត្តទាំងឡាយ មានអាវជ្ជនចិត្តជាដើមក្តី ឈ្មោះថា បុគ្គលនោះ មិនសង្រួមហើយដូច្នោះដូចគ្នា ។ គប្បីជ្រាបសេចក្តីក្នុងបទជាដើមថា **ចក្ខុនា រូបំ ទិស្វា ន និមិត្តគ្គាហី ហោតិ** ដូច្នេះ បទថា **ន និមិត្តគ្គាហី ហោតិ** សេចក្តីថា មិនកាន់យកនិមិត្តដូចពោលហើយ ដោយអំណាចឆន្ទរាគៈ គប្បីជ្រាបបទដ៏សេស ដោយន័យផ្ទុយគ្នាតាមដែលពោលហើយ ដោយប្រការដូច្នេះ ដូចពាក្យដែលលោកពោលហើយខាងដើមថា កាលការទ្រុស្តសីលជាដើមកើតឡើងហើយ ក្នុងជវនចិត្ត កាលការមិនសង្រួមនោះមានទ្វារក្តី ភវង្គចិត្តក្តី វិថីចិត្តទាំងឡាយ មានអាវជ្ជនចិត្តជាដើមក្តី រមែងឈ្មោះថា មិនគ្រប់គ្រងហើយ យ៉ាងណា ក្នុងសេចក្តីនេះក៏យ៉ាងនោះ កាលសីលជាដើមកើតឡើងហើយ ក្នុងជវនចិត្តនោះទ្វារក្តី ភវង្គចិត្តក្តី វិថីចិត្តទាំងឡាយ មានអាវជ្ជនចិត្តជាដើមក្តី ឈ្មោះថាគ្រប់គ្រងហើយ ។ ប្រៀបដូចអ្វី ប្រៀបដូចកាលទ្វារនគរត្រូវបិទហើយ ទោះ

បើមិនបិទទ្វារផ្ទះខាងក្នុងជាដើមក៏ពិត តែទ្រព្យទាំងអស់ខាងក្នុងនគរ ក៏ឈ្មោះថា រក្សាល្អហើយ គ្រប់គ្រងល្អហើយនោះឯង ព្រោះកាលទ្វារនគរបិទ ពួកចោរក៏ចូលទៅមិនបាន យ៉ាងណា កាលសីលជាដើមកើតឡើងហើយក្នុងជវនចិត្ត ទ្វារក្តី ភវង្គចិត្តក្តី វិថីចិត្តទាំងឡាយ មានអាវជ្ជនចិត្តជាដើមក្តី ឈ្មោះថា រក្សាហើយដូចគ្នា ព្រោះហេតុនោះ ការសង្រួមសូម្បីកើតឡើងក្នុងខណៈនៃជវនចិត្ត ក៏ហៅថា ការសង្រួមក្នុងចក្ខុន្ទ្រិយ ។

[ ៣៤៣ ] បទថា **អវស្សុតបរិយាយញ្ច** បានដល់ អវស្សុតបរិយាយសូត្រ គឺសូត្រដែលពោលដោយហេតុនៃការទទឹកដោយកិលេសទាំងឡាយ ។ បទថា **អនវស្សុតបរិយាយញ្ច** បានដល់ អនវស្សុតបរិយាយសូត្រ គឺសូត្រពោលដោយហេតុនៃការមិនទទឹក ដោយកិលេសទាំងឡាយ ។ បទថា **បិយរូបេ រូបេ** បានដល់ ក្នុងរូបារម្មណ៍ដែលគួរប្រាថ្នា ។ បទថា **អប្បិយរូបេ រូបេ** បានដល់ ក្នុងរូបារម្មណ៍ដែលមានសភាវៈមិនគួរប្រាថ្នា ។ បទថា **ព្យាបជ្ជតិ** បាលដល់ ដល់នូវការស្អុយ ដោយអំណាចទោសៈ ។ បទថា **ឱតារំ** បានដល់ ប្រហោង គឺចន្លោះ ។ បទថា **អារម្មណំ** បានដល់ ឱកាស ។ បទថា **អភិភវិសុ** បានដល់ ញាំញី ។ បទថា **ន អភិភវិ** បានដល់ មិនញាំញី ។ បទថា **ពហលមត្តិកា** បានដល់ មានដីក្រាស់បន្ថែមឡើង ដោយការបូករឿយៗ ។ បទថា **អល្លាវលេបនា** បានដល់ លាបដោយដីដែលមិនស្ងួត ។ បទដ៏សេស ក្នុងនិទ្ទេសនេះ មានអត្ថងាយយល់ហើយ ៕

# សុត្តន្តបិដក

[ ៣៨៤ ] បុគ្គល លះបង់នូវវត្ថុជាគ្រឿងប្រាកដនៃគ្រហស្ថ ចេញទៅបួស ស្លៀកដណ្តប់កាសាយៈ ដូចដើមបារិច្ឆត្តព្រឹក្ស មានស្លឹកដ៏ខ្ចាប់ គប្បីប្រព្រឹត្តម្នាក់ឯង ដូចកុយរមាស ។

[ ៣៨៥ ] ពាក្យថា បុគ្គល លះបង់នូវវត្ថុជាគ្រឿងប្រាកដនៃគ្រហស្ថ អធិប្បាយថា សក់ ពុកមាត់ ពុកចង្កា ។បេ។ សំពត់វែង និងខ្វី ហៅថា វត្ថុជាគ្រឿងប្រាកដនៃគ្រហស្ថ ។ ពាក្យថា បុគ្គលលះបង់នូវវត្ថុជាគ្រឿងប្រាកដនៃគ្រហស្ថ គឺដាក់ចុះ ដាក់ស្រឡះ លះបង់នូវវត្ថុជាគ្រឿងប្រាកដនៃគ្រហស្ថ ហេតុនោះ ( លោកពោលថា ) បុគ្គលលះបង់នូវវត្ថុជាគ្រឿងប្រាកដនៃគ្រហស្ថ ។

[ ៣៨៦ ] ពាក្យថា ដូចដើមបារិច្ឆត្តព្រឹក្ស មានស្លឹកដ៏ខ្ចាប់ គឺព្រះបច្ចេកសម្ពុទ្ធនោះ ទ្រទ្រង់នូវបាត្រ និងចីវរដ៏បរិបូណ៌ ដូចដើមបារិច្ឆត្តព្រឹក្ស គឺដើមរលួសផ្អុង មានស្លឹក និងត្រួយដ៏ក្រាស់ មានម្លប់ត្រឈៃ ហេតុនោះ ( លោកពោលថា ) ដូចដើមបារិច្ឆត្តព្រឹក្ស មានស្លឹកដ៏ខ្ចាប់ ។

[ ៣៨៧ ] ពាក្យថា ចេញទៅបួស ស្លៀកដណ្តប់សំពត់កាសាយៈ អធិប្បាយថា ព្រះបច្ចេកសម្ពុទ្ធនោះ កាត់កង្វល់ក្នុងឃរាវាសទាំងពួង កាត់កង្វល់ក្នុងបុត្ត និងភរិយា កាត់កង្វល់ក្នុងញាតិ កាត់កង្វល់ក្នុងការសន្សំ កោរសក់ ពុកមាត់ ពុកចង្កា ទ្រទ្រង់នូវសំពត់កាសាយៈ ចេញចាកផ្ទះបួលទៅកាន់

ផ្ទុស ដល់នូវភាពជាអ្នកមិនមានកង្វល់ ចរ គ្រាច់ទៅ ប្រព្រឹត្ត រក្សា យាត្រា ឲ្យយាត្រាទៅតែម្នាក់ឯង ហេតុនោះ ( លោកពោលថា ) ចេញទៅបួស ស្លៀកដណ្តប់សំពត់កាសាយៈ ។ គប្បីប្រព្រឹត្តម្នាក់ឯង ដូចកុយរមាស ។ ហេតុនោះ ព្រះបច្ចេកសម្ពុទ្ធនោះពោលថា

> បុគ្គល លះបង់នូវវត្ថុជាគ្រឿងប្រាកដនៃគ្រហស្ថ ចេញទៅបួស
> ស្លៀកដណ្តប់សំពត់កាសាយៈ ដូចដើមបារិច្ឆត្តព្រឹក្ស មានស្លឹកដ៏
> ខ្ចាប់ គប្បីប្រព្រឹត្តម្នាក់ឯង ដូចកុយរមាស ។

# អដ្ឋកថា

## គាថាទី ១០

គប្បីជ្រាបវិនិច្ឆ័យក្នុងគាថាទី ១០ ដូចតទៅនេះ

[ ៣៨៤ ] បាទគាថាថា **កាសាយវត្ថោ អភិនិក្ខមិត្វា** គប្បីជ្រាបសេចក្ដីយ៉ាងនេះថា ចេញចាកផ្ទះ ហើយគ្រងសំពត់កាសាយៈ ។ បទដ៏សេសអាចដឹងបានដោយន័យដូចពោលហើយនោះឯង ព្រោះហេតុនោះ ទើបមិនចាំបាច់ពោលដោយពិស្ដារឡើយ ៕ល៚

**អដ្ឋកថាគាថាទី ១០ ចប់**

**ទុតិយវគ្គ ចប់**

# សុត្តន្តបិដក

[ ៣៤៨ ] បុគ្គលមិនធ្វើនូវចំណង់ ក្នុងរសទាំងឡាយ ជាអ្នកមិនរពឹស មិនចិញ្ចឹមបុគ្គលដទៃ ត្រាច់ទៅតាមលំដាប់ច្រក មិនមានចិត្តជាប់ក្នុងត្រកូល ក្នុងត្រកូល គប្បីប្រព្រឹត្តម្នាក់ឯង ដូចកុយរមាស ។

[ ៣៤៩ ] អធិប្បាយពាក្យថា មិនធ្វើនូវចំណង់ក្នុងរសទាំងឡាយ ជាអ្នកមិនរពឹស ត្រង់ពាក្យថា រសទាំងឡាយ បានដល់ រសមើម រសដើម រសសម្បក រសស្លឹក រសផ្កា រសផ្លែ ជូរ ផ្អែម ល្វីង ហឹរ ប្រៃ ខារ ជូរចត់ ចត់ ឆ្ងាញ់ មិនឆ្ងាញ់ ត្រជាក់ ក្តៅ ។ មានពួកសមណព្រាហ្មណ៍ក្នុងលោក ជាអ្នកល្មោភក្នុងរស សមណព្រាហ្មណ៍ទាំងនោះ រមែងដើរស្វែងរកនូវរសព្រោះចុងអណ្តាត ។ បានរសជូរហើយ ស្វែងរករសមិនជូរ បានរសមិនជូរហើយ ស្វែងរករសជូរ ។ បានរសផ្អែមហើយ ស្វែងរករសមិនផ្អែម បានរសមិនផ្អែមហើយ ស្វែងរករសផ្អែម ។ បានរសល្វីងហើយ ស្វែងរករសមិនល្វីង បានរសមិនល្វីងហើយ ស្វែងរករសល្វីង ។ បានរសហឹរហើយ ស្វែងរករសមិនហឹរ បានរសមិនហឹរហើយ ស្វែងរករសហឹរ ។ បានរសប្រៃហើយ ស្វែងរករសមិនប្រៃ បានរសមិនប្រៃហើយ ស្វែងរករសប្រៃ ។ បានរសខារហើយ ស្វែងរករសមិនខារ បានរសមិនខារហើយ ស្វែងរករសខារ ។ បានរសជូរចត់ហើយ ស្វែងរករសចត់ បានរសចត់ហើយ ស្វែងរករសជូរចត់ ។ បានរសឆ្ងាញ់ហើយ ស្វែងរករសមិនឆ្ងាញ់ បានរសមិនឆ្ងាញ់ហើយ ស្វែងរករសឆ្ងាញ់ ។ បានត្រជាក់ហើយ ស្វែងរកក្តៅ បានក្តៅហើយ ស្វែង

រកត្រជាក់ ។ ពួកសមណព្រាហ្មណ៍ទាំងនោះ បានរសណាៗ រមែងមិនសន្តោស ដោយរសនោះៗ ទេ នៅតែស្វែងរករសផ្សេងៗ ទៀត ជាអ្នកត្រេកអរជាប់ចិត្ត ជ្រប់ចិត្ត លង់ចិត្ត ឆប់ចិត្ត ស្អិត ទាក់ ជំពាក់ក្នុងរសទាំងឡាយ ។ ចំណង់ក្នុងរសនោះ ព្រះបច្ចេកសម្ពុទ្ធនោះ លះបង់ គាស់រម្លើងឫសគល់ ធ្វើឲ្យសល់តែទីនៅដូចជាទីនៅនៃដើមត្នោត ឲ្យដល់នូវការមិនកើតមាន ឲ្យជាធម៌លែងកើតតទៅទៀត ព្រោះហេតុនោះ ព្រះបច្ចេកសម្ពុទ្ធនោះ ពិចារណាដោយឧបាយនៃប្រាជ្ញាហើយ ទើបឆាន់នូវអាហារ មិនមែនដើម្បីលេង មិនមែនដើម្បីស្រវឹង មិនមែនដើម្បីប្រដាប់ មិនមែនដើម្បីស្អិតស្អាងទេ គ្រាន់តែដើម្បីឲ្យតាំងនៅនៃកាយនេះតែប៉ុណ្ណោះ ដើម្បីញ៉ាំងឥរិយាបថឲ្យប្រព្រឹត្តទៅ ដើម្បីបំបាត់នូវសេចក្តីលំបាក ដើម្បីអនុគ្រោះដល់ព្រហ្មចរិយៈ ( ឆាន់ដោយគិត ) ថា អាត្មាអញនឹងបំបាត់បង់នូវវេទនាចាស់ផង មិនឲ្យវេទនាថ្មីកើតឡើងផង ការប្រព្រឹត្តទៅផង ការមិនមានទោសផង ការនៅជាសុខផង នឹងមានដល់អាត្មាអញដោយឧបាយនេះ ។ ដូចបុគ្គលលាបដំបៅ គ្រាន់តែនឹងឲ្យដុះសាច់ ឬដូចពួកអ្នករទេះលាបភ្លៅរទេះ គ្រាន់តែនឹងដឹកនូវរបស់ធ្ងន់ ឬក៏ដូចបុគ្គលស៊ីសាច់កូន គ្រាន់តែនឹងឆ្លងផ្លូវកន្តារ ព្រះបច្ចេកសម្ពុទ្ធនោះក៏ដូច្នោះដែរ លោកពិចារណាដោយឧបាយនៃប្រាជ្ញាហើយ ឆាន់នូវអាហារមិនមែនដើម្បីលេង មិនមែនដើម្បីស្រវឹង មិនមែនដើម្បីប្រដាប់ មិនមែនដើម្បីស្អិតស្អាងទេ គ្រាន់តែដើម្បីឲ្យតាំងនៅនៃកាយនេះ ដើម្បីញ៉ាំងឥរិយាបថឲ្យប្រព្រឹត្តទៅ ដើម្បីបំបាត់នូវសេចក្តីលំបាក ដើម្បីអនុគ្រោះដល់ព្រហ្មចរិយៈ ( ឆាន់ដោយគិត ) ថា

អាត្មាអញនឹងបំបាត់បង់នូវវេទនាចាស់ផង មិនឲ្យវេទនាថ្មីកើតឡើងផង ការប្រព្រឹត្តទៅផង ការមិនមានទោសផង ការនៅជាសុខផង នឹងមានដល់អាត្មាអញ ដោយឧបាយនេះ ។ ជាអ្នកឆ្ងាយ វៀរ វៀរលែងចេញ ដោះចេញ រួចផុត ប្រាសចេញចាកចំណង់ក្នុងរស មានចិត្តមិនសល់វល់ ហេតុនោះ ( លោកពោលថា ) មិនធ្វើនូវចំណង់ក្នុងរសទាំងឡាយ ។ ពាក្យថា មិនរពឹស សេចក្ដីថា តណ្ហា លោកហៅថា ការរពឹសផង ហៅថា សេចក្ដីប្រាថ្នាក្រៃពេកផង បានខាងតម្រេក តម្រេកខ្លាំង ។បេ។ អភិជ្ឈា លោភៈ អកុសលមូល ។ តណ្ហា គឺការរពឹស និងសេចក្ដីប្រាថ្នាក្រៃពេកនោះ ព្រះបច្ចេកសម្ពុទ្ធនោះ លះបង់ គាស់រម្លើងឫសគល់ ធ្វើឲ្យសល់តែទីនៅដូចជាទីនៅនៃដើមត្នោត ឲ្យដល់នូវការមិនកើតមាន ឲ្យជាធម៌លែងកើតតទៅទៀត ហេតុនោះ ព្រះបច្ចេកសម្ពុទ្ធ ឈ្មោះថា ជាអ្នកមិនរពឹស ហេតុនោះ ( លោកពោលថា ) មិនធ្វើនូវចំណង់ក្នុងរស ជាអ្នកមិនរពឹស ។

[ ៣៥០ ] អធិប្បាយពាក្យថា មិនចិញ្ចឹមបុគ្គលដទៃ ត្រាច់ទៅតាមលំដាប់ច្រក ត្រង់ពាក្យថា មិនចិញ្ចឹមបុគ្គលដទៃ គឺព្រះបច្ចេកសម្ពុទ្ធនោះ ចិញ្ចឹមតែព្រះអង្គឯង មិនចិញ្ចឹមបុគ្គលដទៃទេ ។

តថាគតហៅបុគ្គលដែលមិនចិញ្ចឹមបុគ្គលដទៃជាអ្នកត្រាស់ដឹងតាំង
នៅស៊ប់ក្នុងសារធម៌ទាំងឡាយ អស់អាសវៈ ខ្ជាក់ចោលនូវ
ទោស ថាជាព្រាហ្មណ៍ ។

ហេតុនោះ ( លោកពោលថា ) មិនចិញ្ចឹមបុគ្គលដទៃ ។ ពាក្យថា

ត្រាច់ទៅ តាមលំដាប់ច្រក គឺព្រះបច្ចេកសម្ពុទ្ធនោះ ទ្រង់ស្បង់ប្រដាប់បាត្រ និងចីវរក្នុងបុព្វណ្ហសម័យ ហើយចូលទៅកាន់ស្រុក ឬនិគម ដើម្បីបិណ្ឌបាត មានកាយរក្សាហើយ មានវាចារក្សាហើយ មានចិត្តរក្សាហើយ មានសតិប្រុងហើយ មានឥន្ទ្រិយសង្រួមហើយ មានចក្ខុដាក់ចុះហើយ បរិបូណ៌ដោយឥរិយាបថ ចេញអំពីត្រកូលទៅកាន់ត្រកូល ត្រាច់ទៅដើម្បីបិណ្ឌបាត ហេតុនោះ ( លោកពោលថា ) មិនចិញ្ចឹមបុគ្គលដទៃ ត្រាច់ទៅតាមលំដាប់ច្រក ។

[ ៣៥១ ] ពាក្យថា មិនជាប់ចិត្តក្នុងត្រកូល អធិប្បាយថា ភិក្ខុដែលមានចិត្តជាប់ជំពាក់ ដោយហេតុ ២ យ៉ាង គឺ ភិក្ខុបន្ទាបខ្លួនឯងឲ្យទាបលើកអ្នកដទៃឲ្យខ្ពស់ ឈ្មោះថា អ្នកមានចិត្តជាប់ជំពាក់ ឬភិក្ខុលើកខ្លួនឯងឲ្យខ្ពស់ បន្ទាបអ្នកដទៃឲ្យទាប ឈ្មោះថា អ្នកមានចិត្តជាប់ជំពាក់ ។

ភិក្ខុបន្ទាបខ្លួនឯងឲ្យទាប លើកអ្នកដទៃឲ្យខ្ពស់ ឈ្មោះថា អ្នកមានចិត្តជាប់ជំពាក់ តើដូចម្តេច ។ ភិក្ខុនោះពោលយ៉ាងនេះថា លោកមានឧបការៈច្រើនដល់ខ្ញុំ ខ្ញុំអាស្រ័យលោក ទើបបានទូវចីវរ បិណ្ឌបាត សេនាសនៈគិលានប្បច្ច័យ ភេសជ្ជបរិក្ខារ ព្រោះពួកជនដទៃ អាស្រ័យទូវលោក ស្គាល់លោក ទើបសម្គាល់នឹងឲ្យ នឹងធ្វើដល់ខ្ញុំ សូម្បីនាម និងគោត្រណាពីដើមរបស់មាតាបិតានៃខ្ញុំ នាម និងគោត្ររបស់ខ្ញុំនោះ បាត់បង់ទៅហើយ ខ្ញុំដែលគេស្គាល់ថា ជាជីតុននៃឧបាសកឯណោះ ជាជីតុននៃឧបាសិកាឯណោះ ដោយសារតែលោក ភិក្ខុបន្ទាបខ្លួនឯងឲ្យទាប លើកអ្នកដទៃឲ្យខ្ពស់ ឈ្មោះថា អ្នកមានចិត្តជាប់ជំពាក់ យ៉ាងនេះឯង ។

ភិក្ខុលើកខ្លួនឯងឲ្យខ្ពស់ បន្ទាបអ្នកដទៃទាប ឈ្មោះថា អ្នកមានចិត្តជាប់ជំពាក់ តើដូចម្តេច ។ ភិក្ខុពោលយ៉ាងនេះថា ខ្ញុំមានឧបការៈច្រើនដល់ពួកអ្នក ពួកអ្នកអាស្រ័យខ្ញុំ ទើបបានដល់នូវព្រះពុទ្ធជាទីពឹង ដល់នូវព្រះធម៌ជាទីពឹង ដល់នូវព្រះសង្ឃជាទីពឹង វៀរចាកបាណាតិបាត វៀរចាកអទិន្នាទាន វៀរចាកកាមេសុមិច្ឆាចារ វៀរចាកមុសាវាទ វៀរចាកសុរាមេរយមជ្ជប្បមាទដ្ឋាន ខ្ញុំឲ្យឧទ្ទេស ខ្ញុំឲ្យបរិបុច្ឆា ខ្ញុំប្រាប់ឧបោសថ ខ្ញុំអធិដ្ឋាននវកម្មដល់លោកចុះ មកខាងក្រោយ លោកលះបោលខ្ញុំ ហើយទៅធ្វើសក្ការៈ ធ្វើការគោរពរាប់អានបូជាអ្នកដទៃវិញ ភិក្ខុលើកខ្លួនឯងឲ្យខ្ពស់ បន្ទាប់អ្នកដទៃឲ្យទាប ឈ្មោះថា អ្នកមានចិត្តជាប់ជំពាក់ យ៉ាងនេះឯង ។

ពាក្យថា មិនមានចិត្តជាប់ក្នុងត្រកូលក្នុងត្រកូល បានសេចក្តីថា ព្រះបច្ចេកសម្ពុទ្ធនោះ មិនមានចិត្តជាប់ជំពាក់ដោយកង្វល់ក្នុងត្រកូល មិនមានចិត្តជាប់ជំពាក់ដោយកង្វល់ក្នុងគណៈ មិនមានចិត្តជាប់ជំពាក់ដោយកង្វល់ក្នុងអាវាស មិនមានចិត្តជាប់ជំពាក់ដោយកង្វល់ក្នុងចីវរ មិនមានចិត្តជាប់ជំពាក់ដោយកង្វល់ក្នុងបិណ្ឌបាត មិនមានចិត្តជាប់ជំពាក់ដោយកង្វល់ក្នុងសេនាសនៈ មិនមានចិត្តជាប់ជំពាក់ដោយកង្វល់ ក្នុងគិលានប្បច្ចយភេសជ្ជបរិក្ខារ ហេតុនោះ ( លោកពោលថា ) មិនមានចិត្តជាប់ជំពាក់ក្នុងត្រកូលក្នុងត្រកូល ។ គប្បីប្រព្រឹត្តម្នាក់ឯង ដូចកុយរមាស ។ ហេតុនោះ ព្រះបច្ចេកសម្ពុទ្ធនោះពោលថា

បុគ្គលមិនធ្វើនូវចំណង់ ក្នុងរសទាំងឡាយ ជាអ្នកមិនរពឹស មិន
ចិញ្ចឹមបុគ្គលដទៃ ត្រាច់ទៅតាមលំដាប់ច្រក មិនមានចិត្តជាប់ក្នុង
ត្រកូល ក្នុងត្រកូល គប្បីប្រព្រឹត្តម្នាក់ឯង ដូចកុយរមាស ។

# អដ្ឋកថា

# ចតុត្ថវគ្គ

## គាថាទី ១

គប្បីជ្រាបវិនិច្ឆ័យក្នុងគាថាទី ១ នៃចតុត្ថវគ្គ ដូចតទៅ

[ ៣៤៨ ] បទថា **រសេសុ** បានដល់ ក្នុងរបស់គួរលិទ្ធភក្ស មានរសជូរ ផ្អែម ល្វីង ហឹរ ប្រៃ ចត់ ប្រហាតជាដើម ។ បទថា **គេធំ អការំ** បានដល់ មិនធ្វើនូវការជាប់ចិត្ត គឺការពេញចិត្ត មានពាក្យអធិប្បាយថា មិនឲ្យតណ្ហាកើតឡើង ។ បទថា **អលោលោ** បានដល់ មិនរីករវក្នុងរសវិសេសយ៉ាងនេះថា អញនឹងលិទ្ធភក្សរសនេះ អញនឹងលិទ្ធភក្សរសនេះ ដូច្នេះ ។

បទថា **អនញ្ញបោសី** បានដល់ មិនមានសទ្ធិវិហារិកដែលត្រូវចិញ្ចឹមជាដើម ។ មានពាក្យអធិប្បាយថា ត្រេកអរត្រឹមតែការទ្រទ្រង់នូវកាយបាន ។ ម្យ៉ាងទៀត លោកសម្តែងថា ក្នុងកាលមុន អាត្មាឡេះឡោះ ជាប់ក្នុងរសទាំងឡាយ ក្នុងឧទ្យាន ទើបចិញ្ចឹមអ្នកដទៃ យ៉ាងណា បុគ្គលមិនដូច្នោះ លះតណ្ហាដែលជាហេតុឲ្យឡេះឡោះ ធ្វើការជាប់ក្នុងរសទាំងឡាយបាន ជាអ្នកមិនចិញ្ចឹមអ្នកដទៃ ព្រោះមិនឲ្យកើតអត្តភាពដទៃ ដែលមានតណ្ហាជាមូលតទៅ ។ ម្យ៉ាងទៀត កិលេសទាំងឡាយ ហៅថា អ្នកដទៃ ព្រោះអត្ថថា កាច់បំបាក់នូវប្រយោជន៍ ក្នុងសេចក្តីនេះ មានអធិប្បាយថា ព្រះបច្ចេកពុទ្ធឈ្មោះថា មិនចិញ្ចឹមអ្នកដទៃ ព្រោះមិនចិញ្ចឹមកិលេសទាំងនោះ ។ បទថា **សបទានចារី** បានដល់ មិនត្រាច់វិលវល់ គឺត្រាច់ទៅតាមលំដាប់ អធិប្បាយ

ថា មិនវៀរលំដាប់ផ្ទះ ចូលទៅកាន់ត្រកូល ទាំងស្តុកស្តម្ភ និងក្រីក្រ ដើម្បីបិណ្ឌបាតតាមលំដាប់ ។ បទថា **កុលេ កុលេ អប្បដិពទ្ធចិត្តោ** សេចក្តីថា មានចិត្តមិនជាប់ជំពាក់ ដោយអំណាចកិលេស ក្នុងត្រកូលណាមួយ បណ្តាត្រកូលក្សត្រជាដើម ជាបុគ្គលដូចព្រះចន្ទ ថ្មីជានិច្ច បទដ៏សេស មានន័យដូចពោលហើយនោះឯង ។

**អដ្ឋកថា គាថាទី ១ ចប់**

# សុត្តន្តបិដក

[ ៣៥២ ] បុគ្គលលះបង់នូវរបាំងរបស់ចិត្ត ៥ បន្ទោបង់នូវឧប-ក្កិលេសទាំងពួង ជាអ្នកមិនអាស្រ័យ កាត់បង់នូវសេចក្តីស្នេហា និងទោសៈ គប្បីប្រព្រឹត្តម្នាក់ឯង ដូចកុយរមាស ។

[ ៣៥៣ ] ពាក្យថា លះបង់នូវរបាំងរបស់ចិត្ត ៥ គឺព្រះបច្ចេកសម្ពុទ្ធនោះ លះ លះបង់ បន្ទោបង់ ធ្វើឲ្យវិនាស ឲ្យដល់នូវការមិនកើតមាន នូវកាមច្ឆន្ទនីវរណៈ លះ លះបង់ បន្ទោបង់ ធ្វើឲ្យវិនាស ឲ្យដល់នូវការមិនកើតមាននូវព្យាបាទនីវរណៈ ថីនមិទ្ធនីវរណៈ ឧទ្ធច្ចកុក្កុច្ចនីវរណៈ វិចិកិច្ឆានីវរណៈ ជាអ្នកស្ងាត់ចាកកាមទាំងឡាយ ស្ងាត់ចាកអកុសលធម៌ទាំងឡាយ ហើយចូលកាន់បឋមជ្ឈាន ប្រកបដោយវិតក្ក និងវិចារៈ មានបីតិ និងសុខកើតអំពីសេចក្តីស្ងាត់ ហេតុនោះ ( លោកពោលថា ) លះបង់នូវរបាំងរបស់ចិត្ត ៥ ។

[ ៣៥៤ ] ពាក្យថា បន្ទោបង់នូវឧបក្កិលេសទាំងពួង សេចក្តីថា រាគៈជាឧបក្កិលេសរបស់ចិត្ត ទោសៈ ជាឧបក្កិលេសរបស់ចិត្ត មោហៈ ជាឧបក្កិ-លេសរបស់ចិត្ត កោធៈ ឧបនាហៈ ។បេ។ អកុសលាភិសង្ខារទាំងពួង ជាឧបក្កិលេសរបស់ចិត្ត ។ ពាក្យថា បន្ទោបង់នូវឧបក្កិលេសទាំងពួង គឺបន្ទោបន្ទោបង់ បន្សាត់បង់ លះបង់ ធ្វើឲ្យវិនាស ឲ្យដល់នូវការមិនកើតមាន នូវឧបក្កិលេសទាំងពួងនៃចិត្ត ហេតុនោះ ( លោកពោលថា ) បន្ទោបង់នូវឧបក្កិលេសទាំងពួង ។

[ ៣៥៥ ] អធិប្បាយពាក្យថា ជាអ្នកមិនអាស្រ័យ កាត់បង់នូវសេចក្តីស្នេហា និងទោសៈ ត្រង់ពាក្យថា ជាអ្នកមិនអាស្រ័យ សេចក្តីថា ការអាស្រ័យ

មាន ២ គឺការអាស្រ័យ គឺតណ្ហា ១ ការអាស្រ័យ គឺទិដ្ឋិ ១ ។បេ។ នេះ ការអាស្រ័យ គឺតណ្ហា ។បេ។ នេះ ការអាស្រ័យ គឺទិដ្ឋិ ។ ពាក្យថា សេចក្ដីស្នេហា បានស្នេហា ២ គឺតណ្ហាស្នេហា ១ ទិដ្ឋិស្នេហា ១ ។បេ។ នេះ តណ្ហាស្នេហា ។បេ។ នេះ ទិដ្ឋិស្នេហា ។ ពាក្យថា ទោសៈ បានដល់ ការអាឃាត គំនុំ ការថ្នាំងថ្នាក់ ការអាក់អន់ ការក្រោធ ការក្រោធខ្លាំង ការកម្រើក ការប្រទូស្ត ការប្រទូស្តខ្លាំង ការក្តៅក្រហាយនៃចិត្ត សេចក្ដីចង្អៀតចង្អល់នៃចិត្ត សេចក្ដីប្រទូស្តនៃចិត្ត សេចក្ដីក្រោធ អាការនៃសេចក្ដីក្រោធ ភាពនៃសេចក្ដីក្រោធ សេចក្ដីប្រទូស្ត អាការនៃសេចក្ដីប្រទូស្ត ភាពនៃសេចក្ដីប្រទូស្ត សេចក្ដីចង្អៀតចង្អល់ អាការនៃសេចក្ដីចង្អៀតចង្អល់ ភាពនៃសេចក្ដីចង្អៀតចង្អល់ សេចក្ដីខឹង ការថ្នាំងថ្នាក់ កាច ការពោលពាក្យមិនពីរោះ ភាពនៃចិត្តមិនត្រេកអរ ។ ពាក្យថា ជាអ្នកមិនអាស្រ័យ កាត់បង់នូវសេចក្ដីស្នេហានិងទោសៈ បានសេចក្ដីថា ព្រះបច្ចេកសម្ពុទ្ធនោះកាត់ កាត់ផ្ដាច់ កាត់ចោល លះបង់ បន្ទោបង់ ធ្វើឲ្យវិនាស ឲ្យដល់នូវការមិនកើតមាននូវតណ្ហាស្នេហា ទិដ្ឋិស្នេហា និងទោសៈ មិនអាស្រ័យនូវចក្ខុ មិនអាស្រ័យនូវសោតៈ ។បេ។ មិនអាស្រ័យ មិនផ្ដេកផ្ដិត មិនប្រកប មិនជាប់ចិត្ត មិនចុះចិត្តស៊ប់ ឆាកចេញ ដោះចេញ រួចស្រឡះ មិនប្រកបនូវធម្មារម្មណ៍ ដែលគប្បីឃើញ ឮ ប៉ះពាល់ ឬដឹង មានចិត្តមិនសល់វល់ ហេតុនោះ ( លោកពោលថា ) ជាអ្នក

មិនអាស្រ័យ កាត់បង់នូវសេចក្តីស្នេហា និងទោសៈ ។ គប្បីប្រព្រឹត្តម្នាក់ឯង ដូចកុយរមាស ។ ហេតុនោះ ព្រះបច្ចេកសម្ពុទ្ធនោះពោលថា

បុគ្គលលះបង់នូវរបាំងរបស់ចិត្ត ៥ បន្ទោបង់នូវឧបក្កិលេសទាំងពួង ជាអ្នកមិនអាស្រ័យ កាត់បង់នូវសេចក្តីស្នេហា និងទោសៈ គប្បីប្រព្រឹត្តម្នាក់ ឯងដូចកុយរមាស ។

# អដ្ឋកថា

## គាថាទី ២

គប្បីជ្រាបវិនិច្ឆ័យក្នុងគាថាទី ២ ដូចតទៅ

[ ៣៥២ ] បទថា **អាវរណានិ** បានដល់ នីវរណៈនោះឯង ។ នីវរណៈទាំងនោះ ដោយអត្ថ បានពោលហើយក្នុងខគ្គវិសាណសូត្រ ។ តែព្រោះនីវរណៈទាំងនោះរារាំងចិត្ត ដូចពពកបិទបាំងព្រះចន្ទ ឬព្រះអាទិត្យ ដូច្នោះ ទើបត្រាស់ថា ជាគ្រឿងរារាំងចិត្ត ។ ព្រះបច្ចេកសម្ពុទ្ធលះនីវរណៈទាំងនោះបានដោយឧបចារៈ ឬដោយអប្បនា ។ បទថា **ឧបក្កិលេសេ** បានដល់ អកុសលធម៌ដែលចូលទៅបៀតបៀនចិត្ត ឬអភិជ្ឈាជាដើម ដូចត្រាស់ហើយក្នុងវត្ថោបមសូត្រ ( វត្ថូបមសូត្រ ) ជាដើម ។

បទថា **ព្យបនុជ្ជ** បានដល់ បន្ទោបង់ កម្ចាត់ អធិប្បាយថា លះដោយវិបស្សនានិងមគ្គ ។ បទថា **សព្វេ** បានដល់ មិនមានចំណែកសេសសល់ ។ បុគ្គលដល់ព្រមដោយសមថៈ និងវិបស្សនា ឈ្មោះថា **អនិស្សិតោ** ព្រោះលះនូវទិដ្ឋិនិស្ស័យ ដោយបឋមមគ្គ កាត់បង់នូវសេចក្តីស្នេហា និងទោសៈ អធិប្បាយថា ( លះ ) តណ្ហារាគៈដែលប្រព្រឹត្តទៅហើយ ក្នុងលោកធាតុទាំង ៣ ដោយមគ្គដ៏សេស ដ្បិតថា ការជាប់ជំពាក់ប៉ុណ្ណោះ ហៅថា សេចក្តីស្នេហា និងទោសៈ ព្រោះជាបដិបក្ខចំពោះគុណធម៌ ។ បទដ៏សេស មានន័យដូចពោលហើយនោះឯង ។៚

**អដ្ឋកថាគាថាទី ២ ចប់**

# សុត្តន្តបិដក

[ ៣៥៦ ] បុគ្គលធ្វើឲ្យនៅពីខាងក្រោយខ្នង នូវសុខ ទុក្ខ សោមនស្ស និងទោមនស្សក្នុងកាលមុន បាននូវឧបេក្ខា និងសមថៈដ៏បរិសុទ្ធ គប្បីប្រព្រឹត្តម្នាក់ឯង ដូចកុយរមាស ។

[ ៣៥៧ ] ពាក្យថា បុគ្គលធ្វើឲ្យនៅពីខាងក្រោយខ្នង នូវសុខ ទុក្ខ សោមនស្ស និងទោមនស្សក្នុងកាលមុន សេចក្តីថា ព្រោះលះសុខផង លះទុក្ខផង ធ្វើនូវសោមនស្ស និងទោមនស្សក្នុងកាលមុនឲ្យវិនាសផង ព្រះបច្ចេកសម្ពុទ្ធនោះ ចូលចតុត្ថជ្ឈាន ឥតទុក្ខ ឥតសុខ មានសេចក្តីបរិសុទ្ធដោយឧបេក្ខា និងសតិ ហេតុនោះ ( លោកពោលថា ) ធ្វើឲ្យនៅពីខាងក្រោយខ្នង សុខ ទុក្ខ សោមនស្ស និងទោសមនស្សក្នុងកាលមុន ។

[ ៣៥៨ ] អធិប្បាយពាក្យថា បាននូវឧបេក្ខា និងសមថៈដ៏បរិសុទ្ធ ត្រង់ពាក្យថា ឧបេក្ខា បានដល់ ការព្រងើយ អាការនៃការព្រងើយ ការព្រងើយកន្តើយ ភាពនៃចិត្តស្ងប់ ភាពនៃចិត្តតាំងនៅជាកណ្តាល ក្នុងចតុត្ថជ្ឈាន ។ ពាក្យថា សមថៈ បានដល់ ការតាំងនៅ ការតាំងនៅព្រម ការតាំងនៅខ្ជាប់ ការមិនរសេមរសាម ការមិនរាយមាយ ភាពមិនអណ្តែតអណ្តូងនៃចិត្ត សមថៈ សមាធិន្ទ្រិយ សមាធិពល សម្មាសមាធិ ។ ឧបេក្ខានិងសមថៈក្នុងចតុត្ថជ្ឈាន ជាសភាវៈបរិសុទ្ធ ស្អាត ផូរផង់ មិនមានទីទួលគឺកិលេស ប្រាសចាកឧបក្កិលេស ជាសភាពទន់ភ្លន់ គួរដល់កម្ម នឹងនួន ដល់នូវការមិនញាប់ញ័រ ។

ពាក្យថា បាននូវឧបេក្ខា និងសមថៈដ៏បរិសុទ្ធ បានសេចក្តីថា បាន បានហើយ នូវឧបេក្ខា និងសមថៈក្នុងចតុត្ថជ្ឈាន ហេតុនោះ ( លោកពោលថា ) បាននូវឧបេក្ខា និងសមថៈដ៏បរិសុទ្ធ ។ គប្បីប្រព្រឹត្តម្នាក់ឯងដូចកុយរមាស ។ ហេតុនោះ ព្រះបច្ចេកសម្ពុទ្ធនោះពោលថា

បុគ្គលធ្វើឲ្យនៅពីខាងក្រោយខ្នង នូវសុខ ទុក្ខ សោមនស្ស និង
ទោមនស្សក្នុងកាលមុន បាននូវឧបេក្ខានិងសមថៈដ៏បរិសុទ្ធ គប្បី
ប្រព្រឹត្តម្នាក់ឯង ដូចកុយរមាស ។

# អដ្ឋកថា

## គាថាទី ៣

គប្បីជ្រាបវិនិច្ឆ័យក្នុងគាថាទី ៣ ដូចតទៅ

[ ៣៥៦ ] បទថា **វិបិដ្ឋិកត្វាន** បានដល់ លះទុកខាងក្រោយខ្នង ។ បទថា **សុខំ ទុក្ខញ្ច** បានដល់ សេចក្ដីត្រេកអរ និងសេចក្ដីមិនត្រេកអរផ្លូវកាយ ។ បទថា **សោមនស្សទោមនស្សំ** បានដល់ សេចក្ដីត្រេកអរផ្លូវចិត្ត និងមិនត្រេកអរផ្លូវចិត្ត ។ បទថា **ឧបេក្ខំ** បានដល់ ឧបេក្ខាក្នុងចតុត្ថជ្ឈាន ។ បទថា **សមថំ** បានដល់ សមថៈក្នុងចតុត្ថជ្ឈាននោះឯង ។ បទថា **វិសុទ្ធំ** បានដល់ ដែលបរិសុទ្ធក្រៃលែង ព្រោះផុតចាកធម៌ដែលជាសត្រូវ ៩ ប្រការ គឺនីវរណៈ ៥ វិតក្ក វិចារៈ បីតិ សុខ អធិប្បាយថា ប្រាសចាកឧបក្កិលេស ដូចមាសដែលរំលាយល្អហើយនោះឯង ។ ឯយោជនាលម្អិតដូច្នេះថា ព្រះបច្ចេកសម្ពុទ្ធលះសុខ និងទុក្ខមុនៗ ហើយ អធិប្បាយថា លះទុក្ខក្នុងឧបចារភូមិនៃបឋមជ្ឈាន និងលះសុខក្នុងឧបចារភូមិនៃតតិយជ្ឈាន ។ ព្រោះនាំ ច អក្ខរៈដែលពោលខាងដើម ទៅខាងក្រោយ ទើបសម្រេចរូបដូច្នេះថា **សោមនស្សំ ទោមនស្សញ្ច វិបិដ្ឋិកត្វាន បុព្វេវ** ដូច្នេះ ។ ដោយបទនោះ លោកសម្ដែងថា លះសោមនស្សក្នុងឧបចារភូមិនៃចតុត្ថជ្ឈាន លះទោមនស្សក្នុងឧបចារភូមិនៃទុតិយជ្ឈាន ។ ពិតហើយ ឈានទាំងនេះ ជាឋានៈនៃការលះទុក្ខ សុខ ទោមនស្ស សោមនស្សទាំងនោះ ដោយបរិយាយតែដោយត្រង់ បឋមជ្ឈានជាឋានៈលះទុក្ខ ទុតិយជ្ឈានជាឋានៈលះទោមនស្ស

តតិយជ្ឈានជាឋានៈលះសុខ ចតុត្ថជ្ឈានជាឋានៈលះសោមនស្ស ដូចព្រះមានព្រះភាគត្រាស់ថា ទុក្ខិន្ទ្រិយកើតឡើងក្នុងបឋមជ្ឈាននេះ តែងរលត់ទៅឥតមានសេសសល់ ដូច្នេះជាដើម ។ គប្បីកាន់យកព្រះតម្រាស់ទាំងអស់នោះតាមន័យដែលពោលហើយខាងដើម ។ តទៅ បទថា **បុព្វេវ** សេចក្តីថា លះទុក្ខ ទោមនស្ស និងសុខបានក្នុងឈានទាំង ៣ មានបឋមជ្ឈានជាដើម ហើយលះនូវសោមនស្សក្នុងចតុត្ថជ្ឈាននេះ បាននូវឧបេក្ខា និងសមថៈដ៏បរិសុទ្ធវិសេសដោយបដិបទានេះ គប្បីត្រាច់ទៅម្នាក់ឯង ។ បទដ៏សេសមានន័យដូចពោលហើយនោះឯង ៕

**អដ្ឋកថាគាថាទី ៣ ចប់**

# សុត្តន្តបិដក

[ ៣៥៩ ] បុគ្គលប្រារព្ធព្យាយាម ដើម្បីសម្រេចនូវប្រយោជន៍ដ៏ឧត្តម មានចិត្តមិនរួញរា ជាអ្នកប្រព្រឹត្តមិនខ្ជិល មានព្យាយាមមាំ បរិបូណ៌ដោយកម្លាំងចិត្ត និងកម្លាំងកាយ គប្បីប្រព្រឹត្តម្នាក់ឯង ដូចកុយរមាស ។

[ ៣៦០ ] ពាក្យថា ប្រារព្ធព្យាយាមដើម្បីសម្រេចនូវប្រយោជន៍ដ៏ឧត្តម សេចក្តីថា អមតនិព្វាន ហៅថា ប្រយោជន៍ដ៏ឧត្តម បានដល់ ការរម្ងាប់សង្ខារទាំងពួង ការលះបង់នូវឧបធិទាំងពួង ការអស់តណ្ហា ការអស់តម្រេក ការរលត់ និព្វាន ។ បុគ្គលជាអ្នកប្រារព្ធព្យាយាម ក្នុងការលះអកុសលធម៌ ក្នុងការបំពេញកុសលធម៌ ដើម្បីការដល់ ការបាន ការបានចំពោះ ការត្រាស់ដឹង ការពាល់ត្រូវ ការធ្វើឲ្យជាក់ច្បាស់នូវប្រយោជន៍ដ៏ឧត្តម គឺជាអ្នកមានកម្លាំងចិត្ត សេចក្តីប្រឹងប្រែងមាំ មិនដាក់ធុរៈក្នុងកុសលធម៌ទាំងឡាយ ហេតុនោះ ( លោកពោលថា ) ប្រារព្ធព្យាយាមដើម្បីសម្រេចនូវប្រយោជន៍ដ៏ឧត្តម ។

[ ៣៦១ ] ពាក្យថា មានចិត្តមិនរួញរា ជាអ្នកប្រព្រឹត្តមិនខ្ជិល អធិប្បាយថា ព្រះបច្ចេកសម្ពុទ្ធនោះ ញុំាងឆន្ទៈឲ្យកើត ព្យាយាម ប្រារព្ធនូវសេចក្តីព្យាយាម ផ្គងចិត្ត តាំងចិត្ត ដើម្បីញុំាងអកុសលធម៌ដ៏លាមកដែលមិនទាន់កើតឡើង មិនឲ្យកើតឡើងបាន ញុំាងឆន្ទៈឲ្យកើត ព្យាយាម ប្រារព្ធនូវសេចក្តីព្យាយាម ផ្គងចិត្ត តាំងចិត្តដើម្បីលះនូវអកុសលធម៌ដ៏លាមកដែលកើតឡើងហើយ ញុំាងឆន្ទៈឲ្យកើត ព្យាយាម ប្រារព្ធនូវសេចក្តីព្យាយាម ផ្គងចិត្ត តាំងចិត្តដើម្បីញុំាងកុសលធម៌ដែលមិនទាន់កើត ឲ្យកើតឡើង ឆន្ទៈឲ្យកើត ព្យាយាម ប្រារព្ធនូវ

សេចក្តីព្យាយាម ផ្គងចិត្ត តាំងចិត្តដើម្បីញ៉ាំងកុសលធម៌ទាំងឡាយដែលកើតឡើងហើយ ឲ្យស្ថិតស្ថេរ មិនឲ្យសាបសូន្យ ឲ្យចម្រើនក្រៃលែង ឲ្យទូលំទូលាយ ឲ្យពេញលេញដោយភាវនា ហេតុនោះ ( លោកពោលថា ) មានចិត្តមិនរួញរា ជាអ្នកប្រព្រឹត្តមិនខ្ជិលយ៉ាងនេះ ។ មួយទៀត បុគ្គលផ្គងចិត្ត តាំងចិត្តថា ចង់សល់នៅតែស្បែក សរសៃ និងឆ្អឹងក៏ដោយចុះ ចង់សាច់ និងឈាមក្នុងសរីរៈ រីងស្ងួតទៅក៏ដោយចុះ គុណជាតណាដែលបុគ្គលគប្បីសម្រេចដោយកម្លាំងចិត្តរបស់បុរស ដោយកម្លាំងកាយរបស់បុរស ដោយសេចក្តីព្យាយាមរបស់បុរស ដោយសេចក្តីប្រឹងប្រែងរបស់បុរស បើអាត្មាមិនទាន់សម្រេចនូវគុណជាតនោះទេ នឹងមិនបញ្ឈប់នូវព្យាយាមឡើយ បុគ្គលមានចិត្តមិនរួញរា ជាអ្នកប្រព្រឹត្តមិនខ្ជិលដោយវិធីយ៉ាងនេះក៏មាន ។ បុគ្គលផ្គងចិត្ត តាំងចិត្តថា ចិត្តរបស់អាត្មាអញមិនទាន់រួចចាកអាសវៈ ព្រោះមិនប្រកាន់មាំ ដរាបណា អាត្មាអញនឹងមិនទម្លាយភ្នែនដរាបនោះ បុគ្គលមានចិត្តមិនរួញរា ជាអ្នកប្រព្រឹត្តមិនខ្ជិលដោយវិធីយ៉ាងនេះក៏មាន ។ បុគ្គលផ្គងចិត្ត តាំងចិត្តថា

កាលបើសរ គឺតណ្ហា មិនទាន់ដកចេញទេ អាត្មាអញនឹងមិនស៊ី
និងមិនផឹក និងមិនចេញអំពីវិហារ ទាំងនឹងមិនដាក់នូវបង្អៀង
( ទម្រេត ) ឡើយ ។

បុគ្គលមានចិត្តមិនរួញរា ជាអ្នកប្រព្រឹត្តមិនខ្ជិល ដោយវិធីយ៉ាងនេះក៏មាន ។ បុគ្គលផ្គង់ចិត្ត តាំងចិត្តថា បើចិត្តរបស់អាត្មាអញនឹងមិនទាន់រួចចាកអាសវៈ ព្រោះមិនប្រកាន់មាំដរាបណា អាត្មាអញនឹងមិនក្រោកចាក

អាសនៈនេះដរាបនោះ បុគ្គលមានចិត្តមិនរួញរា ជាអ្នកប្រព្រឹត្តមិនខ្ជិលដោយវិធីយ៉ាងនេះក៏មាន ។ បុគ្គលផ្គងចិត្ត តាំងចិត្តថា អាត្មាអញនឹងមិនចុះអំពីទីចង្ក្រមនេះ មិនចេញអំពីវិហារនេះ មិនចេញអំពីអឌ្ឍយោគនេះ មិនចេញអំពីប្រាសាទនេះ មិនចេញអំពីប្រាសាទមានជ្រុង ៤ នេះ មិនចេញអំពីគុហានេះ មិនចេញអំពីគុកនេះ មិនចេញអំពីកុដិនេះ មិនចេញអំពីផ្ទះមានកំពូលនេះ មិនចេញអំពីប៉មនេះ មិនចេញអំពីរោងនេះ មិនចេញអំពីរោងដោលនេះ មិនចេញអំពីឧបដ្ឋានសាលានេះ មិនចេញអំពីមណ្ឌបនេះ មិនចេញអំពីគល់ឈើនេះ បើចិត្តរបស់អាត្មាអញ មិនទាន់រួចចាកអាសវៈទាំងឡាយ ព្រោះមិនប្រកាន់មាំ បុគ្គលមានចិត្តមិនរួញរា ជាអ្នកប្រព្រឹត្តមិនខ្ជិល ដោយវិធីយ៉ាងនេះក៏មាន ។ បុគ្គលផ្គងចិត្ត តាំងចិត្តថា អាត្មាអញនឹងនាំមក នឹងប្រមូលមក នឹងត្រាស់ដឹង នឹងពាល់ត្រូវ នឹងធ្វើឲ្យជាក់ច្បាស់នូវអរិយធម៌ ឲ្យទាន់ក្នុងបុព្វណ្ហសម័យនេះ បុគ្គលមានចិត្តមិនរួញរា ជាអ្នកប្រព្រឹត្តមិនខ្ជិល ដោយវិធីយ៉ាងនេះក៏មាន ។ បុគ្គលផ្គងចិត្ត តាំងចិត្តថា អាត្មាអញនឹងនាំមក នឹងប្រមូលមក នឹងត្រាស់ដឹង នឹងពាល់ត្រូវ នឹងធ្វើឲ្យជាក់ច្បាស់នូវអរិយធម៌ឲ្យទាន់ក្នុងវេលាថ្ងៃត្រង់នេះ ក្នុងវេលាថ្ងៃរសៀលនេះ ក្នុងវេលាមុនភត្តនេះ ក្នុងវេលាក្រោយភត្តនេះ ក្នុងបឋមយាមនេះ ក្នុងមជ្ឈិមយាមនេះ ក្នុងបច្ឆិម-យាមនេះ ក្នុងរនោចនេះ ក្នុងខ្នើតនេះ ក្នុងវស្សានរដូវនេះ ក្នុងហេមន្តរដូវនេះ ក្នុងគិម្ហរដូវនេះ ក្នុងចំណែកបឋមវ័យនេះ ក្នុងចំណែកមជ្ឈិមវ័យនេះ ក្នុងចំណែកបច្ឆិមវ័យនេះ បុគ្គលមានចិត្តមិនរួញរា ជាអ្នកប្រព្រឹត្តមិនខ្ជិល

ដោយវិធីយ៉ាងនេះក៏មាន ។

[ ៣៦២ ] អធិប្បាយពាក្យថា មានព្យាយាមមាំ បរិបូណ៌ដោយកម្លាំងចិត្ត និងកម្លាំងកាយ ត្រង់ពាក្យថា មានព្យាយាមមាំ សេចក្តីថា ព្រះបច្ចេកសម្ពុទ្ធនោះ ជាអ្នកមានការសមាទានមាំក្នុងពួកកុសលធម៌ មានការសមាទានខ្ជាប់ខ្ជួនក្នុងកាយសុចរិត ក្នុងវចីសុចរិត ក្នុងមនោសុចរិត ក្នុងការចែករលែក ក្នុងការសមាទានសីល ក្នុងការរក្សាឧបោសថ ក្នុងភាពជាអ្នកគោរពមាតា ក្នុងភាពជាអ្នកគោរពបិតា ក្នុងភាពជាអ្នកគោរពសមណៈ ក្នុងភាពជាអ្នកគោរពព្រាហ្មណ៍ ក្នុងភាពជាអ្នកគោរពបុគ្គលជាច្បងក្នុងត្រកូល ក្នុងធម៌ទាំងឡាយជាអធិកុសលណាមួយ ហេតុនោះ ( លោកពោលថា ) មានព្យាយាមមាំ ។ ពាក្យថា បរិបូណ៌ដោយកម្លាំងចិត្ត និងកម្លាំងកាយ បានសេចក្តីថា ព្រះបច្ចេកសម្ពុទ្ធនោះ ដល់ ដល់ព្រម មកជិត មកជិតព្រម ចូលដល់ ចូលដល់ព្រម ប្រកបដោយកម្លាំងចិត្តផង កម្លាំងកាយផង ព្យាយាមផង សេចក្តីប្រឹងប្រែងផង ហេតុនោះ ( លោកពោលថា ) មានព្យាយាមមាំ បរិបូណ៌ដោយកម្លាំងចិត្ត និងកម្លាំងកាយ ។ គប្បីប្រព្រឹត្តម្នាក់ឯងដូចកុយរមាស ។ ហេតុនោះ ព្រះបច្ចេកសម្ពុទ្ធនោះពោលថា

បុគ្គលប្រារព្ធព្យាយាម ដើម្បីសម្រេចនូវប្រយោជន៍ដ៏ឧត្តម មានចិត្ត
មិនរួញរា ជាអ្នកប្រព្រឹត្តមិនខ្ជិល មានព្យាយាមមាំ បរិបូណ៌ដោយ
កម្លាំងចិត្ត និងកម្លាំងកាយ គប្បីប្រព្រឹត្តម្នាក់ឯង ដូចកុយរមាស ។

# អដ្ឋកថា

## គាថាទី ៤

គប្បីជ្រាបវិនិច្ឆ័យក្នុងគាថាទី ៤ ដូចតទៅ

[ ៣៥៩ ] ឈ្មោះថា **អារទ្ធវីរិយោ** ព្រោះមានសេចក្ដីព្យាយាមប្រារព្ធហើយ ។ ដោយបទនេះ ព្រះបច្ចេកសម្ពុទ្ធសម្ដែងដល់ការផ្ដើមសេចក្ដីព្យាយាម គឺសេចក្ដីព្យាយាមខាងដើមរបស់ខ្លួន ។ និព្វាន ហៅថា បរមត្ថប្រយោជន៍ ។ ដើម្បីដល់នូវនិព្វាននោះ ។ ឈ្មោះថា **បរមត្ថបត្តិយា** ព្រះបច្ចេកសម្ពុទ្ធសម្ដែងដល់ផលដែលគួរសម្រេច ដោយការផ្ដើមសេចក្ដីព្យាយាមនោះ ។ ដោយបទថា **អលីនចិត្តោ** ព្រះបច្ចេកសម្ពុទ្ធសម្ដែងដល់ការមិនធូរថយនៃចិត្ត និងចេតសិកទាំងឡាយ ដែលសេចក្ដីព្យាយាមឧបការៈ ។ ដោយបទថា **អកុសីតវុត្តិ** នេះ ព្រះបច្ចេកសម្ពុទ្ធសម្ដែងដល់ភាពដែលកាយមិនលិចចុះក្នុងទីដែលឈរ ទីអង្គុយ និងទីចង្រ្កមជាដើម ។ ដោយបទថា **ទឡ្ហនិក្កមោ** នេះ ព្រះបច្ចេកពុទ្ធសម្ដែងការតាំងសេចក្ដីព្យាយាម ដែលប្រព្រឹត្តទៅ យ៉ាងនេះថា **កាមំ តចោ ច ន្ហារុ ច**[១] ដូច្នេះជាដើម ។ លោកពោលថា បុគ្គលតម្កល់នូវសេចក្ដីព្យាយាមក្នុងអនុបុព្វសិក្ខាបទជាដើម ហៅថា ធ្វើឲ្យជាក់ច្បាស់នូវបរមត្ថសច្ចផ្លូវកាយ ។ម្យ៉ាងទៀត ដោយបទនេះ ព្រះបច្ចេកសម្ពុទ្ធសម្ដែងដល់សេចក្ដីព្យាយាម ដែលសម្បយុត្តដោយមគ្គ ។ សេចក្ដីព្យាយាមនោះ ឈ្មោះថា **ទឡ្ហ** ព្រោះដល់នូវការបរិបូណ៌ក្នុងការចម្រើនភាវនា និងឈ្មោះថា **និក្កមោ** ព្រោះចេញចាកធម៌ដែលជាសត្រូវ ដោយ

---

១- បិដកលេខ ៤០ ឃ្នាប ២៥១ ។

ប្រការទាំងពួង ។ ព្រោះដូច្នោះ ទើបលោកពោលថា **ទឡ្ហនិក្កមោ** ព្រោះជាអ្នកមានការដល់ព្រមដោយធម៌នោះ មានសេចក្ដីព្យាយាមមាំទាំ ។ បទថា **ថាមពលូបបន្នោ** បានដល់ ដល់ព្រមដោយកម្លាំងកាយ និងកម្លាំងញាណក្នុងខណៈនៃមគ្គ ។ម្យ៉ាងទៀត ដល់ព្រមដោយកម្លាំងដែលជាថាមពល ឈ្មោះថា **ថាមពលូបបន្នោ** ។ មានពាក្យអធិប្បាយថា ដល់ព្រមដោយកម្លាំងញាណដ៏មាំទាំ ។ ដោយបទនេះ ព្រះបច្ចេកពុទ្ធកាលសម្ដែងដល់ការប្រកបព្រមដោយញាណនៃវីរិយៈនោះ ទើបញ៉ាំងសេចក្ដីព្យាយាមដោយឧបាយឲ្យសម្រេច ។ គប្បីប្រកបបទទាំងឡាយ ៣ បទ ដោយអំណាចនៃសេចក្ដីព្យាយាម ដែលជាចំណែកខាងដើម កណ្ដាល និងឧក្រិដ្ឋ ។ បទដ៏សេស មានន័យដូចពោលហើយនោះឯង ។ល។

## អដ្ឋកថា គាថាទី ៤ ចប់

# សុត្តន្តបិដក

[ ៣៦៣ ] បុគ្គលមិនលះបង់នូវការសម្ងំផង នូវឈានផង ជាអ្នកប្រព្រឹត្តធម៌បន្ទាប់បន្សំ ក្នុងធម៌ទាំងឡាយអស់កាលជានិច្ច ពិចារណាឃើញទោសក្នុងភពទាំងឡាយ គប្បីប្រព្រឹត្តម្នាក់ឯង ដូចកុយរមាស ។

[ ៣៦៤ ] ពាក្យថា មិនលះបង់នូវការសម្ងំផង នូវឈានផង អធិប្បាយថា ព្រះបច្ចេកសម្ពុទ្ធនោះ ជាអ្នកមានការសម្ងំជាទីត្រេកអរ ត្រេកអរក្នុងការសម្ងំ ប្រកបរឿយៗ នូវចេតោសមថៈខាងក្នុង មិនធ្វើឈានឲ្យរបូតចុះ មិនលះបង់ឈាន ប្រកប ប្រកបរឿយៗ ប្រកបព្រម ប្រកបមិនដាច់ ប្រកបមិនដាច់ព្រម ដើម្បីធ្វើបឋមជ្ឈានដែលមិនកើតឲ្យកើតឡើង ឬប្រកប ប្រកបរឿយៗ ប្រកបព្រម ប្រកបមិនដាច់ ប្រកបមិនដាច់ព្រម ដើម្បីធ្វើទុតិយជ្ឈានដែលមិនទាន់កើត ឬតតិយជ្ឈានដែលមិនទាន់កើត ឬក៏ចតុត្ថជ្ឈានដែលមិនទាន់កើត ឲ្យកើតឡើង ហេតុនោះ ឈ្មោះថា មិនលះបង់នូវឈានយ៉ាងនេះឯង ។ មួយទៀត ព្រះបច្ចេកសម្ពុទ្ធសេព ចម្រើន ធ្វើឲ្យច្រើននូវបឋមជ្ឈានដែលកើតឡើងហើយ ឬសេព ចម្រើន ធ្វើឲ្យច្រើននូវទុតិយជ្ឈានដែលកើតឡើងហើយ ឬតតិយជ្ឈានដែលកើតឡើងហើយ ឬចតុត្ថជ្ឈានដែលកើតឡើងហើយ ហេតុនោះ ឈ្មោះថា មិនលះបង់នូវឈានយ៉ាងនេះក៏មាន ហេតុនោះ ( លោកពោលថា ) មិនលះបង់នូវការសម្ងំផង នូវឈានផង ។

[ ៣៦៥ ] ពាក្យថា ជាអ្នកប្រព្រឹត្តធម៌បន្ទាប់បន្សំ ក្នុងធម៌ទាំងឡាយអស់

កាលជានិច្ច អធិប្បាយថា សតិប្បដ្ឋាន ៤ ។បេ។ មគ្គប្រកបដោយអង្គ ៨ ដ៏ប្រសើរ ហៅថា ធម៌ ។ ធម៌បន្ទាប់បន្សំ តើដូចម្តេច ។ ការប្រតិបត្តិត្រូវ ការប្រតិបត្តិជាអនុលោម ការប្រតិបត្តិមិនមានទំនាស់ ការប្រតិបត្តិគួរតាមប្រយោជន៍ ការប្រតិបត្តិនូវធម៌តាមធម៌ ការបំពេញក្នុងសីលទាំងឡាយ ការគ្រប់គ្រងទ្វារក្នុងឥន្ទ្រិយ ការស្គាល់ប្រមាណក្នុងភោជន ការប្រកបរឿយៗ នូវសេចក្តីភ្ញាក់រឭក សតិ និងសម្បជញ្ញៈ ទាំងនេះ ហៅថា ធម៌បន្ទាប់បន្សំ ។ ពាក្យថា ជាអ្នកប្រព្រឹត្តធម៌បន្ទាប់បន្សំ ក្នុងធម៌ទាំងឡាយអស់កាលជានិច្ច បានសេចក្តីថា ចរ ត្រាច់ ទៅ ប្រព្រឹត្ត រក្សា យាត្រា ឲ្យយាត្រាទៅក្នុងធម៌ទាំងឡាយអស់កាលជានិច្ច រឿយៗ ជាប់ត មិនដាច់ ញយៗ មិនល្បោះ ជាប់មិនដាច់ ជាប់ត ជិតស្និទ្ធ វេលាមុនកត្ត វេលាក្រោយកត្ត បុរិមយាម មជ្ឈិមយាម បច្ឆិមយាម រនោច ខ្នើត វស្សានរដូវ ហេមន្តរដូវ គិម្ហរដូវ ចំណែកបុរិមវ័យ ចំណែកមជ្ឈិមវ័យ ចំណែកបច្ឆិមវ័យ ហេតុនោះ ( លោកពោលថា ) ជាអ្នកប្រព្រឹត្តធម៌បន្ទាប់បន្សំក្នុងធម៌ទាំងឡាយអស់កាលជានិច្ច ។

[ ៣៦៦ ] ពាក្យថា ពិចារណាឃើញទោស ក្នុងភពទាំងឡាយ គឺ ពិចារណាឃើញទោសក្នុងភពថា សង្ខារទាំងពួង មិនទៀង ថាសង្ខារទាំងពួង ជាទុក្ខ ថាជាធម៌ទាំងពួង ជាអនត្តា ។បេ។ ពិចារណាឃើញទោសក្នុងភពថា ធម្មជាតមានការកើតឡើងជាធម្មតា ធម្មជាតទាំងអស់នោះ មានការ

រលត់ទៅវិញជាធម្មតា ហេតុនោះ ( លោកពោលថា ) ពិចារណាឃើញទោសក្នុងភពទាំងឡាយ ។ គប្បីប្រព្រឹត្តម្នាក់ឯង ដូចកុយរមាស ។ ហេតុនោះ ព្រះបច្ចេកសម្ពុទ្ធនោះពោលថា

បុគ្គលមិនលះបង់នូវការសម្ងំផង នូវឈានផង ជាអ្នកប្រព្រឹត្តធម៌

បន្ទាប់បន្សំ ក្នុងធម៌ទាំងឡាយអស់កាលជានិច្ច ពិចារណាឃើញ

ទោសក្នុងភពទាំងឡាយ គប្បីប្រព្រឹត្តម្នាក់ឯង ដូចកុយរមាស ។

# អដ្ឋកថា

## គាថាទី ៥

គប្បីជ្រាបវិនិច្ឆ័យក្នុងគាថាទី ៥ ដូចតទៅ

[ ៣៦៣ ] បទថា **បដិសល្លានំ** បានដល់ ការចៀសចេញចាកសត្វ និងសង្ខារនោះៗ ហើយពួនសម្ងំ អធិប្បាយថា ការសេពចំពោះខ្លួនម្នាក់ឯង ភាពតែឯង និងកាយវិវេក ។ ចិត្តវិវេក ហៅថា **ឈានំ** ព្រោះដុតនូវធម៌ដែលជាសត្រូវ និងព្រោះសម្លឹងអារម្មណ៍ និងលក្ខណៈ ។ ក្នុងបទនោះ សមាបត្តិ ៨ ហៅថា **ឈាន** ព្រោះដុតនូវធម៌ជាសត្រូវ មាននីវរណៈជាដើម និងព្រោះសម្លឹងដល់អារម្មណ៍ ។ វិបស្សនា មគ្គ និងផល លោកហៅថា **ឈាន** ព្រោះដុតនូវធម៌ដែលជាសត្រូវ មានសត្តសញ្ញាជាដើម និងព្រោះសម្លឹងដល់លក្ខណៈ តែក្នុងទីនេះ បំណងយកការសម្លឹងអារម្មណ៍ប៉ុណ្ណោះ ។ ព្រះបច្ចេកពុទ្ធមិនលះបង់ក្នុងការពួនសម្ងំ និងឈាននេះ ដោយប្រការដូច្នេះ ។

បទថា **អរិញ្ចមានោ** បានដល់ មិនលះបង់ ។ បទថា **ធម្មេសុ** បានដល់ ក្នុងធម៌ មានខន្ធ ៥ ជាដើម ដែលជាគ្រឿងឲ្យចូលដល់វិបស្សនា ។ បទថា **និច្ចំ** បានដល់ ប្រចាំ ជានិច្ច រឿយៗ ។ បទថា **អនុធម្មចារី** បានដល់ ប្រារព្ធធម៌ទាំងនោះហើយប្រព្រឹត្តវិបស្សនាធម៌ ដែលអនុវត្តទៅតាមធម៌ដែលប្រព្រឹត្តទៅ ។ម្យ៉ាងទៀត បទថា **ធម្ម** ក្នុងបទថា **ធម្មេសុ** នេះ បានដល់ លោកុត្តរធម៌ ៩ ។ ឈ្មោះថា **អនុធម្ម** ព្រោះជាធម៌សមគួរដល់ធម៌ទាំងនោះ ។ បទនេះ ជាឈ្មោះរបស់វិបស្សនា ។ ក្នុងបទនោះ កាលគួរនឹង

ពោលថា ប្រព្រឹត្តធម៌សមគួរដល់ធម៌ទាំងឡាយ ជានិច្ច ក៏ពោលថា **ធម្មេសុ** ប្រែថា ក្នុងធម៌ទាំងឡាយ ដោយការផ្លាស់វិភត្តិដើម្បីងាយស្រួលក្នុងការចងគាថា ។ ( គឺគួរជា **ធម្មានំ** តែក្នុងគាថាជា **ធម្មេសុ**) ។ បទថា **អាទីនវំ សម្មសិតា ភវេសុ** សេចក្ដីថា ពិចារណាឃើញទោសក្នុងការមិនទៀងជាដើមក្នុងភពទាំង ៣ ដោយវិបស្សនា ដែលបានដល់ភាពជាអ្នកប្រព្រឹត្តធម៌សមគួរដល់ធម៌នោះ គួរពោលថា លោកបានសម្រេចហើយ ដោយបដិបទា ពោលគឺកាយវិវេក ចិត្តវិវេក និងវិបស្សនាដែលដល់នូវភាពជាកំពូលនេះយ៉ាងនេះ គប្បីជ្រាបការប្រកបយ៉ាងនេះថា **ឯកោ ចរេ** គឺគប្បីត្រាច់ទៅតែម្នាក់ឯង ។

**អដ្ឋកថា គាថាទី ៥ ចប់**

# សុត្តន្តបិដក

[ ៣៦៧ ] បុគ្គល កាលប្រាថ្នានូវការអស់តណ្ហា ជាអ្នកមិនប្រហែស មិនល្ងង់ខ្លៅ ជាអ្នកចេះដឹង មានស្មារតី មានធម៌ពិចារណាហើយ ជាអ្នកទៀងទាត់ មានព្យាយាម គប្បីប្រព្រឹត្តម្នាក់ឯង ដូចកុយរមាស ។

[ ៣៦៨ ] អធិប្បាយពាក្យថា ការប្រាថ្នានូវការអស់តណ្ហា ជាអ្នកមិនប្រហែស ត្រង់ពាក្យថា តណ្ហា បានដល់ រូបតណ្ហា សទ្ទតណ្ហា គន្ធតណ្ហា រសតណ្ហា ផោដ្ឋព្វតណ្ហា ធម្មតណ្ហា ។ ពាក្យថា កាលប្រាថ្នានូវការអស់តណ្ហា គឺការប្រាថ្នា ប៉ុនប៉ង ផ្គង បំណង នូវការអស់រាគៈ ការអស់ទោសៈ ការអស់មោហៈ ការអស់គតិ ការអស់ឧបបត្តិ ការអស់បដិសន្ធិ ការអស់ភព ការអស់សង្សារ ការអស់វដ្ដៈ ហេតុនោះ ( លោកពោលថា ) ការប្រាថ្នានូវការអស់តណ្ហា ។ ពាក្យថា ជាអ្នកមិនប្រហែស គឺព្រះបច្ចេកសម្ពុទ្ធនោះ ជាអ្នកធ្វើសេចក្តីគោរព ។បេ។ ជាអ្នកមិនប្រហែសក្នុងកុសលធម៌ទាំងឡាយ ហេតុនោះ ( លោកពោលថា ) កាលប្រាថ្នានូវការអស់តណ្ហា ជាអ្នកមិនប្រហែស ។

[ ៣៦៩ ] អធិប្បាយពាក្យថា មិនល្ងង់ខ្លៅ ជាអ្នកចេះដឹង មានស្មារតី ត្រង់ពាក្យថា មិនល្ងង់ខ្លៅ គឺព្រះបច្ចេកសម្ពុទ្ធនោះ ជាបណ្ឌិត មានប្រាជ្ញា មានការត្រាស់ដឹង មានញាណ មានការភ្លឺស្វាង មានប្រាជ្ញាជាគ្រឿងទម្លាយកិលេស ហេតុនោះ ( លោកពោលថា ) មិនល្ងង់ខ្លៅ ។ ពាក្យថា ជាអ្នកចេះដឹង គឺព្រះបច្ចេកសម្ពុទ្ធនោះ ជាពហុស្សូត ទ្រទ្រង់នូវចំណេះ សន្សំនូវចំណេះ ពួកធម៌

ណាដែលល្អខាងដើម ល្អកណ្តាល ល្អទីបំផុត ប្រកបដោយអត្ថ ប្រកបដោយព្យញ្ជនៈ ប្រកាសនូវព្រហ្មចរិយធម៌ ដ៏បរិសុទ្ធ បរិបូណ៌ ពេញលេញ ពួកធម៌មានសភាពដូច្នោះ គឺព្រះបច្ចេកសម្ពុទ្ធនោះ បានចេះចាំច្រើន បានទ្រទ្រង់ទុក ចាំស្ទាត់រត់មាត់ ចូលចិត្តច្បាស់លាស់ ចាក់ធ្លុះដោយទិដ្ឋិ ហេតុនោះ ( លោកពោលថា ) ជាអ្នកចេះដឹង ។ ពាក្យថា មានស្មារតី គឺព្រះបច្ចេកសម្ពុទ្ធនោះ មានស្មារតី ប្រកបដោយសតិ និងប្រាជ្ញា ជាគ្រឿងរក្សាខ្លួនដ៏ក្រៃលែង ជាអ្នករឭកឃើញនូវអំពើ ដែលធ្វើយូរហើយផង នូវសម្តីដែលពោលយូរហើយផង ហេតុនោះ ( លោកពោលថា ) មិនល្ងង់ខ្លៅ ជាអ្នកចេះដឹង មានស្មារតី ។

[ ៣៧០ ] ពាក្យថា មានធម៌ពិចារណាហើយ ជាអ្នកទៀងទាត់ មានព្យាយាម អធិប្បាយថា ញាណ លោកហៅថា ធម៌ដែលពិចារណាហើយ បានដល់ បញ្ញា ការដឹងច្បាស់ ។បេ។ ការមិនវង្វេង ការពិចារណានូវធម៌ ការយល់ត្រូវ ។ ពាក្យថា មានធម៌ពិចារណាហើយ គឺព្រះបច្ចេកសម្ពុទ្ធនោះ មានធម៌ពិចារណាហើយ មានធម៌ដឹងហើយ មានធម៌ថ្លឹងហើយ មានធម៌ត្រិះរិះហើយ មានធម៌ច្បាស់ហើយ មានធម៌ធ្វើឲ្យកើតប្រាកដហើយថា សង្ខារទាំងពួង មិនទៀង ។បេ។ មានធម៌ពិចារណាហើយ មានធម៌ដឹងហើយ មានធម៌ថ្លឹងហើយ មានធម៌ត្រិះរិះហើយ មានធម៌ច្បាស់ហើយ មានធម៌ធ្វើឲ្យកើតប្រាកដហើយថា ធម្មជាតណាមួយ មានការកើតឡើងជាធម្មតា ធម្មជាតទាំងអស់នោះ មានការរលត់ទៅវិញជាធម្មតា ។ មួយទៀត ព្រះបច្ចេកសម្ពុទ្ធនោះ បានពិចារណាខន្ធ ពិចារណាធាតុ ពិចារណាអាយតនៈ ពិចារណាគតិ ពិចារណា

ឧបបត្តិ ពិចារណាបដិសន្ធិ ពិចារណាភព ពិចារណាសង្សារ ពិចារណាវដ្ដៈ ។ មួយទៀត ព្រះបច្ចេកសម្ពុទ្ធ ស្ថិតនៅក្នុងទីបំផុតនៃខន្ធ ស្ថិតនៅក្នុងទីបំផុតនៃធាតុ ស្ថិតនៅក្នុងទីបំផុតនៃអាយតនៈ ស្ថិតនៅក្នុងទីបំផុតនៃគតិ ស្ថិតនៅក្នុងទីបំផុតនៃឧបបត្តិ ស្ថិតនៅក្នុងទីបំផុតនៃបដិសន្ធិ ស្ថិតនៅក្នុងទីបំផុតនៃភព ស្ថិតនៅក្នុងទីបំផុតនៃសង្សារ ស្ថិតនៅក្នុងទីបំផុតនៃវដ្ដៈ ស្ថិតនៅក្នុងទីបំផុតនៃសង្ខារ ស្ថិតនៅក្នុងភពជាទីបំផុត ព្រះបច្ចេកសម្ពុទ្ធ ទ្រទ្រង់នូវរាងកាយជាទីបំផុត ។

ភពនេះ ជាខាងក្រោយ រាងកាយនេះ ជាខាងក្រោយ របស់
បុគ្គលណា ការអន្ទោលទៅកាន់ជាតិ ជរា មរណៈ គឺភពថ្មី
របស់បុគ្គលនោះ មិនមានឡើយ ។

ហេតុនោះ ( លោកពោលថា ) មានធម៌ពិចារណាហើយ ។ ពាក្យថា ជាអ្នកទៀងទាត់ សេចក្ដីថា អរិយមគ្គ ៤ ហៅថា ការទៀងទាត់ ។ បុគ្គលប្រកបដោយអរិយមគ្គ ៤ ឈ្មោះថា ជាអ្នកទៀងទាត់ គឺជាអ្នកដល់ ដល់ព្រមពាល់ត្រូវ ធ្វើឲ្យជាក់ច្បាស់ នូវការទៀងទាត់ ដោយអរិយមគ្គទាំងឡាយ ហេតុនោះ ( លោកពោលថា ) ជាអ្នកទៀងទាត់ ។ ពាក្យថា មានព្យាយាម សេចក្ដីថា សេចក្ដីប្រឹងប្រែង ហៅថា សេចក្ដីព្យាយាម បានដល់ ការប្រារព្ធព្យាយាមនៃចិត្ត ការប្រឹងប្រែង ការខ្នះខ្នែង ការឧស្សាហ៍ ការខ្មីឃ្មាត ការសង្វាត ការសង្វាតមាំ ការមិនបន្ធូរបន្ថយព្យាយាម ការមិនដាក់បំណង ការមិនទម្លាក់ធុរៈ ការផ្គងនូវធុរៈ វីរិយៈ វីរិយិន្ទ្រិយ វីរិយពល សម្មាវាយាមៈ ។ ព្រះបច្ចេកសម្ពុទ្ធនោះដល់ ដល់ព្រម មកជិត មកជិតព្រម ចូលទៅដល់

ចូលទៅដល់ព្រម ប្រកបដោយសេចក្ដីព្យាយាមនេះ ហេតុនោះ ព្រះបច្ចេក-សម្ពុទ្ធនោះ ឈ្មោះថា មានព្យាយាម ហេតុនោះ ( លោកពោលថា ) មានធម៌ពិចារណាហើយ ជាអ្នកទៀនទាត់ មានព្យាយាម ។ គប្បីប្រព្រឹត្តម្នាក់ឯង ដូចកុយរមាស ។ ហេតុនោះ ព្រះបច្ចេកសម្ពុទ្ធនោះពោលថា

បុគ្គលប្រាថ្នានូវការអស់តណ្ហា ជាអ្នកមិនប្រហែស មិនល្ងង់ខ្លៅ
ជាអ្នកចេះដឹង មានស្មារតី មានធម៌ពិចារណាហើយ ជាអ្នកទៀន
ទាត់ មានព្យាយាម គប្បីប្រព្រឹត្តម្នាក់ឯង ដូចកុយរមាស ។

# អដ្ឋកថា

## គាថាទី ៦

គប្បីជ្រាបវិនិច្ឆ័យក្នុងគាថាទី ៦ ដូចតទៅ

[ ៣៦៧ ] បទថា **តណ្ហក្ខយំ** បានដល់ ព្រះនិព្វាន ។ ឬការមិនប្រព្រឹត្តទៅនៃតណ្ហា ដែលមានទោស ដែលខ្លួនឃើញហើយយ៉ាងនេះឯង ។ បទថា **អប្បមត្តោ** បានដល់ ជាអ្នកមានប្រក្រតីធ្វើជាប់ត ។ បទថា **អនេឡមូគោ** បានដល់ មិនល្ងង់ខ្លៅ ។ម្យ៉ាងទៀត បានដល់ មិនថ្លង់ មិនគ អធិប្បាយថា ជាបណ្ឌិត ជាអ្នកឈ្លាស ។ ឈ្មោះថា **សុតវា** ព្រោះមានសុតៈដែលឲ្យដល់នូវប្រយោជន៍ និងសេចក្ដីសុខ អធិប្បាយថា ជាអ្នកដល់ព្រមដោយការសិក្សា ។ បទថា **សតិមា** បានដល់ រឭកដល់វត្ថុដែលធ្វើហើយសូម្បីយូរជាដើមបាន ។ បទថា **សង្ខាតធម្មោ** បានដល់ មានធម៌ដែលកំណត់ដឹងហើយ ដោយការពិចារណាធម៌ ។ បទថា **និយតោ** បានដល់ ដល់នូវការទៀងដោយអរិយមគ្គ ។

បទថា **បធានវា** បានដល់ ដល់ព្រមដោយសេចក្ដីព្យាយាម គឺសម្មប្បធាន ។ បាឋៈនេះ ប្រកបខុសលំដាប់ ដ្បិតថា បុគ្គលប្រកបដោយធម៌មានការមិនប្រមាទជាដើម ទាំងនេះយ៉ាងនេះហើយ មានសេចក្ដីព្យាយាមដោយការព្យាយាម ដែលឲ្យដល់នូវការតាំងចិត្តពិត ជាអ្នកទៀង ព្រោះមានធម៌ដែលទៀង គឺអរិយមគ្គ ដែលខ្លួនដល់ហើយ ដោយសេចក្ដីព្យាយាមនោះ បន្ទាប់អំពីនោះ ទើបមានធម៌កំណត់ដឹងហើយ ព្រោះការសម្រេចអរហត្ត ។

ពិតហើយ ព្រះអរហន្ត លោកហៅថា ជាអ្នកមានធម៌កំណត់ដឹងហើយ ព្រោះមិនមានធម៌ដែលគប្បីកំណត់ដឹងទៀត ។

សមដូចព្រះមានព្រះភាគត្រាស់ ( ក្នុងសំយុត្តនិកាយ និទានវគ្គ ) ថា ពួកបុគ្គលណា មានធម៌ពិចារណាហើយក្តី ពួកបុគ្គលណា ជាសេក្ខៈដ៏ច្រើនក្តី ក្នុងសាសនានេះ ដូច្នេះ ។ បទដ៏សេស មានន័យដូចពោលហើយនោះឯង ៕

## អដ្ឋកថាគាថាទី ៦ ចប់

# សុត្តន្តបិដក

[ ៣៧១ ] បុគ្គលអ្នកមិនតក់ស្លុត ព្រោះសំឡេងទាំងឡាយ ដូចសីហៈ មិនជាប់ក្នុងជាលដូចខ្យល់ មិនទទឹកដោយទឹកដូចឈូក គប្បីប្រព្រឹត្តម្នាក់ ដូចកុយរមាស ។

[ ៣៧២ ] ពាក្យថា បុគ្គលមិនតក់ស្លុត ព្រោះសំឡេងទាំងឡាយ ដូចសីហៈ អធិប្បាយថា សីហៈជាស្តេចម្រឹគ មិនតក់ស្លុត មិនរន្ធត់ មិនញាប់ញ័រ មិនភ្ញាក់ផ្អើល មិនព្រឺព្រួច មិនរំភើប មិនខ្លាច មិនភិតភ័យ មិនស្ញប់ស្ញែង មិនរត់ ព្រោះសំឡេងទាំងឡាយ យ៉ាងណាមិញ ឯព្រះបច្ចេកសម្ពុទ្ធ ក៏មិនតក់ស្លុត មិនរន្ធត់ មិនញាប់ញ័រ មិនភ្ញាក់ផ្អើល មិនព្រឺព្រួច មិនរំភើប មិនខ្លាច មិនភិតភ័យ មិនស្ញប់ស្ញែង មិនរត់ លះភ័យគួរខ្លាច មិនព្រឺរោម ព្រោះសំឡេងទាំងឡាយ ក៏យ៉ាងនោះដែរ ហេតុនោះ ( លោកពោលថា ) បុគ្គលមិនតក់ស្លុត ព្រោះសំឡេងទាំងឡាយ ដូចសីហៈ ។

[ ៣៧៣ ] អធិប្បាយពាក្យថា មិនជាប់ក្នុងជាលដូចខ្យល់ ត្រង់ពាក្យថា ខ្យល់ បានដល់ ខ្យល់ខាងកើត ខ្យល់ខាងលិច ខ្យល់ខាងជើង ខ្យល់ខាងត្បូង ខ្យល់មានធូលី ខ្យល់ត្រជាក់ ខ្យល់ក្តៅ ខ្យល់តិច ខ្យល់ច្រើន ខ្យល់កើតតាមកាល ខ្យល់ព្យុះ ខ្យល់ស្លាបសត្វ ខ្យល់គ្រុឌ ខ្យល់ផ្ចិតស្លឹកត្នោត ខ្យល់កើតអំពីការបក់ ។ បណ្តាញធ្វើអំពីអំបោះ ហៅថាជាល ។ ខ្យល់មិនជាប់ បុគ្គលចាប់មិនបាន មិនទើសទាក់ មិនជាប់ជំពាក់ក្នុងជាល យ៉ាងណាមិញ ជាលមាន ២ យ៉ាង គឺជាល គឺតណ្ហា ១ ជាល គឺទិដ្ឋិ ១ ។បេ។ នេះជាល គឺតណ្ហា ។បេ។ នេះ ជាល គឺទិដ្ឋិ ព្រះបច្ចេកសម្ពុទ្ធនោះ លះចោលនូវ

ជាល គឺតណ្ហា លះបោលនូវជាល គឺទិដ្ឋិ ព្រោះតែលះបោលនូវជាល គឺតណ្ហា ព្រោះតែរលាស់ចោលនូវជាល គឺទិដ្ឋិ ព្រះបច្ចេកសម្ពុទ្ធនោះ ទើបមិនជាប់ក្នុងរូប មិនជាប់ក្នុងសំឡេង ។បេ។ មិនជាប់ មិនកាន់យក មិនទើសទាក់ មិនជាប់ជំពាក់ក្នុងធម្មារម្មណ៍ ដែលឃើញ ឮ ប៉ះពាល់ ឬដឹង គឺលោកឆាកចេញ ដោះចេញ រួចស្រឡះ មិនប្រកប មានចិត្តមិនសល់វល់ ក៏យ៉ាងនោះឯង ហេតុនោះ ( លោកពោលថា ) មិនជាប់ក្នុងជាលដូចខ្យល់ ។

[ ៣៧៤ ] ពាក្យថា មិនទទឹកដោយទឹកដូចឈូក អធិប្បាយថា ផ្កាឈូក ហៅថា ឈូក ។ ឧទក ហៅថា ទឹក ។ ផ្កាឈូកមិនជាប់ មិនប្រឡាក់ មិនជិតជាមដោយទឹក យ៉ាងណាមិញ គ្រឿងប្រឡាក់ពីរយ៉ាង គឺគ្រឿងប្រឡាក់ គឺតណ្ហា ១ គ្រឿងប្រឡាក់ គឺទិដ្ឋិ ១ ។បេ។ នេះ គ្រឿងប្រឡាក់ គឺតណ្ហា ។បេ។ នេះ គ្រឿងប្រឡាក់ គឺទិដ្ឋិ ព្រះបច្ចេកសម្ពុទ្ធនោះ លះបង់នូវគ្រឿងប្រឡាក់ គឺតណ្ហា រលាស់ចោលនូវគ្រឿងប្រឡាក់ គឺទិដ្ឋិ ព្រោះតែលះបង់នូវគ្រឿងប្រឡាក់ គឺតណ្ហា ព្រោះតែរលាស់ចោលនូវគ្រឿងប្រឡាក់ គឺទិដ្ឋិ ព្រះបច្ចេក-សម្ពុទ្ធនោះ ទើបមិនប្រឡាក់ក្នុងរូប មិនប្រឡាក់ក្នុងសំឡេង ។បេ។ មិនជាប់ មិនជាប់ស្អិត ក្នុងធម្មារម្មណ៍ដែលឃើញ ឮ ប៉ះពាល់ ឬដឹង គឺថា លោកមិនប្រឡាក់ មិនជិតជាម ឆាកចេញ ដោះចេញ រួចស្រឡះ មិនប្រកប មានចិត្តមិនសល់វល់ ក៏យ៉ាងនោះដែរ ហេតុនោះ ( លោកពោលថា ) មិនទទឹកដោយទឹកដូចឈូក ។ គប្បីប្រព្រឹត្តម្នាក់ឯង ដូចកុយរមាស ។ ហេតុនោះ ព្រះបច្ចេកសម្ពុទ្ធនោះពោលថា

បុគ្គលមិនតក់ស្លុត ព្រោះសំឡេងទាំងឡាយ ដូចសីហៈ មិនជាប់ក្នុងជាលដូចខ្យល់ មិនទទឹកដោយទឹកដូចឈូក គប្បីប្រព្រឹត្តម្នាក់ឯង ដូចកុយមាស ។

# អដ្ឋកថា

## គាថាទី ៧

គប្បីជ្រាបវិនិច្ឆ័យក្នុងគាថាទី ៧ ដូចតទៅ

[ ៣៧១ ] បទថា **សីហោ** បានដល់ សីហៈ ៤ ពួក គឺតិណសីហៈ ១ បណ្ឌុសីហៈ ១ កាឡសីហៈ ១ កេសរសីហៈ ១ ។ កេសរសីហៈ លោកពោលថា ប្រសើរជាងសីហៈទាំងនោះ ក្នុងទីនេះ លោកបំណងយក កេសរសីហៈនោះ ។

ខ្យល់មានច្រើនប្រភេទ មានខ្យល់ដែលបក់មកអំពីទិសខាងកើតជាដើម ផ្កាឈូកមានច្រើនប្រភេទ មានឈូកក្រហម និងឈូក-សជាដើម ។ បណ្ដា ខ្យល់ និងផ្កាឈូកទាំងនោះ ខ្យល់ប្រភេទណាមួយ ផ្កាឈូកប្រភេទណាមួយ គួរទាំងអស់ ។ ក្នុងសេចក្ដីនោះ ព្រោះការតក់ស្លុត រមែងមានដោយការ ស្រឡាញ់ខ្លួន ។ ម្យ៉ាងទៀត ការស្រឡាញ់ខ្លួន បូកលាបដោយតណ្ហា ។ ការស្រឡាញ់ខ្លួននោះ ក៏រមែងមានដោយសេចក្ដីលោភដែលសម្បយុត្តដោយ ទិដ្ឋិ ឬវិប្បយុត្តចាកទិដ្ឋិ ។ ការស្រឡាញ់ខ្លួននោះ គឺតណ្ហានោះឯង ។ ការ ជាប់ជំពាក់នៃអ្នកប្រាសចាកការពិចារណាក្នុងតណ្ហានោះ រមែងមានដោយ មោហៈ ម្យ៉ាងទៀត មោហៈ គឺអវិជ្ជានោះឯង ។ ក្នុងសេចក្ដីនោះ ការលះ តណ្ហា រមែងមានដោយសមថៈ ។ ការលះអវិជ្ជា រមែងមានដោយវិបស្សនា ព្រោះហេតុនោះ ព្រះបច្ចេកសម្ពុទ្ធលះសេចក្ដីស្រឡាញ់ក្នុងខ្លួន ដោយសមថៈ មិនតក់ស្លុតក្នុងការមិនទៀង និងភាពជាទុក្ខជាដើម ដូចសីហៈ មិនតក់ស្លុត ព្រោះសំឡេងទាំងឡាយ លះមោហៈ ដោយវិបស្សនា មិនជាប់ក្នុងខន្ធ និង

អាយតនៈជាដើម ដូចខ្យល់មិនជាប់ក្នុងសំណាញ់ លះលោភៈ និងទិដ្ឋិដែលសម្បយុត្តដោយលោភៈ ដោយសមថៈ មិនជាប់ដោយលោភៈ ដែលមានការត្រេកអរក្នុងភពទាំងពួង ដូចផ្កាឈូកមិនជាប់ដោយទឹក ដូច្នោះ ។ ដោយបទនេះ សីលជាបទដ្ឋាននៃសមថៈ សមថៈ គឺសមាធិ វិបស្សនា គឺបញ្ញា ដោយប្រការដូច្នេះ កាលធម៌ទាំង ២ នោះសម្រេច ខន្ធទាំង ៣ ក៏ឈ្មោះថាសម្រេចផងដែរ ។ ក្នុងខន្ធទាំងនោះ ភាពជាអ្នកក្លៀវក្លា រមែងសម្រេចដោយសីលក្ខន្ធ រមែងមិនតក់ស្លុត ព្រោះភាពជាអ្នកប្រាថ្នាមិនក្រោធក្នុងអាឃាតវត្ថុទាំងឡាយ ដូចសីហៈ មិនតក់ស្លុតក្នុងសំឡេងទាំងឡាយ ជាអ្នកមានសភាវៈចាក់ធ្លុះដោយបញ្ញាខន្ធ មិនជាប់ក្នុងប្រភេទនៃធម៌ មានខន្ធជាដើម ដូចខ្យល់មិនជាប់នៅក្នុងសំណាញ់ ។ ជាអ្នកប្រាសចាករាគៈ ដោយសមាធិក្ខន្ធ មិនជាប់ដោយរាគៈ ដូចផ្កាឈូកមិនជាប់ដោយទឹក ។ គប្បីជ្រាបថា ព្រះបច្ចេកសម្ពុទ្ធមិនតក់ស្លុត មិនជាប់ មិនជំពាក់ ដោយអំណាចការលះអវិជ្ជា តណ្ហា និងអកុសលមូល ៣ តាមដែលកើត ដោយសមថៈ និងវិបស្សនា និងដោយសីលក្ខន្ធ សមាធិក្ខន្ធ បញ្ញាខន្ធ ដោយប្រការដូច្នេះ ។ បទដ៏សេស មានន័យដូចពោលហើយនោះឯង ៕

**អដ្ឋកថា គាថាទី ៧ ចប់**

# សុត្តន្តបិដក

[ ៣៧៥ ] សីហៈ ជាស្តេចម្រឹគ មានចង្កូមជាកម្លាំង ប្រព្រឹត្ត គ្របសង្កត់ កំហែងនូវសត្វទាំងឡាយ យ៉ាងណា បុគ្គលសេព សេនាសនៈដ៏ស្ងាត់ ក៏យ៉ាងនោះ គប្បីប្រព្រឹត្តទៅម្នាក់ឯង ដូច កុយរមាស ។

[ ៣៧៦ ] ពាក្យថា សីហៈ ជាស្តេចម្រឹគ មានចង្កូមជាកម្លាំង ប្រព្រឹត្ត គ្របសង្កត់ កំហែងយ៉ាងណា អធិប្បាយថា សីហៈជាស្តេចម្រឹគ មានចង្កូម ជាកម្លាំង មានចង្កូមជាអាវុធ គំរាម កំហែង គ្របសង្កត់ កាច់កិន ញាំញីនូវ សត្វតិរច្ឆានទាំងពួង ចរ ត្រាច់ទៅ ប្រព្រឹត្ត រក្សា យាត្រា ឲ្យយាត្រាទៅ យ៉ាងណាមិញ ឯព្រះបច្ចេកសម្ពុទ្ធ មានបញ្ញាជាកម្លាំង មានបញ្ញាជាអាវុធ គំរាម កំហែង គ្របសង្កត់ កាច់កិន ញាំញីនូវសត្វទាំងពួង ដោយបញ្ញាហើយ ចរ ត្រាច់ទៅ ប្រព្រឹត្ត រក្សា យាត្រា ឲ្យយាត្រាទៅ ក៏យ៉ាងនោះដែរ ហេតុ នោះ ( លោកពោលថា ) សីហៈជាស្តេចម្រឹគ មានចង្កូមជាកម្លាំង ប្រព្រឹត្ត គ្របសង្កត់ កំហែង យ៉ាងណា ។

[ ៣៧៧ ] ពាក្យថា សេពនូវសេនាសនៈដ៏ស្ងាត់ អធិប្បាយថា សីហៈ ជាស្តេចម្រឹគ ចូលកាន់ព្រៃតូចព្រៃធំ ហើយចរ ត្រាច់ទៅ ប្រព្រឹត្ត រក្សា យាត្រា ឲ្យយាត្រាទៅ យ៉ាងណា ឯព្រះបច្ចេកសម្ពុទ្ធ ក៏សេពព្រៃតូច ព្រៃធំ ជាសេនាសនៈដ៏ស្ងាត់ មិនមានសំឡេង មិនមានសូរគឹកកង ប្រាសចាកខ្យល់ ដែលកើតអំពីសរីរៈរបស់ជន ជាទីស្ងាត់របស់មនុស្ស គួរដល់ការពួនសម្ងំ យ៉ាងនោះដែរ ។ ព្រះបច្ចេកសម្ពុទ្ធនោះ ដើរម្នាក់ឯង ឈរម្នាក់ឯង អង្គុយម្នាក់

ឯង សិងម្នាក់ឯង ចូលទៅកាន់ស្រុក ដើម្បីបិណ្ឌបាតម្នាក់ឯង ត្រឡប់មកវិញម្នាក់ឯង គង់នៅក្នុងទីស្ងាត់ម្នាក់ឯង អធិដ្ឋានចង្រ្កមម្នាក់ឯង ចរ ត្រាច់ទៅ ប្រព្រឹត្ត រក្សា យាត្រា ឲ្យយាត្រាទៅម្នាក់ឯង ហេតុនោះ ( លោកពោលថា ) សេពនូវសេនាសនៈដ៏ស្ងាត់ ។ គប្បីប្រព្រឹត្តម្នាក់ឯង ដូចកុយរមាស ។ ហេតុនោះ ព្រះបច្ចេកសម្ពុទ្ធនោះពោលថា

សីហៈជាស្តេចម្រឹគ មានចង្កូមជាកម្លាំង ប្រព្រឹត្តគ្របសង្កត់ កំហែងនូវសត្វទាំងឡាយ យ៉ាងណា បុគ្គលសេពសេនាសនៈដ៏ស្ងាត់ ក៏យ៉ាងនោះ គប្បីប្រព្រឹត្តម្នាក់ឯង ដូចកុយរមាស ។

# អដ្ឋកថា

## គាថាទី ៨

គប្បីជ្រាបវិនិច្ឆ័យក្នុងគាថាទី ៨ ដូចតទៅ

[ ៣៧៥ ] ឈ្មោះថា **សីហោ** ព្រោះអត់ធន់ ព្រោះសម្លាប់ និងព្រោះមានសម្ទុះរហ័ស ។ ក្នុងទីនេះ បំណងយកកេសរសីហៈ ។ ឈ្មោះថា **ទាឋពលី** ព្រោះសីហៈមានចង្កូមជាកម្លាំង ។ បទថា **បសយ្ហ អភិភុយ្យ** គប្បីប្រកប **ចារី** សព្ទចូលទៅ ជា **បសយ្ហចារី** ប្រែថា ត្របាច់សង្កត់សង្កិន **អភិភុយ្យចារី** ប្រែថា ត្របាច់គ្របសង្កត់ ។ ក្នុង ២ បទនោះ ឈ្មោះថា **បសយ្ហចារី** ព្រោះត្របាច់សង្កត់សង្កិន បៀតបៀន កំហែង ឈ្មោះថា **អភិភុយ្យចារី** ព្រោះត្របាច់គ្របសង្កត់ ធ្វើឲ្យតក់ស្លុត ធ្វើឲ្យនៅក្នុងអំណាច ។ សីហៈនោះ ត្របាច់សង្កត់សង្កិនដោយកម្លាំងកាយ ត្របាច់គ្របសង្កត់ដោយតេជះ ។ ក្នុងសេចក្ដីនោះ បើបុគ្គលណាម្នាក់គប្បីពោលថា ត្របាច់សង្កត់សង្កិន គ្របសង្កត់នូវអ្វី បន្ទាប់អំពីនោះ គប្បីធ្វើឆដ្ឋីវិភត្តិនៃបទថា **មិគានំ** ជាទុតិយាវិភត្តិ ហើយផ្លាស់ថា **មិគេ បសយ្ហ អភិភុយ្យចារី** ត្របាច់សង្កត់សង្កិនគ្របសង្កត់នូវម្រឹគទាំងឡាយ ។ បទថា **បន្តានិ** បានដល់ ឆ្ងាយ ។ បទថា **សេនាសនានិ** បានដល់ ដែលជាលំនៅ ។ បទដ៏សេស អាចដឹងបានដោយន័យដែលពោលហើយ ក្នុងកាលមុននោះឯង ព្រោះហេតុនោះ ទើបខ្ញុំមិនពោលឲ្យពិស្តារ ។៚

**អដ្ឋកថាគាថាទី ៨ ចប់**

# សុត្តន្តបិដក

[ ៣៧៨ ] បុគ្គលកាលសេពនូវវិមុត្តិ គឺមេត្តា ឧបេក្ខា ករុណា និងមុទិតាក្នុងកាលគួរ តែងត្រូវសត្វលោកទាំងពួងមិនស្អប់ គប្បីប្រព្រឹត្តម្នាក់ឯង ដូចកុយរមាស ។

[ ៣៧៩ ] ពាក្យថា កាលសេពនូវវិមុត្តិ គឺមេត្តា ឧបេក្ខា ករុណា និងមុទិតាក្នុងកាលគួរ អធិប្បាយថា ព្រះបច្ចេកសម្ពុទ្ធនោះ មានចិត្តប្រកបដោយមេត្តា ផ្សាយទៅកាន់ទិសទី ១ ទិសទី ២ ដូចគ្នា ទិសទី ៣ ដូចគ្នា ទិសទី ៤ ដូចគ្នា មានចិត្តប្រកបដោយមេត្តាដ៏ធំទូលាយ ប្រមាណមិនបាន មិនមានពៀរ មិនមានព្យាបាទ ផ្សាយទៅកាន់លោកទាំងមូល ក្នុងទិសខាងលើ ទិសខាងក្រោម និងទិសទទឹង ដោយការយកខ្លួន ទៅប្រៀបផ្ទឹមនឹងសត្វទាំងពួង ក្នុងទីទាំងពួង ដោយប្រការដូច្នេះ មានចិត្តប្រកបដោយករុណា មានចិត្តប្រកបដោយមុទិតា មានចិត្តប្រកបដោយឧបេក្ខា ផ្សាយទៅកាន់ទិសទី ១ ទិសទី ២ ដូចគ្នា ទិសទី ៣ ដូចគ្នា ទិសទី ៤ ដូចគ្នា មានចិត្តប្រកបដោយឧបេក្ខាដ៏ធំទូលាយ ប្រមាណមិនបាន មិនមានពៀរ មិនមានព្យាបាទ ផ្សាយទៅកាន់លោកទាំងមូល ក្នុងទិសខាងលើ ទិសខាងក្រោម និងទិសទទឹង ដោយការយកខ្លួន ទៅប្រៀបផ្ទឹមនឹងសត្វទាំងពួង ក្នុងទីទាំងពួង ដោយប្រការដូច្នេះ ហេតុនោះ ( លោកពោលថា ) កាលសេពនូវវិមុត្តិ គឺមេត្តា ឧបេក្ខា ករុណា និងមុទិតា ក្នុងកាលគួរ ។

[ ៣៨០ ] ពាក្យថា តែងត្រូវសត្វលោកទាំងពួងមិនស្អប់ អធិប្បាយថា ព្រោះព្រះបច្ចេកសម្ពុទ្ធនោះ ចម្រើនហើយនូវព្រហ្មវិហារ មានមេត្តាជាដើម ពួកសត្វណាក្នុងទិសខាងកើត ពួកសត្វទាំងនោះ រមែងមិនស្អប់ ពួកសត្វណា

ក្នុងទិសខាងលិច ពួកសត្វណា ក្នុងទិសខាងជើង ពួកសត្វណា ក្នុងទិសខាងត្បូង ពួកសត្វណា ក្នុងទិសអាគ្នេយ៍ ពួកសត្វណា ក្នុងទិសពាយ័ព្យ ពួកសត្វណា ក្នុងទិសឦសាន ពួកសត្វណា ក្នុងទិសនិរតី ពួកសត្វណា ក្នុងទិសខាងក្រោម ពួកសត្វណា ក្នុងទិសខាងលើ ពួកសត្វណា ក្នុងទិសតូចទិសធំទាំង ១០ ពួកសត្វទាំងនោះ រមែងមិនស្អប់ ។ ពាក្យថា តែងត្រូវសត្វលោកទាំងពួងមិនស្អប់ បានសេចក្តីថា សត្វលោកទាំងពួង មិនទោមនស្ស មិនអាក់អន់ មិនថ្នាំងថ្នាក់ មិនខ្ញាំងខ្ញប់ ហេតុនោះ ( លោកពោលថា ) តែងត្រូវសត្វលោកទាំងពួងមិនស្អប់ ។ គប្បីប្រព្រឹត្តម្នាក់ឯង ដូចកុយរមាស ។ ហេតុនោះ ព្រះបច្ចេកសម្ពុទ្ធនោះពោលថា

បុគ្គលកាលសេពនូវវិមុត្តិ គឺមេត្តា ឧបេក្ខា ករុណា និងមុទិតា
ក្នុងកាលគួរ តែងត្រូវសត្វលោកទាំងពួង មិនស្អប់ គប្បីប្រព្រឹត្ត
ម្នាក់ឯង ដូចកុយរមាស ។

# អដ្ឋកថា

## គាថាទី ៩

គប្បីជ្រាបវិនិច្ឆ័យក្នុងគាថាទី ៩ ដូចតទៅ

[ ៣៧៨ ] ភាពជាអ្នកប្រាថ្នានាំប្រយោជន៍ និងសេចក្តីសុខ ចូលទៅឲ្យ ដោយន័យជាដើមថា **សព្វេ សត្តា សុខិតា ភវន្តុ** សូមសត្វទាំងពួង ជាអ្នកមានសេចក្តីសុខចុះ ដូច្នេះ ឈ្មោះថា **មេត្តា** ។

ភាពជាអ្នកប្រាថ្នាដើម្បីដោះនូវវត្ថុមិនជាប្រយោជន៍ និងសេចក្តីទុក្ខចេញទៅ ដោយន័យជាដើមថា **អហោ វត ឥមម្ហា ទុក្ខា វិមុច្ចេយ្យុំ** ឱហ្ន៎ ! សត្វទាំងពួង គប្បីផុតចាកទុក្ខ ដូច្នេះ ឈ្មោះថា **ករុណា** ។

ភាពជាអ្នកប្រាថ្នាដើម្បីមិនឲ្យសត្វប្រាសចាកប្រយោជន៍ និងសេចក្តីសុខ ដោយន័យជាដើមថា **មោទន្តិ វត ភោន្តោ សត្តា មោទន្តិ សាធុ សុដ្ឋុ** លោកដ៏ចម្រើន សត្វទាំងពួង រមែងត្រេកអរហ្ន៎ សាធុ សូមសត្វទាំងពួងត្រេកអរដោយល្អចុះ ឈ្មោះថា **មុទិតា** ។

ភាពជាអ្នកចូលទៅសម្លឹងព្រងើយៗ ក្នុងសុខ និងទុក្ខថា **បញ្ញាយិស្សន្តិ សកេន កម្មេន** សត្វទាំងឡាយនឹងប្រាកដ ដោយកម្មរបស់ខ្លួន ដូច្នេះ ឈ្មោះថា **ឧបេក្ខា** ។

លោកពោលមេត្តា ហើយពោលឧបេក្ខា មុទិតា ក្នុងកាលខាងក្រោយ បញ្ច្រាស់លំដាប់គ្នា ដើម្បីងាយស្រួលក្នុងការចងគាថា ។ បទថា **វិមុត្តឹ** សេចក្តីពិត មេត្តា ករុណា មុទិតា ឧបេក្ខា ធម៌ទាំង ៤ នេះ ឈ្មោះថា

**វិមុត្តិ** ព្រោះផុតចាកធម៌ជាសត្រូវរបស់ខ្លួន ។ ដោយហេតុនោះ ទើបលោកពោលថា

បុគ្គលកាលសេពនូវវិមុត្តិ គឺមេត្តា ឧបេក្ខា ករុណា និងមុទិតា ក្នុងកាលគួរ ដូច្នេះ ។

ក្នុងបទទាំងនោះ បទថា **អាសេវមានោ** បានដល់ ចម្រើនមេត្តា ករុណា មុទិតា ៣ យ៉ាង ដោយអំណាចនៃឈាន ៣ ក្នុងចតុក្កន័យ និងឈាន ៤ ក្នុងបញ្ចកន័យ ចម្រើនឧបេក្ខាដោយអំណាចនៃចតុត្ថជ្ឈាន ។ បទថា **កាលេ** សេចក្តីថា សេពមេត្តា ចេញចាកមេត្តាហើយ សេពករុណា ចេញចាកករុណាហើយ សេពមុទិតា ចេញអំពីមុទិតា ឬចេញអំពីឈានដែលមិនមានបីតិហើយ សេពឧបេក្ខា ហៅថា សេពក្នុងកាលដែលគួរ ឬសេពក្នុងវេលាសប្បាយ ។ បទថា **សព្វេន លោកេន អវិរុជ្ឈមានោ** បានដល់ ដែលសត្វលោកទាំងអស់ ក្នុងទិសទាំង ១០ មិនស្អប់ខ្ពើម ។ ពិតហើយ សត្វទាំងឡាយ ឈ្មោះថា ជាអ្នកមិនគួរស្អប់ ព្រោះជាអ្នកចម្រើនមេត្តាជាដើម ។ ការអាក់អន់ ដែលជាការពិរោធក្នុងសត្វទាំងឡាយ រមែងស្ងប់ ។ ដោយហេតុនោះ ទើបព្រះបច្ចេកសម្ពុទ្ធពោលថា តែងត្រូវសត្វលោកទាំងពួងមិនស្អប់ ដូច្នេះ ។ បទដ៏សេស ដូចគ្នាតាមដែលពោលហើយនោះឯង ។l ៚

**អដ្ឋកថា គាថាទី ៩ ចប់**

# សុត្តន្តបិដក

[ ៣៨១ ] បុគ្គលលះរាគៈ ទោសៈ និងមោហៈ ទម្លាយនូវសញ្ញោជនៈទាំងឡាយ មិនតក់ស្លុតក្នុងការអស់ជីវិត គប្បីប្រព្រឹត្តម្នាក់ឯង ដូចកុយរមាស ។

[ ៣៨២ ] អធិប្បាយពាក្យថា លះរាគៈ ទោសៈ និងមោហៈ ត្រង់ពាក្យថា រាគៈ បានដល់ ការត្រេកអរ ការត្រេកអរខ្លាំង ។បេ។ អភិជ្ឈាលោភៈ អកុសលមូល ។ ពាក្យថា ទោសៈ បានដល់ ការគុំគួននៃចិត្ត ។បេ។ ចិត្តកាច ការពោលពាក្យមិនពីរោះ ភាពនៃចិត្តមិនត្រេកអរ ។ ពាក្យថា មោហៈ បានដល់ ការមិនដឹងក្នុងទុក្ខ ។បេ។ សន្ទុះ គឺអវិជ្ជា មោហៈ អកុសលមូល ។ ពាក្យថា លះរាគៈ ទោសៈ និងមោហៈ បានសេចក្តីថា ព្រះបច្ចេកសម្ពុទ្ធនោះ លះ លះបង់ បន្ទោបង់ ធ្វើឲ្យវិនាស ឲ្យដល់នូវការមិនកើតមាននូវរាគៈ ទោសៈ និងមោហៈ ហេតុនោះ ( លោកពោលថា ) លះរាគៈ ទោសៈ និងមោហៈ ។

[ ៣៨៣ ] ពាក្យថា ទម្លាយនូវសញ្ញោជនៈទាំងឡាយ អធិប្បាយថា សញ្ញោជនៈ ១០ យ៉ាង គឺកាមរាគសញ្ញោជនៈ ១ បដិឃសញ្ញោជនៈ ១ ។បេ។ អវិជ្ជាសញ្ញោជនៈ ១ ។ ពាក្យថា ទម្លាយនូវសញ្ញោជនៈទាំងឡាយ បានសេចក្តីថា ទម្លុះទម្លាយ បំបែក បំផ្លាញ លះបង់ បន្ទោបង់ ធ្វើឲ្យវិនាស ឲ្យដល់នូវការមិនកើតមាន នូវសញ្ញោជនៈទាំងឡាយ ហេតុនោះ ( លោកពោលថា ) ទម្លាយនូវសញ្ញោជនៈទាំងឡាយ ។

[ ៣៨៤ ] ពាក្យថា មិនតក់ស្លុតក្នុងការអស់ជីវិត គឺព្រះបច្ចេកសម្ពុទ្ធនោះ មិនតក់ស្លុត មិនរន្ធត់ មិនញាប់ញ័រ មិនភ្ញាក់ផ្អើល មិនព្រឺព្រួច មិនរំភើប មិនខ្លាច មិនភិតភ័យ មិនស្ញប់ស្ញែង មិនរត់ លះភ័យគួរខ្លាច មិនព្រឺរោមក្នុងការអស់ជីវិត ហេតុនោះ ( លោកពោលថា ) មិនតក់ស្លុតក្នុងការអស់ជីវិត ។ គប្បីប្រព្រឹត្តម្នាក់ឯង ដូចកុយរមាស ។ ហេតុនោះ ព្រះបច្ចេកសម្ពុទ្ធនោះពោលថា

បុគ្គលលះរាគៈ ទោសៈ និងមោហៈ ទម្លាយនូវសញ្ញោជនៈទាំងឡាយ មិនតក់ស្លុតក្នុងការអស់ជីវិត គប្បីប្រព្រឹត្តម្នាក់ឯង ដូចកុយរមាស ។

# អដ្ឋកថា

## គាថាទី ១០

គប្បីជ្រាបវិនិច្ឆ័យក្នុងគាថាទី ១០ ដូចតទៅ

[ ៣៨១ ] បទថា **សញ្ញោជនានិ** បានដល់ សំយោជនៈ ១០ ព្រះបច្ចេកសម្ពុទ្ធទម្លាយសំយោជនៈ ១០ ដោយមគ្គនោះៗ ។ បទថា **អសន្តសំ ជីវិតសង្ខយម្ហិ** សេចក្តីថា ការរលត់នៃចុតិចិត្ត ហៅថា ការអស់ជីវិត ។ ព្រះបច្ចេកសម្ពុទ្ធ ឈ្មោះថា មិនតក់ស្លុតក្នុងការអស់ជីវិតនោះ ព្រោះលះនូវការជាប់ជំពាក់ក្នុងជីវិតបានហើយ ។ ព្រះបច្ចេកសម្ពុទ្ធ កាលសម្តែងសឧបាទិសេសនិព្វានធាតុរបស់ខ្លួនដោយគាថា មានប្រមាណប៉ុណ្ណេះហើយ កាលបញ្ចប់គាថា បានបរិនិព្វានហើយ ដោយអនុបាទិសេសនិព្វានធាតុ ដោយប្រការដូច្នេះ ។ល។

**អដ្ឋកថា គាថាទី ១០ ចប់**

# សុត្តន្តបិដក

[ ៣៨៥ ] ជនទាំងឡាយ អ្នកមានការណ៍ជាប្រយោជន៍ ទើបគប់រក ទើបសេពគប់ ឯមិត្តថ្មីទាំងឡាយដែលឥតត្រូវការណ៍ គេពុំងាយនឹងរកបានទេ ចំណែកមនុស្សទាំងឡាយដែលមិនស្អាត ជាអ្នកយល់ប្រយោជន៍របស់ខ្លួន ( ក៏តែងគប់រក តែងសេពគប់ដែរ ) បុគ្គលគប្បីប្រព្រឹត្តម្នាក់ឯង ដូចកុយរមាស ។

[ ៣៨៦ ] ពាក្យថា ជនទាំងឡាយ អ្នកមានការណ៍ជាប្រយោជន៍ ទើបគប់រក ទើបសេពគប់ សេចក្តីថា ពួកជនមានប្រយោជន៍ខ្លួនជាហេតុ មានប្រ-យោជន៍អ្នកដទៃជាហេតុ មានប្រយោជន៍ទាំងពីរជាហេតុ មានប្រយោជន៍ក្នុងបច្ចុប្បន្នជាហេតុ មានប្រយោជន៍ក្នុងបរលោកជាហេតុ មានប្រយោជន៍ក្នុងព្រះនិព្វានជាហេតុ ទើបគប់រក សមគប់ សេពគប់ រាប់រក ហេតុនោះ ( លោកពោលថា ) ជនទាំងឡាយ អ្នកមានការជាប្រយោជន៍ ទើបគប់រក ទើបសេពគប់ ។

[ ៣៨៧ ] ពាក្យថា មិត្តថ្មីទាំងឡាយដែលឥតត្រូវការណ៍ គេពុំងាយនឹងរកបានទេ អធិប្បាយថា មិត្តមាន ២ ពួក គឺអាគារិកមិត្ត ១ អនាគារិកមិត្ត ១ ។បេ។ នេះ អាគារិកមិត្ត ។បេ។ នេះ អនាគារិកមិត្ត ។ ពាក្យថា មិត្តថ្មីទាំងឡាយដែលឥតត្រូវការណ៍ គេពុំងាយនឹងរកបានទេ បានសេចក្តីថា មិត្តទាំងពីរប្រភេទនេះ ដែលមិនមានការណ៍ មិនមានហេតុ មិនមានបច្ច័យ គេរកបានដោយក្រ ហេតុនោះ ( លោកពោលថា ) មិត្តថ្មីទាំងឡាយ ដែលឥតត្រូវការណ៍ គេពុំងាយនឹងរកបានទេ ។

[ ៣៨៨ ] អធិប្បាយពាក្យថា មនុស្សទាំងឡាយដែលមិនស្អាត ជាអ្នកយល់ប្រយោជន៍របស់ខ្លួន ត្រង់ពាក្យថា ជាអ្នកយល់ប្រយោជន៍របស់ខ្លួន គឺពួកមនុស្សមិនស្អាត តែងគប់រក សមគប់ សេពគប់ រាប់រក អែបនែប អែបជិត ចូលទៅរក ចូលទៅអង្គុយជិត សាកសួរ ដោះសា ព្រោះតែប្រយោជន៍របស់ខ្លួន ព្រោះតែហេតុរបស់ខ្លួន ព្រោះតែបច្ច័យរបស់ខ្លួន ព្រោះតែការណ៍របស់ខ្លួន ហេតុនោះ ( លោកពោលថា ) ជាអ្នកយល់ប្រយោជន៍របស់ខ្លួន ។ ពាក្យថា មនុស្សមិនស្អាត សេចក្តីថា ពួកមនុស្សប្រកបដោយកាយកម្មមិនស្អាត ឈ្មោះថា មនុស្សមិនស្អាត ។ ពួកមនុស្សប្រកបដោយវចីកម្មមិនស្អាត ឈ្មោះថា មនុស្សមិនស្អាត ។ ពួកមនុស្សប្រកបដោយមនោកម្មមិនស្អាត ឈ្មោះថា មនុស្សមិនស្អាត ។ ពួកមនុស្សប្រកបដោយការមិនស្អាត គឺបាណាតិបាត ដោយការមិនស្អាត គឺអទិន្នាទាន ដោយការមិនស្អាត គឺកាមេសុមិច្ឆាចារ ដោយការមិនស្អាត គឺមុសាវាទ ដោយការមិនស្អាត គឺបិសុណវាចា ដោយការមិនស្អាត គឺផរុសវាចា ដោយការមិនស្អាត គឺសម្ផប្បលាបៈ ដោយការមិនស្អាត គឺអភិជ្ឈា ដោយការមិនស្អាត គឺព្យាបាទ ដោយការមិនស្អាត គឺមិច្ឆាទិដ្ឋិ ឈ្មោះថា មនុស្សមិនស្អាត ។ ពួកមនុស្សប្រកបដោយចេតនាមិនស្អាត ឈ្មោះថា មនុស្សមិនស្អាត ។ ពួកមនុស្សប្រកបដោយសេចក្តីប្រាថ្នាមិនស្អាត ឈ្មោះថា មនុស្សមិនស្អាត ។ ពួកមនុស្សប្រកបដោយការតាំងសេចក្តីប៉ុនប៉ងមិនស្អាត ឈ្មោះថា មនុស្សមិនស្អាត ថោកទាប ថោកថយ ទន់ទាប អាក្រក់ លាមក គម្រក់ មនុស្សកម្សត់កម្សួ ហេតុនោះ

( លោកពោលថា ) មនុស្សទាំងឡាយ ដែលមិនស្អាត ជាអ្នកយល់ប្រយោជន៍របស់ខ្លួន ។

[ ៣៨៩ ] អធិប្បាយពាក្យថា គប្បីប្រព្រឹត្តម្នាក់ឯង ដូចកុយរមាស ត្រង់ពាក្យថា ម្នាក់ឯង ។បេ។ ពាក្យថា គប្បីប្រព្រឹត្ត បានដល់ ចរិយា ៨ យ៉ាង ។បេ។ ហេតុនោះ ( លោកពោលថា ) គប្បីប្រព្រឹត្តម្នាក់ឯង ដូចកុយរមាស ។ ហេតុនោះ ព្រះបច្ចេកសម្ពុទ្ធនោះពោលថា

ជនទាំងឡាយ អ្នកមានការណ៍ជាប្រយោជន៍ ទើបគប់រក ទើបសេពគប់ ឯមិត្តថ្មីទាំងឡាយ ដែលឥតត្រូវការណ៍ គេពុំងាយនឹងរកបានទេ ចំណែកមនុស្សទាំងឡាយដែលមិនស្អាត ជាអ្នកយល់ប្រយោជន៍របស់ខ្លួន ( ក៏តែងគប់រក តែងសេពគប់ដែរ ) បុគ្គលគប្បីប្រព្រឹត្តម្នាក់ឯង ដូចកុយរមាស ។

**ខគ្គវិសាណសុត្តនិទ្ទេស ចប់**

និទ្ទេស គឺការសម្តែងចេញ នូវពាក្យប្រៀនប្រដៅរបស់ព្រាហ្មណ៍ ជាអ្នកដល់នូវត្រៃយទាំង ១៦ នាក់នុ៎ះ គឺអជិតៈ ១ តិស្សមេត្តេយ្យ ១ បុណ្ណកៈ ១ មេត្តគូ ១ ធោតកៈ ១ ឧបសីវៈ ១ នន្ទៈ ១ ហេមកៈ ១ តោទេយ្យៈ ១ កប្បៈ ១ ជតុកណ្ណីបណ្ឌិត ១ ភទ្រាវុធ ១ ឧទយៈ ១ បោសាលព្រាហ្មណ៍ ១ មោឃរាជមេធាវី ១ បិង្គិយមហាឥសី ១ ផង និទ្ទេស គឺការសម្តែងចេញ នូវខគ្គវិសាណសូត្រទាំងឡាយ ក្នុងទីនោះផង និទ្ទេសទាំងពីរមានប្រមាណប៉ុណ្ណោះ បណ្ឌិតគប្បីដឹងថា ជានិទ្ទេសដែលបរិបូណ៌ លោកចារឹកត្រឹមត្រូវហើយ ។

**សុត្តនិទ្ទេស ចប់**

# អដ្ឋកថា

## គាថាទី ១១

គប្បីជ្រាបវិនិច្ឆ័យក្នុងគាថាទី ១១ ដូចតទៅ

[ ៣៨៥ ] បទថា **ភជន្តិ** បានដល់ ចូលទៅអង្គុយជិតគ្នា ។ បទថា **សេវន្តិ** បានដល់ រមែងបម្រើ ដោយអញ្ជលីកម្មជាដើម និងដោយព្រម ទទួលធ្វើការងារឲ្យ ។ ឈ្មោះថា **ការណត្ថា** ព្រោះមានប្រយោជន៍ជាហេតុ អធិប្បាយថា មិនមានហេតុដទៃ ដើម្បីគប់រក និងដើម្បីសេព ។ លោកពោល ថា រមែងសេព ព្រោះមានទូវប្រយោជន៍ជាហេតុ ។ បទថា **និក្ការណា ទុល្លភា អជ្ជ មិត្តា** សេចក្តីថា មិត្រក្នុងថ្ងៃនេះ មិនមានហេតុ ព្រោះហេតុនៃ ការបានទូវប្រយោជន៍យ៉ាងនេះថា អាត្មាអញនឹងបានអ្វីចាកមិត្រនេះ ប្រកប ដោយភាពជាមិត្រដ៏ប្រសើរ ដែលព្រះមានព្រះភាគត្រាស់យ៉ាងនេះថា

មិត្តដែលមានឧបការៈ សម្លាញ់ដែលរួមសុខទុក្ខ មិត្តដែលប្រាប់ប្រយោជន៍ មិត្តដែលមានសេចក្តីឈឺឆ្អាល ដូច្នេះ ។ សូម្បីតែមួយ រកបាន លំបាក ។ ឈ្មោះថា **អត្តដ្ឋបញ្ញា** ព្រោះមានបញ្ញាដែលសម្រេចប្រយោជន៍ ដោយប្រាថ្នាចំពោះខ្លួនប៉ុណ្ណោះ មិនប្រាថ្នាដល់អ្នកដទៃ គឺឃើញតែខ្លួន ។ ក្នុង គម្ពីរបុរាណរចនាថា **ទិដ្ឋត្ថបញ្ញា** គឺមានបញ្ញាប្រាថ្នាទូវប្រយោជន៍បច្ចុប្បន្ន ។ មានពាក្យអធិប្បាយថា មានបញ្ញាសម្លឹងដល់ប្រយោជន៍ ដែលខ្លួនឃើញនោះ ឯង ។ បទថា **អសុចី** បានដល់ ប្រកបដោយកាយកម្ម វចីកម្ម និង មនោកម្មដែលមិនស្អាត គឺមិនប្រសើរ ។ បទដ៏សេស គប្បីជ្រាបដោយន័យ ដែលពោលហើយខាងដើមនោះឯង ។ បទណា មិនទាន់បានពោល ព្រោះនាំ

ឲ្យពិស្តារពេក ក្នុងបទនោះៗ បទទាំងនោះ គប្បីជ្រាបតាមទំនងនៃបាឋៈ គឺបាលីនោះៗ ឯង ៗ។

## អដ្ឋកថា គាថាទី ១១ ចប់

## ចតុត្ថវគ្គ ចប់

## អដ្ឋកថា ខគ្គវិសាណសុត្តនិទ្ទេស
## នៃ
## អដ្ឋកថា ខុទ្ទកនិកាយ ចូឡនិទ្ទេសឈ្មោះថា
## សទ្ធម្មប្បជ្ជោតិកា
## ចប់

# និគមគាថា

គម្ពីរមហានិទ្ទេសណា ដែលព្រះថេរៈជាបុត្រច្បងរបស់ព្រះសុគត ជាអ្នកត្រេកអរក្រៃលែង ក្នុងវត្ថុដែលជាប្រយោជន៍ ជាអ្នកមានគុណមិនញាប់ញ័របាន បានចែកល្អហើយ អដ្ឋកថាណា នៃគម្ពីរមហានិទ្ទេសនោះ ដែលខ្ញុំអាស្រ័យន័យ របស់អដ្ឋកថាបុរាណប្រារព្ធហើយ តាមសមត្ថភាព អដ្ឋកថានោះ ចូលដល់ការសម្រេចហើយ ។

មហាវិហារណា តាំងនៅទិសខាងត្បូង នៃក្រុងអនុរាធបុរីដ៏ប្រសើរ មហាស្តូបណា ដែលជាកំពូលនៃមហាវិហារនោះ សាងដោយថ្មដ៏វិចិត្រ ប្រដាប់ដោយកែវផលិក តាំងនៅទិសខាងលិចនៃក្រុងអនុរាធបុរីនោះ ។

ព្រះរាជាព្រះនាម **កិត្តិសេន** ជាអ្នករចនា ទ្រង់មានព្រះចរិយាវត្តដ៏ល្អ សម្បូរដោយការប្រព្រឹត្តស្អាត ទ្រង់ប្រកបក្នុងកុសលធម៌ ទ្រង់សាងបរិវេណ មានដើមឈើម្ចប់ត្រឈឹងត្រឈៃ ដល់ព្រមដោយទឹក លម្អដោយរបង ធ្វើអំពីឈើ ។

ព្រះមហាថេរៈ ឈ្មោះឧបសេន នៅក្នុងបរិវេណដ៏ធំទូលាយ ជាអ្នករចនា ប្រកបដោយកុសលកម្ម ព្រះបាទកិត្តិសេន ទ្រង់ប្រគេនបរិវេណ ដល់ព្រះឧបសេនមហាថេរៈនោះ ព្រះឧបសេនត្ថេរ ជាអ្នកមានសីលខ្ជាប់ខ្ជួន ជាគ្រូនៅត្រង់បរិវេណានោះ បានសមោធានគម្ពីរសទ្ធម្មប្បជ្ជោតិកានេះ ។

អដ្ឋកថានិទ្ទេសសម្រេចក្នុងឆ្នាំទី ២៦ នៃព្រះបាទសិរិសង្ឃពោធិ ដែលប្រថាប់នៅក្នុងនិវេសន៍ដែលជាសិរី អដ្ឋកថានេះ សម្តែងថេរវាទរបស់ព្រះថេរៈទាំងឡាយ អនុលោមតាមយុគសម័យ ញុំាងឲ្យកើតប្រយោជន៍ដល់សត្វលោក ចប់ហើយ យ៉ាងណា សូមមនោរថរបស់សត្វទាំងពួង ដែលអនុលោមតាមព្រះសទ្ធម្ម សូមញុំាងប្រយោជន៍របស់ខ្លួន និងប្រយោជន៍អ្នកដទៃឲ្យសម្រេច ដល់នូវសេចក្តីសម្រេច ដូច្នោះ ។

កាណវារទាំងឡាយជាង ៤០ កាណវារ ប្រកបដោយធម៌ដែល គួរដឹង ក្នុងអដ្ឋកថាសទ្ធម្មប្បជ្ជោតិកា ដែលលោកកំណត់ហើយ ដោយកុសលធម៌ ដែលលោកកំណត់ក្នុងអដ្ឋកថានេះ ។ ឆន្ទទាំងឡាយ នៃអដ្ឋកថានោះ លោកកំណត់ ដោយការចងគាថា ច្រើនជាងម៉ឺនគាថា គប្បីជ្រាបថា ជាគាថាបុណ្យនេះ មិនមែនតិចទូលំទូលាយ ដែលខ្ញុំអ្នករចនានូវអដ្ឋកថានេះ ដោយសេចក្តីអើពើ ដើម្បីការតាំងមាំនៃព្រះសាសនា និងដើម្បីអនុគ្រោះដល់សត្វលោក បានជួបនូវបុណ្យនោះហើយ សូមសត្វលោក បានភ្លក្សនូវរសនៃព្រះសទ្ធម្មរបស់ព្រះទសពល សូមសម្រេចសេចក្តីសុខ ដែលមិនមានមន្ទិល ដោយងាយហោង ។៚

**អដ្ឋកថា ចូឡនិទ្ទេស**

**ឈ្មោះ សទ្ធម្មប្បជ្ជោតិកា ចប់**

# ក្បាលទី ៥៥

# សុត្តន្តបិដក ចាលីប្រែ -៦៧

## សន្ទឹកចង្អុលប្រាប់មាតិកា

មាតិកា លេខទំព័រ

### ចាវាយនវគ្គ


វត្ថុគាថា ...... ...... ...... ...... ២

អជិតមាណវកប្បញ្ហានិទ្ទេស .. .... ...... ...... ...... ១១

អដ្ឋកថាអជិតមាណវកប្បបញ្ហានិទ្ទេស ...... ...... ...... ...... ៤៤

តិស្សមេត្តេយ្យមាណវកប្បញ្ហានិទ្ទេស ...... ...... ...... ...... ៦០

អដ្ឋកថាតិស្សមេត្តេយ្យមាណវកប្បបញ្ហានិទ្ទេស ...... ...... ...... ...... ៧២

បុណ្ណកមាណវកប្បញ្ហានិទ្ទេស ...... ...... ...... ...... ៧៥

អដ្ឋកថាបុណ្ណកមាណវកប្បបញ្ហានិទ្ទេស ...... ...... ...... ...... ១០៩

មេត្តគូមាណវកប្បញ្ហានិទ្ទេស ...... ...... ...... ...... ១២៤

អដ្ឋកថាមេត្តគូមាណវកប្បបញ្ហានិទ្ទេស ...... ...... ...... ...... ១៨០

ធោតកមាណវកប្បញ្ហានិទ្ទេស ...... ...... ...... ...... ១៩៨

អដ្ឋកថាធោតកមាណវកប្បបញ្ហានិទ្ទេស ...... ...... ...... ...... ២២៣

ឧបសីវមាណវកប្បញ្ហានិទ្ទេស ...... ...... ...... ...... ២២៧

អដ្ឋកថាឧបសីវមាណវកប្បបញ្ហានិទ្ទេស ...... ...... ...... ...... ២៤៩

នន្ទមាណវកប្បញ្ហានិទ្ទេស ...... ...... ...... ...... ២៥៦

អដ្ឋកថានន្ទមាណវកប្បបញ្ហានិទ្ទេស ...... ...... ...... ...... ២៨៣

ហេមកមាណវកប្បញ្ហានិទ្ទេស ...... ...... ...... ...... ២៨៦

អដ្ឋកថាហេមកមាណវកប្បបញ្ហានិទ្ទេស ...... ...... ...... ...... ២៩៨

តោទេយ្យមាណវកប្បញ្ហានិទ្ទេស ...... ...... ...... ...... ៣០០
អដ្ឋកថាតោទេយ្យមាណវកប្បបញ្ហានិទ្ទេស ...... ...... ...... ...... ៣០៩
កប្បមាណវកប្បញ្ហានិទ្ទេស ...... ...... ...... ...... ៣១១
អដ្ឋកថាកប្បមាណវកប្បបញ្ហានិទ្ទេស ...... ...... ...... ...... ៣២៥
ជតុកណ្ណីមាណវកប្បញ្ហានិទ្ទេស ...... ...... ...... ...... ៣២៩
អដ្ឋកថាជតុកណ្ណីមាណវកប្បបញ្ហានិទ្ទេស ...... ...... ...... ...... ៣៤៤
ភទ្រាវុធមាណវកប្បញ្ហានិទ្ទេស ...... ...... ...... ...... ៣៥៩
អដ្ឋកថាភទ្រាវុធមាណវកប្បបញ្ហានិទ្ទេស ...... ...... ...... ...... ៣៧២

## ចាលីប្រែ -៦៨

ឧទយមាណវកប្បញ្ហានិទ្ទេស ...... ...... ...... ...... ៣៧៥
អដ្ឋកថាឧទយមាណវកប្បបញ្ហានិទ្ទេស ...... ...... ...... ...... ៣៩៤
បោសាលមាណវកប្បញ្ហានិទ្ទេស ...... ...... ...... ...... ៤០១
អដ្ឋកថាបោសាលមាណវកប្បបញ្ហានិទ្ទេស ...... ...... ...... ...... ៤២០
មោឃរាជមាណវកប្បញ្ហានិទ្ទេស ...... ...... ...... ...... ៤៥៨
អដ្ឋកថាមោឃរាជមាណវកប្បបញ្ហានិទ្ទេស ...... ...... ...... ...... ៤៨៩
បិង្គិយមាណវកប្បញ្ហានិទ្ទេស ...... ...... ...... ...... ៥០៩
អដ្ឋកថាបិង្គិយមាណវកប្បបញ្ហានិទ្ទេស ...... ...... ...... ...... ៥២២
សោឡសមាណវកប្បញ្ហានិគមនិទ្ទេស ...... ...... ...... ...... ៥២៧
អដ្ឋកថាបារាយនត្ថុតិគាថានិទ្ទេស ...... ...... ...... ...... ៥៩៨
អដ្ឋកថាបារាយនានុគីតិគាថានិទ្ទេស ...... ...... ...... ...... ៦០១

## ខគ្គវិសាណសុត្តនិទ្ទេស

សុត្តន្តបិដក គាថាទី ១ ...... ...... ...... ...... ៦២១

## បឋមវគ្គ

អដ្ឋកថា គាថាទី ១ ...... ...... ...... ...... ៦៣២

អត្ថរបស់ភូតសព្ទ ...... ...... ...... ...... ៦៣២

អត្ថរបស់កប្បសព្ទ ...... ...... ...... ...... ៦៣៦

សុត្តន្តបិដក គាថាទី ២ ...... ...... ...... ...... ៦៦៤

អដ្ឋកថា គាថាទី ២ ...... ...... ...... ...... ៦៧៣

សុត្តន្តបិដក គាថាទី ៣ ...... ...... ...... ...... ៦៧៨

អដ្ឋកថា គាថាទី ៣ ...... ...... ...... ...... ៦៨២

សុត្តន្តបិដក គាថាទី ៤ ...... ...... ...... ...... ៦៨៦

អដ្ឋកថា គាថាទី ៤ ...... ...... ...... ...... ៦៩០

សុត្តន្តបិដក គាថាទី ៥ ...... ...... ...... ...... ៦៩២

អដ្ឋកថា គាថាទី ៥ ...... ...... ...... ...... ៦៩៦

សុត្តន្តបិដក គាថាទី ៦ ...... ...... ...... ...... ៦៩៨

អដ្ឋកថា គាថាទី ៦ ...... ...... ...... ...... ៧០០

សុត្តន្តបិដក គាថាទី ៧ ...... ...... ...... ...... ៧០១

អដ្ឋកថា គាថាទី ៧ ...... ...... ...... ...... ៧០៤

សុត្តន្តបិដក គាថាទី ៨ ...... ...... ...... ...... ៧០៥

អដ្ឋកថា គាថាទី ៨ ...... ...... ...... ...... ៧១៦

សុត្តន្តបិដក គាថាទី ៩ ...... ...... ...... ...... ៧៣៧

អដ្ឋកថា គាថាទី ៩ ...... ...... ...... ...... ៧៣៩

សុត្តន្តបិដក គាថាទី ១០ ...... ...... ...... ...... ៧៤០

អដ្ឋកថា គាថាទី ១០ ...... ...... ...... ...... ៧៤៣

## ទុតិយវគ្គ

សុត្តន្តបិដក គាថាទី ១ និងទី ២ ...... ...... ...... ...... ៧៤៥
អដ្ឋកថា គាថាទី ១ និងទី ២ ...... ...... ...... ...... ៧៥០
សុត្តន្តបិដក គាថាទី ៣ ...... ...... ...... ...... ៧៥២
អដ្ឋកថា គាថាទី ៣ ...... ...... ...... ...... ៧៥៦
សុត្តន្តបិដក គាថាទី ៤ ...... ...... ...... ...... ៧៥៨
អដ្ឋកថា គាថាទី ៤ ...... ...... ...... ...... ៧៦០
សុត្តន្តបិដក គាថាទី ៥ ...... ...... ...... ...... ៧៦១
អដ្ឋកថា គាថាទី ៥ ...... ...... ...... ...... ៧៦៤
សុត្តន្តបិដក គាថាទី ៦ ...... ...... ...... ...... ៧៦៥
អដ្ឋកថា គាថាទី ៦ ...... ...... ...... ...... ៧៧២
សុត្តន្តបិដក គាថាទី ៧ ...... ...... ...... ...... ៧៧៩
អដ្ឋកថា គាថាទី ៧ ...... ...... ...... ...... ៧៨១
សុត្តន្តបិដក គាថាទី ៨ ...... ...... ...... ...... ៧៨៣
អដ្ឋកថា គាថាទី ៨ ...... ...... ...... ...... ៧៨៥
សុត្តន្តបិដក គាថាទី ៩ ...... ...... ...... ...... ៧៨៦
អដ្ឋកថា គាថាទី ៩ ...... ...... ...... ...... ៧៩០
សុត្តន្តបិដក គាថាទី ១០ ...... ...... ...... ...... ៧៩២
អដ្ឋកថា គាថាទី ១០ ...... ...... ...... ...... ៧៩៥

## តតិយវគ្គ

សុត្តន្តបិដក គាថាទី ១ ...... ...... ...... ...... ៧៩៧
អដ្ឋកថាគាថាទី ១ ...... ...... ...... ...... ៨០០
សុត្តន្តបិដកគាថាទី ២ ...... ...... ...... ...... ៨០២
អដ្ឋកថា គាថាទី ២ ...... ...... ...... ...... ៨០៩

សុត្តន្តបិដក គាថាទី ៣ ...... ...... ...... ...... ៨១២

អដ្ឋកថា គាថាទី ៣ ...... ...... ...... ...... ៨១៦

សុត្តន្តបិដក គាថាទី ៤ ...... ...... ...... ...... ៨១៨

អដ្ឋកថា គាថាទី ៤ ...... ...... ...... ...... ៨២១

សុត្តន្តបិដក គាថាទី ៥ ...... ...... ...... ...... ៨២៣

អដ្ឋកថា គាថាទី ៥ ...... ...... ...... ...... ៨២៦

សុត្តន្តបិដក គាថាទី ៦ ...... ...... ...... ...... ៨២៧

អដ្ឋកថា គាថាទី ៦ ...... ...... ...... ...... ៨២៩

សុត្តន្តបិដក គាថាទី ៧ ...... ...... ...... ...... ៨៣០

អដ្ឋកថា គាថាទី ៧ ...... ...... ...... ...... ៨៣៣

សុត្តន្តបិដក គាថាទី ៨ ...... ...... ...... ...... ៨៣៥

អដ្ឋកថា គាថាទី ៨ ...... ...... ...... ...... ៨៣៨

សុត្តន្តបិដក គាថាទី ៩ ...... ...... ...... ...... ៨៤០

អដ្ឋកថាគាថាទី ៩ ...... ...... ...... ...... ៨៥០

សុត្តន្តបិដក គាថាទី ១០ ...... ...... ...... ...... ៨៥៥

អដ្ឋកថា គាថាទី ១០ ...... ...... ...... ...... ៨៥៧

## ចតុត្ថយវគ្គ

សុត្តន្តបិដក គាថាទី ១ ...... ...... ...... ...... ៨៥៨

អដ្ឋកថា គាថាទី ១ ...... ...... ...... ...... ៨៦៣

សុត្តន្តបិដក គាថាទី ២ ...... ...... ...... ...... ៨៦៥

អដ្ឋកថា គាថាទី ២ ...... ...... ...... ...... ៨៦៨

សុត្តន្តបិដក គាថាទី ៣ ...... ...... ...... ...... ៨៦៩

អដ្ឋកថា គាថាទី ៣ ...... ...... ...... ...... ៨៧១

សុត្តន្តបិដក គាថាទី ៤ ...... ...... ...... ...... ៨៧៣
អដ្ឋកថា គាថាទី ៤ ...... ...... ...... ...... ៨៧៧
សុត្តន្តបិដក គាថាទី ៥ ...... ...... ...... ...... ៨៧៩
អដ្ឋកថា គាថាទី ៥ ...... ...... ...... ...... ៨៨២
សុត្តន្តបិដក គាថាទី ៦ ...... ...... ...... ...... ៨៨៤
អដ្ឋកថា គាថាទី ៦ ...... ...... ...... ...... ៨៨៨
សុត្តន្តបិដក គាថាទី ៧ ...... ...... ...... ...... ៨៩០
អដ្ឋកថា គាថាទី ៧ ...... ...... ...... ...... ៨៩៣
សុត្តន្តបិដក គាថាទី ៨ ...... ...... ...... ...... ៨៩៥
អដ្ឋកថា គាថាទី ៨ ...... ...... ...... ...... ៨៩៧
សុត្តន្តបិដក គាថាទី ៩ ...... ...... ...... ...... ៨៩៨
អដ្ឋកថា គាថាទី ៩ ...... ...... ...... ...... ៩០០
សុត្តន្តបិដក គាថាទី ១០ ...... ...... ...... ...... ៩០២
អដ្ឋកថា គាថាទី ១០ ...... ...... ...... ...... ៩០៤
សុត្តន្តបិដក គាថាទី ១១ ...... ...... ...... ...... ៩០៥
អដ្ឋកថា គាថាទី ១១ ...... ...... ...... ...... ៩០៩
និគមគាថា ...... ...... ...... ...... ៩១១